# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៣៨

បាលីប្រែ ៥៤

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# បរមត្ថជោតិកា អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# ខុទ្ទកនិកាយ

# សុត្តនិបាត តតិយភាគ

# ៣៨

## បាលីប្រែ ៥៤



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៣៨

# ខុទ្ទកនិកាយ សុត្តនិបាត

##ចូឡវគ្គទី ២

## ធម្មចរិយសូត្រទី៦

[ ២៨ ] ព្រះអរិយៈទាំងឡាយ តែងពោលនូវធម្មចរិយៈ និង ព្រហ្មចរិយៈនេះ ថាជារតនៈដ៏ឧត្តម ប្រសិនបើបុគ្គលចេញ ចាកផ្ទះទៅបួសក្នុងធម្មវិន័យ ។

បើបុគ្គលនោះ ជាអ្នកមានមាត់រឹង ត្រេកអរក្នុងការបៀតបៀន ដូចជាសត្វម្រឹគ ជីវិតរបស់បុគ្គលនោះ ជាជីវិតអាក្រក់ ក្រៃលែង បុគ្គលនោះ តែងញ៉ាំងធូលី គឺ កិលេសឲ្យចម្រើន ឡើងដល់ខ្លួន ។

ភិក្ខុអ្នកត្រេកអរក្នុងជម្លោះ ត្រូវមោហធម៌ចាក់ស្រេះហើយ ក៏ លែងដឹងធម៌ ដែលពួកភិក្ខុបានប្រាប់ហើយផង ដែលព្រះ ពុទ្ធទ្រង់សម្តែងផង ភិក្ខុអ្នកត្រូវអវិជ្ជារួបរឹត ហើយបៀតបៀន នូវព្រះវិញ្ញាស្រេពទាំងឡាយ ដែលជាអ្នកមានខ្លួនអប់រំហើយ រមែងមិនស្គាល់នូវសេចក្តីសៅហ្មង ជាផ្លូវទៅកាន់នរក ហើយ ចូលទៅកាន់អបាយ ៤ ចេញចាកគភ៌ទៅកាន់គភ៌ ចេញចាក

អសុរកាយ ទៅកាន់អសុរកាយ ភិក្ខុនោះ រមែងដល់នូវសេចក្ដីទុក្ខក្នុងបរលោក ។

មួយទៀត បុគ្គលដែលមានសភាពយ៉ាងនេះ ជាអ្នកប្រកបដោយកិលេសដូចទីទួល លាងជម្រះបានដោយកម្រ ដូចជារណ្ដៅលាមក ពេញប្រៀប អួរអាប់រាប់ឆ្នាំ ( ដែលគេលាងសម្អាតបានដោយកម្រ ) ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរដឹងនូវបុគ្គលដែលអាស្រ័យនូវផ្ទះ គឺកាមគុណ ជាអ្នកមានសេចក្ដីប្រាថ្នាលាមក មានសេចក្ដីត្រិះរិះអាក្រក់ មានអាចារៈនិងគោចារៈអាក្រក់បែបនេះ ។ អ្នករាល់គ្នា គប្បីជាអ្នកព្រមព្រៀងគ្នា ចៀសវាងនូវបុគ្គលនោះចេញ ចូរបោះបង់ចោលដូចជាគេបោសសំរាមចោល ចូរទាញចេញ នូវបុគ្គលអ្នកប្រព្រឹត្តកខ្វក់ តពីនោះទៅ គប្បីបណ្ដេញនូវពួកបុគ្គលដែលដូចជាសំដីស្រូវ មិនមែនជាសមណៈ ប្រកាន់ថាខ្លួនជាសមណៈចេញ ។ លុះអ្នកទាំងឡាយ បណ្ដេញបុគ្គលអ្នកប្រាថ្នាអាក្រក់ មានអាចារៈ និងគោចារៈ អាក្រក់បានហើយ ជាអ្នកបរិសុទ្ធ សម្រេចការនៅជាមួយនឹងបុគ្គលបរិសុទ្ធ អ្នកមានសេចក្ដីគោរព គោតក្រែងគ្នា តទៅ នឹងជាអ្នកព្រមព្រៀងគ្នាមានប្រាជ្ញាចាស់ក្លា ធ្វើនូវទីបំផុតនៃទុក្ខបាន ។

**ធម្មចរិយសូត្រទី ៦ ចប់**

# អដ្ឋកថា

## ធម្មចរិយសូត្រ

[ ២៨ ] ក្នុងធម្មចរិយសូត្រទី ៦ មានពាក្យផ្ដើមថា **ធម្មចរិយំ** ដូច្នេះ ។

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅ

កាលព្រះមានព្រះភាគ ព្រះនាមកស្សបៈ ទ្រង់បរិនិព្វានហើយ ដោយន័យដែលពោលហើយក្នុងហេមវតសូត្រនោះឯង ។ កុលបុត្ត ២ នាក់បងប្អូន ចេញបួសក្នុងសម្នាក់នៃសាវកទាំងឡាយ កុលបុត្តច្បងឈ្មោះ សោធនៈ កុលបុត្តប្អូនឈ្មោះ កបិល កុលបុត្តទាំង ២ មានមាតាឈ្មោះសាធនី មានប្អូនស្រីឈ្មោះ តាបនា ទាំងមាតា និងប្អូនស្រីនោះ ក៏បួសក្នុងសម្នាក់ភិក្ខុនី ។ បន្ទាប់អំពីនោះ ភិក្ខុទាំង ២ នោះ ក៏សាកសួរថា បពិត្រលោកម្ចាស់ ក្នុងសាសនាមានធុរៈប៉ុន្មានយ៉ាង ដូច្នេះ ស្ដាប់ចម្លើយដោយន័យដែលខ្ញុំពោលហើយ ក្នុងហេមវតសូត្រនោះឯង ។ ក្នុងបណ្ដាភិក្ខុទាំង២អង្គនោះ កុលបុត្តច្បងគិតថា អញនឹងបំពេញវាសធុរៈ គឺ ធុរៈជាគ្រឿងអប់រំខ្លួន ដូច្នេះហើយ ក៏នៅក្នុងសម្នាក់របស់ឧបជ្ឈាយ៍ និងអាចារ្យទាំងឡាយ អស់ចិរវេលា ៥ ឆ្នាំ មានវស្សាជាគម្រប់ ៥ ស្ដាប់កម្មដ្ឋាន ដែលនាំឲ្យដល់អរហត្ត ហើយចូលទៅកាន់ព្រៃ ប្រារព្ធព្យាយាម ក៏បានសម្រេចអរហត្ត ។

កបិលភិក្ខុគិតថា អញនៅក្មេង ក្នុងកាលចាស់ សឹមបំពេញវាសធុរៈ ដូច្នេះហើយ ក៏រៀនគន្ថធុរៈ បានជាអ្នកទ្រទ្រង់នូវបិដក ៣ ហើយកបិលភិក្ខុនោះមានបរិវារ ព្រោះអាស្រ័យបរិយត្តិ ព្រោះអាស្រ័យបរិវារ លាភក៏កើត

ឡើង ។

កបិលភិក្ខុនោះ ស្រវឹងដោយការស្រវឹង ក្នុងភាពដែលខ្លួនជាពហុស្សូត សម្គាល់ខ្លួនថាជាបណ្ឌិត មានការសម្គាល់ថា ខ្លួនដឹងក្នុងធម៌ដែលខ្លួនមិនដឹង ពោលវត្ថុដែលជាកប្បិយ ដែលភិក្ខុដទៃពោលហើយថា ជាអកប្បិយ វត្ថុជាអកប្បិយ ថាជាកប្បិយ សូម្បីវត្ថុដែលមានទោសថា មិនមានទោស វត្ថុដែលមិនមានទោសថា មានទោស ។

បន្ទាប់អំពីនោះ កបិលភិក្ខុនោះ កាលភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ទូន្មានដោយន័យថា អាវុសោ កបិល លោកកុំពោលយ៉ាងនេះដូច្នេះជាដើម ក៏គំហកភិក្ខុទាំងឡាយ ដោយពាក្យទាំងឡាយថា ពួកលោកដូចគ្នានឹងមនុស្សដៃទទេ ដឹងអ្វី ដូច្នេះជាដើមនោះឯង ។ ភិក្ខុទាំងឡាយបានប្រាប់រឿងនេះដល់ព្រះសោធនត្ថេរដែលជាបងប្រុស ព្រះសោធនត្ថេរនោះ ក៏ចូលទៅរកកបិលភិក្ខុនោះ ហើយពោលថា អាវុសោកបិល បដិបត្តិប្រពៃរបស់ភិក្ខុទាំងឡាយដូចលោក ជាអាយុរបស់សាសនា នៃអាវុសោ លោកកុំពោលរបស់ដែលជាកប្បិយ ថាជាអកប្បិយ របស់ដែលមានទោស ថាមិនមានទោស ។ កបិលភិក្ខុនោះ ក៏មិនដាក់ចិត្តក្នុងពាក្យរបស់ព្រះសោធនត្ថេរដែលជាបងប្រុសនោះ ។ លំដាប់នោះ ព្រះសោធនត្ថេរបានពោលនឹងកបិលភិក្ខុនោះ អស់វារៈពីរបីដងហើយ ក៏ឈប់ពោល ដោយពិចារណាដល់ពាក្យរបស់ព្រះបច្ចេកពុទ្ធថា

បុគ្គលអ្នកឈ្លាស គប្បីនិយាយត្រឹមតែមួយម៉ាត់ ឬពីរម៉ាត់ មិនគប្បី

និយាយឲ្យលើសហួសពីនោះទៅ ដូចទាសៈនិយាយក្នុងសម្នាក់នៃម្ចាស់ ។

ហើយទើបពោលថា អាវុសោ លោកនោះឯង នឹងប្រាកដដោយកម្ម របស់លោក ដូច្នេះហើយ ក៏ចៀសចេញទៅ ។ តាំងអំពីនោះមក ភិក្ខុទាំង-ឡាយដែលមានសីលជាទីស្រឡាញ់ ក៏បោះបង់កបិលភិក្ខុនោះចោល ។

កបិលភិក្ខុនោះ ជាអ្នកប្រព្រឹត្តអាក្រក់ មានភិក្ខុអ្នកប្រព្រឹត្តអាក្រក់ចោមរោម ថ្ងៃមួយ គិតថា អញនឹងសម្តែងឧបោសថ ទើបឡើងកាន់អាសនៈដ៏ប្រសើរ ចាប់ផ្ចិតដ៏វិចិត្រ ក៏ពោលឡើង ៣ ដងថា អាវុសោទាំងឡាយ បាតិមោក្ខ រមែងគួរដល់ភិក្ខុទាំងឡាយក្នុងទីនេះឬ ។ កាលនោះ ភិក្ខុមួយរូប ក៏មិនបានពោលថា បាតិមោក្ខរមែងគួរដល់ខ្ញុំ ទាំងមិនបានពោលថា បាតិមោក្ខ រមែងគួរដល់លោកម្ចាស់ ឬដល់ភិក្ខុទាំងឡាយនោះ ។ លំដាប់នោះ កបិល-ភិក្ខុក៏ពោលថា កាលបាតិមោក្ខ ពួកយើងស្តាប់ក្តី មិនស្តាប់ក្តី ឈ្មោះថា វិន័យ មិនមានទេ ដូច្នេះហើយ ក៏ក្រោកចាកអាសនៈ ។ កបិលភិក្ខុនោះ ធ្វើសាសនា របស់ព្រះមានព្រះភាគកស្សបៈឲ្យសាបសូន្យ គឺឲ្យវិនាសហើយ ដោយប្រការ ដូច្នេះ ។

កាលនោះ ព្រះសោធនត្ថេរក៏បានបរិនិព្វានក្នុងកាលនោះឯង ។ កបិល-ភិក្ខុ ធ្វើសាសនាឲ្យថមថយទៅយ៉ាងនេះហើយ លុះដល់អនិច្ចកម្ម ក៏កើតក្នុង អវិចីមហានរក មាតា និងប្អូនស្រីរបស់លោកដល់នូវទិដ្ឋានុគតិនោះ របស់ លោកនោះឯង ជេរប្រទេចភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ ធ្វើ កាលកិរិយាហើយ ក៏កើតក្នុងនរក ។

ក្នុងកាលនោះឯង បុរសប្រមាណ ៥០០ នាក់ ធ្វើបាបកម្មទាំងឡាយ មានការសម្លាប់អ្នកស្រុកជាដើម ចិញ្ចឹមជីវិតដោយចោរកម្ម ត្រូវអ្នកជនបទដេញតាម រត់ទៅ បានចូលទៅកាន់ព្រៃ មិនឃើញទីពួន ឬអាសនៈណាមួយក្នុងព្រៃនោះ បានឃើញភិក្ខុនៅព្រៃជាវត្តមួយរូប ដែលនៅក្នុងបទេសមិនឆ្ងាយ ថ្វាយបង្គំហើយ ក៏ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ជាទីពឹងនៃពួកខ្ញុំផងចុះ ព្រះថេរៈពោលថា ទីពឹងដទៃដូចសីលសម្រាប់អ្នកទាំងឡាយមិនមាន ចូរអ្នកទាំងឡាយសមាទានបញ្ចសីល ចោរទាំងនោះទទួលហើយ បានសមាទានសីល ។ ព្រះថេរៈពោលថា ឥឡូវនេះ ពួកអ្នកជាអ្នកមានសីលហើយ អ្នកទាំងឡាយ ទោះបីអ្នកដទៃផ្តាច់ជីវិតឲ្យវិនាស អ្នកទាំងឡាយកុំប្រទូស្តសូម្បីដោយចិត្ត ។ ពួកចោរទាំងនោះទទួលពាក្យហើយ ។

កាលនោះ អ្នកជនបទទាំងនោះមកដល់ហើយ ក៏រំពៃរកមើលក្នុងទីផ្សេងៗ ឃើញចោរទាំងនោះ នាំគ្នាសម្លាប់ចោលទាំងអស់ ។ ចោរទាំងនោះធ្វើកាលកិរិយាហើយ កើតក្នុងកាមាវចរទេវលោក ។ បណ្តាចោរទាំងនោះ ចោរដែលជាមេ បានជាប្រធាននៃទេវតាទាំងឡាយ ចោរក្រៅអំពីនេះបានជាបរិវាររបស់ទេវបុត្តដែលជាប្រធាននោះឯង ។ ចោរទាំងនោះ អន្ទោលទៅមកឲ្យពុទ្ធន្តរមួយអស់ទៅក្នុងទេវលោក ច្យុតចាកទេវលោក ក្នុងពុទ្ធុប្បាទនៃព្រះសមណគោតមនៃយើងទាំងឡាយ ទេវបុត្តដែលជាប្រធាន បានបដិសន្ធិក្នុងផ្ទៃនៃភរិយារបស់អ្នកប្រមង់ដែលជាប្រធាន ក្នុងត្រកូលអ្នកប្រមង់ ៥០០ ដែលរស់នៅត្រង់ទ្វារនគរសាវត្ថី ទេវបុត្តក្រៅអំពីនេះ បដិសន្ធិក្នុងគភ៌របស់ភរិយា

នៃអ្នកប្រមង់ដ៏សេសទាំងឡាយ ។ សត្វទាំងនោះបដិសន្ធិ និងចេញចាកគភ៌ ក្នុងថ្ងៃតែមួយនោះឯង ដោយប្រការដូច្នេះ ។

តមក ប្រធានអ្នកប្រមង់គិតថា ក្នុងស្រុកនេះ ក្មេងទាំងឡាយដែលកើតក្នុងថ្ងៃនេះ មានឬហ្ន៎ ដូច្នេះហើយ ទើបបានជួបទារកទាំងនោះហើយ គិតថា ក្មេងទាំងនេះ ជាសម្លាញ់កូនរបស់អញ ដូច្នេះហើយ ក៏បានឲ្យវត្ថុដែលគួរចិញ្ចឹមដល់ក្មេងទាំងនោះគ្រប់គ្នា ក្មេងទាំងនោះ ជាសម្លាញ់លេងដីជាមួយគ្នា ដល់នូវសេចក្តីចម្រើនដោយវ័យតាមលំដាប់ កុមារឈ្មោះថា យសោជៈ ជាប្រធាននៃក្មេងទាំងនោះ ។

កាលនោះ ភិក្ខុឈ្មោះកបិល ក៏មកកើតជាត្រីមានពណ៌ដូចមាស តែមាត់ស្អុយ ក្នុងស្ទឹងអចិរវតី ដោយសេសសល់ផលកម្មមកពីនរក ។ ថ្ងៃមួយ អ្នកប្រមង់ទាំងនោះកាន់យកសំណាញ់ ហើយគិតថា យើងនឹងចាប់ត្រីទាំង-ឡាយ ទៅកាន់ស្ទឹង ហើយបង់សំណាញ់ ។ ត្រីនោះចូលទៅកាន់សំណាញ់របស់អ្នកប្រមង់ទាំងនោះ អ្នកប្រមង់ទាំងអស់ឃើញត្រីនោះហើយ ក៏នាំគ្នាស្រែកដោយសំឡេងខ្លាំងថា កូនរបស់ពួកយើងចាប់ត្រីទាំងឡាយ ក៏ចាប់បានត្រីមាស សេចក្តីចម្រើននឹងមានដល់កុមារទាំងនោះ ឥឡូវនេះ ព្រះរាជាគង់នឹងប្រទានទ្រព្យច្រើនដល់យើងទាំងឡាយ ។

កាលនោះ សម្លាញ់ទាំង ៥០០ នាក់នោះ យកត្រីដាក់ក្នុងទូក ហើយសែងទូកទៅកាន់សម្នាក់របស់ព្រះរាជា។ ទតឃើញហើយ ត្រាស់ថា នែអ្នកទាំងឡាយ នុ៎ះជាអ្វី ពួកជនទាំងនោះឆ្លើយថា បពិត្រព្រះអង្គ ត្រី ។ ព្រះ

រាជាទតឃើញត្រីមាស ក៏ត្រិះរិះថា ព្រះមានព្រះភាគទ្រង់នឹងជ្រាបហេតុដែលត្រីនេះមានពណ៌មាស ដូច្នេះហើយ ទើបត្រាស់ឲ្យយកត្រីទៅកាន់សម្នាក់ព្រះមានព្រះភាគ ក្នុងកាលត្រីហាមាត់ឡើង វត្តជេតពនក៏មានក្លិនស្អុយក្រៃលែង ។ ព្រះរាជាសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុអ្វី ទើបត្រីនេះមានពណ៌ដូចមាស ព្រោះហេតុអ្វី ទើបក្លិនស្អុយផ្សាយចេញអំពីមាត់របស់ត្រីនេះ ។

ព្រះមានព្រះភាគត្រាស់ថា មហាបពិត្រ ត្រីនេះជាភិក្ខុពហុស្សូត រៀនចប់បរិយត្តិ ឈ្មោះកបិល ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមកស្សបៈ ជាអ្នកជេរប្រទេចភិក្ខុទាំងឡាយ ដែលមិនកាន់យកពាក្យរបស់ខ្លួន ជាអ្នកធ្វើសាសនារបស់ព្រះមានព្រះភាគឲ្យអន្តរធានទៅ ព្រោះកម្មដែលភិក្ខុនោះធ្វើសាសនារបស់ព្រះមានព្រះភាគអង្គនោះឲ្យអន្តរធាន ទើបកើតក្នុងអវិចីមហានរក ហើយមកកើតជាត្រីក្នុងកាលឥឡូវនេះ ដោយសេសសល់ផលនៃកម្ម ។ ដោយអានិសង្សនៃកម្មដែលគេបានពោលពុទ្ធវចនៈ សរសើរព្រះពុទ្ធអស់កាលយូរ ទើបត្រីនេះមានពណ៌សម្បុរបែបនេះ ព្រោះភិក្ខុនោះ ជេរប្រទេចភិក្ខុទាំង-ឡាយ ទើបក្លិនស្អុយផ្សាយចេញអំពីមាត់របស់ត្រីនោះ មហាបពិត្រ តថាគតនឹងឲ្យត្រីនោះពោលក្នុងកាលឥឡូវនេះ ។ ព្រះបាទបសេនទិកោសលទូលថា ករុណាព្រះអង្គ ។ កាលនោះ ព្រះមានព្រះភាគត្រាស់សួរត្រីនោះថា អ្នកឈ្មោះកបិលឬ ត្រីពោលថា បពិត្រព្រះអង្គដ៏ចម្រើន ពិតមែនហើយ ខ្ញុំព្រះអង្គឈ្មោះកបិល ព្រះសាស្តាត្រាស់ថា អ្នកមកអំពីណា ត្រីទូលថា បពិត្រ

ព្រះអង្គដ៏ចម្រើន ខ្ញុំមកអំពីអវីចីមហានរក ព្រះសាស្តាត្រាស់សួរថា សោធនៈ បងប្រុសរបស់អ្នកទៅណា ត្រីទូលថា បពិត្រព្រះអង្គដ៏ចម្រើន សោធនៈ បរិនិព្វានហើយ ។ ព្រះសាស្តាត្រាស់សួរថា ចុះនាងសាធនីទៅណា ត្រីទូលថា បពិត្រព្រះអង្គដ៏ចម្រើន សាធនីជាមាតារបស់ខ្ញុំកើតក្នុងនរក ។ ព្រះសាស្តាត្រាស់សួរថា ចុះនាងតាបនាទៅណា ត្រីទូលថា បពិត្រព្រះអង្គដ៏ចម្រើន តាបនាប្អូនស្រី កើតក្នុងមហានរកដូចគ្នា ព្រះមានព្រះភាគត្រាស់សួរថា ចុះឥឡូវនេះ អ្នកនឹងទៅណា ត្រីទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំនឹងទៅកាន់មហានរក ។ រំពេចនោះឯង ត្រីនោះ ត្រូវសេចក្តីក្តៅក្រហាយគ្របសង្កត់ យកក្បាលបោកនឹងទូក ស្លាប់ទៅកើតក្នុងមហានរក ។ មហាជនកើតសេចក្តីសង្វេគ ព្រឺរោម ព្រឺស្បែកហើយ ។ កាលនោះ ព្រះមានព្រះភាគទ្រង់សម្តែងធម៌ដ៏សមគួរក្នុងខណៈនោះដល់បរិស័ទ ដែលមានទាំងគ្រហស្ថ និងបព្វជិតដែលមកប្រជុំគ្នា ទើបត្រាស់សូត្រនេះ ។

ការប្រព្រឹត្តធម៌ មានកាយសុចរិតជាដើម ឈ្មោះថា **ធម្មចរិយំ** ក្នុងព្រះគាថានោះ ។ មគ្គព្រហ្មចរិយៈ ឈ្មោះថា **ព្រហ្មចរិយំ**។

បាទព្រះគាថាថា **ឯតទាហុ វសុត្តមំ** សេចក្តីថា ព្រះអរិយៈទាំងឡាយពោលដល់ការប្រព្រឹត្តសុចរិតទាំងជាលោកិយ និងលោកុត្តរទាំង ២ នេះថាជាសម្បត្តិដ៏ឧត្តម ព្រោះញ៉ាំងសត្វឲ្យជួបនូវសេចក្តីសុខក្នុងស្ថានសួគ៌ និងព្រះនិព្វាន អធិប្បាយថា រតនៈដ៏ឧត្តម គឺរតនៈដែលមិនទូទៅដល់ជនទាំងឡាយមានព្រះរាជាជាដើម ព្រោះជារតនៈដែលអាចជាប់តាមជនទាំងឡាយ ដែល

សទ្ធាំបុណ្យ ឈ្មោះថា **វសុត្តម**។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងថា បដិបត្តិប្រពៃប៉ុណ្ណោះ តែង ជាទីពឹងរបស់គ្រហស្ថ និងបព្វជិតបាន ដោយពាក្យមានប្រមាណប៉ុណ្ណោះ ឥឡូវ នេះ កាលទ្រង់តិះដៀលភិក្ខុឈ្មោះ កបិល ឬភិក្ខុដទៃដែលមានសភាពបែប នោះ ដោយការសម្តែងអសារៈក្នុងបព្វជ្ជា ដែលប្រាសចាកបដិបត្តិ ទើប ត្រាស់ថា **បព្វជិតោបិ ចេ ហោតិ** ជាដើម ។

ក្នុងពាក្យថា **បព្វជិតោបិ ចេ ហោតិ** នេះ មានពណ៌នាអត្ថដូចដូច តទៅនេះ បុគ្គលឯណានីមួយលះនូវយកវាសភេទ បើបួស ដោយការបួស មិនមានផ្ទះ អំពីផ្ទះ មានអត្ថតាមដែលខ្ញុំពោលហើយខាងដើម ដោយការ ចូលដល់ហេតុ ត្រឹមតែកោរសក់ និងស្លៀកដណ្តប់សំពត់ ជ្រលក់ដោយ ទឹកម្ចត់ជាដើម បើជាបុគ្គលមាត់រឹង គឺជាអ្នកពោលនូវពាក្យគ្រោតគ្រាត ត្រេកអរក្នុងការបៀតបៀន ព្រោះពេញចិត្តក្នុងការបៀតបៀន មានប្រការ ផ្សេងៗ ជាបុគ្គលដូចសត្វសាហាវ ព្រោះដូចគ្នានឹងម្រឹគកាច ព្រោះមិនមាន ហិរិឱត្តប្បៈ ។

បាទគាថាថា **ជីវិតំ តស្ស បាបិយោ** សេចក្តីថា ជីវិតរបស់បុគ្គលនោះ គឺបុគ្គលបែបនោះ ជាបាបក្រៃលែង គឺអាក្រក់ក្រៃលែង ។ សួរថា ព្រោះ ហេតុអ្វី ឆ្លើយថា ព្រោះធ្វើនូវធូលីមានប្រការផ្សេងៗ មានរាគៈជាដើមរបស់ ខ្លួនឲ្យចម្រើនដល់ខ្លួន ដោយបដិបត្តិខុសនេះ ។ ជីវិតរបស់បុគ្គលនោះ ជា ជីវិតអាក្រក់ ដោយហេតុនេះតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន តែដោយពិត បុគ្គល

បែបនេះ បានដល់ ភិក្ខុដែលគ្រេកអរក្នុងជម្លោះ ឈ្មោះប្រកែក ព្រោះជាបុគ្គលដែលមាត់រឹង ត្រូវមោហធម៌រួបរឹតហើយ ព្រោះដល់នូវការវង្វេងក្នុងការដឹងច្បាស់នៃសុភាសិត រមែងមិនដឹងនូវពាក្យដែលភិក្ខុទាំងឡាយ ជាអ្នកមានសីលជាទីស្រឡាញ់ពោលហើយ ដោយន័យជាដើមយ៉ាងនេះថា អាវុសោកបិល លោកកុំពោលយ៉ាងនេះ ចូរកាន់យករឿងនោះ ដោយបរិយាយនេះ មិនស្គាល់ធម៌ដែលព្រះពុទ្ធទ្រង់សម្តែង គឺមិនស្គាល់ព្រះធម៌ដែលព្រះពុទ្ធទ្រង់សម្តែង សូម្បីដែលខ្លួនពោលដោយប្រការផ្សេងៗ កាលបើដូច្នោះ ជីវិតរបស់ភិក្ខុនោះ ឈ្មោះថា ជាជីវិតអាក្រក់ ។

ក្នុងកាលនោះ ភិក្ខុបែបនោះ ព្រោះខ្លួនពេញចិត្តក្នុងការបៀតបៀន កាលកំពុងបៀតបៀននូវខ្លួនដែលអប់រំហើយ ឈ្មោះថា បៀតបៀននូវភិក្ខុដែលជាខីណាស្រព ដែលមានខ្លួនអប់រំហើយ មានព្រះសោធនត្ថេរជាដើម ដោយន័យជាដើមថា លោកទាំងឡាយបួសឯចាស់ មិនដឹងវិន័យ មិនចេះព្រះសូត្រ មិនចេះអភិធម្ម ដូច្នេះ ។

បទថា **ភាវិតត្តានំ** នេះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថទុតិយាវិភត្តិ ។ ម្យ៉ាងទៀត គប្បីជ្រាបដល់ព្រះបាលីដ៏សេសថា **វិហេសំ ភាវិតត្តានំ** ដោយន័យដែលពោលហើយ ឆដ្ឋីវិភត្តិរមែងសម្រេចដោយនិប្បរិយាយយ៉ាងនេះ ។

បាទគាថាថា **អវិជ្ជាយ បុរក្ខតោ** សេចក្តីថា បុគ្គលត្រូវអវិជ្ជា មានការបិទបាំងនូវការឃើញទោសជាដើម ក្នុងការបៀតបៀនដែលបុគ្គល មាន

ខ្លួនដែលអប់រំហើយ គ្រប់សង្កត់ បញ្ជូនទៅ ប្រកបទុក ទើបមិនស្គាល់សន្ធិលេស ដោយការពិឃាតចិត្តក្នុងបច្ចុប្បន្នដែលប្រព្រឹត្តទៅហើយ ដោយការបៀតបៀនបព្វជិតដ៏សេសទាំងឡាយ ដែលមានខ្លួនអប់រំ និងមិនស្គាល់ផ្លូវដែលទៅកាន់នរក ដោយធ្វើខ្លួនឲ្យចូលដល់នរកតទៅ ។

កាលមិនដឹងក៏ចូលដល់វិនិបាត មានអបាយទាំង ៤ ជាដើមដោយផ្លូវនោះ និងក្នុងវិនិបាតនោះ បុគ្គលនោះចូលទៅកាន់គភ៌អំពីគភ៌ ទៅកាន់ទីងងឹតអំពីទីងងឹត គឺនៅក្នុងគភ៌មាតាក្នុងពួកសត្វផ្សេងៗ អស់មួយរយជាតិខ្លះ មួយពាន់ជាតិខ្លះ និងចេញអំពីទីងងឹត គឺអសុរកាយ ទៅកាន់ទីងងឹត ដែលពន្លឺព្រះចន្ទ និងព្រះអាទិត្យក៏អាចកម្ចាត់ងងឹតនោះមិនបាន ភិក្ខុបែបនោះ លះលោកនេះទៅហើយ គឺទៅអំពីលោកនេះកាន់បរលោក ក៏ចូលដល់ទុក្ខ មានប្រការផ្សេងៗ ដូចត្រីឈ្មោះកបិលនេះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ដូចរណ្តៅលាមកដែលត្រាំអស់កាលច្រើនឆ្នាំ ពេញដោយលាមកនោះ ឬប្រៀបដូចរណ្តៅលាមកក្នុងវច្ចកុដិ ត្រាំច្រើនឆ្នាំ គឺអស់ឆ្នាំមិនតែមួយ គប្បីពេញដោយលាមកស្មើមាត់អស់កាលច្រើនឆ្នាំ រណ្តៅលាមកនោះ សូម្បីបុគ្គលលាងដោយទឹករាប់រយក្អម រាប់ពាន់ក្អម ក៏លាងឲ្យស្អាតបានដោយក្រ ព្រោះកម្ចាត់ក្លិនស្អុយ និងពណ៌ដែលគួរខ្ពើម ឲ្យប្រាសចាកទៅបានលំបាក យ៉ាងណា បុគ្គលបែបនេះ គប្បីជាបុគ្គលមានការងាររសៅហ្មង អស់កាលយូរ ដូចរណ្តៅលាមក បុគ្គលដែលពេញដោយបាប ព្រោះដល់ព្រមដោយលាមក គឺបាប បុគ្គលបែបនេះ មានការងាររសៅហ្មង ជាបុគ្គលជម្រះឲ្យស្អាតបានលំបាក

សូម្បីសោយវិបាកនៃកិលេសនោះអស់កាលយូរ ក៏បរិសុទ្ធមិនបានយ៉ាងនោះ ដូចគ្នា ព្រោះដូច្នោះ ភិក្ខុនោះឯង លះលោកទៅហើយ រមែងចូលដល់ទុក្ខ អស់កាលយូរប្រមាណមិនបាន ដោយការរាប់ឆ្នាំ ។ ម្យ៉ាងទៀត ក្នុងគាថានេះ មានសម្ពន្ធដូចតទៅនេះ

ក្នុងបាទព្រះគាថាដែលព្រះមានព្រះភាគត្រាស់ថា ភិក្ខុបែបនោះឯង លះលោកទៅហើយ រមែងចូលដល់ទុក្ខ ដូច្នេះ គប្បីមានពាក្យសួរជ្រៀតចូលមកថា ភិក្ខុនេះ អ្នកទាំងឡាយអាចធ្វើដោយប្រការដែលលះលោកទៅហើយ នឹងមិនឲ្យចូលដល់ទុក្ខបានដែរឬទេ ឆ្លើយថា មិនអាច ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះភិក្ខុនេះ ប្រៀបដូចរណ្ដៅលាមក ដែលពេញយូរឆ្នាំ ជារណ្ដៅដែលពេញដោយលាមក ដូច្នេះ ។

ព្រោះព្រះមានព្រះភាគ បានសម្ដែងមុននោះឯងថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយស្គាល់បុគ្គលបែបនោះ ដែលជាអ្នកអាស្រ័យផ្ទះ គឺគប្បីដឹងបុគ្គលនោះ ដែលអាស្រ័យកាមគុណទាំង ៥ ជាបុគ្គលឈ្មោះថា **បាបិច្ឆំ** ព្រោះប្រកបដោយការប្រាថ្នាលាមក ដែលប្រព្រឹត្តទៅដោយអាការ គឺការប្រាថ្នាគុណដែលមិនមានពិត ឈ្មោះថា **បាបសង្កប្បំ** ព្រោះប្រកបដោយសេចក្ដីត្រិះរិះទាំងឡាយ មានកាមវិតក្កជាដើម ឈ្មោះថា **បាបាចារំ** ព្រោះប្រកបដោយការប្រព្រឹត្តអាក្រក់ មានការប្រព្រឹត្តកន្លងសីល ដែលប្រព្រឹត្តទៅតាមកាយជាដើម ដោយប្រភេទ មានការឲ្យឫស្សីជាដើម ដើម្បីទាក់ទាញអ្នកស្រុក ឈ្មោះថា **បាបគោចរំ** ព្រោះត្រាច់ទៅក្នុងទីដែលមិនល្អ ក្នុងទី

ដែលមិនសមគួរ មានទីស្រីពេស្យាជាដើម អ្នកទាំងឡាយទាំងពួង ចូរជាអ្នកសាមគ្គីគ្នា វៀរនូវបុគ្គលនោះចេញ កុំគប្បីជាអ្នកខ្វល់ខ្វាយតិច ដោយហេតុត្រឹមតែការវៀរភិក្ខុនោះប៉ុណ្ណោះ តែដោយពិត ចូរអ្នកទាំងឡាយកម្ចាត់បុគ្គលនោះដែលដូចជាអង្កាម ចូរអូសបុគ្គលនោះដែលជាសំរាមចេញ គឺចូរអូសបុគ្គលដូចសំរាមនោះ ដោយមិនអាលោះអាល័យ ចូរអូសបុគ្គលដែលជាអង្កាម ដូចរាជបុរសអូសមនុស្សចណ្ឌាល ដែលកើតរោគឃ្លង់ ដែលមានដំបៅបែក ដែលចូលទៅកណ្ដាលចំណោមក្សត្រជាដើម គឺចូរអ្នកទាំងឡាយចាប់បុគ្គលនោះត្រង់ដៃ ឬត្រង់ក្បាលហើយ អូសចេញទៅ ដូចព្រះមហាមោគ្គល្លាន ចាប់បុគ្គលអាក្រក់នោះត្រង់ដើមដៃ ទាញចេញទៅអំពីជំនុំសង្ឃដល់ខ្លោងទ្វារខាងក្រៅ ហើយខ្ទាស់គន្លឹះ យ៉ាងណា អ្នកទាំងឡាយក៏ចូរទាញបុគ្គលនោះ ដូច្នោះ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ឈ្មោះថា សង្ឃារាម គេសាងសម្រាប់អ្នកមានសីលទាំងឡាយ មិនមែនសាងសម្រាប់ភិក្ខុទាំងឡាយ ដែលទ្រុស្ដសីលឡើយ ។ បន្ទាប់អំពីនោះទៅ ចូរអ្នកទាំងឡាយបណ្ដេញបុគ្គលអង្កាមដែលមិនមែនសមណៈ សម្គាល់ខ្លួនថាជាសមណៈចេញទៅ ដូចសំដីស្រូវទាំងឡាយ សូម្បីមិនមានអង្ករខាងក្នុង ក៏ប្រាកដដូចគ្រាប់ស្រូវ ព្រោះមានសម្បកនៅខាងក្រៅ យ៉ាងណា បាបភិក្ខុទាំងឡាយក៏ដូច្នោះ សូម្បីវៀរចាកគុណ មានសីលជាដើមខាងក្នុង តែខាងក្រៅប្រាកដដូចភិក្ខុដោយបរិក្ខារ មានកាសាវៈជាដើម ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ហៅថា **បលាបា។** ចូរ

អ្នកទាំងឡាយអូសបុរសអន្ថាមនេះចេញ គឺចូលបណ្ដេញទៅ បានដល់ ចូរកម្ចាត់បុគ្គលអន្ថាមទាំងនោះ ដែលមិនមែនសមណៈ ដោយបរមត្ថ តែសម្គាល់ខ្លួនថាជាសមណៈ ក្នុងកាវៈត្រឹមតែកេទកាលកម្ចាត់បុគ្គលដែលមានការប្រាថ្នាលាមក ដែលមានអាចារ និងគោចរដ៏លាមកចេញហើយយ៉ាងនេះ អ្នកទាំង-ឡាយ ដែលបរិសុទ្ធហើយ មានការគោរពគ្នានិងគ្នារហូតសម្រេចការនៅរួមគ្នា ដោយបុគ្គលដែលបរិសុទ្ធទាំងឡាយ ។

បណ្ដាបទទាំងនោះ បទថា **កប្បយវ្ហោ** សេចក្ដីថា ចូរសម្រេច មានពាក្យដែលលោកអធិប្បាយថា ចូរធ្វើ ។

បទថា **បតិស្សតា** បានដល់ មានសេចក្ដីគោរព មានសេចក្ដីកោតក្រែងដល់គ្នានិងគ្នា ។ បាទព្រះគាថាថា **តតោ សមគ្គា និបកា ទុក្ខស្សន្តំ ករិស្សថ** សេចក្ដីថា កាលបើដូច្នោះ អ្នកទាំងឡាយដែលបរិសុទ្ធយ៉ាងនេះ សម្រេចនូវការនៅរួមជាមួយនឹងបុគ្គលបរិសុទ្ធទាំងឡាយ ជាអ្នកព្រមព្រៀងគ្នា ដោយភាពជាអ្នកមានទិដ្ឋិ និងសីលស្មើគ្នា ជាអ្នកមានបញ្ញារក្សាខ្លួនដោយបញ្ញាដែលដល់នូវការចាស់ក្លាដោយលំដាប់ អ្នកទាំងឡាយ ក៏ធ្វើនូវទីបំផុតទុក្ខ មានទុក្ខក្នុងវដ្ដៈជាដើមនេះបានទាំងអស់ ទើបព្រះមានព្រះភាគឲ្យទេសនាចប់ដោយកំពូល គឺអរហត្ត ដូច្នេះ ។

ក្នុងទីបំផុតនៃទេសនា កូនអ្នកប្រមង់ទាំង ៥០០ នោះ ដល់នូវសេចក្ដីសង្វេគ ប្រាថ្នាធ្វើទីបំផុតទុក្ខ បានបព្វជ្ជាក្នុងសម្នាក់របស់ព្រះមានព្រះភាគ ក្នុងកាលមិនយូរឡើយ ក៏ធ្វើទីបំផុតទុក្ខបាន បានជាបុគ្គលមានការបរិភោគ

រួមជាមួយនឹងព្រះមានព្រះភាគ ដោយការបរិភោគនូវធម៌ គឺអានេញ្ជវិហារ-សមាបត្តិ ។

អានេញ្ជវិហារសមាបត្តិនោះ ឈ្មោះថា ជាសមាបត្តិដែលមានការបរិ-ភោគជាមួយនឹងព្រះមានព្រះភាគរបស់ភិក្ខុទាំងឡាយនោះ ។

សមាបត្តិនោះ គប្បីជ្រាបដោយអំណាចនៃយសោជសូត្រ ដែលខ្ញុំបាន ពោលហើយ ក្នុងឧទាននោះឯង ។៚

**អដ្ឋកថា ធម្មចរិយសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## ព្រាហ្មណធម្មិកសូត្រទី៧

[ ២៩ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ពួកព្រាហ្មណមហាសាលជាច្រើននាក់ នៅក្នុងដែនកោសល ជាមនុស្សចាស់គ្រាំគ្រា ជាព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានអាយុក៏ជ្រុលចូលមកក្នុងបច្ឆិមវ័យហើយ បាននាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រាហ្មណមហាសាលទាំងនោះ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ឥឡូវនេះ ពួកព្រាហ្មណ៍ប្រាកដក្នុងព្រាហ្មណធម៌ របស់ពួកព្រាហ្មណ៍ជាន់ចាស់ដែរឬ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលព្រាហ្មណ៍ទាំងឡាយ ឥឡូវនេះ ពួកព្រាហ្មណ៍មិនប្រាកដក្នុងព្រាហ្មណធម៌ របស់ពួកព្រាហ្មណ៍ជាន់ចាស់ទេ ។ បើព្រះគោតមដ៏ចម្រើន មិនធ្ងន់ព្រះហឫទ័យទេ សូមព្រះគោតមដ៏ចម្រើន សម្តែងព្រាហ្មណធម៌ របស់ពួកព្រាហ្មណ៍ជាន់ចាស់ ដល់ខ្ញុំព្រះអង្គទាំងឡាយចុះ ។ ម្នាលព្រាហ្មណ៍ទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ព្រាហ្មណមហាសាលទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា

[ ៣០ ] ពួកឥសីជាន់មុន ជាអ្នកមានចិត្តសង្រួមហើយ មានតបៈ គឺឥន្ទ្រិយសំវរៈ លះបង់កាមគុណទាំង ៥ ធ្វើប្រយោជន៍បម្រុងខ្លួន ។

ពួកព្រាហ្មណ៍មិនមានសត្វចិញ្ចឹម មិនមានប្រាក់ មិនមានស្រូវសន្សំទុក មានតែទ្រព្យ និងស្រូវ គឺការស្វាធ្យាយ រក្សាតែព្រហ្មវិហារ ជាកំណប់ទ្រព្យ ។

ពួកទាយកតាក់តែងភត្តណា តម្កល់ទៀបទ្វារផ្ទះ ដើម្បីពួកព្រាហ្ម៍ទាំងនោះ ពួកទាយកបានសម្គាល់នូវភត្តនោះ ដើម្បីឲ្យដល់ពួកព្រាហ្មណ៍ កាលស្វែងរកនូវភត្ត ដែលគេចាត់ចែងដោយសទ្ធា ។

ពួកអ្នកជនបទ និងអ្នកដែន ជាមនុស្សស្រស់ប្រដោយសំពត់ជ្រលក់ដោយពណ៌ផ្សេងៗ ដោយទីដេក និងទីនៅអាស្រ័យទាំងឡាយ តែងថ្វាយបង្គំពួកព្រាហ្មណ៍ទាំងនោះ ។

ពួកព្រាហ្មណ៍ ជាអ្នកមិនត្រូវគេបៀតបៀន មិនត្រូវគេសង្កត់សង្កិន ព្រោះធម៌រក្សា ជននីមួយ មិនហាមឃាត់ពួកព្រាហ្មណ៍ទាំងនោះ ក្នុងទ្វារផ្ទះនៃត្រកូល ដោយប្រការទាំងពួងឡើយ ។

ព្រាហ្មណ៍ទាំងនោះ បានប្រព្រឹត្តព្រហ្មចរិយៈ ( តាំងអំពីក្មេង ) អស់ ៤៨ ឆ្នាំ ពួកព្រាហ្មណ៍បានប្រព្រឹត្តនូវការស្វែងរកវិជ្ជា និងចរណៈមុន ។

ព្រាហ្មណ៍ទាំងនោះមិនបានទៅកាន់ផ្ទះនៃបុគ្គលដទៃ នឹងមិនទិញ កិរិយាយកមកនៅរួមសង្វាសគ្នា ដោយសេចក្តីស្រឡាញ់ទេ ។

ពួកព្រាហ្មណ៍ មិនប្រព្រឹត្តមេថុនធម្ម ក្នុងចន្លោះដែលដល់នូវការវៀរចាករដូវ វៀរលែងតែសម័យគួរនោះ ។

ពួកព្រាហ្មណ៍ តែងសរសើរព្រហ្មចរិយៈ សីល សេចក្តីទៀងត្រង់សេចក្តីទន់ភ្លន់ តបៈ គឺឥន្រ្ទិយសំវរៈ សេចក្តីស្លូតបូត សេចក្តីមិនបៀតបៀន និងសេចក្តីអត់ធន់ ។

ព្រាហ្មណ៍ស្មើដោយព្រហ្ម ជាអ្នកមានព្យាយាមមាំមួន ខ្ពង់ខ្ពស់ជាងពួកព្រាហ្មណ៍ទាំងនោះ ព្រាហ្មណ៍ស្មើដោយព្រហ្មនោះ សូម្បីតែយល់សប្តិឃើញសេពមេថុនធម្ម ក៏មិនដែលមាន ។

មនុស្សមួយពួកក្នុងលោកនេះ ជាអ្នកចេះដឹង កាលសិក្សាតាមវត្តរបស់ព្រាហ្មណ៍ ស្មើដោយព្រហ្មនោះ បានសរសើរព្រហ្មចរិយៈ សីល និងខន្តិធម៌ ។

ព្រាហ្មណ៍ទាំងនោះ សូមអង្ករ ទីដេក សំពត់ ទឹកដោះថ្លា និងប្រេងតាមធម៌ ប្រមូលមក សម្រេចនូវយញ្ញអំពីវត្ថុនោះ កាលបើយញ្ញប្រាកដឡើងហើយ ក៏មិនបានសម្លាប់គោទាំងឡាយឡើយ ។

ឱសថ គឺបញ្ចគោរស កើតក្នុងគោទាំងឡាយ គោទាំងនោះ ជាមិត្តដ៏ប្រសើររបស់ពួកយើង ដូចជាមាតាបិតា បងប្អូន និងពួក

ញាតិដទៃៗ ។

គោទាំងនោះ ជាអ្នកឲ្យបាយ ឲ្យកម្លាំង ឲ្យពណ៌សម្បុរ ឲ្យសេចក្តីសុខ ដូច្នោះ ព្រាហ្មណ៍ទាំងនោះ លុះបានដឹងនូវអំណាចនៃប្រយោជន៍នុ៎ះហើយ ក៏មិនដែលសម្លាប់គោទាំងឡាយឡើយ ។

ពួកព្រាហ្មណ៍ ជាអ្នកមានអវយវៈទន់ភ្លន់ មានកាយប្រសើរ មានសម្បុរល្អ មានយស ជាអ្នកខ្វល់ខ្វាយក្នុងកិច្ចតូចធំ តាមធម៌របស់ខ្លួន បានប្រព្រឹត្តក្នុងលោកត្រឹមណា ពួកសត្វនេះ ក៏បានសេចក្តីសុខ ( ត្រឹមណោះ ) ។

ព្រាហ្មណ៍ទាំងនោះ មានសេចក្តីវិបល្លាស ព្រោះឃើញកាមសុខមានប្រមាណតិច ដែលកើតអំពីកាមគុណ មានប្រមាណតិចផង នូវសម្បត្តិរបស់ស្តេចផង នូវនារីទាំងឡាយ តាក់តែងគ្រឿងប្រដាប់ផង នូវរថ ដែលទឹមដោយសេះអាជានេយ្យ ដែលធ្វើល្អ ពាសដោយស្បែកដ៏វិចិត្រផង នូវទីផ្ទះ និងផ្ទះដែលគេចែករាប់ជាចំណែកៗ ផង ពួកព្រាហ្មណ៍តែងចង់បាននូវសម្បត្តិ ជារបស់មនុស្សដ៏លើសលុប ដេរដាសដោយហ្វូងគោ និងប្រកបដោយពួកនារីដ៏ប្រសើរ ។

ព្រាហ្មណ៍ទាំងនោះ តែងមន្តព្រោះចង់បានទ្រព្យនោះ បានចូលទៅរកព្រះបាទឱក្កាកៈ ក្នុងវេលានោះថា ( ព្រះអង្គ ចូរបូជានូវ

ទ្រព្យដ៏វិចិត្រជាច្រើនរបស់ព្រះអង្គ ) សូមព្រះអង្គបូជានូវធន-សម្បត្តិជាច្រើនរបស់ព្រះអង្គ នឹងបានទ្រព្យ និងស្រូវជាច្រើន ។

គ្រានោះ ពួកព្រាហ្មណ៍បានពន្យល់ព្រះរាជា អ្នកមិនញាប់ញ័រដូចគោឧសភក្នុងរថ ( ឲ្យធ្វើយញ្ញ ៥ យ៉ាង ) គឺអស្សមេធៈ ( យញ្ញជាទីបៀតបៀនសេះ ) ១ បុរិសមេធៈ ( យញ្ញជាទីបៀតបៀនបុរស ) ១ សម្មាបាសៈ ( យញ្ញជាទីបោះទៅនូវកាំនឹម ) ១ វាជបេយ្យៈ ( យញ្ញជាទីផឹកនូវទឹកដោះថ្លា និងទឹកឃ្មុំ ដែលគេតាក់តែងឲ្យជាជើងនៃមន្ត ) ១ និរគ្គឡៈ ( យញ្ញមិនមានសន្ទះទ្វារ ) ១ ។

លុះព្រាហ្មណ៍ទាំងនោះ បានបូជានូវការបូជាទាំងនោះរួចហើយ ក៏បានឲ្យទ្រព្យដល់ពួកព្រាហ្មណ៍ ឲ្យគោ ទីដេក សំពត់ និងនារី ដែលមានគ្រឿងប្រដាប់តាក់តែង រថទឹមដោយសេះអាជានេយ្យដែលធ្វើល្អ ពាសដោយស្បែកដ៏វិចិត្រ លំនៅជាទីត្រេកអរ ដែលគេចាត់ចែងដោយសព្វគ្រប់ ផុកទ្រព្យផ្សេងៗពេញហើយ ឲ្យទ្រព្យដល់ពួកព្រាហ្មណ៍ ។

លុះព្រាហ្មណ៍ទាំងនោះ បានទ្រព្យក្នុងទីនោះហើយ ក៏សន្សំគរទុក ព្រាហ្មណ៍ទាំងនោះ ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ តណ្ហាក៏ចម្រើនឡើងក្រៃលែង ព្រាហ្មណ៍ទាំងនោះ តែងមន្ត

ក្នុងទីនោះ ហើយចូលទៅគាល់ព្រះបាទឱក្កាកៈទៀត ។

ទឹក ដី ប្រាក់ ទ្រព្យ និងស្រូវ យ៉ាងណា គោទាំងឡាយ សម្រាប់ប្រកបកិច្ចការ របស់មនុស្សក៏យ៉ាងនោះដែរ ព្រោះថា វត្ថុមានទឹកជាដើមនោះ ជាបរិក្ខាររបស់ពួកសត្វមានជីវិត សូមព្រះអង្គបូជានូវទ្រព្យដ៏វិចិត្រ ជាច្រើនរបស់ព្រះអង្គ សូមព្រះអង្គបូជា នូវធនសម្បត្តិដ៏ច្រើនរបស់ព្រះអង្គ ។

លំដាប់នោះ ព្រះរាជាដូចជាគោឧសភក្នុងរថ ត្រូវពួកព្រាហ្មណ៍ពន្យល់ហើយ ក៏បានសម្លាប់គោ រាប់សែនជាច្រើន ក្នុងការបូជាយញ្ញ ។

គោស្មើគ្នានឹងចៀម ជាសត្វស្លូត រីតទឹកដោះដាក់ថ្នាំងបាន មិនចេះបៀតបៀនគេដោយជើង មិនចេះបៀតបៀនគេ ដោយស្នែង និងដោយអវយវៈណាមួយឡើយ ព្រះរាជាទ្រង់ចាប់គោទាំងនោះត្រង់ស្នែង ហើយសម្លាប់ដោយគ្រឿងសស្ត្រា ។

លំដាប់នោះ ពួកទេវតាក្តី ពួកព្រហ្មជាបិតាក្តី ព្រះឥន្ទ្រក្តី អសុរ និងអារក្សទឹកក្តី ក៏កន្ទក់កន្ទេញថា ស្តេចគ្មានធម៌ដូច្នេះ ព្រោះព្រះរាជាសម្លាប់គោ ដោយគ្រឿងសស្ត្រា ។

ក្នុងបុរីមានរោគ ៣ យ៉ាង គឺសេចក្តីប្រាថ្នា ១ ការគ្មានស៊ី ១ សេចក្តីគ្រាំគ្រា ១ ចម្រើនឡើងដល់ ៩៨ ( មានរោគភ្នែកជាដើម ) ព្រោះសម្លាប់នូវសត្វចិញ្ចឹម ។

នេះជាអធម៌នៃពួកទណ្ឌៈ ប្រព្រឹត្តយូរហើយ អ្នកបូជាទាំងឡាយ
តែងបៀតបៀននូវគោទាំងឡាយ ជាសត្វមិនប្រទូស្ត រមែង
សាបសូន្យចាកធម៌ ។

នេះឯង ជាធម៌ថោកទាប មានមកតាំងពីកាលមុន ដែលអ្នក
ប្រាជ្ញតិះដៀលហើយយ៉ាងនេះ វិញ្ញូជនឃើញនូវអំពើដូច្នេះ ក្នុង
បុគ្គលអ្នកបូជាណា តែងតិះដៀលនូវបុគ្គល អ្នកបូជានោះ ។

កាលបើព្រាហ្មណធម៌ វិនាសយ៉ាងនេះហើយ ពួកសុទ្ទៈ និង
វេស្សៈក៏បែកគ្នា ពួកខត្តិយៈជាច្រើនក៏បែកគ្នា ទាំងភរិយា ក៏
មើលងាយប្តី ។

ពួកក្សត្រក្តី ពួកជនជាផៅពង្សនៃព្រហ្មក្តី និងពួកជនដទៃ អ្នក
ដែលគោត្ររក្សាក្តី ក៏លែងប្រកាន់ពាក្យពោលអំពីជាតិ លុះ
ក្នុងអំណាចនៃកាមទាំងឡាយ ។

[ ៣១ ] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ពួកព្រាហ្មណមហាសាលទាំងនោះ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះអង្គសម្តែងហើយ ដោយអនេកបរិយាយយ៉ាងនេះ ដូចគេផ្ងារនូវរបស់ដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលកំបាំង ពុំនោះ ដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ឬដូចគេទ្រោលប្រទីបប្រេងក្នុងទីងងឹត ដោយគិតថា បុរសអ្នកមានចក្ខុ ឃើញនូវរូបទាំងឡាយ

បាន ខ្ញុំព្រះអង្គទាំងនេះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផងជាទីរឭក សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គទាំងឡាយ ថាជាឧបាសក អ្នកដល់នូវសរណគមន៍ស្មើដោយជីវិត ចាប់ដើមអំពីថ្ងៃនេះតទៅ ។

ព្រាហ្មណធម្មិកសូត្រទី ៧ ចប់

# អដ្ឋកថា

## ព្រាហ្មណធម្មិកសូត្រ

[ ២៩ ] ក្នុងព្រាហ្មណធម្មិកសូត្រទី ៧ មានពាក្យផ្តើមថា **ឯវំមេ សុតំ** ដូច្នេះ ។

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្តេច ឆ្លើយថា ការកើតឡើងនៃព្រះសូត្រនេះ លោកបានពោលក្នុងពាក្យផ្តើមនៃព្រះសូត្រហើយ ដោយន័យជាដើមថា **អថ ខោ សម្ពហុលា** ។

បណ្តាបទទាំងនោះ បទថា **សម្ពហុលា** បានដល់ ច្រើន គឺមិនមែនតិច ។ បទថា **កោសលកា** បានដល់ អ្នកនគរកោសល ។ បទថា **ព្រាហ្មណមហាសាលា** សេចក្តីថា ពួកព្រាហ្មណ៍ដោយជាតិ ឈ្មោះថា មហាសាល ព្រោះជាអ្នកមានសារៈច្រើន ។

បានឮថា ព្រាហ្មណ៍ឯណាមានទ្រព្យរក្សា ៨០ កោដិ ព្រាហ្មណ៍ទាំង នោះ លោកហៅថា ព្រាហ្មណមហាសាល ឯព្រាហ្មណ៍ទាំងនេះក៏ដូច្នោះ ព្រោះ ហេតុនោះ ទើបលោកពោលថា **ព្រាហ្មណមហាសាលា។**

បទថា **ជិណ្ណា** បានដល់ ជាអ្នកមានភាពជរា គឺត្រូវសេចក្ដីជរាឲ្យដល់ នូវភាវៈ មានធ្មេញបាក់ជាដើម ។ បទថា **វុឌ្ឍា** សេចក្ដីថា ដល់នូវព្រំដែន នៃសេចក្ដីចម្រើននៃអវយវៈតូចធំ ។ បទថា **មហល្លកា** បានដល់ ប្រកប ដោយភាពជាអ្នកមានជាតិជាមនុស្សចាស់ អធិប្បាយថា កើតមកយូរហើយ ។

បទថា **អទ្ធគតា** បានដល់ ទៅកាន់ផ្លូវឆ្ងាយ គឺយូរ អធិប្បាយថា កន្លងទៅពីរបីរជ្ជកាល ។ ពីរបទថា **វយោ អនុប្បត្តា** បានដល់ ចូល ដល់បច្ឆិមវ័យ ។ ម្យ៉ាងទៀត បទថា **ជិណ្ណា** បានដល់ បុរាណ អធិប្បាយ ថា កន្លងត្រកូលដែលប្រព្រឹត្តទៅអស់កាលយូរ ។ បទថា **វុឌ្ឍា** បានដល់ ប្រកបដោយគុណ មានសីលាចារវត្តជាដើម ។ បទថា **មហល្លកា** បានដល់ ប្រកបដោយភាពជាអ្នកមានភោគៈច្រើន មានទ្រព្យច្រើន មានភោគសម្បត្តិ ច្រើន ។ បទថា **អទ្ធគតា** បានដល់ បដិបត្តិតាមគន្លង គឺត្រាច់ទៅ មិន ឈានកន្លងមារយាទ មានចរិយាវត្តរបស់ពួកព្រាហ្មណ៍ជាដើម ។

ពីរបទថា **វយោ អនុប្បត្តា** បានដល់ ចូលដល់ភាវៈនៃជាតិវុឌ្ឍិ ដែលជាវ័យចុងក្រោយ ។

គប្បីជ្រាបវាចាប្រកបសេចក្ដីក្នុងព្រះសូត្រនេះយ៉ាងនេះ ។ ពាក្យដ៏សេស ក្នុងព្រះសូត្រនេះ ប្រាកដច្បាស់ហើយ ។

បទទាំងឡាយថា **ភគវតា សទ្ធិំ សម្មោទឹសុ** សេចក្ដីថា ព្រាហ្មណ៍ទាំងនោះ កាលសួរដល់ពាក្យទាំងឡាយ មានពាក្យថា អ្នកសុខសប្បាយឬ ឈ្មោះថា មានការត្រេកអរដល់គ្នានិងគ្នា ព្រាហ្មណ៍ទាំងនោះត្រេកអរដោយពាក្យណាជាដើមថា បពិត្រព្រះគោតម ទ្រង់សុខទេឬ ទ្រង់ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានឬ ទ្រង់មានអាពាធតិចទេឬ មានរោគតិចទេឬ មានកម្លាំងឬ មិនអផ្សុកទេឬ មានការនៅសប្បាយឬ រមែងឲ្យរឭកដល់ពាក្យនោះ ដែលគួរត្រេកអរ ដែលគួររឭកដល់ គឺឲ្យដល់ទីបំផុត ឲ្យចប់ដោយអនេកបរិយាយយ៉ាងនេះ គឺដើម្បីឲ្យត្រេកអរ ដោយឲ្យកើតការត្រេកអរ ពោល គឺបីតិបាមោជ្ជ និងដើម្បីឲ្យរឭកដល់កាលយូរបាន គឺឲ្យប្រព្រឹត្តទៅជានិរន្តរ ព្រោះជាអ្នកមានអត្ថ និងព្យញ្ជនៈពីរោះ ដែលព្រះអរហន្តគប្បីសរសើរ និងឲ្យរឭកដល់ ដោយពាក្យដែលព្រះអរហន្តគប្បីរឭកដល់ ពាក្យដែលគប្បីសរសើរ ដោយមានសេចក្ដីសុខក្នុងខណៈដែលស្ដាប់ និងឲ្យរឭកដល់ដោយមានសេចក្ដីសុខក្នុងខណៈដែលរឭកដល់ ជាពាក្យដែលគប្បីត្រេកអរ ព្រោះជាពាក្យដែលបរិសុទ្ធដោយព្យញ្ជនៈ ជាពាក្យដែលគប្បីរឭកដល់ ព្រោះជាពាក្យដែលបរិសុទ្ធ ដោយអត្ថយ៉ាងនោះ ជាបុគ្គលប្រាថ្នានឹងសួរដល់ប្រយោជន៍ដែលខ្វះមក បានអង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។

ពាក្យនេះ ខ្ញុំបានពោលក្នុងអដ្ឋកថាមង្គលសូត្រ ដោយន័យថា

មិនអង្គុយខាងក្រោយ មិនអង្គុយខាងមុខ មិនអង្គុយជិត មិនអង្គុយឆ្ងាយ មិនអង្គុយចំហៀង មិនអង្គុយលើខ្យល់ មិនអង្គុយក្នុងទីទាប មិនអង្គុយ

ក្នុងទីខ្ពស់ ដូច្នេះជាដើម ។

ព្រាហ្មណមហាសាលនោះ ជាអ្នកអន្ទ័យហើយក្នុងចំណែកម្ខាង យ៉ាង នេះឯង បានក្រាបទូលនូវពាក្យនេះ នឹងព្រះមានព្រះភាគ ។

សួរថា ព្រាហ្មណ៍ទាំងនោះក្រាបទូលដូចម្ដេច ឆ្លើយថា ព្រាហ្មណ៍ទាំង នោះ បានក្រាបទូលពាក្យជាដើមថា **សន្តិស្សន្តិ នុ ខោ** ដូច្នេះ ។ ពាក្យទាំង អស់នោះ មានអត្ថងាយយល់ទាំងអស់ហើយ តែក្នុងសូត្រនេះ មានពាក្យត្រឹម តែមួយ គឺពាក្យថា **ព្រាហ្មណានំ ព្រាហ្មណធម្មេ** សេចក្ដីថា ព្រាហ្មណធម៌ ដែលច្នងផុតកាល និងស្ថានទីជាដើមមកហើយប៉ុណ្ណោះ ។ ពីរបទថា **តេនហិ ព្រាហ្មណា** សេចក្ដីថា ព្រោះអ្នកទាំងឡាយ បានអារាធនាតថាគត ដូច្នោះ ម្នាលព្រាហ្មណ៍ទាំងឡាយ ចូរអ្នកទាំងឡាយស្ដាប់ គឺចូរផ្ទៀងនូវត្រចៀក ចូរ តាំងចិត្តស្ដាប់ឲ្យល្អ គឺធ្វើទុកក្នុងចិត្តដោយឧបាយ ចូរស្ដាប់ដោយបយោគសុទ្ធិ ចូរធ្វើទុកក្នុងចិត្តដោយល្អ ដោយអាសយសុទ្ធិ គឺចូរស្ដាប់ដោយការមិនរាយ មាយ ចូរធ្វើទុកក្នុងចិត្តដោយល្អ ដោយការផ្គងចិត្ត ដូច្នេះជាដើម កាលនោះ ព្រាហ្មណមហាសាលទាំងឡាយនោះ កាលទទួលនូវពាក្យនោះ ដែលព្រះ មានព្រះភាគត្រាស់ហើយ ទើបបានទូលដល់ព្រះមានព្រះភាគ គឺជាអ្នក ប្រាកដចំពោះព្រះភក្ត្រ ទទួលព្រះតម្រាស់របស់ព្រះមានព្រះភាគថា **ឯវំ ភោ**។

[ ៣០ ]ម្យ៉ាងទៀត ព្រាហ្មណ៍ទាំងឡាយស្ដាប់ហើយ មានពាក្យ អធិប្បាយថា ទទួលស្ដាប់ហើយ ព្រោះខ្លួនប្រាថ្នានឹងធ្វើតាមនូវអត្ថ ដែល ព្រះមានព្រះភាគត្រាស់ថា ចូរអ្នកទាំងឡាយស្ដាប់ ចូរធ្វើទុកក្នុងចិត្តឲ្យល្អ ។

កាលនោះឯង ព្រាហ្មណ៍ទាំងនោះទទួលពាក្យយ៉ាងនេះ ទើបព្រះមានព្រះភាគត្រាស់សេចក្ដីនេះ ។

សួរថា ទ្រង់ត្រាស់ដូចម្ដេច ឆ្លើយថា ទ្រង់ត្រាស់ថា **ឥសយោ បុព្វកា** ជាដើម ។ ក្នុងគាថានោះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១ សិន ។ បទថា **សំយតត្តា** សេចក្ដីថា ជាអ្នកមានចិត្តសង្រួមហើយ ដោយការសង្រួមក្នុងសីល ។ បទថា **តបស្សិនោ** សេចក្ដីថា ជាអ្នកប្រកបដោយការសង្រួមនូវឥន្ទ្រិយ ។ បទថា **អត្តឧត្តមចារិសុំ** បានដល់ ធ្វើនូវប្រយោជន៍ដល់ខ្លួន មានការស្វាធ្យាយមន្ត និងការបម្រើនព្រហ្មវិហារជាដើម ។ ពាក្យដ៏សេស ជាក់ច្បាស់ហើយនោះឯង ។

ក្នុងគាថាទាំងឡាយ មានគាថាទី ២ ជាដើម មានពណ៌នាអត្ថដោយសង្ខេបដូចតទៅនេះ

បាទព្រះគាថាថា **ន បសូ ព្រាហ្មណានាសុំ** សេចក្ដីថា ពួកព្រាហ្មណ៍បុរាណ មិនមានបសុសត្វ គឺពួកព្រាហ្មណ៍ទាំងនោះ មិនចិញ្ចឹមបសុសត្វ ។

បាទព្រះគាថាថា **ន ហិរញ្ញំ ន ធានិយំ** សេចក្ដីថា ពួកព្រាហ្មណ៍មិនមានប្រាក់ ដោយហោចសូម្បីត្រឹមតែមាសក ដែលមានតម្លៃទាបបំផុត ម្យ៉ាងទៀត ព្រាហ្មណ៍ទាំងនោះមិនមានសូម្បីតែពូជ និងធញ្ញាហារ មានបុព្វណ្ណជាតិ អបរន្នជាតិ មានស្រូវខ្សាយ ស្រូវសាលី ស្រូវដំណើប និងស្រងែជាដើម ព្រោះថា ព្រាហ្មណ៍ទាំងនោះ លះបង់នូវប្រាក់ និងមាសហើយ ជាអ្នកមិនធ្វើនូវការសន្សំ មានការស្វាធ្យាយជាទ្រព្យ និងជាស្រូវតែម្យ៉ាង គឺជាអ្នក

ប្រកបដោយទ្រព្យ និងស្រូវ ពោល គឺការស្វាធ្យាយមន្តរបស់ខ្លួនតែម្យ៉ាង ។ វិហារធម៌ មានមេត្តាជាដើម លោកហៅថា **ព្រហ្មនិធិ** គឺការសន្សំដ៏ប្រសើរ ព្រោះជាវិហារធម៌ដ៏ប្រសើរ និងព្រោះអាចជាប់តាមខ្លួនបាន ឯពួកព្រាហ្មណ៍ទាំងឡាយរក្សាកំណប់ដ៏ប្រសើរនេះ ដោយការអប់រំព្រហ្មវិហារ មានមេត្តាជាដើមនោះរឿយៗ ។

បាទព្រះគាថាថា **យំ នេសំ បកតំ អាសិ** សេចក្តីថា ភត្តត្រង់ទ្វារផ្ទះណាដែលគេផ្តើមធ្វើដើម្បីព្រាហ្មណ៍ទាំងនេះ ដែលមានវិហារធម៌យ៉ាងនេះ គឺជាភត្តដែលគេធ្វើឧទ្ទិសព្រាហ្មណ៍ទាំងឡាយនោះ ។

បាទព្រះគាថាថា **ទ្វារភត្តំ ឧបដ្ឋិតំ** សេចក្តីថា ភត្តដែលទាយកនោះៗត្រៀមហើយ តម្កល់ត្រង់ទ្វារផ្ទះរបស់ខ្លួន ដោយគិតថា អញនឹងប្រគេនដល់ព្រាហ្មណ៍ទាំងឡាយ ដូច្នេះ ។

បទថា **សទ្ធាបកតំ** បានដល់ ផ្តើមធ្វើដោយសទ្ធា មានពាក្យអធិប្បាយថា គប្បីឲ្យដោយសទ្ធា ។

ក្នុងពាក្យថា **ឯសានំ** មានវិគ្គហៈថា ជនពួកណារមែងស្វែងរក ហេតុនោះ ទើបឈ្មោះថា **ឯសា** មានពាក្យអធិប្បាយថា ដល់ព្រាហ្មណ៍ទាំងឡាយនោះដែលជាអ្នកស្វែង គឺស្វែងរក ត្រាច់ស្វែងរក។ បទថា **ទាតវេ** បានដល់ គប្បីឲ្យ ។ បទថា **តទមញ្ញិសុំ** បានដល់ មិនមើលងាយភត្តនោះ អធិប្បាយថា ជនទាំងឡាយអ្នកឲ្យ បានសម្គាល់នូវភត្តនោះ ដែលខ្លួនត្រៀមទុកត្រង់ទ្វារដែលខ្លួនគប្បីឲ្យដោយសទ្ធា គឺដែលខ្លួនគប្បីឲ្យដល់ព្រាហ្មណ៍ទាំងនោះដែល

ស្វែងរក មិនបានសម្គាល់ក្រៃលែងជាងនោះឡើយ ព្រោះថា ព្រាហ្មណ៍ទាំង នោះមិនត្រូវការ មានហើយដោយប្រការដទៃ គឺមិនស្វែងរកកត្ត ព្រាហ្មណ៍ ទាំងនោះគាប់ចិត្តហើយ ព្រោះជាអ្នកមានអាហារ និងគ្រឿងស្លៀកដណ្តប់ ក្រៃលែងតែម្យ៉ាង គឺត្រូវការអាហារ និងគ្រឿងស្លៀកដណ្តប់ប៉ុណ្ណោះ ។

បទថា **នានារត្តេហិ** បានដល់ ដោយសំពត់ដែលជ្រលក់ដោយពណ៌ ផ្សេងៗ ដោយទីដេក ដែលក្រាលហើយដោយកម្រាលដ៏វិចិត្រ ដោយប្រាសាទ ដ៏ប្រសើរ មានប្រាសាទមួយជាន់ ឬពីរជាន់ជាដើម ។

បទថា **អាវសថេហិ** បានដល់ ដោយឧបករណ៍ទាំងឡាយបែបនោះ ។

អ្នកជនបទ អ្នកដែន គឺអ្នកជនបទដែលនៅក្នុងចំណែកនីមួយរបស់ ប្រទេស និងអ្នកដែនទាំងអស់ពួកខ្លះ រមែងនមស្ការព្រាហ្មណ៍ទាំងឡាយ ទាំង ល្ងាច ទាំងព្រឹក ដូចបុគ្គលនមស្ការទេវតាទាំងឡាយថា ខ្ញុំសូមនមស្ការ ព្រាហ្មណ៍ទាំងឡាយ ដូច្នេះ ។ ព្រាហ្មណ៍ទាំងនោះ ដែលបុគ្គលនមស្ការយ៉ាង នេះ ដែលសត្វលោកមិនគប្បីសម្លាប់ និងមិនគប្បីសម្លាប់តែម្យ៉ាងប៉ុណ្ណោះ ក៏ មិនមែន តែគប្បីឈ្នះសូម្បីបៀតបៀន និងមិនគប្បីឈ្នះ ព្រោះព្រាហ្មណ៍ទាំង នោះ គ្របសង្កត់មិនបាន សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះព្រាហ្មណ៍ ទាំងនោះរក្សាហើយ ឆ្លើយថា ព្រាហ្មណ៍ទាំងនោះ ដែលធម៌រក្សាហើយ ។ ដ្បិតថា ព្រាហ្មណ៍ទាំងនោះ រក្សាធម៌ គឺសីល ៥ ហើយ ឈ្មោះថា ជា បុគ្គលដែលធម៌រក្សាហើយ ព្រោះព្រះបាលីថា **ធម្មោ ហវេ រក្ខតិ ធម្មចារឹ** ប្រែថា ធម៌នោះឯង រមែងរក្សាអ្នកប្រព្រឹត្តធម៌ ដូច្នេះ ទើបឈ្មោះថា ជាបុគ្គល

ដែលបុគ្គលណាម្នាក់ មិនគប្បីសម្លាប់ និងមិនគប្បីឈ្នះ ។

បាទព្រះគាថាថា **ន នេ កោចិ និវារេសិ** សេចក្តីថា បុគ្គលណាម្នាក់ មិនគួរហាមព្រាហ្មណ៍ទាំងនោះ ត្រង់ទ្វារនៃត្រកូលទាំងឡាយ ឈ្មោះថា ត្រង់ទ្វារនៃត្រកូល ក្នុងទីទាំងពួង គឺទាំងខាងក្រៅ ទាំងខាងក្នុង ដោយប្រការទាំងពួង ព្រោះមនុស្សទាំងឡាយជាបុគ្គលដែលមានការស្និទ្ធស្នាលយ៉ាងក្រៃលែងក្នុងព្រាហ្មណ៍ទាំងនោះថា លោកមិនគួរចូលទៅកាន់ស្ថានទីឈ្មោះនេះ ។ គប្បីជ្រាបអធិប្បាយក្នុងព្រះគាថានេះយ៉ាងនេះថា ព្រាហ្មណ៍ពួកណា ទោះជាព្រាហ្មណ៍ចណ្ឌាល ព្រាហ្មណ៍ទាំងនោះ ដែលធម៌រក្សាហើយយ៉ាងនេះ ដែលបុគ្គលណាម្នាក់មិនហាមហើយ ត្រង់ទ្វារនៃត្រកូលទាំងឡាយត្រាច់ទៅ ប្រព្រឹត្តព្រហ្មចរិយៈ តាំងអំពីនៅជាកុមារ ដោយការប្រព្រឹត្ត ចាប់តាំងអំពីកាលនៅជាកុមារអស់ ៤៨ ឆ្នាំ គឺ ៨ ឆ្នាំ និង ៤០ ឆ្នាំ ទីងពោលថ្វីក្នុងព្រាហ្មណ៍ទាំងឡាយ មានព្រាហ្មណ៍ដែលស្មើដោយព្រហ្មជាដើមនោះ ។

ព្រាហ្មណ៍ទាំងនោះប្រព្រឹត្តព្រហ្មចរិយៈយ៉ាងនេះឯង បានត្រាច់ស្វែងរកវិជ្ជា និងចរណៈក្នុងកាលមុន ជាអ្នកមិនប្រព្រឹត្តព្រហ្មចរិយៈក៏មិនមែន ។

បណ្តាបទទាំងនោះ បទថា **វិជ្ជាបរិយេដ្ឋិ** បានដល់ ការស្វែងរកមន្តសមដូចពាក្យដែលលោកពោលថា ព្រាហ្មណ៍នោះក៏រៀនយកនូវមន្ត ប្រព្រឹត្តកោមារព្រហ្មចរិយៈអស់ ៤៨ ឆ្នាំ ។

បទថា **ចរណបរិយេដ្ឋិ** បានដល់ ការរក្សាសីល ព្រះបាលីថា **វិជ្ជា-ចរណបរិយេដ្ឋិ** ដូច្នេះក៏មាន សេចក្តីថា បានត្រាច់ទៅដើម្បីស្វែងរកវិជ្ជា និង

ចរណៈ អធិប្បាយថា ព្រាហ្មណ៍ទាំងឡាយ ជាអ្នកស្មើដោយទេវតា ឬជាអ្នកមានមារយាទ ប្រព្រឹត្តព្រហ្មចរិយៈតាមដែលពោលហើយ បន្ទាប់អំពីប្រព្រឹត្តព្រហ្មចរិយៈនោះហើយ សូម្បីមកគ្រប់គ្រងឃរាវាស ក៏មិនដល់ស្រីដទៃ មិនថា ស្រីក្សត្រ ឬស្រីណាម្នាក់ ក្នុងបណ្តាស្រីទាំងឡាយ មានស្រីវេស្សៈ ( អ្នកជំនួញ ) ជាដើម ។ បន្ទាប់អំពីនោះ ព្រាហ្មណ៍ទាំងនោះ រកទ្រព្យបាន ១០០ ឬ ១០០០ កហាបណៈហើយ ទិញភរិយាមកក៏មិនមែន ដូចបុគ្គលពួកខ្លះ ទិញភរិយាក្នុងបច្ចុប្បន្ន ព្រាហ្មណ៍ទាំងនោះ រមែងស្វែងរកភរិយាដោយធម៌ សេចក្តីនេះដូចម្តេច គឺព្រាហ្មណ៍ទាំងឡាយ ប្រព្រឹត្តព្រហ្មចរិយៈ អស់ ៤៨ ឆ្នាំ សឹកហើយ ត្រាច់ស្វែងរកស្ត្រីក្នុងថ្ងៃនោះឯង ដោយការពោលថា ខ្ញុំប្រព្រឹត្តព្រហ្មចរិយៈមកអស់ ៤៨ ឆ្នាំ បើកុមារីដែលដល់ព្រមដោយវ័យហើយមាន សូមពួកអ្នកឲ្យដល់ខ្ញុំ បន្ទាប់អំពីនោះ បុគ្គលដែលមានធីតាពេញវ័យ ប្រដាប់ធីតានោះហើយ នាំចេញមកឲ្យក្នុងដៃរបស់ព្រាហ្មណ៍ ដែលឈរត្រង់ទ្វារនោះឯង កាលនឹងប្រូចទឹក ក៏ពោលថា បពិត្រលោក ខ្ញុំឲ្យធីតានេះដើម្បីជាភរិយារបស់លោក ដើម្បីជាប្រយោជន៍ដល់ការចិញ្ចឹម ដូច្នេះហើយ ក៏ប្រគល់ឲ្យទៅ ។ បើជនទាំងឡាយ សួរថា ព្រោះហេតុអ្វី ទើបព្រាហ្មណ៍ទាំងនោះប្រព្រឹត្តព្រហ្មចរិយៈយូរយ៉ាងនេះហើយ នៅតែស្វែងរកភរិយា មិនប្រព្រឹត្តព្រហ្មចរិយៈដរាបដល់អស់ជីវិតទៅ ឆ្លើយថា ព្រោះព្រាហ្មណ៍ទាំងនោះ មានមិច្ឆាទិដ្ឋិយ៉ាងនេះថា បុគ្គលណាមិនឲ្យកូនកើតឡើង បុគ្គលនោះ ជាអ្នកកាត់នូវវង្សត្រកូល ព្រោះការកាត់នូវវង្សត្រកូលនោះ រមែងធ្លាក់ក្នុងនរក ។

បានឮថា មនុស្ស និងសត្វ ៤ ពួក គឺជន្ទេន ១ ត្រដេវិច ១ ក្រៀល ១ ព្រាហ្មណ៍ ១ រមែងខ្វាចវត្ថុដែលមិនគួរខ្លាច បានឮថា ជន្ទេនទាំងឡាយ ជាសត្វមានប្រក្រតីស៊ីតែល្មមប្រមាណ ព្រោះខ្លាចមហាប្រឹថពីអស់ទៅ មិនបរិភោគលើសប្រមាណឡើយ ត្រដេវិចញី ដេកផ្ងារលើស៊ុត ព្រោះខ្លាចអាកាសបាក់សង្កត់ ក្រៀលញីរមែងមិនជាន់ផែនដីពេញជើងទាំង ២ ព្រោះខ្លាចផែនដីស្រុត ព្រាហ្មណ៍ទាំងឡាយ រមែងស្វែងរកកិរិយា ព្រោះខ្លាចដាច់វង្សត្រកូល លោកពោលក្នុងគាថានេះថា

សត្វដែលវង្វេង ៤ ពួក គឺជន្ទេន ១ មេត្រដេវិច ១ ក្រៀល ១ ព្រាហ្មណ៍ដែលប្រព្រឹត្តតីងរ៉ឹងក្នុងទំនៀម ១ រមែងខ្លាចវត្ថុដែលមិនគួរខ្លាចដូច្នេះ ។

ព្រាហ្មណ៍ទាំងឡាយ សូម្បីស្វែងរកកិរិយាដោយធម៌យ៉ាងនេះ នៅរួមគ្នាព្រោះសេចក្តីស្រឡាញ់ស្មើគ្នាប៉ុណ្ណោះ និងនៅជាមួយគ្នាដោយកាយដោយសេចក្តីស្រឡាញ់ដែលស្មើគ្នា គឺដោយសេចក្តីស្រឡាញ់គ្នានិងគ្នាប៉ុណ្ណោះ អធិប្បាយថា ជាអ្នកមានចិត្តរួមគ្នា ប៉ះពាល់គ្នា ពេញចិត្តការនៅរួមគ្នា មិនមែននៅរួមគ្នាដោយការមិនស្រឡាញ់ ឬដោយការសម្ងុតកំហែងគ្នាឡើយ ព្រាហ្មណ៍ធ្វើការនៅរួមគ្នា ដោយការស្រឡាញ់ដែលស្មើគ្នាយ៉ាងនេះ ក៏រមែងមិនរួមបវេណីជាមួយកិរិយាដែលមិនមានរដូវ ។

ពីរបទថា **អញ្ញត្រ តម្ហា** សេចក្តីថា ក្នុងសម័យដែលមានរដូវឯណា ព្រាហ្មណ៍គប្បីចូលដល់ព្រាហ្មណីក្នុងសម័យនោះ គឺវៀរនូវសម័យនោះ

ព្រាហ្មណ៍ដែលជាប្ដី ក៏មិនរួមជាមួយភរិយាដែលវៀរហើយចាកវដូវ គឺដែលវៀរចាកវដូវ ដរាបដែលសម័យនោះមិនទាន់មកដល់ទៀត គឺមិនរួមក្នុងចន្លោះដោយពិត ។

បទថា **មេថុនធម្មំ** បានដល់ ធម៌ដែលជាគូៗ ដែលសន្មតថា **មេថុនំ ធម្មំ** នោះ ជាទុតិយាវិភត្តិ ប្រើក្នុងអត្ថចតុត្ថីវិភត្តិ ។ ពីរបទថា **នាស្សុ គច្ឆន្តិ** បានដល់ រមែងមិនដល់ អធិប្បាយថា ជនពួកណាមួយ ជាអ្នកស្មើដោយទេវៈ និងមានមារយាទ ឈ្មោះថា ព្រាហ្មណ៍ ដោយមិនប្លែកគ្នា មនុស្សគ្រប់ពួកគប្បីសរសើរព្រហ្មចរិយៈ ។បេ។ និងការអត់ធន់ ។

មេថុនវិរតិ ឈ្មោះថា ព្រហ្មចរិយៈក្នុងគាថានោះ ៤ សិក្ខាបទ ដ៏សេស ឈ្មោះថា **សីល** ។ ភាពជាអ្នកស្មោះត្រង់ ឈ្មោះថា **អាជ្ជវំ** ដោយអត្ថ គឺអ្នកមិនអួតអាង មិនមានមាយា ។

ភាពជាអ្នកទន់ភ្លន់ ឈ្មោះថា **មទ្ទវំ** ដោយអត្ថ គឺការមិនរឹងត្អឹង និងមិនប្រកាន់ខ្លួន ។ ការសង្រួមឥន្ទ្រិយ ឈ្មោះថា **តបំ** ភាពជាអ្នកស្ងប់ស្ងៀម ការមានសេចក្ដីសុខដោយប្រក្រតី ការប្រព្រឹត្តរៀបរយ មិនគួររង្កៀស ឈ្មោះថា **សោរច្ចំ** ។

ភាពជាអ្នកមានជាតិនៃបុគ្គលមិនបៀតបៀនដោយបាតដៃជាដើម ជាអ្នកមានករុណា ឈ្មោះថា **អវិហឹសំ** ។

ការអត់ធន់ គឺការអត់ធ្មត់ ឈ្មោះថា **ខន្តិ** ។

ព្រាហ្មណ៍ទាំងឡាយសរសើរគុណទាំងឡាយយ៉ាងនេះ ឯព្រាហ្មណ៍ពួក

ណាមិនអាចត្រេកអរក្នុងបដិបទាដោយប្រការទាំងពួងបាន ព្រាហ្មណ៍ទាំងនោះ ក៏មានប្រក្រតីឃើញនូវគុណធម៌ទាំងនោះថា មានប្រយោជន៍ គប្បីសរសើរ គឺ សរសើរដោយវាចា កាលព្រាហ្មណ៍ទាំងនោះសរសើរយ៉ាងនេះថា ព្រាហ្មណ៍ ណាជាអ្នកស្មើដោយព្រហ្ម ជាអ្នកមានសេចក្តីព្យាយាមមាំទាំ ជាបុគ្គលឧត្តម ជាងព្រាហ្មណ៍ទាំងនោះ ហើយព្រាហ្មណ៍ទាំងនោះ រមែងមិនសេពមេថុនធម្ម ដោយហោចសូម្បីក្នុងការយល់សប្តិ ដូច្នេះ ។

ព្រះគាថាថា **យោ នេសំ ។បេ។ នាគមា** សេចក្តីថា ព្រាហ្មណ៍ណា ជាអ្នកស្មើដោយព្រហ្ម គឺជាព្រាហ្មណ៍ដែលឧត្តមបំផុត ស្មើដោយព្រហ្ម ជា បុគ្គលឧត្តមជាងព្រាហ្មណ៍ទាំងនោះ ឈ្មោះថា **ទឡ្ហបរក្កមោ** ព្រោះប្រកប ដោយការព្យាយាមមាំទាំ ។ **វា** សព្ទ ក្នុងពាក្យថា **ស វា** ប្រើក្នុងអត្ថថា ធ្វើឲ្យជាក់ច្បាស់ ព្រោះ **វា** សព្ទនោះ ព្រះមានព្រះភាគ រមែងចង្អុលប្រាប់ ព្រាហ្មណ៍នោះឯងឲ្យជាក់ច្បាស់ថា ព្រាហ្មណ៍នោះ គឺបុគ្គលបែបនេះ ។

បទថា **មេថុនំ ធម្មំ** បានដល់ ចូលដល់មេថុន ។

ពីរបទថា **សុបិនន្តេបិ នាគមា** បានដល់ មិនដល់សូម្បីដោយការ យល់សប្តិ ។ តាំងអំពីនោះ ព្រះមានព្រះភាគក៏ត្រាស់ថា ព្រាហ្មណ៍ពួកខ្លះ ជាអ្នកមានជាតិនៃបុគ្គលដែលដឹងច្បាស់ក្នុងលោកនេះ គឺតាមរក្សាវត្តរបស់ ព្រាហ្មណ៍ដែលស្មើដោយព្រហ្មនោះ បានសរសើរនូវព្រហ្មចរិយៈ សីល និង ខន្តី ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងដោយអំណាចនៃទីបំផុតខាងដើម

ដោយន័យដែលព្រះអង្គត្រាស់ហើយក្នុងគាថាទី ៩ នៃសូត្រនេះឯង ទើបទ្រង់ប្រកាសឲ្យព្រាហ្មណ៍ទាំងឡាយដែលស្មើដោយទេវតា ព្រោះថា បណ្ឌិតទាំង-ឡាយដែលមានជាតិនៃអ្នកដឹងច្បាស់ទាំងនោះ សិក្សាវត្តរបស់ព្រាហ្មណ៍ដែលស្មើដោយព្រហ្មនោះ រមែងសរសើរវត្តរបស់ព្រាហ្មណ៍ ដោយបព្វជ្ជា និងដោយការចម្រើនឈាន ព្រាហ្មណ៍ទាំងនោះ រមែងសរសើរគុណ មានព្រហ្ម-ចរិយៈជាដើមនេះ ដោយបដិបទាប៉ុណ្ណោះ ព្រាហ្មណ៍គ្រប់ពួក គប្បីជ្រាបដោយន័យដែលព្រះមានព្រះភាគត្រាស់ក្នុងទោណសូត្រ ក្នុងបញ្ចកនិបាតនោះឯង ។ ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សរសើរព្រាហ្មណ៍ទាំងឡាយដែលមានមារយាទ ទើបត្រាស់ថា **តណ្ឌុលំ សយនំ** ជាដើម ។

អត្ថនៃព្រះគាថានោះថា បណ្ដាព្រាហ្មណ៍ទាំងនោះ ព្រាហ្មណ៍ពួកណាជាអ្នកមានមារយាទ តែបើបំណងនឹងធ្វើយញ្ញ លំដាប់នោះ ព្រាហ្មណ៍ទាំងនោះ ក៏សូមអង្ករ ទីដេក មានគ្រែ និងតាំងជាដើម សំពត់ មានសំពត់ធ្វើដោយសម្បកឈើជាដើម សប្បិ និងប្រេង មានសប្បិដែលកើតអំពីគោ និងប្រេងដែលកើតអំពីល្ងជាដើម ដែលមានប្រការផ្សេងៗ ព្រោះព្រាហ្មណ៍ទាំងនោះ ជាអ្នកវៀរហើយចាកការទទួលរបស់ឆៅ និងស្រូវ គឺសូមហើយដោយធម៌ បានដល់ ដោយធម៌ ពោល គឺឋានៈដែលឧទ្ទិសចំពោះ ដែលលោកពោលយ៉ាងនេះថា ពួកអរិយៈគ្រាន់តែឈរឧទ្ទិសស្ងៀមៗ ប៉ុណ្ណោះ នុ៎ះជាការសូមរបស់ពួកអរិយៈ ដូច្នេះ លំដាប់នោះ ទើបបានប្រមូល គឺនាំមក រូបរួមនូវវត្ថុ មានអង្ករជាដើមនោះ ដែលបុគ្គលបំណងនឹងឲ្យ ។

ព្រះបាលីថា **សមុទានេត្វា** ដូច្នេះក៏មាន អត្ថក៏ដូចគ្នានោះឯង គប្បី ប្រកបយញ្ញអំពីវត្ថុនោះ គឺកាន់យកវត្ថុនោះ ហើយធ្វើទាន ។

កាលធ្វើ រមែងមិនសម្លាប់គោទាំងឡាយ គឺព្រាហ្មណ៍ទាំងនោះ មិនសម្លាប់មេគោទាំងឡាយ ព្រោះយញ្ញ ពោល គឺទានដែលប្រាកដឡើងហើយយ៉ាងនេះ ។ ក្នុងពាក្យថា **គាវោ** នេះ គប្បីជ្រាបថា លោកពោលដល់សត្វគ្រប់ពួក ដោយលើកមេគោជាប្រធាន ។ សួរថា ព្រោះហេតុអ្វី ទើបព្រាហ្មណ៍ទាំងនោះ មិនសម្លាប់សត្វគ្រប់ពួក ឆ្លើយថា ព្រោះព្រាហ្មណ៍ទាំងនោះប្រកបដោយគុណ មានព្រហ្មចរិយៈជាដើម ។

ម្យ៉ាងទៀត បើពោលដោយវិសេស ព្រាហ្មណ៍ទាំងនោះមិនសម្លាប់គោទាំងឡាយ ដូចគ្នានឹងមាតាបិតា បងប្រុស ប្អូនប្រុស និងញាតិទាំងឡាយដទៃ ។

បណ្តាបទទាំងនោះ បាទព្រះគាថាថា **យាសុ ជាយន្តិ ឱសថា** សេចក្តីថា បញ្ចគោរស ៥ ប្រភេទ ដែលជាភេសជ្ជៈរម្ងាប់នូវរោគទាំងឡាយ មានរោគប្រមាត់ជាដើម រមែងកើតក្នុងមេគោពួកណា ។

បទទាំងឡាយ មានបទថា **អន្នទា** ជាដើម មានអធិប្បាយថា ព្រោះកាលជនទាំងឡាយ បរិភោគបញ្ចគោរស ការស្រេកឃ្លានក៏ស្ងប់បាន កម្លាំងក៏មាន ពណ៌សម្បុរក៏ដូរផង់ សុខកាយ សុខចិត្ត រមែងកើតឡើង ដូច្នោះ គប្បីជ្រាបថា បញ្ចគោរសទាំងនេះ ឈ្មោះថា ឲ្យបាយ ឲ្យកម្លាំង ឲ្យនូវពណ៌សម្បុរ និងឲ្យនូវសេចក្តីសុខ ។ ពាក្យដ៏សេសក្នុងគាថានេះ មានអត្ថងាយ

យល់ហើយ ។

ព្រាហ្មណ៍ទាំងនោះ មិនសម្លាប់មេគោទាំងឡាយ ព្រោះយញ្ញទាំងឡាយយ៉ាងនេះ ជាអ្នកមានរាងកាយដែលជាប្រភពកើតនៃបុណ្យអនុគ្រោះហើយ ទើបជាបុគ្គលសុខមាលជាតិ មានរាងកាយធំ មានពណ៌សម្បុរ មានយស ខ្វល់ខ្វាយក្នុងកិច្ចតូចធំ ដោយធម៌របស់ខ្លួន បានប្រព្រឹត្តហើយដោយបដិបទាដែលជាហេតុឲ្យពួកសត្វដល់នូវសេចក្តីសុខក្នុងលោក ។

បណ្តាបទទាំងនោះ បទថា **សុខុមាលា** បានដល់ ជាអ្នកសុខុម ព្រោះជាអ្នកមានបាតដៃ និងបាតជើងទន់ ។ បទថា **មហាកាយា** បានដល់ ជាអ្នកមានកាយធំ ព្រោះជាអ្នកដល់ព្រមដោយកម្ពស់ និងទំហំ ។

បទថា **វណ្ណវន្តោ** បានដល់ ជាអ្នកមានពណ៌សម្បុរ ព្រោះជាអ្នកមានពណ៌សម្បុរដូចមាស និងព្រោះជាអ្នកប្រកបដោយទ្រង់ទ្រាយសមសួន ។

បទថា **យសស្សិនោ** បានដល់ ជាអ្នកមានយស ព្រោះជាអ្នកដល់ព្រមដោយលាភ និងបរិវារ ។

ពីរបទថា **សេហិ ធម្មេហិ** បានដល់ ដោយចរិតទាំងឡាយដែលជារបស់ខ្លួន ។ បាទគាថាថា **កិច្ចាកិច្ចេសុ ឧស្សុកា** សេចក្តីថា ជាអ្នកដល់នូវការខ្វល់ខ្វាយថា គួរធ្វើវត្ថុនេះក្នុងកិច្ចទាំងឡាយ មិនគួរធ្វើវត្ថុនេះក្នុងវត្ថុដែលមិនគួរធ្វើទាំងឡាយ ព្រាហ្មណ៍សម័យមុនទាំងនោះ ជាបុគ្គលបែបនោះ ទើបជាអ្នកគួរមើល គួរជ្រះថ្លា គួរដល់ទក្ខិណារបស់សត្វលោកយ៉ាងក្រៃលែង ជាបុគ្គលប្រាសចាកនូវចង្រៃ ភ័យ ឧបទ្រព ដរាបណានៅបដិបត្តិបដិបទានេះក្នុង

លោក ដែលជាហេតុឲ្យពួកសត្វដល់ គឺសម្រេចនូវសេចក្ដីសុខ ឬដល់នូវសេចក្ដីសុខ បានដល់ សម្រេច គឺដល់នូវសេចក្ដីចម្រើន ។ ដោយបទថា **អយំ បជា** ព្រះមានព្រះភាគ សម្ដែងនូវសត្វលោក តែដោយកាលកន្លងទៅ កាលពួកព្រាហ្មណ៍ទាំងនោះត្រូវទម្លាយមារយាទ ចរិត បវេណី របស់ខ្លួន ព្រាហ្មណ៍ទាំងនោះ មានសេចក្ដីវិបល្លាស ព្រោះឃើញកាមសុខ មានប្រមាណតិច ដែលកើតអំពីកាមគុណ មានប្រមាណតិចផង នូវសម្បត្តិរបស់ស្ដេចផង នូវនារីទាំងឡាយដែលតាក់តែងគ្រឿងប្រដាប់ផង នូវរថដែលទឹមដោយសេះអាជានេយ្យដែលធ្វើល្អ ពាសដោយស្បែកដ៏វិចិត្រផង នូវទីផ្ទះ និងផ្ទះដែលគេចែករាប់ជាចំណែកៗ ផង ។

ក្នុងគាថានោះ កាលសម្គាល់ខុសឈ្មោះថា វិបល្លាស ។

ពីរបទថា **អណុតោ អណុំ** អធិប្បាយថា ព្រោះឃើញកាមសុខបន្តិចបន្តួច ដែលកើតឡើងហើយចាកកាមគុណ ដែលជារបស់បន្តិចបន្តួច ព្រោះអត្ថថា លាមក ព្រោះអត្ថថា បន្តិចបន្តួច ព្រោះអត្ថថា មិនចម្រើន ដោយមិនចូលដល់នូវការរាប់ចូលក្នុងការប្រៀបធៀបជាមួយនឹងសុខ ដែលកើតអំពីអប្បមញ្ញាឈាន និងនិព្វាន ឬព្រោះឃើញកាមសុខបន្តិចបន្តួច ដោយជាសេចក្ដីសុខដែលកើតអំពីលោកិយសមាបត្តិ ដែលខ្លួនបានហើយ ជារបស់បន្តិចបន្តួច ព្រោះប្រៀបធៀបនឹងលោកុត្តរសុខ គឺព្រោះឃើញកាមសុខតិចតួច ព្រោះជារបស់តិចតួច ។

បទថា **រាជិនោ ច** បានដល់ របស់ព្រះរាជានោះឯង ។ បទថា **វិយាការំ**

បានដល់ ទ្រព្យសម្បត្តិ ។ បទថា **អាជញ្ញសំយុត្តេ** បានដល់ រថទឹមដោយសេះអាជានេយ្យ ។ បទថា **សុកតេ** បានដល់ សម្រេចល្អហើយ ដោយទារុកម្ម និងលោហកម្ម ។ បទថា **ចិត្តសិព្វនេ** បានដល់ មានការរំលេចដ៏វិចិត្រ ដោយអំណាចនៃគ្រឿងអលង្ការណៈ គឺការប្រដាប់ដោយវត្ថុទាំងឡាយមានស្បែកសីហៈជាដើម ។ បទថា **និវេសនេ** បានដល់ ដីសម្រាប់សង់ផ្ទះ ។ បទថា **និវេសេ ច** បានដល់ ផ្ទះដែលគេសាងក្នុងទីនោះៗ ។ បទថា **វិភត្តេ** បានដល់ វាស់ចែកដោយអំណាចនៃចំណែកបណ្តោយ និងចំណែកទទឹង ។

បទថា **ភាគសោ មិតេ** បានដល់ ដែលកំណត់ធ្វើជាចំណែកៗ ដោយអំណាចនៃទីលាន ទ្វារ ប្រាសាទ និងផ្ទះកំពូលជាដើម ។

សួរថា លោកអធិប្បាយដូចម្តេច ឆ្លើយថា លោកអធិប្បាយថា ការសម្គាល់ខុសមានហើយដល់ព្រាហ្មណ៍ទាំងនោះ ព្រោះប្រព្រឹត្តទៅក្នុងវត្ថុទាំង-ឡាយនេះ ដែលជាទុក្ខប៉ុណ្ណោះថាជាសុខ ព្រោះផុយគ្មានឹងការសម្គាល់ក្នុងការចេញបួស ដែលប្រព្រឹត្តទៅហើយក្នុងកាលមុន ព្រោះបានឃើញកាមសុខថាជារបស់តិចតួច ដោយភាពជារបស់តិចតួច ១ សម្បត្តិរបស់ព្រះរាជា ១ នារីដែលប្រដាប់ហើយទាំងឡាយ ១ រថទាំងឡាយ ១ គ្រឿងផ្ទះទាំងឡាយ ១ តួផ្ទះទាំងឡាយ ១ ដែលមានប្រការដូចពោលហើយ ដោយភាពជារបស់តិចតួច ព្រាហ្មណ៍ទាំងឡាយនោះ មានការឃើញវិបរិតយ៉ាងនេះ ទើបសម្លឹងភោគសម្បត្តិដែលជារបស់មនុស្សដ៏ឧឡារ ដែលដេរដាសទៅដោយហ្វូងគោ ដែលប្រកបទៅដោយពួកនារីដ៏ប្រសើរ ។

បណ្ដាបទទាំងនោះ បទថា **គោមណ្ឌលបរិព្យូឡ្ហំ** បានដល់ ដេរដាស ដោយហ្វូងគោទាំងឡាយ ។

បទថា **នារីវរគណាយុតំ** បានដល់ ដែលប្រកបដោយពួកនារីដ៏ប្រសើរ ។ បទថា **ឧឡារំ** បានដល់ បរិបូណ៌ ។

បទថា **មានុសំ ភោគំ** បានដល់ វត្ថុជាគ្រឿងប្រើប្រាស់ មានគ្រឿងផ្ទះជាដើមនៃមនុស្សទាំងឡាយ ។

បទថា **អភិជ្ឈាយឹសុ** បានដល់ ញុំាងតណ្ហាឲ្យចម្រើន ប្រាថ្នាសម្ដីថា ឱហ្ន៎ ! វត្ថុនេះគប្បីជារបស់អញ ។

ព្រាហ្មណ៍ទាំងឡាយនោះគិតថា មនុស្សទាំងនេះសម្ដីយ៉ាងនេះ ជាអ្នកព្រោះព្រំល្អហើយ លាបល្អហើយ កាត់សក់ គោរពុកមាត់ហើយ ពាក់នូវគ្រឿងប្រដាប់ គឺកម្រងផ្កា បម្រើដោយកាមគុណទាំង ៥ តែយើងទាំងឡាយសូម្បីមនុស្សទាំងនោះថ្វាយបង្គំយ៉ាងនេះ ជាអ្នកមានរាងកាយសៅហ្មងដោយផ្កាអំបិល មានក្រចក និងរោមក្លៀកវែង ជាអ្នកឥតភោគៈ ដល់នូវភាពជាបុគ្គលគួរករុណាក្រៃលែង ឯមនុស្សទាំងនេះ ត្រាច់ទៅដោយពាហនៈទាំង-ឡាយ មានការអង្គុយលើកដំរី អង្គុយលើខ្នងសេះ អង្គុយលើរ៉ អង្គុយលើរថដែលធ្វើអំពីមាសជាដើម ឯពួកយើង ត្រូវដើរដោយជើង មនុស្សទាំងនេះនៅលើប្រាសាទ មានប្រាសាទពីរជាន់ជាដើម ពួកយើងនៅក្នុងព្រៃ និងគល់ឈើជាដើម មនុស្សទាំងនេះ ក៏ដេកលើដំណេកដ៏ប្រសើរ ដែលក្រាលហើយដោយវត្ថុទាំងឡាយ មានសំពត់កោជវៈរោមវែងជាដើម ពួកយើងក្រាល

កន្ទេលផែង និងបន្ទះស្បែក ដេកលើផែនដី មនុស្សទាំងនេះ បរិភោគភោជន មានរសច្រើនប្រភេទ ពួកយើង ញុំាងជីវិតឲ្យប្រព្រឹត្តទៅ ដោយការត្រាច់ភិក្ខាចារ សូម្បីពួកយើងគប្បីដូចគ្នានឹងមនុស្សទាំងនេះ បានដូចម្ដេចហ្ន៎ ដូច្នេះហើយ បានសម្រេចចិត្តថា យើងត្រូវប្រាថ្នាទ្រព្យ យើងទាំងឡាយជាអ្នកវៀរចាកទ្រព្យ មិនអាចនឹងទទួលសម្បត្តិនេះបាន ដូច្នេះហើយ ទើបទម្លាយនូវវេទទាំងឡាយ គឺមិនរៀនវេទ ធ្វើមន្តបុរាណ ដែលប្រកបដោយធម៌ឲ្យអន្តរធានទៅ ចងមន្តបញ្ឆោត ដែលមិនប្រកបដោយធម៌ជំនួស ជាបុគ្គលត្រូវការទ្រព្យ ទើបចូលទៅរកព្រះបាទឱក្កាករាជ ហើយបានប្រកបកម្មទាំងឡាយ មានការថ្វាយព្រះពរជាដើម ហើយក្រាបទូលថា បពិត្រមហារាជ អាត្មាទាំង-ឡាយ មានបទមន្តអំពីបុរាណ ដែលបន្តគ្នាមកតាមបវេណី ក្នុងវង្សរបស់ព្រាហ្មណ៍ ពួកអាត្មាមិនបានពោលមន្តនោះដល់បុគ្គលណាម្នាក់ ព្រោះជាអាថ៌កំបាំងរបស់អាចារ្យ មហាបពិត្រ ជាបុគ្គលសមគួរនឹងស្ដាប់មន្តនោះ ដូច្នេះហើយ ទើបពណ៌នាយញ្ញវិធី មានអស្សមេធជាដើម កាលសរសើរហើយកាលនឹងឲ្យព្រះរាជាទ្រង់ឧស្សាហៈ ទើបទូលថា បពិត្រមហារាជ សូមទ្រង់បូជាយញ្ញ កាលបើដូច្នេះ ទ្រង់នឹងជាអ្នកបរិបូណ៌ដោយទ្រព្យ និងស្រូវ ទ្រង់មិនមានការខ្វះខាតក្នុងសម្ភារៈ ជាគ្រឿងបូជាយញ្ញ ព្រោះថា កាលទ្រង់បូជាយ៉ាងនេះ វង្សក្សត្ររបស់ព្រះអង្គ ៧ ជួរត្រកូលនឹងកើតក្នុងស្ថានសួគ៌ ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលសម្ដែងការប្រព្រឹត្តទៅរបស់ព្រាហ្មណ៍ទាំងនោះ ទើបត្រាស់ថា ព្រាហ្មណ៍ទាំងនោះ តែងមន្តព្រោះចង់បានទ្រព្យនោះ

បានចូលទៅរកព្រះបាទឱក្កាកៈក្នុងវេលានោះថា ( សូមព្រះអង្គបូជានូវទ្រព្យដ៏វិចិត្រជាច្រើនរបស់ព្រះអង្គ ) សូមព្រះអង្គបូជានូវធនសម្បត្តិរបស់ព្រះអង្គ នឹងបាននូវទ្រព្យ និងស្រូវជាច្រើន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តត្ថ** បានដល់ ក្នុងទីនោះ មានពាក្យអធិប្បាយថា ព្រាហ្មណ៍ទាំងឡាយសម្ងឹងភោគៈណា បានធ្វើភោគៈនោះឲ្យជាហេតុ ។ បទថា **តត្ថ** នេះ ជាសត្តមីវិភត្តិ ប្រើក្នុងអត្ថថា ហេតុ ។ ពីរបទថា **តទុបាគមុំ** បានដល់ ចូលទៅរកហើយ ក្នុងកាលនោះ ។ បាទគាថាថា **បហូតធនធញ្ញោសិ** អធិប្បាយថា ទ្រង់ជាអ្នកមានទ្រព្យ និងស្រូវសាលីច្រើនក្នុងសម្បរាយភព ព្រោះថា អាចារ្យអ្នកឈ្លាសក្នុងសព្ទទាំងឡាយ ប្រាថ្នាពោលនូវបំណងរបស់ព្រះរាជាក្នុងបច្ចុប្បន្នឲ្យ មានអត្ថក្នុងអនាគតក៏បាន ។

បទថា **យជស្សុ** បានដល់ សូមទ្រង់បូជា ។ ដោយបទថា **វិត្តំ ធនំ** ព្រះមានព្រះភាគត្រាស់ថា ឈ្មោះថា **វិត្តំ** ព្រោះជាហេតុឲ្យត្រេកអរ ឈ្មោះថា **ធនំ** ព្រោះជាហេតុធ្វើឲ្យសម្រេច ។

ម្យ៉ាងទៀត ដែលឈ្មោះថា **វិត្តំ** បានដល់ ឧបករណ៍ មានគ្រឿងប្រដាប់ជាដើម ដែលជាហេតុឲ្យត្រេកអរនោះឯង ដែលមកហើយក្នុងពាក្យទាំងឡាយ មានពាក្យថា **បហូតវិត្តូបករណោ** ( ដ្បិតថា លោកកូដទន្តៈ) ជាអ្នកមានសម្បត្តិច្រើន ។

វត្ថុទាំងឡាយ មានមាស និងប្រាក់ជាដើម ឈ្មោះថា **ធនំ** ។ សួរថា លោកអធិប្បាយដូចម្ដេច ឆ្លើយថា លោកអធិប្បាយថា ព្រាហ្មណ៍ទាំងនោះ

ចងមន្តទាំងឡាយ ហើយបានចូលទៅគាល់ព្រះបាទឱក្កាករាជ ក្នុងកាលនោះ ។

សួរថា ពួកព្រាហ្មណ៍ទាំងនោះទូលដូចម្តេច ឆ្លើយថា ពួកព្រាហ្មណ៍ទាំងនោះទូលថា បពិត្រមហារាជ ទ្រង់មានទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត ប្រាក់ និងមាសច្រើន សូមទ្រង់បូជាយញ្ញ ទ្រង់នឹងជាបុគ្គលមានទ្រព្យ និងស្រូវច្រើនក្នុងអនាគត លំដាប់នោះឯង ព្រះរាជាដ៏ប្រសើរ កាលព្រាហ្មណ៍ទាំងនោះពោលហេតុយ៉ាងនេះហើយ ទ្រង់យល់ព្រម ទើបបូជាយញ្ញឈ្មោះ អស្សមេធ បុរិសមេធ សម្មាបាស វាជបេយ្យ និរគ្គឡ ព្រះរាជាទ្រង់បូជាយញ្ញទាំងនេះហើយ ក៏បានព្រះរាជទានទ្រព្យដល់ព្រាហ្មណ៍ទាំងឡាយ ។

បណ្តាបទទាំងនោះ បទថា **សញ្ញត្តា** បានដល់ ឲ្យទ្រង់ជ្រាបហើយ ។ បទថា **រថេសភោ** បានដល់ ដូចគ្នានឹងគោឧសភ ព្រោះអត្ថថា មិនញាប់ញ័រក្នុងពួកក្សត្រទាំងឡាយដែលមានរថច្រើន ។

ឈ្មោះថា អស្សមេធ ព្រោះជនទាំងឡាយសម្លាប់សេះក្នុងយញ្ញនេះ ។ ពាក្យថា **អស្សមេធ** នេះ ជាឈ្មោះរបស់យញ្ញ ដែលឲ្យនូវទ្រព្យគ្រប់យ៉ាងវៀរលែងតែដី និងមនុស្សជាគ្រឿងទក្ខិណា បោះនូវសសរ ២១ ដើម បូជាដោយយញ្ញបរិវារ ២ ប្រភេទ ។

ជនទាំងឡាយ រមែងសម្លាប់បុរសក្នុងយញ្ញនេះ ហេតុនេះ ទើបយញ្ញនេះ ឈ្មោះថា បុរិសមេធ ។ ពាក្យថា **បុរិសមេធ** នេះ ជាឈ្មោះនៃយញ្ញដែលមានទ្រព្យសម្បត្តិដែលពោលហើយក្នុងអស្សមេធ ព្រមទាំងដី ជាគ្រឿងទក្ខិណាទាន ដែលគប្បីបូជាដោយយញ្ញបរិវារ ៤ ប្រភេទ ។

ជនទាំងឡាយ រមែងចងគ្រឿងបូជាក្នុងយញ្ញនេះ ហេតុនេះ ទើបយញ្ញនេះ ឈ្មោះថា **សម្មាបាស** ។

ពាក្យថា **សម្មាបាស** នេះ ជាឈ្មោះនៃការបូជាដោយសស្រ្តា ដែលបុគ្គលបូជាដោយបោះអន្ទាក់ទៅរាល់ៗ ថ្ងៃ ហើយធ្វើមេទសម្រាប់បូជា ក្នុងឱកាសត្រង់អន្ទាក់នោះធ្លាក់ចុះ ហើយដើរត្រឡប់ តាំងអំពីទីដែលខ្ទមមុជចុះក្នុងស្ទឹងសរស្សតី អំពីសសរជាដើម ដែលផ្លាស់ទីសម្រាប់បោះបង្គោល ហើយបូជាដោយគ្រឿងបូជាទាំងឡាយ ។

ជនទាំងឡាយ រមែងផឹកទឹកដែលឲ្យនូវកម្លាំងក្នុងយញ្ញពិធីនេះ ហេតុនោះ ទើបយញ្ញពិធីនេះ ឈ្មោះថា **វាជបេយ្យ** ។ ពាក្យថា **វាជបេយ្យ** នេះ ជាឈ្មោះនៃការបូជាយញ្ញដែលមានបង្គោលសម្រាប់បូជា ធ្វើដោយដើមព្នៅ មានគ្រឿងបូជាមួយមុខ ១៧ ប្រភេទ ដែលគប្បីបូជាដោយបសុសត្វ ១៧ ប្រភេទ ដោយយញ្ញបរិវារមួយ ។

គន្លឹះទាំងឡាយមិនមាននៅក្នុងយញ្ញនេះ ហេតុនេះ ទើបយញ្ញនេះ ឈ្មោះថា **និរគ្គឡ** ។ ពាក្យថា **និរគ្គឡ** នេះ ជាឈ្មោះហៅអស្សមេធ ដែលមានឈ្មោះដោយអមថា **សព្វមេធ** បែបសម្មតិ មានសម្បត្តិទាំងពួង តាមដែលពោលក្នុងអស្សមេធ មួយអន្លើដោយដី និងបុរសទាំងឡាយ ជាគ្រឿងទក្ខិណា ដែលគប្បីបូជាដោយយញ្ញបរិវារ ២ ប្រភេទទៀត ។ ពាក្យដ៏សេសក្នុងគាថានេះ ជាក់ច្បាស់ហើយនោះឯង ។

ឥឡូវនេះ កាលទ្រង់សម្តែងវត្ថុដែលទ្រង់ត្រាស់ថា **ព្រាហ្មណាធំ អនា**

ធនំ ទើបត្រាស់ ២ គាថាថា **គាវោ សយនញ្ច** ដូច្នេះជាដើម ។ ដ្បិតថា ព្រះរាជាអង្គនោះ ទ្រង់ត្រិះរិះថា ព្រាហ្មណ៍ទាំងឡាយ លំបាកដោយអាហារ ដែលសៅហ្មងអស់កាលយូរ ចូរបានបរិភោគបញ្ចគោរសចុះ ដូច្នេះហើយ ទើបព្រះរាជទានហ្វូងគោ ព្រមទាំងគោដ៏ប្រសើរដល់ព្រាហ្មណ៍ទាំងនោះ ។ ម្យ៉ាងទៀត ទ្រង់ព្រះតម្រិះថា ពួកព្រាហ្មណ៍លំបាកដោយការដេកលើដី ដោយការស្លៀកសំពត់ដែលមានសាច់គ្រោតគ្រាត ដោយការដេកម្នាក់ឯង ដោយការត្រាច់ទៅដោយជើង និងដោយការនៅក្នុងទីទាំងឡាយ មានព្រៃ និងគល់ឈើជាដើម ចូរបានសោយសុខក្នុងទីទាំងឡាយ មានការដេកលើកម្រាលដ៏ប្រសើរ មានសំពត់កោជវៈជាដើម ដូច្នេះហើយ ទើបបានព្រះរាជទានរបស់មានតម្លៃទាំងឡាយ និងទីដេកជាដើម ដល់ព្រាហ្មណ៍ទាំងនោះ ទ្រង់បានព្រះរាជទានរបស់ដទៃ មានប្រការផ្សេងៗ យ៉ាងនេះ និងទ្រព្យ មានប្រាក់ និងមាសជាដើម ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ព្រះរាជាបានព្រះរាជទានទ្រព្យដល់ព្រាហ្មណ៍ទាំងឡាយ ឲ្យគោ ទីដេក សំពត់ នឹងនារីដែលមានគ្រឿងប្រដាប់តាក់តែង រថទឹមដោយសេះអាជានេយ្យដែលធ្វើល្អពាសដោយស្បែកដ៏វិចិត្រ លំនៅជាទីត្រេកអរ ដែលគេចាត់ចែងដោយសព្វគ្រប់ ផ្ទុកទ្រព្យផ្សេងៗ ពេញហើយ ឲ្យទ្រព្យដល់ពួកព្រាហ្មណ៍ ដូច្នេះ ។

លុះព្រាហ្មណ៍ទាំងនោះ បានទ្រព្យក្នុងទីនោះហើយ ក៏សន្សំគរទុក ព្រាហ្មណ៍ទាំងនោះ ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ តណ្ហាក៏ចម្រើនឡើងក្រៃលែង ព្រាហ្មណ៍ទាំងនោះ តែងមន្តក្នុងទីនោះ ហើយចូលទៅគាល់ព្រះបាទ

ឱក្កាកៈទៀត ។

សួរថា លោកអធិប្បាយដូចម្តេច ឆ្លើយថា លោកអធិប្បាយថា ពួកព្រាហ្មណ៍ទាំងនោះ បានទ្រព្យក្នុងកាលបូជានោះៗ អំពីសម្នាក់ព្រះរាជានោះហើយ ក៏ស្វែងរកអាហារ និងសំពត់តែម៉្យាងប៉ុណ្ណោះរាល់ៗ ថ្ងៃ អស់កាលយូរ ទើបបានត្រេកអរក្នុងការសន្សំវត្ថុកាម មានប្រការផ្សេងៗ ។ បន្ទាប់ពីនោះ កាលព្រាហ្មណ៍ទាំងនោះ ដែលឈានចុះកាន់សេចក្តីប្រាថ្នាច្រើន ដែលមានចិត្ត ដែលសេចក្តីលោភៈឈមចុះហើយ ដោយអំណាចនៃការត្រេកអរ ដែលកើតអំពីបញ្ចគោរស មានទឹកដោះស្រស់ជាដើម តណ្ហាក៏ចម្រើនឡើង ព្រោះអាស្រ័យសាច់យ៉ាងនេះថា បញ្ចគោរសទាំងឡាយ មានទឹកដោះស្រស់ជាដើមរបស់គោទាំងឡាយ គង់ឆ្ងាញ់ដល់ម៉្លេះ ហើយសាច់របស់គោទាំងនោះ នឹងឆ្ងាញ់ជាងពិត បន្ទាប់អំពីនោះ ពួកព្រាហ្មណ៍គិតថា បើពួកយើងសម្លាប់គោហើយ បរិភោគ ក៏នឹងជាបុគ្គលត្រូវតិះដៀលបាន កុំដូច្នោះឡើយ ពួកយើងគប្បីចងមន្តទាំងឡាយឡើងល្អជាង ។

លំដាប់នោះ ពួកព្រាហ្មណ៍បានទម្លាយវេទម្តងទៀត គឺចងមន្តទាំងឡាយក្នុងទីនោះ តាមសមគួរដល់រឿងនោះៗ ហើយចងមន្តកោងទាំងឡាយ ដោយទាញយកមន្តដើមនោះឯងជាបែបផែន មានការប្រាថ្នាទ្រព្យ បានចូលទៅគាល់ព្រះបាទឱក្កាករាជទៀត ដើម្បីនឹងទូលអត្ថនេះ ទើបក្រាបទូលថា ទឹក ដី ប្រាក់ ទ្រព្យ និងស្រូវ យ៉ាងណា គោទាំងឡាយ សម្រាប់ប្រកបកិច្ចរបស់មនុស្ស ក៏យ៉ាងនោះដែរ ព្រោះថា វត្ថុមានទឹកជាដើមនោះ ជាបរិក្ខារ

របស់ពួកសត្វមានជីវិត សូមព្រះអង្គបូជានូវទ្រព្យដ៏វិចិត្រជាច្រើនដល់ព្រះអង្គ សូមព្រះអង្គបូជានូវធនសម្បត្តិដ៏ច្រើន របស់ព្រះអង្គ ។

សួរថា លោកអធិប្បាយដូចម្តេច ឆ្លើយថា លោកអធិប្បាយថា ពួកព្រាហ្មណ៍ទាំងឡាយទូលថា បពិត្រមហារាជ មេគោកើតឡើងដើម្បីជាប្រយោជន៍ដល់ការប្រើប្រាស់របស់មនុស្សទាំងឡាយ ដូចគ្នានឹងទឹក ដល់នូវការនាំទៅប្រើដើម្បីសត្វទាំងឡាយ ក្នុងកិច្ចការទាំងពួង មានលាងដៃជាដើម ដូច្នោះ បាបព្រោះការសម្លាប់មេគោទាំងនោះ មិនមាន ព្រោះហេតុអ្វី ព្រោះគោនោះជាគ្រឿងប្រើប្រាស់ គឺកើតឡើងដើម្បីឧបករណ៍របស់សត្វទាំងឡាយ គឺគោទាំងឡាយកើតឡើងដើម្បីជាប្រយោជន៍ ដល់ការនាំទៅប្រើប្រាស់ក្នុងកិច្ចទាំងឡាយរបស់មនុស្សទាំងឡាយ ដូចមហាប្រឹថពីនេះ ដល់នូវការនាំទៅប្រើប្រាស់ក្នុងកិច្ចទាំងពួង មានការដើរ និងការឈរជាដើម ដូចប្រាក់ ពោលគឺកហាបណៈ ទ្រព្យ មានមាស និងប្រាក់ជាដើម និងស្រូវ មានស្រូវដំណើប និងស្រូវស្រងែជាដើម រមែងដល់នូវការប្រើប្រាស់ក្នុងកិច្ចទាំងពួង មានការជួញដូរជាដើម សូមព្រះអង្គបូជានូវទ្រព្យដ៏វិចិត្រជាច្រើនរបស់ព្រះអង្គ សូមព្រះអង្គបូជានូវធនសម្បត្តិដ៏ច្រើនរបស់ព្រះអង្គ ដូច្នេះ ។

ដោយន័យដែលពោលហើយខាងដើមយ៉ាងនេះឯង លំដាប់នោះ ព្រះរាជាដូចជាគោឧសភក្នុងរថ ត្រូវពួកព្រាហ្មណ៍ពន្យល់ហើយ ក៏បានសម្លាប់គោរាប់សែនជាច្រើន ក្នុងការបូជាយញ្ញ មេគោទាំងឡាយណាស្មើដោយពពែ ស្ងប់ស្ងៀម ត្រូវគេរឹតទឹកដោះដាក់ក្នុងឆ្នាំង រមែងមិនបៀតបៀនអ្នកដទៃដោយ

ជើង មិនបៀតបៀនដោយស្នែង មិនបៀតបៀនដោយអវយវៈណាមួយឡើយ ព្រះរាជាដែលមិនធ្លាប់សម្លាប់សត្វណាមួយក្នុងកាលមុន ក៏ចាប់គោទាំងនោះត្រង់ស្នែងទាំងឡាយ ហើយឲ្យសម្លាប់ដោយសស្ត្រា អធិប្បាយថា បានឮថា ក្នុងកាលនោះ ពួកព្រាហ្មណ៍ទាំងឡាយ ធ្វើរណ្តាយញ្ញឲ្យពេញដោយមេគោទាំងឡាយ ហើយក៏ចងគោឧសភដែលជាមង្គល នាំទៅកាន់ទៀបបាទមូលរបស់ព្រះរាជា ហើយក្រាបទូលថា បពិត្រមហារាជ សូមទ្រង់បូជាយញ្ញដោយគោ ផ្លូវនៃព្រហ្មលោករបស់ព្រះអង្គនឹងបរិសុទ្ធ ព្រះរាជាទ្រង់ធ្វើកិច្ចដែលជាមង្គលហើយ ទ្រង់ចាប់ព្រះខ័ន ទ្រង់ត្រាស់ឲ្យសម្លាប់មេគោទាំងឡាយច្រើនសែនជាអនេក មួយអន្លើដោយគោដ៏ប្រសើរ ព្រាហ្មណ៍ទាំងឡាយ ធូតសាច់ទាំងឡាយត្រង់រណ្តាយញ្ញ ហើយបរិភោគ ។ ក្នុងកាលនោះ ពួកព្រាហ្មណ៍បានជណ្តប់សំពត់កម្ពលពណ៌លឿង ស និងក្រហម ឲ្យសម្លាប់គោទាំងឡាយហើយ ។ បានឮថា ព្រោះដូចពោលនោះ គោទាំងឡាយឃើញពួកព្រាហ្មណ៍ជណ្តប់សំពត់ ក៏កើតការតក់ស្លុត ។ ព្រោះដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ន បាទា ។បេ។ ឃាតយិ ។**

បទថា **តតោ ច** ជាដើម សេចក្តីថា កាលព្រះរាជាអង្គនោះទ្រង់ចាប់ផ្តើមឲ្យប្រហារគោទាំងឡាយយ៉ាងនេះ កាលនោះ គឺក្នុងរវាងនោះឯង ទេវតាទាំងឡាយជាន់ចាតុម្មហារាជិកា ព្រហ្មទាំងឡាយ ដែលបានឈ្មោះក្នុងពួកព្រាហ្មណ៍ទាំងឡាយថាជាបិតា សក្កទេវរាជ អសុរ និងអារក្ខទឹកទាំងឡាយ ដែលនៅត្រង់ជើងភ្នំ ដឹងថា ទានវៈ និងយក្ខ បន្ទឺវាចាយ៉ាងនេះថា

មនុស្សមិនមានធម៌ ទើបបាននាំគ្នាពោលថា គួរតិះដៀលពួកមនុស្ស ជាមនុស្ស អធម៌ សំឡេងនោះបានឮតៗ គ្នា តាំងអំពីផែនដី រហូតដល់ព្រហ្មលោក មួយរំពេចប៉ុណ្ណោះ លោកទាំងមូលបានពេញដោយសំឡេងតិះដៀលទូទៅ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះសស្ត្រាធ្លាក់លើមេគោ អធិប្បាយថា ព្រោះសស្ត្រាធ្លាក់លើមេគោ ពួកទេវតាជាដើមនាំគ្នាបន្ទឺសំឡេងតែម្យ៉ាង ក៏មិនមែនការវិនាសដទៃនេះ ក៏បានកើតឡើងហើយ ក្នុងលោក ។ លោកអធិប្បាយថា រោគ គឺសេចក្តីប្រាថ្នា ការគ្មានស៊ី សេចក្តីគ្រាំគ្រាទាំងនោះ មាន ៣ ប្រភេទ ដែលមានហើយក្នុងកាលមុន បានដល់ តណ្ហា គឺសេចក្តីប្រាថ្នានូវវត្ថុណាមួយ ១ ការស្រេកឃ្លាន ១ ការចាស់ដោយជុំវិញ ១ ឯរោគទាំងនោះនៃពួកសត្វបានកើតតៗ ជា ៩៨ ប្រភេទ អធិប្បាយថា ដល់ហើយនូវការកើតរោគ ៩៨ យ៉ាង មានរោគ ភ្នែកជាដើម ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់តិះដៀលការសម្លាប់បសុសត្វ ទើបត្រាស់ថា **ឯសោ អធម្មោ** ដូច្នេះជាដើម ។ អត្ថនៃព្រះគាថាទាំងឡាយនោះថា ធម៌ គឺការសម្លាប់បសុសត្វជាទណ្ឌ ( គឺកម្ម ) ណាមួយ ក្នុងបណ្តាទណ្ឌ ៣ យ៉ាង មានកាយទណ្ឌជាដើម ឈ្មោះថា ជាអធម៌ ព្រោះទៅប្រាសចាកធម៌ បានជាធម៌ដែលឈមចុះហើយ គឺបានជាធម៌ដែលប្រព្រឹត្តទៅហើយ ធម៌នោះឯង ឈ្មោះថា ជាបុរាណធម៌ ព្រោះប្រព្រឹត្តទៅ ចាប់តាំងពីកាលនោះមក មេគោទាំងឡាយឈ្មោះថា ជាសត្វមិនប្រទូស្ត ព្រោះមិនបៀតបៀនដោយអវយវៈណាមួយ មានជើងជាដើម ចាប់តាំងអំពីការឈានចុះ

ណាមួយ រមែងត្រូវសម្លាប់ ជនអ្នកបូជាយញ្ញទាំងឡាយ បានដល់ ជនទាំង-ឡាយដែលជាអ្នកបូជានូវយញ្ញ កាលឲ្យសម្លាប់មេគោពួកណា ក៏រមែងវិនាស គឺរមែងវិនាសចាកធម៌ ព្រោះហេតុនៃការសម្លាប់មេគោទាំងនោះ ។

បទថា **ឯវមេសោ អណុធម្មោ** សេចក្តីថា ធម៌ដែលលាមក គឺធម៌ដ៏ថោកទាប អធិប្បាយថា គឺអធម៌ ... យ៉ាងនេះ ។

ម្យ៉ាងទៀត ហេតុដែលធម៌ គឺការឲ្យទាន ក៏មានតិចតួចក្នុងធម៌នេះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **អណុធម្មោ** សំដៅយកធម៌ គឺទានដែលតិចតួចនោះ ។

បទថា **ចោរាណោ** បានដល់ ជាកាលដែលយូរដកាបនោះ ។

បាទព្រះគាថាថា **ឯវំ ធម្មេ វិយាបន្នេ** បានដល់ កាលព្រាហ្មណធម៌ដែលជារបស់បុរាណវិនាសហើយយ៉ាងនេះ ។ បាលីថា **វិយាវត្តេ** ដូច្នេះក៏មាន អធិប្បាយថា បានដល់ ជាធម៌ដែលផ្លាស់ប្តូរទៅជាដទៃ ។

បាទព្រះគាថាថា **វិភិន្នា សុទ្ទវេស្សិកា** សេចក្តីថា ពួកសូទ្រៈ និងវេស្សៈទាំងឡាយ សាមគ្គីគ្នាក្នុងកាលមុន ពួកជនទាំងនោះក៏បែកគ្នា ។

បាទព្រះគាថាថា **បុថូ វិភិន្នា ខត្តិយា** សេចក្តីថា ពួកក្សត្រជាច្រើនក៏បែកគ្នា ។

បាទព្រះគាថាថា **បតិំ ភរិយា អវមញ្ញថ** សេចក្តីថា ភរិយាដែលស្វាមីឲ្យតាំងនៅក្នុងកម្លាំង គឺឲ្យតាំងនៅក្នុងភាពជាធំ កាលគ្រប់គ្រងផ្ទះ ជាអ្នកចូលដល់ហើយ ដោយកម្លាំងទាំងឡាយ មានកម្លាំងបុត្តជាដើម ក៏មើល

ឆាយ បានដល់ មាក់ឆាយ គឺប្រមាថមើលងាយប្ដី បានដល់ មិនបម្រើដោយគោរព ។

ព្រះគាថាថា **ខត្តិយា ព្រហ្មពន្ធូ ច ... កាមានំ វសមុបាគមុំ** សេចក្ដីថា ពួកក្សត្រ និងពួកព្រាហ្មណ៍ ពួកវេស្សៈ និងសូទ្រៈដទៃណា ជាអ្នកបែកគ្នា យ៉ាងនេះហើយ បុគ្គលឈ្មោះថា គោត្តរក្សាហើយ ព្រោះគោត្តរៀងៗ ខ្លួន រក្សាដោយមិនលាយឡំគ្នាជាមួយវណ្ណៈដទៃ ពួកជនទាំងនោះធ្វើវាទៈថា ជាតិនោះវិនាសហើយ បានធ្វើវាទៈទាំងពួងថា អញជាក្សត្រ អញជាព្រាហ្មណ៍ជាដើមឲ្យវិនាសហើយ ទៅកាន់អំណាចនៃកាមទាំងឡាយ ពោលគឺកាមគុណ ៥ បានដល់ ដល់នូវការចង់បាន អធិប្បាយថា ជនទាំងនោះមិនធ្វើនូវវត្ថុណាមួយ ដែលមិនគួរធ្វើក៏មិនមែន គឺធ្វើវត្ថុដែលមិនគួរធ្វើ ព្រោះកាមជាហេតុ ។

ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់គុណរបស់ពួកព្រាហ្មណ៍អំពីបុរាណ ដោយ ៩ គាថាថា **ឥសយោ បុព្វកា** យ៉ាងនេះហើយ ទ្រង់បានសម្ដែងនូវការប្រព្រឹត្តដែលស្មើដោយព្រហ្ម ដោយគាថាថា **យោ នេសំ បរមោ** ជាដើម ការប្រព្រឹត្តដែលស្មើដោយទេវតា ដោយគាថាថា **តស្ស វត្តមនុសិក្ខន្តា** ជាដើម នូវការប្រព្រឹត្តរៀបរយដោយ ៤ គាថាថា **តណ្ឌុលំ សយនំ** ជាដើម ។ នូវការប្រព្រឹត្តដែលបែកគ្នា ដោយ ១៧ គាថាថា **តេសំ អាសិ វិបល្លាសោ** ជាដើម ទ្រង់សម្ដែងការដែលទេវតាជាដើមចៀសចេញទៅ ព្រោះព្រះរាជានោះធ្វើខុស ហើយឲ្យទេសនាចប់ ។ តែពួកព្រាហ្មណចណ្ឌាល ព្រះ

មានព្រះភាគមិនបានត្រាស់ក្នុងទីនេះឡើយ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមិនមានការធ្វើបដិបត្តិខុសណាមួយ ។ កាលការដល់ព្រមដោយព្រាហ្មណធម៌មាន ( សម្រាប់ព្រាហ្មណ៍ចណ្ឌាល ) តែធម៌របស់ព្រាហ្មណ៍ទាំងឡាយវិនាសហើយ ព្រោះហេតុនោះឯង ទើបទោណព្រាហ្មណ៍ទូលថា បពិត្រព្រះគោតមដ៏ចម្រើន បើតាមទំនងនេះ ខ្ញុំព្រះអង្គមិនពេញជាព្រាហ្មណចណ្ឌាលទេដូច្នេះ ។ ពាក្យដ៏សេសក្នុងគាថានេះ មានន័យដូចខ្ញុំពោលហើយនោះឯង ៕

**អដ្ឋកថា ព្រាហ្មណធម្មិកសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## នាវាសូត្រទី៨

[ ៣២ ] បុរសបានដឹងធម៌ អំពីសម្នាក់អាចារ្យណា គប្បីបូជាអាចារ្យនោះ ដូចជាទេវតាបូជាព្រះឥន្ទ្រ អាចារ្យអ្នកចេះដឹងច្រើន ដែលមានសិស្សបានបូជាហើយនោះ ជាអ្នកមានចិត្តជ្រះថ្លាក្នុងសិស្សនោះ រមែងធ្វើធម៌ឲ្យជាក់ច្បាស់ ។ សិស្សនោះ កាលបើបានធ្វើធម៌នោះ ឲ្យតាំងនៅហើយ បានពិចារណា ជាធីរជនប្រតិបត្តិធម៌សមគួរតាមធម៌ រមែងជាអ្នកដឹង ជាអ្នកធ្វើឲ្យជាក់ច្បាស់ ទាំងជាអ្នកមានបញ្ញាល្អិត បុគ្គលដែលមិនប្រមាទ រមែងសេពគប់អ្នកប្រាជ្ញបែបនោះ ។ សិស្ស កាលបើសេពគប់នឹងអាចារ្យ ជាអ្នកទន់ទាបល្ងង់ខ្លៅ មានប្រយោជន៍មិនទាន់សម្រេច មានតែសេចក្តីប្រណែនគេ រមែងមិនបានធ្វើឲ្យជាក់ច្បាស់ នូវធម៌ក្នុងសាសនានេះ មិនបានឆ្លងផុតសេចក្តីសង្ស័យដល់នូវមរណៈ ។ ជនចុះកាន់ទន្លេមានទឹកច្រើន លម្ហាច ហូរខ្លាំង ជននោះ កាលរសាត់អណ្តែតទៅតាមខ្សែទឹក ធ្វើម្តេចនឹងអាចចម្លងពួកជនឯទៀតបាន យ៉ាងណាមិញ ។ បុគ្គលណា មិនបានធ្វើឲ្យជាក់ច្បាស់នូវធម៌ មិនបានស្តាប់ សេចក្តី ( ក្នុងសម្នាក់ ) នៃពួកពហុស្សូត មិនទាន់យល់ដោយខ្លួនឯង ជាអ្នកមិនទាន់អស់សេចក្តីសង្ស័យ ធ្វើម្តេចនឹងអាចញុំាងជនឯទៀតឲ្យយល់បាន ក៏យ៉ាងនោះដែរ ។ បុគ្គលឡើងជិះទូកដ៏មាំ បរិបូណ៌

ដោយថែវ និងថ្នាល ជាអ្នកដឹងឧបាយក្នុងការទូកនោះ ជាអ្នកឈ្លាសវៃមានគំនិត គប្បីចម្លងពួកជនដទៃជាច្រើន ក្នុងទូកនោះបាន យ៉ាងណាមិញ ចំណែកបុគ្គលណា ជាអ្នកដល់នូវវេទ មានចិត្តបានអប់រំហើយ ជាពហុស្សូតមិនញាប់ញ័រ ( ក្នុងលោកធម៌ ) បុគ្គលនោះឯង ជាអ្នកចេះដឹង ញុំាងពួកជនដទៃដែលជាអ្នកបរិបូណ៌ ដោយការត្រងត្រាប់ និងឧបនិស្ស័យ ឲ្យចេះដឹងបាន ក៏យ៉ាងនោះឯង ។

ព្រោះហេតុនោះ បុគ្គលគួរសេពគប់សប្បុរស ជាអ្នកមានប្រាជ្ញាទាំងជាពហុស្សូត បុគ្គលនោះ កាលដឹងសេចក្តីហើយ ប្រតិបត្តិតាម ជាអ្នកដឹងធម៌ច្បាស់ រមែងបាននូវសេចក្តីសុខ ។

នាវាសូត្រទី ៨ ចប់

# អដ្ឋកថា

## នាវាសូត្រ

[ ៣២ ] ក្នុងនាវាសូត្រទី ៥ មានពាក្យផ្តើមថា **យស្មា ហិ ធម្មំ** ដូច្នេះ ។

ព្រះសូត្រនេះ លោកហៅថា **ធាជសូត្រ** ក៏មាន ។ សួរថា ព្រះសូត្រនេះមានអត្ថុប្បត្តិហេតុដូចម្តេច ឆ្លើយថា ព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់

ប្រារព្ធព្រះសារីបុត្តដ៏មានអាយុ នេះ គឺសេចក្ដីសង្ខេបក្នុងសូត្រនេះ ឯសេចក្ដីពិស្ដារគប្បីជ្រាបចាប់អំពីកាលដែលព្រះអគ្គសាវកទាំង ២ កើតឡើងដូច្នេះថា

បានឮមកថា កាលព្រះមានព្រះភាគមិនទាន់កើតឡើង អគ្គសាវកទាំង ២ បំពេញបារមីមួយអសង្ខេយ្យ និងមួយសែនកប្ប ហើយកើតឡើងក្នុងទេវលោក ។ បណ្ដាអគ្គសាវកទាំង ២ នោះ ព្រះសារីបុត្តឃ្លាតចាកទេវលោកហើយ បដិសន្ធិក្នុងគភ៌របស់ព្រាហ្មណីឈ្មោះរូបសារី នៃព្រាហ្មណ៍ដែលជាមេស្រុក មានទ្រព្យដល់ទៅ ៥៦០ កោដិ ក្នុងស្រុកដែលជាលំនៅរបស់ពួកព្រាហ្មណ៍ ឈ្មោះថា ឧបតិស្សគ្រាម ដែលនៅមិនឆ្ងាយអំពីក្រុងរាជគ្រឹះ ។ ទុតិយសាវក បដិសន្ធិក្នុងផ្ទៃរបស់ព្រាហ្មណីឈ្មោះមោគ្គល្លានី នៃព្រាហ្មណ៍ដែលជាមេស្រុកដែលមានទ្រព្យចំនួន ៥៦០ កោដិដូចគ្នា ក្នុងស្រុកដែលជាទីនៅអាស្រ័យរបស់ពួកព្រាហ្មណ៍ឈ្មោះកោលិតគាម មិនឆ្ងាយអំពីក្រុងរាជគ្រឹះនោះដូចគ្នា ហើយបដិសន្ធិក្នុងថ្ងៃជាមួយគ្នានោះឯង ។

បដិសន្ធិ និងការចេញចាកគភ៌របស់លោកទាំង ២ នោះ មានហើយក្នុងថ្ងៃតែមួយ ញាតិទាំងឡាយបានដាក់ឈ្មោះឲ្យកុមារម្នាក់ ក្នុងបណ្ដាកុមារទាំង ២ នោះថា ឧបតិស្សៈ ព្រោះកើតក្នុងឧបតិស្សគ្រាម ដាក់ឈ្មោះកុមារម្នាក់ទៀតថា កោលិតៈ ព្រោះកើតក្នុងកោលិតគាម ក្នុងថ្ងៃតែមួយដូចគ្នា ។ កុមារទាំង ២ នោះ ជាសម្លាញ់រត់លេងជាមួយគ្នា ដល់នូវការចម្រើនដោយលំដាប់ សម្លាញ់នីមួយៗ មានមាណពជាបរិវារ ៥០០ ។ សម្លាញ់ទាំង ២ នោះ កាលទៅកាន់ឧទ្យានក្ដី ទៅកាន់កំពង់ទឹកក្ដី រមែងទៅជាមួយបរិវារនោះ

ឯង សម្លាញ់ម្នាក់ គឺឧបតិស្សៈទៅដោយវមាស ៥០០ សម្លាញ់ទី ២ គឺកោលិតៈ ទៅដោយរថទឹមដោយសេះអាជានេយ្យ ៥០០ ។

ក្នុងកាលនោះ ក្នុងនគររាជគ្រឹះ មានមហោស្រពលើកំពូលភ្នំ ក្នុងកាលតាមលំដាប់ ។ ក្នុងវេលាល្ងាច ពួកអ្នកដែនអង្គៈ និងអ្នកដែនមគធៈ មានខត្តិយរាជកុមារជាដើម ដែលជាអ្នកមានកេរ្តិ៍ឈ្មោះ បានប្រជុំគ្នាក្នុងទីនោះ គឺត្រង់កណ្តាលព្រះនគរ អង្គុយមើលមហោស្រពផ្សេងៗ នៅលើទីទាំងឡាយដែលក្រាលយ៉ាងល្អ មានគ្រែ និងតាំងជាដើម ។ កាលនោះ សម្លាញ់ទាំង ២ នោះ មួយអន្លើដោយបរិវារ ក៏ទៅក្នុងទីនោះ ហើយអង្គុយលើអាសនៈទាំង-ឡាយដែលក្រាល ។ ខណៈកំពុងមើលមហោស្រព ឧបតិស្សៈបានឃើញមហាជនដែលប្រជុំគ្នា មានការគិតថា ពួកជនមានប្រមាណប៉ុណ្ណោះ ដែលប្រជុំគ្នាអង្គុយមើលមហោស្រពលើគ្រែ និងតាំងជាដើម ដែលក្រាលហើយ មិនទាន់ដល់ ១០០ ឆ្នាំ ក្នុងចន្លោះនេះក៏នឹងស្លាប់ ដូច្នេះ ។ មច្ចុបានមកប្រាកដដល់ឧបតិស្សៈនោះ ដូចទំត្រង់ថ្ងាស ។ ការគិតដូចគ្នានេះ ក៏បានកើតឡើងដល់កោលិតមាណពផងដែរ ។ កាលអ្នករបាំទាំងឡាយ មានចំនួនមិនមែនតិចកំពុងរាំ ចិត្តរបស់សម្លាញ់ទាំង ២ នោះ មិនបានបង្អោនទៅក្នុងហេតុសប្បាយត្រឹមតែមើល ដោយពិត សេចក្តីសង្វេគប៉ុណ្ណោះកើតឡើង ។

លំដាប់នោះ កាលមហោស្រពចប់ហើយ បរិស័ទចៀសចេញទៅហើយ សម្លាញ់ទាំង ២ មួយអន្លើដោយបរិវារកំពុងត្រឡប់ទៅផ្ទះ ទើបកោលិតៈសួរឧបតិស្សៈថា នែសម្លាញ់ ព្រោះហេតុអ្វី ទើបឯងមិនមានសប្បាយត្រឹមតែការ

ត្រេកអរក្នុងការសរសើររបាំជាដើម ឧបតិស្សៈបានប្រាប់សេចក្តីនោះ ហើយបានសួរអត្ថដូចគ្នានោះ ឯកោលិតៈ ក៏ប្រាប់ការប្រព្រឹត្តទៅរបស់ខ្លួនដល់ឧប-តិស្សៈនោះ ហើយពោលបន្តថា មកសម្លាញ់ យើងនឹងបួស ស្វែងរកអមត-ធម៌ចុះ ។ ឧបតិស្សៈទទួលថា សាធុ សម្លាញ់ ។ បន្ទាប់អំពីនោះ ជនទាំង ២ បានលះសម្បត្តិ ហើយធ្វើដំណើរមកដល់ក្រុងរាជគ្រឹះ ដោយលំដាប់ ។

សម័យនោះឯង បរិព្វាជកឈ្មោះសញ្ជ័យ អាស្រ័យក្រុងរាជគ្រឹះ ។ សម្លាញ់ទាំង ២ នោះ មួយអន្លើដោយមាណពបរិវារម្នាក់ ៥០០ បួសក្នុងសម្នាក់របស់សញ្ជ័យបរិព្វាជកនោះ សិក្សាចប់ត្រៃវេទ ក្នុងកាលកន្លងទៅ ២-៣ ថ្ងៃប៉ុណ្ណោះ និងចប់លទ្ធិរបស់បរិព្វាជកទាំងអស់ ។ សម្លាញ់ទាំង ២ នោះកាលចូលទៅពិចារណាដល់ខាងដើម កណ្តាល និងខាងចុង របស់សិល្បសាស្ត្រទាំងឡាយនោះ ក៏មិនឃើញទីបំផុត ក៏សួរអាចារ្យថា ខាងដើម និងកណ្តាលនៃសាស្ត្រទាំងឡាយនេះប្រាកដ តែទីបំផុតមិនប្រាកដ ព្រោះវត្ថុដែលបុគ្គលគប្បីសម្រេចឲ្យក្រៃលែងឡើង ដោយសាស្ត្រទាំងនេះមិនមាន ។ អាចារ្យសញ្ជ័យពោលថា សូម្បីយើង ក៏មិនឃើញទីបំផុតនៃសាស្ត្រទាំងនេះដូចគ្នា ។ សម្លាញ់ទាំង ២ នោះក៏ពោលថា កាលបើដូច្នោះ ពួកយើងនឹងស្វែងរកទីបំផុតនៃសាស្ត្រទាំងនោះ អាចារ្យក៏ពោលថា ពួកអ្នកគប្បីស្វែងរកតាមសប្បាយចុះ ។ សម្លាញ់ទាំង ២ នោះ កាលអាចារ្យសញ្ជ័យនោះអនុញ្ញាតហើយយ៉ាងនេះ ក៏ត្រាច់ស្វែងរកអមតធម៌ ជាអ្នកប្រាកដហើយ ក្នុងជម្ពូទ្វីប ។ ជនទាំងឡាយ មានក្សត្រ និងបណ្ឌិតជាដើម ដែលសម្លាញ់ទាំង

នោះសួរហើយ មិនអាចឆ្លើយបញ្ហាជាន់ខ្ពស់បាន ។ កាលពោលថា ឧប-តិស្សៈ កោលិតៈ ជនណាដែលពោលថា ពួកយើងមិនស្គាល់ជនទាំង ២ នោះ ដូច្នេះ រមែងមិនមាន ទើបសម្លាញ់ទាំង ២ ជាអ្នកប្រាកដ គឺគេស្គាល់ទូទៅយ៉ាងនេះ ។

កាលសម្លាញ់ទាំង ២ នោះ ត្រាច់ស្វែងរកអមតធម៌យ៉ាងនេះ ព្រះមានព្រះភាគនៃយើងទាំងឡាយ ទ្រង់កើតឡើងហើយក្នុងលោក ទ្រង់សម្តែងធម្ម-ចក្កដ៏ប្រសើរ ហើយបានយាងទៅកាន់នគររាជគ្រឹះដោយលំដាប់ ។ បរិព្វាជកទាំង ២ នោះ ត្រាច់ទៅពេញជម្ពូទ្វីប រឿងអមតធម៌មិនចាំបាច់ពោលដល់គាត់មិនបានត្រឹមតែចម្លើយ ដែលទាក់ទងនឹងទីបំផុត ទើបត្រឡប់មកកាន់ក្រុងរាជគ្រឹះវិញ ។ រឿងទាំងអស់ តាំងអំពីពាក្យថា គ្រានោះឯង ព្រះអស្សជិស្លៀកដណ្តប់ហើយ ក្នុងវេលាព្រឹកជាដើម រហូតដល់សម្លាញ់ទាំង ២ នោះបានបួស គប្បីជ្រាបដោយពិស្តារដោយន័យដែលមកហើយក្នុងបព្វជ្ជាខន្ធកៈ ។

កាលសម្លាញ់ទាំង ២ នោះបួសហើយយ៉ាងនេះ ព្រះសារីបុត្តបានធ្វើឲ្យជាក់ច្បាស់នូវសាវកបារមីញាណ ដោយរយៈកាលកន្លះខែ ។ ព្រះសារីបុត្តនោះ កាលនៅក្នុងវិហារជាមួយនឹងព្រះអស្សជិ កាលនោះ លោកទៅកាន់ទីឧបដ្ឋាករបស់ព្រះមានព្រះភាគ បន្ទាប់អំពីនោះ ក៏ទៅកាន់ទីឧបដ្ឋាកព្រះថេរៈដោយការគោរពថា ព្រះថេរៈនេះជាបុព្វាចារ្យនៃអាត្មាអញ អាត្មាអញបានអាស្រ័យលោកម្ចាស់អង្គនេះ ទើបបានដឹងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ តែកាលណា លោកមិនបាននៅក្នុងវិហារជាមួយនឹងព្រះអស្សជិ កាលនោះព្រះ

ថេរៈនៅក្នុងទិសណា លោកក៏បែរមុខទៅកាន់ទិសនោះ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយផ្គងអញ្ជលីនមស្ការ ភិក្ខុទាំងឡាយឃើញការធ្វើនោះហើយ ទើបសន្ទនាគ្នាថា ព្រះសារីបុត្តជាអគ្គសាវក គង់ថ្វាយបង្គំទិស មកទល់នឹងកាលឥឡូវនេះ លោកប្រហែលជាលះទិដ្ឋិរបស់ពួកព្រាហ្មណ៍មិនទាន់បានទេ ។

កាលនោះ ព្រះមានព្រះភាគ ទ្រង់ស្តាប់សំឡេងសន្ទនានោះ ដោយសោតធាតុដែលជាទិព្វ កាលទ្រង់បង្ហាញព្រះកាយ គង់លើបវរពុទ្ធាសនៈដែលគេក្រាលហើយនោះឯង ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ។ ភិក្ខុទាំងនោះបានទូលប្រាប់ការប្រព្រឹត្តទៅនោះ ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្ត មិននមស្ការទិសឡើយ សារីបុត្តបានស្គាល់សាសនាព្រោះអាស្រ័យបុគ្គលណា ក៏នមស្ការបុគ្គលនោះ ដែលជាអាចារ្យរបស់ខ្លួន ម្នាលភិក្ខុទាំងឡាយ សារីបុត្តជាអ្នកបូជាអាចារ្យ ដូច្នេះហើយ ដើម្បីនឹងសម្តែងធម៌ដល់ភិក្ខុទាំងឡាយ ដែលប្រជុំគ្នាក្នុងទីនោះ ទើបត្រាស់ព្រះសូត្រនេះ ។

ក្នុងបណ្តាបទទាំងនោះ បាទព្រះគាថាថា **យស្មា ហិ ធម្មំ បុរិសោ វិជញ្ញា** សេចក្តីថា បុគ្គលស្តាប់ហើយនូវបរិយត្តិធម៌ មានបិដក ៣ ឬស្តាប់ហើយនូវបដិវេធធម៌ មានលោកុត្តរធម៌ ៩ ដែលបុគ្គលស្តាប់បរិយត្តិធម៌ហើយគប្បីសម្រេចអំពីបុគ្គលណា គប្បីដឹងច្បាស់ គឺគប្បីជ្រាប ។ ព្រះបាលីថា

**វិនេយ្យ** ដូច្នេះក៏មាន ឯអត្ថក៏ដូចគ្នា ។

បាទគាថាថា **ឥន្ទំវ ធំ ទេវតា បូជយេយ្យ** សេចក្តីថា ទេវតាទាំងឡាយក្នុងទេវលោកទាំង ២ រមែងបូជានូវសក្កៈ ដែលជាស្តេចទេវតា យ៉ាងណា បុគ្គលនោះក្រោកឡើងអំពីព្រលឹមហើយ កាលធ្វើវត្តបដិបត្តិទាំងពួង មានការដោះស្បែកជើងជាដើម គប្បីបូជា បានដល់ គប្បីធ្វើសក្ការគោរពបុគ្គលនោះ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះអាចារ្យនោះដែលជាពហុស្សូត ដែលអន្តេវាសិកបូជាហើយ មានចិត្តជ្រះថ្លាក្នុងអន្តេវាសិកនោះ រមែងចង្អុលបង្ហាញធម៌ឲ្យជាក់ច្បាស់ ។

បទទាំងឡាយថា **សោ បូជិតោ ។បេ។ ធាតុករោតិ ធម្មំ** សេចក្តីថា អាចារ្យនោះ ឈ្មោះថា ជាពហុស្សូត ដោយអំណាចនៃបរិយត្តិ និងបដិវេធ ដែលសិស្សបូជាហើយយ៉ាងនេះ មានចិត្តជ្រះថ្លាក្នុងអន្តេវាសិកនោះ រមែងធ្វើឲ្យជាក់ច្បាស់ គឺរមែងសម្តែងនូវបរិយត្តិធម៌ ដោយអំណាចនៃទេសនានោះឯង ហើយបដិវេធធម៌ដែលខ្លួនស្តាប់ការសម្តែងហើយ គប្បីសម្រេចបានតាមដែលអាចារ្យនោះទូន្មាន ដោយបដិបត្តិ គឺរមែងធ្វើឲ្យជាក់ច្បាស់នូវបរិយត្តិធម៌ ដោយទេសនា ឬនូវបដិវេធធម៌ដែលខ្លួនបានសម្រេចហើយ ដោយអំណាចនៃឧបមា ។

បាទព្រះគាថាថា **តទដ្ឋិកត្វាន និសម្ម ធីរោ** សេចក្តីថា បុរសឈ្មោះថា ជាអ្នកប្រាជ្ញ ព្រោះអាចស្តាប់ធម៌ហើយ ចាំទុកបាន ដោយធ្វើធម៌ដែលអាចារ្យជ្រះថ្លាហើយយ៉ាងនេះ ធ្វើឲ្យប្រាកដហើយ ឲ្យមានប្រយោជន៍ ។

បាទព្រះគាថាថា **ធម្មានុធម្មំ បដិបជ្ជមានោ** សេចក្ដីថា ចម្រើននូវវិបស្សនាការនាដែលឈ្មោះថា ជាធម៌សមគួរ ព្រោះជាធម៌ដែលអនុលោមដល់លោកុត្តរធម៌ ។

បាទព្រះគាថាថា **វិញ្ញូ វិភាវី និបុណោ ច ហោតិ** សេចក្ដីថា ជាអ្នកដឹងច្បាស់ដោយការត្រាស់ដឹងដោយបញ្ញា ពោល គឺភាពជាអ្នកដឹងច្បាស់ឈ្មោះថា **វិញ្ញូ** ព្រោះដឹងច្បាស់ហើយ ដោយអំណាចធ្វើឲ្យប្រាកដ ឲ្យជនដទៃដឹងបានផង ឈ្មោះថា **និបុណោ** ព្រោះជាអ្នកចាក់ធ្លុះនូវអត្ថ ដែលគម្ពីរភាពក្រៃលែង ។

បាទព្រះគាថាថា **យោ តាទិសំ ភជតិ អប្បមត្តោ** សេចក្ដីថា បុគ្គលណាជាអ្នកមិនប្រមាទ គឺជាអ្នកជ្រះថ្លាក្នុងអាចារ្យនោះជាខាងមុខ សេពគប់អាចារ្យដែលជាពហូសូតបែបនោះ គឺបុគ្គលមានប្រការ ដូចខ្ញុំពោលហើយខាងដើម ។

ព្រះមានព្រះភាគ កាលទ្រង់សរសើរនូវការសេពគប់អាចារ្យដែលជាបណ្ឌិតយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងតិះដៀលការសេពគប់អាចារ្យល្ងង់ខ្លៅ ទើបត្រាស់គាថានេះថា **ខុទ្ទញ្ច ពាលំ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **ខុទ្ទំ** បានដល់ នូវអាចារ្យដែលប្រកបដោយកាយកម្មតិចតួចជាដើម ឈ្មោះថា **ពាលំ** ព្រោះមិនមានបញ្ញា ។

បទថា **អនាគតត្ថំ** បានដល់ ដែលមិនបានសម្រេចប្រយោជន៍ គឺបរិយត្តិ និងបដិវេធ ។

បទថា **ឧសុយ្យកំ** បានដល់ ឈ្មោះថា អត់ធន់មិនបាននូវសេចក្តីចម្រើនរបស់អន្តេវាសិក ព្រោះជាអ្នកប្រណែន ។ ពាក្យដ៏សេសក្នុងគាថានេះ ដោយបទ គឺដោយព្យញ្ជនៈក៏ប្រាកដច្បាស់ហើយទាំងអស់ តែដោយអធិប្បាយ គប្បីជ្រាបអត្ថនៃគាថានោះយ៉ាងនេះថា អាចារ្យណាបានបរិក្ខារទាំងឡាយ មានចីវរជាដើមជាច្រើន ក៏មិនអាចឲ្យចីវរជាដើម ឬមិនឲ្យត្រឹមតែពាក្យថា **អនិច្ចំ ទុក្ខំ អនត្តា** ក្នុងធម្មទានដល់អន្តេវាសិកទាំងឡាយ អន្តេវាសិកសេពគប់នូវអាចារ្យនោះ ប្រកបដោយធម៌តិច ព្រោះជាអ្នកប្រកបដោយធម៌ មានភាពជាធម៌តិចជាដើមនេះ ជាអ្នកល្ងង់ខ្លៅ ជាអ្នកមិនបានសម្រេចប្រយោជន៍ ជាអ្នកប្រណែន សូម្បីខ្លួនឯង ក៏ក្លាយជាល្ងង់ខ្លៅតាម ដោយន័យដែលលោកពោលថា នរជនណាខ្ចប់ត្រីស្អុយដោយចុងស្បូវជាដើម ព្រោះដូច្នោះ បុគ្គលនោះ មិនធ្វើឲ្យជាក់ច្បាស់ និងមិនដឹងបរិយត្តិធម៌ ឬក៏បដិវេធធម៌ណាមួយ មានប្រមាណតិចក្នុងព្រះសាសនានេះ ក៏នៅឆ្លងសេចក្តីសង្ស័យក្នុងធម៌ទាំងឡាយមិនបាន រមែងចូលដល់លំនៅនៃមច្ចុ ។

ឥឡូវនេះ កាលនឹងធ្វើអត្ថនៃព្រះគាថានោះឯងឲ្យប្រាកដ ព្រះមានព្រះភាគក៏ត្រាស់ ២ គាថាថា **យថា នរោ** ដូច្នេះជាដើម ។

ក្នុងពាក្យទាំងឡាយនោះ បទថា **អាបគំ** បានដល់ ស្ទឹង ។ បទថា **មហោទកំ** បានដល់ ទឹកច្រើន ។ បទថា **សលិលំ** បានដល់ ហូរទៅហើយអំពីទីនេះ និងទីនេះ មានពាក្យអធិប្បាយថា ផ្សាយចេញទៅ ។ ព្រះបាលីថា **សរិតំ** ប្រែថា ហូរទៅ ដូច្នេះក៏មាន អត្ថក៏យ៉ាងនោះដូចគ្នា ។

បទថា **សីឃសោតំ** បានដល់ ក្ដួចនូវរបស់ដែលបន្សាត់ទៅបាន មានពាក្យអធិប្បាយថា ហូរទៅដោយកម្លាំងខ្លាំង ។ **សោ** អក្ខរៈ ក្នុងពាក្យថា **កឹ សោ** និង **សោ** អក្ខរៈ ក្នុងបទនេះថា **សោ វុយ្ហមានោ** ជាដើម គ្រាន់តែជានិបាតប៉ុណ្ណោះ ព្រោះជាពាក្យសម្ដែងដល់នរៈនោះ មានអត្ថស្មើគ្នានឹង **កឹសុ** ដូចប្រយោគថា **ន ភវិស្សាមិ នាម សោ វិនស្សិស្សាមិ នាម សោ** ប្រែថា ខ្ញុំនឹងមិនកើតពិត ខ្ញុំនឹងវិនាសពិត ។

បទថា **ធម្មំ** បានដល់ ធម៌ ២ យ៉ាង ដែលពោលហើយខាងដើមនោះឯង ។ បទថា **អនិសាមយត្ថំ** បានដល់ មិនពិចារណានូវអត្ថ ។

ពាក្យដ៏សេសក្នុងគាថានេះ ដោយបទប្រាកដច្បាស់ហើយទាំងអស់ ឯដោយអធិប្បាយ អ្នកសិក្សាគប្បីជ្រាបអត្ថក្នុងគាថានេះ យ៉ាងនេះថា នរជនណាមួយ ចុះកាន់ស្ទឹង មានប្រការដូចពោលហើយ ដែលស្ទឹងនោះក្ដួចទៅតាមក្រសែ គឺទៅតាមក្រសែនោះឯង នឹងអាចធ្វើបុគ្គលដទៃដែលនៅលើច្រាំង គឺអាចនឹងធ្វើបុគ្គលដទៃឲ្យដល់ត្រើយបានដូចម្ដេច យ៉ាងណា ។ ព្រះបាលីថា **សក្កតិ** ដូច្នេះក៏មាន ។

បុគ្គលមិនធ្វើឲ្យជាក់ច្បាស់នូវធម៌ ២ យ៉ាង ដោយបញ្ញារបស់ខ្លួនហើយ និងមិនពិចារណាអត្ថត្រឹមតែពាក្យថា **អនិច្ចំ ទុក្ខំ** និង **អនត្តា** ក្នុងសម្នាក់របស់បុគ្គលដែលជាពហុស្សុតទាំងឡាយ មិនដឹងចំពោះនូវភាពដែលខ្លួនមិនដឹងបានដោយខ្លួនឯង និងឈ្មោះថា **អវិតិណ្ណកង្ខោ** ព្រោះខ្លួនមិនបានពិចារណា តើអាចធ្វើបុគ្គលដទៃឲ្យសម្លឹង គឺឲ្យសម្លឹងពិនិត្យបានដូចម្ដេច ។ ក្នុង

សេចក្តីនេះ អ្នកសិក្សាគប្បីរឭកដល់សុត្តបទ ( មជ្ឈិមនិកាយ សល្លេខ-សូត្រ ) យ៉ាងនេះថា ម្នាលចុន្ទ បុគ្គលណាមុជចុះក្នុងភក់ គឺកាមគុណដោយខ្លួនឯងហើយ ... ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់ពោលឧបមាដើម្បីធ្វើអត្ថនៃការសេពគប់បុគ្គលពាលឲ្យឃើញច្បាស់ ព្រោះបុគ្គលពាលមិនអាចធ្វើអ្នកដទៃ ឲ្យសម្រេចបានយ៉ាងនេះហើយ ឥឡូវនេះ ទើបត្រាស់ ២ គាថាថា **យថាបិ នាវំ** ជាដើម ដើម្បីធ្វើអត្ថឲ្យប្រាកដ ព្រោះបណ្ឌិតដែលព្រះមានព្រះភាគត្រាស់ហើយក្នុងពាក្យនេះថា ជាអ្នកអាចធ្វើអ្នកដទៃឲ្យសម្រេចពិនិត្យ បានដល់ បណ្ឌិតដែលព្រះមានព្រះភាគត្រាស់ហើយ ក្នុងពាក្យនេះថា មិនប្រមាទ សេពគប់បុគ្គលដែលជាពហុស្សូតមានសភាពបែបនោះ ដូច្នេះជាដើម អាចធ្វើអ្នកដទៃឲ្យសម្រេចពិនិត្យបាន ។

បណ្តាបទទាំងនោះ បទថា **ផិយេន** បានដល់ ឈើចែវ ។ បទថា **អរិត្តេន** បានដល់ ច្នៀល ។ បទថា **តត្ថ** បានដល់ ក្នុងទូកនោះ ។ បទថា **តត្រូបយញ្ញូ** បានដល់ ជាអ្នកដឹងឧបាយ ដោយការឲ្យដល់ផ្លូវ ព្រោះដឹងឧបាយ មានការនាំទូកមក និងការអុំទូកទៅជាដើម និងឈ្មោះថា **កុសលោ** ព្រោះភាពជាអ្នកមានសិក្ខាបានសិក្សាហើយ និងព្រោះមានការឈ្លាសជាប្រមាណ ឈ្មោះថា **មុតីមា** ព្រោះអាចកម្ចាត់អន្តរាយដែលកើតឡើងហើយបាន ។ បទថា **វេទគូ** បានដល់ ទៅដោយមគ្គញ្ញាណទាំង ៤ ពោល គឺការដឹង ។ បទថា **ភាវិតត្តោ** បានដល់ មានចិត្តដែលមគ្គភាវនានោះអប់រំ

ហើយ ។ បទថា **ពហុស្សុតោ** បានដល់ ជាពហូសូត ដោយន័យដូចពោល ហើយក្នុងកាលមុន ។ បទថា **អវេធធម្មោ** បានដល់ ជាអ្នកមិនញាប់ញ័រ ក្នុងលោកធម៌ទាំង ៨ ជាសភាវៈ ។

គាថាថា **សោតាវធានូបនិស្សូបបន្នេ** បានដល់ បានកើតឡើងហើយ ដោយការផ្ទៀងសោតប្បសាទស្តាប់ ដោយឧបនិស្ស័យនៃមគ្គ និងផលទាំង-ឡាយ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ សូម្បីយោជនាក្នុងការ អធិប្បាយ ក៏អាចឲ្យដឹងច្បាស់បាន ដោយន័យដែលពោលហើយខាងដើម នោះឯង ព្រោះហេតុនោះ ទើបខ្ញុំមិនចាំបាច់អធិប្បាយឲ្យពិស្តារ ។

ព្រះមានព្រះភាគ កាលត្រាស់ឧបមាដើម្បីធ្វើឲ្យជាក់ច្បាស់ ក្នុងបទ ដែលបណ្ឌិតជាអ្នកអាចធ្វើឲ្យអ្នកដទៃសម្លឹងពិនិត្យយ៉ាងនេះហើយ កាលទ្រង់ ឲ្យតាំងមាំក្នុងការសេពគប់បណ្ឌិតនោះ ទើបត្រាស់គាថាចុងក្រោយថា **តស្មា ហវេ** ដូច្នេះជាដើម ។

អត្ថសង្ខេបក្នុងគាថាចុងក្រោយនេះ មានដូចតទៅនេះ

ព្រោះហេតុដែលជនទាំងឡាយ ដល់ព្រមដោយឧបនិស្ស័យ រមែង សម្រេចនូវគុណវិសេសបានដោយការសេពគប់បណ្ឌិត ដូច្នោះឯង បុគ្គល គប្បីសេពគប់សប្បុរស ។ សួរថា សេពគប់សប្បុរសដូចម្តេច ឆ្លើយថា បុគ្គលគប្បីសេពគប់សប្បុរសដែលមានបញ្ញាផង ជាពហូសូតផង គឺជាអ្នក មានបញ្ញាដោយការដល់ព្រមនៃបញ្ញា និងជាពហូសូត ដោយមានសុត្តៈទាំង ២ ប្រការ តាមដែលពោលហើយ ព្រោះបុគ្គលនោះ កាលសេពគប់បុគ្គលមាន

បញ្ញាបែបនោះ ដឹងហើយនូវធម៌ដែលបុគ្គលនោះពោលហើយ និងដឹងហើយនូវអត្ថយ៉ាងនេះ បដិបត្តិនូវធម៌តាមដែលអាចារ្យអ្នកមានបញ្ញានោះ ប្រៀនប្រដៅហើយ ឈ្មោះថា ជាអ្នកមានធម៌ដឹងច្បាស់ហើយ ដោយអំណាចនៃការចាក់ធ្លុះបានដោយបដិបទានោះ គប្បីបាន គឺគប្បីដល់ បានដល់ គប្បីសម្រេចនូវលោកុត្តរសុខ មានមគ្គផល និងនិព្វានជាដើម ព្រោះដូច្នោះ ទើបព្រះមានព្រះភាគឲ្យទេសនាចប់ដោយកំពូល គឺអរហត្ត ដូច្នេះ ។ល។

**អដ្ឋកថា ធាវាសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## កឹំសីលសូត្រទី៩

[ ៣៣ ] ( ព្រះសារីបុត្តដ៏មានអាយុ ក្រាបទូលសួរថា ) នរជន មានសីលដូចម្តេច មានមារយាទដូចម្តេច ចម្រើននូវអំពើទាំងឡាយដូចម្តេច គប្បីជាបុគ្គលប្រតិស្ឋានមាំល្អ ( ក្នុងសាសនា ) ផង ដល់នូវប្រយោជន៍ខ្ពង់ខ្ពស់ គឺអរហត្តផលផង ។

( ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ) បុគ្គលត្រូវប្រព្រឹត្តកោតក្រែង ចំពោះបុគ្គលដែលចម្រើន ជាអ្នកមិនមានសេចក្តីប្រណែន ស្គាល់កាលគួរជួបនឹងគ្រូ ស្គាល់ខណៈស្តាប់ធម្មីកថាដែលលោកពោល គប្បីស្តាប់សុភាសិតឯទៀតដោយគោរព ។

បុគ្គលគួរធ្វើការរឹងត្អឹង ឲ្យជ្រះស្រឡះ ប្រព្រឹត្តបន្ទាបខ្លួន ហើយចូលទៅកាន់សម្នាក់គ្រូ តាមកាលគួរ គប្បីរឭករឿយៗ ទាំងប្រព្រឹត្តដោយប្រពៃ នូវអត្ថនៃ ( ភាសិត ) ធម៌ សីល និងព្រហ្មចារ្យ ( ដ៏សេស ដែលគ្រូសម្តែងហើយ ) ។

បុគ្គលគួរជាអ្នកមានធម៌ជាទីត្រេកអរ ត្រេកអរក្នុងធម៌ ឋិតនៅក្នុងធម៌ ចេះវិនិច្ឆ័យនូវធម៌ មិនគួរប្រព្រឹត្តនូវពាក្យដែលប្រទូស្តចំពោះធម៌ គប្បីញុំាងកាលឲ្យអស់ទៅ ដោយសុភាសិតទាំងឡាយដែលពិតៗ ។

បុគ្គលគួរលះបង់នូវការសើច រីករាយ ការចរចាឥតប្រយោជន៍

ការខ្សឹកខ្សួល ការប្រទូស្ត ការធ្វើនូវមាយា ការកុហក ការជាប់ចិត្ត ការប្រកាន់ ការប្រណាំងប្រជែង សម្ដីអាក្រក់ ទឹកអម្ចត់ គឺរាគាទិក្កិលេស និងការជ្រប់នៅដោយតណ្ហា គប្បីជាបុគ្គលប្រាសចាកសេចក្ដីស្រវឹង មានចិត្តឋិតនៅមាំ ។

សុភាសិតទាំងឡាយ ( ដែលប្រកបដោយសមថវិបស្សនា ) គឺអ្នកប្រាជ្ញដឹងច្បាស់ថា មានសារៈ ឯញាណសម្រេចអំពីសុតៈ គឺអ្នកប្រាជ្ញដឹងច្បាស់ថា មានសមាធិជាសារៈ បញ្ញា និងសុតៈ រមែងមិនចម្រើនដល់នរជនដែលជាអ្នកមានចិត្តរហ័ស ជាអ្នកធ្វេសប្រហែស ។

មួយទៀត ជនពួកណា ត្រេកអរក្នុងធម៌ ដែលអរិយបុគ្គលសំដែងហើយ ជនពួកនោះ រមែងប្រសើរដោយវចីកម្ម មនោកម្ម និងកាយកម្ម ជនពួកនោះ រមែងឋិតនៅក្នុងសេចក្ដីស្ងប់ស្ងាត់ស្ងប់ស្ងៀម និងសមាធិ ហើយបានដល់នូវខ្លឹមនៃការស្ដាប់ផងនៃប្រាជ្ញាផង ។

**កឹសីលសូត្រទី ៩ ចប់**

# អដ្ឋកថា

## កឹសីលសូត្រ

[ ៣៣ ] ក្នុងកឹសីលសូត្រទី ៩ មានពាក្យផ្ដើមថា **កឹសីលោ** ដូច្នេះ ។

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ព្រះសូត្រនេះ មានហេតុកើតឡើងដូចតទៅនេះ

សម្លាញ់របស់ព្រះសារីបុត្ត កាលនៅជាយាវាសម្នាក់ ជាកូនរបស់ព្រាហ្មណ៍ ដែលជាសម្លាញ់របស់វង្គន្តព្រាហ្មណ៍ ដែលជាបិតារបស់ព្រះថេរៈនោះឯង បរិច្ចាគទ្រព្យ ៥៦០ កោដិ ហើយបួសក្នុងសម្នាក់របស់ព្រះសារីបុត្ត រៀនហើយនូវពុទ្ធវចនៈទាំងអស់ ព្រះថេរៈបានទូន្មានហើយ បានឲ្យកម្មដ្ឋានដល់លោកដ៏ច្រើន ភិក្ខុនោះ ក៏មិនអាចសម្រេចគុណវិសេស ដោយកម្មដ្ឋាននោះបាន បន្ទាប់អំពីនោះ ព្រះថេរៈដឹងថា ភិក្ខុរូបនេះជាពុទ្ធវេនេយ្យ ដូច្នេះហើយ ទើបនាំភិក្ខុនោះមកកាន់សម្នាក់ព្រះមានព្រះភាគ ទូលសួរមិនចំពោះបុគ្គល ប្រារព្ធភិក្ខុនោះថា **កឹសីលោ** ជាដើម ។ លំដាប់នោះ ព្រះមានព្រះភាគ បានត្រាស់ដល់រឿងដទៃអំពីរឿងដែលព្រះសារីបុត្តសួរនោះ ដល់ព្រះសារីបុត្តនោះ ។

ក្នុងគាថានោះ បទថា **កឹសីលោ** បានដល់ ប្រកបដោយចារិតសីលដូចម្ដេច ឬជាអ្នកមានប្រក្រតីដូចម្ដេច ។ បទថា **កឹសមាចារោ** បានដល់ប្រកបដោយការប្រព្រឹត្តដូចម្ដេច ។ បទថា **កានិ កម្មានិ ព្រូហយំ** សេចក្ដីថា ធ្វើនូវកម្មទាំងឡាយ មានកាយកម្មជាដើមដូចម្ដេចឲ្យចម្រើន ។

បាទព្រះគាថាថា **នរោ សម្មា និវិដ្ឋស្ស** សេចក្ដីថា នរៈជាអ្នកត្រេកអរហើយ គឺគប្បីជាអ្នកតាំងនៅហើយដោយប្រពៃក្នុងសាសនា ។

បាទព្រះគាថាថា **ឧត្តមត្ថញ្ច ចាបុណោ** មានពាក្យអធិប្បាយថា គប្បីសម្រេចអរហត្តដែលជាប្រយោជន៍ដ៏ឧត្តមជាងប្រយោជន៍ទាំងពួងផង ។

បន្ទាប់អំពីនោះ ព្រះមានព្រះភាគទ្រង់រំពឹងថា សារីបុត្តបួសហើយបានកន្លះខែ ក៏សម្រេចសាវកបារមីញាណ ព្រោះហេតុអ្វី ទើបសួរបុថុជ្ជនបញ្ហាដែលជាអាទិកម្មិក ទ្រង់ក៏ជ្រាបថា ព្រះសារីបុត្តទូលសួរដើម្បីសទ្ធិវិហារិក ទើបទ្រង់មិនបានចែកចារិតសីល ដែលព្រះសារីបុត្តពោលដោយពាក្យសួរឡើយ ដើម្បីទ្រង់សម្ដែងធម៌ដោយអំណាចសប្បាយដល់ភិក្ខុនោះ ទើបត្រាស់ព្រះគាថាថា **វុឌ្ឍាបចាយី** ដូច្នេះជាដើម ។ វុឌ្ឍបុគ្គលទាំងឡាយ ក្នុងពាក្យថា **វុឌ្ឍាបចាយី** នោះ មាន ៤ ពួក គឺបញ្ញាវុឌ្ឍបុគ្គល ១ គុណវុឌ្ឍបុគ្គល ១ ជាតិវុឌ្ឍបុគ្គល ១ វយវុឌ្ឍបុគ្គល ១ ។

ពិតហើយ ភិក្ខុដែលជាពហូសូតដោយកំណើត ទោះជាក្មេងក្តី ក៏ឈ្មោះថា ជាបញ្ញាវុឌ្ឍបាន ព្រោះជាអ្នកចម្រើនហើយដោយបញ្ញា គឺពាហុសច្ចៈក្នុងសម្នាក់នៃភិក្ខុដល់អ្នកមានការសិក្សាតិចទាំងឡាយ ព្រោះថា សូម្បីភិក្ខុចាស់ទាំងឡាយ រៀននូវពុទ្ធវចនៈ ក្នុងសម្នាក់របស់ភិក្ខុកំលោះនោះ ទន្ទឹងនូវឱវាទការវិនិច្ឆ័យ និងការឆ្លើយបញ្ហាទាំងឡាយ ។ មួយវិញទៀត ភិក្ខុកំលោះ ដែលដល់ព្រមដោយអធិគម ឈ្មោះថា **គុណវុឌ្ឍ** ជាអ្នកចម្រើនដោយគុណ ព្រោះថា ទោះបីភិក្ខុចាស់ទាំងឡាយតាំងនៅក្នុងឱវាទរបស់ភិក្ខុក្មេងនោះហើយ ចម្រើននូវវិបស្សនាហើយ រមែងសម្រេចអរហត្តផលបាន ។

មួយវិញទៀត ព្រះរាជាដែលជាក្សត្រ សូម្បីទ្រង់នៅកំលោះ ជាក្សត្រ បាន

ទទួលមុទ្ធាភិសេកហើយ ឬជាព្រាហ្មណ៍ក្តី ក៏ជាបុគ្គលគួរដល់ការថ្វាយបង្គំនៃជនដ៏សេស ឈ្មោះថា **ជាតិវុឌ្ឍបុគ្គល** គឺបុគ្គលចម្រើនដោយជាតិ ។

ឯបុគ្គលដែលកើតមុន គ្រប់ពួក ឈ្មោះថា **វយវុឌ្ឍ** គឺបុគ្គលចម្រើនដោយវ័យ ។ ក្នុងបណ្តាវុឌ្ឍបុគ្គល ៤ ពួកនោះ វៀរព្រះមានព្រះភាគហើយ បុគ្គលណាដែលស្មើដោយព្រះសារីបុត្ត ខាងបញ្ញាមិនមាន ព្រោះលោកបានសម្រេចសាវកបារមីញាណទាំងពួង មួយអន្លើដោយគុណទាំងឡាយ ក្នុងវេលាកន្លះវ៉ែខ ព្រះសារីបុត្តនោះ ដោយជាតិ ត្រកូល ក៏កើតហើយក្នុងត្រកូលព្រាហ្មណមហាសាល ។ ព្រះសារីបុត្តនោះ ទោះបីស្មើដោយវ័យជាមួយភិក្ខុដែលជាសម្លាញ់នោះ ក៏ឈ្មោះថា ចម្រើនហើយដោយហេតុទាំង ៣ ប្រការនេះ ឯក្នុងព្រះគាថានេះ ព្រះមានព្រះភាគត្រាស់ថា **វុឌ្ឍាបចាយី** ទ្រង់សំដៅយកការដែលព្រះសារីបុត្តនោះ ជាអ្នកចម្រើនហើយ ដោយបញ្ញាវុឌ្ឍិ និងគុណវុឌ្ឍិទាំងឡាយនោះឯង ព្រោះហេតុនោះ ទើបបុគ្គលគួរធ្វើនូវការកោតក្រែងចំពោះវុឌ្ឍបុគ្គលទាំងឡាយនោះ បុគ្គលគប្បីជាអ្នកឈ្មោះថា **អនុសុយ្យកោ** ព្រោះប្រាសចាកនូវឥស្សាក្នុងឥដ្ឋផលទាំងឡាយ មានលាភជាដើមរបស់វុឌ្ឍបុគ្គលទាំងឡាយនោះឯង ព្រោះដូច្នោះ ទើបអត្ថនេះ ជាការអធិប្បាយបទដើម ។

ឯក្នុងពាក្យថា **កាលញ្ញូ ចស្ស** នេះ មានអធិប្បាយថា បុគ្គលកាលរាគៈកើតឡើងហើយ សូម្បីទៅរកគ្រូទាំងឡាយ ដើម្បីបន្ទោបង់នូវរាគៈនោះក្តី កាលទោសៈកើតឡើង កាលមោហៈកើតឡើង ។បេ។ កាលសេចក្តីខ្ជិល

ប្រអូសកើតឡើង ទៅរកគ្រូទាំងឡាយដើម្បីបន្ទោបង់នូវការខ្ជិលប្រអូសនោះក្តី ក៏ឈ្មោះថា **កាលញ្ញូ** ព្រោះបុគ្គលគប្បីស្គាល់កាលដើម្បីចូលទៅរកគ្រូទាំងឡាយយ៉ាងនេះ ។

បទថា **ធម្មឹ កថំ** បានដល់ ប្រកបដោយសមថៈ និងវិបស្សនា ។ បទថា **ឯរយិតំ** គឺដែលពោលហើយ ។ បទថា **ខណញ្ញូ** បានដល់ ដឹងថា បុគ្គលដឹងខណៈនៃពាក្យនោះ ជាបុគ្គលរកបានដោយក្រ ឬថា ខណៈនៃការស្តាប់នូវពាក្យមានសភាពបែបនេះ រកបានដោយក្រ ។

បទថា **សុណេយ្យ សក្កច្ចំ** បានដល់ គប្បីស្តាប់ពាក្យនោះដោយគោរព អធិប្បាយថា បុគ្គលគប្បីស្តាប់ពាក្យនោះតែម្យ៉ាងក៏មិនមែន សូម្បីពាក្យដទៃជាសុភាសិត ដែលបដិសំយុត្តដោយពុទ្ធគុណជាដើម បុគ្គលគប្បីស្តាប់ដោយគោរពដូចគ្នា ។

ក្នុងបាទគាថាថា **កាលញ្ញូចស្ស គរូនំ ទស្សនាយ** នេះ មានវិនិច្ឆ័យដូចតទៅនេះ

ភិក្ខុជ្រាបន័យដែលលោកពោលក្នុងពាក្យនេះ និងជ្រាបការបន្ទោបង់នូវពគៈជាដើមដែលកើតឡើងហើយដល់ខ្លួន កាលទៅកាន់សម្នាក់របស់គ្រូទាំងឡាយ ក៏គប្បីទៅកាន់សម្នាក់របស់គ្រូទាំងឡាយ ដោយកាលសមគួរដោយធ្វើទុកក្នុងចិត្តថា អញនឹងបំពេញកម្មដ្ឋាន នឹងជាអ្នករក្សាធុតង្គ មិនមែនឃើញអាចារ្យឈរហើយ ក្នុងទីណាមួយ ក្នុងបណ្តាទីទាំងឡាយ មានទីថ្វាយបង្គំព្រះចេតិយ លានពោធិព្រឹក្ស តាមផ្លូវបិណ្ឌបាត និងពេលថ្ងៃ ត្រង់

ជាដើមហើយ គប្បីចូលទៅដើម្បីសួរបញ្ហា តែគប្បីកំណត់អាចារ្យ អង្គុយ ហើយលើអាសនៈរបស់ខ្លួន ក្នុងសេនាសនៈរបស់ខ្លួន ដែលមានការក្រវល់ក្រវាយស្ងប់ហើយ ចូលទៅរកដើម្បីសួរវិធីនៃកម្មដ្ឋានជាដើម ។ ភិក្ខុកាលចូលទៅរកយ៉ាងនេះហើយ ធ្វើនូវភាពរឹងត្អឹងឲ្យវិនាស ជាអ្នកប្រព្រឹត្តបន្ទន់បន្ទាប គឺធ្វើមានះដែលធ្វើនូវការរឹងត្អឹងឲ្យវិនាសហើយ មានការប្រព្រឹត្តបន្ទាបខ្លួន ដូចសំពត់ជូតជើង គោស្នែងបាក់ ពស់ដែលគេដកចង្កូមចេញហើយ គប្បីចូលទៅរក លំដាប់នោះ ភិក្ខុនោះក៏គប្បីរឭកដល់អត្ថ ធម៌ ការសង្រួមព្រហ្មចរិយៈ ដែលគ្រូនោះពោលហើយ និងគប្បីប្រព្រឹត្តដោយអើពើដោយល្អ ។

បទថា **អត្ថំ** បានដល់ អត្ថនៃភាសិត ។ បទថា **ធម្មំ** បានដល់ ធម៌ គឺបាលី ។ បទថា **សំយមំ** បានដល់ សីល ។ បទថា **ព្រហ្មចរិយំ** បានដល់ សាសនព្រហ្មចរិយៈដ៏សេស ។

បាទគាថាថា **អនុស្សរេ ចេវ សមាចរេ ច** សេចក្ដីថា គប្បីរឭកដល់ឱកាសដែលអាចារ្យនោះពោលដល់អត្ថ ធម៌ ការសង្រួម និងព្រហ្មចរិយៈ និងមិនពេញចិត្តដោយហេតុត្រឹមតែរឭកដល់តែម្យ៉ាងប៉ុណ្ណោះ តែគប្បីប្រព្រឹត្តអើពើ គឺប្រព្រឹត្តប្រពៃ សមាទានវត្តបដិបត្តិទាំងអស់នោះ ឲ្យប្រព្រឹត្តទៅ អធិប្បាយថា គប្បីធ្វើការខ្វល់ខ្វាយក្នុងការធ្វើកថាទាំងនោះ ប្រព្រឹត្តទៅក្នុងខ្លួន ព្រោះថា បុគ្គលកាលធ្វើយ៉ាងនេះ ឈ្មោះថា ធ្វើវត្តដែលគួរធ្វើ ខាងមុខអំពីនោះទៅ បុគ្គលនោះ ឈ្មោះថា មានធម៌ជាទីមកត្រេកអរ ត្រេកអរហើយ

ក្នុងធម៌ តាំងនៅហើយក្នុងធម៌ គប្បីជាអ្នកស្គាល់វិនិច្ឆ័យធម៌ ។

ពាក្យថា **ធម្មេ** ក្នុងបទទាំងពួង ក្នុងគាថានេះ បានដល់ សមថៈ និង វិបស្សនា ។ ពាក្យថា **អារាមោ** និងពាក្យថា **រតិ** មានអត្ថដូចគ្នាតែមួយ សេចក្តីត្រេកអរក្នុងធម៌របស់បុគ្គលនោះមាន ហេតុនោះ បុគ្គលនោះឈ្មោះថា **ធម្មារាមោ** ជាអ្នកមានធម៌ជាទីមកត្រេកអរ ។

បុគ្គលត្រេកអរហើយក្នុងធម៌ ឈ្មោះថា **ធម្មរតោ** មិនត្រេកអរក្នុងវត្ថុដទៃឡើយ ។

បុគ្គលឈ្មោះថា **ធម្មេ ឋិតោ** ព្រោះបដិបត្តិធម៌ បុគ្គលតែងដឹងនូវការវិនិច្ឆ័យធម៌ថា នេះជាឧទយញ្ញាណ នេះជាវយញ្ញាណ ព្រោះហេតុនោះ ទើបបុគ្គលនេះ ឈ្មោះថា **ធម្មវិនិច្ឆយញ្ញូ** គឺអ្នកដឹងនូវការវិនិច្ឆ័យធម៌ ។ បុគ្គលគប្បីជាបុគ្គលបែបនេះ កាលជាបុគ្គលបែបនេះបានហើយ តិរច្ឆានកថា មានការពោលដល់ព្រះរាជាជាដើមនេះមាន ពាក្យដែលជាតិរច្ឆានកថានោះ រមែងប្រទូស្តចំពោះធម៌ គឺសមថៈ និងវិបស្សនា ព្រោះឲ្យកើតនូវការត្រេកអរក្នុងរូបជាដើមខាងក្រៅ ដល់តរុណវិបស្សកបុគ្គល ព្រោះហេតុនោះ ទើបតិរច្ឆានកថានោះ លោកហៅថា វាទៈដែលជាអន្តរាយចំពោះធម៌ បុគ្គលមិនគប្បីប្រព្រឹត្តវាទៈ ដែលធ្វើអន្តរាយចំពោះធម៌នោះឡើយ ដោយពិត កាលនឹងសេពនូវសប្បាយទាំងឡាយ មានអាវាសសប្បាយ និងគោចរសប្បាយជាដើម គប្បីទូន្មានដោយពាក្យដែលជាសុភាសិត ដែលពិត ។ វាចាទាំងឡាយដែលបដិសំយុត្តដោយសមថៈ និងវិបស្សនា ឈ្មោះថា **សុភាសិតេហិ** ក្នុងគាថា

នេះ ។ បុគ្គលគប្បីទូន្មាន គឺគប្បីដឹកនាំ បានដល់ គប្បីញ៉ាំងកាលវេលាឲ្យអស់ទៅ ដោយពាក្យដែលជាសុភាសិតទាំងឡាយបែបនោះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ធ្វើឧបក្កិលេសឲ្យប្រាកដដល់ភិក្ខុដែលចម្រើនសមថៈ និងវិបស្សនាដែលទ្រង់ត្រាស់ដោយសង្ខេបក្រៃលែង ក្នុងពាក្យនេះថា ពាក្យដែលប្រទូស្តចំពោះធម៌ ដូច្នេះ ទើបត្រាស់គាថានេះថា **ហាស្សំ ច ជប្បំ** មួយអន្លើដោយឧបក្កិលេសដទៃអំពីនោះ ។

ព្រះបាលីថា **ហាសំ** ដូច្នេះក៏មាន ។

ភិក្ខុអ្នកចម្រើនវិបស្សនា គប្បីធ្វើត្រឹមតែការញញឹមប៉ុណ្ណោះ ក្នុងរឿងដែលគួរសើច មិនគប្បីពោលពាក្យខ្សឹបដែលឥតប្រយោជន៍ មិនគប្បីធ្វើការរំខានក្នុងការវិនាសនៃញាតិជាដើម មិនគប្បីធ្វើនូវការក្រេវក្រោធឲ្យកើតឡើងក្នុងការពាល់ត្រូវដង្គត់ និងបន្លាជាដើម ។

បុគ្គលគួរលះនូវទោសទាំងនេះ គឺមាយាដែលព្រះមានព្រះភាគត្រាស់ក្នុងពាក្យថា ការធ្វើនូវមាយា ១ ការបោកបញ្ឆោតបីយ៉ាង ១ ការពេញចិត្តក្នុងបច្ច័យទាំងឡាយ ១ ការប្រកាន់ខ្លួនដោយជាតិកំណើត ១ ការប្រណាំងវាសនា ពោល គឺការត្រេកអរដែលជាសត្រូវ ១ ការគ្រោតគ្រាតដែលមានការពោលគ្រោតគ្រាតជាលក្ខណៈ ១ ធម៌ដែលដូចជាទឹកម្ចត់ទាំងឡាយ មានរាគៈជាដើម ១ ការវង្វេង ដែលមានការចង់បានលើសប្រមាណជាលក្ខណៈ ១ ការធ្វើឲ្យឃើញថា ទោសទាំងនេះ ( ដែលបុគ្គលគប្បីលះ ) ដូចបុគ្គលត្រូវការសេចក្ដីសុខ លះនូវរណ្ដៅរងើកភ្លើង ដូចបុគ្គលស្រឡាញ់របស់

ស្អាត ចៀសវាងទីដែលមានលាមក ដូច្នោះ និងដូចបុគ្គលរក្សាជីវិត ចៀសវាងនូវសត្វកាចទាំងឡាយ មានពស់ជាដើម ដូច្នោះ ។ កាលលះហើយ ជាអ្នកបន្ទោបង់នូវសេចក្ដីស្រវឹងបានហើយ ព្រោះកម្ចាត់នូវការស្រវឹង ក្នុងការមិនមានរោគជាដើម ឈ្មោះថា **ឋិតត្តោ** ព្រោះមិនមានការរាយមាយនៃចិត្ត ។ បុគ្គលដែលប្រព្រឹត្តយ៉ាងនេះ រមែងសម្រេចអរហត្ត ដោយភាវនាដែលបរិសុទ្ធចាកឧបក្កិលេសទាំងពួង ក្នុងកាលមិនយូរឡើយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ហាស្សំ ច ជប្បំ ។បេ។ ឋិតត្តោ** ដូច្នេះ ។

ឥឡូវនេះ កិច្ចប្រកបដោយឧបក្កិលេស ដែលព្រះមានព្រះភាគត្រាស់ដោយន័យថា **ហាស្សំ ច ជប្បំ** ជាដើម ឱវាទដែលព្រះមានព្រះភាគត្រាស់ដោយន័យថា ព្រោះជាអ្នករួសរាន់ ជាអ្នកមិនពិចារណាមុន ហើយធ្វើ និងត្រេកត្រអាលហើយ ដោយអំណាចនៃរាគៈប្រទូស្តហើយដោយអំណាចនៃទោសៈ និងជាអ្នកប្រមាទ មិនធ្វើឲ្យជាប់តក្នុងការចម្រើនកុសលធម៌ទាំងឡាយ និងបុគ្គលគប្បីស្តាប់សុភាសិតទាំងឡាយ របស់បុគ្គលមានសភាពបែបនោះដោយគោរពជាដើម ចាត់ថា ជាឱវាទដែលឥតប្រយោជន៍ ព្រោះដូច្នោះ ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងថា សង្កិលេសនេះ ជាបដិបក្ខចំពោះការចម្រើន មានសុតៈជាដើម ដោយទេសនាដែលជាបុគ្គលាធិដ្ឋាន ទើបត្រាស់ព្រះគាថានេះថា **វិញ្ញាតសារានិ** ដូច្នេះជាដើម ។

អត្ថនៃគាថានោះថា សារៈគប្បីមាន ព្រោះដឹងច្បាស់នូវសុភាសិតទាំង-ឡាយ ដែលបដិសំយុត្តដោយសមថៈ និងវិបស្សនា បើសុភាសិតទាំងនោះ

ដែលភិក្ខុដឹងច្បាស់បាន ជាការល្អ កាលបើដូច្នោះ ពាក្យថា សំឡេងប៉ុណ្ណោះ ដែលបុគ្គលនោះកាន់យកហើយ បុគ្គលនោះនឹងធ្វើអ្វីមិនបាន ជនទាំងឡាយ រមែងដឹងនូវសុភាសិតទាំងនេះ ដោយញាណដែលសម្រេចដោយសុតៈណា ញាណដែលសម្រេចដោយសុតៈនោះ ឈ្មោះថា **សុតញ្ញាណ** ដែលសម្រេច ដោយសុតៈនេះឯង ឈ្មោះថា ដឹងច្បាស់ថា មានសមាធិជាសារៈ ។

បណ្តាធម៌ទាំងឡាយ ដែលបុគ្គលដឹងច្បាស់ហើយនោះ សមាធិណា គឺការមិនរាយមាយនៃចិត្ត ក៏ជាបដិបត្តិដើម្បីភាពយ៉ាងនោះ នេះគឺសារៈរបស់ សមាធិនោះ ដោយហេតុត្រឹមតែដឹងតែម្យ៉ាងប៉ុណ្ណោះ មិនសម្រេចប្រយោជន៍ ឡើយ តែនរៈនេះ ឈ្មោះថា ជាអ្នករួសរាន់ ព្រោះប្រព្រឹត្តទៅដោយអំណាច រាគៈជាដើម និងឈ្មោះថា ប្រមាទ ព្រោះមានប្រក្រតីធ្វើមិនជាប់ត ក្នុងការ អប់រំកុសលធម៌ទាំងឡាយជាដើម បុគ្គលនោះ ជាអ្នកកាន់យកត្រឹមតែសំឡេង ប៉ុណ្ណោះ ព្រោះហេតុនោះ បញ្ញា គឺការដឹងច្បាស់នូវសុភាសិតនោះ មិនចម្រើន ដល់បុគ្គលនោះឡើយ ព្រោះបុគ្គលនោះ មិនដឹងច្បាស់នូវអត្ថ ទាំងសុតៈ ក៏ មិនចម្រើនដល់បុគ្គលនោះ ព្រោះមិនមានបដិបទាដើម្បីសម្រេចនូវភាពយ៉ាង នោះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងនូវការវិនាសនៃបញ្ញា និងការវិនាស នៃសុតៈរបស់សត្វទាំងឡាយ ដែលប្រមាទយ៉ាងនេះហើយ ឥឡូវនេះ កាល នឹងសម្តែងការសម្រេចសារៈទាំង ២ ប្រការនោះ នៃបុគ្គលដែលមិនប្រមាទ ហើយទាំងឡាយ ទើបត្រាស់ថា **ធម្មេ ច យេ ។បេ។ សារមជ្ឈគូ** ដូច្នេះ ។

ក្នុងបណ្តាពាក្យទាំងនោះ ធម៌ គឺសមថៈ និងវិបស្សនា ឈ្មោះថា ធម៌ ដែលព្រះអរិយៈប្រកាសហើយ ។ ពិតហើយ ព្រះពុទ្ធត្រឹមតែមួយអង្គ ទ្រង់មិនសម្តែងធម៌ គឺសមថៈ និងវិបស្សនា ហើយបរិនិព្វានមិនមាន ព្រោះហេតុនោះ នរជនណាត្រេកអរហើយ ត្រេកអរក្រៃលែងហើយ មិនប្រមាទ មានសេចក្តីព្យាយាមជាប់តក្នុងធម៌នេះឯង ដែលព្រះអរិយៈប្រកាសហើយ នរជនទាំងនោះ ជាបុគ្គលប្រសើរជាងសត្វទាំងឡាយដ៏សេសដោយវាចា ដោយចិត្ត និងដោយកាយ គឺជាបុគ្គលប្រសើរ បានដល់ មិនមានបុគ្គលស្មើ ជាបុគ្គលឧត្តម ជាបុគ្គលក្រៃលែង ជាងសត្វដ៏សេសទាំងឡាយ ដោយវាចា ដោយចិត្ត និងដោយកាយ ព្រោះជាអ្នកប្រកបដោយវចីសុចរិត ៤ មនោ-សុចរិត ៣ កាយសុចរិត ៣ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ព្រះមានព្រះភាគទ្រង់សម្តែងសីល ដែលសម្បយុត្តដោយអរិយមគ្គ ដែលមានសីលជាខាងដើម នរជនទាំងនោះ ជាអ្នកមានសីលបរិសុទ្ធហើយយ៉ាងនេះ តាំងនៅហើយក្នុងសន្តិ សោរច្ចៈ សមាធិ ទើបឈ្មោះថា ជាអ្នកសម្រេចសារធម៌នៃសុតៈ និងបញ្ញា នរជនពួកណាត្រេកអរហើយក្នុងធម៌ ដែលព្រះអរិយៈប្រកាសហើយ នរជនទាំងនោះ នឹងជាបុគ្គលប្រសើរជាងសត្វដ៏សេសទាំង-ឡាយ ដោយវាចាជាដើមតែម្យ៉ាងក៏មិនមែន តែដោយពិត បណ្ឌិតគប្បីជ្រាបថា ជាអ្នកតាំងនៅហើយក្នុងសន្តិ និងសោរច្ចៈ និងក្នុងសមាធិ គឺជាអ្នកសម្រេចនូវសារធម៌ បានដល់ ជាអ្នកចូលដល់ហើយ នូវសារធម៌នៃសុតៈ និងបញ្ញា ។ នុ៎ះជាពាក្យដែលត្រឹមត្រូវតាមបំណង ។

បណ្ដាបទទាំងនោះ បទថា **សន្តិ** បានដល់ និព្វាន ។

បទថា **សោរច្ចំ** សំដៅដល់ បញ្ញាដែលចាក់ធ្លុះសភាវធម៌តាមសេចក្ដីពិត ព្រោះភាពជាអ្នកត្រេកអរក្នុងធម៌ដែលស្អាត ។ ភាពដែលល្អដោយសន្តិ មាន ព្រោះហេតុនោះ ទើបឈ្មោះថា **សន្តិសោរច្ច** ពាក្យថា **សន្តិសោរច្ច** នេះ ជាឈ្មោះនៃមគ្គប្បញ្ញាដែលមាននិព្វានជាអារម្មណ៍ ។

បទថា **សមាធិ** បានដល់ មគ្គសមាធិដែលសម្បយុត្តដោយនិព្វាននោះ ។ បទថា **សណ្ឋិតា** បានដល់ តាំងនៅហើយដោយធម៌ទាំង ២ យ៉ាងនោះ ។ វិមុត្តិ គឺអរហត្តផល ឈ្មោះថា សារៈនៃសុតៈ និងបញ្ញា ព្រោះថា ព្រហ្មចរិយៈនេះ មានវិមុត្តិជាសារៈ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងបដិបទាដែលជាចំណែកខាងដើមដោយធម៌ និងសម្ដែងបដិបទាដែលជាចំណែកដទៃដោយខន្ធទាំង ៣ នេះ គឺ សីលក្ខន្ធជាដើមថា **អនុត្តរា វចសា** នូវបញ្ញាខន្ធ និងសមាធិក្ខន្ធ ដោយបញ្ញាដែលល្អប្រពៃ ដោយសន្តិ និងដោយសមាធិ ក្នុងគាថាចុងក្រោយនេះយ៉ាងនេះហើយ កាលទ្រង់សម្ដែងវិមុត្តិដែលមិនកម្រើកដោយសុតៈ និងបញ្ញា ដែលជាសារៈ ទើបទ្រង់ឲ្យទេសនាចប់ដោយកំពូល គឺអរហត្ត ។

ក្នុងទីបំផុតនៃទេសនា កិក្ខុរូបនោះក៏បានសម្រេចសោតាបត្តិផល បន្ទាប់មកមិនយូរប៉ុន្មាន ក៏បានតាំងនៅក្នុងអរហត្ត ដែលជាអគ្គផល ដូច្នេះ ។

**អដ្ឋកថា កឹសីលសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ឧដ្ឋានសូត្រទី ១០

[ ៣៤ ] ( ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងពួកភិក្ខុយ៉ាងនេះថា ) អ្នកទាំងឡាយចូរក្រោក ( ចូរអង្គុយចម្រើនកម្មដ្ឋាន ) ប្រយោជន៍អ្វីដោយការដេកលក់របស់អ្នកទាំងឡាយ ព្រោះថា អ្នកទាំងឡាយឈឺជានិច្ច ត្រូវសរ គឺរាគាទិក្កិលេសចាក់ដោត ហើយ កំពុងតែលំបាក ម្ដេចក៏នៅដេកលក់ ។

អ្នកទាំងឡាយ ចូរក្រោកអង្គុយ ចូរសិក្សាឲ្យមាំមួន ដើម្បីសេចក្ដីស្ងប់ កុំឲ្យមច្ចុរាជបានដឹងនូវអ្នកទាំងឡាយ ថាជាអ្នកប្រមាទហើយ ធ្វើឲ្យវង្វេង លុះក្នុងអំណាចនៃខ្លួនឡើយ ។

ពួកទេវតានិងមនុស្ស ត្រូវការនឹងអារម្មណ៍ជាដើម អាស្រ័យជាប់នៅ ( ក្នុងអារម្មណ៍នោះ ) ព្រោះតណ្ហាណា អ្នកទាំងឡាយ ចូរឆ្លងនូវតណ្ហាជាគ្រឿងផ្សាយទុំ៎ះ កុំឲ្យខណៈកន្លងផុតនូវអ្នកទាំងឡាយឡើយ ព្រោះថា ពួកជនដែលខណៈកន្លងហើយ រមែងសោកណែនណាន់ក្នុងនរក ។

សេចក្ដីប្រមាទជាធូលី ធូលីធ្លាក់ចុះតាមសេចក្ដីប្រមាទ ព្រោះតែសេចក្ដីប្រមាទ កុលបុត្រដកចោលនូវសរ គឺរាគាទិក្កិលេសរបស់ខ្លួនបានដោយវិជ្ជា គឺអាសវក្ខយញ្ញាណ ព្រោះតែសេចក្ដីមិនប្រមាទ ។

ឧដ្ឋានសូត្រទី ១០ ចប់

# អដ្ឋកថា

## ឧដ្ឋានសូត្រ

[ ៣៤ ] ក្នុងឧដ្ឋានសូត្រទី ១០ មានពាក្យផ្ដើមថា **ឧដ្ឋហាថ** ដូច្នេះ ។

សួរថា សូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅនេះ

សម័យមួយ ព្រះមានព្រះភាគ កាលគង់នៅក្នុងនគរសាវត្ថី ទ្រង់នៅក្នុងមហាវិហារជេតពនក្នុងវេលាយប់ ក្នុងវេលាព្រឹកមានភិក្ខុសង្ឃចោមរោមយាងចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ហើយយាងចេញអំពីព្រះនគរ តាមទ្វារទិសខាងកើត បានយាងទៅកាន់ប្រាសាទរបស់មិគារមាតា ដើម្បីគង់ក្នុងពេលថ្ងៃ ។

បានឮថា ការគង់នៅត្រង់វត្តជេតពនវិហារ ក្នុងពេលយប់ ហើយយាងចូលទៅសម្រាកពេលថ្ងៃ ក្នុងប្រាសាទរបស់មិគារមាតា និងការយាងគង់ក្នុងប្រាសាទរបស់មិគារមាតាក្នុងពេលយប់ ហើយយាងចូលទៅសម្រាកក្នុងពេលថ្ងៃក្នុងវត្តជេតពន ព្រះមានព្រះភាគទ្រង់បដិបត្តិជាប្រចាំយ៉ាងនេះ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ដើម្បីអនុគ្រោះត្រកូលទាំង ២ នោះមួយប្រការទៀត ដើម្បីជាប្រយោជន៍សម្ដែងដល់គុណនៃមហាបរិច្ចាគ ។ ប្រាសាទនៃមិគារមាតាជាន់ខាងក្រោម មានផ្ទះកំពូល ៥០០ ដែលជាទីនៅអាស្រ័យរបស់ភិក្ខុប្រមាណ ៥០០ រូប ។ កាលណាព្រះមានព្រះភាគគង់នៅខាងក្រោមប្រាសាទ ក្នុងកាលនោះ ភិក្ខុទាំងឡាយ ក៏មិនឡើងទៅកាន់ប្រាសាទជាន់ខាងលើ ដោយគោរពចំពោះព្រះមានព្រះភាគ ។ ក្នុងថ្ងៃនោះ

ព្រះមានព្រះភាគយាងចូលទៅកាន់ផ្ទះកំពូល ក្នុងប្រាសាទជាន់លើ ព្រោះហេតុនោះ ទើបភិក្ខុ ៥០០ ចូលទៅកាន់បន្ទប់ទាំង ៥០០ ក្នុងប្រាសាទជាន់ក្រោម ភិក្ខុទាំងអស់នោះ ជាអ្នកបួសថ្មី បានមកកាន់ធម្មវិន័យនេះក្នុងកាលមិនយូរ មានចិត្តរាយមាយ ដូចដើមបបុស មានឥន្ទ្រិយមិនចាស់ក្លា ភិក្ខុទាំងនោះចូលទៅកាន់បន្ទប់នោះហើយ ក៏សិងលក់ក្នុងពេលថ្ងៃ ក្រោកឡើងក្នុងពេលល្ងាច ប្រជុំគ្នាត្រង់ទីលានធំ និយាយគ្នាថា ថ្ងៃនេះ លោកម្ចាស់អង្គណាបានអ្វីក្នុងរោងកត្ត លោកម្ចាស់បានទៅទីណា ភិក្ខុទាំងនោះ នាំគ្នាពោលអាមិសកថា មានប្រការផ្សេងៗ ធ្វើសំឡេងខ្លាំងថា អើអាវុសោ ខ្ញុំបានទៅកាន់ប្រាសាទរបស់ស្តេចកោសល ខ្ញុំបានទៅកាន់ផ្ទះរបស់អនាថបិណ្ឌិក ក្នុងរាជវាំងរបស់ស្តេចកោសល និងក្នុងផ្ទះរបស់អនាថបិណ្ឌិកនោះ មានវិធីរៀបចំភោជនបែបនេះ និងបែបនេះ ។

ព្រះមានព្រះភាគ ទ្រង់ស្តាប់សំឡេងនោះ ទ្រង់ព្រះតម្រិះថា ភិក្ខុទាំងនេះ ទាំងដែលនៅជាមួយតថាគត ក៏គង់ប្រមាទយ៉ាងនេះ គួរករុណាហ្ន៎ ភិក្ខុទាំងនេះបានធ្វើនូវវត្ថុដែលមិនគួរធ្វើ ដូច្នេះហើយ ទើបទ្រង់ត្រិះរិះដល់ការដែលនឹងឲ្យព្រះមហាមោគ្គល្លានត្រូវមក ។ ក្នុងខណៈនោះឯង ព្រះមហាមោគ្គល្លាន ដឹងវារៈចិត្តព្រះមានព្រះភាគ ទើបមកដោយឫទ្ធិ បានថ្វាយបង្គំព្រះយុគលបាទនោះឯង ។

គ្រានោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលមហាមោគ្គល្លាន សព្រហ្មចារីរបស់អ្នកទាំងនេះ ជាអ្នកស្រវឹង និងប្រមាទ ណ្ហើយចុះ ចូរអ្នកធ្វើភិក្ខុ

ទាំងនោះឲ្យសង្វេគ ។ ព្រះមហាមោគ្គល្លានទោះទទួលស្នងព្រះមានព្រះភាគថា ករុណាព្រះអង្គ ហើយទើបចូលអាបោកសិណ រំពេចនោះឯង ប្រើមេជើង ធ្វើមហាប្រាសាទ ដែលតាំងនៅក្នុងកាមភូមិឲ្យញាប់ញ័រ មួយអន្ទើដោយចំណែកនៃផែនដីដែលប្រាសាទតាំងនៅ ដូចមហាព្យុះធ្វើនាវាឲ្យឃ្លេងឃ្លោង ដូច្នោះ ។

លំដាប់នោះ ភិក្ខុទាំងនោះភ័យខ្លាច ហើយស្រែកដោយសំឡេងខ្លាំង បោលស្បង់ចីវររៀងៗខ្លួន នាំគ្នារត់ចេញតាមទ្វារទាំង ៤ ។ ព្រះមានព្រះភាគទ្រង់បង្ហាញព្រះកាយដល់ភិក្ខុទាំងនោះ ហាក់បីដូចជាយាងចូលទៅកាន់ព្រះ-គន្ធកុដិតាមទ្វារដទៃ ។ ភិក្ខុទាំងនោះឃើញព្រះមានព្រះភាគហើយ ក៏បានឈរថ្វាយបង្គំ ។ ព្រះមានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកខ្លាចអ្វី ភិក្ខុទាំងនោះទូលថា បពិត្រព្រះអង្គដ៏ចម្រើន ប្រាសាទរបស់មិគារមាតានេះ អ្នកណាធ្វើឲ្យរង្គើ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកដឹងទេថា អ្នកណាធ្វើឲ្យរង្គើ ភិក្ខុទាំងឡាយទូលថា ខ្ញុំព្រះអង្គទាំងឡាយ មិនដឹងទេ ព្រះអង្គ ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ប្រាសាទនេះ មោគ្គល្លានធ្វើឲ្យញាប់ញ័រ ដើម្បីធ្វើបុគ្គលដូចពួកអ្នកដែលមិនមានស្មារតី មិនមានសម្បជញ្ញៈ នៅដោយសេចក្ដីប្រមាទ ឲ្យសង្វេគ ហើយទើបត្រាស់ព្រះសូត្រនេះ ដើម្បីសម្ដែងព្រះធម៌ដល់ភិក្ខុទាំងឡាយនោះ ។

បណ្ដាបទទាំងនោះ បទថា **ឧដ្ឋហថ** សេចក្ដីថា អ្នកទាំងឡាយ ចូរក្រោកឡើងចាកអាសនៈ គឺចូរព្យាយាម ប្រឹងប្រែង គឺកុំបីខ្ជិលច្រអូស ។

បទថា **និសីទថ** សេចក្ដីថា អ្នកទាំងឡាយ ចូរអង្គុយពត់ភ្នែន ដើម្បី

តាមប្រកបកម្មដ្ឋាន ។

បទថា **កោ អត្ថោ សុបិតេន វោ** សេចក្តីថា អ្នកទាំងឡាយដែលបួសហើយ ដើម្បីអនុបាទាបរិនិព្វាន មិនមានប្រយោជន៍ដោយការដេកលក់ទេ គឺមិនមានអ្នកណាសម្រេចប្រយោជន៍ ដោយការដេកលក់ឡើយ ។

បាទព្រះគាថាថា **អាតុរានំ ហិ កា និទ្ទា សល្លវិទ្ធាន រុប្បតំ** សេចក្តីថា ឈ្មោះថា ក្នុងទីណាការដេកលក់រមែងមិនមានដល់មនុស្សទាំងឡាយ បុគ្គលដែលត្រូវបៀតបៀនដោយរោគ មានរោគក្អែកជាដើម ដែលតាំងឡើងហើយ ត្រង់ចំណែកនៃរាងកាយសូម្បីតិចតួច ដែលត្រូវព្រួញប្រភេទណាមួយ ក្នុងបណ្តាព្រួញដែក ព្រួញឆ្អឹង ព្រួញភ្លុក ព្រួញស្នែង ព្រួញឈើដែលចូលទៅកាន់រាងកាយ សូម្បីត្រឹមតែ ១ ធ្នាប់ ឬ ២ ធ្នាប់ ក្នុងកាលនោះ អ្នកទាំងឡាយដែលមានចិត្ត និងរាងកាយទាំងមូល ដែលបរិភោគហើយ ក្រវល់ក្រវាយដោយរោគ គឺកិលេសច្រើនប្រការ ដែលកើតឡើងហើយ ជាបុគ្គលឈ្មោះថា ត្រូវព្រួញមុតហើយ ព្រោះត្រូវព្រួញ ៥ ប្រភេទ គឺរាគៈជាដើម ចាក់ដោតចូលទៅក្នុងហទយៈហើយ រមែងលំបាក តើមានការដេកលក់បានដូចម្តេច ។

ព្រះមានព្រះភាគកាលត្រាស់ដូច្នេះហើយ ដើម្បីធ្វើភិក្ខុទាំងឡាយនោះឲ្យឧស្សាហ៍ និងឲ្យសង្វេគក្រៃលែងឡើង ទើបត្រាស់ថា **ឧដ្ឋហថ ។បេ។ វសានុគេ** ដូច្នេះ ។

ក្នុងព្រះគាថានោះ មានពណ៌នាអត្ថ មួយអន្លើដោយអធិប្បាយ និង

យោជនាដូចតទៅ ម្នាលភិក្ខុទាំងឡាយ កាលអ្នកទាំងឡាយ ត្រូវព្រួញ គឺកិលេសមុតហើយយ៉ាងនេះ នឹងមានពេលស្រវឹង ប្រមាទ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈនេះ មានការផ្ទូរផង់ដ៏ប្រសើរ ព្រះសាស្តាក៏មានចំពោះមុខ ក្នុងកាលមុនអំពីនេះ អ្នកទាំងឡាយដេកលក់ហើយ ត្រង់ភ្នំទាំងឡាយ និងស្ទឹងទាំងឡាយអស់កាលយូរ ដេកលក់ហើយត្រង់ចុងឈើដែលមិនស្មើ ព្រោះមិនឃើញអរិយសច្ចទាំងឡាយ ដើម្បីធ្វើទីបំផុតនៃការដេកលក់នោះ អ្នកទាំងឡាយ ចូរក្រោកឡើង ចូរអង្គុយ និងសិក្សាសន្តិឲ្យមាំទាំ ។ អត្ថក្នុងបាទនៃព្រះគាថានោះ មានន័យដូចខ្ញុំពោលហើយនោះឯង ។

ឯពាក្យថា **សន្តិ** ក្នុងបាទទី ២ សំដៅដល់ សន្តិ ៣ យ៉ាង គឺអច្ចន្តសន្តិ ១ តទង្គសន្តិ ១ សម្មតិសន្តិ ១ ។

ពាក្យថា **សន្តិ** នេះ ជាឈ្មោះនៃព្រះនិព្វាន វិបស្សនា និងទិដ្ឋិ ។ តែក្នុងទីនេះ ព្រះមានព្រះភាគទ្រង់សំដៅដល់អច្ចន្តសន្តិ គឺព្រះនិព្វាន ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ដើម្បីប្រយោជន៍ដល់ព្រះនិព្វាន ចូរអ្នកទាំងឡាយព្យាយាមសិក្សា គឺថា ចូរអ្នកទាំងឡាយ ជាអ្នកមានសេចក្តីព្យាយាមមិនធូរថយសិក្សាចុះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ស្តេចមច្ចុរាជ ដឹងថា អ្នកទាំងឡាយប្រមាទហើយ កុំបីធ្វើអ្នកទាំងឡាយដែលធ្លាក់នៅក្នុងអំណាចឲ្យវង្វេងឡើយ គឺមារដែលបានឈ្មោះថា ស្តេចមច្ចុ ដឹងយ៉ាងនេះថា ភិក្ខុទាំងនេះ ជាអ្នកប្រមាទហើយ កុំបីបានធ្វើអ្នកទាំងឡាយឲ្យធ្លាក់នៅក្នុងអំណាច ឲ្យវង្វេងឡើយ មានពាក្យអធិប្បាយថា អ្នកទាំងឡាយ

រមែងទៅកាន់អំណាចរបស់ស្តេចមច្ចុនោះបានដោយប្រការណា ស្តេចមច្ចុនោះ កុំធ្វើអ្នកទាំងឡាយដែលនៅក្នុងអំណាចដោយប្រការនោះ កុំឲ្យអ្នកទាំងឡាយដល់នូវសេចក្តីវង្វេងឡើយ ។

ព្រោះកាលបុគ្គលទៅកាន់អំណាចនៃស្តេចមារនោះ ទេវតា និងមនុស្សទាំងឡាយ ដែលត្រូវការអាស្រ័យរូបជាដើម តាំងនៅបានដោយតណ្ហាណា អ្នកទាំងឡាយ ចូរឆ្លងនូវតណ្ហានោះ ដែលបន្សាត់ទៅក្នុងអារម្មណ៍ផ្សេងៗ ខណៈកុំកន្លងអ្នកទាំងឡាយឡើយ ព្រោះថា បុគ្គលកន្លងឋានៈហើយ ជាអ្នកចង្អៀតគ្នាក្នុងនរក រមែងសោយសោក គឺទេវតា និងពួកមនុស្សដែលត្រូវការ បានដល់ ត្រូវការរូប សំឡេង ក្លិន រស និងផោដ្ឋព្វៈអាស្រ័យ ចូលទៅអាស្រ័យ ចុះស៊ប់ក្នុងអារម្មណ៍ មានរូបជាដើមនោះ តាំងនៅបានដោយតណ្ហាណា ចូរអ្នកទាំងឡាយឆ្លង គឺចូរឆ្លងផុតនូវតណ្ហានោះ បានដល់ តណ្ហាក្នុងភព និងក្នុងភោគៈ ដែលបន្សាត់ទៅ ព្រោះជាធម្មជាតិដែលផ្សាយទៅជ្រាលជ្រៅ និងទូលំទូលាយ ក្នុងអារម្មណ៍ទាំងឡាយ មានប្រការផ្សេងៗ ខណៈកុំបីកន្លងនូវអ្នកទាំងឡាយឡើយ គឺខណៈនៃការបំពេញសមណធម៌របស់អ្នកទាំងឡាយនេះ កុំបីកន្លងទៅឡើយ ព្រោះថា ខណៈបែបនេះឯង របស់ជនទាំងឡាយណាកន្លងផុតទៅ ជនទាំងឡាយណា ឆ្លងផុតខណៈនេះ ទៅហើយ ជនទាំងឡាយនោះ គឺបុគ្គលកន្លងខណៈទៅនោះឯង ចង្អៀតគ្នាក្នុងនរក រមែងសោយសោក គឺតាំងនៅក្នុងអបាយទាំង ៤ ដែលហៅថា នរក ព្រោះអត្ថថា មិនមានសេចក្តីសុខ រមែងសោយសោក ដោយន័យថា អំពើល្អ

អញមិនបានធ្វើ ដូច្នេះជាដើម ។

ព្រះមានព្រះភាគ ទ្រង់ឲ្យភិក្ខុទាំងឡាយនោះឧស្សាហ៍ និងសង្វេគយ៉ាង នេះហើយ ឥឡូវនេះ កាលទ្រង់តិះដៀលភាពដែលភិក្ខុទាំងនោះនៅដោយការ ប្រមាទ ហើយឲ្យភិក្ខុទាំងនោះតាំងនៅក្នុងសេចក្ដីមិនប្រមាទ ទើបត្រាស់គាថា នេះថា **បមាទោ រជោ** ដូច្នេះជាដើម ។

ដោយសង្ខេប ភាពជាអ្នកនៅប្រាសចាកសតិ ឈ្មោះថា **បមាទោ** ក្នុងគាថានេះ ។ សេចក្ដីប្រមាទនោះ ឈ្មោះថា **រជោ** ព្រោះអត្ថថា ជាមន្ទិល របស់ចិត្ត ធូលីនោះជាប់តាមសេចក្ដីប្រមាទនោះ ឈ្មោះថា ធ្លាក់ចុះតាម សេចក្ដីប្រមាទ កើតឡើងព្រោះសេចក្ដីប្រមាទជាប់តាមមក គឺសេចក្ដីប្រមាទ នោះឯង សេចក្ដីប្រមាទនោះ ឈ្មោះថា ជាធូលី ព្រោះថា តាំងពីកាលណា មក ឈ្មោះថា សេចក្ដីប្រមាទ មិនជាធូលីមិនមានឡើយ ។

សួរថា ព្រះមានព្រះភាគ ទ្រង់សម្ដែងអត្ថអ្វី ដោយបទថា **បមាទោ** នោះ ឆ្លើយថា ព្រះមានព្រះភាគ ទ្រង់សម្ដែងអត្ថថា អ្នកទាំងឡាយ កុំបីដល់ នូវការទុកចិត្តថា ខណៈនេះ ពួកយើងនៅកំលោះក្រមុំ ពួកយើងនឹងដឹងបានក្នុង កាលខាងក្រោយ ព្រោះថា សេចក្ដីប្រមាទ សូម្បីក្នុងពេលជាកំលោះក្រមុំ ក៏ រាប់ថា ជាធូលី សេចក្ដីប្រមាទក្នុងវ័យកណ្ដាលក៏មាន ក្នុងវ័យចាស់ក៏មាន រាប់ ថា ជាមហាធូលី ព្រោះជាប់តាមសេចក្ដីប្រមាទ ទើបចាត់ថា ជាគំនរសំរាម នោះឯង ដូចគ្នានឹងធូលីដែលមានមួយថ្ងៃ ឬពីរថ្ងៃក្នុងផ្ទះ ក៏ចាត់ថា ជាធូលី នោះឯង ធូលីនោះ កាលចម្រើនឡើង រហូតមួយឆ្នាំ ក៏រាប់ថា ជាគំនរសំរាម

នោះឯង តែកាលបើភិក្ខុរៀនពុទ្ធវចនៈក្នុងបឋមវ័យ ហើយចម្រើនសមណធម៌ក្នុងមជ្ឈិមវ័យ និងបច្ឆិមវ័យ ឬភិក្ខុរៀនពុទ្ធវចនៈក្នុងបឋមវ័យ ហើយស្តាប់បន្ទែមក្នុងមជ្ឈិមវ័យ សូម្បីធ្វើសមណធម៌ក្នុងមជ្ឈិមវ័យ មិនរាប់ថា នៅដោយសេចក្តីមិនប្រមាទឡើយ ព្រោះបដិបត្តិនូវបដិបទា ដែលអនុលោមដល់សេចក្តីមិនប្រមាទ តែបើភិក្ខុណា នៅដោយសេចក្តីប្រមាទ ក្នុងវ័យទាំងពួង ប្រកបការដេកអស់ថ្ងៃ និងប្រកបពាក្យដើម្បីបានអាមិស ដូចអ្នកទាំងឡាយ សេចក្តីប្រមាទក្នុងបឋមវ័យនោះរបស់ភិក្ខុនោះឯង ចាត់ថា ជាធូលី និងសេចក្តីប្រមាទធំ ដែលជាប់តាមសេចក្តីប្រមាទ ក្នុងថ្ងៃក្រោយអំពីនេះ រាប់ថា ជាគំនរធូលីធំនោះឯង ។

ព្រះមានព្រះភាគ កាលទ្រង់តិះដៀលភិក្ខុទាំងនោះ ដែលនៅដោយការប្រមាទយ៉ាងនេះហើយ កាលទ្រង់ដឹកនាំក្នុងការមិនប្រមាទ ទើបត្រាស់ថា **អប្បមាទេន វិជ្ជាយ អព្ពុឡ្ហេ សល្លមត្តនោ** ដូច្នេះ ។

អត្ថនៃ ២ គាថានោះ ព្រះមានព្រះភាគញុំាងទេសនាឲ្យចប់ដោយកំពូលគឺអរហត្តថា សេចក្តីប្រមាទក្នុងកាលទាំងពួងនេះ ឈ្មោះថា ជាធូលីយ៉ាងនេះ ។ កុលបុត្តដែលជាបណ្ឌិត គប្បីដកនូវព្រួញ ៥ យ៉ាង មានរាគៈជាដើម ដែល

អាស្រ័យហទយៈរបស់ខ្លួនដោយសេចក្ដីមិនប្រមាទ ពោល គឺការនៅដោយមិនប្រាសចាកសតិ និងដោយវិជ្ជា ពោល គឺអាសវក្ខយញ្ញាណ ។

ក្នុងទីបំផុតនៃព្រះធម្មទេសនា ភិក្ខុទាំងនោះដល់នូវសេចក្ដីសង្វេគ ធ្វើទុកនូវព្រះធម្មទេសនានោះឯង ពិចារណា ផ្ដើមចម្រើនវិបស្សនា ហើយតាំងនៅក្នុងអរហត្ត ដូច្នេះ ។ល។

**អដ្ឋកថា ឧដ្ឋានសូត្រទី ១០ ចប់**

# សុត្តន្តបិដក

## រាហុលសូត្រទី ១១

[ ៣៥ ] ( ព្រះមានព្រះភាគត្រាស់សួរថា ) អ្នកមិនមើលងាយអ្នកប្រាជ្ញ ព្រោះតែនៅរួមគ្នារឿយៗ ទេឬ បុគ្គលអ្នកទ្រោលគប់ភ្លើងបំភ្លឺដល់ពួកមនុស្ស អ្នកកោតក្រែងដែរឬ ។

( ព្រះរាហុលដ៏មានអាយុ ក្រាបទូលថា ) ខ្ញុំព្រះអង្គមិនមើលងាយអ្នកប្រាជ្ញ ព្រោះតែនៅរួមគ្នារឿយៗ ទេ បុគ្គលអ្នកទ្រោលគប់ភ្លើងបំភ្លឺដល់ពួកមនុស្ស ខ្ញុំព្រះអង្គកោតក្រែងជានិច្ច ។

( ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ) អ្នកចូរលះបង់នូវកាមគុណ ៥ មានសភាពជាទីស្រឡាញ់ ជាទីត្រេកអរនៃចិត្ត ចេញចាកផ្ទះមកបួសដោយសទ្ធា ហើយធ្វើនូវទីបំផុតទុក្ខចុះ ។

អ្នកចូរគប់រកនូវកល្យាណមិត្ត និងទីដេក ទីអង្គុយដ៏ស្ងាត់ ស្ងប់ស្ងាត់ មិនមានសំឡេងគឹកកង ចូរជាអ្នកស្គាល់ប្រមាណក្នុងភោជន ។

អ្នកកុំធ្វើបំណងក្នុងបច្ច័យទាំងនេះ គឺចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ និងគិលានប្បច្ច័យឡើយ កុំត្រឡប់មកកាន់លោកទៀតឡើយ ។

អ្នកចូរសង្រួមក្នុងបាតិមោក្ខផង ក្នុងឥន្ទ្រិយទាំង ៥ ផង ចូរមានស្មារតី ប្រព្រឹត្តទៅក្នុងកាយ ចូរជាបុគ្គលច្រើនដោយសេចក្តីនឿយណាយ ។

អ្នកចូរលះនូវសុភនិមិត្តដែលប្រកបដោយរាគៈ ចូរចម្រើនចិត្ត ដោយអសុភ ឲ្យជាចិត្តមូលតែមួយ តាំងមាំដោយប្រពៃ មួយទៀត ចូរចម្រើននូវអនិមិត្តវិបស្សនា ចូរលះនូវអនុស័យ គឺមានៈ លំដាប់តអំពីនោះ អ្នកនឹងប្រព្រឹត្តស្ងប់រម្ងាប់ ព្រោះលះបង់មានៈ ។

ព្រះមានព្រះភាគ ទ្រង់ទូន្មានព្រះរាហុលដ៏មានអាយុ ជារឿយៗ ដោយគាថាទាំងនេះ ដោយប្រការយ៉ាងនេះឯង ។

រាហុលសូត្រទី ១១ ចប់

# អដ្ឋកថា

## រាហុលសូត្រ

[ ៣៥ ] ក្នុងរាហុលសូត្រទី ១១ មានពាក្យផ្តើមថា **កច្ចិ អភិណ្ហ-សំវាសា** ដូច្នេះ ។

សួរថា សូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្តេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅនេះ

ព្រះមានព្រះភាគ បានត្រាស់ដឹងសម្មាសម្ពោធិញ្ញាណហើយ បានយាងចាកមណ្ឌលពោធិព្រឹក្ស ទៅកាន់នគរកបិលពស្តុដោយលំដាប់ ក្នុងនគរកបិលពស្តុនោះ ត្រូវរាហុលកុមារបានទូលសូមភាពជាទាយាទថា បពិត្រ

ព្រះសមណៈ សូមទ្រង់ប្រទានភាពជាវជ្ជទាយាទដល់ខ្ញុំ ដូច្នេះ ព្រះសាស្តាក៏ត្រាស់ដល់ព្រះសារីបុត្តថា ចូរអ្នកឲ្យរាហុលកុមារបព្វជ្ជា រឿងទាំងពួងនោះបណ្ឌិតគប្បីជ្រាបដោយន័យដែលខ្ញុំពោលហើយ ក្នុងអដ្ឋកថាខន្ធកៈ ។ ព្រះរាហុលបានបព្វជ្ជាហើយយ៉ាងនេះ ដល់នូវសេចក្តីចម្រើនហើយ ព្រះសារីបុត្តនោះឯង ក៏បានឲ្យឧបសម្បទា ឯព្រះមោគ្គល្លានជាកម្មវាចាចារ្យរបស់រាហុលនោះ ។

ព្រះរាហុលត្ថេរមិនទាន់បានសម្រេចអរិយភូមិដរាបណា ព្រះមានព្រះភាគក៏ទ្រង់ទូន្មានព្រះថេរៈនោះដរាបនោះ តាំងអំពីកាលដែលលោកនៅក្មេង ដោយទ្រង់ព្រះតម្រិះថា កុមារនេះសម្បូរដោយជាតិជាដើម កុមារនេះ កុំបីធ្វើនូវការប្រកាន់ខ្លួន ឬលើកតម្កើងខ្លួន ព្រោះអាស្រ័យជាតិ គោត្ត ត្រកូល និងពណ៌សម្បុរជាដើម ដូច្នេះហើយ ទើបត្រាស់ព្រះសូត្រនេះរឿយៗ ព្រោះហេតុនោះខាងចុងនៃព្រះសូត្រ ព្រះអានន្ទពោលពាក្យថា បានឮថា ព្រះមានព្រះភាគត្រាស់ទូន្មានរាហុលត្ថេរ ដោយព្រះគាថាទាំងនេះរឿយៗ ដោយប្រការដូច្នេះ ។

សេចក្តីសង្ខេបក្នុងគាថាទី ១ ក្នុងរាហុលសូត្រនោះ មានដូច្នេះ

ព្រះមានព្រះភាគត្រាស់សំដៅយកព្រះសារីបុត្តថា ម្នាលរាហុល អ្នកមិនមើលងាយបណ្ឌិត ដោយជាតិជាដើមណាមួយ ព្រោះការនៅរួមគ្នាជានិច្ចទេឬ ។ ឈ្មោះថា **ឧក្កាធារោ** ព្រោះការទ្រទ្រង់នូវប្រទីប គឺញាណ និងប្រទីប គឺធម្មទេសនា ចំពោះមនុស្សទាំងឡាយអ្នកឱនលំទោនទេឬ គឺដែលអ្នកបូជាហើយជានិច្ចដែរឬ ដូច្នេះ ។

ព្រះមានព្រះភាគ កាលត្រាស់ដូច្នេះហើយ ព្រះរាហុលកាលនឹងសម្ដែងថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គមិនបានធ្វើការប្រកាន់ខ្លួន ឬការលើកតម្កើង ព្រោះការនៅរួមឡើយ ដូចគ្នានឹងបុគ្គលថោកថយ មើលងាយអ្នកឈ្លាសវៃឡើយ ទើបក្រាបទូលគាថានេះថា **នាហំ អភិណ្ហសំវាសា** ដូច្នេះ ។ គាថាឆ្លើយតបនេះ មានអត្ថងាយយល់ហើយ ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ទូន្មានព្រះរាហុលត្ថេរនោះឲ្យក្រៃលែងឡើង ទើបត្រាស់គាថាដ៏សេសទាំងឡាយថា **បញ្ច កាមគុណេ** ដូច្នេះជាដើម ។

ក្នុងគាថាដ៏សេសនោះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដូចតទៅ

ព្រោះកាមគុណទាំង ៥ មានរូបជាទីស្រឡាញ់ មានជាតិជាទីស្រឡាញ់ សម្រាប់សត្វទាំងឡាយ ដែលសត្វទាំងឡាយប្រាថ្នាត្រូវការក្រៃលែង ហើយចិត្តរបស់សត្វទាំងនោះក៏ត្រេកអរ ព្រះរាហុលលះកាមគុណទាំងនោះហើយចេញអំពីព្រះរាជវាំងដោយសទ្ធា មិនមែនព្រះរាជាទ្រង់បណ្ដេញចេញឡើយ មិនមែនចោរនាំចេញឡើយ មិនមែនជាអ្នកជំពាក់បំណុល មិនមែនជាអ្នកខ្លាចភ័យ មិនមែនជាអ្នកបួសដើម្បីចិញ្ចឹមជីវិត ទើបព្រះមានព្រះភាគ ទ្រង់ញុំាងព្រះរាហុលនោះឲ្យក្លាហានដោយព្រះតម្រាស់ថា ចូរអ្នកលះនូវកាមគុណ ៥ មានសភាពជាទីស្រឡាញ់ ជាទីត្រេកអរនៃចិត្ត ចេញចាកផ្ទះមកបួសដោយសទ្ធាហើយ កាលទ្រង់ដឹកនាំក្នុងបដិបត្តិដ៏សមគួរដល់នេក្ខម្មៈនេះ ទើបត្រាស់ថា ហើយធ្វើនូវទីបំផុតទុក្ខចុះ ដូច្នេះ ។

ក្នុងពាក្យថា ព្រះរាហុលចេញបួសដោយសទ្ធានេះ បើមានពាក្យសួរជៀតចូលមកថា ព្រះរាហុលប្រាថ្នារាជសម្បត្តិដែលព្រះមានព្រះភាគទ្រង់ឲ្យបព្វជ្ជាដោយបង្ខំមិនមែនឬ កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ថា ព្រះរាហុលចេញអំពីព្រះរាជវាំងដោយសទ្ធា ដូច្នេះ សេចក្តីនេះ ខ្ញុំនឹងឆ្លើយថា ព្រះមានព្រះភាគត្រាស់យ៉ាងនេះ ក៏ព្រោះព្រះរាហុលមានព្រះហឫទ័យបង្អោនទៅក្នុងនេក្ខម្មៈ ពិតហើយ ព្រះថេរៈនេះមានព្រះហឫទ័យបង្អោនទៅក្នុងនេក្ខម្មៈយូរហើយ គឺកាលនៅជាស្តេចនាគឈ្មោះសង្ខៈ បានឃើញសាមណេរឈ្មោះឧបរេវតៈ ដែលជាឱរសរបស់ព្រះបទុមុត្តរសម្មាសម្ពុទ្ធបានថ្វាយទានអស់កាល ៧ ថ្ងៃ បានប្រាថ្នាយ៉ាងនេះ គឺប្រាថ្នាជាសាមណេរទើបដល់ព្រមដោយសេចក្តីប្រាថ្នា និងអភិនីហារ ចាប់តាំងពីនោះមក បំពេញនូវបារមីអស់មួយសែនកប្ប កើតហើយក្នុងភពចុងក្រោយ ព្រះមានព្រះភាគទ្រង់ជ្រាបភាពដែលព្រះរាហុលនោះ មានព្រះហឫទ័យបង្អោនទៅក្នុងបព្វជ្ជាយ៉ាងនេះ ព្រោះថា ញាណនេះ ជាញាណមួយក្នុងតថាគតពលញ្ញាណ ដោយហេតុនេះ ទើបព្រះមានព្រះភាគត្រាស់ថា រាហុលចេញអំពីរាជវាំងដោយសទ្ធា ។

ម្យ៉ាងទៀត ក្នុងពាក្យថា **សទ្ធាយ ឃរា និក្ខម្ម** នេះ មានអធិប្បាយថា អ្នកចេញអំពីព្រះរាជវាំងដោយសទ្ធាអស់កាលយូរហើយ ឥឡូវនេះក៏ចូរធ្វើទីបំផុតនៃទុក្ខចុះ ។

ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីសម្តែងបដិបទាដោយការធ្វើទីបំផុត

ទុក្ខក្ខន្ធវគ្គ: តាំងអំពីការលះសមុទយ: ទើបត្រាស់គាថានេះថា **មិត្តេ ភជស្សុ កល្យាណេ** ដូច្នេះជាដើម ។

គប្បីជ្រាបអធិប្បាយក្នុងព្រះគាថានេះដូចតទៅ ជនទាំងឡាយ ដែលក្រៃលែងដោយសីលជាដើម ឈ្មោះថា កល្យាណមិត្ត បុគ្គលសេពគប់នូវកល្យាណមិត្តនោះ រមែងចម្រើនដោយគុណទាំងឡាយ មានសីលជាដើម ដូចដើមសាលព្រឹក្សធំ អាស្រ័យព្រៃហិមពាន្ត ចម្រើនដោយឫសជាដើម ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **មិត្តេ ភជស្សុ កល្យាណេ** ដូច្នេះ ។

បទទាំងឡាយថា **បន្តញ្ច សយនាសនំ វិវិត្តំ អប្បនិគ្ឃោសំ** សេចក្តីថា ទីដេក ទីអង្គុយណាដែលជាទីស្ងាត់ គឺនៅឆ្ងាយ ស្ងាត់ មិនប្រឡូកប្រឡល់ប្រាសចាកសំឡេងអឺងកង ។ សេចក្តីសម្គាល់ថា ព្រៃ រមែងកើតឡើងក្នុងសេនាសនៈណា ដោយសំឡេងនៃសត្វ មានម្រឹគ និងជ្រូកជាដើម ចូរអ្នកសេពទីដេក ទីអង្គុយបែបនោះ ។

បាទព្រះគាថាថា **មត្តញ្ញូ ហោហិ ភោជនេ** បានដល់ ចូរជាអ្នកដឹងប្រមាណក្នុងភោជន អធិប្បាយថា ចូរអ្នកដឹងប្រមាណក្នុងការទទួល និងប្រមាណក្នុងការបរិភោគ ។ ក្នុងប្រមាណទាំង ២ យ៉ាងនោះ អ្នកដឹងប្រមាណក្នុងការទទួល កាលទេយ្យធម៌មានតិចផង ទាយកត្រូវការឲ្យតិចផង ក៏ចូរទទួលតែបន្តិចប៉ុណ្ណោះ កាលទេយ្យធម៌មានតិច តែទាយកត្រូវការឲ្យច្រើន ក៏គួរទទួលតែបន្តិចដូចគ្នា តែបើទេយ្យធម៌មានច្រើន ទាយកត្រូវការនឹងឲ្យតិច ក៏គួរទទួលតិចដូចគ្នា កាលទេយ្យធម៌មានច្រើន ទាយកក៏ត្រូវការឲ្យច្រើន ក៏

គួរដឹងកម្លាំងរបស់ខ្លួន ហើយទទួល ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់អធិប្បាយចំពោះការប្រមាណប៉ុណ្ណោះដូច្នេះឯង ។

ភិក្ខុដឹងប្រមាណក្នុងការបរិភោគ ពិចារណាដោយឧបាយហើយ គប្បីឆាន់ភោជន ដូចបុគ្គលបរិភោគសាច់កូន និងដូចបុគ្គលប្រើប្រេងបន្តក់ភ្លៅរថដូច្នោះ ។

ព្រះមានព្រះភាគ កាលទ្រង់ទូន្មានដោយការសេពគប់កល្យាណមិត្តដែលជាឧបការៈដល់ព្រហ្មចរិយៈ និងឲ្យព្រះរាហុលសមាទានក្នុងបារិសុទ្ធិសីល គឺការបរិភោគបច្ច័យ ដោយត្រាស់ដល់ការប្រើប្រាស់សេនាសនៈជាប្រធាន ដោយគាថានេះយ៉ាងនេះហើយ ឥឡូវនេះ ព្រោះហេតុដែលការចិញ្ចឹមជីវិតខុសគប្បីមាន ព្រោះចំណង់ក្នុងចីវរជាដើម ដូច្នោះ ទើបទ្រង់បដិសេធមិច្ឆាជីវៈនោះ កាលនឹងឲ្យព្រះរាហុលត្រូវសមាទានក្នុងអាជីវបារិសុទ្ធិសីលនោះ ទើបត្រាស់ព្រះគាថានេះថា **ចីវរេ បិណ្ឌបាតេ ច** ដូច្នេះ ។

ក្នុងព្រះគាថានោះ បទថា **បច្ចយេ** បានដល់ គិលានប្បច្ច័យ ។

បទថា **ឯតេសុ** បានដល់ ក្នុងរឿងដែលឲ្យភិក្ខុទាំងឡាយកើតការចង់បានក្នុងបច្ច័យ ៤ មានចីវរជាដើមនេះ ។

បទថា **តណ្ហមាកាសិ** សេចក្តីថា កាលឃើញទោសដោយន័យថា បច្ច័យទាំង ៤ នោះ ជាគ្រឿងឧបការៈដល់បុគ្គលទាំងឡាយដែលទុព្វលជានិច្ចក៏ដើម្បីជាប្រយោជន៍ដល់ការបិទបាំងអវយវៈ ដែលធ្វើសេចក្តីខ្មាសឲ្យកម្រើកជាដើមប៉ុណ្ណោះ រមែងជាគ្រឿងទ្រទ្រង់នូវរាងកាយដែលទុព្វលក្រៃលែង ដូច

សសរជាគ្រឿងទ្រទ្រង់ផ្ទះចាស់ដូច្នោះ ដូច្នេះ កុំឲ្យចំណង់កើតឡើង កាលមិនឲ្យកើតឡើង បានដល់ កាលមិនឲ្យកើតឡើង ចូរនៅដោយមិនមានតណ្ហាកើតឡើងនោះ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះថា អ្នកកុំបីមកកាន់លោកនេះទៀតឡើយ ។

បាទព្រះគាថាថា **មា លោកំ បុនរាគមិ** សេចក្តីថា បុគ្គលធ្វើនូវការចង់បានក្នុងបច្ច័យទាំងនេះ ត្រូវសេចក្តីចង់បានអូសទាញ រមែងមកកាន់លោកនេះទៀត ភិក្ខុនោះកុំបីធ្វើនូវការចង់បានក្នុងបច្ច័យទាំងនេះ កាលបើដូច្នេះ ភិក្ខុនោះក៏នឹងមិនមកកាន់លោកនេះទៀត ។

ព្រះមានព្រះភាគ កាលត្រាស់យ៉ាងនេះហើយ ព្រះរាហុលដឹងថា ព្រះមានព្រះភាគបានត្រាស់នឹងអញថា អ្នកកុំធ្វើនូវការចង់បានក្នុងចីវរ ដូច្នេះ ក៏សមាទានធុតង្គ ២ ដែលទាក់ទងក្នុងចីវរ គឺបង្សុកូលិកង្គធុតង្គ ១ តេចីវរិកង្គធុតង្គ ១ ។

ព្រះរាហុលនោះជ្រាបថា ព្រះមានព្រះភាគបានត្រាស់នឹងអញថា អ្នកកុំធ្វើចំណង់ក្នុងបិណ្ឌបាត ដូច្នេះហើយ ទើបបានសមាទានធុតង្គ ៥ ដែលទាក់ទងនឹងបិណ្ឌបាត គឺបិណ្ឌបាតិកង្គធុតង្គ ១ សបទានចារិកង្គធុតង្គ ១ ឯកាសនិកង្គធុតង្គ ១ បត្តបិណ្ឌិកង្គធុតង្គ ១ ខលុបច្ឆាភត្តិកង្គធុតង្គ ១ ។

ព្រះរាហុលនោះដឹងថា ព្រះមានព្រះភាគត្រាស់នឹងអាត្មាអញថា អ្នកកុំធ្វើការចង់បានក្នុងសេនាសនៈ ដូច្នេះ ក៏បានសមាទានធុតង្គ ៦ ដែលទាក់ទង

ដោយសេនាសនៈ គឺអារញ្ញិកង្គធុតង្គ ១ អព្ភោកាសិកង្គធុតង្គ ១ រុក្ខមូលិ-កង្គធុតង្គ ១ យថាសន្ថតិកង្គធុតង្គ ១ សោសានិកង្គធុតង្គ ១ នេសជ្ជិកង្គ-ធុតង្គ ១ ។

ព្រះរាហុលនោះដឹងថា ព្រះមានព្រះភាគត្រាស់នឹងអញថា អ្នកកុំធ្វើនូវចំណង់ក្នុងគិលានប្បច្ច័យ ដូច្នេះហើយ ទើបសន្តោសដោយសន្តោស ៣ ក្នុងបច្ច័យទាំងពួង គឺយថាលាភសន្តោស យថាពលសន្តោស យថាសារុប្ប-សន្តោស ជាអ្នកមានប្រក្រតីទទួលពាក្យប្រៀនប្រដៅដោយគោរព ដូចកុលបុត្តដែលប្រដៅងាយ ។

ព្រះមានព្រះភាគ កាលទ្រង់ឲ្យព្រះរាហុលសមាទានអាជីវបារិសុទ្ធិសីលហើយ ឥឡូវនេះ កាលនឹងឲ្យសមាទានក្នុងសីលដ៏សេស និងក្នុងសមថ-វិបស្សនាទាំងឡាយ ទើបត្រាស់ថា **សំវុតោ បាតិមោក្ខស្មឹ** ដូច្នេះជាដើម ។

ក្នុងបណ្តាបទទាំងឡាយនោះ ក្នុងបាទគាថានេះថា **សំវុតោ បាតិ-មោក្ខស្មឹ** គប្បីបន្ថែមបាលីដែលសល់ចូលមកថា **ភវស្សុ** ឬគប្បីជ្រាបសម្ពន្ធដោយបទចុងក្រោយថា **ភវ** ។ ក្នុងបាទគាថាទី ២ គប្បីបន្ថែមបាលីដ៏សេសចូលដូចគ្នា ។

ព្រះមានព្រះភាគ ទ្រង់ដឹកនាំឲ្យព្រះរាហុលនៅក្នុងបាតិមោក្ខសំវរសីល និងឥន្ទ្រិយសំវរសីល ដោយព្រះតម្រាស់ ២ យ៉ាងនេះ ។ ក្នុងព្រះគាថាថា **ឥន្ទ្រិយេសុ ច បញ្ចសុ** នេះ ព្រះមានព្រះភាគត្រាស់ឥន្ទ្រិយ ៥ ប្រការ ដោយអំណាចនៃអត្ថដែលប្រាកដហើយ ។ តែដោយលក្ខណៈហើយ គប្បីជ្រាបថា

សម្បីឥន្ទ្រិយទី ៦ ក៏ទ្រង់ត្រាស់ហើយដូចគ្នា ។ បាទព្រះគាថាថា **សតិ កាយគតា ត្យត្ថុ** សេចក្ដីថា សតិដែលប្រព្រឹត្តទៅក្នុងកាយ មានចតុធាតុ-វវដ្ឋាន សម្បជញ្ញៈ ៤ អានាបានស្សតិ និងអាហារេបដិកូលសញ្ញាជាដើម ចូរមាន គឺចូរកើតមានដល់អ្នកដែលតាំងនៅហើយ ក្នុងចតុប្បារិសុទ្ធិសីល យ៉ាងនេះ គឺចូរចម្រើនកាយគតាសតិនោះ ។

បាទព្រះគាថាថា **និព្ពិទាពហុលោ ភវ** សេចក្ដីថា ចូរអ្នកជាអ្នកច្រើន ដោយការនឿយណាយក្នុងសង្សារវដ្ដ គឺចូរមានសេចក្ដីសម្គាល់ក្នុងលោកទាំង ពួងថា មិនគួរត្រេកអរ ។

ព្រះមានព្រះភាគ ទ្រង់សម្ដែងឧបចារភូមិដែលជាចំណែកនៃការចាក់ធ្លុះ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ឥឡូវនេះ កាលទ្រង់សម្ដែងអប្បនាភូមិ ក៏ ត្រាស់ពាក្យជាដើមថា **និមិត្តំ បរិវជ្ជេហិ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **និមិត្តំ** បានដល់ សុភនិមិត្តដែលជាទីតាំង នៃរាគៈ ។ ដោយពាក្យថា **និមិត្តំ** នោះឯង ព្រះមានព្រះភាគ កាលទ្រង់ធ្វើ សុភនិមិត្តនោះឲ្យវិសេសក្រៃលែងឡើង ទើបត្រាស់ថា **សុភំ រាគូបសញ្ហិតំ ។**

បទថា **បរិវជ្ជេហិ** បានដល់ ចូរវៀរដោយមនសិការ ។ បាទព្រះគាថា ថា **អសុភាយ ចិត្តំ ភាវេហិ** សេចក្ដីថា ចូរអប់រំចិត្តដោយប្រការ ដែល អសុភភាវនាក្នុងកាយដែលមានវិញ្ញាណ ឬមិនមានវិញ្ញាណសម្រេចបាន ។

បាទព្រះគាថាថា **ឯកគ្គំ សុសមាហិតំ** សេចក្ដីថា ចិត្តបែបនេះរបស់ អ្នក នឹងជាចិត្តដែលមានអារម្មណ៍តែមួយបាន ដោយឧបចារសមាធិ នឹងជា

ចិត្តតាំងមាំបានដោយអប្បនាសមាធិដោយប្រការណា ចូរអ្នកអប់រំចិត្តនោះដោយប្រការនោះ ។

ព្រះមានព្រះភាគ កាលសម្តែងអប្បនាភូមិនៃចិត្តយ៉ាងនេះហើយ កាលសម្តែងវិបស្សនា ទើបត្រាស់ថា **អនិមិត្តំ** ជាដើម ។

បណ្តាបទទាំងនោះ បាទព្រះគាថាថា **អនិមិត្តញ្ច ភាវេហិ** អធិប្បាយថា បុគ្គលមានចិត្តតាំងមាំដោយសមាធិ ដែលជាចំណែកនៃការចាក់ធ្លុះយ៉ាងនេះហើយ ចូរចម្រើនវិបស្សនា ។ ពិតហើយ វិបស្សនារមែងបានវោហារថា **អនិមិត្តំ** ដោយន័យជាដើមថា អនិច្ចានុបស្សនាញាណ ឈ្មោះថា អនិមិត្តវិមោក្ខ ព្រោះផុតចាកនិមិត្តថាទៀង ឬដោយមិនកាន់យកនូវនិមិត្តទាំងឡាយមានរាគនិមិត្តជាដើម ។ ដូចព្រះមហាមោគ្គល្លានពោលក្នុង ( សំយុត្តនិកាយ សឡាយតនវគ្គ ) ថា

ម្នាលអាវុសោទាំងឡាយ ខ្ញុំព្រោះមិនធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងពួង ក៏ដល់នូវចេតោសមាធិ មិនមាននិមិត្ត ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអាវុសោទាំងឡាយ កាលខ្ញុំនៅដោយវិហារធម៌នេះ អនិមិត្តានុសារិវិញ្ញាណក៏កើតឡើង ដូច្នេះ ។

បាទព្រះគាថាថា **មានានុសយមុជ្ជហ** សេចក្តីថា ចូរអ្នកលះ ចូរលះបង់ គឺចូររលោស់ចោលនូវមានានុស័យ ដោយលំដាប់ជាដើមយ៉ាងនេះថា

ម្នាលមេឃិយៈ សេចក្តីសម្គាល់ថា មិនមែនខ្លួន រមែងប្រាកដដល់ភិក្ខុអ្នកមានសេចក្តីសម្គាល់ថា មិនទៀង ភិក្ខុអ្នកមានសេចក្តី

សម្គាល់ថា មិនមែនខ្លួន រមែងដល់ព្រះនិព្វានជាគ្រឿងដកចោល នូវអស្មិមានះ ក្នុងបច្ចុប្បន្ន ដូច្នេះ ។

ពីរបាទនៃព្រះគាថាថា **តតោ មានាភិសមយា ឧបសន្តោ ចរិស្សសិ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ឲ្យទេសនាចប់ដោយកំពូល គឺអរហត្តថា បន្ទាប់អំពីនោះ ព្រោះលះ ព្រោះអស់ទៅ សូន្យទៅ ព្រោះផ្តាច់ផ្តិល ព្រោះការលះបង់នូវមានះ ដោយអរិយមគ្គយ៉ាងនេះ អ្នកនឹងជាបុគ្គលស្ងប់ គឺរម្ងត់ឥតសេសសល់ បានដល់ ជាអ្នកត្រជាក់ គឺជាអ្នកវៀរហើយចាកសេចក្តីក្រវល់ក្រវាយ និងការក្តៅក្រហាយទាំងពួង នឹងត្រាច់ទៅ គឺនឹងនៅដោយធម៌ជាគ្រឿងនៅ គឺផលសមាបត្តិណាមួយ បណ្តាសុញ្ញតនិមិត្ត អនិមិត្តនិមិត្ត និងអប្បណិហិតនិមិត្ត ដរាបទល់នឹងចូលកាន់និព្វាន ដោយអនុបាទិសេសនិព្វានធាតុ ។

បន្ទាប់អំពីនេះទៅ ពាក្យថា **ឥត្ថំ សុទំ ភគវា** ជាដើម ជាពាក្យរបស់សង្គីតិកាចារ្យ ។

បណ្តាបទទាំងនោះ បទថា **ឥត្ថំ សុទំ** បានដល់ បានឮមកយ៉ាងនេះ មានពាក្យអធិប្បាយថា យ៉ាងនេះឯង ។ ពាក្យដ៏សេស ក្នុងគាថានេះ មាន

អត្ថងាយយល់ហើយ ។

ព្រះរាហុល កាលព្រះមានព្រះភាគទ្រង់ប្រទានឱវាទយ៉ាងនេះ ក៏តាំងនៅហើយក្នុងអរហត្ត មួយអន្លើដោយទេវតាទាំងឡាយជាអនេក ក្នុងទីបំផុតនៃចូឡរាហុលោវាទសូត្រ ក្នុងកាលធម៌ទាំងឡាយដែលជាទីតាំងនៃការចោសក្តាដោយជុំវិញ ដើម្បីការបាននូវវិមុត្តិ ដល់នូវការចោសក្តាហើយ ៕

**អដ្ឋកថារាហុលសូត្រទី ១១ ចប់**

# សុត្តន្តបិដក

## វង្គីសសូត្រទី១២

[ ៣៦ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអគ្គាឡវចេតិយវិហារ ជិតក្រុងអាឡវី ។ សម័យនោះឯង ព្រះថេរៈឈ្មោះនិគ្រោធកប្បៈ ជាឧបជ្ឈាយ៍របស់ព្រះវង្គីសៈមានអាយុ ទើបតែបរិនិព្វានថ្មីៗ ក្នុងអគ្គាឡវចេតិយវិហារ ។ គ្រានោះ ព្រះវង្គីសៈដ៏មានអាយុ ទៅក្នុងទីស្ងាត់ គេចចេញចាកអារម្មណ៍ សម្ងំនៅ កើតមានសេចក្តីត្រិះរិះក្នុងចិត្តយ៉ាងនេះថា ព្រះឧបជ្ឈាយ៍របស់អាត្មាអញបរិនិព្វានហើយ ឬមិនទាន់បរិនិព្វានទេ ។ លំដាប់នោះ ព្រះវង្គីសៈដ៏មានអាយុចេញចាកទីសម្ងំក្នុងសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ ព្រះវង្គីសៈដ៏មានអាយុ លុះអង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គទៅក្នុងទីស្ងាត់ ពួនសម្ងំនៅក្នុងអគ្គាឡវចេតិយវិហារនេះ កើតមានសេចក្តីត្រិះរិះក្នុងចិត្តយ៉ាងនេះថា ព្រះឧបជ្ឈាយ៍របស់អាត្មាអញបរិនិព្វានហើយ ឬមិនទាន់បរិនិព្វានទេ ។ លំដាប់នោះ ព្រះវង្គីសៈដ៏មានអាយុក្រោកចាកអាសនៈ ធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគ ហើយក្រាបបង្គំទូលសួរចំពោះព្រះមានព្រះភាគដោយគាថាថា

[ ៣៧ ] ពួកខ្ញុំអង្គសូមសួរព្រះសាស្តា ព្រះអង្គមានបញ្ញាមិន
ខ្សោយខ្សោក ថោកទាប កិក្ខុណា ជាអ្នកកាត់ផ្តាច់នូវសេចក្តី

សង្ស័យក្នុងបច្ចុប្បន្ន មានកេរ្តិ៍ឈ្មោះ មានយស មានចិត្តត្រជាក់ បានធ្វើមរណកាលក្នុងអគ្គាឡវចេតិយវិហារ ។ បពិត្រព្រះមានព្រះភាគ ឈ្មោះរបស់ភិក្ខុជាព្រាហ្មណ៍នោះ ព្រះអង្គទ្រង់ប្រោសប្រទានហើយថា និគ្រោធកប្បភិក្ខុនោះ កាលនមស្ការនូវព្រះអង្គជាអ្នកប្រាថ្នានូវការផុតស្រឡះ ( ចាកកិលេស ) បានប្រារព្ធព្យាយាមឃើញនូវធម៌ដ៏មាំ ។ បពិត្រព្រះសក្យៈ មានចក្ខុជុំវិញគឺសព្វញ្ញុតញ្ញាណ ពួកខ្ញុំព្រះអង្គទាំងអស់គ្នា ចង់ដឹងនូវសាវកនោះ ពួកខ្ញុំព្រះអង្គ បានប្រុងត្រចៀកនឹងស្តាប់ជាស្រេចហើយ ព្រះអង្គជាគ្រូរបស់ពួកខ្ញុំព្រះអង្គ ព្រះអង្គជាបុគ្គលប្រសើរលើស ។ បពិត្រព្រះអង្គអ្នកមានប្រាជ្ញាក្រាស់ដូចជាផែនដី សូមព្រះអង្គកាត់បង់នូវសេចក្តីសង្ស័យ របស់ពួកខ្ញុំព្រះអង្គ សូមទ្រង់សម្តែងនូវសេចក្តីនុ៎ះ ដល់ខ្ញុំព្រះអង្គ សូមទ្រង់ត្រាស់ប្រាប់នូវភិក្ខុដែលបរិនិព្វានហើយ ។ បពិត្រព្រះអង្គអ្នកមានចក្ខុជុំវិញ សូមព្រះអង្គទ្រង់ប្រកាសក្នុងកណ្តាលពួកខ្ញុំព្រះអង្គ ដូចជាព្រះឥន្ទ្រជាសហស្សនេត្រ ( ទ្រង់ប្រកាសក្នុងកណ្តាល ) ពួកទេវតា ។ គន្ថកិលេសណាមួយ ដែលជាផ្លូវនៃមោហៈ ជាពួកនៃកិរិយាមិនដឹង ជាទីតាំងនៃសេចក្តីសង្ស័យក្នុងលោកនេះ គន្ថកិលេសទាំងនោះ មានដល់នូវព្រះតថាគត រមែងមិនមាន ព្រោះព្រះអង្គមានភ្នែកដ៏ឧត្តមជាងនរជនទាំងឡាយ ។ ក៏ប្រសិន

បើព្រះមានព្រះភាគជាវិញ្ញូបុរស មិនកម្ចាត់បង់កិលេស ដូចជាខ្យល់កម្ចាត់នូវពពកទេ លោកទាំងអស់ ដែលមោហៈរួបរឹតហើយ ក៏ទៅជាងងឹតសូន្យ សូម្បីពួកនរជនដែលមានពន្លឺ ក៏មិនគប្បីភ្លឺច្បាស់បាន ។ មួយទៀត ពួកអ្នកប្រាជ្ញ ជាអ្នកធ្វើនូវពន្លឺរុងរឿង គឺបញ្ញា បពិត្រព្រះអង្គជាអ្នកប្រាជ្ញ ព្រោះហេតុនោះ បានជាខ្ញុំព្រះអង្គសម្គាល់នូវព្រះអង្គថា ជាយ៉ាងនោះឯង ពួកខ្ញុំព្រះអង្គដឹងថា ព្រះអង្គជាអ្នកឃើញតាមពិត ទើបនាំគ្នាចូលមកគាល់ព្រះអង្គ សូមព្រះអង្គ ទ្រង់សម្តែងឲ្យប្រាកដនូវនិគ្រោធកប្បត្ថេរ ចំពោះពួកខ្ញុំព្រះអង្គ ក្នុងពួកបរិស័ទ បពិត្រព្រះអង្គមានព្រះសូរសៀងដ៏ពីរោះ សូមព្រះអង្គទ្រង់ត្រាស់នូវព្រះវាចាជាទីគាប់ចិត្តជាឆាប់ សូមព្រះអង្គ ទ្រង់បញ្ចេញព្រះសូរសៀងសន្សើមៗ ដោយព្រះសូរសៀងមូលពីរោះ ដែលសង្ខារតាក់តែងទុកដោយល្អ ដូចហង្សផ្គងស្រែកសម្រែកបន្តិចៗ ខ្ញុំព្រះអង្គទាំងអស់គ្នា តាំងចិត្តត្រង់នឹងប្រុងស្តាប់ព្រះអង្គ ។ ខ្ញុំព្រះអង្គនឹងសូមទទួចអារាធនាព្រះអង្គ អ្នកមានជាតិ និងមរណៈលះបង់ហើយ មិនសេសសល់ កម្ចាត់បង់ ( នូវបាបទាំងពួង ) ឲ្យទ្រង់សម្តែងនូវធម៌ ព្រោះថា ការធ្វើបានតាមប្រាថ្នា មិនមានដល់បុថុជ្ជនឡើយ ចំណែកខាងការពិចារណាហើយ ធ្វើបានតាមប្រាថ្នា រមែងមានដល់ព្រះតថាគតទាំងឡាយ ។

សម្បន្នវេយ្យាករណ៍ ( ការព្យាករណ៍ដ៏ត្រឹមត្រូវ ) នេះ គឺព្រះអង្គមានបញ្ញាវុងរឿងបានត្រាស់ប្រាប់ហើយ អញ្ជលីជាទីបំផុតនេះ ខ្ញុំព្រះអង្គបានប្រណម្យហើយដោយប្រពៃ បពិត្រព្រះអង្គមានប្រាជ្ញាមិនទន់ទាប កាលព្រះអង្គទ្រង់ជ្រាប ( នូវគតិនៃព្រះនិគ្រោធកប្បៈ ) កុំឲ្យខ្ញុំព្រះអង្គវង្វេងឡើយ ។ បពិត្រព្រះអង្គមានព្យាយាមមិនទន់ទាប ព្រះអង្គបានជ្រាបច្បាស់ នូវអរិយសច្ចធម៌ដ៏ប្រសើរក្រៃលែង កាលព្រះអង្គទ្រង់ជ្រាបនូវញេយ្យធម៌ទាំងពួង កុំឲ្យខ្ញុំព្រះអង្គវង្វេងឡើយ ខ្ញុំព្រះអង្គប្រាថ្នានូវព្រះវាចា ( របស់ព្រះអង្គ ) ដូចជាបុគ្គលក្តៅដោយកម្តៅថ្ងៃក្នុងរដូវក្តៅ ប្រាថ្នារកទឹក សូមព្រះអង្គបង្អុរនូវព្រះសូរសៀង ។ និគ្រោធកប្បភិក្ខុ បានប្រព្រឹត្តព្រហ្មចរិយធម៌ដ៏មានប្រយោជន៍ណា ព្រហ្មចរិយធម៌នោះរបស់លោក មិនឥតប្រយោជន៍តិចតួចឡើយ លោកនោះបាននិព្វាន ដូចជាអសេក្ខបុគ្គលដែលមានចិត្តផុតហើយ ឬជាសឧបាទិសេសៈ ( ដូចជាសេក្ខបុគ្គល ) ពួកខ្ញុំព្រះអង្គប្រុងស្តាប់នូវព្រះបន្ទូល របស់ព្រះអង្គនោះ ។

( ព្រះមានព្រះភាគទ្រង់ព្យាករថា ) និគ្រោធកប្បភិក្ខុ បានកាត់ផ្តាច់នូវតណ្ហា ក្នុងនាម និងរូបនេះ ជាខ្សែធម៌ខ្មៅ គឺកិលេសមារ ដែលដេកត្រាំអស់រាត្រីជាអង្វែង បានឆ្លងផុតការកើត និងការស្លាប់មិនមានសេសសល់ ព្រះមានព្រះភាគប្រសើរ

ជាងបញ្ចវគ្គិយភិក្ខុ បានត្រាស់ព្យាករដោយប្រការដូច្នេះ ។ បពិត្រព្រះអង្គជាឥសីគម្រប់ ៧ ខ្ញុំព្រះអង្គនោះ បានស្តាប់ព្រះបន្ទូលព្រះអង្គហើយ ជ្រះថ្លាព្រោះប្រស្នា ដែលខ្ញុំព្រះអង្គក្រាបទូលសួរមិនឥតអំពើឡើយ ព្រះអង្គជាព្រាហ្មណ៍មិនបានបញ្ឆោតខ្ញុំព្រះអង្គឡើយ ។ សាវករបស់ព្រះពុទ្ធនិយាយយ៉ាងណា ធ្វើយ៉ាងនោះ បានកាត់ផ្តាច់នូវបណ្តាញ គឺតណ្ហាដ៏មាំរបស់មច្ចុមារ ដែលមានមាយាច្រើន ដែលផ្សាយទៅ ( ក្នុងតេភូមិកវដ្ដៈ ) នោះ ។ បពិត្រព្រះមានព្រះភាគ និគ្រោធកប្បភិក្ខុ បានឃើញហេតុជាខាងដើមនៃឧបាទាន ឱហ្ន៎ និគ្រោធកប្បភិក្ខុបានប្រព្រឹត្តកន្លងនូវ ( តេភូមិកវដ្ដៈ ) ជាទីទ្រទ្រង់នៅនៃមច្ចុមារ ដែលគេឆ្លងបានដោយកម្រក្រៃពេក ។

**វង្គីសសូត្រទី ១២ ចប់**

# អដ្ឋកថា

## វង្គីសសូត្រ

ក្នុងវង្គីសសូត្រទី ១២ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ជាដើម ។ ព្រះសូត្រនេះ លោកហៅថា និគ្រោធកប្បសូត្រដូច្នេះក៏មាន ។

សួរថា សូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ការកើតឡើងនៃសូត្រនេះ លោកពោលក្នុងនិទាន គឺការផ្ដើមសូត្រនោះហើយ ។

[ ៣៦ ] បណ្ដាបទទាំងឡាយនោះ បទថា **ឯវម្មេ សុតំ** ជាដើម មានអត្ថដូចដែលខ្ញុំពោលហើយនោះឯង ។ ខ្ញុំនឹងវៀរពាក្យ និងពាក្យដទៃៗ បែបនោះ ពណ៌នាចំពោះន័យដែលមិនទាន់បានពោលប៉ុណ្ណោះ ។

បទថា **អគ្គាឡវេ ចេតិយេ** បានដល់ ត្រង់អគ្គាឡវចេតិយ ក្នុងក្រុងអាឡវី ។ ពិតហើយ កាលព្រះមានព្រះភាគមិនទាន់កើតឡើង មានចេតិយជាច្រើន មានអគ្គាឡវចេតិយ និងគោតមចេតិយជាដើម ដែលជាទីស្ថាននៃពួកយក្ខ និងនាគ តែលុះព្រះមានព្រះភាគទ្រង់កើតឡើង ពួកមនុស្សទាំង-ឡាយ ក៏រើចេតិយទាំងនោះ ធ្វើជាវត្តអារាម តែមនុស្សទាំងឡាយ ក៏នៅតែហៅឈ្មោះដើមនោះឯង អធិប្បាយថា ព្រះថេរៈនៅក្នុងវត្ត ពោល គឺអគ្គា-ឡវចេតិយ ។

ពាក្យថា **អាយស្មា** ក្នុងពាក្យថា **អាយស្មតោ វង្គីសស្ស** នេះ ជាពាក្យដែលពោលដោយសេចក្ដីស្រឡាញ់ ។

ពាក្យថា **វង្គីស** នេះ ជាឈ្មោះរបស់ព្រះថេរៈនោះ ព្រះវង្គីសត្ថេរនោះ ជនទាំងឡាយស្គាល់តាំងពីលោកកើតមក ។

បានឮថា វង្គីសៈនោះ ជាកូនរបស់បរិព្វាជក កើតក្នុងផ្ទៃរបស់នាងបរិព្វាជិកា ដោយអានុភាពនៃវិជ្ជាមួយ ដែលគោះលលាដ៍ក្បាលអ្នកស្លាប់ហើយក៏ដឹងគតិ និងកំណើតរបស់សត្វទាំងឡាយ ។ បានឮថា ពួកមនុស្សក៏បាននាំលលាដ៍ក្បាលនៃពួកញាតិរបស់ខ្លួន ដែលស្លាប់ហើយមកអំពីព្រៃខ្មោច ហើយសួរគតិរបស់ញាតិទាំងនោះជាមួយវង្គីសៈ គេក៏ទាយថា បុគ្គលនេះ កើតក្នុងនរកឈ្មោះនោះ បុគ្គលនោះ កើតក្នុងមនុស្សលោក ត្រង់ទីឯណោះ ពួកមនុស្សទាំងនោះ កាលវង្គីសៈនោះទាយហើយ ទើបឲ្យទ្រព្យជាច្រើនដល់វង្គីសៈ ដោយអាការយ៉ាងនេះ ទើបគេប្រាកដ គឺល្បីខ្ចរខ្ចារក្នុងជម្ពូទ្វីបទាំងមូល ។ វង្គីសៈនោះ បំពេញបារមីមក អស់មួយសែនកប្ប បរិបូណ៌ដោយអភិនីហារ មានបុរស ៥០០០ ចោមរោម ត្រាច់ទៅក្នុងគាមនិគម ជនបទរាជធានីទាំងឡាយ មកដល់នគរសាវត្ថីដោយលំដាប់ ។ សម័យនោះឯងព្រះមានព្រះភាគគង់នៅត្រង់នគរសាវត្ថី ពួកអ្នកសាវត្ថីថ្វាយទានក្នុងបុរេភត្តហើយ ក្នុងបច្ឆាភត្ត ក៏នាំគ្នាស្លៀកដណ្តប់ស្អាតបាត កាន់ផ្កា និងគ្រឿងក្រអូបជាដើម ទៅកាន់វត្តជេតពនដើម្បីស្តាប់ធម៌ ។ វង្គីសៈឃើញអ្នកទាំងនោះហើយក៏សួរថា មហាជននាំគ្នាទៅណាហ្ន៎ កាលជនទាំងនោះប្រាប់ថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក កំពុងសម្តែងធម៌ ដើម្បីជាប្រយោជន៍ដល់មហាជនពួកខ្ញុំទៅក្នុងទីនោះ ។ សូម្បីវង្គីសៈ មួយអន្លើដោយជនទាំងនោះ និងបរិវាររបស់ខ្លួនក៏ទៅ ហើយប្រាស្រ័យជាមួយនឹងព្រះមានព្រះភាគ រួចអង្គុយក្នុងចំណែកម្ខាង ។ កាលនោះ ព្រះមានព្រះភាគ ត្រាស់ហៅវង្គីសៈនោះថា ម្នាល

វង្គីសៈ អ្នកចេះគោះលលាដ៍ក្បាលរបស់មនុស្សទាំងឡាយ ហើយប្រាប់គតិនិងកំណើតបានឬ វង្គីសៈទូលថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គរមែងដឹងយ៉ាងនេះ ព្រះសាស្តា ឲ្យនាំយកលលាដ៍ក្បាលរបស់មនុស្សដែលកើតក្នុងនរកមកហើយ ទ្រង់បង្ហាញដល់វង្គីសៈ ព្រាហ្មណ៍នោះប្រើក្រចកគោះហើយ ទូលថា បពិត្រព្រះគោតម នេះជាក្បាលនៃអ្នកកើតក្នុងនរក ។ ព្រះមានព្រះភាគ ទ្រង់បានបង្ហាញលលាដ៍ក្បាលទាំងឡាយ របស់មនុស្សទាំងឡាយ ដែលកើតហើយក្នុងគតិទាំងពួង ដោយអាការយ៉ាងនេះ វង្គីសៈក៏ដឹង ហើយបានក្រាបទូលយ៉ាងនោះ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់បង្ហាញលលាដ៍ក្បាលរបស់ព្រះខីណាស្រពដល់ព្រាហ្មណ៍ គាត់គោះរឿយៗ ក៏មិនដឹង ។ សម័យនោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលវង្គីសៈ លលាដ៍ក្បាលនេះ មិនមែនជាវិស័យរបស់អ្នក នេះជាវិស័យរបស់តថាគត នេះ គឺលលាដ៍ក្បាលរបស់ខីណាសវព្រាហ្មណ៍ ហើយត្រាស់គាថានេះថា

**គតិ មិគានំ បវនំ អាកាសោ បក្ខិនំ គតិ**
**វិភវោ គតិ ធម្មានំ និព្វានំ អរហតោ គតីតិ ។**

ព្រៃ ជាដំណើររបស់ពួកម្រឹគ អាកាស ជាដំណើររបស់ពួកបក្សី
សេចក្តីវិនាស ជាដំណើររបស់សង្ខតធម៌ទាំងឡាយ ព្រះនិព្វាន
ជាដំណើររបស់ព្រះអរហន្ត ដូច្នេះ ។

វង្គីសៈស្តាប់គាថាហើយ ទូលថា បពិត្រព្រះគោតម សូមទ្រង់ឲ្យវិជ្ជានេះដល់ខ្ញុំព្រះអង្គ ព្រះមានព្រះភាគត្រាស់ថា វិជ្ជានេះ មិនសម្រេចដល់ជន

ទាំងឡាយដែលមិនបួស ។ វង្គីសៈនោះទូលថា បពិត្រព្រះគោតម ទ្រង់ឲ្យខ្ញុំព្រះអង្គបួសហើយ សូមធ្វើវត្តដែលទ្រង់ត្រូវការ ហើយឲ្យវិជ្ជានេះដល់ខ្ញុំព្រះអង្គ ។ ខណៈនោះ និគ្រោធកប្បត្ថេរនៅក្បែរព្រះមានព្រះភាគ ព្រះមានព្រះភាគក៏ត្រាស់នឹងព្រះថេរៈថា ម្នាលនិគ្រោធកប្បៈ បើដូច្នោះ ចូរអ្នកឲ្យវង្គីសៈនេះបួស ។ ព្រះថេរៈឲ្យវង្គីសៈនោះបួសហើយ បានប្រាប់តចបញ្ចកកម្មដ្ឋាន ។ វង្គីសភិក្ខុបានជាព្រះអរហន្តសម្រេចបដិសម្ភិទាដោយលំដាប់ និងជាបុគ្គលដែលព្រះមានព្រះភាគ ទ្រង់លើកតម្កើងក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកមានបដិភាណ ស្រេចនឹងវង្គីសៈ។

ឧបជ្ឈាយ៍របស់ព្រះវង្គីសៈ ដែលហៅយ៉ាងនេះ ជាព្រះថេរៈឈ្មោះនិគ្រោធកប្បៈ ដែលបានឈ្មោះយ៉ាងនេះ ( គឺឧបជ្ឈាយ៍ ) ព្រោះជាអ្នកសម្រឹងទោសតូចធំ ។

ពាក្យថា **កប្ប** ជាឈ្មោះរបស់ព្រះថេរៈនោះ តែព្រះភគវាត្រាស់ហៅព្រះថេរៈថា និគ្រោធកប្បៈ ព្រោះលោកសម្រេចអរហត្តត្រង់គល់ជ្រៃ ។ បន្ទាប់អំពីនោះ ភិក្ខុទាំងឡាយក៏ហៅលោកយ៉ាងនោះ លោកដល់នូវភាពជាបុគ្គលមាំទាំក្នុងសាសនា ទើបឈ្មោះថា **ថេរ** ។

បទទាំងឡាយថា **អគ្គាឡវេ ចេតិយេ អចិរបរិនិព្វុតោ ហោតិ** បានដល់ និគ្រោធកប្បត្ថេរនោះនិព្វានហើយ ក្នុងកាលមិនយូរ ត្រង់អគ្គាឡវចេតិយនោះ ។

បទថា **វេហាគតស្ស បដិសល្លីនស្ស** បានដល់ ជាអ្នកមានកាយពួន

សម្ងំចាកពួកគណៈ ជាអ្នកមានចិត្តវិលត្រឡប់ចាកអារម្មណ៍នោះៗ ហើយសម្ងំ ។

បទទាំងឡាយថា **ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ** បានដល់កើតបរិវិតក្កដោយអាការយ៉ាងនេះ ។ សួរថា ព្រោះហេតុអ្វី ទើបកើតបរិវិតក្ក ឆ្លើយថា ព្រោះព្រះឧបជ្ឈាយ៍នោះមិនបាននៅចំពោះមុខ និងព្រោះលោកបានឃើញការស្និទ្ធស្នាល ។ ពិតហើយ ក្នុងពេលដែលនិគ្រោធកប្បៈនោះបរិនិព្វានវង្គីសភិក្ខុនេះ មិនបាននៅចំពោះមុខ តែការស្និទ្ធស្នាលក្នុងកាលមុន មានការរពឹសដែជាដើមរបស់ព្រះថេរៈនោះ ជាបុគ្គលដែលវង្គីសៈនោះធ្លាប់ឃើញមកហើយ ការប្រព្រឹត្តបែបនោះ រមែងមានដល់បុគ្គលដែលមិនមែនព្រះខីណាស្រព និងដល់ព្រះខីណាស្រពទាំងឡាយ ដោយអំណាចនៃវាសនា ពិតហើយ ព្រះបិណ្ឌោលភារទ្វាជៈ ទៅកាន់ឧទ្យានរបស់ព្រះបាទឧទេនប៉ុណ្ណោះ ដើម្បីជាប្រយោជន៍ដល់ការនៅក្នុងពេលថ្ងៃខាងក្រោយកត្ត ឯវាសនាក្នុងកាលមុន គឺកាលនោះ លោកធ្លាប់ជាព្រះរាជា បានស្និទ្ធស្នាលក្នុងទីនោះ ។ ព្រះគវម្បតិត្ថេរទៅកាន់ទេវវិមានទំនេរ គឺវិមានដែលមិនមានទេវតារស់នៅ ក្នុងស្ថានតាវត្តិង្ស ដោយវាសនាក្នុងកាលមុន គឺលោកជាទេវបុត្ត ធ្លាប់រស់នៅក្នុងវិមាននោះ ។

ភិក្ខុឈ្មោះបិលិន្ទវច្ឆៈហៅអ្នកដទៃថា អ្នកថោកទាប ដោយវាសនាក្នុងកាលមុន គឺលោកធ្លាប់កើតជាព្រាហ្មណ៍ ៥០០ ជាតិជាប់គ្នា មិនលាយឡំដោយកំណើតដទៃឡើយ ទើបហៅអ្នកដទៃយ៉ាងនោះ ព្រោះដូច្នោះ ទើបបរិ-

វិតក្កកើតឡើងដល់ព្រះវង្គីសត្ថេរនោះ ព្រោះលោកមិនបាននៅចំពោះមុខ តែធ្លាប់ឃើញ និងស្និទ្ធស្នាលយ៉ាងនេះថា ឧបជ្ឈាយ៍របស់អញនិព្វាន ឬមិននិព្វានហ្ន៎ អត្ថក្រៅពីនេះ មានន័យងាយយល់ហើយ ។

ក្នុងពាក្យថា **ឃកំសំ ចីវរំ កត្វា** នេះ លោកពោលយ៉ាងនេះ ដើម្បីធ្វើចីវរឲ្យហាប់ណែនរឿយៗ ។

ពាក្យថា **ឃកំសំ** នេះ ជាឈ្មោះរបស់សំពត់ដែលលោកដណ្ដប់ធៀងស្មាខាងឆ្វេង ព្រោះដូច្នោះ គប្បីជ្រាបអត្ថនៃ **ឃកំសំ** នេះ យ៉ាងនេះថា ធ្វើចីវរដោយប្រការដែលចីវរនោះ ធ្វើនូវការគ្របស្មាឆ្វេង ។ ពាក្យដ៏សេសជាក់ច្បាស់ទាំងអស់ហើយ ។

[ ៣៧ ] បទថា **អនោមបញ្ញំ** បានដល់ វត្ថុដែលទាប លោកហៅថាតូចតាច ថោកថយ នូវព្រះសាស្ដាមានបញ្ញាមិនថោកថយ អធិប្បាយថាមានបញ្ញាច្រើន ។

បទថា **ឥធេវ ធម្មេ** បានដល់ ដោយប្រចក្សនោះឯង អធិប្បាយថាក្នុងអត្តភាពនេះឯង ។

បទថា **វិចិកិច្ឆានំ** បានដល់ បរិវិតក្កបែបនោះ ។ បទថា **ញាតោ** បានដល់ ប្រាកដហើយ ។ បទថា **យសស្សី** បានដល់ ដល់ព្រមដោយលាភ និងបរិវារ ។ បទថា **អភិនិព្វុតត្តោ** បានដល់ មានចិត្តដែលខ្លួនគ្រប់គ្រងហើយ ឬមានចិត្តដែលភ្លើងមិនឆេះ ។

បទថា **តយា កតំ** សេចក្ដីថា ទ្រង់ពោលថា និគ្រោធកប្បៈ ព្រោះ

លោកអង្គុយហើយត្រង់គល់និគ្រោធ ទ្រង់បានតាំងឈ្មោះហើយ ព្រះមានព្រះភាគរមែងពិចារណាដោយព្រះអង្គដោយប្រការណា រមែងត្រាស់ហៅដោយប្រការនោះ តែទ្រង់ហៅព្រះនិគ្រោធកប្បៈយ៉ាងនោះ ព្រោះលោកអង្គុយហើយត្រង់គល់ជ្រៃនោះឯង ម្យ៉ាងទៀត ព្រោះលោកបានសម្រេចអរហត្តត្រង់គល់ជ្រៃនោះ ។

ដោយពាក្យថា **ព្រាហ្មណស្ស** ព្រះមានព្រះភាគត្រាស់សំដៅដល់ជាតិ បានឮថា និគ្រោធកប្បៈនោះ ចេញបួសអំពីត្រកូលព្រាហ្មណមហាសាល ។

បទថា **នមស្សំ អចរឹ** បានដល់ នមស្ការហើយ ។

បទថា **មុត្យបេក្ខោ** សេចក្តីថា សង្ឃឹមវិមុត្តិ ពោល គឺព្រះនិព្វាន អធិប្បាយថា ប្រាថ្នាព្រះនិព្វាន ។

ព្រះវង្គីសៈហៅព្រះមានព្រះភាគថា **ទឡ្ហធម្មទស្សី** ។ ពិតហើយ ព្រះនិព្វាន ឈ្មោះថាជាធម៌មាំទាំ ព្រោះអត្ថថា មិនបែក ព្រះមានព្រះភាគ ទ្រង់សម្តែងនិព្វាននោះ ព្រោះហេតុនោះ ទើបព្រះវង្គីសៈហៅព្រះមានព្រះភាគនោះថា **ទឡ្ហធម្មទស្សី** ។

ដោយបទថា **សក្ក** ព្រះវង្គីសៈហៅព្រះមានព្រះភាគនោះឯង ដោយគុណនាម ។

ដោយបទថា **មយម្បិ សព្វេ** ព្រះវង្គីសៈសង្គ្រោះយកបរិស័ទដ៏សេស ( តែ ) និយាយលើកខ្លួនឯងជាគោល ។

ដោយបទថា **សមន្តចក្ខុ** លោកក៏ហៅព្រះមានព្រះភាគនោះឯង ដោយ

សព្វញ្ញុតញ្ញាណ ។

បទថា **សម្មាវដ្ឋិតា** បានដល់ តាំងទុកហើយដោយប្រពៃ គឺធ្វើឲ្យជាគោល តាំងទុកហើយ ។

បទថា **នោ** ស្មើគ្នានឹង **អម្ហាកំ** ប្រែថា របស់ខ្ញុំព្រះអង្គទាំងឡាយ ។ បទថា **សវនាយ** បានដល់ ដើម្បីស្តាប់ការឆ្លើយតបបញ្ហានេះ ។ បទថា **សោតា** បានដល់ សោតិន្ទ្រិយ ។

បទថា **តុវំ នោ សត្ថា ត្វមនុត្តរោសិ** នេះ ត្រឹមតែជាពាក្យសរសើរប៉ុណ្ណោះ ។

បទទាំងឡាយថា **ឆិន្ទេវ នោ វិចិកិច្ឆំ** បានដល់ ព្រះវង្គីសៈនោះដែលអស់នូវសេចក្តីសង្ស័យហើយ ដោយការសង្ស័យក្នុងអកុសល តែក៏ពោលសំដៅដល់បរិវិតក្កនោះ ដែលប្រៀបដូចសេចក្តីសង្ស័យនោះឯង ។

បទថា **ព្រូហិ មេតំ** សេចក្តីថា បពិត្រព្រះអង្គជាសក្យៈ ខ្ញុំព្រះអង្គទូលសូមហើយ ដើម្បីឲ្យទ្រង់ប្រាប់នូវសាវកណា សូមទ្រង់ត្រាស់ប្រាប់នូវសាវកនោះដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គទាំងឡាយប្រាថ្នានឹងដឹងសាវកនោះ បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់មានបញ្ញាដូចផែនដី កាលទ្រង់ត្រាស់ ក៏សូមប្រាប់នូវព្រាហ្មណ៍នោះ ដែលបរិនិព្វានហើយ បពិត្រព្រះមានព្រះភាគ ទ្រង់មានបញ្ញាទ្រង់ជ្រាបថា ព្រះថេរៈនោះបរិនិព្វានហើយ ក៏សូមប្រាប់ក្នុងចំណោមខ្ញុំព្រះអង្គទាំងឡាយ គឺត្រាស់ប្រាប់ក្នុងកណ្តាលជំនុំនៃខ្ញុំព្រះអង្គគ្រប់គ្នា ដោយការដែលខ្ញុំព្រះអង្គទាំងឡាយគប្បីដឹងបាន ។

បទថា **សក្កោវ ទេវានំ សហស្សនេត្តោ** នេះ ជាពាក្យសរសើរប៉ុណ្ណោះ ពាក្យនេះមានអធិប្បាយដូច្នេះថា សក្កទេវរាជមានភ្នែក ១០០០ ជាអ្នកមានវាចា ដែលទេវតាទាំងនោះទទួលស្តាប់ហើយដោយគោរព រមែងត្រាស់ក្នុងកណ្តាលនៃពួកទេវតាទាំងឡាយ យ៉ាងណា បពិត្រព្រះមានព្រះភាគ ព្រះអង្គមានព្រះវាចា ដែលខ្ញុំព្រះអង្គទាំងឡាយទទួលស្តាប់ហើយ ក៏សូមត្រាស់ក្នុងកណ្តាលនៃខ្ញុំព្រះអង្គទាំងឡាយ ក៏ដូច្នោះ ។

ព្រះវង្គីសៈ កាលសរសើរព្រះមានព្រះភាគនោះឯង ដើម្បីនឹងញុំាងភាពជាអ្នកប្រាថ្នាដើម្បីពោលឲ្យកើតឡើង ទើបបានពោលគាថានេះទៀតថា **យេ កេចិ** ជាដើម ។

អត្ថនៃគាថានោះថា កិលេសជាគ្រឿងរួបរឹតទាំងឡាយ មានអភិជ្ឈាជាដើម ព្រះវង្គីសៈហៅថា ជាផ្លូវនៃមោហៈ ថាជាចំណែកនៃការមិនដឹង និងថា ជាទីតាំងនៃសេចក្តីសង្ស័យ ព្រោះមិនបានលះមោហៈ និងសេចក្តីសង្ស័យ ព្រោះមិនបានលះនូវគ្រឿងរួបរឹតទាំងនោះ គ្រឿងរួបរឹតទាំងនោះ ដល់នូវព្រះតថាគតហើយ រមែងត្រូវកម្ចាត់ បានដល់ នឹងវិនាសទៅដោយកម្លាំងនៃទេសនារបស់ព្រះតថាគត ។

សួរថា គ្រឿងរួបរឹតទាំងនោះ កម្ចាត់បានដោយហេតុអ្វី ឆ្លើយថា គន្ថកិលេសទាំងនោះមានដល់ព្រះតថាគត រមែងមិនមាន ព្រោះព្រះអង្គមានភ្នែកដ៏ឧត្តមជាងនរជនទាំងឡាយ ។ អធិប្បាយថា ព្រោះព្រះតថាគត ឈ្មោះថាជាអ្នកមានចក្ខុដ៏ឧត្តមជាងនរៈទាំងឡាយ ព្រោះធ្វើបញ្ញាចក្ខុក្នុងការកម្ចាត់គន្ថ-

ក្កិលេសទាំងពួងឲ្យកើតឡើង ។

ព្រះវង្គីសត្ថេរសរសើរព្រះមានព្រះភាគនោះឯង ដើម្បីនឹងញ៉ាំងភាពជាអ្នកប្រាជ្ញា ដើម្បីនឹងពោលឲ្យកើតឡើង ទើបពោលគាថានេះថា **ណោ ចេ ហិ ជាតុ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **ជាតុ** ជាពាក្យបញ្ជាក់ចំណែកមួយ ។ បទថា **បុរិសោ** ព្រះវង្គីសៈពោលសំដៅដល់ព្រះមានព្រះភាគ ។ បទថា **ជោតិមន្តោ** បានដល់ ជនទាំងឡាយដែលប្រកបដោយការរុងរឿង គឺបញ្ញា មានព្រះសារីបុត្តជាដើម ។ លោកពោលអធិប្បាយថា បើព្រះមានព្រះភាគមិនគប្បីកម្ចាត់កិលេសទាំងឡាយ ដោយកម្លាំងនៃទេសនា ដូចគ្នានឹងខ្យល់ មានខ្យល់ទិសខាងកើតជាដើម និងមិនគប្បីកម្ចាត់ពពកហើយសោត សត្វលោកដែលបិទបាំងដោយការមិនដឹង ក៏គប្បីជាអ្នកងងឹត ដូចលោកដែលត្រូវពពកបិទបាំង នឹងជាលោកដែលងងឹត គឺងងឹតតែមួយ ឬជនទាំងឡាយណា ដែលមានសេចក្ដីរុងរឿងក្នុងឥឡូវនេះប្រាកដ មានព្រះសារីបុត្តជាដើម សូម្បីជនទាំងឡាយនោះ ក៏មិនគប្បីក្ដៅក្រហាយ ។

ព្រះវង្គីសត្ថេរ កាលសរសើរព្រះមានព្រះភាគនោះឯង កាលនឹងញ៉ាំងភាពជាអ្នកប្រាជ្ញានឹងពោលឲ្យកើតឡើង ដោយន័យមុននោះឯង ទើបពោលគាថានេះថា **ធីរា ច** ជាដើម អត្ថនៃព្រះគាថានោះថា បុរសទាំងឡាយដែលជាអ្នកប្រាជ្ញ គឺដែលជាបណ្ឌិត ជាអ្នកធ្វើសេចក្ដីរុងរឿង រមែងឲ្យនូវសេចក្ដីរុងរឿងនៃបញ្ញាកើតឡើង បពិត្រព្រះមានព្រះភាគ ទ្រង់ក្លាហាន ប្រកបដោយ

បធានវីរិយៈ ដូច្នោះ ខ្ញុំព្រះអង្គរមែងសម្គាល់ គឺរមែងសម្គាល់ព្រះអង្គថាជាអ្នកប្រាជ្ញ និងថា ជាអ្នកធ្វើសេចក្តីរុងរឿងយ៉ាងនោះ ព្រោះថា ខ្ញុំព្រះអង្គទាំងឡាយ កាលដឹងថា ព្រះមានព្រះភាគជាអ្នកឃើញច្បាស់ គឺជាអ្នកឃើញនូវធម៌ទាំងពួងតាមសេចក្តីពិត ទើបបានចូលទៅរកព្រះអង្គយ៉ាងនេះ ព្រោះហេតុនោះ សូមទ្រង់ធ្វើឲ្យជាក់ច្បាស់ គឺសូមត្រាស់ប្រាប់ ។បេ។ បានដល់ សូមប្រកាសនូវព្រះកប្បត្ថេរ បានដល់ ព្រះនិគ្រោធកប្បៈក្នុងបរិស័ទទាំងឡាយដល់ខ្ញុំព្រះអង្គទាំងឡាយ ។

ព្រះវង្គីសៈ កាលសរសើរព្រះមានព្រះភាគនោះឯង ដើម្បីនឹងញុំាងនូវភាពជាអ្នកប្រាថ្នានឹងពោលឲ្យកើតឡើង ដោយន័យមុននោះឯង ទើបពោលគាថានេះថា **ខិប្បំ** ដូច្នេះជាដើម ។ អត្ថនៃគាថានោះថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់មានព្រះតម្រាស់ពីរោះ សូមទ្រង់មានព្រះវាចាដ៏ពីរោះដោយរួសរាន់ គឺកុំបីយឺតយូរក្នុងការត្រាស់ព្រះតម្រាស់ដ៏ពីរោះ គឺនាំមកនូវការត្រេកអរនៃចិត្ត ប្រៀបដូចសុវណ្ណហង្ស ទៅកាន់ទីរកស៊ី បានជួបស្រះដែលកើតឯង និងដងព្រៃ ទើបអើតក មិនប្រញាប់ប្រញាល់ បន្លឺសំឡេងសន្សឹមៗ ដោយចំពុះពណ៌ក្រហម គឺយំដោយសំឡេងដ៏ពីរោះ យ៉ាងណា ព្រះអង្គក៏ដូច្នោះដូចគ្នា ទ្រង់បន្លឺវាចាសន្សឹមៗ ដោយសំឡេងដ៏ពីរោះ ដែលជាមហាបុរិសលក្ខណៈមួយ ដែលទ្រង់កំណត់ល្អហើយ បានដល់ ដែលព្រះអង្គទ្រង់កំណត់ដោយល្អ ខ្ញុំព្រះអង្គទាំងពួងនេះឯង ជាអ្នកត្រង់ គឺជាអ្នកមិនមានចិត្តកាយមាយានឹងស្តាប់ព្រះសូរសៀង ដែលទ្រង់បន្លឺហើយ ។

ព្រះវង្គីសៈ កាលសរសើរព្រះមានព្រះភាគអង្គនោះឯង កាលនឹងញ៉ាំង
ភាពជាអ្នកប្រាថ្នាដែលនឹងពោលឲ្យកើតឡើងដោយន័យមុននោះឯង ទើបពោល
គាថានេះថា **បហីនជាតិមរណំ** ដូច្នេះជាដើម ។ គប្បីជ្រាបវិគ្គហៈក្នុងពាក្យ
ថា **អសេសំ** នោះថា បាបណាវមែងមិនសេសសល់ ហេតុនោះ បាបនោះ
ឈ្មោះថា **អសេស** ដែលទ្រង់ជាអ្នកកម្ចាត់បាបមិនមានចំណែកសល់នោះ មាន
ពាក្យអធិប្បាយថា ដូចព្រះអរិយៈ មានព្រះសោតាបន្នជាដើម ដែលលះនូវ
ជាតិ និងមរណៈបាន មិនមានសេសសល់ ដូច្នោះ ។

បទថា **និគ្គយ្ហ** បានដល់ អាពធនាដោយល្អហើយ ពោល គឺទូលស្នើ
ហើយ ។ បទថា **ធោនំ** បានដល់ ជាអ្នកមានបាបធម៌ទាំងពួងកម្ចាត់ហើយ ។
បទថា **វទេស្សាមិ** បានដល់ ខ្ញុំព្រះអង្គសូមឲ្យទ្រង់ត្រាស់ព្រះធម៌ ។

បាទព្រះគាថាថា **ន កាមការោ ហិ បុថុជ្ជនានំ** សេចក្ដីថា ដោយការ
ធ្វើនូវសេចក្ដីប្រាថ្នា រមែងមិនមានដល់បុថុជ្ជនទាំងឡាយប៉ុណ្ណោះ អធិប្បាយ
ថា បុថុជ្ជនប្រាថ្នានឹងដឹង ឬនឹងពោលវត្ថុណា ក៏មិនអាចដឹង ឬនឹងពោលវត្ថុ
នោះបានទាំងអស់ ។

បាទព្រះគាថាថា **សង្ខេយ្យការោ ច តថាគតានំ** សេចក្ដីថា ចំណែក
ការធ្វើការពិចារណា គឺការធ្វើដែលមានបញ្ញា ជាសភាវៈដល់មុន រមែងមាន
ដល់ព្រះតថាគតទាំងឡាយ អធិប្បាយថា ព្រះតថាគតទាំងឡាយនោះ ទ្រង់
រមែងប្រាថ្នានឹងដឹង ឬត្រាស់វត្ថុណា ក៏អាចជ្រាប ឬត្រាស់វត្ថុនោះបាន ។

ឥឡូវនេះព្រះវង្គីសៈកាលប្រកាសនូវការធ្វើការពិចារណានោះទើបពោល

គាថានេះថា **សម្បន្នវេយ្យាករណំ** ដូច្នេះជាដើម ។

អត្ថនៃព្រះគាថានោះថា បពិត្រព្រះមានព្រះភាគ ពិតហើយ វេយ្យាករណ៍ដ៏សម្បូរ ដែលមានការប្រព្រឹត្តទៅ ដែលទ្រង់ត្រាស់ល្អហើយ ដែលព្រះអង្គមានបញ្ញារុងរឿង ទ្រង់រៀនមកល្អហើយក្នុងទីនោះៗ នេះមិនខុស ជនទាំងឡាយឃើញហើយក្នុងព្រះតម្រាស់ទាំងឡាយ មានព្រះតម្រាស់យ៉ាងនេះថា សន្តតិមហាមាត្យហោះឡើងកាន់អាកាសអស់ ៧ ជួរត្នោត ហើយបរិនិព្វាន និងថា សុប្បពុទ្ធសក្យៈត្រូវផែនដីស្រូបក្នុងថ្ងៃទី ៧ ដូច្នេះ ។ បន្ទាប់អំពីនោះ ព្រះវង្គីសៈប្រណម្យអញ្ជលីឲ្យល្អក្រៃលែងឡើង ហើយទូលថា អញ្ជលីពេលនេះ ខ្ញុំព្រះអង្គប្រណម្យល្អហើយ គឺអញ្ជលីដទៃទៀតដែលខ្ញុំព្រះអង្គប្រណម្យល្អហើយ ល្អក្រៃលែងឡើង ។

បទថា **មា មោហយិ** សេចក្ដីថា ទ្រង់កាលជ្រាប គឺទ្រង់ដឹងនូវគតិកំណើតរបស់ព្រះថេរៈឈ្មោះកប្បៈ ទ្រង់កុំឲ្យខ្ញុំព្រះអង្គទាំងឡាយវង្វេង ដោយការមិនត្រាស់តបឡើយ ។ ព្រះវង្គីសៈហៅព្រះមានព្រះភាគ ដោយពាក្យថា **អនោមបញ្ញា** ។

ព្រះវង្គីសៈ កាលទូលអារាធនាព្រះមានព្រះភាគ ឲ្យធ្វើនូវការមិនវង្វេងនោះឯង ដោយបរិយាយដទៃ ទើបពោលគាថានេះថា **បរោវរំ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **បរោវរំ** បានដល់ ដែលស្អាត និងដែលមិនស្អាត ឬដែលនៅឆ្ងាយ និងដែលនៅជិត ដោយអំណាចនៃលោកិយធម៌ និងលោកុត្តរធម៌ ។

បទថា **អរិយធម្មំ** បានដល់ ចតុសច្ចធម៌ ។ បទថា **វិធិត្វា** បានដល់ ចាក់ធ្លុះ ។ បទថា **ជានំ** បានដល់ ទ្រង់ដឹងនូវញេយ្យធម៌ទាំងពួង ។

បទថា **វាចាភិកង្ខាមិ** បានដល់ ខ្ញុំព្រះអង្គទន្ទឹងនូវព្រះវាចារបស់ព្រះអង្គ ដូចបុរសដែលមានខ្លួនក្ដៅក្នុងរដូវក្ដៅ ដល់នូវសេចក្ដីលំបាក អន្ទះអន្ទែងហើយ ទន្ទឹងនូវទឹក ដូច្នោះ ។

បទថា **សុតម្បវស្ស** បានដល់ សូមទ្រង់កុំរារែក គឺសូមបន្ទឺ បានដល់ បង្ហើបនូវសទ្ទាយតនៈ ពោល គឺសុតៈ គឺធ្វើសទ្ទាយតនៈឲ្យប្រព្រឹត្តទៅ ។

ព្រះបាលីថា **សុតស្សំ វស្ស** ដូច្នេះក៏មាន អធិប្បាយថា សូមបន្លឺនូវភ្លៀង គឺសទ្ទាយតនៈ មានប្រការដែលទ្រង់ត្រាស់ហើយ ។

ឥឡូវនេះ ព្រះវង្គីសៈទន្ទឹងនូវវាចាបែបណា កាលនឹងប្រកាសនូវវាចាបែបនោះ ទើបពោលគាថានេះថា

និគ្រោធកប្បភិក្ខុ បានប្រព្រឹត្តព្រហ្មចរិយធម៌ដ៏មានប្រយោជន៍ណា
ព្រហ្មចរិយៈនោះរបស់លោក មិនឥតប្រយោជន៍តិចតួចឡើយ
លោកនោះ បាននិព្វាន ដូចព្រះអសេក្ខបុគ្គល ដែលមានចិត្តផុត
ហើយ ឬជាសឧបាទិសេសៈ ( ដូចជាសេក្ខបុគ្គល ) ពួកខ្ញុំ
ព្រះអង្គប្រុងស្ដាប់នូវព្រះបន្ទូលរបស់ព្រះអង្គនោះ ។

ព្រះវង្គីសៈហៅព្រះថេរៈឈ្មោះកប្បៈនោះឯង ដោយអំណាចនៃការបូជានោះឯងថា កប្បាយនៈ ។

បទថា **យថា វិមុត្តោ** បានដល់ ព្រះវង្គីសៈទូលសួរថា ព្រះកប្បាយ-

នត្ថេរនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ដូចព្រះអសេក្ខៈទាំងឡាយ ឬថា និព្វានហើយ ដោយសឧបាទិសេសនិព្វានធាតុ ដូចព្រះសេក្ខៈទាំង-ឡាយ ។ ពាក្យដ៏សេស ក្នុងគាថានេះ ជាក់ច្បាស់ហើយទាំងអស់ ។

ព្រះមានព្រះភាគ កាលព្រះវង្គីសៈទូលអារាធនាហើយ ដោយ ១២ គាថាយ៉ាងនេះ កាលទ្រង់ព្យាករវៀងនោះ ទើបត្រាស់ថា

និគ្រោធកប្បភិក្ខុ បានកាត់ផ្តាច់នូវតណ្ហា ក្នុងនាម និងរូបនេះ ជាខ្សែធមិខ្មៅ គឺកិលេសមារ ដែលដេកត្រាំអស់រាត្រីជាអង្វែង បានឆ្លងផុតការកើត និងការស្លាប់ មិនមានសេសសល់ ព្រះមានព្រះភាគ ប្រសើរជាងបញ្ចវគ្គិយភិក្ខុ បានត្រាស់ព្យាករ ដោយប្រការដូច្នេះ ។

ក្នុងព្រះគាថានោះ បាទដំបូងមានអត្ថដូច្នេះថា តណ្ហា មានកាមតណ្ហាជាដើម ក្នុងនាមរូបនេះ ដេកត្រាំហើយអស់កាលយូរ ព្រោះអត្ថថា ដែលបុគ្គលលះមិនបានហើយ លោកហៅថា ក្រសែនៃមារ ដែលបានឈ្មោះថា **កណ្ហ** ដូច្នេះក៏មាន ។ ព្រះថេរៈឈ្មោះកប្បាយនៈ កាត់ហើយនូវតណ្ហាក្នុងនាមរូបនេះ ដែលដេកត្រាំអស់កាលយូរ ដែលជាក្រសែនៃកណ្ហមារនោះ ។

បទថា **ឥតិ ភគវា** នេះ ក្នុងគាថានេះ ជាពាក្យរបស់ព្រះសង្គីតិកាចារ្យទាំងឡាយ ។ ដោយបាទព្រះគាថាថា **អតារិ ជាតឹ មរណំ អសេសំ** ព្រះមានព្រះភាគទ្រង់សម្តែងថា ព្រះកប្បាយនត្ថេរនោះបានកាត់ហើយនូវតណ្ហានោះ បានឆ្លងហើយនូវជាតិ និងមរណៈមិនមានចំណែកសេសសល់ បរិនិព្វាន

ហើយ ដោយអនុបាទិសេសនិព្វានធាតុ ។

បាទព្រះគាថាថា **ឥច្ចព្រវិ ភគវា បញ្ចសេដ្ឋោ** សេចក្ដីថា ព្រះមានព្រះភាគប្រសើរជាងបញ្ចវគ្គិយដែលជាសិស្សមុនគេ ៥ អង្គដោយឥន្ទ្រិយទាំង ៥ មានសទ្ធាជាដើម ឬដោយធម្មក្ខន្ធទាំងឡាយ មានសីលជាដើម ។ និងជាបុគ្គលប្រសើរដោយចក្ខុដែលប្រសើរក្រៃលែង ដែលព្រះវង្គីសៈទូលសួរហើយបានត្រាស់ហើយយ៉ាងនេះ ។ ពាក្យនេះជាពាក្យរបស់សង្គីតិកាចារ្យ ។

ព្រះមានព្រះភាគ កាលត្រាស់យ៉ាងនេះហើយ ព្រះវង្គីសៈកាលសរសើរភាសិតរបស់ព្រះមានព្រះភាគ ទើបពោលគាថាថា **ឯស សុត្វា** ដូច្នេះ ។

ក្នុងគាថានោះ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១ ដូច្នេះ បទថា **ឥសិ-សត្តម** សេចក្ដីថា ព្រះមានព្រះភាគជាឥសីផង ជាទី ៧ ផង ព្រោះអត្ថថាឧត្តម ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់ធ្វើឥសី ៦ អង្គ មានព្រះនាមវិបស្សី សិខី វេស្សភូ កកុសន្ធៈ កោនាគមនៈ និងកស្សបៈ ឲ្យទ្រង់ជាទី ៧ ប្រាកដទើបព្រះមានព្រះភាគ ជាឥសីអង្គទី ៧ ព្រះវង្គីសៈកាលហៅព្រះមានព្រះភាគអង្គនោះថា ជាឥសីទី ៧ ទើបបានពោលហើយ ។

ពីរបទថា **ន មំ វញ្ចេសិ** សេចក្ដីថា ព្រោះព្រះកប្បាយនត្ថេរបរិនិព្វានហើយ ដូច្នោះ ព្រះអង្គមិនបោកបញ្ឆោតខ្ញុំព្រះអង្គ ដែលប្រាថ្នាដើម្បីដឹងភាពដែលព្រះកប្បាយនត្ថេរបរិនិព្វាន គឺសូមទ្រង់កុំត្រាស់ឲ្យខុស ។ ពាក្យដ៏សេសក្នុងគាថានេះ ប្រាកដហើយ ។

ក្នុងគាថាទី ២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅ

ព្រោះហេតុដែលសាវករបស់ព្រះពុទ្ធ ទន្ទឹងការរួចផុតហើយ ដូច្នោះ ព្រះវង្គីសត្ថេរពោលសំដៅយកអត្ថនោះថា សាវករបស់ព្រះពុទ្ធជាអ្នកមានប្រក្រតីពោលយ៉ាងណា ក៏ធ្វើយ៉ាងនោះ ។

បាទព្រះគាថាថា **មច្ចុនោ ជាលំ តតំ** បានដល់ សំណាញ់ គឺតណ្ហារបស់មារដែលផ្សាយចេញទៅហើយក្នុងវដ្ដៈ ដែលប្រកបដោយភូមិ ៣ នោះ ។

បទថា **មាយាវិនោ** បានដល់ ដែលមានមាយាច្រើន ។ អាចារ្យពួកខ្លះពោលថា **តថា មាយាវិនោ** ដូច្នេះក៏មាន អធិប្បាយរបស់អាចារ្យទាំងឡាយយ៉ាងនេះថា មារណា ចូលគាល់ព្រះមានព្រះភាគច្រើនដងរាប់មិនអស់ដោយមាយាទាំងឡាយជាអនេករបស់មារនោះ គឺអ្នកមានមាយាដូចមារនោះ ។

ក្នុងគាថាទី ៣ មានវិនិច្ឆ័យដូច្នេះថា បទថា **អាទិ** បានដល់ ហេតុ ។ បទថា **ឧបាទានស្ស** បានដល់ នៃវដ្ដៈ ។ ពិតហើយ វដ្ដៈ លោកពោលថាជាឧបាទានក្នុងទីនេះ ព្រោះអត្ថថា ដែលសត្វគប្បីប្រកាន់មាំ ។

ព្រះវង្គីសត្ថេរ ពោលដោយបំណងថា បពិត្រព្រះមានព្រះភាគ ទ្រង់គួរនឹងត្រាស់យ៉ាងនេះថា កប្បត្ថេរបានឃើញហើយ នូវហេតុនៃឧបាទាននោះឯង គឺនូវហេតុ មានអវិជ្ជា និងតណ្ហាជាដើម ។

បទថា **អច្ចគា វត** បានដល់ ឈានកន្លងហើយហ្ន៎ ។

ក្នុងពាក្យថា **មច្ចុធេយ្យំ** មានវិគ្គហៈថា ដែលឈ្មោះថា អន្ទាក់នៃមារ ព្រោះអត្ថថា ជាទីតាំងនៃមច្ចុ ។

ពាក្យថា **មច្ចុធេយ្យំ** នេះ ជាឈ្មោះនៃវដ្ដៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ព្រះវង្គីសៈកើតនូវការដឹងឡើងហើយ ទើបពោលថា ព្រះកប្បាយនត្ថេរបាន កន្លងនូវអន្ទាក់មារនោះ ដែលឆ្លងបានដោយក្រហ្ម ពាក្យដ៏សេស ក្នុងគាថា នេះ ជាក់ច្បាស់ហើយទាំងអស់នោះឯង ៕□

**អដ្ឋកថាវង្គីសសូត្រទី ១២ ចប់**

# សុត្តន្តបិដក

## សម្មាបរិព្វាជនិយសូត្រទី ១៣

[ ៣៨ ] ( ព្រះពុទ្ធនិម្មិត ទ្រង់សួរថា ) ខ្ញុំសូមសួរនូវព្រះមុនី ដែលមានប្រាជ្ញាច្រើន បានឆ្លងចាកឱឃៈ ( ដល់នូវត្រើយ គឺ ព្រះនិព្វាន ) បានរម្ងាត់ហើយ មានព្រះហឫទ័យតាំងនៅមាំ ភិក្ខុ បន្ទោបង់នូវកាមទាំងឡាយ ហើយចេញចាកផ្ទះ ភិក្ខុនោះឈ្មោះ ថា វៀរដោយប្រពៃក្នុងលោក តើដោយប្រការដូចម្តេច ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) ភិក្ខុណា បានគាស់រម្លើងនូវ មង្គលផង នូវការប្រកាន់ឧប្បាត ( មានរន្ទះបាញ់ជាដើម ) ផង នូវការប្រកាន់យល់សប្តិផង នូវការប្រកាន់លក្ខណៈផង ភិក្ខុ នោះ ឈ្មោះថា បានលះបង់ស្រឡះនូវមង្គល ជាទោស ភិក្ខុ នោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

ភិក្ខុបន្ទោបង់នូវតម្រេកក្នុងកាមទាំងឡាយ ជារបស់មនុស្សផង របស់ទេវតាផង កន្លងនូវភព បានត្រាស់ដឹងនូវធម៌ ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

ភិក្ខុធ្វើចិត្តមិនឲ្យត្រេកអរ លះនូវពាក្យញុះញង់ទាំងឡាយ នូវ សេចក្តីក្រោធ និងសេចក្តីកំណាញ់ លះនូវពគៈ និងទោសៈ ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

ភិក្ខុលះបង់នូវសេចក្តីស្រឡាញ់ និងស្អប់ មិនប្រកាន់មាំ មិន អាស្រ័យក្នុងសភាវៈតិចតួច ( ដោយតណ្ហា និងទិដ្ឋិ ) ឡើយ

មានចិត្តផុតស្រឡះហើយ ចាកសំយោជនិយធម៌ទាំងឡាយ ( ធម៌ជាអារម្មណ៍នៃសំយោជនៈ ) ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

ភិក្ខុនោះបន្ទោបង់នូវឆន្ទរាគ ក្នុងខន្ធជាគ្រឿងប្រកាន់ មិនដល់ ( នូវការឃើញ ) ថា មានខ្លឹមក្នុងឧបធិ គឺខន្ធទាំងឡាយនោះ ជាបុគ្គលមិនអាស្រ័យ ( ដោយឆន្ទៈ និងរាគៈ ) មិនបាច់មានបុគ្គលដទៃណែនាំឡើយ ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

ភិក្ខុមិនភ្ជាត់ខុសដោយកាយ វាចា និងចិត្ត ដឹងច្បាស់នូវធម៌ដោយប្រពៃ ប្រាថ្នាយកនូវបទ គឺព្រះនិព្វាន ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

ភិក្ខុណា មិនក្រអឺតក្រឱង ដោយគិតថា គេថ្វាយបង្គំអញ សូម្បីគេជេរ ក៏មិនតបត បាននូវភោជនរបស់អ្នកដទៃឲ្យ ក៏មិនស្រវឹង ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

ភិក្ខុលះបង់សេចក្ដីលោភ និងភព វៀរចាកការកាប់កាត់ និងការចង ( សត្វដទៃ ) ភិក្ខុនោះ ជាអ្នកឆ្លងផុតចាកសេចក្ដីងឿងឆ្ងល់ ប្រាសចាកសរ គឺសេចក្ដីសោក ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

ភិក្ខុណា បានដឹងច្បាស់ នូវសេចក្ដីប្រព្រឹត្តដ៏សមគួរ របស់ខ្លួន

ផង មិនបៀតបៀនជនដទៃណាមួយក្នុងលោកផង ដឹងច្បាស់នូវធម៌តាមសេចក្តីពិត ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

អនុស័យទាំងឡាយណាមួយ មិនមានដល់ភិក្ខុណា អកុសលមូលទាំងឡាយ ភិក្ខុណា បានដកចោលហើយ ភិក្ខុនោះ ជាអ្នកមិនមានសេចក្តីប្រាថ្នា មិនមានសេចក្តីអាឡោះអាល័យ ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

ភិក្ខុអ្នកអស់អាសវៈហើយ លះបង់នូវមានះ កន្លងផុតនូវធម៌ជាគន្លងនៃរាគៈទាំងអស់ ទូន្មានខ្លួន សម្រេចនូវព្រះនិព្វាន មានចិត្តតាំងនៅមាំ ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

ភិក្ខុអ្នកមានសទ្ធា ប្រកបដោយសុតៈ ប្រព្រឹត្តទៅក្នុងបរមត្ថបានឃើញសម្មត្តនិយាម គឺមគ្គ កាលពួកសត្វប្រព្រឹត្តទៅដោយទិដ្ឋិ ៦២ ក៏មិនប្រព្រឹត្តទៅដោយពួក ជាអ្នកប្រាជ្ញ អាចបន្ទោបង់នូវលោភៈ ទោសៈ និងសេចក្តីថ្នាំងថ្នាក់ ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

ភិក្ខុបានឈ្នះកិលេស ដោយអរហត្តមគ្គដ៏បរិសុទ្ធ បើកចេញនូវកិលេសជាគ្រឿងប្រក់ ជាអ្នកស្ទាត់ក្នុងចតុសច្ចធម៌ ដល់នូវត្រើយ គឺព្រះនិព្វាន មានសន្តានមិនរំភើបដោយតណ្ហា ជាអ្នកឈ្លាសវៃក្នុងអរិយមគ្គ គ្រឿងដឹងនូវធម៌ជាទីរលត់នៃសង្ខារ

ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

ភិក្ខុកន្លងនូវកប្បៈ គឺតណ្ហា និងទិដ្ឋិក្នុងខន្ធទាំងឡាយ ដែលជាអតីត និងអនាគត ជាអ្នកមានប្រាជ្ញាដ៏បរិសុទ្ធ ព្រោះកន្លងផុត ( នូវអទ្ធា ៣ ) មានចិត្តផុតស្រឡះចាកអាយតនៈទាំងពួង ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

ភិក្ខុកំណត់ដឹងនូវបទ គឺសច្ចៈមួយៗ ហើយត្រាស់ដឹងនូវសច្ចធម៌ ឃើញនូវព្រះនិព្វានមិនមានគ្រឿងដោតក្រង ជាទីលះបង់នូវអាសវៈទាំងឡាយ ព្រោះអស់ទៅនៃឧបធិកិលេសទាំងពួង ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

( ព្រះពុទ្ធនិម្មិតពោលសរសើរថា ) សេចក្តីពិតថា ព្រះមានព្រះភាគទ្រង់ត្រាស់ព្រះពុទ្ធដីកាយ៉ាងនេះ មានសេចក្តីបែបនោះដដែលថា ភិក្ខុណា មានការនៅយ៉ាងនេះ ជាអ្នកទូន្មានខ្លួន ប្រព្រឹត្តកន្លងនូវសំយោជនិយធម៌ទាំងពួង ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

**សម្មាបរិព្វាជនិយសូត្រទី ១៣ ចប់**

# អដ្ឋកថា

## សម្មាបរិព្វាជនិយសូត្រ

[ ៣៨ ] ក្នុងសម្មាបរិព្វាជនិយសូត្រទី ១៣ មានពាក្យផ្ដើមថា **បុច្ឆាមិ មុនឹ បហូតបញ្ញំ** ដូច្នេះ ។

*លោកហៅថា មហាសមយសូត្រក៏មាន ព្រោះពោលក្នុងថ្ងៃមហាសម័យ សួរថា សូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា សូត្រនេះ មានអត្ថុប្បត្តិហេតុ ព្រោះមានពាក្យសួរ ព្រោះថា ព្រះមានព្រះភាគត្រូវពុទ្ធនិម្មិតសួរ ទើបបានត្រាស់ព្រះសូត្រនេះ មួយអន្លើដោយពាក្យសួរព្រះសូត្រនោះ ទើបលោកហៅថា សម្មាបរិព្វាជនិយសូត្រក៏មាន ។ សេចក្ដីសង្ខេបក្នុងព្រះសូត្រនេះ មានប្រមាណប៉ុណ្ណេះ ។ ឯដោយពិស្ដារនោះ បុរាណាចារ្យបានពណ៌នាតាំងអំពីការកើតនៃសាកិយវង្ស និងកោលិយវង្ស ពណ៌នាត្រឹមឧទ្ទេសក្នុងរឿងនេះ មានដូចតទៅនេះ*

*កាលបឋមកប្ប ព្រះបាទមហាសម្មតិរាជ មានព្រះឱរសព្រះនាមរោជៈ ព្រះបាទរោជៈ មានព្រះឱរសព្រះនាមវររោជៈ ព្រះបាទវររោជៈ មានព្រះឱរសព្រះនាមកល្យាណ ព្រះបាទកល្យាណ មានព្រះឱរសព្រះនាមវរកល្យាណ ព្រះបាទវរកល្យាណ មានព្រះឱរសព្រះនាមមន្ធាតុ ។ ព្រះបាទមន្ធាតុ មានព្រះឱរសព្រះនាមវរមន្ធាតុ ព្រះបាទវរមន្ធាតុ មានព្រះឱរសព្រះនាមឧបោសថ ព្រះបាទឧបោសថ មានព្រះឱរសព្រះនាមចរៈ ព្រះបាទចរៈ មានព្រះឱរសព្រះនាមឧបចរៈ ព្រះបាទឧបចរៈ មានព្រះឱរសព្រះនាមមឃាទេវៈ បន្តអំពីព្រះបាទមឃាទេវៈនោះ មានក្សត្រ ៨៤០០០ អង្គបន្តមក បន្ទាប់អំពីក្សត្រ*

៨៤០០០ អង្គនោះ មានវង្សឱក្កាករាជ ៣ វង្ស ។ ព្រះបាទឱក្កាករាជអង្គទី ៣ មានមហេសី ៥ អង្គ គឺព្រះនាងហត្ថា ១ ព្រះនាងចិត្តា ១ ព្រះនាងជន្តុ ១ ព្រះនាងជាលិនី ១ ព្រះនាងវិសាខា ១ មហេសីមួយអង្គៗ មានបរិវារ ៥០០ ។

មហេសីអង្គធំមានឱរស ៤ អង្គ គឺព្រះបាទឱក្កាមុខ ១ ព្រះបាទកាកណ្ឌៈ ១ ព្រះបាទហត្ថិនិកៈ ១ ព្រះបាទនិបុរៈ ១ ។ មានធីតា ៥ អង្គ គឺព្រះនាងបិយា ១ ព្រះនាងសុប្បិយា ១ ព្រះនាងអានន្ទា ១ ព្រះនាងវិជិតា ១ ព្រះនាងវិជិតសេនា ១ ។ កាលមហេសីអង្គធំបានព្រះឱរស និងព្រះធីតា ៩ អង្គហើយ ក៏អស់ព្រះជន្ម ។

ព្រះរាជាក៏នាំរាជធីតាដទៃដែលនៅវ័យក្មេង មានរូបឆោមលោមពណ៌ល្អ មកតាំងទុកក្នុងតំណែងអគ្គមហេសី ។ អគ្គមហេសីបានប្រសូតព្រះឱរសមួយអង្គ កាលប្រសូតបាន ៥ ថ្ងៃ ពួកមេដោះបានតាក់តែងព្រះជន្តុកុមារ ហើយនាំមកគាល់ព្រះរាជា ។ ព្រះរាជាទ្រង់ត្រេកអរ បានប្រទានពរដល់មហេសី ។ ព្រះនាងក៏ប្រឹក្សាជាមួយបណ្ដាញាតិ ទូលសូមរាជសម្បត្តិឲ្យដល់រាជបុត្តរបស់នាង ។ ព្រះរាជាទ្រង់ពិរោធត្រាស់ថា ស្រីថោកទាប ចូរនាងវិនាសចុះ នាងប្រាថ្នាឲ្យកូនរបស់យើងបានទទួលអន្តរាយ ហើយមិនព្រះរាជទានតាមដែលនាងទូលសូម ។ អគ្គមហេសីលួងលោមព្រះរាជាក្នុងទីស្ងាត់រឿយៗ កាលឲ្យទ្រង់ពេញព្រះហឫទ័យហើយ ទូលថា បពិត្រព្រះអង្គ ទ្រង់មិនគួរពោលកុហក ទូលអង្វរហើយអង្វរទៀត ។

លំដាប់នោះ ព្រះរាជាត្រាស់ហៅព្រះឱរសទាំងឡាយមកហើយ ត្រាស់

ថា នែកូនទាំងឡាយ ឪពុកឃើញជន្តុកុមារប្អូនប្រុសរបស់ពួកកូន ចាប់រួស រាន់ឲ្យពរដល់មាតារបស់ជន្តុកុមារ នាងបំណាងឲ្យឱរសគ្រងរាជសម្បត្តិ អំណឹះឥតអំពីឪពុកទៅ ឯងទាំងឡាយគប្បីមកគ្រប់គ្រងរាជសម្បត្តិចុះ ហើយក៏បញ្ជូនទៅជាមួយនឹងអមាត្យ ៨ នាក់ ព្រះរាជកុមារទាំងនោះ បាននាំបងប្អូនប្រុសស្រីចេញពីនគរ មួយអន្ទើដោយចតុរង្គសេនា ។ ពួកអ្នកនគរដឹងថា ព្រះរាជកុមារនឹងយាងចេញមកគ្រងរាជសម្បត្តិ អំណឹះឥតពីបិតា ដូច្នេះហើយ ទើបគិតថា ពួកយើងនឹងជាប់តាមឧបដ្ឋាកព្រះរាជកុមារទាំងនោះ ក៏នាំគ្នាតាមទៅដោយច្រើន ។ ក្នុងថ្ងៃដំបូង មានពួកសេនាមួយយោជន៍ ក្នុងថ្ងៃទី ២ ប្រមាណ ២ យោជន៍ ក្នុងថ្ងៃទី ៣ ប្រមាណ ៣ យោជន៍ ។

ព្រះរាជកុមារទាំងឡាយទ្រង់ត្រិះរិះថា ពលនិកាយមានច្រើន បើអញលើកទៅវាយដណ្តើមព្រះរាជាជិតខាងណាមួយ ដណ្តើមយកស្រុក ឬនគរជនបទទាំងអស់ ព្រះរាជាទាំងនោះនឹងចាញ់អញ តែប្រយោជន៍អ្វីដោយរាជ-សម្បត្តិដែលបានមកព្រោះបៀតបៀនអ្នកដទៃ ជម្ពូទ្វីបក៏ធំទូលាយ អញនឹងសាងនគរក្នុងព្រៃ ដូច្នេះហើយ ទើបនាំគ្នាបែរមុខទៅកាន់ព្រៃហិមពាន្ត ។

ត្រង់ព្រៃហិមពាន្តមានតាបសឈ្មោះកបិលៈ មានតបៈខ្លាំងក្លា នៅអាស្រ័យក្នុងព្រៃសាកៈ ក្បែរមាត់ស្រះបោក្ខរណី ព្រះរាជកុមារស្វែងរកទីសាងព្រះនគរ បានទៅដល់លំនៅរបស់តាបសនោះ ។ តាបសឃើញព្រះរាជកុមារទាំងនោះ ទើបសួរ កាលជ្រាបរឿងរ៉ាវទាំងអស់ ក៏ធ្វើការអនុគ្រោះព្រះរាជកុមារទាំងនោះ ។ បានឮថា តាបសនោះចេះខាងភូមិជយវិទ្យា ឃើញ

គុណ និងទោសក្នុងអាកាស ៨០ ហត្ថ ខាងក្រោមផែនដី ៨០ ហត្ថ ។ ក្នុងភូមិបទេសនោះ ជ្រូក និងម្រឹគទាំងឡាយ ធ្វើឲ្យរាជសីហ៍ និងខ្លាជាដើមតក់ស្លុត ភ័យខ្លាច រត់ត្រឡប់ទៅ កង្កែប និងកណ្តុរទាំងឡាយ ក៏ធ្វើឲ្យពស់ភ័យខ្លាច ។ តាបសកាលឃើញសត្វទាំងនោះ គិតថា ភូមិបទេសនេះ ជាទីកដីដ៏ប្រសើរ ទើបសាងអាស្រមក្នុងទីនោះ ។ គ្រានោះ តាបសបានទូលព្រះរាជកុមារថា បើទ្រង់សាងព្រះនគរ ដាក់ឈ្មោះរបស់ទូលបង្គំ ទូលបង្គំនឹងឲ្យទីនេះដល់ទ្រង់ទាំងឡាយ ។ ព្រះរាជកុមារទ្រង់ទទួលពាក្យតាបស ។ តាបសពោលថា សូម្បីកូនចណ្ឌាលដែលស្ថិតនៅក្នុងទីនោះ ក៏នឹងសង្កត់សង្កិនស្តេចចក្កពត្តិដោយកម្លាំងបាន ហើយក្រាបទូលបន្តថា សូមទ្រង់ទាំងឡាយសាងព្រះរាជមន្ទីរ សាងព្រះនគរក្នុងទីតាំងអាស្រមចុះ កាលតាបសថ្វាយទីនោះហើយ ខ្លួនឯង ក៏ធ្វើអាស្រមត្រង់ជើងភ្នំ មិនឆ្ងាយប៉ុន្មាន ។ បន្ទាប់អំពីនោះ ព្រះរាជកុមារទាំងឡាយ ក៏សាងព្រះនគរក្នុងទីនោះ ឲ្យចារឹកឈ្មោះថា កបិលពស្តុ ព្រោះកបិលតាបសប្រទានឲ្យ ហើយអាស្រ័យនៅក្នុងនគរកបិលពស្តុនោះ ។

លំដាប់នោះ ពួកអមាត្យគិតថា ព្រះរាជកុមារទាំងនេះ ចម្រើនវ័យហើយ បើនៅក្នុងសម្នាក់របស់ព្រះបិតា ក៏នឹងធ្វើអាវាហមង្គល និងវិវាហមង្គល តែឥឡូវនេះ ជាភាររបស់ពួកយើង ទើបនាំគ្នាទៅទូលប្រឹក្សាជាមួយព្រះរាជកុមារ ។ ព្រះរាជកុមារត្រាស់ថា យើងមិនបានឃើញធីតារបស់ក្សត្រដទៃ ស្មើដោយពួកយើង ហើយយើងមិនឃើញខត្តិយកុមារដទៃ ស្មើដោយ

ព្រះជេដ្ឋកគិនី និងព្រះកនិដ្ឋកគិនីទាំងនេះឡើយ ម្យ៉ាងទៀត យើងមិនឲ្យជាតិលាយឡំគ្នា ។ ព្រោះខ្លាចការលាយឡំដោយជាតិ ទើបតាំងព្រះជេដ្ឋកគិនីក្នុងឋានៈព្រះមាតា ហើយអភិសេកផ្សំផ្គុំព្រះកនិដ្ឋកគិនីជាគូៗ គ្នាទៅ ។

ព្រះបិតារបស់ព្រះរាជកុមារទាំងនោះ កាលទ្រង់ជ្រាបរឿងរ៉ាវទាំងអស់ហើយ ទ្រង់បន្លឺឧទានថា **សក្យ សក្យ** ។ នេះជារឿងរ៉ាវដែលកើតឡើងហើយនៃសក្យវង្ស ។ សមដូចព្រះមានព្រះភាគត្រាស់ថា

ម្នាលអម្ពដ្ឋៈ គ្រានោះ ព្រះបាទឧក្កាករាជ បានត្រាស់ហៅពួកអមាត្យដែលជារាជបរិវារមកថា ម្នាលអ្នកទាំងឡាយដ៏ចម្រើនឥឡូវនេះ កុមារទាំងឡាយទៅនៅក្នុងទីណា ។ ពួករាជអមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព មានដងព្រៃ ឈ្មោះមហាសាក នៅទៀបឆ្នេរនៃស្រះបោក្ខរណី ជិតខាងហិមវន្តប្បទេសឥឡូវនេះ ពួកព្រះរាជកុមារទៅនៅក្នុងដងព្រៃនោះ ព្រះរាជកុមារទាំងនោះ សម្រេចការនៅរួមជាមួយនឹងពួកព្រះភគិនីរបស់ខ្លួនដោយការខ្លាចក្រែងក្លាយខូចជាតិ ។ ម្នាលអម្ពដ្ឋៈ គ្រានោះ ព្រះបាទឧក្កាករាជ ក៏បន្លឺនូវព្រះឧទានវាចាថា **សក្យា វត ភោ កុមារា បរមសក្យា វត ភោ កុមារា** អើហ្ន៎ កុមារទាំងឡាយ ពេញជាអង់អាច អើហ្ន៎ កុមារទាំងឡាយ ពេញជាមោះមុតមែន ។ ម្នាលអម្ពដ្ឋៈ ចាប់ដើមអំពីកាលនោះមក ពួកសក្យវង្សក៏កើតប្រាកដឡើង ។ ព្រះបាទឧក្កាករាជនោះហើយ ជាបុព្វបុរសរបស់ពួកសក្យៈ

ដូច្នេះ ។

ក្នុងកាលតមក បុត្រីច្បងរបស់កុមារទាំងនោះ បានកើតរោគឃ្លង់ ព្រះវរកាយប្រាកដដូចផ្ការលួសផ្អុង ។ ព្រះរាជកុមារទាំងឡាយ ទ្រង់ព្រះតម្រិះថា រោគនេះ រមែងឆ្លងដល់បុគ្គលដែលអង្គុយ ឈរ និងបរិភោគរួមជាមួយព្រះជេដ្ឋកតិនីអង្គនេះ ដូច្នេះហើយ ទើបទូលយាងព្រះនាងឲ្យយាងឡើងលើរថ ធ្វើដូចជាទៅប្រពាតឧទ្យាន ហើយនាំចូលទៅក្នុងព្រៃ ឲ្យជីកអណ្ដូងជ្រៅ ធ្វើជាផ្ទះក្រោមដី ដាក់ព្រះនាងក្នុងទីនោះ មួយអន្លើដោយរបស់គួរទំពា និងគួរបរិភោគ បិទខាងលើ លុបដោយធូលី ហើយយាងទៅ ។

សម័យនោះ ព្រះរាជាព្រះនាមរាមៈ បានកើតរោគឃ្លង់ ត្រូវពួកស្នំនិងពួកអ្នករបាំទាំងគ្នារង្កៀស ទ្រង់សង្វេគ ក៏ប្រគល់រាជសម្បត្តិឲ្យព្រះរាជឱរសច្បង ហើយចូលទៅក្នុងព្រៃ សោយមើមឈើ និងផ្លែឈើក្នុងព្រៃនោះ មិនយូរប៉ុន្មានក៏ជាសះស្បើយ មានពណ៌សម្បុរដូចមាស យាងទៅតាមទីផ្សេងៗទតឃើញដើមឈើមានប្រហង់ធំ ទ្រង់សម្អាតប្រហង់ឈើនោះប្រមាណ ១៦ ហត្ថខាងក្នុងប្រហង់នោះ ទ្រង់ធ្វើទ្វារ និងបង្អួច ហើយដាក់ជណ្ដើរ ប្រថាប់នៅក្នុងប្រហង់ឈើនោះ ទ្រង់បង្កាត់ភ្លើងត្រង់រណ្ដៅរងើកភ្លើង ហើយផ្ទំ បានឮសំឡេងខ្សឹកខ្សួល និងសំឡេងគំរាមក្នុងរាត្រី ទ្រង់កំណត់ថា ត្រង់នោះ រាជសីហ៍បន្លឺសំឡេង ត្រង់នោះ ខ្លាធំគ្រហឹម ដូច្នេះហើយ លុះភ្លឺឡើង ក៏យាងទៅក្នុងទីនោះ ទ្រង់កាន់យក ដុំសាច់ដែលជាវិពាមកអាំងសោយ ។

ថ្ងៃមួយ ពេលទៀបភ្លឺ ទ្រង់ប្រថាប់គង់ដុតភ្លើង ខណៈនោះ ខ្លាធំបាន

ក្និនព្រះរាជធីតា ទើបកាយដីនោះ ធ្វើឲ្យជាប្រហោងលើបន្ទះក្តារ ព្រះនាងទ្រង់ឃើញតាមប្រហោងនោះ ព្រះនាងក៏ភិតភ័យ ក៏ស្រែកភ្ញាត់សំឡេង ។ ព្រះរាជាទ្រង់ស្តាប់សំឡេងនោះ ទ្រង់កំណត់ថា នុ៎ះជាសំឡេងស្រី ដូច្នេះហើយ ទើបយាងទៅទីនោះអំពីព្រលឹម ត្រាស់សួរថា អ្នកណានៅក្នុងទីនេះ ព្រះនាងឆ្លើយថា មនុស្សស្រី ។ ព្រះរាជាត្រាស់ថា មកចុះ ព្រះនាងទូលថា ខ្ញុំចេញទៅមិនបាន ព្រះរាជាត្រាស់ថា ព្រោះហេតុអ្វី ក៏ទូលថា ខ្ញុំជាម្ចាស់ក្សត្រី ។ ព្រះនាងសូម្បីត្រូវឃុំឃាំងក្នុងរណ្តៅយ៉ាងនោះ ក៏នៅមានខត្តិយមានះ ។ ព្រះរាជាត្រាស់សួរដល់រឿងរ៉ាវទាំងអស់ហើយ ទើបត្រាស់ប្រាប់ព្រះជាតិរបស់ព្រះអង្គថា ខ្ញុំក៏ជាក្សត្រា ហើយត្រាស់បន្តថា ចេញមកឥឡូវនេះចុះ ( ពួកយើង ) ប្រាកដដូចសប្បិដាក់ក្នុងទឹកដោះ ។ ព្រះនាងទូលថា ខ្ញុំម្ចាស់កើតរោគឃ្លង់មិនអាចចេញទៅបានទេ ព្រះរាជាត្រាស់ថា ឥឡូវនេះ យើងដូចគ្នា យើងអាចព្យាបាលឲ្យជាបាន ទើបដាក់ជណ្តើរបីព្រះនាងឡើងមក ហើយនាំទៅកាន់ទីប្រថាប់របស់ព្រះអង្គ ព្រះរាជទានថ្នាំដែលទ្រង់សោយមកហើយ មិនយូរប៉ុន្មាន ក៏ធ្វើឲ្យព្រះនាងជាសះស្បើយចាកព្រះរោគ មានព្រះឆវីដូចមាស ព្រះរាជាក៏ទ្រង់នៅរួមជាមួយព្រះនាងនោះ ដោយការនៅរួមលើកទី ១ ប៉ុណ្ណោះ ព្រះនាងក៏ទ្រង់គភ៌ ព្រះសូតព្រះឱរស ២ អង្គ អស់វារៈ ១៦ ដង រួមជាព្រះឱរស ៣២ អង្គ ដោយប្រការដូច្នេះ ។ ព្រះបិតាបានឲ្យឱរសចម្រើនវ័យ បានឲ្យសិក្សាសិប្បៈសព្វយ៉ាង ។

ថ្ងៃមួយ មានព្រានព្រៃម្នាក់ ដែលជាអ្នកនគររបស់ព្រះរាមរាជា ដើរ

ស្វែងរករតនៈលើកំពូលភ្នំ មកដល់តំបន់នោះ ឃើញព្រះរាជាក៏ស្គាល់ ហើយទូលថា បពិត្រព្រះអង្គ ទូលបង្គំចាំទ្រង់បាន ព្រះរាជាត្រាស់សួរថា ឯងមកអំពីណា ព្រានព្រៃទូលថា ទូលបង្គំមកអំពីនគររបស់ព្រះអង្គ ។ បន្ទាប់អំពីនោះ ព្រះរាជាត្រាស់សួរដល់រឿងរ៉ាវទាំងអស់របស់ព្រាន ។ កាលព្រះរាជានិងព្រានព្រៃកំពុងសន្ទនាគ្នា ព្រះរាជកុមារទាំងឡាយក៏នាំគ្នាមកគាល់ ។ ព្រានព្រៃឃើញកុមារទាំងនោះ ទើបសួរថា បពិត្រព្រះអង្គ ក្មេងទាំងនេះជានរណា ព្រះរាជាត្រាស់ថា ជាបុត្តរបស់យើង ព្រានទូលថា បពិត្រព្រះអង្គ ឥឡូវនេះ ទ្រង់ចោមរោមទៅដោយព្រះរាជកុមារដល់ទៅ ៣២ អង្គ ទ្រង់នៅធ្វើអ្វីក្នុងព្រៃ សូមទ្រង់យាងទៅគ្រប់គ្រងរាជសម្បត្តិចុះ ព្រះរាជាត្រាស់ថា កុំអីបា ទីនេះ សុខសប្បាយល្អ ។ ព្រានព្រៃគិតថា ឥឡូវនេះ អញបានរឿងរ៉ាវអំពីការសន្ទនាហើយ ទើបទៅព្រះនគរទូលព្រះឱរសរបស់ព្រះរាជាឲ្យទ្រង់ជ្រាប ព្រះរាជឱរសគិតថា អញនឹងនាំព្រះបិតាឲ្យត្រឡប់ ទើបយាងទៅក្នុងទីនោះ មួយអន្លើដោយចតុរង្គសេនា អង្វរព្រះបិតាដោយប្រការផ្សេងៗ ព្រះរាជាក៏បដិសេធថា កុំឡើយបា ទីនេះសុខសប្បាយល្អហើយ ។

ព្រះរាជបុត្តត្រិះរិះថា ឥឡូវនេះ ព្រះបិតាទ្រង់មិនប្រាថ្នាយាងទៅ ណ្ហើយចុះ អញនឹងសាងព្រះនគរក្នុងទីនេះឯង ដើម្បីព្រះអង្គ ហើយទ្រង់ដកដើមក្រពៅចេញ សាងព្រះរាជមន្ទីរ ហើយសាងព្រះនគរ ទ្រង់ដាក់ឈ្មោះពីរ គឺកោលនគរ ព្រោះដកដើមក្រពៅចេញហើយ ទើបសាង និងព្យគ្ឃបថនគរ ព្រោះជាផ្លូវដែលខ្លាឆ្លងកាត់ ស្រេចហើយ ទើបយាងត្រឡប់ ។ បន្ទាប់អំពី

នោះ ព្រះមាតាក៏ត្រាស់នឹងព្រះរាជកុមារដែលចម្រើនវ័យថា នែកូនទាំងឡាយ ស្តេចសក្យៈនៅនគរកបិលពស្តុ ជាម្ចាស់ពូ និងម្ចាស់មីងរបស់កូន ចូរកូនទៅទទួលព្រះរាជធីតារបស់ស្តេចទាំងនោះមក ព្រះរាជកុមារទាំងឡាយ បានទៅក្នុងថ្ងៃដែលពួកខត្តិយកញ្ញាយាងទៅស្រង់ទឹកត្រង់ស្ទឹង ហើយរាំងកំពង់ទឹកប្រកាសឈ្មោះហើយ នាំព្រះរាជធីតាដែលខ្លួនស្រឡាញ់មក ពួកសក្យៈទាំងឡាយបានឮដំណឹងនេះ ក៏ត្រាស់ថា ណ្ហើយចុះ ពួកកុមារទាំងនោះ ក៏សុទ្ធតែព្រះញាតិរបស់យើង ហើយក៏នៅស្ងៀម ។ នេះជារឿងដែលកើតឡើងនៃកោលិយវង្សទាំងនោះ ។

កាលសក្យៈ និងកោលិយៈ ធ្វើអាវាហមង្គល និងវិវាហមង្គលនូវគ្នានិងគ្នាយ៉ាងនេះ វង្សក៏ជាប់គ្នាមក រហូតដល់ព្រះបាទសីហហនុ ។ ព្រះបាទសីហហនុមានព្រះរាជបុត្ត ៥ អង្គ គឺសុទ្ធោទនៈ ១ អមិតោទនៈ ១ ធោតោទនៈ ១ សុក្កោទនៈ ១ សក្កោទនៈ ១ ។ បណ្តាព្រះរាជបុត្តទាំងនោះ កាលព្រះបាទសុទ្ធោទនៈគ្រងរាជសម្បត្តិ មហាបុរសបំពេញបារមី ចុតិអំពីតុសិត ដោយន័យដែលពោលហើយក្នុងនិទានជាតក ទ្រង់បដិសន្ធិក្នុងគភ៌នៃព្រះនាងមាយាទេវី ព្រះធីតារបស់ព្រះបាទអញ្ជនៈ ជាបជាបតីរបស់ព្រះបាទសុទ្ធោទនៈ ហើយយាងចេញមហាភិនិក្ខមណ៍ដោយលំដាប់ ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ទ្រង់ប្រកាសធម្មចក្កដ៏បវរ យាងទៅក្រុងកបិលពស្តុដោយលំដាប់ ទ្រង់ប្រោសព្រះញាតិវង្សានុវង្ស មានព្រះបាទសុទ្ធោទនមហារាជជាដើម ឲ្យទ្រង់តាំងនៅក្នុងអរិយផល យាងចារិកទៅកាន់ជនបទ

ហើយត្រឡប់មកម្តងទៀត គង់នៅក្នុងវត្តនិគ្រោធារាមក្នុងនគរកបិលពស្តុ មួយអន្លើដោយភិក្ខុ ១៥០០ រូប ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ កាលគង់នៅក្នុងនិគ្រោធារាមនោះ ពួកស្តេចសក្យៈ និងកោលិយៈទាស់តែងគ្នារឿងទឹក ។ តើរឿងនេះដូចម្តេច រឿងនេះ មានដូច្នេះថា ត្រង់ចន្លោះនគរកបិលពស្តុ និងកោលិយៈ មានស្ទឹងរោហិណី ហូរច្រងកាត់ ។ ស្ទឹងនោះ ជួនកាល ក៏មានទឹកតិច ជួនកាល ក៏មានទឹកច្រើន ។ ក្នុងកាលដែលមានទឹកតិច ស្តេចសក្យៈក្តី ស្តេចកោលិយៈក្តី ធ្វើវហាត់ នាំទឹកដើម្បីស្រោចស្រពសម្ទូងរៀងៗ ខ្លួន ។ ពួកមនុស្សរបស់ស្តេចទាំង ២ នគរ ដណ្តើមទឹកគ្នា ជេរដល់ជាតិថា ពួកស្តេចអាក្រក់ រាជត្រកូលរបស់ពួកឯង យកគ្នាតែបងប្អូនឯង ដូចសត្វតិរច្ឆាន មានមាន់ ឆ្កែ និងចចកជាដើម ។ ពួកសក្យៈក៏ជេរតបវិញថា ពួករាជត្រកូលរបស់ពួកឯង រួមរស់ក្នុងព្រៃឈើ ដូចពួកខ្មោចបិសាច ហើយនាំគ្នាក្រាបទូលព្រះរាជារៀងៗ ខ្លួន ។ ព្រះរាជាទាំងនោះខឹងក្រោធជាខ្លាំង លើកទ័ពមកប្រឈមមុខគ្នា ត្រង់ស្ទឹងរោហិណី ។ កម្លាំងពលបានត្រៀមដើម្បីធ្វើសង្គ្រាម ដូចរលកក្នុងមហាសមុទ្ទ ។

សម័យនោះ ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះថា ពួកព្រះញាតិឈ្លោះគ្នា តថាគតនឹងទៅឃាត់ ដូច្នេះហើយ ទើបមកតាមអាកាស ប្រថាប់ឈរត្រង់កណ្តាលទាហានទាំង ២ ចំណែក ។ អាចារ្យពួកខ្លះពោលថា ព្រះសាស្តាទ្រង់ពិចារណាដល់ព្រះញាតិឈ្លោះគ្នា ទើបយាងមកអំពីនគរសាវត្ថី ។ កាល

ព្រះមានព្រះភាគប្រថាប់ឈរ បានត្រាស់អត្តទណ្ឌសូត្រ ។ ស្តេចទាំងសង ខាងស្តាប់សូត្រនោះហើយ កើតនូវសេចក្តីសង្វេគ ទម្លាក់អាវុធ នាំគ្នាឈរ នមស្ការព្រះមានព្រះភាគ ត្រាស់ឲ្យក្រាលអាសនៈខ្ពស់ជាង ព្រះសាស្តាចុះ មកគង់លើអាសនៈដែលគេក្រាល ត្រាស់ផន្ទនជាតកថា **កុឋារិហត្ថោ បុរិសោ** ប្រែថា អ្នកជាបុរសមានដឹងក្នុងដៃ ... ដូច្នេះ ។ ត្រាស់លដុកិកជាតកថា **វន្ទាមិ តំ កុញ្ជរំ** ប្រែថា ខ្ញុំសូមថ្វាយបង្គំលោក ជាដំរី ... ដូច្នេះ ។ និងត្រាស់ វដ្ដកជាតកថា

**សម្មោទមានា គច្ឆន្តិ ជាលមាទាយ បក្ខិនោ**
**យទា តេ វិវទិស្សន្តិ តទា ឯហិន្តិ មេ វសំ។**

ពួកបក្សីស្រុះស្រួលគ្នា នាំយកលប់ទៅបាន តែបើពួកបក្សីទាំង នោះជជែកទាស់គ្នាក្នុងកាលណា ពួកបក្សីទាំងនោះ នឹងលុះ អំណាចអញ ក្នុងកាលនោះមិនខានឡើយ ដូច្នេះ ។

ហើយទ្រង់សម្តែងភាពដែលក្សត្រទាំងនោះជាញាតិនឹងគ្នាមកយូរហើយ ត្រាស់មហាវង្សនេះ ក្សត្រទាំងនោះក៏ជ្រះថ្លាក្រៃលែង កាលទ្រង់ជ្រាបថា គ្រា មុន ពួកយើងក៏ជាព្រះញាតិនឹងគ្នា ។ បន្ទាប់អំពីនោះ ស្តេចទាំង ២ វង្ស ក៏ ប្រគល់កុមារ ៥០០ គឺខាងសក្យៈ ២៥០ ខាងកោលិយៈ ២៥០ ដើម្បីជា បរិវាររបស់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ឃើញបុព្វហេតុរបស់ កុមារទាំងនោះ ក៏ត្រាស់ថា **ឯថ ភិក្ខវោ** អ្នកទាំងឡាយ ចូរមកជាភិក្ខុចុះ ។ ភិក្ខុទាំងអស់នោះក៏បានបរិក្ខារ ៨ ដែលកើតដោយឫទ្ធិ ហោះទៅក្នុងអាកាស

 ១៤៣

មកឈរថ្វាយបង្គំព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់នាំភិក្ខុទាំងនោះ ទៅកាន់ព្រៃមហាវ័ន ។ បណ្តាមហេសីរបស់ភិក្ខុទាំងនោះ ក៏នាំគ្នាបញ្ជូនទូត ទៅឲ្យជ្រាប ។ ភិក្ខុទាំងនោះ ត្រូវភរិយាចាស់លួងលោមដោយប្រការផ្សេងៗ ក៏អផ្សុក ព្រះមានព្រះភាគទ្រង់ជ្រាបថា ភិក្ខុទាំងនោះអផ្សុក ទ្រង់បំណងនឹង បង្ហាញព្រៃហិមពាន្ត ដើម្បីបន្ទោបង់នូវអផ្សុករបស់ភិក្ខុនោះ ដោយត្រាស់ កុណាលជាតកក្នុងទីនោះ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកធ្លាប់ឃើញ ព្រៃហិមពាន្តដែរឬ ភិក្ខុទាំងនោះទូលថា មិនធ្លាប់ឃើញទេ ព្រះអង្គ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មក ចូរពួកអ្នកមើល ហើយទ្រង់នាំ ភិក្ខុទាំងនោះទៅតាមអាកាស ដោយឫទ្ធិរបស់ព្រះអង្គ ទ្រង់បង្ហាញភ្នំជាច្រើន ថា នេះសុវណ្ណបព៌ត នេះរជតបព៌ត នេះមណីបព៌ត ហើយឈរប្រថាប់លើ ផ្ទាំងថ្មទន់ ក្បែរកុណាលស្រះ ។ បន្ទាប់អំពីនោះ ទ្រង់អធិដ្ឋានថា បណ្តា សត្វតិរច្ឆានដែលមានជើង ៤ ទាំងអស់ ចូរមកកាន់ភ្នំហិមពាន្តចុះ ឯសត្វ តាវ៉ៅចូលមកក្រោយគេ ។ ព្រះមានព្រះភាគ កាលទ្រង់ពណ៌នាដល់សត្វ ដែលមកដោយជាតិ ឈ្មោះ និងភាសា ទើបទ្រង់ប្រាប់ដល់ភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ នេះហង្ស នេះក្រៀល នេះចាក្រពាក នេះករវិក នេះ ប្រមោយដំរី នេះនាងនួន ។ ភិក្ខុទាំងឡាយ មានសេចក្តីសង្ស័យ កាលឃើញ សត្វទាំងនោះ បានឃើញតាវ៉ៅដែលមកក្រោយគេ ចោមរោមដោយបក្សីញី ១០០០ ទំលើបង្គង មានសត្វតាវ៉ៅញី ២ ពាំចុងបង្គងសងខាងនាំទៅ ក៏ កើតអស្ចារ្យក្នុងចិត្តដែលមិនធ្លាប់មានមក ទើបទូលព្រះមានព្រះភាគថា បពិត្រ

ព្រះអង្គដ៏ចម្រើន ទ្រង់ធ្លាប់ជាស្តេចតាវៅ ក្នុងទីនេះ មិនមែនឬ ព្រះមានព្រះភាគក៏ត្រាស់មហាកុណាលជាតកទាំងអស់ថា ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ តថាគត បានសាងវង្សត្រាវៅនេះឡើងមក ក្នុងអតីតកាល យើងទាំង ៤ អាស្រ័យនៅក្នុងទីនេះ គឺនារទឥសី ១ ទេវិលឥសី ១ ស្តេចត្មាតឈ្មោះអានន្ទ ១ តថាគតជាសត្វតាវៅ ឈ្មោះបុណ្ណមុខ ១ ។ កាលភិក្ខុទាំងនោះស្តាប់ជាតកនោះហើយ អផ្សុកដែលកើតឡើងព្រោះភរិយាចាស់របស់ភិក្ខុទាំងនោះ ក៏ស្ងប់រម្ងាប់ ។ បន្ទាប់អំពីនោះ ព្រះមានព្រះភាគក៏ត្រាស់សច្ចកថាដល់ភិក្ខុទាំងនោះ លុះចប់សច្ចកថា ភិក្ខុដែលបួសខាងក្រោយ បានជាព្រះសោតាបន្ន ភិក្ខុដែលបួសមុនបានជាអនាគាមី ភិក្ខុដែលជាបុថុជ្ជន និងព្រះអរហន្ត មិនមាន ។ បន្ទាប់អំពីនោះ ព្រះសាស្តា ទ្រង់នាំភិក្ខុទាំងនោះហោះមកកាន់ព្រៃមហាវ័នម្តងទៀត ។ម្យ៉ាងទៀត ភិក្ខុទាំងនោះ កាលមកក៏មកដោយឫទ្ធិរបស់ខ្លួន ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ដល់ភិក្ខុទាំងនោះទៀត ដើម្បីជាប្រយោជន៍ដល់មគ្គជាន់ខ្ពស់ ភិក្ខុ ៥០០ រូបនោះចម្រើនវិបស្សនាតាំងនៅក្នុងអរហត្តផល ។ ភិក្ខុដែលសម្រេចមុន បានទៅមុន ដោយគិតថាអញនឹងក្រាបទូលដល់ព្រះមានព្រះភាគ កាលភិក្ខុនោះមកដល់ហើយ ទើបក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គត្រេកអរក្រៃលែង មិនអផ្សុកដូច្នេះហើយ ថ្វាយបង្គំព្រះមានព្រះភាគ អង្គុយក្នុងចំណែកម្ខាង ភិក្ខុទាំងនោះមកដល់ដោយលំដាប់ អង្គុយចោមរោមព្រះមានព្រះភាគ ។

ក្នុងថ្ងៃឧបោសថ ខែជេស្ឋ វេលាល្ងាច ទេវតាក្នុងម៉ឺនចក្រវាល វៀរតែ

អសញ្ញីសត្វ និងអរូបព្រហ្ម និម្មិតអត្តភាពតូចៗ តាមន័យដែលពោលហើយ ក្នុងអដ្ឋកថាមង្គលសូត្រ នាំគ្នាចោមរោមព្រះមានព្រះភាគ ដល់ទីប្របថាប់ ក្នុងបវរពុទ្ធាសនៈ ដែលព្រះខីណាស្រព ៥០០ អង្គ ចោមរោមហើយ គិតថា អញនឹងស្តាប់ធម្មទេសនាដ៏ពីរោះវិចិត្រ ។ បណ្តាព្រហ្មទាំងនោះ ព្រហ្មដែលជាព្រះខីណាស្រព ៤ អង្គ ចេញអំពីសមាបត្តិ មិនឃើញពួកព្រហ្ម ពិចារណាថា ពួកព្រហ្មទៅណាអស់ហ្ន៎ កាលជ្រាបសេចក្តីនោះហើយ ក៏មកឯក្រោយ កាលមិនបានឱកាសក្នុងព្រៃមហាវ័ន ទើបឈរលើភ្នំកណ្តាប់ចក្រវាល បានពោលបច្ចេកគាថាទាំងឡាយ ដែលលោកពោលដូចតទៅនេះថា

គ្រានោះឯង ទេវតាទាំងឡាយ ដែលនៅក្នុងជាន់សុទ្ធាវាស ៤ អង្គ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះមានព្រះភាគនេះ ព្រះអង្គគង់នៅក្នុងមហាវ័ន ជិតក្រុងកបិលវត្ថុ ក្នុងសក្កជនបទ ព្រមដោយភិក្ខុសង្ឃច្រើន ចំនួន ៥០០ រូបសុទ្ធ តែជាព្រះអរហន្តទាំងអស់ ។ ទេវតាទាំងឡាយ ក៏មកអំពីលោកធាតុទាំង ១០ ប្រជុំគ្នាជាច្រើន ដើម្បីឃើញនូវព្រះមានព្រះភាគ និងភិក្ខុសង្ឃ បើដូច្នេះ គួរយើងទាំងអស់គ្នា ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ គប្បីពោលនូវគាថាមួយម្នាក់ៗ ក្នុងសំម្នាក់នៃព្រះមានព្រះភាគ ។

សេចក្តីទាំងអស់គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងសគាថវគ្គនោះឯង ។ កាលពោលយ៉ាងនេះហើយ ព្រហ្មមួយអង្គក្នុងទីនោះ បានឱកាស

លើកំពូលភ្នំកណ្តាប់ចក្រវាល ទិសខាងកើត ឈរលើកំពូលភ្នំកណ្តាប់ចក្រ-វាលនោះ បានពោលគាថានេះថា

ថ្ងៃនេះ ជាថ្ងៃប្រជុំធំក្នុងដងព្រៃ ពួកទេវតា ក៏មកប្រជុំគ្នាហើយ
យើងទាំងឡាយ ( លុះឃើញពួកទេវតាប្រជុំគ្នាយ៉ាងនេះហើយ )
ក៏នាំគ្នាមកកាន់ទីប្រជុំប្រកបដោយធម៌នេះ ដើម្បីឃើញនូវអបរា-
ជិតសង្ឃ គឺសង្ឃដែលមារផ្ចាញ់មិនបាន ។

កាលព្រហ្មនោះ ពោលគាថានេះ ពួកព្រហ្មដែលឈរនៅភ្នំកណ្តាប់ចក្រវាលទិសខាងលិច បានឮសំឡេង ។ ព្រហ្មអង្គទី ២ បានឱកាសលើកំពូលភ្នំកណ្តាប់ចក្រវាល ទិសខាងលិច ឈរលើកំពូលភ្នំកណ្តាប់ចក្រវាលនោះ ស្តាប់គាថានោះហើយ ទើបពោលគានេះថា

ពួកភិក្ខុក្នុងទីប្រជុំនោះ ប្រកបដោយសមាធិ ធ្វើចិត្តរបស់ខ្លួន
( ដែលវៀចកោង ) ឲ្យជាចិត្តស្លូតត្រង់ ភិក្ខុជាបណ្ឌិតទាំងឡាយ
តែងរក្សានូវឥន្រ្ទិយ ( ដោយល្អ ) ដូចជានាយសារថី ដែល
កាន់ទប់នូវខ្សែបរទុក ដូច្នោះឯង ។

ព្រហ្មអង្គទី ៣ បានឱកាសលើកំពូលភ្នំកណ្តាប់ចក្រវាល ទិសខាងត្បូង ឈរលើកំពូលភ្នំនោះ ស្តាប់គាថានោះហើយ បានពោលគាថានេះថា

ពួកភិក្ខុទាំងនោះ កាត់បង់នូវដែកគោល ( រាគៈ ទោសៈ មោហៈ )
កាត់បង់នូវរនុកទ្វារ ( រាគៈ ទោសៈ មោហៈ ) គាស់រម្លើងនូវ
សសរគោល ( រាគៈ ទោសៈ មោហៈ ) ជាអ្នកមិនមានតណ្ហា

ជាគ្រឿងញាប់ញ័រ ជាអ្នកបរិសុទ្ធស្អាត ប្រាសចាកមន្ទិល ជានាគកំលោះ ដែលព្រះពុទ្ធជាម្ចាស់ប្រកបដោយចក្ខុ ៥ ទ្រង់ទូន្មានល្អហើយ តែងត្រាច់ទៅបានក្នុងទិសទាំង ៤ មិនមានទើសទាល់ ។

ព្រហ្មអង្គទី ៤ បានឱកាសលើកំពូលភ្នំចក្រវាលទិសខាងជើង ឈរលើកំពូលភ្នំកណ្ដាប់ចក្រវាលនោះ ស្ដាប់គាថានោះហើយ បានពោលគាថានេះថា

ពួកជនណាមួយ បានដល់នូវព្រះពុទ្ធជាទីពឹង ទីរឭកហើយ ពួកជននោះឯង នឹងមិនទៅកាន់អបាយភូមិឡើយ លុះលះបង់រាងកាយជារបស់មនុស្សទៅហើយ នឹងទៅបំពេញពពួកនៃទេវតាមិនខាន ។

ព្រហ្មដែលឈរលើកំពូកភ្នំកណ្ដាប់ចក្រវាល ទិសខាងត្បូង បានស្ដាប់សំឡេងរបស់ព្រហ្មនោះ ។ ក្នុងកាលនោះ ព្រហ្ម ៤ អង្គនេះ បានឈរមើលបរិស័ទ ដោយប្រការដូច្នេះ ។ មហាព្រហ្មបានឈរជុំវិញចក្រវាលជាមួយគ្នា ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលទេវបរិស័ទហើយ ទ្រង់ប្រាប់ដល់ភិក្ខុទាំងឡាយថា

ម្នាលភិក្ខុទាំងឡាយ ព្រះមានព្រះភាគទាំងឡាយណា ជាអរហន្តសម្មាសម្ពុទ្ធ ដែលបានត្រាស់ដឹងហើយ ក្នុងអតីតកាល ពួកទេវតាមានប្រមាណប៉ុណ្ណេះដូចគ្នា មកប្រជុំគ្នាដើម្បីឃើញនូវ

ព្រះមានព្រះភាគទាំងនោះ ដូចជាពួកទេវតាដែលមកប្រជុំគ្នា ដើម្បីឃើញតថាគត ក្នុងកាលឥឡូវនេះដែរ ម្នាលភិក្ខុទាំង-ឡាយ ព្រះមានព្រះភាគទាំងឡាយណា ជាអរហន្តសម្មាសម្ពុទ្ធ នឹងបានត្រាស់ដឹងក្នុងអនាគតកាល ពួកទេវតាមានប្រមាណប៉ុណ្ណោះដូចគ្នា នឹងមកប្រជុំគ្នាដើម្បីឃើញនូវព្រះមានព្រះភាគទាំងនោះ ដូចពួកទេវតាដែលមកប្រជុំគ្នា ដើម្បីឃើញតថាគតក្នុងកាលឥឡូវនេះដែរ ។

លំដាប់នោះ ទ្រង់ចែកទេវបរិស័ទនោះជា ២ ពួក គឺជាភព្វសត្វ និងអភព្វសត្វថា ភព្វសត្វមានប្រមាណប៉ុណ្ណោះ អភព្វសត្វមានប្រមាណប៉ុណ្ណោះ ។ បណ្តាទេវបរិស័ទទាំងនោះ បរិស័ទដែលជាអភព្វ ទោះបីព្រះពុទ្ធ ១០០ អង្គសម្តែងធម៌ក៏ត្រាស់ដឹងមិនបាន ឯបរិស័ទដែលជាភព្វអាចត្រាស់ដឹងបាន ទើបទ្រង់បែងចែកភព្វបុគ្គលជា ៦ ប្រភេទ គឺរាគចរិតប្រមាណប៉ុណ្ណោះ ទោស-ចរិត មោហចរិត វិតក្កចរិត សទ្ធាចរិត ពុទ្ធិចរិត មានប្រមាណប៉ុណ្ណោះ ។ កាលកំណត់ចរិតយ៉ាងនេះហើយ ទ្រង់ជ្រើសរើសធម្មកថា សម្តែងធម៌ប្រភេទណា ទើបជាទីសប្បាយដល់បរិស័ទនោះៗ ទ្រង់បានដាក់ព្រះហឫទ័យដល់បរិស័ទនោះៗ ទៀតថា បរិស័ទនោះ គប្បីដឹងដោយអជ្ឈាស្រ័យរបស់ខ្លួនឬហ្ន៎ ឬគប្បីដឹងបាន ដោយអជ្ឈាស្រ័យរបស់បុគ្គលដទៃ ដោយអត្ថុប្បត្តិហេតុ ឬដោយអំណាចនៃពាក្យសួរហ្ន៎ កាលទ្រង់ជ្រាបថា គប្បីដឹងបានដោយពាក្យសួរ ដូច្នេះហើយ ទ្រង់រំពឹងដល់បរិស័ទទាំងអស់បន្តទៅថា អ្នកអាចសួរបញ្ហា មាន ឬមិនមាន កាលទ្រង់ជ្រាបថា មិនមាន ទ្រង់ក៏ពិចារណាថា បើ

តថាគតសួរឯង ធ្លើយឯង ក៏មិនជាទីសប្បាយដល់បរិស័ទនេះ បើដូច្នោះ តថាគតគួរនិម្មិតពុទ្ធនិមិត្ត ដូច្នេះហើយ ទើបចូលសមាបត្តិ មានឈានជាបាទ កាលទ្រង់ចេញចាកឈានហើយ ឧបការៈដោយមនោមយិទ្ធិ ទ្រង់ក៏និម្មិតពុទ្ធ-និមិត្ត ។ ពុទ្ធនិមិត្តបានប្រាកដដំណាលគ្នានឹងចិត្តដែលអធិដ្ឋានថា ពុទ្ធនិមិត្ត ចូរបរិបូណ៌ដោយលក្ខណៈអវយវៈតូចធំទាំងឡាយ មានបាត្រ និងចីវរ ដល់ព្រមដោយចលនា មានការសម្លឹងទៅមុខ និងការក្រឡេកមើលឆ្វេងស្តាំជាដើម ។ ពុទ្ធនិមិត្តនោះយាងមកពីលោកធាតុទិសខាងកើត គង់លើអាសនៈស្មើគ្នានឹងព្រះមានព្រះភាគ ។ ព្រះសាស្តាត្រាស់ ៦ សូត្រ ដោយអំណាចចរិត ក្នុងសមាគមនេះ គឺបុរាភេទសូត្រ ១ កលហវិវាទសូត្រ ១ ចូឡ-ព្យូហសូត្រ ១ មហាព្យូហសូត្រ ១ តុវដកសូត្រ ១ និងសម្មាបរិព្វា-ជនិយសូត្រនេះឯង ១ ។ បណ្តាសូត្រទាំងអម្បាលម៉ាននោះ ពុទ្ធនិមិត្តកាលសួរបញ្ហាដែលប្រព្រឹត្តទៅនៃសូត្រនេះ ដែលគួរពោលដល់សប្បាយនៃពួកទេវតាដែលជារាគចរិត ទើបពោលគាថានេះ មានពាក្យផ្តើមថា **បុច្ឆាមិ មុនឹ បហុតបញ្ញំ** ដូច្នេះ ។

ក្នុងបទទាំងនេះ បទថា **បហូតបញ្ញំ** គឺមានបញ្ញាច្រើន ។ បទថា **តិណ្ណំ** បានដល់ ឆ្លងឱឃៈ ៤ បានហើយ ។ បទថា **ធារគតំ** បានដល់ ដល់នូវព្រះនិព្វានហើយ ។ បទថា **បរិនិព្វុតំ** បានដល់ បរិនិព្វានហើយដោយអនុបាទិសេសនិព្វាន ។ បទថា **ឋិតត្តំ** បានដល់ មានចិត្តមិនញាប់ញ័រដោយលោកធម៌ទាំងឡាយ ។ បទថា **និក្ខម្ម ឃរា បនុជ្ជ កាមេ** បានដល់ បន្ទោ-

បង់វត្ថុកាមទាំងឡាយ ចេញអំពីការគ្រប់គ្រងផ្ទះហើយ ។ បទថា **កថំ ភិក្ខុ សម្មា សោ លោកេ បរិព្វជេយ្យ** សេចក្តីថា ភិក្ខុនោះគប្បីវៀរ គឺគប្បីទៅ គប្បីនៅដោយជុំវិញក្នុងលោកដូចម្តេច លោកអធិប្បាយថា ជាអ្នកមិនជាប់ ជំពាក់ដោយលោក កន្លងលោកទៅបាន ។ បទដ៏សេសក្នុងសូត្រនេះ មាន ន័យដូចពោលហើយក្នុងផ្ទៃសូត្រនោះឯង ។

លំដាប់នោះ ព្រោះបុគ្គលដែលមិនទាន់អស់អាសវៈ និងឈ្មោះថា វៀរ ដោយជុំវិញ រមែងមិនមាន ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់ កំណត់ប្រជុំនៃកព្វបុគ្គល ដោយអំណាចនៃចរិត មានរាគចរិតជាដើម ដើម្បី ឲ្យពួកទេវតាដែលមានទោសតាមដែលមាន លះនូវទោសតាមដែលប្រព្រឹត្ត ជាប្រចាំ ទើបទ្រង់ផ្តើមត្រាស់ព្រះតម្រាស់នោះៗ ថា ភិក្ខុណា បានគាស់រម្លើង នូវមង្គលផង ដូច្នេះ ។ កាលទ្រង់ប្រកាសដល់បដិបទារបស់ព្រះខីណាស្រព ដោយកំពូល គឺអរហត្ត ទើបត្រាស់គាថា ១៥ គាថា

ក្នុង ១៥ គាថានោះ គប្បីជ្រាបបឋមគាថាសិន បទថា **មង្គលា** នេះ ជាឈ្មោះនៃទិដ្ឋមង្គលជាដើមដែលពោលហើយ ក្នុងមង្គលសូត្រ ។ បទថា **សមូហតា** បានដល់ ដកដោយល្អ គឺកាត់ផ្តាច់ដោយសស្ត្រា គឺបញ្ញា ។ បទថា **ឧប្បាតា** បានដល់ ការប្រកាន់នូវការកើតដែលប្រព្រឹត្តទៅយ៉ាងនេះ ថា ឧក្កាបាត ផ្កាយដុះកន្ទុយជាដើម រមែងមានផលយ៉ាងនេះៗ ។ បទថា **សុបិនា** បានដល់ ការកាន់យកតាមយល់សប្តិ ដែលប្រព្រឹត្តទៅយ៉ាងនេះថា យល់សប្តិក្នុងពេលព្រឹកមានផលយ៉ាងនេះ យល់សប្តិពេលថ្ងៃត្រង់ មានផល

យ៉ាងនេះ ដេកយល់សប្តិដែលបែរទៅខាងឆ្វេង មានផលយ៉ាងនេះ ដេកយល់សប្តិបែរទៅខាងស្តាំជាដើម មានផលយ៉ាងនេះ យល់សប្តិឃើញព្រះចន្ទមានផលយ៉ាងនេះ យល់សប្តិឃើញព្រះអាទិត្យជាដើម យ៉ាងនេះៗ ដូច្នេះ ។ បទថា **លក្ខណា** បានដល់ អាងនូវគម្ពីរប្រាប់លក្ខណៈឈើច្រត់ និងលក្ខណៈទ្រព្យជាដើម ហើយកាន់យកលក្ខណៈដែលប្រព្រឹត្តទៅថា ឥឡូវនេះ នឹងទទួលផលយ៉ាងនេះ ។ ទាំងអស់នោះ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងព្រហ្មជាលសូត្រនោះឯង ។ បទថា **ស មង្គលទោស-វិប្បហីនោ** បានដល់ មង្គលដែលជាទោសដ៏សេស វៀរមហាមង្គល ៣៨ ភិក្ខុដកនូវមង្គលជាដើមនោះ ឈ្មោះថា បានលះបង់ស្រឡះនូវមង្គលជាទោសម្យ៉ាងទៀត ភិក្ខុ ឈ្មោះថា បានលះបង់ស្រឡះនូវមង្គលជាទោស ព្រោះលះវត្ថុដែលជាមង្គល និងវត្ថុដែលជាអវមង្គល ដូចជាប្រផ្នូលជាដើម មិនជឿថាមង្គលជាដើម ធ្វើឲ្យបរិសុទ្ធ ជឿថា បុគ្គលបរិសុទ្ធបាន ព្រោះសម្រេចអរិយមគ្គ ។ ព្រោះដូច្នោះ ភិក្ខុនោះគប្បីវៀរដោយប្រពៃក្នុងលោក គឺភិក្ខុនោះជាវិញ្ញូ ស្រេចគប្បីវៀរដោយប្រពៃក្នុងលោក មិនជាប់ជំពាក់ដោយលោក ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ២ ដូច្នេះថា បទថា **រាគំ វិនយេថ មានុសេសុ ទិព្វេសុ កាមេសុ ចាបិ ភិក្ខុ** សេចក្តីថា ភិក្ខុនាំនូវតម្រេកក្នុងកាមគុណទាំងឡាយដែលជារបស់មនុស្ស និងជារបស់ទិព្វ មិនឲ្យកើតឡើងទៀត ដោយអនាគាមិមគ្គ ។ បទថា **អតិក្កម្ម ភវំ សមេច្ច ធម្មំ** សេចក្តីថា ភិក្ខុនាំនូវតម្រេកចេញបានហើយ បន្ទាប់អំពីនោះ ញ៉ាំងនូវការត្រាស់ដឹង ដោយ

ការកំណត់ដឹងឲ្យសម្រេច ដោយប្រការទាំងពួង ដោយអរហត្តមគ្គ ត្រាស់ដឹងនូវធម៌ មានអរិយសច្ច ៤ ជាដើម ហើយឈានកន្លងនូវភពទាំង ៣ ដោយបដិបទានេះបានហើយ ។ បទថា **សម្មា សោ** បានដល់ ភិក្ខុនោះគប្បីវៀរដោយប្រពៃក្នុងលោក ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៣ ដូចតទៅនេះ

បទថា **អនុរោធវិរោធវិប្បហីនោ** គឺលះរាគៈ និងទោសៈ ក្នុងវត្ថុកាមគ្រប់យ៉ាង ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។ម្យ៉ាងទៀត គ្រប់ៗ គាថា គប្បីប្រកបបទថា **សោបិ ភិក្ខុ សម្មា លោកេ បរិព្វជេយ្យ** ប្រែថា ភិក្ខុនោះ គប្បីវៀរដោយប្រពៃក្នុងលោក ដូច្នេះ ។ ព្រោះបន្ទាប់អំពីនេះទៅ យើងនឹងមិនពោលដល់បទប្រកប នឹងពោលតែន័យដែលមិនទាន់ពោលប៉ុណ្ណោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៤ ដូច្នេះថា វត្ថុដែលជាទីស្រឡាញ់ និងមិនជាទីស្រឡាញ់ ២ យ៉ាង ដោយអំណាចសត្វ និងសង្ខារ ។ ក្នុងសេចក្តីនោះ គឺលះដោយការលះឆន្ទរាគៈ និងបដិឃៈ ។ បទថា **អនុបាទាយ** បានដល់ មិនប្រកាន់ក្នុងធម៌ណាមួយដោយឧបាទាន ៤ ។ បទថា **អនិស្សិតោ កុហិញ្ចិ** បានដល់ ដែលតណ្ហានិស្ស័យ ១០៨ និងទិដ្ឋិនិស្ស័យ ៦២ មិនអាស្រ័យហើយក្នុងភពណាមួយ ឬក្នុងភព មានរូបភពជាដើម ។ បទថា **សំយោជនិយេហិ វិប្បមុត្តោ** សេចក្តីថា ធម៌ប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ ឈ្មោះថា **សំយោជនិយេហិ** ព្រោះជាវិស័យនៃសំយោជនៈ ១០ យ៉ាង

ឈ្មោះថា **វិប្បមុត្តោ** ព្រោះកំណត់ដឹង និងព្រោះលះសំយោជនៈទាំងនោះបានដោយមគ្គភាវនា ដោយប្រការទាំងអស់ ។ មា៉្យងទៀត ក្នុងទីនេះ លោកពោលដល់ការលះរាគៈ និងទោសៈដោយបាទដើម ។ ការមិនមានការប្រកាន់ជាទីអាស្រ័យដោយបទទី ២ ។ ការផុតចាកអកុសលដ៏សេស និងវត្ថុដែលជាអកុសលដោយបាទទី ៣ ។ មា៉្យងទៀត ការលះរាគៈ និងទោសៈដោយបាទដើម ឧបាយក្នុងការលះដោយបាទទី ២ គប្បីជ្រាបពាក្យអធិប្បាយថា ទ្រង់ត្រាស់ការរួចផុតចាកធម៌ជាទីតាំងនៃសំយោជនៈដោយបាទទី ៣ ព្រោះលះសំយោជនៈទាំងនោះបាន ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៥ ដូច្នេះ បទថា **ឧបធីសុ** បានដល់ ក្នុងខន្ធូបធិទាំងឡាយ ។ ឧបធិទាំងនោះ ហៅថា **អាទាន** ព្រោះអត្ថថា គប្បីប្រកាន់ ។ បទថា **អនញ្ញនេយ្យោ** បានដល់ ព្រោះឃើញការមិនទៀងជាដើមល្អហើយ បុគ្គលណាម្នាក់គប្បីទូន្មានមិនបានថា នេះប្រសើរ បទដ៏សេសមានអត្ថងាយយល់ហើយ សេចក្តីនេះ លោកអធិប្បាយថា ភិក្ខុនាំឆន្ទរាគៈក្នុងការប្រកាន់មាំចេញទៅហើយទាំងអស់ ដោយមគ្គទី ៤ ជាអ្នកមានឆន្ទរាគៈនាំចេញទៅហើយ រមែងមិនឃើញភាពជាសារៈក្នុងឧបធិទាំងឡាយនោះ គឺរមែងឃើញឧបធិទាំងពួងមិនមានសារៈ បន្ទាប់អំពីនោះ មិនអាស្រ័យក្នុងនិស្ស័យទាំង ២ យ៉ាង ឬដោយភាពដែលបុគ្គលណាម្នាក់ គប្បីទូន្មានមិនបានថា នេះប្រសើរ ភិក្ខុដែលជាព្រះខីណាស្រព គប្បីវៀរដោយប្រពៃក្នុងលោក ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៦ បទថា **អវិរុទ្ធោ** បានដល់ ជាអ្នកមិនភ្ជាំងភ្ជាត់ចាកសុចរិតទាំងឡាយ ព្រោះលះទុច្ចរិត ៣ យ៉ាងបានហើយ ។ បទថា **វិទិត្វា ធម្មំ** បានដល់ ដឹងធម៌ គឺអរិយសច្ច ៤ ដោយមគ្គ ។ បទថា **និព្វានបទាភិបត្ថយានោ** បានដល់ ប្រាថ្នាបទ គឺអនុបាទិសេសនិព្វាន ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៧ បទថា **អក្កុដ្ឋោ** បានដល់ ពាល់ត្រូវដោយអក្កោសវត្ថុ ១០ យ៉ាង ។ បទថា **ន សន្ធិយេថ** បានដល់ មិនចងក្រោធ គឺមិនគប្បីក្រោធ ។ បទថា **លទ្ធា បរភោជនំ ន មជ្ជេ** បានដល់ បានរបស់ដែលគេឲ្យដោយសទ្ធា ដែលបុគ្គលដទៃឲ្យហើយ មិនគប្បីស្រវឹងថា អញជាអ្នកមានឈ្មោះល្បី មានយស មានលាភ ដូច្នេះ ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៨ បទថា **លោភំ** បានដល់ ការលោភខ្លាំង ។ បទថា **ភវំ** បានដល់ កាមភពជាដើម ។ ទ្រង់ត្រាស់ភវតណ្ហា និងភោគតណ្ហា ដោយបទទាំង ២ យ៉ាងនេះ ម្យ៉ាងទៀត ទ្រង់ត្រាស់ដល់តណ្ហាទាំងអស់ដោយបទដើម ត្រាស់ដល់កាមភពដោយបទក្រោយ ។ បទថា **វិរតោ ឆេទនពន្ធនតោ** បានដល់ វៀរចាកនូវការកាប់សម្លាប់ និងការចងនូវសត្វដទៃ ព្រោះលះកម្មក្កិលេសទាំងនេះបានដោយសមុច្ឆេទហើយ ។ បទដ៏សេសក្នុងទីនេះ មានន័យដូចពោលហើយក្នុងផ្ទៃសូត្រនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៩ បទថា **សារុប្បមត្តនោ វិទិត្វា** បាន

ដល់ ដឹងនូវកិច្ចបដិបត្តិដ៏សមគួរដល់ភាពជាភិក្ខុរបស់ខ្លួន ដោយការលះនូវអនេសនៈជាដើម ហើយតាំងមាំក្នុងអាជីវបរិសុទ្ធ មានការស្វែងរកដោយប្រពៃជាដើម និងបដិបត្តិប្រពៃដទៃ ។ មិនមែនត្រឹមតែដឹងប៉ុណ្ណោះឡើយ ។ បទថា **យថាតថំ** បានដល់ ដឹងតាមសេចក្ដីពិត គឺតាមសេចក្ដីពិត ។ បទថា **ធម្មំ** បានដល់ ដឹងធម៌ មានខន្ធ អាយតនៈជាដើម ដោយញាណតាមសេចក្ដីពិត ឬដឹងធម៌ គឺអរិយសច្ច ៤ ដោយមគ្គ ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១០ បទថា **សោ និរាសោ អនាសសានោ** សេចក្ដីថា ភិក្ខុណាមិនមានអនុស័យ ដកនូវអកុសលមូលបានហើយ ដោយអរិយមគ្គ ភិក្ខុនោះ ជាអ្នកមិនមានការសង្ឃឹម មិនមានតណ្ហាបន្ទាប់អំពីនោះ មិនសង្ឃឹមធម៌ មានរូបធម៌ជាដើមណាមួយ ព្រោះមិនមានសង្ឃឹម ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **និរាសោ អនាសសានោ** ដូច្នេះ ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១១ បទថា **អាសវខីណោ** បានដល់ មានអាសវៈ ៤ អស់ហើយ ។ បទថា **បហីនមានោ** បានដល់ លះនូវមានះ ៩ បានហើយ ។ បទថា **រាគបថំ** បានដល់ ធម្មជាតប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលជាវិស័យនៃរាគៈ ។ បទថា **ឧបាតិវត្តោ** បានដល់ ឈានកន្លងដោយការកំណត់ដឹង និងការលះ ។ បទថា **ទន្តោ** បានដល់ លះនូវការសេពខុសក្នុងទ្វារទាំងពួង ហើយដល់នូវភូមិនៃការទូន្មានខ្លួន ដោយការ

ទូន្មានដ៏ប្រសើរ ។ បទថា **បរិនិព្វុតោ** បានដល់ ជាអ្នកស្ងប់ ព្រោះស្ងប់ដោយភ្លើង គឺកិលេស ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១២ បទថា **សទ្ធោ** បានដល់ ជាអ្នកប្រកបដោយការជ្រះថ្លា ដែលមិនញាប់ញ័រ សម្បូរដោយអាការទាំងអស់ ក្នុងពុទ្ធគុណជាដើម ព្រោះវៀរចាកបុគ្គលដទៃជាបច្ច័យ មិនប្រកបដោយបដិបត្តិដោយសទ្ធាចំពោះអ្នកដទៃ ដូចសីហសេនាបតីពោល ( អង្គុត្តរនិកាយ បញ្ចកនិបាត ) ថា ខ្ញុំព្រះអង្គមិនបាច់ជឿព្រះដ៏មានព្រះភាគ ត្រង់ផលទានទាំងនោះទេ ដូច្នេះ ។ បទថា **សុតវា** គឺប្រកបដោយការស្តាប់នូវអត្ថដ៏ក្រៃលែង ( បរមត្ថ ) ព្រោះកិច្ច គឺការស្តាប់យ៉ាងសាមញ្ញ ចប់ហើយ ។ បទថា **និយាមទស្សី** បានដល់ ក្នុងកាលសត្វលោកវង្វេងក្នុងសង្សារកន្តារ ជាអ្នកឃើញផ្លូវប្រពៃ ដែលជាផ្លូវប្រពៃទៅកាន់អមតនគរ ។ លោកអធិប្បាយថា បានឃើញផ្លូវហើយ ។ បទថា **វគ្គគតេសុ ន វគ្គសារី** សេចក្តីថា សត្វទាំងឡាយដែលស្ទុះទៅដោយទិដ្ឋិ ៦២ មានការយល់ឃើញជំទាស់នូវគ្នានិងគ្នាឈ្មោះថា ពួកសត្វប្រព្រឹត្តទៅដោយទិដ្ឋិ ។ ការមិនស្ទុះទៅដោយអំណាចទិដ្ឋិ ក្នុងសត្វទាំងឡាយដែលទៅហើយដោយទិដ្ឋិយ៉ាងនេះ ព្រោះមិនស្ទុះទៅដោយអំណាចទិដ្ឋិថា នេះសូន្យ នេះយ៉ាងនោះ ដូច្នេះ ។ បទថា **បដិឃំ** បានដល់ ការថ្នាំងថ្នាក់ ។ លោកអធិប្បាយថា ការថ្នាំងថ្នាក់ផ្លូវចិត្ត ។ ពាក្យថា **បដិឃំ** នេះ ជាវិសេសនៈរបស់ទោសៈ ។ បទថា **វិនេយ្យ** បានដល់ នាំចេញទៅហើយ ។ បទដ៏សេស មានន័យដូចពោលហើយក្នុងផ្ទៃសូត្រនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១៣ បទថា **សំសុទ្ធជិនោ** បានដល់ ជាអ្នកឈ្នះកិលេសដោយអរហត្តមគ្គដែលបរិសុទ្ធហើយ ។ បទថា **វិវដច្ឆទោ** គឺជាអ្នកមានកិលេសដូចដំបូល គឺរាគៈ ទោសៈ និងមោហៈបើកហើយ ។ បទថា **ធម្មេសុ វសី** បានដល់ ជាអ្នកដល់នូវជំនាញក្នុងធម៌ គឺអរិយសច្ច ៤ ធម៌ទាំងនោះដែលបុគ្គលណាម្នាក់មិនអាចធ្វើបុគ្គលដែលដឹងយ៉ាងនោះ ឲ្យជាអ្នកមិនដឹងបាន ដោយហេតុនោះ ទើបហៅព្រះខីណាស្រពថា **ធម្មេសុ វសី** ។ បទថា **បារគូ** បានដល់ ដល់នូវនិព្វាន ដែលលោកហៅថា **បារ** ។ អធិប្បាយថា សម្រេចដោយសឧបាទិសេសនិព្វាន ។ បទថា **អនេជោ** គឺជាអ្នកមិនញាប់ញ័រ ព្រោះប្រាសចាកតណ្ហាហើយ ។ បទថា **សង្ខារនិរោធញាណ-កុសលោ** គឺនិព្វាន លោកហៅថា រម្ងត់សង្ខារ ការដឹងក្នុងនិព្វាននោះ គឺអរិយមគ្គប្បញ្ញា ជាអ្នកឈ្លាសក្នុងអរិយមគ្គប្បញ្ញានោះ លោកអធិប្បាយថា ឈ្មោះថា ជាអ្នកឈ្លាស ព្រោះចម្រើនហើយ ៤ ដង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១៤ បទថា **អតីតេសុ** បានដល់ ក្នុងបញ្ចក្ខន្ធដែលកន្លងបវត្តិកាលទៅហើយ ។ បទថា **អនាគតេសុ** បានដល់ ក្នុងបញ្ចក្ខន្ធដែលមិនទាន់ដល់បវត្តិកាលនោះឯង ។ បទថា **កប្បាតីតោ** គឺកន្លងការកំណត់ថាអញ ថារបស់អញ ឬកន្លងការកំណត់ដោយតណ្ហា និងទិដ្ឋិទាំងអស់ ។ បទថា **អតិច្ចសុទ្ធិបញ្ញោ** គឺមានបញ្ញា បរិសុទ្ធឈានកន្លងហើយ ។ ឈានកន្លងអ្វី ឈានកន្លងកាលទាំង ៣ ។

ពិតហើយ ព្រះអរហន្ត ឈានកន្លងកាលដែលជាអតីត គឺអវិជ្ជា និង

សង្ខារ កាលដែលជាអនាគត គឺជាតិ ជរា មរណៈ និងកាលដែលជាបច្ចុប្បន្ន ដែលមានវិញ្ញាណជាខាងដើម មានភពជាទីបំផុតទាំងអស់ ធ្វើនូវសេចក្តីសង្ស័យ ជាអ្នកមានបញ្ញាដល់នូវការបរិសុទ្ធក្រៃលែង ដោយហេតុនោះ ទើបត្រាស់ថា **អតិច្ចសុទ្ធិបញ្ញោ** ។ បទថា **សញ្ញាយតនេហិ** គឺចាកអាយតនៈ ១២ ។ បទថា **វិប្បមុត្តោ** សេចក្តីថា ពិតហើយ ព្រះអរហន្តជាអ្នកកន្លងការកំណត់យ៉ាងនេះ មិនចូលដល់អាយតនៈណាមួយតទៅឡើយ ព្រោះកន្លងកំណត់ហើយ ។ និងព្រោះមានបញ្ញាបរិសុទ្ធ ឈានកន្លងហើយ ។ ដោយហេតុនោះ ទើបលោកពោលថា **សញ្ញាយតនេហិ វិប្បមុត្តោ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១៥ បទថា **អញ្ញាយ បទំ** បានដល់ដឹងនូវបទនីមួយៗ ក្នុង ៤ បទនៃសច្ចៈ ដោយបញ្ញាកំណត់សច្ចៈ ដែលជាចំណែកខាងដើម ។ បទថា **សមេច្ច ធម្មំ** គឺបន្ទាប់អំពីនោះ ត្រាស់ដឹងនូវធម៌ គឺអរិយសច្ច ៤ ដោយអរិយមគ្គ ៤ ។ បទថា **វិវដំ ទិស្វាន បហាន-មាសវានំ** បានដល់ ឃើញនូវការអស់អាសវៈជាវិវដ្ដ គឺនិព្វាន គឺបើកផ្សាយឲ្យប្រាកដ ដោយបច្ចវេក្ខណញ្ញាណ ។ បទថា **សព្វុបធីនំ បរិក្ខយា** សេចក្តីថា ព្រះមានព្រះភាគទ្រង់បញ្ចប់ទេសនាថា ភិក្ខុនោះមិនជាប់ជំពាក់ក្នុងភពណាមួយ ព្រោះការអស់ទៅនៃឧបធិទាំងឡាយ ដែលមានប្រភេទនៃខន្ធ កាមគុណ កិលេស និងអភិសង្ខារទាំងពួង គប្បីវៀរ គឺគប្បីនៅដោយប្រពៃក្នុងលោក បានដល់ មិនជាប់ស្អិត គប្បីទៅកាន់លោក ។

បន្ទាប់អំពីនោះ ពុទ្ធនិម្មិតនោះសរសើរទេសនា ពោលគាថានេះថា **អទ្ធា**

**ហិ ភគវា** ដូច្នេះ ។

ក្នុងបទនោះ បទថា **យោ សោ ឍរិវិហារិ** សេចក្តីថា ព្រះពុទ្ធនិម្មិត កាលចង្អុលបង្ហាញភិក្ខុដែលលើកឡើងសម្តែងដោយគាថានោះៗ យ៉ាងនេះថា ភិក្ខុណាជកនូវមន្ទិលជាដើម មានប្រក្រតីនៅដោយការលះទោសនៃមន្ទិល ទាំងពួង ភិក្ខុនោះនាំនូវតម្រេកក្នុងកាមទាំងឡាយដែលជាទិព្វ និងជារបស់ មនុស្សចេញហើយ ឈានកន្លងនូវកាម មានប្រក្រតីនៅដោយការត្រាស់ដឹង ធម៌ ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។ យោជនាលម្អិតថា ព្រះ ពុទ្ធនិម្មិតពោលពាក្យជាដើមថា បពិត្រព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យ ជាដើមថា ជកនូវមន្ទិលទាំងឡាយក្នុងទីបំផុតនៃគាថានោះ បានត្រាស់ថា ភិក្ខុ នោះ គប្បីវៀរជុំវិញដោយប្រពៃក្នុងលោក នេះជាសេចក្តីពិតនោះឯង ។ សួរ ថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះភិក្ខុណាមានប្រក្រតីយ៉ាងនេះ ភិក្ខុនោះ ឈ្មោះ ថា ទូន្មានខ្លួន ដោយការទូន្មានយ៉ាងខ្ពស់ ជាអ្នកឈានកន្លងសំយោជនៈ ១០ និងយោគៈ ៤ ដូច្នោះ ភិក្ខុនោះ គប្បីវៀរជុំវិញដោយប្រពៃក្នុងលោក ខ្ញុំមិន មានសេចក្តីសង្ស័យក្នុងរឿងនេះឡើយ ដូច្នេះ ។ កាលពុទ្ធនិម្មិតពោលគាថា សរសើរទេសនាហើយ ទេសនាក៏ចប់ដោយកំពូលនៃអរហត្ត ដោយប្រការ ដូច្នេះ ។

កាលព្រះសូត្រចប់ ទេវតាមួយសែនកោដិសម្រេចអគ្គផល ឯផលទាំង ៣ គឺសោតាបត្តិផល សកទាគាមិផល អនាគាមិផលរាប់មិនអស់ឡើយ ។

**អដ្ឋកថា សម្មាបរិព្វាជនិយសូត្រទី ១៣ ចប់**

# សុត្តន្តបិដក

## ធម្មិកសូត្រទី១៤

[ ៣៩ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ធម្មិកឧបាសកបានចូលទៅគាល់ព្រះមានព្រះភាគជាមួយនឹងពួកឧបាសក ប្រមាណ ៥០០ នាក់ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ ធម្មិកឧបាសក លុះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដោយគាថាដូច្នេះថា

[ ៤០ ] បពិត្រព្រះគោតម ទ្រង់មានព្រះបញ្ញាដូចផែនដី ខ្ញុំសូមក្រាបទូលសួរព្រះអង្គ បុគ្គលដែលចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្តី ឬក៏ពួកឧបាសកមានផ្ទះក្តី ប្រតិបត្តិដូចម្តេច ទើបហៅថា សាវកល្អ ។

ព្រះអង្គជ្រាបច្បាស់នូវគតិផង នូវដំណើរទៅខាងនាយ ( ចាកគតិ ) ផង របស់សត្វលោក ព្រមទាំងទេវលោក បុគ្គលជាអ្នកឃើញសេចក្តីល្អិត ស្មើដោយព្រះអង្គមិនមានឡើយ អ្នកប្រាជ្ញទាំងឡាយ តែងពោលសរសើរព្រះអង្គថា ជាព្រះពុទ្ធដ៏ប្រសើរ ។

ព្រះអង្គបានត្រាស់ដឹងហើយ ទ្រង់អនុគ្រោះពួកសត្វ ទ្រង់ប្រកាសញាណ និងធម៌ទាំងពួង បពិត្រព្រះអង្គទ្រង់មានចក្ខុ គឺប្រាជ្ញាជុំវិញ ព្រះអង្គជាបុគ្គលមានកិលេសគ្រឿងប្រក់បើកចេញ

ហើយ មិនមានមន្ទិល រុងរឿងក្នុងលោកទាំងពួង ។

ស្តេចដ៏រីឈ្មោះឯករ៍ណា បានឮថា ព្រះមានព្រះភាគ ទ្រង់ឈ្នះនូវបាបធម៌ហើយ ក៏ទៅក្នុងសម្នាក់នៃព្រះអង្គ ស្តេចដ៏រីនោះប្រឹក្សានឹងព្រះអង្គ ហើយបានសម្រេចមគ្គផល បានស្តាប់ធម៌មានចិត្តត្រេកអរ ( អនុមោទនា ) ថា សាធុ ។

សូម្បីស្តេចឈ្មោះវេស្សវណកុវេរៈ ចូលទៅរកព្រះអង្គ ក៏សាកសួរនូវធម៌ លុះស្តេចនោះសួរហើយ ព្រះអង្គក៏បានព្យាករស្តេចនោះលុះបានស្តាប់ ក៏មានចិត្តត្រេកអរ ។ ពួកតិរ្ថិយណាមួយ ទោះបីជាអាជីវក ឬនិគ្រន្ថ មានការពោល ( អួត ) ជាប្រក្រតី ពួកតិរ្ថិយទាំងអស់នោះ ក៏មិនកន្លងព្រះអង្គដោយប្រាជ្ញាបាន ដូចជាបុគ្គលឈរមិនអាចនឹងកន្លងនូវបុរសដែលកំពុងស្ទុះទៅយ៉ាងរហ័សបានដូច្នោះដែរ ។ ពួកព្រាហ្មណ៍ណាមួយ ដែលមានការ ( អួត ) ជាប្រក្រតី ឬពួកព្រាហ្មណ៍ណាមួយ ទោះបីជាព្រឹទ្ធាចារ្យ ពុំនោះសោត ពួកជនដទៃណាដែលមានសេចក្តីសម្គាល់ថា ពួកយើងក៏ជាអ្នកមានវាទៈដែរ ពួកព្រាហ្មណ៍ជាដើមទាំងអស់នោះ សុទ្ធតែជាអ្នកជាប់ជំពាក់ដោយសេចក្តីចំពោះព្រះអង្គ គឺប្រាថ្នាឲ្យព្រះអង្គកាត់សេចក្តីឲ្យ ។

បពិត្រព្រះមានព្រះភាគ ធម៌ណាដែលព្រះអង្គសម្តែងដោយប្រពៃហើយ ធម៌នេះឯង ជាធម៌ដ៏ល្អិតផង ជាធម៌នាំមកនូវ

សេចក្តីសុខផង ពួកខ្ញុំព្រះអង្គទាំងអស់គ្នា ចង់ស្តាប់នូវធម៌នោះឯង បពិត្រព្រះអង្គជាព្រះពុទ្ធដ៏ប្រសើរ កាលបើពួកខ្ញុំព្រះអង្គទូលសួរហើយ សូមព្រះអង្គសម្តែងនូវធម៌នោះឲ្យទាន ។

ពួកភិក្ខុ និងពួកឧបាសកទាំងអស់នេះ ក៏បានអង្គុយប្រជុំគ្នាដើម្បីស្តាប់ក្នុងទីនោះដែរ បានស្តាប់នូវធម៌ដែលព្រះពុទ្ធមិនមានមន្ទិលត្រាស់ដឹងហើយ ដូចជាពួកទេវតា ( អង្គុយប្រជុំគ្នាដើម្បីស្តាប់ ) នូវសុភាសិតរបស់ព្រះឥន្ទ្រ ។

( ព្រះមានព្រះភាគត្រាស់ថា ) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់ពាក្យតថាគតចុះ តថាគតនឹងញុំាងអ្នកទាំងឡាយឲ្យស្តាប់នូវធម៌ ជាគ្រឿងកម្ចាត់បង់នូវកិលេស អ្នកទាំងអស់គ្នា ចូរប្រព្រឹត្តធម៌ ជាគ្រឿងកម្ចាត់បង់នូវកិលេសនោះ បុគ្គលអ្នកមានប្រាជ្ញា ឃើញនូវប្រយោជន៍ គប្បីសេពគប់នូវឥរិយាបថដ៏សមគួរដល់បព្វជិតនោះ ។

ភិក្ខុមិនគប្បីត្រាច់ទៅក្នុងកាលខុស ត្រូវតែត្រាច់ទៅបិណ្ឌបាតក្នុងស្រុក ក្នុងកាលគួរ គឺពេលព្រឹកទល់ថ្ងៃត្រង់ ព្រោះថាកិលេសជាគ្រឿងជាប់ចំពាក់ទាំងឡាយ រមែងជាប់នូវបុគ្គលអ្នកត្រាច់ទៅក្នុងកាលមិនគួរ ព្រោះហេតុនោះ ព្រះពុទ្ធទាំងឡាយមិនទៅក្នុងកាលខុសឡើយ ។

ធម៌ទាំងឡាយណា គឺរូប សំឡេង ក្លិន រស ផ្សព្វ តែងញុំាង

ពួកសត្វឲ្យស្រវឹង ភិក្ខុនោះ បន្ទោបង់នូវសេចក្តីពេញចិត្ត ក្នុងធម៌ទាំងឡាយនុ៎ះ ហើយគប្បីចូលទៅបិណ្ឌបាតក្នុងកាលគួរ លុះបានបិណ្ឌបាតក្នុងកាលគួរហើយ ត្រូវចៀសចេញទៅតែម្នាក់ឯង អង្គុយសម្ងំក្នុងទីស្ងាត់ គិតនូវខន្ធសន្តានខាងក្នុង គ្រប់គ្រងចិត្តបានល្អហើយ មិនគប្បីនាំចិត្តចេញទៅខាងក្រៅឡើយ ។ បើភិក្ខុនោះចរចាជាមួយនឹងសាវកក្តី អន្យតិរ្ថិយណាមួយក្តី ភិក្ខុក្តី គួរពោលឡើងនូវធម៌ដ៏ឧត្តមនោះ មិនគួរពោលពាក្យញុះញង់ផង មិនគួរពោលពាក្យតិះដៀលអ្នកដទៃផង ។ ព្រោះមោឃបុរសពួកមួយ តែងពោលភ្ជាត់នូវការនិយាយ ( ប្រណាំងប្រជែង ) តថាគតមិនសរសើរនូវពួកជនដែលមានប្រាជ្ញាតិចទាំងនោះឡើយ ការជាប់ជំពាក់ ( ដោយវិវាទតាំងឡើង ) អំពីគន្លងនៃពាក្យនោះៗ តែងជាប់ជំពាក់នឹងជនទាំងនោះ ជ្យេតជនទាំងនោះ រមែងញុំាងចិត្តឲ្យប្រព្រឹត្តទៅក្នុងការនិយាយនោះដ៏ឆ្ងាយ ( អំពីសមថៈ និងវិបស្សនា ) ។ សាវកអ្នកមានប្រាជ្ញាដ៏ប្រសើរ ស្តាប់ធម៌ដែលព្រះសុគតទ្រង់សម្តែងហើយ គប្បីពិចារណាហើយសឹមសេពនូវបិណ្ឌបាតផង វិហារផង ទីដេក ទីអង្គុយផង ទឹកសម្រាប់លាងធូលីជាប់នឹងសង្ឃាដិផង ។ ព្រោះហេតុនោះ ភិក្ខុមិនជាប់ចិត្តក្នុងធម៌ទាំងនុ៎ះ គឺបិណ្ឌបាត សេនាសនៈ និងទឹកសម្រាប់លាងធូលីជាប់នឹង

សង្ឃាដិ ដូចដំណក់ទឹកមិនជាប់លើស្លឹកឈូក ។ ម្យ៉ាងទៀត តថាគតសម្តែងនូវវត្តរបស់គ្រហស្ថ ដល់អ្នកទាំងឡាយ សាវក អ្នកធ្វើយ៉ាងណា ទើបឈ្មោះថា ជាអ្នកល្អ ព្រោះថា ធម៌ របស់ភិក្ខុទាំងអស់ណា ( ដែលតថាគតពោលក្នុងកាលមុន ) ធម៌នុ៎ះ គឺបុគ្គលប្រកបដោយសេចក្តីហួងហែង មិនបាន សម្រេចឡើយ ។

បុគ្គលមិនគប្បីសម្លាប់សត្វដោយខ្លួនឯង មិនគប្បីប្រើអ្នកដទៃ ឲ្យសម្លាប់ មិនគប្បីពេញចិត្តនឹងពួកជនដទៃដែលសម្លាប់ ពួក សត្វណាមានសន្តានចិត្តខ្ជាប់ខ្ជួនក្តី ពួកសត្វណាមានចិត្តតក់ស្លុត ក្តី តែងមាននៅក្នុងលោក បុគ្គលគប្បីដាក់ចុះនូវអាជ្ញាក្នុង សត្វទាំងអស់នោះ ។ លំដាប់ពីនោះ សាវកកាលដឹង គប្បីវៀរ បង់នូវទ្រព្យដែលគេមិនបានឲ្យ មិនគប្បីលួចយកទ្រព្យតិចតួច ក្នុងទីណាមួយឡើយ មិនគប្បីពេញចិត្តនឹងពួកជនដែលលួច ទ្រព្យគេឡើយ គប្បីវៀរបង់នូវទ្រព្យទាំងពួងដែលគេមិនបាន ឲ្យ ។ វិញ្ញូជនគួរវៀរបង់នូវអព្រហ្មចរិយៈ ដូចជាបុគ្គលវៀរ រណ្តៅរងើកភ្លើង កំពុងឆេះរន្ទាល កាលបើមិនអាចប្រព្រឹត្ត ព្រហ្មចរិយៈទេ ក៏កុំគប្បីប្រព្រឹត្តកន្លងនូវប្រពន្ធរបស់ជនដទៃ ។ បុគ្គលណាមួយ ចូលទៅក្នុងរោងប្រជុំក្តី ចូលទៅក្នុងកណ្តាល បរិស័ទក្តី មិនគប្បីពោលពាក្យកុហក ចំពោះជនណាមួយ មិន

គប្បីឲ្យអ្នកដទៃនិយាយកុហក មិនគប្បីពេញចិត្តនឹងពួកជន ដែលនិយាយកុហកឡើយ គប្បីវៀរនូវពាក្យមិនពិតទាំងពួង ។ បុគ្គលមិនគប្បីប្រព្រឹត្តផឹកនូវទឹកស្រវឹង គប្បីពេញចិត្តនឹងធម៌ គឺកិរិយាវៀរចាកការផឹកនោះ គ្រហស្ថណា បានដឹងនូវកិរិយាផឹកនោះថា មានភាពឆ្កួតជាទីបំផុត គ្រហស្ថនោះ មិនគប្បីផឹក មិនគប្បីពេញចិត្តនឹងបុគ្គលដែលផឹកឡើយ ។ បុគ្គលពាលទាំងឡាយ ធ្វើនូវអំពើបាបដោយខ្លួនឯងក្តី ឲ្យជនដែលមានសេចក្តីប្រមាទឯទៀតធ្វើក្តី ក៏ព្រោះតែសេចក្តីស្រវឹង ( ហេតុនោះ ) បុគ្គលគួរលះនូវការផឹកនូវទឹកស្រវឹង ជាគ្រឿងបណ្តាលឲ្យកើតបាប នាំឲ្យឆ្កួត នាំឲ្យវង្វេង ទាំងនាំឲ្យល្ងង់ទុំះចេញ ។ បុគ្គលមិនគប្បីសម្លាប់សត្វផង មិនគប្បីកាន់យកទ្រព្យ ដែលគេមិនបានឲ្យផង មិនគប្បីនិយាយពាក្យកុហកផង មិនគប្បីផឹកនូវទឹកស្រវឹងផង គប្បីវៀរចាកការប្រព្រឹត្តមិនប្រសើរ គឺសេពមេថុនធម្មផង មិនគប្បីបរិភោគភោជនក្នុងវេលាយប់ មិនគប្បីបរិភោគភោជនក្នុងកាលខុស គឺថ្ងៃរសៀលផង មិនគប្បីទ្រទ្រង់នូវកម្រងផ្កាផង មិនគប្បីលាបនូវគ្រឿងក្រអូបផង គប្បីដេកលើគ្រែដ៏គួរ ឬកម្រាលដែលក្រាលលើផែនដីផង ព្រោះអ្នកប្រាជ្ញ បានពោលនូវឧបោសថប្រកបដោយអង្គប្រាំបីទុំះ ថាជាឧបោសថ ដែលព្រះពុទ្ធ ព្រះអង្គទ្រង់ដល់

នូវទីបំផុតនៃទុក្ខ ប្រកាសហើយ ។

ព្រោះហេតុនោះ ជនអ្នកមានចិត្តជ្រះថ្លា រក្សាឧបោសថ ដែលប្រកបដោយអង្គប្រាំបី ឲ្យមានសភាពពេញលេញល្អ អស់ថ្ងៃទី ១៤ ទី ១៥ និងថ្ងៃទី ៨ នៃបក្ខផង អស់បាដិហារិកបក្ខផង ។

ន័យមួយទៀត វិញ្ញូជនដែលបានរក្សាឧបោសថ អំពីព្រឹកហើយ គួរមានចិត្តជ្រះថ្លារីករាយ អង្គាសភិក្ខុសង្ឃ ដោយបាយនិងទឹកតាមសមគួរ ។

វិញ្ញូជននោះ គួរចិញ្ចឹមមាតាបិតាដោយធម៌ គួរប្រកបជំនួញដែលប្រកបដោយធម៌ គ្រហស្ថអ្នកមិនប្រមាទ ប្រព្រឹត្តវត្តបែបនេះ រមែងទៅកើតក្នុងពួកទេវតាឈ្មោះថា សយម្បភា ( ទេវតាមានពន្លឺផ្សាយចេញអំពីខ្លួន ) ។

ធម្មិកសូត្រទី ១៤ ចប់

ចូឡវគ្គទី ២ ចប់

## ឧទ្ទាននៃចូឡវគ្គនោះគឺ

រតនសូត្រ ១ អាមគន្ធសូត្រ ១ ហិរិសូត្រ ១ មង្គលសូត្រ ១ សូចិលោមសូត្រ ១ កបិលសូត្រ ឬធម្មចរិយសូត្រ ១ ព្រាហ្មណធម្មិកសូត្រ ១ នាវាសូត្រ ១ កឹសីលសូត្រ ១ ឧដ្ឋានសូត្រ ១ រាហុលសូត្រ ១ វង្គីសសូត្រ ១ សម្មា-បរិព្វាជនិយសូត្រ ១ ធម្មិកសូត្រ ១ អ្នកប្រាជ្ញទាំងឡាយបាន ពោលនូវចូឡវគ្គថា មានសូត្រ ១៤ ដូច្នេះឯង ។

# អដ្ឋកថា

## ធម្មិកសូត្រ

[ ៣៩ ] ក្នុងធម្មិកសូត្រទី ១៤ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះ ។

សួរថា អត្ថុប្បត្តិហេតុនៃសូត្រនេះដូចម្តេច ឆ្លើយថា សូត្រនេះ មានអត្ថុប្បត្តិហេតុដូច្នេះ បានឮថា កាលព្រះមានព្រះភាគជាលោកនាថ ទ្រង់តាំងនៅ មានឧបាសកឈ្មោះធម្មិក ដោយឈ្មោះ និងដោយបដិបត្តិ ។ បានឮថា ធម្មិកឧបាសកនោះ ជាអ្នកដល់នូវព្រះរតនត្រ័យជាសរណៈ បរិបូរដោយសីល ជាពហុសូត ទ្រទ្រង់ព្រះត្រៃបិដក ជាអនាគាមី បាននូវអភិញ្ញា ត្រាច់ទៅក្នុងអាកាសបាន ។ ធម្មិកឧបាសកនោះ មានឧបាសក ៥០០ ជាបរិវារ ឧបាសកទាំងនោះក៏មានសភាពដូច្នោះដូចគ្នា ។

ថ្ងៃមួយ ធម្មិកឧបាសករក្សាឧបោសថហើយ ទៅក្នុងទីស្ងាត់ ពួនសម្ងំខាងចុងនៃមជ្ឈិមយាម ក៏មានបរិវិតក្កយ៉ាងនេះថា ណ្ហើយចុះ អញគួរទូលសួរបដិបទារបស់អ្នកគ្រប់គ្រងផ្ទះ និងរបស់អ្នកបួស ។ ឧបាសកចោមរោមដោយឧបាសក ៥០០ ចូលទៅគាល់ព្រះមានព្រះភាគ ហើយទូលសួរសេចក្តីនោះ ព្រះមានព្រះភាគទ្រង់ឆ្លើយបញ្ហាដល់ឧបាសកនោះ ។

ពាក្យពណ៌នាខាងដើម ក្នុងព្រះសូត្រនេះ អ្នកសិក្សាគប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ខ្ញុំនឹងពណ៌នាពាក្យដែលមិនធ្លាប់ពោល ។

[ ៤០ ] ក្នុងបទទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១ សិន ។ បទថា **កថង្ករោ** គឺធ្វើដូចម្តេច បដិបត្តិដូចម្តេច ។ បទថា **សាធុ ហោតិ** បានដល់ ជាបុគ្គលល្អ ជាអ្នកមិនមានទោស ជាអ្នកញុំាងប្រយោជន៍ឲ្យសម្រេច ។ បទថា **ឧបាសកាសេ** មានអត្ថស្មើគ្នានឹងឧបាសកនោះឯង ។ បទដ៏សេស តាមសព្ទជាក់ច្បាស់ហើយ ។ ដោយយោជនាមានអធិប្បាយថា បណ្តាសាវក ២ ពួក គឺសាវកដែលចេញអំពីផ្ទះ មិនបានគ្រប់គ្រងផ្ទះ បួសក្តី សាវកដែលគ្រប់គ្រងផ្ទះ ជាឧបាសកក្តី សាវកធ្វើដូចម្តេច ទើបញុំាងប្រយោជន៍ឲ្យសម្រេច ។

ឥឡូវនេះ ធម្មិកឧបាសក កាលសម្តែងដល់ការអាចឆ្លើយបញ្ហារបស់ព្រះមានព្រះភាគដែលត្រូវសួរបញ្ហាយ៉ាងនេះហើយ ទើបពោល ២ គាថា ថា **តុវំ ហិ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **គតឹ** បានដល់ គតិដែលជាអជ្ឈាស្រ័យ ។

បទថា **បរាយណំ** បានដល់ ការសម្រេចផល ។ម្យ៉ាងទៀត បទថា **គតិ** បានដល់ ប្រភេទនៃគតិ ៥ មាននរកជាដើម ។ បទថា **បរាយណំ** បានដល់ ការចេញទៅចាកគតិ ការផុតចាកគតិ គឺបរិនិព្វាន ។ បទថា **ន ចត្ថិ តុល្យោ** បានដល់ ដូចគ្នានឹងព្រះអង្គមិនមាន ។ បទថា **សព្វំ តុវំ ញាណមវេច្ច ធម្មំ បកាសេសិ សត្តេ អនុកម្បមានោ** សេចក្តីថា បពិត្រព្រះមានព្រះភាគ ទ្រង់ចាក់ធ្លុះញេយ្យធម៌មិនមានសេសសល់ ទ្រង់អនុគ្រោះសត្វទាំងឡាយ ទ្រង់ប្រកាសញាណ និងធម៌ទាំងពួង គឺទ្រង់ធ្វើឲ្យជាក់ច្បាស់ ទ្រង់ចង្អុលបង្ហាញវត្ថុជាប្រយោជន៍ប៉ុណ្ណោះ អធិប្បាយថា ការបិទបាំងនូវការបង្រៀននៃអាចារ្យរមែងមិនមានដល់ទ្រង់ ។ បទថា **វិរោចសិ វិមលោ** សេចក្តីថា ទ្រង់ប្រាសចាកមន្ទិល ជាអ្នករុងរឿង ព្រោះមិនមានមន្ទិល មានរាគៈជាដើម ដូចព្រះចន្ទវៀរចាកពពក និងធូលីជាដើម បទដ៏សេសក្នុងគាថានេះ មានអត្ថងាយយល់ទាំងអស់ហើយ ។

ឥឡូវនេះ ធម្មិកឧបាសក កាលប្រកាសឈ្មោះទេវបុត្តដែលព្រះមានព្រះភាគទ្រង់សម្តែងធម៌ទាំងនោះ ក្នុងកាលនោះ កាលនឹងសរសើរព្រះមានព្រះភាគ ទើបពោល ២ គាថាថា **អគច្ឆិ តេ សន្តិកេ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **នាគរាជា ឯរាវណោ នាម** សេចក្តីថា បានឮថា ទេវបុត្តនេះ ឈ្មោះថា ឯរាវណ មានរូបជាទេវតាក្នុងស្ថានសួគ៌ស្ថិតនៅក្នុងទិព្វវិមាន ។ ទេវបុត្តនោះ ក្នុងកាលដែលសក្កៈយាងប្រពាតឧទ្យាន បាននិម្មិតកាយ ១៥០ យោជន៍ និម្មិតពោង ៣៣ ជាដំរីឯរាវណ ។ លើពោង

នីមួយ មានភ្នក ២ លើភ្នកនីមួយៗ មានស្រះបោក្ខរណី ៧ ក្នុងស្រះបោក្ខរណីនីមួយៗ មានគុម្ពឈូក ៧ គុម្ពឈូកនីមួយៗ មានផ្កា ៧ លើផ្កានីមួយៗ មានត្របក ៧ លើត្របកនីមួយៗ មានទេពអប្សរ ៧ នាក់ ប្រាកដឈ្មោះថា បទុមអប្សរាដូចគ្នា ។ ស្រីស្នំរបស់សក្កទេវរាជ មានក្នុងវិមានវត្ថុថា ទេពកញ្ញាដែលបានហាត់ហើយ ក៏បិតនៅលើផ្កាឈូក ដូច្នេះ ។ ត្រង់កណ្តាលពោធ ៣៣ នោះ មានពោធឈ្មោះសុទស្សនៈ ទំហំ ៣០ យោជន៍ ។ ត្រង់ពោធឈ្មោះសុទស្សនៈនោះ មានបល្ល័ង្កកែវមណីប្រមាណមួយយោជន៍ តាំងនៅក្នុងមណ្ឌបត្របកឈូកកម្ពស់ ៣ យោជន៍ ជាទីប្រថាប់គង់របស់សក្កទេវរាជ ដែលចោមរោមដោយពួកទេពអប្សរ សោយទិព្វសម្បត្តិ ។ កាលសក្កទេវរាជយាងត្រឡប់អំពីប្រពាតឧទ្យាន ដំរីឯរាវ័ណ ក៏បានរំសាយអត្តភាពជាទេវបុត្តវិញ ។ ធម្មិកឧបាសកពោលថា ស្តេចដំរីឈ្មោះឯរាវ័ណ បានឮថា ព្រះមានព្រះភាគ ទ្រង់ឈ្នះបាបកម្មហើយ ដូច្នេះ ក៏ទៅក្នុងសម្នាក់នៃព្រះអង្គ សំដៅដល់ទេវបុត្តនោះ ។ បទថា **សោបិ តយា មន្តយិត្វា** បានដល់ ទេវបុត្តនោះមានការប្រឹក្សាជាមួយព្រះអង្គ អធិប្បាយថា សួរនូវបញ្ហា ។ បទថា **អជ្ឈគមា** គឺបានសម្រេចហើយ អធិប្បាយថា ដល់ព្រមហើយ ។ បទថា **សាធូតិ សុត្វាន បតីតរូបោ** សេចក្តីថា ទេវបុត្តស្តាប់បញ្ហានោះហើយ ឲ្យនូវសាធុការ ត្រេកអរហើយ ត្រឡប់ទៅ ។

ក្នុងបទថា **រាជាបិ តំ វេស្សវណោ កុវេរោ** នេះ មានអធិប្បាយថា យក្ខនោះ ឈ្មោះថា ជាព្រះរាជា ព្រោះអត្ថថា ជាទីត្រេកអរ ឈ្មោះវេស្សវណ

ព្រោះគ្រងរាជសម្បត្តិក្នុងវិសាណរាជធានី ។ ឈ្មោះថា កុវេរៈ គប្បីជ្រាបថា ជាឈ្មោះដើម បានឮថា យក្ខឈ្មោះកុវេរៈនោះ ជាព្រាហ្មណមហាសាល ធ្វើបុណ្យមានទានជាដើម បដិសន្ធិជាធំ ក្នុងវិសាណរាជធានី ព្រោះដូច្នោះ ទើបឈ្មោះថា កុវេរៈ ដូចលោកពោលក្នុងអាដានាដិយសូត្រថា

បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ស្តេចជាធំឈ្មោះកុវេរៈ មានរាជធានីឈ្មោះវិសាណា ព្រោះហេតុនោះ ស្តេចជាធំ ទ្រង់ព្រះនាមកុវេរៈ មហាជននាំគ្នាហៅថា វេស្សវណ ដូច្នេះ ។

បទដ៏សេស ក្នុងសូត្រនេះ មានអត្ថជាក់ច្បាស់ហើយ ។ ក្នុងរឿងនេះ បើមានពាក្យសួរថា ព្រោះហេតុអ្វី ឯកវណាទេវបុត្តនៅស្ថានសួគ៌ ជាន់តាវត្តិង្ស ជាជាន់ដែលឆ្ងាយជាង ហេតុអ្វី ទើបមកដល់មុន វេស្សវណទេវបុត្តមកឯក្រោយ ឧបាសកនេះក៏នៅក្នុងនគរតែមួយ តែមកដល់ក្រោយគេ ឧបាសកនោះដឹងការមករបស់ទេវតាទាំងនោះបានដូចម្តេច លោកពោលយ៉ាងនេះដោយហេតុដូចម្តេច ខ្ញុំនឹងពោលឲ្យជ្រាបដូចតទៅ

បានឮថា ក្នុងកាលនោះ វេស្សវណទេវបុត្តឡើងលើបល្ល័ង្កកែវ ប្រពាលទាំងឡាយ ១០០០ កម្ពស់ ១២ យោជន៍ មាននារីលីទៅ មានយក្ខមួយសែនកោដិ កាន់ដំបងកែវប្រពាលចោមរោម គិតថា នឹងទូលសួរបញ្ហាជាមួយព្រះមានព្រះភាគ ដូច្នេះហើយ ទើបប្រាប់វិមានដែលតាំងនៅលើអាកាសឲ្យចុះមកលើផែនដី មកឈប់លើផ្ទះរបស់នន្ទមាតាឧបាសិកា ក្នុងវេឡុកណ្ឌកនគរ ។ នេះជាអានុភាពរបស់ឧបាសិកាៗ ជាអ្នកមានសីលបរិសុទ្ធ វៀរការ

បរិភោគអាហារក្នុងវិកាលជានិច្ច ទ្រទ្រង់នូវព្រះត្រៃបិដក តាំងនៅក្នុងអនាគា-មិផល ។ ខណៈនោះ នាងបើកបង្អួច ឈរសំដិលខ្លួនយកខ្យល់អាកាស ហើយស្វាធ្យាយអដ្ឋកវគ្គ និងបរាយនវគ្គ ដោយសំឡេងដ៏ពីរោះ ដោយបទ និងព្យញ្ជនៈដ៏ពីរោះរណ្តំ ។ វេស្សវណទេវបុត្តបញ្ឈប់យានក្នុងទីនោះ បានឮសំឡេងទាំងអស់ តាំងអំពីឧបាសិកាបានស្វាធ្យាយបទសរុបថា **ឥទមវោច ភគវា មគធេសុ វិហរន្តោ បាសាណកេ ចេតិយេ បរិចារកសោឡសន្នំ ព្រាហ្មណានំ** ដូច្នេះ ។ កាលចប់វគ្គចុងក្រោយ បានផ្គងអញ្ជលីដែលដូចគ្នានឹងស្គរមាស ឲ្យនូវសាធុការថា សាធុ សាធុ ប្អូនស្រី ។ នាងសួរថា អ្នកជានរណា វេស្សវណទេវបុត្តឆ្លើយថា យើងជាទេវបុត្ត ។ បានឮថា ឧបាសិកាបានជាព្រះសោតាបន្នមុន វេស្សវណបានឯក្រោយ ។ វេស្សវណទេវបុត្តនោះហៅឧបាសិកានោះដោយវាទៈថា ប្អូនស្រី សំដៅដល់ភាពជាអ្នករួមឧទរដោយធម៌ ។ ឧបាសិកាពោលថា បងប្រុសដែលមានមុខល្អ ឥឡូវនេះ ដល់ពេលហើយ ។ វេស្សវណពោលថា នែប្អូនស្រី យើងជ្រះថ្លានឹងនាង យើងសូមសម្តែងអាការជ្រះថ្លាក្នុងនាង ។ ឧបាសិកាពោលថា អ្នកមានមុខដ៏ចម្រើន បើដូច្នោះ ពួកកម្មករមិនអាចនាំស្រូវសាលីដែលច្រូតមកហើយបាន សូមអ្នកប្រាប់បរិស័ទរបស់អ្នកឲ្យនាំមកចុះ វេស្សវណទទួលថា សាធុ ប្អូនស្រី ទើបប្រើពួកយក្ខ ។ ពួកយក្ខនាំស្រូវសាលីដាក់ក្នុងជង្រុក ចំនួន ១២៥០ រហូតពេញ ។ តាំងអំពីនោះមក ជង្រុកក៏មិនបានស្រកឡើយ ។ ទើបមានពាក្យឲ្យពរក្នុងលោកថា ដូចជង្រុករបស់នន្ទមាតា ។ វេស្សវណទេវបុត្តដាក់ស្រូវ

សាលីពេញជង្រុក រួចក៏ចូលទៅគាល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ត្រាស់ថា អ្នកមកខុសកាល ទើបក្រាបទូលរឿងទាំងអស់ឲ្យទ្រង់ជ្រាប ដោយហេតុនេះ វេស្សវណទេវបុត្តនៅក្នុងចាតុម្មហារាជិកា សូម្បីនៅជិត ក៏មកឯក្រោយ ចំណែកឯភវណទេវបុត្ត មិនមានកិច្ចណាមួយដែលត្រូវធ្វើតាមផ្លូវដូច្នោះ ទើបមកដល់មុន ឯឧបាសកនេះ ជាអនាគាមី ជាធម្មតា បរិភោគអាហារតែមួយពេលក៏ពិត តែខណៈនោះ ជាថ្ងៃឧបោសថ ទើបគាត់អធិដ្ឋានអង្គឧបោសថក្នុងពេលល្ងាច ស្លៀកដណ្តប់សំពត់យ៉ាងល្អ ចោមរោមដោយឧបាសក ៥០០ ទៅកាន់វត្តជេតពន ស្តាប់ធម្មទេសនាហើយ មកផ្ទះរបស់ខ្លួន ប្រាប់ធម៌ដល់ឧបាសក មានសរណៈ សីល និងអានិសង្សរបស់ឧបោសថជាដើម ដល់ឧបាសកទាំងនោះដោយខ្លួនឯង ហើយឲ្យឧបាសកទាំងនោះត្រឡប់ទៅ ។ ក្នុងផ្ទះរបស់ធម្មិកឧបាសក មានគ្រែដែលជាកប្បិយ ៥០០ មានជើងប្រមាណ ១ ហត្ថក្តាប់ តម្កល់ក្នុងបន្ទប់រៀងៗ ខ្លួន សម្រាប់ឧបាសកទាំងនោះ ។ ឧបាសកទាំងនោះ ចូលបន្ទប់រៀងៗ ខ្លួន អង្គុយចូលសមាបត្តិ សូម្បីធម្មិកឧបាសកក៏បានធ្វើយ៉ាងនោះដូចគ្នា ។ សម័យនោះ ក្នុងក្រុងសាវត្ថី មានត្រកូល ៥ លាន ៧ សែននៅអាស្រ័យ កាលរាប់ចំនួនមនុស្ស ក៏មាន ១៨ កោដិ ដោយហេតុនោះ ក្នុងបឋមយាម ក្នុងក្រុងសាវត្ថី មានសំឡេងដំរី សេះ មនុស្ស និងសំឡេងស្គរជាដើម ជាសំឡេងតែមួយ ដូចគ្នានឹងសំឡេងរលកមហាសមុទ្ទ ។ ក្នុងមជ្ឈិមយាម សំឡេងនោះក៏ស្ងប់ ក្នុងកាលនោះ ឧបាសកចេញអំពីសមាបត្តិ រំឭកដល់គុណរបស់ខ្លួនហើយ គិតថា អញនៅ

ជាសុខ ដោយមគ្គសុខ ផលសុខណា សុខនេះ អញបាន ព្រោះអាស្រ័យអ្នកណា ដូច្នេះហើយ ដឹងថា ព្រោះអាស្រ័យព្រះមានព្រះភាគ ទើបមានចិត្តជ្រះថ្លាក្នុងព្រះមានព្រះភាគ ពិចារណាតទៅថា ឥឡូវនេះ ព្រះមានព្រះភាគគង់នៅឯណា បានឃើញឯរាវណទេវបុត្ត និងវេស្សវណទេវបុត្តដោយទិព្វចក្ខុ ហើយក៏ស្តាប់នូវព្រះធម្មទេសនាដោយទិព្វសោត ដឹងថា ទេវបុត្តទាំង ២ នោះ មានចិត្តជ្រះថ្លា ដោយចេតោបរិយញ្ញាណ ទើបគិតថា បើដូច្នោះ អញគួរសួរបដិបទាដែលជាប្រយោជន៍ទាំង ២ ជាមួយនឹងព្រះមានព្រះភាគ ព្រោះដូច្នោះ ឧបាសកនោះ សូម្បីនៅក្នុងនគរជាមួយគ្នា ក៏មកដល់ឯក្រោយ នឹងបានដឹងការមករបស់ទេវបុត្តទាំងនោះ ដោយប្រការដូច្នេះ ដោយហេតុនោះ ទើបធម្មិកឧបាសកពោលថា **អគច្ឆិ តេ សន្តិកេ នាគរាជា ។បេ។ សោ ចាបិ សុត្វាន បតីតរូបោ** ដូច្នេះ ។

ឥឡូវនេះ ធម្មិកឧបាសក កាលសរសើរព្រះមានព្រះភាគឲ្យក្រៃលែងជាងសមណព្រាហ្មណ៍ ដែលលោកសន្មតខាងក្រៅសាសនានេះ ទើបពោល ២ គាថាថា **យេ កេចិមេ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **តិត្ថិយា** បានដល់ ជនទាំងឡាយដែលកើតក្នុងលទ្ធិខាងក្រៅព្រះសាសនា ដែលជាមេលទ្ធិ ៣ គឺនន្ទៈ វច្ឆៈ និងសង្កិច្ចៈជាអ្នកតាំងឡើង ។ សាស្តាទាំង ៦ មានបូរណកស្សបៈជាដើម បួសហើយក្នុងសាសនារបស់មេលទ្ធិទាំងនោះ ក្នុងសាស្តាទាំង ៦ នោះ នាដបុត្ត ជានិគ្រន្ថ សាស្តាដ៏សេស ៥ ទៀតជាអាជីវក ធម្មិកឧបាសក កាលសម្តែង

ដល់ជនទាំងអស់នោះ ទើបពោលថា **យេ កេចិមេ វាទសីលា** ដូច្នេះ ។ ពួកមេលទ្ធិមានប្រក្រតីធ្វើវាទៈយ៉ាងនេះថា យើងជាអ្នកបដិបត្តិប្រពៃ អ្នកដទៃបដិបត្តិខុស ត្រាច់និយាយចាក់ដោតសត្វលោកដោយលំពែង គឺមាត់ ។ បទថា **អាជីវកា វា** ធម្មិកឧបាសកសម្ដែងការញាំញីទិដ្ឋិ សម្ដែងរួមគ្នារបស់បុគ្គលទាំងនោះ ។

បទថា **នាតិតរន្តិ** គឺរមែងមិនកន្លង ។ បទថា **សព្វេ** សេចក្ដីថា ធម្មិកឧបាសកពោលរួមដល់សាវកតិរ្ថិយជាដើមពួកដទៃផងដែរ ។ បទថា **ឋិតោ វជន្តំ វិយ** សេចក្ដីថា ដូចបុគ្គលទន់ខ្សោយឈរនៅមួយកន្លែង មិនក្រៃលែងជាងអ្នកដើរលឿនដែលកំពុងដើរ យ៉ាងណា ជនទាំងឡាយនោះព្រោះមិនមានគតិ គឺ បញ្ញាកំពុងឈប់ មិនអាចដឹងប្រភេទអត្ថនោះៗបាន រមែងមិនកន្លងព្រះមានព្រះភាគ ដែលមានបញ្ញាក្រៃលែង ដូច្នោះ ។

បទថា **ព្រាហ្មណា វាទសីលា វុឌ្ឍា វា** ធម្មិកឧបាសកសម្ដែងដល់ចង្កីព្រាហ្មណ៍ តារុក្ខព្រាហ្មណ៍ បោក្ខរសាតិព្រាហ្មណ៍ ជាណុស្សោណិព្រាហ្មណ៍ជាដើម ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។ ដោយបទនេះថា **អបិ ព្រាហ្មណា សន្តិ កេចិ** បានដល់ ពួកព្រាហ្មណ៍មជ្ឈិមវ័យខ្លះ កំលោះខ្លះឯណាមួយ មានប្រាកដ រកបាន ។ ធម្មិកឧបាសកសម្ដែងដល់អស្សលាយនមាណព វាសិដ្ឋមាណព អម្ពដ្ឋមាណព និងឧត្តរមាណពជាដើម ដោយបទថា **កេចិ** ។ បទថា **អត្ថពទ្ធា** បានដល់ ជនទាំងឡាយដែលទាក់ទងដោយប្រយោជន៍យ៉ាងនេះថា ព្រះមានព្រះភាគគប្បីព្យាករបញ្ហានេះ គប្បីឆ្លើយនូវ

សេចក្តីសង្ស័យនេះបានខ្វះឬទេហ្ន៎ ។ បទថា **យេ ចាបិ អញ្ញេ** ធម្មិកឧបាសក សម្តែងថា ជនពួកណាត្រាច់ទៅសម្គាល់ខុសយ៉ាងនេះថា អញជាអ្នកមានវាទៈ ជនទាំងអស់នោះរាប់មិនអស់ មានក្សត្រ បណ្ឌិតព្រាហ្មណ៍ ព្រហ្មទេវតា និងយក្ខជាដើម ជាបុគ្គលទាក់ទងដោយប្រយោជន៍ ក្នុងព្រះអង្គ ។

ធម្មិកឧបាសកសរសើរព្រះមានព្រះភាគ ដោយប្រការផ្សេងៗ យ៉ាងនេះហើយ ឥឡូវនេះ កាលសរសើរព្រះអង្គដោយធម៌ ទើបអារាធនាសូមនូវធម្មកថា ដោយពោល ២ គាថាថា **អយញ្ហិ ធម្មោ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អយញ្ហិ ធម្មោ** ធម្មិកឧបាសកពោលសំដៅដល់ពោធិបក្ខិយធម៌ ៣៧ ប្រការ ។ បទថា **និបុណោ** បានដល់ ធម៌សុខុម គឺធម៌ដែលត្រាស់ដឹងបានដោយក្រ ។ បទថា **សុខោ** គឺជាធម៌ដែលចាក់ធ្លុះបាន នាំលោកុត្តរសុខមកឲ្យ ព្រោះដូច្នោះ ទើបហៅថា **សុខោ** ព្រោះជាហេតុនាំមកនូវសេចក្តីសុខ ។ បទថា **សុប្បវុត្តោ** គឺដែលព្រះមានព្រះភាគទ្រង់សម្តែងល្អហើយ ។ បទថា **សុស្សូសមានា** សេចក្តីថា ពួកខ្ញុំព្រះអង្គបំណងនឹងស្តាប់ ។ បទថា **តំ នោ វទ** បានដល់ សូមទ្រង់ត្រាស់ប្រាប់សេចក្តីនោះដល់ខ្ញុំព្រះអង្គទាំងឡាយចុះ ។ បាលីថា **ត្វំ នោ** ដូច្នេះក៏មានសេចក្តីថា សូមទ្រង់ត្រាស់ដល់ខ្ញុំព្រះអង្គទាំងឡាយចុះ ។ បទថា **សព្វេបិមេ ភិក្ខវោ** សេចក្តីថា បានឮថា ក្នុងខណៈនោះ ភិក្ខុ ៥០០ រូបអង្គុយហើយ ។ ធម្មិកឧបាសក កាលសម្តែងដល់ភិក្ខុ ៥០០ នោះ ទើបទូលអារាធនា ។ បទថា **ឧបាសកា ចាបិ** សេចក្តីថា ធម្មិកឧបាសកសម្តែងដល់បរិវាររបស់ខ្លួន

និងមនុស្សដទៃៗ ។ បទដ៏សេស ក្នុងគាថានេះ ជាក់ច្បាស់ហើយ ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងបដិបទារបស់អ្នកបួសមុន ទើបត្រាស់ហៅភិក្ខុទាំងឡាយមកដោយព្រះតម្រាស់ថា **សុណាថ មេ ភិក្ខវោ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ធម្មំ ធុតំ តញ្ច ចរាថ សព្វេ** សេចក្ដីថា ធម៌ឈ្មោះថា **ធុត** ព្រោះកម្ចាត់កិលេសទាំងឡាយ តថាគតនឹងញុំាងអ្នកទាំងឡាយឲ្យស្ដាប់ធម្មប្បដិបត្តិ ដែលកម្ចាត់កិលេសបែបនេះ អ្នកទាំងឡាយ ចូរប្រព្រឹត្ត គឺបដិបត្តិធម៌ ដែលតថាគតប្រកាសហើយ អធិប្បាយថា ពួកអ្នកកុំប្រមាទ ។ បទថា **ឥរិយាបថំ** បានដល់ ឥរិយាបថ ៤ មានការដើរជាដើម ។ បទថា **បព្វជិតានុលោមិកំ** បានដល់ ឥរិយាបថដែលសមគួរដល់សមណៈ គឺប្រកបដោយសតិសម្បជញ្ញៈ ។ អាចារ្យមួយពួកទៀតពោលថា ឥរិយាបថដែលប្រព្រឹត្តទៅ ដោយការបំពេញកម្មដ្ឋានក្នុងព្រៃ ។ បទថា **សេវេថ នំ** គឺគប្បីសេពឥរិយាបថនោះ ។ បទថា **អត្ថទស្សី** គឺឃើញប្រយោជន៍ ។ បទថា **មតិមា** គឺមានការគិត ។ បទដ៏សេស ក្នុងគាថានេះប្រាកដជាក់ច្បាស់ហើយ ។

បទថា **នោ វេ វិកាលេ** សេចក្ដីថា ភិក្ខុសេពឥរិយាបថ សមគួរដល់បព្វជិតយ៉ាងនេះ មិនគួរត្រាច់ទៅក្នុងវេលាវិកាល សំដៅដល់ ហួសអំពីថ្ងៃត្រង់ទៅ តែគួរត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងស្រុក ក្នុងកាលដែលគួរ ។ ព្រោះហេតុអ្វី ព្រោះថា កិលេសជាគ្រឿងជាប់ចំពាក់ទាំងឡាយ រមែងជាប់នូវបុគ្គល

អ្នកត្រាច់ទៅក្នុងកាលមិនគួរ សេចក្តីថា ធម៌ជាប់ចំពាក់ទាំងឡាយ មិនតិច មានជាប់ចំពាក់ដោយរាគៈជាដើម រមែងជាប់ គឺជាប់ជំពាក់ ចូលទៅតោង ជាប់នូវបុគ្គលដែលត្រាច់ទៅក្នុងកាលដែលមិនសមគួរ ។ ព្រោះហេតុនោះ ធីរជនទាំងឡាយមិនត្រាច់ទៅក្នុងវេលាវិកាល ដូច្នោះ ព្រះអរិយបុគ្គលដែល ត្រាស់ដឹងសច្ចៈ ៤ រមែងមិនត្រាច់បិណ្ឌបាតក្នុងវេលាវិកាល ។ បានឮថា សម័យនោះ មិនទាន់បានបញ្ញត្តវិកាលភោជនសិក្ខាបទ ព្រោះដូច្នោះ ព្រះមាន ព្រះភាគ កាលទ្រង់សម្តែងទោសរបស់បុថុជ្ជនទាំងឡាយក្នុងសេចក្តីនេះ ដោយ ធម្មទេសនា ទើបត្រាស់គាថានេះ ។ តែព្រះអរិយៈទាំងឡាយ វៀរការត្រាច់ ទៅក្នុងវេលាវិកាលនោះ មួយអន្លើដោយការបានមគ្គនោះឯង នេះជាជាធម្មតា ។

ព្រះមានព្រះភាគ កាលទ្រង់ឃាត់នូវការត្រាច់ទៅក្នុងវេលាវិកាលយ៉ាង នេះហើយ កាលទ្រង់សម្តែងថា សូម្បីភិក្ខុត្រាច់ទៅក្នុងកាល ក៏គួរប្រព្រឹត្ត យ៉ាងនេះ ដូច្នេះ ទើបត្រាស់ថា **រូបា ច សទ្ទា ច** ដូច្នេះ ។

គាថានោះ មានអធិប្បាយដូច្នេះថា រូបជាដើមណា ញុំាងនូវការស្រវឹង មានប្រការផ្សេងៗ ឲ្យកើត ញុំាងសត្វទាំងឡាយឲ្យស្រវឹង ភិក្ខុគប្បីកម្ចាត់ នូវការពេញចិត្តក្នុងរូបជាដើមនោះ ដោយន័យដែលពោលហើយ ក្នុងបិណ្ឌ-បាតិតបារិសុទ្ធិសូត្រ ( បិណ្ឌបាតបារិសុទ្ធិសូត្រ )[១] ជាដើម គប្បីចូលទៅ បរិភោគអាហារក្នុងពេលព្រឹក ដោយកាលដ៏សមគួរ ។ម្យ៉ាងទៀត ឈ្មោះ ថា **ទាតរាសោ** ព្រោះជាអាហារគប្បីបរិភោគក្នុងពេលព្រឹក បទនេះជាឈ្មោះ

---

១- បិ. ២៨ ទំ. ៣៥៦ ។

របស់បិណ្ឌបាត ។ ក្នុងបទនេះ លោកពោលថា ភិក្ខុនោះ បានទូវបិណ្ឌបាត ក្នុងទីណា ទីកដីទីនោះ ឈ្មោះថា **ចាតរាស** ព្រោះការខ្វល់ខ្វាយនោះ ។ ក្នុងបទនេះ គប្បីជ្រាបអធិប្បាយយ៉ាងនេះថា ភិក្ខុគប្បីចូលទៅកាន់ឱកាស ដែលនឹងបានបិណ្ឌបាត ។

ម្យ៉ាងទៀត ភិក្ខុចូលទៅហើយយ៉ាងនេះ បានបិណ្ឌបាតហើយ តាមសម័យ ត្រូវចៀសចេញទៅតែម្នាក់ឯង អង្គុយសម្ងំក្នុងទីស្ងាត់ គិតនូវខន្ធ-សន្តានខាងក្នុង គ្រប់គ្រងចិត្តបានល្អហើយ មិនគប្បីនាំចិត្តចេញទៅខាងក្រៅឡើយ ។

បណ្តាបទទាំងនោះ បទថា **បិណ្ឌំ** បានដល់ ភិក្ខាលាយគ្នា ។ ភិក្ខានោះ លោកហៅថា **បិណ្ឌ** ព្រោះអត្ថថា រួមចាករបស់នោះ ហើយនាំមកប្របល់គ្នា ។ បទថា **សមយេន** បានដល់ ខាងក្នុងថ្ងៃត្រង់ ។ បទថា **ឯកោ បដិក្កម្ម** គឺឲ្យកើតកាយវិវេក ត្រឡប់ទៅអង្គុយមិនមានសម្លាញ់ ។ បទថា **អជ្ឈត្តចិន្តី** បានដល់ គិតដល់ខន្ធសន្តាន លើកឡើងកាន់ព្រះត្រៃលក្ខណ៍ ។ បទថា **ន មនោ ពហិទ្ធា និច្ឆារយេ** សេចក្តីថា មិនគប្បីបញ្ជូនចិត្តទៅខាងក្រៅ សេចក្តីថា មិនគប្បីនាំចិត្តទៅក្នុងរូបជាដើម ដោយអំណាចកិលេសមានរាគៈជាដើម ។ បទថា **សង្គហិតត្តភាវោ** បានដល់ មានចិត្តប្រកាន់មាំដោយល្អ ។

បើភិក្ខុនោះនៅយ៉ាងនេះ គប្បីចរចាជាមួយសាវ័កដទៃ ឬជាមួយភិក្ខុណាមួយរូប ភិក្ខុនោះ គប្បីពោលធម៌ដ៏ប្រណីត មិនគប្បីពោលពាក្យញុះញង់

មិនគប្បីពោលពាក្យតិះដៀលអ្នកដទៃ ។ លោកអធិប្បាយដូចម្ដេច លោកអធិប្បាយថា ព្រះយោគាវចរនោះ បើនិយាយជាមួយមាតុគ្រាម ដែលចូលទៅរកដើម្បីបំណងនឹងស្ដាប់ក្ដី ជាមួយគ្រហស្ថដែលជាតិត្ថិយក្ដី ជាមួយភិក្ខុដែលបួសហើយក្នុងសាសនានេះក្ដី គប្បីពោលធម៌ដ៏ប្រណីត មិនធ្វើឲ្យបុគ្គលនោះក្ដៅក្រហាយ ប្រកបដោយមគ្គផលជាដើម ឬកថាវត្ថុ ១០ មិនគប្បីពោលពាក្យញុះញង់ដទៃៗ ឬពោលពាក្យតិះដៀលអ្នកដទៃសូម្បីតិចតួច ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងទោស ក្នុងការពោលនូវពាក្យតិះដៀលអ្នកដទៃនោះ ទើបត្រាស់ថា **វាចញ្ហិ ឯកេ** ដូច្នេះជាដើម ។ បទនោះ មានអធិប្បាយដូច្នេះថា ព្រះមានព្រះភាគត្រាស់ថា មោឃបុរសពួកខ្លះ ក្នុងលោកនេះ រមែងពោលភ្លាត់ គឺឆ្លើយឆ្លងនូវវាទៈដែលធ្វើឲ្យកើតវិវាទច្រើនប្រការ ទាំងដែលដឹងថា ជាពាក្យតិះដៀលអ្នកដទៃ ត្រូវប្រកួតប្រជែង ដូចប្រឈមមុខនឹងអ្នកចម្បាំង តថាគតមិនសរសើរបុគ្គលនោះ ដែលមានបញ្ញាថោកថយ ព្រោះហេតុអ្វី ព្រោះការជាប់ជំពាក់ ( ដោយវិវាទតាំងឡើង ) អំពីគន្លងនៃពាក្យនោះៗ គឺជាប់ជំពាក់អំពីវិវាទ ដែលកើតឡើងអំពីគន្លងនៃពាក្យនោះៗ រមែងទាក់ គឺចងនូវបុគ្គលបែបនោះ ។ ព្រោះហេតុអ្វីទើបចង ព្រោះបុគ្គលទាំងនោះ កាលពោលប្រណាំងប្រជែង រមែងបញ្ជូនចិត្តទៅក្នុងរឿងនោះ ចិត្តរមែងទៅឆ្ងាយអំពីសមថៈ និងវិបស្សនា ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងដល់ការប្រព្រឹត្តទៅ នៃបុគ្គលដែលមានបញ្ញាតិចហើយ ឥឡូវនេះ កាលទ្រង់សម្ដែងដល់ការប្រព្រឹត្តទៅរបស់អ្នក

មានបញ្ញាច្រើន ទើបត្រាស់ថា **បិណ្ឌំ វិហារំ ។បេ។ វរបញ្ញសាវកោ** ដូច្នេះ ។

ក្នុងបទទាំងនោះ លោកពោលដល់សេនាសនៈតែម្យ៉ាង ដោយ ៣ បទ គឺដោយវិហារ ដោយទីដេក គឺគ្រែ ដោយទីអង្គុយ គឺតាំង ។ បទថា **អាបំ** ស្មើគ្នានឹង **ឧទកំ** ប្រែថា ទឹក ។ បទថា **សង្ឃាដិរជូបវាហនំ** បានដល់ បោកធូលីដែលជាប់នឹងសង្ឃាដី ដែលជាមន្ទិលជាដើម ។ បទថា **សុត្វាន ធម្មំ សុគតេន ទេសិតំ** បានដល់ ស្ដាប់ធម៌ដែលព្រះមានព្រះភាគទ្រង់សម្ដែងហើយ ក្នុងការរាំងចាកអាសវៈទាំងពួងដោយន័យជាដើមថា ភិក្ខុពិចារណាដោយឧបាយហើយ អាស្រ័យសេព គឺប្រើប្រាស់នូវសំពត់ចីវរ គ្រាន់តែដើម្បីការពារនូវត្រជាក់ ដូច្នេះ ។ បទថា **សង្ខាយ សេវេ វរបញ្ញសាវកោ** សេចក្ដីថា សាវកអ្នកមានបញ្ញា ពិចារណាបច្ច័យ ៤ គឺបិណ្ឌបាត ដែលពោលថា **បិណ្ឌ** ក្នុងទីនេះ ១ សេនាសនៈដែលលោកពោលដោយ **វិហារ** សព្ទជាដើម ១ គិលានប្បច្ច័យដែលលោកសម្ដែងដោយ **អាប** សព្ទ ១ ចីវរដែលលោកពោលដោយ **សង្ឃាដិ** សព្ទ ១ គឺពិចារណាដោយន័យជាដើមថា បរិភោគគ្រាន់តែឲ្យតាំងនៅនៃកាយនេះ ហើយគប្បីសេព សាវករបស់ព្រះតថាគត ជាអ្នកមានបញ្ញាល្អ ដែលជាសេក្ខៈក្ដី បុថុជ្ជនក្ដី ព្រះអរហន្តក្ដីដោយត្រង់ក៏បាន ។ ពិតហើយ លោកពោលដល់អបស្សេនធម៌ គឺធម៌ដែលជាទីពឹង ៤ យ៉ាង គឺពិចារណាហើយ ទើបសេពនូវរបស់ដែលគួរសេព ពិចារណាហើយ ទើបអត់សង្កត់នូវហេតុដែលគួរអត់សង្កត់ ពិចារណាហើយ ទើបវៀរនូវហេតុដែលគួរវៀរ ពិចារណាហើយ ទើបបន្ទោបង់នូវហេតុដែលគួរ

បន្ទោបង់ ដូច្នេះ ។ ព្រោះសាវ័កអ្នកមានបញ្ញាល្អ ពិចារណាហើយ ទើបសេព ដូច្នោះ គប្បីជ្រាបថា ព្រោះហេតុនោះ ភិក្ខុមិន ( គួរ ) ជាប់ចិត្តក្នុងធម៌ទាំងនុ៎ះ គឺបិណ្ឌបាត សេនាសនៈ និងទឹកសម្រាប់លាងធូលីជាប់នឹងសង្ឃាដិ ដូចតំណក់ទឹក មិនជាប់លើស្លឹកឈូក ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងបដិបទារបស់ព្រះធីណាស្រេព ញុំាងកិច្ចបដិបត្តិរបស់អ្នកបួសឲ្យចប់ដោយកំពូល គឺអរហត្តយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងបដិបទារបស់គ្រហស្ថ ទើបត្រាស់ពាក្យជាដើមថា **គហដ្ឋវត្តំ បន វោ** ដូច្នេះ ។

ក្នុងគាថាទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាដំបូងមុនថា បទថា **សាវកោ** បានដល់ សាវ័កអ្នកគ្រប់គ្រងផ្ទះ ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។ តែដោយយោជនា មានដូច្នេះថា សាវ័កមិនអាចពាល់ត្រូវ គឺមិនអាចសម្រេចធម៌របស់ភិក្ខុ គឺមិនមានអាមិស បានដល់ បរិបូណ៌ឥតសេសសល់ តថាគតពោលមុនអំពីនេះ ដោយវត្ថុដែលមានការហួងហែង ដោយវត្ថុហួងហែង ដូចជាស្រែ និងចម្ការជាដើម ។

ព្រះមានព្រះភាគ ទ្រង់បដិសេធធម៌របស់ភិក្ខុដល់សាវ័កដែលជាអ្នកនៅគ្រប់គ្រងផ្ទះនោះ ដើម្បីសម្តែងនូវធម៌របស់គ្រហស្ថប៉ុណ្ណោះ ទើបត្រាស់ថា **បាណំ ន ហានេ** ដូច្នេះ ។

ក្នុងបទទាំងនោះ គប្បីជ្រាបវិនិច្ឆ័យតទៅថា ទ្រង់ត្រាស់ការវៀរចាកនូវការសម្លាប់សត្វ ដែលជាសេចក្តីបរិសុទ្ធ ៣ ចំណែក ដោយកន្លះគាថាដំបូង

ត្រាស់កិច្ចបដិបត្តិប្រយោជន៍ក្នុងសត្វទាំងឡាយ ដោយកន្ទះគាថាក្រោយ ។ លោកពណ៌នាបាទទី ៣ ក្នុងខគ្គវិសាណសូត្រ ក្នុងសុត្តនិបាតនេះហើយ ក្នុងបាទទី ៤ លោកពណ៌នាប្រភេទរបស់សត្វដែលមាំទាំ និងសត្វដែលតក់ស្លុតក្នុងអដ្ឋកថាមេត្តសូត្រគ្រប់ប្រការ ។ បទដ៏សេសមានអត្ថងាយយល់ហើយ ។

គប្បីប្រកបប្រាសលំដាប់ថា សាវកអ្នកគ្រប់គ្រងផ្ទះ ដាក់ចុះនូវអាជ្ញាក្នុងពួកសត្វ ទាំងដែលមិនញាប់ញ័រ ទាំងដែលតក់ស្លុត មិនគប្បីសម្លាប់ឯងមិនគប្បីប្រើអ្នកដទៃឲ្យសម្លាប់ និងមិនគប្បីអនុញ្ញាតឲ្យអ្នកដទៃសម្លាប់ ។ ម្យ៉ាងទៀត ក្រៅអំពីបទថា **និធាយ ទណ្ឌំ** នេះ គួរនាំបាឋៈដ៏សេសមកប្រើថា **វត្តេយ្យ** គប្បីប្រព្រឹត្តទៅ ដូច្នេះ ។ ក្រៅអំពីនេះ មិនគួរភ្ជាប់បទខាងក្រោយ ដោយបទដើម ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងសិក្ខាបទដើមយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងសិក្ខាបទទី ២ ទើបត្រាស់ថា **តតោ អទិន្នំ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **កិញ្ចិ** គឺរបស់តិចក្តី របស់ច្រើនក្តី ។ បទថា **ក្វចិ** គឺក្នុងស្រុកក្តី ក្នុងព្រៃក្តី ។ បទថា **សាវកោ** បានដល់ សាវកអ្នកគ្រប់គ្រងផ្ទះ ។ បទថា **ពុជ្ឈមានោ** គឺដឹងថា នេះជារបស់អ្នកដទៃ ។ បទថា **សព្វំ អទិន្នំ បរិវជ្ជយេយ្យ** គឺកាលវៀរយ៉ាងនេះ គប្បីវៀរវត្ថុទាំងអស់ ដែលគេមិនបានឲ្យ លោកចង្អុលបង្ហាញថា មិនវៀរដោយវិធីដទៃ ។ បទដ៏សេសក្នុងសេចក្តីនេះ មានន័យដូចពោលហើយ និងប្រាកដជាក់ច្បាស់ហើយ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងសិក្ខាបទទី ២ ឲ្យបរិសុទ្ធទាំង ៣

ចំណែកហើយយ៉ាងនេះ កាលទ្រង់សម្តែងសិក្ខាបទទី ៣ ដោយលើកមាតិកាឲ្យក្រលែងឡើង ទើបត្រាស់ថា **អព្រហ្មចរិយំ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អសម្ភុណន្តោ** ស្មើគ្នានឹង **អសក្កោន្តោ** ប្រែថា កាលមិនអាច ។ ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងសិក្ខាបទទី ៤ ទើបត្រាស់ថា **សភគ្គតោ វា** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **សភគ្គតោ** បានដល់ ទៅកាន់សណ្ឋាគារជាដើម ។ បទថា **បរិសគ្គតោ** គឺនៅក្នុងកណ្តាលប្រជុំជន ។ បទដ៏សេស ក្នុងសេចក្តីនេះ មានន័យដូចពោលហើយ និងប្រាកដច្បាស់ហើយ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងសិក្ខាបទទី ៤ ឲ្យបរិសុទ្ធទាំង ៣ ចំណែកហើយ កាលទ្រង់សម្តែងសិក្ខាបទទី ៥ ទើបត្រាស់ថា **មជ្ជញ្ច បានំ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **មជ្ជញ្ច បានំ** លោកពោលយ៉ាងនេះ ដើម្បីងាយស្រួលក្នុងការចងគាថា ។ តែមានអត្ថថា **មជ្ជបានញ្ច ន សមាចរេយ្យ** ប្រែថា មិនគប្បីផឹកទឹកស្រវឹង ។ បទថា **ធម្មំ ឥមំ** បានដល់ ធម៌ គឺវៀរចាកការផឹកទឹកស្រវឹង ។ បទថា **ឧម្មាទនន្តំ** គឺការផឹកទឹកស្រវឹងនោះ មានការឆ្កួតជាទីបំផុត ព្រោះថា ផលនៃការផឹកទឹកស្រវឹងយ៉ាងស្រាល កាលកើតជាមនុស្សក៏ជាមនុស្សឆ្កួត ។ បទថា **ឥតិ នំ វិទិត្វា** គឺដឹងច្បាស់នូវការផឹកទឹកស្រវឹងនោះដោយអាការយ៉ាងនេះ ។ បទដ៏សេស ក្នុងសេចក្តីនេះ មានន័យដូចពោលហើយ និងប្រាកដច្បាស់ហើយ ។

ព្រះមានព្រះភាគ ទ្រង់សម្ដែងសិក្ខាបទទី ៥ ឲ្យបរិសុទ្ធជាក់ច្បាស់យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងដល់ការផឹកទឹកស្រវឹង នៃសិក្ខាបទមុនថា ជាការធ្វើនូវសេចក្ដីសៅហ្មង និងនាំមកនូវពៀរវេរា ទ្រង់ទូន្មានក្នុងការវៀរចាកការផឹកទឹកស្រវឹងនោះ ឲ្យមាំទាំក្រៃលែងឡើង ទើបត្រាស់ថា **មជ្ជំ ហិ បានំ ករោន្តិ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **មជ្ជំ** គឺហេតុនៃការស្រវឹង ។ **ហិ** សព្ទ ជានិបាត គ្រាន់តែធ្វើបទឲ្យពេញ ។ បទថា **ឧម្មាទនំ មោហនំ** បានដល់ ការឆ្កួតក្នុងលោកខាងមុខ ការវង្វេងក្នុងលោកនេះ ។ បទដ៏សេស មានអត្ថងាយយល់ទាំងអស់ហើយ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងនិច្ចសីលរបស់សាវក ដែលគ្រប់គ្រងផ្ទះ ដោយហេតុមានប្រមាណប៉ុណ្ណោះហើយ ឥឡូវនេះ ដើម្បីសម្ដែងអង្គនៃឧបោសថ ទើបត្រាស់ថា **បាណំ ន ហានេ** បុគ្គលមិនគប្បីសម្លាប់សត្វដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អព្រហ្មចរិយា** បានដល់ ប្រព្រឹត្តនូវធម៌មិនប្រសើរ ។ បទថា **មេថុនា** គឺចាកការចូលដល់មេថុនធម្ម ។ បទថា **រត្តឹ ន ភុញ្ជេយ្យ វិកាលភោជនំ** បានដល់ មិនគប្បីបរិភោគក្នុងពេលយប់ មិនគប្បីបរិភោគភោជនកន្លងកាលក្នុងពេលថ្ងៃ ។ មៀសម្រាប់លាបជាដើម គប្បីជ្រាបថា ទ្រង់កាន់យកដោយ **គន្ធ** សព្ទ ក្នុងបទថា **ន ច គន្ធំ** នេះ ។ បទថា **មញ្ចេ** គឺគ្រែដែលជាកប្បិយ ។ បទថា **សន្ថតេ** បានដល់ លើផ្ទៃដែល

ក្រាលដោយកម្រាលជាកប្បិយ មានកន្ទេលតូចជាដើម ។ កម្រាលដែលក្រាលដោយព្រំធ្វើអំពីរោមចៀមជាដើម លើផែនដី ក៏គួរ ។ បទថា **អដ្ឋង្គិកំ** គឺមិនផុតអង្គ ៨ ដូចតន្ត្រីមានអង្គ ៥ ។ បទថា **ទុក្ខន្តគុនា** គឺព្រះពុទ្ធដល់នូវទីបំផុតទុក្ខក្នុងវដ្ដៈ ។ បទដ៏សេស ក្នុងសេចក្ដីនេះ ប្រាកដជាក់ច្បាស់ល្អហើយ ។ បុរាណាចារ្យពោលថា កន្ទុះគាថាក្រោយ ព្រះសង្គីតិកាចារ្យពោលក៏មាន ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងអង្គនៃឧបោសថយ៉ាងនេះហើយ ឥឡូវនេះ គ្រាទ្រង់សម្ដែងកាលនៃឧបោសថ ទើបត្រាស់ថា **តតោ ច បក្ខស្ស** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **តតោ** ជានិបាត គ្រាន់តែធ្វើបទឲ្យបរិបូណ៌ ។ គប្បីប្រកបដោយបទក្រោយយ៉ាងនេះថា **បក្ខស្សុបវស្សុបោសថំ** សេចក្ដីថា គប្បី រក្សាឧបោសថរៀងរាល់ ៣ ថ្ងៃ គឺថ្ងៃ ១៤ , ១៥ និងថ្ងៃ ៨ នៃបក្ខ គប្បីរក្សាឧបោសថប្រកបដោយអង្គ ៨ នេះឯង ។ ក្នុងបទថា **បាដិហារិ-កបក្ខញ្ច** នេះ ៥ ខែ គឺខែអាសាឍដើមជិតថ្ងៃចូលវស្សា ៣ ខែ ក្នុងវស្សា និងខែកត្តិក លោកហៅថា បាដិហារិយបក្ខ ។ អាចារ្យពួកដទៃពោលថា បាដិហារិយបក្ខមាន ៣ ខែប៉ុណ្ណោះ គឺខែអាសាឍ ខែកត្តិក និងខែផល្គុន អាចារ្យមួយពួកទៀតពោលថា មាន ៤ ថ្ងៃ គឺថ្ងៃ ១៣ ថ្ងៃ ១ ថ្ងៃ ៧ និងថ្ងៃ ៩ រាល់ៗ បក្ខ ដោយថ្ងៃមុន និងថ្ងៃក្រោយ របស់ថ្ងៃឧបោសថនៃបក្ខ ។ គាប់ចិត្តយ៉ាងណា ក៏គប្បីកាន់យកយ៉ាងនោះចុះ ។ បុគ្គលប្រាថ្នាបុណ្យ គប្បី

ធ្វើបានគ្រប់យ៉ាង ។ គប្បីផ្គងចិត្តថា បុគ្គលមានចិត្តជ្រះថ្លាក្នុងបាដិហារិយបក្ខនេះ ដោយប្រការដូច្នេះ មិនវៀរសូម្បីត្រឹមតែមួយថ្ងៃ ចូលដល់អង្គ ៨ ធ្វើឲ្យសម្បូរដោយល្អ បរិបូណ៌ដោយល្អ គប្បីរក្សាឧបោសថដែលប្រកបដោយអង្គ ៨ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងកាលនៃឧបោសថយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងដល់កិច្ចដែលបុគ្គលនោះធ្វើឧបោសថនោះ ក្នុងកាលទាំងនោះគួរធ្វើ ទើបត្រាស់ថា **តតោ ច បាតោ** ដូច្នេះ ។

បទថា **តតោ** ក្នុងបទនេះ ក៏ជានិបាត ត្រឹមតែធ្វើបទឲ្យពេញ ។ ឬចុះក្នុងអត្ថមិនមានចន្លោះ លោកអធិប្បាយថា កាលនោះ ។ បទថា **បាតោ** បានដល់ ចំណែកខាងដើមនៃថ្ងៃដទៃ ។ បទថា **ឧបវុដ្ឋុបោសថោ** បានដល់ ចូររក្សាឧបោសថ ។ បទថា **អន្នេន** បានដល់ បបរ និងកត្តជាដើម ។ បទថា **បានេន** គឺទឹកបាន ៨ យ៉ាង ។ បទថា **អនុមោទមានោ** បានដល់ ត្រេកអររឿយៗ អធិប្បាយថា សរសើរសព្វកាល ។ បទថា **យថារហំ** គឺសមគួរដល់ខ្លួន លោកអធិប្បាយថា តាមសមត្ថភាព តាមកម្លាំង ។ បទថា **សំវិភជេថ** គឺគប្បីចែករំលែក គប្បីបូជា ។ បទដ៏សេស ប្រាកដជាក់ច្បាស់ហើយ ។

ព្រះមានព្រះភាគ ត្រាស់ដល់កិច្ចរបស់បុគ្គលដែលរក្សាឧបោសថយ៉ាងនេះហើយ ឥឡូវនេះ ត្រាស់ដល់គុរវត្ត គឺការគោរព និងអាជីវបារិសុទ្ធិសីល កាលទ្រង់សម្ដែងដល់ឋានៈ ដែលគួរដល់ដោយបដិបទានោះ ទើបត្រាស់ថា

**ធម្មេន មាតាបិតរោ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ធម្មេន** បានដល់ ដោយភោគសម្បត្តិដែលបានមកដោយធម៌ ។ បទថា **ភរេយ្យ** បានដល់ គប្បីចិញ្ចឹម ។ បទថា **ធម្មិកំ សោ វណិជ្ជំ** បានដល់ វៀរនូវការជួញដូរដែលមិនប្រកបដោយធម៌ ៥ យ៉ាង គឺជួញសត្វរស់ ១ ជួញគ្រឿងសស្ត្រា ១ ជួញសាច់សត្វ ១ ជួញសុរា ១ ជួញថ្នាំពិស ១ និងជួញរបស់ដែលមិនប្រកបដោយធម៌ដ៏សេសនេះឈ្មោះថា ការប្រកបជំនួញដែលប្រកបដោយធម៌ ។ ដោយគោលនៃការជួញក្នុងទីនេះ លោកសំដៅដល់ការជួញ ដែលប្រកបដោយធម៌ដទៃ ដូចជាកសិកម្ម និងគោរក្ខកម្ម ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។ យោជនាអធិប្បាយថា អរិយសាវកណា ប្រកបដោយធម៌ គឺនិច្ចសីល ឧបោសថសីល និងទាន គប្បីប្រកបការលក់ដូរតាមធម៌ ចិញ្ចឹមមាតាបិតា ដោយភោគសម្បត្តិ ដែលបានមកដោយធម៌ ព្រោះបានមកអំពីការជួញដែលមិនប្រាសចាកធម៌ កាលអរិយសាវក ដែលជាគ្រហស្ថមិនប្រមាទហើយយ៉ាងនេះ បំពេញវត្តនេះ ដូចពោលហើយខាងដើម កាលកាយបែកធ្លាយ បុគ្គលណាកម្ចាត់ងងឹតដោយរស្មីរបស់ខ្លួន ជាទេវតាជាន់កាមាវចរ ៦ ជាន់នោះឈ្មោះថា **សយម្បភា** ព្រោះធ្វើនូវពន្លឺ បុគ្គលនោះ រមែងចូលដល់ គឺរមែងគប់រក រមែងជាប់ត ទេវតាឈ្មោះ **សយម្បភា** តែងកើតក្នុងទីដែលទេវតាទាំងនោះកើត ដោយប្រការដូច្នេះ ។

**អដ្ឋកថាធម្មិកសូត្រទី ១៤ ចប់**

**ចូឡវគ្គទី ២ ចប់**

# សុត្តន្តបិដក

# សុត្តនិបាត

## មហាវគ្គទី ៣

### បព្វជ្ជាសូត្រទី ១

[ ៤១ ] ( ព្រះអានន្ទដ៏មានអាយុពោលថា ) ខ្ញុំនឹងសម្តែងនូវបព្វជ្ជា ដែលព្រះពុទ្ធមានចក្ខុនោះ បានទ្រង់ព្រះផ្នួសហើយដោយប្រការយ៉ាងណា ទ្រង់ពិចារណាឃើញយ៉ាងណា ទើបទ្រង់ពេញព្រះហឫទ័យនឹងបព្វជ្ជា ។ ព្រះអង្គទ្រង់ឃើញថាឃរាវាសនេះ ចង្អៀតចង្អល់ ជាទីកើតនៃធូលី គឺកិលេស មួយទៀត ទ្រង់ឃើញថា បព្វជ្ជាមានឱកាសទូលាយ ទើបទ្រង់ព្រះផ្នួស ។ លុះព្រះអង្គទ្រង់ព្រះផ្នួសហើយ វៀរចាកបាបកម្មដោយកាយ លះបង់ការប្រព្រឹត្តអាក្រក់ ដោយវាចា ជម្រះអាជីវៈឲ្យបរិសុទ្ធ ។ ព្រះពុទ្ធមានលក្ខណៈ ដ៏ប្រសើរបរិបូណ៌ ទ្រង់យាងទៅកាន់ក្រុងរាជគ្រឹះ មានភ្នំព័ទ្ធជុំវិញ ដូចជាក្រោលរបស់ពួកអ្នកមគធៈ ទ្រង់យាងបិណ្ឌបាត ។ ព្រះរាជាពិម្ពិសារទ្រង់ឋិតលើប្រាសាទ បានទតឃើញនូវព្រះពុទ្ធនោះ លុះទ្រង់ឃើញព្រះពុទ្ធ បរិបូណ៌ដោយលក្ខណៈហើយ ទើបត្រាស់សេចក្តីនេះ (ចំពោះអមាត្យទាំងឡាយ) ថា នែអ្នកទាំងឡាយ

ដ៏ចម្រើន អ្នកទាំងឡាយ ចូរមើលសមណៈនេះ ( សមណៈនេះ ) មានរូបល្អ បរិបូណ៌ដោយកម្ពស់ និងទំហំ មានសម្បុរស្អាត ទាំងបរិបូណ៌ដោយដំណើរដ៏សមរម្យ ក្រឡេកមៀងមើលត្រឹមមួយជួរនឹម មានចក្ខុក្រឡេកចុះក្រោម មានស្មារតី សមណៈនេះ ដូចជាមិនមែនចេញចាកត្រកូលថោកទាបមក ( បួស ) ទេ ពួករាជទូត ចូរស៊ើបតាមទៅ ( ឲ្យដឹងថា ) ភិក្ខុ ( នេះ ) នឹងទៅក្នុងទីណា ។ រាជទូតទាំងនោះ ដែលព្រះរាជាទ្រង់បញ្ជូនទៅហើយ ក៏ដើរប្រកិតទៅតាមក្រោយ ( ដើម្បីឲ្យដឹងថា ) ភិក្ខុ ( នេះ ) នឹងទៅក្នុងទីណា ការនៅនឹងមានក្នុងទីណា ។ ( ព្រះពោធិសត្វ ) ទ្រង់ត្រាច់ទៅកាន់ទីសព្វប្រកទ្រង់គ្រប់គ្រងទ្វារ សង្រួមល្អ ព្រះអង្គមានសម្បជញ្ញៈ មានស្មារតី បានញ៉ាំងបាត្រឲ្យពេញជាឆាប់ គឺទ្រង់ទទួលតែល្មម ។ ព្រះពោធិសត្វជាអ្នកប្រាជ្ញនោះ លុះទ្រង់ត្រាច់បិណ្ឌបាតហើយ ក៏ស្តេចចេញអំពីនគរ យាងឡើងកាន់ភ្នំបណ្ឌវៈ ដោយគិតថាការនៅនឹងមានក្នុងទីនុ៎ះ ។

ពួកទូត ៣ នាក់ លុះបានឃើញហើយ ក៏ចូលទៅរកព្រះអង្គដែលទៅគង់ក្នុងទីនោះ ចំណែកទូតម្នាក់ បានមកក្រាបទូលស្តេចថា បពិត្រមហារាជ ភិក្ខុនោះ អង្គុយក្នុងញកភ្នំបណ្ឌវៈបែរមុខទៅខាងកើត ( ឥតរន្ធត់ ) ដូចខ្លាធំ គោឧសភ និង

សីហៈ ។ លុះព្រះមហាក្សត្រិយ៍ ទ្រង់ព្រះសណ្តាប់ពាក្យរាជ-ទូតហើយ ទ្រង់ប្រញាប់ប្រសាន់ យាងចេញទៅកាន់ភ្នំបណ្ឌវៈដោយព្រះរាជយានដ៏ប្រសើរ ។ ព្រះមហាក្សត្រិយ៍នោះ លុះទ្រង់យាងផុតទីដែលទៅដោយយានហើយ ក៏ចុះចាកយានស្តេចចូលទៅដោយព្រះបាទ បានដល់ហើយ ក៏ចូលទៅរកព្រះពោធិសត្វ ។ ព្រះរាជាទ្រង់គង់ហើយ ទ្រង់ថ្លែងសំណេះសំណាល ដោយព្រះបន្ទូលគួររឭក លុះទ្រង់បញ្ចប់ព្រះបន្ទូលនោះហើយ ត្រាស់សេចក្តីនេះថា ខ្លួនលោកនៅកំពុងពេញវ័យនៅក្មេងកំលោះ ជំទង់ ទើបកើតឡើងបានត្រឹមតែបឋមវ័យនៅជំទង់ បរិបូណ៌ដោយសម្បុរ និងកម្ពស់ ដូចជាមានជាតិជាក្សត្រិយ៍ លោកចូរញ៉ាំងជនជាប្រធាននៃសេនា ( មេទាហាន ) ឲ្យរុងរឿង ហើយចូរជាបុគ្គលមានពួកជន អ្នកមិនធ្វើអំពើអាក្រក់ជាបរិវារ ចូរបរិភោគនូវភោគៈទាំងឡាយចុះ ខ្ញុំឲ្យដល់លោក កាលបើខ្ញុំសួរហើយ លោក ចូរប្រាប់ជាតិដល់ខ្ញុំ ។

( ព្រះពោធិសត្វត្រាស់ថា ) បពិត្រមហារាជ ត្រង់ទៅ មានជនបទមួយ នៅប្របភ្នំហិមវន្ត ជាជនបទបរិបូណ៌ដោយទ្រព្យ និងជនអ្នកមានព្យាយាម អាស្រ័យនៅនឹងដែនកោសល ( មានជនមួយពួក ) មានគោត្រជាអាទិច្ចគោត្រ មានជាតិជាសាកិយៈ អាត្មាភាពបានចេញចាកត្រកូលនោះមកបួស អាត្មាភាពមិនត្រូវ

ការដោយកាមទាំងឡាយឡើយ អាត្មាភាពបានឃើញទោស
ក្នុងកាមទាំងឡាយ បានឃើញនូវការចេញចាកកាម ថាជា
គ្រឿងក្សេម នឹងទៅប្រឹងប្រែកបព្យាយាម ចិត្តរបស់អាត្មាភាព
ត្រេកអរក្នុងព្យាយាមនុ៎ះ ។

បព្វជ្ជាសូត្រទី ១ ចប់

# អដ្ឋកថា

## មហាវគ្គទី ៣

## បព្វជ្ជាសូត្រ

[ ៤១ ] ក្នុងបព្វជ្ជាសូត្រទី ១ នៃមហាវគ្គទី ៣ មានពាក្យផ្ដើមថា **បព្វជ្ជំ កិត្តយិស្សាមិ** ដូច្នេះ ។

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅនេះ

បានឮថា ព្រះមានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន ព្រះអានន្ទកើតបរិវិតក្កថា បព្វជ្ជារបស់មហាសាវក មានព្រះសារីបុត្តជាដើម បានទទួលការសរសើរ ពួកភិក្ខុ និងឧបាសក ឧបាសិកាទាំងឡាយ ក៏ជ្រាបរឿងដែលគេសរសើរដូចគ្នា តែបព្វជ្ជារបស់ព្រះមានព្រះភាគ មិនមានអ្នកណាសរសើរ បើ

ដូច្នោះ អញគប្បីសរសើរឯង ។ ព្រះអានន្ទអង្គុយកាន់ផ្លិតវាលវីជនីដ៏វិចិត្រ ក្នុងវិហារជេតពន កាលសរសើរបញ្ញារបស់ព្រះមានព្រះភាគ ទើបពោលសូត្រនេះថា

ខ្ញុំនឹងសម្តែងនូវបញ្ញា ដែលព្រះពុទ្ធមានចក្ខុនោះ បានទ្រង់ព្រះផ្នួសហើយ ដោយប្រការយ៉ាងណា ទ្រង់ពិចារណាឃើញយ៉ាងណា ទើបទ្រង់ពេញព្រះហឫទ័យនឹងបញ្ញា ដូច្នេះ ។

សេចក្តីក្នុងគាថានោះ មានដូច្នេះថា ព្រះអានន្ទពោលថា ព្រោះបុគ្គលសរសើរបញ្ញា គួរសរសើរបញ្ញានោះ ដូចព្រះមានព្រះភាគទ្រង់បញ្ញាម្យ៉ាងទៀត កាលពោលបញ្ញានោះ ក៏គួរសរសើរបញ្ញានោះ ដូចដែលព្រះមានព្រះភាគទ្រង់ពិចារណា ទ្រង់ពេញព្រះហឫទ័យបញ្ញា ដូច្នោះ អញនឹងសរសើរបញ្ញា ហើយទើបពោលពាក្យជាដើមថា **យថា បព្វជិ** ដូច្នេះ ។ បទថា **ចក្ខុមា** សេចក្តីថា ដល់ព្រមដោយចក្ខុ ៥ ។ បទដ៏សេស ក្នុងគាថាដើម ងាយយល់ទាំងអស់ហើយ ។

ឥឡូវនេះ ព្រះអានន្ទកាលប្រកាសសេចក្តីនោះថា **យថា វីមំសមានោ** ដូច្នេះហើយ ទើបពោលថា **សម្ពាធោយំ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សម្ពាធោ** គឺអស់ឱកាសបំពេញកុសល ព្រោះចង្អៀតដោយកូន និងប្រពន្ធជាដើម និងព្រោះចង្អៀតដោយកិលេស ។ បទថា **រជស្សាយតនំ** បានដល់ ឃរាវាស ជាទីកើតនៃធូលី មានរាគៈជាដើម ដូចនគរកម្ពុជៈ ជាទីកើតនៃសេះទាំងឡាយ ។ បទថា **អព្ភោកាសោ**

បានដល់ បព្វជ្ជាទូលាយដូចអាកាស ព្រោះផុយគ្នានឹងសេចក្ដីចង្អៀតចង្អល់ដូចពោលហើយ ។ បទថា **ឥតិ ធិស្វាន បព្វជិ** សេចក្ដីថា ព្រះមានព្រះភាគមានព្រះហឫទ័យដែលជរាព្យាធិ និងមរណៈ ចាំដាស់តឿនដោយល្អ ក្នុងឃរាវាស និងបព្វជ្ជា ទ្រង់ឃើញទោស និងអានិសង្សហើយ ទើបចេញមហាភិនេស្ក្រមណ៍ យកដាវកាត់ព្រះកេសាត្រង់ឆ្នេរស្ទឹងអនោមា ខណៈនោះ មានព្រះកេសា និងព្រះមស្សុ សមគួរដល់សមណៈ តាំងនៅត្រឹម ២ អង្គុលី ទទួលបរិក្ខារ ៨ ដែលឃដិការព្រហ្មបង្អោនចូលទៅថ្វាយ មិនមានអ្នកណាប្រាប់ថា គប្បីស្លៀកយ៉ាងនេះ គប្បីដណ្ដប់យ៉ាងនេះ ដែលការប្រព្រឹត្តបព្វជ្ជារបស់ព្រះអង្គ ប្រព្រឹត្តទៅហើយច្រើនពាន់ជាតិ ឲ្យសិក្សា ទើបទ្រង់បព្វជ្ជា ។ អធិប្បាយថា ព្រះមានព្រះភាគ ទ្រង់ស្លៀកសំពត់កាសាវៈមួយផ្ទាំង ទ្រង់ដណ្ដប់មួយផ្ទាំង ទ្រង់ពាក់ចីវរត្រង់ក ស្ពាយបាត្រដីត្រង់ចង្កូយស្មា ទ្រង់អធិដ្ឋានភេទជាបព្វជិត ។ ពាក្យដ៏សេស ក្នុងទីនោះ មានអត្ថងាយយល់ហើយ ។

ព្រះអានន្ទ កាលសរសើរបព្វជ្ជារបស់ព្រះមានព្រះភាគយ៉ាងនេះហើយ បន្ទាប់អំពីនេះទៅ ដើម្បីប្រកាសបដិបទារបស់បព្វជ្ជា និងការលះនូវត្រើយស្ទឹងអនោមា យាងទៅដើម្បីបំពេញព្យាយាម ទើបពោលពាក្យទាំងអស់ថា **បព្វជិត្វាន កាយេន** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **កាយេន បាបកម្មំ វិវជ្ជយិ** បានដល់ ទ្រង់វៀរកាយទុច្ចរិត ៣ យ៉ាង ។ បទថា **វចីទុច្ចរិតំ** បានដល់ វចីទុច្ចរិត ៤

យ៉ាង ។ បទថា **អាជីវំ បរិសោធយិ** បានដល់ ទ្រង់លះនូវមិច្ឆាជីវៈ ទ្រង់ប្រកបសម្មាជីវៈ ។ ព្រះពុទ្ធទ្រង់ជម្រះសីល មានអាជីវៈជាគម្រប់ ៨ យ៉ាងនេះហើយ បានយាងដល់នគររាជគ្រឹះប្រមាណ ៣០ យោជន៍ អំពីត្រើយស្ទឹងអនោមាអស់កាល ៧ ថ្ងៃ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទនេះថា សេចក្តីពិត ព្រះមានព្រះភាគមិនបានជាព្រះពុទ្ធក្នុងខណៈយាងទៅកាន់នគររាជគ្រឹះ នុ៎ះជាបុព្វចរិយារបស់ព្រះពុទ្ធដែលពោលយ៉ាងនោះ ដូចពាក្យរបស់សត្វលោកថា ព្រះរាជាប្រសូតក្នុងនគរនេះ បានទទួលរាជសម្បត្តិត្រង់នគរនេះជាដើម ។

បទថា **មគធានំ** លោកអធិប្បាយថា ជានគររបស់អ្នកដែនមគធៈ សូម្បីបទថា **គិរិព្វជំ** នេះ ក៏ជាឈ្មោះរបស់នគរមគធៈនេះ ។ គិរិព្វជនគរនោះតាំងនៅដូចក្រោលគោ ត្រង់កណ្តាលភ្នំ ៥ គឺភ្នំបណ្ឌវៈ ១ គិជ្ឈកូដ ១ វេភារៈ ១ ឥសិគិលិ ១ វេបុល្ល ១ ព្រោះហេតុនោះ ទើបហៅថា គិរិព្វជ-នគរ។ បទថា **បិណ្ឌាយ អភិហារេសិ** គឺយាងទៅក្នុងនគរនោះ ដើម្បីបិណ្ឌបាត ។

បានឮមកថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ឈរត្រង់ទ្វារនគរ ទ្រង់ព្រះតម្រិះថា បើអញគប្បីឲ្យដំណឹងនៃការមកដល់របស់អញដល់ព្រះបាទពិម្ពិសារថា សិទ្ធត្ថកុមារបុត្រារបស់ព្រះបាទសុទ្ធោទនៈមក ព្រះបាទពិម្ពិសារក៏ទ្រង់នាំបច្ច័យមកឲ្យច្រើន ។ ឯការទទួលបច្ច័យនោះ មិនសមគួរដល់សមណៈ ណ្ហើយចុះ អញនឹងត្រាច់ទៅបិណ្ឌបាត ។ ព្រះមានព្រះភាគ ទ្រង់

*ដណ្តប់សំពត់បង្សុកូលចីវរដែលទេវតាប្រទាន កាន់បាត្រដីយាងទៅកាន់នគរ ទ្វារទិសខាងកើត បានត្រាច់បិណ្ឌបាតតាមប្រកផ្ទះ ដោយហេតុនោះ ទើបព្រះអានន្ទពោលថា* **បិណ្ឌាយ អភិហារេសិ** *ដូច្នេះ ។*

*បទថា* **អាកិណ្ណវរលក្ខណោ** *បានដល់ ព្រះមានព្រះភាគមានលក្ខណៈល្អតាំងនៅ ឬមានលក្ខណៈប្រសើរជាច្រើនផ្សាយទៅពេញវរកាយ ។ ភាពបរិបូណ៌ លោកហៅថា* **អាកិណ្ណំ** *គឺខ្ចាយទៅ ដូចលោកពោលនៅក្នុង ( សំយុត្តនិកាយ សគាថវគ្គ ) ថា* **អាកិណ្ណលុទ្ទោ បុរិសោ អតិវេលំវ មក្ខិតោ** *បុរសដែលល្មោភផ្តេសផ្តាស ជាអ្នកប្រឡាក់ ( ដោយរាគាទិក្កិលេស ) ហួសកំណត់ ដូច្នេះ ។ អធិប្បាយថា ល្មោភខ្លាំង ។*

*បទថា* **តមទ្ទសា** *សេចក្តីថា បានឮថា ក្នុងព្រះនគរមានការឃោសនាលេងនក្ខត្តឫក្សអស់ ៧ ថ្ងៃ ។ បន្ទាប់អំពីនោះ វាយស្គរត្រាច់ប្រកាសថា នក្ខត្តឫក្សកន្លងទៅហើយ គួរប្រកបការងារចុះ ។ កាលនោះ មហាជនប្រជុំគ្នាត្រង់លានព្រះរាជវាំង សូម្បីព្រះរាជាក៏ត្រិះរិះថា នឹងត្រៀមការងារ ដូច្នេះ ទើបទ្រង់បើកសីហបញ្ជរទតពួកពល បានឃើញព្រះមហាសត្វយាងបិណ្ឌបាត ដោយហេតុនោះ ទើបព្រះអានន្ទពោលថា ព្រះរាជាពិម្ពិសារទ្រង់ឋិតលើប្រាសាទ បានទតឃើញនូវព្រះពុទ្ធនោះ ដូច្នេះ ។*

*ឥឡូវនេះ ព្រះអានន្ទ កាលសម្តែងព្រះតម្រាស់ដែលព្រះបាទពិម្ពិសារត្រាស់ដល់អមាត្យទាំងឡាយ ទើបពោលថា* **ឥមំ ភោន្តោ** *ដូច្នេះ ។*

*ក្នុងបទទាំងនោះ បទថា* **ឥមំ** *បានដល់ ព្រះរាជានោះ ទ្រង់សំដៅដល់*

ព្រះពោធិសត្វ ។ ទ្រង់ហៅពួកអមាត្យថា **ភោន្តោ** ។ បទថា **និសាមេថ** បានដល់ ចូរមើល ។ បទថា **អភិរូបោ** គឺមានរូបគួរមើល ។ បទថា **ព្រហា** គឺសម្បូរដោយកម្ពស់ និងទំហំ ។ បទថា **សុចិ** គឺមានព្រះឆវីវណ្ណបរិសុទ្ធ ។ បទថា **ចរណេន** គឺដោយការត្រាច់ទៅ ។

បទថា **នីចកុលាមិវ** សេចក្តីថា ភិក្ខុរូបនេះមិនមែនដូចអ្នកបួសចាកត្រកូលទាបឡើយ ។ **ម** អក្ខរៈ ជាបទសន្ធិ ។ បទថា **កុហឹ ភិក្ខុ គមិស្សតិ** សេចក្តីថា ព្រះបាទពិម្ពិសារត្រាស់ដោយមានបំណងថា ពួករាជទូត ចូរប្រញាប់ទៅ ដើម្បីដឹងថា ភិក្ខុរូបនេះ នឹងទៅណា ថ្ងៃនេះនឹងនៅក្នុងទីណា ព្រោះបំណងនឹងឃើញភិក្ខុរូបនោះ ។

បទថា **គុត្តទ្វារោ** គឺទ្រង់គ្រប់គ្រងនូវទ្វារ សង្រួមល្អហើយ ដោយសតិ ព្រោះមានចក្ខុដាក់ចុះ ឬគ្រប់គ្រងទ្វារដោយសតិ គឺសង្រួមដោយល្អ ដោយការគ្រងសង្ឃាដិ និងចីវរគួរជ្រះថ្លា ។ បទថា **ខិប្បំ បត្តំ អបូរេសិ** បានដល់ ទ្រង់ញ៉ាំងបាត្រ ឲ្យពេញដោយរហ័ស ដោយបរិបូណ៌ ដោយព្រះអធ្យាស្រ័យថា មិនទទួលច្រើនពេក ឬត្រឹមតែប៉ុណ្ណេះក៏ល្មម ព្រោះមានសតិសម្បជញ្ញៈ ។

បទថា **មុនិ** សេចក្តីថា ឈ្មោះថា មុនី ព្រោះបដិបត្តិដើម្បីភាពឈ្លាសម្យ៉ាងទៀត ពោលដោយវោហាររបស់សត្វលោកថា មិនទាន់ដល់នូវភាពជាអ្នកឈ្លាស ក៏ជាមុនី ព្រោះសត្វលោកទាំងឡាយ ពោលដល់អ្នកបួស មិនទាន់ដល់ព្រមដោយភាពឈ្លាស ថាជាមុនី ។ បទថា **បណ្ឌវំ អភិហារេសិ**

*បានដល់ ព្រះមានព្រះភាគយាងឡើងទៅកាន់ភ្នំបណ្ឌវៈ បានឮថា រាជទូតសួរមនុស្សថា នគរនេះ មានបព្វជិតនៅទីណា ពួកមនុស្សក៏ប្រាប់ថា មានភិក្ខុមួយរូបនៅត្រង់ញកភ្នំទិសខាងកើត លើភ្នំបណ្ឌវៈ ព្រោះដូច្នោះ ទើបព្រះរាជាយាងទៅលើភ្នំបណ្ឌវៈនោះ ទ្រង់ត្រិះយ៉ាងនេះថា ក្នុងភ្នំនេះ ពិតជាទីលំនៅ ។ បទថា* **ព្យគ្ឃុសភោវ សីហោវ គិរិគព្ភរេ** *គឺដូចគ្នានឹងខ្លាធំ ដូចគោឧសភរាជ និងដូចរាជសីហ៍ អាស្រ័យនៅក្នុងគុហាភ្នំៗ ព្រោះសត្វទាំង ៣ នេះ ជាសត្វប្រសើរបំផុត មិនខ្លាចភ័យ អាស្រ័យនៅក្នុងគុហា ព្រោះដូច្នោះ រាជទូតក៏បានប្រៀបធៀបយ៉ាងនេះ ។*

*បទថា* **ភទ្រយានេន** *គឺដោយយានដ៏ឧត្តម មានយានដំរី សេះ រថ និងវជាដើម ។ បទថា* **ស យាមភូមឹ យាយិត្វា** *គឺយាងទៅអស់ផ្លូវដែលអាចទៅបានដោយយាន មានដំរី និងសេះជាដើម ។ បទថា* **អាសជ្ជ** *គឺដល់ហើយ អធិប្បាយថា យាងទៅក្បែរភ្នំនោះ ។ បទថា* **ឧបាវិសិ** *គឺប្រថាប់គង់ ។*

*បទថា* **យុវា** *គឺនៅជាកំលោះ ។ បទថា* **ទហរោ** *គឺនៅក្មេងដោយជាតិ ។ បទថា* **បឋមុប្បត្តិតោ សុសូ** *នេះ ជាវិសេសនៈរបស់បទទាំង ២ នោះ ។ បទថា* **យុវា សុសូ** *គឺកំលោះមកតាំងពីបឋមវ័យ ។ បទថា* **ទហរោ ចាមិ** *គឺកាលនៅភាពជាកំលោះ រមែងប្រាកដ ដូចមាណព ។ បទថា* **អនីកគ្គំ** *បានដល់ ពួកពលមកចំពោះមុខ ។ ក្នុងបទថា* **ទទាមិ ភោគេ ភុញ្ជស្សុ** *នេះ គប្បីជ្រាបការភ្ជាប់សេចក្តីយ៉ាងនេះថា ខ្ញុំនឹងឲ្យភោគ-*

សម្បត្តិ ក្នុងដែនអង្គៈ មគធៈដល់លោកតាមត្រូវការ សូមលោកញុំាងពួកពលឲ្យស្អាត ចោមរោមដោយពួកពលដ៏ប្រសើរ បរិភោគនូវសម្បត្តិចុះ ។

បទថា **ឧជុំ ជនបទោ រាជ** សេចក្ដីថា បានឮថា កាលព្រះរាជាត្រាស់ថា ខ្ញុំនឹងឲ្យភោគសម្បត្តិ សូមលោកបរិភោគសម្បត្តិចុះ លោកដែលខ្ញុំសួរហើយ សូមប្រាប់ជាតិដល់ខ្ញុំចុះ ។ មហាបុរសត្រិះរិះថា បើអាត្មាអញត្រូវការរាជសម្បត្តិស្ដេចចាតុម្មហារាជិកា ក៏គប្បីអញ្ជើញអញដោយរាជសម្បត្តិរបស់ខ្លួន ។ ម្យ៉ាងទៀត អញតាំងនៅក្នុងផ្ទះ ក៏គប្បីគ្រងរាជសម្បត្តិ ជាស្ដេចចក្កពត្តិ តែព្រះរាជាមិនស្គាល់អញ ទើបត្រាស់យ៉ាងនេះ ណ្ហើយចុះ អញនឹងឲ្យព្រះរាជាទ្រង់ស្គាល់អញ ដូច្នេះហើយ ទើបបន្លឺវាចា ប្រាប់ដល់ទិសផ្លូវ និងទីដែលទ្រង់យាងមកថា **ឧជុំ ជនបទោ រាជ** ដូច្នេះជាដើម ។ ព្រះមហាបុរសកាលត្រាស់ថា **ហិមវន្តស្ស បស្សតោ** ទ្រង់សម្ដែងដល់ការមិនខ្វះខាតស្រូវ និងសម្បត្តិ ព្រោះថា សូម្បីដើមសាលព្រឹក្សធំកើតត្រង់ ប្រហោងថ្មអាស្រ័យហិមវន្តប្បទេស ក៏ចម្រើនដោយសេចក្ដីចម្រើន ៥ យ៉ាង នឹងពោលថ្វីដល់សម្ទូងដែលដាំក្នុងស្រែ ។ មហាបុរស កាលត្រាស់ថា **ធនវីរិយេន សម្បន្នោ** ឈ្មោះថា ទ្រង់សម្ដែងដល់ការមិនខ្វះខាតដោយរតនៈ ៧ និងភាពដែលមានវីរបុរសសន្ទឹកសន្ទាប់ ដែលព្រះរាជាជាសត្រូវ គ្របសង្កត់មិនបានឲ្យព្រះរាជាទ្រង់ជ្រាប ។

ព្រះមហាបុរសកាលត្រាស់ថា **កោសលស្ស និកេតិនោ** ឈ្មោះថា ទ្រង់បដិសេធភាពជាព្រះរាជាអង្គថ្មី ។ ព្រោះព្រះរាជាអង្គថ្មី លោកមិនហៅថា

**និកេតី** ។ ជនបទដែលជាទីនៅអាស្រ័យ ដោយបន្តគ្នាមកតាំងអំពីដើម ទើបលោកហៅថា **និកេតី** ប្រែថា ជាទីលំនៅ ។ ព្រះមហាបុរស ត្រាស់ថា **កោសលេសុ និកេតិនោ** ទ្រង់សំដៅដល់ព្រះបាទសុទ្ធោទនៈ ។ ដោយហេតុនោះ ព្រះមហាបុរសទ្រង់សម្តែងដល់ភោគសម្បត្តិ ដែលធ្លាក់បន្តគ្នាមក ។

ដោយហេតុមានប្រមាណប៉ុណ្ណេះ ព្រះមហាបុសទ្រង់សម្តែងដល់ភោគ-សម្បត្តិរបស់ព្រះអង្គ និងទ្រង់ប្រាប់ជាតិសម្បត្តិ ដោយបទនេះថា មានគោត្តជាអាទិច្ចគោត្ត មានជាតិជាសាកិយៈ ដូច្នេះ កាលទ្រង់បដិសេធព្រះតម្រាស់ដែលព្រះរាជាត្រាស់ថា ចូរបរិភោគនូវភោគៈទាំងឡាយចុះ ខ្ញុំឲ្យដល់លោក ទើបត្រាស់ថា បពិត្រមហារាជ អាត្មាចេញអំពីត្រកូល មិនប្រាថ្នារាជសម្បត្តិ ។ ក្នុងសេចក្តីនេះមានអធិប្បាយដូច្នេះថា បើអាត្មាប្រាថ្នារាជសម្បត្តិ នឹងមិនបោះបង់ត្រកូលដែលច្រើនដោយវីរបុរស ៨២០០០ ត្រកូល ដែលសម្បូរដោយទ្រព្យ និងសេចក្តីព្យាយាមបែបនេះឡើយ ។

ព្រះមហាសត្វ កាលទ្រង់បដិសេធពាក្យទូលរបស់ព្រះរាជាយ៉ាងនេះហើយ បន្ទាប់អំពីនោះ កាលទ្រង់សម្តែងដល់ហេតុនៃបព្វជ្ជារបស់ព្រះអង្គ ទើបត្រាស់ថា អាត្មាភាពបានឃើញទោសក្នុងកាមទាំងឡាយ បានឃើញការចេញចាកកាមជាគ្រឿងក្សេម ដូច្នេះ ។ គួរភ្ជាប់ដោយបទនេះថា **ឯវំ បព្វជិ-តោម្ហិ** ( ដោយហេតុនេះ ទើបអាត្មាបួស ) ។ ក្នុងបទទាំងនោះ បទថា **ទិស្វា** ប្រែថា ឃើញហើយ ។ បទដ៏សេស ក្នុងសូត្រនេះ គប្បីជ្រាបថា ក្នុងគាថាដើមចាកគាថានេះ បទទាំងពួង ដែលមិនទាន់បានវិចារណ៍ មានអត្ថងាយយល់

ទាំងអស់ហើយ ទើបមិនពោល ។

ព្រះមហាសត្វត្រាស់ហេតុនៃបព្វជ្ជារបស់ព្រះអង្គយ៉ាងនេះហើយ មានបំណងនឹងយាងទៅដើម្បីជាប្រយោជន៍ដល់សេចក្តីព្យាយាម កាលទូលព្រះរាជា ទើបត្រាស់ថា នឹងទៅប្រឹងប្រកបព្យាយាម ចិត្តរបស់អាត្មាភាព ត្រេកអរក្នុងព្យាយាមនុ៎ះ ដូច្នេះ ។

អធិប្បាយសេចក្តីនៃបទនោះថា មហាបពិត្រ ព្រោះអាត្មាឃើញបព្វជ្ជាទូលាយ ទើបចេញបួស ដូច្នោះ អាត្មាប្រាថ្នាបព្វជ្ជា ដែលមានប្រយោជន៍ក្រៃលែងនោះ គឺអមតនិព្វាន ដែលឈ្មោះថា បធាន ព្រោះក្រៃលែងជាងធម៌ទាំងពួង នឹងទៅដើម្បីប្រយោជន៍ដល់សេចក្តីព្យាយាម ចិត្តរបស់អាត្មាត្រេកអរក្នុងសេចក្តីព្យាយាមនេះ ដូច្នេះ ។

កាលព្រះមហាសត្វត្រាស់យ៉ាងនេះហើយ ព្រះរាជាត្រាស់នឹងព្រះពោធិសត្វថា បពិត្រលោកម្ចាស់ ខ្ញុំបានឮអំពីមុនហើយថា សិទ្ធត្ថកុមារបុត្តរបស់ព្រះបាទសុទ្ធោទនៈឃើញនូវបុព្វនិមិត្ត ៤ ប្រការ ចេញបួស នឹងបានជាព្រះពុទ្ធ ដូច្នេះ បពិត្រលោកម្ចាស់ ខ្ញុំឃើញអធ្យាស្រ័យរបស់លោក ទើបជ្រះថ្លាយ៉ាងនេះ ទ្រង់នឹងសម្រេចនូវភាពជាព្រះពុទ្ធដោយពិត សាធុ បើទ្រង់បានជាព្រះពុទ្ធហើយ សូមនិមន្តមកកាន់ដែនរបស់ខ្ញុំមុនចុះ ។ល។

**អដ្ឋកថា បព្វជ្ជាសូត្រទី ១ ចប់**

# សុត្តន្តបិដក

## បធានសូត្រទី២

[ ៤២ ] ( ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ) មារកាល ពោលនូវវាចា ប្រកបដោយសេចក្តីអាណិត ចូលទៅជិតតថាគតនោះ ដែលមានចិត្តស្ទុងទៅរកព្យាយាម បានទៅដល់ស្ទឹងនេរញ្ជរា កំពុងតែសង្វាតជុតបំផ្លាញកិលេស ដើម្បីសម្រេចនូវធម៌ ជាទីក្សេមចាកយោគៈថា អ្នកស្គាំងស្គមហើយ មានសម្បុរអាក្រក់ សេចក្តីស្លាប់កាន់តែជិតអ្នកហើយ ។

អ្នកមានសេចក្តីស្លាប់មួយពាន់ភាគហើយ នៅរស់តែមួយភាគទេ បើអ្នកមានជីវិតរស់នៅ ប្រសើរជាង ព្រោះកាលអ្នករស់នៅ គង់នឹងបានធ្វើបុណ្យទាំងឡាយ ។

កាលអ្នកប្រព្រឹត្តព្រហ្មចារ្យ និងបូជាភ្លើង គង់សន្សំបុណ្យបានច្រើន អ្នកនឹងធ្វើអ្វីកើត ដោយការព្យាយាម ។

ផ្លូវទៅរកព្យាយាម ជាផ្លូវទៅបានដោយក្រ ធ្វើបានក៏ដោយក្រ ឲ្យសម្រេចបានដោយក្រ មារបានឈរពោលគាថាទាំងឡាយនេះ ក្នុងសម្នាក់នៃព្រះពុទ្ធ ។

ព្រះមានព្រះភាគ បានត្រាស់នឹងមារនោះ ដែលមកនិយាយដូច្នោះយ៉ាងនេះថា ម្នាលមារមានចិត្តបាប អ្នកមានសេចក្តីប្រមាទជាផៅពង្ស តថាគតមកក្នុងទីនេះ ព្រោះសេចក្តីត្រូវការ ( ដោយបុណ្យ ) ណា សេចក្តីត្រូវការដោយបុណ្យនោះ សូម្បី

បន្តិចបន្តួចមិនមានដល់តថាគតឡើយ បើពួកជនណា ត្រូវការ ដោយបុណ្យ ទើបមារគួរនិយាយ ( យ៉ាងនេះ ) នឹងពួកជន នោះចុះ ។

សទ្ធាផង តបៈផង វីរិយៈផង បញ្ញាផង រមែងមានដល់ តថាគត កាលបើយ៉ាងនេះ ហេតុអ្វី ក៏អ្នកមកសួរនូវការរស់ នៅនឹងតថាគត ដែលមានចិត្តស្ទុងទៅកាន់ព្រះនិព្វាន ។

សូម្បីខ្យល់នេះ ដែលអាចញុាំងខ្សែទឹកស្ទឹងទាំងឡាយ ឲ្យរីង ស្ងួតបាន ក៏មិនអាចញុាំងឈាមរបស់តថាគត ដែលមាន ចិត្តស្ទុងទៅកាន់ព្រះនិព្វាន ឲ្យរីងស្ងួតបានតិចតួចឡើយ ។

កាលបើឈាមរីងស្ងួតហើយ ប្រមាត់ និងស្លេស្មក៏រីងស្ងួត កាលបើសាច់អស់ហើយ ចិត្តតថាគតរឹងរឹតតែជ្រះថ្លា សតិផង បញ្ញាផង សមាធិផង របស់តថាគត រឹងរឹតតែតាំងនៅមាំ ។

ចិត្តរបស់តថាគតនោះ កាលសម្រាកសម្រាន្តនៅយ៉ាងនេះ ដល់ នូវទុក្ខវេទនាដ៏ក្លៀវក្លា ក៏មិននឹកនា នូវកាមទាំងឡាយឡើយ អ្នកចូរមើលសេចក្តីបរិសុទ្ធ របស់សត្វចុះ ។

កាមទាំងឡាយជាសេនាទី ១ របស់អ្នក សេចក្តីអផ្សុក ជា សេនាទី ២ សេចក្តីឃ្លាន និងស្រេក ជាសេនាទី ៣ របស់ អ្នក តណ្ហាជាសេនាទី ៤ ថីនមិទ្ធៈជាសេនាទី ៥ សេចក្តីតក់- ស្លុតជាសេនាទី ៦ សេចក្តីសង្ស័យជាសេនាទី ៧ របស់អ្នក

ការរមិលគុណ និងសេចក្តីរឹងត្អឹង ជាសេនាទី ៨ របស់អ្នក លាភ សេចក្តីសរសើរ សក្ការៈ និងយស ដែលបានដោយអំពើខុស បុគ្គលណាលើកតម្កើងខ្លួនឯងផង បង្អាប់បង្អោនពួកជនដទៃផង ម្នាលមារ នេះជាសេនារបស់អ្នក ជាសេនាសម្រាប់ប្រហាររបស់មារ បុគ្គលមិនក្លៀវក្លា មិនឈ្នះនូវសេនានោះទេ លុះតែឈ្នះសេនានោះ ទើបបាននូវសេចក្តីសុខ ។

តថាគតនុ៎ះ គួររក្សាទុកនូវស្មៅយាប្លង ( ដូចទង់ជ័យ ) តថាគតខ្ពើមជីវិតរបស់តថាគត ( ដែលចាញ់សេនាមារ ) ការស្លាប់របស់តថាគត ក្នុងសង្គ្រាមប្រសើរជាង តថាគតចាញ់សេនាមារ ហើយរស់នៅមិនប្រសើរសោះឡើយ ។

សមណព្រាហ្មណ៍ពួកមួយ ដែលលិចលង់ក្នុងកាមទាំងនុ៎ះ រមែងមិនប្រាកដដោយ ( សីលាទិគុណ ) ឡើយ ពួកជនអ្នកមានវត្តល្អ រមែងទៅ ( កាន់ព្រះនិព្វាន ) តាមផ្លូវណា មារក៏មិនដឹងនូវផ្លូវនោះទេ ។

តថាគត បានឃើញនូវសេនាព័ទ្ធជុំវិញ ហើយក៏បែរមុខឆ្ពោះទៅ ដើម្បីតយុទ្ធនូវមារ ដែលលើកចូលមក ព្រមទាំងវាហនៈ ដោយវាចាថា អ្នកកុំញ៉ាំងតថាគត ឲ្យឃ្លាតចាកទីឡើយ លោក ព្រមទាំងទេវលោក មិនអាចគ្របសង្កត់នូវសេនារបស់អ្នកណា តថាគតអាចគ្របសង្កត់នូវសេនារបស់អ្នកនោះ

ដោយប្រាជ្ញា ដូចជាយកថ្មមកសង្កត់ នូវភាជន៍ដីឆ្អិនបាន ។

តថាគតនឹងធ្វើនូវសម្មាសង្កប្បឲ្យស្ទាត់ផង ធ្វើស្មារតីឲ្យតាំងនៅមាំផង និងទូន្មានពួកសាវកជាច្រើន ចេញអំពីដែនមួយទៅកាន់ដែនមួយ ។

ពួកសាវកនោះមិនប្រមាទ មានចិត្តស៊ុងទៅកាន់ព្រះនិព្វាន ជាអ្នកធ្វើតាមពាក្យប្រដៅតថាគត អ្នកមិនប្រាថ្នា ( នូវកាម ) ពួកសាវកនោះ នឹងទៅក្នុងទីណា ហើយមិនសោក ក៏ទៅក្នុងទីនោះ ។

( មារបានបន្លឺឧទានថា ) អាត្មាអញបានជាប់ប្រកិត តាមព្រះមានព្រះភាគ អស់ ៧ ឆ្នាំហើយ មិនបាននូវចន្លោះ គឺទោសរបស់ព្រះសម្ពុទ្ធ អ្នកមានសិរីសោះ ។

ដូចសត្វក្អែក បានហើរចឹកជុំវិញថ្ម ដែលមានពណ៌ដូចខ្លាញ់ខាប់ ដោយគិតថា អាត្មាអញគង់បានរបស់ទន់ក្នុងកន្លែងនុ៎ះខ្លះ គ្រឿងឆ្ងាញ់ពិសា គង់មានក្នុងកន្លែងនុ៎ះខ្លះមិនលែង ។

អាត្មាអញតាមយាយី ព្រះសមណគោតម ដូចគ្នានឹងក្អែក ( ដែលប្រឹងចឹក ) ថ្មក្អំ ហើយមិនបានវត្ថុឆ្ងាញ់ពិសា ក៏ហើរចេញទៅ ។

កាលមារនោះ ត្រូវសេចក្ដីសោកគ្របសង្កត់ហើយ ពិណក៏របូតចេញចាកក្លៀក តពីនោះមក មារនោះមានចិត្តអាក់អន់

*ហើយ ក៏បាត់ទៅចាកទីនោះឯង ។*

**បធានសូត្រទី ២ ចប់**

# អដ្ឋកថា

## បធានសូត្រ

[ ៤២ ] *ក្នុងបធានសូត្រទី ២ មានពាក្យផ្ដើមថា* **តំ មំ បធានបហិតត្តំ** *ដូច្នេះជាដើម ។*

*សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅនេះ*

*ព្រះអានន្ទញ៉ាំងបព្វជ្ជាសូត្រឲ្យចប់ ដោយបទថា* **បធានាយ គមិស្សាមិ ឯត្ថ មេ រញ្ជតី មនោ** *ប្រែថា នឹងទៅប្រឹងប្រកបព្យាយាម ចិត្តរបស់អាត្មាភាពត្រេកអរក្នុងព្យាយាមនុ៎ះ ដូច្នេះ ។*

*ព្រះមានព្រះភាគ ទ្រង់គង់ក្នុងព្រះគន្ធកុដិ ទ្រង់ព្រះតម្រិះថា តថាគតប្រាថ្នាសេចក្ដីព្យាយាមអស់ ៦ ឆ្នាំ ធ្វើទុក្ករកិរិយា ថ្ងៃនេះ តថាគតនឹងពោលដល់សេចក្ដីព្យាយាមនោះដល់ភិក្ខុទាំងឡាយ ។ លំដាប់នោះ ព្រះមានព្រះភាគយាងចេញអំពីព្រះគន្ធកុដិ គង់ក្នុងពុទ្ធាសនៈ ទ្រង់ប្រារព្ធថា* **តំ មំ បធានបហិតត្តំ** *ដូច្នេះហើយ ត្រាស់សូត្រនេះ ។*

*ក្នុងបទនោះ ព្រះមានព្រះភាគទ្រង់អាងដល់ព្រះអង្គ ដោយពាក្យ ២*

ម៉ាត់ថា **តំ មំ ។** បទថា **បធានបហិតត្តំ** បានដល់ មានចិត្តបញ្ជូនទៅហើយ ឬលះអត្តភាព ដើម្បីជាប្រយោជន៍ដល់ព្រះនិព្វាន ។ ព្រះមានព្រះភាគ ទ្រង់ចង្អុលបង្ហាញលក្ខណៈដោយបទថា **នទី នេរញ្ជរំ បតិ** ដូច្នេះ ។ ពិតហើយ លក្ខណៈ គឺស្ទឹងនេរញ្ជរា ព្រោះមានខ្លួនបញ្ជូនទៅហើយ ដើម្បីសេចក្តីព្យាយាម ។ ដោយហេតុក្នុងបទថា **នទី នេរញ្ជរំ** ជាទុតិយាវិភត្តិ តែមានភាពជាសត្តមីវិភត្តិថា **នទិយា នេរញ្ជរាយ** អធិប្បាយថា ក្បែរស្ទឹងនេរញ្ជរា ។ បទថា **វិបរក្កម្ម** គឺព្យាយាមក្រៃលែង ។ បទថា **ឈាយន្តំ** គឺបំពេញឈាន ដោយខ្យល់ដង្ហើមតិចតួច ។ បទថា **យោគក្ខេមស្ស បត្តិយា** គឺដើម្បីសម្រេចនិព្វានដែលក្សេមចាកយោគៈ ៤ ។

បទថា **នមុចិ** បានដល់ មារ ព្រោះមារនោះមិនព្រមលែងនូវទេវតា និងមនុស្សដែលបំណងនឹងចេញអំពីនិស្ស័យរបស់ខ្លួន និងធ្វើអន្តរាយដល់ទេវតា និងមនុស្សទាំងនោះ ដូច្នោះ ទើបលោកហៅថា **នមុចិ ។** បទថា **ករុណំ វាចំ** បានដល់ ប្រកបដោយការអាណិតអាសូរ ។ បទថា **ភាសមានោ ឧបាគមិ** បទនេះ ងាយយល់ហើយ ។ សួរថា ព្រោះហេតុអ្វីទើបមារចូលទៅជិត ឆ្លើយថា បានឮថា ថ្ងៃមួយ ព្រះមហាបុរសត្រិះរិះថា បុគ្គលស្វែងរកអាហារសព្វកាល ជាអ្នកបំណងក្នុងការរស់នៅ ដែលបុគ្គលបំណងក្នុងការរស់នៅមិនអាចនឹងសម្រេចអមតធម៌បាន ។ បន្ទាប់អំពីនោះ ព្រះមានព្រះភាគ ទ្រង់ក៏បដិបត្តិដោយការបន្ថយអាហារ ដោយហេតុនោះ ទ្រង់ក៏ស្គាំងស្គម មានពណ៌សម្បុរសៅហ្មង ។

កាលនោះ មារមិនដឹងថា នេះជាផ្លូវនៃការត្រាស់ដឹង ឬមិនមែនជាផ្លូវ ដូច្នេះហើយ ទើបពោលថា ទ្រង់បំពេញព្យាយាមដ៏ខ្លាំងក្លា ជួនកាលអាចផុតវិស័យរបស់ខ្ញុំ ទើបមកដោយគិតថា អញគប្បីនិយាយយ៉ាងនេះៗ ដូច្នេះ ។ ដោយហេតុនោះ ទើបមារពោលថា អ្នកស្គាំងស្គមហើយ មានពណ៌សម្បុរអាក្រក់ សេចក្តីស្លាប់កាន់តែជិតហើយ ដូច្នេះ ។ កាលមារពោលយ៉ាងនេះហើយ ទើបប្រកាសភាពដែលព្រះអង្គនៅជិតសេចក្តីស្លាប់ ពោលថា អ្នកមានសេចក្តីស្លាប់មួយពាន់ភាគហើយ នៅរស់តែមួយភាគទេ ដូច្នេះ ។ អត្ថនៃបទនោះដូច្នេះថា ឈ្មោះថា **សហស្សភាគោ** ព្រោះមានមួយពាន់ចំណែក ។ មានពាក្យអធិប្បាយថា អ្វីជាបច្ច័យនៃសេចក្តីស្លាប់ ។ ចំណែកមួយ ឈ្មោះថា **ឯកំសោ** ។ លោកអធិប្បាយថា មួយពាន់ចំណែក មានការសម្លឹងខ្យល់ដង្ហើមតិចតួចជាដើមនេះ ជាបច្ច័យនៃការស្លាប់របស់លោក ការរស់នៅរបស់លោក មានចំណែកមួយប៉ុណ្ណោះ បន្ទាប់ពី លោកធ្វើសេចក្តីព្យាយាម ការស្លាប់របស់លោកនៅទីជិត ដូច្នេះ ។ កាលមារប្រកាសភាពដែលទ្រង់ជិតនឹងការស្លាប់យ៉ាងនេះហើយ កាលជាស់តឿនព្រះអង្គក្នុងការរស់នៅ ទើបពោលថា បើអ្នកមានជីវិតរស់នៅប្រសើរជាង ព្រោះកាលអ្នករស់នៅ គង់នឹងបានធ្វើបុណ្យទាំងឡាយ ដូច្នេះ ។ សម័យនោះ មារកាលសម្តែងបុណ្យដែលខ្លួនឃើញ ទើបពោលថា **ចរតោ ច តេ ព្រហ្មចរិយំ** ដូច្នេះ ។

ក្នុងបទនោះ បទថា **ព្រហ្មចរិយំ** មារពោលដល់ការវៀរចាកមេថុនម្តង

ម្កាល ។ បទថា **ជូហាតោ** បានដល់ បូជាភ្លើង ។ បទដ៏សេស ក្នុងទីនោះ មានអត្ថប្រាកដច្បាស់ហើយ ។

មារកាលឲ្យព្រះអង្គបោះបង់សេចក្តីព្យាយាម ទើបពោលកន្លះគាថាថា **ទុគ្គោ មគ្គោ** ដូច្នេះ ។ ក្នុងបទនោះ គប្បីជ្រាបសេចក្តីយ៉ាងនេះថា ឈ្មោះថា **ទុគ្គោ** ព្រោះនាំទៅកាន់ការសម្ងំ ខ្យល់ ដង្ហើម តិចតួចជាដើម ឈ្មោះថា **ទុក្ករោ** ព្រោះធ្វើដោយកាយ និងចិត្តដែលជាទុក្ខ ឈ្មោះថា **ទុរភិសម្ភវោ** ព្រោះមិនអាចសម្រេចបែបនោះបាន ដោយការស្លាប់ខិតចូលមក ។ ខាងមុខអំពីនេះទៅ ព្រះសង្គីតិកាចារ្យពោលកន្លះគាថាថា **ឥមា គាថា ភណំ មារោ អដ្ឋា ពុទ្ធស្ស សន្តិកេ** ដូច្នេះ ។ អាចារ្យពួកខ្លះពោលថា ពោលទាំងមួយគាថាក៏មាន ។ តែខ្ញុំឃើញថា ត្រង់នេះ ព្រះមានព្រះភាគអាងព្រះអង្គដូចអ្នកដទៃ ត្រាស់ដល់ការកើតយ៉ាងនេះទាំងអស់ ។

ក្នុងបទទាំងនោះ បទថា **អដ្ឋា** ប្រែថា បានឈរ ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៦ ដូចតទៅនេះ ក្នុងបទថា **យេនត្ថេន** នេះ មានអធិប្បាយដូច្នេះ ម្នាលមារមានចិត្តបាប អ្នកមកទីនេះដោយប្រយោជន៍របស់ខ្លួន ដែលធ្វើអន្តរាយដល់អ្នកដទៃ ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។ ព្រះមានព្រះភាគ កាលទ្រង់បដិសេធពាក្យនេះថា ព្រោះកាលអ្នករស់នៅ គង់នឹងបានធ្វើបុណ្យទាំងឡាយ ទើបត្រាស់គាថានេះថា **អណុមត្តោបិ** ។

ក្នុងបទទាំងនោះ បទថា **បុញ្ញេន** ព្រះមានព្រះភាគត្រាស់សំដៅដល់បុណ្យដែលទៅកាន់វដ្តៈ ដែលមារពោល ។ បទដ៏សេសងាយយល់ហើយ ។

ឥឡូវនេះ ព្រះមានព្រះភាគ គំរាមមារដោយប្រារព្ធពាក្យនេះថា ការរស់នៅរបស់អ្នក មានចំណែកមួយ ទើបត្រាស់គាថានេះថា **អត្ថិ សទ្ធា** ដូច្នេះ ។ ក្នុងគាថានោះ មានអធិប្បាយដូច្នេះថា ព្រះមានព្រះភាគទ្រង់គំរាមមារយ៉ាងនេះថា ម្នាលមារមានចិត្តបាប បុគ្គលណាមិនជឿក្នុងសន្តិវរបទ គឺបទស្ងប់ដ៏ប្រសើរ ដ៏កំពូល ឬសូម្បីមានសទ្ធា ក៏ខ្ជិលច្រអូស ឬមានសទ្ធា សូម្បីប្រារព្ធព្យាយាម ក៏មានបញ្ញាថោកថយ អ្នកគួរសួរនូវការរស់នៅរបស់បុគ្គលនោះ តែតថាគតមានសទ្ធា ឈមចុះក្នុងសន្តិវរបទដ៏កំពូល តថាគតមានសេចក្តីព្យាយាម ពោល គឺសេចក្តីព្យាយាមមិនធូរថយ តាមផ្លូវកាយ និងចិត្ត ហើយតថាគតមានបញ្ញាប្រៀបដូចពេជ្រ អ្នកសួរតថាគត ដែលមានខ្លួនបញ្ជូនទៅហើយ គឺមានអធ្យាស្រ័យដ៏ប្រសើរ មានការរស់នៅយ៉ាងនេះ ព្រោះហេតុអ្វីទើបអ្នកសួរ ។ គួររួមយកសតិ និង សមាធិ ដោយ ច សព្ទ ក្នុងបទនេះថា **បញ្ញា ច មម** ដូច្នេះ។ កាលបើយ៉ាងនេះ បុគ្គលប្រកបដោយឥន្ទ្រិយ ៥ ពួកណា រមែងដល់នូវនិព្វាន អ្នកសួរដល់ការរស់នៅជាមួយតថាគត ដែលមិនវៀរឥន្ទ្រិយទាំង ៥ នោះ សូម្បីតែមួយ ដែលមានខ្លួនបញ្ជូនទៅហើយ ធ្វើអ្វី ។

ព្រះមានព្រះភាគ ទ្រង់សង្កត់នូវមារយ៉ាងនេះថា

ការរស់នៅត្រឹមមួយថ្ងៃ របស់លោកដែលប្រារព្ធសេចក្តីព្យា-

ឈាមមាំមួន របស់លោកដែលមានប្រាជ្ញា របស់លោកដែល
ឃើញការកើតឡើង និងការវិនាសទៅ ប្រសើរជាង ដូច្នេះ
មិនមែនឬ ។

កាលទ្រង់សម្តែងការប្រព្រឹត្តទៅនៃរាងកាយ និងចិត្តរបស់ព្រះអង្គ ក៏ត្រាស់ ២ គាថាថា **នទីនមបិ** ដូច្នេះជាដើម ។ ២ គាថានោះ ដោយអត្ថប្រាកដជាក់ច្បាស់ល្អហើយ តែអដ្ឋកថាបានអធិប្បាយថា ខ្យល់ណាដែលតាំងឡើងអំពីសេចក្តីព្យាយាម ក្នុងការសម្លឹងពិនិត្យនូវខ្យល់ដង្ហើមបន្តិចបន្តួច ដែលបក់បោកក្នុងសរីរៈរបស់តថាគត ខ្យល់នេះគប្បីបក់នូវទឹកក្នុងស្ទឹងគង្គា និងយមុនាជាដើម ឲ្យរីងស្ងួតទៅបាន ។ ឈាមប្រមាណ ៤ នាឡិ របស់តថាគត ដែលមានចិត្តដាច់ខាតហើយ មិនគប្បីរីងស្ងួត មិនមែនត្រឹមតែឈាមរបស់តថាគតប៉ុណ្ណោះដែលរីងស្ងួតទៅ កាលឈាមរីងស្ងួតទៅ ប្រមាត់ដែលនៅក្នុងរាងកាយ ជាប្រមាត់មានស្រោមក្តី មិនមានស្រោមក្តី រមែងរីងស្ងួតទៅ ស្លេស្មប្រមាណ ៤ នាឡិ ដែលបិទបាំងនូវអាហារដែលបរិភោគ ឬផឹកជាដើម និងអាការដទៃទៀត រមែងរីងស្ងួតទៅ ព្រោះដូច្នោះ ទឹកមូត្រ និងអាហារដែលមានរស រមែងរីងស្ងួតទៅ កាលទឹកមូត្រ និងអាហារ មានរសរីងស្ងួតទៅ សូម្បីសាច់ក៏អស់ទៅ កាលសាច់របស់តថាគតអស់ទៅដោយលំដាប់យ៉ាងនេះ ចិត្តរមែងជ្រះថ្លាដោយក្រៃលែង ចិត្តមិនបានលិចចុះ ព្រោះវត្ថុនោះជាបច្ច័យ អ្នកមិនមានចិត្តបែបនោះ ឃើញត្រឹមតែសរីរៈប៉ុណ្ណោះ ក៏ពោលថា អ្នកស្គាំងស្គម ហើយមានសម្បុរអាក្រក់ សេចក្តីស្លាប់កាន់តែជិត

អ្នកហើយ ព្រោះហេតុនោះ មិនមែនចិត្តរបស់តថាគតតែម្យ៉ាងប៉ុណ្ណោះដែលជ្រះថ្លាឡើយ សូម្បីសតិ បញ្ញា និងសមាធិរបស់តថាគត រមែងតាំងមាំដោយក្រៃលែង សេចក្តីប្រមាទក្តី ការវង្វេងក្តី ការរាយមាយរបស់ចិត្តក្តី ត្រឹមតែបន្តិចបន្តួចក៏មិនមាន កាលតថាគតរស់នៅយ៉ាងនេះ សមណៈ និងព្រាហ្មណ៍ពួកណាមួយ រមែងសោយនូវវេទនាដ៏ឈឺចាប់សព្វកាល ទាំងជាអតីត អនាគត និងបច្ចុប្បន្ន ។ ចិត្តរបស់អ្នកបានទទួលវេទនាដ៏ខ្លាំងក្លា ដែលជាគំរូនៃវេទនាទាំងនោះ រមែងសម្ងំងដល់សេចក្តីសុខរបស់អ្នកដទៃ ។ បុគ្គលដែលទុក្ខពាល់ត្រូវហើយ សម្ងឹងដល់ការក្តៅ កាលបានទទួលនូវការត្រជាក់ សម្ងឹងដល់ការត្រជាក់ កាលបានទទួលការក្តៅ សម្ងឹងដល់ភោជន កាលបានទទួលនូវការឃ្លាន សម្ងឹងដល់ទឹក កាលបានទទួលនូវការស្រេក យ៉ាងណា ចិត្តរមែងមិនសម្ងឹងក្នុងកាមគុណ ៥ ណាមួយ ក៏ដូច្នោះ ចិត្តរបស់តថាគតមិនកើតនូវអាការបែបនេះថា ធ្វើម្តេចហ្ន៎ អញគប្បីបរិភោគអាហារល្អហើយដេកសប្បាយ ម្នាលមារ ចូរអ្នកមើលភាពដែលសត្វ ជាអ្នកបរិសុទ្ធ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងភាពដែលព្រះអង្គជាអ្នកបរិសុទ្ធហើយ ដើម្បីកាច់បំបាក់នូវបំណងរបស់មារដែលមកហើយ ដោយសង្ឃឹមថានឹងឃាត់ព្រះអង្គ កាលទ្រង់ប្រកាសនឹងមារ មួយអន្លើដោយសេនាហើយ ទ្រង់សម្តែងភាពដែលព្រះអង្គ ជាបុគ្គលដែលមារ និងសេនា ឲ្យបាញ់មិនបាន ដោយអាការយ៉ាងនេះ ទើបត្រាស់ ៦ គាថាថា **កាមា តេ បឋមា សេនា ។**

ព្រោះកិលេសកាមទាំងឡាយ រមែងញ៉ាំងសត្វដែលគ្រប់គ្រងផ្ទះឲ្យវង្វេង

ក្នុងវត្ថុកាម និងកិលេសកាមទាំងឡាយនោះឯង កាលសត្វទាំងឡាយ ត្រូវកិលេសកាមគ្របសង្កត់បានហើយ ចូលទៅបួសហើយ ក៏មិនត្រេកអរក្នុងសេនាសនៈស្ងាត់ ឬក្នុងធម៌ ដែលជាអធិកុសលណាមួយ សមដូចលោកពោលថា ម្នាលអាវុសោ សេចក្តីត្រេកអរ ( មិនអផ្សុកក្នុងបព្វជ្ជានេះឯង ) ដែលបព្វជិតធ្វើបានដោយកម្រ ដូច្នេះ ។ បន្ទាប់អំពីនោះ ការស្រេកឃ្លានរមែងបៀតបៀន ព្រោះមានជីវិតទាក់ទងដោយអ្នកដទៃ ព្រោះត្រូវសេចក្តីស្រេកឃ្លានបៀតបៀន ចំណង់ក្នុងការស្វែងរក រមែងធ្វើឲ្យចិត្តនឿយណាយ កាលបើដូច្នោះ ថីនមិទ្ធៈ រមែងគ្របសង្កត់បុគ្គលដែលមានចិត្តនឿយណាយទាំងនោះ ។ បន្ទាប់អំពីនោះ កាលមិនទាន់បានសម្រេចគុណវិសេស នៅក្នុងសេនាសនៈស្ងាត់ក្នុងដងព្រៃ ដែលត្រេកអរបានដោយក្រ រមែងកើតនូវការខ្លាចមានចិត្តតក់ស្លុត កាលជនទាំងនោះកើតនូវការខ្លាច និងការរង្កៀស មិនពេញចិត្តក្នុងរសនៃវិវេកអស់កាលយូរ កើតសេចក្តីសង្ស័យ ក្នុងកិច្ចបដិបត្តិថានេះប្រហែលជាមិនមែនផ្លូវ កាលបន្ទោបង់នូវសេចក្តីសង្ស័យនោះ ព្រោះសម្រេចគុណវិសេសបន្តិចបន្តួច ក៏កើតមានះ មក្ខៈ ថម្ភៈ កាលបន្ទោបង់នូវមានះ មក្ខៈ ថម្ភៈ រមែងកើតលាភសក្ការៈ និងសេចក្តីសរសើរ ព្រោះអាស្រ័យការសម្រេចគុណវិសេសក្រៃលែងជាងនោះ ។ បុគ្គលនោះ រមែងឈ្លក់វង្វេងក្នុងលាភ ប្រកាសនូវធម្មប្បដិរូប ចូលដល់នូវផ្លូវខុស តាំងនៅក្នុងផ្លូវខុសនោះ រមែងលើកខ្លួន សង្កត់អ្នកដទៃ ដោយជាតិជាដើម ដូច្នោះគប្បីជ្រាបភាពដែលកាមជាដើម ជាសេនាទី ១ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងសេនា ១០ យ៉ាងនេះហើយ ព្រោះសេនានោះប្រព្រឹត្តទៅដើម្បីឧបការៈដល់មារមានចិត្តបាប ព្រោះប្រកបដោយធម៌ខ្មៅ ដូច្នោះ កាលទ្រង់អាងដល់មារនោះថា សេនារបស់អ្នក ... ទើបត្រាស់ថា **ឯសា នមុចិ តេ សេនា កណ្ហស្សាភិប្បហារិនី** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អភិប្បហារិនី** បានដល់ កម្ចាត់ គឺធ្វើអន្តរាយដល់សមណព្រាហ្មណ៍ទាំងឡាយ ។ បទថា **ន នំ អសូរោ ជិនាតិ ជេត្វា ច លភតេ សុខំ** សេចក្តីថា កាលបើដូច្នេះ បុគ្គលមិនហ៊ាន គឺបុគ្គលដែលមិនជាប់ជំពាក់ក្នុងកាយ និងជីវិត រមែងមិនឈ្នះសេនារបស់អ្នក តែបុគ្គលក្លាហានរមែងឈ្នះបាន កាលឈ្នះហើយ រមែងសម្រេចមគ្គសុខ និងផលសុខ ។ ព្រោះបាននូវសេចក្តីសុខ ដូច្នោះ សូម្បីតថាគតក៏ប្រាថ្នាសេចក្តីសុខនោះ ទើបរក្សានូវស្មៅយាប្លង ដូចបុរសដែលចូលសង្គ្រាម មិនព្រមរាថយ ដើម្បីឲ្យដឹងថា ខ្លួនមិនថយ ទើបចងស្មៅយាប្លងលើក្បាល ត្រង់ទង់ ឬត្រង់អាវុធ ចូរអ្នកចាំតថាគតថា ព្រះគោតមនេះ រក្សាស្មៅយាប្លងដូចគ្នា កាលមានជីវិតរបស់តថាគតដែលចាញ់សេនារបស់អ្នក គួរតិះដៀល ព្រោះដូច្នោះ ចូរអ្នកចាំយ៉ាងនេះថា ការស្លាប់របស់តថាគតក្នុងសង្គ្រាមប្រសើរជាង តថាគតចាញ់សេនារបស់មារ ហើយរស់នៅមិនប្រសើរសោះឡើយ អធិប្បាយថា តថាគតស្លាប់ក្នុងសង្គ្រាម ជាមួយនឹងបុគ្គលដែលធ្វើអន្តរាយដល់អ្នកបដិបត្តិប្រពៃ ល្អជាងចាញ់ហើយ មានជីវិតរស់នៅ ។

បើមានពាក្យសួរថា ព្រោះហេតុអ្វី ទើបស្លាប់ល្អជាង ឆ្លើយថា ព្រោះ

សមណព្រាហ្មណ៍ពួកមួយ ដែលលិចលង់ក្នុងកាមទាំងនុ៎ះ រមែងមិនប្រាកដ ដោយ ( សីលាទិគុណ ) ឡើយ ពួកជនអ្នកមានវត្តល្អ រមែងទៅ ( កាន់ព្រះនិព្វាន ) តាមផ្លូវណា មារក៏មិនដឹងនូវផ្លូវនោះទេ អធិប្បាយថា សមណ-ព្រាហ្មណ៍ពួកខ្លះ ឈមចុះទៅហើយ គឺលិចចុះទៅហើយ ចូលទៅហើយ ក្នុងសេនារបស់អ្នក មានវត្ថុកាមជាខាងដើម មានការលើកខ្លួន សង្កត់អ្នកដទៃជាទីបំផុត រមែងមិនប្រាកដ គឺរមែងមិនប្រកាសគុណទាំងឡាយ មានសីលជាដើម ដូចចូលទៅកាន់ទីងងឹត សមណព្រាហ្មណ៍ទាំងនេះ ឈមចុះទៅហើយយ៉ាងនេះ ជួនកាល ក៏ងើបឡើង ដោយន័យជាដើមថា សទ្ធាធ្វើប្រយោជន៍ឲ្យសម្រេច ដូចបុរសងើបឡើងម្តងម្កាល ហើយលិចចុះ ដូច្នោះ ។ ចំណែកពួកជនអ្នកមានវត្តល្អ មានព្រះពុទ្ធ ព្រះបច្ចេកពុទ្ធជាដើម រមែងទៅ ( កាន់ព្រះនិព្វាន ) តាមផ្លូវណា ពួកជនទាំងនោះ ក៏មិនដឹងនូវផ្លូវនោះទេ ព្រោះត្រូវសេនានោះ គ្របសង្កត់ មិនឲ្យទៅកាន់ព្រះនិព្វាន ដែលជាដែនដ៏ក្សេម ។

ចំណែកមារស្តាប់គាថានេះហើយ មិនពោលពាក្យណាមួយ ហើយក៏ចៀសចេញទៅ កាលមារនោះ ចៀសចេញទៅហើយ ព្រះមហាសត្វមិនទាន់សម្រេចគុណវិសេស យ៉ាងណា ព្រោះបំពេញទុក្ករកិរិយានោះ ទ្រង់ពិចារណាជាបន្តថា គប្បីមានផ្លូវដទៃដើម្បីការត្រាស់ដឹងឬហ្ន៎ ដូច្នេះហើយ ទើបទ្រង់សោយអាហារគ្រោតគ្រាត ល្មមមានកម្លាំង ក្នុងថ្ងៃ ១៥ កើតខែពិសាខ ទ្រង់សោយបាយាសរបស់នាងសុជាតាអំពីព្រលឹម គង់ប្រថាប់សម្រាកពេលថ្ងៃ

ក្នុងដងព្រៃ ញុំាងសមាបត្តិ ៨ ឲ្យកើតក្នុងទីនោះ ញុំាងពេលថ្ងៃ ឲ្យកន្លងទៅក្នុងវេលាល្ងាច ក៏បែរមុខទៅកាន់មណ្ឌលពោធិព្រឹក្ស ទ្រង់ក្រាលស្មៅ ៨ ក្តាប់ ដែលសោត្ថិយព្រាហ្មណ៍ប្រគេន ត្រង់គល់ពោធិ៍ ជាបុគ្គលដែលទេវតា ក្នុងសែនលោកធាតុបូជាដោយសក្ការៈដ៏ច្រើន ទ្រង់អធិដ្ឋានសេចក្តីព្យាយាមមានអង្គ ៤ ថា សូមឲ្យស្បែក សរសៃ និងឆ្អឹង សល់នៅចុះ ឯសាច់ឈាមក្នុងសរីរៈរបស់អាត្មាអញ ចង់រីងស្ងួត ក៏រីងស្ងួតទៅចុះ ដូច្នេះហើយ ទ្រង់ធ្វើប្បដិញ្ញាថា ពេលនេះ បើអញមិនសម្រេចភាពជាព្រះពុទ្ធទេ នឹងមិនទម្លាយនូវភ្នែន ដូច្នេះ គង់ត្រង់អបរាជិតបល្ល័ង្ក ។

មារមានចិត្តបាបដឹងយ៉ាងនេះហើយ ទើបគិតថា ថ្ងៃនេះ សិទ្ធត្ថ ធ្វើប្បដិញ្ញាហើយអង្គុយ ឥឡូវនេះ អញត្រូវរាំងប្បដិញ្ញារបស់សិទ្ធត្ថនោះ ទើបប្រជុំមារសេនា តាំងអំពីពោធិមណ្ឌល ដល់ទីបំផុតចក្រវាល ដែលមានបណ្តោយ ១២ យោជន៍ ខាងលើ ៩ យោជន៍ ជិះដំរីគិរិមេខលៈ កម្ពស់ប្រមាណ ១៥០ យោជន៍ និម្មិតដៃ ១០០០ កាន់យកអាវុធច្រើនប្រភេទ ប្រកាសថា ចូរចាប់ ចូរសម្លាប់ ចូរប្រហារ បណ្តាលភ្លៀងជាដើម ដូចពោលហើយក្នុងអាឡវកសូត្រ ឲ្យធ្លាក់ចុះ លុះភ្លៀងមកដល់ព្រះមហាបុរស មានប្រការដូចពោលហើយក្នុងអាឡវកសូត្រនោះឯង ។ បន្ទាប់អំពីនោះ មារយកកន្ទេរពេជ្រកាប់ក្បាលដំរី ឲ្យស្ទុះចូលទៅជិតព្រះមហាបុរស ហើយពោលថា នែសិទ្ធត្ថ ចូរក្រោកអំពីបល្ល័ង្ក មហាបុរសត្រាស់ថា ម្នាលមារ យើងមិនក្រោកឡើយ ទ្រង់ពិចារណាមើលសេនានោះដោយជុំវិញ បានត្រាស់ព្រះគាថានេះថា **សមន្តា**

**ធជិនឹ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ធជិនឹ** គឺសេនា ។ បទថា **យុត្តំ** បានដល់លើកក្បួនទ័ពចេញហើយ ។ បទថា **សវាហនំ** គឺរួមជាមួយស្ដេចដំរីគិរិមេខលៈ ។ បទថា **បច្ចុគ្គច្ឆាមិ** គឺតថាគតបែរមុខចូលទៅតយុទ្ធ ។ តែព្រះពោធិសត្វនោះ ទៅដោយតេជះ មិនមែនដោយកាយ ព្រោះហេតុអ្វី ឆ្លើយថា អ្នកកុំញុំាងយើងឲ្យឃ្លាតចាកទីឡើយ ។ លោកអធិប្បាយថា មារកុំធ្វើឲ្យយើងឃ្លាតចាកអបរាជិតបល្ល័ង្កនោះ ។ បទថា **នប្បសហតិ** គឺមិនអាចញាំញីឬគ្របសង្កត់បាន ។ បទថា **អាមបត្តំ** បានដល់ ភាជនៈដី ឆៅក្ដី ធ្និនក្ដី ។ បទថា **អម្ហនា** បានដល់ ដោយដុំថ្ម ។ បទដ៏សេស ក្នុងគាថានេះ ប្រាកដជាក់ច្បាស់ហើយ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងថា ម្នាលមារ តថាគតនឹងទម្លាយសេនារបស់អ្នក បន្ទាប់អំពីនោះ តថាគតជាអ្នកឈ្នះសង្គ្រាមហើយដល់នូវធម្មាភាភិសេក នឹងធ្វើសម្មាសង្កប្បនេះឲ្យជំនាញ ទើបត្រាស់ថា **វសី ករិត្វា** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **វសី ករិត្វា សង្កប្បំ** សេចក្ដីថា លះនូវមិច្ឆាសង្កប្បទាំងអស់ដោយមគ្គភាវនា ហើយធ្វើសង្កប្បឲ្យជំនាញ ដោយឲ្យសម្មាសង្កប្បប៉ុណ្ណោះប្រព្រឹត្តទៅ ។ បទថា **សតិញ្ច សុបតិដ្ឋិតំ** សេចក្ដីថា តថាគតនឹងធ្វើសតិរបស់ខ្លួនក្នុងឋានៈ ៤ មានកាយជាដើម ឲ្យតាំងមាំដោយល្អ ធ្វើសង្កប្បឲ្យជំនាញយ៉ាងនេះហើយ មានសតិតាំងមាំដោយល្អ ត្រាច់ទៅចាកដែន

នេះ ទៅកាន់ដែននោះ ទូន្មានសាវកជាច្រើន ទាំងទេវតា និងមនុស្ស កាលបើដូច្នោះ សាវកដែលមិនប្រមាទទាំងនោះ ដែលតថាគតទូន្មានហើយ មានចិត្តតែមួយ ធ្វើតាមពាក្យប្រៀនប្រដៅរបស់តថាគត នឹងដល់ទីដែលមិនមានសេចក្តីប្រាថ្នា ដែលជនទាំងឡាយទៅដល់ហើយ មិនសោយសោក អធិប្បាយថាទីនោះ បានដល់ អមតមហានិព្វាននោះឯង ។

លំដាប់នោះ មារពោលថា នៃភិក្ខុ លោកឃើញយើងជាយក្ខដូច្នេះហើយ មិនខ្លាចទេឬ ព្រះមានព្រះភាគត្រាស់ថា ម្នាលមារ តថាគតមិនខ្លាចទេ មារទូលថា ហេតុអ្វី មិនខ្លាច ទ្រង់ឆ្លើយថា ព្រោះតថាគតបានធ្វើបុញ្ញបារមីមានទានបារមីជាដើម ។ មារសួរថា អ្នកណាដឹងថា លោកធ្វើបារមី មានទានជាដើម ក៏ត្រាស់ថា ម្នាលមារមានចិត្តបាប ប្រយោជន៍អ្វី ដោយមហាទានក្នុងភពនេះ កាលតថាគតជាព្រះវេស្សន្តរក្នុងភពមួយ បានធ្វើឯណា ដោយអានុភាពនៃទាននោះ មហាប្រឹថពីនេះឯងជាបន្ទាល់ បានកម្រើករំពើកអស់វារៈ ៦-៧ ដង ។ កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ មហាប្រឹថពីបានកម្រើកដល់ទីបំផុតទឹក សំឡេងគំរាមគួរខ្លាច មារបានឮដូចរន្ទះ ភិតភ័យបោលនូវទង់គេចទៅ មួយអន្លើដោយសេនា ។

សម័យនោះ ព្រះមហាបុរសទ្រង់ចាក់ធ្លុះនូវវិជ្ជា ៣ ដោយយាម ៣ លុះអរុណរះឡើង ទ្រង់បន្លឺឧទានថា

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វល់តែ )

ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោល

ទៅកាន់សង្សារវដ្ដ មានជាតិដ៏ច្រើន សេចក្ដីកើតជាទុក្ខរឿយៗ ។
នៃជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺអត្តភាព តថាគតឃើញហើយ
អ្នកនឹងធ្វើផ្ទះ ( របស់តថាគត ) ទៀត មិនបានឡើយ ឆ្អឹង
ជំនីរ គឺកិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់
ហើយ ជំបូលផ្ទះ គឺអវិជ្ជា តថាគតកម្ចាត់ចោលហើយ ចិត្ត
របស់តថាគតដល់ព្រះនិព្វាន ដែលមានសង្ខារប្រាសហើយ
តថាគតបានដល់ធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ។

មារត្រឡប់មក ដោយបានឮសំឡេងឧទាន គិតថា សិទ្ធត្ថនេះប្ដេជ្ញាថា តថាគតជាព្រះពុទ្ធហើយ ទើបគិតថា ណ្ហើយចុះ អញនឹងជាប់តាមដើម្បីមើលការប្រព្រឹត្ត បើព្រះពុទ្ធអង្គនេះ មានកំហុសខុសឆ្គងផ្លូវកាយក្ដី ផ្លូវវាចាក្ដី អញនឹងកម្ចាត់ កាលមុនជាប់តាមក្នុងទីដែលព្រះពោធិសត្វគង់នៅអស់ ៦ ឆ្នាំហើយ ហើយជាប់តាមព្រះមានព្រះភាគ ដែលបានត្រាស់ដឹងហើយ អស់មួយឆ្នាំទៀត ។ ទោះជាយ៉ាងនោះ មារក៏មិនឃើញការខុសភ្លាំងភ្លាត់នៃព្រះមានព្រះភាគ ទើបពោលគាថាដោយការរារែកចិត្តថា **សត្តវស្សានិ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ឱតារំ** បានដល់ កំហុស គឺបានដល់ ឱកាស ។ បទថា **នាធិគច្ឆិស្សំ** គឺអាត្មាអញមិនបានជួប ។ បទថា **មេទវណ្ណំ** បានដល់ ដូចគ្នានឹងដុំខ្លាញ់ខាប់ ។ បទថា **អនុបរិយគា** គឺបានទៅដោយជុំវិញ ។ បទថា **មុទុ** គឺទន់ ។ បទថា **វិន្ទេម** បានដល់ អាត្មាអញនឹងបានជួប ។ បទថា **អស្សាទនា** បានដល់ សេចក្ដីសម្រេច ។ បទថា **វាយសេត្តោ** កាត់បទជា

**វាយសោ ឃដ្ដោ** បានដល់ បានក្លាយជាខ្យល់ ។ បទដ៏សេសប្រាកដច្បាស់ល្អហើយ ។ តែយោជនាលម្អិតថា មារគិតថា អញសម្ងឹងរកឱកាសជាប់តាមព្រះមានព្រះភាគអស់ ៧ ឆ្នាំ មិនលះផ្លូវ និងមិនមែនផ្លូវក្នុងទីណាមួយឡើយ សូម្បីជាប់តាមយ៉ាងនេះហើយ ក៏មិនជួបឱកាស ដូចក្អែកសម្គាល់ដុំថ្មដែលមានពណ៌ដូចខ្លាញ់ខាប់ ថាជាខ្លាញ់ខាប់ យកចំពុះចឹក មិនជួបនូវការពេញចិត្ត ទើបចឹកដោយជុំវិញ ដោយគិតថា អញនឹងជួបសាច់ទន់ត្រង់ទីនេះ ការពេញចិត្តគប្បីមានត្រង់នេះ ទើបចឹកដោយជុំវិញ ក៏មិនបាននូវការពេញចិត្តត្រង់ទីណាមួយឡើយ ក៏គិតថា នេះជាថ្មពិតៗ ហើយចៀសចេញទៅ យ៉ាងណា អញក៏ដូច្នោះដូចគ្នា ព្រោះជាបុគ្គលមានបញ្ញាតិចតួច យកចំពុះចឹកព្រះមានព្រះភាគក្នុងកាយកម្មជាដើម ជាប់តាមដោយជុំវិញ គិតថា ធ្វើម្តេចហ្ន៎ អញគប្បីជួបការទន់ មានកាយសមាចារដែលមិនបរិសុទ្ធជាដើមក្នុងទីណាមួយ ការពេញចិត្តគប្បីមានអំពីទីនោះខ្លះ ឥឡូវនេះ អញមិនបាននូវការពេញចិត្តដូចក្អែកមកដល់ក្ដុំថ្ម ហើយរួញរា គឺអញមកដល់ព្រះគោតមហើយ ចៀសចេញទៅ ។

បានឮថា កាលមារពោលយ៉ាងនេះ ក៏កើតទោមនស្សយ៉ាងខ្លាំងខ្លាព្រោះអាស្រ័យការក្តៅក្រហាយដែលឥតផល អស់ ៧ ឆ្នាំ ដោយហេតុនោះពិណាឃ្លោករបស់មារ ដែលមានអង្គាវយវៈតូចធំ ក៏ជ្រុះអំពីក្លៀក ។ បានឮថា ពិណានោះ អ្នកឈ្លាសដេញតែម្តង សំឡេងពីរោះដល់ទៅ ៤ ខែ សក្កទេវរាជទទួលពិណានោះ យកទៅឲ្យបញ្ចសិខទេវបុត្ត ។ មារនោះ សូម្បី

ជ្រុះពិណ ក៏មិនដឹង ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលមារនោះ ត្រូវសេចក្ដីសោកគ្របសង្កត់ហើយ ពិណក៏របូតចេញចាកក្លៀក តពីនោះមក មារនោះ មានចិត្តអាក់អន់ហើយ ក៏បាត់ទៅចាកទីនោះឯង ។

អាចារ្យមួយពួកពោលថា ព្រះសង្គីតិកាចារ្យពោល ។ តែពាក្យនោះមិនគាប់ចិត្តរបស់ពួកយើង ។៚

**អដ្ឋកថា បធានសូត្រទី ២ ចប់**

# សុត្តន្តបិដក

## សុភាសិតសូត្រទី៣

[ ៤៣ ] ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ វាចាដែលប្រកបដោយអង្គ ៤ ឈ្មោះថាជាសុភាសិត មិនមែនជាទុព្ភាសិតឡើយ ជាវាចាមិនមានទោសផង ដែលពួកវិញ្ញូជនមិនគប្បីតិះដៀលផង ។ ប្រកបដោយអង្គ ៤ តើដូចម្ដេច ។ គឺបុគ្គលក្នុងលោកនេះ និយាយតែវាចាជាសុភាសិត មិននិយាយវាចាជាទុព្ភាសិត ១ និយាយវាចាជាធម៌តែម្យ៉ាង មិននិយាយវាចាមិនមែនជាធម៌ ១ និយាយតែវាចាគួរស្រឡាញ់ មិននិយាយវាចា ដែលមិនគួរស្រឡាញ់ ១ និយាយតែវាចាពិត មិននិយាយវាចាឡេះឡោះ ១ ។ ម្នាលភិក្ខុទាំងឡាយ វាចាប្រកបដោយអង្គ ៤ នេះឯង ឈ្មោះថាជាសុភាសិត មិនមែនជាទុព្ភាសិតឡើយ ជាវាចាមិនមានទោសផង ដែលពួកវិញ្ញូជនមិនគប្បីតិះដៀលផង ។

ព្រះមានព្រះភាគ បានត្រាស់នូវសូត្រនេះ លុះព្រះសុគតជាសាស្ដាទ្រង់ត្រាស់នូវសូត្រនេះហើយ ទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលំដាប់តទៅថា

ពួកសប្បុរសបានពោល នូវវាចាជាសុភាសិតដ៏ឧត្តម ( នោះជាទី ១ ) ពោលនូវវាចាជាធម៌ មិនពោលនូវវាចា មិនមែនជា

ធម៌ នោះជាទី ២ ពោលវាចាគួរស្រឡាញ់ មិនពោលវាចា ដែលមិនគួរស្រឡាញ់ នោះជាទី ៣ ពោលពាក្យពិត មិនពោល ពាក្យឡេះឡោះ នោះជាទី ៤ ។

[ ៤៤ ] លំដាប់នោះឯង ព្រះវង្គីសៈដ៏មានអាយុ ក្រោកចាកអាសនៈ ព័ទ្ធចីវរឆៀងស្មាម្ខាង ហើយប្រណមអញ្ជលី ចំពោះព្រះមានព្រះភាគ រួចក្រាប បង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូម សម្ដែងធម៌ បពិត្រព្រះសុគត ខ្ញុំព្រះអង្គសូមសម្ដែងធម៌ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលវង្គីសៈ អ្នកចូរសម្ដែងធម៌ចុះ ។ លំដាប់នោះ ព្រះ វង្គីសៈដ៏មានអាយុ បានសរសើរដោយគាថាទាំងឡាយដ៏សមគួរ ក្នុងទីចំពោះ ព្រះភក្ត្រថា

បុគ្គលមិនញុំាងខ្លួនឲ្យក្ដៅក្រហាយ មិនបៀតបៀនពួកជនដទៃ ដោយវាចាណា បុគ្គលគួរពោលវាចានោះឯង វាចានោះឈ្មោះ ថា ជាសុភាសិត ។ វាចាណាដែលគួរត្រេកត្រអាល ( ឬ ) បុគ្គលមិនប្រកាន់នូវពាក្យអាក្រក់ ហើយពោលវាចាណាជា ទីស្រឡាញ់ នៃពួកជនដទៃ បុគ្គលគួរពោលវាចា ជាទីស្រឡាញ់ នោះឯង ។ វាចាពិត ជាវាចាមិនស្លាប់ នេះជាធម៌មានមកយូរ ហើយ ពួកសប្បុរសបានតាំងនៅក្នុងអត្ថផង ក្នុងធម៌ផងព្រោះ សច្ចៈ ។

ព្រះពុទ្ធទ្រង់ត្រាស់នូវព្រះវាចាណា ជាគ្រឿងក្សេម ដើម្បី

ដល់នូវព្រះនិព្វាន ដើម្បីធ្វើនូវទីបំផុតនៃទុក្ខ វាចានោះឯង
ឈ្មោះថា ជាវាចាដ៏ឧត្តម ។

សុភាសិតសូត្រទី ៣ ចប់

# អដ្ឋកថា

## សុភាសិតសូត្រ

ក្នុងសុភាសិតសូត្រទី ៣ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះ ។

ព្រះសូត្រនេះ កើតឡើងដោយអធ្យាស្រ័យរបស់ព្រះអង្គ ព្រោះថា ព្រះមានព្រះភាគ ទ្រង់ពេញព្រះហឫទ័យនូវពាក្យដែលជាសុភាសិត ។ កាលទ្រង់ហាមការពោលពាក្យអាក្រក់របស់សត្វទាំងឡាយ ដោយទ្រង់ប្រកាសវាចាជាសុភាសិតរបស់ព្រះអង្គ ទើបត្រាស់ព្រះសូត្រនេះ ។

[ ៤៣ ] ក្នុងបទទាំងនោះ បទថា **ឯវម្មេ សុតំ** ជាដើម ជាពាក្យរបស់សង្គីតិកាចារ្យ ។ ក្នុងព្រះសូត្រ បទថា **តត្រ ខោ ភគវា ។បេ។ ភគវន្តោតិ តេ ភិក្ខូ** នេះ មិនធ្លាប់បានអធិប្បាយ ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។ ព្រោះដូច្នោះ ដើម្បីពណ៌នាបទដែលមិនធ្លាប់មានមក ទើបលោកពោលពាក្យនេះ ។ បទថា **តត្រ** សំដែងដល់កាលៈ និងទេសៈ ។

ព្រះមានព្រះភាគ ទ្រង់សំដែងដល់សម័យដែលទ្រង់គង់នោះ និងក្នុង

អាកាមដែលទ្រង់គង់នោះ ម្យ៉ាងទៀត ទ្រង់សម្ដែងក្នុងទេសៈ និងកាលៈ ដែលសមគួរនឹងត្រាស់ ។ ព្រោះព្រះមានព្រះភាគមិនត្រាស់ធម៌ក្នុងទេសៈ ឬក្នុងកាលៈដែលមិនសមគួរឡើយ ដូចក្នុងសេចក្ដីនេះជាដើមថា **អកាលោ ខោ តាវ ពាហិយ** ម្នាលពាហិយៈ ឈប់សិន កាលនេះជាកាលមិនគួរ ដូច្នេះ ។ បទថា **ខោ** ជានិបាត ចុះក្នុងអត្ថត្រឹមតែធ្វើបទឲ្យពេញ ឬក្នុងអត្ថប្រាប់កាលពិតប្រាកដជាដើម ។ បទថា **ភគវា** សម្ដែងដល់សេចក្ដីគោរពរបស់សត្វលោក ។ បទថា **ភិក្ខូ** សម្ដែងដល់បុគ្គលដែលគួរស្ដាប់ពាក្យ ។ បទថា **អាមន្តេសិ** គឺហៅ ឬពោល បានដល់ ដាស់តឿនឲ្យដឹង ។ បទថា **ភិក្ខវោ** សម្ដែងការហៅរក ។ ម្យ៉ាងទៀត បទនោះ លោកពោល ព្រោះសម្រេចដោយគុណ មានភាពជាអ្នកមានប្រក្រតីសូមជាដើម ដោយហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់ប្រកាសដល់ការប្រព្រឹត្ត ដែលជនអាក្រក់ និងជនល្អសេព ( និង ) ធ្វើដល់ភិក្ខុទាំងនោះ ទើបទ្រង់រម្ងាប់មិនឲ្យ ( ភិក្ខុទាំងនោះ ) រាយមាយនិងរោយរាយ ។ ម្យ៉ាងទៀត ដោយបទថា **ភិក្ខវោ** នេះ ព្រះមានព្រះភាគ ទ្រង់ហៅភិក្ខុទាំងនោះឲ្យបែរមុខទៅរកព្រះអង្គ ដោយព្រះតម្រាស់ដែលដល់មុន គឺប្រាថ្នាសេចក្ដីករុណា និងព្រះហឫទ័យសុភាពត្រជាក់និងកែវភ្នែកដាក់ចុះ ហើយឲ្យភិក្ខុទាំងនោះ កើតនូវសេចក្ដីប្រាថ្នានឹងស្ដាប់ព្រះតម្រាស់ដែលដល់នូវភាពជាអ្នកប្រាថ្នាដើម្បីនឹងពោលនោះឯង ។ ម្យ៉ាងទៀត ដោយព្រះតម្រាស់នោះ ទ្រង់ដាស់តឿនភិក្ខុទាំងនោះ ក្នុងការដាក់ចិត្តស្ដាប់ដោយល្អ ។ ពិតហើយ ការដល់ព្រមដោយពាក្យទូន្មាន អាស្រ័យការដាក់

ចិត្តដើម្បីស្តាប់ដោយល្អ ។

បើសួរថា កាលទេវតា និងមនុស្សផងទៃមាន ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ហៅតែភិក្ខុប៉ុណ្ណោះ ឆ្លើយថា ព្រោះភិក្ខុទាំងនោះ ជាអ្នកធំ និងជាអ្នកប្រសើរ ជាអ្នកនៅជិត ត្រៀមខ្លួនសព្វកាល ។ ពិតហើយ ព្រះធម្មទេសនានេះទូទៅដល់បរិស័ទទាំងអស់ មិនចំពោះបុគ្គល ។ ភិក្ខុ ឈ្មោះថាជាអ្នកធំក្នុងបរិស័ទ ព្រោះកើតមុន ភិក្ខុ ឈ្មោះថា ជាបុគ្គលប្រសើរ ព្រោះធ្វើតាមចរិយារបស់ព្រះសាស្តាតាំងអំពីចេញបួស និងទទួលពាក្យប្រៀនប្រដៅបានសព្វគ្រប់ ឈ្មោះថា ជាអ្នកជិតស្និទ្ធ ព្រោះកាលភិក្ខុទាំងនោះអង្គុយក្នុងទីនោះ ក៏អង្គុយជិតព្រះសាស្តា ឈ្មោះថា ត្រៀមខ្លួនសព្វកាល ព្រោះជាអ្នកនៅក្នុងសម្នាក់របស់ព្រះសាស្តា ដោយហេតុនោះ ព្រះមានព្រះភាគ កាលសម្តែងធម៌ ទូទៅដល់បរិស័ទទាំងអស់ ទើបត្រាស់ហៅភិក្ខុប៉ុណ្ណោះ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងនោះ ព្រោះភិក្ខុទាំងនោះ ដូចភាជនៈទ្រទ្រង់នូវកថាដោយត្រូវបដិបត្តិតាមពាក្យប្រៀនប្រដៅ ។ បទថា **ភទន្តេ** នេះ ជាឈ្មោះនៃការគោរព ។ បទថា **តេ ភិក្ខូ** សេចក្តីថា ព្រះមានព្រះភាគត្រាស់ហៅភិក្ខុពួកណា ភិក្ខុទាំងនោះ ទទួលព្រះតម្រាស់របស់ព្រះមានព្រះភាគដែលត្រាស់ហៅ ។

បទថា **ចតូហិ អង្គេហិ** គឺអំពីហេតុ ៤ ឬដោយចំណែក ៤ ។ អង្គ ៤ មានវៀរចាកការនិយាយកុហកជាដើម ជាហេតុនៃវាចាសុភាសិត អង្គ ៤ មានពោលពិតជាដើម ជាចំណែកប្រកប ។ ម្យ៉ាងទៀត **អង្គ** សព្ទ ប្រើក្នុង

អត្ថថា ហេតុ ។ ពាក្យបញ្ចមីវិភត្តិថា **ចត្ហិ អង្គេហិ** ជាតតិយាវិភត្តិ ប្រើក្នុងអត្ថថា ចំណែកប្រកប ។ បទថា **សមន្នាគតា** គឺមកតាមជានិច្ច បានដល់ ប្រព្រឹត្តទៅហើយ និងប្រកបហើយ ។ បទថា **វាចា** បានដល់ វាចាដែលសន្ទនាគ្នា ។ វាចានោះ បានមកក្នុងពាក្យជាដើមថា វាចា ការបន្លឺគន្លងពាក្យ និងព្រះតម្រាស់ថា ក៏សម្ដីណាមិនមានទោស នាំមកនូវសេចក្ដីសុខដល់ត្រចៀក ដូច្នេះ ។ វិញ្ញត្តិវាចាយ៉ាងនេះថា បើអ្នកធ្វើកម្មដោយវាចាជាដើមឯណា វិរតិវាចាយ៉ាងនេះថា ការវៀរ ការចៀសវាង ការគេចចេញការដាកចេញចាកវចីទុច្ចរិតទាំង ៤ ។បេ។ នេះ សម្មាវាចា កើតមានក្នុងសម័យនោះ ដូច្នេះ ។ និងចេតនាដែលប្រើវាចាយ៉ាងនេះថា ម្នាលភិក្ខុទាំង-ឡាយ ផរុសវាចា ដែលបុគ្គលថ្នឹកហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយប្រព្រឹត្តទៅដើម្បីនរក ដូច្នេះជាដើម វាចាទាំងអស់នេះ លោកមិនបំណងយកក្នុងសូត្រនេះ ។ សួរថា ព្រោះហេតុអ្វី ព្រោះមិនមែនពោល ( តាមប្រក្រតី )។

បទថា **សុភាសិតា ហោតិ** បានដល់ ពោលនូវពាក្យប្រពៃ ដោយពាក្យនោះ លោកសម្ដែងភាពដែលវាចានោះនាំប្រយោជន៍មកឲ្យ ។ បទថា **ន ទុព្ភាសិតា** បានដល់ ពោលមិនប្រពៃ ។ ដោយបទនោះ លោកសម្ដែងភាពដែលវាចានោះ នាំវត្ថុដែលមិនជាប្រយោជន៍មកឲ្យ ។ បទថា **អនវជ្ជា** បានដល់ វៀរចាកទោស មានរាគៈជាដើម ដែលចាត់ថាជាទោស ។ ដោយបទនោះ លោកសម្ដែងភាពដែលវាចានោះ បរិសុទ្ធដោយហេតុ និងភាពដែលវាចានោះមិនមានទោស ដែលធ្វើឲ្យដល់នូវអគតិជាដើម ។ បទថា **អននុវជ្ជា**

៥ បានដល់ វៀរចាកការតិះដៀល ។ ដោយបទនោះ លោកសម្ដែងដល់ការដល់ព្រមដោយអាការទាំងអស់របស់វាចានោះ ។ បទថា **វិញ្ញូនំ** បានដល់បណ្ឌិតទាំងឡាយ ។ ដោយបទនោះ ទ្រង់សម្ដែងថា ក្នុងការនិន្ទា និងការសរសើរ ( របស់ ) បុគ្គលពាលយកជាប្រមាណមិនបាន ។ បទថា **កតមេហិ ចតូហិ** ជាពាក្យសួរដែលព្រះមានព្រះភាគបំណងនឹងឆ្លើយឯង ។ បទថា **ឥធ** គឺក្នុងសាសនានេះ ។ បទថា **ភិក្ខវេ** បានដល់ ហៅបុគ្គលដែលបំណងនឹងពោល ។ បទថា **ភិក្ខុ** ចង្អុលដល់បុគ្គលដែលនឹងពោលវាចាដោយប្រការដូចពោលមកហើយ ។

បទថា **សុភាសិតំ យេវ ភាសតិ** ជាពាក្យចង្អុលដល់អង្គណានីមួយក្នុងវាចាមានអង្គ ៤ ដោយទេសនាដែលជាបុគ្គលាធិដ្ឋាន ។ បទថា **នោ ទុព្ភាសិតំ** ជាការហាមវាចាដែលផ្ទុយនឹងអង្គរបស់វាចានោះ ។ ដោយបទនោះរមែងបដិសេធការឃើញថា ជួនកាល សូម្បីមុសាវាទជាដើម ក៏គួរពោលបានឬពោលដោយបទថា **នោ ទុព្ភាសិតំ** នេះ សម្ដែងដល់ការលះមិច្ឆាវាចា ។ បទថា **សុភាសិតំ** នេះ ទ្រង់សម្ដែងជាលក្ខណៈនៃវាចា ដែលបុគ្គលលះមិច្ឆាវាចាហើយគួរពោល ដូចត្រាស់ដល់ការមិនធ្វើអាក្រក់ ហើយធ្វើកុសលឲ្យដល់ព្រម ។ ដើម្បីសម្ដែងដល់អង្គនៃវាចា ព្រះមានព្រះភាគត្រាស់ដល់វាចាដែលមិនគួរពោលមុន តែមិនត្រាស់ដល់វាចាដែលគួរពោលឡើយ ។ សូម្បីក្នុងពាក្យជាដើមថា **ធម្មំយេវ** ក៏មានន័យនេះឯង ។ ក្នុងសូត្រនេះ ទ្រង់ត្រាស់ដល់ពាក្យដែលធ្វើឲ្យសុភាព វៀរចាកទោស មានញុះញង់ជាដើម ដោយបទ

នេះថា **សុភាសិតំ យេវ ភាសតិ នោ ទុព្ភាសិតំ** និយាយតែវាចាជាសុភាសិត មិននិយាយវាចាជាទុព្ភាសិត ដូច្នេះ ។ ដោយបទថា **ធម្មំ យេវ ភាសតិ នោ អធម្មំ** និយាយវាចាជាធម៌តែម្យ៉ាង មិននិយាយវាចាមិនមែនជាធម៌នេះ ទ្រង់ត្រាស់ដល់ពាក្យជាបញ្ញា មិនប្រាសចាកធម៌ វៀរចាកទោសគឺពាក្យរោយរាយ ។ ដោយបទទាំង ២ នោះ ទ្រង់ត្រាស់ដល់ពាក្យគួរស្រឡាញ់ ដែលជាពាក្យសច្ចៈ វៀរចាកពាក្យគ្រោតគ្រាត និងពាក្យឡេះឡោះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងអង្គទាំងនោះដោយប្រចក្ស ទើបទ្រង់សរុបពាក្យនោះ ដោយបទជាដើមថា **ឥមេហិ ខោ** ដូច្នេះ ។ ក្រៅអំពីនោះ ក្នុងបទនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វាចាប្រកបដោយអង្គ ៤ នេះឯង ឈ្មោះថា ជាសុភាសិត ទើប ( ស្មើគ្នា ) បដិសេធដោយធម៌ ( ត្រឹមត្រូវ ) នូវវាចាដែលប្រកបដោយចំណែកទាំង-ឡាយ មានបេយ្យាជាដើម ដោយបទមាននាមជាដើម និងដោយសម្បត្តិ មានលិង្គវចនៈ វិភត្តិ កាល និងការកៈជាដើម ដែលពួកទេវបញ្ញត្តថាជាសុភាសិត ។

វាចាប្រកបដោយការញុះញង់ជាដើម សូម្បីដល់ព្រមដោយចំណែកប្រកបជាដើម ក៏ជាវាចាទុព្ភាសិតនោះឯង ព្រោះជាវាចាដែលនាំការវិនាសមកឲ្យដល់ខ្លួន និងអ្នកដទៃ ។ វាចាប្រកបដោយអង្គ ៤ នេះ សូម្បីទាក់ទងដោយភាសារបស់អ្នកមិលក្ខៈ ឬទាក់ទងដោយភាសារបស់ស្រីបម្រើ និងអ្នក

វប៉ាំ ដូច្នោះ ក៏ជាសុភាសិតដូចគ្នា ព្រោះនាំលោកិយសុខ និងលោកុត្តរសុខ មកឲ្យ ។ បានឮថា ទាសីម្នាក់យាមស្រូវក្បែរផ្លូវ ក្នុងកោះសីហឡ ច្រៀងទាក់ទងដោយជាតិ ជរា ព្យាធិ និងមរណៈ ដោយសីហឡភាសា ភិក្ខុអ្នកបំពេញវិបស្សនា ៦០ រូប ដើរទៅតាមផ្លូវបានឮសំឡេងនោះ ក៏សម្រេចអរហត្តក្នុងទីនោះឯង នេះជាសាធកៈ ។ ម្យ៉ាងទៀត ភិក្ខុផ្ដើមវិបស្សនាឈ្មោះតិស្សៈ ទៅជិតស្រះឈូក បានឮសំឡេងស្រីបម្រើកាច់ផ្កាឈូកក្នុងស្រះ ច្រៀងនូវចម្រៀងនេះថា

**ចាតដុល្លំ កោកនទំ    សូរិយាលោកេន តជ្ជិយតេ**
**ឯវំ មនុស្សត្តគតា    សត្តា ជរាភិវេគេន មិលាយន្តិ ។**

ផ្កាឈូករីកក្នុងពេលព្រឹក ត្រូវពន្លឺព្រះអាទិត្យដុតរោល តែងរុះរោយទៅ សត្វទាំងឡាយដល់នូវភាពជាមនុស្ស ក៏យ៉ាងនោះ តែងរុះរោយទៅ ដោយអំណាចនៃជរា ដូច្នេះ ភិក្ខុក៏សម្រេចអរហត្ត ។

ក្នុងពុទ្ធន្តរ បុរសម្នាក់ចេញអំពីព្រៃ មួយអន្លើដោយកូន ៧ នាក់ បានឮសំឡេងច្រៀងរបស់ស្រីម្នាក់ ដែលបុកស្រូវថា

**ជរាយ បរិមទ្ទិតំ ឯតំ    មិលាតច្ឆវិចម្មនិស្សិតំ**
**មរណេន ភិជ្ជតិ ឯតំ    មច្ចុស្ស យសមាមិសំ ។**
**កិមីនំ អាលយំ ឯតំ    នានាកុណបេន បូរិតំ**
**អសុចិស្ស ភាជនំ ឯតំ    កទលិក្ខន្ធសមំ ឥទំ ។**

សរីរៈនេះ ត្រូវជរាញាំញី ស្បែកជ្រីវជ្រួញ រមែងបែក

ធ្លាយដោយមរណៈ ដល់នូវភាពជាអាហារ និងជាចំណី

របស់មច្ចុ ។ សរីរៈនេះ ជាទីអាស្រ័យរបស់ពួកដង្កូវ ពេញ

ដោយសាកសពច្រើនប្រការ សរីរៈនេះជាភាជនៈនៃវត្ថុដែល

មិនស្អាត សរីរៈនោះ ស្មើដោយដើមចេក ដូច្នេះ ។

បុរសនោះបានសម្រេចបច្ចេកពោធិញ្ញាណ មួយអន្លើដោយបុត្រទាំង-ឡាយ ។ម្យ៉ាងទៀត នៅមានឧទាហរណ៍ដទៃទៀត ដែលសម្រេចអរិយភូមិដោយឧបាយបែបនេះទៀត ។ នុះមិនទាន់ជាអស្ចារ្យ ភិក្ខុ ៥០០ រូប ស្តាប់គាថាដែលព្រះមានព្រះភាគ ទ្រង់ឈ្វាសក្នុងអាសយានុសយញ្ញាណ ត្រាស់ដោយន័យជាដើម **សព្វេ សង្ខារា អនិច្ចា** ដូច្នេះ បានសម្រេចអរហត្ត ។ម្យ៉ាងទៀត ទេវតា និងមនុស្សដទៃ មិនមែនតិច ស្តាប់កថាដែលជាភាសិតប្រកបដោយខន្ធ និងអាយតនៈជាដើម បានសម្រេចអរហត្ត ។

វាចាប្រកបដោយអង្គ ៤ យ៉ាងនេះ សូម្បីជាវាចាទាក់ទងដល់ភាសារបស់ពួកមិលក្ខៈ និងទាក់ទងដោយភាសារបស់អ្នកបម្រើ និងអ្នករបាំជាដើមគប្បីជ្រាបថា វាចាសុភាសិតដូចគ្នា ដោយប្រការដូច្នេះ ព្រោះវាចាសុភាសិតនោះឯង ទើបជាវាចាមិនមានទោស និងវិញ្ញូជន គឺកុលបុត្តដែលត្រូវការប្រយោជន៍ កាន់យកអត្ថជាទីតាំង មិនកាន់យកព្យញ្ជនៈ មិនតិះដៀល ។

បទថា **ឥទមវោច ភគវា** គឺព្រះមានព្រះភាគ កាលត្រាស់លក្ខណៈនៃពាក្យជាសុភាសិតនេះហើយ ។ បទថា **ឥទំ វត្វាន សុគតោ អថាបរំ**

ឯតទវោច សត្ថា សេចក្តីថា ព្រះសាស្តាត្រាស់លក្ខណៈនេះហើយ បាន ត្រាស់ ( គាថា ) ដទៃបន្តទៅទៀត ។ ព្រះសង្គីតិកាចារ្យ កាលសម្តែងគាថាដែលគួរពោលក្នុងឥឡូវនេះហើយ ទើបពោលបទទាំងអស់តទៅ ។

ក្នុងបទទាំងនោះ បទថា អបរំ លោកពោលសំដៅដល់ពាក្យជាគាថាពន្ធ ។ គាថាពន្ធនោះមាន ២ យ៉ាង គឺសម្តែងដល់ប្រយោជន៍ចំពោះដែលបំណាងដល់បុគ្គលដែលមកឯក្រោយ ឬការមិនបានស្តាប់ ការបានស្តាប់ ការចងចាំ និងធ្វើឲ្យមាំជាដើម និងសម្តែងដល់ប្រយោជន៍វិសេស ដោយការចង្អុលបង្ហាញដល់ប្រយោជន៍ដែលនឹងឲ្យកើតសេចក្តីវិនាស ដោយហេតុណាមួយមកអំពីមុន ដូចប្រយោគជាដើមថា បុរិសស្ស ហិ ជាតស្ស កុឋារី ជាយតេ មុខេ យាយ ឆិន្ទតិ អត្តានំ ពាលោ ទុព្ភាសិតំ ភណំ បុគ្គលពាលពោលពាក្យទុព្ភាសិត រមែងកាត់នូវឫសគល់នៃខ្លួន ( កុសល-មូល ) ដោយផុរសវាចាណា វាចា ( នោះ ) ដូចជាដឹងចាំង កើតក្នុងមាត់នៃបុរស ( នោះ ) ដូច្នេះ ។ តែក្នុងទីនេះ ជាពាក្យសម្តែងដល់ប្រយោជន៍តែម្យ៉ាង ។ ក្នុងបទទាំងនោះ បទថា សន្តោ គឺព្រះពុទ្ធជាដើម ។ ពិតហើយ សប្បុរសទាំងនោះ រមែងពោលពាក្យដែលជាសុភាសិតថា ជាពាក្យឧត្តមប្រសើរបំផុត ។ បទថា ទុតិយំ តតិយំ ចតុត្ថំ នេះ លោកពោលសំដៅដល់លំដាប់ដែលសម្តែងមុនហើយ ។

ក្នុងទីបំផុតនៃគាថា ព្រះវង្គីសត្ថេរជ្រះថ្លាក្នុងសុភាសិតរបស់ព្រះមានព្រះភាគ ។ ព្រះសង្គីតិកាចារ្យ កាលសម្តែងពាក្យដែលវង្គីសត្ថេរធ្វើអាការជ្រះថ្លា

នឹងពាក្យដែលព្រះមានព្រះភាគបានត្រាស់ ទើបពោលពាក្យជាដើមថា **អជ្ឈេវា អាយស្មា** ដូច្នេះ ។

[ ៤៤ ] ក្នុងបទទាំងនោះ បទថា **បដិភាតិ មំ** គឺចំណែករបស់ខ្ញុំព្រះអង្គជាក់ច្បាស់ចេញមក ។ បទថា **បដិភាតុ តំ** គឺចូរប្រាប់ចំណែក ( ដែលអ្នកយល់ ) ចេញមកចុះ ។ បទថា **សារុប្បាហិ** គឺសមគួរ ។ បទថា **អភិត្ថវិ** គឺសរសើរ ។ បទថា **ន តាបយេ** គឺមិនឲ្យអ្នកដទៃក្តៅក្រហាយដោយការក្តៅក្រហាយចិត្ត ។ បទថា **ន វិហឹសេយ្យ** គឺមិនគប្បីទម្លាយបៀតបៀនគ្នានិងគ្នា ។ បទថា **សា វេ វាចា** គឺវាចានោះ ជាសុភាសិតដោយចំណែកមួយ ។ ព្រះវង្គីសត្ថេរសរសើរព្រះមានព្រះភាគ ដោយវាចាដែលមិនញុះញង់ ដោយពាក្យដូចពោលនេះ ។ បទថា **បដិនន្ទិតា** បានដល់មានចិត្តត្រេកអរ គួរស្រឡាញ់ រហូតប្រាកដចេញចំពោះមុខ ។ បទថា **យំ អនាទាយ ទាទានិ បរេសំ ភាសតេ បិយំ** បុគ្គល កាលពោលវាចាណារមែងពោលពាក្យគួរស្រឡាញ់ ពីរោះដោយអត្ថ និងព្យញ្ជនៈ មិនពិចារណាដល់ពាក្យអាក្រក់ ពាក្យមិនជាទីស្រឡាញ់ ពាក្យគួរខ្ពើម ពាក្យគ្រោតគ្រាតរបស់អ្នកដទៃ គប្បីពោលតែវាចាគួរជាទីស្រឡាញ់តែម្យ៉ាង ។

ព្រះវង្គីសត្ថេរសរសើរព្រះមានព្រះភាគ ដោយវាចាគួរស្រឡាញ់ដោយគាថានេះ ។ បទថា **អមតា** បានដល់ វាចាដូចអមតៈ ព្រោះពីរោះ ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា **សច្ចំ ហវេ សាធុតរំ រសានំ** ពាក្យសត្យ មានរសឆ្ងាញ់ពីសា លើសរសទាំងឡាយ ដូច្នេះ ។

ម្យ៉ាងទៀត វាចា ឈ្មោះថា ជាអមតៈ ព្រោះជាបច្ច័យនៃអមតៈ គឺនិព្វាន ។ បទថា **ឯស ធម្មោ សនន្តនោ** បានដល់ ធម៌ គឺសច្ចវាចា ជាបុរាណធម៌ ជាចរិយធម៌ ជាបវេណិធម៌ ។ សច្ចៈនេះ ប្រព្រឹត្តតគ្នាមកតាំងពីបុរាណ លោកទាំងនោះ មិនពោលឡេះឡោះ ។ ដោយហេតុនោះ ទើបព្រះវង្គីសត្ថេរពោលថា **សច្ចេ អត្ថេ ច ធម្មេ ច អហុ សន្តោ បតិដ្ឋិតា** ដូច្នេះ ។ ក្នុងបទនោះ គប្បីជ្រាបថា ព្រោះតាំងនៅក្នុងសច្ចៈនោះឯង ទើបឈ្មោះថាតាំងនៅក្នុងប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ ព្រោះតាំងនៅក្នុងប្រយោជន៍នោះឯង ទើបឈ្មោះថា ជាអ្នកតាំងនៅក្នុងធម៌ ។ គប្បីជ្រាបថា ទាំង ២ នោះ ជាវិសេសនៈនៃសច្ចៈនោះឯង គឺតាំងនៅក្នុងសច្ចៈ ។ សួរថា តាំងនៅក្នុងសច្ចៈដូចម្តេច ឆ្លើយថា គឺដែលជាអត្ថ និងជាធម៌ ។ លោកអធិប្បាយថា ធ្វើនូវការពេញចិត្ត ដែលឈ្មោះថា ជាប្រយោជន៍ ព្រោះមិនប្រាសចាកប្រយោជន៍អ្នកដទៃ ។ ម្យ៉ាងទៀត លោកអធិប្បាយថា កាលមានការពេញចិត្ត រមែងធ្វើវត្ថុដែលមានភាពជាធម៌ឲ្យសម្រេច ដែលឈ្មោះថា ធម៌ ព្រោះមិនប្រាសចាកធម៌ ។ ព្រះវង្គីសត្ថេរ សរសើរព្រះមានព្រះភាគដោយសច្ចៈដោយគាថានេះ ។ បទថា **ខេមំ** បានដល់ មិនមានភ័យ គឺមិនមានអន្តរាយ ។ បើមានពាក្យសួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះឲ្យដល់នូវការរលត់កិលេស ដោយការដល់ព្រះនិព្វាន ធ្វើទីបំផុតនៃទុក្ខ អធិប្បាយថា រមែង ប្រព្រឹត្តទៅដើម្បីធ្វើទីបំផុតទុក្ខក្នុងវដ្តៈ ។

ម្យ៉ាងទៀត ព្រះពុទ្ធត្រាស់វាចាក្សេម ព្រោះប្រកាសផ្លូវក្សេម ដើម្បី

ប្រយោជន៍ដល់ព្រះនិព្វានទាំងពីរ គឺដើម្បីសម្រេចនិព្វាន ដើម្បីធ្វើទីបំផុតនៃទុក្ខ ។ បទថា **សា វេ វាចានមុត្តមា** គប្បីជ្រាបសេចក្ដីក្នុងគាថានេះយ៉ាងនេះថា វាចានោះជាវាចាប្រសើរជាងវាចាទាំងពួង ។ ព្រះវង្គីសត្ថេរសរសើរព្រះមានព្រះភាគ ដោយវាចាបញ្ញា ដោយគាថានេះ ញុំាងទេសនាឲ្យចប់ដោយធម៌កំពូល គឺអរហត្ត នេះជាពណ៌នាបទតាមលំដាប់ក្នុងព្រះសូត្រនេះ ។ បទដ៏សេស គប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ៕

## អដ្ឋកថា សុភាសិតសូត្រទី ៣ ចប់

# សុត្តន្តបិដក

## សុន្ទរិកសូត្រទី៩

[ ៤៥ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅប្របច្រាំងស្ទឹង ឈ្មោះសុន្ទរិកា ក្នុងកោសលជនបទ ។ សម័យនោះ ឯង សុន្ទរិកភារទ្វាជព្រាហ្មណ៍ បូជាភ្លើង បម្រើការបូជាភ្លើង ប្របច្រាំងស្ទឹង សុន្ទរិកា ។ សុន្ទរិកភារទ្វាជព្រាហ្មណ៍ លុះបូជាភ្លើង បម្រើការបូជាភ្លើងរួច ហើយ ក៏ក្រោកចាកអាសនៈ ក្រឡេកមើលសព្វទិសទាំង ៤ ជុំវិញ ដោយ គិតថា អ្នកណាហ្ន៎ គួរបរិភោគរបស់ជាសំណល់ អំពីយញ្ញនេះ ។ សុន្ទរិក-ភារទ្វាជព្រាហ្មណ៍ បានឃើញព្រះមានព្រះភាគ គង់ដណ្តប់ព្រះកាយ ព្រមទាំង ព្រះសិរ្ស ប្របគល់ឈើមួយដើមក្នុងទីជិត លុះឃើញហើយ ក៏កាន់យករបស់ ជាសំណល់ អំពីយញ្ញដោយដៃឆ្វេង កាន់យកល័ក្កចាន់ដោយដៃស្តាំ ចូលទៅ រកព្រះមានព្រះភាគ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់បើកព្រះសិរ្សដោយ ( ឮ ) សូរជើងនៃសុន្ទរិកភារទ្វាជព្រាហ្មណ៍ ។ លំដាប់នោះ សុន្ទរិកភារទ្វាជ-ព្រាហ្មណ៍ មានប្រាថ្នាត្រឡប់ អំពីទីនោះមកវិញ ដោយគិតថា យីអើ អ្នកដ៏ ចម្រើននេះ ជាអ្នកកំណោរទេតើ យីអើ អ្នកដ៏ចម្រើននេះ ជាអ្នកកំណោរទេ តើ ។ លំដាប់នោះ សុន្ទរិកភារទ្វាជព្រាហ្មណ៍ មានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះ សូម្បីជាអ្នកកំណោរក៏មាន បើដូច្នោះ មានតែ អាត្មាអញ ចូលទៅសួរនូវជាតិចុះ ។ លំដាប់នោះ សុន្ទរិកភារទ្វាជព្រាហ្មណ៍ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបបង្គំទូលសួរ ព្រះមានព្រះភាគដូច្នេះថា អ្នកដ៏ចម្រើន មានជាតិជាអ្វី ។ លំដាប់នោះ ព្រះ

មានព្រះភាគ ទ្រង់ត្រាស់នឹងសុន្ទរិកភារទ្វាជព្រាហ្មណ៍ ដោយគាថាដូច្នេះថា

[ ៤៦ ] តថាគតមិនមែនជាព្រាហ្មណ៍ មិនមែនជារាជបុត្ត មិនមែនជាវេស្សៈ ឬជាវណ្ណៈណាមួយក៏មិនមែន តថាគតបាន កំណត់ដឹងនូវគោត្រ របស់ពួកបុថុជ្ជន ហើយជាអ្នកមិនមាន កង្វល់ ប្រព្រឹត្តទៅដោយប្រាជ្ញាក្នុងលោក តថាគតជាអ្នក អាស្រ័យនៅនឹងសង្ឃាដិ មិនមានសេចក្តីប្រកាន់ ប្រាសចាក សក់ មានចិត្តត្រជាក់ មិនជាប់ជំពាក់នឹងពួកមនុស្ស ក្នុង លោក ( ម្នាលព្រាហ្មណ៍ ថ្វីក៏ ) អ្នកមកសាកសួរប្រស្នា ចំពោះគោត្រ ដ៏មិនសមគួរនឹងតថាគត ។

( ព្រាហ្មណ៍ក្រាបទូលថា ) បពិត្រអ្នកដ៏ចម្រើន ពួក ព្រាហ្មណ៍តែងសាកសួរ ជាមួយនឹងពួកព្រាហ្មណ៍ថា អ្នកដ៏ ចម្រើន ជាព្រាហ្មណ៍ ឬមិនមែនទេ ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) បើអ្នកនិយាយថា ខ្លួន អ្នកជាព្រាហ្មណ៍ ហើយនិយាយថា តថាគត មិនមែនជា ព្រាហ្មណ៍ទេ ។ ព្រោះហេតុនោះ តថាគត សូមសួរនូវសាវិត្តិ-សាស្ត្រ ដែលមានបទ ៣ មានអក្ខរៈ ២៤ នឹងអ្នក ។

( ព្រាហ្មណ៍ក្រាបទូលសួរថា ) ពួកឥសី មនុស្ស ក្សត្រ និងព្រាហ្មណ៍ ជាច្រើនក្នុងលោកនេះ អាស្រ័យហេតុដូចម្តេច ទើបតាក់តែងនូវគ្រឿងយញ្ញ ចំពោះពួកទេវតា ។

( ព្រះមានព្រះភាគត្រាស់ថា ) តថាគតពោលថា បុគ្គលណាដល់នូវទីបំផុតនៃវដ្តទុក្ខ ដល់នូវវេទ ( បុគ្គលនោះ ) គប្បីបាននូវគ្រឿងបូជារបស់ជនណា ក្នុងកាលជាទីបូជា គ្រឿងបូជារបស់ជននោះ រមែងសម្រេច គឺមានផលច្រើន ។

( ព្រាហ្មណ៍ក្រាបទូលថា ) ខ្ញុំព្រះអង្គ បើឃើញបុគ្គលណាមួយ ជាអ្នកដល់នូវវេទ ប្រហែលនឹងព្រះអង្គ គ្រឿងបូជារបស់ខ្ញុំព្រះអង្គនោះ គង់សម្រេចដោយពិត ព្រោះមកពីខ្ញុំព្រះអង្គ មិនបានជួបប្រទះនឹងពួកជន ប្រហែលនឹងព្រះអង្គ ទើបជនឯទៀត បរិភោគនូវនំ ឈ្មោះ បូរឡាសៈរបស់ខ្ញុំព្រះអង្គ ។

( ព្រះមានព្រះភាគត្រាស់ថា ) ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះឯង អ្នកត្រូវការដោយប្រយោជន៍ គួរអ្នកចូលទៅសួរនូវបុគ្គលអ្នកស្ងប់រម្ងាប់ ប្រាសចាកផ្សែង គឺសេចក្តីក្រោធ មិនមានទុក្ខ មិនមានសេចក្តីប្រាថ្នា អ្នកមុខជានឹងបានលោកអ្នកមានប្រាជ្ញាល្អ ក្នុងសាសនានេះមិនខាន ។

( ព្រាហ្មណ៍ក្រាបទូលថា ) បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គត្រេកអរនឹងគ្រឿងយញ្ញ ចង់បូជាគ្រឿងយញ្ញ ខ្ញុំព្រះអង្គមិនដឹង សូមព្រះអង្គដ៏ចម្រើន ប្រៀនប្រដៅខ្ញុំ ការបូជាចំពោះបុគ្គលណា មានផលច្រើន សូមព្រះអង្គប្រាប់បុគ្គលនុ៎ះដល់ខ្ញុំព្រះអង្គ ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរប្រុងសោតប្បសាទ តថាគតនឹងសម្ដែងធម៌ដល់អ្នក អ្នកកុំសួរជាតិ សួរតែកិរិយាគ្រឿងប្រព្រឹត្តចុះ ភ្លើងតែងកើតអំពីឧស ព្រះទីណាសវមុនី សូម្បីជាអ្នកមានត្រកូលថោកទាប រមែងជាអ្នកទ្រទ្រង់គុណ ជាអាជានិយៈ ហាមឃាត់ទោសដោយហិរិបានដែរ ។

( បុគ្គលណា ) បានទូន្មានខ្លួន ដោយបរមត្ថសច្ច ប្រកបដោយការទូន្មានឥន្ទ្រិយ ជាអ្នកដល់នូវមគ្គញាណទី ៤ ជាទីបំផុតនៃវេទ បានប្រព្រឹត្តមគ្គព្រហ្មចរិយៈចប់ហើយ ព្រាហ្មណ៍ណាប្រាថ្នាបុណ្យ ហើយបូជា ( ព្រាហ្មណ៍នោះ ) គួរឲ្យទេយ្យធម៌ ចំពោះបុគ្គលនោះ តាមកាលគួរ ។ ពួកជនណាបានលះបង់កាមទាំងឡាយ មិនមានសេចក្ដីប្រកាន់ មានចិត្តសង្រួមត្រង់ល្អដូចខ្នារ ព្រាហ្មណ៍ណាប្រាថ្នាបុណ្យហើយបូជាគួរឲ្យទក្ខិណាទាន ចំពោះពួកជននោះក្នុងកាលគួរ ។ ពួកជនណាប្រាសចាកតម្រេក មានឥន្ទ្រិយតាំងមាំល្អ ដូចជាព្រះចន្ទ្រផុតចាករាហុគ្រាស ព្រាហ្មណ៍គួរឲ្យទក្ខិណាទាន ចំពោះពួកជននោះក្នុងកាលគួរ ។ ពួកជនណាមិនជាប់ជំពាក់ ត្រាច់ទៅក្នុងលោក មានស្មារតីសព្វកាល លះបង់នូវសេចក្ដីប្រកាន់ ព្រាហ្មណ៍គួរឲ្យទក្ខិណាទាន ចំពោះពួកជននោះ ក្នុងកាលគួរ ។

ព្រះតថាគតណា បានលះបង់នូវកិលេសកាម ជាអ្នកប្រព្រឹត្ត គ្របសង្កត់នូវវត្ថុកាម ឬក៏ព្រះតថាគតណា ដឹងច្បាស់នូវទីបំផុតនៃជាតិ មរណៈ បានបរិនិព្វាន មានចិត្តត្រជាក់ដូចអន្លង់ទឹក ព្រះតថាគតនោះ ទើបគួរទទួលគ្រឿងបូជា ឈ្មោះបូរឡាសៈ ។ ព្រះតថាគត ស្មើដោយព្រះសម្ពុទ្ធទាំងឡាយដែលមានគុណស្មើគ្នា ឆ្ងាយអំពីពួកជនដែលមានគុណមិនស្មើ ទ្រង់មានប្រាជ្ញា មិនមានទីបំផុត មានព្រះហឫទ័យមិនជាប់ចំពាក់ ក្នុងលោកនេះ និងលោកខាងមុខ ព្រះតថាគត ទើបគួរទទួលគ្រឿងបូជា ឈ្មោះបូរឡាសៈ ។ មាយា និងមានះ មិនមាននៅក្នុងព្រះតថាគតណា ព្រះតថាគតណា ប្រាសចាកសេចក្តីលោភ មិនមានសេចក្តីប្រកាន់ មិនមានសេចក្តីប្រាថ្នា បានបន្ទោបង់នូវសេចក្តីក្រោធ មានចិត្តត្រជាក់ ឬថាព្រះតថាគតណា ជាអ្នកបណ្តេតបោលនូវបាប បានលះបង់មន្ទិល គឺសេចក្តីសោក ព្រះតថាគតនោះ ទើបគួរទទួលនូវគ្រឿងបូជា ឈ្មោះបូរឡាសៈ ។ ព្រះតថាគតណា បានលះបង់នូវកិលេសជាគ្រឿងអាស្រ័យនៅនៃចិត្ត គឺតណ្ហា និងទិដ្ឋិ ឬថា សេចក្តីប្រកាន់ណាមួយ ក៏មិនមានដល់ព្រះតថាគតណា ព្រះតថាគតនោះ ជាអ្នកមិនមានសេចក្តីប្រកាន់ក្នុងលោកនេះ និងលោកខាងមុខ ទើបគួរទទួលគ្រឿងបូជា ឈ្មោះបូរឡាសៈ ។ ព្រះ

តថាគតណា ជាអ្នកមានចិត្តតាំងមាំ បានធ្វើនូវឱឃៈ បានដឹងធម៌ដោយទិដ្ឋិដ៏ឧត្តម ជាអ្នកអស់អាសវៈ ទ្រទ្រង់រាងកាយជាទីបំផុត ព្រះតថាគតនោះ ទើបគួរទទួលគ្រឿងបូជា ឈ្មោះបូរឡាសៈ ។ កវាសវៈទាំងឡាយផង វាចាអាក្រក់ផង ដែលព្រះតថាគតណា កម្ចាត់បង់ហើយ ដល់នូវការតាំងនៅមិនបាន គឺថា មិនមាន ព្រះតថាគតនោះ ជាអ្នកបាននូវវេទ មានចិត្តផុតចាកធម៌ មានខន្ធជាដើមទាំងអស់ ទើបគួរទទួលគ្រឿងបូជា ឈ្មោះបូរឡាសៈ ។ កិលេសជាគ្រឿងជាប់ចំពាក់ទាំងឡាយ មិនមានដល់ព្រះតថាគតណា ព្រះតថាគតណា កន្លងផុតនូវកិលេសជាគ្រឿងជាប់ចំពាក់ កាលពួកសត្វជាប់ដោយមានះ ព្រះអង្គក៏មិនជាប់ដោយមានះ បានកំណត់ដឹងនូវទុក្ខ ព្រមទាំងខេត្តវត្ថុ គឺហេតុ និងបច្ច័យ ព្រះតថាគតនោះ ទើបគួរទទួលគ្រឿងបូជា ឈ្មោះបូរឡាសៈ ។ ព្រះតថាគតណា មិនអាស្រ័យនូវសេចក្ដីប្រាថ្នា ឃើញនូវព្រះនិព្វាន ជាធម៌ស្ងប់ស្ងាត់ ប្រព្រឹត្តកន្លងនូវមិច្ឆាទិដ្ឋិ ដែលជនឯទៀត គប្បីឲ្យដឹងធម៌ទាំងឡាយណាមួយជាអារម្មណ៍ គឺជាបច្ច័យ មិនមានដល់ព្រះតថាគតណា ព្រះតថាគតនោះ ទើបគួរទទួលគ្រឿងបូជា ឈ្មោះបូរឡាសៈ ។ ធម៌ទាំងឡាយទាំងខាងក្នុង និងខាងក្រៅមិនមាន ដែលព្រះតថាគតណា បានត្រាស់ដឹង កម្ចាត់បង់ហើយ ជាធម៌ដល់នូវកិរិយា

តាំងនៅមិនបាន គឺថា មិនមាន ព្រះតថាគតនោះ ជាអ្នកមានចិត្តស្ងប់ មានចិត្តផុតស្រឡះ ព្រោះអស់ទៅនៃឧបាទាន ទើបគួរទទួលគ្រឿងបូជា ឈ្មោះបូរឡាសៈ ។ ព្រះតថាគតណា បានឃើញធម៌ ជាទីអស់ទៅនៃសំយោជនៈផង ឃើញនូវធម៌ ជាទីអស់ទៅនៃជាតិផង បានបន្ទោបង់នូវគន្លងនៃរាគៈ មិនមានសេសសល់ ជាអ្នកបរិសុទ្ធ មិនមានទោស ប្រាសចាកមន្ទិល ទាំងមិនមានសេចក្តីប្រាថ្នា ព្រះតថាគតនោះ ទើបគួរទទួលគ្រឿងបូជា ឈ្មោះបូរឡាសៈ ។ ព្រះតថាគតណា មិនឃើញខ្លួនដោយខ្លួនឯង ជាអ្នកមានចិត្តតាំងមាំ មានចិត្តប្រព្រឹត្តទៅត្រង់ មានចិត្តនឹងធឹង ព្រះតថាគតនោះ មានព្រះហឫទ័យមិនរំភើប មិនរីងរូស មិនសង្ស័យ ទើបគួរទទួលគ្រឿងបូជាឈ្មោះបូរឡាសៈ ។ សភាវធម៌ទាំងឡាយ ដែលមានមោហៈជាហេតុណាមួយ មិនមានដល់ព្រះតថាគតណា ព្រះតថាគតណា បានឃើញដោយប្រាជ្ញា ក្នុងធម៌ទាំងឡាយទាំងពួង ហើយទ្រទ្រង់នូវសរីរៈជាទីបំផុត ទាំងសម្រេចនូវសម្ពោធិញ្ញាណ ជាគ្រឿងក្សេមយ៉ាងប្រសើរ ព្រះអង្គមានសេចក្តីបរិសុទ្ធ យ៉ាងអស់ជើងត្រឹមប៉ុណ្ណោះ ( ព្រះតថាគតនោះ ទើបគួរទទួលនូវគ្រឿងបូជាឈ្មោះបូរឡាសៈ ) ។

( ព្រាហ្មណ៍ក្រាបទូលថា ) ការបូជារបស់ខ្ញុំព្រះអង្គ ជាការ

បូជាមានផលពិតៗ ព្រោះខ្ញុំព្រះអង្គ បានបុគ្គលអ្នកដល់នូវវេទ ប្រហែលនឹងព្រះអង្គ ហេតុនេះ សូមព្រះមានព្រះភាគ ជាបន្ទាល់ ដ៏ប្រសើរ ទទួលគ្រឿងបូជារបស់ខ្ញុំព្រះអង្គ សូមព្រះមាន ព្រះភាគ សោយគ្រឿងបូជាឈ្មោះបូរឡាសៈ របស់ខ្ញុំព្រះអង្គ ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) តថាគត មិនគួរបរិភោគ ភោជន ដែលបានមកអំពីការពោលគាថាទេ ម្នាលព្រាហ្មណ៍ នេះ មិនមែនជាធម្មតា របស់ពួកបុគ្គលអ្នកឃើញ ( ធម៌ ) ទេ ព្រះ ពុទ្ធទាំងឡាយ តែងបន្ទោបង់នូវអាហារ ដែលពោលគាថា ម្នាល ព្រាហ្មណ៍ កាលបើធម៌មានហើយ នេះឯងជាគ្រឿងចិញ្ចឹម ជីវិត ។ អ្នកចូរទំនុកបម្រុង បុគ្គលជាខីណាស្រព មានគុណដ៏ បរិបូណ៌ អ្នកស្វែងរកនូវគុណដ៏ធំ អ្នករម្ងាប់សេចក្ដីពិស ដោយបាយ និងទឹកដទៃ ព្រោះថា នុ៎ះជាខេត្តរបស់បុគ្គលអ្នក ប្រាថ្នាបុណ្យ ។

( ព្រាហ្មណ៍ក្រាបទូលថា ) បពិត្រព្រះមានព្រះភាគ សូមទ្រង់ ព្រះមេត្តាប្រោស ទក្ខិណេយ្យបុគ្គលណា គួរបរិភោគទក្ខិ-ណាទាន របស់បុគ្គលដូចជាខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គបានដល់នូវ សាសនានៃព្រះអង្គ ស្វែងរកទក្ខិណេយ្យបុគ្គលណា នឹងទំនុក បម្រុង ក្នុងកាលដែលបូជា ខ្ញុំព្រះអង្គដឹងច្បាស់ ( នូវទក្ខិ-ណេយ្យបុគ្គលនោះ ) ដោយប្រការដូច្នោះ ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) សេចក្តីប្រណាំងប្រជែង របស់បុគ្គលណា ទៅប្រាសហើយផង ឬចិត្តរបស់បុគ្គលណា មិនល្អក់ផង បុគ្គលណា ផុតស្រឡះចាកកាមទាំងឡាយផង សេចក្តីងោកងក់ ដែលបុគ្គលណាបន្ទោបង់ហើយផង អ្នកទាំងឡាយ ចូរបំបាត់នូវការក្រញូវមុខ ហើយផ្គងអញ្ជលីនមស្ការ បូជាបុគ្គលអ្នកទូន្មាននូវពួកបុថុជ្ជន និងសេក្ខបុគ្គល អ្នកដឹងច្បាស់នូវជាតិនិងមរណៈ ជាអ្នកប្រាជ្ញ បរិបូណ៌ដោយប្រាជ្ញា ប្រាកដដូច្នោះ មកកាន់ទីជាទីបូជានោះ ដោយម្ហូបចំណី និងទឹក កាលបើយ៉ាងនេះ ទក្ខិណាទានទាំងឡាយ រមែងសម្រេច ។

( ព្រាហ្មណ៍ក្រាបទូលថា ) ព្រះពុទ្ធដ៏ចម្រើន ព្រះអង្គជាបុញ្ញក្ខេត្តដ៏ប្រសើរ គួរទទួលគ្រឿងបូជាឈ្មោះបូរឡាសៈ ជាការបូជាក្នុងលោកទាំងអស់ ទានដែលបុគ្គលឲ្យហើយ ចំពោះព្រះពុទ្ធដ៏ចម្រើន មានផលច្រើន ។

[ ៨៧ ] លំដាប់នោះ សុន្ទរិកភារទ្វាជព្រាហ្មណ៍ បានក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើន សំដែងហើយដោយអនេកបរិយាយ ដូចជាគេផ្ងារនូវរបស់ដែលផ្កាប់ ឬបើកបង្ហាញនូវរបស់ដែលកំបាំង ពុំនោះសោត ដូចគេប្រាប់ផ្លូវ ដល់មនុស្សវង្វេងផ្លូវ ឬដូចជាគេទ្រោលប្រទីបប្រេង បំភ្លឺក្នុងទីងងឹត ដោយ

គិតថា ឲ្យពួកមនុស្សមានភ្នែក មើលឃើញរូបទាំងឡាយបាន ខ្ញុំព្រះអង្គនោះ សូមដល់ព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ ខ្ញុំព្រះអង្គគួរបានទូវបព្វជ្ជា គួរបានទូវឧបសម្បទា ក្នុងសម្នាក់ព្រះគោតមដ៏ចម្រើន ។ សុន្ទរិកភារទ្វាជព្រាហ្មណ៍ បានបព្វជ្ជា បានឧបសម្បទាក្នុងសម្នាក់ព្រះមានព្រះភាគ ។បេ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះសុន្ទរិកភារទ្វាជៈដ៏មានអាយុ ក៏ជាព្រះអរហន្តមួយដែរ ។

សុន្ទរិកភារទ្វាជសូត្រទី ៤ ចប់

# អដ្ឋកថា

## សុន្ទរិកភារទ្វាជសូត្រ

ក្នុងបូរឡាសសូត្រទី ៤ មានពាក្យផ្តើមថា **ឯវំ មេ សុតំ** ដូច្នេះ ។

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្តេច ឆ្លើយថា ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ក្នុងកាលសោយព្រះក្រយាហារស្រេចហើយ ទតឃើញព្រាហ្មណ៍ឈ្មោះសុន្ទរិកភារទ្វាជៈ ដល់ព្រមដោយឧបនិស្ស័យនៃអរហត្ត ទ្រង់ជ្រាបថា កាលតថាគតទៅក្នុងទីនោះ នឹងបានទូវការសន្ទនា បន្ទាប់អំពីនោះ កាលចប់ការសន្ទនា ព្រាហ្មណ៍នោះស្តាប់ធម្មទេសនាហើយ នឹងបួស សម្រេចអរហត្ត ដូច្នេះ ទើបទ្រង់យាងទៅក្នុងទីនោះ ផ្តើមសន្ទនា ហើយត្រាស់សូត្រនេះ ។

[ ៤៥ ] ក្នុងបទទាំងនោះ បទថា **ឯវម្មេ សុតំ** ជាដើម ជាពាក្យរបស់សង្គីតិកាចារ្យ ។ បទថា **កឹជច្ចោ ភវំ** អ្នកមានជាតិអ្វី ដូច្នេះ ជាពាក្យនៃព្រាហ្មណ៍នោះ ។ ពាក្យថា **ន ព្រាហ្មណោ នោម្ហិ** ជាដើម ជាព្រះតម្រាស់របស់ព្រះមានព្រះភាគ ។ សរុបរឿងទាំងអស់នោះ ហៅថា បូរ-ឡាសសូត្រ ។ គប្បីជ្រាបពាក្យអធិប្បាយហើយក្នុងសូត្រនេះ តាមន័យដែលពោលហើយនោះឯង ។ ខ្ញុំនឹងពណ៌នាពាក្យដែលមិនទាន់បានពោល ។ និងមិនប៉ះពាល់ពាក្យដែលមានអត្ថងាយយល់ហើយ ។ បទថា **កោសលេសុ** បានដល់ ព្រះរាជកុមារអ្នកជនបទឈ្មោះកោសល ។ ជាជនបទមួយដែលជាទីប្រថាប់របស់ព្រះរាជកុមារទាំងនោះ លោកហៅថា **កោសលា** ( គឺជាពហុវចនៈ ) ព្រោះការក្លាយសព្ទ ។ ក្នុងដែនកោសលជនបទនោះ ។ តែអាចារ្យពួកខ្លះពណ៌នាថា កាលមុន ព្រះរាជាទ្រង់ស្តាប់ថា មហាបនាទរាជ-កុមារ ទតការរាំហើយ មិនសម្តែងអាការសូម្បីត្រឹមតែការញញឹម ទើបត្រាស់ថា អ្នកណាធ្វើរាជបុត្តរបស់យើងឲ្យសើចបាន យើងនឹងឲ្យអាភរណៈសព្វយ៉ាងដល់អ្នកនោះ ។ បន្ទាប់អំពីនោះ ពួកមហាជន ដាក់នង្គ័លប្រជុំគ្នា ពួកមនុស្សសម្តែងអាការផ្សេងៗ ជាង ៧ ឆ្នាំ ក៏មិនអាចឲ្យព្រះរាជកុមារញញឹមបាន ។ គ្រានោះ សក្កទេវរាជទ្រង់បញ្ជូនអ្នកកំប្លែង ដែលជាទេវតាទៅ ។ អ្នករបាំដែលជាទេវតាសម្តែងសិប្បៈដែលជាទិព្វហើយ ធ្វើឲ្យព្រះរាជកុមារទ្រង់សើចបាន ។ ទើបពួកមនុស្សទាំងនោះនាំគ្នា ត្រឡប់ទៅកាន់លំនៅរៀងៗខ្លួន ។ ពួកមនុស្សឃើញមិត្រ និងសម្លាញ់ជាដើម ធ្វើដំណើរប្រាសផ្លូវមក

បានធ្វើបដិសណ្ឋារៈថា **កច្ចិ ភោតោ កុសលំ កច្ចិ ភោតោ កុសលំ** នៃអ្នក តើឈ្លាសដែរឬទេ នៃអ្នក តើឈ្លាសដែរឬទេ ព្រោះដូច្នោះ ប្រទេសនោះហៅថា **កោសល** សំដៅដល់ សំឡេងថា **កោសលំ កោសលំ** នោះ ។ បទថា **សុន្ទរិកាយ ឆរិយា តីរេ** គឺត្រង់ច្រាំងស្ទឹងដែលមានឈ្មោះថា សុន្ទរិកា ។ បទថា **តេន ខោ បន** បានដល់ ដោយសម័យដែលព្រះមានព្រះភាគមានបំណងនឹងទូន្មានព្រាហ្មណ៍នោះ ទើបយាងទៅគង់ដោយឥរិយាបថគង់ ទ្រង់ទទូរសីសៈ ត្រង់គល់ឈើប្របច្រាំងស្ទឹងនោះ ។

បទថា **សុន្ទរិកភារទ្វាជោ** បានដល់ ព្រាហ្មណ៍នោះ នៅត្រង់ច្រាំងស្ទឹងនោះ ហើយបូជាភ្លើង ។ ពិតហើយ ភារទ្វាជៈជាគោត្តរបស់ព្រាហ្មណ៍ ព្រោះដូច្នោះ ទើបលោកពោលយ៉ាងនោះ ។ បទថា **អគ្គឹ ជុហាតិ** បានដល់ ឲ្យភ្លើងឆេះដោយការដាក់គ្រឿងបូជា ។ បទថា **អគ្គិហុតំ បរិចរតិ** បានដល់ បម្រើការបូជាភ្លើង គឺចូលទៅកាន់ទីបន្ទាត់ភ្លើង ដោយការបោស ការលាប និងពលីកម្មជាដើម ។ បទថា **កោ នុ ខោ ឥមំ ហព្យសេសំ ភុញ្ជេយ្យ** សេចក្តីថា បានឮថា ព្រាហ្មណ៍នោះបូជាភ្លើង ឃើញបាយាសដែលសេសសល់ គិតថា មហាព្រហ្មបរិភោគបាយាស ដែលដាក់ក្នុងភ្លើង តែបាយាសនេះនៅ បើអញឲ្យបាយាសនោះដល់ព្រាហ្មណ៍ ដែលកើតអំពីមាត់ព្រហ្មសូម្បីកូន និងឪពុក របស់អញ ក៏គប្បីឆ្លូត ផ្លូវទៅកាន់ព្រហ្មលោក ឈ្មោះថា អញជម្រះល្អហើយ ណ្ហើយចុះ អញនឹងស្វែងរកព្រាហ្មណ៍ ។ គ្រានោះភារទ្វាជព្រាហ្មណ៍ក្រោកអំពីទីអគ្គិយ ដើម្បីរកព្រាហ្មណ៍ សម្លឹងមើលទិសទាំង

*៤ ដោយគិតថា អ្នកណាហ្ន៎ គួរបរិភោគបាយាសដែលសល់នេះ ។ បទថា* **អញ្ញតរស្មឹ រុក្ខមូលេ** *បានដល់ ត្រង់គល់ឈើដ៏ប្រសើរ ក្នុងដងព្រៃនោះ ។ បទថា* **សសីសំ ចារុតំ** *គឺទទូរកាយរហូតដល់សីសៈ ។ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគធ្វើយ៉ាងនោះ ហេតុមានដូច្នេះថា ជាអ្នកមានកម្លាំងដូចព្រះនរាយក៏មិនអាចហាមមិនឲ្យសន្សើមធ្លាក់ ឬការរងា និងខ្យល់បាន ។ ពិតហើយ ព្រះពុទ្ធទាំងឡាយ ទ្រង់មិនផ្គាប់ផ្គុន ព្រះវរកាយដោយប្រការទាំងពួងក៏ពិត តែទ្រង់ត្រិះរិះថា កាលព្រាហ្មណ៍មករក តថាគតបើកក្បាល កាលព្រាហ្មណ៍ឃើញ នឹងបានសន្ទនាគ្នា កាលបើដូច្នោះ តថាគតនឹងសម្តែងធម៌ឲ្យព្រាហ្មណ៍ស្តាប់ អនុលោមទៅតាមពាក្យរបស់តថាគត ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ធ្វើយ៉ាងនេះ ដើម្បីបានសន្ទនាគ្នា ។ បទថា* **ទិស្វាន ភាគវន្តំ ។បេ។ តេនុបសង្កមិ** *សេចក្តីថា បានឮថា ព្រាហ្មណ៍នោះ ឃើញព្រះមានព្រះភាគហើយ គិតថា បុរសនេះទទូរក្បាល ប្រកបដោយសេចក្តីព្យាយាមអស់រាត្រី អញនឹងឲ្យទក្ខិណោទក ហើយឲ្យបាយាស ដែលសល់នេះ សម្គាល់ថាជាព្រាហ្មណ៍ ទើបចូលទៅរក ។ បទថា* **មុណ្ឌោ អយំ ភវំ មុណ្ឌកោ អយំ ភវំ** *សេចក្តីថា លុះព្រះមានព្រះភាគបើកសីសៈ ព្រាហ្មណ៍ឃើញព្រះកេសា ទើបពោលថា* **មុណ្ឌោ** *ដូច្នេះ ។ ពេលនោះ ព្រាហ្មណ៍សម្លឹងមើលមិនឃើញចុងព្រះកេសាតែបន្តិច ទើបពោលថា* **មុណ្ឌកោ** *ដូច្នេះ ព្រោះថា ព្រាហ្មណ៍នោះ មានទិដ្ឋិបែបនេះ ។ បទថា* **តតោវ** *បានដល់ ចាកទីដែលគាត់ឈរ ហើយបានឃើញ ។ បទថា* **មុណ្ឌាបិ ហោន្តិ** *បាន*

ដល់ សូម្បីព្រាហ្មណ៍ពួកខ្លះ ក៏ជាបុគ្គលក្បាលត្រងោល ដោយហេតុឯណាមួយ ។

**ន** អក្ខរៈ ក្នុងបទថា **ន ព្រាហ្មណោ នោម្ហិ** នេះ ចុះក្នុងអត្ថបដិសេធ **នោ** អក្ខរៈ ចុះក្នុងអវធារណៈ ដូចក្នុងប្រយោគថា **ន នោ សមំ** ទ្រព្យ និងរតនវត្ថុទាំងនោះ ស្មើដោយព្រះតថាគតមិនមានឡើយ ដូច្នេះជាដើម ។ ដោយបទនោះ ព្រះមានព្រះភាគត្រាស់ប្រាប់ថា តថាគតមិនមែនព្រាហ្មណ៍ ដូច្នេះ ។ បទថា **ន រាជបុត្តោ** តថាគត មិនមែនជារាជឱរស ។ បទថា **ន វេស្សាយនោ** បានដល់ តថាគតមិនមែនជាវេស្សៈ។ បទថា **ឧទ កោចិ នោម្ហិ** មិនមែនជាសូទ្រៈ ឬចណ្ឌាលណាមួយឡើយ ។ ព្រះមានព្រះភាគ ទ្រង់បដិសេធពាក្យពោល ដោយអាងដល់ជាតិ ដោយឥតសេសសល់យ៉ាងនេះ ។ សួរថា ព្រោះហេតុអ្វី ព្រោះកុលបុត្តដែលបានបួសហើយ រមែងលះនូវឈ្មោះ និងគោត្តដែលមានមកអំពីមុន ដូចទឹកស្ទឹងហូរទៅកាន់មហាសមុទ្ទ ដូច្នោះ បហារាទសូត្រជាសាធកៈក្នុងសេចក្តីនេះ ។ ព្រះមានព្រះភាគ ទ្រង់ជំទាស់ពាក្យពោលដល់ជាតិយ៉ាងនេះ ទ្រង់បើកព្រះអង្គតាមសេចក្តីពិត ត្រាស់ថា តថាគតបានកំណត់ដឹងនូវគោត្តរបស់ពួកបុថុជ្ជន ហើយមិនមានកង្វល់ ប្រព្រឹត្តទៅដោយប្រាជ្ញា ក្នុងលោក ដូច្នេះ ។ បើមានពាក្យសួរថា ព្រះមានព្រះភាគបានកំណត់ដឹងគោត្តដូចម្តេច ឆ្លើយថា ព្រោះព្រះមានព្រះភាគ ទ្រង់កំណត់បញ្ចក្ខន្ធទាំងឡាយដោយបរិញ្ញា ៣ កាលទ្រង់កំណត់ដឹងបញ្ចក្ខន្ធដូច្នេះហើយ ឈ្មោះថា ទ្រង់កំណត់ដឹងដោយគោត្តបានទាំងអស់ ។ ទ្រង់មិនមាន

កន្ទល់ ព្រោះមិនមានកន្ទល់ដោយរាគៈជាដើម ទ្រង់ដឹងដោយបញ្ញា ត្រាច់ទៅដោយកាយកម្មជាដើម ដែលវិលទៅតាមញាណទាំងឡាយ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា តថាគតបានកំណត់ដឹងនូវគោត្តរបស់ពួកបុថុជ្ជន ហើយមិនមានកន្ទល់ ប្រព្រឹត្តទៅដោយប្រាជ្ញាក្នុងលោកដូច្នេះ ។ បញ្ញា លោកហៅថា **មន្តា** ។ ព្រះអង្គត្រាច់ទៅដោយបញ្ញានោះ ។ ដោយហេតុនោះឯង ទើបត្រាស់ថា **មន្ត ចរាមិ លោកេ** ធ្វើជារស្សៈដោយអំណាចនៃឆន្ទ ( ដំណើររបស់កាព្យ ) ។

ព្រះមានព្រះភាគ កាលទ្រង់បើកព្រះអង្គយ៉ាងនេះហើយ ឥឡូវនេះកាលជំទាស់នឹងពាក្យរបស់ព្រាហ្មណ៍ដោយព្រះតម្រាស់ថា អ្នកឃើញបុគ្គលមានភេទប្រសើរយ៉ាងនេះហើយ នៅមិនដឹងពាក្យដែលគួរសួរ ឬមិនគួរសួរក៏ត្រាស់ថា **សង្ឃាដិវាសី ។បេ។ គោត្តបញ្ហំ** ។

ក្នុងគាថានេះ មានអធិប្បាយដូច្នេះថា ចីវរសម្បី ៣ ផ្ទាំង លោកហៅថា សង្ឃាដី ព្រោះកាត់តគ្នា ។ ឈ្មោះថា **សង្ឃាដិវាសី** ព្រោះដណ្តប់ចីវរទាំងនោះ ។ បទថា **អគហោ** បានដល់ មិនមានផ្ទះ ។ អធិប្បាយថា មិនមានតណ្ហា ។ ផ្ទះដែលប្រថាប់ក្នុងវត្តជេតពន របស់ព្រះមានព្រះភាគមានច្រើន ដូចជាមហាគន្ធកុដិ រោងមណ្ឌល ក្រោមដើមជលា កុដិដើមម្កាក់ រោងដើមចាន់ មិនគួរសំដៅយកផ្ទះដែលប្រថាប់នោះ ។ បទថា **និវុត្តកេសោ** បានដល់ កោរសក់ អធិប្បាយថា កោរនូវសក់ និងពុកមាត់ បទថា **អភិ-និព្វុតត្តោ** បានដល់ មានចិត្តស្ងប់ចាកការក្តៅក្រហាយ ឬមានចិត្តគ្រប់គ្រង

ហើយ ។ បទថា **អលិម្បមានោ ឥធ មាណវេហិ** គឺមិនជាប់ មិនប្រឡូកប្រឡំជាមួយមនុស្សទាំងឡាយ ព្រោះលះនូវការជាប់ជំពាក់ក្នុងរបស់ប្រើប្រាស់បានហើយ គឺនៅយ៉ាងស្ងាត់ ដោយចំណែកមួយ ។ បទថា **អកល្លំ មំ ព្រាហ្មណ** សេចក្ដីថា តថាគតស្លៀកដណ្ដប់ត្រៃចីវរយ៉ាងនេះ ។បេ។ មិនប្រឡូកប្រឡំដោយមនុស្សទាំងឡាយក្នុងលោកនេះ ម្នាលព្រាហ្មណ៍ នាមគោត្តក៏មាន តាមប្រក្រតី អ្នកសួរបញ្ហា ទាក់ទងដោយគោត្តដែលមិនសមគួរជាមួយនឹងតថាគត ដែលជាសមណៈដើម្បីអ្វី ។

ព្រះមានព្រះភាគ កាលត្រាស់យ៉ាងនេះហើយ ព្រាហ្មណ៍កាលនឹងដោះនូវពាក្យតិះដៀល ទើបពោលថា បពិត្រអ្នកដ៏ចម្រើន ពួកព្រាហ្មណ៍ តែងសាកសួរជាមួយនឹងពួកព្រាហ្មណ៍ថា អ្នកដ៏ចម្រើន ជាព្រាហ្មណ៍ ឬមិនមែនទេ ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **ព្រាហ្មណោ នោ** សេចក្ដីថា លោកជាព្រាហ្មណ៍ឬហ្ន៎ ។ លោកអធិប្បាយថា លោកដ៏ចម្រើន ខ្ញុំមិនសួរវត្ថុមិនសមគួរក្នុងសម័យដែលខ្ញុំជាព្រាហ្មណ៍ ពួកព្រាហ្មណ៍ មកប្រជុំជាមួយនឹងពួកព្រាហ្មណ៍ ហើយសួរដល់ជាតិខ្លះ គោត្តខ្លះ យ៉ាងនេះថា លោកជាព្រាហ្មណ៍ឬហ្ន៎ លោកជាព្រាហ្មណភារទ្វាជគោត្តឬហ្ន៎ ដូច្នេះ ។

កាលព្រាហ្មណ៍ពោលយ៉ាងនេះហើយ ព្រះមានព្រះភាគ កាលទ្រង់ប្រកាសភាពដែលព្រះអង្គដឹងច្បាស់ក្នុងមន្តទាំងឡាយ ដើម្បីធ្វើឲ្យព្រាហ្មណ៍មានចិត្តទន់ ទើបត្រាស់ថា

**ព្រាហ្មណោ ចេ ត្វំ ព្រូសិ ។បេ។ ចតុវីសតក្ខរំ** ដូច្នេះ ។

បទនោះ មានសេចក្តីថា បើអ្នកពោលថា ខ្ញុំជាព្រាហ្មណ៍ តែអ្នកពោលនឹងតថាគតដែលមិនមែនព្រាហ្មណ៍ ព្រោះដូច្នោះ តថាគតសួរសាវិត្តិសាស្រ្តនឹងអ្នក ចូរអ្នកប្រាប់សាវិត្តិសាស្រ្តដែលមានបទ ៣ មានអក្ខរៈ ២៤ ដល់តថាគត ។ ក្នុងបទនេះ ព្រះមានព្រះភាគត្រាស់សំដៅដល់អរិយសាវិត្តិសាស្រ្តនេះថា **ពុទ្ធំ សរណំ គច្ឆាមិ ធម្មំ សរណំ គច្ឆាមិ សង្ឃំ សរណំ គច្ឆាមិ** ដែលជាខាងដើមនៃព្រះត្រៃបិដក ដែលជាបរមត្ថវេទ ដែលព្រះពុទ្ធគ្រប់អង្គជាអគ្គព្រាហ្មណ៍ប្រកាសហើយ សម្បូរដោយអត្ថ និងព្យញ្ជនៈ ។ បើព្រាហ្មណ៍ពោលដទៃ ព្រះមានព្រះភាគក៏ត្រាស់នឹងព្រាហ្មណ៍នោះថា ម្នាលព្រាហ្មណ៍នេះមិនមែនសាវិត្តិសាស្រ្តក្នុងវិន័យរបស់ព្រះអរិយៈយ៉ាងពិតប្រាកដ ព្រោះហេតុនោះ កាលទ្រង់សម្តែងដល់ភាពមិនមែនសាវិត្តិសាស្រ្តដល់ព្រាហ្មណ៍នោះ ក៏ទ្រង់ឲ្យព្រាហ្មណ៍តាំងនៅក្នុងសាវិត្តិសាស្រ្តនោះ ។ តែព្រាហ្មណ៍សួរដល់សាវិត្តិសាស្រ្តដែលស្តាប់ពាក្យនេះថា មានបទ ៣ មានអក្ខរៈ ២៤ ដែលចូលគ្នាបានជាមួយលទ្ធិរបស់ខ្លួន ជាសាវិត្តិសាស្រ្តដែលមានលក្ខណៈ និងព្យញ្ជនៈបន្លឺចេញមកដោយសំឡេង ដូចសំឡេងព្រហ្ម ទើបមើលងាយថា សមណៈនេះដល់នូវការសម្រេចក្នុងលទ្ធិរបស់ព្រាហ្មណ៍ពិត តែអញមើលងាយថាបុរសនេះមិនមែនព្រាហ្មណ៍ ព្រោះមិនដឹង បុរសនេះជាព្រាហ្មណ៍ ជាមនុស្សល្អដល់នូវត្រើយនៃមន្ត្រ ដូច្នេះហើយ គិតថា ណ្ហើយចុះ អញនឹងសួរយញ្ញពិធីនិងទក្ខិណេយ្យវិធីនឹងសមណៈនេះ ដូច្នេះ ទើបពោលគាថាដែលមិនរៀបរយ ២ បទថា **កឹនិស្សិតា ។បេ។ លោកេ** ដូច្នេះ ។

បទនោះ មានសេចក្តីថា ពួកឥសី ក្សត្រ ព្រាហ្មណ៍ មនុស្សដទៃ អាស្រ័យអ្វី គឺបំណងអ្វី ប្រាថ្នាអ្វី បានកំណត់យញ្ញដើម្បីជាប្រយោជន៍ដល់ទេវតាទាំងឡាយ ។ **ម** អក្ខរៈ ក្នុងបទថា **យញ្ញមកប្បយិំសុ** ជាបទសន្ធិ ។ បទថា **អកប្បយិំសុ** បានដល់ ជាក់ច្បាស់ហើយ គឺបានធ្វើហើយ ។ បទថា **បុថូ** គឺច្រើន មានប្រការមិនតិច មានបាយ និងទឹកជាដើម ។ ព្រាហ្មណ៍សួរដោយបំណងថា ឥសី មនុស្ស ក្សត្រ និងព្រាហ្មណ៍ជាច្រើនអាស្រ័យអ្វី បានកំណត់នូវយញ្ញ កម្មនោះ សម្រេចដល់បុគ្គលនោះបានដូចម្តេច ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ព្យាករសេចក្តីនោះដល់ព្រាហ្មណ៍ ទើបត្រាស់ ២ បទដ៏សេសថា **យទន្តគូ វេទគូ យញ្ញកាលេ យស្សា ហុតី លភេ តស្សិជ្ឈេតិ ព្រូមិ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **យទន្តគូ** ប្រែថា ជាអ្នកដល់នូវទីបំផុតនៃទុក្ខ កាត់បទជា **យោ អន្តគូ** ផ្លាស់ **ឱ** អក្ខរៈ ជា **អ** អក្ខរៈ ។ **ទ** អក្ខរៈ ប្រើដូច **ម** អក្ខរៈ ក្នុងបទជាដើមថា **អសាធារណមញ្ញេសំ** ប្រែថា កំណប់ទ្រព្យ គឺបុណ្យ មិនទូទៅដល់ពួកជនដទៃ ដូច្នេះ ។ អធិប្បាយថា តថាគតប្រាប់ថា បុគ្គលណា ឈ្មោះថា ដល់នូវទីបំផុតនៃទុក្ខ ព្រោះដល់នូវទីបំផុតនៃវដ្តទុក្ខ ដោយបរិញ្ញា ៣ និងឈ្មោះថា ដល់នូវទីបំផុតនៃវេទ ព្រោះទម្លាយកិលេសដោយវេទ គឺមគ្គញាណ ៤ ហើយដល់ទីបំផុត បុគ្គលនោះគប្បីបាននូវគ្រឿងបូជា ក្នុងកាលអាហារណាមួយ ដោយហោច សូម្បីស្លឹកឈើ ឫសឈើ និងផ្លែឈើក្នុងព្រៃជាដើម ចូលទៅតាំងទុកក្នុងកាលនៃយញ្ញរបស់

ឥសី មនុស្ស ក្សត្រ និងព្រាហ្មណ៍ណាមួយ គឺគប្បីបានទូវទេយ្យធម៌ណាមួយ អំពីគ្រឿងបូជានោះ យញ្ញកម្មរបស់បុគ្គលនោះ គប្បីសម្រេច គប្បីសម្រេចដោយល្អ គប្បីមានផលច្រើន ដូច្នេះ ។ លំដាប់នោះ ព្រាហ្មណ៍ស្តាប់ទេសនារបស់ព្រះមានព្រះភាគ ដែលសម្បូរដោយបរមត្ថធម៌ដ៏ជ្រាលជ្រៅ ដោយសំឡេងដ៏ពីរោះក្រៃលែង ជាសំឡេងមិនខ្វះខាត សរសើរនូវភាពដែលព្រះអង្គជាអ្នកមានសរីរសម្បត្តិដ៏ស្អាត និងគុណសម្បត្តិទាំងពួង កើតនូវបីតិសោមនស្ស ពោលគាថាថា **អទ្ធា ហិ តស្ស** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ឥតិ ព្រាហ្មណោ** ជាពាក្យនៃសង្គីតិកាចារ្យ ។ បទដ៏សេសជាពាក្យរបស់ព្រាហ្មណ៍ ។ បទនោះ មានអធិប្បាយថា ព្រាហ្មណ៍ទូលថា ការបូជារបស់ខ្ញុំព្រះអង្គនោះ គប្បីសម្រេចពិតប្រាកដ ថ្ងៃនេះទេយ្យធម៌នោះ នឹងសម្រេចដោយល្អ នឹងមានផលច្រើន ព្រោះខ្ញុំព្រះអង្គបានឃើញបុគ្គលដែលដល់ទីបំផុតនៃវេទបែបនេះ គឺខ្ញុំព្រះអង្គបានឃើញបុគ្គលដែលដល់នូវទីបំផុតនៃវេទ ជាអ្នកចម្រើនបែបនេះ ពិតហើយ ទ្រង់នោះឯងជាអ្នកក្រៃលែងជាងបុគ្គលដែលដល់នូវទីបំផុតនៃវេទទាំងឡាយ ម្យ៉ាងទៀតមុនអំពីនេះជនដទៃរមែងបរិភោគនំសម្រាប់បូជា បាយសម្រាប់បូជា នំដែលខ្ញុំព្រះអង្គត្រៀមក្នុងយញ្ញ ព្រោះមិនទាន់ឃើញបុគ្គលដែលដល់ទីបំផុតនៃវេទ និងដល់ទីបំផុតនៃទុក្ខដូចព្រះអង្គ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបថាព្រាហ្មណ៍រមែងជ្រះថ្លាក្នុងព្រះអង្គ នឹងទទួលព្រះតម្រាស់ហើយ មានបំណងប្រកាសទក្ខិណេយ្យបុគ្គលដោយប្រការផ្សេងៗ ឲ្យជាក់ច្បាស់ដល់ព្រាហ្មណ៍

ទើបត្រាស់គាថាថា **តស្មាតិហ ត្វំ** ដូច្នេះជាដើម ។

គាថានោះ មានអធិប្បាយថា ព្រះមានព្រះភាគ កាលទ្រង់សម្តែងព្រះអង្គ ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ ព្រោះអ្នកជាបុគ្គលជ្រះថ្លាក្នុងតថាគតដូច្នោះឯង ចូរអ្នកសួរចុះ ។ ខាងមុខអំពីនេះទៅ គួរភ្ជាប់បទដើមជាមួយបទថា អត្ថ ( ប្រយោជន៍ ) ភ្ជាប់បទថា **អត្ថិក** ( ត្រូវការ ) ចូលជាមួយបទក្រោយ ។ អធិប្បាយថា អ្នកជាបុគ្គលមានសេចក្តីត្រូវការដោយប្រយោជន៍ អ្នកនៅក្នុងទីនេះឯង កុំទៅណា នឹងជួបនូវទក្ខិណេយ្យបុគ្គលដែលមានបញ្ញាល្អ មានបញ្ញាប្រសើរ ជាព្រះខីណាស្រព ឈ្មោះថា **សន្តំ** ព្រោះស្ងប់ចាកភ្លើងគឺកិលេស ដែលសមគួរដល់ភាពជាអ្នកមានសេចក្តីត្រូវការដោយប្រយោជន៍នោះ ឈ្មោះថា **វិធូមំ** ព្រោះស្ងប់សេចក្តីក្រោធបាន ឈ្មោះថា **អនីឃំ** ព្រោះមិនមានទុក្ខ ឈ្មោះថា **និរាសំ អបេ្យរិធ** ព្រោះមិនមានការសង្ឃឹមច្រើនយ៉ាង ក្នុងសាសនានេះពិត ម្យ៉ាងទៀត ព្រះមានព្រះភាគ កាលទ្រង់សម្តែងព្រះអង្គ ទើបត្រាស់ថា ព្រោះអ្នកជ្រះថ្លាក្នុងតថាគត ម្នាលព្រាហ្មណ៍ ដូច្នោះឯង អ្នកជាបុគ្គលមានសេចក្តីត្រូវការដោយប្រយោជន៍ ចូរទៅសួរលោកអ្នកស្ងប់ ដែលមិនមានការក្រោធ មិនមានទុក្ខ មិនមានសង្ឃឹមចុះ ។ ក្នុងបទនេះគប្បីជ្រាបយោជនាថា កាលសួរយ៉ាងនេះ អ្នកនឹងជួបទក្ខិណេយ្យបុគ្គលដែលមានបញ្ញាល្អ ជាព្រះខីណាស្រព ក្នុងសាសនានេះពិត ។

លំដាប់នោះ ព្រាហ្មណ៍បដិបត្តិតាមព្រះមានព្រះភាគទ្រង់ប្រៀនប្រដៅ ទើបទូលព្រះមានព្រះភាគថា **យញ្ញោ រនោហំ ភោ ។បេ។ ព្រូហិ មេតំ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **យញ្ញោ** ការបួងសួង និងបទថា **យាគោ** គឺការបូជាយញ្ញ និងបទថា **ទានំ** គឺការឲ្យ ដោយអត្ថដូចគ្នានោះឯង ។ ព្រោះហេតុនោះ គប្បីជ្រាបការប្រកបសេចក្តីក្នុងបទយ៉ាងនេះថា ខ្ញុំព្រះអង្គត្រេកអរហើយក្នុងទាន បំណងនឹងឲ្យទាន ព្រោះសេចក្តីត្រេកអរក្នុងទាននោះឯង តែខ្ញុំព្រះអង្គមិនទាន់ដឹងច្បាស់ សូមទ្រង់ទូន្មានខ្ញុំព្រះអង្គដែលមិនដឹងយ៉ាងនេះចុះ បពិត្រព្រះអង្គដ៏ចម្រើន កាលទ្រង់ទូន្មាន សូមប្រាប់ភាពដែលសម្រេចនៃការបូជាដល់ខ្ញុំព្រះអង្គ ដោយន័យដែលងាយយល់ចុះ ។ បាឋៈថា **យថា ហុតំ** ដូច្នេះក៏មាន ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់បំណងនឹងពោលដល់ព្រាហ្មណ៍នោះ ទើបត្រាស់ថា **តេន ហិ** ។បេ។ **ទេសិស្សាមិ** ដើម្បីទ្រង់ទូន្មាននូវព្រាហ្មណ៍ដែលផ្ទៀងសោតាហើយ ទើបត្រាស់គាថាដំបូងថា **មា ជាតឹ បុច្ឆ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **មា ជាតឹ បុច្ឆ** សេចក្តីថា បើអ្នកបំណងនឹងមានផលច្រើនក្នុងការបូជា សេចក្តីសម្រេច និងការឲ្យ ចូរកុំសួរដល់ជាតិ ព្រោះការសួរដល់ជាតិ មិនមែនហេតុក្នុងការពិចារណាដល់ទក្ខិណេយ្យ-បុគ្គល ។ បទថា **ចរណញ្ច បុច្ឆ** បានដល់ ចូរសួរអំពីធម៌ សម្រាប់ប្រព្រឹត្តដែលបានដល់គុណធម៌ មានសីលជាដើមចុះ ព្រោះធម៌សម្រាប់ប្រព្រឹត្តនេះជាហេតុក្នុងការពិចារណាដល់ទក្ខិណេយ្យបុគ្គល ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ចង្អុលបង្ហាញសេចក្តីនោះឲ្យជាក់

ប្រាប់ដល់ព្រាហ្មណ៍នោះ ទើបទ្រង់លើកសាធកៈថា **កដ្ឋា ហវេ ជាយតិ ជាតវេទោ** ដូច្នេះជាដើម អធិប្បាយសេចក្ដីក្នុងបទនោះថា ព្រះមានព្រះភាគត្រាស់ថា ភ្លើងរមែងកើតអំពីឈើ ម្យ៉ាងទៀត ភ្លើងនោះ មិនមែនកើតអំពីឈើមានដើមសាលព្រឹក្សជាដើមប៉ុណ្ណោះឡើយ ទើបធ្វើកិច្ចរបស់ខ្លួនបាន កើតអំពីឈើដែលធ្វើជណ្ដើរ និងស្នូកទឹកជាដើម ធ្វើកិច្ចមិនបាន ( នោះឡើយ ) តែធ្វើបាន ព្រោះដល់ព្រមដោយគុណសម្បត្តិ មានអណ្ដាតភ្លើងជាដើម យ៉ាងណា បុគ្គលដែលជាទក្ខិណេយ្យក៏ដូច្នោះ មិនមែនកើតក្នុងត្រកូលព្រាហ្មណ៍ប៉ុណ្ណោះ ទើបជាទក្ខិណេយ្យបុគ្គលបាន កើតក្នុងត្រកូលចណ្ឌាលជាដើមមិនបាន ដែលពិត សូម្បីកើតក្នុងត្រកូលទាបខ្ពស់ ក៏ជាមុនីវិណា-ស្រព មានបញ្ញាបៀតបៀននូវអកុសលដោយហិរិ ជាបុគ្គលអាជានេយ្យបាន មានកំណើតល្អដោយគុណ មានបញ្ញា និងហិរិជាប្រធាន ជាទក្ខិណេយ្យ-បុគ្គលដ៏ឧត្ដមបាន ព្រោះហេតុនោះ រមែងទ្រទ្រង់នូវគុណដោយបញ្ញា រមែងបៀតបៀននូវទោសទាំងឡាយដោយហិរិ សមដូចព្រះមានព្រះភាគត្រាស់ថា ឯពួកសប្បុរសមិនធ្វើបាប ព្រោះខ្លាចបាប ដូច្នេះ ដោយហេតុនោះ តថាគតប្រាប់ដល់អ្នកថា អ្នកកុំសួរដល់ជាតិ សួរតែក្រិត្យគ្រឿងប្រព្រឹត្តចុះ ភ្លើងតែងកើតអំពីឧស ព្រះខីណាសវមុនី សូម្បីជាអ្នកមានត្រកូលថោកទាប រមែងជាអ្នកទ្រទ្រង់គុណជាអាជានិយៈ ហាមឃាត់ទោសដោយហិរិបានដែរ ដូច្នេះ ។ នេះជាសេចក្ដីសង្ខេប ។ ឯសេចក្ដីពិស្ដារ គប្បីជ្រាបដោយពិចារណាមើលក្នុងអស្សលាយនសូត្រ ( មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ) ។

ព្រះមានព្រះភាគ កាលទ្រង់ទូន្មានព្រាហ្មណ៍នោះ ដោយសេចក្ដីបរិសុទ្ធនៃវណ្ណៈ ៤ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្ដែងទីដែលសម្រេចនៃការបូជាយញ្ញ ទើបត្រាស់គាថាជាដើមថា **សច្ចេន ទន្តោ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **សច្ចេន** បានដល់ បរមត្ថសច្ច ។ ពិតហើយ បុគ្គលសម្រេចបរមត្ថសច្ចនោះ ឈ្មោះថា ជាអ្នកទូន្មានខ្លួនហើយ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **សច្ចេន ទន្តោ** ដូច្នេះ ។ បទថា **ទមសា ឧបេតោ** បានដល់ ប្រកបហើយដោយការទូន្មានឥន្ទ្រិយ ។ បទថា **វេទន្តគូ** បានដល់ ដល់ទីបំផុតនៃកិលេសដោយវេទ ឬដល់នូវមគ្គញាណទី ៤ ដែលជាទីបំផុតនៃវេទទាំងឡាយ ។ បទថា **វុសិតព្រហ្មចរិយោ** បានដល់ មានព្រហ្មចរិយៈនៅចប់ហើយ ព្រោះមិនមានកិច្ចដែលត្រូវនៅទៀត ។ បទថា **កាលេន តម្ហិ ហព្យំ បវេច្ឆេ** សេចក្ដីថា គប្បីកំណត់ពេលដែលខ្លួននឹងយកទេយ្យធម៌ទៅតម្កល់ទុក និងពេលដែលទក្ខិណេយ្យបុគ្គលនោះនៅចំពោះមុខ ហើយគប្បីបង្ហូរ គឺបង្អោនទេយ្យធម៌ ក្នុងទក្ខិណេយ្យបុគ្គលបែបនោះតាមកាលនោះ ។ បទថា **កាមេ** បានដល់ វត្ថុកាម និងកិលេសកាម ។ បទថា **សុសមាហិតិន្ទ្រិយោ** គឺមានឥន្ទ្រិយតាំងមាំហើយដោយល្អ លោកអធិប្បាយថា មានឥន្ទ្រិយមិនរាយមាយ ។ បទថា **ចន្ទោវ រាហុគ្គហណា បមុត្តោ** បានដល់ ដូចព្រះចន្ទដែលផុតចាកការចាប់របស់រាហូ យ៉ាងណា បុគ្គលផុតចាកការចាប់របស់កិលេស រមែងរុងរឿង ដូច្នោះ ។ បទថា **សតា** គឺជាអ្នកដល់ព្រមដោយសតិ ។ បទថា **មមាយិតានិ** បានដល់ លះតណ្ហា

និងទិដ្ឋិ ដែលបុគ្គលពាលប្រកាន់ថា ជារបស់អញបានហើយ ។ បទថា **យោ កាមេ ហិត្វា** ព្រះមានព្រះភាគ ត្រាស់សំដៅដល់ព្រះអង្គ ។ ក្នុងបទទាំងនោះ បទថា **កាមេ ហិត្វា** គឺលះកិលេសកាមបានហើយ ។ បទថា **អភិភុយ្យចារី** បានដល់ ឈ្មោះថា គ្របសង្កត់នូវវត្ថុកាមទាំងឡាយ ត្រាច់ទៅ ព្រោះលះវត្ថុកាមនោះបានហើយ ។ និព្វាន លោកហៅថា ជាទីបំផុតនៃជាតិ និងមរណៈ ។ បទថា **យោ វេទិ** គឺជាអ្នកដល់នូវទីបំផុតនៃជាតិ និងមរណៈនោះ ដោយកម្លាំងបញ្ញា ។ បទថា **ឧទករហទោវ** ដូចអន្លង់ទឹក សេចក្តីថា ស្រះធំ ៧ ក្នុងព្រៃហិមវន្ត គឺអនោតត្តស្រះ ១ កណ្ណមុណ្ឌ ១ រថការ ១ ឆទ្ទន្ត ១ កុណាល ១ មណ្ឌាកិនី ១ សីហបបាត ១ ទាំងនេះត្រជាក់សព្វកាល ព្រោះមិនត្រូវកម្តៅ គឺភ្លើង និងព្រះអាទិត្យប៉ះពាល់ បុគ្គលដឹងទីបំផុតនៃជាតិ និងមរណៈ ឈ្មោះថា រម្ងត់នូវកម្តៅបាន ជាបុគ្គលត្រជាក់ រម្ងត់នូវកម្តៅ គឺកិលេសបាន ដូចអន្លង់ទឹកទាំងនោះ អន្លង់ទឹកណាមួយដូច្នោះ ។ បទថា **សមោ** បានដល់ ស្មើគ្នា ។ បទថា **សមេហិ** បានដល់ព្រះពុទ្ធទាំងឡាយ មានព្រះវិបស្សីជាដើម ព្រោះព្រះពុទ្ធទាំងឡាយ លោកពោលថា **សមា** គឺជាអ្នកស្មើគ្នា ព្រោះស្មើដោយការត្រាស់ដឹង ។ ព្រះពុទ្ធទាំងនោះ មិនមានការផ្សេងគ្នា ក្នុងគុណដែលគួរសម្រេចក្នុងការត្រាស់ដឹង ឬក្នុងទោសដែលគួរលះ ព្រះពុទ្ធទាំងនោះ មានការផ្សេងគ្នាដោយកាល អាយុ ត្រកូល ប្រមាណ បព្វជ្ជា សេចក្តីព្យាយាម ដើមឈើត្រាស់ដឹង និងព្រះរស្មី ។ ពិតហើយ ព្រះពុទ្ធទាំងឡាយ កំណត់យ៉ាងទាប បំពេញបារមី ៤

អសង្ខេយ្យ និង ១ សែនកប្ប កំណត់យ៉ាងខ្ពស់ គឺ ១៦ អសង្ខេយ្យ និង ១ សែនកប្ប នេះគឺការផ្សេងគ្នានៃកាលរបស់ព្រះពុទ្ធទាំងនោះ ម្យ៉ាងទៀត ដោយកំណត់យ៉ាងទាប ព្រះពុទ្ធទាំងឡាយ កើតឡើងក្នុងកាលដែលមនុស្ស មានអាយុ ១០០ ឆ្នាំ ដោយកំណត់យ៉ាងខ្ពស់ ក្នុងកាលដែលមនុស្សអាយុ ១ សែនឆ្នាំ នេះគឺការផ្សេងគ្នានៃអាយុ ។ ព្រះពុទ្ធទាំងឡាយ ទ្រង់កើតឡើងក្នុង ត្រកូលក្សត្រ ឬក្នុងត្រកូលព្រាហ្មណ៍ នេះគឺការផ្សេងគ្នានៃត្រកូល ។ ព្រះ សម្ពុទ្ធទាំងឡាយ កម្ពស់ប្រមាណ ៨៨ ហត្ថ ឬទាបប្រមាណ ១៥ ឬ ១៨ ហត្ថ នេះគឺការផ្សេងគ្នានៃប្រមាណ ។ ព្រះពុទ្ធទាំងឡាយចេញបួសដោយដំរី សេះ រថ និងវជាដើម ឬដោយតាមអាកាស ព្រះពុទ្ធវិបស្សី ព្រះពុទ្ធ កកុសន្ធៈ ចេញបួសដោយរថដែលទឹមដោយសេះ ព្រះសិខី និងព្រះកោនា- គមនៈ ចេញបួសដោយយានដំរី ព្រះវេស្សភូ ចេញបួសដោយវ ព្រះកស្សបៈ ចេញបួសតាមផ្លូវអាកាស ព្រះសក្យមុនីចេញបួសដោយសេះ នេះគឺការ ផ្សេងគ្នានៃបព្វជ្ជា ។ ព្រះពុទ្ធទ្រង់បំពេញសេចក្តីព្យាយាម ៧ ថ្ងៃខ្លះ កន្លះ ខែខ្លះ មួយខែខ្លះ ពីរខែខ្លះ បីខែខ្លះ បួនខែខ្លះ ប្រាំខែខ្លះ ប្រាំមួយខែខ្លះ មួយ ឆ្នាំខ្លះ ពីរឆ្នាំខ្លះ បីឆ្នាំខ្លះ បួនឆ្នាំខ្លះ ប្រាំឆ្នាំខ្លះ ប្រាំមួយឆ្នាំខ្លះ នេះគឺការផ្សេងគ្នា នៃសេចក្តីព្យាយាម ។ ដើមឈើជាទីត្រាស់ដឹង គឺដើមជ្រៃខ្លះ ដើមនិគ្រោធខ្លះ ជាដើម នេះគឺការផ្សេងគ្នានៃដើមឈើត្រាស់ដឹង ព្រះពុទ្ធទាំងឡាយ មានរស្មី មួយព្យាម មានរស្មី ៨០ ព្យាម និងព្រះរស្មីមិនមានកំណត់ ក្នុងព្រះរស្មី ទាំងនោះ ព្រះរស្មីមួយព្យាម និង ៨០ ព្យាម ដូចគ្នាគ្រប់អង្គ តែរស្មីមិន

មានកំណត់ ផ្សាយទៅឆ្ងាយខ្លះ ជិតខ្លះ មួយគាវុតខ្លះ ពីរគាវុតខ្លះ មួយយោជន៍ខ្លះ ច្រើនយោជន៍ខ្លះ និងទីបំផុតចក្កវាឡខ្លះ ។ រស្មីរបស់ព្រះពុទ្ធមណ្ឌលផ្សាយទៅបានមួយម៉ឺនចក្កវាឡ កាលបើដូច្នេះ ព្រះរស្មីរបស់ព្រះពុទ្ធទាំងឡាយ រមែងផ្សាយទៅតាមបំណង ព្រោះទាក់ទងដោយចិត្តគិត នេះគឺការផ្សេងគ្នានៃព្រះរស្មី ។ វៀរការផ្សេងគ្នា ៨ យ៉ាងនេះ ព្រះពុទ្ធទាំងឡាយ មិនមានការផ្សេងគ្នាក្នុងគុណ ដែលគួរសម្រេចដល់ការត្រាស់ដឹងដ៏សេស ឬក្នុងទោសដែលគួរលះ ព្រោះដូច្នោះ ទើបលោកពោលថា **សមា** គឺជាអ្នកស្មើ ។ ព្រះតថាគត ជាអ្នកស្មើនឹងព្រះពុទ្ធទាំងឡាយ ដោយប្រការដូច្នេះ ។ បទថា **វិសមេហិ ទូរេ** សេចក្តីថា មិនមានបុគ្គលស្មើ ឈ្មោះថា បុគ្គលមិនស្មើសត្វដ៏សេស មានព្រះបច្ចេកពុទ្ធជាដើម ឈ្មោះថា នៅឆ្ងាយ ព្រោះដូចគ្នានឹងបុគ្គលដែលមិនស្មើទាំងនោះ ។ ពិតហើយ ព្រះបច្ចេកពុទ្ធទាំងឡាយ អង្គុយពត់ភ្នែនពេញផ្ទៃជម្ពូទ្វីប ក៏មិនបានស្មើនឹងចំណែកទី ១៦ របស់ព្រះសម្មាសម្ពុទ្ធមួយអង្គ ដោយគុណទាំងឡាយ នឹងពោលថ្វីដល់ពួកសាវកជាដើម ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **វិសមេ ទូរេ** ។ បទថា **ទូរេ** គប្បីប្រកបជាមួយ ២ បទថា **តថាគតោ ហោតិ** ។ បទថា **អនន្តបញ្ញោ** គឺមានបញ្ញាកំណត់មិនបាន ។ ពិតហើយ មិនគួរពោលថា កាលប្រៀបធៀបជាមួយបញ្ញារបស់មនុស្សលោក បញ្ញារបស់ព្រះអរិយៈទី ៨ ( សោតាបត្តិមគ្គ ) ក្រៃលែងជាង កាលប្រៀបធៀបបញ្ញារបស់ព្រះអរិយៈទី ៨ បញ្ញារបស់ព្រះសោតាបន្នក្រៃលែងជាង ប្រៀបធៀបយ៉ាងនេះ រហូតដល់បញ្ញា

របស់ព្រះអរហន្ត បញ្ញារបស់ព្រះបច្ចេកពុទ្ធក្រៃលែងជាង កាលប្រៀបធៀប បញ្ញារបស់ព្រះបច្ចេកពុទ្ធ បញ្ញារបស់ព្រះតថាគតក្រៃលែងជាង ។ តែគួរពោលថា **អនន្តា** គឺមិនមានទីបំផុត ។ ដោយហេតុនោះ ទើបទ្រង់ត្រាស់ថា **អនន្តបញ្ញោ** ។ បទថា **អន្ធុបលិត្តោ** បានដល់ បុគ្គលដែលគ្រឿងលាប គឺតណ្ហា និងទិដ្ឋិមិនបូកលាបហើយ ។ បទថា **ឥធ វា ហុរំ វា** គឺក្នុងលោកនេះ និងលោកដទៃ ។ តែក្នុងបទនេះ យោជនាបានលម្អិតថា ព្រះតថាគតស្មើនឹងបុគ្គលស្មើ ឆ្ងាយចាកបុគ្គលមិនស្មើ ព្រោះហេតុអ្វី ព្រោះទ្រង់មានបញ្ញាមិនមានទីបំផុត ទ្រង់ជាបុគ្គលដែលតណ្ហា និងទិដ្ឋិមិនបូកលាបក្នុងលោកនេះ ឬលោកដទៃ ដូច្នោះ ទើបព្រះតថាគតគួរដល់គ្រឿងបូជា ។

បទថា **យម្ហិ ន មយា** សេចក្តីថា គាថានេះ និងគាថាដទៃ គប្បីជ្រាបថា លោកពោលដូច្នេះ ដើម្បីលះនូវការសម្គាល់ក្នុងព្រាហ្មណ៍ ដែលប្រកបដោយសេចក្តីវិនាស មានមាយាជាដើមថា ជាទក្ខិណេយ្យបុគ្គល ។ ក្នុងបទទាំងនោះ បទថា **អមមោ** បានដល់ លះនូវការប្រកាន់ក្នុងសត្វ និងសង្ខារទាំងឡាយ ថានេះជារបស់អញ ។ បទថា **និវេសនំ** បានដល់ ទីអាស្រ័យ គឺតណ្ហា និងទិដ្ឋិ ។ ដោយបទនោះ ចិត្តរមែងអាស្រ័យនៅក្នុងភព ៣ ។ ដោយហេតុនោះ ទើបលោកពោលថា លះនូវតណ្ហា ទិដ្ឋិ ដែលនៅប្រចាំបានហើយ ។ ម្យ៉ាងទៀត អាស្រ័យនៅក្នុងតណ្ហា និងទិដ្ឋិនោះ ព្រោះមិនអាចលះបាន ។ ព្រោះដូច្នោះ ទើបពោលថា **និវេសនំ** គឺនៅអាស្រ័យ ។ បទថា **បរិគ្គហា** បានដល់ តណ្ហា និងទិដ្ឋិនោះឯង ។ ព្រោះតណ្ហា និងទិដ្ឋិ

ទាំងនោះជាវត្ថុដែលខ្លួនប្រកាន់ ។ បទថា **កោចិ** គឺមានប្រមាណតិច ។ បទថា **អនុបាទិយានោ** បានដល់ មិនប្រកាន់មាំដល់វត្ថុណាមួយ ព្រោះមិនមានតណ្ហា និងទិដ្ឋិ ជាទីនៅអាស្រ័យ ។ បទថា **សមាហិតោ** គឺតាំងមាំដោយមគ្គសមាធិ ។ បទថា **ឧទតារិ** គឺឆ្លងបានហើយ ។ បទថា **ធម្មមញ្ញាសិ** គឺបានដឹងនូវធម៌ដែលគួរដឹងទាំងអស់ ។ បទថា **បរមាយ ទិដ្ឋិយា** គឺដោយសព្វញ្ញុតញ្ញាណ ។ បទថា **ភវាសវា** បានដល់ ភវតណ្ហា គឺរាគសហគតៈដោយការមិនប្រាថ្នាក្នុងឈាន និងសស្សតទិដ្ឋិ ។ បទថា **វចី** បានដល់វាចា ។ បទថា **ខរា** បានដល់ វាចាគ្រោតគ្រាត ។ បទថា **វិធូបិតា** គឺដុតហើយ ។ បទថា **អត្ថគតា** គឺតាំងនៅមិនបាន ។ បទថា **ន សន្តិ** គឺព្រោះកម្ចាត់ហើយ ព្រោះតាំងនៅមិនបាន ។ គប្បីប្រកប ២ បទ គឺ **វិធូបិតា អត្ថគតា** ចូលជាមួយ ២ បទ គឺ **ន សន្តិ** ។ បទថា **សព្វធិ** គឺក្នុងធម៌មានខន្ធ និងអាយតនៈទាំងពួងជាដើម ។ បទថា **មានសត្តេសុ** បានដល់ក្នុងពួកសត្វដែលមានមានះ ។ បទថា **ទុក្ខំ បរិញ្ញាយ** បានដល់ កំណត់ដឹងទុក្ខក្នុងវដ្តៈដោយបរិញ្ញា ៣ ។ បទថា **សខេត្តវត្ថុំ** គឺព្រមដោយហេតុនិងបច្ច័យ អធិប្បាយថា មួយអន្លើដោយកិលេសទាំងឡាយ ។ បទថា **វាសំ អនិស្សាយ** គឺមិនជាប់ដោយតណ្ហា ។ បទថា **វិវេកទស្សី** គឺឃើញព្រះនិព្វានដោយប្រក្រតី ។ បទថា **បវេទិយំ** គឺគប្បីឲ្យអ្នកដទៃដឹង ។ បទថា **ទិដ្ឋិមុបាតិវត្តោ** បានដល់ ឈានកន្លងនូវមិច្ឆាទិដ្ឋិ ដែលមានប្រភេទ ៦២ ។ បទថា **អារម្មណា** បានដល់ បច្ច័យ អធិប្បាយថា ហេតុធ្វើឲ្យកើតក្នុងភព

ថ្មី ។ បទថា **បរោបរា** បានដល់ ធម៌ល្អដទៃៗ ឬធម៌ខាងក្នុងផង ខាងក្រៅផង ។ បទថា **សមេច្ច** បានដល់ ត្រាស់ដឹងហើយដោយញាណ ។ បទថា **ធម្មា** បានដល់ ធម៌ មានខន្ធ និងអាយតនៈជាដើម ។

បទថា **ឧបាទានក្ខយេ វិមុត្តោ** គឺបង្អោនទៅក្នុងនិព្វានដោយមាននិព្វានជាអារម្មណ៍ អធិប្បាយថា មានប្រក្រតីបានបង្អោនទៅក្នុងអារម្មណ៍ គឺនិព្វាន ។ បទថា **សំយោជនជាតិក្ខយន្តទស្សី** បានដល់ ឃើញនូវទីបំផុតនៃការអស់ទៅនៃសំយោជនៈ និងទីបំផុតនៃការអស់ទៅនូវជាតិ ។ ម្យ៉ាងទៀត ក្នុងបទនេះ ទ្រង់ត្រាស់ដល់សឧបាទិសេសនិព្វានធាតុ ដោយការអស់ទៅនៃសំយោជនៈ ត្រាស់អនុបាទិសេសនិព្វាន ដោយការអស់ទៅនៃជាតិ ។ បទថា **ខយន្តោ** នេះ ជាឈ្មោះនៃការលះបានជាសមុច្ឆេទ ដែលជាការអស់ទៅដោយចំណែកមួយ ។ ម្យ៉ាងទៀត ក្នុងបទនេះ លោកមិនលុបនិគ្គហិត ដូចក្នុងបទជាដើមថា **វិវេកជម្បីតិសុខំ** (មានបីតិ និងសុខដែលកើតអំពីវិវេក) ។ បទថា **យោ បានុទិ** គឺព្រះតថាគតបន្ទោបង់បានហើយ ។ បទថា **រាគបថំ** បានដល់ មានរាគៈជាអារម្មណ៍ ឬរាគៈនោះឯង ។ ពិតហើយ សូម្បីរាគៈលោកក៏ហៅថា **រាគបថោ** ព្រោះជាផ្លូវនៃទុគ្គតិ ដូចផ្លូវនៃកម្មបថ ។ បទថា **សុទ្ធោ និទ្ទោសោ វិមលោ អកាមោ** សេចក្ដីថា ឈ្មោះថា **សុទ្ធោ** ព្រោះមានការប្រព្រឹត្តផ្លូវកាយបរិសុទ្ធ ឈ្មោះថា **និទ្ទោសោ** ព្រោះមិនមានទោសដែលលោកពោលថា ពួកសត្វនេះ មានរាគៈ ទោសៈ មោហៈ ជាទោស ឈ្មោះថា **វិមលោ** ព្រោះមិនមានមន្ទិលចូលទៅប្រឡាក់ ឈ្មោះថា **អកាមោ**

ព្រោះមិនមានឧបក្កិលេស ។ ពិតហើយ បុគ្គលដែលត្រូវឧបក្កិលេសចូលទៅធ្វើឲ្យល្អក់កករ លោកហៅថា **សក្កាមោ** គឺប្រកបដោយសេចក្តីប្រាថ្នា ។ម្យ៉ាងទៀត ព្រោះបុគ្គលបរិសុទ្ធ ក៏ឈ្មោះថា ជាអ្នកមិនមានទោស ឈ្មោះថាប្រាសចាកមន្ទិល ព្រោះជាបុគ្គលមិនមានទោស ឈ្មោះថា មិនមានសេចក្តីប្រាថ្នា ព្រោះមិនមានមន្ទិល ព្រោះមិនមានមន្ទិលខាងក្រៅ ។ ពិតហើយ បុគ្គលមានមន្ទិល ហៅថា បុគ្គលមានការប្រាថ្នា បុគ្គលមិនធ្វើបាប ក៏ព្រោះជាអ្នកប្រាសចាកមន្ទិល ទើបឈ្មោះថា មិនមានការប្រាថ្នាដោយការមិនធ្វើបាបនោះពិតហើយ ការធ្វើបាប លោកហៅថា **កាមោ** ព្រោះធ្វើនូវការចង្អៀតចង្អល់ ។

បទថា **អត្តនា អត្តានំ នានុបស្សតិ** សេចក្តីថា ព្រះតថាគតទ្រង់ឃើញច្បាស់ដោយចិត្តសម្បយុត្តដោយញាណ មិនពិចារណាឃើញវត្ថុដទៃដែលឈ្មោះថាខ្លួន ក្នុងខន្ធទាំងឡាយរបស់ខ្លួន ពិចារណាឃើញត្រឹមតែខន្ធប៉ុណ្ណោះ មិនពិចារណាឃើញខ្លួន ដោយភាពជាខ្លួន ព្រោះមិនមានទិដ្ឋិកើតឡើង ដោយភាពជារបស់ពិតដល់ព្រះតថាគតនោះថា តថាគតដឹងច្បាស់ខ្លួនដោយភាពជាខ្លួននោះឯង រមែងពិចារណាឃើញខន្ធទាំងឡាយ ដោយបញ្ញាដោយពិត ។ ព្រះតថាគតមានចិត្តតាំងមាំដោយមគ្គសមាធិ ទ្រង់បដិបត្តិត្រង់ព្រោះមិនមានការវៀចដោយកាយជាដើម ទ្រង់តម្កល់ខ្លួនមាំ ព្រោះមិនញាប់ញ័រដោយលោកធម៌ទាំងឡាយ មិនមានការចង់បាន មិនមានកិលេសដូចដង្គត់ មិនមានសេចក្តីសង្ស័យ ព្រោះមិនមានការចង់បាន គឺតណ្ហា មិនមានចេតោខិល ៥ យ៉ាង និងសេចក្តីសង្ស័យក្នុងវត្ថុ ដែលមិនមែនឋានៈ ៨

យ៉ាង ។ បទថា **មោហាន្តរា** បានដល់ មានមោហៈជាហេតុជាបច្ច័យ ។ ពាក្យនេះ ជាឈ្មោះរបស់កិលេសគ្រប់ប្រភេទ ។ បទថា **សព្វេសុ ធម្មេសុ ច ញាណទស្សី** សេចក្តីថា ព្រះមានព្រះភាគទ្រង់ធ្វើឲ្យជាក់ច្បាស់នូវព្រះសព្វញ្ញុតញ្ញាណ ទ្រង់ឃើញញាណក្នុងធម៌ទាំងពួង ទ្រង់ធ្វើឲ្យជាក់ច្បាស់ថា តថាគតសម្រេចហើយ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **សព្វេសុ ធម្មេសុ ច ញាណទស្សី** ដូច្នេះ ។ បទថា **សម្ពោធិ** បានដល់ ព្រះអរហត្ត ។ បទថា **អនុត្តរំ** បានដល់ គឺដែលមិនទូទៅដល់ព្រះបច្ចេកពុទ្ធ និងសាវកពុទ្ធទាំងឡាយ ។ បទថា **សិវំ** បានដល់ ក្សេម មិនមានអន្តរាយ ឬមានសិរី ។ បទថា **យក្ខស្ស** បានដល់ បុរស ។ បទថា **សុទ្ធិ** បានដល់ សេចក្តីផូរផង់ ។ ក្នុងបទថា **សុទ្ធិ** នេះ បានដល់ មិនមានទោសគ្រប់យ៉ាង ព្រោះមិនមានមោហៈជាហេតុជាបច្ច័យ ទ្រង់កាត់ហេតុបានជាសមុច្ឆេទ ទ្រទ្រង់នូវសរីរៈក្នុងជាតិចុងក្រោយ ដោយសេចក្តីបរិសុទ្ធ មានគុណធម៌ទាំងពួង ព្រោះឃើញបានដោយញាណ ទ្រង់សម្រេចសម្ពោធិញ្ញាណដ៏កំពូលដោយញាណនោះ បន្ទាប់អំពីនោះ មិនមានវត្ថុដែលគួរលះ ឬវត្ថុដែលគួរសម្រេច ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ឯត្តាវតា យក្ខស្ស សុទ្ធិ** ដូច្នេះ ។ កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ព្រាហ្មណ៍កាលធ្វើអាការជ្រះថ្លាក្នុងព្រះមានព្រះភាគឲ្យក្រៃលែងឡើង ទើបទូលថា **ហុតញ្ច មយ្ហំ** ដូច្នេះជាដើម ។

បទនោះ មានសេចក្តីថា ព្រាហ្មណ៍ទូលថា កាលមុននេះ ខ្ញុំព្រះអង្គប្រារព្ធព្រហ្ម ទើបបូជាភ្លើង ការបូជារបស់ខ្ញុំព្រះអង្គនោះ នឹងជាការបូជាពិត

ឬជាការបូជាបោកបញ្ឆោត ខ្ញុំព្រះអង្គមិនដឹង តែថ្ងៃនេះ ការបូជារបស់ខ្ញុំព្រះអង្គ ជាការបូជាពិត កាលបង្អោនគ្រឿងបូជាដ៏សេសចូលទៅប្រគេន ទើបទូលថា ព្រោះខ្ញុំព្រះអង្គឈរក្នុងទីនេះ ទើបបានបុគ្គលដែលដល់នូវវេទ ជាបុគ្គលចម្រើនបែបនោះ ព្រះមានព្រះភាគជាព្រហ្ម ជាអ្នកឃើញឯងពិត សូមទ្រង់ទទួល លុះទទួលហើយ សូមទ្រង់បរិភោគនូវគ្រឿងបូជារបស់ខ្ញុំព្រះអង្គ ។

លំដាប់នោះ ព្រះមានព្រះភាគ បានត្រាស់ ២ គាថា ដោយន័យដែលពោលហើយ ក្នុងកសិភារទ្វាជសូត្រ ។ បន្ទាប់អំពីនោះ ព្រាហ្មណ៍គិតថា ព្រះតថាគតនេះ មិនប្រាថ្នាដោយខ្លួនឯង គង់ពោលសំដៅដល់អ្នកដទៃថា ចូរអ្នកទំនុកបម្រុងព្រះខីណាស្រពដែលបរិបូរដោយគុណទាំងពួង អ្នកស្វែងរកគុណធំ ជាអ្នកស្ងប់នូវការរពឹស ហើយដោយបាយ និងទឹកចុះ ដូច្នេះ កាលមិនយល់អត្ថនៃព្រះគាថា បំណងនឹងដឹងសេចក្តីនោះ ទើបទូលថា **សាធាហំ ភគវា** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សាធុ** ជានិបាត ចុះក្នុងអត្ថថា អង្វរ ។ បទថា **តថា** គឺដោយប្រការដែលទ្រង់ត្រាស់ ។ បទថា **វិជញ្ញំ** បានដល់ គប្បីដឹង ។ បទថា **យំ** បានដល់ ស្វែងរកទក្ខិណេយ្យបុគ្គលក្នុងកាលនៃយញ្ញ ។ បទថា **បបុយ្យ** ស្មើគ្នានឹង **បត្វា** ប្រែថា ដល់ហើយ ។ បទថា **តវ សាសនំ** បានដល់ ឱវាទរបស់ទ្រង់ ។ លោកអធិប្បាយថា ព្រាហ្មណ៍ទូលថា បពិត្រព្រះមានព្រះភាគ សូមប្រទានវរោកាស ខ្ញុំព្រះអង្គគប្បីដឹងច្បាស់ទាក់ទងដោយពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ដូចដែលទ្រង់ត្រាស់ដល់ខ្ញុំ

ព្រះអង្គ សូមទ្រង់សម្តែងទក្ខិណេយ្យបុគ្គល ដែលគប្បីបរិភោគនូវទក្ខិណា របស់បុគ្គលដូចខ្ញុំព្រះអង្គ ដែលខ្ញុំព្រះអង្គគប្បីស្វែងរកក្នុងកាលនៃយញ្ញ ដល់ខ្ញុំព្រះអង្គចុះ បើទ្រង់មិនបរិភោគ ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងទក្ខិណេយ្យបុគ្គល បែបនោះដល់ព្រាហ្មណ៍តាមន័យដែលប្រាកដហើយ ទើបត្រាស់ ២ គាថាថា **សារម្ភា យស្ស** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **សីមា** ក្នុងបទថា **សីមន្តានំ វិនេតារំ** បានដល់ ជាមារយាទ គឺជាការប្រព្រឹត្តរបស់មនុស្សល្អ កិលេសទាំងឡាយ លោកពោលថា **សីមន្តា** ព្រោះមានចំណែកដែលជាទីបំផុតនៃមារយាទនោះ អធិប្បាយថា នាំកិលេសនោះចេញបានហើយ អាចារ្យមួយពួកពោលថា បទថា **សីមន្តា** គឺបុគ្គលណែនាំ សេក្ខបុគ្គល និងបុថុជ្ជន ដែលជាពុទ្ធវេនេយ្យ ដូច្នេះក៏មាន ។ បទថា **ជាតិមរណកោវិទំ** សេចក្តីថា ជាអ្នកឈ្លាសក្នុងជាតិ និងមរណៈ គឺឈ្លាសក្នុងជាតិ និងមរណៈថា ជាតិយ៉ាងនេះ មរណៈយ៉ាងនេះ ។ បទថា **មោនេយ្យសម្បន្នំ** បានដល់ សម្បូរដោយបញ្ញា ឬបរិបូណ៌ដោយការឈ្លាសតាមកាយជាដើម ។ បទថា **ភកុដី វិនយិត្វាន** សេចក្តីថា បុគ្គលមានបញ្ញាថោកថយខ្លះ ឃើញយាចកហើយ ធ្វើមុខក្រញូវ គប្បីកម្ចាត់នូវមុខក្រញូវនោះចេញ អធិប្បាយថា ជាអ្នកមានមុខថ្លូរផង់ ។ បទថា **បញ្ជលិកា** គឺជាអ្នកផ្គងនូវអញ្ជលី ។ លំដាប់នោះ ព្រាហ្មណ៍ កាលសរសើរព្រះមានព្រះភាគ ទើបទូលថា **ពុទ្ធោ ភវំ** ដូច្នេះជាដើម ។

*ក្នុងបទទាំងនោះ បទថា* **អាយាគោ** *គឺជាបុគ្គលគួរបូជា ។ ម្យ៉ាងទៀត ឈ្មោះថា* **អាយាគោ** *ព្រោះមកក្នុងទីនោះៗ ហើយគួរបូជា ដូច្នេះក៏បាន ។ លោកអធិប្បាយថា ជាបុគ្គលគួរទទួលនូវទេយ្យធម៌ទាំងឡាយ ។ បទដ៏សេស ក្នុងសូត្រនេះ បទណាមិនបានពណ៌នាក្នុងគាថា បទនោះ សូម្បីមិនពណ៌នា ក៏អាចយល់បាន ព្រោះមានអត្ថងាយស្រាប់ហើយ ដូច្នោះ ទើបមិនពណ៌នា ឯបទបន្ទាប់អំពីនេះ មានន័យដូចពោលហើយ ក្នុងកសិភារទ្វាជសូត្រនោះឯង ៕*

**អដ្ឋកថា សុន្ទរិកសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## មាយសូត្រទី៩

[ ៤៨ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅនាភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ គ្រានោះ មាយមាណពបានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបបង្គំទូលសំណេះសំណាលជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យគួររីករាយ គួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ មាយមាណព លុះអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គជាទាយកជាទានបតី អ្នកដឹងនូវពាក្យពេចន៍ ( របស់ស្មូម ) អ្នកគួរគេសូមបាន ស្វែងរកនូវភោគៈទាំងឡាយតាមធម៌ លុះខ្ញុំព្រះអង្គស្វែងរកភោគៈទាំងឡាយតាមធម៌បានហើយ ( ក៏យក ) នូវភោគៈទាំងឡាយ ដែលបានមកតាមធម៌សម្រេចមកតាមធម៌នោះ ឲ្យដល់បុគ្គលម្នាក់ខ្លះ ឲ្យដល់បុគ្គលពីរនាក់ខ្លះ ឲ្យដល់បុគ្គល ៣ នាក់ខ្លះ ឲ្យដល់បុគ្គល ៤ នាក់ខ្លះ ឲ្យដល់បុគ្គល ៥ នាក់ខ្លះ ឲ្យដល់បុគ្គល ៦ នាក់ខ្លះ ឲ្យដល់បុគ្គល ៧ នាក់ខ្លះ ឲ្យដល់បុគ្គល ៨ នាក់ខ្លះ ឲ្យដល់បុគ្គល ៩ នាក់ខ្លះ ឲ្យដល់បុគ្គល ១០ នាក់ខ្លះ ឲ្យដល់បុគ្គល ២០ នាក់ខ្លះ ឲ្យដល់បុគ្គល ៣០ នាក់ខ្លះ ឲ្យដល់បុគ្គល ៤០ នាក់ខ្លះ ឲ្យដល់បុគ្គល ៥០ នាក់ខ្លះ ឲ្យដល់បុគ្គលមួយរយនាក់ខ្លះ ឲ្យដល់បុគ្គលច្រើនជាងនោះខ្លះ បពិត្រព្រះគោតមដ៏ចម្រើន កាលខ្ញុំព្រះអង្គឲ្យយ៉ាងនេះ បូជាយ៉ាងនេះ តើបានបុណ្យច្រើនដែរឬ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា អើ មាណព កាលបើអ្នកឲ្យយ៉ាងនេះ បូជាយ៉ាងនេះ រមែងបានបុណ្យច្រើន ។

ម្នាលមាណព បើទាយកទានបតី អ្នកដឹងនូវពាក្យពេចន៍ ( របស់ស្មូម ) អ្នកគួរគេសូមបាន ដែលស្វែងរកភោគៈទាំងឡាយតាមធម៌ លុះស្វែងរកភោគៈទាំងឡាយតាមធម៌ហើយ ( ក៏យក ) ភោគៈទាំងឡាយតាមធម៌ សម្រេចមកតាមធម៌នោះ ឲ្យដល់បុគ្គលម្នាក់ខ្លះ ។បេ។ ឲ្យដល់បុគ្គលមួយរយនាក់ខ្លះ ឲ្យដល់បុគ្គលច្រើនជាងនោះខ្លះ ទាយកនោះរមែងបានបុណ្យច្រើន ។ លំដាប់នោះ មាឃមាណព បានក្រាបបង្គំទូលព្រះមានព្រះភាគ ដោយគាថាដូច្នេះថា

[ ៤៩ ] ខ្ញុំសូមទូលសួរព្រះគោតម ព្រះអង្គទ្រង់ជ្រាបនូវពាក្យពេចន៍ ទ្រង់អាស្រ័យនៅដោយសំពត់កាសាយៈ មិនមានផ្ទះ ត្រាច់ទៅផ្សេងៗ គ្រហស្ថណាជាម្ចាស់ទាន គួរគេសូមបាន ជាអ្នកត្រូវការដោយបុណ្យ ប្រាថ្នាបុណ្យ កាលឲ្យនូវបាយទឹក បូជាដល់ពួកជនដទៃក្នុងលោកនេះ ការបូជារបស់បុគ្គលដែលបូជានោះ តើបរិសុទ្ធដូចម្តេច ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) ម្នាលមាណព គ្រហស្ថ ( ណា ) ជាម្ចាស់ទាន គួរគេសូមបាន ជាអ្នកត្រូវការដោយបុណ្យ ប្រាថ្នាបុណ្យ កាលឲ្យនូវបាយ និងទឹក បូជាដល់ពួកជនដទៃក្នុងលោកនេះ គ្រហស្ថប្រាកដដូច្នោះ គប្បីញ៉ាំងទក្ខិណេយ្យបុគ្គលទាំងឡាយឲ្យត្រេកអរបាន ។

( មាឃមាណព ក្រាបទូលថា ) គ្រហស្ថ ( ណា ) ជា

ម្ចាស់ទាន គួរគេសូមបាន ជាអ្នកត្រូវការដោយបុណ្យ ប្រាថ្នាបុណ្យ កាលឲ្យនូវបាយ និងទឹក បូជាដល់ពួកជនដទៃ ក្នុងលោកនេះ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គប្រាប់នូវទក្ខិណេយ្យបុគ្គលទាំងឡាយ ( របស់គ្រហស្ថនោះ ) ចំពោះខ្ញុំព្រះអង្គ ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) ពួកជនណាមិនមានចិត្តជាប់ជំពាក់ក្នុងលោក មិនមានកង្វល់ មានកិច្ចសម្រេចហើយ ជាអ្នកគ្រប់គ្រងចិត្ត ព្រាហ្មណ៍ណាប្រាថ្នាបុណ្យហើយ បូជាព្រាហ្មណ៍នោះ គួរបរិច្ចាគទក្ខិណាទានចំពោះពួកជននោះ តាមកាលគួរ ។

ពួកជនណា បានផ្តាច់ចំណង គឺសំយោជនៈទាំងពួង ជាអ្នកបានទូន្មាននូវឥន្រ្ទិយ មានចិត្តផុតស្រឡះ មិនមានទុក្ខ មិនមានសេចក្តីប្រាថ្នា ព្រាហ្មណ៍ណា ប្រាថ្នានូវបុណ្យហើយ បូជាព្រាហ្មណ៍នោះ គប្បីបរិច្ចាគទក្ខិណាទាន ចំពោះពួកជននោះ តាមកាលគួរ ។ ពួកជនណា ផុតស្រឡះចាកសំយោជនៈទាំងពួង ជាអ្នកទូន្មាននូវឥន្រ្ទិយ មានចិត្តផុតស្រឡះ មិនមានទុក្ខ មិនមានសេចក្តីប្រាថ្នា ព្រាហ្មណ៍គួរបរិច្ចាគទក្ខិណាទានចំពោះពួកជននោះ តាមកាលគួរ ។ ( ពួកជនណា ) បានលះបង់រាគៈផង ទោសៈផង មោហៈផង មានអាសវៈអស់ហើយ មាន

មគ្គព្រហ្មចារ្យប្រព្រឹត្តរួចហើយ ព្រាហ្មណ៍គួរបរិច្ចាគទក្ខិណា-ទានចំពោះពួកជននោះ តាមកាលគួរ ។

ការបិទបាំងទោសខ្លួន និងការប្រកាន់ មិនមាននៅក្នុងពួកជនណា ដែលមានអាសវៈអស់ហើយ មានមគ្គព្រហ្មចារ្យប្រព្រឹត្តរួចហើយ ព្រាហ្មណ៍គួរបរិច្ចាគទក្ខិណាទានចំពោះពួកជននោះ តាមកាលគួរ ។

ពួកជនណា ប្រាសចាកសេចក្តីលោភ មិនប្រកាន់ មិនមានសេចក្តីប្រាថ្នា មានអាសវៈអស់ហើយមានមគ្គព្រហ្មចារ្យប្រព្រឹត្តរួចហើយ ព្រាហ្មណ៍គួរបរិច្ចាគទក្ខិណាទាន ចំពោះពួកជននោះ តាមកាលគួរ ។

ពួកជនណា មិនដល់នូវការធ្លាក់ចុះក្នុងតណ្ហាទាំងឡាយ មិនប្រកាន់ ហើយឆ្លងអន្លង់បាន ព្រាហ្មណ៍គួរបរិច្ចាគទក្ខិណាទានចំពោះពួកជននោះ តាមកាលគួរ ។ តណ្ហារបស់ពួកជនណាដើម្បីកើតមានទៅទៀតក្នុងលោកនេះ ឬលោកខាងមុខ ណាមួយ មិនមានទេ ព្រាហ្មណ៍គួរបរិច្ចាគទក្ខិណាទាន ចំពោះពួកជននោះ តាមកាលគួរ ។

ពួកជនណា បានលះបង់កាមទាំងឡាយ ជាអ្នកមិនមានសេចក្តីប្រកាន់ សង្រួមចិត្តត្រង់ល្អដូចខ្នារ ព្រាហ្មណ៍គួរបរិច្ចាគទក្ខិណាទាន ចំពោះពួកជននោះ តាមកាលគួរ ។

ពួកជនណា ប្រាសចាករាគៈ មានឥន្ទ្រិយតម្កល់មាំល្អ ដូចព្រះចន្ទដែលផុតស្រឡះចាករាហុគ្រាស ព្រាហ្មណ៍គួរបរិច្ចាគទក្ខិណាទានចំពោះពួកជននោះ តាមកាលគួរ ។

ពួកជនណា ជាអ្នកស្ងប់ចាកកិលេស ប្រាសចាករាគៈ មិនមានសេចក្ដីក្រោធ គតិរបស់ជនណាមិនមាន ព្រោះលះបង់ ( នូវខន្ធ ) ក្នុងលោកនេះ ព្រាហ្មណ៍គួរបរិច្ចាគទក្ខិណាទានចំពោះជននោះ តាមកាលគួរ ។

ពួកជនណា លះបង់ជាតិ និងមរណៈ មិនមានសេសសល់ ឆ្លងផុតសេចក្ដីងឿងឆ្ងល់គ្រប់យ៉ាង ព្រាហ្មណ៍គួរបរិច្ចាគទក្ខិណាទាន ចំពោះពួកជននោះ តាមកាលគួរ ។

ពួកជនណា មានខ្លួនជាទីពឹង ត្រាច់ទៅក្នុងលោក មិនមានកង្វល់ ផុតស្រឡះចាកសភាវធម៌ទាំងពួង ព្រាហ្មណ៍គួរបរិច្ចាគទក្ខិណាទានចំពោះពួកជននោះ តាមកាលគួរ ។

ពួកជនណា ដឹងក្នុងសភាវធម៌នុ៎ះតាមសេចក្ដីពិតថា ជាតិនេះជាជាតិបំផុតហើយ ភពថ្មីមិនមានតទៅទៀតឡើយ ព្រាហ្មណ៍គួរបរិច្ចាគទក្ខិណាទានចំពោះពួកជននោះ តាមកាលគួរ ។

ជនណាបានដល់នូវវេទ ត្រេកអរក្នុងឈាន ជាអ្នកមានស្មារតី បានសម្រេចនូវសម្ពោធិញ្ញាណ ជាទីពឹងរបស់ជនច្រើន ព្រាហ្មណ៍ណា ជាអ្នកប្រាថ្នានូវបុណ្យ ហើយបូជាព្រាហ្មណ៍នោះ គួរ

បរិច្ចាគទក្ខិណាទានចំពោះពួកជននោះ តាមកាលគួរ ។

( មាឃមាណព ក្រាបបង្គំទូលថា ) បពិត្រព្រះមានព្រះភាគ ការក្រាបទូលសួររបស់ខ្ញុំព្រះអង្គ មិនមែនជាការផុតអំពើ ដោយពិតព្រះអង្គបានសំដែងប្រាប់ទក្ខិណេយ្យបុគ្គលទាំងឡាយ ចំពោះខ្ញុំព្រះអង្គ ទើបខ្ញុំព្រះអង្គបានដឹងសេចក្តីនុ៎ះតាមពិត ធម៌ព្រះអង្គជ្រាបពិតយ៉ាងនោះហើយ ។

( មាឃមាណពក្រាបទូលថា ) គ្រហស្ថ ( ណា ) ជាម្ចាស់ទាន អ្នកគួរគេសូមបាន ជាអ្នកត្រូវការដោយបុណ្យ ប្រាថ្នានូវបុណ្យ កាលឲ្យបាយ និងទឹក បូជាដល់ពួកជនដទៃក្នុងលោកនេះ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គទ្រង់សំដែងប្រាប់នូវយញ្ញសម្បទា ( របស់គ្រហស្ថនោះ ) ដល់ខ្ញុំព្រះអង្គ ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលមាឃៈ អ្នកចូរបូជាចុះ កាលដែលអ្នកបូជា ចូរញុំាងចិត្តឲ្យជ្រះថ្លា ក្នុងកាលទាំងពួង ( ព្រោះ ) គ្រឿងយញ្ញជាអារម្មណ៍របស់អ្នកបូជា បុគ្គលដែលបានប្រតិស្ឋានក្នុងគ្រឿងយញ្ញនុ៎ះហើយ រមែងលះបង់នូវទោសបាន លុះបុគ្គលនោះប្រាសចាករាគៈ បន្ទោបង់នូវទោសៈហើយ រមែងចម្រើននូវមេត្តាចិត្តមិនមានប្រមាណ ជាបុគ្គលមិនធ្វេសប្រហែសជានិច្ច អស់យប់ និងថ្ងៃ ផ្សាយនូវមេត្តាចិត្តមិនមានប្រមាណ ក្នុងទិសទាំងពួង ។

( មាឃមាណពក្រាបទូលថា ) បុគ្គលដូចម្តេចបរិសុទ្ធ បុគ្គលដូចម្តេចរួច បុគ្គលដូចម្តេចជាប់នៅ បុគ្គលទៅកាន់ព្រហ្មលោកបាន ដោយហេតុដូចម្តេច បពិត្រព្រះអង្គជាអ្នកប្រាជ្ញ កាលបើខ្ញុំព្រះអង្គជាអ្នកមិនដឹង ក្រាបទូលសួរហើយ សូមព្រះអង្គទ្រង់សម្តែង បពិត្រព្រះអង្គជាព្រហ្ម ដ្បិតក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គបានឃើញព្រះអង្គជាបន្ទាល់ហើយ ព្រោះព្រះអង្គពិតជាស្មើគ្នានឹងព្រហ្មរបស់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គទ្រង់មានសេចក្តីរុងរឿង បុគ្គលទៅកាន់ព្រហ្មលោកបាន ដោយប្រការដូចម្តេច ។

( ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ) ម្នាលមាឃៈ តថាគតពោលថា បុគ្គលណាបូជានូវយញ្ញសម្បទា ៣ ប្រការ បុគ្គលបែបនោះ ញ៉ាំងពួកទក្ខិណេយ្យបុគ្គលឲ្យត្រេកអរបាន លុះបូជាយ៉ាងនេះហើយ ជាអ្នកគួរគេសូមបានដោយប្រពៃ រមែងចូលទៅកាន់ព្រហ្មលោក ។

[ ៥០ ] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ មាឃមាណព ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ ។ បេ ។ ថាជាអ្នកដល់នូវព្រះគោតមដ៏ចម្រើនជាសរណៈ ស្មើដោយជីវិត ចាប់ដើមអំពីថ្ងៃនេះតទៅ ។

**មាឃសូត្រទី ៥ ចប់**

# អដ្ឋកថា

## មាឃសូត្រ

[ ៤៨ ] ក្នុងមាឃសូត្រទី ៥ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះ។ សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា អត្ថុប្បត្តិ-ហេតុ លោកពោលហើយ ក្នុងនិទាននៃមាឃសូត្រនោះឯង ។

មានរឿងសង្ខេបថា មាឃមាណពនេះ ជាទាយក ជាទានបតី គាត់មានបរិវិតក្កថា ទានដែលឲ្យដល់មនុស្សកំព្រា និងអ្នកដំណើរដែលមកដល់ជាទានដែលមានផលច្រើន ឬមិនមានផលច្រើនហ្ន៎ អញនឹងទូលសួរសេចក្ដីនេះនឹងព្រះសមណគោតម ព្រោះបានឮថា ព្រះសមណគោតម ទ្រង់ជ្រាបអតីត អនាគត និងបច្ចុប្បន្ន ទើបចូលទៅសួរព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ព្យាករសមគួរដល់ពាក្យសួររបស់គាត់ សូត្រនេះសរុបពាក្យទាំង ៣ គឺពាក្យរបស់សង្គីតិកាចារ្យ ព្រាហ្មណ៍ និងព្រះមានព្រះភាគ ហៅថា **មាឃសូត្រ។**

ក្នុងបទទាំងនោះ បទថា **រាជគហេ** គឺក្នុងនគរមានឈ្មោះយ៉ាងនោះ ។ នគរនោះ ហៅថា រាជគ្រឹះ ព្រោះព្រះបាទមន្ធាតុ និងមហាគោវិន្ទគ្រប់គ្រង ។ អាចារ្យពួកដទៃពណ៌នាក្នុងទំនងដទៃអំពីនេះក៏មាន ។ លោកពណ៌នាដូចម្ដេច លោកពណ៌នាថា ពាក្យថា រាជគ្រឹះនេះ ជាឈ្មោះរបស់នគរនោះ នគរនោះជានគរដែលមានក្នុងកាលដែលព្រះពុទ្ធកើតឡើង និងក្នុងកាលដែលស្ដេចចក្រពត្តិកើតឡើងប៉ុណ្ណោះ ក្នុងកាលដ៏សេស ជានគរទទេ ត្រូវយក្ខគ្រប់គ្រងជាព្រៃ ជាទីលំនៅនៃយក្ខទាំងនោះ ។ ព្រះអានន្ទសម្ដែងដល់គោចរគ្រាម

យ៉ាងនេះហើយ ទើបពោលដល់ទីគង់ថា **គិជ្ឈកូដេ បព្វតេ** ដូច្នេះ ។ គប្បីជ្រាបថា ត្មាតរស់នៅលើកំពូលភ្នំនោះ ឬកំពូលភ្នំនោះ មានសណ្ឋានដូចត្មាត ទើបឈ្មោះថា **គិជ្ឈកូដ** ដូច្នេះ ។

ក្នុងបទថា **អជ ខោ ។បេ។ អវោច** មានវិនិច្ឆ័យដូចតទៅនេះ បទថា **មាឃ** ជាឈ្មោះរបស់ព្រាហ្មណ៍នោះ លោកហៅថា **មាណវ** ព្រោះជាអ្នកអាស្រ័យខាងក្នុងសម្នាក់ ។ តែដោយកំណើតជាអ្នកធំ ។ អាចារ្យមួយពួកពោលថា ជាអ្នកធំដោយការប្រព្រឹត្តប្រពៃមកអំពីមុន ដូចបិង្គិយមាណព ព្រោះថា បិង្គិយៈនោះ ទោះបីមានអាយុ ១២០ ឆ្នាំ ដោយការប្រព្រឹត្តប្រពៃមកអំពីមុន ក៏នៅតែហៅថា មាណពនោះឯង ។ បទដ៏សេស មានន័យដូចពោលហើយ ។

ក្នុងបទថា **អហំ ហិ ភោ ។បេ។ បសវាមិ** មានវិនិច្ឆ័យដូច្នេះ បទថា **ទាយកោ ទានបតិ** បានដល់ ជាទាយកផង ជាទានបតីផង ។ បុគ្គលណាត្រូវគេបបួលហើយ ឲ្យរបស់ដែលមានដល់អ្នកដទៃ បុគ្គលនោះ ត្រឹមតែជាទាយក តែមិនមែនជាទានបតី ព្រោះមិនជាធំក្នុងទាននោះ តែមាឃមាណពនេះ ឲ្យរបស់ខ្លួនពិតៗ ដោយហេតុនោះ ទើបមាឃមាណពពោលថា ខ្ញុំព្រះអង្គជាទាយក ជាទានបតី នេះជាអធិប្បាយក្នុងបទនោះ ។ គួរពោលដោយន័យជាដើមថា បុគ្គលដែលត្រូវសេចក្តីកំណាញ់គ្របសង្កត់ ក្នុងចន្លោះៗ ជាទាយក ជាអ្នកមិនត្រូវគ្របសង្កត់ ជាទានបតី ។ បទថា **វទញ្ញូ** គឺខ្ញុំព្រះអង្គដឹងនូវពាក្យរបស់អ្នកសូម គ្រាន់តែគេពោលប៉ុណ្ណោះ ក៏ដឹងថា បុគ្គលនេះ គួរ

ដល់វត្ថុនេះ បុគ្គលនេះ គួរឲ្យវត្ថុនេះ ដោយការទទួលភាពជាបុរសវិសេស ឬដោយការទទួលថា ជាអ្នកមានឧបការៈច្រើន ។ បទថា **យាចយោគោ** គឺ គួរដើម្បីសូម ។ មាណពពោលថា បុគ្គលណាឃើញយាចកហើយ ចងចិញ្ចើម ពោលនូវពាក្យគ្រោតគ្រាតជាដើម បុគ្គលនោះមិនឈ្មោះថា ជាបុគ្គលគួរដើម្បីសូម តែខ្ញុំព្រះអង្គមិនមែនដូច្នោះឡើយ ។ បទថា **ធម្មេន** សេចក្ដីថា វៀរនូវការលួច ការកែប្រវ័ញ្ច និងការបោកបញ្ឆោតជាដើម ដើម្បីភិក្ខាចារ អធិប្បាយថា ដោយការសូម ។ ការសូមជាទំនៀមក្នុងការស្វែងរកភោគទ្រព្យ របស់ពួកព្រាហ្មណ៍ដោយពិត ភោគទ្រព្យដែលអ្នកដទៃបំណងនឹងអនុគ្រោះឲ្យដល់ព្រាហ្មណ៍អ្នកសូមនោះ ឈ្មោះថា បានមកហើយដោយធម៌ និងបានទទួលហើយដោយធម៌ ឯមាយមាណពនោះ ស្វែងរកយ៉ាងនោះបានមក ដោយហេតុនោះ ទើបមាយមាណពពោលថា **ធម្មេន ភោគេ បរិយេសាមិ ។បេ។ ធម្មាធិគតេហិ** ដូច្នេះ ។ បទថា **ភិយ្យោបិ ទទាមិ** សេចក្ដីថា មាយមាណពចង្អុលបង្ហាញថា ខ្ញុំព្រះអង្គថ្វាយក្រៃលែងជាងនោះខ្លះ មិនមានកំណត់ ខ្ញុំព្រះអង្គថ្វាយតាមចំនួនភោគទ្រព្យដែលបានមក ។ បទថា **តគ្ឃ** ជានិបាត ចុះក្នុងអត្ថថា ចំណែកមួយ ។ ពិតហើយ ទានដែលព្រះពុទ្ធគ្រប់អង្គ ព្រះបច្ចេកពុទ្ធ និងសាវកទាំងឡាយសរសើរហើយ ដោយចំណែកមួយប៉ុណ្ណោះ ដោយហោច ឲ្យដល់សត្វតិរច្ឆាន ។ សមដូចលោកពោលថា សេចក្ដីថា ទាន លោកសរសើរក្នុងទីទាំងពួង ទាន លោកមិនតិះដៀលក្នុងទីណាមួយឡើយ ព្រោះដូច្នោះ សូម្បីព្រះមានព្រះភាគ កាលទ្រង់សរសើរ

ទាននោះ ដោយចំណែកមួយ ទើបត្រាស់ថា **តស្ស តុំ មាណវ** ។បេ។ **បសវសិ** ដូច្នេះ ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។

ព្រះមានព្រះភាគ កាលត្រាស់ថា **ពហុំ សោ បុញ្ញំ បសវតិ** ព្រាហ្មណ៍បំណងនឹងស្តាប់ទក្ខិណាវិសុទ្ធិ ចាកទក្ខិណេយ្យបុគ្គល ទើបទូលព្រះមានព្រះភាគក្រែលែងឡើង ដោយហេតុនោះ ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលថា **អថ ខោ មាឃោ មាណវោ ភគវន្តំ គាថាយ អជ្ឈភាសិ** ដោយសេចក្តី ពាក្យនោះ មានន័យដូចពោលហើយនោះឯង ។

[ ៤៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាដើមថា **បុច្ឆាមហំ** ដូចតទៅ បទថា **វទញ្ញុំ** បានដល់ អ្នកដឹងនូវវាចា ។ លោកអធិប្បាយថា ដឹងបំណងរបស់សត្វទាំងឡាយដែលនិយាយគ្រប់យ៉ាង ។ បទថា **សុជ្ឈេ** បានដល់ គប្បីបរិសុទ្ធ គឺគប្បីមានផលច្រើន ដោយអំណាចទក្ខិណេយ្យបុគ្គល តែក្នុងបទនេះ យោជនាអធិប្បាយថា បុគ្គលណាជាគ្រហស្ថ គួរដល់ការសូម ជាទានបតី ត្រូវការដោយបុណ្យ ឲ្យនូវបាយ និងទឹក បូជាដល់ជនដទៃ តែមិនដាក់គ្រឿងបូជាក្នុងភ្លើង ប្រាថ្នាបុណ្យប៉ុណ្ណោះ មិនប្រាថ្នាផលតបស្នង មានកិត្តិសព្ទដ៏ល្អជាដើម ការបូជារបស់បុគ្គលនោះ ដែលបូជាបែបនេះ គប្បីបរិសុទ្ធបានដូចម្តេច ។ បទថា **អារាធយេ ទក្ខិណេយ្យេហិ តាទិ** សេចក្តីថា គួរដល់ការសូមបែបនោះ គប្បីឲ្យទក្ខិណេយ្យបុគ្គលត្រេកអរ ពេញចិត្ត ឲ្យបរិសុទ្ធ រមែងធ្វើការបូជាឲ្យមានផលច្រើន មិនមែនដទៃឡើយ ដោយបទនេះ ឈ្មោះថា ទ្រង់ព្យាករពាក្យថា ការបូជារបស់បុគ្គលដែលបូជានោះ តើ

បរិសុទ្ធដូចម្ដេច ។ ក្នុងបទថា **អក្ខាហិ មេ ភគវា ទក្ខិណេយ្យេ** គប្បី ជ្រាបយោជនាយ៉ាងនេះថា បុគ្គលណាគួរដល់ការសូម ឲ្យទាន បូជាដល់អ្នកដទៃ សូមព្រះមានព្រះភាគ ទ្រង់ប្រាប់ទក្ខិណេយ្យបុគ្គលដល់ខ្ញុំព្រះអង្គផងចុះ ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ប្រកាសទក្ខិណេយ្យបុគ្គលដល់មាណពនោះ ដោយន័យច្រើនប្រការ បានត្រាស់គាថាថា **យេ វេ អលគ្គា** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **អលគ្គា** គឺមិនជំពាក់ដោយគ្រឿងជាប់ជំពាក់មានរាគៈជាដើម ។ បទថា **កេវលិនោ** គឺមានកិច្ចដែលត្រូវធ្វើស្រេចហើយ ។ បទថា **យតត្តា** ស្មើគ្នានឹង **គុត្តចិត្តា** ប្រែថា មានចិត្តគ្រប់គ្រងហើយ ។ បទថា **ឧត្តា** បានដល់ ដោយការទូន្មានដ៏កំពូល ។ បទថា **វិមុត្តា** បានដល់ ដោយបញ្ញាវិមុត្តិ និងចេតោវិមុត្តិ ។ បទថា **អនីឃា** បានដល់ ព្រោះមិនមានទុក្ខក្នុងវដ្តៈតទៅ ។ បទថា **និរាសា** បានដល់ ព្រោះមិនមានទុក្ខក្នុងបច្ចុប្បន្ន ។ គប្បីជ្រាបថា លោកពោលគាថាទី ២ នៃគាថានេះ ដោយវិធីដែលប្រកាសអានុភាពរបស់ភាវនា ។ ក្នុងសេចក្ដីនេះ មានសូត្រ ( ក្នុងអង្គុត្តរនិកាយ សត្តកនិបាត ) ជាសាធកៈថា

ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមិនប្រកបរឿយៗ នូវភាវនា បើទុកជាមានសេចក្ដីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ ចិត្តរបស់អាត្មាអញ គប្បីផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំដូច្នេះក៏ដោយ ក៏គង់តែចិត្តរបស់ភិក្ខុនោះ មិនរួចស្រឡះចាក

អាសវៈទាំងឡាយ ព្រោះតែមិនប្រកាន់មាំដែរ ដូច្នេះ ។

បទថា **រាគញ្ច ។បេ។ យេសុ ន មាយា ។បេ។ ន តណ្ហាសុ ឧបាតិបន្នា** មានអធិប្បាយថា បទថា **ន តណ្ហាសុ ឧបាតិបន្នា** បានដល់ ជាអ្នកមិនបង្អោនទៅក្នុងកាមតណ្ហាជាដើម ។ បទថា **វិតរេយ្យ** ប្រែថា ឆ្លងហើយ ។ បទថា **តណ្ហា** បានដល់ តណ្ហា ៦ យ៉ាង មានរូបតណ្ហាជាដើម ។ បទថា **ភវាភវាយ** បានដល់ សស្សតទិដ្ឋិ ឬឧច្ឆេទទិដ្ឋិ ។ ម្យ៉ាងទៀត ដើម្បីការមិនមាននៃភព ឈ្មោះថា **ភវាភវាយ** ។ លោកអធិប្បាយថា ដើម្បីកើតក្នុងភពថ្មី ។ បទថា **ឥធ វា ហុរំ វា** នេះ ជាពាក្យពង្រីករបស់បទនេះថា **កុហិញ្ចិ លោកេ** ។ បទថា **យេ វីតរាគា ។បេ។ សមិតាវិនោ** អធិប្បាយថា ជាអ្នកស្ងប់ មានកិលេសស្ងប់ហើយ ។ ម្យ៉ាងទៀត ឈ្មោះថា ជាអ្នកប្រាសចាកតម្រេក ជាអ្នកមិនក្រោធ ព្រោះមានកិលេសស្ងប់ហើយ ។ បទថា **ឥធ វិប្បហាយ** លោកអធិប្បាយថា ព្រោះលះខន្ធដែលប្រព្រឹត្តទៅក្នុងលោកនេះហើយ បន្ទាប់អំពីនោះ ក៏មិនមានការទៅកាន់លោកដទៃ ។ បន្ទាប់អំពីនេះទៅ អាចារ្យពួកខ្លះពោលគាថានេះថា

ជនទាំងឡាយណា លះបង់កាមទាំងឡាយ ជាអ្នកមិនមាន
សេចក្តីប្រកាន់ សង្រួម ចិត្តត្រង់ល្អដូចខ្នារ ដូច្នេះ ។

បទថា **ជហេត្វា** បានដល់ លះហើយ ។ បាលីថា **ជហិត្វា** ក៏មានសេចក្តីក៏តែមួយដូចគ្នា ។ បទថា **អត្តទីបា** លោកពោលដល់ព្រះខីណាស្រពធ្វើគុណរបស់ខ្លួននោះឯងឲ្យជាទីពឹងរបស់ខ្លួន ត្រាច់ទៅ ។ **ហ** អក្ខរៈ ក្នុង

បទថា **យេ ហោន្តិ** ជានិបាត ប្រើក្នុងអត្ថត្រឹមតែធ្វើបទឲ្យពេញ ។ សេចក្តីនេះ មានអធិប្បាយថា ជនឯណាដឹងនូវការបន្តនៃខន្ធ និងអាយតនៈជាដើមតាមសេចក្តីពិតថា នេះ គឺខន្ធ នេះ គឺអាយតនៈ កាលដឹងសភាវៈតាមសេចក្តីពិត ដោយអំណាចនៃភាពជារបស់មិនទៀងជាដើម រមែងដឹងយ៉ាងនេះថា **អយមន្តិមា ជាតិ បុនព្ភវោ** អធិប្បាយថា ជាតិរបស់យើងទាំង-ឡាយនេះមានក្នុងទីបំផុត ឥឡូវនេះ ភពថ្មីមិនមាន ។ បទថា **យោ វេទគូ** ព្រះមានព្រះភាគត្រាស់គាថានេះ សំដៅដល់ព្រះអង្គក្នុងឥឡូវនេះ ។

ក្នុងបទទាំងនោះ បទថា **សតីមា** គឺប្រកបដោយសតិដែលជាវិហារធម៌ជានិច្ច ៦ យ៉ាង ។ បទថា **សម្ពោធិបត្តោ** គឺសម្រេចសព្វញ្ញុតញ្ញាណ ។ បទថា **សរណំ ពហុន្នំ** គឺទីពឹងរបស់ទេវតា និងមនុស្សទាំងឡាយជាច្រើនដោយឲ្យផុតចាកសេចក្តីខ្លាច និងការបៀតបៀន ។

ព្រាហ្មណ៍ កាលបានស្តាប់ទក្ខិណេយ្យបុគ្គលយ៉ាងនេះហើយ ពេញចិត្តទើបក្រាបទូលថា **អទ្ធា អមោឃា** ជាដើម ។

ក្នុងបទទាំងនោះ បទថា **តព្ភេវ** **ជានាសិ** **យថា** **តថា** **ឥទំ** សេចក្តីថា ពិតហើយ ព្រះអង្គទ្រង់ដឹងញេយ្យធម៌នេះក្នុងលោកនេះតាមសេចក្តីពិត គឺទ្រង់ដឹងតាមសេចក្តីពិត ។ ម្យ៉ាងទៀត លោកអធិប្បាយថា ទ្រង់ដឹងនូវញេយ្យធម៌នោះឯង ។ បទថា **តថា ហិ តេ វិទិតោ ឯស ធម្មោ** គឺពិតដូច្នោះ ធម្មធាតុនេះ ទ្រង់ចាក់ធ្លុះហើយ អធិប្បាយថា ទ្រង់ជ្រាបធម្មធាតុដែលទ្រង់ប្រាថ្នា ព្រោះទ្រង់ចាក់ធ្លុះហើយ ។

ព្រាហ្មណ៍នោះ ជ្រះថ្លាក្នុងព្រះមានព្រះភាគនោះយ៉ាងនេះហើយ កាល ដឹងនូវភាពសម្បូរនៃយញ្ញ បានដោយភាពសម្បូរនៃទក្ខិណេយ្យបុគ្គលហើយ បំណងស្តាប់ភាពសម្បូរនៃយញ្ញដែលបរិបូណ៌ដោយអង្គ ៦ នោះ ដោយការ សម្បូរនៃទាយកទៀត ទើបទូលសួរបញ្ហាតទៅថា **យាចយោគោ** ដូច្នេះ ជាដើម ។

ក្នុងបទនោះ យោជនាលម្អិតសេចក្តីថា បុគ្គលណា ជាបុគ្គលគួរដល់ ការសូម ឲ្យបាយ និងទឹក បូជាដល់ជនពួកដទៃ សូមព្រះមានព្រះភាគទ្រង់ ត្រាស់ប្រាប់ការសម្បូរនៃយញ្ញរបស់បុគ្គលនោះ ដល់ខ្ញុំព្រះអង្គចុះ ។ គ្រា នោះ ព្រះមានព្រះភាគទ្រង់ប្រាប់ដល់គាត់ដោយ ២ គាថា ។

ក្នុងគាថានោះ យោជនាលម្អិតថា ម្នាលមាឃៈ កាលអ្នកបូជា ក៏ចូរ បូជាចុះ ចូរធ្វើចិត្តឲ្យផូរផង់ក្នុងកាលទាំងពួង គឺចូរធ្វើចិត្តឲ្យផូរផង់ក្នុងកាល ទាំង ៣ ព្រះមានព្រះភាគទ្រង់ត្រាស់យញ្ញសម្បទានេះ ក្នុងអង្គុត្តរនិកាយ ឆក្កនិបាតថា

ទាយកមានចិត្តរីករាយ ក្នុងវេលាមុនអំពីកាលឲ្យ កំពុងឲ្យ ធ្វើចិត្តឲ្យជ្រះថ្លា លុះឲ្យហើយ ក៏មានចិត្តត្រេកអរ ( តាម ក្រោយ ) នេះជាសេចក្តីបរិបូណ៌របស់ទាន ដូច្នេះ ។

យញ្ញនឹងសម្បូរដោយសម្បទានៃយញ្ញនោះ ក្នុងសេចក្តីនោះ មាន ពាក្យសួរថា ធ្វើចិត្តឲ្យផូរផង់បានដូចម្តេច ឆ្លើយថា ដោយការលះទោសៈ ។ សួរថា លះទោសៈបានដូចម្តេច ឆ្លើយថា ដោយការទាញយញ្ញជាអារម្មណ៍

អធិប្បាយថា កាលបូជាទាញយញ្ញជាអារម្មណ៍ តាំងនៅក្នុងយញ្ញនោះ លះនូវទោសៈចេញ កាលបូជា មានចិត្តកម្ចាត់នូវធនីត គឺមោហៈ យកសម្មាទិដ្ឋិជាប្រទីប មានមេត្តាក្នុងសត្វទាំងឡាយជាប្រធាន យញ្ញ គឺទេយ្យធម៌នេះជាអារម្មណ៍ បុគ្គលនោះតាំងមាំក្នុងយញ្ញនេះ ដោយការទាញយកជាអារម្មណ៍ ឈ្មោះថា រមែងលះនូវវត្ថុមិនល្អទាំង ៣ នេះ គឺលោភៈ ដែលមានទេយ្យធម៌ជាបច្ច័យ លះសេចក្ដីក្រោធ ដែលមានបដិឃាតកជាបច្ច័យ លះមោហៈដែលជាហេតុនៃលោភៈ និងក្រោធៈទាំង ២ ។ បុគ្គលនោះជាអ្នកប្រាសចាកតម្រេកក្នុងភោគទ្រព្យយ៉ាងនេះ គប្បីកម្ចាត់ទោសៈក្នុងសត្វទាំងឡាយ លះនីវរណៈ ៥ បានដោយការកម្ចាត់ទោសៈនោះឯង ចម្រើនមេត្តាចិត្តដែលមិនមានប្រមាណ ដែលមានប្រភេទជាឧបចារៈ និងអប្បនាដោយលំដាប់ ដោយការផ្សាយមេត្តាទៅកាន់សត្វ មិនមានប្រមាណ ឬដោយការផ្សាយមេត្តា មិនមានចំណែកសេសសល់ក្នុងសត្វមួយ ជាអ្នកមិនប្រមាទក្នុងឥរិយាបថទាំងអស់រឿយៗ ទាំងពេលថ្ងៃ យប់ ដើម្បីការបរិបូណ៌នៃភាវនាតទៅ រមែងផ្សាយអប្បមញ្ញាភាវនា គឺមេត្តាឈាននោះឯងទៅគ្រប់ទិស ។

លំដាប់នោះ ព្រាហ្មណ៍មិនដឹងមេត្តានោះថា នេះជាផ្លូវនៃព្រហ្មលោក កាលស្ដាប់មេត្តាភាវនាដែលកន្លងវិស័យរបស់ខ្លួន កើតនូវការសរសើរក្នុងព្រះសព្វញ្ញូ ក្នុងព្រះមានព្រះភាគក្រៃលែងឡើង ព្រោះខ្លួនឯងមានអធ្យាស្រ័យក្នុងព្រហ្មលោក ទើបសម្គាល់ថា ការកើតក្នុងព្រហ្មលោកប៉ុណ្ណោះ ជាសេចក្ដីបរិសុទ្ធ និងការរួចផុត កាលទូលសួរដល់ផ្លូវទៅព្រហ្មលោក ទើបពោលគាថា

ថា **កេោ សុជ្ឈតី** ដូច្នេះជាដើម ។

ក្នុងគាថានោះ ព្រាហ្មណ៍ពោលថា **កោ សុជ្ឈតី មុញ្ចតិ** សំដៅដល់បុគ្គលដែលធ្វើបុណ្យដើម្បីទៅព្រហ្មលោក ពោលថា **ពជ្ឈតី ច** សំដៅដល់បុគ្គលដែលមិនធ្វើបុណ្យដើម្បីទៅព្រហ្មលោក ។ បទថា **កេនត្តនា** គឺដោយហេតុអ្វី ។ បទថា **សក្ខិ ព្រហ្មជ្ជ ទិដ្ឋោ** សេចក្ដីថា ថ្ងៃនេះ អាងព្រះអង្គដែលព្រហ្មជាបន្ទាល់ ។ បទថា **សច្ចំ** បានដល់ ព្រាហ្មណ៍ប្រារព្ធភាពដែលព្រះមានព្រះភាគជាបុគ្គលស្មើដោយព្រហ្ម ទើបតាំងនូវពាក្យសួរ ដោយសេចក្ដីគោរពក្រៃលែង ។ បទថា **កថំ ឧបបជ្ជតិ** ព្រាហ្មណ៍សួរទៀត ដោយសេចក្ដីគោរពក្រៃលែង ។ ព្រាហ្មណ៍ហៅព្រះមានព្រះភាគថា **ជុតិមា** ។

ក្នុងគាថានោះ មានអធិប្បាយដូច្នេះថា ព្រោះភិក្ខុណាញុំាងឈាន ៣ និង ៤ ឲ្យកើតដោយមេត្តាភាវនា ធ្វើឈាននោះឲ្យជាបាទហើយ រមែងសម្រេចអរហត្ត ភិក្ខុនោះ ឈ្មោះថា រមែងបរិសុទ្ធ និងរមែងរួចផុត ភិក្ខុបែបនោះ មិនទៅព្រហ្មលោក តែភិក្ខុណាញុំាងឈាន ៣ និង ៤ ឲ្យកើតដោយមេត្តាភាវនា ពេញចិត្តក្នុងឈាននោះ ដោយន័យជាដើមថា សមាបត្តិនេះល្អិត ភិក្ខុនោះ ឈ្មោះថា នៅជាប់នៅឡើយ ម្យ៉ាងទៀត កាលឈានមិនទាន់សាបសូន្យ រមែងទៅកាន់ព្រហ្មលោក ដោយឈាននោះ ដូច្នោះ ព្រះមានព្រះភាគទ្រង់មិនឃើញដោយការទៅព្រហ្មលោក ទើបមិនពាល់ត្រូវនូវបុគ្គលអ្នកបរិសុទ្ធ ដែលរួចផុត កាលទ្រង់សម្ដែងដល់ការទៅព្រហ្មលោកដោយឈាននោះដល់ព្រាហ្មណ៍ ដែលកំពុងជាប់ ទើបត្រាស់គាថានេះថា

**យោ យជតិ** ដូច្នេះជាដើម ដោយន័យដែលជាទីសប្បាយដល់ព្រាហ្មណ៍ ។

ក្នុងបទទាំងនោះ បទថា **តិវិធំ** ព្រះមានព្រះភាគត្រាស់សំដៅដល់ការជ្រះថ្លាទាំង ៣ កាល ។ ដោយបទនោះ សម្តែងដល់អង្គ ៣ របស់ទាយក ។ បទថា **អារាធយេ ទក្ខិណេយ្យេហិ តាទិ** សេចក្តីថា បុគ្គលនោះ គឺបុគ្គលដែលញ៉ាំងការដល់ព្រមដោយយញ្ញ ៣ យ៉ាងឲ្យសម្រេច គប្បីញ៉ាំងការដល់ព្រមដោយយញ្ញ ៣ យ៉ាងឲ្យសម្រេច គឺឲ្យសម្បូរដោយទក្ខិណេយ្យបុគ្គល គឺព្រះខីណាស្រព ។ ដោយបទនេះ លោកសម្តែងដល់អង្គ ៣ របស់បដិគ្គាហក ។ បទថា **ឯវំ យជិត្វា សម្មា យាចយោគោ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ធ្វើព្រាហ្មណ៍ឲ្យកើតនូវឧស្សាហ៍ថា តថាគតពោលបុគ្គលនោះថា ជាបុគ្គលគួរដល់ការសូម កាលបូជាយញ្ញដែលដល់ព្រមដោយអង្គ ៦ មានមេត្តាឈានជាបទដ្ឋាន ដោយប្រពៃហើយយ៉ាងនេះ រមែងចូលដល់ព្រហ្មលោក ដោយមេត្តាឈាន ដែលចូលទៅអាស្រ័យយញ្ញ ដែលប្រកបដោយអង្គ ៦ នោះ ដូច្នេះ ទ្រង់ញ៉ាំងទេសនាឲ្យចប់បរិបូណ៌ ។ បទដ៏សេស ក្នុងគាថាទាំងអស់ មានអត្ថងាយយល់ហើយ ពាក្យខាងចុង ក៏មានន័យដូចពោលហើយ ក្នុងកាលមុននោះឯង ។៚

**អដ្ឋកថាមាឃសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## សភិយសូត្រទី៦

[ ៥១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ទេវតាជាសាលោហិតពីដើម របស់បរិព្វាជកឈ្មោះសភិយៈ បានសម្តែងឡើងនូវប្រស្នាទាំងឡាយថា ម្នាលសភិយៈ សមណៈ ឬព្រាហ្មណ៍ណាដែលអ្នកសួរប្រស្នាទាំងនេះហើយ ឆ្លើយរួច អ្នកត្រូវប្រព្រឹត្តព្រហ្មចារ្យក្នុងសម្នាក់នៃសមណៈ ឬព្រាហ្មណ៍នោះចុះ ។ គ្រានោះ សភិយបរិព្វាជក រៀនប្រស្នាទាំងឡាយក្នុងសម្នាក់ទេវតានោះ ទើបចូលទៅរកពួកសមណព្រាហ្មណ៍ជាអ្នកមានពួក មានក្រុម ( ប្តេជ្ញាខ្លួនថាជាសព្វញ្ញុសាស្តា ) ជាគណាចារ្យដែលអ្នកផងធ្លាប់ស្គាល់ ជាអ្នកមានយស ធ្វើនូវកំពង់ គឺទិដ្ឋិដែលជនច្រើនគ្នាសន្មតថា ជាសប្បុរស គឺគ្រូឈ្មោះបូរណកស្សបៈ ឈ្មោះមក្ខលិគោសាលឈ្មោះអជិតកេសកម្ពល ឈ្មោះបកុទ្ធកច្ចាយនៈ ឈ្មោះសញ្ជយវេឡដ្ឋបុត្តឈ្មោះនិគន្ថនាដបុត្ត ហើយសួរប្រស្នាទាំងនោះ ។ គ្រូទាំងនោះ លុះត្រូវសភិយបរិព្វាជក សួរប្រស្នាទាំងឡាយ ក៏ឆ្លើយមិនរួច កាលបើឆ្លើយមិនរួច ក៏ធ្វើនូវសេចក្តីក្រោធ ប្រទូស្តអាក់អន់ចិត្តឲ្យប្រាកដឡើង រួចក៏សួរត្រឡប់ទៅរកសភិយបរិព្វាជកវិញ ។ គ្រានោះ សភិយបរិព្វាជក មានសេចក្តីត្រិះរិះយ៉ាងនេះថា សមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនណា ជាអ្នកមានពួក មានក្រុម ជាគណាចារ្យដែលអ្នកផងធ្លាប់ស្គាល់ ជាអ្នកមានយស ធ្វើនូវកំពង់ គឺទិដ្ឋិ ដែលជនច្រើនគ្នាសន្មតថា ជាសប្បុរស គឺគ្រូឈ្មោះបូរណកស្សបៈ ។បេ។

ឈ្មោះនិគន្ថនាដបុត្ត សមណព្រាហ្មណ៍ទាំងនោះ លុះត្រូវអញសួរប្រស្នាទាំង-ឡាយហើយ ក៏ឆ្លើយមិនរួច កាលបើឆ្លើយមិនរួច ក៏ធ្វើនូវសេចក្ដីក្រោធ ប្រទូស្តអាក់អន់ចិត្តឲ្យប្រាកដឡើង រួចក៏សួរត្រឡប់មករកអញក្នុងប្រស្នាទាំងនុ៎ះវិញ បើដូច្នោះ គួរតែអាត្មាអញ ត្រឡប់មកកាន់ភេទថោកទាប គឺភេទគ្រហស្ថ បរិភោគកាមវិញចុះ ។ លំដាប់នោះ សភិយបរិព្វាជក មានសេចក្ដីត្រិះរិះយ៉ាងនេះថា ព្រះសមណគោតមនេះឯង ក៏ជាអ្នកមានពួក មានក្រុម ជាគណាចារ្យ ដែលអ្នកផងធ្លាប់ស្គាល់ ជាអ្នកមានយស ធ្វើនូវកំពង់ គឺទិដ្ឋិ ដែលជនច្រើនគ្នាសន្មតថា ជាសប្បុរសដែរ បើដូច្នោះ គួរតែអាត្មាអញចូលទៅរកព្រះសមណគោតម ហើយសួរប្រស្នាទាំងនេះ ។ លំដាប់នោះ សភិយ-បរិព្វាជក មានសេចក្ដីត្រិះរិះយ៉ាងនេះទៀតថា សមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនណា ដែលចាស់គ្រាំគ្រា ជាព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅយូរឆ្នាំមកហើយ មានអាយុក៏ជ្រុលចូលមកក្នុងបច្ឆិមវ័យហើយ ជាអ្នកខ្ជាប់ខ្ជួន ( ក្នុងសមណធម៌ ) ស្គាល់រាត្រីច្រើន បួសយូរយារហើយ ជាអ្នកមានពួក មានក្រុម ជាគណាចារ្យ ដែលអ្នកផងធ្លាប់ស្គាល់ ជាអ្នកមានយស ធ្វើនូវកំពង់ គឺទិដ្ឋិដែលជនច្រើនគ្នាសន្មតថាជាសប្បុរស គឺគ្រូឈ្មោះបូរណកស្សបៈ ។បេ។ ឈ្មោះនិគន្ថនាដបុត្ត សមណព្រាហ្មណ៍ទាំងនោះសោត លុះត្រូវអញសួរប្រស្នាទាំងឡាយហើយ ក៏ឆ្លើយមិនរួច កាលបើឆ្លើយមិនរួច ក៏ធ្វើនូវសេចក្ដីក្រោធ ប្រទូស្តអាក់អន់ចិត្តឲ្យប្រាកដឡើង រួចក៏សួរត្រឡប់មកអញក្នុងប្រស្នាទាំងនុ៎ះវិញ ។ ចុះព្រះសមណគោតម កាលបើត្រូវអញសួរប្រស្នា

ទាំងនេះហើយ តើនឹងឆ្លើយយ៉ាងណាទៅអេះ ។ ព្រោះថា ព្រះសមណ-គោតម ក្មេងដោយជាតិផង ថ្មីដោយផ្នួសផង ។ លំដាប់នោះ សភិយ-បរិព្វាជក មានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះសមណគោតម អញមិនត្រូវមើលងាយ មិនត្រូវពេបជ្រាយថាក្មេងទេ ទោះបីព្រះអង្គ ជាសមណៈក្មេងក៏ពិត ប៉ុន្តែព្រះអង្គជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ។ បើដូច្នោះ គួរតែអញចូលទៅរកព្រះសមណគោតម ហើយសួរប្រស្នាទាំងនេះ ។ គ្រានោះ សភិយបរិព្វាជក ក៏ជៀសចេញទៅកាន់ចារិក សំដៅទៅក្រុងរាជគ្រឹះ កាលដើរទៅកាន់ចារិកតាមលំដាប់ ក៏បានចូលទៅរកព្រះមានព្រះភាគឯវត្តវេឡុវ័នជាកលន្ទកនិវាបស្ថាន ក្នុងក្រុងរាជគ្រឹះ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរីករាយ ស្មោះសរជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ គួរឲ្យរឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ សភិយបរិព្វាជក លុះអង្គុយក្នុងទីដ៏សមគួរហើយ បានពោលចំពោះព្រះមានព្រះភាគដោយគាថា

[ ៥២ ] ( សភិយបរិព្វាជកពោលថា ) ខ្ញុំព្រះអង្គមានសេចក្តី
ងឿងឆ្ងល់សង្ស័យ ទើបមកប៉ុនប៉ងនឹងសួរប្រស្នាទាំងឡាយ
( ហេតុនោះ ) ព្រះអង្គ កាលបើខ្ញុំព្រះអង្គសួរប្រស្នាទាំងឡាយ
ហើយ សូមធ្វើនូវទីបំផុតនៃប្រស្នាទាំងនោះ សូមព្រះអង្គសម្តែង
ធម៌តាមសមគួរដល់សេចក្តី ជាលំដាប់លំដោយដល់ខ្ញុំព្រះអង្គ
ឲ្យទាន ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសភិយៈ ) អ្នកមក

អំពីចម្ងាយ ប៉ុនប៉ងនឹងសួរប្រស្នាទាំងឡាយ តថាគតកាល
បើអ្នកសួរប្រស្នាទាំងឡាយហើយ នឹងធ្វើនូវបំផុតនៃប្រស្នាទាំង
នោះ តថាគតនឹងដោះស្រាយនូវធម៌ ដ៏សមគួរដល់សេចក្តីជា
លំដាប់លំដោយដល់អ្នក ។ ម្នាលសភិយៈ អ្នកប៉ុនប៉ងក្នុងចិត្ត
ចំពោះប្រស្នាណាមួយ ចូរសួរប្រស្នានោះមកតថាគតចុះ តថា-
គតនឹងធ្វើនូវបំផុតនៃប្រស្នានោះៗ ដល់អ្នក ។

[ ៥៣ ] គ្រានោះ សភិយបរិព្វាជក នឹកយ៉ាងនេះថា យីអើ អស្ចារ្យ
ណាស់ យីអើ ចម្លែកណាស់ អញមិនដែលបានសូម្បីត្រឹមតែកម្ម គឺឱកាស
ក្នុងសម្នាក់នៃសមណព្រាហ្មណ៍ទាំងឡាយដទៃ ដោយហេតុណា ហេតុនោះ
ព្រះសមណគោតមបានធ្វើកម្ម គឺឱកាសនោះដល់អញហើយៗ ក៏ត្រេកអរ
រីករាយ មានចិត្តអណ្តែតឡើង កើតបីតិសោមនស្ស ហើយសួរប្រស្នានឹង
ព្រះមានព្រះភាគ ។

( សភិយបរិព្វាជកសួរថា ) បណ្ឌិតទាំងឡាយ ហៅបុគ្គល
អ្នកបានគុណវិសេសដូចម្តេច ថាជាភិក្ខុ បណ្ឌិតទាំងឡាយហៅ
បុគ្គលអ្នកស្ងប់រម្ងាប់ដោយធម៌ល្អ ដោយហេតុដូចម្តេច បុគ្គល
ដែលមានខ្លួនទូន្មានហើយ ដោយប្រការដូចម្តេច អ្នកផងតែង
ហៅថា ព្រះពុទ្ធ តើដោយប្រការដូចម្តេច បពិត្រព្រះមានព្រះ
ភាគ ព្រះអង្គកាលបើខ្ញុំព្រះអង្គសួរហើយ សូមឆ្លើយឲ្យទាន ។
( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសភិយៈ ) បុគ្គលណា

បានដល់នូវការរម្ងត់ទុក្ខ ដោយមគ្គដែលខ្លួនបានចម្រើនហើយ ឆ្លងផុតសេចក្ដីសង្ស័យហើយ លះបង់នូវសេចក្ដីវិនាស និង សេចក្ដីចម្រើន មានមគ្គប្រព្រឹត្តគ្រប់គ្រាន់ហើយ មានភពថ្មី អស់ហើយ បុគ្គលនោះ ឈ្មោះថា ជាភិក្ខុ ។ បុគ្គលណា ជា អ្នកប្រងើយកន្តើយក្នុងអារម្មណ៍ទាំងពួង មានស្មារតី បុគ្គល នោះមិនបៀតបៀន ( សត្វណាមួយ ) ក្នុងលោកទាំងពួង ជា អ្នកឆ្លងអន្លង់រួចហើយ ជាអ្នករម្ងាប់បាប មានចិត្តមិនល្អក់ ចំហាយ គឺកិលេស មិនមានដល់បុគ្គលណា បុគ្គលនោះ ឈ្មោះ ថា អ្នកស្ងប់រម្ងាប់ដោយល្អ បុគ្គលណាបានចម្រើននូវឥន្ទ្រិយ ទាំងឡាយ ទាំងខាងក្នុង និងខាងក្រៅក្នុង លោកទាំងអស់ ដឹងច្បាស់នូវលោកនេះ និងលោកដទៃ ទន្ទឹងតែមរណកាល បុគ្គលនោះ មានឥន្ទ្រិយអប់រំហើយ ( យ៉ាងនេះ ) ឈ្មោះថា មានខ្លួនទូន្មានហើយ ។ បុគ្គលណា ពិចារណានូវកប្បៈទាំង អស់ និងសង្សារ ចុតិ និងបដិសន្ធិទាំងពីរ បណ្ឌិតទាំងឡាយ ហៅបុគ្គល ដែលមានធូលី គឺកិលេសទៅប្រាសហើយ អ្នកមិន មានទីទួល គឺកិលេស ស្អាតដោយវិសេស ដល់នូវព្រះនិព្វាន ជាគ្រឿងក្ស័យនៃជាតិនោះថា ជាព្រះពុទ្ធ ។

[ ៥៤ ] គ្រានោះ សភិយបរិព្វាជក មានចិត្តត្រេកអរខ្ពស់ឡើង កើត បីតិសោមនស្ស ត្រេកអររីករាយចំពោះភាសិតព្រះមានព្រះភាគ ហើយសួរ

ប្រស្នានឹងព្រះមានព្រះភាគតទៅ ។

( សភិយបរិព្វាជកសួរថា ) បណ្ឌិតទាំងឡាយហៅបុគ្គលអ្នកបានគុណវិសេសដូចម្តេចថាជាព្រាហ្មណ៍ ថាជាសមណៈ ដោយហេតុដូចម្តេច អ្នកផងតែងហៅថា ជាអ្នកងូតលាង ( កិលេស ) ដោយប្រការដូចម្តេចហៅថានាគ តើដោយប្រការដូចម្តេច បពិត្រព្រះមានព្រះភាគ ព្រះអង្គកាលបើខ្ញុំព្រះអង្គសួរហើយ សូមឆ្លើយឲ្យទាន ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសភិយៈ ) បុគ្គលណា បន្សាត់បង់នូវបាបទាំងពួង ប្រាសចាកមន្ទិល មានចិត្តតាំងនៅល្អ មានចិត្តខ្ជាប់ខ្ជួន កន្លងផុតនូវសង្សារ មានកិច្ចសម្រេចហើយ បុគ្គនោះ ជាអ្នកមិនអាស្រ័យ ( ដោយតណ្ហា និងទិដ្ឋិ ) ជាអ្នកនឹងធឹង បុគ្គលនោះ តថាគតហៅថា ព្រាហ្មណ៍ ។ បុគ្គលណារម្ងាប់ ( កិលេសដោយអរិយមគ្គ ) លះបុណ្យ និងបាប ប្រាសចាកធូលី គឺកិលេស ដឹងច្បាស់នូវលោកនេះ និងលោកខាងមុខ ប្រព្រឹត្តកន្លងនូវជាតិ និងមរណៈ បុគ្គលនោះ ជាអ្នកនឹងធឹងមានសភាពដូច្នោះ តថាគតហៅថា សមណៈ ។ បុគ្គលណាលាងបាបទាំងពួង ទាំងខាងក្នុង និងខាងក្រៅ ក្នុងលោកទាំងមូល មិនដល់នូវកប្បៈ គឺតណ្ហា និងទិដ្ឋិ ក្នុងពួកទេវតា និងមនុស្សដែលគួរដល់កប្បៈ បណ្ឌិត

ទាំងឡាយ ហៅបុគ្គលនោះ ថាអ្នកឆ្លងលាងនូវកិលេស ។

បុគ្គលណា មិនបានធ្វើបាបណាមួយក្នុងលោក លះបង់នូវគ្រឿងប្រកបសត្វទុកទាំងពួងនូវកិលេសជាគ្រឿងចង មិនជាប់ក្នុងគ្រឿងជាប់ទាំងពួង ( មានខន្ធជាដើម ) ជាអ្នករួចស្រឡះ បុគ្គលជាអ្នកនឹងធឹង មានសភាពដូច្នោះនោះ តថាគតហៅថា នាគ ។

[ ៥៥ ] គ្រានោះ សភិយបរិព្វាជក ។បេ។ សួរនូវប្រស្នានឹងព្រះមានព្រះភាគតទៅ

( សភិយបរិព្វាជកសួរថា ) ព្រះពុទ្ធទាំងឡាយ ហៅបុគ្គលណាថាជាអ្នកឈ្នះនូវខេត្ត គឺអាយតនៈ ហៅបុគ្គលអ្នកប្រុតកាត់នូវស្រោម គឺកម្ម ដោយហេតុដូចម្តេច ហៅថាបណ្ឌិត តើដោយហេតុដូចម្តេច ហៅថាមុនី តើដោយហេតុដូចម្តេច បពិត្រព្រះមានព្រះភាគ ព្រះអង្គកាលបើខ្ញុំព្រះអង្គសួរហើយ សូមឆ្លើយឲ្យទាន ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសភិយៈ ) បុគ្គលណាពិចារណានូវខេត្ត គឺអាយតនៈទាំងអស់ គឺខេត្តជាទិព្វ ខេត្តជារបស់មនុស្ស ខេត្តជារបស់ព្រហ្ម រួចស្រឡះចាកចំណង ( គឺអវិជ្ជា ភវតណ្ហាជាដើម ) ជាឫសគល់នៃខេត្ត ( ទាំងអស់ ) បុគ្គលនឹងធឹង មានសភាពដូច្នោះនោះ ឈ្មោះថាអ្នកឈ្នះនូវខេត្ត

គឺអាយតនៈ ព្រោះមានចិត្តទៀងទាត់ ។ បុគ្គលណាពិចារណា ឃើញនូវស្រោម គឺកម្មទាំងអស់ គឺស្រោមជាទិព្វ ជារបស់មនុស្ស និងស្រោមជារបស់ព្រហ្ម រួចស្រឡះចាកចំណង ( គឺ អវិជ្ជា ភវតណ្ហាជាដើម ) ជាឫសគល់នៃស្រោមទាំងអស់ បុគ្គលនឹងធឹង មានសភាពដូច្នោះនោះ ឈ្មោះថាជាអ្នកប្រូតកាត់នូវស្រោម គឺកម្ម ។ បុគ្គលណាមានបញ្ញាស្អាត ពិចារណាឃើញនូវធម្មជាតស្អាត គឺអាយតនៈទាំងពីរ ទាំងខាងក្នុង ខាងក្រៅ កន្លងនូវធម៌ខ្មៅ និងធម៌ស គឺបាប និងបុណ្យ បុគ្គលនឹងធឹង មានសភាពដូច្នោះនោះ ឈ្មោះថាជាបណ្ឌិត ។ បុគ្គលណា ដឹងច្បាស់ធម៌របស់ពួកអសប្បុរស និងសប្បុរសក្នុងលោកទាំងមូល ទាំងខាងក្នុង ទាំងខាងក្រៅ កន្លងបង់នូវគ្រឿងជាប់ជំពាក់ដោយបណ្តាញ បុគ្គលនោះ គួរទេវតា និងមនុស្សបូជា បុគ្គលនោះ ឈ្មោះថា មុនី ។

[ ៥៦ ] គ្រានោះ សភិយបរិព្វាជក ។បេ។ បានសួរប្រស្នានឹងព្រះមានព្រះភាគតទៅ

( សភិយបរិព្វាជកសួរថា ) បណ្ឌិតទាំងឡាយ ហៅបុគ្គលអ្នកបានគុណវិសេសដូចម្តេច ថាជាអ្នកដល់នូវវេទ ហៅថាអ្នកត្រាស់ដឹងតាម តើដោយហេតុដូចម្តេច ហៅថា អ្នកមានព្យាយាម តើដោយប្រការដូចម្តេច ហៅថា អាជានេយ្យ តើ

ព្រោះហេតុដូចម្ដេច បពិត្រព្រះមានព្រះភាគ ព្រះអង្គកាលបើខ្ញុំព្រះអង្គសួរហើយ សូមឆ្លើយឲ្យទាន ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសភិយៈ ) បុគ្គលណាពិចារណាឃើញនូវវេទទាំងអស់ ដែលជាវេទរបស់ពួកសមណព្រាហ្មណ៍ ប្រាសចាកតម្រេកក្នុងវេទនាទាំងពួង កន្លងបង់នូវវេទទាំងអស់ បុគ្គលនោះ ឈ្មោះថា អ្នកដល់នូវវេទ ។

បុគ្គលណា ពិចារណារឿយៗ នូវបបញ្ចធម៌ និងនាមរូប ជាឫសគល់នៃរោគ ទាំងខាងក្នុង ទាំងខាងក្រៅ រួចស្រឡះចាកចំណង គឺអវិជ្ជា កវតណ្ហាជាដើម ជាឫសគល់នៃរោគទាំងអស់ បុគ្គលអ្នកនឹងធឹង មានសភាពដូច្នោះនោះ ហៅថា អ្នកត្រាស់ដឹងតាម ។

បុគ្គលណា វៀរចាកបាបទាំងពួង កន្លងបង់និរយទុក្ខ បុគ្គលនោះ ឈ្មោះថា អ្នកមានព្យាយាម បុគ្គលអ្នកមានព្យាយាមមាំជាធីរជន ( អាចកម្ចាត់បង់កិលេសជាដើម ) ជាអ្នកនឹងធឹងមានសភាពដូច្នោះនោះ ហៅថា អ្នកមានព្យាយាម ។

បុគ្គលណាប្រូតកាត់នូវចំណង ( គឺសំយោជនៈ ) និងឫសគល់នៃគ្រឿងជាប់ជំពាក់ទាំងខាងក្នុង ទាំងខាងក្រៅ ជាអ្នករួចស្រឡះចាកឫសគល់នៃគ្រឿងជាប់ជំពាក់ដោយចំណង ( គឺសំយោជនៈ ) ទាំងអស់ បុគ្គលអ្នកនឹងធឹង មានសភាពដូច្នោះ

នោះ ហៅថា អាជានេយ្យបុរស ។

[ ៥៧ ] គ្រានោះ សភិយបរិព្វាជក ។បេ។ បានសួរប្រស្នានឹងព្រះមានព្រះភាគតទៅ

( សភិយបរិព្វាជកសួរថា ) បណ្ឌិតទាំងឡាយ ហៅបុគ្គលអ្នកបាននូវគុណវិសេសដូចម្តេច ថាជាសោត្ថិយបុគ្គល ហៅថាអរិយៈដោយហេតុដូចម្តេច ហៅថាអ្នកមានចរណៈដោយប្រការដូចម្តេច ហៅថាបរិព្វាជក ព្រោះហេតុដូចម្តេច បពិត្រព្រះមានព្រះភាគ ព្រះអង្គកាលបើខ្ញុំព្រះអង្គសួរហើយ សូមឆ្លើយឲ្យទាន ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសភិយៈ ) បុគ្គលណាបានស្តាប់ហើយ ដឹងច្បាស់នូវធម៌ទាំងពួង នូវអំពើមានទោសនិងមិនមានទោសណាមួយក្នុងលោក បណ្ឌិតទាំងឡាយ ហៅបុគ្គលអ្នកគ្របសង្កត់ ( ធម៌ជាទីតាំងនៃកិលេស ) មិនមានសេចក្តីងឿងឆ្ងល់ រួចស្រឡះ ( ចាកចំណង គឺកិលេស ) មិនមានសេចក្តីបង្អៀតបង្អល់ ក្នុងធម៌ទាំងពួងនោះថា ជាសោត្ថិយ-បុគ្គល ។

បុគ្គលណា កាត់បង់នូវអាល័យ និងអាសវៈ ជាអ្នកប្រាជ្ញ បុគ្គលនោះ មិនចូលទៅកាន់ដំណេកក្នុងគភ៌ បុគ្គលណាបន្ទោបង់នូវសញ្ញា ៣ ប្រការ និងភក់ ( គឺកាម ) មិនដល់នូវកប្បៈ

គឺតណ្ហា និងទិដ្ឋិ បណ្ឌិតទាំងឡាយហៅបុគ្គលនោះថា អរិយៈ ។
បុគ្គលណា ក្នុងសាសនានេះ បានដល់នូវអរហត្តដែលគេគប្បីដល់ ព្រោះចរណធម៌ទាំងឡាយ បុគ្គលនោះ ជាអ្នកឈ្លាសវៃ បានដឹងធម៌គ្រប់កាលទាំងពួង មិនជាប់នៅក្នុងធម៌ទាំងពួង មានចិត្តរួចស្រឡះហើយ បុគ្គលណា មិនមានសេចក្តីថ្នាំងថ្នាក់ចិត្ត បុគ្គលនោះ ឈ្មោះថា មានចរណធម៌ ។
បុគ្គលណា កម្ចាត់បង់នូវកម្មដែលឲ្យផលជាទុក្ខ ទាំងអតីត ទាំងអនាគត ទាំងបច្ចុប្បន្ន ទាំងកម្មជាចន្លោះកណ្តាលនៃកាល ជាអ្នកប្រព្រឹត្តដោយប្រាជ្ញា មួយទៀត គេបាន ( លះបង់ ) មាយា មានះ លោភៈ កោធៈ និងធ្វើនាមរូបឲ្យមានទីបំផុត បណ្ឌិតទាំងឡាយ ហៅបុគ្គលអ្នកដល់នូវគុណសម្បត្តិ ដែលគេគប្បីដល់នោះថាជាបរិព្វាជក ។

[ ៥៨ ] គ្រានោះ សភិយបរិព្វាជកត្រេកអររីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ជាអ្នកមានចិត្តត្រេកអរ មានចិត្តអណ្តែតឡើង រីករាយ កើតបីតិ និងសោមនស្ស ហើយក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគ សរសើរព្រះមានព្រះភាគចំពោះព្រះភក្ត្រដោយគាថាទាំងឡាយ ដ៏សមគួរថា

បពិត្រព្រះអង្គជាបុគ្គលមានប្រាជ្ញាស្មើដោយផែនដី ទិដ្ឋិទាំង-
ឡាយ ៣ ណា និងទិដ្ឋិទាំងឡាយ ៦០ ណា ដែលអាស្រ័យ

នៅដោយវាទសាស្ត្ររបស់សមណៈ ( ជាអន្យតិ្ថយ ) អាស្រ័យនៅនឹងពាក្យ ( ថាស្ត្រី-បុរស ) និងសញ្ញា ( ខុសរបស់មនុស្សពាល ) ជាកំពង់ ជាទីចុះរបស់សត្វ ព្រះមានព្រះភាគបានកម្ចាត់ចោល ( នូវទិដ្ឋិទាំងនោះ ) បានកន្លងផុតនូវងងឹត គឺឱឃៈ ។

ព្រះអង្គជាអ្នកដល់នូវទីបំផុត ជាអ្នកដល់នូវត្រើយនៃទុក្ខ គឺព្រះនិព្វាន ព្រះអង្គជាអរហន្ត ( សម្មាសម្ពុទ្ធ ) ខ្ញុំព្រះអង្គសម្គាល់ព្រះអង្គថា ជាព្រះខីណាស្រព ព្រះអង្គមានសេចក្ដីរុងរឿង មានយោបល់ មានប្រាជ្ញាច្រើន ធ្វើនូវទីបំផុតនៃទុក្ខបានចម្លងខ្ញុំព្រះអង្គ ( ចាកសេចក្ដីសង្ស័យ ) ។

ព្រះអង្គជ្រាបនូវសេចក្ដីសង្ស័យណា ដែលខ្ញុំព្រះអង្គសង្ស័យហើយ បានចម្លងខ្ញុំព្រះអង្គឲ្យរួចចាកសង្ស័យ ( នោះ ) ( បពិត្រព្រះអង្គជាអ្នកប្រាជ្ញ ) ខ្ញុំសូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គជាអ្នកដល់នូវគុណសម្បត្តិ ដែលគួរដល់ដោយគន្លងនៃអ្នកប្រាជ្ញទាំងឡាយ ព្រះអង្គជាអាទិច្ចពង្ស មិនរឹងត្អឹង ជាអ្នកស្លូតបូត ។ សេចក្ដីសង្ស័យណា របស់ខ្ញុំមានមកក្នុងកាលមុនព្រះអង្គជាអ្នកមានចក្ខុ បានដោះស្រាយហើយនូវសេចក្ដីសង្ស័យរបស់ខ្ញុំព្រះអង្គនោះ ព្រះអង្គជាអ្នកប្រាជ្ញត្រាស់ដឹងហើយដោយពិត ព្រះអង្គមិនមាននីវរណៈទាំងឡាយឡើយ ។

សេចក្ដីចង្អៀតចង្អល់ទាំងអស់ ដែលព្រះអង្គកម្ចាត់បង់ហើយ

បានធ្វើឲ្យជ្រះស្រឡះហើយ ព្រះអង្គជាបុគ្គលត្រជាក់ ដល់នូវការទូន្មានឥន្ទ្រិយ មានប្រាជ្ញា មានព្យាយាម ដោយទៀងទាត់ ។

កាលព្រះអង្គ ជាមហាវីរបុរសដ៏ប្រសើរក្រៃលែងនោះ កំពុងសម្តែងពួកទេវតាទាំងពួង រមែងអនុមោទនា ទាំងទេវតាពីរពួក គឺនារទៈ និងបព្វតៈ ក៏អនុមោទនា ។

បពិត្រព្រះអង្គ ជាបុរសអាជានេយ្យ ខ្ញុំព្រះអង្គសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គ ជាបុរសឧត្តម ខ្ញុំព្រះអង្គសូមនមស្ការព្រះអង្គ ព្រះអង្គមិនមានបុគ្គលប្រៀបផ្ទឹម ក្នុងលោក ព្រមទាំងទេវលោក ។

ព្រះអង្គជាអ្នកត្រាស់ដឹង ព្រះអង្គជាសាស្តាចារ្យ ព្រះអង្គជាអ្នកប្រាជ្ញ គ្របសង្កត់នូវមារ ( ទាំងបួន ) ព្រះអង្គកាត់បង់នូវអនុសយក្កិលេស ឆ្លងបានហើយ ទើបចម្លងពពួកសត្វទាំងនេះ ។ ព្រះអង្គបានកន្លងឧបធិហើយ ព្រះអង្គបានទម្លាយអាសវៈហើយ ព្រះអង្គជាបុគ្គលដូចសីហៈ មិនមានឧបាទាន បានលះភ័យ និងសេចក្តីស្ញប់ស្ញែងហើយ ។

ផ្កាឈូកសដ៏ល្អ មិនជាប់ក្នុងទឹកយ៉ាងណាមិញ ព្រះអង្គមិនជាប់ក្នុងអំពើទាំងពីរ គឺបុណ្យ និងបាបក៏យ៉ាងនោះដែរ បពិត្រព្រះអង្គជាវីរបុរស សូមព្រះអង្គសណ្តូកព្រះបាទ សភិយបរិញ្វាជកថ្វាយបង្គំ ( ព្រះបាទ ) ព្រះ

សាស្តា ។

[ ៥៩ ] គ្រានោះ សភិយបរិព្វាជក ឱនសិរ្សៈទៀបព្រះបាទទាំងគូរបស់ព្រះមានព្រះភាគហើយ សរសើរព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះមានព្រះភាគ សម្ដែងហើយដោយអនេកបរិយាយយ៉ាងនេះ ( ភ្លឺច្បាស់ណាស់ ) ដូចជាគេផ្ងាររបស់ដែលផ្កាប់ចុះ ពុំនោះដូចជាគេបើកបង្ហាញ របស់ដែលកំបាំង ពុំនោះសោត ដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ឬក៏ដូចជាគេទ្រោលប្រទីបប្រេង បំភ្លឺក្នុងទីងងឹត ឲ្យមនុស្សមានចក្ខុ មើលឃើញនូវរូបទាំងឡាយបាន ខ្ញុំព្រះអង្គនុ៎ះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគួរបានបព្វជ្ជា គួរបានឧបសម្បទា ក្នុងសម្នាក់ព្រះមានព្រះភាគ ។ ម្នាលសភិយៈ អ្នកណាធ្លាប់ជាអន្យតិរ្ថិយ ប្រាថ្នាបព្វជ្ជា ប្រាថ្នាឧបសម្បទាក្នុងធម្មវិន័យនេះ អ្នកនោះនៅបរិវាសអស់ ៤ ខែសិន លុះអំណឹះ ៤ ខែហើយ ភិក្ខុទាំងឡាយ អ្នកមានចិត្តប្រោសប្រាណ ទើបញុំាងបុគ្គលអ្នកនៅបរិវាសហើយ ឲ្យបព្វជ្ជា ឲ្យឧបសម្បទា ដើម្បីឲ្យបានជាភិក្ខុ តែថា សេចក្ដីផ្សេងនៃបុគ្គលក្នុងកិច្ចបរិវាសនោះ តថាគតដឹងច្បាស់ហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន បើពួកជនដែលធ្លាប់ជាអន្យតិរ្ថិយ ប្រាថ្នាបព្វជ្ជា ប្រាថ្នាឧបសម្បទាក្នុងធម្មវិន័យនេះ នៅបរិវាសអស់ ៤ ខែសិន លុះអំណឹះ ៤ ខែហើយ ភិក្ខុទាំងឡាយអ្នកមានចិត្តប្រោសប្រាណ ញុំាងពួកកុលបុត្ត អ្នកនៅបរិវាសរួចហើយ

ឲ្យបព្វជ្ជា ឲ្យឧបសម្បទា ដើម្បីឲ្យបានជាភិក្ខុ ។ ខ្ញុំព្រះអង្គសូមនៅបរិវាស អស់ ៤ ឆ្នាំ លុះកន្លង ៤ ឆ្នាំហើយ សូមឲ្យភិក្ខុទាំងឡាយ អ្នកមានចិត្តប្រោស ប្រាណ ញុំាងខ្ញុំព្រះអង្គ អ្នកនៅបរិវាសរួចហើយ ឲ្យបព្វជ្ជា ឲ្យឧបសម្បទា ដើម្បីឲ្យបានជាភិក្ខុ ។ សភិយបរិព្វាជក ក៏បានបព្វជ្ជា បានឧបសម្បទាក្នុង សម្នាក់ព្រះមានព្រះភាគ ។ ព្រះសភិយៈដ៏មានអាយុ បានឧបសម្បទាមិនយូរ ប៉ុន្មាន ក៏ចៀសចេញទៅតែម្នាក់ឯង មិនធ្វេសប្រហែស មានព្យាយាមដុតកម្តៅ កិលេស មានចិត្តស្ងប់ទៅ ( កាន់ព្រះនិព្វាន ) កុលបុត្តទាំងឡាយ ចេញចាក ផ្ទះ ចូលកាន់ផ្នួសដោយត្រឹមត្រូវ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិន យូរប៉ុន្មាន ( លោក ) ក៏បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវអនុត្តរធម៌នោះ មានព្រហ្មចរិយធម៌ជាទីបំផុត ដោយប្រាជ្ញាដ៏ប្រសើរ របស់ខ្លួនឯងក្នុងបច្ចុប្បន្ន បានដឹងថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញប្រព្រឹត្តចប់ហើយ កិច្ច ដែលគួរធ្វើបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡស- កិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ សភិយៈដ៏មាន អាយុ បានជាព្រះអរហន្ត ១ អង្គដែរ ។

សភិយសូត្រទី ៦ ចប់

# អដ្ឋកថា

## សភិយសូត្រ

[ ៥១ ] ក្នុងសភិយសូត្រទី ៦ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះ ។

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា អត្ថុប្បត្តិហេតុ ពោលហើយក្នុងនិទាននៃសូត្រនោះឯង ម្យ៉ាងទៀត សូត្រនេះ សូម្បីនៅក្នុងលំដាប់ពណ៌នាសេចក្ដី ក៏គប្បីជ្រាបថា ដូចគ្នានឹងសូត្រមុន មានន័យដូចពោលហើយក្នុងសូត្រមុននោះឯង ។ តែបទណាមិនទាន់បានពោល ខ្ញុំនឹងចៀសវាងបទដែលមានសេចក្ដីជាក់ច្បាស់ ពណ៌នាបទដែលមិនទាន់បានពោល ។

បទថា **វេឡុវនំ** ក្នុងបទថា **វេឡុវនេ កលន្ទកនិវាបេ** ជាឈ្មោះនៃឧទ្យាននោះ ។ បានឮថា ឧទ្យាននោះ ព័ទ្ធដោយដើមឫស្សី មានពណ៌ខៀវគួរត្រេកអរ ប្រកបដោយខ្លោងទ្វារ ប៉ម និងកំពែង ១៨ ហត្ថ ដោយហេតុនោះទើបហៅថា **វេឡុវន** ។ ត្រង់ឧទ្យាននោះ ជនទាំងឡាយបានឲ្យចំណីដល់កង្ហែន ដោយហេតុនោះ ទើបហៅថា **កលន្ទកនិវាប** ។ កង្ហែនទាំងឡាយលោកហៅថា **កលន្ទក** ។

មានរឿងតំណាលថា កាលមុន ព្រះរាជាមួយអង្គយាងមកប្រពាតឧទ្យានក្នុងទីនោះ ទ្រង់ស្រវឹងដោយឫទ្ធិសុរា ផ្ទំលក់ក្នុងពេលថ្ងៃ ។ បរិវាររបស់ព្រះអង្គដឹងថា ព្រះរាជាផ្ទំលក់ ក៏គេចទៅបេះផ្កា និងផ្លែឈើក្នុងទីផ្សេងៗ លំដាប់នោះ ពស់វែកបានក្លិនសុរា លូនចេញអំពីព្រៃឈើមួយកន្លែង ទៅរកព្រះរាជា ។ រុក្ខទេវតាឃើញដូច្នោះ ក៏គិតថា អញនឹងឲ្យជីវិតដល់ព្រះរាជា

ទើបកាឡាខ្លួនជាកង្អែន ធ្វើសំឡេងត្រង់ព្រះកាណ៌របស់ព្រះរាជា ។ ព្រះរាជាក៏ភ្ញាក់ពីបន្ទំ ពស់វែកក៏លូនត្រឡប់ ព្រះរាជាទតឃើញសត្វកង្អែននោះ ទ្រង់គិតថា កង្អែននេះឲ្យជីវិតអញ ទើបឲ្យរៀបចំចំណី ដើម្បីកង្អែនត្រង់ព្រះរាជឧទ្យាននោះ ហើយទ្រង់ប្រកាសព្រះរាជឧទ្យាននោះ ជាទីឲ្យអភ័យដល់សត្វកង្អែន ។ ព្រោះដូច្នោះ តាំងអំពីនោះមក ព្រះរាជឧទ្យាននោះក៏បានឈ្មោះថា **កលន្ទកនិវាបស្ថាន** គឺទីឲ្យចំណីដល់សត្វកង្អែន ។

បទថា **សភិយ** ក្នុងបទថា **សភិយស្ស បរិព្វាជកស្ស** ជាឈ្មោះរបស់បរិព្វាជកនោះ ។ បទថា **បរិព្វាជកោ** លោកពោលសំដៅដល់អ្នកបួសខាងក្រៅសាសនា ។ បទថា **ទោរាណសាលោហិតាយ ទេវតាយ** គឺមិនមែនមាតា មិនមែនបិតា តែដូចជាមាតា និងបិតារបស់សភិយបរិព្វាជកនោះទេវបុត្តនោះ លោកពោលថា ជាទេវតាដែលជាសាលោហិតចាស់ ព្រោះជាអ្នកមានអជ្ឈាស្រ័យអនុគ្រោះ ។

បានឮមកថា កាលព្រះមានព្រះភាគ ព្រះនាមកស្សបៈបរិនិព្វានហើយ ពុទ្ធបរិស័ទបានប្រតិស្ឋានសុវណ្ណចេតិយ គឺសាងឡើងហើយ ។ កុលបុត្ត ៣ រូប បួសក្នុងសម្នាក់របស់សាវ័កដែលនៅព្រមចំពោះមុខ ( ទាន់ព្រះសម្មាសម្ពុទ្ធ ) រៀនកម្មដ្ឋានដែលសមគួរដល់ចរិតទៅកាន់ជនបទ ជាយដែន បំពេញសមណធម៌ក្នុងដងព្រៃ ចូលក្រុងម្ដងម្កាល ដើម្បីថ្វាយបង្គំព្រះចេតិយ និងដើម្បីស្ដាប់ធម៌ ។ គ្រាតមក ភិក្ខុទាំងនោះ មិនគាប់ចិត្តចេញអំពីព្រៃ ជាអ្នកមិនប្រមាទ នៅក្នុងព្រៃនោះឯង ។ សូម្បីនៅយ៉ាងនេះ ក៏មិនអាចសម្រេចគុណ

វិសេសណាមួយបាន លំដាប់នោះ ភិក្ខុទាំងនោះគិតថា អញចេញទៅបិណ្ឌ-បាតហើយបិណ្ឌបាតទៀត ឈ្មោះថា ជាអ្នកជាប់ជំពាក់ក្នុងជីវិត បុគ្គលជាប់ជំពាក់ក្នុងជីវិត មិនអាចសម្រេចលោកុត្តរធម៌បាន ការស្លាប់នៅជាបុថុជ្ជនជាទុក្ខ ណ្ហើយចុះ អញដាក់ជណ្តើរឡើងកាន់ភ្នំ មិនអាឡោះអាល័យក្នុងរាងកាយ និងជីវិត បំពេញសមណធម៌ ។ ភិក្ខុទាំងនោះ បានធ្វើយ៉ាងនោះ ។

កាលនោះ បណ្តាភិក្ខុទាំងនោះ មហាថេរៈដល់ព្រមដោយឧបនិស្ស័យបានសម្រេចអរហត្ត មួយអន្លើដោយអភិញ្ញា ៦ ក្នុងថ្ងៃនោះឯង ។ ព្រះមហាថេរៈនោះ ក៏ទៅកាន់ហិមវន្តប្បទេសដោយឫទ្ធិ លុបលាងព្រះភក្ត្រត្រង់អនោតត្តស្រះ ត្រាច់ទៅបិណ្ឌបាតក្នុងឧត្តរកុរុទ្វីប ឆាន់អាហារស្រេចហើយ ក៏ទៅកាន់ទីដទៃ បានកត្តពេញបាត្រហើយ ដងទឹកត្រង់អនោតត្តស្រះ និងកាន់យកឈើស្ទន់ឈ្មោះនាគលតា មករកភិក្ខុទាំងនោះ ពោលថា អាវុសោទាំងឡាយ ពួកលោក ចូរមើលអានុភាពជំ បិណ្ឌបាតនេះ នាំមកអំពីឧត្តរ-កុរុទ្វីប ទឹក និងឈើស្ទន់ នាំមកអំពីហិមវន្តប្បទេស អ្នកទាំងឡាយ ចូរឆាន់កត្តាហារនេះ បំពេញសមណធម៌ចុះ ខ្ញុំនឹងបម្រើលោកម្ចាស់ទាំងឡាយយ៉ាងនេះរហូតទៅ ។ ភិក្ខុទាំងនោះបានស្តាប់ហើយ ក៏ពោលថា បពិត្រលោកម្ចាស់ៗ ធ្វើកិច្ចស្រេចហើយ ពួកខ្ញុំ សូម្បីត្រឹមតែសន្ទនាជាមួយលោកម្ចាស់ក៏ខាតពេល ឥឡូវនេះ សូមលោកម្ចាស់កុំមករកពួកខ្ញុំទៀតឡើយ ។ ព្រះមហាថេរៈមិនអាចឲ្យភិក្ខុទាំងនោះយល់ព្រមបាន ដោយវិធីណាមួយ ក៏ចៀសចេញទៅ ។

តែក្នុងបណ្តាភិក្ខុទាំងនោះ ភិក្ខុមួយរូប កន្លងទៅបាន ២-៣ ថ្ងៃ ក៏បាន ជាព្រះអនាគាមី បានអភិញ្ញា ៥ ភិក្ខុនោះក៏បានធ្វើយ៉ាងនោះដូចគ្នា កាលត្រូវ ភិក្ខុមួយរូបទៀតឃាត់ ក៏ត្រឡប់ទៅយ៉ាងនោះដូចគ្នា ។ ភិក្ខុនោះបដិសេធ ការធ្វើនោះហើយ ព្យាយាមដល់ថ្ងៃទី ៧ បន្ទាប់ពីថ្ងៃឡើងទៅកាន់ភ្នំ ក៏មិន បានសម្រេចគុណវិសេសណាមួយ កាលមរណកាលហើយ ក៏ទៅកើត ឯទេវលោក ។ ឯព្រះថេរៈដែលជាព្រះខីណាស្រព ក៏បរិនិព្វានក្នុងថ្ងៃនោះឯង ។ ព្រះអនាគាមី បានទៅកើតក្នុងសុទ្ធាវាស ។ ទេវបុត្តសោយទិព្វសម្បត្តិក្នុង កាមាវចរសួគ៌ ៦ ជាន់ អន្ទោលទៅមក កាលដល់សាសនារបស់ព្រះមាន ព្រះភាគនៃយើង បានចុតិអំពីទេវលោក បដិសន្ធិក្នុងគភ៌របស់បរិព្វាជិកាម្នាក់ បានឮថា បរិព្វាជិកានោះ ជារាជធីតារបស់ក្សត្រមួយអង្គ ។ ព្រះជនក ព្រះជននីបានប្រគល់រាជធីតានោះដល់បរិព្វាជកម្នាក់ ដោយតាំងព្រះហឫទ័យ ថា ធីតារបស់អញ ចូរបេះនូវលទ្ធិដទៃចុះ បរិព្វាជកដែលជាសិស្សម្នាក់របស់ បរិព្វាជកនោះ ប្រព្រឹត្តមេថុនធម្មជាមួយព្រះរាជធីតានោះ ព្រះនាងក៏មានព្រះ គភ៌ បរិព្វាជកទាំងឡាយឃើញព្រះរាជធីតានោះមានគភ៌ ក៏នាំគ្នាបណ្តេញ ចេញទៅ ។ ព្រះនាងបានទៅកាន់ទីមួយកន្លែង ប្រសូតព្រះរាជបុត្រត្រង់ សាលាប្រជុំក្នុងរវាងផ្លូវ ដោយហេតុនោះ ទើបកុមារនោះ ឈ្មោះថា **សភិយ** ប្រែថា អ្នកកើតត្រង់សាលាប្រជុំ ។ សភិយៈនោះចម្រើនដឹងក្តីហើយ ក៏បួស ជាបរិព្វាជក រៀនសាស្ត្រផ្សេងៗ ជាអ្នកមានវាទៈច្រើន ត្រាច់ទៅពេញជម្ពូទ្វីប ដើម្បីលើកវាទៈ មិនឃើញវាគ្មិនប្រហែលនឹងខ្លួន ទើបឲ្យធ្វើអាស្រមត្រង់ទ្វារ

នគរ បង្រៀនសិប្បៈដល់ខត្តិយកុមារជាដើម អាស្រ័យនៅទីនោះឯង ។

កាលនោះ ព្រះមានព្រះភាគ ទ្រង់ផ្សាយព្រះធម្មចក្កដ៏ប្រសើរ យាងដល់ក្រុងរាជគ្រឹះដោយលំដាប់ គង់នៅក្នុងវេឡុវនមហាវិហារកលន្ទកនិវាបស្ថាន តែសភិយបរិព្វាជកមិនដឹងថា ព្រះពុទ្ធបានកើតឡើងហើយ លំដាប់នោះ សុទ្ធាវាសព្រហ្ម ចេញអំពីសមាបត្តិ ប្រមើលមើលថា អញបានសម្រេចគុណវិសេសនេះ ដោយអានុភាពរបស់នរណា ពិចារណាដល់សម្លាញ់រួមបំពេញសមណធម៌ទាំងនោះ ក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមកស្សបៈ បណ្តាសម្លាញ់ទាំងនោះ មួយរូបបរិនិព្វានហើយ ពិចារណាបន្តថា ឥឡូវនេះមួយរូបទៀតនៅឯណា កាលដឹងហើយថា ភិក្ខុរូបនោះ ចុតិចាកទេវលោកហើយ ទៅកើតក្នុងជម្ពូទ្វីប នឹងមិនដឹងថា ព្រះពុទ្ធកើតហើយ ទើបគិតថា ណ្ហើយចុះ អញនឹងបបួលសម្លាញ់អញ ដើម្បីចូលគាល់ព្រះពុទ្ធ ទើបចងប្រស្នា ២០ កណ្តាលរាត្រី បានមកកាន់អាស្រមសភិយបរិព្វាជកនោះ ឈរលើអាកាស ពោលថា **សភិយ** ដូច្នេះ សភិយៈកំពុងដេកលក់ បានឮនូវសំឡេងហៅ ៣ ដង ទើបចេញទៅ ឃើញពន្លឺ ទើបឈរប្រណម្យ ។ លំដាប់នោះ ព្រហ្មបានពោលនឹងសភិយបរិព្វាជកនោះថា នែសភិយៈ យើងនាំបញ្ហា ២០ មក ដើម្បីអ្នក ចូរអ្នករៀនបញ្ហាទាំងនេះ សមណៈ ឬព្រាហ្មណ៍ណាត្រូវអ្នកសួរបញ្ហានេះហើយ ព្យាករបាន ចូរអ្នកប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់បុគ្គលនោះចុះ ។

បទថា **បុរាណសាលោហិតាយ ទេវតាយ បញ្ហា ឧទ្ទិដ្ឋា ហោន្តិ**

នេះ លោកពោលសំដៅដល់ទេវបុត្តនេះ ។

បទថា **ឧទ្ទិដ្ឋា** លោកពោលត្រឹមតែមាតិកាប៉ុណ្ណោះ មិនបានពោលដោយការចែក ។

កាលព្រហ្មពោលយ៉ាងនេះហើយ សភិយៈបានរៀនបញ្ហាទាំងនោះតាមលំដាប់បទ ដោយការពោលត្រឹមតែម្តងប៉ុណ្ណោះ ។ កាលព្រហ្មដឹង ក៏មិនប្រាប់ថា ព្រះពុទ្ធកើតឡើងហើយដល់សភិយៈនោះឡើយ ។ ព្រហ្មពោលយ៉ាងនេះថា ម្នាលសភិយៈ សមណៈ ឬព្រាហ្មណ៍ណា ដែលអ្នកសួរប្រស្នាទាំងនេះហើយឆ្លើយរួច អ្នកត្រូវប្រព្រឹត្តព្រហ្មចារ្យក្នុងសម្នាក់នៃសមណៈ ឬព្រាហ្មណ៍នោះចុះ ។ ដោយបំណងនេះថា សភិយបរិព្វាជក កាលស្វែងរកប្រយោជន៍នឹងស្គាល់ព្រះសាស្តាដោយខ្លួនឯង និងស្គាល់ថា សមណព្រាហ្មណ៍ខាងក្រៅសាសនានេះទទេ ។ តែកេចិអាចារ្យពណ៌នារឿងរ៉ាវរបស់ព្រះសភិយត្ថេរក្នុងថេរគាថា ចតុក្កនិបាតថា មាតារបស់សភិយៈនោះ គិតដល់កិច្ចបដិបត្តិខុសរបស់ខ្លួន ទើបរង្កៀសក្នុងកិច្ចបដិបត្តិខុសនោះ ញុំាងឈានឲ្យកើតហើយ ទៅកើតក្នុងព្រហ្មលោក មាតាជាទេវតាជាន់ព្រហ្មនោះ បានប្រាប់បញ្ហាទាំងនេះដូច្នេះ ។

បទថា **យេ តេ** ជាបទលើកឡើងសម្តែងដល់បុគ្គលដែលគួរពោលដល់ក្នុងបច្ចុប្បន្ន ។

បទថា **សមណព្រាហ្មណា** បានដល់ ជាសមណៈ និងព្រាហ្មណ៍ដោយការចូលទៅបព្វជ្ជា និងដោយលោកសម្មតិ ។ បទថា **សង្ឃិនោ** គឺ

មានពួក ។ បទថា **គណិនោ** គឺអ្នកប្តេជ្ញាយ៉ាងនេះថា យើងជាសាស្តាជាសព្វញ្ញូ ។ បទថា **គណាចរិយា** គឺជាអាចារ្យរបស់គណៈបព្វជិត និងគ្រហស្ថ ដោយការរៀន និងការសាកសួរជាដើម ។ បទថា **ញាតា** បានដល់ មានឈ្មោះបោះសំឡេង គឺស្គាល់ច្រើន លោកអធិប្បាយថា ជាបុគ្គលប្រាកដ ។ បទថា **យសស្សិនោ** គឺសម្បូរដោយលាភ និងបរិវារ ។ បទថា **តិត្ថករា** គឺជាម្ចាស់ទិដ្ឋិ ដែលដល់នូវទិដ្ឋានុគតិ ។ បទថា **សាធុសម្មតា ពហុជនស្ស** គឺជនចំណែកច្រើនលើកតម្កើងថា លោកទាំងនេះ ជាមនុស្សល្អ គឺជាសប្បុរស ។ បទថា **សេយ្យថីទំ** ជានិបាត ចុះក្នុងសេចក្តីនេះថា បើមានពាក្យសួរថា លោកទាំងនោះ គឺអ្នកណា ។

ពាក្យថា **បូរណោ** ជាឈ្មោះ ។ ពាក្យថា **កស្សបោ** ជាគោត្រ ។ បានឮថា បូរណកស្សបៈនោះ ជាទាសៈដោយកំណើត កើតជាទាសៈទី ( គម្រប់ ) ១០០ ដោយហេតុនោះ ជនទាំងឡាយដាក់ឈ្មោះថា បូរណៈ ។ តែរត់ទៅបួសក្នុងសម្នាក់អចេលក៍ ប្រាប់គោត្តថា យើងជាកស្សបគោត្ត និងបានប្រកាសភាពជាសព្វញ្ញូ ។ បទថា **មក្ខលិ** គឺជាឈ្មោះ ។ ហៅថា **គោសាលោ** ព្រោះកើតក្នុងរោងគោ ។ បានឮថា មក្ខលិគោសាលនោះដោយជាតិជាទាសៈដូចគ្នា គេចទៅបួសហើយបានប្រកាសភាពជាសព្វញ្ញូ ។

បទថា **អជិតោ** គឺជាឈ្មោះ ព្រោះភាពជាអ្នកប្រាថ្នាតិច ទើបស្លៀកដណ្តប់សំពត់កេសកម្ពលដែលធ្វើអំពីសក់មនុស្ស ព្រោះហេតុនោះ ទើបគេហៅថា **កេសកម្ពលោ**។ អជិតៈនោះ ក៏ប្រកាសភាពជាសព្វញ្ញូ ។

បទថា **បកុធោ** គឺជាឈ្មោះ ។ បទថា **កច្ចាយនោ** ជាគោត្ត ។ ដោយភាពជាអ្នកប្រាថ្នាតិច និងដោយសម្គាល់ថា ក្នុងទឹកមានសត្វមានជីវិត ទើបមិនផ្ទូតទឹក មិនលុបមុខជាដើម បកុធៈនោះ ក៏ប្រកាសភាពជាសព្វញ្ញូ ។

បទថា **សញ្ជយោ** គឺជាឈ្មោះ ។ បិតារបស់គេ ឈ្មោះវេឡដ្ឋៈ ព្រោះហេតុនោះ ទើបហៅថា វេឡដ្ឋបុត្ត សញ្ជ័យនោះ ក៏ប្រកាសភាពជាសព្វញ្ញូ ។

បទថា **និគណ្ឋោ** បានដល់ ហៅឈ្មោះកាលបួស ។ បទថា **នាដ-បុត្តោ** ជាឈ្មោះរបស់បិតា បានឮថា ឪពុករបស់គេ ឈ្មោះថា **នាដ** ។ ឈ្មោះថា នាដបុត្ត ព្រោះជាបុត្តរបស់នាដៈ ។ នាដបុត្តនោះក៏ប្រកាសភាពជាសព្វញ្ញូ ទាំងអស់នោះ មានសិស្សជាបរិវារម្នាក់ ៥០០ ។ បទថា **តេ** បានដល់ សាស្តាទាំង ៦ ។ បទថា **តេ បញ្ហេ** បានដល់ បញ្ហា ២០ នោះ ។ បទថា **នេវ សម្បាយន្តិ** គឺឆ្លើយមិនបាន ។ បទថា **កោបំ** គឺភាពដែលចិត្ត និងចេតសិកល្អក់កករ គឺខឹងក្រោធ ។

បទថា **ទោសំ** គឺភាពជាអ្នកមានចិត្តប្រទូស្ត ។ សូម្បីទាំង ២ បទនោះ ក៏ជាឈ្មោះនៃសេចក្តីក្រោធ ទាំងខ្សោយ និងខ្លាំងក្លា ។ បទថា **អប្បច្ចយំ** បានដល់ ការមិនពេញចិត្ត លោកពោលថា បានដល់ ទោមនស្ស ។ បទថា **ចាតុករោន្តិ** គឺសម្តែងកាយវិការ និងវចីវិការឲ្យប្រាកដ ។ បទថា **ហីនាយ** គឺភាពជាគ្រហស្ថ ។ ពិតហើយ គ្រហស្ថប្រៀបជាមួយបព្វជ្ជាហើយ ក៏ពោលបានថា អាក្រក់ ព្រោះថោកថយចាកគុណ មានសីលជាដើម ឬព្រោះសេព

កាមសុខដែលថោកទាប ទើបបព្វជ្ជាជារបស់ប្រសើរ ។ បទថា **អាវត្តិត្វា** គឺថយក្រោយ ។ បទថា **កាមេ បរិភុញ្ជេយ្យំ** បានដល់ សេពកាម ។ បានឮថា សភិយៈនោះ បានឃើញពួកអ្នកបួសប្តេជ្ញាភាពជាសព្វញ្ញូ ក៏ទទេទាំងអស់ ។ កាលនោះឯង សភិយបរិព្វាជកដែលមកដោយបរិវិតក្កដែលកើតឡើងហើយ ពិចារណារឿយៗ ត្រិះរិះថា សមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនណា ... អញមិនត្រូវមើលងាយ ... ទោះបីព្រះអង្គជាសមណៈក្មេងក៏ពិត ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ជិណ្ណា** ជាដើម មានន័យដូចពោលហើយនោះឯង ។ បទថា **ថេរា** បានដល់ ជាអ្នកដល់នូវការមាំទាំក្នុងសមណធម៌របស់ខ្លួន ។ បទថា **រត្តញ្ញូ** គឺដឹងរតនៈ ឬដឹងរាត្រីច្រើនដែលសត្វលោកសន្មតដោយប្តេជ្ញារបស់ខ្លួនយ៉ាងនេះថា ខ្ញុំដឹងរតនៈ គឺនិព្វាន ។ ឈ្មោះថា **ចិរបព្វជិតា** ព្រោះជាអ្នកបួសយូរ ។

បទថា **ន ឧញ្ញាតព្វោ** គឺមិនគួរមើលងាយ ។ លោកអធិប្បាយថា មិនគួរមើលងាយថា ជាបុគ្គលថោកថយ ។ បទថា **ន បរិភោតព្វោ** បានដល់ គឺមិនគួរពេបជ្រាយ ។ លោកអធិប្បាយថា មិនគួរប្រកាន់យ៉ាងនេះថា លោកនឹងដឹងអ្វី ។

[ ៥២ ] បទថា **កង្ខី វេចិកិច្ឆី** សេចក្តីថា សភិយបរិព្វាជកតម្កើងព្រះមានព្រះភាគ សរសើរភាពជាសព្វញ្ញូ ដែលសម្បូរដោយព្រះរូប មានការស្ងប់ និងការស្អាតរបស់ព្រះមានព្រះភាគយ៉ាងនោះ ជាអ្នកប្រាសចាកការរាយមាយ ទើបពោលថា **កង្ខី វេចិកិច្ឆី** ដូច្នេះ ។

ក្នុង ២ បទនោះ ឈ្មោះថា **កង្ខី** ព្រោះសង្ស័យក្នុងព្យាករទាំងឡាយយ៉ាងនេះថា អាត្មាអញគប្បីបានព្យាករបញ្ហាទាំងនេះឬហ្ន៎ ឈ្មោះថា **វេចិកិច្ឆី** ព្រោះវង្វេងយ៉ាងនេះថា អត្ថនៃបញ្ហានោះៗ ដូចម្តេចហ្ន៎ ។ ម្យ៉ាងទៀត ឈ្មោះថា **កង្ខី** ព្រោះសង្ស័យក្នុងអត្ថនៃបញ្ហាទាំងនោះ ដោយសេចក្តីសង្ស័យយ៉ាងខ្សោយ ឈ្មោះថា **វេចិកិច្ឆី** ព្រោះកាលពិចារណា ក៏នៅលំបាកនោះឯង ដោយសង្ស័យយ៉ាងខ្លាំងក្លា គឺមិនអាចសម្រេចចិត្តបាន ។ បទថា **អភិកង្ខមានោ** គឺប្រាថ្នាយ៉ាងក្រៃលែង ។ បទថា **តេសន្តករោ** បានដល់ ចូរធ្វើបញ្ហាទាំងនោះឲ្យដល់ទីបំផុត ។ សភិយបរិព្វាជកកាលសម្តែងថា ចូរជាយ៉ាងនោះ ទើបទូលថា **បញ្ហេ មេ បុដ្ឋោ ។បេ។ ព្យាករោហិ មេ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **បញ្ហេ មេ** ស្មើគ្នានឹង **បញ្ហេ មយា** សេចក្តីថា ដែលខ្ញុំព្រះអង្គទូលសួរហើយ សូមទ្រង់ព្យាករបញ្ហា ។ បទថា **បុដ្ឋោ** ស្មើគ្នានឹង **បុច្ឆិតោ** ប្រែថា ទូលសួរហើយ ។ បទថា **អនុបុព្វំ** គឺតាមលំដាប់នៃបញ្ហា ។ បទថា **អនុធម្មំ** បានដល់ អាងបាលីឲ្យសមគួរដល់អត្ថ ។ បទថា **ព្យាករោហិ មេ** គឺសូមទ្រង់ព្យាករដល់ខ្ញុំព្រះអង្គចុះ ។

បទថា **ទូរតោ** បានឮថា សភិយបរិព្វាជកនោះត្រាច់ទៅក្នុងទីផ្សេងៗក្នុងនគរនេះ មកតាំងអំពីចម្ងាយផ្លូវ ៧៧ យោជន៍ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា អ្នកមកអំពីចម្ងាយ ដូច្នេះ ។ ព្រះមានព្រះភាគត្រាស់នឹងសភិយបរិព្វាជកថា អ្នកមកអំពីចម្ងាយ ព្រោះមកអំពីសាសនារបស់ព្រះកស្សបទសពល ។ បទថា **បុច្ឆ មំ** គឺព្រះសាស្តាទ្រង់បវារណា

នូវសព្វញ្ញុបវារណា ដល់សភិយៈដោយគាថាថា ម្នាលសភិយៈ អ្នកប្រាថ្នាបញ្ហាណា ចូរសួរតថាគតចុះ ។ បទថា **មនសិច្ឆសិ** បានដល់ ប្រាថ្នាដោយចិត្ត ។

[ ៥៣ ] បទថា **យំ វតាហំ** កាត់បទជា **យំ វត អហំ។** បទថា **អត្តមនោ** គឺមានចិត្តដែលបីតិបាមោជ្ជ និងសោមនស្សពាល់ត្រូវហើយ ។ បទថា **ឧទគ្គោ** ប្រែថា ប៉ោងឡើង គឺផុសឡើងតាមកាយ និងចិត្ត ។ តែបទនេះ មិនមែនមានក្នុងបាឋៈទាំងអស់ឡើយ ។ ឥឡូវនេះ សភិយបរិព្វាជកកាលសម្តែងធម៌ដែលជាហេតុឲ្យខ្លួនសរសើរ ទើបពោលថា **បមុទិតោ បីតិសោមនស្សជាតោ** ដូច្នេះ ។

បទថា **កឹ បត្តិនំ** ប្រែថា គឺភិក្ខុដល់អ្វី សម្រេចអ្វី ។ បទថា **សោរតំ** គឺជាអ្នកស្ងប់ស្ងៀមដោយល្អ ។ បាឋៈថា **សុរតំ** ដូច្នេះក៏មាន អធិប្បាយថា រៀបរយល្អ ។ បទថា **ទន្តំ** ជាអ្នកទូន្មានខ្លួនហើយ ។ បទថា **ពុទ្ធោ** គឺអ្នកដឹងច្បាស់ ឬត្រាស់ដឹងជាព្រះពុទ្ធ ។

សភិយបរិព្វាជកធ្វើនូវគាថានីមួយៗ ឲ្យជាបួនរឿង ហើយទូលសួរបញ្ហា ២០ ដោយគាថា ៥ ។ តែព្រះមានព្រះភាគទ្រង់ធ្វើបញ្ហានីមួយៗ របស់សភិយបរិព្វាជកជាមួយរឿង ១ គាថា ហើយព្យាករដោយ ២០ គាថា ដោយកំពូល គឺអរហត្ត ។

វិនិច្ឆ័យក្នុងគាថានោះថា ព្រោះភិក្ខុនោះដែលទម្លាយកិលេសបានហើយ ជាភិក្ខុដ៏ឧត្តម ភិក្ខុនោះជាអ្នកដល់នូវព្រះនិព្វានហើយ ដូច្នោះ ទើបព្រះមាន

*ព្រះភាគ កាលនឹងព្យាករបញ្ហានេះរបស់សភិយបរិព្វាជកថា* **កឹ បត្តិនមាហុ ភិក្ខុនំ** *ដូច្នេះ ទើបត្រាស់ពាក្យជាដើមថា* **បជ្ជេន** *ជាដើម ។*

*បទនោះ មានសេចក្តីថា បុគ្គលណាដល់នូវនិព្វានដោយមគ្គដែលខ្លួនអប់រំហើយ គឺសម្រេចដល់នូវការរម្ងត់កិលេស ព្រោះដល់នូវនិព្វាន ទើបឈ្មោះថា ជាអ្នកឆ្លងផុតសេចក្តីសង្ស័យ លះនូវការមិនកើត និងការកើតដែលចែកជាវិបត្តិ និងសម្បត្តិ ការវិនាស ការចម្រើន ការសាបសូន្យ ការទៀង បាប និងបុណ្យដោយមគ្គ ជាបុគ្គលគួរដល់ពាក្យសរសើរថា* **វីណា-បុនព្ភវោ** *មានភពថ្មីអស់ហើយ បុគ្គលនោះឈ្មោះថា ជាភិក្ខុ ។ ភិក្ខុឈ្មោះថា ជាអ្នកស្ងប់ ព្រោះជាអ្នកស្ងប់ដោយល្អ ចាកបដិបត្តិខុស និងព្រោះស្ងប់ចាកកិលេស មានប្រការផ្សេងៗ ដូច្នោះ ព្រះមានព្រះភាគកាលទ្រង់ត្រាស់សេចក្តីនោះ ទើបព្យាករបញ្ហាទី ២ ដោយន័យជាដើមថា* **សព្វត្ថ ឧបេក្ខកោ** *ដូច្នេះ ។*

*បទនោះ មានសេចក្តីថា បុគ្គលណាព្រងើយកន្តើយក្នុងអារម្មណ៍ មានរូបជាដើម ដោយឧបេក្ខាមានអង្គ ៦ ដែលប្រព្រឹត្តទៅហើយ យ៉ាងនេះថា ភិក្ខុនោះបានឃើញរូបដោយចក្ខុក៏មិនជាសោមនស្ស មិនជាទោមនស្សឡើយ ជាអ្នកមានសតិ ព្រោះសតិដល់នូវភាពបរិបូរ មិនបៀតបៀនសត្វណាមួយដែលមានប្រភេទ មានការតក់ស្លុត និងមិនតក់ស្លុតជាដើម ជាអ្នកឆ្លងឱឃៈបានហើយ ព្រោះឆ្លងនូវឱឃៈក្នុងលោកទាំងពួង គឺក្នុងលោកទាំងអស់ ជាអ្នកស្ងប់ ព្រោះស្ងប់ចាកបាប ជាអ្នកមានចិត្តមិនល្អក់ ព្រោះលះនូវការត្រិះរិះ*

ដែលល្អក់កករចេញបាន ជាអ្នកមិនមានចំហាយ គឺកិលេស បានដល់ រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ កិលេសគ្រប់ប្រភេទ ទាំងគ្រោតគ្រាត និងល្អិត បុគ្គលនោះ ឈ្មោះថា ជាអ្នកស្ងប់រម្ងាប់ដោយល្អ ចាកបដិបត្តិខុស ព្រោះមានធម៌ជាគ្រឿងនៅ គឺឧបេក្ខា ព្រោះមានសតិបរិបូណ៌ និងព្រោះមិនបៀតបៀន និងដោយការស្ងប់កិលេស មានប្រការផ្សេងៗ មានឱឃៈជាដើម ។

បុគ្គលមានឥន្ទ្រិយអប់រំហើយ មិនមានភ័យ មិនវិការ ជាអ្នកអប់រំខ្លួនហើយ ដូច្នោះ ព្រះមានព្រះភាគកាលទ្រង់សម្តែងសេចក្តីនោះ ទើបទ្រង់ព្យាករដោយគាថាថា **យស្សិន្ទ្រិយានិ** ដូច្នេះ ។

បទនោះ មានសេចក្តីដូចតទៅនេះ បុគ្គលណា លើកឥន្ទ្រិយទាំង ៦ មានចក្ខុន្ទ្រិយជាដើមឡើងកាន់ត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈជាដើម ដោយគោចរភាវនា ហើយកាន់យកក្ងិន គឺសតិសម្បជញ្ញៈ ដោយវាសនាភាវនាចម្រើនហើយ ចាក់ធ្លុះ គឺដឹង ត្រាស់ដឹងលោកនេះ និងលោកដទៃ ដែលបានដល់ លោក គឺខន្ធ ដែលប្រព្រឹត្តទៅក្នុងសន្តានរបស់ខ្លួន និងខន្ធលោកដែលប្រព្រឹត្តទៅក្នុងសន្តានរបស់អ្នកដទៃ ដោយគោចរភាវនាទាំងឡាយ ខាងក្នុង និងខាងក្រៅ ក្នុងលោកទាំងពួងថា ការខ្វះខាតនៃឥន្ទ្រិយទាំងឡាយក្តី ការកើតអំពីការខ្វះខាតក្តី ក្នុងអារម្មណ៍ណាមួយ អប់រំឥន្ទ្រិយហើយ ដោយការមិនសម្ងឹងជាដើម ក្នុងអារម្មណ៍នោះៗ ដូច្នេះហើយ បំណងនឹងស្លាប់ក្នុងកាលយូរ ទន្ទឹងដល់កាល គឺរង់ចាំពេលអស់ជីវិត មិនខ្លាចចំពោះការស្លាប់ ដូចលោកពោលក្នុងថេរៈគាថាថា

**មរណំ មេ ភយំ នត្ថិ និក្កន្តិ នត្ថិ ជីវិតេ**
**នាភិនន្ទាមិ មរណំ នាភិនន្ទាមិ ជីវិតំ**
**កាលញ្ច បដិកង្ខាមិ និព្វិសំ ភតកោ យថា។**

ខ្ញុំមិនមានមរណភ័យទេ សេចក្តីអាល័យក្នុងជីវិតក៏មិនមាន អាត្មាមិនត្រេកអរនឹងសេចក្តីស្លាប់ មិនត្រេកអរនឹងការរស់នៅ អាត្មារង់ចាំតែកាលនឹងបរិនិព្វាន ដូចជាអ្នកស៊ីឈ្នួល ទន្ទឹងតែអស់ថ្ងៃ ។

បទថា **ភាវិតោ ស ឧន្តោ** គឺជាបុគ្គលដែលអប់រំឥន្ទ្រិយហើយ បុគ្គលនោះ បណ្ឌិតពោលថា ជាអ្នកទូន្មានខ្លួនហើយ ។

ព្រោះធម្មតា ព្រះពុទ្ធ ជាបុគ្គលសម្បូរដោយបញ្ញា ទ្រង់ជាអ្នកភ្ញាក់អំពីការដេកលក់ គឺកិលេស ដូច្នោះ កាលទ្រង់សម្តែងសេចក្តីនោះ ទើបទ្រង់ព្យាករបញ្ហាទី ៤ ដោយគាថាថា **កប្បានិ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **កប្បានិ** បានដល់ កប្ប គឺតណ្ហា និងទិដ្ឋិ ។ ពិតហើយ តណ្ហា និងទិដ្ឋិ លោកហៅថា **កប្ប** ព្រោះកំណត់យកយ៉ាងនោះ បទថា **វិចេយ្យ** គឺពិចារណាដោយភាពជារបស់មិនទៀងជាដើម ។ បទថា **កេវលានិ** បានដល់ ទាំងអស់ ។ បទថា **សំសារំ** បានដល់ សង្សារទាំងមូល ដែលបានដល់ លំដាប់ខន្ធជាដើម យ៉ាងនេះថា

**ខន្ធានញ្ច បដិបាដិ ធាតុអាយតនាន ច**
**អព្វោច្ឆិន្នំ វត្តមានា សំសារោតិ បវុច្ចតិ។**

លំដាប់នៃខន្ធ ធាតុ អាយតនៈទាំងឡាយ ដែលប្រព្រឹត្តទៅមិនដាច់ខ្សែ លោកហៅថា សង្សារ ។

ដោយហេតុមានប្រមាណប៉ុណ្ណេះ លោកពោលដល់វិបស្សនាក្នុងវដ្ដៈ ៣ យ៉ាងនេះ គឺក្នុងកម្មវដ្ដៈ និងកិលេសវដ្ដៈ ដែលជាមូលនៃខន្ធទាំងឡាយ និងក្នុងខន្ធទាំងឡាយ ។ បទថា **ឧភយំ ចុតូបបាតំ** បានដល់ ពិចារណា គឺដឹងទាំងចុតិ និងបដិសន្ធិទាំង ២ របស់សត្វទាំងឡាយ ។ ដោយបទថា **ចុតូបបាតំ** នេះ លោកពោលដល់ចុតូបបាតិញ្ញាណ ។ បទថា **វិគតរជមនង្គណំ វិសុទ្ធំ** សេចក្ដីថា ឈ្មោះថា ប្រាសចាកធូលី មិនមានកិលេសជាគ្រឿងជាប់ជំពាក់ ជាអ្នកបរិសុទ្ធ ព្រោះប្រាសចាកធូលី មានរាគៈជាដើម ព្រោះមិនមានកិលេស ជាគ្រឿងជាប់ជំពាក់ ព្រោះប្រាសចាកមន្ទិល ។ បទថា **បត្តំ ជាតិក្ខយំ** បានដល់ សម្រេចនូវព្រះនិព្វាន ។ បទថា **តមាហុ ពុទ្ធំ** សេចក្ដីថា បុគ្គលនោះ បណ្ឌិតពោលថា ជាអ្នកដឹងដល់ការអស់នៃជាតិ ព្រោះដល់ព្រមដោយការដឹង គឺចំណែកនៃចុតូបបាតិញ្ញាណ ដោយលោកុត្តរវិបស្សនានេះ និងព្រោះជាបុគ្គលបរិសុទ្ធចាកការដេកលក់ គឺកិលេស ព្រោះប្រាសចាកកិលេស មានធូលីជាដើមនេះ ដោយបដិបទានោះ ។

ម្យ៉ាងទៀត បទថា **កប្បានិ វិចេយ្យ កេវលានិ** សេចក្ដីថា ពិចារណាដោយន័យជាដើមថា រឭកបានច្រើនសំវដ្ដកប្បខ្លះ ច្រើនវិវដ្ដកប្បខ្លះ ច្រើនសំវដ្ដវិវដ្ដកប្បខ្លះ ដូច្នេះ ។ ដោយបទនេះ ទ្រង់ត្រាស់ដល់វិជ្ជាទី ១ គឺបុព្វេនិវាសានុស្សតិញ្ញាណ ។ បទថា **សំសារំ ឧភយំ ចុតូបបាតំ** សេចក្ដីថា ពិចារណាសង្សារទាំង ២ យ៉ាងនេះ គឺចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ដោយន័យជាដើមថា សត្វទាំងឡាយ ដែលចម្រើនទាំងនេះ ដូច្នេះ ។

បទនេះ ទ្រង់ត្រាស់ដល់វិជ្ជាទី ២ គឺចុតូបបាតិញ្ញាណ ។ ដោយបទដ៏សេស ទ្រង់ត្រាស់ដល់វិជ្ជាទី ៣ គឺអាសវក្ខយញ្ញាណ ។ ភាពជាអ្នកប្រាសចាកធូលីជាដើម និងការសម្រេចព្រះនិព្វាន រមែងមានដោយអាសវក្ខយញ្ញាណ ។ បទថា **តមាហុ ពុទ្ធំ** សេចក្តីថា ខ្ញុំពោលបុគ្គលនោះ ដែលជាបុគ្គលដល់ព្រមដោយបញ្ញា គឺវិជ្ជា ៣ យ៉ាងនេះថា ជាព្រះពុទ្ធ ។

ព្រះមានព្រះភាគ កាលទ្រង់ឆ្លើយបញ្ហា ដែលព្រាហ្មណ៍សួរដោយគាថាដំបូងយ៉ាងនេះហើយ ព្រោះជាបុគ្គលដល់នូវភាពជាព្រហ្ម ភាពជាបុគ្គលប្រសើរ ជាព្រាហ្មណ៍ដ៏កំពូល ជាអ្នកបន្សាត់បាបទាំងអស់បានហើយ ដូច្នោះ កាលទ្រង់សម្តែងសេចក្តីនោះ ទើបទ្រង់ព្យាករបញ្ហាដំបូងដោយគាថាថា **ពាហិត្វា** ដូច្នេះជាដើម ( ដែលជាគាថា ) ក្នុងក្រុមបញ្ហាដែលសួរដោយគាថាទី ២ ។

គាថានោះ មានសេចក្តីថា បុគ្គលណាបន្សាត់បាបទាំងអស់បានហើយ ដោយមគ្គទី ៤ តម្កល់ខ្លួនមាំទាំ អធិប្បាយថា មិនញាប់ញ័រ ជាអ្នកប្រាសចាកមន្ទិល ព្រោះបន្សាត់បាបបានហើយ ដល់នូវភាពជាអ្នកមិនមានមន្ទិល ភាពជាព្រហ្ម ភាពជាបុគ្គលប្រសើរ ជាអ្នកតាំងមាំហើយដោយល្អ ដោយអរហត្តផលសមាធិ ដែលស្ងប់មន្ទិល គឺកិលេស ដែលធ្វើឲ្យសមាធិរាយមាយ ឈានកន្លងនូវសង្សារបានហើយ ដោយការឈានកន្លងហេតុនៃសង្សារ ជាអ្នកសម្រេចកិច្ច ព្រោះធ្វើកិច្ចស្រេចហើយ បុគ្គលនោះ លោកពោលថា ជាអ្នកមិនមានទីអាស្រ័យ ព្រោះតណ្ហា និងទិដ្ឋិមិនអាស្រ័យហើយ និងជាអ្នក

មិនញាប់ញ័រ ព្រោះមិនធ្វើឲ្យខុសប្រក្រតីដោយលោកធម៌ ដោយប្រការដូច្នេះ បុគ្គលនោះ លោកពោលថា ជាព្រហ្ម គឺជាព្រាហ្មណ៍ គួរដល់ការសរសើរ ។

ព្រោះលោកពោលថា ជាសមណៈ ព្រោះជាអ្នកស្ងប់បាបបានហើយ ជាអ្នកលាងបាប ព្រោះលាងបាបបានហើយ ជានាគ ព្រោះមិនធ្វើបាបទាំង-ឡាយ ដូច្នោះ កាលទ្រង់សម្តែងសេចក្តីនោះ ទើបទ្រង់ព្យាករបញ្ហាទី ៣ ដោយ ៣ គាថាដទៃទៀត ។

[ ៥៤ ] បទថា **សមិតាវិ** គឺស្ងប់កិលេស ដោយអរិយមគ្គ តាំងនៅ ។ បទថា **សមណោ បវុច្ចតិ តថត្តា** សេចក្តីថា បុគ្គលបែបនោះ លោកហៅថា សមណៈ ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ទ្រង់ព្យាករបញ្ហាហើយ ។ ពាក្យដ៏សេសជាពាក្យសរសើរ ដើម្បីឲ្យសភិយបរិព្វាជកកើតសេចក្តីរាប់អានក្នុងសមណៈនោះច្រើនឡើង ។ ពិតហើយ បុគ្គលណាជាអ្នកមានសេចក្តីស្ងប់ បុគ្គលនោះ ឈ្មោះថា ជាអ្នកមិនមានកិលេស ដូចធូលី ព្រោះប្រាសចាកកិលេសដូចធូលី ព្រោះលះបុណ្យ និងបាបបាន ដោយមិនធ្វើការបន្តនៃបុណ្យ និងបាប ជាអ្នកឈានកន្លងជាតិ និងមរណៈបាន ព្រោះដឹងនូវលោកនេះ និងលោកដទៃ ដោយអំណាចនៃលក្ខណៈ មានការមិនទៀងជាដើម និងជាតាទិបុគ្គល ។ម្យ៉ាងទៀត ក្នុងគាថានេះថា **និន្នហាយ ។បេ។ ន្ហាតកោ** ដូច្នេះ ។ គប្បីជ្រាបសេចក្តីយ៉ាងនេះថា បុគ្គលណា លាង គឺជម្រះបាបទាំងអស់ដែលគួរដល់ការកើត ដោយអំណាចអារម្មណ៍ខាងក្នុង និងខាងក្រៅ ក្នុងអាយតនលោកទាំងអស់ ពោល គឺខាងក្នុង និងខាងក្រៅ ដោយ

មគ្គញ្ញាណ មិនមកកាន់កប្បក្នុងទេវតា និងមនុស្សទាំងឡាយ ដែលសមគួរ ដោយកប្ប គឺតណ្ហា និងទិដ្ឋិ ព្រោះលាងជម្រះបាបបានហើយនោះ បណ្ឌិត ពោលបុគ្គលនោះថា ជាអ្នកលាងបាប ។

ក្នុងគាថាទី ៤ ក៏គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា បទថា **អាគុំ ន ករោតិ កិញ្ចិ លោកេ** សេចក្ដីថា បុគ្គលណាមិនធ្វើបាបដែលជាអំពើ អាក្រក់ មានប្រមាណតិចតួចក្នុងលោក បុគ្គលនោះលោកហៅថា ជានាគ ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ព្រះមានព្រះភាគទ្រង់ព្យាករបញ្ហា ហើយ ។ ពាក្យដ៏សេស ជាពាក្យសរសើរដោយន័យដូចពោលហើយ ក្នុង កាលមុននោះឯង ពិតហើយ បុគ្គលណាមិនធ្វើអាក្រក់ ព្រោះលះនូវសេចក្ដី អាក្រក់បានដោយមគ្គ បុគ្គលនោះរលាស់ចេញ គឺលះនូវយោគៈទាំងអស់ មានកាមយោគៈជាដើម និងសំយោជនៈទាំងអស់ ដែលបានដល់សំយោជនៈ ១០ មិនជាប់ជំពាក់ដោយរបស់ណាមួយក្នុងខន្ធជាដើម និងរួចផុតបានជា សមុច្ឆេទ ដោយវិមុត្តិទាំង ២ ជាបុគ្គលមិនញាប់ញ័រ ។

ក្នុងបញ្ហាដែលព្រះមានព្រះភាគទ្រង់ឆ្លើយ ដែលព្រាហ្មណ៍សួរដោយ គាថាទី ២ យ៉ាងនេះហើយ ទើបត្រាស់ដោយគាថាទី ៣ តទៅ ព្រោះ អាយតនៈទាំងឡាយលោកតហៅថា **ខេត្តានិ** ដូចលោកពោល ( ក្នុងធម្ម- សង្គណី ) ថា **ចក្ខុបេតំ ចក្ខាយតនំបេតំ ។បេ។ ខេត្តំបេតំ វត្ថុំបេតំ** ក្អែកនុ៎ះ ហៅថា ចក្ខុក៏បាន ( ព្រោះជាអ្នកត្រូតត្រាខាងការឃើញ ) ហៅថា ចក្ខាយតនៈក៏បាន ( ព្រោះជាទីប្រជុំចុះនៃកំណើតរបស់ខ្លួន ) ។បេ។ ហៅថា

ខេត្តក៏បាន ( ព្រោះជាកន្លែងកើតផស្សៈជាដើម ) ហៅថា វត្ថុក៏បាន ( ព្រោះជាទីតម្កល់ផស្សៈជាដើម ) ដូច្នេះ ។ បុគ្គលណាឈ្នះ គឺគ្របសង្កត់ខេត្តទាំងនោះម្យ៉ាងទៀត ពិចារណា គឺកំណត់ខេត្តទាំងមូល មិនមានសេសសល់ ដោយភាពជារបស់មិនទៀងជាដើម តែដោយការផ្សេងគ្នា ខេត្តដែលជារបស់ទិព្វ ខេត្តរបស់មនុស្ស និងខេត្តរបស់ព្រហ្ម មានការទាក់ទងគ្នាជាហេតុ ខេត្តណាជារបស់ទិព្វ មាន ១២ ប្រភេទ ខេត្តដែលជារបស់មនុស្សក៏យ៉ាងនោះ ម្យ៉ាងទៀត ខេត្តណាជារបស់ព្រហ្ម មានប្រភេទ គឺអាយតនៈ ១២ មានចក្ខាយតនៈជាដើម ក្នុងអាយតនៈ ៦ គប្បីធ្វើឲ្យស្ងប់ ឬគប្បីពិចារណាខេត្តទាំងអស់នោះ បន្ទាប់អំពីនោះ ជាអ្នករួចផុតចាកចំណងដែលជាឫសគល់នៃខេត្តទាំងអស់ មានអវិជ្ជា តណ្ហា និងភពជាដើមជាគ្រឿងចងដែលជាឫសគល់នៃខេត្តទាំងពួង ឈ្មោះថា ជាអ្នកឈ្នះនូវខេត្តទាំងពួង ព្រោះខេត្តទាំងនោះ ដែលខ្លួនឈ្នះបានហើយ ឬពិចារណាហើយយ៉ាងនេះ ដូច្នោះទើបព្រះមានព្រះភាគទ្រង់ព្យាករបញ្ហាដំបូង ដោយគាថានេះថា **ខេត្តានិ** ដូច្នេះ ។ ក្នុងបទថា **ខេត្តានិ** អាចារ្យពួកខ្លះពោលថា កម្មទាំងឡាយ ឈ្មោះថា ជាខេត្ត ព្រោះបាលីថា កម្ម ជាស្រែ វិញ្ញាណ ជាពូជ តណ្ហា ជាទឹក ដូច្នេះ ។ ម្យ៉ាងទៀត ក្នុងបទថា **ទិព្វំ មានុសកញ្ច ព្រហ្មក្ខេត្តំ** នេះ លោក ពណ៌នាថា កម្មដែលជាខេត្តនៃទិព្វ ចូលដល់ទេវលោក កម្មដែលជាខេត្តរបស់មនុស្សចូលដល់មនុស្ស កម្មដែលជាខេត្តរបស់ព្រហ្មចូលដល់ព្រហ្ម ។ បទដ៏សេសមានន័យដូចពោលហើយនោះឯង ។

ព្រោះកម្មទាំងឡាយ លោកហៅថាកោស ព្រោះដូចគ្នានឹងសម្បកស៊ុត ដែលតាំងនៅក្នុងខ្លួន ឈ្មោះថា **កុសលោ** ព្រោះកាត់ គឺកាត់នូវសម្បក ទាំងនោះបាន ដូច្នោះ កាលទ្រង់សម្ដែងសេចក្ដីនោះ ទើបទ្រង់ព្យាករបញ្ហាទី ២ ដោយគាថាថា **កោសានិ** ដូច្នេះ ។

បទនោះ មានសេចក្ដីដូច្នេះ ភិក្ខុណាពិចារណាសម្បកស៊ុត គឺកម្មទាំងអស់ ដែលបានដល់កុសលកម្ម ដោយភាពជារបស់មិនទៀងជាដើម ដោយអារម្មណ៍ និងដោយកិច្ច ដោយលោកិយវិបស្សនា និងលោកុត្តរវិបស្សនា តែដោយការផ្សេងគ្នា ពិចារណានូវសម្បកស៊ុតដែលជារបស់ទិព្វ និងរបស់មនុស្ស មានកាមាវចរកុសលចេតនា ៨ ដែលជាហេតុទាក់ទងគ្នានឹងសម្បកស៊ុតរបស់ព្រហ្ម មានមហគ្គតកុសលចេតនា ៩ ជាដើម បន្ទាប់អំពីនោះ រួចផុតចាកចំណងដែលជាឫសគល់នៃសម្បកស៊ុតទាំងអស់ ដូចជាអវិជ្ជា និងភវតណ្ហាជាដើម ដោយមគ្គភាវនា លោកពោលថាជា **កុសលោ** ព្រោះកម្ចាត់នូវសម្បកទាំងនោះបាន ដោយប្រការដូច្នេះ និងជាតាទិបុគ្គល ព្រោះជាបុគ្គលមានសភាពបែបនោះ ។ ម្យ៉ាងទៀត គប្បីជ្រាបភព ៣ និងអាយតនៈ ១២ ថា ជាកោសៈ ព្រោះដូចគ្នានឹងស្រោមដាវ ដោយអត្ថថា ជាទីនៅរបស់សត្វ និងធម៌ទាំងឡាយ ។ ក្នុងបទនេះ គប្បីជ្រាបអធិប្បាយតាមគាថាដូចពោលមកនេះ ។

ម្យ៉ាងទៀត ព្រោះលោកពោលថា ជាបណ្ឌិត ដោយបទនេះថា រមែងប្រព្រឹត្តទៅ ( ដោយបញ្ញា ) ត្រឹមតែម្យ៉ាង តែដោយពិត លោកពោលថា

ជាបណ្ឌិត ព្រោះដល់ គឺចូលដល់អាយតនៈទាំងឡាយ ទាញយកដោយបញ្ញាជាគ្រឿងពិចារណា ដូច្នោះ កាលទ្រង់សម្ដែងសេចក្ដីនោះ ទើបទ្រង់ព្យាករបញ្ហាទី ៣ ដោយគាថាថា **ឧភយានិ** ដូច្នេះជាដើម ។

គាថានោះ មានសេចក្ដីដូច្នេះថា បុគ្គលណាពិចារណាអាយតនៈទាំង ២ យ៉ាងនេះ គឺទាំងខាងក្នុង និងខាងក្រៅ ដោយភាពជារបស់មិនទៀងជាដើម ។ បទថា **បណ្ឌរានិ** បានដល់ អាយតនៈទាំងឡាយ ។ លោកពោលយ៉ាងនោះ ព្រោះបរិសុទ្ធដោយប្រក្រតី និងព្រោះស្អាត បុគ្គលមានបញ្ញាបរិសុទ្ធបែបនោះ លោកពោលថា ជាបណ្ឌិត ព្រោះពិចារណាអាយតនៈទាំងនោះ កម្ចាត់មន្ទិលចេញបាន ដោយការបដិបត្តិនេះ ។ ព្រោះជាបុគ្គលដល់ហើយនូវអាយតនៈទាំងនោះ ដោយបញ្ញា ។ បទដ៏សេស ជាពាក្យសរសើរបណ្ឌិតនោះ បុគ្គលនោះជាអ្នកឈានកន្លងនូវធម៌ខ្មៅ និងធម៌សដែលបានដល់បាប និងបុណ្យបានហើយ និងជាអ្នកមិនញាប់ញ័រ ដូច្នោះ ទើបបុគ្គលត្រូវសរសើរយ៉ាងនេះ ដោយប្រការដូច្នេះ ។

ព្រោះលោកពោលថា ការដឹង លោកហៅថា **មោនៈ** បានដល់ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការសន្សំធម៌ ការយល់ឃើញត្រូវ មុនីប្រកបព្រមដោយការដឹងនោះ ឈ្មោះថា អ្នកដល់នូវមោនៈ ដូច្នេះ ។ ដូច្នោះ កាលទ្រង់សម្ដែងសេចក្ដីនេះ ទើបទ្រង់ព្យាករបញ្ហាទី ៤ ដោយគាថាថា **អសតញ្ច** ដូច្នេះជាដើម ។

បទនោះ មានសេចក្ដីដូច្នេះ បុគ្គលណាដឹងនូវធម៌របស់អសប្បុរស និង

សប្បុរស ជាអកុសលផង កុសលផង ដោយញាណជាគ្រឿងពិចារណាក្នុងលោកទាំងពួងនេះ គឺខាងក្នុង និងខាងក្រៅ តាំងនៅ កន្លង គឺឈានកន្លងនូវធម៌ដែលជាគ្រឿងជំពាក់ ៧ យ៉ាង មានរាគៈជាដើម និងសំណាញ់ ២ យ៉ាង មានតណ្ហា និងទិដ្ឋិ ព្រោះបុគ្គលបានដឹងហើយ លោកពោលបុគ្គលនោះថា ជាមុនី ព្រោះប្រកបដោយញាណជាគ្រឿងពិចារណា បានដល់ **មោន** នោះ ។ បទថា **ទេវមនុស្សេហិ បូជិយោ** នេះ ជាពាក្យសរសើររបស់បុគ្គលនោះ ។ ពិតហើយ បុគ្គលនោះ ជាបុគ្គលគួរដល់ការបូជានៃទេវតា និងមនុស្សទាំងឡាយ ព្រោះជាមុនីអស់នូវអាសវៈហើយ ដូច្នោះ ទើបត្រូវសរសើរយ៉ាងនេះ ដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគកាលទ្រង់ឆ្លើយបញ្ហា ដែលព្រាហ្មណ៍សួរដោយគាថាទី ៣ ហើយ ព្រោះបុគ្គលនោះ ធ្វើនូវការអស់កិលេស ដល់ហើយនូវវេទ គឺមគ្គញាណ ៤ បុគ្គលនោះ ឈ្មោះថា ជាអ្នកដល់នូវវេទដោយបរមត្ថ ។ មួយវិញទៀត បុគ្គលណាពិចារណាវេទទាំងឡាយ ដែលដឹងថា ជាសាស្ត្ររបស់សមណៈ និងព្រាហ្មណ៍ទាំងឡាយ ដោយភាពជារបស់មិនទៀងជាដើមដោយកិច្ច ដោយមគ្គភាវនានោះឯង ឈានកន្លងនូវវេទទាំងពួងនោះ ដោយការលះនូវតម្រេកក្នុងវេទនោះ វេទនាណាកើតឡើង ព្រោះវេទជាបច្ច័យ ឬដោយប្រការដទៃ ជាអ្នកប្រាសចាកតម្រេកក្នុងវេទនាទាំងនោះ គឺក្នុងវេទនាទាំងអស់ ដូច្នោះ កាលទ្រង់សម្តែងសេចក្តីនោះ មិនបានត្រាស់ថា បុគ្គលសម្រេចវត្ថុនេះ តែទ្រង់ព្យាករបញ្ហាទី ១ ដោយគាថាថា **វេទានិ** ជាដើម ដែលជាគាថា

ក្នុងបញ្ហាដែលសួរដោយបញ្ហាទី ៤ ។

[ ៥៦ ] ព្រោះបុគ្គលណាពិចារណានូវវេទទាំងឡាយ ដោយបញ្ញាដែលជាគ្រឿងពិចារណានោះ ឈានកន្លងនូវវេទទាំងពួង ដោយការលះនូវតម្រេកក្នុងវេទនានោះ បុគ្គលនោះដល់ គឺដឹង និងឈានកន្លងនូវវេទទាំងឡាយដែលតែងហៅថា ជាសាស្ត្រ បុគ្គលណាប្រាសចាកតម្រេកក្នុងវេទនាទាំងឡាយ បុគ្គលនោះ ដល់ និងឈានកន្លងនូវវេទទាំងឡាយ ដែលដឹងថា ជាវេទនា បុគ្គលនោះ ឈ្មោះថា **វេទគូ** ព្រោះជាអ្នកដល់នូវវេទ ដូច្នោះ កាលទ្រង់សម្តែងសេចក្តីនោះផង ទើបមិនបានត្រាស់ថា បុគ្គលសម្រេចវត្ថុនេះ តែទ្រង់ព្យាករបញ្ហាទី ១ ដោយគាថានេះ ។

ក្នុងបញ្ហាទី ២ ទ្រង់ត្រាស់ថា **អនុវិច្ច** បានដល់ បុគ្គលតាមដឹង បុគ្គលនោះពិចារណានាមរូបដែលធ្វើឲ្យយឺតយូរ ដែលជាខាងក្នុង គឺខាងក្នុងសន្តានរបស់ខ្លួន ដែលបានដល់ធម៌ដែលធ្វើឲ្យយឺតយូរ មានតណ្ហា មានះ និងទិដ្ឋិ និងនាមរូបដែលមានធម៌ធ្វើឲ្យយឺតយូរនោះជាបច្ច័យ ដោយអនិច្ចានុបស្សនាជាដើម មិនមែនពិចារណានូវធម៌ដែលជាខាងក្នុងតែម្យ៉ាងឡើយ គង់ពិចារណានូវធម៌ ដែលជាឫសគល់នៃរោគខាងក្រៅផងដែរ បានដល់ពិចារណានូវធម៌ ដែលជាឫសគល់ និងធម៌ធ្វើឲ្យយឺតយូរ មានអវិជ្ជា និងភវតណ្ហាជាដើមរបស់នាមរូប និងរោគនេះ ក្នុងសន្តានរបស់អ្នកដទៃ ឬជាអ្នកផុតចាកចំណង ដែលជាឫសគល់នៃរោគទាំងឡាយទាំងពួងដោយការនានោះ ឬចាកចំណងដែលជាឫសគល់ទាំងពួងនៃរោគទាំងឡាយ ឬចាកធម៌ដែលធ្វើ

ឲ្យយឺតយូរនោះ មានអវិជ្ជា និងកវតណ្ហាជាដើម ដូច្នោះ កាលទ្រង់សម្តែង សេចក្តីនោះ ទើបព្យាករបញ្ហាទី ២ ដោយគាថាថា **អនុវិច្ច** ដូច្នេះជាដើម ។

ក្នុងបទថា **កថញ្ចុ វីរិយវា** នេះ មានវិនិច្ឆ័យដូចតទៅនេះថា ព្រោះ បុគ្គលណាវៀរចាកបាបទាំងពួង ដោយអរិយមគ្គ ម្យ៉ាងទៀត ព្រោះជាអ្នក វៀរយ៉ាងនេះបាន ទើបឈានកន្លងនូវទុក្ខក្នុងនរក ដោយមិនមានបដិសន្ធិតទៅ តាំងនៅដោយសេចក្តីព្យាយាម មានការព្យាយាមជាទីអាស្រ័យ បុគ្គលនោះ ជាព្រះខីណាស្រព រមែងគួរពោលបានថា ជាអ្នកមានសេចក្តីព្យាយាម ដូច្នោះ កាលទ្រង់សម្តែងសេចក្តីនោះ ទើបទ្រង់ព្យាករបញ្ហាទី ៣ ដោយគាថាថា **វិរតោ** ដូច្នេះជាដើម ។ បទថា **បធានវា ធីរោ តាទិ** នេះ ជាពាក្យ សរសើរបុគ្គលនោះ ព្រោះបុគ្គលនោះ ឈ្មោះថា **បធានវា** ព្រោះសេចក្តី ព្យាយាមក្នុងមគ្គ និងឈាន ឈ្មោះថា **ធីរោ** ព្រោះអាចកម្ចាត់កិលេស ជាដើមបាន ឈ្មោះថា **តាទិ** ព្រោះមិនធ្វើឲ្យប្លែកចេញទៅ ដូច្នោះ ទើប បុគ្គលត្រូវសរសើរ ដោយប្រការដូច្នេះ ។ បទដ៏សេស គួរពោលប្រកបគ្នា ។

ក្នុងបទថា **អាជានិយោ កិន្តិ នាម ហោតិ** បុគ្គលជាអាជានេយ្យ នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

ព្រះមានព្រះភាគ កាលទ្រង់សម្តែងថា សេះក្តី ដំរីក្តី ដឹងហេតុដែលគួរ និងមិនគួរ លះនូវទោស គឺការកោងទាំងអស់បាន លោកពោលថា ជាអាជា- នេយ្យក្នុងលោក តែអាជានេយ្យនោះ មិនទាន់លះទោសទាំងអស់បាន តែព្រះ ខីណាស្រព លះទោសទាំងនោះបានទាំងអស់ ដូច្នោះ ទើបគួរពោលដោយ

បរមត្ថថា ជាអាជានេយ្យ ទើបទ្រង់ព្យាករបញ្ហាទី ៤ ដោយគាថាថា **យស្ស** ដូច្នេះជាដើម ។ គាថានោះ មានសេចក្ដីដូចតទៅនេះ បទថា **អជ្ឈត្តំ ពហិទ្ធា** ច សេចក្ដីថា បុគ្គលណាកាត់នូវចំណង ដែលបានដល់សំយោជនៈទាំង-ឡាយ ទាំងខាងក្នុង ខាងក្រៅបានហើយ គឺកាត់ ទម្លាយដោយសស្ត្រា គឺបញ្ញា ។ បទថា **សង្គមូលំ** សេចក្ដីថា គ្រឿងចងដែលជាឫសគល់នៃការជាប់ជំពាក់ មិនឈានកន្ទង់ក្នុងវត្ថុនោះៗ ។ ម្យ៉ាងទៀត បុគ្គលណាកាត់នូវចំណងមានរាគៈជាដើម ដែលជាឫសគល់នៃធម៌ ជាគ្រឿងជាប់ជំពាក់ទាំងខាងក្នុងនិងខាងក្រៅបានហើយ បុគ្គលនោះ រួចផុតចាកចំណងទាំងពួង ដែលជាឫសគល់នៃធម៌ជាគ្រឿងជាប់ជំពាក់ ឬដែលជាឫសគល់នៃធម៌ជាគ្រឿងជាប់ជំពាក់ទាំងពួង លោកពោលបុគ្គលនោះថា ជាអាជានេយ្យ និងជាតាទិបុគ្គលព្រោះសភាពបែបនោះ ។

ព្រះមានព្រះភាគ កាលទ្រង់ឆ្លើយបញ្ហាដោយគាថាទី ៤ ហើយ ដែលត្រាស់ហើយ ( សម្រាប់ ) ក្នុងបញ្ហាដែលសួរដោយគាថាទី ៥ ព្រោះចិន្តកវីទាំងឡាយ ពណ៌នាភាពជាបុគ្គលសម្បូរដោយសុត្តៈ ដោយហេតុត្រឹមតែការជំនាញក្នុងឆន្ទ ( ដំណើររបស់កាព្យ ) បុគ្គលនោះ ជាអ្នកសម្បូរត្រឹមតែវោហារសុត្តៈ តែព្រះអរិយៈជាអ្នកបរិបូណ៌ដោយបរមត្ថសុត្តៈ ព្រោះជាពហូសូតនិងព្រោះមិនមានសុត្តៈដែលអាក្រក់ ដូច្នោះ កាលទ្រង់សម្ដែងសេចក្ដីនោះទើបមិនត្រាស់ថា បុគ្គលសម្រេចវត្ថុនេះ ទ្រង់ព្យាករបញ្ហាដំបូង ដោយគាថាថា **សុត្វា** ដូច្នេះជាដើម ។

បទនោះ មានសេចក្តីដូច្នេះ បុគ្គលណាក្នុងលោកនេះ ស្តាប់ដោយកិច្ច គឺសុតមយប្បញ្ញា ឬស្តាប់ដោយកិច្ចដែលគួរធ្វើ ដឹងក្រៃលែងនូវធម៌ទាំងពួង ដែលចូលដល់វិបស្សនា គ្របសង្កត់នូវធម៌ដែលមានទោស និងមិនមានទោស ណាមួយ កិលេសទាំងឡាយ និងធម៌ជាទីតាំងនៃកិលេស ដោយបដិបទានេះ ដល់នូវការរាប់បានថា **អភិភូ** ( គឺអ្នកគ្របសង្កត់ ) ស្តាប់ ដូច្នេះហើយ ដឹង ក្រៃលែងនូវធម៌ទាំងពួង គ្របសង្កត់នូវធម៌ដែលមានទោស និងធម៌មិនមាន ទោសណាមួយ លោកហៅបុគ្គលនោះថា ជាអ្នកសម្បូរដោយសុតៈ ព្រោះជា អ្នកស្តាប់ហើយ ម្យ៉ាងទៀត ព្រោះបុគ្គលណា មិនមានសេចក្តីសង្ស័យ ផុត ហើយចាកគ្រឿងចង គឺកិលេស នឹងជាបុគ្គលមិនមានទុក្ខក្នុងទីទាំងពួងដោយ ទុក្ខទាំងឡាយ មានរាគៈជាដើម គឺក្នុងធម៌ទាំងពួង មានខន្ធ និងអាយតនៈ ជាដើម ព្រោះហេតុនោះ ទើបលោកពោលបុគ្គលមិនមានសេចក្តីសង្ស័យ ជា អ្នកផុតហើយ ជាអ្នកមិនមានទុក្ខក្នុងធម៌ទាំងពួងថា **សោត្តិយោ** ( អ្នក សម្បូរដោយសុតៈ ) ដូច្នេះ ។

ព្រោះបុគ្គលឈ្មោះថាជាអរិយៈ ព្រោះដែលជនប្រាថ្នាប្រយោជន៍ គប្បី បូជា អធិប្បាយថា គួរចូលដល់ ព្រោះហេតុនោះ ព្រះមានព្រះភាគ កាល ទ្រង់សម្តែងនូវគុណដែលជាហេតុឲ្យជាអរិយៈ ទើបព្យាករបញ្ហាទី ២ ដោយ គាថាថា **ឆេត្វា** ។

គាថានោះ មានសេចក្តីថា បុគ្គលនោះជាអ្នកប្រាជ្ញ ជាអ្នកចេះដឹង ជា អ្នកដឹងច្បាស់នូវមគ្គ ៤ កាត់ហើយ គឺទម្លាយនូវអាសវៈ ៤ អាល័យ ២

ដោយសស្រ្តា គឺបញ្ញា រមែងមិនចូលដល់នូវការដេកក្នុងគភ៌ ដោយអំណាចកពថ្មី គឺមិនចូលដល់កំណើតណាមួយឡើយ បន្ទាបង់នូវសញ្ញា ៣ យ៉ាងមានកាមជាដើម និងភក់ គឺកាមគុណ រមែងមិនមកកាន់កប្បណាមួយ នៃតណ្ហាកប្ប និងទិដ្ឋិកប្ប លោកពោលបុគ្គលនោះ ដែលប្រកបដោយគុណមានការកាត់អាសវៈជាដើមយ៉ាងនេះថា ជាអរិយៈ ឬឈ្មោះថា **អរិយំ** ព្រោះឆ្ងាយចាកបាបទាំងឡាយ និងឈ្មោះថា **អនរិយំ** ព្រោះការមិនប្រព្រឹត្តិទៅដោយសេចក្តីទុក្ខ ដូច្នោះ កាលទ្រង់សម្តែងសេចក្តីនោះ ទើបទ្រង់ព្យាករដោយបញ្ហាទី ២ នៃគាថានេះ ។ ពិតហើយ ធម៌លាមក មានអាសវៈជាដើមដែលសន្មតថាជាទុក្ខ ធម៌លាមកទាំងនេះ ដែលបុគ្គលនោះកាត់ហើយបន្ទាបង់ហើយ ទាំងមិនញាប់ញ័រដោយធម៌លាមកទាំងនោះ ទើបឈ្មោះថាជាអ្នកឆ្ងាយធម៌ទាំងនោះ និងមិនកម្រើកទៅក្នុងធម៌ទាំងនោះ ដូច្នោះ ទើបលោកពោលបុគ្គលនោះថាជាអរិយៈ ដោយគន្លងថា បុគ្គលនោះ ជាអ្នកឆ្ងាយចាកធម៌លាមក ដោយគន្លងថា បុគ្គលនោះ មិនកម្រើកក្នុងសេចក្តីទុក្ខ ។ ក្នុងបទនេះ គប្បីជ្រាបយោជនាយ៉ាងនេះ ។ បទថា **វិទ្វា សោ ច ឱបេតិ គត្តាសេយ្យំ** នេះ ជាពាក្យសរសើរក្នុងការកំណត់សេចក្តីនេះ ។

ក្នុងបទនេះ គឺបទថា **កថំ ចរណវា** គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា ព្រោះបុគ្គលសម្រេចធម៌ដែលគួរសម្រេច ដោយចរណៈទាំងឡាយ រមែងគួរពោលថា **ចរណវា** ដូច្នោះ កាលទ្រង់សម្តែងសេចក្តីនោះ ទើបទ្រង់ព្យាករបញ្ហា ៣ ដោយគាថាថា **យោ ឥធ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **យោ ៩៨** បានដល់ បុគ្គលណា ក្នុងសាសនានេះ ។ បទថា **ចរណេសុ** ព្រោះធម៌ ១៥ យ៉ាង មានសីលជាដើម ដែលលោកពោលហើយ ក្នុងហេមវតសូត្រ ។ បទថា **ចរណេសុ** ជាសត្តមីវិភត្តិ ចុះក្នុងអត្ថតតិយាវិភត្តិ ។ បទថា **បត្តិបត្តោ** គឺសម្រេចធម៌ដែលគួរសម្រេច អធិប្បាយថា បុគ្គលណាសម្រេចអរហត្តដែលគួរសម្រេច ព្រោះមានចរណៈជានិមិត្ត មានចរណៈជាហេតុ មានចរណៈជាបច្ច័យ ។ បទថា **ចរណវា សោ** បុគ្គលនោះលោកពោលថា មានចរណៈ ព្រោះសម្រេចធម៌ដែលគួរសម្រេចនេះ ដោយចរណៈទាំងឡាយ ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ព្យាករបញ្ហាហើយ ។ បទដ៏សេស ជាពាក្យសរសើរបុគ្គលនោះ អធិប្បាយថា បុគ្គលណាក្នុងសាសនា ជាអ្នកសម្រេចធម៌ដែលគួរសម្រេច ព្រោះមានចរណៈ បុគ្គលនោះជាអ្នកឈ្លាស រមែងដឹងទូទៅដល់ធម៌ គឺនិព្វានសព្វកាល ព្រោះមានចិត្តបង្អោនទៅក្នុងនិព្វាននោះរឿយៗ មិនជាប់ជំពាក់ក្នុងធម៌ មានខន្ធជាដើម មានចិត្តផុតហើយ ដោយវិមុត្តិទាំង ២ និងមិនមានបដិឃៈ ។

បុគ្គលឈ្មោះថា ជាបរិព្វាជក ព្រោះបណ្តេញនូវកម្មជាដើមចេញបានដូច្នោះ កាលទ្រង់សម្តែងសេចក្តីនោះ ទើបទ្រង់ព្យាករបញ្ហាទី ៤ ដោយគាថាថា **ទុក្ខវេបក្កំ** ដូច្នេះជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះដូច្នេះ វិបាកនោះឯង ឈ្មោះថា **វេបក្កំ** ។ ដែលឈ្មោះថា **ទុក្ខវេបក្កំ** ព្រោះមានទុក្ខជាផល ។ កម្មក្នុងភពទាំង ៣ ព្រះ

មានព្រះភាគត្រាស់ថា ទុក្ខ ព្រោះធ្វើឲ្យកើតទុក្ខក្នុងបវត្តិកាល ។ បទថា **ឧទ្ធំ** គឺអតីត ។ បទថា **អធោ** គឺអនាគត ។ បទថា **តិរិយំ វាបិ មជ្ឈេ** គឺ បច្ចុប្បន្នកាល ។ ពាក្យថា បច្ចុប្បន្ននោះ លោកពោលថា ទទឹង ព្រោះមិនមែនខាងលើ មិនមែនខាងក្រោម លោកពោលថា កណ្តាល ក្នុងរវាងខាងលើ និងក្រោមទាំង ២ នោះ ។ បទថា **បរិញ្ញាជយិត្វា** គឺឲ្យបេញទៅកម្ចាត់ចេញ ។ បទថា **បរិញ្ញចារី** បានដល់ កំណត់ដោយបញ្ញាត្រាច់ទៅនេះត្រឹមតែជាពណ៌នាបទដែលមិនធ្លាប់មានមក តែដោយយោជនាអធិប្បាយបទនេះដូច្នេះថា បុគ្គលណាញ៉ាំងនូវការជាប់ជំពាក់ គឺតណ្ហា និងអវិជ្ជាឲ្យវិនស្ទួតទៅដោយអរិយមគ្គ បណ្តេញបង់នូវកម្មទាំងអស់ ដែលធ្វើឲ្យកើតទុក្ខទាក់ទងដោយកាល ៣ ដោយការធ្វើមិនឲ្យបដិសន្ធិ ម្យ៉ាងទៀត ព្រោះបណ្តេញទៅបានហើយ ឈ្មោះថា មានប្រក្រតីកំណត់ដោយបញ្ញា ព្រោះកំណត់កម្មនោះ មិនមែនកម្មតែម្យ៉ាងប៉ុណ្ណោះ សូម្បីកំណត់ការលះនូវធម៌ទាំងនេះ គឺមាយា មានះ លោភៈ កោធៈ ក៏ឈ្មោះថា ជាអ្នកកំណត់ដោយបញ្ញា បានធ្វើនាមរូបឲ្យដល់ទីបំផុត និងធ្វើទីបំផុតនៃនាមរូប គឺបណ្តេញទៅ ។ មានសេចក្តីដោយប្រការនេះឯង ។ លោកពោលបុគ្គលនោះថា ជាបរិព្វាជក ព្រោះបណ្តេញនូវកម្មជាដើមចេញទៅ ។ បទថា **បត្តិបត្តំ** នេះ ជាពាក្យសរសើរបុគ្គលនោះ ។

[ ៥៨ ] ក្នុងគាថាសរសើរថា **យានិ ច តីណិ** ជាដើម របស់សភិយបរិព្វាជក ដែលត្រេកអរដោយការព្យាករណ៍ក្នុងបញ្ហាយ៉ាងនេះ គប្បី

ជ្រាបអត្ថដូច្នេះ បទថា **ឱសរណានិ** បានដល់ ឈមចុះកាន់លទ្ធិ អធិប្បាយថា ទិដ្ឋិទាំងឡាយ ព្រោះទិដ្ឋិទាំងនោះ រួមគ្នាជា ៦៣ ព្រោះកាន់យកទិដ្ឋិ ៦២ ដែលពោលហើយក្នុងព្រហ្មជាលសូត្រ រួមជាមួយសក្កាយទិដ្ឋិ និងព្រោះទិដ្ឋិទាំងនោះ ជាវាទៈនៃសមណៈដែលជាតិរ្ថិយដទៃ អាស្រ័យគម្ពីរ ដោយការអាន មិនមែនដោយការកើត តែអាស្រ័យអក្ខរៈ គឺការសន្មត គឺមានឈ្មោះហៅថា ស្រី ប្រុស ដោយការកើត ។ សញ្ញាវិបរិត រមែងកើតដល់បុគ្គលពាលទាំងឡាយថា ខ្លួនគួរជាបុគ្គលបែបនេះ ដូច្នេះ ដោយមិច្ឆាបរិវិតក្ក ។ ទិដ្ឋិដែលអាស្រ័យទាំង ២ យ៉ាងនោះ រមែងកើតឡើងដោយអំណាចនៃសមណៈដែលជាតិរ្ថិយដទៃទាំងនោះ មិនមែនឃើញដោយខ្លួនឯង ព្រះមានព្រះភាគទ្រង់ឈានកន្លង គឺនាំចេញនូវទិដ្ឋិទាំងនោះ ទើបឈ្មោះថា ទ្រង់បានកន្លងផុតនូវងងឹត គឺឱឃៈ បានដល់ ទ្រង់ឈានកន្លង គឺចូងផុតងងឹត គឺឱឃៈហើយ ។ ម្យ៉ាងទៀត បាលីថា **ឱឃន្តមគ្គា** ក៏មាន ។ ទ្រង់ឈានកន្លងទីបំផុតនៃឱឃៈបានហើយ ព្រោះហេតុនោះ ទើបបរិព្វាជកពោលថា បពិត្រព្រះអង្គជាបុគ្គលមានប្រាជ្ញាស្មើដោយផែនដី ទិដ្ឋិទាំងឡាយ ៣ ណា និងទិដ្ឋិទាំងឡាយ ៦០ ណា ដែលអាស្រ័យនៅដោយវាទសាស្ត្រ ។បេ។ បានកន្លងផុតនូវងងឹត គឺឱឃៈ ។ បន្ទាប់អំពីនោះ សភិយបរិព្វាជកពោលថា **អន្តគូសិ បារគូ ទុក្ខស្ស** សំដៅដល់ទីបំផុត និងត្រើយនៃទុក្ខក្នុងវដ្តៈ គឺនិព្វាន ព្រោះមិនកើត ព្រោះមិនមានទុក្ខ និងព្រោះផុយគ្នានឹងទុក្ខក្នុងវដ្តៈនោះ ។ ម្យ៉ាងទៀត គួរជ្រាបការភ្ជាប់សេចក្តីត្រង់នេះថា ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា

ជាអ្នកដល់នូវត្រើយ ព្រោះដល់នូវព្រះនិព្វានហើយ សភិយបរិព្វាជក កាល ហៅព្រះអង្គ ទើបក្រាបទូលថា ព្រះអង្គជាអ្នកដល់នូវទីបំផុត ជាអ្នកដល់ នូវត្រើយនៃទុក្ខ គឺព្រះនិព្វាន ដូច្នេះ ។

ព្រះពុទ្ធទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ព្រោះត្រាស់ដឹងដោយប្រពៃ និងត្រាស់ដឹងឯង ។ បទថា **តំ មញ្ញេ** សេចក្តីថា អាចារ្យពួកខ្លះពោលដោយ ការគោរពក្រៃលែងថា ខ្ញុំព្រះអង្គសម្គាល់ទ្រង់ប៉ុណ្ណោះ មិនសម្គាល់អ្នកដទៃ ។ បទថា **ជុតិមា** គឺដល់ព្រមដោយពន្លឺផង ដោយកម្ចាត់ងងឹតរបស់អ្នកដទៃ ផង ។ បទថា **អតិមា** ប្រែថា មានការដឹង ដល់ព្រមដោយការដឹង គឺ បញ្ញា អាចដឹងនូវវត្ថុដែលគួរដឹងជាបច្ច័យនៃការដឹងដទៃៗ ។ បទថា **បហូតបញ្ញោ** គឺមានបញ្ញាមិនមានទីបំផុត ។ ក្នុងទីនេះ សំដៅដល់ សព្វញ្ញុតញ្ញាណ ។ សភិយបរិព្វាជក កាលនឹងទូលហៅ ទើបពោលពាក្យថា **ទុក្ខស្សន្តករំ** ដូច្នេះ ។ បទថា **អតារេសិ មំ** គឺញ៉ាំងខ្ញុំព្រះអង្គឲ្យឆ្លងចាក សេចក្តីសង្ស័យ ។

សភិយបរិព្វាជក ពោលដល់ការធ្វើនមស្ការ ដោយពោលកន្លះគាថា ថា **យំ មេ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **កង្ខិតំ** សភិយបរិព្វាជក ពោលសំដៅដល់អត្ថដែលទាក់ទងដោយបញ្ហា ២០ ។ ព្រោះសភិយបរិព្វាជកនោះ មានសេចក្តីសង្ស័យដោយសេចក្តីនោះ ។ បទថា **មោនបថេសុ** គឺក្នុងផ្លូវនៃញាណ ។ បទថា **ខិលក្ខិកតា** គឺធ្វើឲ្យប្រាសចាកកិលេស ដូច ដើមបបុស លោកអធិប្បាយថា កាត់ដាច់ហើយ ។ បទថា **ឆាគនាគស្ស**

នេះ ជាពាក្យហៅមួយបែប ។ គប្បីសម្ពន្ធដោយពាក្យនេះថា កាលព្រះមានព្រះភាគដ៏ប្រសើរកំពុងត្រាស់ ពួកទេវតារមែងសរសើរ ។ គប្បីបន្ថែមពាក្យថា **ធម្មទេសនំ** ចូលមក ។ បទថា **សព្វេ ទេវា** បានដល់ អាកាសដ្ឋទេវតា និងភុម្មដ្ឋទេវតា ។ បទថា **ឆារទបព្វតា** បានឮថា ពួកទេវតាទាំង ២ ពួកនោះ ជាអ្នកមានបញ្ញាញុំាងអនុមោទនា ព្រោះហេតុនោះ ទើបសភិយបរិព្វាជកពោលនមស្ការដោយជ្រះថ្លាបំផុត ។ សភិយបរិព្វាជក ស្តាប់សេចក្តីសម្បូរនៃព្យាករដែលសមគួរដល់អនុមោទនា ក៏ផ្គងអញ្ជលីពោលថា **នមោ តេ** ដូច្នេះ ។ បទថា **បុរិសាជញ្ញា** គឺបពិត្រព្រះអង្គដ៏ចម្រើន ទ្រង់សម្បូរដោយជាតិ ក្នុងបណ្តាបុរសទាំងឡាយ ។ បទថា **បដិបុគ្គលោ** បានដល់ បុគ្គលដែលមានចំណែកប្រៀបស្មើជាមួយព្រះអង្គ ។ ទ្រង់ឈ្មោះថា **ពុទ្ធោ** ព្រោះចាក់ធ្លុះអរិយសច្ច ៤ ឈ្មោះថា **សត្ថា** ព្រោះទ្រង់ទូន្មាន និងព្រោះជាអ្នកនាំពួក ។ ឈ្មោះថា **មារាភិភូ** ព្រោះគ្របសង្កត់នូវមារ ៤ ឈ្មោះថា **មុនិ** ព្រោះជាពុទ្ធមុនី ។ បទថា **ឧបធិ** បានដល់ ឧបធិ ៤ យ៉ាង គឺខន្ធ កិលេស កាមគុណ និងអភិសង្ខារ ។ បទថា **វគ្គុ** គឺមានរូបស្អាត ។ បទថា **បុញ្ញេ ច** បានដល់ បុណ្យដែលជាលោកិយ ទ្រង់មិនជាប់ក្នុងបុណ្យ និងបាប ព្រោះមិនធ្វើបុណ្យ និងបាបទាំងនោះខ្លះ ព្រោះមិនមានការសោយផលរបស់បុណ្យ និងបាបដែលធ្វើក្នុងកាលមុនតទៅខ្លះ ព្រោះគ្រឿងបូកលាប គឺតណ្ហា និងទិដ្ឋិ ដែលមានបុណ្យ និងបាបនោះជានិមិត្តខ្លះ ។ សភិយបរិព្វាជកពោលយ៉ាងនេះថា **វន្ទតិ សត្ថុនោ** ហើយក្រាបចុះត្រង់កព្រះបាទ

ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ។

[ ៥៩ ] បទថា **អញ្ញតិត្ថិយបុព្វោ** គឺអញ្ញតិត្ថិយនោះឯង ។ បទថា **អាកង្ខតិ** បានដល់ ប្រាថ្នា ។ បទថា **អារទ្ធចិត្តា** គឺត្រេកអរហើយ ។ បទថា **អបិច មេត្ថ បុគ្គលវេមត្តតា វិទិតា** សេចក្តីថា តថាគតដឹងនូវការផ្សេងគ្នានៃបុគ្គលក្នុងការនៅបរិវាសនេះរបស់តិរ្ថិយទាំងឡាយ មិនមែនគួរនៅបរិវាសទាំងអស់ ។ សួរថា នរណាមិនគួរនៅបរិវាស ឆ្លើយថា ជដិលបូជាភ្លើង និងស្តេចសក្យៈដោយជាតិ លះភេទមកហើយ ម្យ៉ាងទៀត បុគ្គលណាមិនទាន់លះភេទមក តែជាអ្នកសម្បូរដោយហេតុ ដើម្បីបានមគ្គ និងផលដូចសភិយបរិព្វាជកនោះ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលសភិយៈ សេចក្តីនោះ តថាគតដឹងហើយថា អ្នកមិនមានហេតុត្រូវនៅបរិវាសដើម្បីបំពេញវត្តរបស់តិរ្ថិយ អ្នកត្រូវការប្រយោជន៍ សម្បូរដោយហេតុដើម្បីបានមគ្គផល កាលទ្រង់អនុញ្ញាតឲ្យសភិយបរិព្វាជកបព្វជ្ជា ទើបត្រាស់ថាតែថា សេចក្តីផ្សេងគ្នានៃបុគ្គលក្នុងកិច្ចបរិវាសនោះ តថាគតដឹងច្បាស់ហើយដូច្នេះ ។ ឯសភិយបរិព្វាជក កាលសម្តែងសេចក្តីគោរពរបស់ខ្លួន ទើបក្រាបទូលថា **សចេ ភន្តេ** ដូច្នេះ ។ បទទាំងអស់ និងបទដទៃដែលមិនបានពណ៌នាក្នុងទីនេះ ព្រោះមានអត្ថងាយយល់ហើយ និងព្រោះមានន័យដូចបានពោលហើយខាងដើមនោះឯង គប្បីជ្រាបតាមន័យដែលពោលហើយ ។

## អដ្ឋកថា សភិយសូត្រទី ៦ ចប់

# សុត្តន្តបិដក

## សេលសូត្រទី៧

[ ៦០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងអង្គុត្តរាបជនបទ ជាមួយនឹងភិក្ខុសង្ឃច្រើនរូប គឺភិក្ខុមួយពាន់ពីររយហាសិប ( ១២៥០ ) យាងសំដៅទៅនិគមឈ្មោះអាបណៈ របស់ពួកអ្នកអង្គុត្តរាបជនបទ ។ កេណិយជដិល បានឮដំណឹងថា ព្រះសមណគោតម ជាសក្យបុត្ត ចេញចាកសក្យត្រកូល ទ្រង់ព្រះផ្នួស កំពុងធ្វើពុទ្ធដំណើរមកកាន់ចារិក ក្នុងអង្គុត្តរាបជនបទ ជាមួយនឹងភិក្ខុសង្ឃច្រើនរូប គឺភិក្ខុមួយពាន់ពីររយហាសិប មកដល់និគមឈ្មោះអាបណៈហើយ ។ កិត្តិសព្ទដ៏ពីរោះ របស់ព្រះគោតមដ៏ចម្រើននោះ ឮខ្ចរខ្ចាយសុសសាយយ៉ាងនេះថា ព្រះមានព្រះភាគនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ គឺសេចក្តីចេះដឹង និងក្រឹត្យ ដែលបុគ្គលគប្បីប្រព្រឹត្ត ព្រះអង្គមានដំណើរល្អទៅកាន់ព្រះនិព្វាន ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់កពថ្មីទៀត ព្រះមានព្រះភាគនោះ ព្រះអង្គបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ដោយព្រះអង្គ ហើយញ៉ាំងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញ៉ាំងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និង

មនុស្សដ៏សេសឲ្យត្រាស់ដឹងផង ព្រះអង្គទ្រង់សម្ដែងធម៌ពីរោះបទដើម បទកណ្ដាល និងបទចុង ព្រះអង្គប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈ ពេញបរិបូណ៌ បរិសុទ្ធទាំងអស់ ក៏ដំណើរបានឃើញ បានជួបនឹងព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងនោះ ជាការប្រពៃពេក ។ គ្រានោះកេណិយជដិល ចូលសំដៅ ទៅត្រង់ទីដែលព្រះមានព្រះភាគគង់ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះកេណិយជដិល អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់សម្ដែងពន្យល់ណែនាំ ធ្វើឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ។ លំដាប់នោះកេណិយជដិល ដែលព្រះមានព្រះភាគ ពន្យល់ណែនាំ ធ្វើឲ្យអាចហ៊ានឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រាបទូលនិមន្តព្រះមានព្រះភាគ យ៉ាងនេះថា សូមព្រះគោតមដ៏ចម្រើន ព្រមទាំងភិក្ខុសង្ឃ ទទួលចង្ហាន់របស់ខ្ញុំព្រះអង្គ ក្នុងថ្ងៃស្អែកឲ្យទាន ។

[ ៦១ ] កាលដែលកេណិយជដិលក្រាបទូលយ៉ាងនេះហើយ ព្រះអង្គទ្រង់ត្រាស់នឹងកេណិយជដិលដូច្នេះថា ម្នាលកេណិយៈ ភិក្ខុសង្ឃច្រើនណាស់ គឺភិក្ខុមួយពាន់ពីររយហាសិប អ្នកសោតក៏ជាប់ជ្រះថ្លាក្នុងពួកព្រាហ្មណ៍ហើយ ។ កេណិយជដិល ទូលព្រះមានព្រះភាគ អស់វារៈពីរដងយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ភិក្ខុសង្ឃច្រើនរូប គឺភិក្ខុមួយពាន់ពីររយហាសិប ខ្ញុំព្រះអង្គសោត ជាអ្នកជាប់ជ្រះថ្លាក្នុងពពួកព្រាហ្មណ៍ក៏ពិតមែន តែថា សូម

ព្រះគោតមដ៏ចម្រើន ព្រមទាំងភិក្ខុសង្ឃ ទទួលចង្ហាន់របស់ខ្ញុំព្រះអង្គ ក្នុងថ្ងៃស្អែកឲ្យទាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងកេណិយជដិល អស់វារៈពីរដងយ៉ាងនេះថា ម្នាលកេណិយៈ ភិក្ខុសង្ឃច្រើន គឺភិក្ខុមួយពាន់ពីររយហាសិប អ្នកសោត ជាអ្នកជ្រាប់ជ្រះថ្លាក្នុងពួកព្រាហ្មណ៍ហើយ ។ កេណិយ-ជដិលទូលព្រះមានព្រះភាគ អស់វារៈ ៣ ដងយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ភិក្ខុសង្ឃច្រើនរូប គឺភិក្ខុមួយពាន់ពីររយហាសិប ខ្ញុំព្រះអង្គសោតជាអ្នកជ្រាប់ជ្រះថ្លាក្នុងពួកព្រាហ្មណ៍ក៏ពិតមែន តែថា សូមព្រះគោតមដ៏ចម្រើនព្រមទាំងភិក្ខុសង្ឃ ទទួលចង្ហាន់របស់ខ្ញុំព្រះអង្គ ក្នុងថ្ងៃស្អែកឲ្យទាន ។ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ លំដាប់នោះ កេណិយ-ជដិលដឹងច្បាស់នូវការទទួលនិមន្ត របស់ព្រះមានព្រះភាគហើយ ក៏ក្រោកចាកអាសនៈ ចូលសំដៅទៅត្រង់អាស្រមរបស់ខ្លួន លុះចូលទៅដល់ហើយក៏ប្រាប់ពួកមិត្តអាមាត្យ និងញាតិសាលោហិតថា ពួកមិត្តអាមាត្យ និងញាតិសាលោហិតដ៏ចម្រើន ចូរស្តាប់ពាក្យខ្ញុំ ព្រោះខ្ញុំបាននិមន្តព្រះសមណគោតមព្រមទាំងភិក្ខុសង្ឃ ដើម្បីចង្ហាន់ក្នុងថ្ងៃស្អែក អ្នកទាំងឡាយ ត្រូវជួយធ្វើការខ្វល់ខ្វាយ ដោយកាយដល់ខ្ញុំ ។ ពួកមិត្តអាមាត្យ និងញាតិសាលោហិតរបស់កេណិយជដិលក៏ទទួលស្តាប់ពាក្យកេណិយជដិលថា អើលោក ពួកខ្លះ ជីកចង្ក្រាន ជីកគុក ពួកខ្លះ ពុះឧស ពួកខ្លះ លាងភាជន៍ ពួកខ្លះ តម្កល់ពាងទឹក ពួកខ្លះ ក្រាលអាសនៈ ឯកេណិយជដិល ក៏ចាត់ចែងបារាំដោយខ្លួនឯង ។

[ ៦២ ] សម័យនោះឯង សេលព្រាហ្មណ៍ នៅអាស្រ័យក្នុងនិគមឈ្មោះ

អាបណៈ ជាអ្នកដល់នូវត្រើយនៃវេទ ៣ ព្រមទាំងគម្ពីរឈ្មោះនិឃណ្ឌុ និង គម្ពីរឈ្មោះកេដុភៈ និងអក្ខរប្បភេទ មានគម្ពីរឈ្មោះឥតិហាសជាគម្រប់៥ ជាអ្នករៀននូវបទ ចេះព្យាករណ៍ មិនទើសទាល់ក្នុងលោកាយតសាស្រ្ត និង មហាបុរិសលក្ខណសាស្រ្ត បង្រៀនមន្តទាំងឡាយ ដល់មាណពបីរយនាក់ ។ សម័យនោះឯង កេណិយជដិល ក៏ជាអ្នកជាប់ជ្រះថ្លាក្នុងសេលព្រាហ្មណ៍ដែរ ។ គ្រានោះឯង សេលព្រាហ្មណ៍ មានមាណពបីរយចោមរោម ត្រាច់ដើរទៅមក សម្រាកស្មង រួចក៏ចូលសំដៅទៅត្រង់អាស្រមកេណិយជដិល ។ សេល-ព្រាហ្មណ៍ បានឃើញមនុស្សពួកខ្លះ កំពុងជីកចង្ក្រាន ជីកគុក ទៀបអាស្រម កេណិយជដិល ។បេ។ មនុស្សពួកខ្លះ កំពុងក្រាលអាសនៈ ទាំងកេណិយ-ជដិល ក៏កំពុងចាត់ចែងបាកំដោយខ្លួនឯង លុះឃើញហើយ ក៏សួរកេណិយ-ជដិលយ៉ាងនេះថា កេណិយៈដ៏ចម្រើន នឹងមានកិច្ចអាវាហៈ ឬវិវាហៈ ឬរៀបចំ មហាយញ្ញ ឬក៏អញ្ជើញព្រះបាទពិម្ពិសារមាគធសេនិយៈ ព្រមទាំងពួកពល ដើម្បីជប់លៀង ក្នុងថ្ងៃស្អែកឬហ្ន៎ ។ បពិត្រសេលព្រាហ្មណ៍ដ៏ចម្រើន អាត្មា មិនមានកិច្ចអាវាហៈ មិនមានកិច្ចវិវាហៈទេ ទាំងមិនបានអញ្ជើញព្រះបាទ ពិម្ពិសារមាគធសេនិយៈ ព្រមទាំងពួកពល ដើម្បីជប់លៀងក្នុងថ្ងៃស្អែកទេ ។ ប៉ុន្តែ អាត្មាមានការរៀបចំមហាយញ្ញ ព្រះសមណគោតមជាសក្យបុត្ត ចេញចាកសក្យត្រកូល ទ្រង់ព្រះផ្នួស ធ្វើពុទ្ធដំណើរមកកាន់ចារិក ក្នុងអង្គុត្តរាប-ជនបទ ជាមួយនឹងភិក្ខុសង្ឃជាច្រើនរូប គឺភិក្ខុមួយពាន់ពីររយហាសិប យាង មកដល់អាបណៈនិគមហើយ កិត្តិសព្ទដ៏ពីរោះ របស់ព្រះគោតមដ៏ចម្រើននោះ

ព្ធួរខ្ចាយសុសសាយយ៉ាងនេះថា ព្រះមានព្រះភាគនោះ ។បេ។ ព្រះអង្គបាន ត្រាស់ដឹងនូវសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់ មកកាន់ភពថ្មីទៀត ។ អាត្មា បាននិមន្តព្រះសមណគោតមនោះ ព្រមទាំងភិក្ខុសង្ឃ ដើម្បីចង្ហាន់ក្នុងថ្ងៃស្អែក ។ បពិត្រកេណិយៈដ៏ចម្រើន លោកនិយាយថាព្រះពុទ្ធឬ ម្នាលសេលព្រាហ្មណ៍ ដ៏ចម្រើន អាត្មានិយាយថាព្រះពុទ្ធ ។ បពិត្រកេណិយៈដ៏ចម្រើន លោកនិយាយ ថាព្រះពុទ្ធឬ ។ ម្នាលសេលព្រាហ្មណ៍ដ៏ចម្រើន អាត្មានិយាយថាព្រះពុទ្ធ ។ គ្រានោះ សេលព្រាហ្មណ៍ មានសេចក្តីត្រិះរិះយ៉ាងនេះថា សំឡេងគឹកកងថា ពុទ្ធៈនេះ គេរកបានដោយក្រក្នុងលោក ។ មហាបុរិសលក្ខណៈ ៣២ ប្រការ មានមកហើយក្នុងមន្តទាំងឡាយរបស់យើង មហាបុរស ដែលប្រកបដោយ មហាបុរិសលក្ខណៈទាំងនោះ រមែងមានគតិពីរយ៉ាង មិនប្លែកអំពីនេះទេ គឺ នៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិ ព្រះអង្គជាធម្មិកធម្មរាជ ជាឥស្សរៈ លើផែនដី ប្រដាប់ដោយទ្វីប ៤ មានសមុទ្រទាំង ៤ ជាទីបំផុត ទ្រង់មាន ជ័យជម្នះ ខាងក្នុង និងខាងក្រៅ ដល់នូវភាពមាំមួនក្នុងជនបទ ទ្រង់បរិបូណ៌ ដោយរតនៈ ៧ ប្រការ ឯរតនៈ ៧ ប្រការ របស់ស្តេចចក្រពត្តិនោះ គឺ ចក្ករតនៈ ១ ហត្ថិរតនៈ ១ អស្សរតនៈ ១ មណិរតនៈ ១ ឥត្ថីរតនៈ ១ គហបតិរតនៈ ១ បរិនាយករតនៈ ១ រួមត្រូវជា ៧ ប្រការ ។ ឯស្តេច ចក្រពត្តិនោះ មានព្រះរាជបុត្តច្រើនពាន់ ប្រកបដោយជាតិដ៏ថ្លៃថ្លា សុទ្ធសឹង តែក្លៀវក្លា មានរូបឆោមល្អ អាចសង្កត់សង្កិននូវសេនារបស់ស្តេចដទៃបាន ។ ស្តេចចក្រពត្តិនោះ ទ្រង់ត្រួតត្រា គ្រប់គ្រងផែនដីនេះ មានសាគរជាព្រំប្រទល់

ដោយធម៌ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រាវុធ ( នេះ ១ ) ។ ប្រសិនបើចេញចាករាជដំណាក់ ទៅទ្រង់ព្រះផ្នួស នឹងបានជាអរហន្តសម្មាសម្ពុទ្ធក្នុងលោក មានដំបូលផុះ គឺកិលេសបើកហើយ ( ១ ) ។ សេលព្រាហ្មណ៍បានសួរថា ម្នាលកេណិយៈដ៏ចម្រើន ចុះឥឡូវនេះ ព្រះគោតមដ៏ចម្រើន ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គគង់នៅក្នុងទីណា ។

[ ៦៣ ] កាលសេលព្រាហ្មណ៍ និយាយយ៉ាងនេះ កេណិយជដិលក៏ផ្គងដៃខាងស្តាំ និយាយនឹងសេលព្រាហ្មណ៍ យ៉ាងនេះថា ម្នាលសេលព្រាហ្មណ៍ដ៏ចម្រើន ជួរនៃព្រៃខៀវៗ នុ៎ះ មានក្នុងចំណែកទិសណា ( ព្រះអង្គគង់ក្នុងចំណែកទិសនោះ ) ។ លំដាប់នោះ សេលព្រាហ្មណ៍ ព្រមទាំងមាណព ៣០០ នាក់ ចូលសំដៅទៅត្រង់កន្លែងដែលព្រះមានព្រះភាគគង់ ។ លំដាប់នោះ សេលព្រាហ្មណ៍ ប្រាប់ពួកមាណពទាំងនោះថា អ្នកដ៏ចម្រើនទាំងឡាយ ចូរនិយាយគ្នាតិចៗ ចូរដើរដាក់ជើងជិតជើង ( ដើរសន្សឹមៗ ) ព្រោះលោកដ៏ចម្រើនទាំងនោះ មកអំពីចម្ងាយ ដើរតែម្នាក់ឯងដូចសីហៈ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ទម្រាំអញប្រឹក្សានឹងព្រះសមណគោតមសិន ម្នាលអ្នកដ៏ចម្រើនទាំងឡាយ អ្នកទាំងឡាយកុំស្កាត់សម្តីអញ ត្រង់ចន្លោះៗ ឡើយ អ្នកដ៏ចម្រើនទាំងឡាយ ចូររង់ចាំនូវទីបំផុតនៃពាក្យអញសិន ។ លំដាប់នោះ សេលព្រាហ្មណ៍ចូលសំដៅទៅត្រង់កន្លែងដែលព្រះមានព្រះភាគគង់ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ សេលព្រាហ្មណ៍

លុះអង្គុយក្នុងទីសមគួរហើយ ក៏ពិនិត្យមើលមហាបុរិសលក្ខណៈ ៣២ ប្រការ ក្នុងព្រះកាយរបស់ព្រះមានព្រះភាគ ។ សេលព្រាហ្មណ៍ បានឃើញនូវមហា-បុរិសលក្ខណៈ ៣២ ប្រការក្នុងព្រះកាយ របស់ព្រះមានព្រះភាគដោយច្រើន លើកលែងតែមហាបុរិសលក្ខណៈពីរប្រការ ក៏សង្ស័យងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនយល់ច្បាស់ ក្នុងមហាបុរិសលក្ខណៈ ២ ប្រការ គឺវត្ថគុយ្ហប្រទេស ដែលស្រោបដោយស្រោម ១ ព្រះជិវ្ហាល្វន់ល្វៃ ១ ។ គ្រានោះ ព្រះមានព្រះភាគ មានព្រះតម្រិះយ៉ាងនេះថា សេលព្រាហ្មណ៍ ឃើញតែមហាបុរិស-លក្ខណៈ ៣២ ប្រការ របស់តថាគតដោយច្រើន លើកលែងតែមហាបុរិស-លក្ខណៈ ២ ប្រការ ក៏សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនយល់ច្បាស់ ក្នុងមហាបុរិសលក្ខណៈ ២ ប្រការ គឺវត្ថគុយ្ហប្រទេស ដែលស្រោបដោយស្រោម ១ ព្រះជិវ្ហាល្វន់ល្វៃ ១ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់និម្មិតរូបដែលតាក់តែងដោយឫទ្ធិ មានទំនងល្មមឲ្យសេលព្រាហ្មណ៍ ឃើញបាននូវគុយ្ហប្រទេស ដែលស្រោបដោយស្រោមរបស់ព្រះអង្គ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់លៀនព្រះជិវ្ហា ហើយមូរស៊កតាមរន្ធនៃព្រះកាណ៌ទាំងពីរផង មូរស៊កតាមរន្ធនៃព្រះនាសិកទាំងពីរផង បិទបាំងនូវមណ្ឌលនៃនលាដទាំងអស់ដោយព្រះជិវ្ហាផង ។ លំដាប់នោះ សេលព្រាហ្មណ៍ មានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះសមណគោតមប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ គ្រប់គ្រាន់ មិនមែនមិនគ្រប់គ្រាន់ទេ ប៉ុន្តែ អញមិនទាន់ស្គាល់នូវលោកថា ជាព្រះពុទ្ធ ឬមិនមែនព្រះពុទ្ធ ។ ប៉ុន្តែ អញបានឮពាក្យ របស់ព្រាហ្មណ៍ចាស់ទុំ

មានអាយុច្រើន ជាអាចារ្យ ប្រធានលើអាចារ្យនិយាយថា ពួកជនណា ជាអរហន្តសម្មាសម្ពុទ្ធដ៏មានព្រះភាគ ពួកជននោះ កាលបើត្រូវគេថ្លែងគុណជារបស់ខ្លួន រមែងសម្ដែងខ្លួនឲ្យប្រាកដ បើដូច្នោះ គួរតែអញសរសើរព្រះសមណគោតម ក្នុងទីចំពោះព្រះភក្ត្រ ដោយសារុប្បគាថាចុះ ។ លំដាប់នោះ សេលព្រាហ្មណ៍សរសើរព្រះមានព្រះភាគ ក្នុងទីចំពោះព្រះភក្ត្រដោយសារុប្បគាថាដូច្នេះថា

ព្រះអង្គជាបុគ្គល មានព្រះកាយបរិបូណ៌ មានពន្លឺសរីរៈល្អ មានព្រះជាតិល្អ មានការមៀងមើលល្អ ព្រះមានព្រះភាគមានសម្បុរដូចជាមាស មានព្រះទាឋាសសុទ្ធ មានព្យាយាម ព្រោះថា មហាបុរិសលក្ខណៈទាំងអស់នោះ មានប្រាកដក្នុងព្រះកាយរបស់ព្រះអង្គ ដែលជាជនមានកំណើតល្អ ។ ព្រះអង្គមានព្រះនេត្រថ្លា មានព្រះភក្ត្រល្អ មានព្រះកាយសមរម្យ ( ទាំងកម្ពស់ និងទំហំ ) មានព្រះកាយត្រង់ មានរស្មីរុងរឿង ក្នុងកណ្ដាលនៃពួកសមណៈ ដូចព្រះអាទិត្យ ។ ព្រះអង្គជាភិក្ខុ អ្នកមៀងមើលល្អ មានព្រះតចោភ្លឺថ្លាដូចមាស ប្រយោជន៍អ្វីដោយភាពជាសមណៈ ដល់ព្រះអង្គ ដែលមានសម្បុរដ៏ឧត្តមយ៉ាងនេះ ។ ព្រះអង្គគួរជាស្ដេចចក្រពត្តិ ជាឧសភក្នុងរថ ជាឥស្សរៈលើផែនដី ប្រដាប់ដោយទ្វីប ៤ មានសមុទ្រទាំង ៤ ជាទីបំផុត មានជ័យជម្នះទាំងខាងក្នុង និងខាងក្រៅ ជាឥស្សរៈរបស់ជម្ពូ-

ទ្វីប ក្សត្រទាំងឡាយជាស្តេចបម្រើ ចុះបូលព្រះអង្គ បពិត្រព្រះគោតម ព្រះអង្គជាស្តេច ដែលពួកស្តេចគោរពបូជា ជាធំជាងពួកមនុស្ស សូមសោយរាជ្យទៅវិញ ។

[ ៦៤ ] ( ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ) ម្នាលសេលៈ តថាគតជាស្តេចធម្មរាជ ជាបុគ្គលប្រសើរ ញ៉ាំងចក្កឲ្យប្រព្រឹត្តទៅដោយធម៌ ជាចក្កដែលអ្នកណាមួយ ឲ្យប្រព្រឹត្តទៅមិនបាន ។

( សេលព្រាហ្មណ៍ និយាយថា ) ព្រះអង្គប្តេជ្ញាជាព្រះសម្ពុទ្ធ ជាធម្មរាជ ជាបុគ្គលប្រសើរ បពិត្រព្រះគោតមដ៏ចម្រើន ព្រះអង្គត្រាស់ថា តថាគត ញ៉ាំងចក្កឲ្យប្រព្រឹត្តទៅដោយធម៌ ចុះសាវ័កណាជាសេនាបតី ជាអ្នកប្រព្រឹត្តតាមព្រះសាស្តាដ៏ចម្រើន សាវ័កណា ញ៉ាំងធម្មចក្កជាកេរដំណែលរបស់ព្រះអង្គនេះ ឲ្យប្រព្រឹត្តទៅបាន ។

( ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសេលៈ ) សារីបុត្តជាអនុជាត ញ៉ាំងធម្មចក្កជាចក្កដ៏ប្រសើរ ដែលតថាគតឲ្យប្រព្រឹត្តទៅហើយ ( នោះ ) ឲ្យប្រព្រឹត្តតាមតថាគត ។ វិជ្ជា និងវិមុត្តិ ដែលគប្បីដឹងច្បាស់ តថាគតដឹងច្បាស់ហើយ មគ្គសច្ចដែលគប្បីចម្រើន តថាគតបានចម្រើនហើយ សមុទយសច្ចដែលគប្បីលះ តថាគតលះបង់ហើយ ម្នាលព្រាហ្មណ៍ ព្រោះ

ហេតុនោះ ទើបតថាគតឈ្មោះថាពុទ្ធ: ម្នាលព្រាហ្មណ៍ អ្នកចូរកម្ចាត់សេចក្ដីសង្ស័យ ចូរជឿស៊ប់ចំពោះតថាគតចុះ ការបានជួបប្រទះនឹងព្រះសម្ពុទ្ធទាំងឡាយរឿយៗ ជាការបានដោយក្រ ។

ការកើតឡើងនៃព្រះសម្ពុទ្ធ ក្នុងលោករឿយៗ ជាការបានដោយក្រ ម្នាលព្រាហ្មណ៍ តថាគតនោះ ជាអ្នកត្រាស់ដឹង ជាអ្នកកាត់នូវសរ គឺរាគាទិក្កិលេស ជាបុគ្គលប្រសើរ ។

តថាគតជាបុគ្គលប្រសើរ កន្ទេងនូវសេចក្ដីប្រៀបផ្ទឹម ញាំញីនូវមារសេនា ឥតមានភ័យអំពីទីណាឡើយ រមែងរីករាយព្រោះបានធ្វើសត្រូវទាំងអស់ ឲ្យលុះក្នុងអំណាច ។

( សេលព្រាហ្មណ៍ និយាយថា ) ម្នាលអ្នកដ៏ចម្រើនទាំង-ឡាយ ព្រះពុទ្ធអ្នកមានចក្ខុ ទ្រង់កាត់នូវសរ គឺរាគាទិក្កិលេស ជាមហាវីរបុរស ដូចជាសីហៈបន្លឺក្នុងព្រៃ សម្ដែងយ៉ាងណា អ្នកទាំងឡាយ ចូរស្ដាប់នូវពាក្យនេះ យ៉ាងនោះចុះ ។

បុគ្គលណាឃើញព្រះសម្ពុទ្ធ ជាបុគ្គលប្រសើរ កន្ទេងនូវសេចក្ដីប្រៀបផ្ទឹម ញាំញីនូវមារសេនា ហើយមិនគប្បីជ្រះថ្លា សូម្បីកណ្ហាភិជាតិកជន ( ជនកើតក្នុងត្រកូលថោកទាប មានត្រកូលចណ្ឌាលជាដើម ក៏ជ្រះថ្លាដែរ ) ។

អ្នកណា ចង់ ( បួស ) ចូរមកតាមខ្ញុំ អ្នកណា មិនចង់ ចូរ

ទៅវិញចុះ ខ្ញុំនឹងបួសក្នុងសម្នាក់ព្រះពុទ្ធ មានប្រាជ្ញាដ៏ប្រសើរ ក្នុងទីនេះ ។

( ពួកមាណពនិយាយថា ) បើលោកដ៏ចម្រើន គាប់ចិត្ត នឹងសាសនា របស់ព្រះសម្មាសម្ពុទ្ធយ៉ាងនេះ ពួកយើងក៏នឹង បួសក្នុងសម្នាក់ព្រះពុទ្ធ មានប្រាជ្ញាដ៏ប្រសើរដែរ ។

( សេលព្រាហ្មណ៍និយាយថា ) ពួកព្រាហ្មណ៍ទាំង ៣ រយ នាក់ទាំងនេះ ប្រណមអញ្ជលី សូម ( ផ្នួស ) បពិត្រព្រះមាន ព្រះភាគ ពួកយើងនឹងប្រព្រឹត្តព្រហ្មចារ្យក្នុងសម្នាក់ព្រះអង្គ ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសេលៈ ) បព្វជ្ជា របស់កុលបុត្ត អ្នកមិនធ្វេសប្រហែស កាលសិក្សា ជាគុណ-ជាតិមិនឥតអំពើ ក្នុងព្រហ្មចរិយធម៌ណា ព្រហ្មចរិយធម៌នោះ តថាគតសម្តែងទុកល្អហើយ ជាគុណឲ្យផលជាក់ច្បាស់ មិន កំណត់កាល ។

[ ៦៥ ] សេលព្រាហ្មណ៍ ព្រមទាំងបរិស័ទ ក៏បានបព្វជ្ជា បានឧប-សម្បទា ក្នុងសម្នាក់នៃព្រះមានព្រះភាគ ។ លំដាប់នោះ លុះកន្លងរាត្រីនោះ ហើយ កេណិយជដិល ក៏ឲ្យតាក់តែងខាទនីយភោជនីយាហារ ដ៏ផ្ចិតផ្ចង់ក្នុង អាស្រមរបស់ខ្លួន ហើយឲ្យក្រាបទូលភត្តកាល ដល់ព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន កាលគួរហើយ ភត្តសម្រេចហើយ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រ ចីវរ ក្នុងបុព្វណ្ហសម័យ ហើយទ្រង់

យានសំដៅចូលទៅ ឯអាស្រមកេណិយជដិល លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ព្រមទាំងភិក្ខុសង្ឃ ។ គ្រានោះ កេណិយ-ជដិល បានអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយខាទនីយភោជនី-យាហារ ដ៏ផ្ចិតផ្ចង់ដោយដៃខ្លួនឯង ឲ្យឆ្អែតស្កប់ស្កល់ ទាល់តែហាមឃាត់ ។ លំដាប់នោះ កេណិយជដិល ( បានចូលទៅគាល់ ) ព្រះមានព្រះភាគ ដែលទ្រង់សោយកត្តរួចហើយ មានព្រះហស្តដាក់ចេញពីបាត្រហើយ រួចក៏កាន់យកអាសនៈ ១ ដ៏ទាប អង្គុយក្នុងទីសមគួរ ។ កាលដែលកេណិយជដិល អង្គុយស៊ប់ក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់អនុមោទនា ដោយគាថាទាំងនេះថា

> ការបូជាទាំងឡាយ មានការបូជាភ្លើងជាប្រធាន គម្ពីរសាវិត្តិ-
> សាស្ត្រជាប្រធាន នៃគម្ពីរឆន្ទសាស្ត្រ ព្រះរាជាជាប្រធាននៃ
> មនុស្សទាំងឡាយ សាគរជាប្រធាននៃទន្លេទាំងឡាយ ។ ព្រះ
> ចន្ទ្រជាប្រធាននៃផ្កាយទាំងឡាយ ព្រះអាទិត្យជាប្រធាននៃ
> កម្តៅទាំងឡាយ ( យ៉ាងណាមិញ ) ព្រះសង្ឃជាប្រធាននៃ
> ជនទាំងឡាយ កាលបូជាប្រាថ្នានូវបុណ្យ ក៏យ៉ាងនោះដែរ ។

[ ៦៦ ] គ្រានោះ ព្រះមានព្រះភាគ លុះទ្រង់អនុមោទនា ចំពោះកេណិយជដិល ដោយគាថាទាំងនេះហើយ ទ្រង់ក្រោកចាកអាសនៈ យាងចៀសចេញទៅ ។ លំដាប់នោះ ព្រះសេលៈដ៏មានអាយុ ព្រមទាំងបរិស័ទគេចចេញទៅ ( ចាកពួក ) តែម្នាក់ឯងៗ ជាអ្នកមិនប្រមាទ មានព្យាយាម

មានចិត្តស្ទុងទៅ ( កាន់ព្រះនិព្វាន ) កុលបុត្តទាំងឡាយ ចេញចាកផ្ទះចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរយារប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវអនុត្តរធម៌នោះ ជាទីបំផុតនៃព្រហ្មចរិយៈ ដោយប្រាជ្ញាដ៏ប្រសើរ ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈ អាត្មាអញប្រព្រឹត្តចប់ហើយ សោឡសកិច្ចដែលគួរធ្វើ អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះសេលៈដ៏មានអាយុ ព្រមទាំងបរិស័ទ ក៏រាប់ថាជាព្រះអរហន្តមួយរូបដែរ ។ គ្រានោះ ព្រះសេលៈដ៏មានអាយុ ព្រមទាំងបរិស័ទ ចូលសំដៅទៅត្រង់ទីដែលព្រះមានព្រះភាគគង់ លុះចូលទៅដល់ហើយ ធ្វើចីវរឆៀងស្មាម្ខាង រួចប្រណមអញ្ជលីទៅ ត្រង់ទីដែលព្រះមានព្រះភាគគង់ ហើយបានទូលព្រះមានព្រះភាគដោយគាថាដូច្នេះថា

បពិត្រព្រះមានព្រះភាគ ទ្រង់មានចក្ខុ ពួកយើងបានដល់នូវព្រះអង្គជាទីពឹង ក្នុងថ្ងៃទី ៨ អំពីថ្ងៃនេះ ជាបុគ្គលរៀបរយហើយក្នុងសាសនារបស់ព្រះអង្គ ដោយកាលត្រឹមតែ ៧ រាត្រី ។ ព្រះអង្គជាអ្នកត្រាស់ដឹង ព្រះអង្គជាសាស្តាចារ្យ ព្រះអង្គជាអ្នកគ្របសង្កត់នូវមារ ជាអ្នកប្រាជ្ញ ព្រះអង្គកាត់បង់នូវអនុសយក្កិលេស ឆ្លងចាកកិលេសបានហើយ ចម្លងពួកសត្វនេះ ព្រះអង្គបានកន្លងផុតឧបធិហើយ ព្រះអង្គបានទម្លាយអាសវៈ

ហើយ ព្រះអង្គជាបុគ្គលដូចសីហៈ មិនមានឧបាទាន បានលះបង់ភ័យ និងសេចក្ដីស្ញប់ស្ញែងហើយ បពិត្រព្រះអង្គជាវីរបុរស ពួកភិក្ខុទាំង ៣០០ រូបនេះ ធ្វើអញ្ជលី ( ចំពោះព្រះអង្គ ) សូមព្រះអង្គសណ្ដូកព្រះបាទទាំងគូ ពួកភិក្ខុដ៏ប្រសើរ សូមថ្វាយបង្គំព្រះបាទទាំងគូ របស់ព្រះសាស្ដា ។

សេលសូត្រទី ៧ ចប់

# អដ្ឋកថា

## សេលសូត្រ

[ ៦០ ] ក្នុងសេលសូត្រទី ៧ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះ ។

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា អត្ថុប្បត្តិហេតុ លោកពោលក្នុងនិទាននៃសូត្រនោះឯង ។ ក្នុងលំដាប់ពណ៌នាសេចក្ដីនៃសូត្រនេះ ក៏ដូចគ្នានឹងសូត្រមុន គប្បីជ្រាបដោយន័យដែលពោលហើយក្នុងសូត្រមុននោះឯង ។ បទណាដែលមិនទាន់បានពោល ខ្ញុំនឹងចៀសវាងបទទាំងឡាយ ដែលមានអត្ថងាយយល់ ពណ៌នាបទនោះ ។

បទថា **អង្គុត្តរាបេសុ** បានដល់ ជនបទអង្គានោះឯង ដែលមានត្រពាំងទឹកនៅទិសខាងជើងនៃស្ទឹងគង្គា លោកហៅថា ឧត្តរាបៈក៏មាន ព្រោះនៅមិនឆ្ងាយអំពីត្រពាំងទឹកនោះ សួរថា ត្រពាំងទឹកនៅទិសខាងជើងនៃស្ទឹង

គង្គាមួយណា ឆ្លើយថា ស្ទឹងគង្គាដែលឈ្មោះថា មហាមហី ។ ដើម្បីការជាក់ច្បាស់នៃស្ទឹងនោះ ក្នុងសូត្រនេះ នឹងពណ៌នាលំនាំដើមដូចតទៅនេះ

បានឮមកថា ជម្ពូទ្វីបនេះ មានប្រមាណមួយម៉ឺនយោជន៍ ។ ក្នុងជម្ពូទ្វីបនោះ ផ្ទៃដីប្រមាណ ៤ ពាន់យោជន៍ គ្របដណ្តប់ដោយទឹក ហៅថា សមុទ្រ ពួកមនុស្សអាស្រ័យក្នុងផ្ទៃដីប្រមាណ ៣ ពាន់យោជន៍ មានភ្នំហិមពាន្តតាំងនៅលើផ្ទៃដី ៣ ពាន់យោជន៍ កម្ពស់ប្រមាណ ៥ រយយោជន៍ ប្រដាប់ដោយកំពូល ៨៤០០០ កំពូល វិចិត្រទៅដោយស្ទឹងធំ ៥ ខ្សែ មានបរិវេណជុំវិញ ១៥០ កន្ទែង មួយកន្ទែងៗ បណ្តោយទទឹង និងជម្រៅ ១ រយយោជន៍ មានស្រះធំ ៧ មានអនោតត្តស្រះជាដើមតាំងនៅ ដូចបានពោលហើយ ក្នុងអដ្ឋកថាសុន្ទរិកសូត្រ ។

ក្នុងស្រះ ៧ នោះ អនោតត្តស្រះមានភ្នំ ៥ នៅជុំវិញ គឺសុទស្សនកូដ ចិត្តកូដ កាឡកូដ គន្ធមាទនកូដ កៃលាសកូដ ។ ក្នុងភ្នំ ៥ នោះ សុទស្សនកូដជាវិការនៃមាស កម្ពស់ ២០០ យោជន៍ ខាងក្នុងកោង មានសណ្ឋានដូចចំពុះក្អែកព័ទ្ធស្រះនោះ ចិត្តកូដជាវិការនៃរតនៈទាំងពួង កាឡកូដសម្រេចដោយព្រៃអញ្ជន គន្ធមាទនកូដសម្រេចដោយកែវមក៌ត ខាងក្នុងមានពណ៌ដូចសណ្តែកបាយ ដេរដាសទៅដោយឱសថច្រើនយ៉ាង ក្នុងថ្ងៃឧបោសថខាងខ្នោច មានពន្លឺដូចរងើកភ្លើង ។ កៃលាសកូដសម្រេចដោយប្រាក់ ភ្នំទាំងនេះ កម្ពស់ស្មើនឹងភ្នំសុទស្សនកូដ ព័ទ្ធជុំវិញស្រះនោះ ។ ភ្លៀងធ្លាក់គ្រប់ភ្នំ ដោយអានុភាពរបស់ទេវតា និងអានុភាពរបស់នាគ ។ម្យ៉ាងទៀត ស្ទឹងហូរ

ចូលទៅក្នុងភ្នំទាំងនោះ ។ ទឹកទាំងអស់ក៏ហូរទៅកាន់អនោតត្តស្រះ ។ ព្រះចន្ទ និងព្រះអាទិត្យ គោចរខាងត្បូង ឬខាងជើង ធ្វើឲ្យស្រះនោះបាននូវពន្លឺ ដែលចាំងត្រង់ចន្លោះភ្នំ បើគោចរពីលើ មិនបានទទួលពន្លឺឡើយ ព្រោះហេតុនោះទើបស្រះនោះ ឈ្មោះអនោតត្តៈ ។ ក្នុងអនោតត្តៈនោះ មានកំពង់សម្រាប់ងូត មានហរតាល និងមនោសិលា ដូចគ្នានឹងកែវផលិក មិនមានត្រី មានទឹកថ្លាស្អាត ត្រូវ ( ធម្មជាតិ ) តាក់តែងយ៉ាងល្អ ជាកំពង់សម្រាប់ងូតរបស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះខីណាស្រព និងពួកឥសី និងជាទីកម្សាន្តរបស់ពួកទេវតា និងយក្សជាដើម ។ ត្រង់មាត់ច្រាំងទាំង ៤ នៃស្រះនោះមានផ្លូវ ៤ គឺផ្លូវសីហៈ ១ ផ្លូវដំរី ១ ផ្លូវសេះ ១ ផ្លូវគោឧសភ ១ ។ ទឹកទាំង ៤ ខ្សែ ហូរចេញអំពីស្រះតាមផ្លូវនោះ ។ ត្រង់ច្នេរស្ទឹងដែលហូរតាមប្រកសីហៈ មានសីហៈជាច្រើន តាមប្រកដំរីក៏មានដំរី តាមប្រកសេះ និងប្រកគោក៏ដូចគ្នា ។ ស្ទឹងដែលហូរអំពីទិសខាងកើត ហូរប្រទក្សិណស្រះ ៣ ជុំ មិនជួបជាមួយស្ទឹង ៣ ខ្សែដទៃ ហូរទៅតាមផ្លូវរបស់អមនុស្ស កាត់តាមព្រៃហិមពាន្ត ទៅកាន់ទិសខាងកើត ហើយធ្លាក់ទៅកាន់មហាសមុទ្រ ។ ស្ទឹងដែលហូរចេញអំពីទិសខាងលិច ខាងជើង ក៏ហូរប្រទក្សិណដូចគ្នា ហើយហូរទៅកាន់ដែនដីរបស់អមនុស្ស ធ្វើងកាត់ព្រៃហិមពាន្តទិសខាងលិច និងធ្វើងកាត់ព្រៃហិមពាន្តទិសខាងជើង ហើយចាក់ចូលក្នុងមហាសមុទ្រ ។ ឯស្ទឹងដែលហូរចេញអំពីទិសខាងត្បូង ហូរប្រទក្សិណ ៣ ជុំ ហើយហូរត្រោះទៅទិសខាងត្បូង លើថ្មនោះឯង ចម្ងាយ ៦០ យោជន៍ ហើយប៉ះនឹងភ្នំមួយ ធ្លារ

ទឹកទទឹងប្រមាណ ៣ គាវុត ក៏ហោះទៅតាមអាកាសចម្ងាយ ៦០ យោជន៍ ហើយធ្លាក់ចុះលើផ្ទាំងថ្ម ឈ្មោះតិយគ្គឡៈ ។ ផ្ទាំងថ្មនោះ ក៏បែកដោយកម្លាំងទឹកកើតជាស្រះបោក្ខរណី ឈ្មោះតិយគ្គឡៈ ប្រមាណ ៥០ យោជន៍ ទឹកនោះក៏ទម្លុះប្រាំងស្រះបោក្ខរណី ហូរក្រោមដីកាត់ថ្មទៅចម្ងាយ ៦០ យោជន៍ បន្ទាប់អំពីនោះ ក៏ទម្លុះដីរឹងទៅប្រមាណ ៦០ យោជន៍ ជាឧមង្គ ហើយបុកជាមួយទីងតិរច្ឆានបព៌ត ឈ្មោះវិជ្ឈៈ បែកជាផ្លូវទឹក ៥ ខ្សែ ដូចម្រាមដៃហូរទៅ ។ ស្ទឹងដែលហូរក្នុងទីដែលហូរប្រទក្សិណអនោតត្តស្រះ ៣ ជុំ ហៅថា អាវដ្តគង្គា ទីដែលហូរលើផ្ទាំងថ្ម ៦០ យោជន៍ ហៅថា អាកិណ្ណគង្គា ក្នុងទីដែលទឹកហោះទៅតាមអាកាស ៦០ យោជន៍ ហៅថា អាកាសគង្គា ទឹកដែលធ្លាក់ចុះលើផ្ទាំងថ្ម ឈ្មោះតិយគ្គឡៈ តាំងនៅលើទីប្រមាណ ៥៤ យោជន៍ ហៅថា តិយគ្គឡបោក្ខរណី ផ្លូវទឹកដែលហូរទម្លុះប្រាំងស្រះក្រោមផ្ទាំងថ្ម ប្រមាណ ៦០ យោជន៍ ហៅថា ពហលគង្គា ។ ផ្លូវទឹកដែលទម្លុះដីរឹងហូរទៅជាឧមង្គ ៦០ យោជន៍ទៀត ហៅថា ឧមង្គគង្គា ។ ផ្លូវទឹកដែលបុកនឹងតិរច្ឆានបព៌ត ឈ្មោះវិជ្ឈៈ ហូរទៅ លោកហៅថា **បញ្ចធារា** គឺគង្គា ១ យមុនា ១ អចិរវតី ១ សរភូ ១ មហី ១ ។ មហាគង្គាទាំង ៥ នេះ មានសន្ទៀមធ្លាក់ ។ ក្នុងស្ទឹង ៥ ខ្សែនោះ ស្ទឹងខ្សែទី ៥ ឈ្មោះមហីនោះឯង លោកបំណងយកថា ស្ទឹងគង្គាដែលឈ្មោះថា មហាមហី ក្នុងទីនេះ ។

ជនបទដែលមានត្រពាំងទឹកទិសខាងជើងនៃស្ទឹងគង្គានោះ ជនបទនោះគប្បីជ្រាបថា ឈ្មោះអង្គុត្តរាបៈ ព្រោះមិនឆ្ងាយអំពីត្រពាំងទឹកនោះ ។ បទថា

**ចារិកំ ចរមានោ** ទ្រង់យាងចារិកទៅ គឺធ្វើដំណើរទៅ ។ ក្នុងបទនោះ គប្បីជ្រាបការចារិករបស់ព្រះមានព្រះភាគ មាន ២ យ៉ាង គឺតុរិតចារិកា គឺចារិកដោយរួសរាន់ ១ អតុរិតចារិកា គឺ ចារិកដោយមិនប្រញាប់ប្រញាល់ ១ ។ ក្នុងចារិក ២ យ៉ាងនោះ ព្រះមានព្រះភាគទ្រង់ឃើញបុគ្គលដែលគួរប្រោសក្នុងទីឆ្ងាយ ក៏ប្រញាប់យាងទៅ ឈ្មោះថា **តុរិតចារិកា** ។ តុរិតចារិកានោះ គប្បីឃើញក្នុងការទទួលព្រះមហាកស្សបៈជាដើម ព្រះមានព្រះភាគយាងទៅទទួលព្រះមហាកស្សបៈនោះអស់ចម្ងាយផ្លូវ ៣ គាវុតត្រឹមមួយសម្ទុះប៉ុណ្ណោះ ទ្រង់យាងទៅ ៣០ យោជន៍ ដើម្បីទូន្មានអាឡវកយក្ស បានយាងទៅ ៣០ យោជន៍ ដើម្បីប្រោសអង្គុលិមាល ទ្រង់យាងទៅ ៤៥ យោជន៍ ដើម្បីប្រោសព្រះបាទបុក្កុសាតិ ទ្រង់យាងទៅ ១២០ យោជន៍ ដើម្បីប្រោសព្រះមហាកប្បិន ទ្រង់យាងទៅចម្ងាយ ៧០០ យោជន៍ ដើម្បីប្រោសធនិយៈ អ្នកចិញ្ចឹមគោ នេះឈ្មោះថា **តុរិតចារិកា** ។ ការយាងទៅដើម្បីអនុគ្រោះសត្វលោក ដោយការត្រាច់បិណ្ឌបាតទៅតាមលំដាប់ស្រុក និគម នគរ ឈ្មោះថា **អតុរិតចារិកា** ។ អតុរិតចារិកានេះ លោកបំណងយកក្នុងទីនេះ ដោយហេតុនេះ ទើបពោលថា **ចារិកំ ចរមានោ**។

បទថា **មហតា** បានដល់ ច្រើនដោយចំនួន និងច្រើនដោយគុណ ។ បទថា **ភិក្ខុ សង្ឃេន** គឺដោយពួកសមណៈ ។ បទថា **អឌ្ឍតេឡសេហិ** គឺ ១២ កន្លះ លោកអធិប្បាយថា ជាមួយភិក្ខុ ១២៥០ រូប ។ បទថា **យេន ។បេ។ តទវសរិ** សេចក្ដីថា និគមនោះ បានឈ្មោះថា **អាបណា** ព្រោះមាន

ផ្សារច្រើន ។ បានឮថា និគមនោះមានផ្សារធំសម្រាប់លក់ដូរ ពីរម៉ឺនផ្សារ ។ មនុស្សម្នាអ្នកធ្វើដំណើរមកជួបជុំគ្នា ត្រង់និគមនៃវង្គរបស់អ្នកអង្គុត្តរាបៈ គ្រប់ទិសទី ដោយហេតុនោះ ទើបលោកពោលថា ព្រះមានព្រះភាគយាងដល់និគមនោះ ។

បទថា **កេណិយោ ជដិលោ** បានដល់ ជដិលឈ្មោះថា កេណិយៈ ។ ពាក្យថា **ជដិលោ** សេចក្តីថា ជាតាបស បានឮមកថា កេណិយជដិលនោះជាព្រាហ្មណមហាសាល តែដើម្បីរក្សាទ្រព្យ ក៏កាន់យកភេទបព្វជ្ជាជាតាបស ថ្វាយគ្រឿងបណ្ណាការដល់ព្រះរាជា សាងអាស្រមក្នុងទីនោះ មានបុគ្គលនៅអាស្រ័យជាមួយ ១០០០ ត្រកូល ។ អាចារ្យពួកខ្លះពោលថា ត្រង់អាស្រមរបស់កេណិយជដិលនោះ មានដើមត្នោតមួយជ្រុះផ្លែជាមាសមួយថ្ងៃមួយៗរាល់ថ្ងៃ ។ កេណិយជដិលនោះ ពេលថ្ងៃ ស្លៀកដណ្តប់សំពត់កាសាវៈ ហើយចងជដា ក្នុងពេលយប់ ដល់ព្រមដោយការបម្រើដោយកាមគុណ ៥ តាមសប្បាយ ។ បទថា **សក្យបុត្តោ** សម្តែងដល់ត្រកូលខ្ពស់ ។ បទថា **សក្យកុលា បព្វជិតោ** សម្តែងដល់ការបួសដោយសទ្ធា លោកអធិប្បាយថា ជាបុគ្គលមិនមានការសោបសូន្យណាមួយគ្របសង្កត់ លះត្រកូលទាំងដែលមិនវិនាស ចេញបួសដោយសទ្ធា ។ បទថា **តំ ខោ បន** ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃឥត្ថម្ភូត ។ បានសេចក្តីថា **តស្ស ខោ បន ភោតោ គោតមស្ស** ប្រែថា របស់ព្រះគោតមនោះឯង ។ បទថា **កល្យាណោ** គឺប្រកបដោយគុណដែលស្អាត អធិប្បាយថា ប្រសើរបំផុត ។ បទថា **កិត្តិ-**

**សទ្ទោ** គឺកេរ្តិ៍ឈ្មោះ ឬការប្រកាសសរសើរ ។ លំដាប់ដំបូង ក្នុងបទជាដើមថា **ឥតិបិ សោ ភគវា** នេះ មានពាក្យអធិប្បាយដូច្នេះថា ព្រះមានព្រះភាគអង្គនោះជាព្រះអរហន្ត ដោយហេតុនេះ ជាអ្នកត្រាស់ដឹងឯង ដោយប្រពៃ ដោយហេតុនេះ ។បេ។ ជាអ្នកចែកធម៌ ដោយហេតុនេះ អធិប្បាយថា ដោយហេតុនេះៗ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អរហំ** ដូច្នេះថា ព្រះមានព្រះភាគទ្រង់ជាព្រះអរហន្តដោយហេតុនេះមុន គឺជាអ្នកឆ្ងាយចាកកិលេស ព្រោះកាច់បំបាក់នូវកាំ គឺកិលេស ព្រោះជាអ្នកគួរដល់បច្ច័យជាដើម ព្រោះមិនធ្វើបាបក្នុងទីស្ងាត់ ។ ពិតហើយ ព្រះមានព្រះភាគអង្គនោះ ជាអ្នកឆ្ងាយចាកកិលេសទាំងពួង ព្រោះកម្ចាត់កិលេស មួយអន្លើដោយវាសនា ដោយមគ្គ ព្រោះដូច្នោះ ទើបជាព្រះអរហន្ត ព្រោះជាអ្នកឆ្ងាយចាកកិលេស ។ ម្យ៉ាងទៀត ទ្រង់កាច់បំបាក់នូវកម្ម គឺកិលេសដោយមគ្គ ព្រោះដូច្នោះ ទើបទ្រង់ព្រះនាមថា **អរហំ** ព្រោះទ្រង់កាច់បំបាក់នូវកម្ម គឺកិលេសបាន ។ ម្យ៉ាងទៀត ដុំ គឺអវិជ្ជា ភវតណ្ហាដំណាប់ គឺអភិសង្ខារ មានបុញ្ញាភិសង្ខារជាដើម ខ្នងកង់ គឺជរា និងមរណៈ តម្រៀបចូលក្នុងភ្លៅ ដែលសម្រេចដោយសមុទយៈ គឺអាសវៈ ប្រកបចូលក្នុងរថ គឺភព ៣ មានសង្សារជាទីស្លុះទៅ ក្នុងកាលដែលមិនមានខាងដើម ទ្រង់តាំងនៅលើដី គឺសីល ដោយព្រះបាទ គឺសេចក្ដីព្យាយាម ត្រង់ពោធិ-មណ្ឌល ទ្រង់កាន់ពូថៅ គឺបញ្ញា ដែលធ្វើឲ្យអស់នូវកម្ម ដោយអរហត្ត គឺសទ្ធា ហើយកាច់បំបាក់នូវកាំទាំងពួងបាន ព្រោះហេតុនោះ ទើបទ្រង់ព្រះនាម

ថា **អរហំ** ព្រោះកម្ចាត់នូវកាំ គឺកិលេសបាន ម្យ៉ាងទៀត ទ្រង់ជាទក្ខិណេយ្យ-បុគ្គលដ៏ប្រសើរ ទើបគួរទទួលបច្ច័យ មានចីវរជាដើម និងគ្រឿងសក្ការៈ និងសេចក្តីគោរពជាដើម ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **អរហំ** ព្រោះជាអ្នកគួរដល់បច្ច័យជាដើម ម្យ៉ាងទៀត ទ្រង់មិនធ្វើសេចក្តីអាក្រក់ក្នុងទីណាឡើយ ដូចបុគ្គលពាលពួកខ្លះក្នុងលោក សម្គាល់ខ្លួនថាជាបណ្ឌិត តែធ្វើបាបក្នុងទីស្ងាត់ ព្រោះខ្លាចត្រូវតិះដៀល ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **អរហំ** ព្រោះមិនធ្វើបាបក្នុងទីស្ងាត់ ។ ម្យ៉ាងទៀត ក្នុងបទថា **អរហំ** នេះ មានគាថាដូច្នេះ

> ព្រះមុនីនោះ ព្រោះទ្រង់ឆ្ងាយចាកកិលេស ជាអ្នកកាច់បំបាក់នូវ
> កាំ គឺកិលេសបាន ជាអ្នកកម្ចាត់នូវសង្សារចក្របាន ជាបុគ្គល
> គួរដល់បច្ច័យជាដើម ជាអ្នកធ្វើបាបក្នុងទីស្ងាត់មិនមាន ដោយ
> ហេតុនោះ ទើបបណ្ឌិតថ្វាយព្រះនាមថា **អរហំ** ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ព្រោះត្រាស់ដឹងនូវធម៌ដោយប្រពៃ ដោយព្រះអង្គឯង ។ ទ្រង់ព្រះនាមថា **វិជ្ជាចរណសម្បន្នោ** ព្រោះប្រកបដោយវិជ្ជាដែលបរិសុទ្ធក្រៃលែង និងដោយចរណៈដ៏ឧត្តម ។ ទ្រង់ព្រះនាមថា **សុគតោ** ព្រោះយាងទៅល្អ ព្រោះយាងទៅកាន់ឋានៈដែលល្អ ព្រោះទ្រង់ទៅដោយល្អ និងព្រោះត្រាស់ដឹងដោយប្រពៃ ។ ទ្រង់ព្រះនាមថា **លោកវិទូ** ព្រោះទ្រង់ដឹងនូវលោកដោយប្រការទាំងពួង ។ ពិតហើយ ព្រះមានព្រះភាគទ្រង់ដឹងនូវសង្ខារលោក ដែលមានខន្ធ និងអាយតនៈជាដើម

ដោយប្រការទាំងពួង គឺដោយសភាវៈ ដោយសមុទយៈ ដោយនិរោធ ដោយឧបាយនៃនិរោធ ។ ទ្រង់ដឹងនូវសង្ខារលោក ដោយប្រការទាំងពួងយ៉ាងនេះ គឺលោក ១ សត្វទាំងឡាយទាំងពួងតាំងនៅបានដោយអាហារ លោក ២ គឺនាម និងរូប លោក ៣ គឺវេទនា ៣ លោក ៤ គឺអាហារ ៤ លោក ៥ គឺឧបាទានក្ខន្ធ ៥ លោក ៦ គឺអាយតនៈខាងក្នុង ៦ លោក ៧ គឺវិញ្ញាណដ្ឋិតិ ៧ លោក ៨ គឺលោកធម៌ ៨ លោក ៩ គឺសត្តាវាស ៩ លោក ១០ គឺអាយតនៈ ១០ លោក ១២ គឺអាយតនៈ ១២ លោក ១៨ គឺធាតុ ១៨ ។

ទ្រង់ដឹងនូវសត្វលោកដោយប្រការទាំងពួង គឺទ្រង់ដឹងអធ្យាស្រ័យរបស់សត្វទាំងឡាយ ទ្រង់ដឹងនូវកិលេសដែលដេកត្រាំរឿយៗ ក្នុងសន្តានរបស់សត្វទាំងឡាយ ទ្រង់ដឹងចារិក ទ្រង់ដឹងអារម្មណ៍ ទ្រង់ដឹងសត្វដែលមានធូលី គឺកិលេសតិច សត្វមានធូលី គឺកិលេសច្រើន សត្វមានឥន្ទ្រិយចាស់ក្លា សត្វមានឥន្ទ្រិយទន់ខ្សោយ សត្វមានអាការល្អ សត្វមានអាការអាក្រក់ សត្វឲ្យដឹងបានងាយ សត្វឲ្យដឹងបានលំបាក សត្វដែលជាភព្វៈ សត្វដែលជាអភព្វៈ ។ម្យ៉ាងទៀត ចក្រវាលមួយ ដោយបណ្តោយ និងទទឹងមួយលានពីរសែនបីពាន់បួនរយហាសិបយោជន៍ ដោយជុំវិញបីលានប្រាំមួយសែនមួយម៉ឺនបីរយហាសិបយោជន៍ ។

ក្នុងចក្រវាលនោះ គប្បីជ្រាបដូចតទៅនេះ

ផែនដីនេះ រាប់ដោយកម្រាស់ ២៤០០០០ យោជន៍ តាំងនៅលើទឹកដែលមានកម្រាស់ ៤៨០០០០ យោជន៍ ទឹកតាំងនៅលើខ្យល់ដែលមាន

កម្រាស់ ៩៦០០០០ យោជន៍ នេះគឺសណ្ឋានរបស់លោក ។ លោកមានសណ្ឋានយ៉ាងនេះ ។

កាលលោកមានសណ្ឋានយ៉ាងនេះ គប្បីជ្រាបដូចតទៅ

ភ្នំសិនេរុខ្ពស់ជាងភ្នំទាំងឡាយ មានឫសចាក់ទៅក្នុងមហាសមុទ្រ ៨៤០០០ យោជន៍ កម្ពស់ឡើងទៅលើក៏ប៉ុណ្ណោះដូចគ្នា បន្ទាប់អំពីនោះ ភ្នំធំដែលជាទិព្វ វិចិត្រដោយកែវច្រើនប្រការ លិចចូលក្នុងមហាសមុទ្រ និងផុសឡើងតាមលំដាប់ ដោយប្រមាណ ពាក់កណ្តាលៗ គឺភ្នំយុគន្ធរ ឥសិន្ធរ ករវិកៈ សុទស្សនៈ នេមិន្ធៈ វិន្តកៈ អស្សកណ្ណៈ ។

ភ្នំទាំង ៧ នេះ ជាភ្នំធំ ព័ទ្ធជុំវិញភ្នំសិនេរុ ដែលជាលំនៅរបស់ទេវ-មហារាជ និងយក្ខ ។

ភ្នំហិមពាន្តកម្ពស់ ៥០០ យោជន៍ ដោយបណ្តោយ និងទទឹង ៣០០០ យោជន៍ ប្រដាប់ដោយកំពូល ៨៤០០០ កំពូល ភ្នំនេះព័ទ្ធដោយឈើដើម ៣៥ យោជន៍ ដោយជុំវិញ ដើមឈើ និងមែកប្រវែង ៥០ យោជន៍ រំកាយមែកពីម្ខាងទៅម្ខាង ១០០ យោជន៍ ដើមឈើដែលដុះជុំវិញ មានដើម ( ពីគល់ដល់មែក ) ៣ យោជន៍ខ្វះ ៥ យោជន៍ខ្វះ ធំដោយជុំវិញរហូតដល់ដើម និងមែក ៥០ យោជន៍ រំកាយមែក១០០ យោជន៍ កម្ពស់ក៏ប៉ុណ្ណោះដូចគ្នា ដើមឈើនោះ ឈ្មោះថា ដើមព្រីង ដោយអានុភាពរបស់ដើមព្រីងនោះ ទើបហៅថា ជម្ពូទ្វីប ដើមព្រីងនោះ ចាក់ចូលទៅក្នុងអន្លង់ទឹកធំ ២៨០០០ យោជន៍ កម្ពស់ឡើងទៅលើក៏ប៉ុណ្ណោះដូចគ្នា ភ្នំចក្រវាលផុសឡើង ព័ទ្ធជុំវិញសម្ភារៈ

ទាំងអស់នេះ សម្រេចជាចក្រវាល ។

ក្នុងចក្រវាលលោកនោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

ចន្ទមណ្ឌល ៤៩ យោជន៍ សូរិយមណ្ឌល ៥០ យោជន៍ តាវត្តិង្សភព ១០០០០ យោជន៍ អសុរភព និងអវីចិមហានរក និងជម្ពូទ្វីបក៏ប៉ុនគ្នា ។ អាមរគោយានទ្វីប និងបុព្វវិទេហទ្វីប ៧០០០ យោជន៍ដូចគ្នា ឧត្តរកុរុទ្វីប ៨០០០ យោជន៍ មហាទ្វីបនីមួយៗ មានទ្វីបតូចប្រាំរយៗ ជាបរិវារ ។ ទាំងអស់នេះ ជាចក្រវាល ១ ជាលោកធាតុ ១ ក្នុងចន្លោះចក្រវាល ជាលោកន្តរិកនរក ។

ព្រះមានព្រះភាគ ទ្រង់ដឹងឱកាសលោក ដោយប្រការទាំងពួង គឺទ្រង់ដឹងចក្រវាលមិនមានទីបំផុត លោកធាតុមិនមានទីបំផុត ទ្រង់ដឹងដោយពុទ្ធញ្ញាណ មិនមានទីបំផុត ។ គប្បីជ្រាបថា ព្រះមានព្រះភាគអង្គនោះ ជាលោកវិទូ ព្រោះទ្រង់ដឹងនូវលោកដោយប្រការទាំងពួង ដោយប្រការដូច្នេះ ។ ទ្រង់ព្រះនាមថា **អនុត្តរោ** ព្រោះមិនមានបុគ្គលណាមួយប្រសើរជាង ដោយគុណទាំងឡាយនៃព្រះអង្គ ។

ទ្រង់ព្រះនាមថា **បុរិសទម្មសារថិ** ព្រោះញុំាងបុរសដែលគួរទូន្មានបានឲ្យស្ទុះទៅដោយឧបាយ ។

ទ្រង់ព្រះនាមថា **សត្ថា** ព្រោះទ្រង់ប្រៀនប្រដៅ និងទ្រង់ឲ្យពិចារណាតាម គួរដោយទិដ្ឋធម្មិកប្រយោជន៍ សម្បរាយិកប្រយោជន៍ និងបរមត្ថ-ប្រយោជន៍ ។ សព្ទថា **ទេវមនុស្សានំ** លោកប្រារព្ធដោយការកំណត់បុគ្គល

យ៉ាងឧក្រិដ្ឋ និងដោយការកំណត់ដល់បុគ្គលដែលសមគួរសម្រេច តែព្រះមានព្រះភាគអង្គនោះ ទ្រង់ប្រៀនប្រដៅសត្វទាំងឡាយ មាននាគជាដើម ដោយប្រយោជន៍ដែលជាលោកិយ ។ ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះត្រាស់ដឹងវត្ថុដែលគួរត្រាស់ដឹង ដែលមានគ្រប់យ៉ាង ដោយឈ្មោះដែលមានក្នុងទីបំផុតនៃវិមោក្ខ ព្រោះព្រះមានព្រះភាគអង្គនោះ ទ្រង់ជាអ្នកមានជោគ ជាអ្នកទម្លាយនូវកិលេស ជាបុគ្គលប្រកបដោយជោគទាំងឡាយ ជាអ្នកចែក ជាអ្នកចែករំលែក ជាអ្នកខ្ជាក់ចោលនូវការទៅក្នុងភពទាំងឡាយ ដូច្នោះ ទើបទ្រង់ព្រះនាមថា **ភគវា**។

នេះជាសេចក្ដីសង្ខេបក្នុងបទនេះ តែដោយពិស្ដារ លោកពោលបទទាំងនេះក្នុងវិសុទ្ធិមគ្គហើយ ។

បទថា **សោ ឥមំ លោកំ** គឺព្រះមានព្រះភាគអង្គនោះ ទ្រង់ធ្វើនូវលោកនេះ ។ ឥឡូវនេះ គួរចង្អុលបង្ហាញនូវបទដែលគួរពោល ។ បទទាំងឡាយថា **សទេវកំ** ជាដើម មានន័យដូចបានពោលហើយក្នុងកសិភារទ្វាជសូត្រ និងអាឡវកសូត្រជាដើម ។ បទថា **សយំ** បានដល់ ដោយព្រះអង្គឯង គឺមិនមានអ្នកដទៃប្រៀនប្រដៅ ។ បទថា **អភិញ្ញា** បានដល់ ដោយបញ្ញាដ៏ក្រៃលែង ។ បទថា **សច្ឆិកត្វា** គឺធ្វើឲ្យប្រចក្ស ។ បទថា **បវេទេតិ** គឺទ្រង់ឲ្យដឹង ឲ្យជាក់ ឲ្យច្បាស់ ។

បទថា **សោ ធម្មំ ទេសេតិ ។បេ។ បរិយោសានកល្យាណំ** សេចក្ដីថា ព្រះមានព្រះភាគអង្គនោះ ទ្រង់អាស្រ័យសេចក្ដីករុណាក្នុងសត្វទាំងឡាយ ទ្រង់

លះនូវសេចក្ដីសុខ កើតអំពីវិវេកដ៏កំពូល ហើយទ្រង់សម្ដែងធម៌ ។ កាល ទ្រង់សម្ដែងធម៌នោះ តិចក្ដី ច្រើនក្ដី ឈ្មោះថា ទ្រង់សម្ដែងមានលម្អបទដើម ជាដើម ។ សួរថា ទ្រង់សម្ដែងដូចម្ដេច ឆ្លើយថា ពិតហើយ ព្រោះធម៌មាន លម្អិតដោយជុំវិញ សូម្បីក្នុងមួយគាថា ក៏ឈ្មោះថា លម្អក្នុងខាងដើម ដោយ បទទី ១ លម្អត្រង់កណ្ដាល ដោយបទទី ២ លម្អក្នុងទីបំផុត ដោយបទចុង ក្រោយ ។

ព្រះសូត្រមានអនុសន្ធិតែមួយ លម្អបទដើមដោយនិទាន លម្អក្នុងទីបំផុត ដោយបទសរុប លម្អត្រង់កណ្ដាលដោយបទដ៏សេស ។

សូត្រដែលមានអនុសន្ធិផ្សេងគ្នា លម្អបទដើម ដោយអនុសន្ធិដើម លម្អ បទចុង ដោយបទចុងក្រោយ លម្អត្រង់កណ្ដាល ដោយបទដ៏សេស ។

សាសនធម៌ទាំងមូល លម្អបទដើម ដោយសីលដែលជាប្រយោជន៍នៃ ខ្លួន លម្អត្រង់កណ្ដាល ដោយសមថៈ វិបស្សនា មគ្គ និងផល លម្អខាងចុង ដោយនិព្វាន ។

ម្យ៉ាងទៀត លម្អបទដើម ដោយសីល និងសមាធិ លម្អត្រង់កណ្ដាល ដោយវិបស្សនា និងមគ្គ លម្អក្នុងទីបំផុត ដោយផល និងនិព្វាន ។

ម្យ៉ាងទៀត លម្អក្នុងខាងដើម ព្រោះការត្រាស់ដឹងរបស់ព្រះពុទ្ធ លម្អ ត្រង់កណ្ដាល ព្រោះព្រះធម៌ជាស្វាក្ខាតធម៌ លម្អបទចុង ព្រោះព្រះសង្ឃជា សុបដិបន្នៈ ។

ម្យ៉ាងទៀត លម្អខាងដើម ដោយអភិសម្ពោធិញ្ញាណ ដែលបុគ្គលស្ដាប់

ធម៌នោះហើយបដិបត្តិយ៉ាងនោះ គប្បីសម្រេចបាន ល្អត្រង់កណ្តាល ដោយបច្ចេកពោធិញ្ញាណ ល្អខាងចុង ដោយសាវកពោធិញ្ញាណ ។

ម្យ៉ាងទៀត បុគ្គលកាលស្តាប់ធម៌នោះ រមែងនាំមកនូវលម្អដោយការស្តាប់ ព្រោះសង្កត់នូវនីវរណៈទាំងឡាយបាន ព្រោះដូច្នោះ ទើបល្អខាងដើម កាលបដិបត្តិ រមែងនាំមកនូវលម្អក្នុងកិច្ចបដិបត្តិ ព្រោះនាំមកនូវសេចក្តីសុខដែលកើតអំពីសមថៈ និងវិបស្សនា ព្រោះដូច្នោះ ទើបល្អត្រង់កណ្តាល កាលបដិបត្តិយ៉ាងនោះហើយ កាលសម្រេចផលនៃកិច្ចបដិបត្តិ រមែងនាំមកនូវលម្អដោយផលនៃកិច្ចបដិបត្តិ ព្រោះនាំមកនូវភាពជាតាទិបុគ្គល ព្រោះហេតុនោះ ទើបល្អក្នុងទីបំផុត ។

ម្យ៉ាងទៀត ព្រោះជាដែនកើតនៃទីពឹង ល្អក្នុងខាងដើម ព្រោះបរិសុទ្ធដោយដែនកើត ល្អត្រង់កណ្តាល ព្រោះបរិសុទ្ធដោយប្រយោជន៍ ល្អក្នុងទីបំផុត ព្រោះបរិសុទ្ធដោយកិច្ច ព្រោះដូច្នោះ គប្បីជ្រាបថា ព្រះមានព្រះភាគកាលទ្រង់សម្តែងធម៌តិចក្តី ច្រើនក្តី ឈ្មោះថា ទ្រង់សម្តែងធម៌មានលម្អក្នុងខាងដើមជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទជាដើមថា **សាត្ថំ សព្យញ្ជនំ** ដូចតទៅ ព្រោះព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌នេះ ឈ្មោះថា ទ្រង់ប្រកាសសាសនព្រហ្មចរិយៈ និងមគ្គព្រហ្មចរិយៈ ទ្រង់សម្តែងដោយន័យផ្សេងៗ ។ ព្រហ្មចរិយទាំងពីរនោះ ឈ្មោះថា ព្រមទាំងអត្ថ ព្រោះសម្បូរដោយអត្ថ តាមការកើតដូចម្តេច ឈ្មោះថា ព្រមទាំងព្យញ្ជនៈ ព្រោះសម្បូរដោយព្យញ្ជនៈ ។

ឈ្មោះថា ព្រមទាំងអត្ថ ព្រោះប្រកបស្មើដោយសេចក្ដីដូចគ្នា ការប្រកាស ការពន្រ្ទឹកសេចក្ដី ការបែក ការធ្វើឲ្យងាយ ការបញ្ញត្តិ និងបទនៃអត្ថ ឈ្មោះថា ព្រមទាំងព្យញ្ជនៈ ព្រោះសម្បូរដោយអក្ខរៈ បទ ព្យញ្ជនៈ អាការ ភាសា និងការទូន្មាន ឈ្មោះថា មួយអន្លើដោយអត្ថ ព្រោះជ្រៅដោយអត្ថ និងជ្រៅដោយបដិវេធ ឈ្មោះថា ព្រមទាំងព្យញ្ជនៈ ព្រោះជ្រាលជ្រៅដោយធម៌ ជ្រាលជ្រៅដោយការសម្ដែង ឈ្មោះថា ព្រមទាំងអត្ថ ព្រោះជាវិស័យនៃការបែកធ្លាយ ដោយអត្ថ និងបដិភាណ ឈ្មោះថា ព្រមទាំងព្យញ្ជនៈ ព្រោះជាវិស័យនៃការបែកធ្លាយដោយធម៌ និងភាសា ឈ្មោះថា ព្រមដោយអត្ថ ព្រោះញុំាងជនដែលពិចារណាឲ្យជ្រះថ្លា ដោយដឹងថា ជាបណ្ឌិត ឈ្មោះថា មួយអន្លើដោយព្យញ្ជនៈ ព្រោះញុំាងលោកិយជនឲ្យជ្រះថ្លា ដោយភាពជារបស់គួរជឿបាន ឈ្មោះថា ព្រមទាំងអត្ថ ព្រោះបំណងនូវអត្ថជ្រាលជ្រៅ ឈ្មោះថា មួយអន្លើដោយព្យញ្ជនៈ ព្រោះជាបទងាយ ឈ្មោះថា បរិបូណ៌ ព្រោះបរិបូណ៌ឥតសេសសល់ ដោយមិនមានវត្ថុដែលគួរនាំចូលទៅ ឈ្មោះថា បរិសុទ្ធ ព្រោះមិនមានទោស ដោយមិនមានវត្ថុដែលគួរនាំចេញទៅ ឈ្មោះថា ព្រហ្មចរិយៈ ព្រោះកំណត់យកសិក្ខា ៣ ព្រោះជាធម៌ដែលព្រហ្ម គឺអ្នកប្រសើរគួរប្រព្រឹត្ត និងព្រោះភាពដែលធម៌ ទាំងនោះ ជាធម៌គួរប្រព្រឹត្ត ព្រោះហេតុនោះ ទើបកេណិយជដិលពោលថា ព្រះអង្គប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈ ពេញបរិបូណ៌បរិសុទ្ធទាំងអស់ដូច្នេះ ។

ម្យ៉ាងទៀត ព្រោះព្រះមានព្រះភាគ កាលទ្រង់សម្ដែងធម៌ មួយអន្លើ

ដោយហេតុ មួយអន្ទើដោយរឿងដែលកើតឡើង ឈ្មោះថា ទ្រង់សម្តែងធម៌ល្អខាងដើម កាលទ្រង់សម្តែងធម៌ ដោយសមគួរដល់វេនេយ្យជនទាំងឡាយដោយមិនខុសរឿង និងប្រកបដោយហេតុ និងឧទាហរណ៍ ឈ្មោះថា ទ្រង់សម្តែងធម៌ល្អត្រង់កណ្តាល កាលទ្រង់សម្តែងធម៌ ដោយឲ្យអ្នកស្តាប់បាននូវសទ្ធា និងដោយបទសរុប ឈ្មោះថា ទ្រង់សម្តែងធម៌ ល្អក្នុងទីបំផុត កាលសម្តែងធម៌បែបនេះ ឈ្មោះថា ប្រកាសព្រហ្មចរិយៈផងដែរ ។ ឯព្រហ្មចរិយៈនោះ លោកពោលថា ឈ្មោះថា ព្រមទាំងអត្ថ ព្រោះឈ្វាសក្នុងអធិគមដោយបដិបទា ។ ឈ្មោះថា ព្រមទាំងព្យញ្ជនៈ ព្រោះឈ្វាសក្នុងអាគមដោយបរិយត្តិ ។ ឈ្មោះថា បរិបូណ៌ ព្រោះប្រកបដោយធម្មក្ខន្ធ ៥ មានសីលជាដើម ។ ឈ្មោះថា បរិសុទ្ធ ព្រោះមិនមានឧបក្កិលេស ព្រោះប្រព្រឹត្តទៅ ដើម្បីការឆ្លងផុត និងព្រោះមិនសម្លឹងដល់លោកាមិស ។ ឈ្មោះថា ព្រហ្មចរិយៈ ព្រោះជាវត្តដែលគួរប្រព្រឹត្តរបស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវកទាំងឡាយ ដែលជាបុគ្គលប្រសើរ ដោយអត្ថថា ជាបុគ្គលប្រសើរ ដូច្នោះ ទើបកេណិយជដិលពោលថា ព្រះអង្គទ្រង់សម្តែងធម៌ពីរោះបទដើម បទកណ្តាល និងបទចុង ព្រះអង្គប្រកាសនូវព្រហ្មចរិយៈ ។បេ។

បទថា **សាធុ ខោ បន** គឺជាសេចក្តីល្អ អធិប្បាយថា នាំប្រយោជន៍ នាំសេចក្តីសុខមកឲ្យ ។

បទថា **ធម្មិយា កថាយ** បានដល់ ដែលប្រកបដោយអានិសង្សនៃទឹកបាន ។ ព្រោះថា ក្នុងវេលាល្ងាច កេណិយជដិលនេះ បានដំណឹងថា ព្រះ

មានព្រះភាគយាងមក ជាអ្នកមានដៃទទេចូលទៅគាល់ ក៏នឹងខ្មាស គិតថា អញនឹងនាំទឹកបាន រមែងសមគួរដល់ទ្រង់ដែលវៀរការបរិភោគក្នុងកាលខុស ដូច្នេះ ទើបឲ្យវែកទឹកពុទ្រា ដែលផ្សំយ៉ាងល្អ ដោយជងវែក ៥០០ ទៅ ។ សមដូចលោកពោលក្នុងភេសជ្ជក្ខន្ធកៈថា លំដាប់នោះ កេណិយជដិលមានសេចក្ដីត្រិះរិះដូច្នេះថា គួរអញឲ្យគេនាំយករបស់អ្វីហ្ន៎ ទៅថ្វាយព្រះសមណគោតម ដូច្នេះ គួរសិក្សារឿងទាំងអស់នោះឯង ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ចង្អុលបង្ហាញកេណិយជដិលឲ្យឃើញពិតនូវអានិសង្សនៃការថ្វាយទឹកបាន ដោយកថាប្រកបដោយអានិសង្សនៃការថ្វាយទឹកបាន ដែលសមគួរក្នុងខណៈនោះ ដូចទ្រង់ចង្អុលបង្ហាញសក្យៈទាំងឡាយ ដោយអានិសង្សកថា ថ្វាយទីស្នាក់អាស្រ័យក្នុងសេក្ខសូត្រ ទ្រង់ចង្អុលបង្ហាញនូវកុលបុត្ត ៣ រូប ដោយកថាប្រកបដោយសាមគ្គីរស ក្នុងគោសិង្គសាលវនសូត្រ ទ្រង់ចង្អុលបង្ហាញភិក្ខុទាំងឡាយ ដែលមានជាតិភូមិជាមួយគ្នាដោយកថាវត្ថុ ១០ ក្នុងរថវិនីតសូត្រ ដូច្នោះ ។ ទ្រង់ឲ្យកេណិយជដិលខ្វល់ខ្វាយសមាទាន ដើម្បីធ្វើបុណ្យបែបនោះតទៅ ទ្រង់ឲ្យកេណិយជដិល កើតនូវឧស្សាហ៍ អាចហ៊ានក្រៃលែងឡើង ទ្រង់សរសើរឲ្យកេណិយជដិល ត្រេកអរដោយផលវិសេស ដែលនឹងមានក្នុងភពនេះ និងភពខាងមុខ ។ ដោយហេតុនោះ ទើបលោកពោលថា **ធម្មិយា កថាយ ។បេ។ សម្បហំសេសិ** ដូច្នេះ ។

កេណិយជដិល ជ្រះថ្លាក្នុងព្រះមានព្រះភាគយ៉ាងក្រៃលែង ទើបក្រាប

ទូលនិមន្តព្រះមានព្រះភាគៗ ទ្រង់បដិសេធអស់វារៈ ៣ ដងហើយ ទើបទទួលនិមន្ត ដោយហេតុនោះ ទើបលោកពោលថា **អថ ខោ កេណិយោ ជដិលោ ។បេ។ អធិវាសេសិ ភគវា តុណ្ហីភាវេន** ដូច្នេះ ។ សួរថា ព្រះមានព្រះភាគទ្រង់បដិសេធដើម្បីអ្វី ឆ្លើយថា ព្រោះអាពធនាវៀយៗ កេណិយជដិលនឹងមានសេចក្តីចម្រើនដោយបុណ្យ និងត្រៀមឲ្យក្រៃលែងឡើង ។ របស់ដែលត្រៀមសម្រាប់ភិក្ខុ ១២៥០ រូប ក៏គ្រប់គ្រាន់ដល់ភិក្ខុ ១៥៥០ រូប ។ បើសួរថា ភិក្ខុ ៣០០ រូបទៀតមកអំពីណា ឆ្លើយថា កាលកេណិយជដិលមិនទាន់បានត្រៀមអាហារនោះឯង សេលព្រាហ្មណ៍ មួយអន្លើដោយមាណព ៣០០ នាក់នឹងបួស ព្រះមានព្រះភាគទ្រង់ឃើញហេតុនោះ ទើបត្រាស់យ៉ាងនេះ ។

[ ៦១ ] បទថា **មិត្តាមច្ចេ** បានដល់ មិត្ត និងកម្មករ ។ បទថា **ញាតិសាលោហិតេ** បានដល់ បុត្តធីតាជាដើម ដែលកាន់យកកំណើតតែមួយ មានឈាមស្មើគ្នាដោយពូជដ៏សេស ។ បទថា **យេន** គឺព្រោះហេតុណា ។ បទថា **មេ** ប្រែថា របស់ខ្ញុំ ។ បទថា **កាយវេយ្យាវដិកំ** គឺខ្វល់ខ្វាយដោយកាយ ។ បទថា **មណ្ឌលមាលំ បដិយាទេតិ** គឺតាក់តែងមណ្ឌបពាសពិតានស ។

[ ៦២ ] បទថា **តិណ្ណំ វេទានំ** បានដល់ ឥរុវេទ យជុវេទ និងសាមវេទ រួមគម្ពីរនិឃណ្ឌុសាស្ត្រ និងកេដុភសាស្ត្រចូលគ្នា ឈ្មោះថា **សនិឃណ្ឌុកេដុភានំ** ។ បទថា **និឃណ្ឌុ** គឺគម្ពីរដែលប្រាប់ការផ្សេងគ្នា ជា

គម្ពីរប្រាប់ឈ្មោះដែលផ្សេងគ្នារបស់ដើមឈើជាដើម ។ បទថា **កេដុភំ** គឺគម្ពីរកំណត់ពាក្យកិរិយា ជាគម្ពីរជំនួយដល់កវីទាំងឡាយ មួយអន្លើដោយអក្ខរប្បភេទ ឈ្មោះថា **សាក្ខរប្បភេទានំ** ។ បទថា **អក្ខរប្បភេទោ** បានដល់ ការសិក្សាអក្សរ និងភាសា ។ បទថា **ឥតិហាសបញ្ចមានំ** មានវិគ្គហៈថា ឈ្មោះថា មានគម្ពីរឥតិហាសៈជាគម្រប់ ៥ ព្រោះរាប់អាថព្វនវេទជាទី ៤ មានឥតិហាសៈដែលជារឿងបុរាណ ដែលក្នុងគម្ពីរនេះ មានពាក្យផ្តើមគ្រប់រឿងថា **ឥតិហ អាស ឥតិហ អាស** ជាគម្រប់ ៥ ។ វេទទាំងនោះ មានឥតិហាសៈជាគម្រប់ ៥ ។ សេលព្រាហ្មណ៍ ជាបុគ្គលយល់បទយល់ក្នុងវេយ្យាករណ៍ ព្រោះរៀន និងចេះបទ និងវេយ្យាករណ៍ ដែលក្រៅអំពីបទនោះ ។ សេលព្រាហ្មណ៍ ឈ្មោះថា ជាអ្នកជំនាញក្នុងគម្ពីរលោកាយតៈ និងតម្រាទាយមហាបុរិសលក្ខណៈ ព្រោះជាអ្នកចេះចប់ បរិបូណ៌ក្នុងគម្ពីរលោកាយតៈ និងគម្ពីរវិតណ្ឌវាទសាស្ត្រ និងគម្ពីរមហាបុរិសលក្ខណសាស្ត្រ ១២០០០ ដែលជាគម្ពីរគោលរបស់គម្ពីរមហាបុរិសលក្ខណៈ លោកអធិប្បាយថា មិនមាននូវការវិនាស ។ បុគ្គលមិនអាចទ្រទ្រង់ចាំនូវគម្ពីរទាំងនោះបានដោយអត្ថ និងដោយគន្ថៈ បុគ្គលនោះ ឈ្មោះថា វិនាស ។

ការសម្រាកដែលជាប្រយោជន៍ដល់ស្មង ហៅថា **ជង្ឃាវិហារំ** ។ លោកអធិប្បាយថា ការដើរទៅមិនឆ្ងាយ ដើម្បីសម្រួលស្មង ដើម្បីបន្ទោបង់នូវការចុកស្រពន់ ដែលកើតអំពីការអង្គុយយូរជាដើម ។ បទថា **អនុចង្កមមានោ** បានដល់ ដើរទៅមកនោះឯង ។ បទថា **អនុវិចរមានោ** បានដល់ ត្រាច់ទៅ

ដោយជុំវិញ ។ បទថា **កេណិយស្ស ជដិលស្ស អស្សមោ** បានដល់ អាស្រមដែលជាលំនៅរបស់កេណិយជដិល ។ បទថា **អាវាហោ** បានដល់ នាំកូនក្រមុំមក ។ បទថា **វិវាហោ** បានដល់ នាំកូនក្រមុំទៅ ។ បទថា **មហាយញ្ញោ** បានដល់ ការបូជាធំ ។ បទថា **មាគធោ** បានដល់ ជាអ្នកធំនៃអ្នកមគធៈ ។ ឈ្មោះថា **សេនិយោ** ព្រោះប្រកបដោយមហាសេនា ។ បទថា **ពិម្ពិ** បានដល់មាស ។ ព្រោះហេតុនោះ ឈ្មោះថា **ពិម្ពិសារ** ព្រោះមានពណ៌ដូចជុំមាស ។ បទថា **សោ មេ និមន្តិតោ** សេចក្តីថា ខ្ញុំនិមន្តព្រះមានព្រះភាគមក ។

លំដាប់នោះ ព្រាហ្មណ៍បានឮសំឡេងថា **ពុទ្ធ** ព្រោះភាពដែលខ្លួនសន្សំបុណ្យមកអំពីមុន ទើបដូចស្រោចដោយទឹកអម្រឹត មានការអស្ចារ្យពោលថា បពិត្រកេណិយៈដ៏ចម្រើន លោកនិយាយថា ព្រះពុទ្ធឬ ។ កេណិយជដិលប្រាប់តាមសេចក្តីពិត ពោលថា បពិត្រសេលព្រាហ្មណ៍ដ៏ចម្រើន អាត្មានិយាយថា ព្រះពុទ្ធ ។ ដើម្បីឲ្យច្បាស់លាស់ សេលព្រាហ្មណ៍ បានសួរកេណិយជដិលនោះដដែលទៀត កេណិយជដិលក៏ប្រាប់យ៉ាងនោះ ។

លំដាប់នោះ សេលព្រាហ្មណ៍ កាលនឹងសម្តែងសំឡេងថា **ពុទ្ធោ** រកបានដោយលំបាក អស់សែនកប្ប ទើបពោលថា សំឡេងគឹកកងថា **ពុទ្ធ** នេះ គេរកបានដោយក្រក្នុងលោក ។ បណ្តាបទទាំងនោះ បទថា **យគិធំ** ជានិបាត ។ លោកពោលអធិប្បាយថា ស្មើគ្នានឹង **យោ ឯសោ** ប្រែថា ព្រះអង្គនោះ ។ លំដាប់នោះ ព្រាហ្មណ៍បានឮសំឡេងថា **ពុទ្ធ** ទើបគិតប្រាថ្នា

នឹងសាកល្បងមើលថា បុគ្គលនោះជាព្រះពុទ្ធពិត ឬជាព្រះពុទ្ធត្រឹមឈ្មោះប៉ុណ្ណោះ ទើបបានពោលថា **អាគតានិ ខោ បន។បេ។ វិវដច្ឆទោ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មន្តេសុ** គឺក្នុងវេទទាំងឡាយ ។ ទេវតាជាន់សុទ្ធាវាសបានដំណឹងថា ព្រះពុទ្ធនឹងកើតឡើងក្នុងលោក ប្រញាប់កាឡាខ្លួនជាព្រាហ្មណ៍ដាក់ព្រះលក្ខណៈចូលទៅ ហើយប្រាប់នូវវេទទាំងឡាយ ដោយគិតថា បណ្ដាសត្វដែលមានសក្តិធំ នឹងស្គាល់ព្រះតថាគត ដោយមើលតាមព្រះលក្ខណៈនោះ ។ ដោយហេតុនោះ ទើបមហាបុរិសលក្ខណៈ មកក្នុងវេទទាំងឡាយ តែកាលព្រះតថាគតបរិនិព្វានហើយ វេទទាំងឡាយ ក៏បាត់ទៅដោយលំដាប់ ឥឡូវនេះ មិនមានឡើយ ។ បទថា **មហាបុរិសស្ស** បានដល់បុរសធំដោយគុណ មានការតាំងចិត្ត ការសមាទាន និងញាណជាដើម ។ បទថា **ទ្វេវ គតិយោ** បានដល់ សេចក្ដីសម្រេច ២ យ៉ាងនោះឯង ។ ម្យ៉ាងទៀត **គតិ** សព្ទនេះ រមែងប្រព្រឹត្តទៅក្នុងប្រភេទនៃភព ទីលំនៅ បញ្ញា សេចក្ដីបរិសុទ្ធជាដើម ។

មកក្នុងអត្ថថា ភព ដូចក្នុងប្រយោគជាដើមថា **បញ្ច ខោ ឥមា សារីបុត្ត គតិយោ** មា□សារីបុត្រ ភពមាន ៥ នេះ ដូចេ□ះ

ប្រព្រឹត្តទៅក្នុង ទីលំនៅ ដូចក្នុងប្រយោគជាដើមថា **គតិ មិគានំ បវនំ** □ព្រៃធំជាទីអាស្រ័យនៅរបស□ម្រឹគទាំងឡាយ ដូចេ□ះ

ប្រព្រឹត្តទៅក្នុង បញ្ញា ដូចក្នុងប្រយោគជាដើមថា **ឯវំ អធិមត្ត-គតិមន្តោ** អ□មានបញ្ញា□ច្រើនបែបនេះ ដូចេ□ះ

*ប្រព្រឹត្តទៅក្នុងសេចក្តីបរិសុទ្ធ ដូចក្នុងប្រយោគជាដើមថា* **គតិគតំ** *ប្រព្រឹតទៅតាមគតិ ដូចេះ ៗ តែក្នុងទីនេះ គប្បីជ្រាបថា ប្រព្រឹត្តទៅក្នុងសេចក្តីសម្រេច ។*

*ក្នុងពាក្យនោះ ទោះបីបុគ្គលប្រកបដោយលក្ខណៈជាស្តេចចក្រពត្តិបាន តែជាព្រះពុទ្ធបានដោយលក្ខណៈនោះក៏មិនមែន តែជនទាំងឡាយ ហៅយ៉ាងនោះឯង ព្រោះស្មើគ្នាដោយកំណើត ព្រោះហេតុនោះ ទើបសេលព្រាហ្មណ៍ពោលថា* **យេហិ សមន្នាគតស្ស** *ដូច្នេះ ។ បទថា* **សចេ អគារំ អជ្ឈាវសតិ** *គឺបើនៅគ្រប់គ្រងផ្ទះ ។ បទថា* **រាជា ហោតិ ចក្កវត្តី** *មានវិគ្គហៈថា ឈ្មោះថា* **រាជា** *ព្រោះញុំាងសត្វលោកឲ្យត្រេកអរដោយអច្ឆរិយ-ធម៌ និងដោយសង្គហវត្ថុ ៤ ឈ្មោះថា* **ចក្កវត្តិ** *ព្រោះញុំាងចក្ករតនៈឲ្យប្រព្រឹត្តទៅ រមែងវិលទៅដោយចក្រ ដែលជាសម្បត្តិ ៤ យ៉ាង និងញុំាងអ្នកដទៃឲ្យវិលទៅដោយចក្កសម្បត្តិទាំងនោះ មានការវិលទៅនៃចក្រ គឺឥរិយាបថ ដើម្បីប្រយោជន៍ដល់អ្នកដទៃ ។ ក្នុង ២ បទនេះ បទថា* **រាជា** *ជាឈ្មោះ បទថា* **ចក្កវត្តី** *ជាឈ្មោះវិសេស ។ ឈ្មោះថា* **ធម្មិកោ** *ព្រោះប្រព្រឹត្តដោយធម៌ អធិប្បាយថា ប្រព្រឹត្តទៅដោយការដឹង ដោយភាពស្មើ ។ ឈ្មោះថា* **ធម្មរាជា** *ព្រោះបាននូវរាជសម្បត្តិដោយធម៌ ហើយជាព្រះរាជា ។ម្យ៉ាងទៀត ឈ្មោះថា* **ធម្មិកោ** *ព្រោះបំពេញប្រយោជន៍ដើម្បីអ្នកដទៃ ។ ឈ្មោះថា* **ធម្មរាជា** *ព្រោះបំពេញដើម្បីប្រយោជន៍ដល់ខ្លួន ។ ឈ្មោះថា* **ចាតុរន្តោ** *ព្រោះជាធំក្នុងផែនដី មានមហាសមុទ្រ ៤ ជាព្រំដែន អធិប្បាយ*

ថា ជាធំក្នុងផែនដី មានសមុទ្រ ៤ ជាទីបំផុត និងមានទ្វីប ៤ ជាគ្រឿងប្រដាប់ ឈ្មោះថា **វិជិតាវី** ព្រោះទ្រង់ឈ្នះនូវសត្រូវ មានសេចក្ដីក្រោធជាដើមខាងក្នុង និងឈ្នះព្រះរាជាទាំងអស់ខាងក្រៅ ។ បទថា **ជនបទត្ថាវរិយប្បត្តោ** គឺដល់នូវសេចក្ដីចម្រើន មាំទាំ ក្នុងជនបទដែលបុគ្គលណាម្នាក់មិនអាចធ្វើឲ្យញាប់ញ័របាន ។ ម្យ៉ាងទៀត ឈ្មោះថា **ជនបទត្ថាវរិយប្បត្តោ** ព្រោះជនបទដល់នូវការមាំទាំក្នុងសេចក្ដីចម្រើននោះ មិនមានខ្វល់ខ្វាយក្នុងការងាររបស់ខ្លួន មិនញាប់ញ័រ មិនកក្រើករំពើក ដូច្នេះក៏មាន ។ បទថា **សេយ្យថីទំ** ជានិបាត សេចក្ដីថា រតនៈ ៧ មានអ្វីខ្លះ ។ រតនៈ ៧ គឺចក្ករតនៈ ១ ហត្ថីរតនៈ ១ អស្សរតនៈ ១ មណិរតនៈ ១ ឥត្ថីរតនៈ ១ គហបតិរតនៈ ១ បរិនាយករតនៈ ១ ទាំងអស់ លោកពោលហើយក្នុងអដ្ឋកថា រតនសូត្រ ។

ក្នុងរតនៈទាំងនោះ ស្ដេចចក្រពត្តិ ទ្រង់ឈ្នះដែនដោយចក្រហើយទ្រង់ត្រាច់ទៅតាមសប្បាយក្នុងដែន ដោយដំរីកែវ និងសេះកែវ ទ្រង់រក្សាដែន ដោយបរិនាយកកែវ សោយសុខ ដែលជាគ្រឿងឧបភោគបរិភោគដោយរតនៈដ៏សេស ស្ដេចចក្រពត្តិនោះ ទ្រង់អាចក្នុងផ្លូវដែលរឹងមាំ ដោយចក្រកែវ ទ្រង់ប្រើអំណាចក្នុងការគ្រប់គ្រងដោយដំរីកែវ សេះកែវ និងគហបតីកែវ ទ្រង់ប្រើអំណាចក្នុងការប្រឹក្សារឿងដែលជ្រាលជ្រៅ ដោយបរិនាយកកែវ ដែលគ្រប់បរិបូណ៌ដោយល្អ ។ ផលនៃការប្រើអំណាច ៣ យ៉ាងសម្រេចដោយស្រីកែវ និងកែវមណី ។ ស្ដេចចក្រពត្តិនោះ សោយភោគសុខ

ដោយស្រីកែវ និងកែវមណី សោយឥស្សរិយសុខ ដោយកែវដ៏សេស ។ ក្រៃលែងជាងនោះ គប្បីជ្រាបថា កែវ ៣ យ៉ាង ខាងដើមរបស់ស្តេចចក្រពត្តិនោះ សម្រេចដោយអានុភាពនៃកម្មដែលកើតអំពីកុសលមូល គឺអទោសៈ កែវកណ្តាល ( ៣ ) សម្រេចដោយអានុភាពនៃកម្ម ដែលកើតអំពីកុសល-មូល គឺអលោភៈ កែវចុងក្រោយ សម្រេចដោយអានុភាពនៃកម្ម គឺអមោហៈ ។

បទថា **បរោសហស្សំ** គឺមានច្រើនជាងពាន់ ។ បទថា **សូរា** គឺមិនខ្លាច ។ បទថា **វីរង្គរូបា** គឺមានកាយដូចទេវបុត្ត ។ អាចារ្យមួយពួកពោលត្រឹមប៉ុណ្ណេះ ។ តែសេចក្តីពិត ក្នុងបទនេះ មានដូច្នេះថា ពាក្យថា **វីរ** លោកពោលថា ក្លាហានបំផុត អង្គរបស់អ្នកក្លាហាន ឈ្មោះថា **វីរង្គ** លោកអធិប្បាយថា ហេតុនៃការក្លាហាន ឈ្មោះថា **វីរិយ** ។ ឈ្មោះថា **វីរង្គរូបា** ព្រោះមានរូបសមជាអ្នកក្លាហាន អធិប្បាយថា ដូចមានសរីរៈសម្រេចដោយសេចក្តីក្លាហាន ។ បទថា **បរសេនប្បមទ្ទនា** អធិប្បាយថា បើសត្រូវប្រឈមមុខ អាចញាំញីសត្រូវនោះបាន ។ បទថា **ធម្មេន** គឺដោយធម៌ បានដល់ សីល ៥ មាន **ពាណោ ន ហន្តព្វោ** ប្រែថា កុំសម្លាប់សត្វជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទនេះ **អរហំ ហោតិ សម្មាសម្ពុទ្ធោ លោកេ វិវដ្ដច្ឆទោ** ដូចតទៅនេះថា

ព្រះសម្មាសម្ពុទ្ធ ឈ្មោះថា **វិវដ្ដច្ឆទោ** ព្រោះកាលលោកងងឹតដោយកិលេស ត្រូវដំបូល គឺកិលេស ដែលបានដល់ រាគៈ ទោសៈ មោហៈ មានះ

ទិដ្ឋិ អវិជ្ជា និងទុច្ចរិតទាំង ៧ យ៉ាងបិទបាំង ជាអ្នកបើកនូវដំបូល គឺកិលេស នោះ ធ្វើឲ្យមានពន្លឺតាំងនៅដោយជុំវិញ ។ ក្នុងពាក្យទាំងនោះ គប្បីជ្រាបថា ភាពជាបុគ្គលគួរបូជា លោកពោលដោយពាក្យដំបូង ព្រោះហេតុនៃភាពជា បុគ្គលគួរបូជាដោយពាក្យទី ២ ភាពជាបុគ្គលត្រាស់ដឹងដោយប្រពៃ ដោយ ព្រះអង្គឯង ភាពជាបុគ្គលមានដំបូល គឺរាគាទិក្កិលេសបើកហើយដោយពាក្យ ទី ៣ ។ម្យ៉ាងទៀត ព្រះសម្មាសម្ពុទ្ធ ឈ្មោះថា **វិវដច្ឆទោ** ព្រោះបើក និង មិនបិទ លោកអធិប្បាយថា វៀរចាកការវិលវល់ និងវៀរចាកការបិទ ។ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **អរហំ** ព្រោះមិនមានការវិលវល់ និង ព្រះនាមថា **សម្មាសម្ពុទ្ធោ** ព្រោះមិនមានការបិទបាំង ។ ឈ្មោះថា លោក អធិប្បាយហេតុទាំង ២ នៃបទ ២ ខាងដើមនោះឯង ។ ម្យ៉ាងទៀត ក្នុងបទ នោះគប្បីសម្រេចកាលមុន រមែងមានដោយវេសារជ្ជធម៌ទី ២ សេចក្ដីសម្រេច លើកទី ២ រមែងមានដោយវេសារជ្ជធម៌ទី ១ សេចក្ដីសម្រេចលើកទី ៣ រមែងមានដោយវេសារជ្ជធម៌ទី ៣ និងទី ៤ ។ ម្យ៉ាងទៀត គប្បីជ្រាបថា ធម្មចក្ខុសម្រេចមុន ពុទ្ធចក្ខុសម្រេចលើកទី ២ សមន្តចក្ខុសម្រេចលើកទី ៣ ។ ឥឡូវនេះ សេលព្រាហ្មណ៍បំណងនឹងគាល់ព្រះមានព្រះភាគ ទើបពោលថា **កហំ បន ភោ គោតម ។បេ។ សម្មាសម្ពុទ្ធោ** ដូច្នេះ ។

[ ៦៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឯវំ វុត្តេ** ជាដើមដូចតទៅនេះ បទថា **យេនេសា** គឺព្រះមានព្រះភាគគង់នៅដោយទិសាភាគនោះ ។ បទថា **នីលវនរាជី** បានដល់ ជួរព្រៃមានពណ៌ខៀវ បានឮថា ព្រៃនោះ ដូចគ្នានឹង

ផ្លូវនៃមេឃ ព្រះមានព្រះភាគគង់នៅក្នុងដងព្រៃនោះ កេណិយជដិលកាលនឹងចង្អុលព្រៃនោះ ទើបពោលថា ម្នាលសេលព្រាហ្មណ៍ដ៏ចម្រើន ផ្លូវនៃព្រៃខៀវៗ នុ៎ះ មានក្នុងចំណែកទិសណា ( ព្រះអង្គគង់ក្នុងចំណែកទិសនោះ ) ។ ត្រង់នេះឲ្យបន្ថែមពាក្យចូលមកថា **តត្ថ សោ វិហរតិ** ទ្រង់គង់នៅក្នុងទីនោះ ។ បទថា **យេន** ជាតតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ បទថា **បទេ បទំ** គឺដើរតិចៗ តាមគ្នាមក ។ ដោយបទនោះ បដិសេធការដើរលឿន ។ បទថា **ទុរាសទា ហិ** នេះ សេលព្រាហ្មណ៍ពោលដល់ហេតុថា ព្រោះលោកដ៏ចម្រើនទាំងនោះ ចូលដល់បានដោយលំបាក ព្រោះហេតុនោះ លោកដ៏ចម្រើនទាំងឡាយ ចូរមកយ៉ាងនេះ ។ បើមានពាក្យសួរថា ព្រោះហេតុអ្វី ទើបចូលដល់បានដោយលំបាក ។ ឆ្លើយថា ព្រោះត្រាច់ទៅម្នាក់ឯង ដូចរាជសីហ៍ ។ ពិតហើយ លោកដ៏ចម្រើនទាំងឡាយនោះ ត្រាច់ទៅម្នាក់ឯង ព្រោះប្រាថ្នានូវការស្ងាត់ ដូចរាជសីហ៍ ត្រាច់ទៅតែឯង ព្រោះមិនមានសម្លាញ់ ។ សេលព្រាហ្មណ៍ ឲ្យមាណពទាំងនោះសិក្សាមារយាទ ដោយបទជាដើមថា **យទា ចាហំ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **មា ឱបាតេថ** គឺកុំញុះញង់ អធិប្បាយថា កុំពោលញុះញង់ ។ បទថា **អាគមេន្តុ** គឺបង្អង់ អធិប្បាយថា ចូរនៅស្ងៀមសិន ទម្រាំនិយាយចប់ ។

បទថា **សមន្នេសិ** គឺពិនិត្យពិច័យមើល ។ បទថា **យេភុយ្យេន** គឺបានឃើញចំណែកច្រើន មិនបានឃើញចំណែកតិច ។ បន្ទាប់អំពីនោះ សេលព្រាហ្មណ៍ កាលប្រាប់មហាបុរិសលក្ខណៈដែលមិនឃើញ ទើបពោលថា

**ថបេត្វា ទេ្វ** ដូច្នេះ ។ បទថា **កង្ខតិ** គឺកើតសង្ស័យថា គប្បីឃើញបានដូចម្ដេចហ្ន៎ ។ បទថា **វិចិកិច្ឆតិ** គឺបន្ទាប់អំពីនោះ កាលគិត ក៏ងឿងឆ្ងល់មិនឃើញលក្ខណៈទាំងនោះ ។ បទថា **នាធិមុច្ចតិ** គឺព្រោះការសង្ស័យនោះទើបមិនជឿ ។ បទថា **ន សម្បសីទតិ** គឺមិនជ្រះថ្លាក្នុងព្រះមានព្រះភាគថាទ្រង់មានលក្ខណៈបរិបូណ៌ហើយ ។ សេចក្ដីសង្ស័យយ៉ាងខ្សោយ លោកពោលថា **កង្ខា** សេចក្ដីសង្ស័យយ៉ាងកណ្ដាល លោកពោលដោយបទថា **វិចិកិច្ឆា** សេចក្ដីសង្ស័យយ៉ាងខ្លាំងក្លា លោកប្រើក្នុងពាក្យថា **អនធិ-មុច្ចនតា** គឺភាពដែលចិត្តងឹតដោយធម៌ ៣ យ៉ាង ព្រោះមិនជ្រះថ្លា ។ បទថា **កោសោហិតេ** បានដល់ លាក់ក្នុងស្រោម ។ បទថា **វត្ថគុយ្ហេ** បានដល់ ព្រះអង្គជាតិ ។ ពិតហើយ ព្រះអង្គជាតិរបស់ព្រះមានព្រះភាគ លាក់នៅក្នុងស្រោម ដូចអង្គជាតិដំរី មានពណ៌ដូចមាស ដូចគ្រាប់ក្នុងផ្កាឈូក សេលព្រាហ្មណ៍មិនឃើញអង្គជាតិនោះ ព្រោះបិទបាំងក្នុងសំពត់ និងមិនបានសង្កេតឃើញព្រះជិវ្ហាដែលនៅក្នុងមហាព្រះឱស្ឋ ទើបសង្ស័យក្នុងព្រះលក្ខណៈទាំង ២ នោះ ។

បទថា **តថារូបំ** គឺមានរូបដូចម្ដេច ក្នុងបទនេះ យើងគួរពោលដូចម្ដេច លោកអធិប្បាយថា ព្រះនាគសេនត្ថេរ ត្រូវព្រះបាទមិលិន្ទត្រាស់សួរថា បពិត្រព្រះនាគសេន ព្រះមានព្រះភាគទ្រង់ធ្វើវត្ថុដែលធ្វើបានដោយក្រ ។ ព្រះនាគសេនសួរថា ក្រដូចម្ដេច ព្រះបាទមិលិន្ទត្រាស់ថា បពិត្រព្រះនាគសេន ព្រះមានព្រះភាគទ្រង់សម្ដែងឱកាស ( វត្ថុ ) ដែលមហាជនខ្មាស ដល់ព្រហ្មាយុ-

ព្រាហ្មណ៍ ដល់អន្តេវាសិកឧត្តរៈ ដល់ព្រាហ្មណ៍ ១៦ នាក់ ដែលជាអន្តេ-វាសិករបស់ពាវរីព្រាហ្មណ៍ និងដល់មាណព ៣០០ នាក់ ដែលជាអន្តេ-វាសិករបស់សេលព្រាហ្មណ៍ ។ ព្រះនាគសេនថ្វាយព្រះពរថា បពិត្រមហារាជ ព្រះមានព្រះភាគ មិនបានបង្ហាញព្រះគុយ្ហ ទ្រង់សម្តែងព្រះឆាយា ព្រះមានព្រះភាគទ្រង់បណ្តាលដោយឫទ្ធិ ទ្រង់បង្ហាញសំពត់ស្លៀក សំពត់ចងកាយ សំពត់ដណ្តប់ ត្រឹមតែរូបស្រមោល ។ ព្រះបាទមិលិន្ទត្រាស់សួរថា កាលឃើញព្រះឆាយា ក៏ជាការឃើញហើយ មិនមែនឬ ។ ព្រះនាគសេនថ្វាយព្រះពរថា បពិត្រមហារាជ សេចក្តីនោះ ចូរលើកទុក បើសត្វដែលឃើញហទយរូប ហើយត្រាស់ដឹងបាន ព្រះសម្មាសម្ពុទ្ធ ទ្រង់នឹងខ្វេះហទយៈមកបង្ហាញ ព្រះបាទមិលិន្ទត្រាស់ថា បពិត្រព្រះនាគសេន លោកម្ចាស់ឈ្លាសពេកណាស់ ។

បទថា **ជិវ្ហាមេត្វា** គឺទ្រង់នាំចេញមក ។ ក្នុងបទនេះ គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់ប្រកាសដល់ភាពដែលព្រះជិវ្ហាវែង ដោយស៊កចូលក្នុងរន្ធព្រះកាណ៌ទាំង ២ ភាពដែលព្រះជិវ្ហាស្តើង ដោយស៊កចូលរន្ធព្រះនាសិកទាំង ២ ភាពដែលជិវ្ហាធំ ដោយបិទព្រះនលាដ ។

បទថា **អាចរិយចាចរិយានំ** បានដល់ អាចារ្យទាំងឡាយ និងអាចារ្យនៃអាចារ្យទាំងឡាយ ។ បទថា **សកេ វណ្ណេ** បានដល់ គុណរបស់ខ្លួន ។

គ្រានោះឯង សេលព្រាហ្មណ៍ បានសរសើរព្រះមានព្រះភាគចំពោះព្រះភក្ត្រដោយគាថាដែលសមគួរថា

ព្រះអង្គជាបុគ្គល មានព្រះកាយបរិបូណ៌ មានពន្លឺសរីរៈល្អ មានព្រះជាតិល្អ មានការមៀងមើលល្អ ព្រះមានព្រះភាគមានសម្បុរដូចជាមាស មានព្រះទាឋាសសុទ្ធ មានព្យាយាម ព្រោះថាមហាបុរិសលក្ខណៈទាំងអស់នោះ មានប្រាកដក្នុងព្រះកាយរបស់ព្រះអង្គ ដែលជាជនមានកំណើតល្អ ។

បទថា **បរិបុណ្ណកាយោ** បានដល់ មានព្រះសរីរៈបរិបូណ៌ ព្រោះពេញដោយលក្ខណៈទាំងឡាយ និងព្រោះអវយវៈតូចធំមិនអាក្រក់ ។ បទថា **សុរុចិ** បានដល់ មានព្រះរស្មីនៃព្រះសរីរៈល្អ ។ បទថា **សុជាតោ** បានដល់ ទ្រង់កើតល្អហើយ ដោយសម្បត្តិ គឺកម្ពស់ និងទំហំ និងដោយសម្បត្តិគឺសណ្ឋាន ។ បទថា **ចារុទស្សនោ** បានដល់ ព្រះមានព្រះភាគ ឈ្មោះថា **ចារុទស្សនោ** ព្រោះមើលល្អ ធ្វើឲ្យអ្នកមើលមិនឆ្អែតឆ្អន់ មិនគួរស្អប់ គួរត្រេកអរ ។ តែអាចារ្យពួកខ្លះពោលថា បទថា **ចារុទស្សនោ** គឺមានព្រះនេត្រល្អ ។ បទថា **សុវណ្ណវណ្ណោ** គឺមានព្រះឆវីដូចមាស ។ បទថា **អសិ** ប្រែថា មាន ។ បទនេះ គប្បីប្រកបចូលគ្រប់បទទាំងអស់ ។ បទថា **សុសុក្កទាឋោសិ** គឺមានព្រះចង្កូមសស្អាត ពិតហើយ ព្រះរស្មីពណ៌សដ៏ក្រៃលែង ផ្សាយចេញអំពីចង្កូមទាំងឡាយរបស់ព្រះមានព្រះភាគ ដូចពន្លឺចន្ទ ដោយហេតុនោះ ទើបសេលព្រាហ្មណ៍ពោលថា **សុសុក្កទាឋោសិ** ដូច្នេះ ។ បទថា **មហាបុរិសលក្ខណា** សេចក្តីថា សេលព្រាហ្មណ៍ពោលសរុបព្យញ្ជនៈ ដែលពោលមុនហើយ ដោយរវាងបទ ។ ឥឡូវនេះ សេលព្រាហ្មណ៍

សរសើរព្រះមានព្រះភាគ ដោយព្រះលក្ខណៈដែលខ្ជូនគាប់ចិត្តក្រៃលែង ក្នុងបណ្តាលក្ខណៈទាំងនោះ ទើបពោលពាក្យជាដើមថា **បសន្ននេត្តោ** ដូច្នេះ ។

ពិតហើយ ព្រះមានព្រះភាគ ឈ្មោះថា **បសន្ននេត្តោ** ព្រោះសម្បូរដោយបសាទទាំង ៥ ឈ្មោះថា **សុមុខោ** ព្រោះមានព្រះភក្ត្រដូចមណ្ឌលនៃព្រះចន្ទពេញវង់ ។ ឈ្មោះថា **ព្រហា** ព្រោះសម្បូរដោយកម្ពស់ និងទំហំ ឈ្មោះថា **ឧជុ** ព្រោះមានកាយត្រង់ដូចកាយព្រហ្ម ឈ្មោះថា **បតាបវា** ព្រោះមានរស្មីរុងរឿង ។ម្យ៉ាងទៀត ក្នុងបទទាំងនេះ ពាក្យណា លោកពោលមុនហើយ ពាក្យនោះ ព្រាហ្មណ៍ក៏បានពោលដដែលទៀត ព្រោះជាពាក្យសរសើរដោយបរិយាយនេះថា **មជ្ឈេ សមណសង្ឃស្ស** ដូច្នេះ ។ ព្រោះលោកអ្នកជាបុគ្គលបែបនេះ រមែងរុងរឿងដោយប្រការ ដូច្នេះ ។ សូម្បីក្នុងគាថាដ៏សេស ក៏ន័យនេះឯង ។

បទថា **ឧត្តមវណ្ណិនោ** គឺជាអ្នកសម្បូរដោយវណ្ណៈដ៏ឧត្តម ។ បទថា **ជម្ពុសណ្ឌស្ស** គឺជម្ពូទ្វីប ។ សេលព្រាហ្មណ៍ពោលសរសើរភាពជាធំក្រៃលែងឲ្យប្រាកដ ។ ម្យ៉ាងទៀត ស្តេចចក្រពត្តិ រមែងជាធំក្នុងទ្វីបទាំង ៤ ។ បទថា **ខត្តិយា** គឺជាក្សត្រដោយជាតិ ។ បទថា **ភោជ** គឺមានភោគសម្បត្តិ ។ បទថា **រាជានោ** គឺព្រះរាជាអង្គណាមួយ គ្រងរាជសម្បត្តិ ។ បទថា **អនុយន្តា** បានដល់ សេវកៈដែលដើរតាម ។ បទថា **រាជាភិរាជា** គឺជាព្រះរាជាដែលព្រះរាជាទាំងឡាយបូជា បំណងយកស្តេចចក្រពត្តិ ។ បទថា **មនុជិន្ទោ** គឺជាធំក្នុងមនុស្ស ជាធំក្រៃលែង ។

កាលសេលព្រាហ្មណ៍ក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ កាលទ្រង់ធ្វើសេចក្តីប្រាថ្នានេះ របស់សេលព្រាហ្មណ៍ឲ្យពេញថា បុគ្គលណា ជាព្រះអរហន្តសម្មាសម្ពុទ្ធ បុគ្គលនោះ កាលពោលដល់គុណរបស់ខ្លួន រមែងធ្វើខ្លួនឲ្យប្រាកដ ទើបត្រាស់ថា **រាជាហមស្មិ** ដូច្នេះ ។

ក្នុងបទនោះ មានអធិប្បាយដូច្នេះថា ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសេលព្រាហ្មណ៍ អ្នករមែងពោលសេចក្តីណាថា ទ្រង់គួរជាស្តេចក្រពត្តិ ព្រោះហេតុនោះ ចូរអ្នកធ្វើសេចក្តីខ្វល់ខ្វាយតិចក្នុងសេចក្តីនេះ ព្រោះតថាគត ជាព្រះរាជា កាលបើភាពជាព្រះរាជាមាន ព្រះរាជាអង្គដទៃសូម្បីមាន រមែង គ្រប់គ្រងក្នុងទី ១ រយយោជន៍ខ្វះ ២ រយយោជន៍ខ្វះ ៣ រយយោជន៍ខ្វះ ៤ រយយោជន៍ខ្វះ ៥ រយយោជន៍ខ្វះ ឬ ១ ពាន់យោជន៍ខ្វះ សូម្បីជាស្តេច ចក្រពត្តិក៏គ្រប់គ្រងទ្វីបធំ មានទ្វីប ៤ ជាព្រំដែន យ៉ាងណា តថាគត មិន មានព្រំដែនកំណត់យ៉ាងនោះ ជាធម្មរាជាដ៏កំពូល គ្រប់គ្រងលោកធាតុទាំង-ឡាយ រាប់មិនអស់ រាប់តាំងអំពីភវគ្គព្រហ្ម រហូតដល់អវិចីនរកជាទីបំផុត តថាគតជាបុគ្គលប្រសើរជាងសត្វមិនមានជើង និងសត្វជើង ២ ជាដើម មិន មានអ្នកណាប្រៀបជាមួយតថាគតដោយសីល ។បេ។ ឬវិមុត្តិញ្ញាណទស្សនៈ តថាគតជាធម្មរាជាដ៏កំពូលយ៉ាងនេះ ញ៉ាំងចក្រឲ្យប្រព្រឹត្តទៅដោយធម៌ គឺ ពោធិបក្ខិយធម៌ មានសតិប្បដ្ឋាន ៤ ជាដើមដ៏កំពូលនោះឯង តថាគតញ៉ាំង អាណាចក្រឲ្យប្រព្រឹត្តទៅ ដោយន័យជាដើមថា ចូរពួកអ្នកលះធម៌នេះ ចូរ ដល់ធម៌នេះ ដូច្នេះ ឬញ៉ាំងធម្មចក្រ ឲ្យប្រព្រឹត្តទៅដោយបរិយត្តិធម៌ថា ម្នាល

ភិក្ខុទាំងឡាយ នេះឯងជាទុក្ខអរិយសច្ច ដូច្នេះជាដើម ។ បទថា **ចក្កំ អប្បដិវត្តិយំ** សេចក្តីថា តថាគតញុំាងចក្រដែលសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី បុគ្គលណាមួយក្តីក្នុងលោក ឲ្យប្រព្រឹត្តទៅមិនបាន ឲ្យប្រព្រឹត្តទៅដោយធម៌ ។

សេលព្រាហ្មណ៍ឃើញព្រះមានព្រះភាគ បើកព្រះអង្គឲ្យជាក់ច្បាស់យ៉ាងនេះហើយ កើតបីតិសោមនស្ស ធ្វើឲ្យមាំទាំក្រៃលែង ទើបពោល ២ គាថាថា **សម្ពុទ្ធោ បដិជានាសិ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **កោ នុ សេនាបតី** សេលព្រាហ្មណ៍ទូលសួរថា អ្នកណាជាសេនាបតី ដែលជាប់តាមធម្មចក្រ ដែលទ្រង់ជាធម្មរាជាឲ្យប្រព្រឹត្តទៅហើយដោយធម៌ ។ សម័យនោះ ព្រះសារីបុត្តអង្គុយខាងស្តាំព្រះមានព្រះភាគ ល្អដោយសិរី ដូចដុំមាស ។ ព្រះមានព្រះភាគ កាលទ្រង់បង្ហាញព្រះសារីបុត្តនោះ ទើបត្រាស់គាថាថា **មយា បវត្តិតំ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អនុជាតោ តថាគតំ** សេចក្តីថា ព្រះសារីបុត្តជាអនុជាត គឺកើតព្រោះតថាគតជាហេតុ ។

ព្រះមានព្រះភាគ កាលទ្រង់ព្យាករបញ្ហាថា សាវកណាជាសេនាបតី ដូច្នេះហើយ មានបំណងនឹងធ្វើឲ្យសេលព្រាហ្មណ៍ដែលពោលថា ព្រះអង្គប្តេជ្ញាជាព្រះសម្ពុទ្ធ ឲ្យអស់សង្ស័យក្នុងសេចក្តីនោះ ដើម្បីឲ្យដឹងថា តថាគតមិនបានប្តេជ្ញា ត្រឹមតែពាក្យប្តេជ្ញាប៉ុណ្ណោះ សូម្បីតថាគតក៏ប្តេជ្ញាថាជាព្រះពុទ្ធដោយហេតុនេះ ទើបត្រាស់គាថាថា **អភិញ្ញេយ្យំ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អភិញ្ញេយ្យំ** បានដល់ វិជ្ជា និងវិមុត្តិ ។ ឯមគ្គសច្ច និងសមុទយសច្ច ជាធម៌ដែលគួរចម្រើន និងគួរលះ ។ សេចក្តីនេះលោកអធិប្បាយយ៉ាងនេះថា សូម្បីនិរោធសច្ច និងទុក្ខសច្ច ដែលជាផលនៃមគ្គសច្ច និងសមុទយសច្ចទាំងនោះ ដោយសម្រេចជាផល ឈ្មោះថាពោលដោយពោលដល់ហេតុ ព្រោះធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ តថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ធម៌ដែលគួរដឹង តថាគតដឹងច្បាស់ហើយ ។ ដើម្បីទ្រង់សម្តែងការញុំាងសច្ចៈ ៤ ឲ្យកើតផលនៃការចម្រើនសច្ចៈ ៤ វិជ្ជា និងវិមុត្តិ ទើបទ្រង់ប្រកាសភាពជាពុទ្ធៈ ដោយហេតុដែលត្រាស់ហើយថា តថាគតត្រាស់ដឹងធម៌ដែលគួរត្រាស់ដឹងហើយ ទើបជាពុទ្ធៈ ។

ព្រះមានព្រះភាគ កាលទ្រង់ធ្វើព្រះអង្គឲ្យប្រាកដដោយ ត្រង់យ៉ាងនេះហើយ កាលញុំាងព្រាហ្មណ៍ឲ្យប្រញាប់ខ្វល់ខ្វាយ ដើម្បីឆ្លងផុតសេចក្តីសង្ស័យក្នុងព្រះអង្គ ទើបត្រាស់គាថាទី ៣ ថា **វិនយស្សុ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សល្លកត្តោ** គឺជាអ្នកវះកាត់នូវព្រួញដែលដោតសត្វ មានព្រួញ គឺរាគៈជាដើមចេញបាន ។ បទថា **ព្រហ្មភូតោ** គឺជាបុគ្គលប្រសើរបំផុត ។ បទថា **អតិតុលោ** គឺកន្លងនូវការថ្លឹង កន្លងនូវការប្រៀបធៀប អធិប្បាយថា ប្រៀបមិនបាន ។ បទថា **មារសេនប្ប-មទ្ទនោ** គឺញុំាញីនូវមារ និងសេនា ពោល គឺបរិស័ទរបស់មារ ដែលលោកពោលយ៉ាងនេះថា កាមជាសេនាទី ១ របស់អ្នក និងបន្ទាប់បន្ទោនពួកជនដទៃផង ដូច្នេះ ។ បទថា **សព្វាមិត្តេ** បានដល់ សត្រូវទាំងអស់ មានខន្ធមារ

កិលេសមារ អភិសង្ខារមារ មច្ចុមារ និងទេវបុត្តមារជាដើម ។ បទថា **វសីកត្វា** គឺឲ្យប្រព្រឹត្តទៅក្នុងអំណាចនៃខ្លួន ។ បទថា **អកុតោភយោ** គឺ មិនមានភ័យអំពីទីណា ។

ព្រះមានព្រះភាគ កាលត្រាស់យ៉ាងនេះហើយ រំពេចនោះឯង សេល-ព្រាហ្មណ៍កើតនូវសេចក្តីជ្រះថ្លាក្នុងព្រះមានព្រះភាគ ប្រាថ្នានឹងបួស ទើបពោលគាថាទី ៣ ថា **ឥមំ ភោន្តោ** ព្រោះសេលព្រាហ្មណ៍ បានទទួលការទូន្មានដោយប្រពៃ ព្រោះដល់ព្រមដោយឧបនិស្ស័យ ដល់នូវភាពជាអ្នកចាស់ក្លា ។

ក្នុងបទទាំងនោះ បទថា **កណ្ហាភិជាតិកោ** គឺកើតក្នុងត្រកូលថោកទាប មានត្រកូលចណ្ឌាលជាដើម ។ បន្ទាប់អំពីនោះ បណ្តាមាណពទាំងនោះក៏ប្រាថ្នានឹងបួសដូចគ្នា ទើបពោលថា **ឯវំ ចេ រុច្ចតិ ភោតោ** ព្រោះជាកុលបុត្តដែលសន្សំបុណ្យមកជាមួយសេលព្រាហ្មណ៍នោះឯង ។ លំដាប់នោះ សេលព្រាហ្មណ៍ត្រេកអរក្នុងពួកមាណពទាំងនោះ នាំមាណពទាំងនោះចូលគាល់កាលសូមបួសទើបពោលថា ពួកព្រាហ្មណ៍ ៣ រយនាក់ទាំងនេះជាដើម ។

បន្ទាប់អំពីនោះ ព្រះមានព្រះភាគ ព្រោះសេលព្រាហ្មណ៍បានជាមេគណៈបុរស ៣០០ នាក់នោះ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈក្នុងអតីត បានសាងបរិវេណជាមួយនឹងបុរសទាំងនោះ ហើយធ្វើនូវបុណ្យ មានទានជាដើម សោយនូវទេវសម្បត្តិ និងមនុស្សសម្បត្តិ ដោយលំដាប់ ក្នុងភពចុងក្រោយ កើតជាអាចារ្យនៃបុរសទាំងនោះ ហើយកម្មនៃជនទាំងនោះក៏ចាស់ក្លា ព្រោះចាស់ក្លាដោយវិមុត្តិ និងមានឧបនិស្ស័យនៃភាព

ជាឯហិភិក្ខុ ដូច្នោះ ទើបទ្រង់ឲ្យជនទាំងនោះបព្វជ្ជា ដោយឯហិភិក្ខុបព្វជ្ជា ត្រាស់គាថាថា ក្នុងព្រហ្មចរិយធម៌ណា ព្រហ្មចរិយធម៌នោះ តថាគតសម្ដែងល្អហើយជាដើម ។

ក្នុងបទទាំងនោះ បទថា **សន្ទិដ្ឋិកំ** គឺប្រចក្សឯង បទថា **អកាលិកំ** គឺមានផលសម្រេចអំពីការកើតផលបន្ទាប់អំពីមគ្គ មិនមែនក្នុងវេលាបន្ទាប់មក ។ បទថា **យត្ថ** គឺនិមិត្តយ៉ាងណា ។ ពិតហើយ បព្វជ្ជា មានមគ្គព្រហ្មចរិយៈជានិមិត្ត រមែងមិនទទេចាកប្រយោជន៍ ដល់អ្នកសិក្សាក្នុងសិក្ខា ៣ ដែលមិនប្រមាទ វៀរការនៅប្រាសចាកសតិ ។ ដោយហេតុនោះ ទើបទ្រង់ត្រាស់ថា **ស្វាក្ខាតំ ។បេ។ សិក្ខតោ** ដូច្នេះ ។ ព្រះមានព្រះភាគត្រាស់ហៅថា ចូរពួកអ្នកជាភិក្ខុចុះ ភិក្ខុទាំងអស់នោះទ្រទ្រង់នូវបាត្រ និងចីវរមកតាមអាកាស ថ្វាយបង្គំព្រះមានព្រះភាគ ។ ព្រះសង្គីតិកាចារ្យពោលថា **អលត្ថ ខោ សេលោ ព្រាហ្មណោ ។បេ។ ឧបសម្បទំ** សំដៅដល់ ភាពជាឯហិភិក្ខុរបស់លោកទាំងនោះ ដោយប្រការដូច្នេះ ។

[ ៦៥ ] បទថា **ភុត្តាវី** គឺសោយស្រេចហើយ ។ បទថា **ឱនីតបត្តបាណឹ** គឺដកព្រះហស្តចេញអំពីបាត្រហើយ ។ លោកអធិប្បាយថា នាំព្រះហស្តចេញហើយ ។ ក្នុងបទនោះ គប្បីឃើញបាឋៈដែលខ្វះថា **ឧបគន្ត្វា** ចូលទៅជិតហើយ ។ កាលកាន់យកសេចក្ដីតាមនេះ មិនគួរប្រើថា **ភគវន្តំ ឯកមន្តំ និសីទិ។**

បទថា **អគ្គិហុតំ មុខា** ព្រះមានព្រះភាគ កាលទ្រង់អនុមោទនាដោយ

សេចក្តីអនុគ្រោះកេណិយៈ ទើបត្រាស់យ៉ាងនេះ ។

ក្នុងបទនោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា ព្រះមានព្រះភាគត្រាស់ថា ការបូជាទាំងឡាយ មានការបូជាភ្លើងជាប្រធាន ព្រោះពួកព្រាហ្មណ៍មិនមានការបូជាក្រៅអំពីការបូជាភ្លើង អធិប្បាយថា ការបូជាភ្លើង ប្រសើរបំផុត គឺការបូជាភ្លើងជាប្រមុខ ព្រះមានព្រះភាគត្រាស់ថា គម្ពីរសាវិត្តិសាស្រ្ត ជាប្រធាននៃគម្ពីរឆន្ទសាស្រ្ត ព្រោះបុគ្គលស្វាធ្យាយវេទទាំងឡាយ ត្រូវស្វាធ្យាយមុន ។ ទ្រង់ត្រាស់ថា ព្រះរាជាជាប្រធាន ព្រោះប្រសើរបំផុត ជាងមនុស្សទាំងឡាយ ទ្រង់ត្រាស់ថា សាគរជាប្រធាន ព្រោះជាទីទទួល និងជាទីអាស្រ័យនៃស្ទឹងទាំងឡាយ ។ ទ្រង់ត្រាស់ថា ព្រះចន្ទ្រជាប្រធាននៃផ្កាយទាំងឡាយ ព្រោះការគោចររបស់ព្រះចន្ទ្រ ធ្វើឲ្យដឹងថា ថ្ងៃនេះ ជាកត្តិកាឫក្ស ថ្ងៃនេះជារោហិណីឫក្ស ព្រោះធ្វើឲ្យមានពន្លឺ និងព្រោះមានពន្លឺល្អ ។ ទ្រង់ត្រាស់ថា ព្រះអាទិត្យជាប្រធាននៃកំដៅទាំងឡាយ ព្រោះព្រះអាទិត្យប្រសើរជាងកំដៅទាំងឡាយ ។ ទ្រង់ត្រាស់ថា ព្រះសង្ឃជាប្រធាននៃជនទាំងឡាយ កាលបូជាប្រាថ្នានូវបុណ្យ ក៏យ៉ាងនោះដែរ សំដៅដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធានក្នុងសម័យនោះ ព្រោះព្រះសង្ឃដោយចំពោះ ដែលមានព្រះពុទ្ធជាប្រធាន ប្រសើរជាងទក្ខិណេយ្យបុគ្គលទាំងឡាយ ។ ដោយពាក្យនោះ ទ្រង់សម្តែងថា ព្រះសង្ឃជាប្រធាន នៃការចម្រើននូវបុណ្យ ។

ចំណែកសេលភិក្ខុ ក្រាបទូលការព្យាករណ៍ព្រះអរហត្ត ដោយគាថាថា **យន្តំ សរណំ** ជាដើម ។ បទនោះ មានអធិប្បាយដូច្នេះថា បពិត្រព្រះមាន

ព្រះភាគ ទ្រង់មានចក្ខុ ៥ ព្រោះខ្ញុំព្រះអង្គទាំងឡាយ ដល់នូវព្រះអង្គជាទីពឹង ក្នុងថ្ងៃទី ៨ រាប់អំពីថ្ងៃនេះ គឺដល់សរណៈបានត្រឹម ៨ ថ្ងៃ ដូច្នោះ ទើបខ្ញុំព្រះអង្គទាំងឡាយទូន្មានខ្លួន ដោយការទូន្មានខ្លួនយ៉ាងក្រៃលែង ក្នុងសាសនារបស់ព្រះអង្គ ៧ រាត្រី គួរអស្ចារ្យអានុភាពនៃសរណៈរបស់ព្រះអង្គ ។

បន្ទាប់អំពីនោះ សេលភិក្ខុសរសើរព្រះមានព្រះភាគដោយ ២ គាថា ហើយនមស្ការដោយគាថាទី ៣ ថា

បពិត្រព្រះអង្គជាវីរបុរស ពួកភិក្ខុទាំង ៣០០ រូបនេះ ធ្វើ
អញ្ជលី ( ចំពោះព្រះអង្គ ) សូមទ្រង់សណ្ដូកព្រះបាទទាំងគូ
ពួកភិក្ខុដ៏ប្រសើរ សូមថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះសាស្ដា ។

**អដ្ឋកថា សេលសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## សល្លសូត្រទី៨

[ ៦៧ ] ( សេចក្តីថា ព្រះមានព្រះភាគ ទ្រង់សម្តែងសល្លសូត្រនេះ ) ថា ជីវិតរបស់សត្វទាំងឡាយ ក្នុងលោកនេះ មិនមានកំណត់ មិនមានអ្នកណាមួយអាចដឹងបាន ជីវិតនោះ ជារបស់ក្រផង តិចផង ប្រកបដោយសេចក្តីទុក្ខផង ។ ពួកសត្វដែលកើតហើយ រមែងមិនស្លាប់ ដោយសេចក្តីព្យាយាមណា សេចក្តីព្យាយាមនោះមិនមានឡើយ កាលដល់នូវសេចក្តីគ្រាំគ្រាហើយស្លាប់តែងមាន ព្រោះពួកសត្វទាំងឡាយ មានយ៉ាងនេះ ជាធម្មតា ។ ផ្លែឈើទាំងឡាយដែលទុំហើយ តែងមានភ័យអំពីការជ្រុះ ក្នុងពេលព្រឹក យ៉ាងណាមិញ សត្វទាំងឡាយដែលកើតហើយ តែងមានសេចក្តីភ័យ អំពីសេចក្តីស្លាប់ អស់កាលជានិច្ច យ៉ាងនោះដែរ ។ ភាជន៍ដីទាំងឡាយ ដែលស្មូនឆ្នាំងធ្វើហើយ ភាជន៍ទាំងអស់នោះ សុទ្ធតែមានកិរិយាបែកជាទីបំផុត យ៉ាងណាមិញ ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។ ពួកជនណា ក្មេងក្តី ចាស់ក្តី ពាលក្តី បណ្ឌិតក្តី ពួកជនទាំងអស់នោះ តែងលុះក្នុងអំណាចនៃមច្ចុ ពួកជនទាំងអស់មានមច្ចុទៅស្អាក់ខាងមុខ ។ កាលពួកជនទាំងនោះ ត្រូវមច្ចុគ្របសង្កត់ហើយ កាលទៅក្នុងបរលោក បិតាការពារបុត្តមិនបាន ឬពួកញាតិក៏ការពារញាតិមិនបាន ។ អ្នកចូរមើលនូវការ

រៀបរាប់ជាច្រើនរបស់ពួកញាតិ ដែលកំពុងអាឡោះអាល័យ បណ្ដាសត្វទាំងឡាយ សត្វតែម្នាក់ៗ ដែលត្រូវមច្ចុនាំទៅ ដូចជាគោត្រូវគេសម្លាប់ សត្វលោកត្រូវមច្ចុ និងជរា គ្របសង្កត់ហើយ យ៉ាងនេះ ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយ រមែងមិនសោកស្ដាយឡើយ ព្រោះដឹងច្បាស់នូវបរិយាយនៃសត្វលោក ។ អ្នកមិនស្គាល់ផ្លូវរបស់សត្វណា ដែលមក ឬទៅ មិនឃើញជាក់លាក់ នូវចំណែកទាំងពីររបស់សត្វនោះ អ្នកខ្សឹកខ្សួលឥតអំពើទេ បើបុគ្គលវង្វេងវង្វាន់ ខ្សឹកខ្សួល ផ្តួលខ្លួនហើយបាននូវប្រយោជន៍តិចតួច ម៉្លេះសមអ្នកប្រាជ្ញឈ្លាសវៃ គប្បីធ្វើនូវសេចក្ដីខ្សឹកខ្សួលនោះដែរ ។ បុគ្គលមិនមែនដល់នូវការស្ងប់រម្ងាប់ចិត្ត ព្រោះការយំការសោកទេ ទុក្ខកើតឡើងដោយក្រៃលែងដល់បុគ្គល កាលយំសោកនោះ ទាំងសរីរៈក៏លំបាក ។ បុគ្គលដែលផ្តួលខ្លួនដោយខ្លួនឯង តែងជាអ្នកស្គម អាប់សម្បុរ អ្នកចែកឋានទាំងឡាយ រមែងមិនរស់វិញបាន ដោយការខ្សឹកខ្សួលនោះទេ ការខ្សឹកខ្សួល ជាការឥតអំពើ ។ សត្វកាលប្ដូរស្ដាយបុគ្គលដែលធ្វើមរណកាល លុះអំណាចសេចក្ដីសោក មិនលះបង់សេចក្ដីសោកចេញទេ រមែងដល់នូវទុក្ខជាយ៉ាងក្រៃលែង ។ អ្នកចូរមើលសត្វទាំងឡាយ មានជីវិតឯទៀតក្នុងលោកនេះ ដែលអន្ទោលទៅតាមកម្ម ហៀបនឹងទៅ ( កាន់បរលោក ) បម្រះ

នទៀត ព្រោះលុះអំណាចនៃមច្ចុ ។ ពួកសត្វតែងសម្គាល់ ( ថានឹងមានអាយុវែង ) ដោយអាការណា។ ការសម្គាល់នោះរមែងផ្សេងអំពីអាការនោះៗ ការព្រាត់និរាសប្រាកដដូច្នោះ អ្នកចូរមើលបរិយាយរបស់សត្វលោកចុះ ។ ទោះបីសត្វដែលរស់នៅអស់មួយរយឆ្នាំ ឬលើសជាង សេចក្តីព្រាត់ប្រាសចាកពួកញាតិរមែងមាន ( ព្រោះថា ) សត្វក្នុងលោកនេះ រមែងលះបោលជីវិត ។ ព្រោះហេតុនោះ បុគ្គលបានស្តាប់ ( ធម្មទេសនា ) របស់ព្រះអរហន្តហើយ ឃើញអ្នកដែលចែកឋាន ធ្វើមរណកាលទៅហើយ គប្បីបន្ទោបង់សេចក្តីខ្សឹកខ្សួលថា អ្នកចែកឋានទៅនុ៎ះ អាត្មាអញ ឃាត់មិនបានទេ ។ បុគ្គលគប្បីលត់ផ្ទះ ដែលភ្លើងឆេះដោយទឹក យ៉ាងណាមិញ នរជនជាអ្នកប្រាជ្ញ ប្រកបដោយប្រាជ្ញា ជាបណ្ឌិត ឆ្លៀវឆ្លាស គប្បីកម្ចាត់បង់ឲ្យធ្លាប់រហ័ស នូវសេចក្តីសោកដែលកើតឡើង ដូចខ្យល់បំបើុងបុ៉យគរ ក៏យ៉ាងនោះដែរ ។ បុគ្គលកាលស្វែងរកសេចក្តីសុខបម្រុងខ្លួន គប្បីដកចេញនូវសរ គឺសេចក្តីខ្សឹកខ្សួលរបស់ខ្លួន ទាំងតណ្ហា និងទោមនស្សរបស់ខ្លួនចេញ បុគ្គលមានសរដកហើយ មិនអាស្រ័យ ( ដោយតណ្ហា និងទិដ្ឋិ ) គប្បីដល់នូវសេចក្តីស្ងប់នៃចិត្ត កន្លងផុតសេចក្តីសោកទាំងអស់ ហើយជាអ្នកមិនមានសោក ជាអ្នករលត់ទុក្ខ ។

# អដ្ឋកថា

## សល្លសូត្រ

[ ៦៧ ] ក្នុងសល្លសូត្រទី ៨ មានពាក្យផ្ដើមថា **អនិមិត្តំ** ដូច្នេះ ។

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅនេះ

បានឮថា ឧបាសកម្នាក់ ជាឧបដ្ឋាករបស់ព្រះមានព្រះភាគ បុត្តរបស់ឧបដ្ឋាកនោះ បានធ្វើអនិច្ចកម្ម គាត់ត្រូវសេចក្ដីសោកព្រោះបុត្តគ្របសង្កត់ ធ្វើនូវការអត់អាហារអស់ ៧ ថ្ងៃ ព្រះមានព្រះភាគ កាលទ្រង់អនុគ្រោះ ទើបយាងទៅកាន់ផ្ទះឧបាសកនោះ ដើម្បីបន្ទោបង់សេចក្ដីសោក ទើបត្រាស់សូត្រនេះ ។

ក្នុងបទទាំងនោះ បទថា **អនិមិត្តំ** បានដល់ វៀរគ្រឿងសម្គាល់ គឺកិរិយាអាការ ។ ដូចមានគ្រឿងសម្គាល់ គឺកិរិយាអាការក្នុងបទជាដើមថា ខ្ញុំនឹងប៉ប្រិចភ្នែក ឬក៏ញាក់ចិញ្ចើម ចូរអ្នកលួចទ្រព្យនោះ ដោយសញ្ញានោះយ៉ាងណា ក្នុងជីវិតមិនដូច្នោះឡើយ បុគ្គលណាម្នាក់មិនអាចបាន ( តាមពាក្យសូម ) ថា ចូរអ្នករស់នៅសិន កុំអាលស្លាប់ ទម្រាំខ្ញុំធ្វើវត្ថុនោះហើយ ។ បទថា **អនញ្ញាតំ** គឺដែលបុគ្គលណាម្នាក់ មិនអាចដឹងដោយពិតប្រាកដថា បុគ្គលនេះ រស់នៅអស់កាលប៉ុណ្ណេះៗ ដោយគតិ ឬទីបំផុតនៃអាយុ ដូចជាអាយុរបស់ទេវតាជាន់ចាតុម្មហារាជិកាជាដើមកំណត់បាន អាយុរបស់សត្វទាំងឡាយ មិនដូច្នោះឡើយ ដោយហេតុនេះ ទើបជីវិតនៃសត្វទាំងឡាយ បុគ្គលណាម្នាក់ដឹងមិនបានដោយពិត ។ បទថា **កសិរំ** គឺលំបាក ព្រោះការ

ប្រព្រឹត្តទៅ ទាក់ទងដោយបច្ច័យច្រើនយ៉ាង មិនមែនប្រព្រឹត្តទៅបានដោយងាយឡើយ ។ សេចក្តីពិតយ៉ាងនោះ ជីវិតទាក់ទងដោយខ្យល់ដង្ហើមចេញចូល ទាក់ទងដោយមហាភូតរូប ទាក់ទងដោយកវឡិង្ការាហារ ទាក់ទងដោយភ្លើងធាតុ និងទាក់ទងដោយវិញ្ញាណ ។ កាលមិនដកដង្ហើមចេញចូល ក៏រស់នៅមិនបាន ។ម្យ៉ាងទៀត ក្នុងធាតុ ៤ កាយដូចត្រូវអាសិរពិស មានកដ្ឋមុខជាដើមខាំ ព្រោះបឋវីធាតុកម្រើក កាយនឹងរឹង ដូចគ្នានឹងអង្កត់ឧស ដូចលោកពោលថា

កាយដែលត្រូវពស់កដ្ឋមុខចឹក រមែងរឹង ឬព្រោះបឋវីធាតុកម្រើក
កាយនោះ រមែងដូចនៅក្នុងមាត់ពស់កដ្ឋមុខ ដូច្នោះ ។

កាយព្រោះអបោធាតុកម្រើក ដល់នូវការរលួយ មានសាច់ និងឈាមទាំងឡាយហូរចេញ សល់តែឆ្អឹង និងស្បែកប៉ុណ្ណោះ ដូចលោកពោលថា

កាយដែលត្រូវពស់បូតិមុខចឹក រមែងជារបស់ស្អុយ រលួយ ឬ
ព្រោះអាបោធាតុកម្រើក កាយនោះ ក៏ហាក់ដូចជានៅក្នុងមាត់
ពស់បូតិមុខ ដូច្នោះ ។

កាយព្រោះតេជោធាតុកម្រើក រមែងត្រូវដុតរោលដោយជុំវិញ ដូចដាក់ទៅក្នុងរណ្តៅរងើកភ្លើង ដូចលោកពោលថា

កាយដែលត្រូវពស់អគ្គិមុខចឹក រមែងក្តៅក្រហាយព្រម ឬព្រោះ
តេជោធាតុកម្រើក កាយនោះ រមែងដូចជានៅក្នុងមាត់ពស់អគ្គិមុខ
ដូច្នេះ ។

កាយព្រោះវាយោធាតុកម្រើក មានទឹតត្រូវកាត់ផ្តាច់អំពីគ្នា ដូចភ្លើងដែលត្រូវដុំថ្ម គប់ឲ្យខ្ចាយទៅ សមដូចលោកពោលថា

កាយដែលត្រូវពស់សត្ថមុខចឹក រមែងត្រូវដាច់ ឬព្រោះ
វាយោធាតុកម្រើក កាយនោះ រមែងដូចជានៅក្នុងមាត់ពស់
សត្ថមុខ ដូច្នោះ ។

កាយដល់នូវសេចក្តីវិនាស ព្រោះធាតុកម្រើក ក៏រស់នៅមិនបាន ។ កាលណាធាតុទាំងនោះ ធ្វើកិច្ចនៃគ្នានិងគ្នាជាប្រក្រតី ប្រព្រឹត្តទៅស្មើ កាលនោះ ជីវិតក៏នៅប្រព្រឹត្តទៅបាន ។ ជីវិតទាក់ទងដោយមហាភូតរូបយ៉ាងនេះ ។ ក្នុងខណៈរកភិក្ខាបានដោយលំបាកជាដើម ព្រោះខ្វះអាហារ សត្វទាំងឡាយក៏នឹងស្លាប់ទាំងអស់ ជីវិតទាក់ទងដោយកវឡិង្ការាហារយ៉ាងនេះ ។

ម្យ៉ាងទៀត កាលអស់ភ្លើងធាតុដែលកើតអំពីកម្មដែលធ្វើឲ្យអាហាររលួយ ព្រោះការបរិភោគ ការផឹកជាដើម សត្វទាំងឡាយ ក៏ដល់នូវការស្លាប់ទាំងអស់ ជីវិតទាក់ទងដោយភ្លើងធាតុយ៉ាងនេះ ។

កាលវិញ្ញាណរលត់ សត្វស្លាប់តាមប្រក្រតី នឹងមិនមានជីវិត ជីវិតប្រាកដនៅក្នុងលោក ដោយអាការយ៉ាងនេះ ។ ជីវិតទាក់ទងដោយវិញ្ញាណយ៉ាងនេះ ។ គប្បីជ្រាបជីវិត ឈ្មោះថា លំបាក ព្រោះមានការរស់នៅទាក់ទងដោយបច្ច័យច្រើនយ៉ាង ។

បទថា **បរិត្តញ្ច** គឺជីវិតរបស់មនុស្ស ប្រៀបធៀបនឹងជីវិតរបស់ទេវតាទាំងឡាយហើយ តិចតួច ដូចជាតំណក់ទឹកសន្សើមលើចុងស្មៅ ម្យ៉ាង

ទៀត ឈ្មោះថា តិច ព្រោះមិនរស់នៅខ្ពស់ជាងខណៈចិត្ត ពិតហើយ សត្វ សូម្បីមានអាយុវែងរស់នៅហើយដោយចិត្តអតីត មិនមែនកំពុងរស់នៅ មិនមែននឹងរស់នៅ ។ ក្នុងអនាគត ចិត្តមិនមែននឹងរស់នៅ មិនមែនកំពុងរស់នៅ មិនមែនធ្លាប់រស់នៅ ។ ក្នុងបច្ចុប្បន្ន ចិត្តកំពុងរស់នៅ មិនមែនធ្លាប់រស់នៅហើយ មិនមែននឹងរស់នៅ សមដូចលោកពោលក្នុង ( ខុទ្ទកនិកាយ មហានិទ្ទេស ) ថា

**ជីវិតំ អត្តភាវោ ច សុខទុក្ខា ច កេវលា**
**ឯកចិត្តសមាយុត្តា លហុសោ វត្តតេ ខណោ។**
**ចុល្លាសីតិ សហស្សានិ កប្បា តិដ្ឋន្តិ យេ មរូ**
**ឯត្វេវ តេបិ ជីវន្តិ ទ្វីហិ ចិត្តេហិ សមាហិតា។**

ជីវិត អត្តភាព សុខ និងទុក្ខទាំងអស់ ប្រកបដោយខណៈ ចិត្តតែមួយ ព្រោះខណៈប្រព្រឹត្តទៅរហ័ស ពួកទេវតាណា ឋិតនៅអស់ ៨៤០០០ កប្ប ទេវតាទាំងនោះ មិនមែនប្រកបដោយចិត្តពីរ ហើយរស់នៅទេ ។

បទថា **តញ្ច ទុក្ខេន សំយុតំ** សេចក្តីថា ជីវិតនោះ មិនមានគ្រឿងសម្គាល់ បុគ្គលណាម្នាក់ ដឹងមិនបានយ៉ាងនេះ ជារបស់លំបាកផង តិចផង និងប្រកបដោយទុក្ខ ដែលកើតអំពីសម្ផស្ស រងា ក្តៅ របោម និងមូសជាដើម កើតអំពីការស្រេកឃ្លាន កើតអំពីទុក្ខប្រចាំសង្ខារ ទុក្ខព្រោះការប្រែប្រួល និងទុក្ខព្រោះជាសភាពអត់ធន់បានលំបាក ។ ព្រះមានព្រះភាគ ទ្រង់

ត្រាស់ដូចម្តេច ។ ទ្រង់ត្រាស់ថា ជីវិតនៃសត្វទាំងឡាយ បែបនេះ ដូច្នោះ ចូរអ្នកប្រព្រឹត្តព្រហ្មចរិយៈ ដរាបជីវិតនោះ មិនទាន់អស់ទៅ អ្នកកុំសោយសោកដល់បុត្តឡើយ ។

អ្នកគប្បីសម្គាល់ដូច្នោះ កុំសោយសោកយ៉ាងនេះថា កាលអញមើលថែបុត្ត ដោយគ្រឿងឧបភោគបរិភោគសព្វយ៉ាង បុត្តនោះ បានស្លាប់ហើយ ខ្ញុំសោយសោកដោយហេតុនោះ ដូច្នេះ ។ សត្វទាំងឡាយ ដែលកើតហើយ នឹងមិនស្លាប់ ដោយសេចក្តីព្យាយាមណាមួយ ការព្យាយាមនោះមិនមានទេ លោកអធិប្បាយថា បុគ្គលណាម្នាក់មិនអាចនឹងរក្សាដោយសេចក្តីព្យាយាមណាមួយថា សត្វទាំងឡាយ ដែលកើតហើយ ចូរកុំស្លាប់ឡើយ ។ ព្រោះឧបាសកគិតថា បុត្តនោះនៅបានដល់ចាស់ហើយ សឹមស្លាប់គួរ បុត្តរបស់ខ្ញុំព្រះអង្គនៅក្មេងណាស់ បានស្លាប់ហើយ ដូច្នេះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ជរម្បិ បត្វា មរណំ ឯវំធម្មា ហិ ចាណិនោ** មានអធិប្បាយថា ដល់ជរាក្តី មិនទាន់ដល់ជរាក្តី ក៏ត្រូវស្លាប់ មិនមានកំណត់ក្នុងសេចក្តីនេះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ឲ្យសេចក្តីនោះជាក់ច្បាស់ដោយឧបមា ទើបត្រាស់គាថាជាដើមថា **ផលានមិវ បក្កានំ** ដូច្នោះ ។

បទនោះ មានអធិប្បាយដូច្នេះថា កាលផ្លែឈើមិនទាន់ទុំ តាំងអំពីព្រះអាទិត្យរះ រសនៃផែនដី និងរសនៃទឹកត្រង់ដើមឈើដែលក្តៅ ដោយកម្តៅរបស់ព្រះអាទិត្យ រមែងចូលទៅកាន់ផែនដីតាមឫសដោយលំដាប់យ៉ាងនេះ គឺ

តាំងអំពីស្ទឹកដល់ឫស តាំងអំពីឫសដល់ដើម តាំងអំពីដើមដល់ឫស តែកាលព្រះអាទិត្យលិច មែក ស្ទឹក ពន្លកជាដើម រមែងតាំងឡើងទៀត ដោយលំដាប់យ៉ាងនេះ គឺតាំងអំពីផែនដីដល់ឫស តាំងអំពីឫសដល់ដើម ។ កាលដើមឈើតាំងនៅយ៉ាងនេះ ផ្លែឈើដែលទុំ រមែងមិនជាប់ត្រង់ទង កាលទងត្រូវពន្លឺព្រះអាទិត្យ រមែងក្តៅ ព្រោះហេតុនោះ ទើបផ្លែឈើនោះ ធ្លាក់ចុះសព្វកាល ភ័យរបស់ផ្លែឈើនោះក៏មាន ព្រោះការជ្រុះអំពីព្រឹក អធិប្បាយថា ភ័យតែងមានព្រោះការជ្រុះយ៉ាងនេះ ។ សត្វទាំងឡាយ កើតហើយ មានភ័យ ព្រោះត្រូវស្លាប់ជានិច្ច សត្វទាំងឡាយ ដូចគ្នានឹងផ្លែឈើទុំ ។ សួរថា ប្រៀបដូចអ្វីទៀត ឆ្លើយថា ប្រៀបដូចភាជន៍ដីដែលស្មូនធ្លាំងធ្វើហើយគ្រប់ប្រភេទ មានការបែកជាទីបំផុត យ៉ាងណា ជីវិតនៃសត្វទាំងឡាយក៏ដូច្នោះ ។ ព្រោះហេតុនោះ ទើបលោកកាន់យកយ៉ាងនេះថា ពួកជនណា ក្មេងក្តី ចាស់ក្តី ពាលក្តី បណ្ឌិតក្តី ពួកជនទាំងអស់នោះ តែងលុះក្នុងអំណាចមច្ចុ ពួកជនទាំងអស់ មានមច្ចុនៅស្មាក់ខាងមុខ ។ កាលកាន់យកយ៉ាងនេះហើយ ទ្រង់កាន់យកយ៉ាងនេះទៀតថា កាលពួកជនទាំងនោះ ត្រូវមច្ចុគ្របសង្កត់ហើយ កាលទៅក្នុងបរលោក បិតាការពារបុត្តមិនបាន ឬពួកញាតិក៏ការពារញាតិមិនបាន ។ ព្រោះឪពុកការពារកូនមិនបាន ឬពួកញាតិការពារពួកញាតិមិនបាន ដូច្នោះ ចូរអ្នកមើលនូវការរៀបរាប់ជាច្រើន របស់ពួកញាតិដែលកំពុងអាឡោះអាល័យ បណ្តាសត្វទាំងឡាយ សត្វតែម្នាក់ៗ ដែលត្រូវមច្ចុនាំទៅ ដូចជាគោត្រូវគេសម្លាប់ ។ ក្នុងទីនោះ មានពាក្យអធិប្បាយថា ម្នាលឧបាសក

ចូរអ្នកឃើញដូចកាលពួកញាតិរបស់សត្វទាំងឡាយ ដែលត្រូវស្លាប់ កំពុងសម្លឹងមើល យំរៀបរាប់ដោយប្រការផ្សេងៗ ដោយន័យជាដើមថា លោកឪពុក អ្នកម្ដាយ សត្វដែលត្រូវស្លាប់ម្នាក់ឯងប៉ុណ្ណោះ ត្រូវមច្ចុនាំទៅ ដូចគោដែលត្រូវសម្លាប់ ត្រូវនាំទៅតែម្នាក់ដូច្នោះ ចូរសម្លឹងថា លោក មិនមានគ្រឿងការពារ ដូច្នេះ ។

ក្នុងពាក្យនោះ លោកអធិប្បាយថា បុគ្គលបរិបូណ៌ដោយបញ្ញា មានព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធជាដើមណា លោកទាំងនោះ រមែងដឹងថា លោកត្រូវមច្ចុ និងជរាបៀតបៀនយ៉ាងនេះ លោកនោះ ដែលបុគ្គលណាម្នាក់ មិនអាចជ្រកកោណបាន ព្រោះដូច្នោះ អ្នកប្រាជ្ញទាំងឡាយ រមែងមិនសោយសោក កាលដឹងសភាពរបស់លោកហើយ គឺដឹងសេចក្ដីពិតរបស់លោកនេះហើយ រមែងមិនសោយសោក ។

ពាក្យថា អ្នកមិនស្គាល់ផ្លូវរបស់សត្វណា ដែលមក ឬទៅ មិនឃើញជាក់លាក់នូវចំណែកទាំងពីររបស់សត្វនោះ អ្នកខ្សឹកខ្សួលឥតអំពើទេ លោកអធិប្បាយដូចម្ដេច លោកអធិប្បាយថា អ្នកមិនដឹងផ្លូវមករបស់អ្នកមកកាន់គភ៌មាតា ឬផ្លូវទៅរបស់អ្នក ចុតិអំពីលោកនេះហើយ ទៅក្នុងលោកដទៃ កាលមិនឃើញទីបំផុតទាំង ២ នោះ ទោះបីខ្សឹកខ្សួល ក៏ឥតប្រយោជន៍ ឯអ្នកប្រាជ្ញទាំងឡាយ ឃើញទីបំផុតទាំងនោះ កាលដឹងហើយ រមែងមិនសោយសោកដល់លោកសម្មតិ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ញុំាងការខ្សឹកខ្សួល ដែលមិន

មានប្រយោជន៍ ឲ្យជាប្រយោជន៍ដែលត្រាស់ក្នុងពាក្យនេះថា អ្នកខ្សឹកខ្សួល ឥតអំពើទេ ទើបត្រាស់ពាក្យថា បើបុគ្គលវង្វេងវង្វាន់ ខ្សឹកខ្សួល ផ្ដួលខ្លួនជាដើម ។

ក្នុងបទទាំងនោះ បទថា **ឧទព្ពហេ** គឺគប្បីឲ្យកើតឡើង ទ្រទ្រង់ទុក អធិប្បាយថា ឲ្យកើតព្រមក្នុងខ្លួន ។ បទថា **សម្មូឡ្ហោ ហឹសមត្តានំ** គឺជាអ្នកវង្វេង បៀតបៀននូវខ្លួនឯង ។ បទថា **កយិរា ចេនំ វិចក្ខណោ** សេចក្ដីថា បើបុគ្គលបែបនោះ គប្បីញ៉ាំងប្រយោជន៍ណាមួយឲ្យកើតបាន សូម្បីបុរសដែលឃើញច្បាស់ គប្បីធ្វើសេចក្ដីខ្សឹកខ្សួលនោះ ។ ក្នុងបទថា **ន ហិ រុណ្ណេន** នេះ មានពាក្យអធិប្បាយថា បុគ្គលមិនមែនដល់នូវការស្ងប់រម្ងាប់ព្រោះការយំ ការសោកទេ ។ ម្យ៉ាងទៀត កាលបុគ្គលនោះយំ និងសោក ទុក្ខកើតឡើងដោយក្រៃលែង ដល់បុគ្គលកាលយំសោកនោះ ទាំងសរីរៈក៏លំបាក ដល់នូវការស្គាំងស្គមដោយភាពជាអ្នកមានពណ៌សម្បុរសៅហ្មងជាដើម ។ បទថា **ន តេន បេតា** សេចក្ដីថា ដោយការខ្សឹកខ្សួលនោះ សត្វទាំងឡាយ ដែលលះលោកទៅហើយ រមែងរក្សាខ្លួនមិនបាន គឺញ៉ាំងខ្លួនឲ្យប្រព្រឹត្តទៅមិនបាន ការខ្សឹកខ្សួលនោះ មិនជាប្រយោជន៍ ដល់បុគ្គលទាំងនោះ ព្រោះហេតុនោះ ទើបការខ្សឹកខ្សួលមិនមានប្រយោជន៍ឡើយ ។ មិនមែនមិនមាននូវប្រយោជន៍តែម្យ៉ាងប៉ុណ្ណោះទេ គង់ញ៉ាំងនូវសេចក្ដីវិនាសជាច្រើនទៀត សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះសត្វកាលបូរស្ដាយបុគ្គលដែលធ្វើមរណកាល លុះអំណាចសេចក្ដីសោក មិនលះបង់សេចក្ដីសោក

ចេញទៅ រមែងដល់នូវទុក្ខយ៉ាងក្រៃលែង ។ ក្នុងបទទាំងនោះ បទថា **អនុត្ថុនន្តោ** គឺសោយសោកដល់ ។ បទថា **វសមន្វគូ** គឺទៅកាន់អំណាច ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងថា សេចក្តីសោក មិនមានប្រយោជន៍ និងភាពដែលសេចក្តីសោកនាំសេចក្តីវិនាសមកឲ្យហើយ ឥឡូវនេះ កាលទ្រង់ទូន្មានឲ្យកម្ចាត់សេចក្តីសោក ទើបត្រាស់ពាក្យជាដើមថា **អញ្ញេបិ បស្ស** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **គមិនេ** គឺអ្នកទៅ អធិប្បាយថា អ្នកត្រៀមនឹងទៅកាន់បរលោក ។ បទថា **ផន្ទន្តេវិធ បាណិនេ** បានដល់ សត្វក្នុងលោកនេះ កំពុងនាំគ្នាអន្ទះអន្ទែង ព្រោះខ្លាចសេចក្តីស្លាប់ ។ បទថា **យេន យេន** បានដល់ សត្វទាំងឡាយ រមែងសម្គាល់ដោយអាការណាថា ជាបុគ្គលមានអាយុវែង ជាអ្នកមិនមានរោគ អាការនោះ រមែងប្រែប្រួលទៅជាដទៃសម្គាល់យ៉ាងនេះហើយ រមែងស្លាប់ខ្លះ រមែងមានរោគខ្លះ ការព្រាត់ប្រាសចាកគ្នានិងគ្នា បែបនេះ រមែងមានដោយការសម្គាល់ថាជាសត្រូវ ម្នាលឧបាសក ចូរអ្នកមើលសភាវៈនៃលោកចុះ គប្បីជ្រាបយោជនាអធិប្បាយក្នុងបទនេះ ដោយប្រការដូច្នេះ ។

បទថា **អរហតោ សុត្វា** គឺបុគ្គលស្តាប់ធម្មទេសនារបស់ព្រះអរហន្តបែបនេះហើយ ។ បទថា **នេសោ លព្ភា មយា ឥតិ** សេចក្តីថា បុគ្គលអនិច្ចកម្មទៅហើយនោះ ឥឡូវនេះ អាត្មាអញមិនគប្បីបានថា ចូររស់នៅទៀតចុះ លោកអធិប្បាយថា កាលកំណត់ដឹងដោយប្រការដូច្នេះ គប្បីកម្ចាត់នូវការ

ខ្សឹកខ្សួលចោល ។ សួរថា មានអ្វីទឹងពោលទៀត ឆ្លើយថា បុគ្គលគប្បី លត់ផ្ទះដែលភ្លើងឆេះដោយទឹក យ៉ាងណាមិញ នរជនជាអ្នកប្រាជ្ញ ប្រកប ដោយប្រាជ្ញា ជាបណ្ឌិត ឆ្លៀវឆ្លាស គប្បីកម្ចាត់ឲ្យធាប់រហ័ស នូវសេចក្តី សោក ដែលកើតឡើង ដូចខ្យល់បំបើុងប៉ុយគរ ក៏យ៉ាងនោះដែរ ។

ក្នុងបទថា **ធីរោ** ជាដើម គប្បីជ្រាបដូច្នេះថា ឈ្មោះថា **ធីរោ** ព្រោះ ដល់ព្រមដោយបញ្ញា ។ ឈ្មោះថា **សប្បញ្ញោ** ព្រោះមានបញ្ញាសន្សំមក ច្រើន ។ ឈ្មោះថា **បណ្ឌិតោ** ព្រោះមានបញ្ញាកើតអំពីការស្តាប់ច្រើន ។ ឈ្មោះថា **កុសលោ** ព្រោះជាអ្នកគិត ។ ម្យ៉ាងទៀត គប្បីប្រកបចិន្តា- មយប្បញ្ញា សុតមយប្បញ្ញា ភាវនាមយប្បញ្ញាចូលផងដែរ ។ មិនមែនតែ សេចក្តីសោកតែម្យ៉ាងនោះទេ បុគ្គលកាលស្វែងរកសេចក្តីសុខបម្រុងខ្លួន គប្បី ដកចេញនូវសរ គឺសេចក្តីខ្សឹកខ្សួលរបស់ខ្លួន ទាំងតណ្ហា និងទោមនស្ស របស់ខ្លួនចេញ ។

ក្នុងបទទាំងនោះ បទថា **បជប្បំ** គឺតណ្ហា ។ បទថា **ទោមនស្សំ** គឺ ទុក្ខផ្លូវចិត្ត ។ បទថា **អព្វុឡ្ហេ** គឺគប្បីដក ។ បទថា **សល្លំ** នេះ បានដល់ សរ ៣ យ៉ាង ឈ្មោះថា សរ ព្រោះអត្ថថា នាំចេញបានដោយលំបាក និង ព្រោះអត្ថថា ទម្លុះចូលទៅខាងក្នុង ឬដែលពោលមុន ៧ ប្រការ បានដល់ សរ គឺរាគៈជាដើម ។ កាលដកនូវសរនោះបានហើយ ជាអ្នកមានសរ គឺ កិលេសដកឡើងហើយ ដែលតណ្ហា និងទិដ្ឋិមិនអាស្រ័យ ហើយដល់នូវការ ស្ងប់ ឈានកន្លងនូវសោកបានទាំងអស់ ជាអ្នកមិនមានសេចក្តីសោក ត្រជាក់

ដូច្នេះឯង ។

ព្រះមានព្រះភាគបញ្ចប់ទេសនា ដោយកំពូលនៃធម៌ គឺអរហត្ត ។ ក្នុងបទទាំងនោះ បទថា **អសិតោ** បានដល់ ដែលតណ្ហា និងទិដ្ឋិមិនអាស្រ័យហើយ ។ បទថា **បប្បុយ្យ** បានដល់ ដល់ហើយ ។ បទដ៏សេសក្នុងសូត្រនេះ មានអត្ថងាយយល់ហើយ ព្រោះដូច្នោះ មិនចាំបាច់ពណ៌នា ៕□

**អដ្ឋកថា សល្លសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## វាសេដ្ឋសូត្រទី៩

[ ៦៨ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងដងព្រៃឈ្មោះឥច្ឆានង្គលៈ ជិតស្រុកឈ្មោះឥច្ឆានង្គលៈ ។ សម័យនោះឯង ពួកព្រាហ្មណមហាសាលជាច្រើន មានឈ្មោះល្បីល្បាញ អាស្រ័យនៅក្នុងស្រុកឈ្មោះឥច្ឆានង្គលៈ គឺចង្កីព្រាហ្មណ៍ តារុក្ខព្រាហ្មណ៍ បោក្ខរសាតិព្រាហ្មណ៍ ជាណុស្សោណិព្រាហ្មណ៍ តោទេយ្យព្រាហ្មណ៍ និង ពួកព្រាហ្មណមហាសាលឯទៀត ដែលមានឈ្មោះល្បីល្បាញ ។ គ្រានោះ វាសេដ្ឋមាណព និងភារទ្វាជមាណពកំពុងដើរទៅដើរមកសម្រាកស្មង ក៏កើត អន្តរាកថានេះឡើងថា ម្នាលគ្នាយើង បុគ្គលឈ្មោះថាជាព្រាហ្មណ៍ តើដោយ ប្រការដូចម្តេច ។ ភារទ្វាជមាណពនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន បុគ្គលដែលមានកំណើតល្អទាំងពីរចំណែក គឺខាងមាតា និងខាងបិតា ជាអ្នក កើតក្នុងផ្ទៃរបស់ព្រាហ្មណីដែលបរិសុទ្ធ ដរាបអំពីគូនៃជីដូនជីតា ៧ តំណមក មិនមានអ្នកណាពោលទោសតិះដៀល ដោយការពោលអំពីជាតិបាន ម្នាល អ្នកដ៏ចម្រើន បុគ្គលបានឈ្មោះថាព្រាហ្មណ៍ ដោយហេតុប៉ុណ្ណោះឯង ។ វាសេដ្ឋមាណពនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏ម្រើន លុះតែបុគ្គលមាន សីលផង បរិបូណ៌ដោយវត្តផង ម្នាលអ្នកដ៏ចម្រើន បុគ្គលនោះ ទើប ហៅថា ព្រាហ្មណ៍ ដោយហេតុប៉ុណ្ណោះឯង ។ ភារទ្វាជមាណព មិនអាច ញុំាងវាសេដ្ឋមាណពឲ្យយល់ឃើញបាន ទាំងវាសេដ្ឋមាណព ក៏មិនអាច ញុំាងភារទ្វាជមាណពឲ្យយល់ឃើញបាន ។ គ្រានោះ វាសេដ្ឋមាណពហៅ

ការទ្វាជមាណពថា ម្នាលការទ្វាជៈដ៏ចម្រើន ព្រះសមណគោតមនេះ ជាសក្យបុត្ត ចេញចាកសក្យត្រកូល ទ្រង់ព្រះផ្នួស ( ឥឡូវនេះ ) គង់នៅក្នុងដងព្រៃឥច្ឆានង្គលៈ ជិតស្រុកឈ្មោះឥច្ឆានង្គលៈ កិត្តិសព្ទដ៏ពីរោះរបស់ព្រះគោតមដ៏ចម្រើននោះ ខ្ចរខ្ចាយសុសសាយទៅយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ។បេ។ ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងត្រឡប់មកកើតក្នុងភពថ្មីទៀត ម្នាលការទ្វាជៈ មក យើងនឹងចូលសំដៅទៅត្រង់ទីដែលព្រះសមណគោតមគង់ លុះចូលទៅហើយនឹងសួរសេចក្ដីនេះ ព្រះសមណគោតមនឹងដោះស្រាយឲ្យយើងយ៉ាងណា យើងនឹងចាំទុកនូវសេចក្ដីនោះយ៉ាងនោះ ។ ការទ្វាជមាណពទទួលស្ដាប់ពាក្យរបស់វាសេដ្ឋមាណពថា អើអ្នក ។ គ្រានោះ វាសេដ្ឋមាណព និងការទ្វាជមាណព ចូលសំដៅទៅត្រង់កន្លែងដែលព្រះមានព្រះភាគគង់ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ វាសេដ្ឋមាណព លុះអង្គុយក្នុងទីសមគួរហើយ ក្រាបទូលព្រះមានព្រះភាគ ដោយគាថាទាំងឡាយថា

[ ៦៩ ] បពិត្រព្រះអង្គដ៏ចម្រើន យើងជាអ្នកមានត្រៃវិជ្ជា ដែល
អាចារ្យអនុញ្ញាត និងប្ដេជ្ញាហើយដោយពិត ខ្ញុំព្រះអង្គជាសិស្ស
បោក្ខរសាតិព្រាហ្មណ៍ មាណពនេះ ជាសិស្សរបស់តារុក្ខ-
ព្រាហ្មណ៍ ។ ពាក្យណារបស់អ្នកមានត្រៃវិជ្ជាទាំងឡាយ ដែល
អាចារ្យបានប្រាប់ហើយ ពួកយើងជាអ្នកសម្រេចក្នុងពាក្យនោះ

ហើយ យើងទាំងឡាយជាអ្នកចេះបទ ចេះវេយ្យាករណ៍ក្នុងវេទ ប្រហែលនឹងអាចារ្យ ។ បពិត្រព្រះគោតម ពួកយើងនោះ មានការជជែកគ្នាក្នុងការពោលអំពីជាតិ ការទ្វាជមាណពនិយាយថា បុគ្គលជាព្រាហ្មណ៍ ព្រោះជាតិ ។ ឯខ្ញុំព្រះអង្គនិយាយថា បុគ្គលដែលឈ្មោះថាព្រាហ្មណ៍ព្រោះកម្ម បពិត្រព្រះអង្គជាបុគ្គលមានចក្ខុ សូមព្រះអង្គជ្រាបយ៉ាងនេះ ។ យើងទាំងពីរនាក់នោះ មិនអាចញ៉ាំងគ្នានិងគ្នាឲ្យយល់ឃើញបានទេ ( ព្រោះហេតុនោះ ) ទើបយើងទាំងឡាយមកដើម្បីសួរព្រះអង្គដ៏ចម្រើន ដែលល្បីល្បាញថា ជាអ្នកត្រាស់ដឹងឯង បពិត្រព្រះគោតម ពួកជនផ្គងអញ្ជលីចូលទៅ កាលថ្វាយបង្គំ ក៏ថ្វាយបង្គំព្រះចន្ទ ដែលកន្លងនូវការអស់ទៅនៃងងឹត ( ព្រះចន្ទពេញវង់ ) យ៉ាងណាមិញ ពួកជនក្នុងលោក ( ក៏ថ្វាយបង្គំព្រះអង្គ ) យ៉ាងនោះដែរ ។ ពួកយើង សូមសួរព្រះគោតម ដែលមានចក្ខុកើតហើយក្នុងលោក បុគ្គលឈ្មោះថាព្រាហ្មណ៍ព្រោះជាតិ ឬព្រោះកម្ម សូមព្រះអង្គសម្តែងប្រាប់ពួកយើង ដែលជាអ្នកមិនទាន់ស្គាល់ ឲ្យទាល់តែពួកយើងស្គាល់ ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលវាសេដ្ឋៈ ) បើដូច្នោះ តថាគតនឹងសម្តែងឲ្យពិស្តារអំពីជាតិ របស់សត្វទាំងឡាយតាមពិត ដោយលំដាប់ដល់អ្នកទាំងឡាយនោះ ធម្មតា

សត្វទាំងឡាយ រមែងមានជាតិផ្សេងៗ គ្នា ។ អ្នកទាំងឡាយស្គាល់ស្មៅ និងឈើ ( ឬទេ ) ឬក៏មិនដែលប្តេជ្ញាថា ស្មៅ និងឈើទេ លិង្គ គឺភេទរបស់ស្មៅ និងឈើទាំងនោះ តែងសម្រេចអំពីជាតិ ព្រោះថា សត្វទាំងឡាយ មានជាតិផ្សេងៗ គ្នា ។ លិង្គ គឺភេទ តាំងអំពីកណ្តូប និងមមង់ រហូតដល់ស្រមោចខ្មៅ និងស្រមោចក្រហមទាំងនោះ តែងសម្រេចអំពីជាតិ ព្រោះថា សត្វទាំងឡាយមានជាតិផ្សេងៗ គ្នា ។ អ្នកទាំងឡាយស្គាល់ពួកសត្វមានជើងបួន ទាំងតូចទាំងធំ ( ឬទេ ) លិង្គ គឺភេទរបស់សត្វទាំងនោះ តែងសម្រេចអំពីជាតិ ព្រោះថា សត្វទាំងឡាយ មានជាតិផ្សេងៗ គ្នា ។

អ្នកទាំងឡាយស្គាល់ពស់មានទ្រូងជាជើង មានខ្នងវែង ( ឬទេ ) លិង្គ គឺភេទរបស់ពស់ទាំងនោះ តែងសម្រេចអំពីជាតិ ព្រោះថា សត្វទាំងឡាយមានជាតិផ្សេងៗ គ្នា ។

លំដាប់អំពីនោះ អ្នកទាំងឡាយស្គាល់ពួកត្រីក្នុងទឹក មានទឹកជាគោចរ ( ឬទេ ) លិង្គ គឺភេទរបស់ត្រីទាំងនោះ តែងសម្រេចអំពីជាតិ ព្រោះថា សត្វទាំងឡាយមានជាតិផ្សេងៗ គ្នា ។

លំដាប់អំពីនោះ អ្នកទាំងឡាយស្គាល់ពួកសត្វស្លាបមានស្លាបជាយាន ដែលហើរឯអាកាស ( ឬទេ ) លិង្គ គឺភេទរបស់សត្វស្លាបទាំងនោះ តែងសម្រេចអំពីជាតិ ព្រោះថា សត្វ

ទាំងឡាយ មានជាតិផ្សេងៗ គ្នា ។

លិង្គ គឺភេទក្នុងជាតិទាំងឡាយនោះ សម្រេចអំពីជាតិជាច្រើន យ៉ាងណាមិញ លិង្គ គឺភេទក្នុងមនុស្សទាំងឡាយ សម្រេចអំពីជាតិមិនច្រើនយ៉ាងនោះទេ ។ លិង្គ គឺភេទមិនហៅព្រោះសក់ទាំងឡាយ មិនហៅព្រោះក្បាលទាំងឡាយ មិនហៅព្រោះត្រចៀកទាំងឡាយ មិនហៅព្រោះភ្នែកទាំងឡាយ មិនហៅព្រោះប្រមាត់ មិនហៅព្រោះច្រមុះ មិនហៅព្រោះបបូរមាត់ទាំងឡាយ មិនហៅព្រោះចិញ្ចើមទាំងឡាយ មិនហៅព្រោះក មិនហៅព្រោះស្មាទាំងឡាយ មិនហៅព្រោះពោះ មិនហៅព្រោះខ្នង មិនហៅព្រោះត្រគាក មិនហៅព្រោះទ្រូង មិនហៅព្រោះទីចង្អៀត មិនហៅព្រោះមេថុន មិនហៅព្រោះដៃទាំងឡាយ មិនហៅព្រោះជើងទាំងឡាយ មិនហៅព្រោះស្រោមទាំងឡាយ មិនហៅព្រោះក្រចកទាំងឡាយ មិនហៅព្រោះស្មងទាំងឡាយ មិនហៅព្រោះភ្លៅទាំងឡាយ មិនហៅព្រោះពណ៌ មិនហៅព្រោះសំឡេងទេ លិង្គ គឺភេទរបស់មនុស្ស សម្រេចអំពីជាតិ មិនដូចជាភេទក្នុងជាតិទាំងឡាយឯទៀតៗ ទេ ។ លិង្គ គឺភេទផ្សេងដោយសណ្ឋានមានសក់ជាដើម ដូចជាលិង្គ គឺភេទតិរច្ឆានទុំះ មិនមានប្រាកដក្នុងសរីរៈរបស់ខ្លួនទាំងឡាយក្នុងពួកមនុស្សទេ ពាក្យសម្រាប់ហៅ (ថាព្រាហ្មណ៍ជាដើម) គេតែងហៅតាមឈ្មោះក្នុងមនុស្ស

ទាំងឡាយ ។ បណ្តាមនុស្សទាំងឡាយ នរណាមួយចិញ្ចឹមជីវិត ដោយការរក្សាស្រែចម្ការ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះ ជាអ្នកកួរាស់ មិនមែនព្រាហ្មណ៍ទេ ។ បណ្តាមនុស្សទាំងឡាយ នរណាមួយចិញ្ចឹមជីវិតដោយសិល្បៈច្រើនយ៉ាង ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះ ជាអ្នកចិញ្ចឹមជីវិតដោយសិល្បៈ មិនមែនព្រាហ្មណ៍ទេ ។ បណ្តាមនុស្សទាំងឡាយ នរណាមួយចិញ្ចឹមជីវិត ដោយការជួញប្រែ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះ ជាពាណិជ្ជ មិនមែនព្រាហ្មណ៍ទេ ។ បណ្តាមនុស្សទាំងឡាយ នរណាមួយចិញ្ចឹមជីវិតដោយការបម្រើអ្នកដទៃ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះ ជាអ្នកបម្រើ មិនមែនព្រាហ្មណ៍ទេ ។ បណ្តាមនុស្សទាំងឡាយ នរណាមួយចិញ្ចឹមជីវិតដោយការលួចទ្រព្យគេ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះ ជាចោរ មិនមែនព្រាហ្មណ៍ទេ ។ បណ្តាមនុស្សទាំងឡាយ នរណាមួយចិញ្ចឹមជីវិត ដោយភាពជាអ្នកកាន់អាវុធ ( ទាហាន ) ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះ ជាអ្នកចិញ្ចឹមជីវិតដោយភាពជាទាហាន មិនមែនព្រាហ្មណ៍ទេ ។ បណ្តាមនុស្សទាំងឡាយ នរណាមួយចិញ្ចឹមជីវិត ដោយភាពជាបុរោហិត ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះ ជា

អ្នកបូជា មិនមែនព្រាហ្មណ៍ទេ ។ បណ្ដាមនុស្សទាំងឡាយ នរណាមួយបរិភោគនូវធរណីផល ដែលកើតអំពីស្រុក ឬដែន ( ស្ដេច ) ប្រើប្រាស់ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះ ជាស្ដេច មិនមែនព្រាហ្មណ៍ទេ ។ តថាគត មិនហៅបុគ្គលដែលមានកំណើតកើតអំពីមាតា ថាជាព្រាហ្មណ៍ទេ បុគ្គលនោះ ឈ្មោះថា ភោវាទី បុគ្គលនោះ ប្រកបដោយគ្រឿងកង្វល់ តថាគត ហៅបុគ្គលដែលមិនមានគ្រឿងកង្វល់ មិនមានកំណាន់នោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណាកាត់សំយោជនៈទាំងអស់ហើយ មិនតក់ស្លុត តថាគតហៅបុគ្គលអ្នកកន្លងសង្គធម៌ ប្រាសចាកយោគៈទាំង ៤ នោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណាកាត់ខ្សែជ្រាម គឺសេចក្ដីក្រោធផង ព្រ័ត្រ គឺតណ្ហាផង ទីត គឺមិច្ឆាទិដ្ឋិ ព្រមទាំងអនុសយក្កិលេសផង ជាអ្នកបានដករនុក គឺអវិជ្ជា ត្រាស់ដឹងសច្ចធម៌ ៤ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណាមិនប្រទូស្ដ ចេះអត់ធ្មត់ចំពោះពាក្យជេរផង ការវាយ និងការចងផង តថាគតហៅបុគ្គលអ្នកមានខន្តិធម៌ជាកម្លាំង មានខន្តិធម៌ជាវេហ៍ពលនោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គលមិនខឹង ជាអ្នកមានវត្ត មានសីលធម៌

មិនមានចំហាយ គឺតណ្ហា មានឥន្ទ្រិយបានទូន្មាន មានសរីរៈកើតក្នុងទីបំផុតនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណាមិនជាប់ក្នុងកាមទាំងឡាយ ដូចទឹកលើស្លឹកឈូក ឬដូចគ្រាប់ស្ពៃលើចុងដែកស្រួច តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍ ។

បុគ្គលណាដឹងច្បាស់នូវការអស់ទៅនៃសេចក្ដីទុក្ខ របស់ខ្លួនក្នុងលោកនេះ តថាគតហៅបុគ្គលអ្នកដាក់ភារៈចុះហើយប្រាសចាកយោគៈនោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គលមានប្រាជ្ញាជ្រាលជ្រៅ មានប្រាជ្ញាឈ្លាសវៃ ឆ្លៀវឆ្លាសក្នុងមគ្គ និងមិនមែនមគ្គ បានសម្រេចប្រយោជន៍ខ្ពង់ខ្ពស់នោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គល អ្នកមិនច្រឡូកច្រឡំដោយបុគ្គលពីរពួក គឺគ្រហស្ថ ១ បព្វជិត ១ ដែលត្រាច់ទៅដោយមិនប្រកាន់លំនៅ មិនមានសេចក្ដីប្រាថ្នានោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណាដាក់ចេញនូវអាជ្ញា ក្នុងពួកសត្វអ្នកតក់ស្លុតនិងពួកសត្វនឹងនួន មិនសម្លាប់ មិនបៀតបៀនសត្វ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គលអ្នកមិនមានគំនុំ ក្នុងពួកជនដែលមានគំនុំ អ្នកមានចិត្តត្រជាក់ចំពោះអាជ្ញារបស់ខ្លួន ជាអ្នកមិន

ប្រកាន់ក្នុងពួកជន ដែលប្រកបដោយអំពើគួរប្រកាន់នោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណាបានទម្លាក់ចោលចេញនូវរាគៈ ទោសៈ មានះ និងមក្ខៈ ដូចគ្រាប់ស្ពៃដែលធ្លាក់អំពីចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណាពោលវាចាមិនទ្រគោះ វាចាញ៉ាំងគេឲ្យស្គាល់ច្បាស់នូវប្រយោជន៍ ជាសម្ដីពិត ដែលមិនញ៉ាំងគេឲ្យចំពាក់ចិត្តតិចតួច ( ដោយអំណាចញ៉ាំងគេឲ្យខឹង ) តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណាមិនកាន់យកទ្រព្យដែលគេមិនបានឲ្យ ទោះជាទ្រព្យវែងក្ដី ខ្លីក្ដី តូចក្ដី ធំក្ដី ល្អ និងមិនល្អក្ដី ក្នុងលោក តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណាមិនមានសេចក្ដីប៉ុនប៉ង ក្នុងលោកនេះក្ដី ក្នុងលោកខាងមុខក្ដី តថាគតហៅបុគ្គលអ្នកមិនមានសេចក្ដីប៉ុនប៉ងប្រាសចាកកិលេសនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណាមិនមានសេចក្ដីអាល័យ មិនមានការងឿងឆ្ងល់ព្រោះដឹងច្បាស់ តថាគតហៅបុគ្គលអ្នកដល់នូវធម៌ ជាគ្រឿងឈមទៅរកព្រះនិព្វានឈ្មោះអមតៈនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ( កាត់បង់ ) អំពើទាំងពីរ គឺបុណ្យ ១

បាប ១ កន្លងផុតនូវសទ្ធម៌ តថាគតហៅបុគ្គលអ្នកមិនមានសេចក្តីសោក ប្រាសចាកធូលី គឺរាគៈជាដើម ជាបុគ្គលបរិសុទ្ធនោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅអ្នកស្អាត ដូចព្រះចន្ទប្រាសចាកមន្ទិល មានចិត្តថ្លា មិនល្អក់ដោយកិលេស មានតណ្ហាក្នុងភពអស់ហើយនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណាកន្លងនូវផ្លូវវាង គឺរាគៈ នូវផ្លូវទុគ៌ម គឺកិលេស នូវសង្សារវដ្ត នូវមោហៈ ជាអ្នកឆ្លង ( នូវឱឃៈទាំង ៤ ) បានដល់ត្រើយ គឺព្រះនិព្វាន ជាអ្នកមានឈាន មិនមានសេចក្តីញាប់ញ័រ មិនមានសេចក្តីសង្ស័យ មិនប្រកាន់មាំ ជាអ្នករលត់កិលេស តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណាលះកាមទាំងឡាយក្នុងលោកនេះ ជាអ្នកមិនមានផ្ទះ បួស តថាគតហៅបុគ្គលអ្នកមានកាមរាគៈអស់ហើយនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណាបានលះតណ្ហាក្នុងលោកនេះ ជាអ្នកមិនមានផ្ទះ តថាគតហៅបុគ្គលដែលមានតណ្ហា និងភពអស់ហើយនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណាលះយោគៈជារបស់មនុស្ស កន្លងផុតនូវយោគៈជារបស់ទិព្វ តថាគតហៅបុគ្គលដែលប្រាសចាកយោគៈ ទាំង

អស់នោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គលអ្នកលះសេចក្ដីត្រេកអរ ( ក្នុងកាមគុណ ) និងសេចក្ដីអផ្សុក មានចិត្តត្រជាក់ មិនមានឧបធិ គ្របសង្កត់នូវលោកទាំងអស់ ជាអ្នកមានព្យាយាមនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណាបានដឹងច្បាស់នូវចុតិ និងបដិសន្ធិ របស់សត្វទាំងឡាយដោយសព្វគ្រប់តថាគតហៅបុគ្គលអ្នកមិនជាប់ចំពាក់ មានដំណើរល្អ ត្រាស់ដឹងសច្ចធម៌នោះ ថាជាព្រាហ្មណ៍ ។

ទេវតា គន្ធព្វ និងមនុស្សទាំងឡាយ មិនដឹងគតិរបស់បុគ្គលណា តថាគតហៅបុគ្គលដែលអស់អាសវៈហើយឆ្ងាយចាកកិលេសនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណាមិនមានកង្វល់ គឺកិលេស មានរាគៈជាដើមក្នុងអតីតក្ខន្ធ អនាគតក្ខន្ធ និងបច្ចុប្បន្នក្ខន្ធ តថាគតហៅបុគ្គលដែលមិនមានគ្រឿងកង្វល់ មិនមានការប្រកាន់ស្អិតនោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គលអ្នកអង់អាចដូចគោឧសភ អ្នកប្រសើរ មានប្រាជ្ញា ស្វែងរកគុណដ៏ធំ មានជ័យជម្នះ មិនមានសេចក្ដីញាប់ញ័រ ងូតលាង ( នូវកិលេស ) ត្រាស់ដឹងសច្ចធម៌នោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណាដឹងច្បាស់នូវបុព្វេនិវាសផង ឃើញឋានសួគ៌និងអបាយផង ទាំងដល់នូវធម៌ជាទីក្ស័យនៃជាតិ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

នាម និងគោត្តណា ដែលគេបានកំណត់ទុកហើយ ( ថាព្រាហ្មណ៍ក្សត្រ ) នេះគ្រាន់តែជាឈ្មោះ ( ជាបញ្ញត្តិវោហារ ) ក្នុងលោក ( ព្រោះនាម និងគោត្តនោះ ) គឺពួកញាតិសាលោហិត បានផ្សំផ្គុំកំណត់ទុកហើយ ក្នុងកាលដែលកើតមកនោះៗ ។

ទិដ្ឋិរបស់ពួកជនដែលមិនដឹង តែងដេកត្រាំអស់កាលអង្វែង ពួកជនដែលមិនដឹងហ្នឹងឯង តែងនាំគ្នានិយាយថាបុគ្គលឈ្មោះថា ព្រាហ្មណ៍ ព្រោះជាតិ ។

បុគ្គលមិនមែនឈ្មោះថាព្រាហ្មណ៍ព្រោះជាតិទេ បុគ្គលមិនមែនព្រាហ្មណ៍ ក៏មិនមែនព្រោះជាតិដែរ បុគ្គលឈ្មោះថាព្រាហ្មណ៍ព្រោះកម្ម ( ការងារ ) ឈ្មោះថាមិនមែនព្រាហ្មណ៍ក៏ព្រោះកម្ម ។

បុគ្គលឈ្មោះថាអ្នកភ្ជួររាស់ព្រោះកម្ម ឈ្មោះថាអ្នកមានសិល្បសាស្ត្រ ក៏ព្រោះកម្ម ឈ្មោះថាអ្នកជំនួញ ក៏ព្រោះកម្ម ឈ្មោះថាអ្នកបម្រើក៏ព្រោះកម្ម ។

បុគ្គលឈ្មោះថាចោរ ព្រោះកម្ម ឈ្មោះថាយោធាជីវៈក៏

ព្រោះកម្ម ឈ្មោះយាជកៈ ( អ្នកបូជា ) ក៏ព្រោះកម្ម ឈ្មោះថា ស្តេច ក៏ព្រោះកម្ម ។

បណ្ឌិតទាំងឡាយ អ្នកឃើញបដិច្ចសមុប្បាទ ( ថាវត្ថុយ៉ាងនេះកើតឡើងដោយបច្ច័យនេះ ) ឈ្លាសវៃក្នុងកម្ម និងវិបាក រមែងឃើញកម្មនុ៎ះតាមសេចក្តីពិតយ៉ាងនេះ ។

លោករមែងប្រព្រឹត្តទៅព្រោះកម្ម ប្រជាជនក៏ប្រព្រឹត្តទៅព្រោះកម្ម ពួកសត្វជាប់ចំពាក់ដោយកម្ម ( ទើបប្រព្រឹត្តទៅបាន ) ដូចភ្លៅនៃរថដែលវិលទៅ ។

បុគ្គលឈ្មោះថាព្រាហ្មណ៍បាន ដោយកម្មនេះ គឺតបធម៌ ( ការសង្រួមឥន្ទ្រិយ ) ១ ព្រហ្មចរិយៈ ( ការប្រព្រឹត្តប្រសើរ ) ១ សញ្ញមៈ ( ការសង្រួមក្នុងសីល ) ១ ទមៈ ( ការទូន្មាន ) ១ កម្មដ៏ឧត្តមនេះឯង ដែលធ្វើឲ្យទៅជាព្រាហ្មណ៍ បុគ្គលអ្នកបរិបូណ៌ដោយវិជ្ជា ៣ ប្រការ ជាអ្នកស្ងប់ មានភពថ្មីអស់ហើយ ទើបឈ្មោះថាព្រះព្រហ្ម ឈ្មោះថាព្រះឥន្ទ្រ របស់អ្នកប្រាជ្ញទាំងឡាយ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ ។

[ ៧០ ] កាលដែលព្រះមានព្រះភាគសម្តែងយ៉ាងនេះហើយ វាសេដ្ឋមាណព និងភារទ្វាជមាណពក៏សរសើរព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើនចំណាំនូវពួកយើងថាជាឧបាសក អ្នកដល់សរណគមន៍ស្មើដោយជីវិត ក្នុងកាលតាំងអំពីថ្ងៃនេះជាដើមតរៀងទៅ ។

# អដ្ឋកថា

## វាសេដ្ឋសូត្រ

[ ៦៨-៦៩ ]ក្នុងវាសេដ្ឋសូត្រទី ៩ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះ ។

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ការកើតឡើងនេះ លោកពោលហើយក្នុងនិទាននៃសូត្រនោះឯង ។ តែខ្ញុំនឹងពណ៌នារៀបរៀងអត្ថនៃសូត្រនោះ និងបទដែលមានអត្ថងាយយល់ ។

បទថា **ឥច្ឆានង្គលំ** ជាឈ្មោះនៃស្រុក ។ បទថា **ចង្កី តារុក្ខោ តោទេយ្យោ** ជាឈ្មោះប្រចាំខ្លួនរបស់ព្រាហ្មណមហាសាលទាំងនោះ។ បទថា **ចោក្ខរសាតិ ជាណុស្សោណិ** ជានេមិត្តកនាម ។ បានឮថា ព្រាហ្មណ៍ ២ នាក់នោះ ព្រាហ្មណ៍ម្នាក់ កើតក្នុងផ្កាឈូកក្នុងស្រះបោក្ខរណី ជិតហិមវន្តប្បទេស តាបសម្នាក់បេះផ្កានោះ ឃើញទារកដេកក្នុងផ្កាឈូក ចិញ្ចឹមឲ្យធំហើយ នាំមកថ្វាយព្រះរាជា ព្រោះទារកនោះដេកក្នុងផ្កាឈូក ទើបឈ្មោះថា បោក្ខរសាតិ ។ បុរសម្នាក់ទៀត មានតំណែងជាអ្នកទាយជោគជតា បានឮថា ព្រោះជាអ្នកទាយជោគជតានោះ ទើបបានទូវតំណែងបុរោហិត ឈ្មោះថា ជាណុស្សោណិ ព្រាហ្មណ៍នោះមានឈ្មោះល្បី ព្រោះហេតុនោះឯង ។ បើមានពាក្យសួរថា ព្រាហ្មណ៍ទាំងឡាយនោះ ជាព្រាហ្មណមហាសាល មានឈ្មោះបោះសំឡេង ហេតុអ្វី ទើបអាស្រ័យនៅក្នុងឥច្ឆានង្គលគ្រាម ឆ្លើយថា ដើម្បីប្រឡងការរៀនវេទ ។ បានឮថា សម័យនោះ ក្នុងកោសលជនបទ ព្រាហ្មណ៍អ្នករៀនវេទ ប្រជុំគ្នាក្នុងស្រុកនោះ ដើម្បីស្វាធ្យាយវេទ ដើម្បីផ្ទៀងផ្ទាត់វេទរបស់ខ្លួន ដោយហេតុនោះ ព្រាហ្មណ៍ពួកខ្លះ ក៏ចេញអំពីស្រុករបស់

ខ្លួនជាលំដាប់ៗ មកអាស្រ័យនៅក្នុងឥដ្ឋានដ្ឋលគ្រាមនោះ ។ បទថា **វាសេដ្ឋភារទ្វាជានំ** បានដល់ វាសេដ្ឋមាណព និងភារទ្វាជមាណព ។ បទថា **អយមន្តរាកថា** អធិប្បាយថា មាណពទាំង ២ នោះដើរទៅ ពោលរឿងណា ដែលមិត្តគួរពោល ការពោលរឿងដទៃនេះ កើតឡើងក្នុងចន្លោះ គឺត្រង់កណ្តាលរឿងនោះ ។

បទថា **សំសុទ្ធគហណិកោ** គឺមានគភ៌បរិសុទ្ធ អធិប្បាយថា កើតក្នុងគភ៌របស់ព្រាហ្មណីដែលបរិសុទ្ធនោះឯង ។ ភ្លើងធាតុលោកថា **គហណី** ដូចក្នុងប្រយោគជាដើមថា **សមវេបាកិនិយា គហណិយា** ប្រែថា ភ្លើងធាតុរម្លាយអាហារ តែក្នុងទីនេះ សំដៅដល់ គភ៌មាតា ។ បទថា **យាវសត្តមា** គឺ ៧ ជួរបុព្វបុរស ដោយរាប់ថយក្រោយទៅយ៉ាងនេះ គឺមាតារបស់មាតា បិតារបស់បិតា ។ ក្នុងបទនោះ មានអធិប្បាយថា ជីតា និងជីដូន ឈ្មោះថា **បិតាមហា** ម្យ៉ាងទៀត ជីតា និងជីដូន ឈ្មោះថា **មតា-មហា** ជីដូន និងជីតានោះឯង ឈ្មោះថា **បិតាមហា** ដូចគ្នា ។ យុគរបស់ជីដូនជីតា ឈ្មោះថា **បិតាមហយុគ** ។ បទថា **យុគ** បានដល់ប្រមាណនៃអាយុ ។ ម្យ៉ាងទៀត បទនោះ ត្រឹមតែវាចាពោលប៉ុណ្ណោះ ។ បទថា **អក្ខិត្តោ** គឺមិនមានអ្នកណាជំទាស់ ប្រារព្ធដល់ជាតិថា បុគ្គលនោះជាតិអ្វី ។ បទថា **អនុបក្កុដ្ឋោ** គឺ មិនធ្លាប់មានអ្នកណាតិះដៀល ដោយការខ្វះខាតនៃជាតិ ។ បទថា **វត្តសម្បន្នោ** គឺ បរិបូណ៌ដោយមារយាទ ។ បទថា **សញ្ញាបេតុំ** គឺដើម្បីឲ្យដឹង ដើម្បីឲ្យយល់ អធិប្បាយថា ដើម្បីចាក់

ផ្ទុះ ។ បទថា **អាយាម** គឺចូរទៅ ។

បទថា **អនុញ្ញាតប្បដិញ្ញាតា** សេចក្តីថា ខ្ញុំព្រះអង្គទាំង ២ ដែលអាចារ្យលើកតម្កើង និងអះអាងខ្លួនឯងថា ខ្ញុំទាំង ២ ជាអ្នកបានត្រៃវិជ្ជា ។ បទថា **អស្មា** ប្រែថា រមែងជា ។ បទថា **ឧភោ** គឺជនទាំង ២ ។

បទថា **អហំ បោក្ខរសាតិស្ស តារុក្ខស្សាយំ មាណវោ** សេចក្តីថា វាសេដ្ឋមាណព កាលនឹងសម្តែងដល់គុណសម្បត្តិរបស់អាចារ្យ និងគុណ-សម្បត្តិរបស់ខ្លួន ទើបពោលដោយបំណងថា ខ្ញុំព្រះអង្គជាអន្តេវាសិកច្បងរបស់បោក្ខរសាតិព្រាហ្មណ៍ ភារទ្វាជមាណពនេះ ជាសិស្សដ៏ប្រសើររបស់តារុក្ខព្រាហ្មណ៍ ។ បទថា **តេវិជ្ជានំ** បានដល់ ដែលចប់ត្រៃវេទ ។ បទថា **កេវលិនោ** គឺដល់នូវការសម្រេចហើយ ។ ឥឡូវនេះ វាសេដ្ឋមាណព កាលញុំាងសេចក្តីសម្រេចនោះឲ្យទូលំទូលាយតទៅ ទើបទូលថា **បទកស្មា ។បេ។ សាទិសា** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **ជប្បេ** បានដល់ ក្នុងវេទ ។ បទថា **កម្មុនា** បានដល់ កម្ម គឺកុសលកម្មបថ ១០ ។ វាសេដ្ឋមាណពនេះពោលថា លុះតែបុគ្គលមានសីលផង សំដៅដល់ កាយកម្ម និងវចីកម្ម ៧ ខាងដើម ពោលថា បរិបូណ៌ដោយវត្ត សំដៅដល់ មនោកម្ម ៣ យ៉ាង ។

ព្រោះថា វាសេដ្ឋមាណពនោះ ប្រកបហើយដោយវត្តនោះ ជាអ្នកដល់ព្រមដោយមារយាទ ។ ឥឡូវនេះ វាសេដ្ឋមាណព កាលឲ្យទ្រង់ជ្រាបថា រឿងនោះ មានពាក្យពោលជំទាស់គ្នា ទើបក្រាបទូលថា **អហញ្ច កម្មុនា ព្រូមិ** ដូច្នេះ ។ បទថា **ខយាតីតំ** គឺផុតចាកងងឹតមកហើយ អធិប្បាយថា

ពេញវង់ ។ បទថា **បេច្ច** បានដល់ ចូលមក ។ បទថា **ឆមស្សន្តិ** គឺធ្វើនូវការថ្វាយបង្គំ ។ បទថា **ចក្ខុំ លោកេ សមុប្បន្នំ** សេចក្ដីថា ព្រះគោតមអ្នកមានចក្ខុដោយការកម្ចាត់នូវងងឹតនោះ ហើយទ្រង់ចង្អុលបង្ហាញដល់ប្រយោជន៍ មានប្រយោជន៍ក្នុងបច្ចុប្បន្នជាដើម ដល់សត្វលោក ទ្រង់កើតឡើងល្អហើយក្នុងលោក ដែលងងឹតដោយអវិជ្ជា ។

ព្រះមានព្រះភាគ ដែលវាសេដ្ឋមាណពក្រាបទូលសរសើរយ៉ាងនេះហើយ កាលទ្រង់សង្គ្រោះជនទាំង ២ នោះ ទើបត្រាស់ថា **តេសំ វោហំ ព្យក្ខិស្សំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ព្យក្ខិស្សំ** គឺតថាគតនឹងព្យាករ ។ បទថា **អនុបុព្វំ** សេចក្ដីថា ការគិតរបស់ព្រាហ្មណ៍ស្ទេះសិទចុះ ។ ក្នុងបទនោះមានពាក្យអធិប្បាយយ៉ាងនេះថា តថាគតនឹងព្យាករដល់ពួកអ្នកតាមលំដាប់ផ្ដើមតាំងអំពីដង្កូវ កណ្ដូប ស្មៅ និងដើមឈើ ពិតហើយ ព្រោះមាណពទាំងនោះ គួរបានការទូន្មាន ដោយពាក្យពិស្ដារ ។ បទថា **ជាតិវិភង្គំ** គឺផ្សេងគ្នាដោយជាតិ ។

បទថា **អញ្ញមញ្ញា ហិ ជាតិយោ** គឺព្រោះជាតិរបស់សត្វទាំងឡាយនោះៗ ផ្សេងៗ គ្នា ។

លំដាប់នោះ កាលព្រះមានព្រះភាគត្រូវត្រាស់ដល់ការផ្សេងគ្នានៃជាតិរបស់សត្វទាំងឡាយ ទើបទ្រង់ប្រារព្ធដើម្បីត្រាស់ដល់វត្ថុ ដែលមិនមានចិត្តគ្រប់គ្រងមុនថា **តិណរុក្ខេបិ ជានាថ** ជាដើម ។ បើមានពាក្យសួរថា

ត្រាស់ដូច្នោះដើម្បីអ្វី ឆ្លើយថា ដើម្បីឲ្យដឹងនាយ ក្នុងសត្វដែលមានចិត្តគ្រប់គ្រងទាំងឡាយ ។ ព្រោះកាលកាន់យកការផ្សេងគ្នានៃកំណើត ក្នុងវត្ថុដែលមិនមានចិត្តគ្រប់គ្រងទាំងឡាយ ការផ្សេងគ្នាក្នុងកំណើត សត្វដែលមានចិត្តគ្រប់គ្រង និងឃើញច្បាស់ឡើង ។

បទថា **តិណរុក្ខេ** នោះ ឈ្មោះថា **តិណ** បានដល់ មានស្រោយខាងក្នុង មានខ្លឹមខាងក្រៅ ព្រោះដូច្នោះ សូម្បីត្នោត និងដូងជាដើម ក៏សង្គ្រោះថាជាស្មៅបាន ឈ្មោះថា **រុក្ខ** បានដល់ មានស្រោយខាងក្រៅ មានខ្លឹមខាងក្នុង ។ ស្មៅ និងដើមឈើ ឈ្មោះថា **តិណរុក្ខេ** ។ ព្រះមានព្រះភាគកាលទ្រង់សម្តែងស្មៅ និងដើមឈើទាំងនោះ ដោយទុតិយាវិភត្តិ ពហុវចនៈ ទើបត្រាស់ថា **តិណរុក្ខេបិ ជានាថ** ដូច្នេះ ។ បទថា **ន ចាបិ បដិជានរេ** បានដល់ ស្មៅ និងដើមឈើ ក៏មិនព្រមទទួលយ៉ាងនេះថា អញជាស្មៅ អញជាដើមឈើ ដូច្នេះ ។ បទថា **លិង្គំ ជាតិមយំ** គឺស្មៅ និងដើមឈើទាំងនោះ សូម្បីមិនដឹងខ្លួនឯង ក៏ប្រព្រឹត្តទៅតាមធម្មជាតិ ( កំណើត ) នោះឯង សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះជាតិផ្សេងៗ គ្នា គប្បីជ្រាបសេចក្តីពិស្តារយ៉ាងនេះថា តិណជាតិមួយបែប រុក្ខជាតិមួយបែប តាលជាតិ គឺដើមត្នោតមួយបែប នាឡិកេរជាតិ គឺដើមដូងមួយបែប ។

សួរថា តិណជាតិនោះ លោកសម្តែងដូចម្តេច ។ ឆ្លើយថា តិណជាតិណា ផ្សេងគ្នាដោយអំណាចនៃជាតិ តិណជាតិនោះ សូម្បីវៀរការទទួលរបស់ខ្លួន ឬរបស់អ្នកដទៃ ក៏កាន់យកបានថា មានការផ្សេងគ្នាចាកកំណើត

( ពូជ ) ដែលផ្សេងគ្នា ។ បើព្រាហ្មណ៍ណា គប្បីជាព្រាហ្មណ៍ដោយជាតិ ព្រាហ្មណ៍នោះ វៀរការអះអាងរបស់ខ្លួន ឬលេសរបស់អ្នកដទៃហើយ ក៏មិនផ្សេងគ្នា ដោយភាពជាស្តេច វេស្សៈ ឬសូទ្រៈ និងមិនគួរកាន់យក ព្រោះហេតុនោះ បុគ្គលមិនមែនជាព្រាហ្មណ៍ដោយជាតិ ។ បន្ទាប់អំពីនោះ ព្រះមានព្រះភាគទ្រង់ធ្វើនូវសេចក្តីនេះឲ្យជាក់ច្បាស់ដោយចែកពាក្យហៅ ដោយគាថានេះថា **យថា ឯតាសុ ជាតីសុ** ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងការផ្សេងគ្នានៃជាតិ ក្នុងវត្ថុមិនមានចិត្តយ៉ាងនេះហើយ កាលទ្រង់សម្តែងការផ្សេងគ្នានៃជាតិក្នុងសត្វ ដែលមានចិត្តគ្រប់គ្រង ទើបត្រាស់ពាក្យយ៉ាងនេះថា **តតោ កីដេ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **កីដេ** បានដល់ ដង្កូវ[១] ។ បទថា **បដង្គេ** បានដល់ កណ្តូប[២] ។ បទថា **យាវ កុន្ថកិបិល្លិកេ** បានដល់ រហូតស្រមោចខ្មៅ និងស្រមោចក្រហមជាទីបំផុត ។ បទថា **ខុទ្ទកេ** បានដល់ កង្កែប កំប្រុកជាដើម ។ បទថា **មហល្លកេ** បានដល់ ទន្សាយ និងឆ្មាជាដើម ព្រោះសត្វទាំងអស់នោះ មានច្រើនប្រភេទ ។ បទថា **ចាតុប្បទេ** គឺមានពោះជាជើង លោកអធិប្បាយថា សត្វមានទ្រូងជាជើង ។ បទថា **ទីឃបិដ្ឋិកេ** គឺសត្វមានខ្នងវែង ព្រោះពស់មានខ្នង ចាប់ពីក្បាលរហូតដល់កន្ទុយ ព្រោះដូច្នោះទើបលោកហៅពស់ទាំងនោះថា **ទីឃបិដ្ឋិកេ** ។ សត្វទាំងនោះ មានច្រើនប្រភេទដោយចំពោះ ជាប្រភេទអាសិរពិសជាដើម ។

---

១- បិដកខ្មែរជាសត្វកណ្តូប ។ ២- បិដកខ្មែរជាសត្វមមង់ ។

បទថា **ឱទកេ** គឺកើតក្នុងទឹក ។ សូម្បីត្រីទាំងឡាយ ក៏មានច្រើនប្រភេទ ដោយចំពោះ ជាប្រភេទត្រីឆ្លិនជាដើម ។ បទថា **បក្ខី** បានដល់ សត្វស្លាប ទាំងឡាយ ពិតហើយ បក្សីទាំងនោះ លោកហៅថា **បក្ខី** ព្រោះជាសត្វទៅ ដោយស្លាប ។ ឈ្មោះថា **បត្តយានា** ព្រោះទៅដោយស្លាប ។ បទថា **វិហង្គមា** ព្រោះទៅតាមអាកាស ។ សត្វទាំងនោះ មានច្រើនពួក ដោយ ចំពោះ ជាប្រភេទក្អែកជាដើម ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងប្រភេទនៃជាតិរបស់សត្វទាំងឡាយ ដែលត្រាច់ទៅលើគោក ក្នុងទឹក និងក្នុងអាកាសយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីធ្វើឲ្យច្បាស់ដល់បំណងដែលទ្រង់សម្តែង ទើបត្រាស់គាថាថា **យថា ឯតាសុ** ដូច្នេះជាដើម ។

គប្បីជ្រាបវិនិច្ឆ័យអត្ថនៃបទនោះដោយសង្ខេប ដោយពណ៌នាដល់ បំណងដូចលោកពោលហើយនោះឯង តែដោយពិស្តារក្នុងបទនេះ ព្រះមាន ព្រះភាគ កាលទ្រង់សម្តែងប្រការដែលគួរត្រាស់ដោយព្រះអង្គឯង ទើបត្រាស់ ពាក្យថា **ន កេសេហិ** ដូច្នេះជាដើម ។ ក្នុងបទនោះ យោជនាលម្អិតថា ពាក្យណាដែលត្រាស់ថា លិង្គ គឺភេទក្នុងមនុស្សទាំងឡាយ សម្រេចអំពី ជាតិ មិនច្រើនយ៉ាងនោះទេ គប្បីជ្រាបថា ពាក្យនោះ មិនមានយ៉ាងនេះ ។ សួរថា សេចក្តីនេះដូចម្តេច ឆ្លើយថា ដូចបទថា **ន កេសេហិ** គប្បីប្រកប ពាក្យទាំងពួង ដោយន័យនេះថា មានកំណត់ថា សក់ ដូច្នេះ មិនមានដល់ ពួកព្រាហ្មណ៍ សក់នេះ មានដល់ក្សត្រ ដូចជារោមនេះ មានដល់ដំរី សេះ

និងម្រឹគទាំងឡាយជាដើម ។ ពាក្យថា លិង្គ គឺភេទក្នុងមនុស្សទាំងឡាយ សម្រេចអំពីជាតិមិនច្រើនយ៉ាងនោះទេ ដូចសណ្ឋានដែលសម្រេចមកអំពីជាតិក្នុងជាតិពួកដទៃ ដូច្នោះ គប្បីជ្រាបថា ជាពាក្យសរុបនៃអត្ថ ដូចដែលពោលមកហើយនោះឯង ។ បទនោះ មានពាក្យអធិប្បាយថា ព្រោះសណ្ឋានសម្រេចមកអំពីជាតិជាច្រើន មិនមានក្នុងមនុស្សទាំងឡាយ ដោយសក់ជាដើម ដូច្នោះ គប្បីជ្រាបសេចក្តីនេះថា សណ្ឋាន សម្រេចមកអំពីជាតិមិនមានក្នុងមនុស្សទាំងឡាយ មានព្រាហ្មណ៍ជាដើម ដូចសណ្ឋានសម្រេចមកអំពីជាតិក្នុងកំណើតដទៃ ។

ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្តែងការផ្សេងថាជាព្រាហ្មណ៍ ជាក្សត្រ សូម្បីក្នុងសត្វទាំងឡាយដែលផ្សេងគ្នាដោយជាតិយ៉ាងនេះ កើតមានឡើងបានដូចម្តេច ទើបត្រាស់គាថាថា **បច្ចត្តំ** ដូច្នេះជាដើម ។ បទនោះ មានសេចក្តីថា ការផ្សេងគ្នានៃសណ្ឋាន មានសក់ជាដើមនេះ ដែលសម្រេចមកអំពីកំណើត រមែងមិនមានក្នុងសរីរៈរៀងៗ ខ្លួន នៃព្រាហ្មណ៍ជាដើម ក្នុងមនុស្សទាំងឡាយឡើយ ដូចរបស់សត្វតិរច្ឆាន កាលមិនមានការផ្សេងគ្នា តែការផ្សេងគ្នា ដែលជាវិធីប្រាប់ឲ្យដឹងថា ផ្សេងគ្នា គឺជាព្រាហ្មណ៍ ជាក្សត្រ ក្នុងមនុស្សទាំងឡាយ លោកពោលដោយសន្មត គឺពោលត្រឹមតែជាវោហារ ។

ដោយហេតុត្រឹមប៉ុណ្ណេះ ព្រះមានព្រះភាគ ទ្រង់សង្កត់នូវវាទៈរបស់ភារទ្វាជមាណព បើបុគ្គលគប្បីជាព្រាហ្មណ៍បានព្រោះជាតិ សូម្បីបុគ្គលដែលមានអាជីវវិបត្តិ សីលវិបត្តិ អាចារវិបត្តិ ក៏គប្បីជាព្រាហ្មណ៍បាន ព្រោះ

ព្រាហ្មណ៍ទាំងឡាយអំពីបុរាណ មិនប្រាថ្នាឲ្យបុគ្គលនោះជាព្រាហ្មណ៍ សូម្បីមនុស្សជាបណ្ឌិតពួកដទៃក្នុងលោកក៏មិនប្រាថ្នា ព្រោះហេតុនោះ ឥឡូវនេះ កាលទ្រង់សម្តែងសេចក្តីនោះ ដើម្បីឧបការៈវាទៈរបស់វាសេដ្ឋមាណព ទើបត្រាស់គាថា ៨ ថា **យោ ហិ កោចិ មនុស្សេសុ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **គោរក្ខំ** បានដល់ ថែរក្សាស្រែ អធិប្បាយថា ធ្វើកសិកម្ម ។ សេចក្តីពិត ផែនដី លោកហៅថា **គោ** ឯផ្ទៃដីនោះ លោកហៅថា **ខេត្ត**។ បទថា **បុថុសិប្បេន** បានដល់ ដោយសិប្បៈ មានការត្បាញជាដើម ។ បទថា **វោហារំ** បានដល់ ការជួញដូរ ។ បទថា **បរ-បេស្សេន** បានដល់ ដោយការទទួលបម្រើអ្នកដទៃ ។ បទថា **ឥស្សត្ថំ** បានដល់ ប្រើអាវុធចិញ្ចឹមជីវិត អធិប្បាយថា ព្រួញ និងសស្ត្រា ។ បទថា **បោរោហិច្ចេន** គឺដោយការធ្វើប្រយោជន៍ដល់អ្នកដទៃ ។

ព្រះមានព្រះភាគ កាលទ្រង់ប្រកាសថា បុគ្គលមានអាចារវិបត្តិ សីល-វិបត្តិ និងមារយាទវិបត្តិមិនមែនជាព្រាហ្មណ៍ ដោយលទ្ធិរបស់ព្រាហ្មណ៍ និងវោហារដោយរបស់សត្វលោកយ៉ាងនេះហើយ ទើបទ្រង់ត្រាស់បដិបទា ដោយសេចក្តីដូច្នេះថា កាលបើដូច្នោះ បុគ្គលរមែងមិនជាព្រាហ្មណ៍ព្រោះជាតិ តែជាព្រាហ្មណ៍ដោយគុណ ព្រោះដូច្នោះ បុគ្គលមានគុណ ទោះកើតក្នុងត្រកូលណា បុគ្គលនោះក៏ជាព្រាហ្មណ៍បាន នេះជាបដិបទាក្នុងសេចក្តីនេះ កាលទ្រង់ប្រកាសបដិបទានោះ ដោយចែកជាពួកៗ ទើបត្រាស់ថា **ន ចាហំ ព្រាហ្មណំ ព្រូមិ** ដូច្នេះ ។

បទនោះ មានសេចក្តីដូច្នេះថា តថាគតមិនពោលបុគ្គលដែលកើតក្នុងកំណើត ៤ ណាមួយ ឬដែលកើតអំពីកំណើតក្នុងផ្ទៃមាតា ដែលព្រាហ្មណ៍សរសើរដោយន័យជាដើមថា មានជាតិដ៏ល្អទាំងពីរចំណែក និងដោយន័យនេះថា ពួកព្រាហ្មណ៍ពោលដល់កំណើត ដែលបានដល់ផ្លូវមគ្គដ៏បរិសុទ្ធរបស់ព្រាហ្មណ៍ថា កើតអំពីផ្ទៃដ៏បរិសុទ្ធស្អាត ការដល់ព្រមនៃមាតា លោកពោលថា ឈ្មោះថា **យោនិជោ មត្តិសម្ភវោ** ព្រោះកើតអំពីគភ៌ដ៏បរិសុទ្ធនោះ សូម្បីអ្នកកើតអំពីផ្ទៃរបស់មាតានោះថា ជាព្រាហ្មណ៍ ដោយត្រឹមតែកើតអំពីកំណើតនេះ និងដោយគ្រាន់តែកើតអំពីមាតានេះ ។ សួរថា ព្រោះហេតុអ្វីព្រោះបុគ្គលនោះ ឆ្លើយថា ព្រោះបុគ្គលនោះត្រឹមតែឈ្មោះថា **ភោវាទី** ព្រោះអ្នកដទៃដែលនៅមានកិលេស ជាគ្រឿងកង្វល់ លើកតម្កើងត្រឹមតែពាក្យថា **ភោ ភោ** បុគ្គលនោះឯង នៅជាបុគ្គលមានកិលេសជាគ្រឿងកង្វល់ ។ ឯបុគ្គលណា កើតក្នុងត្រកូលណាក៏ដោយ ជាអ្នកមិនមានកិលេសជាគ្រឿងកង្វល់ ព្រោះមិនមានកិលេសជាគ្រឿងកង្វល់ មានរាគៈជាដើម ជាអ្នកមិនប្រកាន់មាំ ព្រោះលះនូវការប្រកាន់មាំទាំងពួងបាន តថាគតហៅបុគ្គលដែលមិនមានគ្រឿងកង្វល់ មិនមានកំណាន់នោះ ថាជាព្រាហ្មណ៍ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះជាអ្នកមានបាបបន្សាត់ហើយ ។ សួរថា មានអ្វីក្រៃលែងជាងនោះ ឆ្លើយថា មានគាថា ២៧ គាថាថា **សព្វសំយោជនំ ឆេត្វា** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **សព្វសំយោជនំ** បានដល់ សំយោជនៈ ១០ យ៉ាង ។ បទថា **ន បរិតស្សតិ** គឺមិនខ្វាចព្រោះតណ្ហា ។ បទថា **តមហំ**

សេចក្ដីថា តថាគតពោលបុគ្គលដែលកន្ទេងនូវធម៌ជាគ្រឿងជាប់ជំពាក់ ព្រោះកន្ទេងនូវធម៌ជាគ្រឿងជាប់ជំពាក់ មានរាគៈជាដើម បុគ្គលប្រាសចាក ព្រោះមិនមានយោគៈទាំង ៤ ថាជាព្រាហ្មណ៍ ។ បទថា **នន្ទឹ** គឺសេចក្ដីក្រោធដែលប្រព្រឹត្តទៅដោយការចង ។ បទថា **វរត្តំ** គឺតណ្ហាដែលប្រព្រឹត្តទៅដោយអំណាចចង ។ បទថា **សន្ទានំ សហានុក្កមំ** បានដល់ ទិដ្ឋិ គឺទិដ្ឋិ ៦២ ដែលនៅក្នុងលំដាប់អនុស័យ អធិប្បាយថា តថាគតពោលបុគ្គលដែលកាត់កិលេសទាំងអស់នេះបាន ជាអ្នកមានគន្លឹះដកហើយ ព្រោះដកនូវគន្លឹះ គឺអវិជ្ជាបាន ឈ្មោះថា ជាអ្នកត្រាស់ដឹងហើយ ព្រោះត្រាស់ដឹងអរិយសច្ច ៤ ថាជាព្រាហ្មណ៍ ។

បទថា **អទុដ្ឋោ** ព្រោះមិនប្រទូស្ដ អធិប្បាយថា តថាគតពោលបុគ្គលមិនក្រោធ អត់ធន់នូវពាក្យជេរ ដោយអក្កោសវត្ថុ ១០ ការវាយដោយបាតដៃជាដើម និងការចងដោយខ្សែជាដើម បុគ្គលមានកម្លាំង គឺខន្ដិ ព្រោះជាអ្នកប្រកបដោយកម្លាំង គឺខន្តី ជាអ្នកមានពួកពល ព្រោះជាបុគ្គលប្រកបដោយពួកពល គឺខន្តីនោះឯង ដែលជាពួកពល នៃការកើតរឿយៗ បុគ្គលបែបនោះថាជាព្រាហ្មណ៍ ។

បទថា **វតវន្តំ** អធិប្បាយថា តថាគតពោលបុគ្គលដែលប្រកបដោយវត្តដែលកម្ចាត់កិលេស ដែលមានសីល គឺចតុប្បារិសុទ្ធិសីល ដែលមិនមានកិលេសផ្សាយឡើង ព្រោះមិនមានកិលេសដែលផ្សាយឡើង គឺតណ្ហា ជាអ្នកទូន្មានខ្លួនហើយ ដោយការទូន្មានឥន្ទ្រិយ ៦ ទ្រទ្រង់នូវសរីរៈ ដែលមានក្នុងទី

បំផុត ដោយអត្ថកាពដែលតាំងនៅក្នុងទីបំផុត ថាជាព្រាហ្មណ៍ ។ បទថា **យោ ឆលិម្បតិ** សេចក្តីថា តថាគតពោលបុគ្គលដែលមិនជាប់នៅដោយកាម ២ យ៉ាងខាងក្នុង គឺមិនតាំងនៅក្នុងកាមនោះ ថាជាព្រាហ្មណ៍ ។ បទថា **ទុក្ខស្ស** បានដល់ នៃទុក្ខ គឺខន្ធ ។ បទថា **បន្នភារំ** អធិប្បាយថា តថាគតពោលអ្នកដាក់ចុះនូវភារៈ គឺខន្ធបានហើយ កន្លងហើយចាកយោគៈ ៤ ឬ កិលេសទាំងអស់ ថាជាព្រាហ្មណ៍ ។

បទថា **គម្ភីរបញ្ញំ** អធិប្បាយថា តថាគតពោលបុគ្គលអ្នកប្រកប ដោយបញ្ញា ដែលប្រព្រឹត្តទៅក្នុងខន្ធជាដើម ដែលជ្រាលជ្រៅ ជាអ្នកមានបញ្ញា ដោយបញ្ញា មានឱជៈកើតអំពីធម៌ ជាអ្នកឈ្លាសក្នុងផ្លូវ និងមិនមែនផ្លូវយ៉ាងនេះថា នេះជាផ្លូវនៃទុគ្គតិ នេះជាផ្លូវនៃសុគតិ នេះជាផ្លូវនៃនិព្វាន នេះមិនមែនជាផ្លូវ ដែលសម្រេចប្រយោជន៍ដ៏ឧត្តម គឺអរហត្ត ថាជាព្រាហ្មណ៍ ។

បទថា **អសំសដ្ឋំ** បានដល់ អ្នកមិនជាប់ជំពាក់ ព្រោះមិនមានការជាប់ជំពាក់ ដោយការឃើញ ការស្តាប់ ការសន្ទនា ការបរិភោគ និងការប្រឡូកប្រឡំផ្លូវកាយ ។ បទថា **ឧភយំ** គឺមិនជាប់ជំពាក់ដោយបុគ្គល ២ ពួក គឺគ្រហស្ថ និងបព្វជិត ។ បទថា **អនោកសារឹ** សេចក្តីថា តថាគតពោលបុគ្គលមិនមានអាល័យ ត្រាច់ទៅបែបនោះ ថាជាព្រាហ្មណ៍ ។

បទថា **និធាយ** បានដល់ ដាក់ចុះ គឺទម្លាក់ចុះ ។ បទថា **តសេសុ ថាវរេសុ ច** គឺឈ្មោះថា ជាអ្នកតក់ស្លុត ព្រោះមានតណ្ហា ឈ្មោះថា ជាអ្នកនឹងនួន ព្រោះជាអ្នកមាំទាំ ដោយមិនមានតណ្ហា ។ បទថា **យោ ហន្តិ**

សេចក្តីថា បុគ្គលណាដាក់អាជ្ញាហើយ ព្រោះប្រាសចាកការបង្អៀតបង្អល់ក្នុងសត្វទាំងពួងយ៉ាងនេះ មិនសម្លាប់សត្វណាមួយដោយខ្លួនឯង មិនមែនឲ្យអ្នកដទៃសម្លាប់ តថាគតហៅថាបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បទថា **អវិរុទ្ធំ** អធិប្បាយថា តថាគតពោលបុគ្គលដែលមិនគុំកួន ព្រោះមិនមានអាឃាតក្នុងលោកិយមហាជន សូម្បីបុគ្គលនោះប្រទូស្តដោយសេចក្តីអាឃាត ជាអ្នករម្ងត់ គឺដាក់នូវអាជ្ញាបានក្នុងជនទាំងឡាយ ដែលមានអាជ្ញាក្នុងខ្លួន ព្រោះមិនទាន់វៀរនូវការប្រហារអ្នកដទៃ កាលមិនមានដំបង ឬសស្ត្រាក្នុងដៃ បុគ្គលមិនប្រកាន់ ព្រោះមិនមានការប្រកាន់ក្នុងបុគ្គលអ្នកមានសេចក្តីប្រកាន់ ព្រោះប្រកាន់ស្អិតក្នុងខន្ធ ៥ ថាអញ របស់អញ បុគ្គលបែបនោះថាជាព្រាហ្មណ៍ ។

បទថា **អារគ្គា** អធិប្បាយថា កិលេស មានរាគៈជាដើម និងមក្ខៈមានលក្ខណៈលុបគុណរបស់អ្នកដទៃនេះ មិនតាំងនៅក្នុងចិត្តរបស់បុគ្គលណា ដូចគ្រាប់ស្ពៃធ្លាក់អំពីចុងដែកស្រួច គឺដូចគ្រាប់ស្ពៃមិនតាំងនៅលើចុងដែកស្រួច តថាគតពោលបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បទថា **អកក្កសំ** គឺមិនគ្រោតគ្រាត ។ បទថា **វិញ្ញាបនឹ** គឺឲ្យដឹងនូវអត្ថបាន ។ បទថា **សច្ចំ** គឺពិត ។ បទថា **ណាភិសជេ** គឺមិនធ្វើឲ្យអ្នកដទៃជាប់ជំពាក់ ដោយធ្វើឲ្យបុគ្គលនោះក្រោធដោយវាចា ។ ឈ្មោះថា ព្រះខីណាស្រព គប្បីពោលពាក្យបែបនោះ ព្រោះហេតុនោះ ទើបតថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

សេចក្តីថា តថាគតពោលបុគ្គលដែលមិនកាន់យកទ្រព្យដែលគេមិនឲ្យ ក្នុងលោកនេះ ក្នុងបណ្តាអាករណៈ គឺសំពត់សាដកជាដើម វែង ឬខ្លី ក្នុងកែវមណី និងកែវមុក្តាជាដើម តូច ឬធំ ស្អាត ឬមិនស្អាត ថ្លៃ ឬថោក ថាជាព្រាហ្មណ៍ ។

បទថា **និរាសយំ** គឺមិនមានតណ្ហា ។ បទថា **វិសំយុត្តំ** គឺប្រាសចាកកិលេសទាំងអស់ តថាគតពោលបុគ្គលដែលមិនមានតណ្ហា ជាអ្នកប្រាសចាកកិលេសនោះ ថាជាព្រាហ្មណ៍ ។

បទថា **អាលយា** បានដល់ តណ្ហា ។ បទថា **អញ្ញាយ អកថំកថី** សេចក្តីថា ដឹងទូទៅដល់វត្ថុ ៨ តាមសេចក្តីពិត មិនមានសេចក្តីសង្ស័យដោយការសង្ស័យក្នុងវត្ថុ ៨ ។ បទថា **អមតោគធំ អនុប្បត្តំ** សេចក្តីថា ជាអ្នកឈមចុះកាន់អមតៈ គឺនិព្វាន តថាគតពោលបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បទថា **ឧភោ** សេចក្តីថា លះនូវបុណ្យ និងបាបទាំង ២ យ៉ាង ។ បទថា **សង្គំ** គឺធម៌ជាគ្រឿងជាប់ជំពាក់ មានរាគៈជាដើម ។ បទថា **ឧបច្ចគា** គឺឈានកន្លងហើយ អធិប្បាយថា តថាគតពោលបុគ្គលដែលមិនសោកស្តាយដោយសេចក្តីសោក មានវដ្តៈជាមូល ដែលប្រាសចាកធូលី ព្រោះមិនមានធូលី គឺរាគៈជាដើមខាងក្នុង ជាអ្នកបរិសុទ្ធ ព្រោះមិនមានឧបក្កិលេស ថាជាព្រាហ្មណ៍ ។

បទថា **វិមលំ** គឺវៀរចាកមន្ទិល មានពពកជាដើម ។ បទថា **សុទ្ធំ** គឺ

មិនមានឧបក្កិលេស ។ បទថា **វិប្បសន្នំ** គឺមានចិត្តផូរផង់ ។ បទថា **អនាវិលំ** គឺវៀរចាកការល្អក់កករ គឺកិលេស ។ បទថា **នន្ទិភវបរិក្ខីណំ** សេចក្តីថា តថាគតពោលបុគ្គលដែលអស់តណ្ហាក្នុងភព ៣ ថាជាព្រាហ្មណ៍ ។

សេចក្តីថា តថាគតពោលភិក្ខុដែលឈានកន្លងនូវផ្លូវអម គឺរាគៈ រណ្តៅ គឺកិលេស សង្សារវដ្ត និងមោហៈ គឺការមិនដឹងច្បាស់នូវអរិយសច្ច ៤ ជាអ្នកឆ្លងឱឃៈ ៤ ជាអ្នកដល់ត្រើយ ជាអ្នកសម្ងំដោយឈាន ២ យ៉ាង ជាអ្នកមិនញាប់ញ័រ ព្រោះមិនមានតណ្ហា ជាអ្នកមិនមានសេចក្តីសង្ស័យ ព្រោះអស់សេចក្តីសង្ស័យ ជាអ្នករម្ងត់ ព្រោះរម្ងត់កិលេស មិនប្រកាន់មាំ ព្រោះមិនមានឧបាទាន ថាជាព្រាហ្មណ៍ ។

សេចក្តីថា តថាគតពោលបុគ្គលលះកាមទាំង ២ ក្នុងលោកនេះបាន ជាអ្នកមិនមានផ្ទះ ចេញបួស ជាអ្នកអស់នូវកាម និងអស់នូវភព ថាជាព្រាហ្មណ៍ ។

សេចក្តីថា តថាគតពោលបុគ្គលអ្នកលះតណ្ហា ដែលប្រព្រឹត្តទៅក្នុងទ្វារ ៦ ក្នុងលោកនេះ មិនត្រូវការគ្រប់គ្រងផ្ទះ មិនមានផ្ទះចេញបួស ព្រោះលះតណ្ហា និងភពអស់ហើយ ថាជាព្រាហ្មណ៍ ។

បទថា **មានុសកំ យោគំ** បានដល់ អាយុ និងកាមគុណ ៥ ដែលជារបស់មនុស្ស ។ សូម្បីក្នុងយោគៈដែលជាទិព្វ ក៏មានន័យដូចគ្នា ។ បទថា **ឧបច្ចគា** សេចក្តីថា តថាគតពោលបុគ្គលអ្នកលះនូវយោគៈ ដែលជា

របស់មនុស្ស ឈានកន្លងយោគៈដែលជារបស់ទិព្វបាន ប្រាសចាកយោគៈ ៤ ថាជាព្រាហ្មណ៍ ។

បទថា **រតឹ** គឺសេចក្ដីត្រេកអរក្នុងកាមគុណ ៥ ។ បទថា **អរតឹ** គឺនឿយណាយក្នុងការនៅក្នុងព្រៃ ។ បទថា **សីតិភូតំ** គឺអ្នករម្ងាប់កិលេស ។ បទថា **និរុបធឹ** គឺមិនមានកិលេស ។ បទថា **វីរំ** គឺតថាគតពោលបុគ្គលដែលមានសេចក្ដីព្យាយាម គ្របសង្កត់នូវខន្ធលោកទាំងអស់បែបនេះ តាំងនៅ ថាជាព្រាហ្មណ៍ ។

បទថា **យោ វេទិ** សេចក្ដីថា តថាគតពោលបុគ្គលដែលដឹងចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ធ្វើឲ្យប្រាកដដោយអាការទាំងពួង ជាអ្នកមិនជាប់ជំពាក់ ព្រោះមិនមានកិលេសជាគ្រឿងជាប់ជំពាក់ ជាអ្នកទៅល្អ ព្រោះទៅដោយល្អក្នុងផ្លូវបដិបត្តិ ជាអ្នកត្រាស់ដឹងហើយ ព្រោះត្រាស់ដឹងអរិយសច្ច ៤ ថាជាព្រាហ្មណ៍ ។

បទថា **យស្ស** ជាដើម សេចក្ដីថា តថាគតពោលបុគ្គលដែលទេវតាជាដើម មិនដឹងគតិ ជាអ្នកអស់អាសវៈ ព្រោះអាសវៈទាំងឡាយអស់ហើយ ជាព្រះអរហន្ត ព្រោះឆ្ងាយចាកកិលេសទាំងឡាយ ថាជាព្រាហ្មណ៍ ។

បទថា **បុរេ** គឺក្នុងខន្ធដែលជាអតីតទាំងឡាយ ។ បទថា **បច្ឆា** គឺក្នុងខន្ធដែលជាអនាគតទាំងឡាយ ។ បទថា **មជ្ឈេ** គឺក្នុងខន្ធដែលជាបច្ចុប្បន្ន ។ បទថា **អកិញ្ចនំ** សេចក្ដីថា តថាគតពោលបុគ្គលមិនមានកង្វល់ គឺការប្រកាន់ដោយអំណាចតណ្ហាក្នុងឋានៈទាំងនេះ ដែលមិនប្រកាន់ ថាជាព្រាហ្មណ៍ ។

សេចក្តីថា តថាគតពោលបុគ្គលអង់អាច ដែលដូចគ្នានឹងគោឧសភ ដោយអត្ថថា មិនមានការតក់ស្លុត ជាបុគ្គលប្រសើរ ព្រោះឧត្តម ជាអ្នកក្លៀវក្លា ព្រោះដល់ព្រមដោយសេចក្តីព្យាយាម ជាអ្នកស្វែងរកគុណធំ ព្រោះទ្រង់ស្វែងរកសីលក្ខន្ធជាដើម ដែលជាគុណធំ ជាអ្នកឈ្នះ ព្រោះឈ្នះមារ ៣ ពួក ជាអ្នកលាង គឺលាងកិលេសបានទាំងអស់ ជាអ្នកត្រាស់ដឹង ព្រោះត្រាស់ដឹងនូវអរិយសច្ច ៤ ថាជាព្រាហ្មណ៍ ។

សេចក្តីថា តថាគតពោលបុគ្គល អ្នករឭកជាតិមុនៗ បាន ជាអ្នកឃើញស្ថានសួគ៌ គឺទេវលោក ២៦ និងអបាយ ៤ ដោយទិព្វចក្ខុ ជាអ្នកសម្រេចអរហត្ត ពោល គឺការអស់ជាតិ ថាជាព្រាហ្មណ៍ ។

ព្រះមានព្រះភាគកាលត្រាស់នឹងព្រាហ្មណ៍ ដោយគុណយ៉ាងនេះហើយ កាលទ្រង់សម្តែងថា បុគ្គលណាធ្វើនូវការប្រកាន់ថា ជាព្រាហ្មណ៍ដោយកំណើត បុគ្គលនោះមិនដឹងវោហារនេះ ម្យ៉ាងទៀត ការឃើញនៃបុគ្គលនោះជាការឃើញអាក្រក់ ទើបត្រាស់គាថា ២ ថា **សមញ្ញា ហេសា** ដូច្នេះជាដើម ។

បទនោះ មានសេចក្តីដូច្នេះ នាម និងគោត្រ ដែលគេកំណត់ជាបញ្ញត្តិក្នុងលោក ថាជាព្រាហ្មណ៍ ជាក្សត្រ ជាភារទ្វាជមាណព ជាវាសេដ្ឋមាណពនេះ គប្បីជ្រាបថា ជាបញ្ញត្តិក្នុងលោក ត្រឹមតែជាវោហារបញ្ញត្តិប៉ុណ្ណោះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះជារបស់ដែលហៅតគ្នាមក ដោយសន្មត ។ ព្រោះនាម និងគោត្រនោះ ញាតិសាលោហិតសន្មតក្នុងកាលដែល

ជននោះកើតហើយនោះឯង បើមិនកំណត់នាម និងគោត្រយ៉ាងនេះ បុគ្គលឃើញបុគ្គល ក៏ដឹងមិនបានថា បុគ្គលនេះជាព្រាហ្មណ៍ ឬជាការទ្វាជមាណព ។ នាម និងគោត្រដែលកំណត់ហើយយ៉ាងនេះ ជាការឃើញរបស់ពួកជនមិនដឹង ដែលបន្តជាប់គ្នាមកអស់កាលយូរ នាម និងគោត្រកំណត់បន្តគ្នាជាការឃើញគ្នា ក្នុងហទយៈនៃសត្វទាំងឡាយ ដែលមិនដឹងអស់កាលយូរថា នេះគ្រាន់តែជានាម និងគោត្រ កំណត់ត្រឹមតែសម្រាប់ហៅឈ្មោះគ្នា ជនទាំងឡាយជាអ្នកមិនដឹង រមែងហៅនាម និងគោត្រនោះ ថាជាព្រាហ្មណ៍ដោយជាតិ ព្រោះនាម និងគោត្រនោះទាក់ទងគ្នាមក លោកអធិប្បាយថា អ្នកមិនដឹងប៉ុណ្ណោះ តែងពោលយ៉ាងនេះ ។

ជនទាំងឡាយណា ធ្វើនូវការប្រកាន់ថាជាព្រាហ្មណ៍ដោយជាតិ ជនទាំងនោះ មិនដឹងថា គ្រាន់តែជាវោហារ ។ ម្យ៉ាងទៀត ទិដ្ឋិរបស់ជនទាំងនោះ ជាទិដ្ឋិអាក្រក់ កាលទ្រង់សម្តែងដោយប្រការដូច្នេះហើយ ឥឡូវនេះ កាលទ្រង់បដិសេធវាទៈថាជាព្រាហ្មណ៍ព្រោះជាតិដោយត្រង់ និងកាលទ្រង់បណ្តុះនូវវាទៈ ថាជាព្រាហ្មណ៍ព្រោះកម្ម ទើបត្រាស់ថា **ន ជច្ចា** ដូច្នេះជាដើម ។

ក្នុងគាថានោះ ព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា **កស្សកោ កម្មុនា** ដើម្បីសេចក្តីពិស្តារនៃអត្ថដោយកន្លះគាថានេះថា **កម្មុនា ព្រាហ្មណោ ហោតិ កម្មុនា ហោតិ អព្រាហ្មណោ** ។

បទទាំងនោះ បទថា **កម្មុនា** បានដល់ ដោយចេតនាកម្មដែលធ្វើឲ្យកើតការងារខាងកសិកម្មជាដើមដែលជាបច្ចុប្បន្ន ។ បទថា **បដិច្ចសមុប្បាទ-**

**ទស្សា** បានដល់ បណ្ឌិតទាំងឡាយឃើញបដិច្ចសមុប្បាទយ៉ាងនេះថា ធម៌នេះកើតឡើងដោយបច្ច័យនេះ ។ បទថា **កម្មវិបាកកោវិទា** បានដល់ ឈ្លាសក្នុងកម្ម និងវិបាកយ៉ាងនេះថា ជាអ្នកកើតក្នុងត្រកូលដែលគួរសរសើរ និងមើលងាយដោយអំណាចកម្ម សូម្បីកើតជាសត្វដទៃ ក៏កើតដោយអំណាចកម្ម ភាពជាបុគ្គលថោកទាប និងប្រណីត ក៏កើតព្រោះកម្មថោកទាប និងកម្មប្រណីតឲ្យផល ។

ដោយគាថាថា **កម្មុនា វត្តតី** មានសេចក្ដីតែមួយដូចគ្នាថា សត្វលោក ពួកសត្វ ឬសត្វនោះឯង គ្រាន់តែផ្សេងគ្នាដោយវាចាប៉ុណ្ណោះ ។ ម្យ៉ាងទៀត ក្នុងបទថា **កម្មុនា វត្តតី** នេះ បទដំបូងគប្បីជ្រាបការបដិសេធទិដ្ឋិថា **អត្ថិ ព្រហ្មា មហាព្រហ្មា ។បេ។ សេដ្ឋោ សជ្ជិតា វសី បិតា ភូតព្យានំ** ព្រហ្មដ៏ចម្រើននេះ ជាមហាព្រហ្ម ។បេ។ ជាឥស្សរៈក្នុងលោក ជាអ្នកសាងលោក តាក់តែងលោក ជាចម្បងជាងសត្វលោក ជាអ្នកបញ្ញត្តលោក ជាអ្នកស្ទាត់ជំនាញ ជាបិតានៃពួកភូត និងពួកគព្ភៈ ដូច្នេះ ។ ពិតហើយ លោករមែងប្រព្រឹត្តទៅព្រោះកម្ម គឺតែងកើតក្នុងគតិទាំងឡាយនោះៗ លោកនោះមិនមានអ្នកសាង ។ ដោយបទទី ២ ទ្រង់សម្ដែងថា លោកសូម្បីកើតឡើងដោយកម្មយ៉ាងនេះ ក្នុងការប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ក៏រមែងប្រព្រឹត្តទៅដោយកម្មក្នុងអតីត និងបច្ចុប្បន្ន សោយសុខ និងទុក្ខ ដល់នូវការថោកទាប និងប្រណីតជាដើម ប្រព្រឹត្តទៅ ។ ដោយបទទី ៣ ទ្រង់សម្ដែងសរុបសេចក្ដីនោះ ដោយប្រការទាំងពួងយ៉ាងនេះ សត្វទាំងឡាយ ដែលមានកម្មជាគ្រឿង

ចង រមែងប្រព្រឹត្តទៅជាប់ជាមួយកម្មនោះឯង មិនមែនដទៃឡើយ ។ ដោយបទទី ៤ ទ្រង់សម្តែងសេចក្តីនោះដោយឧបមា ។ បទថា **រថស្សាណីវ យាយតោ** បានដល់ កម្ម ឈ្មោះថា ជាគ្រឿងចង ព្រោះកើតឡើង និងព្រោះការប្រព្រឹត្តទៅនៃសត្វលោក មិនមែនមិនមានគ្រឿងចងដែលកើតឡើង គឺប្រព្រឹត្តទៅមិនបាន ដូចភ្ជៅជាគ្រឿងឧបការៈដល់រថដែលស្ទុះទៅ មិនមែនមិនមានគ្រឿងឧបការៈនោះ ដូច្នោះ ។ ព្រោះលោកមានកម្មជាគ្រឿងចងយ៉ាងនេះ ដូច្នោះ ទើបព្រះមានព្រះភាគសម្តែងភាពជាបុគ្គលប្រសើរ ព្រោះកម្មប្រសើរ ទើបត្រាស់ ២ គាថាថា **តបេន** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **តបេន** បានដល់ ការសង្រួមឥន្ទ្រិយ ។ បទថា **ព្រហ្មចរិយេន** បានដល់ ការប្រព្រឹត្តដ៏ប្រសើរដែលសល់អំពីពោលហើយអាស្រ័យការសិក្សា ។ បទថា **សំយមេន** គឺដោយសីល ។ បទថា **ទមេន** គឺដោយបញ្ញា ។

បុគ្គលជាព្រាហ្មណ៍ ព្រោះកម្មដ៏ប្រសើរ គឺប្រសើរនោះ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះកម្មនេះ នាំភាពជាព្រាហ្មណ៍ដ៏ខ្ពង់ខ្ពស់មកឲ្យ លោកអធិប្បាយថា ភាពជាព្រាហ្មណ៍ដែលខ្ពង់ខ្ពស់ គឺកម្មនេះ ។ បាឋៈថា **ព្រហ្មានំ** ដូច្នេះក៏មាន ។ បទនោះ មានសេចក្តីដូច្នេះថា ឈ្មោះថា **ព្រហ្មានំ** ព្រោះនាំមកនូវភាពជាព្រហ្ម លោកអធិប្បាយថា នាំនូវភាពជាព្រាហ្មណ៍មកឲ្យ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ២ ដូច្នេះថា បទថា **សន្តោ** គឺមានកិលេសស្ងប់ហើយ ។ បទថា **ព្រហ្មា សក្កោ** គឺជាព្រហ្មផង ជាអ្នកអង់អាចផង ។

លោកអធិប្បាយថា បុគ្គលដែលមានសភាពយ៉ាងនោះ មិនមែនជាព្រាហ្មណ៍តែម្យ៉ាងទេ ការពិតបុគ្គលនោះ ជាព្រហ្មផង ជាអ្នកអង់អាចនៃបណ្ឌិតទាំងឡាយដែលដឹងច្បាស់ផង ម្នាលវាសេដ្ឋៈ ចូរអ្នកដឹងយ៉ាងនេះចុះ ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ដោយប្រការដូច្នេះ ៗ៚

**អដ្ឋកថា វាសេដ្ឋសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## កោកាលិកសូត្រទី ១០

[ ៧១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ កោកាលិកភិក្ខុចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ កោកាលិកភិក្ខុ លុះអង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សារីបុត្ត និងមោគ្គល្លាន ជាអ្នកមានសេចក្តីប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក ។

[ ៧២ ] លុះកោកាលិកភិក្ខុ ក្រាបបង្គំទូលយ៉ាងនេះហើយ ទើបព្រះមានព្រះភាគទ្រង់ត្រាស់នឹងកោកាលិកភិក្ខុដូច្នេះថា នែកោកាលិក អ្នកកុំពោលយ៉ាងនេះឡើយ នែកោកាលិក អ្នកកុំពោលយ៉ាងនេះឡើយ នែកោកាលិក អ្នកចូរធ្វើចិត្តឲ្យជ្រះថ្លាក្នុងសារីបុត្ត និងមោគ្គល្លានចុះ ដ្បិតសារីបុត្ត និងមោគ្គល្លានមានសីលជាទីស្រឡាញ់ ។ កោកាលិកភិក្ខុ ក្រាបបង្គំទូលព្រះមានព្រះភាគជាគម្រប់ពីរដងទៀតដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគគួរខ្ញុំព្រះអង្គជឿ គួរខ្ញុំព្រះអង្គចូលចិត្តពិតមែន តែថា សារីបុត្ត និងមោគ្គល្លាន ជាអ្នកមានសេចក្តីប្រាថ្នាលាមក លុះអំណាចនៃសេចក្តីប្រាថ្នាលាមក ។ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងកោកាលិកភិក្ខុជាគម្រប់ពីរដងទៀតដូច្នេះថា នែកោកាលិក អ្នកកុំពោលយ៉ាងនេះឡើយ នែកោកាលិក អ្នកកុំពោលយ៉ាងនេះឡើយ នែកោកាលិក អ្នកចូរធ្វើចិត្តឲ្យជ្រះថ្លាក្នុងសារីបុត្ត និង

មោគ្គល្លានចុះ ដ្បិតសារីបុត្ត និងមោគ្គល្លាន មានសីលជាទីស្រឡាញ់ ។ កោកាលិកភិក្ខុ ក្រាបបង្គំទូលព្រះមានព្រះភាគជាគម្រប់បីដងទៀត ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគគួរខ្ញុំព្រះអង្គជឿ គួរខ្ញុំព្រះអង្គចូលចិត្តពិតមែន តែថា សារីបុត្ត និងមោគ្គល្លាន ជាអ្នកមានសេចក្ដីប្រាថ្នាលាមក លុះអំណាចនៃសេចក្ដីប្រាថ្នាលាមក ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងកោកាលិកភិក្ខុជាគម្រប់បីដងទៀត ដូច្នេះថា នែកោកាលិក អ្នកកុំពោលយ៉ាងនេះឡើយ នែកោកាលិក អ្នកកុំពោលយ៉ាងនេះឡើយ នែកោកាលិក ចូរអ្នកធ្វើចិត្តឲ្យជ្រះថ្លាក្នុងសារីបុត្ត និងមោគ្គល្លានចុះ ដ្បិតសារីបុត្ត និងមោគ្គល្លាន មានសីលជាទីស្រឡាញ់ ។ គ្រានោះ កោកាលិកភិក្ខុក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ ចៀសចេញទៅ ។ កាលកោកាលិកភិក្ខុចៀសចេញទៅមិនយូរប៉ុន្មាន ស្រាប់តែរាងកាយទាំងមូល មានពកប្រមាណប៉ុនគ្រាប់ស្ពៃ ដុះដោរឡើង ។ ពកប្រមាណប៉ុនគ្រាប់ស្ពៃ ក៏ធំឡើងប៉ុនគ្រាប់សណ្ដែកបាយ ។ ពកប្រមាណប៉ុនគ្រាប់សណ្ដែកបាយ ក៏ធំឡើងប៉ុនគ្រាប់សណ្ដែកខ្មៅ ។ ពកប្រមាណប៉ុនគ្រាប់សណ្ដែកខ្មៅ ក៏ធំឡើងប៉ុនគ្រាប់ផ្លែពុទ្រា ។ ពកប្រមាណប៉ុនគ្រាប់ផ្លែពុទ្រា ក៏ធំឡើងប៉ុនផ្លែពុទ្រា ។ ពកប្រមាណប៉ុនផ្លែពុទ្រា ក៏ធំឡើងប៉ុនផ្លែសម៉ ។ ពកប្រមាណប៉ុនផ្លែសម៉ ក៏ធំឡើងប៉ុនក្ដឹបល្ពៅ ។ ពកប្រមាណប៉ុនក្ដឹបល្ពៅ ក៏ធំឡើងប៉ុនផ្លែល្ពៅ ។ ពកប្រមាណប៉ុនផ្លែល្ពៅ ក៏បែក ( ពេញទាំងសរីរៈ ) ។ ខ្ទុះ និងឈាមក៏ហូរហៀរចេញ ។ លំដាប់នោះ កោកាលិកភិក្ខុ ក៏ធ្វើមរណៈដោយអាពាធនោះឯង ។

កោកាលិកភិក្ខុ លុះធ្វើមរណកាលហើយ ក៏ទៅកើតក្នុងបទុមនរក ព្រោះចងចិត្តអាឃាតក្នុងព្រះសារីបុត្ត និងព្រះមោគ្គល្លាន ។ គ្រានោះ រាត្រីបឋមយាមកន្លងទៅ សហម្បតីព្រហ្មមានរស្មីរុងរឿង បណ្ដាលវត្តជេតពនជុំវិញទាំងអស់ឲ្យភ្លឺប្រាល ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។ សហម្បតីព្រហ្ម លុះឋិតនៅក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កោកាលិកភិក្ខុធ្វើមរណកាលហើយ បពិត្រព្រះអង្គដ៏ចម្រើន កោកា-លិកភិក្ខុ លុះធ្វើមរណកាលហើយ ក៏ទៅកើតក្នុងបទុមនរក ព្រោះចងចិត្តអាឃាតក្នុងព្រះសារីបុត្ត និងព្រះមោគ្គល្លាន ។ សហម្បតីព្រហ្មក្រាបបង្គំទូលសេចក្ដីនេះរួចហើយ លុះពោលពាក្យនេះហើយ ធ្វើប្រទក្សិណ រួចក៏បាត់ទៅក្នុងទីនោះឯង ។ គ្រានោះ លុះកន្លងរាត្រីនោះទៅ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ យប់មិញនេះ នារាត្រីបឋមយាមកន្លងទៅហើយ សហម្បតីព្រហ្ម ។បេ។ ម្នាលភិក្ខុទាំងឡាយ សហម្បតីព្រហ្មបានពោលពាក្យនេះ លុះពោលពាក្យនេះហើយ ធ្វើប្រទក្សិណ រួចក៏បាត់ទៅក្នុងទីនោះឯង ។

[ ៧៣ ] កាលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ ភិក្ខុ ១ រូបក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ប្រមាណនៃអាយុក្នុងបទុមនរក តើយូរអង្វែងយ៉ាងណាទៅ ។ ម្នាលភិក្ខុ ប្រមាណនៃអាយុក្នុងបទុមនរកយូរអង្វែងណាស់ ប្រមាណនោះ បុគ្គលមិនងាយនឹងរាប់បានថា

ប៉ុណ្ណេះឆ្នាំ ឬប៉ុណ្ណោះរយឆ្នាំ ប៉ុណ្ណេះពាន់ឆ្នាំ ឬប៉ុណ្ណេះសែនឆ្នាំឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គអាចនឹងធ្វើសេចក្តីឧបមាបានដែរឬ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ តថាគតអាចនឹងធ្វើបាន ។ ម្នាលភិក្ខុ ដូចរទេះសម្រាប់ផ្ទុកគ្រាប់ល្ង របស់អ្នកដែនកោសល មានចំណុះ ២០ ខារី មានបុរសម្នាក់ លុះកន្លងទៅ ១ រយឆ្នាំ ១ ពាន់ឆ្នាំ ១ សែនឆ្នាំ ទើបរើសគ្រាប់ល្ង ម្តងមួយគ្រាប់ៗ អំពីរទេះនោះ ម្នាលភិក្ខុ រទេះសម្រាប់ផ្ទុកគ្រាប់ល្ង របស់អ្នកដែនកោសល ចំណុះ ២០ ខារីនោះ ដល់នូវការអស់ទៅ ដោយព្យាយាមនេះ ឆាប់ជាង ឯកាលយូរអង្វែងរបស់អព្វុទនរកមួយ មិនងាយនឹងដល់នូវការអស់បានឡើយ ម្នាលភិក្ខុ អព្វុទនរក ២០ ជង ( យូរ ) យ៉ាងណា និរព្វុទនរកតែមួយ ក៏យ៉ាងនោះដែរ ម្នាលភិក្ខុ និរព្វុទនរក ២០ ជងយូរយ៉ាងណា អពពនរកតែមួយ ក៏យ៉ាងនោះដែរ ម្នាលភិក្ខុ អពពនរក ២០ ជង យូរយ៉ាងណា អហហនរកតែមួយ ក៏យូរយ៉ាងនោះដែរ ម្នាលភិក្ខុ អហហនរក ២០ ជង ( យូរ ) យ៉ាងណា អដដនរកតែមួយ ក៏យូរយ៉ាងនោះដែរ ម្នាលភិក្ខុ អដដនរក ២០ ជង ( យូរ ) យ៉ាងណា កុមុទនរកតែមួយ ក៏យូរយ៉ាងនោះដែរ ម្នាលភិក្ខុ កុមុទនរក ២០ ជង ( យូរ ) យ៉ាងណា សោគន្ធិកនរកតែមួយ ក៏យូរយ៉ាងនោះដែរ ម្នាលភិក្ខុ សោគន្ធិកនរក ២០ ជង ( យូរ ) យ៉ាងណា ឧប្បលនរកតែមួយ ក៏យូរយ៉ាងនោះដែរ ម្នាលភិក្ខុ ឧប្បលនរក ២០ ជង ( យូរ ) យ៉ាងណា បុណ្ឌរីកនរកតែមួយ ក៏យូរយ៉ាងនោះដែរ ម្នាលភិក្ខុ បុណ្ឌរីកនរក ២០ ជង ( យូរ ) យ៉ាងណា បទុមនរក

តែមួយ ក៏យ៉ូរយ៉ាងនោះដែរ ម្នាលភិក្ខុ ឯកោកាលិកភិក្ខុ ចូលទៅកើតក្នុងបទុមនរក ( នោះ ) ព្រោះចងចិត្តអាឃាតក្នុងសារីបុត្ត និងមោគ្គល្លាន ។

ព្រះមានព្រះភាគទ្រង់ត្រាស់ព្រះពុទ្ធដីកានេះ ព្រះសុគតជាសាស្តា លុះទ្រង់ត្រាស់ព្រះពុទ្ធដីកានេះរួចហើយ ទើបទ្រង់ត្រាស់គាថាព័ន្ធតទៅទៀតថា

[ ៧៤ ] បុគ្គលពាលពោលពាក្យទុព្ភាសិត រមែងកាត់នូវឫសគល់នៃខ្លួន ( កុសលមូល ) ដោយផរុសវាចាណា វាចា ( នោះ ) ដូចជាដឹងចាំង កើតក្នុងមាត់នៃបុរស ( នោះ ) ។ បុគ្គលណាសរសើរនូវបុគ្គលដែលគួរនិន្ទា ឬនិន្ទានូវបុគ្គល ដែលគួរសរសើរវិញ បុគ្គលនោះឈ្មោះថា សន្សំនូវទោសកំហុសដោយមាត់ មិនបានសេចក្តីសុខ ដោយទោសកំហុសនោះទេ ។ កិរិយាចាញ់ដោយទ្រព្យទាំងអស់ ឬជាមួយនឹងខ្លួនផង ព្រោះល្បែងភ្នាល់ទាំងឡាយណា ការចាញ់នេះជាទោសកំហុស មានប្រមាណតិចទេ បុគ្គលណា ធ្វើចិត្តប្រទូស្តក្នុងព្រះសុគត គឺព្រះសម្មាសម្ពុទ្ធ បច្ចេកពុទ្ធ ពុទ្ធសាវក ការប្រទូស្តនេះឯង ជាទោសកំហុសធំជាង ។

បុគ្គលតិះដៀលព្រះអរិយៈ តម្កល់វាចា ចិត្តលាមករមែងចូលទៅកាន់បទុមនរក អស់កាលណា កាលនោះ កំណត់ ១ សែននិរព្វុទៈ ៣៦ និង ៥ អព្វុទនរកទៀត ។

បុគ្គលណា ពោលពាក្យមិនពិត ឬបុគ្គលណា ធ្វើហើយ

និយាយថា អាត្មាអញមិនធ្វើវិញ រមែងទៅនរក បុគ្គលទាំងពីរពួកនោះ ជាមនុស្សមានកម្មដ៏ថោកទាប លុះលះអត្តភាពនេះទៅ រមែងស្មើគ្នាក្នុងលោកខាងមុខ ។

បុគ្គលណាប្រទូស្ត ចំពោះជនដែលមិនប្រទូស្ត ជាបុរសបរិសុទ្ធ មិនមានកិលេស បាបរមែងត្រឡប់ត្រូវបុគ្គលពាលនោះវិញ ដូចជាធូលីដ៏ល្អិត ដែលបុគ្គលបាចទៅកាន់ទីច្រាសខ្យល់ ។

បុគ្គលណា ប្រកបរឿយៗ ក្នុងលោភគុណ ( តណ្ហា ) បុគ្គលនោះ មិនមានសទ្ធា មានតែសេចក្តីកំណាញ់ស្វិតស្វាញ មិនស្គាល់ពាក្យឱវាទ ជាអ្នកកំណាញ់ ប្រកបរឿយៗ ក្នុងបិសុណាវាចា រមែងតិះដៀលនូវបុគ្គលដទៃ ដោយពាក្យ ។

ម្នាលអ្នកមានមាត់អាក្រក់ ពោលពាក្យគ្មានពិត មិនប្រសើរ បំផ្លាញនូវសេចក្តីចម្រើន ជាមនុស្សលាមក ធ្វើអំពើអាក្រក់ ជាបុរសថោកទាប បុរសឥតបុណ្យ មានកំណើតថោកទាប អ្នកឯងដូចជាសត្វនរក អ្នកកុំនិយាយច្រើន ក្នុងទីនេះឡើយ ។ អ្នករោយចុះនូវធូលីលើខ្លួន ដើម្បីមិនជាប្រយោជន៍ អ្នកតិះដៀលពួកសប្បុរស ធ្វើអំពើអាក្រក់ ប្រព្រឹត្តទុច្ចរិតច្រើនប្រការ អ្នកនឹងទៅកាន់នរក អស់កាលយូរអង្វែង ។ កម្មរបស់សត្វនីមួយៗ មិនវិនាសទេ សត្វជាម្ចាស់ រមែងបាននូវកម្មនោះសត្វល្ងង់ខ្លៅ អ្នកធ្វើកម្មអាក្រក់ ឃើញនូវទុក្ខចំពោះខ្លួន ក្នុង

លោកខាងមុខ ។ អ្នកធ្វើអំពើអាក្រក់ តែងចូលទៅកាន់ចម្រូង ដែកដ៏មុត ជាទីដែលនាយនិរយបាល ចាក់នឹងដែកស្រួច ទាំង ដុំដែកមានសណ្ឋាន ប្រហែលផ្លែព្នៅដ៏ក្តៅ សមគួរដល់កម្មនោះ ជាភោជន ( របស់សត្វទាំងនោះ ) ។ ពួកនិរយបាល កាល និងពោល មិនពោលពាក្យពីរោះឡើយ មិនស្ទុះទៅដោយមុខរីក រាយ មិនមែនចូលទៅឲ្យជាទីពឹងបានទេ ឲ្យដេកលើកម្រាលរងើក ភ្លើង បញ្ចូលទៅកាន់អណ្តាតភ្លើង ដែលឆេះសន្ធោសន្ធៅ ។ ពួកនាយនិរយបាល ព័ទ្ធដោយសំណាញ់ វាយដោយញញួរ ដែក ក្នុងទីនោះ សត្វនរក ដើរទៅកាន់នរក ( ឈ្មោះភូម- ភារុត ) ងងឹតឈ្ងប់ ដែលធ្វើឲ្យខ្វាក់ នរកនោះ ជំទូលាយ ដូចជាផ្ទៃផែនដី ។ មួយវិញទៀត សត្វនរកចូលទៅកាន់ លោហកុម្ភីនរក ដែលមានអណ្តាតភ្លើងឆេះសន្ធោសន្ធៅ ជា សត្វលិចអណ្តែតៗ ឆេះនៅក្នុងលោហកុម្ភីនោះ ដែលមានភ្លើង ឆេះជុំវិញ អស់កាលយូរអង្វែង ។ បុគ្គលធ្វើកម្មអាក្រក់ តែង ឆេះនៅក្នុងលោហកុម្ភីនរកនោះ ប្រឡំដោយខ្ទុះ និងឈាម តើ ដូចម្តេច សត្វនរកទៅកាន់ទិសណាៗ សឹងប៉ះពាល់ដោយខ្ទុះ និងឈាម ប្រឡូកប្រឡាក់ក្នុងទិសនោះៗ ។ បុគ្គលធ្វើកម្ម អាក្រក់ តែងរងផលកម្មក្នុងទឹក ( ទង់ដែង ) ជាទីនៅរបស់ ដង្កូវ ក្នុងគូថនរកនោះ តើដូចម្តេច ទីជម្រាល គឺច្រាំង អាច

នឹងឡើងចុះបានពុំមានឡើយ ព្រោះថា រណ្ដៅនរក ( នោះ ) មានអម្បែងបោត ស្មើជុំវិញទាំងអស់ ។ មួយវិញទៀត សត្វនរកចូលទៅកាន់ព្រៃឈើ មានស្លឹកជាដាវដ៏មុត មានខ្នងមុតជាប់សត្វអន្ទើដោយដាវនោះ នាយនិរយបាលក៏ថ្ពក់ទាញអណ្ដាតដោយផ្ទៃសន្ទូចហើយ កាប់សម្លាប់ហើយ សម្លាប់ទៀត ។ តពីនោះ សត្វនរកស្ទុះចូលទៅកាន់ស្ទឹងទឹកផ្សា ( ទឹកក្រុត ) ដែលសត្វហែលទៅបានដោយកម្រ ឬស្ទុះចូលទៅកាន់មុខកាំបិតកោរ មានមុខដ៏មុត សត្វល្ងង់ខ្លៅ ជាអ្នកធ្វើអំពើលាមក លុះធ្វើអំពើលាមកទាំងឡាយហើយ រមែងធ្លាក់ទៅក្នុងនរកនោះ ។ ហ្វូងក្អែកខ្មៅ ហ្វូងឆ្កែសម្បុរលឿង សម្បុរពព្រុស ហ្វូងចចកហ្វូងត្មាត ហ្វូងតាដក់ ហ្វូងក្អែកស តែងចឹកជញ្ជែងស៊ីរូង ( នូវសត្វនរក ) ដែលកំពុងស្រែកយំក្នុងនរកនោះ ។ ជនអ្នកធ្វើនូវកម្មអាក្រក់ ឃើញនូវសេចក្ដីប្រព្រឹត្តណា សេចក្ដីប្រព្រឹត្តក្នុងនរកនេះ ជាការលំបាកមែន ព្រោះហេតុនោះ កាលបើមានជីវិតរស់នៅក្នុងលោកនេះ នរជនគប្បីធ្វើកិច្ចកុំប្រមាទឡើយ ។ ពួកសត្វណា ចូលទៅកើតក្នុងបទុមនរកអស់ ១ នហុត ( មួយរយសែនកោដិប្បកោដិ ) និង ៥ កោដិឆ្នាំទៀត ឬអស់ ១២ រយកោដិដទៃទៀត ពួកសត្វនរកទាំងនោះ អ្នកប្រាជ្ញទាំងឡាយរាប់ហើយ ដោយរទេះល្ង ។ សេចក្ដីទុក្ខក្នុងនរក ដែលលោក

ពោលហើយ ក្នុងទីនេះ យូរត្រឹមណា កោកាលិកភិក្ខុគប្បីទៅក្នុងនរកនោះ អស់កាលយូរត្រឹមនោះ ព្រោះហេតុនោះ បុគ្គលគប្បីរក្សាវាចា ចិត្ត ឲ្យល្អជាប្រក្រតីក្នុងគុណដ៏ប្រពៃ គឺសេចក្តីស្អាត និងសីលជាទីស្រឡាញ់ចុះ ។

កោកាលិកសូត្រទី ១០ ចប់

# អដ្ឋកថា

## កោកាលិកសូត្រ

[ ៧១ ] ក្នុងកោកាលិកសូត្រទី ១០ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះ ។

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្តេច ឆ្លើយថា ការកើតកើតឡើងនៃសូត្រនេះ មានច្បាស់ក្នុងអដ្ឋកថានៃសូត្រនោះឯង ។

បទ មានបទថា **ឯវម្មេ សុតំ** នៃសូត្រនេះ មានន័យដូចពោលហើយក្នុងអដ្ឋកថានោះឯង ។

ក្នុងបទថា **អថ ខោ កោកាលិកោ** នេះ កោកាលិកជានរណា ហេតុអ្វី ទើបចូលទៅគាល់ព្រះមានព្រះភាគ ខ្ញុំនឹងពោលដូចតទៅនេះ

បានឮថា កោកាលិកៈនេះ ជាបុត្តរបស់កោកាលិកសេដ្ឋី ក្នុងក្រុងកោកាលិកៈ ដែនកោកាលិកៈ ចេញបួសហើយ អាស្រ័យក្នុងវិហារដែលបិតា

សានំនោះឯង មានឈ្មោះថា ចូឡកោកាលិកៈ មិនមែនជាសិស្សរបស់ទេវទត្តឡើយ ព្រោះកោកាលិកៈដែលជាសិស្សទេវទត្តនោះ ជាកូនព្រាហ្មណ៍ឈ្មោះថា មហាកោកាលិកៈ ។ បានឮថា កាលព្រះមានព្រះភាគគង់នៅក្នុងនគរសាវត្ថី អគ្គសាវក ២ រូប មួយអន្លើដោយភិក្ខុប្រមាណ ៥០០ ចារិកទៅកាន់ជនបទ កាលកៀកនឹងចូលវស្សា បញ្ជូនភិក្ខុទាំងនោះត្រឡប់ ខ្លួនឯងកាន់បាត្រ និងចីវរ ទៅដល់នគរក្នុងជនបទនោះ បានទៅកាន់វិហារនោះ ក្នុងទីនោះ អគ្គសាវកទាំង ២ រូប សន្ទនាជាមួយកោកាលិកភិក្ខុនោះហើយ ពោលថា អាវុសោ ខ្ញុំនឹងនៅក្នុងទីនេះ ៣ ខែ លោកកុំប្រាប់អ្នកណា ។ កោកាលិកភិក្ខុទទួលពាក្យហើយ ។ លុះកន្លងទៅ ៣ ខែ ថ្ងៃមួយ កោកាលិកភិក្ខុប្រញាប់ចូលទៅកាន់នគរពោលថា អ្នកទាំងឡាយ មិនដឹងទេឬថា អគ្គសាវកទាំង ២ មកនៅក្នុងទីនេះ ទើបមិនមាននរណានិមន្តដើម្បីប្រគេនបច្ច័យ ។ អ្នកនគរសួរថា ចុះហេតុអ្វី លោកម្ចាស់មិនប្រាប់ពួកខ្ញុំ ។ កោកាលិកភិក្ខុឆ្លើយថា ចាំបាច់ប្រាប់ធ្វើអ្វី ពួកអ្នកមិនឃើញភិក្ខុ ២ រូប នៅអាស្រ័យទេឬ លោកទាំង ២ នោះជាអគ្គសាវកមិនមែនឬ អ្នកនគរប្រជុំគ្នាដោយរួសរាន់ នាំសប្បិ ស្ករអំពៅ និងសំពត់ជាដើម មកដាក់ក្បែរកោកាលិកភិក្ខុ ។ កោកាលិកភិក្ខុគិតថា អគ្គសាវកទាំង ២ ជាអ្នកប្រាថ្នាតិចក្រៃលែង កាលដឹងថាលាភកើតឡើងព្រោះមាត់របស់អញ នឹងមិនទទួល កាលមិនទទួលនឹងពោលថា ចូរអ្នកទាំងឡាយ ប្រគេនដល់ភិក្ខុម្ចាស់អាវាសចុះដោយពិត ឈ្មោយចុះ អញនឹងឲ្យអគ្គសាវកទាំង ២ ទទួលលាភនេះ ។ កោកាលិកភិក្ខុបានធ្វើយ៉ាង

នោះ ព្រះថេរៈទាំង ២ ឃើញហើយ ក៏ដឹងថា លាភកើតឡើង ព្រោះវាចាជាខ្នាស ទើបគិតថា បច្ច័យទាំងនេះមិនគួរដល់អញទាំង ២ ឡើយ និងមិនគួរដល់កោកាលិកភិក្ខុផងដែរ ទើបមិនពោលថា ចូរអ្នកទាំងឡាយ ប្រគេនដល់ម្ចាស់អាវាសចុះ បដិសេធហើយ ក៏នាំគ្នាចៀសចេញទៅ ។ ដោយហេតុនោះកោកាលិកភិក្ខុក៏កើតទោមនស្សថា នេះអ្វីហ្ន៎ អគ្គសាវកទាំង ២ មិនទទួលដោយខ្លួនឯង ទាំងមិនប្រាប់ឲ្យប្រគេនដល់អញ ។ អគ្គសាវកទាំង ២ បានទៅគាល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ កាលទ្រង់បវារណាហើយ បើទ្រង់មិនយាងចារិកទៅកាន់ជនបទដោយព្រះអង្គឯង ក៏ទ្រង់នឹងប្រាប់អគ្គសាវកទាំង ២ ឲ្យទៅថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយត្រាច់ទៅកាន់ចារិក ( គឺស្រុក និងនិគម និងរាជធានី ហើយសម្ដែងធម៌ ) ដើម្បីជាប្រយោជន៍និងសេចក្ដីសុខដល់ជនជាច្រើន ដូច្នេះជាដើម ។ នេះជាប្រពៃណីរបស់ព្រះតថាគតទាំងឡាយ ។

សម័យនោះ ព្រះអង្គមិនមានបំណងយាងទៅមួយព្រះអង្គឯង ទើបបញ្ជូនអគ្គសាវកទាំង ២ ទៅ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរពួកអ្នកទៅ ចូរត្រាច់ចារិកទៅចុះ ដូច្នេះ ។ ព្រះអគ្គសាវកទាំង ២ មួយអន្លើដោយភិក្ខុប្រមាណ ៥០០ រូប ត្រាច់ចារិកទៅ បានដល់ នគរនោះ ក្នុងដែននោះៗ ដោយលំដាប់ ។ អ្នកនគរចាំព្រះថេរៈទាំង ២ បាន ទើបត្រៀមទាន មួយអន្លើដោយបរិក្ខារ សាងមណ្ឌបកណ្ដាលនគរនាំគ្នាថ្វាយទាន បង្អោនបរិក្ខារចូលទៅប្រគេនព្រះថេរៈទាំង ២ ។ ព្រះថេរៈទាំង ២ ទទួលហើយ បាន

ឲ្យដល់ភិក្ខុសង្ឃ ។ កោកាលិកភិក្ខុឃើញដូច្នោះ ក៏គិតថា ក្នុងកាលមុន អគ្គ-សាវកទាំង ២ រូបនេះ ជាអ្នកប្រាថ្នាតិច ឥឡូវនេះ ត្រូវសេចក្ដីលោភគ្រប សង្កត់ ជាអ្នកប្រាថ្នាលាមកហើយ កាលមុន លោកទាំង ២ ជាអ្នកប្រាថ្នា តិច សន្ដោស ប្រកបដោយវិវេក ឥឡូវនេះ មានការប្រាថ្នាលាមក ជាភិក្ខុ លាមក សម្ដែងនូវគុណនៃអសប្បុរស ។ កោកាលិកភិក្ខុក៏ចូលទៅរកព្រះថេរៈ ទាំង ២ ពោលថា អាវុសោ លោកទាំង ២ កាលមុន ជាអ្នកប្រាថ្នាតិច សន្ដោស ប្រកបដោយវិវេក តែឥឡូវនេះ ក្លាយជាភិក្ខុលាមកទៅហើយ កាន់ បាត្រ និងចីវរចេញទៅមួយរំពេច គិតថា នឹងក្រាបទូលសេចក្ដីនេះ ដល់ព្រះ មានព្រះភាគ ទើបបែរមុខទៅកាន់ក្រុងសាវត្ថី គាល់ព្រះមានព្រះភាគដោយ លំដាប់ ។ ក្នុងសូត្រនេះ កោកាលិកភិក្ខុនេះ បានចូលទៅគាល់ព្រះមាន ព្រះភាគ ដោយហេតុនេះ ។ ដូចព្រះសង្គីតិកាចារ្យពោលពាក្យជាដើមថា គ្រានោះ កោកាលិកភិក្ខុចូលទៅគាល់ព្រះមានព្រះភាគ ដូច្នេះ ។

ព្រះមានព្រះភាគ ទតឃើញកោកាលិកភិក្ខុនោះ រលាស់រលាំងចូលមក ទើបទ្រង់ពិចារណាមើល បានដឹងថា កោកាលិកភិក្ខុបំណងនឹងជេរអគ្គសាវក ទាំង ២ ទ្រង់ពិចារណាបន្តថា ទ្រង់អាចឃាត់បានឬហ្ន៎ ទ្រង់ក៏ឃើញថា មិន អាចឃាត់បាន កោកាលិកភិក្ខុនោះ មកដើម្បីប្រទូស្តក្នុងអគ្គសាវកទាំង ២ នឹងកើតក្នុងបទុមនរកដោយពិត ។ ព្រះសាស្ដា កាលទ្រង់ដោះនូវពាក្យនិន្ទា របស់អ្នកដទៃថា ព្រះមានព្រះភាគសូម្បីទ្រង់ឃើញយ៉ាងនេះ ទ្រង់ស្ដាប់ពាក្យ តិះដៀលព្រះសារីបុត្ត និងព្រះមោគ្គល្លានហើយ ទ្រង់មិនឃាត់ និងដើម្បី

សម្តែងការមានទោសច្រើនរបស់បុគ្គលដែលតិះដៀលព្រះអរិយៈ ទើបត្រាស់ហាមដល់ទៅ ៣ ដង ដោយន័យជាដើមថា នែកោកាលិកៈ អ្នកកុំពោលយ៉ាងនេះឡើយ ដូច្នេះ ។

[ ៧២ ] ក្នុងបទទាំងនោះ បទថា **មា ហេវំ** សេចក្តីថា អ្នកកុំពោលយ៉ាងនេះឡើយ ។ បទថា **បេសលា** ប្រែថា មានសីលជាទីស្រឡាញ់ ។ បទថា **សទ្ធាយិកោ** គឺនាំឲ្យបង្អោនចិត្តជឿ អធិប្បាយថា នាំមកនូវការជឿ ។ បទថា **បច្ចយិកោ** បានដល់ ធ្វើឲ្យមានបច្ច័យក្នុងការជឿ អធិប្បាយថា ឲ្យនាំមកនូវការជាក់ចិត្តថា នេះពិតជាយ៉ាងនោះ ។

បទថា **អចិរបក្កន្តស្ស** គឺកាលកោកាលិកភិក្ខុចៀសចេញទៅមិនយូរប៉ុន្មាន ។ បទថា **សព្វោ កាយោ ផុដ្ឋោ អហោសិ** សេចក្តីថា ពេញរាងកាយមិនវៀរសាច់ប៉ុនចម្រៀកសក់ មានពកទម្លាយឆ្អឹង កើតឡើងពេញសរីរៈ ព្រោះដោយពុទ្ធានុភាព កម្មបែបនោះ មិនឲ្យផលក្នុងកាលនៅចំពោះព្រះភក្ត្ររបស់ព្រះសម្ពុទ្ធ លុះផុតក្រសែចក្ខុទៅហើយ ទើបឲ្យផល ដូច្នោះ កាលកោកាលិកភិក្ខុចៀសចេញទៅមិនយូរ ពកក៏កើតឡើង ដោយហេតុនោះ ទើបលោកពោលថា កាលកោកាលិកភិក្ខុ ចៀសចេញទៅមិនយូរប៉ុន្មាន ដូច្នេះ ។ បើមានពាក្យសួរថា កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបកោកាលិកភិក្ខុមិននៅក្នុងទីនោះ ឆ្លើយថា ដោយអានុភាពរបស់កម្ម ។ ព្រោះកម្មរង់ចាំឱកាសឲ្យផលពិតប្រាកដ ព្រោះហេតុនោះ ទើបកម្មមិនឲ្យកោកាលិកភិក្ខុនៅក្នុងទីនោះ ។ កោកាលិកភិក្ខុនោះ ត្រូវកម្មដាស់តឿន ដោយអានុភាពនៃកម្ម ទើបក្រោកពីទី

អន្តុយ ចៀសចេញទៅ ។ បទថា **កឡាយមត្តិយោ** ប្រែថា ប៉ុនគ្រាប់សណ្តែកខ្មៅ គឺប៉ុនគ្រាប់ស្ពួយ ។ បទថា **វេឡុវសលាដុកមត្តិយោ** គឺប៉ុនផ្លែព្នៅខ្ចី ។ បទថា **បភិជ្ជឹសុ** គឺបែកហើយ ។ កាលពកទាំងឡាយបែកហើយ សរីរៈទាំងមូលដូចផ្លែខ្នុរទុំ ។ កោកាលិកភិក្ខុនោះ មានខ្លួនស្អុយ ដល់នូវសេចក្តីលំបាក ត្រូវសេចក្តីទុក្ខគ្របសង្កត់ ដេកត្រង់ខ្លោងទ្វារវត្តជេតពនមហាវិហារ ។ លំដាប់នោះមនុស្សទាំងឡាយ នាំគ្នាមកដើម្បីស្តាប់ធម៌ កាលឃើញកោកាលិកភិក្ខុនោះ ក៏ពោលតិះដៀលថា ឱ ! កោកាលិកៈ ឱ ! កោកាលិកៈ លោកធ្វើកម្មមិនសមគួរឡើយ លោកអាស្រ័យមាត់របស់ខ្លួនឯងពិត ទើបដល់នូវសេចក្តីលំបាក ។ បណ្តាអារក្ខទេវតា បានស្តាប់ពាក្យរបស់មនុស្សទាំងនោះ ក៏តិះដៀលដោយសំឡេងតែមួយ ។ បណ្តាអាកាសទេវតាបានស្តាប់សំឡេងនៃអារក្ខទេវតា ក៏តិះដៀលដោយសំឡេងតែមួយដោយឧបាយនេះ រហូតដល់អកនិដ្ឋភព ។

កាលនោះ ភិក្ខុឈ្មោះតុទុ[១] ជាឧបជ្ឈាយ៍របស់កោកាលិកភិក្ខុ បានអនាគាមិផល កើតជាព្រហ្មក្នុងសុទ្ធាវាស ។ ព្រហ្មនោះ ចេញអំពីសមាបត្តិបានឮសំឡេងនោះ ទើបមកឲ្យឱវាទដល់កោកាលិកភិក្ខុ ដើម្បីឲ្យកើតសេចក្តីជ្រះថ្លាក្នុងព្រះសារីបុត្ត និងព្រះមោគ្គល្លាន ។ កោកាលិកភិក្ខុនោះ មិនជឿពាក្យរបស់ព្រហ្មនោះ ក៏ដល់នូវមរណភាពទាំងដែលមិនជ្រះថ្លានោះឯង បានកើតក្នុងបទុមនរក ។

---

១- ក្នុងទីខ្លះជា ចតុទី , ចតុទីប និង តុរុ ក៏មាន ។

ដោយហេតុនោះ ទើបព្រះសង្គីតិកាចារ្យពោលថា លំដាប់នោះ កោកាលិកភិក្ខុក៏ធ្វើមរណៈដោយអាពាធនោះឯង ។ កោកាលិកភិក្ខុ លុះធ្វើមរណកាលហើយ ក៏ទៅកើតក្នុងបទុមនរក ព្រោះចងចិត្តអាឃាតក្នុងព្រះសារីបុត្ត និងព្រះមោគ្គល្លាន ។

បទថា **អថខោ ព្រហ្មា សហម្បតិ** សួរថា ព្រហ្មនេះ ជានរណា ព្រោះហេតុអ្វី ទើបចូលគាល់ព្រះមានព្រះភាគ ហើយពោលពាក្យនេះ ឆ្លើយថា សហម្បតីព្រហ្មនេះ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមកស្សបៈ ជាភិក្ខុឈ្មោះសហកៈ បានជាអនាគាមី កើតក្នុងសុទ្ធាវាសព្រហ្ម ។ សុទ្ធាវាសនោះ ព្រហ្មទាំងឡាយហៅលោកថា សហម្បតីព្រហ្ម ។ សហម្បតីព្រហ្មនោះគិតថា អញនឹងចូលទៅគាល់ព្រះមានព្រះភាគ ហើយទូលសួរដល់បទុមនរក បន្ទាប់អំពីនោះ ព្រះមានព្រះភាគនឹងត្រាស់ប្រាប់ដល់ភិក្ខុទាំងឡាយ ពេលនោះ ភិក្ខុទាំងឡាយដែលជាអ្នកឈ្លាសក្នុងលំដាប់រឿង នឹងទូលសួរកំណត់អាយុនៅក្នុងបទុមនរកនោះ ព្រះមានព្រះភាគ កាលត្រាស់ប្រាប់អាយុនោះ ទ្រង់នឹងប្រកាសទោសក្នុងការតិះដៀលព្រះអរិយៈ ដោយហេតុនេះ ទើបចូលទៅគាល់ព្រះមានព្រះភាគ ទូលរឿងនោះ ។ ព្រះមានព្រះភាគ ទ្រង់បានធ្វើយ៉ាងនោះ ។ សូម្បីភិក្ខុមួយរូបក៏បានទូលសួរ កាលភិក្ខុរូបនោះទូលសួរហើយ ទើបព្រះមានព្រះភាគ ត្រាស់ពាក្យជាដើមថា **សេយ្យថាបិ ភិក្ខុ** ដូច្នេះ ។

[ ៧៣ ] ក្នុងបទទាំងនោះ បទថា **វីសតិខារិកោ** គឺ ៤ នាឡិមគធៈ ជា ១ នាឡិក្នុងដែនកោសល ដោយនាឡិនោះ ៤ នាឡិ ទើបជា ១ អាឡ្ហកៈ

៤ អាឡ្ហកៈជា ១ ទោណ ៤ ទោណជា ១ មាណិកៈ ៤ មាណិកៈ ជា ១ ខារិ ជា ២០ ខារិដោយខារិនោះ ( ១ ខារិ = ១២៥៦ នាឡិ ) ។ បទថា **តិលវាហោ** បានដល់ រទេះផ្ទុកល្ង ។ បទថា **អព្វុទោ និរយោ** សេចក្តីថា មិនមាននរក ឈ្មោះថា អព្វុទនរក ដែលជាចំណែកចំពោះឡើយ តែស្ថាន ទីដែលឆេះក្នុងអវីចីនោះឯង ដែលរាប់ជាអព្វុទៈ ហៅថា អព្វុទនរក ។ ក្នុង និរព្វុទនរកជាដើម ក៏មានន័យនេះ ។ ក្នុងនិរព្វុទនរកនោះ គប្បីជ្រាបការរាប់ ឆ្នាំយ៉ាងនេះថា ១០០ សែនជា ១ កោដិ ១០០ សែនកោដិ ជា ១ បកោដិ ១០០ សែនបកោដិជា ១ កោដិបកោដិ ១០០ សែនកោដិបកោដិជា ១ នហុត ១០០ សែននហុតជា ១ និន្នហុត ១០០ សែននិន្នហុតជា ១ អព្វុទៈ យក ២០ គុណនឹងអព្វុទៈជា ១ និរព្វុទៈ ។ ក្នុងនរកទាំងពួង ក៏មានន័យនេះ ។

តែអាចារ្យពួកខ្លះពោលថា ក្នុងនរកនោះៗ បានឈ្មោះដោយការផ្សេង គ្នានៃការសោយទុក្ខខ្លះ ដោយការផ្សេងគ្នានៃកម្មករណៈខ្លះ ។ អាចារ្យមួយ ពួកទៀតពោលថា នរកទាំងនេះ ជាសីតនរក ។ បទថា **អថាបរំ** លោក ពោលសំដៅដល់គាថាពន្ធ សម្តែងសេចក្តីឲ្យវិសេសអំពីសេចក្តីនោះ ។

[ ៧៤ ] ក្នុង ២០ គាថា ១ គាថាថា **សតំ សហស្សានិ** ប្រែថា ១០០ ពាន់ គឺ ១ សែន សម្តែងសេចក្តីដូចពោលហើយ ក្នុងបាឋៈនោះឯង ។ គាថាដ៏សេស សម្តែងការផ្សេងគ្នា ។ តែ ២ គាថាចុងក្រោយ មិនមាន វិនិច្ឆ័យក្នុងមហាអដ្ឋកថា ដោយហេតុនោះ ទើបខ្ញុំពោលថាក្នុង ២០ គាថា ។

ក្នុងបទទាំងនោះ បទថា **កុឋារី** បានដល់ វាចាគ្រោតគ្រាត ដូចគ្នានឹង

ពូជៅ ព្រោះពុះរំខ្លួនឯង ។ បទថា **ឆិន្ទតិ** គឺកាត់កុសលមូលរបស់ខ្លួន ។ បទថា **និន្ទិយំ** បានដល់ គួរនិន្ទា ។ បទថា **តំ វា និន្ទតិ យោ បសំសិយោ** សេចក្តីថា បុគ្គលណាគួរសរសើរ ដោយអត្ថថា ជាបុគ្គលឧត្តម បែរជាលើកទោស តិះដៀលបុគ្គលនោះ ថាជាបុគ្គលលាមកជាដើម ។ បទថា **វិចិណាតិ** បានដល់ រមែងបន្តូវរឿង ។ បទថា **កលឹ** ប្រែថា ទោស ។ បទថា **អយំ កលិ** បានដល់ ទោសនេះ ។ បទថា **អក្ខេសុ** គឺលេងនូវការក្អាល់ ។ បទថា **សព្វស្សាបិ សហាបិ អត្តនា** គឺជាមួយនឹងទ្រព្យរបស់ខ្លួនទាំងអស់ខ្លះ ជាមួយនឹងខ្លួនឯងខ្លះ ។ បទថា **សុគតេសុ** បានដល់ ក្នុងព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវកដែលមានឈ្មោះថា បដិបត្តិល្អ ព្រោះទៅដោយល្អ និងព្រោះទៅកាន់ឋានៈល្អ ។ បទថា **មនំ បទូសយេ** អធិប្បាយថា ចិត្តរបស់បុគ្គលដែលប្រទូស្តក្នុងព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវកមានទោសច្រើនជាង សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបុគ្គលតាំងវាចា និងចិត្តលាមកហើយ ជាអ្នកតិះដៀលព្រះអរិយៈ រមែងចូលដល់នរកអស់កាលប្រមាណដោយការរាប់ឆ្នាំ ១៣៦០០០ និរព្វុទៈ និង ៥ អព្វុទៈ អធិប្បាយថា ព្រោះបុគ្គលតាំងវាចា និងចិត្តលាមក ជាអ្នកតិះដៀលព្រះអរិយៈ រមែងចូលដល់នរក គឺឆេះក្នុងនរកនោះ អស់កាលប្រមាណប៉ុណ្ណោះដោយការរាប់ឆ្នាំ ។ នេះជាប្រមាណអាយុក្នុងបទុមនរកដោយសង្ខេប ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ចង្អុលបង្ហាញសេចក្តីនេះឲ្យជាក់ច្បាស់ដោយន័យមួយថា បុគ្គលដែលញ៉ាំងចិត្តឲ្យប្រទូស្តក្នុងអ្នកបដិបត្តិល្អ

ទាំងឡាយ មានទោសច្រើនជាង ទើបត្រាស់ពាក្យជាដើមថា **អភូតវាទី** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អភូតវាទី** បានដល់ អ្នកពោលឡេះឡោះ ព្រោះពោលតិះដៀលព្រះអរិយៈ ។ បទថា **និរយំ** បានដល់ បទុមនរកជាដើម ។ បទថា **បេច្ច សមា ភវន្តិ** បានដល់ លះចាកលោកនេះទៅហើយ រមែងស្មើគ្នាក្នុងការចូលដល់នរក ។ បទថា **បរត្ថ** គឺក្នុងលោកដទៃ ។ ក្រៅលែងជាងនេះ មានអ្វីទៀត ក្នុងបទថា **យោ អប្បទុដ្ឋស្ស** នេះ គប្បីជ្រាបថា ឈ្មោះថា ជាអ្នកមិនប្រទូស្ត ព្រោះមិនមានទោស ឈ្មោះថា ជាអ្នកបរិសុទ្ធ ព្រោះមិនមានមន្ទិល គឺអវិជ្ជា ឈ្មោះថា ជាអ្នកមិនមានកិលេសជាគ្រឿងសាំញ៉ាំ ព្រោះមិនមានសេចក្តីប្រាថ្នាលាមក ។ ក្នុងបទនេះ គប្បីប្រកបយ៉ាងនេះថា ជាអ្នកបរិសុទ្ធ ព្រោះជាអ្នកមិនប្រទូស្ត និងជាអ្នកមិនមានកិលេសជាគ្រឿងសាំញ៉ាំ ព្រោះជាអ្នកបរិសុទ្ធ ។ ព្រះមានព្រះភាគ ទ្រង់ចង្អុលបង្ហាញដល់បុគ្គលដែលមានចិត្តប្រទូស្ត ក្នុងអ្នកបដិបត្តិល្អទាំងឡាយថា មានទោសច្រើនជាងយ៉ាងនេះហើយ ទើបត្រាស់គាថាទី ១៤ ឈ្មោះថា ជាវិតវត្ថុគាថា គឺគាថាដែលទ្រង់តាំងទុក ។

បានឮថា គាថាទាំងនោះ ព្រះមហាមោគ្គល្លានពោលទូន្មានកោកាលិកភិក្ខុដែលជិតស្លាប់នោះឯង ។ អាចារ្យពួកខ្លះពោលថា មហាព្រហ្មជាអ្នកពោលប្រៀនប្រដៅ ។ ដើម្បីសង្គ្រោះគាថានោះ ឲ្យដូចគ្នានឹងសូត្រនេះ ទើបលើកមាតិកានេះមក ផ្តើមអំពីគាថាថា **យោ លោភគុណេ អនុយុត្តោ**

ដូច្នេះ ។

ក្នុងគាថានោះ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាដើមជាដំបូងថា សេចក្តីលោភនោះឯង ឈ្មោះថា **លោភគុណោ** ព្រោះប្រើពាក្យថា **គុណោ** ឬព្រោះប្រព្រឹត្តទៅច្រើនដង ។ បទថា **លោភគុណោ** នេះ ជាឈ្មោះនៃតណ្ហា ។ បទថា **អវទញ្ញូ** គឺមិនដឹងវាចា ព្រោះមិនដាក់ចិត្តសូម្បីក្នុងឱវាទព្រះពុទ្ធទាំងឡាយ ។ បទថា **មច្ឆរិ** គឺដោយការកំណាញ់ ៥ យ៉ាង ។ ឈ្មោះថា **បេសុណិយស្មឹ អនុយុត្តោ** ព្រោះបំណងឲ្យអគ្គសាវកទាំង ២ បែកគ្នា ។ បទដ៏សេសប្រាកដច្បាស់ហើយ ។ បទនេះ លោកអធិប្បាយថា នែអាវុសោកោកាលិកៈ បុគ្គលណាដូចលោក ប្រកបរឿយៗ ក្នុងគុណ គឺសេចក្តីលោភ មិនមានសទ្ធា រឹងត្អឹង មិនដឹងបំណងរបស់អ្នកសូម កំណាញ់ ប្រកបរឿយៗ ក្នុងវាចាញុះញង់ បុគ្គលនោះ រមែងបរិភាសអ្នកដទៃ គឺបុគ្គលដែលមិនគួរពោលដល់ដោយវាចា ដោយហេតុនោះ ទើបព្រះតថាគតពោលគាថា ៣ ថា **មុខទុគ្គ** ដូច្នេះជាដើម ។ តទៅនេះ ជាពាក្យអធិប្បាយបទដែលលំបាកក្នុងគាថានោះ ។ បទថា **មុខទុគ្គ** នោះ គឺមានមាត់មិនរៀបរយ ពោលពាក្យគ្មានពិត គឺប្រាសចាកសេចក្តីពិត ពោលពាក្យឡេះឡោះ ជាបុគ្គលមិនប្រសើរ គឺអសប្បុរស ជាអ្នកបំផ្លាញនូវសេចក្តីចម្រើន គឺកម្ចាត់ភាពសម្បូរ ធ្វើនូវភាពសម្បូរឲ្យវិនាស ជាបុរសថោកទាប គឺជាបុគ្គលចុងក្រោយ ( អភព្វ ) ជាបុរសឥតបុណ្យ គឺជាបុគ្គលដែលមានគ្រោះកាច ជាអ្នកមានកំណើតថោកទាប គឺជាអវជាតបុត្ររបស់ព្រះពុទ្ធ ជាអ្នករោយចុះនូវធូលីលើខ្លួន គឺលោក

រោយធូលី គឺកិលេសដាក់ក្នុងខ្លួន ។ បទថា **បបតំ** បានដល់ មហានរក ។ បាឋៈថា **បបដំ** ដូច្នេះក៏មាន ឯសេចក្តីក៏ដូចគ្នា ។ បាឋៈថា **បបត្តំ** ដូច្នេះក៏មាន ។ បទថា **ហ** ក្នុងបទថា **ឃតិ ហ តំ** នេះ ត្រឹមតែជានិបាត ។ បទថា **តំ** បានដល់ កុសលកម្ម និងអកុសលកម្មនោះ ម្យ៉ាងទៀត បទថា **ហាតំ** បានដល់ ទៅហើយ គឺដល់ហើយ អធិប្បាយថា សន្សំហើយ ។ បទថា **សុវាមិ** គឺជាម្ចាស់របស់កម្មនោះ ព្រោះបានធ្វើ លោកអធិប្បាយថា រមែងបានទទួលនូវកម្មនោះពិតប្រាកដ កម្មនោះរបស់បុគ្គលនោះ មិនបាត់ទៅ ។ ព្រោះបុគ្គលនោះបានទទួលនូវកម្ម ព្រោះហេតុនោះ បុគ្គលល្ងង់ខ្លៅដែលធ្វើកម្មគ្រោតគ្រាត រមែងឃើញនូវទុក្ខចំពោះខ្លួនក្នុងលោកខាងមុខ ។ ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ប្រកាសដល់សេចក្តីទុក្ខ ដែលបុគ្គលល្ងង់ខ្លៅគប្បីជួប ទើបត្រាស់នូវពាក្យជាដើមថា អ្នកធ្វើអំពីអាក្រក់ តែងចូលទៅកាន់ចម្រូងដែកដ៏មុត ដូច្នេះ ។ ក្នុងបទនោះ គប្បីជ្រាបសេចក្តីក្នុងកន្លះគាថាដើមមុន ។ ព្រះមានព្រះភាគ ទ្រង់សំដៅដល់ឋានៈ ដែលនិរយបាលនាំមកនូវលំពែងដែកឯណា ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ធ្វើកម្មករណ៍ឈ្មោះបញ្ចពិធពន្ធន៍ ( ចំណង ៥ ប្រការ ) ចំពោះសត្វនរកនោះ ដូច្នេះ បុគ្គលធ្វើកម្មគ្រោតគ្រាត រមែងចូលដល់ឋានៈនោះ កាលចូលដល់និរយបាលឲ្យដេកលើផែនដីដែកក្តៅ លើលំពែងដែកនោះ ហើយចូលដល់លំពែងដែកដ៏មុត រឹងក្តៅ ត្រូវនិរយបាលវាយក្នុងទី ៥ អន្លើ ព្រះមានព្រះភាគ ទ្រង់សំដៅដល់លំពែងដែក ទើបត្រាស់ថា គឺផ្តេក ( សត្វនរកនោះ )

ហើយ បោះដែកគោលដ៏ក្តៅត្រង់ដៃ ដូច្នេះ ។

ព្រះមានព្រះភាគ ត្រាស់កន្ទះគាថាបន្តអំពីនោះ ទ្រង់សំដៅដល់ពាក្យដែលទ្រង់ត្រាស់ថា និរយបាលញាត់ដុំដែកក្តៅក្នុងមាត់របស់សត្វនរក ដែលឆេះក្នុងនរកនោះច្រើនពាន់ឆ្នាំ ហើយទៅកាន់ស្ទឹងទឹកក្រុតតាមលំដាប់ ដើម្បីសោយផលកម្មដ៏សេស ក្រៅអំពីការឆេះដោយភ្លើង និរយបាលបញ្ចូកទឹកទង់ដែង ដែលក្តៅក្នុងមាត់ ។

ក្នុងបទទាំងនោះ បទថា **អយោ** គឺដែក ។ បទថា **គុឡសន្និភំ** គឺមានសណ្ឋានដូចផ្លែត្នោត ។ ក្នុងបទថា **អយោ** នេះ គប្បីជ្រាបលោហៈទង់ដែងដោយ **អយ** សព្ទ ក្រៅអំពីនោះ គប្បីជ្រាបថាជាដុំដែក ។ បទថា **បដិរូបំ** គឺសមគួរដល់កម្មដែលបានធ្វើ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាដទៃអំពីនោះដូចតទៅនេះ បទថា **ន ហិ វគ្គុ** សេចក្តីថា និរយបាលពោលថា ចូរចាប់ ចូរប្រហារ ដូច្នេះជាដើម ឈ្មោះថាមិនពោលពាក្យពីរោះឡើយ ។ បទថា **នាភិជវន្តិ** គឺទោះបីធ្វើមុខរីករាយក៏មិនបាន និងធ្វើមុខញញឹមចូលទៅរក ក៏មិនបាន ។ លោកអធិប្បាយថា នឹងចូលទៅរក ព្រោះនាំសេចក្តីវិនាសឲ្យមកក៏មិនបាន[១] ។ បទថា **ន តាណាមុបេន្តិ** គឺនឹងចូលទៅសូមជ្រកកោណា ពួនសម្ងំ ជាទីអាស្រ័យក៏មិនបាន លោកអធិប្បាយថា នាយនិរយបាល ចូលទៅចាប់សម្លាប់តែម្យ៉ាង ។ បទថា **អង្គារេ សន្ថតេ សេន្តិ** គឺសត្វនរកត្រូវអូស ឡើងភ្នំរងើកភ្លើង ដេកលើ

១- ប្រែមកពីពាក្យបាលីថា អនព្យសនមាវហន្តា ឯវ ឧបសង្កមន្តីតិ ។

រងើកភ្លើង ដែលក្រាលរាប់ពាន់ឆ្នាំ ។ បទថា **អគ្គិនិសមំ បជ្ជលិតំ** គឺចូលទៅកាន់គំនរភ្លើងដែលឆេះដោយជុំវិញ និងរុងរឿងក្នុងទិសទាំងពួង ។ បទថា **បវិសន្តិ** គឺនិរយបាលចាប់ទម្លាក់ក្នុងមហានរក ។ មហានរកនោះ លោកពោលថា មាន ៤ ជ្រុង បុគ្គលដែលឈរ ( មើល ) ក្នុងទីចម្ងាយ ១០០ យោជន៍ ភ្នែករមែងបែកបាន ។ បទថា **ជាលេន ច ឱនហិយានា** គឺនិរយបាលយកសំណាញ់ដែកចង ហើយប្រហារដូចព្រានសម្លាប់ម្រឹគ ដូច្នោះ នេះជាកម្មករណ៍ដែលមិនបានពោលក្នុងទេវទូតសូត្រ ។ បទថា **អន្ធំវ តិមិសមាយន្តិ** សេចក្ដីថា សត្វនរកទាំងឡាយ រមែងទៅកាន់រោរុវនរកដែលងងឹត សេចក្ដីថា សត្វនរករមែងទៅកាន់រោរុវនរកដែលងងឹតស្លុប ដែលដឹងថា ងងឹត ព្រោះធ្វើសេចក្ដីងងឹត ដែលដឹងថា ងងឹតក្រាស់ ព្រោះងងឹតខ្លាំង បានឮថា ក្នុងរោរុវនរកនោះ ភ្នែកតាំងនៅមិនបាន គឺបែក ព្រោះត្រូវផ្សែង ។ ដោយហេតុនោះ ទើបលោកពោលថា **អន្ធំវ** ប្រែថា ដូចការងងឹត ។ បទថា **តំ វិតតំ យថា មហិកាយោ** សេចក្ដីថា ការងងឹតនោះ ផ្សាយទៅ ដូចដុំពពកកើតជារូបរាងប្រាកដមកទៀត សេចក្ដីនេះ ក៏ជាកម្ម ដែលលោកមិនបានពោលក្នុងទេវទូតសូត្រដូចគ្នា ។ បទថា **អថ លោហមយំ** សេចក្ដីថា លោហកុម្ភីនេះ នៅត្រង់ទីបំផុតផែនដី មានជម្រៅ ២ សែន ៤ ម៉ឺនយោជន៍ ពេញទៅដោយលោហៈ ក្ដៅពេញទំហឹង ។ បទថា **បច្ចន្តិ ហិ តាសុ ចិររត្តំ** បានដល់ ឆេះក្នុងឆ្នាំងដែកបែបនោះអស់កាលយូរ ។ បទថា **អគ្គិនិសមាសុ** គឺដែលភ្លើងឆេះសន្ធោសន្ធៅ ។ បទថា **សមុប្បិលវាសោ** បានដល់ អណ្ដែត

ទៅមក អធិប្បាយថា សត្វនរកឡើងទៅលើម្តង ចុះទៅខាងក្រោមម្តង ផុសឡើងហើយលិចចុះ ព្រោះកម្លាំងនៃទឹកដែលពុះ ។ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងទេវទូតសូត្រនោះឯង ។

បទថា **បុព្វលោហិតមិស្សេ** គឺប្រឡាក់ដោយខ្ទុះ និងឈាម ។ បទថា **តត្ថ កឹ** គឺក្នុងទិសនោះៗ ។ បទថា **យំ យទ្ធិសកំ** គឺទិស ។ បទថា **អធិសេតិ** គឺទៅ បាឋៈថា **អភិសេតិ** ដូច្នេះក៏មាន អធិប្បាយថា នៅអាស្រ័យក្នុងទិសដែលកំពុងជាប់ ។ បទថា **កិលិស្សតិ** គឺត្រូវបៀតបៀន ។ បាឋៈថា **កិលេជ្ជតិ** ដូច្នេះក៏មាន អធិប្បាយថា ស្អុយ ។ បទថា **សម្មុស្សមានោ** គឺខ្ទុះ និងឈាម ប្រឡាក់ប្រឡូស ។ សូម្បីសេចក្តីនេះ ក៏ជាកម្មករណ៍ដែលលោកមិនបានពោលក្នុងទេវទូតសូត្រ ។ បទថា **បុឡវាវសថេ** បានដល់ ជាលំនៅរបស់ពួកដង្កូវ ។ លោហកុម្ភីនេះ លោកពោលក្នុងទេវទូតសូត្រថា ជាគូថនរក សត្វដែលធ្លាក់ក្នុងគូថនរកនោះ សត្វមាត់ស្រួចនឹងបោះស្បែកជាដើម ហើយទំពាស៊ីខួរក្នុងឆ្អឹង ។ បទថា **គន្តុំ ន ហិ តីរមបត្ថិ** គឺក្នុងគូថនរកនោះ សូម្បីច្រាំងដែលនឹងទៅក៏មិនមានឡើយ ។ បាឋៈថា **តីរវមត្ថិ** ដូច្នេះក៏មាន ឯសេចក្តីដ៏ដូចគ្នា។ ត្រើយនោះឯង លោកពោលថា **តីរំ** ក្នុងបទនេះ ។ បទថា **សព្វសមា ហិ សមន្តកបល្លា** សេចក្តីថា ព្រោះលោហកុម្ភីនោះ សូម្បីមាត់ខ្ទះក៏បិទជិតក្នុងចំណែកខាងលើ ដូច្នោះ ទើបពោលថា មិនមានត្រើយដែលនឹងឆ្លងទៅ ។ ព្រៃមានស្លឹកជាដាវដ៏មុត មានន័យដូចពោលហើយ ក្នុងទេវទូតសូត្រនោះឯង ។

ព្រៃនោះ ប្រាកដអំពីចម្ងាយ ដូចព្រៃស្វាយគួរជាទីត្រេកអរ ។ កាលបើដូច្នោះ សត្វនរកទាំងឡាយ នាំគ្នាចូលទៅដោយសេចក្ដីលោភ ។ បន្ទាប់អំពីនោះ ស្លឹកនៃដើមឈើនោះ ត្រូវខ្យល់បក់ក៏ធ្លាក់ ហើយកាត់នូវអវយវៈតូចធំ ដោយហេតុនោះ ទើបលោកពោលថា **តំ បវិសន្តិ សមុច្ឆិន្នគត្តា** ដូច្នេះ ។ បទថា **ធង្កំ ពឡិសេន គហេត្វា អារចយារចយា វិហានន្តិ** សេចក្ដីថា ពួកនិរយបាលយកផ្ទៃសន្ទូចថ្កក់អណ្ដាតរបស់សត្វនរក ដែលជាអ្នកពោលកុហក រត់ទៅឲ្យដួលចុះក្នុងព្រៃ ដែលមានស្លឹកជាដាវ ហើយវាយប្រហារដូចពួកមនុស្សពន្លាត់ស្បែកដាក់លើផែនដី ហើយវាយដោយអន្ទ្រែដែក ដូច្នោះ និងនាំយកដីងពុះវះពន្លះជាចំណែកៗ ធូតសាច់ ធ្វើឲ្យលំបាក ទីដែលធូត ក៏តាំងនៅដូចដើមវិញ ។ បាឋៈថា **អារជយារជយា** ដូច្នេះក៏មាន សេចក្ដីថា ទាញចេញមក ថ្កក់ទាញមក ដូច្នេះ សូម្បីកម្មករណ៍នេះ ក៏លោកមិនបានពោលក្នុងទេវទូតសូត្រ ។

បទថា **វេត្តរណឹ** បានដល់ ស្ទឹង ដែលលោកពោលក្នុងទេវទូតសូត្រថា ជាស្ទឹងធំ បានឮថា ស្ទឹងនោះ ប្រាកដមានទឹកពេញដូចស្ទឹងគង្គា កាលបើដូច្នោះ សត្វនរកទាំងឡាយគិតថា អញនឹងងូត អញនឹងផឹក ទើបធ្លាក់ទៅក្នុងស្ទឹងនេះ ។ បទថា **តិណ្ហធារំ ខុរធារំ** អធិប្បាយថា សត្វនរកទាំង-ឡាយ រមែងធ្លាក់ទៅលើមុខកាំបិតកោរដ៏មុត ។ បានឮថា ត្រង់ច្រាំងទាំងសងខាង ទាំងខាងលើ និងខាងក្រោមនៃស្ទឹងនោះ ប្រាកដដូចមុខកាំបិតកោរដ៏មុត ដែលតម្រៀបគ្នា ។ ដោយហេតុនោះ ទើបលោកពោលថា ស្ទឹងនោះ

មានមុខកាំបិតកោរដ៏មុត អធិប្បាយថា សត្វនរកទាំងឡាយ រមែងចូលដល់ គឺជាប់នៅលើមុខកាំបិតកោរដ៏មុតនោះ ព្រោះស្រេកទឹក កាលសត្វនរកទាំង-ឡាយចូលដល់យ៉ាងនេះ ត្រូវបាបកម្មដាស់តឿនហើយ ជាបុគ្គលល្ងង់ គឺ បុគ្គលពាល រមែងធ្លាក់លើកាំបិតកោរនោះ ។ គប្បីប្រកបបទនេះថា **សាមា សពលា** ចូលជាមួយបទថា **សោណា** ខាងក្រោយ ។ លោកពោល អធិប្បាយថា ឆ្កែខ្មៅ និងឆ្កែពពាលដញ្ជែងខាំស៊ី ។ បទថា **កាកោលគណា** បានដល់ ហ្វូងក្អែកខ្មៅ ។ បទថា **បដិគិជ្ឈា** បានដល់ សត្វដែលកើត ស្រេកឃ្លានពេញកម្លាំង អាចារ្យពួកខ្លះពោលថា ស្ទាចត្មាត ។ បទថា **កុលលា** បានដល់ សត្វត្រដក់ អាចារ្យពួកខ្លះពោលថា បទថា **កុលលា** នេះ ជាឈ្មោះរបស់ខ្លែង ។ បទថា **វាយសា** បានដល់ សត្វក្អែកដែល មានពណ៌មិនខ្មៅ ។ ការដាក់ទោសនេះ ក៏មិនបានពោលក្នុងទេវទូតសូត្រនោះ តែមិនបានពោលក្នុងសូត្រនេះ ការដាក់ទោសនោះ គប្បីជ្រាបថា បានពោល ហើយ ព្រោះធ្លាស់លំដាប់គ្នា ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងការប្រព្រឹត្តទៅរបស់សត្វ នរកទាំងអស់នេះហើយ កាលទ្រង់ទូន្មាន ទើបត្រាស់គាថាថា **កិច្ឆា វតាយំ** ដូច្នេះជាដើម ។

បទនោះ មានសេចក្តីថា ជនអ្នកធ្វើកម្មគ្រោតគ្រាត រមែងឃើញការ ប្រព្រឹត្តទៅ ដែលមានកម្មករណ៍ផ្សេងៗ ក្នុងនរកនេះថា លំបាកហ្ន៎ ព្រោះ ដូច្នោះ កាលនៅមានជីវិតសេសសល់ក្នុងលោកនេះ គប្បីជាអ្នកធ្វើកិច្ចក្នុង

ជីវិតដ៏សេសនេះ ដោយការតាំងចិត្តធ្វើកុសលធម៌ មានការដល់នូវព្រះត្រៃសរណគមន៍ជាដើម កាលធ្វើកិច្ចក៏គប្បីធ្វើដោយការធ្វើសេចក្តីព្យាយាមជាប់តគ្នាទៅ មិនគប្បីប្រមាទ គឺមិនដល់នូវសេចក្តីប្រមាទត្រឹមតែមួយខណៈ ។ នេះជាពណ៌នាសរុបក្នុងសូត្រនេះ ។ បទទាំងឡាយដ៏សេសបានពោលហើយ និងមានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលហើយក្នុងកាលមុន និងព្រោះមានអត្ថងាយយល់ ដូច្នោះ ទើបមិនចាំបាច់ពណ៌នាតាមលំដាប់បទដោយប្រការដូច្នេះ ។ល។

**អដ្ឋកថាកោកាលិកសូត្រទី ១០ ចប់**

# សុត្តន្តបិដក

## នាឡកសូត្រទី ១១

[ ៧៥ ] អសិតឥសី សម្រាកនៅក្នុងទិវាវិហារ បានឃើញនូវពួកទេវតាជាន់តាវត្តិង្ស មានសេចក្តីសោមនស្ស រីករាយផង នូវសក្កទេវរាជជាធំជាងទេវតាផង នូវពួកទេវតាដែលស្លៀកសំពត់ស្អាតផង កាន់នូវសំពត់ហើយ សរសើរក្រៃពេក ។ លុះឃើញទេវតា ( ទាំងនោះ ) មានចិត្តរីករាយ មានចិត្តខ្ពស់ឡើង ក៏ធ្វើនូវសេចក្តីអើពើ សួរដូច្នេះថា ពួកទេវតាក្នុងជាន់តាវត្តិង្សនោះ មានសភាពរីករាយក្រៃពេក ព្រោះហេតុអ្វី អ្នកទាំងឡាយ កាន់សំពត់ត្រេកអរ ព្រោះអាស្រ័យហេតុអ្វី ។ ( អសិតឥសីដឹងថា ) ក្នុងវេលាណា មានសង្គ្រាមជាមួយពួកអសុរ ជ័យជម្នះមានដល់ពួកទេវតា ពួកអសុរចាញ់ក្នុងវេលានោះ ពួកទេវតាក៏មិនមានការព្រឺរោម ប្រាកដដូច្នោះឡើយ ពួកទេវតាត្រេកអររីករាយ ព្រោះឃើញនូវហេតុចម្លែកដូចម្តេច ។ ពួកទេវតាហួចផង ច្រៀងផង ប្រគំផង ទះដៃទាំងសងខាងផង រាំផងថា នែទេវតាទាំងឡាយ ជាបុគ្គលនិទ្ទុក្ខ ខ្ញុំសួរអ្នកទាំងឡាយ ដែលនៅលើកំពូលភ្នំមេរុ គឺជាន់តាវត្តិង្ស ( នេះ ) សូមអ្នកទាំងឡាយ បន្ទោបង់សេចក្តីសង្ស័យ របស់ខ្ញុំដោយឆាប់ ។ ( ពួកទេវតាតបថា ) ពោធិសត្វនោះ ដូចជាកែវដ៏ប្រសើរ ឥតមានអ្វីទីងផ្ទឹមបាន ទ្រង់កើតក្នុងព្រៃលុម្ពិនីវ័ន ក្នុង

ជនបទជាស្រុករបស់ពួកសក្យៈ ក្នុងមនុស្សលោក ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខ ព្រោះហេតុនោះ បានជាយើងខ្ញុំមានសេចក្ដីត្រេកអរ មានសភាពរីករាយក្រៃពេក ។ ពោធិសត្វនោះ ប្រសើរជាងសព្វសត្វ ( ទេវតា និងមនុស្ស ) ជាអគ្គបុគ្គល ជានរៈអង់អាច ឧត្ដមជាងពួកសត្វទាំងអស់ អាចញុំាងចក្កឲ្យប្រព្រឹត្តទៅ ក្នុងព្រៃឥសិបតនមិគទាយវ័ន ដូចសត្វសីហៈ ជាសត្វមានកម្លាំង គ្របសង្កត់នូវពួកម្រឹគ បន្លឺសីហនាទដែរ ។ អសិតឥសីនោះ លុះឮសំឡេងនោះហើយ ទើបចុះមកដោយរួសរាន់ ចូលសំដៅទៅកាន់ព្រះដំណាក់ របស់ព្រះបាទសុទ្ធោទនៈ ក្នុងកាលណោះ លុះអង្គុយនៅក្នុងព្រះដំណាក់ហើយ ក៏សួរពួកសក្យៈដូច្នេះថា ព្រះរាជកុមារនៅឯណា អាត្មាភាពត្រូវការចង់ឃើញ ។ គ្រានោះ ពួកសក្យៈបង្ហាញព្រះរាជកុមារជារាជឱរស មានសម្បុររុងរឿង ដូចមាសត្រង់មុខបាវ ដែលជាងមាសអ្នកឈ្លាសវៃ ឲ្យដីហើយថ្មីៗ មានសម្បុរសដ៏រុងរឿងដោយសិរី មានសម្បុរមិនឱនថយ ដល់អសិតឥសី ។ អសិតឥសី លុះឃើញព្រះរាជកុមារ មានសម្បុររុងរឿងដូចអណ្ដាតភ្លើង ដូចព្រះចន្ទ្រដ៏រុងរឿង ក្នុង កណ្ដាលហ្វូងផ្កាយឋិតនៅឰដ៏អាកាស បរិសុទ្ធដូចព្រះអាទិត្យផុតអំពីពពក រុងរឿងក្នុងសរទរដូវ មានសេចក្ដីរីករាយ បាននូវបីតិធំទូលាយ ។

ពួកទេវតាបាំងឆត្រស មានឆ្អឹងច្រើន មានមណ្ឌលមួយពាន់ ( សម្រេចអំពីមាសឆ្អិន ) នាកណ្តាលអាកាស ចាមរទាំង-ឡាយ មានដងជាវិការៈនៃមាស សំយុងចុះ ពួកទេវតាអ្នកកាន់ចាមរនិង ឆត្រ ក៏មិនប្រាកដឡើយ ។ ជដិលជាឥសី ឈ្មោះកណ្ហសិរី លុះឃើញព្រះរាជកុមារ មានរស្មីរុងរឿងដូចដុំមាស លើកម្រាលសំពត់បណ្ឌុកម្ពល ដែលពួកទេវតាបាំងស្វេតច្ឆត្រលើព្រះសិរ្សហើយ ក៏មានចិត្តអណ្តែតខ្ពស់ឡើង មានចិត្តរីករាយ ហើយទទួលយក ( ព្រះរាជកុមារនោះ ) ។ តាបសនោះជាអ្នកត្រិះរិះ រំពឹងនូវកាលជាអនាគត ជាអ្នកចេះចប់នូវមន្តសម្រាប់ស្គាល់នូវលក្ខណៈ លុះទទួលព្រះរាជកុមារដ៏ប្រសើររបស់ពួកសក្យៈហើយ មានចិត្តរីករាយ បញ្ចេញសំណើចថា ព្រះរាជកុមារនេះប្រសើរ ឧត្តមជាងពួកសត្វមានជើងពីរ គឺទេវតា និងមនុស្ស ។ លំដាប់នោះ កណ្ហសិរីរឭកឃើញដំណើររបស់ខ្លួន ក៏មានសភាពមិនរីករាយ ទើបយំស្រក់ទឹកភ្នែកវិញ ពួកសក្យៈឃើញហើយ ក៏សួរឥសីដែលកំពុងយំថា សេចក្តីអន្តរាយ នឹងមានដល់ព្រះរាជកុមារនៃយើងឬ ។ ឥសីលុះឃើញពួកសក្យៈមិនរីករាយហើយ ទើបពោលថា អាត្មាមិនបានរឭកនូវអំពើមិនមែនជាប្រយោជន៍ចំពោះព្រះរាជកុមារឡើយ មួយទៀត សេចក្តីអន្តរាយ នឹងមិនមាន

ដល់ព្រះរាជកុមារទេ ព្រះរាជកុមារនេះ មិនថោកថយឡើយ សូមអ្នកទាំងឡាយ មានចិត្តរីករាយចុះ ។ ព្រះរាជកុមារនេះ នឹងបានត្រាស់ដឹងនូវសម្ពោធិញ្ញាណដ៏ប្រសើរ ព្រះរាជកុមារនេះ ជាអ្នកឃើញនូវព្រះនិព្វាន ដ៏បរិសុទ្ធក្រៃលែង ព្រះរាជកុមារនេះ ជាអ្នកអនុគ្រោះនូវប្រយោជន៍ដល់ជនច្រើន នឹងញ៉ាំងព្រះធម្មចក្កឲ្យប្រព្រឹត្តទៅ ព្រហ្មចរិយៈ គឺសាសនារបស់ព្រះរាជ-កុមារនេះ នឹងសាយកាយទៅ ។ ឯអាយុរបស់អាត្មា មិនបានតាំងនៅយូរ ក្នុងមនុស្សនេះទេ កាលកិរិយារបស់អាត្មា នឹងមានក្នុងរវាង ( នេះ ) ឯង អាត្មានឹងមិនបានស្ដាប់ធម៌ របស់ព្រះរាជកុមារ អ្នកមានព្យាយាម មិនមានអ្នកណាស្មើឡើយ ព្រោះហេតុនោះ បានជាអាត្មាស្ដាយក្រោយ ព្រួយចិត្តកើតទុក្ខ ។ តាបសអ្នកមានព្រហ្មចរិយធម៌នោះ ញ៉ាំងបីតិដ៏ធំទូលាយ ឲ្យកើតឡើងដល់ពួកសក្យៈ ហើយក៏ចៀសចេញ អំពីបរមរាជវាំងទៅ តាបសនោះ មានសេចក្ដីអនុគ្រោះ ចំពោះក្មួយរបស់ខ្លួន ក៏បបួលឲ្យកាន់យកធម៌ របស់មហាបុរស អ្នកមានព្យាយាម មិនមានអ្នកណាស្មើថា បើអ្នកបានឮសំឡេងថា ពុទ្ធោ អំពីសម្នាក់បុគ្គលដទៃហើយ ( ត្រូវដឹងថា ) មហាបុរសដល់នូវការត្រាស់ដឹងហើយ បើកផ្លូវទៅកាន់ព្រះនិព្វានហើយ អ្នកគប្បីចូលទៅសាកសួរលទ្ធិ ក្នុងសម្នាក់នៃមហាបុរសនោះ ហើយ

ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះមានព្រះភាគនោះចុះ ។ នាឡកកុមារនោះ ជាបុគ្គលមានបុណ្យសន្សំទុកហើយ ដែលឥសីនោះ មានចិត្តប្រកបដោយប្រយោជន៍ មិនញាប់ញ័រឃើញថា ព្រះនិព្វានបរិសុទ្ធក្រៃលែង ក្នុងអនាគត ប្រៀនប្រដៅហើយ ក៏នៅរង់ចាំព្រះជិនស្រី រក្សាសោតិន្ទ្រិយ បួសដោយភេទនៃខ្លួនជាតាបស ។ នាឡកតាបស លុះឮសំឡេងគឹកកង ( ដែលទេវតាទាំងឡាយធ្វើហើយ ) ក្នុងកាលដែលព្រះជិនស្រីញុំាងចក្កដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ក៏ទៅ ( កាន់ទីនោះ ) លុះទៅដល់ហើយ ឃើញព្រះមានព្រះភាគដូចឥសី ក៏មានចិត្តជ្រះថ្លា បានសាកសួរនូវមោនេយ្យវត្ត គឺមគ្គញ្ញាណដ៏ប្រសើរនឹងព្រះពុទ្ធជាមុនីវិសេស តាមពាក្យប្រៀនប្រដៅ របស់អសិតឥសីទូន្មានហើយ ។

## វត្ថុកថា ចប់

[ ៧៦ ] នាឡកតាបសសួរថា បពិត្រព្រះគោតម នេះជាពាក្យពិតរបស់អសិតតាបស ដែលខ្ញុំព្រះអង្គដឹងហើយ ព្រោះហេតុនោះ ខ្ញុំព្រះអង្គសូមសួរព្រះអង្គ អ្នកដល់ត្រើយនៃធម៌ទាំងពួង កាលបើខ្ញុំព្រះអង្គសួរហើយ សូមព្រះអង្គសំដែងប្រាប់ នូវមោនេយ្យប្បដិបទា ជាវត្តដ៏ឧត្តមរបស់អ្នកប្រាជ្ញ ( ដើម្បីជាវត្ត ) របស់អ្នកបួសស្វែងរកភិក្ខាចារ ( ដល់ខ្ញុំព្រះអង្គ ) ។

( ព្រះមានព្រះភាគ ) ទ្រង់ត្រាស់ថា តថាគតនឹងបញ្ញត្ត មោនេយ្យប្បដិបទា ដែលជាវត្តធ្វើបានដោយកម្រ អត់ធន់បាន ដោយកម្រ ដល់អ្នក បើដូច្នោះ តថាគតនឹងសម្តែង មោនេ-យ្យប្បដិបទានោះដល់អ្នក អ្នកត្រូវផ្គងព្យាយាមឲ្យមាំមួនចុះ ។ បុគ្គលត្រូវធ្វើខ្លួនឲ្យមានភាពស្មើ ចំពោះបុគ្គលអ្នកជេរ និងអ្នក ថ្វាយបង្គំក្នុងស្រុក បុគ្គល ( បើគេជេរ ) ត្រូវរក្សាសេចក្តី ប្រទូស្តក្នុងចិត្ត ( បើគេថ្វាយបង្គំ ) ត្រូវស្ងប់ កុំប៉ោងតាម អារម្មណ៍ ។ អារម្មណ៍ខ្ពស់ និងទាបទាំងឡាយ ( អារម្មណ៍ល្អ និងអាក្រក់ ) តែងផ្សាយចេញមក ( កាន់វង់ចក្ខុជាដើម ) ឧបមាដូចអណ្តាតភ្លើងដែលឆេះក្នុងព្រៃ នារីទាំងឡាយ តែង ប្រលោមនូវអ្នកប្រាជ្ញ នារីទាំងឡាយនោះ កុំគប្បីប្រលោមអ្នក បានឡើយ ។ បុគ្គលវៀរហើយចាកមេថុនធម្ម លះកាមដែលល្អ និងអាក្រក់ទាំងឡាយ កុំទោមនស្ស កុំត្រេកអរ ចំពោះសត្វដែល តក់ស្លុត និងសត្វដែលមាំមួន ( មិនតក់ស្លុត ) ក្នុងសត្វទាំង-ឡាយ ។ គប្បីប្រៀបខ្លួនឯងថា អាត្មាអញយ៉ាងណា សត្វទាំង-ឡាយនុ៎ះ ក៏យ៉ាងនោះដែរ សត្វទាំងឡាយនុ៎ះយ៉ាងណា អាត្មាអញ ក៏យ៉ាងនោះដែរ ហើយមិនត្រូវសម្លាប់ មិនត្រូវប្រើគេឲ្យសម្លាប់ ឡើយ ។ បុថុជ្ជនជាប់ជំពាក់ក្នុងបច្ច័យណា បុរសអ្នកមាន បញ្ញាចក្ខុត្រូវតែលះចោលនូវសេចក្តីប្រាថ្នាផង នូវសេចក្តីលោភ

ផង ( ក្នុងបច្ច័យនោះ ) ហើយត្រូវប្រតិបត្តិ នូវមោនេយ្យ-
ប្បដិបទា ត្រូវតែប្រចាំងនូវតណ្ហាដែលបំពេញបានដោយកម្រនេះ ។
បុគ្គលគួរមានពោះធូរ មានអាហារកំណត់ មានប្រាថ្នាតិច មិន
លោភ បុគ្គលមិនឃ្លានដោយសេចក្តីប្រាថ្នាសព្វៗ កាល ជាអ្នក
មិនមានសេចក្តីប្រាថ្នា រមែងរលត់សេចក្តីក្តៅក្រហាយ ព្រោះ
កិលេស ( ដោយមិនមានសេចក្តីប្រាថ្នា ) ។ ភិក្ខុអ្នកប្រតិបត្តិ
មោនេយ្យប្បដិបទានោះ ប្រព្រឹត្តនូវបិណ្ឌបាតចារិកវត្តរួចហើយ
គប្បីប្រញាប់ចូលទៅកាន់ព្រៃ ហើយចូលបិតនៅក្រោមម្លប់ឈើ
រួចចូលទៅកាន់អាសនៈ ។ អ្នកប្រាជ្ញនោះ គួរខ្វល់ខ្វាយក្នុងឈាន
គួរត្រេកអរក្នុងព្រៃ គួរត្រេកអរនឹងខ្លួនឯង ហើយគប្បីចម្រើន
ឈាន ក្រោមម្លប់ឈើ ។ តអំពីនោះ លុះកន្លងរាត្រីទៅ គប្បី
ចូលទៅកាន់ស្រុក មិនគួរត្រេកអរនឹងការនិមន្តផង មិនគួរទទួល
នូវភោជនដែលគេនាំចេញអំពីស្រុកផង ។ មុនីចូលទៅកាន់ស្រុក
មិនគួរត្រាច់ទៅ ដោយការរួសរាន់ ក្នុងត្រកូលទាំងឡាយឡើយ
គួរជាអ្នកកាត់បង់នូវកថា ( ពាក្យពោល ) មិនគួរពោលពាក្យ
ផ្សេងៗស្វែងរកស៊ីឡើយ ។ មុនីនោះ ជាតាទិបុគ្គល ដោយហេតុ
ទាំងពីរប្រការ គឺអាត្មាអញបាននេះ ជាការប្រពៃ អាត្មាអញមិន
បាន ក៏ជាការល្អ ហើយក៏ចូលទៅកាន់ត្រកូល ដូចអ្នករកផ្លៃឈើ
ចូលទៅកាន់ដើមឈើ ។ មុនីមានបាត្រក្នុងដៃត្រាច់ទៅ មិនគ

សន្ទូតថាដូចគ មិនគួរពេបជ្រាយនឹងទាន ដែលមានប្រមាណតិច មិនគួរមើលងាយនូវបុគ្គលអ្នកឲ្យទាន ។ ឯបដិបទាដែលខ្ពស់ និងទាប សមណៈបានប្រកាសហើយ ធម្មតាព្រះអរិយបុគ្គល មិនដែលទៅកាន់ត្រើយខាងនាយ គឺព្រះនិព្វាន ដល់ពីរដងឡើយ ព្រះនិព្វាននេះ មិនគួរបានដោយគុណតែមួយទេ ។ ភិក្ខុណា មិនមានតណ្ហា សេចក្តីក្រហល់ក្រហាយ នឹងមិនមានដល់ភិក្ខុនោះ ជាអ្នកមានខ្សែកិលេសកាត់ហើយ អ្នកលះបោលនូវកិច្ចតូច និងកិច្ចធំហើយ ។

( ព្រះមានព្រះភាគ ) ទ្រង់ត្រាស់ថា តថាគតនឹងបញ្ញត្តនូវមោនេយ្យប្បដិបទាដល់អ្នក ភិក្ខុអ្នកប្រព្រឹត្តនូវមោនេយ្យប្បដិបទា គប្បីប្រៀបធៀបខ្លួន ដូចមុខកាំបិតកោរ គប្បីទល់ពិតានដោយអណ្តាត ហើយសង្រួមផ្ទៃ ( ដោយការមិនសេពបច្ច័យ ដែលកើតឡើងដោយផ្លូវសៅហ្មង ) ។ ភិក្ខុនោះ មិនមានចិត្តខ្ជិលផង កុំគិតច្រើនផង ជាអ្នកមិនមានកិលេសផង មិនអាស្រ័យតណ្ហាផង មានសាសនព្រហ្មចរិយៈ ជាខាងមុខផង គួរសិក្សាបម្រុងនឹងសេពនូវអាសនៈស្ងាត់ម្នាក់ឯងផង បម្រុងសេពអារម្មណ៍ ដែលសមណៈ គប្បីចូលទៅជិតផង អ្នកជាបុគ្គលម្នាក់ឯង ទាំងត្រេកអរនូវមោនេយ្យប្បដិបទា ជាចំណែកមួយ ដែលតថាគតសម្តែងហើយដោយពិត ។

( អ្នកនឹងល្បីឮខ្ទរខ្ទាយទៅក្នុងទិសទាំង ១០ ក្នុងកាលជាខាងក្រោយ ) អ្នកឮសំឡេងល្បី ( អំពីសម្នាក់ ) អ្នកប្រាជ្ញទាំងឡាយ ជាអ្នកមានឈាន លះបង់កាម គប្បីធ្វើដោយក្រៃលែង នូវហិរិផង នូវសទ្ធាផង ក្នុងកាលនោះ ទើបឈ្មោះថាជាសាវ័ករបស់តថាគត ។ អ្នកត្រូវដឹងបរិយាយនោះ ដោយសេចក្តីឧបមា ដោយទន្លេទាំងឡាយ ( ត្រូវដឹងបរិយាយផ្សេងទៀត ) ចំពោះបឹង និងស្ទឹងទាំងឡាយថា ស្ទឹងតូចទាំងឡាយ តែងធ្វើសំឡេងហូរទៅ ឯស្ទឹងធំតែងហូរទៅស្ងៀមៗ ។ ទឹកណាដែលកន្ទះ ទឹកនោះតែងឮសូរ ទឹកណាដែលពេញ ទឹកនោះតែងស្ងប់ ជនពាលមានឧបមាដូចទឹកកន្ទះក្អម ជនបណ្ឌិតមានឧបមាដូចអន្លង់ទឹកដ៏ពេញ ។ សមណៈគឺ ព្រះពុទ្ធ តែងសម្តែងនូវធម៌ ដែលប្រកបដោយប្រយោជន៍ដ៏ច្រើន សមណៈនោះជ្រាបប្រាកដ ទើបសម្តែងនូវធម៌ សមណៈនោះជ្រាបប្រាកដ ទើបសម្តែងដោយច្រើន ។ មួយទៀត មុនីណាជ្រាបប្រាកដនូវធម៌ មានចិត្តសង្រួមហើយ ជ្រាបប្រាកដនូវធម៌មិននិយាយច្រើន មុនីនោះ គួរដល់មោនេយ្យប្បដិបទា មុនីនោះបានដល់នូវអរហត្តមគ្គញាណ ។

**នាឡកសូត្រទី ១១ ចប់**

# អដ្ឋកថា

## នាឡកសូត្រ

[ ៧៥ ] ក្នុងនាឡកសូត្រទី ១១ មានពាក្យផ្តើមថា **អានន្ទជាតេ** ដូច្នេះ

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្តេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅនេះថា បានឮថា តាបសឈ្មោះនាឡកៈ ជាក្មួយរបស់អសិតឥសី ឃើញសាវករបស់ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ បដិបត្តិមោនេយ្យប្បដិបទា គឺបដិបត្តិដើម្បីភាពជាមុនី ទើបប្រាថ្នាយ៉ាងក្រៃលែង ដើម្បីមានសភាពយ៉ាងនោះ ចាប់តាំងពីនោះមក បានបំពេញបារមីមួយសែនកប្ប បានទូលសួរមោនេយ្យប្បដិបទាជាមួយនឹងព្រះមានព្រះភាគ ២ គាថាថា **អញ្ញាតមេតំ** ដូច្នេះ ក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃដែលព្រះមានព្រះភាគ ទ្រង់ញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅហើយ ។

ព្រះមានព្រះភាគ ទ្រង់ព្យាករមោនេយ្យប្បដិបទានោះដល់នាឡកតាបស ដោយន័យជាដើមថា **មោនេយ្យន្តេ ឧបញ្ញិស្សំ** ដូច្នេះ ។ ព្រះមានព្រះភាគកាលរម្ងត់ខន្ធបរិនិព្វានហើយ ព្រះអានន្ទដែលព្រះមហាកស្សបៈជ្រើសធ្លាយនាសួរមោនេយ្យប្បដិបទានោះ បំណងនឹងសម្តែងរឿងរ៉ាវទាំងអស់ថា នាឡកតាបសត្រូវអ្នកណាទូន្មាន និងទូន្មានក្នុងកាលណា ទើបទូលសួរព្រះមានព្រះភាគឲ្យប្រាកដ ទើបពោលវត្ថុគាថា ២០ មានពាក្យថា **អានន្ទជាតេ** ដូច្នេះជាដើម ។

លោកហៅរឿងទាំងអស់នោះថា នាឡកសូត្រ ។

ក្នុងបទទាំងនោះ បទថា **អានន្ទជាតេ** បានដល់ ជាអ្នកកើតនូវការសម្រេច គឺដល់នូវការចម្រើន ។ បទថា **បតីតេ** គឺត្រេកអរ ។ម្យ៉ាងទៀត បទថា **អានន្ទជាតេ** គឺសរសើរ ។ បទថា **បតីតេ** គឺមានសេចក្តីសោមនស្ស ។ បទថា **សុចិវសនេ** គឺក្នុងលំនៅដែលមិនសៅហ្មង ពិតហើយ លំនៅរបស់ទេវតាទាំងឡាយ កើតត្រង់ដើមកប្បព្រឹក្ស ទើបមិនប្រឡាក់ធូលីឬមន្ទិល ។ បទថា **ឧុស្សំ គហេត្វា** បានដល់ លើកសំពត់ទិព្វដែលបានឈ្មោះថា **ឧុស្សំ** ព្រោះដូចគ្នានឹងសំពត់ក្នុងលោកនេះ ។ បទថា **អសិតោ ឥសិ** គឺអសិតឥសី ដែលបានឈ្មោះយ៉ាងនេះ ព្រោះមានសម្បុរកាយខ្មៅ ។ បទថា **ទិវាវិហារេ** គឺក្នុងទីសម្រាកពេលថ្ងៃ ។ ពាក្យដ៏សេស ដោយបទងាយហើយ តែដោយការសម្ពន្ធគ្នា គប្បីជ្រាបដូច្នេះថា បានឮថា អសិតឥសីនោះ ជាបុរោហិតរបស់ព្រះបាទសីហហនុ បិតារបស់ព្រះបាទសុទ្ធោទនៈ បានជាអាចារ្យបង្រៀនសិប្បៈ តាំងអំពីព្រះបាទសុទ្ធោទនៈមិនទាន់បានអភិសេក លុះអភិសេកហើយ បានជាបុរោហិត កាលអសិតឥសីមកទទួលរាជការក្នុងវេលាល្ងាច និងក្នុងវេលាព្រឹក ព្រះរាជាទ្រង់មិនបានធ្វើសេចក្តីគោរព ដូចកាលនៅកំលោះ ទ្រង់ធ្វើត្រឹមតែលើកព្រះហស្តប្រណម្យប៉ុណ្ណោះ បានឮថា នេះជាធម្មតារបស់សក្យៈទាំងឡាយ ដែលបានអភិសេកហើយ ។ បុរោហិតនឿយណាយដោយការទទួលរាជការ ទើបក្រាបទូលថា បពិត្រមហារាជ ទូលបង្គំនឹងបព្វជ្ជា ។ ព្រះរាជាទ្រង់ជ្រាបការតាំងចិត្តពិតប្រាកដរបស់បុរោហិតនោះ ទើបសំណូមពរថា បើដូច្នោះ សូមលោកអាចារ្យនៅក្នុងឧទ្យានរបស់

ខ្ញុំចុះ ខ្ញុំនឹងទៅសួរសុខទុក្ខលោកអាចារ្យរឿយៗ ។ បុរោហិតទទួលព្រះតម្រាស់ ហើយបួសជាតាបស ព្រះរាជាទ្រង់ឧបត្ថម្ភក្នុងឧទ្យាននោះឯង តាបសធ្វើកសិណបរិកម្ម ញ៉ាំងសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតហើយ តាំងអំពីនោះមក អសិតតាបសនោះ ក៏ទៅឆាន់ក្នុងរាជត្រកូល ហើយទៅសម្រាកពេលថ្ងៃក្នុងព្រៃហិមពាន្ត ស្ថានសួគ៌ជាន់ចាតុម្មហារាជិកា និងនាគពិភពជាដើមណាមួយ ។

ថ្ងៃមួយ អសិតតាបសបានទៅកាន់ស្ថានសួគ៌ជាន់តាវត្តិង្ស ចូលទៅកាន់រតនវិមាន អង្គុយលើទិព្វរតនបល្ល័ង្ក សោយសមាធិសុខ ពេលល្ងាចទើបចេញពីសមាធិ ហើយទៅឈរលើវិមាន បានឃើញទេវតា មានសក្កទេវរាជជាប្រធានឈរលើកសំពត់ទិព្វ ត្រង់ផ្ចាំប្រមាណ ៦០ យោជន៍ ហើយពោលពាក្យសរសើរគុណនៃព្រះពោធិសត្វ ដោយហេតុនោះ ទើបព្រះអានន្ទពោលថា **អានន្ទជាតេ ។បេ។ ទិវាវិហារេ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឧទគ្គេ** គឺមានកាយខ្ពស់ឡើង ។ បទថា **ចិត្តីករិត្វា** បានដល់ ធ្វើសេចក្ដីគោរព ។ បទថា **កល្យរូបោ** គឺត្រេកអរច្រើន ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។

ឥឡូវនេះ គប្បីជ្រាបគាថាជាដើមថា **យធាបិ អាសិ** មានការភ្ជាប់អត្ថងាយយល់ហើយ ។ តែគប្បីជ្រាបអត្ថរបស់ពាក្យក្នុងគាថាដើមមុន ។ បទថា **សង្គាមោ** បានដល់ សង្គ្រាម ។ បទថា **ជយោ សុរានំ** គឺការឈ្នះមានដល់ពួកទេវតា ។ ដើម្បីការជាក់ច្បាស់នៃបទនោះ គប្បីជ្រាបកថាតាមលំដាប់ ដូច

តទៅនេះ

បានឮថា សក្កៈជាមាណព ឈ្មោះមាឃៈ ជាធំក្នុងមនុស្ស ៣៣ នាក់ ជាអ្នកស្រុកមចលគ្រាម ក្នុងដែនមគធៈ បំពេញវត្តបទ ៧ កើតក្នុងតាវត្តិង្ស-ពិភព មួយអន្លើដោយបរិស័ទ ។ លំដាប់នោះ ពួកទេវតាមុនៗ ពោលថា ពួកទេវបុត្រអាគន្តុកៈមកហើយ ពួកយើងនឹងស្វាគមន៍ពួកគេ ទើបនាំផ្កាឈូកទិព្វចូលទៅឲ្យ និងអញ្ជើញគ្រងរាជសម្បត្តិពាក់កណ្តាល ។ សក្កទេវរាជមិនត្រេកអរដោយរាជសម្បត្តិត្រឹមពាក់កណ្តាល ទើបប្រកាសឲ្យបរិស័ទរបស់ខ្លួនដឹង ថ្ងៃមួយ កាលទេវតាមុនៗ ស្រវឹង ទើបចាប់ជើងគ្រវែងទៅកាន់ជើងភ្នំសិនេរុ ។ ក្នុងទីខាងក្រោមនៃភ្នំសិនេរុរបស់ទេវតាទាំងនោះ ក៏កើតជាភពអសុរប្រមាណមួយម៉ឺនយោជន៍ លម្អដោយចិត្តបាដលី គឺដើមប្រទៀង គ្របដណ្តប់ដោយផ្កាដ៏ជាទិព្វ ។ តាំងអំពីនោះ ពួកបុព្វទេវតាទាំងឡាយនោះ កាលដឹងខ្លួន មិនឃើញតាវត្តិង្សភព ទើបពោលថា ឱ ! អាក្រក់ពិតហ្ន៎ ពួកយើងវិនាស ព្រោះទោសនៃសុរា ឥឡូវនេះ ពួកយើងកុំផឹកសុរាទៀត ពួកយើងនឹងផឹករបស់ដែលមិនមែនជាសុរា ឥឡូវនេះ ពួកយើងជាអសុរ ( អ្នកមិនផឹកស្រា ) តាំងអំពីនោះ ក៏កើតមានឈ្មោះឡើងថា **អសុរា អសុរា** ហើយគិតគ្នាថា ពួកយើងនឹងធ្វើសង្គ្រាមជាមួយទេវតាក្នុងឥឡូវនេះ ទើបនាំគ្នាបែរមុខទៅកាន់ភ្នំសិនេរុ លំដាប់នោះ សក្កទេវរាជក៏ចេញទៅច្បាំងជាមួយពួកអសុរ ចាប់ពួកអសុរបោះទៅក្នុងមហាសមុទ្រទៀត ធ្វើឥន្ទនិមិត្ត តម្កល់ក្នុងទ្វារទិសទាំង ៤ ។ បន្ទាប់អំពីនោះ ពួកអសុរគិតថា សក្កទេវរាជនេះ មិនប្រមាទ

ហ្ន៎ មកឈរយាមជានិច្ច ។ ហើយនាំគ្នាត្រឡប់ចូលនគរ លំដាប់នោះ ពួកទេវតាប្រកាសនូវជ័យជម្នះរបស់ខ្លួន លើកសំពត់ទិព្វឡើងត្រង់ថ្ងាជំ នាំគ្នាលេងនក្ខត្តឫក្ស ។

សម័យនោះ អសិតឥសី ព្រោះខ្លួនអាចរឭកជាតិក្នុងអតីត និងអនាគតបាន ៤០ កប្ប ក៏ពិចារណាថា ពួកទេវតាទាំងនេះធ្លាប់លេងនក្ខត្តឫក្សយ៉ាងនេះក្នុងកាលមុនឬហ្ន៎ ឃើញទេវតាឈ្នះសង្គ្រាម រវាងទេវតា និងអសុរទើបពោលថា ក្នុងវេលាណា មានសង្គ្រាមជាមួយពួកអសុរ ជ័យជម្នះមានដល់ពួកទេវតា ពួកអសុរចាញ់ ក្នុងវេលានោះ ពួកទេវតា ក៏មិនមានការព្រឺរោមប្រាកដដូច្នោះឡើយ ដូច្នេះ ។ បទថា **កិមព្ភុតំ ទដ្ឋុ មរូ បមោទិតា** សេចក្ដីថា ថ្ងៃនេះ ទេវតាទាំងឡាយបានឃើញហេតុអ្វី ដែលមិនធ្លាប់មានមកទើបនាំគ្នាត្រេកអរយ៉ាងនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ២ ដូចតទៅនេះ បទថា **សេឡេន្តិ** គឺទេវតាទាំងឡាយបន្លឺសំឡេងសរសើរ ។ បទថា **គាយន្តិ** គឺចម្រៀងជាច្រើន ។ បទថា **វាទយន្តិ** គឺប្រគំតន្ត្រី ៦ ម៉ឺន ៨ ពាន់ ប្រភេទ ។ បទថា **ផោដេន្តិ** គឺទះដៃ ។ បទថា **បុច្ឆាមិ វោហំ** គឺអសិតឥសីទោះអាចដឹងបានដោយខ្លួនឯង ក៏សួរព្រោះបំណងនឹងស្ដាប់ពាក្យរបស់ទេវតាទាំងនោះ ។ បទថា **មេរុ-មុទ្ធវាសិនេ** គឺនៅលើកំពូលភ្នំសិនេរុ ។ ពិតហើយ ក្នុងផ្ទៃខាងក្រោមនៃភ្នំសិនេរុ មានអសុរភព ទំហំប្រមាណមួយម៉ឺនយោជន៍ ។ ក្នុងផ្ទៃកណ្ដាលមានមហាទ្វីប ៤ មានទ្វីបតូច ២០០០ ជាបរិវារ ។ ក្នុងផ្ទៃខាងលើមាន

តាវត្តិង្សភព ទំហំមួយម៉ឺនយោជន៍ ដូច្នោះ ទើបលោកពោលថា នៅលើកំពូលភ្នំសិនេរុ ដូច្នេះ ។ អសិតឥសីហៅពួកទេវតាថា **មារិសា** ។ លោកអធិប្បាយថា ជាអ្នកមិនមានទុក្ខ និងមិនមានរោគ ។

បន្តទៅគប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៣ ដែលទេវតាទាំងឡាយប្រាប់នូវសេចក្តីនោះដល់អសិតឥសី បានពោលហើយ ។ បទថា **ពោធិសត្តោ** បានដល់ សត្វដែលនឹងត្រាស់ដឹង គឺសត្វដែលគួរសម្រេចសម្មាសម្ពោធិញ្ញាណ ។ បទថា **រតនវរោ** គឺជាអ្នកមានរតនៈដ៏ប្រសើរ ។ បទថា **តេនម្ហា តុដ្ឋា** គឺព្រោះហេតុនោះ ទើបពួកយើងត្រេកអរ ។ ព្រោះព្រះពោធិសត្វនោះ គ្រាសម្រេចភាពជាព្រះពុទ្ធហើយ នឹងសម្តែងធម៌ ដោយប្រការដែលពួកយើងនិងពួកទេវតាដ៏សេស នឹងសម្រេចសេក្ខភូមិ និងអសេក្ខភូមិបាន ឯមនុស្សទាំងឡាយណា បានស្តាប់ធម៌របស់ទ្រង់ហើយ មិនទាន់ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានបាន មនុស្សទាំងឡាយនោះនឹងធ្វើទានជាដើម ហើយទៅកើតក្នុងទេវលោកបាន នេះជាអធិប្បាយរបស់ពួកទេវតាទាំងនោះ ដោយប្រការដូច្នេះ ក្នុងបទទាំងនោះ បទថា **តុដ្ឋា កល្យរូបា** សេចក្តីថា ២ បទនេះ មិនផ្សេងគ្នាក៏ពិត តែគប្បីជ្រាបថា លោកពោលដើម្បីឆ្លើយបញ្ហាដែលថា ពួកទេវតាត្រេកអររីករាយព្រោះហេតុដូចម្តេច និងថា ព្រោះហេតុអ្វីអ្នកទាំងឡាយ កាន់សំពត់ត្រេកអរ ព្រោះអាស្រ័យហេតុអ្វី ដូច្នេះ ។

ឥឡូវនេះ គប្បីជ្រាបសេចក្តីក្នុងគាថាទី ៤ ដែលទេវតាទាំងឡាយប្រាប់បំណាងដែលធ្វើឲ្យត្រេកអរ កាលព្រះពោធិសត្វកើតឡើងហើយ ព្រះសង្គីតិ-

កាចារ្យសម្ដែងភាពដែលព្រះពោធិសត្វជាបុគ្គលប្រសើរក្នុងគតិ ៥ ដោយ ២ បទនេះ សម្ដែងដល់ការកាន់យកកំណើតជាទេវតា និងមនុស្ស ដោយ **សត្ត** សព្វ សម្ដែងការកាន់យកគតិដ៏សេស ដោយ **បជា** សព្វ ។ ពិតហើយ សត្វតិរច្ឆានទាំងឡាយ មានសីហៈជាដើម ប្រកបដោយគុណ មានការមិនតក់ស្លុតជាដើម ព្រះពោធិសត្វនេះឯង ធ្វើឲ្យសត្វទាំងនោះតក់ស្លុតបាន ព្រោះដូច្នោះ ទើបលោកពោលថា **បជានមុត្តមោ** ដូច្នេះ ។ ក្នុងបណ្ដាទេវតា និងមនុស្សទាំងឡាយ បុគ្គល ៤ ពួក មានអ្នកបដិបត្តិដើម្បីជាប្រយោជន៍ដល់ខ្លួនជាដើមនោះ អ្នកបដិបត្តិដើម្បីជាប្រយោជន៍ទាំង ២ ជាអគ្គបុគ្គល និងជាអ្នកអង់អាចជាងនរជន ព្រោះដូចគ្នានឹងគោឧសភក្នុងពួកជន ។ ដោយហេតុនោះ ទេវតាទាំងឡាយ កាលពោលសរសើរព្រះពោធិសត្វនោះ ទើបពោលបទទាំង ២ នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៥ ថា បទថា **តំ សទ្ទំ** សេចក្ដីថា អសិតឥសីបានស្ដាប់ពាក្យដែលទេវតាទាំងឡាយបានពោលហើយនោះ ។ បទថា **អវសរី** គឺចុះមក ។ បទថា **តទភវនំ** កាត់បទជា **តទា ភវនំ** បានដល់ចូលទៅកាន់ទីប្រថាប់របស់ព្រះបាទសុទ្ធោទនៈក្នុងខណៈនោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៦ ថា បទថា **តតោ** បានដល់ បន្ទាប់អំពីពាក្យរបស់អសិតឥសី ។ បទថា **ឧក្កាមុខេវ** គឺដូចគ្នានឹងមាសត្រង់មាត់បាវ អធិប្បាយថា ដូចមាសបរិសុទ្ធក្នុងមាត់បាវរបស់ជាងមាស ។ បទថា **សុកុសលសម្បហដ្ឋំ** បានដល់ ជាងមាសអ្នកឈ្លាសរម្ងាយល្អហើយ

អធិប្បាយថា ដេញមន្ទិលយ៉ាងល្អ ។ បទថា **ឧឡារុមានំ** គឺដែលរុងរឿង ។ បទថា **អសិតវ្ហយស្ស** គឺដល់ឥសីឈ្មោះអសិតៈ ។ ឥសីនេះមានឈ្មោះម្យ៉ាងទៀតថា កណ្ហទេវិលឥសី ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៧ ថា បទថា **តារាសភំ វ** គឺដូចផ្កាយអណ្តែតក្នុងពួកផ្កាយ អធិប្បាយថា ដូចព្រះចន្ទ ។ បទថា **វិសុទ្ធំ** គឺវៀរចាកឧបក្កិលេស មានពពកជាដើម ។ បទថា **សរទរិវ** គឺដូចព្រះអាទិត្យក្នុងសរទកាល ។ បទថា **អានន្ទជាតោ** គឺកើតបីតិ ដោយត្រឹមតែបានឮប៉ុណ្ណោះ ។ បទថា **អលត្ថ បីតឹ** គឺកាលឃើញហើយ ក៏បាននូវបីតិក្រៃលែង ។

បន្ទាប់អំពីនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៨ ដែលពួកទេវតាពោលដើម្បីសម្តែងសក្ការៈដែលពួកទេវតាចាត់ចែងឡើង ដើម្បីព្រះពោធិសត្វ ។ បទថា **អនេកសាខំ** គឺមានឆ្អឹងច្រើន ។ បទថា **សហស្សមណ្ឌលំ** គឺមានមណ្ឌល ១០០០ សម្រេចដោយមាសឆ្អិន ។ បទថា **ឆត្តំ** គឺស្វេតច្ឆត្រដែលជាទិព្វ ។ បទថា **វីតិបតន្តិ** គឺផ្ចិតដងមាសទាំងឡាយទោរទន់មក បក់ផាត់ព្រះសរីរៈ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៩ ថា បទថា **ជដី** បានដល់ ជដិល ។ បទថា **កណ្ហសិរិវ្ហយោ** ឥសីឈ្មោះថា កណ្ហសិរី គឺហៅឈ្មោះ ដោយ **កណ្ហ** សព្ទ និង **សិរិ** សព្ទ ។ លោកអធិប្បាយថា បានឮថា គេតែងហៅលោកថា សិរិកណ្ហក៏មាន ។ បទថា **បណ្ឌុកម្ពលេ** បានដល់ លើសំពត់កម្ពល

ក្រហម ។ រឿងក្នុងទីនេះ គួរពោលថា នូវព្រះរាជកុមារ ឬគួរធ្វើបាឋៈដ៏សេស ឬគួរបន្ថែមពាក្យចូលមក ។ ម្យ៉ាងទៀត ក្នុងគាថាដើម លោកពោលថា **ធិស្វា** សំដៅដល់ ព្រះរាជកុមារមិនបាននៅក្នុងហត្ថបាស ។ តែបទថា **ធិស្វា** នេះ សំដៅដល់នាំចូលដល់ហត្ថបាស ទើបលោកពោលថា **ធិស្វា** ដដែលទៀត ។ ម្យ៉ាងទៀត ការឃើញមុន បញ្ជាក់ការដែលឥសីបាននូវបីតិ ព្រោះបានពោលខាងចុងនៃគាថាថា **វិបុលមលត្ថ បីតឹ** ការឃើញលើកនេះ គឺក្នុងកាលដែលព្រះរាជកុមារ ព្រោះពោលក្នុងគាថាចុងក្រោយថា **សុមនោ បដិគ្គហោ** ដូច្នេះ ។ ម្យ៉ាងទៀត ការឃើញមុន ទាក់ទងនឹងព្រះកុមារប៉ុណ្ណោះ ការឃើញគ្រានេះ ទាក់ទងនឹងស្វេតច្ឆត្រ សេចក្តីថា បានឃើញព្រះកុមារដូចដុំមាស ដាក់លើសំពត់កម្ពលក្រហម ដែលកើតក្នុងដែនគន្ធារៈមានតម្លៃមួយសែន និងស្វេតច្ឆត្រដែលបាំងលើព្រះសិរ ដូចដែលបានពោលហើយ ក្នុងបទនេះថា **ឆត្តំ មរុ** ។ តែអាចារ្យពួកខ្លះពោលថា ឆត្រនេះលោកពោលសំដៅដល់ឆត្រដែលជារបស់មនុស្ស ។ សូម្បីពួកមនុស្សក៏កាន់យកឆត្រចាមរ ឆត្រកន្ទុយក្ងោក ផ្ចិតស្លឹកត្នោត និងផ្ចិតវាលវីជនី ចូលទៅរកមហាបុរស ដូចទេវតាបានដូចគ្នា ។ កាលបើដូច្នោះ ក៏មិនមានអ្វីដែលក្រៃលែងជាងពាក្យរបស់អសិតឥសីនោះ ព្រោះដូច្នោះ ពាក្យតាមដែលលោកពោលក៏ល្អហើយ ។ បទថា **បដិគ្គហោ** បានដល់ ឥសីយកដៃទាំង ២ ទទួល បានឮថា ស្តេចសក្យៈទាំងឡាយ នាំព្រះរាជកុមារចូលទៅដើម្បីឲ្យថ្វាយបង្គំឥសី កាលនោះ បាទាទាំងទ្វេរបស់ព្រះរាជកុមារ ក៏ត្រឡប់ទៅតាំង

នៅលើសីសៈរបស់ឥសី ។ ឥសីឃើញភាពអស្ចារ្យដូច្នោះ ក៏មានចិត្តត្រេកអរ ហើយទទួល ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១០ ថា បទថា **ឯតីសកោ** បានដល់ ប្រាថ្នា ពិចារណា ស្វែងរក ។ លោកអធិប្បាយថា ចូលទៅត្រួតត្រា ។ បទថា **លក្ខណមន្តបារគូ** គឺឥសីនោះ ដល់នូវត្រើយនៃលក្ខណៈ និងនៃវេទទាំងឡាយ ។ បទថា **អនុត្តរាយំ** គឺព្រះរាជកុមារនេះ មិនមានអ្នកដទៃប្រសើរជាង ។ បានឮថា អសិតឥសីនោះ ឃើញចក្រត្រង់ព្រះបាទរបស់ព្រះមហាសត្វនៅចំពោះមុខរបស់ខ្លួន ទើបពិនិត្យមើលព្រះលក្ខណៈដ៏សេសដោយទំនងនោះ កាលឃើញការសម្បូរនៃព្រះលក្ខណៈទាំងអស់ ក៏ដឹងថា ព្រះរាជកុមារនេះ នឹងបានជាព្រះពុទ្ធពិតប្រាកដ ទើបពោលយ៉ាងនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១១ ថា បទថា **អថត្តនោ គមនំ** បានដល់ ចូលដល់អរូប ដោយអំណាចបដិសន្ធិ ។ បទថា **អកល្យរូបោ គឡយតិ អស្សុកានិ** គឺអសិតឥសី រឭកដល់ការកើតក្នុងអរូបភពរបស់ខ្លួននោះ ទោមនស្សថា ឥឡូវនេះ អញមិនបានស្ដាប់ព្រះធម្មទេសនារបស់ព្រះរាជកុមារនេះ កើតទោមនស្ស ព្រោះការសោកមានកម្លាំង ទើបស្រក់ទឹកភ្នែក គឺហូរទឹកភ្នែក ។ បាឋៈថា **គវឥតិ** ដូច្នេះក៏មាន ។ បើអសិតឥសីបង្អោនចិត្តទៅក្នុងរូបភព ក៏នឹងមិនកើតការក្ដៅក្រហាយណាមួយ រហូតដល់យំយ៉ាងនេះ តែកើតក្ដៅក្រហាយព្រោះការមិនឈ្លាស និងមិនដឹងវិធី ។ បើមានពាក្យសួរថា បើដូច្នោះ អសិតឥសីនោះ មិនគួរកើតទោមនស្ស ព្រោះសង្កត់បាន

ដោយការបានសមាបត្តិមិនមែនឬ ។ ឆ្លើយថា ព្រោះសង្កត់មិនបាននោះឯង ។ ពិតហើយ កិលេសទាំងឡាយ ដែលកាត់ផ្តាច់ដោយមគ្គភាវនា នឹងកើតឡើងមិនបាន តែកិលេសទាំងឡាយ កើតឡើងបានព្រោះបច្ច័យ មានកម្លាំងនៃការបានសមាបត្តិ ។ បើមានពាក្យសួរថា កាលកិលេសកើតឡើង ព្រោះឈានសាបសូន្យ គាត់នឹងបានដល់អរូបភពបានអំពីណា ។ ឆ្លើយថា ព្រោះសម្រេចបានទៀតដោយការលំបាកបន្តិចបន្តួច ព្រោះបុគ្គលបានសមាបត្តិទាំងឡាយ កាលកិលេសកើតឡើង នឹងមិនដល់នូវការអស់កម្លាំងទៅនោះឯង លុះកាលកម្លាំងកិលេសស្ងប់ប៉ុណ្ណោះ រមែងសម្រេចគុណវិសេសនោះបានទៀត ដោយសេចក្តីលំបាកបន្តិចបន្តួចប៉ុណ្ណោះ ។ បុគ្គលសាបសូន្យគុណវិសេស ដឹងបានលំបាកថា បានដល់ បុគ្គលនេះ អសិតឥសី ក៏ដូច្នោះ ។ បទថា **នោ ចេ កុមារេ ភវិស្សតិ អន្តរាយោ** សេចក្តីថា អន្តរាយនឹងមិនមានក្នុងព្រះរាជកុមារនោះឬ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១២ ថា បទថា **ន ឱរកាយំ** គឺព្រះរាជ-កុមារនេះ ជាបុគ្គលមិនថោកថយ គឺមិនជាបុគ្គលតូចតាច ។ អសិតឥសីពោលដល់ពុទ្ធានុភាពដែលគួរពោលក្នុងគាថាតទៅ

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១៣ ថា បទថា **សម្ពោធិយគ្គំ** គឺសព្វញ្ញុ-តញ្ញាណ ។ ពិតហើយ សព្វញ្ញុតញ្ញាណនោះ ឈ្មោះថា **សម្ពោធិ** ព្រោះត្រាស់ដឹងដោយប្រពៃ ដោយការមិនវិបរិត ។ សព្វញ្ញុតញ្ញាណ លោកពោលថា ប្រសើរ ព្រោះឧត្តមជាងញាណទាំងពួង ព្រោះមិនមានគ្រឿងរារាំងក្នុង

ទីទាំងពួង ។ បទថា **ផុសិស្សតិ** បានដល់ នឹងសម្រេច ។ បទថា **បរម-វិសុទ្ធទស្សី** បានដល់ ឃើញព្រះនិព្វាន ។ ពិតហើយ ព្រះនិព្វាននោះ ឈ្មោះថា បរិសុទ្ធក្រៃលែង ព្រោះបរិសុទ្ធដោយចំណែកមួយ ។ បទថា **វិត្ថារិកស្ស** កាត់បទជា **វិត្ថារិកំ អស្ស** បានដល់ ព្រហ្មចរិយៈនឹងសាយកាយ ។ បទថា **ព្រហ្មចរិយំ** គឺពាក្យប្រៀនប្រដៅ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១៤ ដូច្នេះថា បទថា **អថន្តរា** គឺក្នុងចន្លោះនោះឯង ។ លោកអធិប្បាយថា ក្នុងរវាងដែលព្រះរាជកុមារនោះ ទ្រង់សម្រេចនូវសម្មោធិញ្ញាណនោះឯង ។ បទថា **ន សុស្សុំ** បានដល់ នឹងមិនបានស្តាប់ ។ បទថា **អសមធុរស្ស** គឺមានសេចក្តីព្យាយាមមិនមានបុគ្គលស្មើ ។ បទថា **អដ្ដោ** គឺជាអ្នកក្តៅក្រហាយស្តាយក្រោយ ។ បទថា **ព្យសនំ គតោ** គឺដល់នូវសេចក្តីវិនាសចាកសេចក្តីសុខ ។ បទថា **អឃាវី** គឺដល់នូវសេចក្តីទុក្ខ ។ អសិតឥសីពោលសំដៅដល់ការកើតទោមនស្សទាំងអស់ ។ ពិតហើយ គាត់ក្តៅក្រហាយ ព្រោះទោមនស្ស ។ ទោមនស្សនោះ ឈ្មោះថា ព្យសនៈ ព្រោះជាការវិនាសចាកសេចក្តីសុខរបស់អសិតឥសីនោះ ទើបលោកពោលថា ដោយវិនាសចាកសេចក្តីសុខ ។ ដោយបទនោះ ទើបអសិតឥសីនោះ ឈ្មោះថា **អឃាវី** ព្រោះមានទុក្ខផ្លូវចិត្ត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១៥ ថា បទថា **វិបុលំ ជនេត្វាន** គឺញុំាងបីតិដែលបរិបូណ៌ឲ្យកើត ។ម្យ៉ាងទៀត បាលីថា **ជនេត្វា** ដូច្នេះក៏មាន ។ បទថា **និគ្គមា** គឺអសិតឥសីចេញទៅហើយ ។

អសិតឥសីចៀសចេញអំពីបរមរាជវាំងទៅ តាបសនោះ មានសេចក្តីអនុគ្រោះចំពោះក្មួយរបស់ខ្លួន បានដល់ បុត្ររបស់ប្អូនស្រីខ្លួន ។ បទថា **សមាទបេសិ** សេចក្តីថា អសិតឥសីដឹងថា ខ្លួនមានអាយុតិច និងដឹងថា នាឡកមាណពបុត្ររបស់ប្អូនស្រីបានសន្សំបុណ្យ ដោយកម្លាំងបញ្ញារបស់ខ្លួន គិតថា នាឡកមាណព លុះមានបញ្ញាហើយ គប្បីប្រមាទ ទើបទៅកាន់ផ្ទះរបស់ប្អូនស្រីដើម្បីអនុគ្រោះនាឡកមាណពនោះ លុះទៅដល់ហើយ សួរថា នាឡកៈទៅឯណា ប្អូនស្រីឆ្លើយថា ទៅលេងខាងក្រៅ ប្រើមនុស្សឲ្យហៅមកហើយ ឲ្យបួសជាតាបសក្នុងខណៈនោះ ឲ្យសមាទាន ឲ្យឱវាទ ប្រៀនប្រដៅ ។ អសិតឥសីឲ្យសមាទាន ឲ្យឱវាទ ប្រៀនប្រដៅដូចម្តេច ។

អសិតឥសីពោលគាថាទី ១៦ ថា បើអ្នកឮសំឡេងថា **ពុទ្ធោ** អំពីសម្នាក់បុគ្គលដទៃហើយ ( ត្រូវដឹងថា ) មហាបុរសដល់នូវការត្រាស់ដឹងហើយ បើកផ្លូវទៅកាន់ព្រះនិព្វានហើយ អ្នកគប្បីចូលទៅសាកសួរលទ្ធិ ក្នុងសម្នាក់នៃមហាបុរសនោះ ហើយប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះមានព្រះភាគនោះចុះ ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **យទិ បរតោ** បានដល់ក្នុងកាលខាងមុខ ។ បទថា **ធម្មមគ្គំ** បានដល់ ធម៌ដែលជាផ្លូវនៃនិព្វាន គឺបរមត្ថធម៌ ឬផ្លូវ គឺនិព្វាន និងបដិបទា ។ បទថា **តស្មឹ** គឺក្នុងសម្នាក់របស់ព្រះអង្គនោះ ។ បទថា **ព្រហ្មចរិយំ** គឺសមណធម៌ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១៧ បទថា **តាទិនា** គឺតាំងមាំយ៉ាងនោះ អធិប្បាយថា ក្នុងសម័យនោះ កាលមានការសេង្កត់អាសវៈ គឺកិលេស ដោយ

ការសង្កត់កិលេស ( អសិតឥសី ) សង្កត់កិលេសបាន និងមានចិត្តតាំងមាំ ។ បទថា **អនាគតេ បរមវិសុទ្ធទស្សិនោ** សេចក្តីថា អសិតឥសីនោះពោលថា ឈ្មោះថា ជាអ្នកមានប្រក្រតីឃើញនិព្វានដ៏បរិសុទ្ធក្រៃលែងក្នុងអនាគត ដោយបរិយាយនេះ ព្រោះបុគ្គលនោះឃើញយ៉ាងនេះថា នាឡកៈនឹងឃើញព្រះនិព្វានបរិសុទ្ធយ៉ាងក្រៃលែង ក្នុងសម្នាក់របស់ព្រះមានព្រះភាគ ក្នុងអនាគត ។ អសិតឥសីនោះ ជាអ្នកមានប្រក្រតីឃើញនិព្វានដ៏បរិសុទ្ធយ៉ាងក្រៃលែង ក្នុងអនាគត ( ប្រៀនប្រដៅហើយ ) ។ បទថា **ឧបចិតបុញ្ញសញ្ចយោ** គឺសន្សំបុណ្យមកតាំងពីសាសនាព្រះបទុមុត្តរសម្មាសម្ពុទ្ធ ។ បទថា **បតិក្ខំ** បានដល់រង់ចាំ ។ បទថា **បរិវសិ** គឺបួសដោយភេទតាបស ។ បទថា **រក្ខិតិន្ទ្រិយោ** គឺរក្សាសោតិន្ទ្រិយ ។ បានឮថា ចាប់តាំងអំពីកាលនោះ នាឡកតាបសនោះ មិនងូតទឹក ដោយគិតថា សោតិន្ទ្រិយរបស់អញ គប្បីវិនាសព្រោះងូតទឹក កាលបើដូច្នោះ នឹងមិនបានស្តាប់ធម៌ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១៨ បទថា **សុត្វាន ឃោសំ** សេចក្តីថា នាឡកៈនោះរង់ចាំយ៉ាងនោះ កាលព្រះមានព្រះភាគទ្រង់សម្រេចសម្ពោធិញ្ញាណដោយលំដាប់ ហើយទ្រង់ប្រកាសធម្មចក្រក្នុងនគរពារាណសី បានស្តាប់សំឡេងប្រកាស ដែលព្រះជិនសីហៈទ្រង់ប្រកាសធម្មចក្រដ៏ប្រសើរ ដោយន័យជាដើមថា ព្រះមានព្រះភាគទ្រង់ប្រកាសធម្មចក្កហើយ ព្រះមានព្រះភាគអង្គនោះ ជាព្រះសម្មាសម្ពុទ្ធទ្រង់កើតហើយហ្ន៎ ដែលពួកទេវតាប្រាថ្នាប្រយោជន៍ដល់ខ្លួន នាំគ្នាមកប្រាប់ហើយ ។ បទថា **គន្ត្វាន ទិស្វា ឥសិនិ-**

**សកំ** សេចក្ដីថា កាលទេវតាធ្វើនូវកោលាហល ដោយមោនេយ្យប្បដិបទាអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ នាឡកៈបានទៅកាន់ព្រៃឥសិបតនៈហើយ ឃើញព្រះមានព្រះភាគជាឥសីអង់អាច គឺអង់អាច ជាឥសីដែលគង់លើបវរពុទ្ធាសនៈ ដោយបំណងនេះថា នាឡកៈនឹងមក តថាគតនឹងសម្ដែងធម៌ដល់នាឡកៈនោះ ។ បទថា **បសន្នោ** គឺមានចិត្តជ្រះថ្លា ដល់ព្រមដោយការឃើញប៉ុណ្ណោះ ។ បទថា **មោនេយ្យសេដ្ឋំ** គឺញាណ ដ៏ឧត្ដម ដែលបានដល់មគ្គញ្ញាណ ។ បទថា **សមាគតេ អសិតវ្ហយស្ស សាសនេ** គឺក្នុងកាលពាក្យប្រៀនប្រដៅរបស់អសិតឥសីមកដល់ ។ កាលណានាឡកតាបសប្រព្រឹត្តមគ្គធម៌ កាលនោះ ក៏ត្រូវអសិតឥសីទៅសួរ ហើយទូន្មានថា ចូរអ្នកប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់ព្រះមានព្រះភាគនោះចុះ ។ នេះឯង គឺកាលនោះ ។ ដោយហេតុនោះ ទើបលោកពោលថា តាមពាក្យប្រៀនប្រដៅរបស់អសិតឥសីទូន្មានហើយ ដូច្នេះ ។ បទដ៏សេស ក្នុងគាថានេះ ប្រាកដច្បាស់ហើយ គប្បីជ្រាបពណ៌នាវត្ថុកថានេះត្រឹមប៉ុណ្ណោះ ។

[ ៧៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុង ២ គាថា ដែលជាពាក្យសួរដូច្នេះថា បទថា **អញ្ញាតមេតំ** គឺខ្ញុំព្រះអង្គបានដឹងពាក្យនេះហើយ ។ បទថា **យថាតថំ** គឺមិនវិបរិត ។ សួរថា សេចក្ដីនេះអធិប្បាយដូចម្ដេច ឆ្លើយថា អធិប្បាយថា នាឡកតាបសពោលថា អសិតឥសីដឹងថា កុមារនេះ នឹងសម្រេចសម្ពោធិញ្ញាណ បានប្រាប់ខ្ញុំព្រះអង្គថា ក្នុងកាលខាងមុខ អ្នកបានឮសំឡេងល្បីថា **ពុទ្ធោ** ដូច្នេះសោត ព្រះមានព្រះភាគទ្រង់បានសម្រេច សម្ពោធិញ្ញាណហើយ

ទ្រង់បើកផ្លូវបរមត្ថធម៌ ថ្ងៃនេះ ខ្ញុំព្រះអង្គបានដឹងតាមពាក្យរបស់អសិតឥសីនោះថា ពាក្យនោះ ជាពាក្យពិត ព្រោះឃើញព្រះមានព្រះភាគជាបន្ទាល់ ។ បទថា **តំ តំ** គឺព្រោះដូច្នោះ ។ បទថា **សព្វធម្មានំ ចារគុំ** បានដល់ ជាអ្នកដល់នូវត្រើយនៃធម៌ដោយអាការ ៦ តាមន័យដែលបានពោលហើយ ក្នុងហេមវតសូត្រ ។ បទថា **អនាគារិយុបេតស្ស** កាត់បទជា **អនាគារិយំ ឧបេតស្ស** អធិប្បាយថា បព្វជិត ។ បទថា **ភិក្ខាចរិយំ ជិគីសតោ** គឺស្វែងរកកិក្ខាចារដែលមិនសៅហ្មង ដែលព្រះអរិយៈប្រព្រឹត្តបន្តគ្នាមកហើយ ។ បទថា **មោនេយ្យំ** បានដល់ ជារបស់មុនិ ។ បទថា **ឧត្តមំ បទំ** គឺបដិបទាដ៏ឧត្តម ។ បទដ៏សេស ក្នុងគាថានេះ ប្រាកដច្បាស់ហើយ ។

កាលនាឡកតាបសបានទូលសួរយ៉ាងនេះហើយ ទើបព្រះមានព្រះភាគទ្រង់ព្យាករមោនេយ្យប្បដិបទាដល់នាឡកតាបសនោះ ដោយន័យជាដើមថា **មោនេយ្យំ តេ ឧបញ្ញិស្សំ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឧបញ្ញិស្សំ** គឺតថាគតគប្បីបញ្ញត្ត អធិប្បាយថា គប្បីណែនាំ គប្បីឲ្យដឹងទូទៅ ។ បទថា **ទុក្ករំ ទុរភិសម្ភវំ** លោកអធិប្បាយថា លំបាកធ្វើបាន លំបាកធ្វើឲ្យកើតបាន ។ ពាក្យនេះ មានអធិប្បាយដូចតទៅនេះ តថាគតគប្បីបញ្ញត្តបដិបទារបស់មុនីដល់អ្នក បើបដិបទាគប្បីធ្វើ ឬគប្បីឲ្យកើតបានងាយ នូវបដិបទារបស់មុនីនោះ ឈ្មោះថាធ្វើបានលំបាក ឲ្យកើតបានលំបាកយ៉ាងនេះ ព្រោះគួរបដិបត្តិមិនឲ្យចិត្តសៅហ្មង កើតឡើងតាំងអំពីកាលជាបុថុជ្ជន ។ ជាសេចក្តីពិត ដូច្នោះ សាវក

មួយរូបប៉ុណ្ណោះរបស់ព្រះពុទ្ធមួយអង្គ រមែងធ្វើបាន និងធ្វើឲ្យកើតបាន ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់ភាពដែលបដិបទារបស់មុនីធ្វើបានលំបាក និងធ្វើឲ្យកើតបានលំបាក មានបំណងនឹងឲ្យនាឡកតាបសកើតឧស្សាហ៍ ទើបត្រាស់មោនេយ្យប្បដិបទាដល់នាឡកៈថា តថាគតនឹងសម្តែងមោនេយ្យប្បដិបទាដល់អ្នក អ្នកត្រូវផ្គងព្យាយាមឲ្យមាំមួនចុះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ហន្ទ** ជានិបាត ចុះក្នុងអត្ថប្រាប់នូវការជាស់តឿន ។ បទថា **តេ ឆំ បវក្ខាមិ** បានដល់ តថាគតនឹងប្រាប់បដិបទារបស់មុនីនោះដល់អ្នក ។ បទថា **សន្ថម្ភស្សុ** គឺចូរអ្នកជួយស្រោចស្រង់ខ្លួនឯងដោយការធ្វើឲ្យកើតព្យាយាម អាចធ្វើវត្ថុដែលបុគ្គលធ្វើបានលំបាក ។ បទថា **ទឡ្ហោ ភវ** គឺចូរជាអ្នកមាំទាំ ព្រោះមានសេចក្តីព្យាយាមមិនធូរថយ អាចអត់ធន់ចំពោះការធ្វើឲ្យកើតបានលំបាក លោកអធិប្បាយដូចម្តេច លោកអធិប្បាយថា ព្រោះអ្នកបានសន្សំបុណ្យច្រើន ព្រោះហេតុនោះ តថាគតជាអ្នកជំនាញដោយចំណែកមួយ និងប្រាប់នូវបដិបទារបស់មុនីនោះ ដែលបុគ្គលធ្វើបានលំបាក ធ្វើឲ្យកើតបានដោយក្រដល់អ្នក ចូរអ្នកជាបុគ្គលជួយស្រោចស្រង់ខ្លួន ចូរជាអ្នកមាំទាំចុះ ។

ព្រះមានព្រះភាគ មានបំណងនឹងត្រាស់បដិបទារបស់មុនី ដែលជាគ្រឿងដុសខាត់ក្រៃលែងយ៉ាងនេះ ទើបទ្រង់ដឹកនាំនាឡកតាបសក្នុងការជួយខ្លួន និងក្នុងភាពជាអ្នកមាំទាំ កាលទ្រង់សម្តែងនូវការលះកិលេសដែលចូលទៅពាក់ព័ន្ធជាមួយអ្នកស្រុក ទើបត្រាស់កន្លះគាថាថា **សមានភាគំ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សមានភាគំ** និងបទថា **សមភាគំ** បានដល់ តែមួយដូចគ្នា មិនផ្សេងគ្នា ។ បទថា **អក្កុដ្ឋវន្ទិតំ** បានដល់ ការជេរ និងការថ្វាយបង្គំ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងឧបាយដែលនឹងធ្វើការជេរ និងការថ្វាយបង្គំនោះឲ្យស្មើគ្នា ទើបត្រាស់កន្លះគាថាថា **មនោបទោសំ** ដូច្នេះជាដើម ។

បទថា **មនោបទោសំ** នោះ មានអធិប្បាយថា បុគ្គលនោះជេរហើយ គប្បីរក្សានូវការប្រទូស្តនៃចិត្ត អ្នកដទៃថ្វាយបង្គំហើយ គប្បីប្រព្រឹត្តជាអ្នកស្ងប់ គឺសូម្បីព្រះរាជា ទ្រង់នមស្កា ក៏មិនមានការតម្កើងខ្លួនថា ព្រះរាជាថ្វាយបង្គំអញ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងការលះកិលេស ដែលពាក់ព័ន្ធក្នុងព្រៃ ទើបត្រាស់ថា **ឧច្ចាវចា** ដូច្នេះជាដើម ។

បទថា **ឧច្ចាវចា** នេះ មានអធិប្បាយថា អារម្មណ៍ដែលខ្ពស់ទាបច្រើនយ៉ាង គឺឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ សូម្បីក្នុងព្រៃ រមែងផ្សាយទៅ គឺស៊ុះទៅ រមែងមកកាន់គន្លងនៃចក្ខុជាដើម អារម្មណ៍ទាំងនោះដែលខ្ពស់ទាប ព្រោះមានច្រើនយ៉ាង ប្រៀបដូចអណ្តាតភ្លើង ព្រោះធ្វើឲ្យកើតអន្តរាយ ដូចអណ្តាតភ្លើងក្នុងព្រៃ ដែលត្រូវភ្លើងឆេះ មានផ្សែងខ្លះ មិនមានផ្សែងខ្លះ ខៀវខ្លះ លឿងខ្លះ ក្រហមខ្លះ តិចខ្លះ ច្រើនខ្លះ យ៉ាងណា អារម្មណ៍ទាំងឡាយក្នុងព្រៃ ទាំងខ្ពស់ ទាំងទាប ព្រោះមានច្រើនយ៉ាង ដូចរាជសីហ៍ ខ្លាធំ មនុស្ស អមនុស្ស

សំឡេងរងាវរបស់បក្សីផ្សេងៗ ផ្កាផ្លែឈើ ស្លឹកឈើខ្ចីជាដើមរមែងផ្សាយទៅ គួរខ្លាចខ្លះ មិនគួរខ្លាចខ្លះ គួរត្រេកអរខ្លះ គួរបង់បានខ្លះ គួរអាក់អន់ខ្លះ គួររង្វេងខ្លះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ឧច្ចាវចា និច្ឆរន្តិ ទាយេ អគ្គិសិខូបមា** ដូច្នេះ ។ បណ្ដាអារម្មណ៍ ទាំងឡាយទាំងខ្ពស់ទាបផ្សាយទៅយ៉ាងនេះ អារម្មណ៍ណាមួយ ដែលត្រាច់ទៅក្នុងឧទ្យាន និងព្រៃ ឬនារីទាំងឡាយ មានស្រីទូលឧសជាដើម ត្រាច់ទៅក្នុងព្រៃជាប្រក្រតី ឃើញមុនីនៅក្នុងទីស្ងាត់ហើយ លួងលោមមុនីដោយម្រិកម្រ៉ក់ ចរចា យំរំសាយសំពត់ជាដើម ។ បទថា **តា សុ តំ មា បលោភយុំ** សេចក្ដីថា នារីទាំងនោះកុំបី លួងលោមអ្នក អធិប្បាយថា ចូរអ្នកធ្វើអាការដែលនារីទាំងនោះលួងលោមមិនបាន ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងវិធីបដិបត្តិក្នុងព្រៃ និងក្នុងស្រុកដល់នាឡកតាបសយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងការសង្រួមក្នុងសីលជាដើម ទើបត្រាស់ ២ គាថាថា **វិរតោ មេថុនា ធម្មា** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ហិត្វា កាមេ វរាវរេ** សេចក្ដីថា មុនីលះកាមគុណ ៥ ទាំងល្អ ទាំងមិនល្អ ដែលសល់អំពីមេថុនធម្មទៀតផង ។ ដោយការលះមេថុនធម្មនោះ កាលវៀរចាកមេថុន ឈ្មោះថា បរិបូណ៌ដោយល្អហើយ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ហិត្វា កាមេ វរាវរេ** ដូច្នេះ នេះជាអធិប្បាយក្នុងសេចក្ដីនេះ ។ បទទាំងឡាយ មានបទថា **អវិរុទ្ធោ** ជាដើម ព្រះមានព្រះភាគ ត្រាស់ដើម្បីសម្ដែងដល់ការវៀរចាកនូវ

ការសម្លាប់សត្វ ដូចត្រាស់ ក្នុងគាថានេះថា **ន ហនេយ្យ ន ឃាតយេ** មិនត្រូវសម្លាប់ មិនត្រូវប្រើគេឲ្យសម្លាប់ឡើយ ដូច្នេះ ។ ក្នុងគាថានោះ មានពណ៌នាដោយសង្ខេបដូចតទៅនេះថា បុគ្គលមិនអាក់អន់ក្នុងសត្វទាំងឡាយដែលជាចំណែកដទៃ មិនត្រេកអរក្នុងសត្វទាំងឡាយដែលជាចំណែករបស់ខ្លួន គឺមិនត្រេកអរ មិនប្រទូស្តក្នុងសត្វទាំងពួង ទាំងដែលតក់ស្លុត ព្រោះនៅមានតណ្ហា និងនឹងនួន ព្រោះមិនមានតណ្ហា កម្ចាត់នូវការប្រទូស្តក្នុងសត្វទាំងនោះចេញ ដោយប្រៀបជាមួយខ្លួនថា អាត្មាអញយ៉ាងណា សត្វទាំងឡាយនេះក៏ដូច្នោះ ព្រោះចង់មានជីវិត ព្រោះមិនចង់ស្លាប់ ព្រោះស្រឡាញ់សេចក្តីសុខ និងព្រោះស្អប់ខ្ពើមទុក្ខ និងកម្ចាត់នូវការត្រេកអរក្នុងខ្លួន ដោយប្រៀបខ្លួននឹងអ្នកដទៃថា សត្វទាំងនេះយ៉ាងណា អាត្មាអញក៏ដូច្នោះដោយទំនងនោះឯង ឈ្មោះថា ជាអ្នកលះនូវការត្រេកអរ និងអាក់អន់បានទាំង ២ យ៉ាង ធ្វើខ្លួនឲ្យជាឧបមា ព្រោះខ្ពើមនូវសេចក្តីស្លាប់ មិនគប្បីបៀតបៀនបណ្តាសត្វមានជីវិតទាំងឡាយ សត្វពួកណានីមួយ ដែលជាអ្នកតក់ស្លុតក្តី ជាអ្នកនឹងនួនក្តី មិនគប្បីសម្លាប់ឯង ដោយសាហត្ថិកប្បយោគជាដើម មិនគប្បីឲ្យអ្នកដទៃសម្លាប់ដោយអាណត្តិកប្បយោគជាដើម ។

ព្រះមានព្រះភាគត្រាស់បាតិមោក្ខសំវរសីល ដោយសង្ខេប ដោយមាតិកា គឺវៀរចាកមេថុន និងវៀរចាកការសម្លាប់សត្វដល់នាឡកតាបស និងទ្រង់សម្តែងនូវការសង្រួមឥន្ទ្រិយ ដោយបទថា **ហិត្វា កាមេ** ជាដើម ដូច្នេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងអាជីវបារិសុទ្ធិសីល ទើបត្រាស់គាថាថា បុថុជ្ជន

ជាប់ចំពាក់ក្នុងបច្ច័យណា បុរសអ្នកមានបញ្ញាចក្ខុ ត្រូវតែលះបោលនូវសេចក្ដីប្រាថ្នាផង នូវសេចក្ដីលោភផង ( ក្នុងបច្ច័យនោះ ) ហើយប្រតិបត្តិនូវមោនេយ្យប្បដិបទា ត្រូវតែប្រឆាំងនូវតណ្ហាដែលបំពេញបានដោយកម្រនេះ ។

បទនោះ មានអធិប្បាយដូច្នេះថា តណ្ហា លោកពោលថា **ឥច្ឆា** ព្រោះប្រាថ្នាហួសវិស័យដែលនឹងបានយ៉ាងនេះ គឺបានមួយហើយប្រាថ្នា ២ បាន ២ ហើយប្រាថ្នា ៣ បានមួយសែនហើយប្រាថ្នាក្រៃលែងជាងនោះ លោកពោលថា លោភៈ ព្រោះលោភក្នុងវិស័យដែលអាចបាន ។ មុនីលះសេចក្ដីប្រាថ្នានិងសេចក្ដីលោភក្នុងបច្ច័យ មានចីវរជាដើម ដែលបុថុជ្ជនជាប់ជំពាក់ហើយ គឺលះទាំង ២ យ៉ាងនោះ ក្នុងបច្ច័យដែលបុថុជ្ជនជាប់ជំពាក់ហើយ ជាប់ហើយពាក់ព័ន្ធហើយដោយការប្រាថ្នា និងសេចក្ដីលោភ មិនធ្វើអាជីវបារិសុទ្ធិឲ្យវិនាសដើម្បីបច្ច័យ ជាអ្នកមានចក្ខុ ញាណចក្ខុ គប្បីបដិបត្តិមោនេយ្យប្បដិបទានេះ លោកអធិប្បាយថា បុគ្គលកាលបដិបត្តិបានយ៉ាងនេះហើយ គប្បីឆ្លងនរកនេះចេញ គឺគប្បីឆ្លងនូវការចង់បានក្នុងបច្ច័យដែលជាហេតុនៃមិច្ឆាជីវៈ ដែលសន្មតថា នរក ព្រោះបំពេញបានដោយក្រនេះចេញ ឬគប្បីឆ្លងដោយបដិបទានេះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងសេចក្ដីបរិសុទ្ធនៃអាជីវៈ ដោយមាតិកា គឺលះនូវការចង់បានក្នុងបច្ច័យយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងសីល គឺការបរិភោគបច្ច័យដោយមាតិកាភោជនេមត្តញ្ញុតា គឺការស្គាល់

ប្រមាណក្នុងការបរិភោគ និងបដិបទាដ៏ជាបដល់ការសម្រេចអរហត្ត ដោយ
ទំនងនោះ ទើបត្រាស់គាថាថា

បុគ្គលគួរមានពោះធូរ មានអាហារកំណត់ មានប្រាថ្នាតិច មិន
ល្មោភ បុគ្គលមិនឃ្លានដោយសេចក្តីប្រាថ្នាសព្វៗ កាល ជាអ្នកមិន
មានសេចក្តីប្រាថ្នា រមែងរលត់សេចក្តីក្តៅក្រហាយ ព្រោះកិលេស
( ដោយមិនមានសេចក្តីប្រាថ្នា ) ។

បទនោះ មានសេចក្តីដូច្នេះ លោកអធិប្បាយថា ភិក្ខុកាលបានបច្ច័យ
មានចីវរជាដើម តាមមាន តាមបាន ដោយធម៌ជានិច្ចហើយ កាលទឹងធាន់
អាហារ គប្បីកុំឃើញដល់តែផ្ទៃ ដោយន័យដែលលោកពោលថា

**ចត្តារោ បញ្ច អាលោបេ អភុត្វា ឧទកំ បិវេ**
**អលំ ផាសុវិហារាយ បហិតត្តស្ស ភិក្ខុនោ។**

ភិក្ខុឈប់បរិភោគ ៤ ឬ ៥ ពំនូត ( ក្នុងកាលជិតឆ្អែត ) ហើយ
គប្បីផឹកទឹក នេះជាការល្មមដល់កិរិយានៅជាសុខនៃភិក្ខុ អ្នក
មានចិត្តស្ងួនទៅរក ( ព្រះនិព្វាន ) ។

មិនគួរមានពោះតឹង ដូចស្នប់ពេញដោយខ្យល់ គប្បីរាំងនូវបីនមិទ្ធៈ
ព្រោះស្រវឹងក្នុងអាហារជាហេតុ ភិក្ខុគប្បីជាអ្នកកំណត់អាហារដោយគុណ និង
ទោស ដោយការពិចារណាថា ភិក្ខុគប្បីជាអ្នកមិនឃើញតែផ្ទៃ មានអាហារ
ល្មមប្រមាណ គប្បីស្គាល់ប្រមាណក្នុងការបរិភោគ មិនបរិភោគដើម្បីលេង
ដូច្នេះ ។

សូម្បីជាអ្នកមានអាហារល្មមប្រមាណយ៉ាងនេះ គប្បីជាអ្នកមានសេចក្តីប្រាថ្នាតិច មានការប្រាថ្នាតិច ៤ យ៉ាង គឺបច្ច័យ ធុតង្គ បរិយត្តិ និងអធិគម ។

ពិតហើយ ភិក្ខុអ្នកបដិបត្តិមោនេយ្យប្បដិបទាដោយចំណែកមួយ ត្រូវជាអ្នកមានសេចក្តីប្រាថ្នាតិចយ៉ាងនេះ ។ សេចក្តីសន្តោសដោយសន្តោស ៣ យ៉ាងក្នុងបច្ច័យទីមួយៗ នោះ ឈ្មោះថា ភាពជាបុគ្គលប្រាថ្នាតិចក្នុងបច្ច័យ ។

ភាពដែលភិក្ខុទ្រទ្រង់នូវធុតង្គនោះឯង មិនប្រាថ្នាថា ជនដទៃ ចូរស្គាល់អញថា មានធុតង្គ ឈ្មោះថា ភាពជាអ្នកប្រាថ្នាតិច ក្នុងធុតង្គ ។

ភាពដែលភិក្ខុជាពហូសូតនោះឯង មិនប្រាថ្នាថា ជនដទៃចូរស្គាល់អញថា ជាពហូសូត ឈ្មោះថា ភាពជាអ្នកមានសេចក្តីប្រាថ្នាតិច ក្នុងបរិយត្តិ ដូចការប្រាថ្នាតិចរបស់ព្រះមហាមជ្ឈន្តិកត្ថេរ ដូច្នោះ ។

ភាពដែលភិក្ខុសម្បូរដោយអធិគមនោះឯង មិនប្រាថ្នាថា អ្នកដទៃចូរស្គាល់អញថា អ្នកនេះ សម្រេចកុសលធម៌ ឈ្មោះថា ជាអ្នកមានសេចក្តីប្រាថ្នាតិច ក្នុងអធិគម ។ ភាពជាអ្នកប្រាថ្នាតិចក្នុងអធិគមនោះ គប្បីជ្រាបថា ទាបជាងការសម្រេចអរហត្ត ព្រោះនេះជាបដិបទា ដើម្បីសម្រេចអរហត្ត ។

ម្យ៉ាងទៀត ភិក្ខុដែលមានសេចក្តីប្រាថ្នាតិចយ៉ាងនេះក៏លះនូវការចង់បាន និងការលោភចេញបានដោយអរហត្តមគ្គ គប្បីជាអ្នកមិនមានសេចក្តីលោភ ។ ពិតហើយ បុគ្គលមិនមានសេចក្តីលោភយ៉ាងនេះ ឈ្មោះថា ជាអ្នកមិនមានសេចក្តីប្រាថ្នា រម្ងាប់សេចក្តីក្តៅក្រហាយបានហើយសព្វកាល ព្រោះលះនូវ

ការប្រាថ្នាជាដើម សត្វទាំងឡាយដែលជាអ្នកស្រេកឃ្លាន មិនឆ្អែត ដូចបុគ្គលក្តៅក្រហាយ ព្រោះស្រេកឃ្លាន ដោយការប្រាថ្នាឯណា ភិក្ខុជាអ្នកមិនប្រាថ្នាដោយការប្រាថ្នានោះ ក៏ព្រោះជាអ្នកមិនប្រាថ្នា ទើបឈ្មោះថា ជាអ្នកអស់នូវការឃ្លាន មិនក្តៅក្រហាយ ដល់នូវការឆ្អែត ព្រោះជាអ្នកមិនប្រាថ្នា ទើបឈ្មោះថា ជាអ្នករម្ងាត់នូវការក្តៅក្រហាយ គឺស្ងប់ចាកការក្តៅក្រហាយ គឺកិលេសទាំងពួង ព្រោះហេតុនោះ គប្បីជ្រាបការប្រកបក្រៅលំដាប់ក្នុងបទនេះ ដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគ កាលត្រាស់បដិបទា បរាបដល់ការសម្រេចអរហត្តយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងត្រាស់ដល់ការសមាទានធុតង្គ និងវត្តដែលទាក់ទងដោយសេនាសនៈ ដែលបញ្ចប់ដោយការសម្រេចអរហត្តរបស់ភិក្ខុដែលបដិបត្តិបដិបទានោះ ទើបត្រាស់ ២ គាថាថា **ស បិណ្ឌចារំ** ដូច្នេះ។

ក្នុងបទទាំងនោះ បទថា **ស បិណ្ឌចារំ ចរិត្វា** បានដល់ ភិក្ខុនោះត្រាច់ទៅដើម្បីភិក្ខា ឬធ្វើនូវភត្តកិច្ចហើយ ។ បទថា **វនន្តមភិហារយេ** គឺជាអ្នកមិនយឺតយូរ ដូចគ្រហស្ថដែលយឺតយូរ គប្បីទៅព្រៃនោះឯង ។ បទថា **ឧបដ្ឋិតោ រុក្ខមូលស្មឹ** គឺអាស្រ័យនូវត្រង់គល់ឈើជាដើម ។ បទថា **អាសនូបគតោ** គឺចូលទៅរកទីអង្គុយ អធិប្បាយថា អង្គុយ ។ បទថា **មុនិ** គឺអ្នកបដិបត្តិមោនេយ្យប្បដិបទា ។ ម្យ៉ាងទៀត ក្នុងទីនេះ ទ្រង់ត្រាស់បិណ្ឌបាតិកង្គធុតង្គ ដោយបទនេះថា **បិណ្ឌចារំ ចរិត្វា** ដូច្នេះ ។ ព្រោះភិក្ខុដែលជាអ្នកសមាទានបិណ្ឌបាតជាវត្តយ៉ាងឧក្រិដ្ឋ ត្រាច់ទៅតាមលំដាប់ប្រក

មានអាហារមួយពេល ឆាន់អាហារក្នុងបាត្រ ហាមអាហារក្រោយ ចាប់ផ្ដើមឆាន់ហើយ ដោយស្មើគ្នានឹងសមាទានតេចីវរិកង្គធុតង្គ និងបង្សុកូលិកង្គធុតង្គផងដែរ ដូច្នោះ ទើបឈ្មោះថា គ្រប់ធុតង្គទាំង ៦ នេះ ។ ទ្រង់ត្រាស់អារញ្ញិកង្គធុតង្គ ដោយបទនេះថា **វនន្តមភិហារយេ** ដូច្នេះ ។ ទ្រង់ត្រាស់រុក្ខមូលិកង្គធុតង្គដោយបទថា **ឧបដ្ឋិតោ រុក្ខមូលស្មឹ** ដូច្នេះ ។ ទ្រង់ត្រាស់នេសជ្ជិកង្គធុតង្គ ដោយបទនេះថា **អាសនូបគតោ** ដូច្នេះ ឈ្មោះថា ត្រាស់ដល់អព្ភោកាសិកង្គធុតង្គ យថាសន្ថតិកង្គធុតង្គ និងសោសានិកង្គធុតង្គ ព្រោះអនុលោមតាមធុតង្គទាំងនោះ តាមលំដាប់ ។ ព្រះមានព្រះភាគត្រាស់ធុតង្គ ១៣ ដោយគាថានេះយ៉ាងនេះ ដល់ព្រះនាឡកត្ថេរ ។

បទថា **ស ឈានបសុតោ ធីរោ** សេចក្ដីថា មុនីនោះជាអ្នកខ្វល់ខ្វាយ គឺប្រកបរឿយៗ ក្នុងឈានទាំងឡាយ ដោយធ្វើឈានដែលមិនទាន់កើត ឲ្យកើតឡើង និងដោយអាវជ្ជនៈ សមាបជ្ជនៈ អធិដ្ឋាន វុដ្ឋាន និងបច្ចវេក្ខណៈ ( វសី ៥ ) ជាអ្នកប្រាជ្ញ គឺសម្បូរដោយបញ្ញា ។ បទថា **វនន្តេ រមិតោ សិយា** គឺគប្បីត្រេកអរក្នុងព្រៃ លោកអធិប្បាយថា មិនគប្បីត្រេកអរក្នុងសេនាសនៈក្បែរស្រុក ។ បទថា **ឈាយេថ រុក្ខមូលស្មឹ អត្តានមភិតោសយំ** សេចក្ដីថា មិនគប្បីខ្វល់ខ្វាយដោយលោកិយជ្ឈានតែម្យ៉ាងប៉ុណ្ណោះឡើយ ដោយពិត គប្បីធ្វើចិត្តឲ្យត្រេកអរក្រៃលែង សម្ងឹងដោយលោកុត្តរជ្ឈានដែលសម្បយុត្តដោយសោតាបត្តិមគ្គជាដើម ត្រង់គល់ឈើនោះ ពិតហើយ ចិត្តរមែងត្រេកអរពន់ពេកក្នុងលោកុត្តរជ្ឈានទាំងនោះ ព្រោះដល់នូវ

ការស្រស់ស្រាយចិត្តក្រៃលែង មិនមែនត្រេកអរជវៃទៀយ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **អត្តានមភិតោសយំ** ដូច្នេះ ។

ព្រះមានព្រះភាគ កាលត្រាស់ដល់ការត្រេកអរក្នុងសេនាសនៈព្រៃ និង អរហត្ត ព្រោះភាពជាអ្នកខ្វល់ខ្វាយក្នុងឈាន ដោយគាថានេះយ៉ាងនេះហើយ ឥឡូវនេះ ព្រោះព្រះនាឡកត្ថេរស្តាប់ព្រះធម្មទេសនានេះហើយ ចូលទៅកាន់ព្រៃ អត់អាហារ បានជាអ្នកខ្វល់ខ្វាយក្រៃលែងក្នុងការបំពេញបដិបទា ទោះអត់អាហារក៏មិនអាចបំពេញសមណធម៌បាន កាលព្រះនាឡកត្ថេរកំពុងតែបំពេញយ៉ាងនោះ ជីវិតក៏លំបាក តែបុគ្គលដែលធ្វើកិលេសមិនឲ្យកើតឡើងក៏គួរស្វែងរកអាហារ នេះជាគោលក្នុងរឿងនេះ ដូច្នោះ ព្រះមានព្រះភាគដើម្បីទ្រង់សម្តែងថា គួរត្រាច់បិណ្ឌបាតក្នុងថ្ងៃតៗ ទៅ តែមិនគួរឲ្យកិលេសកើតឡើង កាលត្រាស់ថា ភិក្ខាចារវត្តចប់ដោយការសម្រេចអរហត្ត ទើបត្រាស់ ៦ គាថា មានជាដើមថា **តតោ រត្យា វិវសនេ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **តតោ** គឺបន្ទាប់អំពីទទួលបិណ្ឌបាតហើយ ត្រាច់ទៅកាន់ជាយព្រៃ ដូចដែលពោលក្នុងបទថា ភិក្ខុអ្នកប្រតិបត្តិមោនេយ្យប្បដិបទានោះ ប្រព្រឹត្តនូវបិណ្ឌបាតចារិកវត្តរួចហើយ គប្បីប្រញាប់ចូលទៅកាន់ព្រៃ ដូច្នេះ ។ បទថា **រត្យា វិវសនេ** គឺកាលរាត្រីកន្លងទៅ លោកអធិប្បាយថា ក្នុងថ្ងៃទី ២ ។ បទថា **គាមន្តមភិហារយេ** សេចក្តីថា ធ្វើនូវអភិសមាចារិកវត្ត ហើយគប្បីចម្រើននូវវិវេក រហូតដល់ពេលភិក្ខាចារ រួចមនសិការកម្មដ្ឋាន ដោយន័យដែលពោលហើយក្នុងគតបច្ចាគតវត្ត គប្បីទៅ

កាន់ស្រុក ។ បទថា **អប្ភាគំ ឆាភិឆន្ទេយ្យ** សេចក្តីថា ភិក្ខុអ្នកបំពេញបដិបទា មិនគប្បីត្រេកអរក្នុងការនិមន្តថា និមន្តលោកម្ចាស់ចាន់ក្នុងផ្ទះរបស់ពួកខ្ញុំចុះ និងកោជនដែលមានវិតក្កយ៉ាងនេះថា គេឲ្យ ឬមិនឲ្យ ឲ្យល្អ ឬឲ្យមិនល្អហ្ន៎ ដូច្នេះ លោកអធិប្បាយថា មិនគួរទទួល ។ បើជនទាំងឡាយទទួលបាត្រទៅ ដោយកម្លាំង ដួសបាយដាក់រហូតពេញ ភិក្ខុចាន់ហើយ បំពេញសមណធម៌ ធុតង្គមិនបែកធ្លាយ តែមិនគួរចូលស្រុកនោះ ព្រោះអាស្រ័យហេតុនោះ ។ បទថា **អភិហារញ្ច គាមតោ** សេចក្តីថា បើជនទាំងឡាយនាំអាហារមក ១០០ ថាស ប្រគេនដល់ភិក្ខុដែលចូលទៅកាន់ស្រុក ភិក្ខុមិនគប្បីត្រេកអរក្នុងអាហារនោះ ទាំងមិនគប្បីទទួលសូម្បីត្រឹមតែមួយគ្រាប់ គួរត្រាច់ទៅបិណ្ឌបាត តាមលំដាប់ផ្ទះ ដោយពិត ។

បទថា **ន មុនិ គាមមាគម្ម កុលេសុ សហសា ចរេ** សេចក្តីថា មុនីបដិបត្តិដើម្បីភាពជាអ្នកឈ្លាសនោះ ទៅកាន់ស្រុក មិនគួរត្រាច់ទៅក្នុងត្រកូលដោយរួសរាន់ ។ លោកអធិប្បាយថា មិនគួរជាប់ជំពាក់ជាមួយគ្រហស្ថ មិនគួរអនុលោមជាមួយគ្រហស្ថ រួមទុក្ខសោកស្តាយជាដើម ។ បទថា **ឃាសេសនំ ឆិន្នកថោ ន វាចំ បយុត្តំ ភណេ** សេចក្តីថា ដូចជាកាត់នូវពាក្យ មិនគប្បីពោលវាចាទាក់ទងដោយការស្វែងរករបស់បរិភោគ ប្រកបដោយឱកាស បរិកថា និមិត្ត វិញ្ញត្តិ បើបំណងព្យាបាលជំងឺ គួរពោលដើម្បីបំបាត់ជំងឺ ដើម្បីត្រូវការបច្ច័យដ៏សេស ឬដើម្បីត្រូវការសេនាសនៈ គួរពោលពាក្យប្រកបដោយឱកាស បរិកថា និងនិមិត្ត វៀរវិញ្ញត្តិ ( ហារមាត់សូម )

ចេញ ។ តែបើមិនឈឺ មិនគួរពោលពាក្យណាមួយឡើយ ។

គាថានេះថា **អលត្ថំ យទិទំ** ជាដើម មានអត្ថដូចតទៅនេះថា មុនីចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត កាលបានរបស់ណាមួយ សូម្បីតិចតួចក៏គិតថា អាត្មាអញបាននូវវត្ថុណា វត្ថុនេះញុំាងប្រយោជន៍ឲ្យសម្រេច កាលមិនបាន ក៏គិតថា អញមិនបានក៏ជាការល្អ ដូច្នេះហើយ ជាអ្នកមិនញាប់ញ័រ គឺមិនមានការខុសប្រក្រតី ព្រោះការបាន និងមិនបានទាំង ២ យ៉ាងនោះឯង រមែងកន្លងនូវទុក្ខបាន ដូចបុរសស្វែងរកផ្លែឈើ ចូលទៅកាន់ដើមឈើហើយ សូម្បីបាន ឬមិនបាននូវផ្លែឈើ ក៏មិនត្រេកអរ មិនទោមនស្ស ដាក់ចិត្តជាកណ្តាល ត្រឡប់ទៅ យ៉ាងណា មុនីចូលទៅកាន់ត្រកូល សូម្បីបាន និងមិនបានលាភ ក៏ដាក់ចិត្តជាកណ្តាល ត្រឡប់ទៅ ដូច្នោះ ។

គាថាថា **សបត្តទាណី** ជាដើម មានអត្ថងាយយល់ហើយ ។ គប្បីជ្រាបការទាក់ទងគ្នានៃគាថាថា **ឧច្ចាវចា** ដូចតទៅនេះថា មុនីជាអ្នកសម្បូរដោយកិច្ចាចារវត្តយ៉ាងនេះហើយ មិនគប្បីត្រេកអរត្រឹមប៉ុណ្ណោះ គួរត្រេកអរក្នុងបដិបទាតទៅ ព្រោះពាក្យទូន្មាន មានសារៈត្រង់កិច្ចបដិបត្តិ ។ បដិបទានោះ ទាំងខ្ពស់ និងទាប ព្រះសមណៈទ្រង់ប្រកាសហើយ មុនីទាំងឡាយរមែងមិនទៅកាន់និព្វានអស់វារៈ ២ ដង និព្វាននេះ គួរពាល់ត្រូវតែម្តងប៉ុណ្ណោះ ក៏មិនមែន ។

បទនោះ មានអធិប្បាយដូចតទៅនេះថា មគ្គប្បដិបទានេះ ឈ្មោះថាខ្ពស់ទាប ព្រោះមានប្រភេទល្អ និងអាក្រក់ ដែលព្រះពុទ្ធសមណៈទ្រង់បាន

ប្រកាសហើយ ។ ពិតហើយ បដិបត្តិឯាយ ត្រាស់ដឹងរហ័ស ជាបដិបទាខ្ពស់ បដិបត្តិលំបាក ត្រាស់ដឹងក៏យឺតយូរ ជាបដិបទាទាបទាំង ២ យ៉ាងនោះ ជាបដិបទាខ្ពស់ដោយអង្គ ១ ទាបដោយអង្គ ១ម្យ៉ាងទៀត បដិបទាដើមខ្ពស់ បដិបទា ៣ ទៀតទាប ។ មុនីទាំងឡាយរមែងមិនទៅកាន់និព្វាន ដល់ទៅ ២ ដង ដោយបដិបទាខ្ពស់ ឬទាបនេះ ។ បាឋៈថា **ទុគុណំ** ប្រែថា ២ ដងក៏មាន អធិប្បាយថា មុនីទាំងឡាយ រមែងមិនទៅកាន់និព្វាន ២ ដង ដោយមគ្គតែមួយឡើយ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះកិលេសណាត្រូវលះទៅហើយ ដោយមគ្គណា មិនគប្បីលះកិលេសទាំងនោះទៀត ។ ដោយបទនោះ លោកសម្ដែងការមិនវិនាសនៃធម៌ ។ បទថា **ន យិទំ ឯកគុណំ មុត្តំ** អធិប្បាយថា និព្វាននេះ សូម្បីគួរពាល់ត្រូវតែម្ដងប៉ុណ្ណោះ ក៏មិនមែន សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមិនមានការលះកិលេសទាំងអស់បានដោយមគ្គ ១ ។ ដោយបទនេះ លោកសម្ដែងការមិនសម្រេចអរហត្តដោយមគ្គមួយប៉ុណ្ណោះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងអានិសង្សរបស់បដិបទា ទើបត្រាស់គាថាថា **យស្ស ច វិសតា** ដូច្នេះជាដើម ។

បទនោះ មានអធិប្បាយដូចតទៅនេះថា កាលភិក្ខុបដិបត្តិហើយយ៉ាងនេះ ឈ្មោះថា មិនមានតណ្ហា ព្រោះលះបានដោយបដិបទានោះ ឈ្មោះថា រលាស់ចេញ ព្រោះរលាស់តណ្ហាវិចរិត ១០៨ ចោលបាន ភិក្ខុនោះ កាត់នូវក្រសែកិលេសបានហើយ លះកិច្ចតូចធំបានជាសមុច្ឆេទហើយ ដោយការលះ

កុសលកម្ម និងអកុសលកម្ម មិនមានការក្តៅក្រហាយ សូម្បីតែតិចតួច ដែលកើតអំពីរាគៈក្តី កើតអំពីទោសៈក្តី ។

ឥឡូវនេះ ព្រោះចិត្តកើតឡើងដល់ព្រះនាឡកត្ថេរ ព្រោះបានស្តាប់គាថាទាំងនេះថា ឈ្មោះថា បដិបទារបស់មុនីមានត្រឹមប៉ុណ្ណេះ ក៏ធ្វើបានដោយងាយ មិនលំបាក អាចបំពេញបានដោយសេចក្តីលំបាកតិចតួច ព្រោះហេតុនោះ កាលព្រះមានព្រះភាគទ្រង់សម្តែងដល់ព្រះនាឡកត្ថេរថា បដិបទារបស់មុនីធ្វើបានដោយលំបាក ដូច្នេះហើយ ទើបត្រាស់គាថាថា **មោនេយ្យន្តេ ឧបញ្ញិស្សំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ឧបញ្ញិស្សំ** បានដល់ នឹងប្រាប់ អធិប្បាយថា តថាគតនឹងប្រាប់ ។ ឈ្មោះថា **ខុរធារូបមោ** ព្រោះជាបុគ្គលមានមុខកាំបិតកោរជាគ្រឿងប្រៀបធៀប ។ បទថា **ភវេ** ប្រែថា គប្បីជា ។ មានអធិប្បាយដូចម្តេច លោកអធិប្បាយថា ភិក្ខុដែលបដិបត្តិបដិបទារបស់មុនី គប្បីប្រព្រឹត្តក្នុងបច្ច័យទាំងឡាយ ធ្វើនូវមុខកាំបិតកោរជាគ្រឿងប្រៀបធៀប កាលបានបច្ច័យដោយប្រពៃហើយបរិភោគ គប្បីរក្សាចិត្តឲ្យផុតចាកកិលេស ដូចការលិទ្ធនូវមុខកាំបិតកោរ ដែលមានតំណក់ទឹកឃ្មុំ រមែងរក្សាអណ្តាតក្រែងមុតដូច្នោះ ។ ពិតហើយ បច្ច័យទាំងឡាយ គប្បីបានដោយវិធីដែលបរិសុទ្ធ តែមិនអាចបរិភោគវត្ថុដែលមិនមានទោសបានងាយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ដល់ការអាស្រ័យបច្ច័យប៉ុណ្ណោះ ដោយច្រើន ។ បទថា **ជិវ្ហាយ តាលុំ អាហច្ច ឧទរេ សញ្ញតោ សិយា** សេចក្តីថា សង្កត់ពិតាន

ដោយអណ្តាត បន្ទាបង់ចំណង់ក្នុងរស គប្បីសង្រួមផ្ទៃ ព្រោះមិនសេពបច្ច័យដែលកើតឡើងដោយផ្លូវសៅហ្មង ។

បទថា **អលីនចិត្តោ ច សិយា** សេចក្តីថា គប្បីជាអ្នកមានចិត្តមិនខ្ជិលច្រអូស ព្រោះធ្វើឲ្យមាំទាំក្នុងការបំពេញកុសលធម៌ជានិច្ច ។ បទថា **ន ចាបិ ពហុ ចិន្តយេ** គឺមិនគប្បីគិតច្រើន ដោយញាតិវិតក្ក ជនបទវិតក្ក និងទេវតាវិតក្ក ។ បទថា **និរាមគន្ធោ អសិតោ ព្រហ្មចរិយបរាយនោ** សេចក្តីថា ជាអ្នកមិនមានកិលេស ដែលតណ្ហា និងទិដ្ឋិមិនអាស្រ័យហើយក្នុងភពណាមួយ គប្បីជាអ្នកមានត្រៃសិក្ខា និងសាសនព្រហ្មចរិយៈទាំងមូលជាទីទៅខាងមុខនោះឯង ។

បទថា **ឯកាសនស្ស** គឺអង្គុយក្នុងទីស្ងាត់ ។ ក្នុងបទនេះ ពោលដល់ឥរិយាបថទាំងអស់ ដោយមាតិកាថា ការអង្គុយ គប្បីជ្រាបថា លោកអធិប្បាយថា គប្បីសិក្សាដើម្បីភាពជាបុគ្គលតែឯងគ្រប់ឥរិយាបថ ។ ម្យ៉ាងទៀត បទថា **ឯកាសនស្ស** នេះ ជាចតុត្ថីវិភត្តិ ប្រែថា ដើម្បីការអង្គុយម្នាក់ឯង ។ បទថា **សមណូបាសនស្ស ច** សេចក្តីថា ដើម្បីប្រកបការនាមានអារម្មណ៍ ៣៨ ដែលសមថៈគប្បីអប់រំ ឬដើម្បីប្រភេទនៃអារម្មណ៍ ៣៨ ដែលជាទីអប់រំរបស់សមណៈទាំងឡាយ ។ សូម្បីបទនេះ ក៏ជាចតុត្ថីវិភត្តិដូចគ្នា លោកអធិប្បាយថា ដើម្បីអប់រំ ។ ម្យ៉ាងទៀត បទនេះ គប្បីជ្រាបថា លោកពោលដល់កាយវិវេក ដោយការអង្គុយម្នាក់ឯង ពោលដល់ចិត្តវិវេក ដោយការអប់រំរបស់សមណៈ ។ បទថា **ឯកត្តំ មោនមក្ខាតំ** សេចក្តីថា

តថាគតប្រាប់ហើយថា ជាមុនីដោយចំណែកមួយ ដោយកាយវិវេក និងចិត្ត-វិវេក ដោយប្រការដូច្នេះ ។ បទថា **ឯកោ ច អភិរមិស្សសិ** នេះ ជាពាក្យលម្អិតសេចក្ដីនៃគាថាតទៅ គប្បីភ្ជាប់ដោយបទនេះថា **អថ ភាសិហិ ទស ទិសា** ។ បទថា **ភាសិហិ** គឺលោកនឹងពោល នឹងប្រកាស អធិប្បាយថា កាលអ្នកចម្រើនបដិបទានេះ នឹងជាអ្នកប្រាកដដោយកិត្តិយសគ្រប់ទិស អត្ថនៃបទ ៤ មានអត្ថថា **សុត្វា ធីរានំ** នេះ មានអធិប្បាយដូចតទៅនេះ ចូរអ្នកប្រកាសទៅសព្វទិសទាំង ១០ ដោយការប្រកាសដល់កិត្តិសព្ទ អ្នកបានស្ដាប់សំឡេងប្រកាសកិត្តិសព្ទ នៃអ្នកប្រាជ្ញទាំងឡាយ ដែលជាអ្នកសម្ងំឈាន ជាអ្នកលះបង់កាមហើយ បន្ទាប់អំពីនោះ មិនរាយមាយ គប្បីធ្វើហិរិនិងសទ្ធាឲ្យក្រៃលែងឡើងក្នុងរូប ខ្ពើមនូវការប្រកាសនោះ ញ៉ាំងសទ្ធាឲ្យកើតឡើងថា នេះជាបដិបទាដើម្បីនាំចេញចាកទុក្ខ ហើយចម្រើននូវកិច្ចបដិបត្តិឲ្យក្រៃលែងឡើងនោះឯង ។ បទថា **មាមកោ** សេចក្ដីថា កាលបើដូច្នេះ ក៏ជាសាវករបស់តថាគតបាន ។ បទថា **តំ នទីហិ** សេចក្ដីថា ពាក្យណាដែលតថាគតពោល អ្នកគប្បីធ្វើហិរិ និងសទ្ធាឲ្យក្រៃលែង ពោលថា មិនគួរធ្វើនូវការរាយមាយ ចូរអ្នកដឹងពាក្យដែលតថាគតពោលនោះ ដោយការបង្ហាញខ្ទនដូចស្ទឹងនេះ ចូរអ្នកដឹងការផ្ទុយគ្នានៃពាក្យដែលតថាគតពោលនោះ ទាំងក្នុងបឹង និងក្នុងស្ទឹងតូច ។ បទថា **សោព្ភេសុ** គឺបឹង ។ បទថា **បទរេសុ** គឺស្ទឹងតូច ។ សេចក្ដីនេះ ដូចម្ដេច បទថា **សណ្ដា យន្តិ កុសុព្ភា តុណ្ហី យន្តិ មហោទធិ** សេចក្ដីថា សេចក្ដីពិត ស្ទឹងតូចទាំងអស់ មានបឹង និង

ស្ទឹងតូចជាដើម តែងហូរឮសំឡេងខ្លាំង ឯស្ទឹងធំ មានស្ទឹងគង្គាជាដើម ហូរដោយស្ងប់ស្ងៀម បុគ្គលមិនជាពុទ្ធមាមកៈ រមែងជាអ្នកវាយមាយថា អាត្មាអញបំពេញបដិបទារបស់មុនីយ៉ាងនេះ ចំណែកបុគ្គលជាពុទ្ធមាមកៈ គឺកាន់យកព្រះពុទ្ធថាជារបស់យើង ញុំាងហិរិ និងសទ្ធាឲ្យកើតជាអ្នកមានចិត្តមិនវាយមាយ ។

មានអ្វីទឹងពោលឲ្យក្រៃលែងជាងនោះទៀត មានគាថាថា

ទឹកណា ដែលកន្ទះ ទឹកនោះ តែងឮសូរ ទឹកណា ដែលពេញ
ទឹកនោះតែងស្ងប់ ជនពាលមានឧបមាដូចទឹកកន្ទះក្អម ជនបណ្ឌិត
មានឧបមាដូចអន្លង់ទឹកដ៏ពេញ ។

ក្នុងគាថានោះ គប្បីមានពាក្យសួរថា បើបុគ្គលពាលប្រៀបដូចក្អមទឹកដែលមានទឹកកន្ទះ ព្រោះមានសំឡេងខ្លាំង បណ្ឌិតប្រៀបដូចអន្លង់ទឹកដែលពេញ ព្រោះជាអ្នកស្ងប់ កាលបើដូច្នោះ ហេតុអ្វី ទើបព្រះពុទ្ធសមណៈជាអ្នកខ្វល់ខ្វាយក្នុងការសម្តែងធម៌យ៉ាងនេះ ដោយសម្ពន្ធនេះ ទើបព្រះមានព្រះភាគត្រាស់គាថាថា **យំ សមណោ** ដូច្នេះ ។

បទនោះ មានអធិប្បាយដូចតទៅនេះថា ព្រះពុទ្ធសមណៈពោលពាក្យណាច្រើន ដែលចូលដល់ប្រយោជន៍ ប្រកបដោយប្រយោជន៍ គឺមិនសោះសូន្យប្រយោជន៍ និងមានប្រយោជន៍ មិនពោលដោយការវាយមាយ ម្យ៉ាងទៀត កាលដឹង ទើបសម្តែងធម៌ កាលសម្តែងធម៌សូម្បីអស់មួយថ្ងៃ ក៏មិនយឺតយូរ ព្រោះពាក្យទាំងអស់របស់ព្រះពុទ្ធសមណៈនោះ ជាវចីកម្ម អនុ-

លោមតាមញាណ ។ ម្យ៉ាងទៀត កាលព្រះពុទ្ធសមណៈនោះសម្តែងធម៌យ៉ាងនេះ ដឹងនូវពាក្យនោះ ដោយប្រការផ្សេងៗ ថា ពាក្យនេះ គប្បីជាប្រយោជន៍ ទើបពោលពាក្យច្រើន មិនមែនពោលព្រោះនិយាយច្រើនតែម្យ៉ាង ។

គប្បីជ្រាបសម្ពន្ធគ្នានៃគាថាចុងក្រោយដូចតទៅនេះថា ព្រះពុទ្ធសមណៈប្រកបដោយសព្វញ្ញុតញ្ញាណ ទ្រង់ដឹងទើបសម្តែងធម៌ ទ្រង់ដឹងទើបពោលនូវពាក្យច្រើន ។ ម្យ៉ាងទៀត សមណៈណាដឹងនូវធម៌ដែលព្រះពុទ្ធសមណៈនោះ សម្តែងហើយដោយញាណ ដែលជាចំណែកនៃការចាក់ធ្លុះ មុនីណាជ្រាបប្រាកដនូវធម៌ មានចិត្តសង្រួមហើយ ជ្រាបប្រាកដនូវធម៌ មិននិយាយច្រើន មុនីនោះ គួរដល់មោនេយ្យប្បដិបទា មុនីនោះ បានដល់នូវអរហត្តមគ្គញ្ញាណ ។

ពាក្យនោះ មានសេចក្តីដូចតទៅនេះថា សមណៈដឹងនូវធម៌នោះ ជាអ្នកសង្រួមខ្លួនហើយ គ្រប់គ្រងចិត្តហើយ ដឹងពាក្យដែលមិននាំមកនូវប្រយោជន៍ សេចក្តីចម្រើន និងសេចក្តីសុខមកឲ្យដល់សត្វទាំងឡាយ រមែងមិនពោលច្រើន សមណៈយ៉ាងនេះ រមែងគួរដល់ភាពជាមុនី មុនីនោះ ជាអ្នកបដិបត្តិដើម្បីភាពជាមុនី រមែងគួរដល់បដិបទារបស់មុនី ដែលបានដល់មោនេយ្យប្បដិបទា មិនមែនគួរតែម្យ៉ាងប៉ុណ្ណោះទេ ដែលពិតនោះ គប្បីជ្រាបថា បានដល់ ធម៌ធ្វើឲ្យជាមុនី គឺអរហត្តមគ្គញ្ញាណ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់បញ្ចប់ទេសនា ដោយធម៌ដែលជាកំពូល គឺអរហត្ត ។

ព្រះនាឡកត្ថេរកាលស្តាប់ដូច្នេះហើយ ជាអ្នកមានសេចក្តីប្រាថ្នាតិចក្នុង

ឋានៈ ៣ គឺក្នុងការឃើញ ១ ក្នុងការស្ដាប់ ១ ក្នុងការសាកសួរ ១ ព្រោះកាលចប់ទេសនា ព្រះនាឡកត្ថេរនោះ មានចិត្តជ្រះថ្លា ថ្វាយបង្គំព្រះមានព្រះភាគ ចូលទៅកាន់ព្រៃ មិនកើតសេចក្ដីឡេះឡោះថា ធ្វើដូចម្ដេចហ្ន៎ អាត្មាអញគប្បីបានគាល់ព្រះមានព្រះភាគទៀត នេះគឺភាពជាអ្នកមានសេចក្ដីប្រាថ្នាតិចក្នុងការឃើញរបស់ព្រះនាឡកត្ថេរនោះ ។ ម្យ៉ាងទៀត មិនកើតនូវការឡេះឡោះថា ធ្វើដូចម្ដេចហ្ន៎ អញគប្បីបានស្ដាប់ព្រះធម្មទេសនាទៀត នេះគឺភាពជាអ្នកមានសេចក្ដីប្រាថ្នាតិច ក្នុងការស្ដាប់របស់ព្រះនាឡកត្ថេរនោះ ។ ម្យ៉ាងទៀត ព្រះនាឡកត្ថេរនោះ មិនកើតនូវការឡេះឡោះថា ធ្វើដូចម្ដេចហ្ន៎ អញគប្បីបានសួរមោនេយ្យប្បដិបទាទៀត នេះគឺជាអ្នកប្រាថ្នាតិចក្នុងការសាកសួររបស់ព្រះនាឡកត្ថេរនោះ ។ ព្រនាឡកត្ថេរនោះ ជាអ្នកមានសេចក្ដីប្រាថ្នាតិចយ៉ាងនេះ ទើបចូលទៅកាន់ជើងភ្នំ ហើយមិននៅលើស ២ ថ្ងៃ ក្នុងព្រៃមួយ មិនអង្គុយលើស ២ ថ្ងៃក្នុងគល់ឈើ ១ មិនចូលទៅបិណ្ឌបាតលើស ២ ថ្ងៃក្នុងស្រុក ១ ។ ព្រះនាឡកៈត្រាច់អំពីព្រៃចូលកាន់ព្រៃ អំពីដើមឈើចូលកាន់ដើមឈើ អំពីស្រុកចូលកាន់ស្រុក បដិបត្តិបដិបទាដែលសមគួរហើយ តាំងនៅក្នុងអគ្គផល ( អរហត្ត ) ព្រោះជាអ្នកបំពេញមោនេយ្យប្បដិបទាដោយឧក្រិដ្ឋ និងមានជីវិតនៅបានត្រឹម ៧ ខែ ប៉ុណ្ណោះ បើបំពេញយ៉ាងមធ្យម នឹងមានជីវិតនៅបាន ៧ ឆ្នាំ បើបំពេញយ៉ាងខ្សោយ នឹងមានជីវិតនៅបាន ១៦ ឆ្នាំ ព្រះនាឡកត្ថេរនេះបំពេញយ៉ាងឧក្រិដ្ឋ ដូច្នោះ ទើបនៅបាន ៧ ខែ ដឹងថាខ្ជួនអស់អាយុ ទើបស្រង់ទឹក ស្លៀកសំពត់ ចងវត្ថពន្ធ

ដណ្តប់សន្សំព្រាដី ២ ជាន់ បែរមុខមករកព្រះទសពល ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ផ្គងអញ្ជលីឈរផ្អែកភ្នំឈ្មោះហិង្គុលិក បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។ ព្រះមានព្រះភាគ កាលទ្រង់ជ្រាបថា ព្រះនាឡកត្ថេរបរិនិព្វានហើយ ទើបយាងទៅកាន់ភ្នំនោះ មួយអន្លើដោយភិក្ខុសង្ឃ ធ្វើឈាបនកិច្ច ឲ្យរក្សាព្រះធាតុ បញ្ចុះក្នុងចេតិយ ហើយយាងត្រឡប់ដោយប្រការដូច្នេះ ។ល។

**អដ្ឋកថានាឡកសូត្រទី ១១ ចប់**

# សុត្តន្តបិដក

## ទ្វយតានុបស្សនាសូត្រទី ១២

[ ៧៧ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងបុព្វារាម មិគារមាតុប្រាសាទ ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ មានភិក្ខុសង្ឃចោមរោម គង់ក្នុងទីវាល នារាត្រីពេញបូណ៌មី ក្នុងថ្ងៃឧបោសថទី ១៥ នោះ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ឆ្មៀងមើល នូវភិក្ខុសង្ឃ ដែលស្ងៀមស្ងាត់ហើយ ទ្រង់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ កុសលធម៌ទាំងឡាយណា ជាអរិយធម៌ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅ ដើម្បីសម្ពោធិញ្ញាណ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើមានគេសួរអ្នកទាំងឡាយ ថា ប្រយោជន៍អ្វីដល់អ្នកទាំងឡាយ ក្នុងកិរិយាស្តាប់នូវកុសលធម៌ទាំងឡាយ នោះ ដែលជាអរិយធម៌ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅ ដើម្បីសម្ពោ-ធិញ្ញាណ ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នាគួរពោលយ៉ាងនេះ ទៅនឹងជនទាំង នោះវិញថា ប្រយោជន៍ដើម្បីដឹងតាមពិត នូវសភាពនៃធម៌ជាគូនឹងគ្នាជាកំណត់ អ្នករាល់គ្នា ពោលនូវសភាពនៃធម៌ ដែលគូនឹងគ្នាតើដូចម្តេច ( គប្បីពោល ) ថា នេះជាទុក្ខ នេះជាហេតុនាំឲ្យកើតទុក្ខ នេះជាអនុបស្សនាទី ១ នេះជាទី រលត់ទុក្ខ នេះជាបដិបទាទៅកាន់ទីរលត់ទុក្ខ នេះជាអនុបស្សនាទី ២ ម្នាល ភិក្ខុទាំងឡាយ កាលបើភិក្ខុពិចារណាឃើញរឿយៗ នូវសភាពនៃធម៌ជាគូនឹង គ្នា ដោយប្រពៃយ៉ាងនេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿង ដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន បណ្តាផលទាំងពីរប្រការ ផលណាមួយនឹងប្រាកដ គឺនឹងបាននូវអរហត្តផលក្នុងបច្ចុប្បន្ន ឬមួយបើខន្ធ

ដ៏សេស ដែលគប្បីកើតតទៅទៀតនៅមាន នឹងបានដល់នូវអនាគាមិផល ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះ លុះព្រះសុគតជាសាស្តា ទ្រង់ត្រាស់ពាក្យនេះហើយ ទើបទ្រង់ត្រាស់គាថាព័ន្ធតទៅទៀតថា

[ ៧៨ ] ពួកជនណា មិនដឹងច្បាស់នូវទុក្ខ ទាំងនូវហេតុនាំឲ្យកើតទុក្ខ នូវព្រះនិព្វានជាទីរម្ងត់ទុក្ខ មិនសេសសល់ ដោយសព្វគ្រប់ ទាំងមិនដឹងនូវផ្លូវ ទៅកាន់ទីរម្ងាប់ទុក្ខនោះ ពួកជននោះសាបសូន្យហើយ ចាកចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ពួកជននោះ មិនគួរដើម្បីនឹងធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃវដ្តទុក្ខបាន ពួកជននោះ ចូលទៅកាន់ជាតិ និងជរាតែម្យ៉ាង ។ ពួកជនណាដឹងច្បាស់នូវទុក្ខ នូវហេតុនាំឲ្យកើតទុក្ខ នូវព្រះនិព្វានជាទីរម្ងត់ទុក្ខ ឥតសេសសល់ដោយសព្វគ្រប់ ទាំងដឹងច្បាស់នូវផ្លូវ ដែលទៅកាន់ទីរម្ងាប់ទុក្ខនោះ ពួកជននោះ បរិបូណ៌ដោយចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ពួកជននោះ ទើបគួរនឹងធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃវដ្តទុក្ខបាន ពួកជននោះ មិនចូលទៅកាន់ជាតិ និងជរាឡើយ ។

[ ៧៩ ] ម្នាលភិក្ខុទាំងឡាយ ប្រសិនបើគេសួរថា ការពិចារណានូវសភាពនៃធម៌ ដែលជាគូនឹងគ្នាដោយប្រពៃ ដោយបរិយាយដទៃទៀត មានដែរឬ អ្នករាល់គ្នាគួរប្រាប់ថា មាន តើមានដូចម្តេច ( ត្រូវប្រាប់ថា ) ទុក្ខនីមួយទាំងអស់ តែងកើតឡើងព្រោះឧបធិជាបច្ច័យ នេះជាអនុបស្សនាទី ១

មួយទៀត ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ដោយប្រាសចាកតម្រេក មិនសេសសល់នៃពួកឧបធិធម៌ គឺកម្ម នេះជាអនុបស្សនាទី ២ ភិក្ខុអ្នកពិចារណាឃើញនូវសភាពនៃធម៌ ដែលជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះ ។បេ។ ព្រះសាស្ដាទ្រង់ត្រាស់គាថាព័ន្ធដទៃតទៅទៀតថា

ទុក្ខទាំងឡាយ រមែងកើតឡើងព្រោះមានឧបធិ ( កម្ម ) ជាបច្ច័យ ពួកសត្វណានីមួយក្នុងលោក មានរូបច្រើនប្រការ ( រមែងទទួលនូវទុក្ខនោះ ) បុគ្គលពាលណា មិនស្គាល់ច្បាស់ ហើយធ្វើនូវឧបធិ បុគ្គលពាល ( នោះ ) តែងបាននូវទុក្ខរឿយៗ ព្រោះហេតុនោះ អ្នកប្រាជ្ញពិចារណាឃើញនូវឧបធិ ជាហេតុឲ្យកើតទុក្ខ កាលស្គាល់ច្បាស់ មិនគប្បីធ្វើនូវឧបធិឡើយ ។

[ ៨០ ] ម្នាលភិក្ខុទាំងឡាយ ប្រសិនបើមានគេសួរថា ការពិចារណានូវសភាពនៃធម៌ ដែលជាគូនឹងគ្នាដោយប្រពៃ ដោយបរិយាយដទៃទៀត មានដែរឬ អ្នករាល់គ្នាគប្បីតបថា មាន តើមានដូចម្ដេច ( ត្រូវប្រាប់ថា ) ទុក្ខនីមួយទាំងអស់ តែងកើតឡើងព្រោះអវិជ្ជាជាបច្ច័យ នេះជាអនុបស្សនាទី ១ មួយទៀត ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ដោយប្រាសចាកតម្រេក មិនមានសេសសល់នៃអវិជ្ជា នេះជាអនុបស្សនាទី ២ ភិក្ខុពិចារណាឃើញនូវសភាពនៃធម៌ ដែលជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះ ។បេ។ ព្រះសាស្ដាទ្រង់ត្រាស់គាថាព័ន្ធដទៃ តទៅទៀតថា

ពួកសត្វរមែងទៅកាន់ជាតិ មរណៈ និងការអន្ទោលទៅក្នុងភពថ្មីរឿយៗ ( ដោយអវិជ្ជាគតិណា ) អវិជ្ជាគតិនោះ មិនដឹងនូវសភាពជាមនុស្សនេះផង និងភាពនៃនិកាយដទៃផង ។ ការអន្ទោលទៅ ( ក្នុងភព ) អស់កាលដ៏វែងនេះ ក៏ព្រោះតែអវិជ្ជា គឺមោហៈធំនេះឯង ពួកសត្វណាដែលមានវិជ្ជាគតិ ពួកសត្វនោះ រមែងមិនទៅកាន់ភពថ្មីទៀតឡើយ ។

[ ៨១ ] ដោយបរិយាយដទៃទៀត មានដែរឬ ។បេ។ តើមានដូចម្តេច ( ត្រូវប្រាប់ថា ) ទុក្ខនីមួយទាំងអស់ តែងកើតឡើងព្រោះសង្ខារជាបច្ច័យ នេះជាអនុបស្សនាទី ១ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ដោយប្រាសចាកតម្រេក មិនមានសេសសល់នៃសង្ខារ នេះជាអនុបស្សនាទី ២ ភិក្ខុអ្នកពិចារណាឃើញនូវសភាព នៃធម៌ដែលជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះឯង ។បេ។ ព្រះសាស្តាទ្រង់ត្រាស់គាថាព័ន្ធដទៃតទៅទៀតថា

ទុក្ខនីមួយទាំងអស់តែងកើតឡើង ព្រោះសង្ខារជាបច្ច័យ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ទៅនៃសង្ខារទាំងឡាយ ។ អ្នកប្រាជ្ញជ្រាបនូវទោសនុ៎ះថា ទុក្ខកើតឡើង ព្រោះសង្ខារជាបច្ច័យ ព្រោះរម្ងាប់នូវសង្ខារទាំងពួង ព្រោះរម្ងត់ទៅនៃកាមសញ្ញាជាដើមបាន ព្រោះជ្រាបនូវកងទុក្ខនុ៎ះតាមពិត ។ បណ្ឌិតទាំងឡាយ អ្នកដល់នូវវេទ ឃើញដោយប្រពៃ ជ្រាបដោយប្រពៃ គ្របសង្កត់នូវមារសំយោគ គឺវដ្តៈក្នុងភូមិទាំង ៣ ហើយ

រមែងមិនត្រឡប់មកកាន់ភពថ្មីទៀតឡើយ ។

[ ៨២ ] ដោយបរិយាយដទៃទៀត មានដែរឬ ។បេ។ តើមានដូចម្តេច ( ត្រូវប្រាប់ថា ) ទុក្ខនីមួយទាំងអស់ តែងកើតឡើងព្រោះវិញ្ញាណជាបច្ច័យ នេះជាអនុបស្សនាទី ១ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ដោយប្រាស ចាកតម្រេក មិនមានសេសសល់នៃវិញ្ញាណ នេះជាអនុបស្សនាទី ២ ភិក្ខុអ្នក ពិចារណាឃើញរឿយៗ នូវសភាពនៃធម៌ដែលជាគូនឹងគ្នា ដោយប្រពៃយ៉ាង នេះឯង ។បេ។ ព្រះសាស្តាទ្រង់ត្រាស់គាថាព័ន្ធដទៃតទៅទៀតថា

ទុក្ខនីមួយទាំងអស់តែងកើតឡើង ព្រោះវិញ្ញាណជាបច្ច័យ ការ
កើតឡើងនៃទុក្ខមិនមាន ព្រោះរលត់វិញ្ញាណ ។ អ្នកប្រាជ្ញ
ដឹងនូវទោសនេះថា ទុក្ខ ( កើតឡើង ) ព្រោះវិញ្ញាណជាបច្ច័យ
ភិក្ខុមិនមានតណ្ហា បានបរិនិព្វាន ព្រោះរម្ងាប់បង់នូវវិញ្ញាណ ។

[ ៨៣ ] ដោយបរិយាយដទៃទៀត មានដែរឬ ។បេ។ តើមានដូចម្តេច ( ត្រូវប្រាប់ថា ) ទុក្ខនីមួយទាំងអស់ តែងកើតឡើងព្រោះផស្សៈជាបច្ច័យ នេះជាអនុបស្សនាទី ១ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ដោយប្រាស ចាកតម្រេក មិនមានសេសសល់នៃផស្សៈ នេះជាអនុបស្សនាទី ២ ភិក្ខុអ្នក ពិចារណាឃើញរឿយៗ នូវសភាពធម៌ដែលជាគូនឹងគ្នាយ៉ាងនេះឯង ។បេ។ ព្រះសាស្តាទ្រង់ត្រាស់គាថាព័ន្ធដទៃតទៅទៀតថា

ការអស់សំយោជនៈ ជាធម៌ឃ្លាងរបស់ពួកជនទាំងនោះ ដែល
មានផស្សៈគ្របសង្កត់ហើយ ប្រព្រឹត្តតាមខ្សែតណ្ហាក្នុងភព

ជាអ្នកប្រតិបត្តិតាមផ្លូវខុស ។ ពួកជនណា កំណត់ដឹងនូវផស្សៈ ត្រេកអរក្នុងព្រះនិព្វាន ជាទីរម្ងាប់ ( សង្ខារទាំងពួង ) ដោយបញ្ញា ពួកជននោះ មិនមានតណ្ហា រមែងបរិនិព្វានព្រោះរម្ងត់បង់នូវផស្សៈ ។

[ ៨៤ ] ដោយបរិយាយដទៃទៀត មានដែរឬ ។បេ។ តើមានដូចម្ដេច ( ត្រូវប្រាប់ថា ) ទុក្ខនីមួយទាំងអស់ តែងកើតឡើងព្រោះវេទនាជាបច្ច័យ នេះជាអនុបស្សនាទី ១ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ដោយប្រាសចាកតម្រេក មិនមានសេសសល់នៃវេទនា នេះជាអនុបស្សនាទី ២ ភិក្ខុអ្នកពិចារណាឃើញរឿយៗ នូវសភាពធម៌ដែលជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះឯង ។បេ។ ព្រះសាស្ដាទ្រង់ត្រាស់គាថាព័ន្ធដទៃតទៅទៀតថា

អ្នកប្រាជ្ញជ្រាបថា ធម្មជាតនីមួយ ទោះបីជាសុខ ឬជាទុក្ខ ព្រមទាំងមិនទុក្ខមិនសុខ ដែលមានខាងក្នុងក្ដី ខាងក្រៅក្ដី ដែលសត្វទទួលហើយ ធម្មជាតនុ៎ះសុទ្ធតែជាទុក្ខ បានពាល់ត្រូវសម្រេចនូវធម៌ សម្រាប់វិនាស និងធម៌សម្រាប់ទ្រុឌទ្រោម ( ដោយឧទយព្វយញ្ញាណ ) ឃើញនូវការសូន្យទៅ ដឹងច្បាស់វេទនានោះ ដោយប្រការដូច្នេះ ។ ការកើតឡើងនៃទុក្ខមិនមាន ព្រោះអស់ទៅនៃវេទនាទាំងឡាយ ។

[ ៨៥ ] ដោយបរិយាយដទៃទៀត មានដែរឬ ។បេ។ តើមានដូចម្ដេច ( ត្រូវប្រាប់ថា ) ទុក្ខនីមួយទាំងអស់ តែងកើតឡើងព្រោះតណ្ហាជាបច្ច័យ

នេះជាអនុបស្សនាទី ១ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ដោយប្រាសចាកតម្រេក មិនមានសេសសល់នៃតណ្ហា នេះជាអនុបស្សនាទី ២ ភិក្ខុអ្នកពិចារណាឃើញរឿយៗ នូវសភាពធម៌ដែលជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះឯង ។បេ។ ព្រះសាស្តាទ្រង់ត្រាស់គាថាព័ន្ធដទៃតទៅទៀតថា

បុរសដែលមានតណ្ហាជាគម្រប់ពីរ ( នឹងខ្លួន ) រមែងអន្ទោលទៅកាន់អត្តភាពនេះ និងអត្តភាពដទៃ អស់កាលយូរអង្វែង មិនងាយនឹងប្រព្រឹត្តកន្លងសង្សារបានឡើយ ។ ភិក្ខុលុះដឹងទោសនៃតណ្ហានុ៎ះ ដ៏ជាហេតុឲ្យកើតទុក្ខ គប្បីជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីប្រកាន់ មានសតិវៀរចេញ ( ចាកតណ្ហា ឧបាទាន ) ។

[ ៨៦ ] ដោយបរិយាយដទៃទៀត មានដែរឬ ។បេ។ តើមានដូចម្តេច ( ត្រូវប្រាប់ថា ) ទុក្ខនីមួយទាំងអស់ តែងកើតឡើងព្រោះឧបាទានជាបច្ច័យ នេះជាអនុបស្សនាទី ១ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ដោយប្រាសចាកតម្រេក មិនសេសសល់នៃឧបាទាន នេះជាអនុបស្សនាទី ២ ភិក្ខុអ្នកពិចារណាឃើញរឿយៗ នូវសភាពធម៌ដែលជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះឯង ។បេ។ ព្រះសាស្តាទ្រង់ត្រាស់គាថាព័ន្ធដទៃតទៅទៀតថា

ភពកើតឡើង ព្រោះឧបាទានជាបច្ច័យ សត្វដែលកើតហើយ រមែងបាននូវទុក្ខ មរណៈក៏កើតមាន ដល់សត្វដែលកើតហើយដែរ នេះជាសភាវៈកើតឡើងព្រមនៃទុក្ខ ។ ព្រោះហេតុនោះ

អ្នកប្រាជ្ញទាំងឡាយ មិនត្រឡប់មកកាន់ភពថ្មីវិញទៀត ព្រោះ
អស់ឧបាទាន ព្រោះដឹងត្រូវ ព្រោះជ្រាបច្បាស់នូវព្រះនិព្វាន
ជាទីអស់ទៅនៃជាតិ ។

[ ៨៧ ] ដោយបរិយាយដទៃទៀត មានដែរឬ ។បេ។ តើមានដូចម្ដេច ( ត្រូវប្រាប់ថា ) ទុក្ខនីមួយទាំងអស់ តែងកើតឡើងព្រោះព្យាយាម ( ដ៏សម្បយុត្តដោយកម្ម ) ជាបច្ច័យ នេះជាអនុបស្សនាទី ១ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ដោយប្រាសចាកតម្រេក មិនមានសេសសល់នៃព្យាយាម នេះជាអនុបស្សនាទី ២ ភិក្ខុអ្នកពិចារណាឃើញរឿយៗ នូវសភាពធម៌ដែលជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះឯង ។បេ។ ព្រះសាស្ដាទ្រង់ត្រាស់គាថាព័ន្ធដទៃតទៅទៀតថា

ទុក្ខនីមួយទាំងអស់តែងកើតឡើង ព្រោះព្យាយាមជាបច្ច័យ
ការមិនកើតឡើងនៃទុក្ខ ព្រោះរលត់នូវព្យាយាម ។ អ្នកប្រាជ្ញ
ជ្រាបនូវទោសនុ៎ះថា ទុក្ខកើតឡើង ព្រោះព្យាយាមជាបច្ច័យ
ហើយក៏លះបោល នូវព្យាយាមទាំងពួងចេញ កាលភិក្ខុជឿ
ស៊ប់ក្នុងព្រះនិព្វាន ជាដែនមិនមានព្យាយាម បានផ្ដាច់ផ្ដិលនូវ
តណ្ហាក្នុងភព មានចិត្តស្ងប់រម្ងាប់ហើយ ការអន្ទោលទៅកាន់
ជាតិ ក៏អស់រលីង ភិក្ខុនោះ មិនមានភពថ្មីទៀតឡើយ ។

[ ៨៨ ] ដោយបរិយាយដទៃទៀត មានដែរឬ ។បេ។ តើមានដូចម្ដេច ( ត្រូវប្រាប់ថា ) ទុក្ខនីមួយទាំងអស់ តែងកើតឡើងព្រោះអាហារជាបច្ច័យ

នេះជាអនុបស្សនាទី ១ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ដោយប្រាសចាកតម្រេក មិនមានសេសសល់នៃអាហារ នេះជាអនុបស្សនាទី ២ ភិក្ខុអ្នកពិចារណាឃើញរឿយៗ នូវសភាពធម៌ដែលជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះឯង ។បេ។ ព្រះសាស្ដាទ្រង់ត្រាស់គាថាព័ន្ធដទៃតទៅទៀតថា

*ទុក្ខនីមួយទាំងអស់តែងកើតឡើង ព្រោះអាហារជាបច្ច័យ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់អាហារ ។ អ្នកប្រាជ្ញលុះជ្រាបនូវទោសនុ៎ះថា ទុក្ខ ( កើតឡើង ) ព្រោះអាហារជាបច្ច័យ ហើយមិនអាស្រ័យ នូវអាហារទាំងពួង ព្រោះកំណត់ដឹងនូវអាហារទាំងពួង ជាអ្នកពិចារណាហើយ ទើបសេព ( បច្ច័យ ៤ ) តាំងនៅក្នុងសច្ចធម៌ មិនដល់នូវការរាប់ ( ថាជាមនុស្សឬទេវតា ) ព្រោះជ្រាបច្បាស់ដោយប្រពៃ នូវព្រះនិព្វាន ជាដែនមិនមានរោគ ព្រោះអស់នៃអាសវៈទាំងឡាយ ។*

[ ៨៩ ] ដោយបរិយាយដទៃទៀត មានដែរឬ ។បេ។ តើមានដូចម្ដេច ( ត្រូវប្រាប់ថា ) ទុក្ខនីមួយទាំងអស់ តែងកើតឡើងព្រោះធម៌ ជាគ្រឿងញាប់ញ័រជាបច្ច័យ នេះជាអនុបស្សនាទី ១ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ដោយប្រាសចាកតម្រេក មិនមានសេសសល់នៃធម៌ជាគ្រឿងញាប់ញ័រ នេះជាអនុបស្សនាទី ២ ភិក្ខុអ្នកពិចារណាឃើញរឿយៗ នូវសភាពធម៌ដែលជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះឯង ។បេ។ ព្រះសាស្ដាទ្រង់ត្រាស់គាថាព័ន្ធដទៃតទៅទៀតថា

ទុក្ខនីមួយទាំងអស់តែងកើតឡើង ព្រោះសេចក្ដីញាប់ញ័រជា
បច្ច័យ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់នៃសេចក្ដី
ញាប់ញ័រ ។ ភិក្ខុដឹងនូវទោសទុំះថា ទុក្ខ ( កើតឡើង ) ព្រោះ
សេចក្ដីញាប់ញ័រជាបច្ច័យ ព្រោះហេតុនោះ ភិក្ខុគប្បីលះបង់
តណ្ហា រម្ងាប់សង្ខារទាំងឡាយ ជាអ្នកមិនមានតណ្ហា មិនមាន
ឧបាទាន វៀរស្រឡះចាកសេចក្ដីញាប់ញ័រនោះ ។

[ ៩០ ] ដោយបរិយាយដទៃទៀត មានដែរឬ ។បេ។ តើមានដូចម្ដេច ( ត្រូវប្រាប់ថា ) សភាពញ័ររន្ធត់ តែងមានដល់បុគ្គលដែលអាស្រ័យ ( តណ្ហា មានះ ទិដ្ឋិ ) នេះជាអនុបស្សនាទី ១ បុគ្គលដែលមិនអាស្រ័យ ( តណ្ហា មានះ ទិដ្ឋិ ) រមែងមិនរន្ធត់ឡើយ នេះជាអនុបស្សនាទី ២ ភិក្ខុអ្នកពិចារណាឃើញរឿយៗ នូវសភាពធម៌ដែលជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះឯង ។បេ។ ព្រះសាស្ដាទ្រង់ត្រាស់គាថាព័ន្ធដទៃតទៅទៀតថា

បុគ្គលមិនអាស្រ័យ ( តណ្ហា មានះ ទិដ្ឋិ ) រមែងមិនរន្ធត់
បុគ្គលអ្នកអាស្រ័យនូវការប្រកាន់ រមែងមិនប្រព្រឹត្តកន្លង នូវ
ការអន្ទោលទៅកាន់អត្តភាពនេះ និងអត្តភាពដទៃ ។ ភិក្ខុដឹង
នូវទោសទុំះថាជាភ័យធំ ព្រោះការអាស្រ័យ ( តណ្ហា មានះ
ទិដ្ឋិ ) គប្បីជាបុគ្គលមិនអាស្រ័យ ( តណ្ហា មានះ ទិដ្ឋិ ) មិន
មានឧបាទាន មានសតិវៀរស្រឡះ ។

[ ៩១ ] ដោយបរិយាយដទៃទៀត មានដែរឬ ។បេ។ តើមានដូចម្ដេច

ម្នាលភិក្ខុទាំងឡាយ ពួកអរូបល្អិតជាងពួករូប នេះជាអនុបស្សនាទី ១ ព្រះនិព្វាន ជាធម៌ល្អិតជាងពួកអរូប នេះជាអនុបស្សនាទី ២ ភិក្ខុអ្នកពិចារណាឃើញរឿយៗ នូវសភាពធម៌ដែលជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះឯង ។បេ។ ព្រះសាស្តាទ្រង់ត្រាស់គាថាព័ន្ធដទៃតទៅទៀតថា

ពួកសត្វណា តាំងនៅក្នុងរូបភពក្តី ពួកសត្វណា តាំងនៅក្នុង អរូបភពក្តី ពួកសត្វទាំងនោះ មិនស្គាល់ច្បាស់នូវព្រះនិព្វាន ជាអ្នកត្រឡប់មកកាន់ភពថ្មីទៀត មួយទៀត ពួកជនណា កំណត់ដឹងក្នុងរូប មិនឋិតនៅក្នុងអរូប មានចិត្តជឿស៊ប់ក្នុងព្រះ និព្វាន ជនទាំងនោះ ឈ្មោះថា មានមច្ចុសាបសូន្យហើយ ។

[ ៩២ ] ដោយបរិយាយដទៃទៀត មានដែរឬ ។បេ។ តើមានដូចម្តេច ម្នាលភិក្ខុទាំងឡាយ នាម និងរូបណា ដែលលោក ព្រមទាំងទេវលោក មារ-លោក ព្រហ្មលោក ពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ពិនិត្យឃើញថានេះជារបស់ពិត តែនាម និងរូបនោះ ព្រះអរិយៈទាំងឡាយ ឃើញច្បាស់ដោយបញ្ញាដ៏ប្រពៃ តាមពិតថា នេះជារបស់មិនពិត នេះជាអនុបស្សនាទី ១ ម្នាលភិក្ខុទាំងឡាយ ព្រះនិព្វានណា ដែលលោក ព្រមទាំងទេវលោក ។បេ។ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសពិនិត្យឃើញថា នេះជារបស់មិនពិត តែព្រះនិព្វាននោះ ព្រះអរិយៈទាំងឡាយ ឃើញច្បាស់ដោយចក្ខុដ៏ប្រពៃ តាមពិតថា នុ៎ះជារបស់ពិត នេះជាអនុបស្សនាទី ២ ភិក្ខុអ្នកពិចារណាឃើញរឿយៗ នូវសភាពធម៌ដែល

ជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះឯង ។បេ។ ព្រះសាស្តាទ្រង់ត្រាស់គាថាព័ន្ធតទៅទៀតថា

អ្នកចូរមើលនូវលោក ព្រមទាំងទេវលោក ដែលតាំងនៅក្នុងនាម និងរូប បុគ្គលមានសេចក្តីសម្គាល់ថា ខ្លួនក្នុងរបស់ដែលមិនមែនខ្លួន តែងសម្គាល់ថានេះទៀង ។ ពួកសត្វតែងសម្គាល់ដោយរូបជាដើមណាៗ ថា ( រូបរបស់អញ វេទនារបស់អញ ) នាម និងរូបនោះ ទៅជារបស់ដទៃអំពីការសម្គាល់នោះ ព្រោះនាម និងរូបនោះ របស់សត្វនោះជារបស់មិនពិត ជាធម៌សោះសូន្យទទេ ។ ព្រះអរិយៈទាំងឡាយ ដឹងច្បាស់នូវព្រះនិព្វាននោះ ដែលជាធម៌មិនសោះសូន្យដោយពិត ទើបព្រះអរិយៈទាំងនោះមិនមានតណ្ហា បានដល់ព្រះនិព្វាន ព្រោះបានត្រាស់ដឹងនូវសច្ចធម៌ ។

[ ៩៣ ] ម្នាលភិក្ខុទាំងឡាយ ប្រសិនបើគេសួរថា ការពិចារណាឃើញរឿយៗ នូវសភាពធម៌ដែលជាគូនឹងគ្នា ដោយប្រពៃដទៃទៀត មានដែរឬ ត្រូវប្រាប់ថា មាន តើមានដូចម្តេច ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ទាំង ៦ ប្រការ មានរូបារម្មណ៍ជាដើមណា ដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ពិនិត្យឃើញថា នេះជាសុខ ឯអារម្មណ៍នោះ ព្រះអរិយៈទាំងឡាយឃើញច្បាស់ ដោយបញ្ញាដ៏ប្រពៃតាមពិតថា នេះជាទុក្ខវិញ នេះជាអនុ-

បស្សនាទី ១ ម្នាលភិក្ខុទាំងឡាយ ព្រះនិព្វានណា ដែលលោក ព្រមទាំងទេវ-លោក ។បេ។ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ពិនិត្យឃើញថានេះជាទុក្ខ ឯព្រះនិព្វាននោះ ព្រះអរិយៈទាំងឡាយ ឃើញច្បាស់ដោយបញ្ញាដ៏ប្រពៃតាមពិតថា នេះជាសុខវិញ នេះជាអនុបស្សនាទី ២ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកពិចារណាឃើញរឿយៗ នូវសភាពធម៌ដែលជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន បណ្ដាផលទាំងពីរ ផលណាមួយនឹងកើតប្រាកដ គឺនឹងបាននូវអរហត្តផលក្នុងបច្ចុប្បន្ន ឬមួយបើខន្ធដ៏សេស ដែលគប្បីកើតតទៅទៀតនៅមាន នឹងបានដល់នូវអនាគាមិផល ។ ព្រះមានព្រះភាគទ្រង់ត្រាស់ពាក្យនេះ លុះព្រះសុគតជាសាស្ដា ទ្រង់ត្រាស់ពាក្យនេះហើយ ទើបទ្រង់ត្រាស់គាថាព័ន្ធតទៅទៀតថា

រូប សំឡេង ក្លិន រស សម្ផស្ស ធម្មារម្មណ៍ ទាំងអស់ជាទីប្រាថ្នា ជាទីស្រឡាញ់ និងជាទីពេញចិត្ត លោកពោលថា មាននៅដរាបណា អារម្មណ៍ទាំងនុ៎ះ សត្វលោក ព្រមទាំងទេវលោកសន្មតថាជាសុខ ( ដរាបនោះ ) អារម្មណ៍ទាំងនោះ តែងរលត់ទៅ ក្នុងព្រះនិព្វានណា ព្រះនិព្វាននោះ ពួកសត្វលោកទាំងនោះ សន្មតថាជាទុក្ខវិញ ។ ការរលត់នូវសក្កាយ គឺខន្ធទាំង ៥ ព្រះអរិយៈទាំងឡាយ ឃើញថាជាសុខពិត ការឃើញ ( របស់ព្រះអរិយៈ ) អ្នកយល់នេះ ជាទំនាស់នឹងសត្វលោក

ទាំងពួង ។ ពួកជនពាលដទៃ ពោលនូវវត្ថុកាមណា ថាជាសុខ ព្រះអរិយៈទាំងឡាយ ពោលនូវវត្ថុកាមនោះ ថាជាទុក្ខ ពួកជនពាលដទៃ ពោលនូវព្រះនិព្វានណាថាទុក្ខ ព្រះអរិយៈទាំងឡាយ ដឹងច្បាស់នូវព្រះនិព្វាននោះ ថាជាសុខ អ្នកចូរឃើញនូវនិព្វានធម៌ ដែលដឹងបានដោយក្រ ពួកអ្នកមិនដឹងវង្វេងហើយក្នុងធម៌នុ៎ះ ។ សេចក្ដីងងឹតធ្វើនូវភាពខ្វាក់ តែងប្រាកដដល់ពួកជនពាល ដែលអវិជ្ជាបិទបាំង មិនឃើញនូវព្រះនិព្វាន ឯព្រះនិព្វានដូចជាពន្លឺ រមែងបើកបង្ហាញដល់ពួកសប្បុរសអ្នកឃើញ ពួកជនអ្នកមិនឈ្លាសវៃនូវធម៌ គឺព្រះនិព្វាន រមែងមិនដឹងច្បាស់ ( នូវព្រះនិព្វានសូម្បីមាន ) ក្នុងទីជិតឡើយ ។ ព្រះនិព្វាននេះ ពួកជនពាលដែលមានភវរាគៈ គ្របសង្កត់ហើយ កំពុងអន្ទោលទៅតាមខ្សែក្នុងភព កើតហើយក្នុងកន្លែងរបស់មារ មិនងាយនឹងត្រាស់ដឹងបានឡើយ ។ នរណាហ្ន៎ វៀរលែងតែព្រះអរិយៈចេញ គួរនឹងត្រាស់ដឹងនូវព្រះនិព្វានបាន ព្រះអរហន្តទាំងឡាយ មិនមានអាសវធម៌ បរិនិព្វានហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃ នូវព្រះនិព្វាន ។

[ ៩៤ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់សូត្រនេះរួចហើយ ។ ភិក្ខុទាំងនោះក៏មានចិត្តត្រេកអរ រីករាយនឹងភាសិត របស់ព្រះមានព្រះភាគ ។ កាល

ដែលព្រះមានព្រះភាគ ទ្រង់ពោលវេយ្យាករណ៍នេះ ពួកភិក្ខុប្រមាណ ៦០ រូប មានចិត្តរួចស្រឡះចាកអាសវធម៌ ព្រោះមិនមានឧបាទាន ។

ទ្វយតានុបស្សនាសូត្រទី ១២ ចប់

### ឧទ្ទានក្នុងទ្វយតានុបស្សនាសូត្រនោះគឺ

និយាយអំពីចតុរារិយសច្ច ១ ឧបធិ ១ អវិជ្ជា១ សង្ខារ ១ វិញ្ញាណ ១ ជាគម្រប់ប្រាំ ផស្សៈ ១ វេទនា ១ តណ្ហា ១ ឧបាទាន ១ អារម្ភៈ ( ព្យាយាម ) ១ អាហារ ១ សេចក្តីញាប់ញ័រ ១ ការរន្ធត់ ១ រូប ១ សច្ចៈ ១ ទុក្ខ ១ ជា ១៦ ។

មហាវគ្គទី ៣ ចប់

### ឧទ្ទាននៃមហាវគ្គនោះគឺ

និយាយអំពីបព្វជ្ជាសូត្រ ១ បធានសូត្រ ១ សុភាសិតសូត្រ ១ សុន្ទរិកភារទ្វាជសូត្រ ១ មាឃសូត្រ ១ សភិយសូត្រ ១ សេលសូត្រ ១ សល្លសូត្រ ១ សេដ្ឋសូត្រ ១ កោកាលិកសូត្រ ១ នាឡកសូត្រ ១ ទ្វយតានុបស្សនាសូត្រ ១ សូត្រទាំង ១២ នុ៎ះ ហៅថា មហាវគ្គ ។

# អដ្ឋកថា

## ទ្វយតានុបស្សនាសូត្រ

[ ៧៧ ] ទ្វយតានុបស្សនាសូត្រទី ១២ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះ ។

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅនេះ

ព្រះសូត្រនេះកើតឡើង ព្រោះព្រះអជ្ឈាស្រ័យរបស់ព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់សម្ដែងព្រះសូត្រនេះ ដោយព្រះអជ្ឈាស្រ័យរបស់ព្រះអង្គ ។ នេះជាសេចក្ដីសង្ខេបក្នុងព្រះសូត្រនេះ ។ ឯសេចក្ដីពិស្ដាររបស់សូត្រនេះ នឹងមានច្បាស់ក្នុងអដ្ឋកថានោះឯង ។

ក្នុងបទទាំងនោះ បទថា **ឯវម្មេ សុតំ** ជាដើម មានន័យដូចពោលមកហើយ ។ បទថា **បុព្វារាមេ** គឺអារាមដែលនៅទិសខាងកើតនៃក្រុងសាវត្ថី ។ ក្នុងបទថា **មិគារមាតុ បាសាទេ** នេះ សេចក្ដីថា នាងវិសាខាឧបាសិកា លោកហៅថា **មិគារមាតា** ព្រោះមិគារសេដ្ឋីជាឪពុកក្មេករបស់នាង លើកនាងទុកក្នុងឋានៈជាមាតា នាងវិសាខាមិគារមាតានោះ លះបង់នូវគ្រឿងប្រដាប់មហាលតាមានតម្លៃ ៩ កោដិ សាងប្រាសាទ មានបន្ទប់ខាងលើជាផ្ទះកំពូល ១០០០ បន្ទប់ គឺខាងក្រោម ៥០០ បន្ទប់ ខាងលើ ៥០០ បន្ទប់ ទើបហៅប្រាសាទនោះថា ប្រាសាទរបស់នាងវិសាខាមិគារមាតា ។ លើប្រាសាទរបស់នាងវិសាខាមិគារមាតានោះ ។ បទថា **តេន ខោ បន សមយេន ភគវា** សេចក្ដីថា សម័យដែលព្រះមានព្រះភាគ ទ្រង់អាស្រ័យក្រុងសាវត្ថី

គង់នៅក្នុងបុព្វារាម ដែលជាប្រាសាទរបស់នាងវិសាខាមិគារមាតា ។ បទថា **តទហុបោសថេ** កាត់បទជា **តំ អហុ ឧបោសថេ** គឺក្នុងថ្ងៃឧបោសថ ។ បទថា **បណ្ណរសេ** នេះ ជាពាក្យបដិសេធថ្ងៃឧបោសថដ៏សេស ដែលមកដល់ដោយ **ឧបោសថ** សព្ទ ។ បទថា **បុណ្ណាយ បុណ្ណមាយ រត្តិយា** សេចក្ដីថា កាលរាត្រីពេញបូណ៌មី ព្រោះជាថ្ងៃ ១៥ កើត ដោយការរាប់ថ្ងៃ ព្រោះវៀរចាកការសៅហ្មង មានពពកជាដើម ព្រោះពេញដោយគុណសម្បត្តិនៃរាត្រី និងព្រោះមានព្រះចន្ទពេញវង់ ។ បទថា **ភិក្ខុសង្ឃបរិវុតោ** គឺដែលពួកភិក្ខុចោមរោមហើយ ។ បទថា **អព្ភោកាសេ និសិន្នោ ហោតិ** សេចក្ដីថា ព្រះមានព្រះភាគគង់ក្នុងទីវាល ដែលជាបរិវេណនៃរតនប្រាសាទរបស់នាងវិសាខាមិគារមាតា គឺក្នុងពុទ្ធាសនៈ ដែលគេក្រាលក្នុងស្ថានទីដែលមិនមានអ្វីប្រក់បាំងខាងលើ ។ បទថា **តុណ្ហីភូតំ តុណ្ហីភូតំ** គឺភិក្ខុសង្ឃស្ងប់ស្ងៀម សូម្បីកាយក៏ស្ងប់ចាកការក្រឡេកមើលឆ្វេងស្ដាំ ។ បទថា **ភិក្ខុសង្ឃំ អនុវិលោកេត្វា** សេចក្ដីថា ទ្រង់ឆ្មៀងមើលភិក្ខុសង្ឃច្រើនពាន់រូបដែលអង្គុយចោមរោមព្រះអង្គ ស្ងប់ស្ងៀម ដើម្បីទ្រង់កំណត់ព្រះធម្មទេសនាដែលជាទីសប្បាយថា ក្នុងទីនេះ មានសោតាបន្នប្រមាណប៉ុណ្ណេះ មានសកទាគាមីប្រមាណប៉ុណ្ណេះ មានអនាគាមីប្រមាណប៉ុណ្ណេះ មានកល្យាណបុថុជ្ជនអ្នកផ្ដើមចម្រើនវិបស្សនាប្រមាណប៉ុណ្ណេះ ធម្មទេសនាដូចម្ដេច ទើបជាទីសប្បាយរបស់ភិក្ខុសង្ឃទាំងនេះ ដូច្នេះ ។

បទថា **យេ តេ ភិក្ខវេ កុសលា ធម្មា** សេចក្ដីថា ពោធិបក្ខិយធម៌ ៣៧

ឬបរិយត្តិធម៌ដែលធ្លុះបញ្ចាំងនូវពោធិបក្ខិយធម៌នោះ ឈ្មោះថា ជាកុសល ព្រោះអត្ថថា មិនមានរោគ មិនមានទោស មានផលគួរប្រាថ្នា កើតអំពីការឈ្លាស ។ បទថា **អរិយា និយ្យានិកា សម្ពោធិគាមិនោ** សេចក្តីថា ឈ្មោះថា **អរិយា** ព្រោះគួរចូលដល់ ឈ្មោះថា **និយ្យានិកា** ព្រោះនាំចេញទៅចាកលោក ឈ្មោះថា **សម្ពោធិគាមិនោ** ព្រោះឲ្យបានសម្រេចអរហត្ត ។

គាថាថា ម្នាលភិក្ខុទាំងឡាយ ប្រសិនបើមានគេសួរអ្នកទាំងឡាយថា ប្រយោជន៍អ្វីដល់អ្នកទាំងឡាយ ក្នុងកិរិយាស្តាប់នូវកុសលធម៌ទាំងឡាយនោះ ដែលជាអរិយធម៌ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅ ដើម្បីសម្ពោធិញ្ញាណ លោកអធិប្បាយថា អ្វីជាទីតាំង អ្វីជាហេតុ អ្វីជាប្រយោជន៍នៃការស្តាប់ធម៌របស់អ្នកទាំងឡាយ អ្នកទាំងឡាយស្តាប់ធម៌ទាំងនោះដើម្បីអ្វី ។ បទថា **យាវទេវ** ក្នុងបទថា **យាវទេវ ទ្វយតានំ ធម្មានំ យថាភូតំ ញាណាយ** នេះ ជាពាក្យប្រាប់ដែនកំណត់ ។ ធម៌ ឈ្មោះថា **ទ្វយា** ព្រោះមានចំណែកប្រកប ២ យ៉ាង ។ ធម៌ ២ យ៉ាងនោះឯង ឈ្មោះថា **ទ្វយតា** ។ ធម៌ ២ យ៉ាងនោះ ។ បាឋៈថា **ទ្វយានំ** ដូច្នេះក៏មាន ។ បទថា **យថាភូតំ ញាណាយ** គឺដើម្បីដឹងមិនខុស ។ សួរថា លោកអធិប្បាយដូចម្តេច ឆ្លើយថា លោកអធិប្បាយថា ការដឹងតាមសេចក្តីពិតនោះ បានដល់ ឃើញច្បាស់នូវធម៌ដែលលោកកំណត់ ២ យ៉ាង មានលោកិយ និងលោកុត្តរជាដើម ដើម្បីជាប្រយោជន៍ដល់ការត្រាស់ដឹងតាមសេចក្តីពិតនោះ មិនក្រៃលែងជាងនោះ ព្រោះហេតុនោះ ធម៌ប្រមាណប៉ុណ្ណេះ រមែងមានដោយការស្តាប់ ការ

សម្រេចគុណវិសេសក្រៃលែងជាងនោះ រមែងមានដោយការភាវនា ។

ក្នុងបទថា **កិញ្ច ទ្វយតំ វទេថ** នេះ អធិប្បាយថា ម្នាលភិក្ខុទាំងឡាយ បើមានបុគ្គលសួរថា លោកដ៏ចម្រើន លោកពោលអ្វី ថាជាធម៌ ២ យ៉ាង ។ សេចក្ដីថា លោកទាំងឡាយពោលភាពជាធម៌ ២ យ៉ាង គឺអ្វី ។ គ្រានោះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងភាពជាធម៌ ២ យ៉ាង ទើបត្រាស់ពាក្យជាដើមយ៉ាងនេះថា **ឥទំ ទុក្ខំ** ។ ក្នុងបទនោះ ធម៌ គឺអរិយសច្ច ៤ ជាធម៌ ២ ចំណែក ការពិចារណាឃើញរឿយៗ ដោយការឃើញទុក្ខមួយអន្លើដោយហេតុ ដែលជាចំណែកមួយនៃលោកិយយ៉ាងនេះថា នេះទុក្ខ នេះហេតុឲ្យកើតទុក្ខ នេះជាប្រការមួយ ។ ការពិចារណាឃើញរឿយៗ ដោយការឃើញនិរោធ ព្រមដោយឧបាយដែលជាចំណែកទី ២ នៃលោកុត្តរដែលជារបស់ទី ២ ។ មួយវិញទៀត ក្នុងបទនេះ ប្រការទី ១ សម្រេចបានដោយវិសុទ្ធិទី ៣ ទី ៤ ប្រការទី ២ សម្រេចដោយវិសុទ្ធិទី ៥ ។ បទថា **ឯវំ សម្មា ទ្វយតានុបស្សិនោ** សេចក្ដីថា ភិក្ខុពិចារណាឃើញធម៌ ២ យ៉ាង ដោយប្រពៃ តាមន័យដែលពោលហើយនេះ ឈ្មោះថា **អប្បមត្តស្ស** ព្រោះមិននៅប្រាសចាកសតិ ឈ្មោះថា **អាតាបិនោ** ព្រោះមានសេចក្ដីព្យាយាមដុតនូវកិលេសផ្លូវកាយ និងផ្លូវចិត្ត ឈ្មោះថា **បហិតត្តស្ស** ព្រោះអស់នូវការសម្លឹងក្នុងកាយ និងជីវិត ។ បទថា **បាដិកង្ខំ** គឺសង្ឃឹមបាន ។ បទថា **ទិដ្ឋេវ ធម្មេ អញ្ញា** បានដល់ អរហត្តផលក្នុងអត្តភាពនេះ ។ បទថា **សតិ វា ឧបាទិសេសេ អនាគាមិតា** សេចក្ដីថា នៅមានការប្រកាន់មាំក្នុងខន្ធដ៏សេស

ដោយកើតទៀត លោកហៅថា បើខន្ធដ៏សេសដែលគប្បីកើតតទៅទៀតនៅមាន លោកសម្តែងថា កាលនៅមាន ការប្រកាន់មាំសេសសល់នោះ គប្បីសង្ឃឹមនូវភាពជាព្រះអនាគាមី ។ ក្នុងបទនោះ សូម្បីផលខាងក្រោមក៏គង់មានដល់ភិក្ខុដែលពិចារណាឃើញនូវធម៌ជាធម៌ ២ យ៉ាងរឿយៗ យ៉ាងនេះក៏ពិត តែព្រះមានព្រះភាគ កាលញ៉ាំងនូវឧស្សាហ៍ឲ្យកើតក្នុងផលខាងលើទើបត្រាស់យ៉ាងនេះ ។

បទថា **ឥទមវោច** នេះជាពាក្យរបស់ព្រះសង្គីតិកាចារ្យទាំងឡាយ ។ ក្នុងបទទាំងនោះ បទថា **ឥធំ** ជាពាក្យសម្តែងដល់ព្រះតម្រាស់ ដែលទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ប្រសិនបើមានគេសួរអ្នកទាំងឡាយថា ប្រយោជន៍អ្វីដល់អ្នកទាំងឡាយ ក្នុងកិរិយាស្តាប់នូវកុសលធម៌ទាំងឡាយនោះជាដើម ។ បទថា **ឯតំ** ជាបទសម្តែងគាថាពន្ធ ដែលទ្រង់ត្រាស់យ៉ាងនេះថា ជនពួកណា មិនដឹងច្បាស់នូវទុក្ខ ដូច្នេះ ។ ម្យ៉ាងទៀត គាថានេះ ក៏សម្តែងរឿងដែលត្រាស់ហើយនោះឯង ព្រោះសម្តែងសច្ចៈ ៤ ដូចគ្នា ។ តែទោះជាយ៉ាងនោះ ព្រះមានព្រះភាគក៏ត្រាស់ជាគាថាទៀត ដើម្បីប្រយោជន៍ដល់បុគ្គលដែលកើតខាងក្រោយ ដែលគាប់ចិត្តក្នុងពាក្យជាគាថា ១ បុគ្គលដែលកំណត់ការដែលត្រាស់ទុកមុនមិនទាន់ ព្រោះមិនមានសមត្ថភាព សង្ស័យថា ឥឡូវនេះ បើត្រាស់ជាគាថាទុកក៏ល្អ គឺចាំបានងាយ ១ បុគ្គលដែលមានចិត្តរាយមាយ ក្នុងកាលទ្រង់ត្រាស់ព្រះតម្រាស់ដំបូង ១ ។ ម្យ៉ាងទៀត គាថាក៏ចន្លុលប្រយោជន៍ដែលល្អក្រៃលែងឡើង ព្រោះចន្លុលប្រាប់ទាំងបុគ្គលមិនឃើញ

ច្បាស់ និងបុគ្គលឃើញច្បាស់ ចង្អុលបង្ហាញផ្លូវ និងមិនមែនផ្លូវ ( វដ្តៈ និង វិវដ្តៈ ) ដល់ជនទាំងនោះ ព្រោះហេតុនោះ ទើបត្រាស់គាថាដើម្បីសម្តែង បំណងដ៏ប្រសើរនេះឯង ។ ក្នុងពាក្យដែលជាគាថាដទៃ បន្ទាប់អំពីនេះ ក៏មាន ន័យដូចគ្នានេះ ព្រោះសម្តែងដល់បុគ្គលដែលមិនឃើញច្បាស់ និងបុគ្គលឃើញ ច្បាស់ហើយ សម្តែងដល់វដ្តៈ វិវដ្តៈដែលកាត់ដាច់ និងមិនទាន់កាត់ដាច់ របស់លោកទាំងនោះថា លោកពោលសម្តែងដល់អត្ថដែលផ្សេងគ្នា ដើម្បីជា ប្រយោជន៍ដល់បុគ្គលដែលគាប់ចិត្តក្នុងគាថា ដែលមកខាងក្រោយ បំណង អនុគ្រោះ ព្រោះមិនអាចដឹងមកអំពីមុនបានថា ឥឡូវនេះ បើពោលក៏ល្អ និង ដល់បុគ្គលដែលមានចិត្តរាយមាយមកអំពីមុន ព្រោះហេតុនោះ ទើបត្រាស់ គាថានេះ ដើម្បីសម្តែងអត្ថដែលផ្សេងគ្នានោះឯង ។ ក្នុងគាថាវចនៈក្រៅអំពី នេះ ក៏មានន័យដូចគ្នា ។

[ ៧៨ ] ក្នុងបទទាំងនោះ បទថា **យត្ថ** លោកសម្តែងដល់និព្វាន ព្រោះទុក្ខរមែងរលត់ទៅក្នុងនិព្វាន ដោយប្រការទាំងពួង ទុក្ខរមែងរលត់ទៅ សព្វគ្រប់ប្រការ ទុក្ខ មួយអន្លើដោយហេតុរមែងរលត់ ទុក្ខរមែងរលត់ទៅ មិនមានសេសសល់ ។ បទថា **តញ្ច មគ្គំ** បានដល់ មគ្គមានអង្គ ៨ នោះ ។ ក្នុងបទថា **ចេតោវិមុត្តិហីនា តេ អថោ បញ្ញាវិមុត្តិយា** នេះ គប្បីជ្រាបថា អរហត្តផលសមាធិ ជាចេតោវិមុត្តិ ព្រោះខ្ជាក់នូវរាគៈ អរហត្តផលប្បញ្ញា ដែលជាបញ្ញាវិមុត្តិ ព្រោះខ្ជាក់នូវអវិជ្ជា ។

ម្យ៉ាងទៀត អរហត្តផល ដែលតណ្ហាចរិតបុគ្គលសង្កត់កិលេសទាំងឡាយ

ដោយផលនៃអប្បនាឈានហើយ ទើបសម្រេច ឈ្មោះថា ចេតោវិមុត្តិ ព្រោះខ្វាក់នូវរាគៈ ។ អរហត្តផលដែលទិដ្ឋិចរិតបុគ្គលញុំាងត្រឹមតែឧបចារជ្ឈានឲ្យកើត ឃើញច្បាស់ហើយ ទើបសម្រេច ឈ្មោះថា បញ្ញាវិមុត្តិ ព្រោះខ្វាក់នូវអវិជ្ជា ។ម្យ៉ាងទៀត អនាគាមិផល ឈ្មោះថា **ចេតោវិមុត្តិ** ព្រោះខ្វាក់ចោលនូវរាគៈ គឺកាមរាគៈ អរហត្តផល ឈ្មោះថា **បញ្ញាវិមុត្តិ** ព្រោះខ្វាក់ចោលនូវអវិជ្ជា ដោយអាការទាំងពួង ។

បទថា **អន្តកិរិយាយ** គឺដើម្បីធ្វើទីបំផុតនៃទុក្ខក្នុងវដ្តៈ ។ បទថា **ជាតិជរូបគា** បានដល់ ជាតិ និងជរា ឬដែលជាតិ និងជរាចូលដល់ រមែងមិនផុតចាកជាតិ និងជរា គប្បីជ្រាបយ៉ាងនេះ ដោយប្រការដូច្នេះ ។ បទដ៏សេសក្នុងគាថានេះ ប្រាកដច្បាស់ហើយ ។

កាលចប់គាថា ភិក្ខុប្រមាណ ៦០ រូប ទទួលនូវទេសនានោះហើយ ក៏ឃើញច្បាស់ គឺសម្រេចអរហត្តក្នុងអាសនៈនោះឯង ។ ក្នុងវារៈទាំងអស់ដូចក្នុងបទនេះ ។

លំដាប់នោះ ព្រះមានព្រះភាគត្រាស់ទូយតានុបស្សនា គឺការពិចារណាឃើញនូវធម៌ ២ ដោយន័យជាដើមថា **សិយា អញ្ញេនាបិ បរិយាយេន** ដូច្នេះ ។

[ ៧៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ២ បទថា **ឧបធិប្បច្ចយា** គឺព្រោះកម្មមានអាសវៈជាបច្ច័យ ។ ពិតហើយ កម្មដែលមានអាសវៈ លោកបំណងយកថាជាឧបធិក្នុងទីនេះ ។ បទថា **អសេសវិរាគនិរោធា** បានដល់

ព្រោះឧបធិទាំងឡាយរលត់ទៅ ព្រោះការខ្ចាក់ដោយឥតសេសសល់ ឬព្រោះឧបធិទាំងឡាយរលត់ទៅ ពោល គឺខ្ចាក់ដោយមិនសេសសល់ ។ បទថា **ឧបធិនិទានា** គឺព្រោះកម្មជាបច្ច័យ ។ បទថា **ទុក្ខស្ស ជាតិប្បភវានុបស្សី** គឺពិចារណាឃើញរឿយៗ ថា ឧបធិជាហេតុនៃវដ្តទុក្ខ ។ បទដ៏សេស ក្នុងវារៈនេះ មានសេចក្តីប្រាកដជាក់ច្បាស់ទាំងអស់ហើយ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងអរិយសច្ច ៤ ហើយត្រាស់វារៈនេះ ដោយកំពូលនៃធម៌ គឺអរហត្ត ដោយប្រការដូច្នេះ ។ វារៈទាំងអស់ ដូចវារៈនេះ ។

[ ៨០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ៣ ដូចតទៅនេះ បទថា **អវិជ្ជា-បច្ចយា** សេចក្តីថា ទុក្ខណាមួយ រមែងកើតឡើងព្រោះអវិជ្ជា សន្សំកម្ម ដែលជាហេតុឲ្យកើតបច្ច័យ ។ តែទុក្ខក្នុងទីទាំងអស់ ជាវដ្តទុក្ខប៉ុណ្ណោះ ។ បទថា **ជាតិមរណសំសារំ** អធិប្បាយថា ជាតិ គឺការកើតនៃខន្ធ មរណៈ គឺការបែកទៅនៃខន្ធ សង្សារ គឺការបន្តនៃខន្ធ ។ បទថា **វជន្តិ** បានដល់ ទៅ គឺចូលដល់ ។ បទថា **ឥត្ថភាវញ្ញថាភាវំ** គឺភាពជាមនុស្សនេះ និងភាពជាពួក ( សត្វ ) ដទៃចាកភាពជាមនុស្សនេះ ។ បទថា **គតិ** គឺភាពជាបច្ច័យ ។ បទថា **អវិជ្ជា ហាយំ** កាត់បទជា **អវិជ្ជា ហិ អយំ** ។ បទថា **វិជ្ជាគតា ច យេ សត្តា** សេចក្តីថា សត្វពួកណា ទម្លាយកិលេសដោយវិជ្ជាក្នុងអរហត្តមគ្គ ហើយ ជាសត្វដែលអស់អាសវៈហើយ ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។

[ ៨១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ៤ បទថា **សង្ខារប្បច្ចយា** គឺព្រោះបុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អនេញ្ជាភិសង្ខារ ( ជាបច្ច័យ ) ។ បទថា **ឯតមាទីនវំ ញត្វា** គឺដឹងថា នេះទុក្ខ នេះទោស ព្រោះសង្ខារជាបច្ច័យ ។ បទថា **សព្វសង្ខារសមថា** គឺឈ្មោះថា ស្ងប់សង្ខារទាំងអស់ ដូចបានពោលហើយ ដោយមគ្គញាណ អធិប្បាយថា ព្រោះកម្ចាត់ ព្រោះរម្ងាប់ផល ។ បទថា **សញ្ញានំ** គឺព្រោះសញ្ញា មានកាមសញ្ញាជាដើម រលត់ដោយមគ្គនោះឯង ។ បទថា **ឯតំ ញត្វា យថាតថំ** គឺដឹងនូវការអស់ទៅនៃទុក្ខដោយមិនវិបរិត ។ បទថា **សម្មទ្ទសា** គឺឃើញដោយប្រពៃ ។ បទថា **សម្មទញ្ញាយ** គឺដឹងសង្ខតធម៌ដោយភាពជារបស់មិនទៀង និងដឹងអសង្ខតធម៌ដោយភាពជារបស់ទៀង ។ បទថា **មារសំយោគំ** គឺវដ្តៈ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។

[ ៨២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ៥ បទថា **វិញ្ញាណប្បច្ចយា** គឺព្រោះវិញ្ញាណតាក់តែងឲ្យកើតរួមជាមួយកម្មប្បច្ច័យ ។ បទថា **និច្ឆាតោ** គឺអស់នូវការចង់បាន ។ បទថា **បរិនិព្វុតោ** គឺជាអ្នករម្ងត់ជុំវិញ ដោយការរម្ងត់កិលេស ។ បទដ៏សេស មានអត្ថប្រាកដជាក់ច្បាស់ហើយ ។

[ ៨៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ៦ បទថា **ផស្សប្បច្ចយា** អធិប្បាយថា ព្រោះផស្សៈដែលសម្បយុត្តដោយអភិសង្ខារ និងវិញ្ញាណជាបច្ច័យ ក្នុងទីនេះ លោកពោលដល់ផស្សៈ មិនបានពោលដល់នាមរូប និងសឡាយតនៈនោះទេ គួរនឹងពោលតាមលំដាប់ ព្រោះនាមរូប និងសឡាយតនៈ

ទាំងនោះ មិនបានសម្បយុត្តដោយកម្មឡើយ ព្រោះលាយឡំនឹងរូប ម្យ៉ាងទៀត វេទ្ទុក្ខនេះ គប្បីកើតអំពីកម្ម ឬអំពីធម៌ដែលសម្បយុត្តដោយកម្ម ។ បទថា **ភវសោតានុសារិនំ** គឺស្ទុះទៅតាមតណ្ហា ។ បទថា **បរិញ្ញាយ** គឺកំណត់ដោយបរិញ្ញា ៣ ។ បទថា **បញ្ញាយ** គឺដឹងដោយអរហត្តមគ្គប្បញ្ញា ។ បទថា **ឧបសមេ រតា** គឺត្រេកអរហើយក្នុងនិព្វាន ដោយអំណាចផលសមាបត្តិ ។ បទថា **ផស្សាភិសមយា** គឺព្រោះផស្សៈរលត់ទៅ ។ បទដ៏សេស មានអត្ថប្រាកដច្បាស់ហើយ ។

[ ៨៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ៧ បទថា **វេទនាបច្ចយា** គឺព្រោះវេទនាសម្បយុត្តដោយកម្មជាបច្ច័យ ។ បទថា **អទុក្ខមសុខំ សហា** គឺជល់ព្រមដោយអទុក្ខមសុខវេទនា ។ បទថា **ឯតំ ទុក្ខន្តិ ញត្វាន** គឺដឹងថាការសោយអារម្មណ៍ទាំងពួងនោះ ជាហេតុនៃទុក្ខ ឬដឹងថា ទុក្ខ ព្រោះការប្រែប្រួលទៅ មិនមាំទាំ និងភាពជាទុក្ខ ព្រោះមិនដឹង ។ បទថា **មោសធម្មំ** គឺមានការសោះសូន្យទៅជាធម្មតា ។ បទថា **បលោកិនំ** គឺមានការទ្រុឌទ្រោមទៅដោយជរា និងមរណៈ ជាធម្មតា ។ បទថា **ផុស្ស ផុស្ស** គឺពាល់ត្រូវហើយ ដោយឧទយព្វយញ្ញាណ ។ បទថា **វយំ បស្សំ** គឺឃើញនូវការបែកធ្លាយក្នុងទីបំផុតនោះឯង ។ បទថា **ឯវំ តត្ថ វិជ្ជានតិ** គឺដឹងច្បាស់នូវវេទនានោះយ៉ាងនេះ ឬដឹងច្បាស់នូវភាពជាទុក្ខក្នុងវេទនានោះ ។ បទថា **វេទនានំ ខយា** គឺខាងមុខអំពីនោះ ព្រោះវេទនាសម្បយុត្តដោយកម្មអស់ទៅដោយមគ្គញាណ ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។

[ ៨៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ៨ បទថា **តណ្ហាបច្ចយា** គឺព្រោះតណ្ហាសន្សំកម្មជាបច្ច័យ ។ បទថា **ឯតមាទីនវំ ញត្វា តណ្ហា ទុក្ខស្ស សម្ភវំ** គឺដឹងទោសរបស់តណ្ហានោះ ថាជាហេតុនៃទុក្ខ ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ៩ បទថា **ឧបាទានប្បច្ចយា** គឺព្រោះឧបាទានសន្សំកម្មជាបច្ច័យ ។ បទថា **ភវោ** បានដល់ មានភពជាវិបាក គឺការប្រាកដនៃខន្ធ ។ បទថា **ភូតោ ទុក្ខំ** គឺសត្វដែលកើតហើយ ឧប្បត្តិកហើយ រមែងចូលដល់ទុក្ខ ។ បទថា **ជាតស្ស មរណំ** សេចក្តីថា ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់ទុក្ខប៉ុណ្ណោះ ក្នុងកាលបុគ្គលពាលទាំងឡាយសម្គាល់ថា កើតហើយ រមែងចូលដល់សុខ ទើបត្រាស់ថា **ជាតស្ស មរណំ ហោតិ ។** គប្បីប្រកបសេចក្តីក្នុងគាថាទី ២ ថា បណ្ឌិតទាំងឡាយដឹងហើយដោយប្រពៃ ដោយការមិនទៀងជាដើម ដឹងដ៏ក្រៃលែងនូវនិព្វានថាជាការអស់ជាតិ ព្រោះអស់ឧបាទានហើយ រមែងមិនទៅកាន់ភពថ្មី ។

[ ៨៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ១០ បទថា **អារម្ភប្បច្ចយា** គឺព្រោះការព្យាយាមដែលសម្បយុត្តដោយកម្មជាបច្ច័យ ។ បទថា **អនារម្ភេ វិមុត្តិនោ** បានដល់ បង្អោនទៅក្នុងព្រះនិព្វានដែលមិនមានការផ្តើម ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។

[ ៨៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ១១ បទថា **អាហារប្បច្ចយា** គឺព្រោះអាហារសម្បយុត្តដោយកម្មជាបច្ច័យ ។ អាចារ្យមួយពួកពោលថា សត្វ

៤ ប្រភេទ គឺរូបូបគា ( ចូលដល់រូប ) ១ វេទនូបគា ១ សញ្ញូបគា ១ សង្ខារូបគា ១ ។

ក្នុងសត្វ ៤ ប្រភេទនោះ សត្វដែលជាប់ជំពាក់ដោយកាមធាតុ ១១ ឈ្មោះថា **រូបូបគា** ព្រោះសេពនូវកពឡិង្ការាហារ ។ សត្វដែលជាប់ជំពាក់ដោយរូបធាតុ វៀរអសញ្ញីសត្វ ឈ្មោះថា **វេទនូបគា** ព្រោះសេពនូវផស្សាហារ ។ សត្វដែលជាប់ជំពាក់ដោយរូបធាតុ ៣ យ៉ាងខាងក្រោម ឈ្មោះថា **សញ្ញូបគា** ព្រោះសេពនូវមនោសញ្ចេតនាហារដែលកើតអំពីសញ្ញា សត្វក្នុងអគ្គភូមិ គឺនេវសញ្ញានាសញ្ញាយតនភូមិ ឈ្មោះថា **សង្ខារូបគា** ព្រោះសេពនូវវិញ្ញាណាហារដែលកើតអំពីសង្ខារ ។ គប្បីជ្រាបថា ទុក្ខណាមួយកើតឡើងព្រោះអាហារជាបច្ច័យ ។ បទថា **អារោគ្យំ** គឺនិព្វាន ។ បទថា **សង្ខាយ សេវី** សេចក្ដីថា ពិចារណាបច្ច័យ ហើយសេពបច្ច័យ ៤ ឬពិចារណាលោកយ៉ាងនេះថា ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ដូច្នេះហើយ សេពនូវញាណថា **អនិច្ចំ ទុក្ខំ អនត្តា** ដូច្នេះ ។ បទថា **ធម្មដ្ឋោ** គឺតាំងនៅក្នុងសច្ចៈ ៤ ។ បទថា **សង្ខ្យំ នោបេតិ** គឺមិនចូលដល់ការរាប់ថាជាទេវតា ឬជាមនុស្សជាដើម ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។

[ ៨៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ១២ បទថា **ឥញ្ជិតប្បច្ចយា** គឺព្រោះក្នុងបណ្ដា **ឥញ្ជិត** ( ការញាប់ញ័រ ) គឺតណ្ហា មានះ ទិដ្ឋិ កម្ម និងកិលេស ការញាប់ញ័រឯណាមួយសន្សំកម្មជាបច្ច័យ ។ បទថា **ឯជំ វោស្សជ្ជ** គឺលះតណ្ហា ។ បទថា **សង្ខារេ ឧបរុន្ធិយា** គឺរម្ងត់កម្ម និងសង្ខារ ដែល

សម្បយុត្តដោយកម្ម ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ១៣ បទថា **និស្សិតស្ស ចលិតំ** គឺការអន្ទះអន្ទែង ព្រោះការខ្វាច រមែងមានដល់បុគ្គលដែលតណ្ហា មានះ និងទិដ្ឋិអាស្រ័យហើយក្នុងខន្ធ ដូចការអន្ទះអន្ទែងព្រោះការខ្វាច រមែងមានដល់ទេវតាទាំងឡាយក្នុងសីហសូត្រ ដូច្នោះ ។ បទដ៏សេសមានអត្ថយល់ហើយ ។

[ ៩១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ១៤ បទថា **រូបេហិ** គឺជាងរូបកពឬជាងរូបសមាបត្តិ ។ បទថា **អារុប្បា** គឺអរូបកព ឬអរូបសមាបត្តិ ។ បទថា **និរោធោ** គឺព្រះនិព្វាន ។ បទថា **មច្ចុហាយិនោ** គឺជាអ្នកលះមរណមច្ចុ កិលេសមច្ចុ និងទេវបុត្តមច្ចុចេញបាន ។ លោកអធិប្បាយថា លះមច្ចុ ៣ យ៉ាងនោះបាន ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។

[ ៩២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ១៥ បទថា **យំ** ទ្រង់ពោលសំដៅដល់នាមរូប ព្រោះនាមរូបនោះ ដែលសត្វលោកចូលទៅសម្គាល់ឃើញថា នេះជារបស់ពិត ដោយការស្ថិតស្ថេរ ស្អាត សុខ ។ បទថា **តទមរិយានំ** កាត់បទជា **តំ អមំ អរិយានំ** លុបនិគ្គហិត និង **អ** អក្ខរៈ ជា **តំ អមំ** ទើបសន្ធិជា **តទ**។ បទថា **ឯតំ មុសា** គឺនាមរូបនោះ សូម្បីប្រកាន់ដោយភាពជារបស់ស្ថិតស្ថេរជាដើម ក៏ជារបស់កុហក គឺមិនមែនយ៉ាងនោះ ។ បទថា **យំ** ទ្រង់ពោលសំដៅដល់និព្វានទៀត ។ ព្រោះនិព្វាននោះ ដែលសត្វលោកមើលឃើញថា និព្វាននេះជារបស់កុហក មិនមានអ្វី ព្រោះមិនមានរូបឬវេទនាជាដើម ។ បទថា **តទមរិយានំ ឯតំ សច្ចំ** សេចក្តីថា ព្រះអរិយៈ

ទាំងឡាយឃើញដោយល្អហើយ ដោយបញ្ញាដ៏ប្រពៃតាមសេចក្ដីពិតថា និព្វាន នោះ ជារបស់ពិតដោយបរមត្ថ ក្នុងការមិនប្រាសចាកសេចក្ដីសុខ គឺមិនមាន កិលេស មិនប្រាសចាកសេចក្ដីសុខ ដែលជាបដិបក្ខចំពោះសេចក្ដីទុក្ខ មិន ប្រាសចាកភាពជារបស់ទៀង ដែលបានដល់ការស្ងប់ដោយចំណែកមួយ ។

បទថា **អានត្តនិ អត្តមានី** គឺមានការសម្គាល់ក្នុងរបស់ដែលមិនមែន ខ្លួន ថាជាតួខ្លួន ដោយសភាវៈរបស់នាមរូប និងវេទនាជាដើម ។ បទថា **ឥទំ សច្ចន្តិ មញ្ញតិ** គឺរមែងសម្គាល់ថា នាមរូបនេះជារបស់ពិត ដោយភាពជា របស់ស្ថិតស្ថេរជាដើម ។ បទថា **យេន យេន ហិ** គឺរមែងសម្គាល់ដោយ ន័យជាដើមថា រូបរបស់អញ វេទនារបស់អញ ដោយរូប ឬវេទនាណាមួយ ។ បទថា **តតោ តំ** គឺនាមរូបនោះ រមែងជារបស់ដទៃចាកអាការដែលសម្គាល់ នោះ ព្រោះហេតុអ្វី ព្រោះនាមរូបនៃបុគ្គលនោះជារបស់កុហក អធិប្បាយថា ព្រោះនាមរូបនោះជារបស់កុហកចាកអាការតាមដែលសម្គាល់ ដូច្នោះ ទើបជា របស់ដទៃ ព្រោះហេតុអ្វី ទើបជារបស់កុហក ព្រោះនាមរូបមានការសូន្យជា ធម្មតា គឺព្រោះវត្ថុណាប្រាកដឡើងតិចតួច រមែងមានការសោះសូន្យជាធម្មតា គឺមានការលំបាកទៅជាធម្មតា ព្រោះនាមរូបជារបស់យ៉ាងនោះ ។ បទថា **សម្មាភិសមយា** គឺដឹងនូវព្រះនិព្វាននោះតាមសេចក្ដីពិត ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។

[ ៩៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ១៦ បទថា **យំ** ព្រះមានព្រះភាគ ត្រាស់សំដៅដល់អារម្មណ៍ដែលគួរប្រាថ្នា ៦ យ៉ាង ព្រោះអារម្មណ៍នោះដែល

សត្វលោកសម្មឹងឃើញថា ជាសេចក្តីសុខ ដូចមមាចឃើញពន្លឺប្រទីប ត្រីឃើញសន្ទូច និងស្វាឃើញបន្ទុះក្តារដែលលាបដោយជ័រ ថាជាសុខ ។ បទថា **តទមរិយានំ ឯតំ ទុក្ខំ** អធិប្បាយថា ព្រះអរិយៈទាំងឡាយឃើញដោយល្អដោយបញ្ញាដ៏ប្រពៃតាមសេចក្តីពិតថា នុ៎ះជាទុក្ខ ដោយន័យជាដើមថា ពិតហើយ កាមទាំងឡាយដ៏វិចិត្រ មានរសផ្អែម ជាទីរីករាយនៃចិត្ត តែងញាំញីនូវចិត្ត ដោយសភាពដ៏ប្លែកៗ ដូច្នេះ ។ បទថា **ឥទំ** ព្រះមានព្រះភាគត្រាស់សំដៅដល់និព្វាននោះឯងទៀត ។ ព្រោះនិព្វាននោះ ដែលសត្វលោកសម្មឹងឃើញហើយ ថាជាទុក្ខ ព្រោះមិនមានកាមគុណ ។ បទថា **តទមរិយានំ** សេចក្តីថា ព្រះអរិយៈទាំងឡាយឃើញហើយដោយល្អ ដោយបញ្ញាដ៏ប្រពៃតាមសេចក្តីពិតថា និព្វាននេះជាសុខ ដោយជាបរមត្ថសុខ ។ បទថា **កេវលា** គឺមិនមានសេសសល់ ។ បទថា **ឥដ្ឋា** គឺគួរត្រូវការ ។ បទថា **កន្តា** គឺគួរស្រឡាញ់ ។ បទថា **មនាបា** គឺគួរធ្វើសេចក្តីចម្រើនឲ្យដល់ចិត្ត ។ បទថា **យាវតត្ថីតិ វុច្ចតិ** គឺលោកពោលថា អារម្មណ៍ទាំងអស់ ៦ ។ គប្បីជ្រាបការមុតស្រួច នៃពាក្យ ។ បទថា **វោ** ក្នុងបទថា **ឯតេ វោ** នេះ ត្រឹមតែជានិបាត ប្រែថា អារម្មណ៍ទាំង ៦ នេះ ។ បទថា **សុខន្តិ ទិដ្ឋមរិយេហិ សក្កាយស្សុបរោធនំ** បានដល់ ការរម្ងត់នៃបញ្ចក្ខន្ធដែលព្រះអរិយៈឃើញហើយថា ជាសេចក្តីសុខ លោកអធិប្បាយថា បានដល់ និព្វាន ។ បទថា **បច្ចនីកមិទំ ហោតិ** គឺការឃើញជំទាស់គ្នា ។ បទថា **បស្សតំ** គឺអ្នកឃើញ លោកអធិប្បាយថា បានដល់ បណ្ឌិតទាំងឡាយ ។ បទថា **យំ** ក្នុងបទថា

**យំ បរេ** នេះ ព្រះមានព្រះភាគត្រាស់សំដៅដល់វត្ថុកាម ។ បទថា **យំ បុរេ** នេះ សំដៅដល់និព្វាន ។ បទថា **បស្ស** ព្រះមានព្រះភាគត្រាស់ហៅអ្នកស្តាប់ ។ បទថា **ធម្មំ** បានដល់ ធម៌ គឺនិព្វាន ។ បទថា **សម្បមូឡ្ហេត្ថ អវិទ្ទសូ** គឺបុគ្គលពាលទាំងឡាយមិនដឹងច្បាស់ នាំគ្នាវង្វេងក្នុងលោកនេះ នាំគ្នាវង្វេងព្រោះអ្វីជាហេតុ ព្រោះការងងឹត រមែងមានដល់បុគ្គលពាលទាំង-ឡាយដែលត្រូវអវិជ្ជាបិទបាំងហើយ ជាអ្នកមិនឃើញ ព្រោះមានការងងឹតធ្វើឲ្យបុគ្គលពាលទាំងឡាយត្រូវអវិជ្ជាបិទបាំង ជាបុគ្គលខ្វាក់ ដូច្នោះ បុគ្គលពាលទាំងឡាយមិនអាចឃើញធម៌ គឺនិព្វាន ។ បទថា **សតញ្ច វិវដំ ហោតិ អាលោកោ បស្សតាមិវ** សេចក្តីថា និព្វានជាធម្មជាតបើកផ្ចាវដល់សប្បុរសទាំងឡាយ ដែលឃើញដោយបញ្ញាទស្សនៈ ដូចពន្លឺ ដូច្នោះ ។

បទថា **សន្តិកេ ន វិជានន្តិ មគា ធម្មស្ស កោវិទា** សេចក្តីថា និព្វានឈ្មោះថា មានក្នុងទីជិត ព្រោះត្រឹមតែកំណត់តចបញ្ចកកម្មដ្ឋាន ក្នុងសរីរៈរបស់ខ្លួន ក៏គប្បីសម្រេចបានដោយលំដាប់ បន្ទាប់អំពីនោះ ឬត្រឹមតែរម្ងត់ខន្ធរបស់ខ្លួន ក៏គប្បីសម្រេចបាន ជនទាំងឡាយដែលជាបុគ្គលល្ងង់ខ្លៅ មិនឈ្លាសចំពោះធម៌ដែលជាផ្លូវនិងមិនមែនផ្លូវ ឬចំពោះធម៌ទាំងអស់ រមែងមិនដឹងច្បាស់នូវនិព្វាននោះ សូម្បីមានក្នុងទីជិតយ៉ាងនេះ គប្បីជ្រាបដោយប្រការទាំងពួងថា ជនទាំងឡាយដែលត្រូវភវរាគៈគ្របសង្កត់ហើយ ស្ទុះទៅតាមក្រសែភវតណ្ហា ចូលដល់វដ្តៈដែលជាអន្ទាក់នៃមារៀយៗ មិនត្រាស់ដឹងនូវធម៌នេះបានដោយងាយឡើយ ។ ក្នុងបទទាំងនោះ បទថា **មារធេយ្យានុប្ប-**

**ឆ្លេហិ** គឺជាអ្នកចូលដល់វដ្ដៈ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។

គប្បីជ្រាបការភ្ជាប់សេចក្ដីក្នុងគាថាក្រោយថា ក្រៅអំពីព្រះអរិយៈទាំង-ឡាយ អ្នកណាហ្ន៎ គួរដឹងបទ គឺនិព្វានដែលព្រះអរិយៈទាំងឡាយដឹងដោយប្រពៃយ៉ាងនេះ ។ បទនោះ មានអធិប្បាយដូច្នេះថា ក្រៅអំពីព្រះអរិយៈទាំងឡាយហើយ បុគ្គលដទៃណាហ្ន៎ គួរដឹងនិព្វានបទ ជាបទដែលព្រះអរិយៈទាំងឡាយ ជាអ្នកមិនមានអាសវៈតាមលំដាប់ ព្រោះដឹងដោយប្រពៃ ដោយអរិយមគ្គទី ៤ រមែងបរិនិព្វានដោយការរម្ងត់កិលេស ឬជាអ្នកមិនមានអាសវៈព្រោះដឹងដោយប្រពៃ រមែងបរិនិព្វានដោយឧបាទិសេសនិព្វានធាតុក្នុងទីបំផុត ។ ព្រះមានព្រះភាគ ទ្រង់ញុំាងទេសនាឲ្យចប់ដោយធម៌ជាកំពូល គឺអរហត្ត ។

[ ៩៤ ] បទថា **អត្តមនា** គឺមានចិត្តត្រេកអរ ។ បទថា **អភិនន្ទុំ** គឺរីករាយក្រៃលែង ។ បទថា **ឥមស្មិញ្ច បន វេយ្យាករណស្មឹ** គឺវេយ្យា-ករណភាសិតទី ១៦ នេះ ។ បទថា **ភញ្ញមានេ** គឺកាលព្រះមានព្រះភាគត្រាស់ ។ បទដ៏សេស ប្រាកដច្បាស់ហើយ ។ ព្រោះវេយ្យាករណភាសិត ១៦ វារៈនេះ ចិត្តរបស់ភិក្ខុ ៩០០ រូប ចែកជាពួកៗ ប្រមាណមួយពួកហុកសិប និងដែលលើសហុកសិប ផុតចាកអាសវៈ ព្រោះមិនប្រកាន់មាំ ក្នុងសូត្រនេះ ព្រះមានព្រះភាគទ្រង់សម្ដែងសច្ចធម៌ ១៦ ដង មួង ៤ រួមជា ៦៤ ដង ដោយវេយ្យាករណភាសិត មានប្រការផ្សេងៗ ដោយប្រការដូច្នេះ ។

**អដ្ឋកថា ទ្វយតានុបស្សនាសូត្រទី ១២ ចប់**

**មហាវគ្គទី ៣ ចប់**

# សុត្តន្តបិដក

## កាមសូត្រទី១

[ ៩៥ ] កាលសត្វប្រាថ្នាកាមណា បើកាមនោះសម្រេចដល់សត្វនោះ លុះសត្វ ( នោះ ) បានតាមប្រាថ្នាហើយ រមែងមានចិត្តប្រកបដោយបីតិដោយពិត ។ កាលបើសត្វនោះប្រាថ្នាមានឆន្ទៈកើតហើយ កាមនោះសាបសូន្យទៅ សត្វក៏សុបសៅទៅ ដូចជាមុតដោយសរ ។ សត្វណា វៀរស្រឡះចាកកាមទាំងឡាយ ដូចជាបុរសគេចនឹងក្បាលពស់ ដោយជើងរបស់ខ្លួន សត្វនោះជាអ្នកមានសតិ ប្រព្រឹត្តកន្លងនូវតណ្ហា ជាគ្រឿងផ្សាយទៅនេះ ក្នុងលោកបាន ។ មួយទៀត ជនណា ជាប់ជំពាក់នឹងស្រែចម្ការ កន្លែង ប្រាក់ គោ សេះ និងបុរសជាខ្ញុំ ពួកស្ត្រី ពួកផៅពង្ស និងកាមដ៏ច្រើន ពួកកិលេសយ៉ាងខ្សោយរមែងគ្របសង្កត់ជននោះ អន្តរាយទាំងឡាយ ញាំញីជននោះតពីនេះទៅ ទុក្ខនឹងជាប់ជននោះ ដូចជាទឹកហូរចូលទូកដែលបែកធ្លាយ ។ ព្រោះហេតុនោះ សត្វអ្នកមានសតិសព្វកាល គួរវៀរចាកកាមទាំងឡាយ លុះលះកាមទាំងនោះហើយ ទើបឆ្លងអន្លង់បាន ដូចជាបុរសស្ដារទូក ហើយទៅដល់ត្រើយខាងនាយ ។

កាមសូត្រទី ១ ចប់

# អដ្ឋកថា

# អដ្ឋកវគ្គទី ៤

## កាមសូត្រ

[ ៩៥ ] ក្នុងកាមសូត្រទី ១ នៃអដ្ឋកវគ្គទី ៤ មានពាក្យផ្ដើមថា **កាមំ កាមយមានស្ស** ដូច្នេះ ។

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅនេះ

បានឮថា កាលព្រះមានព្រះភាគគង់នៅក្នុងក្រុងសាវត្ថី ព្រាហ្មណ៍ម្នាក់គិតថា អញនឹងព្រោះស្រូវដំណើបជិតស្ទឹងអចិរវតី ក្នុងចន្លោះក្រុងសាវត្ថី និងវត្តជេតពនមហាវិហារ ដូច្នេះហើយ ទើបទៅភ្ជួរស្រែ ។ ព្រះមានព្រះភាគចោមរោមដោយភិក្ខុសង្ឃ ចូលទៅបិណ្ឌបាត ឃើញព្រាហ្មណ៍នោះ ទ្រង់អាវជ្ជនៈឃើញថា ស្រូវដំណើបរបស់ព្រាហ្មណ៍នេះនឹងអន្តរាយ ដូច្នេះហើយ ទើបទ្រង់ពិចារណាដល់ឧបនិស្ស័យសម្បត្តិរបស់ព្រាហ្មណ៍នោះតទៅ ទ្រង់ឃើញឧបនិស្ស័យនៃសោតាបត្តិមគ្គរបស់ព្រាហ្មណ៍នោះ ទ្រង់ពិចារណាថា ព្រាហ្មណ៍នឹងសម្រេចកាលណា ទ្រង់ដឹងថា កាលស្រូវវិនាស ព្រាហ្មណ៍ត្រូវសេចក្ដីសោកគ្របសង្កត់ ស្ដាប់ធម្មទេសនាហើយ ( នឹងសម្រេច ) ។ ទ្រង់ត្រិះរិះបន្តថា បើតថាគតចូលទៅរកព្រាហ្មណ៍ ក្នុងពេលនោះតែម្ដង ព្រាហ្មណ៍នឹងមិនសម្គាល់ឱវាទរបស់តថាគតថាគួរស្ដាប់ ព្រោះព្រាហ្មណ៍ទាំងឡាយគាប់ចិត្តផ្សេងៗ គ្នា ណ្ហើយចុះ តថាគតនឹងសង្គ្រោះចាប់ពីពេលនេះតែ

មួង ព្រាហ្មណ៍នឹងមានចិត្តទន់យ៉ាងនេះ ក៏នឹងស្តាប់ឱវាទរបស់តថាគត ដូច្នេះហើយ ទើបទ្រង់យាងទៅរកព្រាហ្មណ៍ សួរថា ម្នាលព្រាហ្មណ៍ អ្នកធ្វើអ្វី ។ ព្រាហ្មណ៍គិតថា ព្រះសមណគោតមមានត្រកូលខ្ពស់ គង់ធ្វើបដិសណ្ឋារៈជាមួយអញ ទើបមានចិត្តជ្រះថ្លាក្នុងព្រះមានព្រះភាគ រំពេចនោះឯង ក្រាបទូលថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គកំពុងភ្ជួរស្រែដើម្បីព្រោះស្រូវជំណើប ។ លំដាប់នោះ ព្រះសារីបុត្តត្ថេរគិតថា ព្រះមានព្រះភាគ ទ្រង់ធ្វើបដិសណ្ឋារៈជាមួយព្រាហ្មណ៍ ព្រះតថាគតទាំងឡាយ មិនមានហេតុបច្ច័យហើយ នឹងមិនធ្វើយ៉ាងនោះ ណ្ហើយចុះ អញក៏នឹងធ្វើបដិសណ្ឋារៈនឹងព្រាហ្មណ៍នោះ ទើបចូលទៅរកព្រាហ្មណ៍ ហើយបានធ្វើបដិសណ្ឋារៈយ៉ាងនោះដូចគ្នា ។ ព្រះមហាមោគ្គល្លានត្ថេរ និងព្រះមហាសាវ័ក ៨០ ក៏ធ្វើយ៉ាងនោះ ព្រាហ្មណ៍ត្រេកអរក្រៃលែង ។

សម័យនោះ កាលសម្ពូងបរិបូរ ថ្ងៃមួយ សោយភត្តាហារស្រេចហើយ យាងទៅកាន់ក្រុងសាវត្ថី ទៅកាន់វត្តជេតពន ទ្រង់ចៀសចេញអំពីផ្លូវចូលទៅរកព្រាហ្មណ៍ត្រាស់ថា ម្នាលព្រាហ្មណ៍ ស្រូវជំណើបរបស់អ្នកល្អឬ ព្រាហ្មណ៍ទូលថា បពិត្រព្រះគោតម បើស្រែជំណើបកើតល្អយ៉ាងនេះ ខ្ញុំព្រះអង្គនឹងចែកដល់ទ្រង់ខ្លះ ។ លុះកន្លងទៅបាន ៤ ខែ ស្រូវជំណើបរបស់ព្រាហ្មណ៍បានចេញផ្លែបរិបូណ៌ កាលព្រាហ្មណ៍កំពុងខ្វល់ខ្វាយថា អញនឹងច្រូតថ្ងៃនេះ ឬស្អែកនេះ មហាមេឃតាំងឡើងហើយ ភ្លៀងក៏ធ្លាក់ពេញមួយរាត្រី ស្ទឹងអចិរវតីក៏ពេញ ហូរនាំស្រូវជំណើបទៅអស់ ។ ព្រាហ្មណ៍ទោមនស្សអស់

មួយយប់ លុះភ្លឺឡើង ក៏ទៅកាន់ឆ្នេរស្ទឹង ឃើញស្រូវវិនាសអស់ ក៏កើតសេចក្តីសោកយ៉ាងខ្លាំងថា អញវិនាសហើយ ឥឡូវនេះ អញនឹងរស់នៅបានដូចម្តេច ព្រឹកនោះឯង ទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ជ្រាបថា ថ្ងៃនេះ ដល់ពេលសម្តែងធម៌ដល់ព្រាហ្មណ៍ហើយ ទើបយាងចូលទៅបិណ្ឌ-បាត កាន់ក្រុងសាវត្ថី ឈរក្បែរផ្ទះរបស់ព្រាហ្មណ៍ ។ ព្រាហ្មណ៍ឃើញព្រះមានព្រះភាគហើយ គិតថា ព្រះសមណគោតម មានបំណងជួយរំលែកទុក្ខអញ ដែលត្រូវសេចក្តីសោកគ្របសង្កត់ ទើបនិមន្តមក ហើយក្រាលអាសនៈទទួលបាត្រ និមន្តឲ្យគង់ ។ ព្រះមានព្រះភាគទ្រង់ជ្រាប ទើបត្រាស់សួរព្រាហ្មណ៍ថា ម្នាលព្រាហ្មណ៍ អ្នកទោមនស្សរឿងអ្វីឬ ។ ព្រាហ្មណ៍ទូលថា បពិត្រព្រះគោតម ត្រូវហើយ ស្រូវដំណើបរបស់ខ្ញុំព្រះអង្គ ត្រូវទឹកកួចអស់គ្រានោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលព្រាហ្មណ៍ បើដល់កាលវិបត្តិ មិនគួរទោមនស្ស បើដល់កាលសម្បូរ ក៏មិនគួរត្រេកអរ ព្រោះថា កាមទាំង-ឡាយ រមែងសម្បូរខ្លះ រមែងវិបត្តិខ្លះ ដូច្នេះ ។ ទ្រង់ដឹងធម៌ដែលជាសប្បាយរបស់ព្រាហ្មណ៍នោះ ទើបត្រាស់សូត្រនេះ ដោយវិធីសម្តែងធម៌ ។ ក្នុងសូត្រនោះ ខ្ញុំនឹងពណ៌នាការសម្ពន្ធគ្នា រវាងអត្ថនៃពាក្យដោយសង្ខេបប៉ុណ្ណោះ ។ ឯសេចក្តីពិស្តារ គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងគម្ពីរនិទ្ទេសនោះឯង ។ ក្នុងសូត្រទាំងអស់ក្រៅអំពីនេះ ក៏ដូចសូត្រនេះ ។

ក្នុងបទទាំងនោះ បទថា **កាមំ** បានដល់ វត្ថុកាម គឺធម៌ប្រព្រឹត្តទៅក្នុងភូមិ ៣ មានរូបដែលគួរស្រឡាញ់ជាដើម ។ បទថា **កាមយមានស្ស** គឺ

ប្រាថ្នា ។ បទថា **តស្ស ចេ តំ សមិជ្ឈតិ** សេចក្តីថា បើវត្ថុកាមនោះសម្រេចដល់បុគ្គលប្រាថ្នានោះ លោកអធិប្បាយថា បើបុគ្គលនោះបាននូវវត្ថុកាមនោះ ។ បទថា **អទ្ធា បីតិមនោ ហោតិ** បានដល់ រមែងជាអ្នកមានចិត្តត្រេកអរដោយចំណែកមួយ ។ បទថា **លទ្ធា** បានដល់ បានហើយ ។ បទថា **មច្ចោ** គឺសត្វលោក ។ បទថា **យទិច្ឆតិ** កាត់បទជា **យំ ឥច្ឆតិ** ( តាមប្រាថ្នា ) ។ បទថា **តស្ស ចេ កាមយមានស្ស** គឺកាលបុគ្គលនោះប្រាថ្នាកាម ឬត្រេកអរដោយកាម ។ បទថា **ឆន្ទជាតស្ស** គឺកើតនូវការចង់បាន ។ បទថា **ជន្តុនោ** គឺសត្វលោក ។ បទថា **តេ កាមា បរិហាយន្តិ** គឺបើកាមទាំងនោះវិនាសទៅសោត ។ បទថា **សល្លវិទ្ធោវ រុប្បតិ** គឺបន្ទាប់អំពីនោះ សត្វរមែងលំបាក ដូចត្រូវព្រួញដែកមុតជាដើម ។

ក្នុងគាថាទី ៣ មានសេចក្តីសង្ខេបដូចតទៅនេះថា បុគ្គលណាវៀរនូវកាមទាំងនេះដោយការសង្កត់នូវការត្រេកអរ ដោយការពេញចិត្ត ឬដោយការកាត់ផ្តាច់ក្នុងកាមនោះ ដូចវៀរក្បាលពស់ដោយជើងរបស់ខ្លួន បុគ្គលនោះជាអ្នកមានសតិ រមែងឈានកន្លងនូវតណ្ហានេះ គឺការផ្សាយទៅក្នុងលោកបាន ព្រោះផ្សាយទៅពេញក្នុងលោក តាំងនៅ ។

បន្ទាប់អំពីនេះទៅ ជាសេចក្តីសង្ខេបនៃគាថា ដែលទ្រង់បានសម្តែង ។ បុគ្គលណាត្រេកអរក្នុងស្រែ មានស្រែដំណើបជាដើម ត្រង់ដី មានដីសង់ផ្ទះជាដើម ប្រាក់ គឺកហាបណៈ គោ សេះ សត្វប្រភេទគោ និងសេះ ស្រីដែលដឹងថា ជាស្រីសាលោហិតរបស់ញាតិជាដើម ឬកាមដ៏ច្រើន មានរូបដទៃដែលជាទីស្រឡាញ់ជាដើម កិលេសទាំងឡាយ ទោះបីមានកម្លាំងតិច រមែងញាំញីបុគ្គលនោះបាន អធិប្បាយថា កិលេសទាំងឡាយ ទោះបីមានកម្លាំងតិច រមែងគ្របសង្កត់បុគ្គលដែលមានកម្លាំងតិចនោះ ព្រោះវៀរចាកកម្លាំងសទ្ធាជាដើម ឬព្រោះមិនមានកម្លាំង ។ កាលបើដូច្នោះ អន្តរាយដែលប្រាកដមានរាជសីហ៍ជាដើម និងអន្តរាយមិនប្រាកដ មានកាយទុច្ចរិតជាដើម រមែងញាំញីបុគ្គលនោះ ដែលជាអ្នកចង់បានក្នុងកាម រក្សាកាម និងស្វែងរកកាម ។ បន្ទាប់ពីនោះ ទុក្ខ មានជាតិជាដើម រមែងជាប់តាមបុគ្គលនោះ ដែលត្រូវអន្តរាយមិនប្រាកដគ្របសង្កត់ ដូចទឹកហូរចូលកាន់ទូកដែលបែកហើយ ដូច្នោះ ព្រោះហេតុនោះ សត្វគប្បីជាអ្នកមានសតិសព្វកាល ដោយការចម្រើនកាយគតាសតិជាដើម កាលវៀរកិលេសកាមទាំងអស់ក្នុងវត្ថុកាម មានរូបជាដើម ដោយការសង្កត់សង្កិន និងការកាត់ផ្តាច់ គប្បីវៀរកាមទាំងឡាយ សត្វលះកាមទាំងនោះបានយ៉ាងនេះហើយ គប្បីឆ្លង គឺអាចឆ្លងឱឃៈ ៤ យ៉ាង ដោយ

មគ្គដែលធ្វើនូវការលះកាមទាំងនោះបាន ។ បន្ទាប់ពីនោះ គប្បីស្តារនូវទូក គឺអត្តភាពដែលធ្ងន់ដោយទឹក គឺកិលេស ហើយគប្បីដល់ត្រើយ ដោយអត្តភាពដែលស្រាល គប្បីដល់នូវនិព្វានដែលជាត្រើយនៃធម៌ទាំងពួង និងគប្បីដល់ដោយការសម្រេចអរហត្ត រមែងបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ដូចបុរសបាចទូក ដែលពេញដោយទឹក ហើយគប្បីដល់ត្រើយ គឺទៅដល់ត្រើយដោយទូកដែលស្រាល ដោយសេចក្តីព្យាយាមបន្តិចបន្តួចប៉ុណ្ណោះ ។ ព្រះមានព្រះភាគទ្រង់បញ្ចប់ទេសនាដោយធម៌ដ៏កំពូល គឺអរហត្ត ។

លុះចប់ទេសនា ព្រាហ្មណ៍ និងព្រាហ្មណី ក៏តាំងនៅក្នុងសោតាបត្តិផល ៗ។

## អដ្ឋកថាកាមសូត្រទី ១ ចប់

# សុត្តន្តបិដក

## គុហដ្ឋកសូត្រទី២

[ ៩៦ ] ជនជាប់ជំពាក់ក្នុងគុហា គឺរាងកាយស្រោបដោយកិលេសច្រើនប្រការ ធ្លាក់ចុះក្នុងមោហៈ គឺកាមគុណ ហើយស្ថិតនៅ ជនមានសភាពដូច្នោះ ឈ្មោះថា ឆ្ងាយអំពីវិវេក ព្រោះថា កាមទាំងឡាយក្នុងលោក បុគ្គលមិនងាយនឹងលះបានឡើយ ។ សត្វទាំងនោះ ជាប់ជំពាក់ដោយសេចក្តីប្រាថ្នាក្នុងភព ព្រោះសេចក្តីប្រាថ្នាជាហេតុ អាឡោះអាល័យនូវកាមទាំងឡាយក្នុងអនាគតផង ក្នុងអតីតផង ប្រាថ្នានូវកាមទាំងឡាយ ជាបច្ចុប្បន្ននេះ និងអតីត អនាគត ជាសត្វរួចបានដោយក្រ មិនរួចដោយហេតុដទៃបាន ។ សត្វទាំងនោះ ជាប់ជំពាក់ ខ្វល់ខ្វាយ វង្វេងក្នុងកាមទាំងឡាយ មិនកាន់យកពុទ្ធវចនៈ តាំងនៅមាំក្នុងធម៌មិនស្មើ គឺកាយទុច្ចរិត ដល់នូវសេចក្តីទុក្ខ តែងខ្សឹកខ្សួលថា ឱហ្ន៎ អាត្មាអញច្យុតអំពីអត្តភាពនេះ នឹងទៅកើតក្នុងទីណាអេះ ។ ព្រោះហេតុនោះ សត្វគប្បីសិក្សាក្នុងសាសនានេះ អ្នកប្រាជ្ញគប្បីដឹងនូវកម្មទីមួយ ថាជាកម្មមិនរាបទាបក្នុងលោក មិនគប្បីប្រព្រឹត្តធម៌មិនរាបទាប ព្រោះហេតុនៃកម្មនោះ អ្នកប្រាជ្ញទាំងឡាយ តែងពោលនូវជីវិតនោះថា ជារបស់មានប្រមាណតិច ។ តថាគតឃើញនូវពពួកសត្វនេះ ដែលកំពុងអន្ទះអន្ទែងក្នុងលោក លុះក្នុងអំណាចតណ្ហា ក្នុង

ភពទាំងឡាយ ពួកជនអ្នកថោកថយ មិនប្រាសចាកតណ្ហា ក្នុងភពតូច ភពធំទាំងឡាយ រមែងខ្សឹកខ្សួលក្នុងមាត់នៃមច្ចុ ។ អ្នកទាំងឡាយ ចូរមើលពួកសត្វ កំពុងអន្ទះអន្ទែង ក្នុងវត្ថុជាកំណាន់ ដូចជាមច្ឆជាតិ ដែលកំពុងអន្ទះអន្ទែង ក្នុងទីមានទឹកតិច មានខ្សែទឹករីងអស់ហើយ អ្នកប្រាជ្ញមិនមានសេចក្តីប្រកាន់ លុះឃើញទោសនុ៎ះហើយ មិនគប្បីសន្សំនូវតណ្ហាគ្រឿងជាប់ជំពាក់ក្នុងភពហើយ ត្រាច់ទៅ ។ អ្នកប្រាជ្ញកំណាត់ដឹងនូវផស្សៈហើយ លះបង់នូវឆន្ទរាគៈ ក្នុងផស្សៈទាំងពីរប្រការ គឺផស្សៈដែលកើតហើយ និងហេតុដែលនាំឲ្យកើតផស្សៈដ៏លាមក មិនជាប់ជំពាក់ ( ក្នុងផស្សៈទាំងនោះ ) អ្នកប្រាជ្ញមិនតិះដៀលអាត្មាឯង ដោយកម្មណា មិនធ្វើនូវកម្មនោះ មិនជាប់នៅក្នុងអារម្មណ៍ ដែលបានឃើញបានឮ ។ អ្នកប្រាជ្ញកំណត់ដឹងនូវកាមសញ្ញាហើយ ឆ្លងចាកអន្លង់ មានចិត្តមិនជាប់ជំពាក់ក្នុងបរិគ្គហធម៌ គឺតណ្ហា និងទិដ្ឋិទាំងឡាយឡើយ ដកចោលនូវសរ គឺរាគាទិក្កិលេស មិនមានសេចក្តីប្រមាទត្រាច់ទៅ ទាំងមិនមានសេចក្តីប្រាថ្នាក្នុងលោកនេះ និងលោកខាងមុខ ។

## គុហដ្ឋកសូត្រទី ២ ចប់

# អដ្ឋកថា

## គុហដ្ឋកសូត្រ

[ ៩៦ ] ក្នុងគុហដ្ឋកសូត្រទី ២ មានពាក្យផ្ដើមថា **សត្តោ គុហាយំ** ដូច្នេះ ។

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅនេះ

បានឮមកថា ព្រះមានព្រះភាគ កាលគង់នៅក្នុងនគរសាវត្ថី ព្រះបិណ្ឌោលភារទ្វាជៈបានទៅកាន់ព្រះរាជឧទ្យាន ឈ្មោះអាវដ្តកៈ របស់ព្រះបាទឧទេន ប្របច្នេរស្ទឹងគង្គា ក្នុងក្រុងកោសម្ពី ។ ម្យ៉ាងទៀត ព្រះបិណ្ឌោលភារទ្វាជៈនេះ ក្នុងកាលដទៃ ធ្លាប់ចូលទៅសម្រាកត្រង់ព្រះរាជឧទ្យាននោះរឿយៗ ដូចព្រះគវម្បតិត្ថេរ ទៅសម្រាកក្នុងតាវត្តិង្សភព ដូច្នោះ សេចក្ដីនេះ មានន័យដូចពោលហើយ ក្នុងអដ្ឋកថាវង្គីសសូត្រ ។ ព្រះបិណ្ឌោលភារទ្វាជៈនោះ អង្គុយសម្រាកពេលថ្ងៃ សម្ងំក្នុងសមាបត្តិ ត្រង់គល់ឈើ ដែលមានម្លប់ត្រជាក់ ក្បែរច្នេរស្ទឹងគង្គានោះ ។

ក្នុងថ្ងៃនោះ ព្រះបាទឧទេនយាងទៅប្រពាតព្រះរាជឧទ្យាន ទ្រង់ត្រេកអរក្នុងព្រះរាជឧទ្យាន ដោយការដេញដំប្រគំកូតជាដើមអស់មួយថ្ងៃ ទ្រង់ស្រវឹងព្រោះសោយទឹកចណ្ឌច្រើន ផ្ទំកើយភ្លៅរបស់ស្រីស្នំម្នាក់ ស្រីក្រៅពីនោះគិតថា ព្រះរាជាផ្ទំលក់ហើយ ទើបនាំគ្នាក្រោកទៅបេះផ្កា និងផ្លែឈើជាដើមក្នុងព្រះរាជឧទ្យាន កាលឃើញព្រះថេរៈ ក៏កើតហិរិឱត្តប្បៈ ហាមគ្នាថា ពួកយើងកុំធ្វើមាត់ខ្លាំង ចូលទៅសន្សឹមៗ ថ្វាយបង្គំហើយ អង្គុយចោមរោមព្រះថេរៈ

ព្រះថេរៈចេញអំពីសមាបត្តិ សម្តែងធម៌ដល់ស្រីទាំងនោះ ។ ស្រីទាំងនោះក៏ត្រេកអរ បន្លឺវាចាថា សាធុ សាធុ ហើយអង្គុយស្តាប់ ។ ស្រីស្នំម្នាក់ដែលអង្គុយឲ្យព្រះរាជាកើយភ្លៅ ស្រពន់ភ្លៅ គិតថា ពួកស្រីទាំងនេះចោលអញដើរលេងអស់ ក៏កើតសេចក្តីប្រណែនក្នុងស្រីទាំងនោះ ទើបអង្រួនភ្លៅឲ្យព្រះរាជាតើន ។ ព្រះរាជាកាលទ្រង់តើន មិនឃើញស្រីស្នំទាំងនោះ ត្រាស់សួរថា ពួកស្រីថោកទាបទាំងនោះ ទៅណា ស្រីនោះទូលថា ពួកគេនាំគ្នាទៅ ដោយគិតថា អញមិនត្រេកអរក្នុងព្រះរាជា ហើយទៅត្រេកអរជាមួយសមណៈដូច្នេះ ។ ព្រះរាជាទ្រង់ពិរោធ បែរមុខទៅរកព្រះមហាថេរៈ ។ ស្រីទាំងនោះឃើញព្រះរាជា ក៏ក្រោកឡើង ពួកស្រីដែលមិនទាន់ក្រោក ទូលថា បពិត្រមហារាជ ពួកខ្ញុំម្ចាស់ស្តាប់ធម៌ក្នុងសម្នាក់អ្នកបួស កាលស្រីទាំងនោះ ទូលយ៉ាងនោះ ព្រះរាជាទ្រង់ពិរោធខ្លាំងឡើង ដោយការស្រេវឹង មិនថ្វាយបង្គំព្រះថេរៈ ត្រាស់សួរថា លោកមកដើម្បីអ្វី ព្រះថេរៈថ្វាយព្រះពរថា បពិត្រមហារាជ ដើម្បីស្ងប់ស្ងាត់ ។ ព្រះរាជាត្រាស់ថា លោកមកដើម្បីវិវេក អង្គុយឲ្យស្រីស្នំចោមរោមយ៉ាងនេះឬ ហើយត្រាស់ថា ចូរលោកប្រាប់វិវេករបស់លោកមកចុះ ។ ព្រះថេរៈទោះជំនាញក្នុងការពោលដល់វិវេក បាននៅស្ងៀម ដោយគិតថា ព្រះរាជានេះត្រាស់សួរបំណងដើម្បីចេះដឹងក៏មិនមែន ។ ព្រះរាជាត្រាស់ថា បើលោកមិនប្រាប់ យើងនឹងឲ្យអង្ក្រងខាំលោក ហើយទ្រង់កាច់សម្បុកអង្ក្រងត្រង់ដើមអសោកមួយដើម ក៏ខ្ចាតលើព្រះកាយរបស់ព្រះអង្គទ្រង់បោសព្រះកាយហើយ កាច់សម្បុកដទៃតម្រង់ទៅរកព្រះថេរៈៗ គិតថា បើ

ព្រះរាជាប្រទូស្តអញ នឹងទៅកាន់អបាយ ទើបអនុគ្រោះព្រះរាជា ហោះឡើង ទៅកាន់អាកាសដោយឫទ្ធិ ។ ស្រីទាំងឡាយនោះទូលថា បពិត្រព្រះអង្គ ព្រះរាជាដទៃឃើញបព្វជិតហើយ ក៏នាំគ្នាបូជាដោយផ្កា និងគ្រឿងក្រអូបជាដើម ទ្រង់បែរជាមិនពេញព្រះហឫទ័យ យកសម្បុកអង្ក្រងទៅបូជា វង្សរបស់ព្រះអង្គនឹងដល់នូវសេចក្ដីវិនាស ព្រះរាជាទ្រង់ព្វកទោសរបស់ព្រះអង្គ ទើបទ្រង់នៅស្ងៀម ត្រាស់សួរឧទ្យានបាលថា ថ្ងៃដទៃ ព្រះថេរៈនឹងមកក្នុងឧទ្យាននេះទៀតដែរឬទេ អ្នករក្សាឧទ្យានទូលថា បពិត្រព្រះអង្គ ព្រះថេរៈនឹងមក ។ ព្រះរាជាត្រាស់ថា បើដូច្នោះ ចូរឯងប្រាប់យើងក្នុងពេលដែលព្រះថេរៈមក ។ ថ្ងៃមួយ កាលព្រះថេរៈមក អ្នកយាមឧទ្យានក៏ទូលឲ្យព្រះរាជាទ្រង់ជ្រាប ។ ព្រះរាជាយាងចូលទៅរកព្រះមហាថេរៈ សួរបញ្ហាហើយ បានដល់នូវសរណៈ ជរាបដល់អស់ជីវិត ក្នុងថ្ងៃដែលព្រះថេរៈ ត្រូវព្រះរាជាមិនពេញព្រះហឫទ័យដោយយកសម្បុកអង្ក្រងមកបូជា ព្រះថេរៈហោះទៅតាមអាកាស ហើយមុជក្នុងដី ផុសឡើងក្នុងព្រះគន្ធកុដិរបស់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគមានព្រះសតិសម្បជញ្ញៈ សម្រេចសីហសេយ្យាសនៈ ដោយព្រះបន្ទៀងស្ដាំ ទតឃើញព្រះថេរៈហើយ ត្រាស់សួរថា ម្នាលភារទ្វាជៈ អ្នកមកក្នុងពេលពុំដូកាលឬ ព្រះថេរៈទូលថា បពិត្រព្រះអង្គដ៏ចម្រើន ត្រូវហើយ ទើបក្រាបទូលរឿងនោះឲ្យទ្រង់ជ្រាប ។ ព្រះមានព្រះភាគ ទ្រង់ស្ដាប់ដូច្នេះហើយ ទើបត្រាស់ថា ការពោលវិវេកដល់ព្រះរាជាដែលកំពុងត្រូវការកាមគុណ នឹងមានប្រយោជន៍អ្វី ដូច្នេះ ទ្រង់ផ្ទំដោយព្រះបន្ទៀងស្ដាំនោះឯង បានត្រាស់សូត្រនេះ

ដើម្បីសម្តែងធម៌ដល់ព្រះថេរៈ ។

ក្នុងបទទាំងនោះ បទថា **សត្តោ** គឺអ្នកជាប់ជំពាក់ ។ បទថា **គុហាយំ** គឺក្នុងកាយ ។ ពិតហើយ **កាយ** លោកហៅថា **គុហា** ព្រោះជាឱកាសឲ្យកិលេសកាច មានរាគៈជាដើមនៅ ។ បទថា **ពហុនាភិច្ឆន្នោ** គឺត្រូវកិលេសមានរាគៈជាដើមបិទបាំង ។ ដោយបទនេះ ព្រះមានព្រះភាគត្រាស់ដល់គ្រឿងចងខាងក្នុង ។ បទថា **តិដ្ឋំ** គឺតាំងនៅដោយអំណាចកិលេស មានរាគៈជាដើម ។ បទថា **នរោ** គឺសត្វ ។ បទថា **មោហនស្មឹ បគាឡ្ហោ** សេចក្តីថា លោកពោលកាមគុណថា ជាគ្រឿងធ្វើចិត្តឲ្យវង្វេង ព្រោះទេវតា និងមនុស្សទាំងឡាយ រមែងវង្វេងក្នុងកាមគុណនេះ ជាបុគ្គលឈមចុះក្នុងកាម-គុណទាំងនោះ ។ ដោយបទនេះ ព្រះមានព្រះភាគត្រាស់ដល់គ្រឿងចងខាងក្រៅ ។ បទថា **ទូរេ វិវេកា ហិ តថាវិធោ សោ** សេចក្តីថា នរជនបែបនោះ ជាអ្នកឆ្ងាយចាកវិវេក ៣ មានកាយវិវេកជាដើម សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះកាមទាំងឡាយក្នុងលោក លះបានដោយកម្រ អធិប្បាយថា ព្រោះកាមទាំងឡាយក្នុងលោក មិនជារបស់ដែលគប្បីលះបានដោយងាយឡើយ ។

ព្រះមានព្រះភាគ កាលទ្រង់លើកឧបមាឲ្យឃើញថា នរជនបែបនោះឯង ជាអ្នកឆ្ងាយចាកវិវេកក្នុងគាថាដើមយ៉ាងនេះហើយ កាលទ្រង់ធ្វើឲ្យជាក់ច្បាស់ ដល់ធម្មតារបស់សត្វទាំងឡាយបែបនោះទៀត ទើបត្រាស់គាថាថា **ឥច្ឆានិទានា** ដូច្នេះជាដើម ។

*ក្នុងបទទាំងនោះ បទថា* **ឥច្ឆានិទានា** *គឺមានតណ្ហាជាហេតុ ។ បទថា* **ភវ-សាតពទ្ធា** *គឺទាក់ទងដោយសេចក្តីត្រេកអរក្នុងភព មានសុខវេទនាជាដើម ។ បទថា* **តេ ទុប្បមុញ្ចា** *គឺធម៌ដែលជាទីតាំងនៃការត្រេកអរក្នុងភពទាំងនោះ ឬសត្វទាំងឡាយ មានសេចក្តីប្រាថ្នាជាហេតុ ទាក់ទងដោយសេចក្តីត្រេកអរក្នុងភពទាំងនោះ ដោះចេញបានដោយលំបាក ។ បទថា* **ន ហិ អញ្ញមោក្ខា** *គឺអ្នកដទៃមិនអាចដោះចេញបាន ម្យ៉ាងទៀត ពាក្យនេះ ជាពាក្យសម្តែងហេតុថា សត្វទាំងនោះ ជាអ្នកដោះចេញបានលំបាក ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះអ្នកដទៃមិនគប្បីដោះចេញបាន បើអ្នកដទៃគប្បីដោះចេញបាន ក៏គប្បីដោះបានដោយកម្លាំងរបស់ខ្លួនឯង នេះជាអធិប្បាយនៃបទថា* **ន ហិ អញ្ញមោក្ខា** *នោះ ។ បទថា* **បច្ឆា បុរេ វាបិ អបេក្ខមានា** *គឺនរជនទាំងឡាយសង្ឃឹមនូវកាមទាំងឡាយ ក្នុងអនាគតខ្លះ ក្នុងអតីតខ្លះ ។ បទថា* **ឥមេវ កាមេ បុរិមេវ ជប្បំ** *សេចក្តីថា ប្រាថ្នាកាមទាំងនេះ ដែលជាបច្ចុប្បន្ន ឬដែលធ្លាប់មានមកហើយ ទាំង ២ យ៉ាង គឺទាំងអតីត និងអនាគត ដោយតណ្ហាដ៏ខ្លាំងក្លា ។ គប្បីជ្រាបការភ្ជាប់បទទាំង ២ នេះ និងបទនេះថា* **តេ ទុប្បមុញ្ចា ន ហិ អញ្ញមោក្ខា** *ដូច្នេះ ។ នរជនទាំងឡាយប្រាថ្នាចង់បាន ( របស់ ) ដទៃទៀតរឿយៗ ទៅ ទើបមិនដឹងថា កំពុងធ្វើអ្វី ឬធ្វើអ្វីហើយ ។*

*ព្រះមានព្រះភាគ កាលទ្រង់លើកឧបមាថា* **ទូរេ វិវេកា ហិ តថាវិធោ** *ក្នុងគាថាដើមយ៉ាងនេះ នឹងទ្រង់ធ្វើឲ្យជាក់ច្បាស់ដល់ធម្មតារបស់សត្វទាំង-*

ឡាយបែបនោះ ដោយគាថាទី ២ ហើយ ឥឡូវនេះ កាលទ្រង់ធ្វើឲ្យជាក់ច្បាស់ដល់ការធ្វើបាបកម្មរបស់សត្វទាំងនោះ ទើបត្រាស់គាថាថា **កាមេសុ គិទ្ធា** ដូច្នេះ ។

បទនោះ មានសេចក្តីដូចតទៅនេះថា សត្វទាំងនោះ ត្រេកអរក្នុងកាមទាំងឡាយ ដោយចង់បរិភោគ ខ្វល់ខ្វាយក្នុងកាមទាំងឡាយ ព្រោះខ្វល់ខ្វាយក្នុងការស្វែងរកជាដើម វង្វេងក្នុងកាមទាំងឡាយ ព្រោះដល់នូវការវង្វេងព្រមមិនកាន់យកនូវពាក្យ ព្រោះមិនកាន់យកនូវពាក្យរបស់បណ្ឌិត មានព្រះពុទ្ធជាដើម ព្រោះការមើលងាយ ព្រោះសេចក្តីកំណាញ់ តាំងនៅក្នុងធម៌ដែលមិនស្ងប់ មានការមិនស្ងប់ផ្លូវកាយជាដើម ត្រូវទុក្ខ គឺសេចក្តីស្លាប់គ្របសង្កត់ក្នុងកាលចុងក្រោយ រមែងកន្ទក់កន្ទេញថា អញចុតិអំពីលោកនេះហើយ នឹងដូចម្តេចហ្ន៎ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រោះហេតុនោះ សត្វគប្បីសិក្សា ក្នុងសាសនានេះ អ្នកប្រាជ្ញគប្បីដឹងនូវកម្មនីមួយ ថាជាកម្មមិនរាបទាបក្នុងលោក មិនគប្បីប្រព្រឹត្តធម៌មិនរាបទាប ព្រោះហេតុនៃកម្មនោះ អ្នកប្រាជ្ញទាំង-ឡាយ តែងពោលដល់ជីវិតនោះថា ជារបស់មានប្រមាណតិច ។

ក្នុងបទទាំងនោះ បទថា **សិក្ខេថ** គឺគប្បីសិក្សាត្រៃសិក្ខា ។ បទថា **ឥធេវ** គឺក្នុងសាសនានេះឯង ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់សេចក្តីវិនាសរបស់សត្វដែលមិនធ្វើយ៉ាងនោះ ទើបត្រាស់គាថាថា **បស្សាមិ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **បស្សាមិ** គឺតថាគតឃើញដោយមំសចក្ខុជាដើម ។ បទថា **លោកេ** បានដល់ ក្នុងអបាយជាដើម ។ បទថា **បរិផន្ទមានំ** គឺកំពុងអន្ទះអន្ទែងទៅខាងនោះខាងនេះ ។ បទថា **បជំ ឥមំ** គឺពួកសត្វនេះ ។ បទថា **តណ្ហាគតំ** គឺត្រូវតណ្ហាគ្របសង្កត់ អធិប្បាយថា ធ្វើឲ្យធ្លាក់ចុះទៅ ។ បទថា **ភវេសុ** គឺក្នុងកាមភពជាដើម ។ បទថា **ហីនា នរា** គឺមនុស្សដែលមានកម្មអាក្រក់ ។ បទថា **មច្ចុមុខេ លបន្តិ** គឺរវើរវាយក្នុងមាត់របស់មច្ចុដែលមកដល់ហើយក្នុងទីបំផុត ។ បទថា **អវីតតណ្ហាសេ** គឺមិនទាន់ប្រាសចាកតណ្ហា ។ បទថា **ភវាភវេសុ** បានដល់ ក្នុងកាមភពជាដើម ។ម្យ៉ាងទៀត បទថា **ភវាភវេសុ** បានដល់ ក្នុងភព និងមិនមែនភព ។ លោកអធិប្បាយថា ក្នុងភពទាំងឡាយរឿយៗ ។ ឥឡូវនេះ ព្រោះសត្វទាំងឡាយមិនទាន់ប្រាសចាកតណ្ហា ទើបអន្ទះអន្ទែង និងកន្ទក់កន្ទេញយ៉ាងនេះ ដូច្នោះព្រះមានព្រះភាគ កាលទ្រង់ដឹកនាំឲ្យសត្វទាំងឡាយកម្ចាត់នូវតណ្ហា ទើបត្រាស់គាថាថា **មមាយិតេ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **មមាយិតេ** គឺវត្ថុនោះៗ ថាជារបស់អញដោយតណ្ហា និងទិដ្ឋិ ។ បទថា **បស្សថ** ចូរអ្នកទាំងឡាយមើលនេះ ព្រះមានព្រះភាគត្រាស់ហៅអ្នកស្តាប់ទាំងឡាយ ។ បទថា **ឯតម្បិ** គឺទោសនោះ ។ បទដ៏សេស ប្រាកដជាក់ច្បាស់ហើយ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងគុណដោយគាថាមួយនេះ និងទោសដោយ ៤ គាថាទៀត យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្តែងការលោស់

ចេញ និងអានិសង្សនៃការលោសចេញ មួយអន្លើដោយឧបាយ ទើបទ្រង់សម្ដែងទោស គឺការថោកទាប និងការសៅហ្មងនៃកាមទាំងឡាយ ដោយគាថាទាំងអស់នេះ ដើម្បីសម្ដែងដល់អានិសង្សក្នុងនេក្ខម្មៈក្នុងឥឡូវនេះ ទើបត្រាស់ ២ គាថាថា **ឧភោសុ អន្តេសុ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **ឧភោសុ អន្តេសុ** គឺក្នុងការកំណត់ ២ យ៉ាងមានផស្សៈ និងហេតុកើតនៃផស្សៈជាដើម ។ បទថា **វិនេយ្យ ឆន្ទំ** បានដល់គប្បីកម្ចាត់នូវតម្រេកដោយការពេញចិត្តចេញ ។ បទថា **ផស្សំ បរិញ្ញាយ** សេចក្ដីថា កំណត់ដឹងនាមរូបទាំងមូល ដោយបរិញ្ញា ៣ គឺកំណត់ដឹងផស្សៈមានចក្ខុសម្ផស្សជាដើម កំណត់ដឹងអរូបធម៌ទាំងពួងដែលប្រកបដោយផស្សៈនោះ ដោយទំនងដូចគ្នានឹងផស្សៈនោះឯង និងកំណត់ដឹងរូបធម៌ ដោយអំណាច ជាវត្ថុ ទ្វារ និងអារម្មណ៍របស់អរូបធម៌ទាំងនោះ ។ បទថា **អនានុគិទ្ធោ** គឺមិនត្រេកអរក្នុងធម៌ទាំងពួង មានរូបជាដើម ។ បទថា **យទត្តគរហី តទកុព្វមានោ** គឺតិះដៀលខ្លួនឯង ព្រោះសេចក្ដីណាមិនគួរ ធ្វើសេចក្ដីនោះ ។ បទថា **ន លិម្បតី ទិដ្ឋសុតេសុ** សេចក្ដីថា អ្នកប្រាជ្ញដល់ព្រមដោយបញ្ញាបែបនោះ មិនជាប់ដោយការជាប់ ២ យ៉ាងណាមួយ ក្នុងធម៌ គឺរូបដែលបានឃើញ និងសំឡេងដែលបានឮ ឈ្មោះថា ជាអ្នកមិនជាប់គឺដល់នូវការផូរផង់ក្រៃលែង ដូចអាកាស ដូច្នោះ ។ បទថា **សញ្ញំ បរិញ្ញា** មានសេចក្ដីសង្ខេបដូចតទៅនេះថា មិនមែនកំណត់ដឹងត្រឹមតែវាចា ដែលឥតប្រយោជន៍តែម្យ៉ាងប៉ុណ្ណោះទេ ដែលពិត កំណត់ដឹងសញ្ញា មានកាមសញ្ញា

ជាដើមផងដែរ កំណត់ដឹងនាមរូបដោយទំនងដូចគ្នានឹងសញ្ញា ឬដោយន័យដែលពោលហើយខាងដើម ដោយបរិញ្ញា ៣ យ៉ាង គប្បីឆ្លងឱឃៈ ៤ យ៉ាងបានដោយបដិបទានេះ បន្ទាប់អំពីនោះ នរជននោះឆ្លងឱឃៈបានហើយ ជាមុនីខីណាស្រព មិនជាប់ក្នុងតណ្ហា និងទិដ្ឋិ ព្រោះលះនូវកិលេស គឺតណ្ហា និងទិដ្ឋិហើយ ដកនូវព្រួញចេញបាន ព្រោះបានដកនូវព្រួញ គឺកិលេស មានរាគៈជាដើមចេញបាន ជាអ្នកមិនប្រមាទត្រាច់ទៅ ព្រោះមានសតិបរិបូណ៌ ឬមិនប្រមាទ ត្រាច់ទៅក្នុងចំណែកខាងដើម ជាអ្នកដកនូវព្រួញបានហើយ ព្រោះត្រាច់ទៅ ដោយការមិនប្រមាទនោះ មិនសង្ឃឹមលោកនេះ និងលោកខាងមុខមានអត្តភាពរបស់ខ្លួន និងរបស់អ្នកដទៃជាដើម ជាអ្នកមិនប្រកាន់មាំ ព្រោះរម្ងត់ចិត្តដួងចុងក្រោយ ( ចរិមចិត្ត ) ដោយពិត រមែងរលត់ទៅ ដូចភ្លើងអស់កំញម ដូច្នោះ ។ ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនាដោយកំពូលធម៌ គឺអរហត្ត ទ្រង់បញ្ញត្តដើម្បីជាផ្លូវបដិបត្តិធម៌ប៉ុណ្ណោះ មិនមែនឲ្យកើតមគ្គ ឬផល ដោយទេសនានេះ ព្រោះទ្រង់សម្តែងដល់ព្រះខីណាស្រព ។ល។

## អដ្ឋកថា គុហដ្ឋកសូត្រទី ២ ចប់

# សុត្តន្តបិដក

## ទុដ្ឋដ្ឋកសូត្រទី៣

[ ៩៧ ] តិរ្ថិយ ១ ពួក មានចិត្តប្រទូស្ត ពោលតិះដៀល ( ព្រះមានព្រះភាគ និងភិក្ខុសង្ឃ ) មិនតែប៉ុណ្ណោះ តិរ្ថិយដទៃទៀត ដែលមានសេចក្តីសម្គាល់ថាមែន ក៏ពោលតិះដៀលដែរ ឯអក្កោសវាទដែលកើតហើយ មិនចូលទៅដល់ព្រះមុនី ព្រោះហេតុនោះ ត្រូវដឹងថា ព្រះមុនីមិនមានសសរខឿន គឺរាគាទិក្កិលេស ក្នុងសន្ទានតិចតួចសោះឡើយ ។ បុគ្គលកន្លងនូវទិដ្ឋិ របស់ខ្លួនដូចម្តេចបាន បុគ្គលត្រូវឆន្ទៈដឹកនាំហើយ តាំងនៅមាំហើយ តាមគាប់ចិត្ត ធ្វើនូវទិដ្ឋិឲ្យពេញដោយខ្លួនឯង ដឹងយ៉ាងណា ពោលយ៉ាងនោះ ។ សត្វណា គេមិនទាន់សាកសួរ ស្រាប់តែសម្តែងប្រាប់នូវសីល និងវត្តរបស់ខ្លួនដល់ជនដទៃ សត្វណាពោលសរសើរខ្លួនដោយខ្លួនឯង អ្នកឈ្លាសវៃទាំងឡាយ ពោលនូវវាទៈរបស់សត្វនោះ ថាជាធម៌មិនប្រសើរឡើយ ។ មួយទៀត ភិក្ខុអ្នកស្ងប់រម្ងាប់ហើយ មានខ្លួនរលត់ហើយ មិនពោលអួតព្រោះសីល ( ទប់ខ្លួន ) ថាអាត្មាអញ មានសីលដូច្នេះៗ ឬមួយធម៌ជាចំហាយ គឺរាគាទិក្កិលេស ក្នុងលោកនីមួយ មិនមានដល់ភិក្ខុណា អ្នកឈ្លាសវៃទាំងឡាយ ពោលនូវការមិនពោលអួតរបស់ភិក្ខុនោះ ថាជាធម៌ដ៏ប្រសើរ ។ ធម៌

គឺទិដ្ឋិ ៦២ ដែលបច្ច័យកំណត់តាក់តែងធ្វើខាងមុខ មិនផូរផង់មានដល់សត្វណាមួយ ( ជាទិដ្ឋិគតិកៈ ) បុគ្គលនោះឃើញអានិសង្សណាក្នុងខ្លួន ក៏អាស្រ័យអានិសង្សនោះ និងកុប្បបដិច្ចសន្តិទិដ្ឋិ ។ សេចក្តីប្រកាន់ទិដ្ឋិ គឺសត្វមិនងាយប្រព្រឹត្តកន្លងបាន ព្រោះចូលចិត្តនូវទិដ្ឋិដែលខ្លួនប្រកាន់ហើយ ក្នុងទិដ្ឋិធម៌ ៦២ ព្រោះហេតុនោះ ជនរលាស់ចោលខ្លះ កាន់យកខ្លះនូវធម៌ គឺទិដ្ឋិ ក្នុងការប្រកាន់យកនូវទិដ្ឋិទាំងនោះ ។ ព្រះអរហន្តក្នុងលោក មិនមានទិដ្ឋិដែលបុគ្គលកំណត់ក្នុងភពតូច ភពធំ ក្នុងលោកតិចតួចឡើយ ព្រះអរហន្តនោះលះបង់មាយាផង មានះផង គប្បីទៅដោយគតិវិសេសដូចម្តេច ព្រះអរហន្តនោះ មិនផ្តេកផ្តិតនូវតណ្ហា និងទិដ្ឋិទៀតទេ ។ ព្រោះបុគ្គលអ្នកផ្តេកផ្តិតនូវតណ្ហា និងទិដ្ឋិ តែងចូលទៅជិតកាន់វាទៈ ក្នុងទិដ្ឋិធម៌ទាំងឡាយ បុគ្គលគប្បីពោលទោស ចំពោះបុគ្គលអ្នកមិនផ្តេកផ្តិតនូវតណ្ហា និងទិដ្ឋិដោយរាគាទិទោសដូចម្តេចបាន ឯអត្តទិដ្ឋិ និងឧច្ឆេទទិដ្ឋិរបស់ព្រះអរហន្តនោះ មិនមានឡើយ ព្រះអរហន្តនោះកម្ចាត់បង់ហើយ នូវទិដ្ឋិទាំងអស់ក្នុងលោក ។

ទុដ្ឋដ្ឋកសូត្រទី ៣ ចប់

# អដ្ឋកថា

## ទុដ្ឋដ្ឋកសូត្រ

[ ៩៧ ] ក្នុងទុដ្ឋដ្ឋកសូត្រទី ៣ មានពាក្យផ្ដើមថា **វទន្តិ វេ ទុដ្ឋមនាបិ** ដូច្នេះ ។

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា សូត្រនេះ មានអត្ថុប្បត្តិហេតុដូច្នេះ

ព្រះមានព្រះភាគ ត្រាស់ការកើតទុក្ខដោយគាថាដើម ក្នុងសូត្រហើយ ពួកតិរ្ថិយអត់ធន់មិនបាន ដែលឃើញលាភសក្ការៈកើតឡើងដល់ព្រះមានព្រះភាគ និងភិក្ខុសង្ឃ ទើបបញ្ជូននាងសុន្ទរីបរិព្វាជិកាទៅ ។ បានឮថា នាងសុន្ទរីបរិព្វាជិកានោះ ជាជនបទកល្យាណី បានជាបរិព្វាជិកា ស្លៀកដណ្ដប់ស ។ នាងងូតទឹក ជម្រះសរីរៈ ហើយតាក់តែងដោយសំពត់ស្អាត និងទ្រទ្រង់នូវផ្កាឈើ ប្រោះព្រំដោយគ្រឿងក្រអូប គ្រឿងលាប ក្នុងវេលាដែលអ្នកក្រុងសាវត្ថីស្ដាប់ធម៌របស់ព្រះមានព្រះភាគ ហើយចេញអំពីវត្តជេតពន នាងក៏ចេញអំពីក្រុងសាវត្ថី ធ្វើដំណើរទៅកាន់វត្តជេតពន កាលមហាជនទាំង-ឡាយសួរថា តើនាងទៅណា នាងក៏ឆ្លើយថា ទៅដើម្បីឲ្យព្រះសមណគោតម និងសាវករបស់ព្រះអង្គអភិរម ហើយដើរឆ្លងខ្លោងទ្វារវត្តជេតពន កាលខ្លោងទ្វារវត្តជេតពនបិទ ក៏ចូលទៅកាន់ក្រុង លុះភ្លឺឡើង នាងក៏ទៅកាន់វត្តជេតពនទៀត ដើរវេរ ធ្វើដូចជាបេះផ្កាក្បែរព្រះគន្ធកុដិ កាលនាងត្រូវជនទាំងឡាយដែលមកឧបដ្ឋាកព្រះសម្មុទ្ធសួរថា នាងមកធ្វើអ្វី ក៏ឆ្លើយបង្វែរទៅបង្វែរមកយ៉ាងនោះឯង ។ លុះកន្លងទៅកន្លះខែ ពួកតិរ្ថិយក៏សម្លាប់នាងសុន្ទរីបរិព្វា-

ជិកាចោល ហើយក៏យកទៅកប់ត្រង់គូទឹក លុះភ្លឺឡើងក៏ធ្វើជាភ្ញាក់ផ្អើលថា ពួកយើងមិនឃើញនាងសុន្ទរី ទើបទៅទូលព្រះរាជា ។ ព្រះរាជាទ្រង់អនុញ្ញាតហើយ ទើបចូលទៅកាន់វត្តជេតពន ធ្វើដូចជាស្វែងរក ហើយលើកនាងសុន្ទរីឡើងអំពីទីដែលកប់ ដាក់លើគ្រែ នាំទៅកាន់ព្រះនគរ នាំគ្នាជេរប្រទេច ។ គប្បីជ្រាបរឿងទាំងអស់ ដោយន័យដែលមកហើយក្នុងបាលីនោះឯង ។ ថ្ងៃនោះ ក្នុងពេលទៀបភ្លឺ ព្រះមានព្រះភាគ ទ្រង់ប្រមើលលោកដោយពុទ្ធចក្ខុ ទ្រង់ជ្រាបថា ថ្ងៃនេះ ពួកតិរ្ថិយនឹងធ្វើឲ្យកើតការវិនាសយសទ្រង់ត្រិះរិះថា មហាជនជឿតិរ្ថិយទាំងនោះ ហើយនឹងនាំគ្នាទីងក្រោធតថាគតណ្ហើយចុះ ជននោះ កុំទៅអបាយឡើយ ទើបទ្រង់បិទទ្វារព្រះគន្ធកុដិ គង់នៅខាងក្នុងព្រះគន្ធកុដិនោះឯង មិនយាងចូលព្រះនគរ ដើម្បីបិណ្ឌបាតឡើយ ។ ឯភិក្ខុទាំងឡាយ ឃើញទ្វារបិទ ក៏ចូលទៅដូចពេលមុនៗ ។ ជនទាំងឡាយឃើញពួកភិក្ខុ ក៏នាំគ្នាជេរប្រទេច ។ លំដាប់នោះ ព្រះអានន្ទទូលរឿងនោះដល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ពួកតិរ្ថិយធ្វើនូវការវិនាសយសជំឲ្យកើតឡើងហើយ ពួកយើងមិនអាចនៅក្នុងទីនេះបានឡើយ ជម្ពូទ្វីបធំធេង សូមទ្រង់យាងទៅកាន់ទីដទៃ ។ ព្រះមានព្រះភាគត្រាស់សួរថា ម្នាលអានន្ទ បើទោសកើតឡើងក្នុងទីនោះទៀត អ្នកនឹងទៅទីណា ក៏ក្រាបទូលថា យើងទៅនគរដទៃទៀត ។ គ្រានោះ ព្រះមានព្រះភាគក៏ត្រាស់ថា ម្នាលអានន្ទរង់ចាំមើលសិន សំឡេងនេះមានត្រឹម ៧ ថ្ងៃប៉ុណ្ណោះ កាលបើហួសពី ៧ ថ្ងៃទៅហើយ បុគ្គលណាធ្វើនូវការវិនាសយស ការវិនាសយសនោះ ក៏នឹងធ្លាក់

មកលើបុគ្គលនោះឯង ដើម្បីទ្រង់សម្តែងធម៌ដល់ព្រះអានន្ទ ទើបត្រាស់គាថានេះថា **វទន្តិ វេ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **វទន្តិ** គឺពួកតិរ្ថិយនាំគ្នាតិះដៀលព្រះមានព្រះភាគ និងភិក្ខុសង្ឃ ។ បទថា **ទុដ្ឋមនាបិ ឯកេ អថោបិ វេ សច្ចមនា** សេចក្តីថា ពួកអ្នកស្រុកខ្លះមានចិត្តប្រទូស្ត ពួកខ្លះសម្គាល់ថា ពិត ពួកតិរ្ថិយមានចិត្តប្រទូស្តហើយ អធិប្បាយថា ជនពួកណាស្តាប់ពាក្យរបស់តិរ្ថិយនោះហើយ ជនទាំងនោះយល់ថា ជាការពិត ក៏នាំគ្នាជឿ ។ បទថា **វាទញ្ច ជាតំ** គឺវាទៈកើតឡើងហើយយ៉ាងនេះ ។ បទថា **មុនិ នោ ឧបេតិ** គឺពុទ្ធមុនីមិនចូលទៅជិត ព្រោះមិនបានធ្វើ និងព្រោះមិនក្រោធ ។ បទថា **តស្មា មុនី នត្ថិ ខិលោ កុហិញ្ចិ** គឺដោយហេតុនោះ គប្បីជ្រាបថា មុនីរមែងមិនមានសសរខឿន ដោយសសរ គឺរាគៈជាដើមក្នុងលោកណាមួយ ។

ព្រះមានព្រះភាគ កាលទ្រង់ត្រាស់គាថានេះហើយ ក៏ត្រាស់សួរព្រះ-អានន្ទត្ថេរថា ម្នាលអានន្ទ ភិក្ខុទាំងឡាយត្រូវជេរ ត្រូវចំអកយ៉ាងនេះហើយពោលដូចម្តេច ក៏ក្រាបទូលថា មិនបានពោលអ្វីឡើយព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ភិក្ខុទាំងឡាយមិនគួរនៅស្ងៀមក្នុងរឿងទាំងអស់ដោយគិតថា អាត្មាអញជាអ្នកមានសីល ព្រោះជនក្នុងលោក កាលបុគ្គលមិនពោល រមែងមិនដឹងថា បណ្ឌិតមាននៅក្នុងក្រុមជនពាលទាំងឡាយ ហើយបានត្រាស់គាថានេះថា អ្នកពោលពាក្យមិនពិត ឬបុគ្គលណាធ្វើ ( អំពើអាក្រក់ ) ហើយ និយាយថា អញមិនធ្វើទេ ( បុគ្គលនោះ ) រមែងទៅកាន់

នរក ដូច្នេះ ។ ដើម្បីប្រយោជន៍ក្នុងការសម្តែងធម៌ថា ម្នាលអានន្ទ ភិក្ខុទាំង-ឡាយ ចូរឆ្លើយនឹងពួកជនទាំងនោះយ៉ាងនេះ ។ ព្រះថេរៈទទួលព្រះពុទ្ធតម្រាស់នោះហើយ ទើបពោលនឹងភិក្ខុទាំងឡាយថា អ្នកទាំងឡាយគួរឆ្លើយនឹងជនទាំងឡាយដោយគាថានេះ ។ ភិក្ខុទាំងឡាយបានធ្វើយ៉ាងនោះហើយ ។ ជនជាបណ្ឌិតក៏នៅស្ងៀម ។ សូម្បីព្រះរាជា ក៏បញ្ជូនពួករាជបុរសទៅគ្រប់កន្លែង ដើម្បីស៊ើបអង្កេតរកពួកអ្នកលេង ដែលពួកតិរ្ថិយជួលឲ្យសម្លាប់នាងសុន្ទរី កាលទ្រង់ជ្រាបរឿងរ៉ាវហើយ បានបរិភាសពួកតិរ្ថិយ ។ សូម្បីជនទាំងឡាយឃើញតិរ្ថិយ ក៏យកដុំដីគប់បាចធូលីដាក់ដោយខឹងក្រោធថា ពួកតិរ្ថិយធ្វើព្រះមានព្រះភាគឲ្យអាប់យស ។ ព្រះអានន្ទឃើញដូច្នោះ ទើបក្រាបទូលដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ បានត្រាស់ព្រះគាថានេះថាដល់ព្រះថេរៈថា **សកញ្ហិ ទិដ្ឋឹ ។បេ។ វទេយ្យ** ដូច្នេះជាដើម ។

បទនោះ មានសេចក្តីដូចតទៅនេះ ទិដ្ឋិរបស់តិរ្ថិយយល់ថា យើងសម្លាប់នាងសុន្ទរីបរិព្វាជិកាហើយ ប្រកាសទោសរបស់សមណសក្យបុត្រ ក៏នឹងបានសក្ការៈដោយឧបាយនេះ បុគ្គលគប្បីកន្លងនូវទិដ្ឋិនោះបានដូចម្តេចដែលពិត ទោសនោះ នឹងត្រឡប់មកដល់តិរ្ថិយទាំងនោះ ដែលមិនអាចកន្លងទិដ្ឋិនោះបាន ម្យ៉ាងទៀត ជនតិរ្ថិយមានវាទៈថា ទៀងជាដើម ត្រូវការពេញចិត្តក្នុងទិដ្ឋិនោះគ្រប់សង្កត់ ហើយតាំងនៅក្នុងការពេញចិត្តក្នុងទិដ្ឋិ គប្បីកន្លងនូវទិដ្ឋិរបស់ខ្លួនបានដូចម្តេច ដែលពិត បុគ្គលនោះ ធ្វើទិដ្ឋិទាំងនោះឲ្យបរិបូណ៌ដោយខ្លួនឯង ខ្លួនឯងដឹងយ៉ាងណា ពោលយ៉ាងនោះ ។

សម័យនោះ ព្រះរាជាកាលកន្លងទៅ ៧ ថ្ងៃ ក៏ត្រាស់ឲ្យយកសពរបស់នាងសុន្ទរីនោះទៅចោល ពេលល្ងាច ទ្រង់យាងទៅកាន់ព្រះវិហារ ថ្វាយបង្គំព្រះមានព្រះភាគហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលការវិនាសយសបែបនេះកើតឡើង គួរប្រាប់ខ្ញុំព្រះអង្គផង ។ កាលព្រះរាជាក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគថ្វាយព្រះពរថា មហាបពិត្រ ការប្រាប់ដល់អ្នកដទៃថា តថាគតជាអ្នកមានសីល សម្បូរដោយគុណ ជាការសមគួរដល់ព្រះអរិយៈឬ ។ ព្រោះរឿងនោះជាអត្ថុប្បត្តិហេតុ ទើបត្រាស់គាថាដ៏សេសថា **យោ អត្តនោ សីលវតានិ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **សីលវតានិ** គឺសីលមានបាតិមោក្ខជាដើម និងធុតង្គ មានអារញ្ញិកធុតង្គជាដើម ។ បទថា **អនានុបុដ្ឋោ** គឺមិនចាំបាច់សួរឡើយ ។ បទថា **ចាវា** គឺពោលអួតអាង ។ បទថា **អនរិយធម្មំ កុសលា តមាហុ យោ អាតុមានំ សយមេវ ចាវា** គឺបុគ្គលណាពោលអួតអាងខ្លួនដោយខ្លួនឯង អ្នកប្រាជ្ញទាំងឡាយពោលបុគ្គលនោះថា ជាអ្នកមិនមានអរិយធម៌ ។ បទថា **សន្តោ** ប្រែថា អ្នកស្ងប់ ឈ្មោះថា **សន្តោ** ព្រោះស្ងប់កិលេសមានរាគៈជាដើម ។ បទថា **អភិនិព្វុតត្តោ** ក៏មានន័យដូចគ្នា ។ បទថា **ឥតិហន្តិ សីលេសុ អកត្ថមានោ** គឺមិនពោលអួតអាងក្នុងសីលទាំងឡាយ ដោយន័យជាដើមថា អាត្មាអញជាអ្នកដល់ព្រមហើយដោយសីល លោកអធិប្បាយថា មិនពោលវាចា បង្ហាញខ្លួនថា មានសីល ។ បទថា **តមរិយធម្មំ កុសលា វទន្តិ** គឺអ្នកឈ្លាសក្នុងខន្ធទាំងឡាយ មានព្រះពុទ្ធ

ជាដើម រមែងពោលភិក្ខុអ្នកមិនអួតអាងនោះថា ភិក្ខុនេះជាអ្នកមានអរិយធម៌ ។ បទថា **យស្សុស្សទា នត្ថិ កុហិញ្ចិ លោកេ** សេចក្តីថា ភិក្ខុជាខីណាស្រពណា មិនមានកិលេសជាគ្រឿងផ្សាយឡើង ៧ យ៉ាង មានរាគៈជាដើម ក្នុងលោកណាមួយ អ្នកប្រាជ្ញទាំងឡាយ រមែងហៅភិក្ខុអ្នកមិនអួតអាងនោះថា ភិក្ខុនេះ ជាអ្នកមានអរិយធម៌ ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់កិច្ចបដិបត្តិនៃព្រះខីណាស្រពយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងដល់កិច្ចបដិបត្តិរបស់ពួកតិរ្ថិយដែលជាមេលទ្ធិដល់ព្រះរាជា ទើបត្រាស់ថា **បកប្បិតា សង្ខតា** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **បកប្បិតា** គឺដែលបច្ច័យកំណាត់ហើយ ។ បទថា **សង្ខតា** គឺដែលបច្ច័យតាក់តែងហើយ ។ បទថា **យស្ស** គឺដល់មេលទ្ធិណាមួយ ។ បទថា **ធម្មា** គឺទិដ្ឋិ ។ បទថា **បុរក្ខតា** គឺធ្វើខាងមុខ ។ បទថា **សន្តិ** បានដល់ មាន ។ បទថា **អវីវទាតា** បានដល់ មិនសផូរផង់ ។ បទថា **យទត្តនិ បស្សតិ អានិសំសំ តំ និស្សិតោ កុប្បបដិច្ចសន្តឹ** សេចក្តីថា ធម៌ គឺទិដ្ឋិដែលបច្ច័យចោមរោមមិនផូរផង់ រមែងមានដល់បុគ្គលណា បុគ្គលនោះក៏យ៉ាងនេះ ព្រោះហេតុដែលបុគ្គលនោះឃើញសក្ការៈជាដើម ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងអានិសង្ស មានគតិវិសេសជាដើម ដែលប្រព្រឹត្តទៅក្នុងសម្បរាយភពនៃទិដ្ឋិនោះក្នុងខ្លួន ដូច្នោះ ទើបជាបុគ្គលអាស្រ័យអានិសង្សនោះ និងទិដ្ឋិដែលមាននោះ អាស្រ័យការកម្រើក ព្រោះការកម្រើក ព្រោះ

អាស្រ័យគ្នាកើតឡើង និងព្រោះមានដោយសន្មតិ បុគ្គលនោះគប្បីលើកខ្លួន ឬគប្បីសង្កត់សង្កិនអ្នកដទៃ ព្រោះអាស្រ័យទិដ្ឋិនោះ ដោយគុណ និងទោស សូម្បីមិនពិត និងដោយការអាស្រ័យយ៉ាងនេះ នរជនកាត់សម្រេចនូវធម៌ ដែលខ្លួនប្រកាន់មាំហើយ ក្នុងធម៌ទាំងឡាយ មិនគប្បីកន្លងនូវការប្រកាន់មាំ ដោយទិដ្ឋិបានដោយងាយឡើយ ព្រោះហេតុនោះ នរជនរមែងប្រកាន់ និង ប្រកាន់មាំក្នុងធម៌ ព្រោះការប្រកាន់មាំដោយទិដ្ឋិទាំងនោះ ។

ក្នុងបទទាំងនោះ បទថា **ទិដ្ឋីនិវេសា** គឺប្រកាន់មាំដោយទិដ្ឋិ បានដល់ ប្រកាន់មាំថា នេះជារបស់ពិត ។ បទថា **ន ហិ ស្វាតិវត្តា** បានដល់ មិនគប្បីកន្លងទៅដោយងាយឡើយ ។ បទថា **ធម្មេសុ និច្ឆេយ្យ សមុគ្គហីតំ** លោកអធិប្បាយថា មិនគប្បីកន្លងនូវការប្រកាន់មាំដោយទិដ្ឋិបានដោយងាយ ឡើយ ព្រោះនរជនកាត់នូវធម៌នោះៗ ដែលខ្លួនប្រកាន់ គឺប្រកាន់មាំ ប្រព្រឹត្ត ទៅហើយក្នុងធម៌ គឺទិដ្ឋិ ៦២ ។ ព្រោះដូច្នោះ នរជនរមែងប្រកាន់ និងប្រកាន់ មាំនូវធម៌ព្រោះការប្រកាន់មាំនោះ អធិប្បាយថា ព្រោះមិនកន្លងនូវការប្រកាន់ មាំដោយទិដ្ឋិបានដោយងាយ ដូច្នោះ នរជនរមែងប្រកាន់ប្រកាន់មាំ សេព និង សមាទានធម៌នោះៗ ដូចជា សីលពតែ សីលគោ សីលសុនខ តបៈ ៥ ទេវតាប្រាប់ហេតុ ( ទេវតាឲ្យឫក្ស ) ធ្វើសេចក្តីព្យាយាមដោយការអង្គុយ ប្រហោង និងដេកលើបន្លាជាដើម និងដូចជាពួកជនដែលពោលបន្ទាច់ធម៌ របស់ព្រះសាស្តាជាដើម លោកអធិប្បាយថា ដូចជាស្វាព្រៃដែលចាប់មែក ឈើនោះៗ ដូច្នោះ ។ នរជនកាលប្រកាន់ និងប្រកាន់មាំយ៉ាងនេះ ព្រោះមាន

ចិត្តមិនមាំទាំ ទើបធ្វើឲ្យយស និងមិនមែនយសកើតដល់ខ្លួន ឬដល់អ្នកដទៃ ដោយគុណ និងទោសដែលមិនមាន ។

បុគ្គលណា ឈ្មោះថា ជាអ្នកមានបញ្ញា ព្រោះប្រកបដោយបញ្ញាកម្ចាត់ទោស មានទិដ្ឋិទាំងពួងជាដើម បុគ្គលដែលមានបញ្ញានោះ មិនមានទិដ្ឋិដែលបច្ច័យកំណាត់ហើយក្នុងភពតូច និងភពធំ ក្នុងលោកណាមួយ បុគ្គលអ្នកមានបញ្ញានោះលះនូវមាយា និងមានះបានហើយ គប្បីដល់នូវការរាប់ចូលដោយគតិវិសេស ។ លោកអធិប្បាយដូចម្តេច លោកអធិប្បាយដូច្នេះថា បុគ្គលអ្នកមានបញ្ញា ព្រោះប្រកបដោយធោនធម៌ គឺធម៌ធ្វើឲ្យឈ្លាសវៃ កម្ចាត់បាបទាំងពួងបាន ជាអ្នកឆ្ងាយចាកកិលេស មិនមានទិដ្ឋិ ដែលបច្ច័យកំណាត់ហើយក្នុងភពទាំងឡាយនោះៗ ក្នុងលោកណាមួយ ព្រោះមិនមានទិដ្ឋិនោះ បុគ្គលដែលមានបញ្ញានោះ ទើបលះមាយា និងមានះនោះបាន ពួកត្រិយបិទបាំងនូវកម្មអាក្រក់ដែលខ្លួនធ្វើហើយ ដល់នូវអគតិដោយមាយា និងមានះ គប្បីចូលដល់ការរាប់ក្នុងគតិវិសេស មាននរកជាដើម ក្នុងទិដ្ឋធម៌ ឬសម្បរាយភពដោយគតិវិសេសណាមួយ ។ ពិតហើយ បុគ្គលអ្នកមានបញ្ញានោះ ឈ្មោះថា ជាអ្នកមិនមានតណ្ហា និងទិដ្ឋិ ព្រោះមិនមានតណ្ហា និងទិដ្ឋិទាំង ២ នៅអាស្រ័យ ។ មួយវិញទៀត បុគ្គលណា ឈ្មោះថា ជាអ្នកមានតណ្ហា និងទិដ្ឋិ

ព្រោះមានទាំង ២ យ៉ាងនោះ បុគ្គលមានតណ្ហា និងទិដ្ឋិ រមែងចូលដល់វាទៈក្នុងធម៌ទាំងឡាយ បុគ្គលនោះ គប្បីពោលនូវព្រះខីណាស្រពដែលមិនមានតណ្ហា និងទិដ្ឋិ ដោយហេតុអ្វីហ្ន៎ ការឃើញថាខ្លួន ឬការឃើញថាដាច់សូន្យ រមែងមិនមានដល់ព្រះខីណាស្រពនោះឡើយ ព្រោះព្រះខីណាស្រពនោះ លះតណ្ហា និងទិដ្ឋិបានទាំងអស់ ក្នុងអត្តភាពនេះ ដូច្នេះឯង ។

ក្នុងបទទាំងនោះ បទថា **ឧបយោ** គឺដែលតណ្ហា និងទិដ្ឋិអាស្រ័យហើយ ។ បទថា **ធម្មេសុ ឧបេតិ វាទំ** គឺចូលដល់វាទៈក្នុងធម៌ទាំងឡាយនោះៗ យ៉ាងនេះថា ត្រេកអរហើយ ដូច្នេះ ឬប្រទូស្តហើយ ដូច្នេះ ។ បទថា **អនូបយំ កេន កថំ វទេយ្យ** សេចក្តីថា គប្បីពោលនឹងព្រះខីណាស្រពជាអ្នកមិនមានតណ្ហា និងទិដ្ឋិ ព្រោះលះតណ្ហា និងទិដ្ឋិបានហើយ ជាអ្នកត្រេកអរ ឬជាអ្នកមិនត្រេកអរបានដូចម្តេច ដោយតម្រេក ឬដោយការប្រទូស្តណាមួយ អធិប្បាយថា ព្រះខីណាស្រពនោះ ជាអ្នកមិនគួរប្រទូស្តយ៉ាងនោះ និងជាអ្នកបិទបាំងនូវវត្ថុដែលធ្វើហើយ ដូចពួកតិរ្ថិយបានដូចម្តេច ។ បទថា **អត្តំ និរត្តំ ន ហិ តស្ស អត្ថិ** សេចក្តីថា ការឃើញថាជាខ្លួន ឬឃើញថាដាច់សូន្យ រមែងមិនមានដល់បុគ្គលមិនមានតណ្ហា និងទិដ្ឋិនោះ ឬសម្បីការកាន់យក និងការមិនកាន់យក ដែលហៅថា តម្រេកក្នុងខ្លួនក៏មិនមាន បើសួរថា

ព្រោះហេតុអ្វី ទើបមិនមាន ឆ្លើយថា ព្រោះបុគ្គលមិនមានតណ្ហា និងទិដ្ឋិនោះ លះនូវទិដ្ឋិបានទាំងអស់ក្នុងអត្តភាពនេះ អធិប្បាយថា ព្រោះមិនមានតណ្ហា និងទិដ្ឋិនោះ លះនូវទិដ្ឋិបានទាំងអស់ដោយខ្សល់ គឺញាណ ក្នុងអត្តភាព នេះឯង ។

ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនាដោយកំពូលនៃធម៌ គឺអរហត្ត ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយ ទ្រង់ពេញព្រះទ័យ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយទ្រង់យាងត្រឡប់ ។

**អដ្ឋកថាទុដ្ឋដ្ឋកសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## សុទ្ធដ្ឋកសូត្រទី៤

[ ៩៨ ] ជនពាលតែងដឹងថា អាត្មាអញឃើញ ( នូវរូប ) ស្អាតប្រសើរ មិនមានរោគ ការស្អាតតែងមានដល់សត្វ ដោយរូបដែលឃើញហើយ ការដឹងយ៉ាងនេះថា ប្រសើរ ដូច្នេះហើយ ជាអ្នកពិចារណាឃើញរឿយៗ ថាស្អាត រមែងជឿថាជាញាណ ។ ប្រសិនបើការស្អាត មានដល់សត្វ ព្រោះរូបដែលឃើញហើយមែន សត្វនោះគង់នឹងលះបង់នូវកងទុក្ខ ដោយញាណបាន ឬសត្វដែលប្រកបដោយឧបធិនោះ គង់នឹងស្អាតដោយមគ្គ មិនស្អាតដោយគុណដទៃ ព្រោះទិដ្ឋិ រមែងប្រាប់បុគ្គល អ្នកមានទិដ្ឋិនោះ ដែលពោលយ៉ាងនោះ ។ ខីណាសវព្រាហ្មណ៍ មិនពោលសរសើរនូវការស្អាត ត្រង់អារម្មណ៍ដែលបានឃើញ បានឮ បានប៉ះពាល់ ឬត្រង់សីល និងវត្ត ជាងអរិយមគ្គញាណទេ ( លោក ) មិនប្រឡាក់នឹងបុណ្យបាប លះបង់នូវសេចក្តីយល់ថា ខ្លួនមានធ្វើនូវកម្មក្នុងលោកនេះ ។ ពួកអ្នកសុទ្ធិវាទៈ អ្នកលុះក្នុងអំណាចតណ្ហា លះបង់នូវលទ្ធិមុនហើយ អាស្រ័យនូវលទ្ធិខាងក្រោយទៀត ពួកសុទ្ធិវាទៈនោះ រមែងឆ្លងនូវកិលេសគ្រឿងជាប់មិនរួចឡើយ សុទ្ធិវាទៈទាំងនោះ តែងកាន់យកខ្លះលះបោលវិញខ្លះ ដូចពានរចាប់យកមែកឈើ ដែលនៅចំពោះមុខ ។ សត្វកាន់យកនូវវត្តទាំងឡាយ ដោយខ្លួនឯង

ជាសត្វជាប់ស្អិតក្នុងកាមសញ្ញាហើយ តែងទៅគប់រកគ្រូខ្ពស់ និងទាប អ្នកប្រាជ្ញមានបញ្ញាក្រាស់ដូចផែនដី ត្រាស់ដឹងនូវសច្ចធម៌ដោយវេទ គឺមគ្គញាណទាំង ៤ មិនបានទៅគប់រកគ្រូខ្ពស់ និងទាបឡើយ ។ អ្នកប្រាជ្ញនោះ កម្ចាត់បង់នូវមារសេនាហើយ ឋិតនៅនឹងនួន ក្នុងអារម្មណ៍ទាំងពួង ទោះអារម្មណ៍ដែលឃើញ ដែលឮ ដែលប៉ះពាល់ណាមួយក្តី ( អ្នកណាមួយ ) គប្បីកំណត់នូវអ្នកប្រាជ្ញ អ្នកឃើញ ( ដ៏បរិសុទ្ធ ) មានគ្រឿងប្រក់ គឺកិលេសបើកហើយនោះឯង ដោយគ្រឿងកំណត់ណាក្នុងលោកបាន ។ អ្នកប្រាជ្ញទាំងឡាយ បែបនោះមិនកំណត់ មិនធ្វើតណ្ហា និងទិដ្ឋិ ឲ្យជាប្រធាន ទាំងមិនពោលសរសើរនូវទិដ្ឋិថាជារបស់ស្អាតម៉ត់ចត់ទេ តែងផ្តាច់ចោលនូវចំណង គឺសេចក្តីប្រកាន់ ដែលចងក្នុងចិត្តសន្ដានរបស់ខ្លួន តែងមិនធ្វើសេចក្តីប្រាថ្នាក្នុងសន្ដានឯណានីមួយក្នុងលោកទេ ។ ( អ្នកប្រាជ្ញនោះ ) ប្រព្រឹត្តកន្លងនូវខេត្តដែន ( កិលេស ) បន្សាត់បង់បាប លោកមិនមានសេចក្តីប្រកាន់ ព្រោះជ្រាប ព្រោះឃើញទេ លោកមិនត្រេកអរក្នុងកាមរាគ មិនរីករាយក្នុងរូបភព និងអរូបភព អ្នកប្រាជ្ញនោះ មិនមានសេចក្តីប្រកាន់ថា នេះជារបស់ប្រសើរក្នុងលោកនេះឡើយ ។

សុទ្ធដ្ឋកសូត្រទី ៤ ចប់

# អដ្ឋកថា

## សុទ្ធដ្ឋកសូត្រ

[ ៩៨ ] ក្នុងសុទ្ធដ្ឋកសូត្រទី ៤ មានពាក្យផ្តើមថា **បស្សាមិ សុទ្ធំ** ដូច្នេះ ។

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្តេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូច្នេះ

បានឮថា ក្នុងអតីតកាល ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមកស្សបៈ កុដុម្ពិកៈម្នាក់ ជាអ្នកក្រុងពារាណសី បានទៅកាន់បច្ចន្តជនបទមួយអន្លើដោយរទេះ ៥០០ ដើម្បីជួញដូរក្នុងទីនោះ ។ កុដុម្ពិកៈបានធ្វើសេចក្តីស្និទ្ធស្នាលជាមួយព្រានព្រៃ ឲ្យរបស់ប្រើប្រាស់ដល់បុរសនោះហើយសួរថា សម្លាញ់ឯងធ្លាប់ឃើញខ្លឹមចន្ទន៍ខ្លះដែរឬទេ កាលព្រានព្រៃឆ្លើយថាធ្លាប់ឃើញ ទើបចូលទៅព្រៃចន្ទន៍ជាមួយបុរសនោះ កាប់ដើមចន្ទន៍ដាក់ពេញរទេះទាំង ៥០០ ហើយពោលនឹងព្រានព្រៃនោះថា សម្លាញ់ បើឯងមកពារាណសី ឯងគប្បីយកខ្លឹមចន្ទន៍មកផង ហើយត្រឡប់ទៅនគរពារាណសីវិញ ។ ក្រោយមក ព្រានព្រៃនោះ ក៏យកខ្លឹមចន្ទន៍ទៅផ្ទះកុដុម្ពិកៈនោះ កុដុម្ពិកៈឃើញព្រានព្រៃក៏ទទួលយ៉ាងល្អ លុះដល់វេលាល្ងាច ឲ្យបុកខ្លឹមចន្ទន៍ដាក់ពេញស្មុគ ហើយពោលថា នែសម្លាញ់ ចូរឯងងូតទឹក ហើយត្រឡប់មកចុះ ហើយបញ្ជូនបុរសនោះទៅកាន់កំពង់ទឹកជាមួយមនុស្សរបស់ខ្លួន ។ ពេលនោះនៅឯក្រុងពារាណសី កំពុងមានមហោស្រព ។ អ្នកក្រុងពារាណសីថ្វាយទានអំពីព្រលឹម វេលាល្ងាច ស្លៀកសំពត់សាច់ល្អ កាន់ផ្កានិងគ្រឿងក្រអូប

ជាដើម ទៅថ្វាយបង្គំព្រះមហាចេតិយ របស់ព្រះមានព្រះភាគព្រះនាមកស្សបៈ ព្រានព្រៃឃើញមនុស្សទាំងនោះ ក៏សួរថា តើពួកគេទៅណា កាលបានស្តាប់ថា ពួកគេទៅវិហារ ថ្វាយបង្គំព្រះចេតិយ ខ្លួនឯងក៏ទៅក្នុងទីនោះ ព្រានព្រៃឃើញបុគ្គលដែលធ្វើការបូជាព្រះចេតិយ ដោយវិធីផ្សេងៗ មានបូជាដោយហរតាល និងមនោសិលាជាដើម ខ្លួនឯងមិនដឹងថា ធ្វើអ្វីឲ្យស្អាត ទើបយកខ្លឹមចន្ទន៍នោះ ធ្វើជារង្វង់មូលប្រមាណប៉ុនថាសសំរិទ្ធិ ដាក់ខាងលើឥដ្ឋមាសក្នុងមហាចេតិយនោះ កាលនោះ ក្នុងពេលដែលព្រះអាទិត្យរះឡើង រស្មីព្រះអាទិត្យក៏បញ្ចេញពន្លឺ គាត់ឃើញដូច្នោះ ជ្រះថ្លា ធ្វើសេចក្តីប្រាថ្នាថា បើខ្ញុំកើតក្នុងទីណា សូមឲ្យរស្មីបែបនេះកើតឡើងត្រង់ទ្រូងរបស់ខ្ញុំ ។ ព្រានព្រៃបានធ្វើកាលកិរិយាហើយ ទៅកើតក្នុងស្ថានសួគ៌ជាន់តាវត្តិង្ស រស្មីបានផុសឡើងត្រង់ទ្រូងរបស់ទេវបុត្តនោះជារង្វង់ រុងរឿងដូចមណ្ឌលព្រះចន្ទ ។ ទើបជនទាំងឡាយហៅទេវបុត្តនោះថា ចន្ទាភទេវបុត្ត ។

ចន្ទាភទេវបុត្តនោះ ញុំាងពុទ្ធន្តរមួយឲ្យអស់ទៅ ដោយអន្ទោលទៅមកក្នុងស្ថានសួគ៌ ៦ ជាន់នោះ ដោយសម្បត្តិនោះ កាលព្រះមានព្រះភាគរបស់យើងកើតឡើងក្នុងលោក បានច្យុតមកកើតក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងក្រុងសាវត្ថី ត្រង់ទ្រូងរបស់គាត់ មានរស្មីជារង្វង់ ដូចគ្នានឹងមណ្ឌលរបស់ព្រះចន្ទ ក្នុងថ្ងៃដាក់ឈ្មោះ ពួកព្រាហ្មណ៍ធ្វើមង្គល ឃើញរស្មីជារង្វង់នោះ ទើបអស្ចារ្យក្នុងចិត្ត គិតថា កុមារនេះ លក្ខណៈជាអ្នកមានបុណ្យ ទើបដាក់ឈ្មោះថា ចន្ទាភៈដូចគ្នា ។ ព្រាហ្មណ៍ទាំងឡាយ នាំកុមារ

ដែលចម្រើនវ័យហើយ គាត់តែងយ៉ាងល្អ ឲ្យឡើងលើរថ នាំគ្នាបូជា ពោលថា នេះមហាព្រហ្មរបស់យើង ហើយត្រាច់ប្រកាសទៅតាមនិគម រាជធានីថា អ្នកណាបានឃើញចន្ទាភៈ អ្នកនោះនឹងបានយស និងទ្រព្យជាដើម ស្លាប់ហើយ នឹងទៅកើតក្នុងស្ថានសួគ៌ ។ ក្នុងទីដែលទៅហើយ ពួកជននាំគ្នាមកច្រើនឡើងៗ ដោយឮដំណឹងដែលគេប្រកាសថា អ្នកដ៏ចម្រើនទាំងឡាយ កុមារឈ្មោះចន្ទាភៈនេះ បុគ្គលណាឃើញ បុគ្គលនោះនឹងបានយស បានទ្រព្យ នឹងបានស្ថានសួគ៌ជាដើម ក៏ញាប់ញ័រពេញជម្ពូទ្វីប ។ ពួកព្រាហ្មណ៍មិនបង្ហាញដល់បុគ្គលដែលមកដៃទទេ បង្ហាញចំពោះបុគ្គលដែលកាន់យកទ្រព្យ ១០០ ឬ ១០០០ មកឲ្យប៉ុណ្ណោះ ។ ពួកព្រាហ្មណ៍នាំចន្ទាភកុមារត្រាច់ទៅយ៉ាងនេះ រហូតដល់ក្រុងសាវត្ថីតាមលំដាប់ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ប្រកាសធម្មចក្រដ៏ប្រសើរ បានយាងមកដល់ក្រុងសាវត្ថីដោយលំដាប់ កាលទ្រង់សម្ដែងធម៌ដើម្បីប្រយោជន៍ដល់ជនច្រើន ទើបគង់ក្នុងវត្តជេតពន-មហាវិហារ ក្នុងក្រុងសាវត្ថី ។ សម័យនោះ ចន្ទាភកុមារ បានទៅដល់ក្រុងសាវត្ថី មិនមានអ្នកណាឲ្យតម្លៃ ជាបុគ្គលដូចស្ទឹងតូចហូរទៅក្នុងមហាសមុទ្រដូច្នោះ សូម្បីអ្នកនិយាយដល់ចន្ទាភៈក៏មិនមាន ក្នុងវេលាល្ងាច ចន្ទាភៈឃើញពួកជននាំគ្នាកាន់គ្រឿងក្រអូប និងផ្កាជាដើម បែរមុខទៅកាន់វត្តជេតពន-មហាវិហារ ទើបសួរថា ពួកលោកនាំគ្នាទៅណា មហាជនឆ្លើយថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក ទ្រង់សម្ដែងធម៌ដើម្បីជាប្រយោជន៍ដល់មហាជន ខ្ញុំទៅព្រះវិហារជេតពនដើម្បីស្ដាប់ធម៌ ។

ចន្ទាភៈ បានស្តាប់ពាក្យនោះហើយ ចោមរោមដោយគណៈព្រាហ្មណ៍ ក៏បានទៅក្នុងវត្តជេតពនមហាវិហារនោះ ក្នុងកាលនោះ ព្រះមានព្រះភាគ គង់លើបវរពុទ្ធាសនៈ ក្នុងធម្មសភា ។ ចន្ទាភៈចូលទៅគាល់ព្រះមានព្រះភាគ ធ្វើបដិសណ្ឋារៈដោយពាក្យពីរោះ ហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ រំពេចនោះឯង ពន្លឺរបស់ចន្ទាភៈក៏បាត់ទៅ ។ ព្រោះនៅក្នុងទីជិតព្រះរស្មី របស់ព្រះពុទ្ធខាងក្នុង ៨០ ហត្ថ រស្មីដទៃគ្របសង្កត់មិនបាន ។ ចន្ទាភៈនោះ មិនអង្គុយ ដោយគិតថា រស្មីរបស់អញបាត់ទៅហើយ ទើបក្រោកឡើង ត្រៀមនឹងត្រឡប់ ។ លំដាប់នោះ បុរសម្នាក់ពោលនឹងចន្ទាភៈថា លោក ចន្ទាភៈដ៏ចម្រើន លោកខ្លាចសមណៈឬ ទើបត្រឡប់ ចន្ទាភៈឆ្លើយថា យើង មិនខ្លាចទេ ម្យ៉ាងទៀត រស្មីរបស់យើងមិនប្រាកដ ដោយតេជះរបស់សមណៈ នេះ ។ ចន្ទាភៈត្រឡប់ទៅអង្គុយខាងមុខព្រះមានព្រះភាគ ឃើញការសម្បូរ មានព្រះរូប ព្រះរស្មី និងព្រះលក្ខណៈជាដើម តាំងអំពីផ្ទៃព្រះបាទ រហូតដល់ ចុងព្រះកេសា មានចិត្តជ្រះថ្លាក្រៃលែង គិតថា ព្រះសមណគោតម មានសក្តិ ច្រើន រស្មីបន្តិចបន្តួចកើតឡើងត្រង់ទ្រូងរបស់អញ គង់ពួកព្រាហ្មណ៍នាំអញ ត្រាច់ទៅពេញជម្ពូទ្វីបយ៉ាងនេះ ហើយព្រះសមណគោតម ជាបុគ្គលប្រកប ដោយការសម្បូរនៃព្រះលក្ខណៈដ៏ល្អ ទ្រង់មិនប្រកាន់ខ្លួនឡើយ សមណៈនេះ ប្រកបដោយគុណសម្បត្តិដ៏ល្អ ទ្រង់ពិតជាសាស្តារបស់ទេវតា និងមនុស្ស ទាំងឡាយដោយពិត ទើបថ្វាយបង្គំព្រះមានព្រះភាគ ទូលសូមបួស ។ ព្រះ មានព្រះភាគមានព្រះពុទ្ធតម្រាស់នឹងព្រះថេរៈមួយរូបថា ចូរអ្នកបំបួសចន្ទាភៈ

នេះ ព្រះថេរៈនោះកាលឲ្យចន្ទាភៈបួសហើយ ក៏ប្រាប់តចបញ្ចកកម្មដ្ឋាន ។ ចន្ទាភភិក្ខុផ្ដើមចម្រើនវិបស្សនាហើយ មិនយូរប៉ុន្មានក៏សម្រេចអរហត្ត មានឈ្មោះថា ចន្ទាភត្ថេរ ។

ភិក្ខុទាំងឡាយ ប្រជុំសន្ទនាគ្នាប្រារព្ធចន្ទាភត្ថេរថា អាវុសោទាំងឡាយ បុគ្គលដែលឃើញចន្ទាភៈហើយ នឹងបានយស ទ្រព្យ ឬបានទៅកាន់ស្ថានសួគ៌ ឬបានដល់នូវសេចក្ដីបរិសុទ្ធ ដោយឃើញរូបតាមចក្ខុទ្វារនោះឬហ្ន៎ ព្រះមានព្រះភាគត្រាស់សូត្រនេះ ព្រោះរឿងរបស់ចន្ទាភត្ថេរនេះឯងជាហេតុនេះ ។

ក្នុងសូត្រនោះ គប្បីជ្រាបសេចក្ដីក្នុងគាថាដំបូងសិន ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការបរិសុទ្ធមិនមានដោយការឃើញបែបនេះឡើយ មួយប្រការទៀត បុគ្គលពាលដែលជាមិច្ឆាទិដ្ឋិ ឃើញចន្ទាភព្រាហ្មណ៍ ឬបុគ្គលដទៃដែលមានសភាពបែបនោះ ឈ្មោះថា មិនបរិសុទ្ធ ព្រោះសៅហ្មងដោយកិលេស ឈ្មោះថា មិនមានរោគ ព្រោះមិនប្រាសចាករោគ គឺកិលេសហើយសម្គាល់ឯងថា បានឃើញបុគ្គលបរិសុទ្ធ ជាបុគ្គលជំក្រៃលែង មិនមានរោគ ការបរិសុទ្ធដោយល្អ រមែងមានដល់នរជនដោយការឃើញ ដែលបានដល់ ការដែលខ្លួនបានឃើញហើយនោះ ។ បុគ្គលពាលនោះ សម្គាល់យកឯងយ៉ាងនេះថា ដឹងថា ការឃើញនោះ ជាការឃើញក្រៃលែង កាលជាបុគ្គលឃើញថា បរិសុទ្ធក្នុងការឃើញនោះ ក៏ជឿថា ការឃើញនោះ ជាមគ្គញាណ ។ តែការឃើញនោះ មិនមែនជាមគ្គញាណឡើយ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **បស្សាមិ សុទ្ធំ** ដូច្នេះ ។

គប្បីជ្រាបអត្ថនៃគាថាទី ២ ថា បើសេចក្តីបរិសុទ្ធនៃកិលេស រមែងមានដល់នរជន ដោយការឃើញ ពោល គឺការឃើញរូបនោះ ឬនរជននោះរមែងលះនូវទុក្ខ មានជាតិជាដើមបានដោយញាណនោះ កាលបើដូច្នោះ ក៏កើតការឃើញថា នរជននោះ រមែងបរិសុទ្ធបានដោយមគ្គដែលមិនបរិសុទ្ធដទៃចាកអរិយមគ្គ នរជនអ្នកមានឧបធិ ក៏នឹងបរិសុទ្ធបានដោយឧបធិ មានរាគៈជាដើម តែនរជនបែបនេះ រមែងមិនបរិសុទ្ធឡើយ ព្រោះដូច្នោះ ទើបទិដ្ឋិសបញ្ជាក់បុគ្គលនោះ ដែលពោលយ៉ាងនោះ គឺទិដ្ឋិនោះ រមែងសបញ្ជាក់ដល់បុគ្គលនោះថា បុគ្គលនេះជាមិច្ឆាទិដ្ឋិ តែអាចារ្យពួកខ្លះពោលយ៉ាងនោះដោយន័យជាដើមថា លោកទៀង ដូច្នេះ ។

គប្បីជ្រាបគាថាទី ៣ ថា **ន ព្រាហ្មណោ** ដូច្នេះជាដើម ។ បទនោះមានសេចក្តីដូចតទៅនេះ បុគ្គលណា ឈ្មោះថា ជាព្រាហ្មណ៍ ព្រោះជាអ្នកបន្សាត់បាបបានហើយ បុគ្គលនោះ ជាព្រាហ្មណខីណាស្រព ដល់នូវការអស់អាសវៈដោយមគ្គ មិនពោលសេចក្តីបរិសុទ្ធដោយមិច្ឆាទិដ្ឋិញាណដទៃ ក្រៅអំពីអរិយមគ្គញាណ ដែលកើតឡើងព្រោះរូបដែលបានឃើញ បានដល់ រូបសម្បត្តិ ថាជាមង្គលក្រៃលែង ព្រោះសំឡេងដែលបានស្តាប់ ដែលបានដល់សំឡេងយ៉ាងនោះ ក្នុងសីល ដែលបានដល់ការមិនកន្លង ព្រោះវត្ត មានវត្តដំរីជាដើម និងព្រោះអារម្មណ៍ដែលបានជ្រាប មានបឋវីធាតុជាដើម ។ បទដ៏សេស ព្រះមានព្រះភាគត្រាស់ដើម្បីលើកតម្កើងព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍នោះមិនបានជាប់ក្នុងបុណ្យ ដែលមានធាតុ ៣ និងក្នុងបាបទាំងពួង ឈ្មោះថា

លះនូវការឃើញថា ជារបស់ខ្លួនបាន ព្រោះលះនូវទិដ្ឋិថា ជាខ្លួនបានហើយ ឬព្រោះលះនូវការប្រកាន់ណាមួយបាន ត្រាស់ថា មិនប្រឡាក់នឹងបុណ្យបាប ព្រោះមិនធ្វើបុញ្ញាភិសង្ខារជាដើម ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សរសើរព្រាហ្មណ៍នោះ ទើបត្រាស់យ៉ាងនេះ ។ ម្យ៉ាងទៀត គប្បីជ្រាបការភ្ជាប់សេចក្ដីនៃបទទាំងអស់នោះ ដោយបទដើម ដូច្នេះ ព្រាហ្មណ៍មិនជាប់ក្នុងបុណ្យ និងបាប លះបង់នូវសេចក្ដីយល់ថា ខ្លួនមានធ្វើកម្មក្នុងលោកនេះ ព្រាហ្មណ៍មិនពោលដល់សេចក្ដីបរិសុទ្ធ ដោយមិច្ឆាទិដ្ឋិញាណដទៃចាកអរិយ-មគ្គញាណ ។ ព្រះមានព្រះភាគ កាលត្រាស់ថា **ន ព្រាហ្មណោ អញ្ញតោ សុទ្ធិមាហ** ដូច្នេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងថា ព្រាហ្មណ៍ដែលមានទិដ្ឋិពោលដល់សេចក្ដីបរិសុទ្ធដទៃ ចាកអរិយមគ្គញាណក្រៅអំពីទិដ្ឋិនោះមិនបាន ទើបត្រាស់គាថាថា **បុរិមំ បហាយ** ដូច្នេះ ។

បទនោះ មានសេចក្ដីដូចតទៅនេះថា ពិតហើយ ព្រាហ្មណ៍ទាំងនោះជាអ្នកមានវាទៈថា បរិសុទ្ធចាកអរិយមគ្គដទៃ លះសាស្ដាខាងដើមជាដើមចោល អាស្រ័យសាស្ដាដទៃ ដោយទិដ្ឋិដែលផុតពីការប្រកាន់ ព្រោះមិនទាន់លះបាន ដែលតណ្ហា គឺការចង់បានគ្របសង្កត់ រមែងឆ្លងនូវធម៌ជាគ្រឿងជាប់ជំពាក់ មានរាគៈជាដើមទៅមិនបាន កាលឆ្លងធម៌ដែលជាគ្រឿងជាប់ជំពាក់នោះៗ មិនបាន ឈ្មោះថា កាន់យកធម៌នោះ ដោយលះនូវធម៌នោះមិនបានផងដែរ ដូចស្វាចាប់ និងលែងមែកឈើចំពោះមុខ ដើម្បីចាប់មែកឈើដទៃ ដូច្នោះ ។

គប្បីជ្រាបការភ្ជាប់សេចក្តីនៃគាថាទី ៥ ដូចតទៅនេះ សត្វនោះ ដែលត្រាស់ថា ព្រោះទិដ្ឋិ រមែងប្រាប់បុគ្គលអ្នកមានទិដ្ឋិនោះ ដែលពោលយ៉ាងនោះ ដោយបទថា សត្វកាន់យកនូវវត្ថុទាំងឡាយដោយខ្លួនឯង ។

ក្នុងបទទាំងនោះ បទថា **សយំ** បានដល់ ដោយឯង ។ បទថា **សមាទាយ** បានដល់ កាន់យក ។ បទថា **វតានិ** បានដល់ វត្ថុដ៏វីជាដើម ។ បទថា **ឧច្ចាវចំ** គឺជ្រើសរើសសាស្តាជាដើមម្តងហើយម្តងទៀត ឬអាក្រក់និងប្រណីត ។ បទថា **សញ្ញសត្តោ** គឺជាប់ជំពាក់ក្នុងកាមសញ្ញាជាដើម ។ បទថា **វិទ្វា ច វេទេហិ សមេច្ច ធម្មំ** សេចក្តីថា ជាអ្នកដឹងច្បាស់នូវបរមត្ថធម៌ ជាព្រះអរហន្ត ត្រាស់ដឹងនូវធម៌ គឺអរិយសច្ច ៤ ដោយវេទ គឺមគ្គញាណ ៤ ។ បទដ៏សេសជាក់ច្បាស់ហើយ ។ បទថា **ស សព្វធម្មេសុ វិសេនិភូតោ យំ កិញ្ចិ ទិដ្ឋំ វ សុតំ មុតំ វា** សេចក្តីថា ព្រះខីណាស្រពដែលមានបញ្ញានោះ ឈ្មោះថា ជាអ្នកគ្របសង្កត់នូវមារ និងសេនា ព្រោះធ្វើមារនិងសេនាឲ្យវិនាសទៅក្នុងធម៌ទាំងពួងនោះ គឺអារម្មណ៍ណាមួយ ដែលបានឃើញ បានឮ ឬបានជ្រាប ។ បទថា **តមេវ ទស្សឹ** គឺព្រះខីណាស្រពនោះ ជាអ្នកឃើញបរិសុទ្ធយ៉ាងនេះ ។ បទថា **វិវដំ ចរន្តំ** គឺកិលេសដែលបើកហើយ ព្រោះប្រាសចាកដំបូល គឺតណ្ហាជាដើមត្រាច់ទៅ ។ បទថា **កេនីធ**

**លោកស្មឹ វិកប្បយេយ្យ** សេចក្ដីថា បុគ្គលណាម្នាក់ គប្បីកំណត់ព្រះខីណាស្រព ដោយការកំណត់ដោយតណ្ហា ឬដោយការកំណត់ដោយទិដ្ឋិណាមួយក្នុងលោកនេះ ឬគប្បីកំណត់ដោយរាគៈជាដើម ដូចបានពោលហើយខាងដើម ព្រោះលះតណ្ហា និងទិដ្ឋិបានហើយ ។

គប្បីជ្រាបការភ្ជាប់សេចក្ដីនៃគាថាថា **ន កប្បយន្តិ** ដូច្នេះ ។ មានអ្វីដែលគួរពោលក្រៃលែងជាងនោះ ព្រោះព្រះខីណាស្រពទាំងនោះ ជាបុគ្គលស្ងប់ អ្នកប្រាជ្ញទាំងឡាយបែបនោះមិនកំណត់ មិនធ្វើតណ្ហា និងទិដ្ឋិឲ្យជាប្រធាន ក្នុងបណ្ដាការកំណត់ និងការធ្វើទុកខាងមុខទាំង ២ យ៉ាងនោះ ព្រះខីណាស្រពទាំងនោះ រមែងមិនពោលថា សេចក្ដីបរិសុទ្ធមានទីបំផុតដោយអរិយទិដ្ឋិ និងសស្សតទិដ្ឋិដែល មិនជាសេចក្ដីបរិសុទ្ធ ដោយឥតសេសសល់ ព្រោះមិនទាន់ប្រាសចាកសេចក្ដីបរិសុទ្ធដោយបរមត្ថ ។ បទថា **អាទានគន្ថំ គធិតំ វិសជ្ជ** សេចក្ដីថា លោកលះបង់ គឺកាត់នូវគន្ថកិលេសជាគ្រឿងរួបរឹត ដែលធ្វើឲ្យប្រកាន់មាំ ព្រោះជាហេតុឲ្យប្រកាន់មាំជាដើម ៤ យ៉ាង ដែលចងរឹតជាប់ក្នុងសន្ដានរបស់ខ្លួន បានដោយសស្ត្រា គឺអរិយមគ្គ ។

បទថា **សីមាតិគោ** សេចក្ដីថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ដោយទេសនាដែលជាបុគ្គលាធិដ្ឋានតែម្យ៉ាង ។ ការអធិប្បាយភ្ជាប់សេចក្ដីនៃគាថា

នោះ ដូចគ្នានឹងគាថាមុននោះឯង ។ គឺគប្បីជ្រាបដូចគ្នានឹងអដ្ឋកថា ។ លោកអធិប្បាយបន្ថែមថា ព្រះខីណាស្រពដែលមានបញ្ញាដូចផែនដីបែបនេះ ឈ្មោះថា កន្លងដែននៃកិលេសបាន ព្រោះកន្លងព្រំដែននៃកិលេស ៤ យ៉ាងបាន ឈ្មោះថា ជាព្រាហ្មណ៍ ព្រោះជាអ្នកបន្សាត់បាបចោលហើយ លោកមិនមានសេចក្តីប្រកាន់ថាជាយ៉ាងនេះ ព្រោះជ្រាប ដោយញាណ គឺដឹងចិត្តអ្នកដទៃ និងដឹងការរឭកជាតិបាន ព្រោះបានឃើញដោយមំសចក្ខុ និងទិព្វចក្ខុ មិនមានសេចក្តីប្រកាន់ គឺមិនមានការប្រកាន់មាំ ព្រះខីណាស្រពនោះ លោកមិនត្រេកអរដោយកាមរាគៈ ព្រោះមិនមានកាមរាគៈ ជាអ្នកមិនមានតម្រេកក្នុងសមាបត្តិដែលប្រាសចាកតម្រេក ព្រោះមិនមានរូបរាគៈ និងអរូបរាគៈ ព្រះខីណាស្រពនោះមិនមានការប្រកាន់ដោយវត្ថុ និងអារម្មណ៍ណាមួយថា វត្ថុនេះជារបស់ក្រៃលែង ក្នុងលោកនេះ ។ ព្រះមានព្រះភាគទ្រង់បញ្ចប់ទេសនាដោយកំពូលនៃធម៌ គឺអរហត្ត ៕ល៚

## អដ្ឋកថាសុទ្ធដ្ឋកសូត្រទី ៤ ចប់

# សុត្តន្តបិដក

## បរមដ្ឋកសូត្រទី៥

[ ៩៩ ] សត្វនៅត្រាំក្នុងទិដ្ឋិទាំងឡាយថា នេះប្រសើរ តែងលើក ( គោរព ) គ្រូណាថា វិសេសផុតក្នុងលោក បានពោលបន្ទាប់ ពួកគ្រូទាំងអស់ដទៃ អំពីគ្រូខ្លួននោះថាថោកទាប ព្រោះហេតុនោះ បានជាសត្វប្រព្រឹត្តកន្លង នូវវិវាទទាំងឡាយមិនរួច ។ សត្វឃើញនូវអានិសង្សណាក្នុងខ្លួន ត្រង់អារម្មណ៍ដែលបានឃើញ បានឮ បានប៉ះពាល់ ឬត្រង់សីល និងវត្ត សត្វនោះប្រកាន់ខ្ជាប់ នូវអានិសង្សនោះ ក្នុងសក្កាយទិដ្ឋិនោះ ហើយឃើញនូវគ្រូដទៃទាំងអស់ថា ថោកថយ ។ សត្វអាស្រ័យគ្រូរបស់ខ្លួន ហើយឃើញគ្រូដទៃថា ថោកថយ អ្នកប្រាជ្ញទាំង-ឡាយ ពោលនូវការឃើញនោះថា ជាចំណងពិត ព្រោះហេតុនោះ ភិក្ខុមិនគប្បីអាស្រ័យអារម្មណ៍ ដែលបានឃើញ បានឮ បានប៉ះពាល់ ឬសីល និងវត្តឡើយ ។ ភិក្ខុមិនគប្បីធ្វើទិដ្ឋិ ឲ្យកើតឡើងក្នុងលោកដោយញាណ ឬដោយសីល និងវត្តទេ មិនគប្បីប្រៀបធៀបខ្លួនថា អាត្មាអញជាអ្នកស្មើ ( នឹងគេ ) ទេ មិនគប្បីសម្គាល់ខ្លួនថា អាត្មាអញជាអ្នកថោកថយទេ ឬថា អាត្មាអញជាអ្នកវិសេសជាងគេទេ ។ កាលភិក្ខុនោះ លះបង់នូវអត្តទិដ្ឋិហើយ មិនប្រកាន់មាំ ទាំងមិនសន្សំនូវនិស្ស័យ ក្នុងញាណ កាលបើសត្វបែកផ្សេងគ្នា ភិក្ខុនោះ ក៏មិនប្រព្រឹត្តជា

ពួក ភិក្ខុនោះ មិនត្រឡប់មកកាន់ទិដ្ឋិនីមួយទេ ។ ព្រះខីណា-ស្រពណា មិនមានតណ្ហា ដើម្បីនឹងកើតរឿយៗ ក្នុងលោកនេះ ឬលោកខាងមុខ ត្រង់ទីបំផុតទាំងពីរទៀតទេ ព្រះខីណាស្រព ណា មិនមានទីអាស្រ័យនៅនីមួយឡើយ ព្រះខីណាស្រពនោះ ( មិនមាន ) សេចក្ដីប្រកាន់ ព្រោះពិចារណាឃើញ ក្នុងពួក ទិដ្ឋិធម៌ទាំងឡាយ សូម្បីសញ្ញាតិចតួច ដែលកំណត់ក្នុងអា-រម្មណ៍ បានឃើញ បានឮ បានប៉ះពាល់ក្នុងលោកនេះ របស់ព្រះខីណាស្រពនោះ ក៏មិនមានឡើយ បុគ្គលណាគប្បីកំណត់នូវខីណាសវព្រាហ្មណ៍នោះ អ្នកមិនប្រកាន់នូវទិដ្ឋិ ដោយសេចក្ដីកំណត់ដូចម្ដេច ក្នុងលោកនេះបាន ។ ព្រះខីណាស្រព ទាំងឡាយមិនកំណត់ មិនធ្វើតណ្ហា និងទិដ្ឋិ ឲ្យជាប្រធានទេ ធម៌ទាំងឡាយ គឺទិដ្ឋិមិនបិទបាំង ( បញ្ញា ) របស់ព្រះខីណា-ស្រពទាំងអម្បាលនោះបានឡើយ ព្រះខីណាសវព្រាហ្មណ៍ មិនប្រព្រឹត្តទៅតាមសីល និងវត្ត ( ជាទេ ) ទេ បានដល់ត្រើយ គឺព្រះនិព្វាន មានសភាពជាតាទិបុគ្គល មិនត្រឡប់មកកាន់ភព ( ថ្មី ) ទៀតឡើយ ។

**បរមដ្ឋកសូត្រទី ៥ ចប់**

# អដ្ឋកថា

## បរមដ្ឋកសូត្រ

[ ៩៩ ] ក្នុងបរមដ្ឋកសូត្រទី ៥ មានពាក្យផ្តើមថា **បរមន្តិ ទិដ្ឋីសុ** ដូច្នេះ សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្តេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូច្នេះ

បានឮថា កាលព្រះមានព្រះភាគ គង់នៅក្នុងក្រុងសាវត្ថី ពួកតិរ្ថិយផ្សេងៗ ប្រជុំគ្នាសម្តែងទិដ្ឋិរៀងៗ ខ្លួនថា វត្ថុនេះក្រៃលែង កើតនូវការប្រកែកគ្នា ហើយនាំគ្នាទៅក្រាបទូលព្រះរាជាៗ ឲ្យប្រជុំមនុស្សភ្នែកខ្វាក់អំពីកំណើតជាច្រើន ហើយត្រាស់ថា ចូរពួកអ្នកយកដំរីមកឲ្យមនុស្សទាំងនេះមើល ។ ពួករាជបុរសឲ្យមនុស្សភ្នែកខ្វាក់ប្រជុំហើយ ប្រាប់ថា ចូរលាដៃទៅខាងមុខហើយស្ទាបមើល ។ ពួកមនុស្សភ្នែកខ្វាក់ទាំងនោះ ស្ទាបអវយវៈរបស់ដំរីម្នាក់មួយចំណែក ។ ព្រះរាជាត្រាស់សួរថា នែអ្នក ដំរីដូចអ្វី បុរសដែលស្ទាបប្រមោយ ក៏ទូលថា ដូចយាមនង្គ័ល ។ ពួកដែលស្ទាបក្លុក ក៏ជេរបុរសម្នាក់នោះ ពោលថា នែអ្នក កុំនិយាយកុហកចំពោះព្រះភក្ត្រព្រះរាជា ហើយក្រាបទូលថា ដំរី ដូចតម្ពក់ដែលភ្ជាប់នឹងជញ្ជាំង ។ ព្រះរាជាទ្រង់ស្តាប់ពាក្យទាំងអស់ហើយ ទើបទ្រង់បញ្ជូនពួកតិរ្ថិយត្រឡប់ទៅ ដោយព្រះតម្រាស់ថា លទ្ធិរបស់ពួកអ្នកក៏មានសភាពដូច្នេះឯង ភិក្ខុកាន់យកបិណ្ឌបាតជាវត្តមួយរូបដឹងរឿងនោះហើយ ទើបទៅក្រាបទូលព្រះមានព្រះភាគ ព្រះមានព្រះភាគទ្រង់កាន់យករឿងនោះជាហេតុ ទើបត្រាស់ហៅភិក្ខុទាំងឡាយមក ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មនុស្សខ្វាក់អំពីកំណើត មិនស្គាល់ដំរី ស្ទាបអវយវៈមួយ

ផ្នែកៗ នៃដីហើយ ក៏ប្រកែកគ្នា យ៉ាងណា ពួកតិរ្ថិយក៏ដូច្នោះ មិនស្គាល់ធម៌ដែលជាហេតុឲ្យផុតទុក្ខ ស្ទាបអង្អែលនូវទិដ្ឋិនោះៗ ហើយក៏ប្រកែកគ្នា ដើម្បីសម្តែងធម៌ ទើបត្រាស់ព្រះសូត្រនេះ ។

ក្នុងបទទាំងនោះ បទថា **បរមន្តិ ទិដ្ឋីសុ បរិព្វសានោ** គឺប្រកាន់ក្នុងទិដ្ឋិរៀងៗ ខ្លួនថា វត្ថុនោះ ក្រៃលែង ។ បទថា **យទុត្តរឹ កុរុតេ** គឺរមែងធ្វើសាស្តាជាដើមរបស់ខ្លួនឲ្យជាបុគ្គលប្រសើរ ។ បទថា **ហីនាតិ មញ្ញតតោ សព្វមាហា** គឺពោលអ្នកដទៃ វៀរសាស្តាជាដើមរបស់ខ្លួនថា ជនទាំងនោះអាក្រក់ទាំងអស់ ។ បទថា **តស្មា វិវាទានិ អវីតិវត្តោ** គឺព្រោះហេតុនោះ ទើបអ្នកនោះមិនកន្លងផុតការវិវាទបានពិត គប្បីជ្រាបអត្ថនៃគាថាទី ២ ថា កាលមិនកន្លងផុតបានយ៉ាងនេះហើយ បុគ្គលនោះ ឃើញអានិសង្សឯណា ដូចពោលហើយខាងដើម ពោល គឺទិដ្ឋិដែលកើតឡើងក្នុងវត្ថុទាំងនេះ គឺក្នុងរូបដែលបានឃើញ ក្នុងសំឡេងដែលបានស្តាប់ ក្នុងសីល និងវត្ត ក្នុងអារម្មណ៍ដែលបានដឹង បុគ្គលនោះប្រកាន់មាំអានិសង្សនោះឯង ក្នុងទិដ្ឋិរបស់ខ្លួនថា វត្ថុនេះប្រសើរបំផុត ឃើញសាស្តាទាំងអស់ ជាសាស្តាអ្នកដទៃជាដើម ដោយភាពជាមនុស្សអាក្រក់ ។

គប្បីជ្រាបអត្ថនៃគាថាទី ៣ ថា កាលឃើញយ៉ាងនេះ បុគ្គលអាស្រ័យសាស្តាជាដើមរបស់ខ្លួន ឃើញសាស្តារបស់អ្នកដទៃជាដើមជាមនុស្សអាក្រក់ ព្រោះការឃើញឯណា បុគ្គលដែលឈ្លាសទាំងឡាយ ពោលការឃើញនោះថា ជាកិលេសគ្រឿងរួបរឹត អធិប្បាយថា ជាគ្រឿងចង ។ លោកអធិប្បាយថា

ព្រោះហេតុនោះឯង ភិក្ខុមិនគប្បីអាស្រ័យ គឺមិនប្រកាន់មាំក្នុងរូបដែលបានឃើញ ក្នុងសំឡេងដែលបានឮ ក្នុងអារម្មណ៍ដែលបានជ្រាប ឬក្នុងសីលនិងវត្ត ។

គប្បីជ្រាបអត្ថនៃគាថាទី ៤ ថា មិនមែនមិនគប្បីប្រកាន់រូបដែលបានឃើញ សំឡេងដែលបានឮជាដើមតែម៉្យាងប៉ុណ្ណោះទេ ដែលពិត មិនគប្បីកំណត់ទិដ្ឋិក្រៃលែងឡើងៗ ដែលមិនទាន់កើតក្នុងលោកទៀតផង អធិប្បាយថា មិនគប្បីឲ្យកើត ។ សេចក្តីនេះ ដូចអ្វី មិនគប្បីកំណត់ទិដ្ឋិដែលកំណត់ដោយញាណ ឬដោយសីល និងវត្ត ឬដោយញាណ មានសមាបត្តិញាណជាដើម ឬដោយសីល និងវត្ត ។ ម៉្យាងទៀត មិនមែនគប្បីកំណត់ទិដ្ឋិតែម៉្យាងសេចក្តីពិត មិនគប្បីនាំខ្លួនចូលទៅប្រៀបដោយមានះថា អញស្មើនឹងគេ មិនគប្បីសម្គាល់ថា អញអាក្រក់ជាងគេ ឬវិសេសជាងគេ ដោយរឿងទាំង-ឡាយ មានជាតិជាដើមឡើយ ។

គប្បីជ្រាបអត្ថនៃគាថាទី ៥ ថា កាលមិនកំណត់ គឺមិនសម្គាល់ទិដ្ឋិយ៉ាងនេះ ភិក្ខុលះនូវការឃើញថាជាខ្លួនបានហើយ មិនប្រកាន់មាំ គឺលះវត្ថុដែលខ្លួនប្រកាន់មកអំពីមុន ហើយមិនប្រកាន់វត្ថុដទៃ រមែងមិនធ្វើនិស្ស័យ ២ យ៉ាង ( តណ្ហានិស្ស័យ និងទិដ្ឋិនិស្ស័យ ) ក្នុងញាណ មានប្រការដូចពោលហើយនោះ កាលមិនធ្វើ ភិក្ខុនោះឯងមិនជាអ្នកស្ទុះទៅចូលក្នុងពួកសត្វទាំង-ឡាយ ដែលមានសភាពផ្សេងៗ គ្នា ដោយអំណាចទិដ្ឋិផ្សេងៗ ជាអ្នកមិនទៅដោយអំណាចការពេញចិត្តជាដើមជាធម្មតា រមែងមិនត្រឡប់មកកាន់ទិដ្ឋិណា

មួយ ក្នុងទិដ្ឋិ ៦២ ទៀតឡើយ ។

ឥឡូវនេះ ព្រះមានព្រះភាគត្រាស់ ៣ គាថាថា **យស្សូភយន្តេ** ជាដើម ដើម្បីពោលសរសើរព្រះខីណាស្រព ដូចបានពោលក្នុងគាថានេះ

ក្នុងបទទាំងនោះ បទថា **ឧភយន្តេ** គឺផស្សៈជាដើម ដូចពោលហើយក្នុងកាលមុន ។ បទថា **បណិធិ** បានដល់ តណ្ហា ។ បទថា **ភវាភវាយ** គឺដើម្បីកើតរឿយៗ ។ បទថា **ឥធ វា ហុរំ វា** គឺក្នុងលោកនេះ មានអត្តភាពរបស់ខ្លួនជាដើម ឬក្នុងលោកដទៃ មានអត្តភាពរបស់អ្នកដទៃជាដើម ។ បទថា **ទិដ្ឋេវ** គឺក្នុងសេចក្តីបរិសុទ្ធនៃរូបដែលបានឃើញ ។ ក្នុងសំឡេងដែលបានស្តាប់ជាដើមក៏ន័យនេះ ។ បទថា **សញ្ញា** បានដល់ ទិដ្ឋិដែលកើតអំពីសញ្ញា ។ បទថា **ធម្មាបិ តេសំ ន បដិច្ឆិតាសេ** បានដល់ សូម្បីធម៌ គឺទិដ្ឋិ ៦២ ក៏ព្រះខីណាស្រពទាំងនោះមិនបានប្រាថ្នាហើយយ៉ាងនេះថា នេះប៉ុណ្ណោះជារបស់ពិត ដទៃជាមោឃៈ ។ បទថា **ចារំ គតោ ន បច្ចេតិ តាទី** គឺដល់នូវត្រើយ គឺព្រះនិព្វាន ជាអ្នកមិនញាប់ញ័រដោយអាការ ៥ រមែងមិនត្រឡប់មកកាន់កិលេសដែលលះបានដោយមគ្គនោះៗ ទៀត ។ បទដ៏សេសមានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថាបរមដ្ឋកសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ជរាសូត្រទី៦

[ ១០០ ] ជីវិតនេះ មានប្រមាណតិចហ្ន៎ សត្វតែងស្លាប់ថយ អំពី ១០០ ឆ្នាំ ប្រសិនបើរស់ហួសពី ១០០ ឆ្នាំ សត្វនោះនឹង ស្លាប់ដោយជរាជាប្រាកដ ។ ជនទាំងឡាយតែងសោក ព្រោះ វត្ថុដែលប្រកាន់ថា របស់យើង សេចក្តីប្រកាន់ថា ជារបស់ ទៀងទាត់ មិនមានឡើយ ជីវិតនេះ មានការព្រាត់ប្រាសចាក របស់ដែលមានជាធម្មតា អ្នកប្រាជ្ញលុះឃើញដូច្នេះហើយ រមែង មិននៅគ្រប់គ្រងផ្ទះឡើយ ។ បុរសសម្គាល់របស់ណាថា នេះ ជារបស់អញ រមែងលះរបស់នោះ ដោយមរណៈ ឯអ្នកប្រាជ្ញ រាប់អានព្រះរតនត្រ័យ ជ្រាបច្បាស់នូវទោសនុ៎ះហើយ មិន បង្អោន ( ចិត្ត ) ទៅ ដើម្បីសេចក្តីប្រកាន់ថា របស់យើង ឡើយ ។ បុរសអ្នកភ្ញាក់ ( ពីដេក ) រមែងមិនឃើញរូបា- រម្មណ៍ជាដើម ដែលមកជួបប្រទះ ដោយយល់សប្តិ យ៉ាងណា មិញ បុគ្គលមិនឃើញជនជាទីស្រឡាញ់ ដែលធ្វើកាលកិរិយា ទៅកាន់លោកខាងមុខ ក៏យ៉ាងនោះដែរ ។ ជនទាំងនោះដែល គេឃើញហើយ ឮហើយ គេតែងហៅឈ្មោះ កាលលះលោក នេះទៅ នៅសល់តែឈ្មោះសម្រាប់ហៅប៉ុណ្ណោះ ។ ពួកសត្វ មានសេចក្តីលោភ តែងមិនលះបង់នូវសេចក្តីសោក ខ្សឹកខ្សួល និងសេចក្តីកំណាញ់ ក្នុងវត្ថុដែលជាទីរាប់អានបានឡើយ ព្រោះ

ហេតុនោះ អ្នកប្រាជ្ញទាំងឡាយ ដែលឃើញព្រះនិព្វានថា ជាទីក្សេមហើយ រមែងលះបង់សេចក្តីប្រកាន់បាន ។ ភិក្ខុណាមិនសម្តែងខ្លួនក្នុងភព ( ថ្មីទៀត ) អ្នកប្រាជ្ញទាំងឡាយ ហៅអំពើនោះ របស់ភិក្ខុនោះ អ្នកប្រព្រឹត្តរួញរា អ្នកគប់ប្រសព្វអាសនៈស្ងាត់ ថាជាសភាពសមរម្យហើយ ។ អ្នកប្រាជ្ញមិនបានអាស្រ័យក្នុងអាយតនៈទាំងអស់ឡើយ មិនធ្វើសត្វ និងសង្ខារឲ្យជាទីស្រឡាញ់ ទាំងមិនធ្វើសត្វ និងសង្ខារ ឲ្យមិនជាទីស្រឡាញ់ សេចក្តីខ្សឹកខ្សួល និងសេចក្តីកំណាញ់ មិនជាប់ក្នុងសន្តានរបស់ព្រះខីណាស្រពនោះ ដូចទឹកមិនប្រឡាក់លើស្លឹកឈូក ដូច្នោះដែរ ។ ដំណក់ទឹកមិនជក់នៅលើស្លឹកឈូក ដូចម្តេចក្តី ទឹកមិនទទឹកនាផ្កាឈូក ដូចម្តេចក្តី អ្នកប្រាជ្ញមិនជាប់នៅក្នុងអារម្មណ៍ទីមួយ សូម្បីអារម្មណ៍បានឃើញបានប៉ះពាល់ ក៏ដូច្នោះដែរ ។ មួយទៀត ព្រះអរហន្ត មិនសម្គាល់ក្នុងអារម្មណ៍ទីមួយ សូម្បីអារម្មណ៍ដែលឃើញ ដែលឮ ដែលប៉ះពាល់ដោយវត្ថុនោះៗ ឡើយ ទាំងមិនប្រាថ្នាការស្អាតដោយវត្ថុដទៃទេ ព្រោះព្រះអរហន្តនោះ មិនត្រេកត្រអាលមិនប្រាសតម្រេក ( ដូចកល្យាណបុថុជ្ជន និងសេក្ខៈ ) ។

**ជរាសូត្រទី ៦ ចប់**

# អដ្ឋកថា

## ជរាសូត្រ

[ ១០០ ] ក្នុងជរាសូត្រទី ៦ មានពាក្យផ្ដើមថា **អប្បំ វត ជីវិតំ** ដូច្នេះ សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅនេះ

សម័យមួយ ព្រះមានព្រះភាគ ទ្រង់ចាំព្រះវស្សាក្នុងក្រុងសាវត្ថី ទ្រង់ពិចារណាដល់ការប្រព្រឹត្តរបស់ព្រះពុទ្ធទាំងឡាយ ក្នុងការដែលទ្រង់ចារិកទៅកាន់ជនបទមាន ឲ្យដល់ការមិនមានរោគ បញ្ញត្តសិក្ខាបទដែលមិនបានបញ្ញត្តទុកទុន្នានវេនេយ្យសត្វ ពោលជាតកជាដើម ដែលជាហេតុឲ្យកើតរឿងនោះៗ ទើបយាងចារិកទៅកាន់ជនបទ ។ ព្រះមានព្រះភាគទ្រង់ចារិកទៅដោយលំដាប់ ដល់នគរសាកេតក្នុងវេលាល្ងាច ទ្រង់ចូលទៅកាន់ព្រៃអញ្ជន ។ អ្នកនគរសាកេតបានដំណឹងហើយ គិតថា ឥឡូវនេះ មិនទាន់ដល់ពេលគាល់ព្រះមានព្រះភាគ កាលភ្លឺហើយ ទើបកាន់យកផ្កា និងគ្រឿងប្រអប់ជាដើម ទៅគាល់ព្រះមានព្រះភាគ ធ្វើនូវការបូជា ក្រាបថ្វាយបង្គំ និងសរសើរជាដើម បានឈរចោមរោម រហូតដល់ពេលដែលព្រះមានព្រះភាគចូលទៅកាន់ស្រុក ។ គ្រានោះ ព្រះមានព្រះភាគ ចោមរោមដោយភិក្ខុសង្ឃ ទ្រង់ចូលទៅបិណ្ឌបាត ។

ព្រាហ្មណមហាសាលម្នាក់ អ្នកក្រុងសាកេតចេញអំពីនគរ បានឃើញព្រះមានព្រះភាគត្រង់ទ្វារនគរ ។ កាលឃើញហើយ ក៏កើតសេចក្ដីស្រឡាញ់ដូចជាបុត្ត បានដើរតម្រង់ទៅចំពោះព្រះភក្ត្រ យំរៀបរាប់ថា កូនជាទីស្រឡាញ់ ឪពុកខានឃើញកូនមកយូរហើយ ។ ព្រះមានព្រះភាគ ទ្រង់ប្រាប់ដល់ភិក្ខុទាំង-

ឡាយថា ម្នាលភិក្ខុទាំងឡាយ ចូរព្រាហ្មណ៍នេះធ្វើវត្ថុដែលខ្លួនត្រូវការ កុំឃាត់ឡើយ ។ សុម្បីព្រាហ្មណ៍ ក៏ចូលទៅឱបព្រះវរកាយរបស់ព្រះមានព្រះភាគដោយជុំវិញ គឺខាងមុខ ខាងក្រោយ ខាងស្តាំ ខាងឆ្វេង ដូចមេគោត្រូវការកូនគោ ដូច្នោះ ពោលថា កូនសម្លាញ់ ឪពុកខានឃើញកូនមកយូរហើយ ។ បើព្រាហ្មណ៍នោះមិនបានធ្វើយ៉ាងនោះ ហទយៈនឹងបែក ។ គាត់បានក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ អាចថ្វាយទានដល់ភិក្ខុទាំងឡាយ ដែលមកជាមួយទ្រង់បាន សូមទ្រង់អនុគ្រោះដល់ខ្ញុំព្រះអង្គចុះ ។ ព្រះមានព្រះភាគ ទ្រង់ទទួលដោយតុណ្ហីភាព ។ ព្រាហ្មណ៍ទទួលបាត្ររបស់ព្រះមានព្រះភាគ ដើរទៅមុន ឲ្យដំណឹងដល់ព្រាហ្មណីថា កូនរបស់យើងមកហើយ គប្បីក្រាលអាសនៈ ។ ព្រាហ្មណីបានធ្វើតាមនោះហើយឈរមើលឃើញព្រះមានព្រះភាគក្នុងរវាងផ្លូវ កើតសេចក្តីស្រឡាញ់ថាជាបុត្តចាប់ត្រង់ព្រះបាទ យំរៀបរាប់ថា ម៉ែខានឃើញកូនមកយូរហើយ រួចនាំទៅផ្ទះ អង្គាសដោយគោរព ។

កាលព្រះមានព្រះភាគសោយស្រេចហើយ ព្រាហ្មណ៍នាំបាត្រចេញ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបធម៌ជាទីសប្បាយរបស់ព្រាហ្មណ៍ និងព្រាហ្មណីនោះ ទើបទ្រង់សំម្តែងធម៌ កាលចប់ទេសនា ជនទាំង ២ ក៏បានជាព្រះ-សោតាបន្ន ។

លំដាប់នោះ ព្រាហ្មណ៍ និងព្រាហ្មណី ក្រាបទូលអារាធនាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំព្រះអង្គ

អស់កាលដែលទ្រង់គង់នៅក្នុងនគរនេះចុះ ។ ព្រះមានព្រះភាគ ទ្រង់បដិសេធថា ព្រះពុទ្ធទាំងឡាយមិននៅក្នុងទីតែមួយ ។ ព្រាហ្មណ៍ និងព្រាហ្មណីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ដូច្នោះ បើទ្រង់ត្រាច់បិណ្ឌបាតជាមួយភិក្ខុសង្ឃហើយ សូមនិមន្តមកធាន់ក្នុងទីនេះ សម្ដែងធម៌ សឹមត្រឡប់ទៅឯវិហារ ។ ព្រះមានព្រះភាគទ្រង់បានធ្វើតាមនោះ ដើម្បីអនុគ្រោះព្រាហ្មណ៍ និងព្រាហ្មណីនោះ ។ ជនទាំងឡាយនាំគ្នាពោលដល់ព្រាហ្មណ៍ និងព្រាហ្មណីថា ជាពុទ្ធបិតា ពុទ្ធមាតា ។ សូម្បីត្រកូលនោះ ក៏បានឈ្មោះយ៉ាងនោះ ។

ព្រះអានន្ទទូលសួរព្រះមានព្រះភាគថា ខ្ញុំព្រះអង្គស្គាល់ព្រះមាតា ព្រះបិតារបស់ព្រះអង្គ តើហេតុអ្វី ទើបព្រាហ្មណ៍ និងព្រាហ្មណីនេះពោលថា ខ្ញុំជាពុទ្ធបិតា ខ្ញុំជាពុទ្ធមាតា ដូច្នេះ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ព្រាហ្មណ៍ និងព្រាហ្មណីធ្លាប់ជាមាតាបិតារបស់តថាគតជាលំដាប់មក អស់ ៥០០ ជាតិ ជាអ៊ំប្រុស អ៊ំស្រីរបស់តថាគតអស់ ៥០០ ជាតិ ជាមា និងមីង អស់ ៥០០ ជាតិ ព្រាហ្មណ៍ និងព្រាហ្មណីនោះ ពោលដោយសេចក្ដីស្រឡាញ់ ក្នុងជាតិមុននោះឯង និងបានត្រាស់គាថានេះថា

**បុព្វេវ សន្និវាសេន បច្ចុប្បន្នហិតេន វា**
**ឯវន្តំ ជាយតេ បេមំ ឧប្បលំវ យថោទកេ។**

សេចក្ដីស្រឡាញ់នោះ រមែងកើតដោយហេតុពីរយ៉ាង គឺដោយធ្លាប់នៅរួមគ្នាក្នុងកាលមុន ១ ដោយការទំនុកបម្រុង គ្នាក្នុងបច្ចុប្បន្ននេះ ១ ដូចជាឧប្បលដែលដុះក្នុងទឹក ដោយហេតុ ២ យ៉ាង គឺទឹក ១

ភក់ ១ ។

បន្ទាប់អំពីនោះមក ព្រះមានព្រះភាគ ទ្រង់គង់នៅតាមការពេញព្រះហឫទ័យក្នុងនគរសាកេតហើយ ទ្រង់ចារិកទៅទៀត ទើបត្រឡប់ទៅក្រុងសាវត្ថី ។ ព្រាហ្មណ៍ និងព្រាហ្មណី ចូលទៅរកភិក្ខុទាំងឡាយ ស្តាប់ធម្មទេសនាដែលសមគួរហើយ សម្រេចមគ្គដ៏សេស បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។ ក្នុងនគរ ពួកព្រាហ្មណ៍ប្រជុំប្រឹក្សាគ្នាថា យើងនឹងធ្វើសក្ការៈញាតិរបស់ពួកយើង ។ ពួកឧបាសក និងឧបាសិកាដែលជាសោតាបន្ន សកទាគាមី និងអនាគាមី ក៏ប្រជុំប្រឹក្សាគ្នាថា ពួកយើងនឹងធ្វើសក្ការៈសម្លាញ់ដែលរួមបដិបត្តិធម៌របស់ពួកយើង ។ ជនទាំងអស់នោះ ក៏លើកផ្ទះកំពូលដែលពាសដោយសំពត់កម្ពល បូជាដោយផ្កា និងគ្រឿងក្រអូបជាដើម ចេញអំពីនគរទៅ ។

ក្នុងថ្ងៃនោះ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលលោកដោយពុទ្ធចក្ខុក្នុងវេលាទៀបភ្លឺ ទ្រង់ជ្រាបថា ព្រាហ្មណ៍ និងព្រាហ្មណីបរិនិព្វាន កាលតថាគតទៅក្នុងទីនោះ មហាជននឹងសម្រេចធម៌ ព្រោះស្តាប់ធម្មទេសនា ទើបទ្រង់កាន់បាត្រ និងចីវរយាងមកកាន់ក្រុងសាវត្ថី ទ្រង់ចូលទៅកាន់ឈាបនដ្ឋាន ។ ពួកជនឃើញហើយ បានឈរប្រជុំគ្នាពោលថា ព្រះមានព្រះភាគមានបំណងនឹងធ្វើឈាបនកិច្ចមាតាបិតា ទើបយាងមក ។ សូម្បីអ្នកនគរ ក៏នាំគ្នាបូជាផ្ទះកំពូល នាំគ្នាមកកាន់ឈាបនដ្ឋាន ក្រាបទូលសួរព្រះមានព្រះភាគថា អរិយសាវកដែលជាគ្រហស្ថ គប្បីបូជាដូចម្តេច ។ ព្រះមានព្រះភាគ កាល

ទ្រង់សម្ដែងភាពជាអសេក្ខមុនីរបស់អរិយសាវក ដែលជាគ្រហស្ថនោះ ដោយបំណងថា គួរបូជាអរិយសាវកដែលជាគ្រហស្ថទាំងនោះ ដូចបូជាព្រះអសេក្ខៈ បានត្រាស់គាថាធម្មបទនេះថា

ជនទាំងឡាយណាជាអ្នកប្រាជ្ញ មិនបៀតបៀនសត្វដទៃ សង្រួមហើយ ដោយកាយទ្វារ ( ជាដើម ) ជានិច្ច ជនទាំងឡាយនោះរមែងទៅកាន់ស្ថាន ដ៏មិនប្រែប្រួល ជាស្ថានដែលគេទៅដល់ហើយ តែងមិនសោកស្ដាយ ។

ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលបរិស័ទនោះ កាលទ្រង់សម្ដែងធម៌សមគួរដល់ខណៈនោះ ទើបត្រាស់ព្រះសូត្រនេះ ។

ក្នុងបទទាំងនោះ បទថា **អប្បំ វត ជីវិតំ ឥទំ** នេះ មានន័យដូចបានពោលហើយ ក្នុងសល្លសូត្រថា ជីវិតរបស់មនុស្សទាំងឡាយនេះតិចតួច ព្រោះធម្មជាតិតាំងនៅតិច ព្រោះកិច្ចរបស់ខ្លួនតិច[១] ដូច្នេះ ។ បទថា **ឱរំ វស្សសតាបិ មិយ្យតិ** គឺសត្វស្លាប់មិនដល់ ១០០ ឆ្នាំ ស្លាប់ក្នុងវេលាដែលនៅជាកលលៈក៏មាន ។ បទថា **អតិច្ច** គឺរស់ហួស ១០០ ឆ្នាំ ។ បទថា **ជរសាបិ មិយ្យតិ** គឺសត្វនោះរមែងស្លាប់ព្រោះជរា ។

បទថា **មមាយិតេ** គឺព្រោះហេតុនៃវត្ថុដែលខ្លួនប្រកាន់ថា ជារបស់អញ ។ បទថា **វិនាភាវសន្តមេវិទំ** គឺវត្ថុនេះ មានការព្រាត់ប្រាសចាកគ្នានិងគ្នាមាន លោកអធិប្បាយថា មានការព្រាត់ប្រាសចាកគ្នា ។ បទថា

១- ក្នុងសល្លសូត្រមិនឃើញមានគាថានេះ សល្លសូត្រក្នុងទីដទៃទេដឹង ។

**មាមកោ** គឺដល់នូវការរាប់ថា ឧបាសក ឬភិក្ខុរបស់អញ ឬរាប់អានព្រះពុទ្ធជាដើមថា ជារបស់អញ ។ បទថា **សង្ខតំ** គឺអារម្មណ៍ដែលមកដល់ ឬដែលធ្លាប់ឃើញ ។ បទថា **បិយាយិតំ** គឺបុគ្គលដែលខ្លួនធ្វើឲ្យជាទីស្រឡាញ់ ។ បទថា **ឆាមមេវាវសិស្សតិ អក្ខេយ្យំ** គឺធម្មជាតិ មានរូបទាំងអស់ជាដើម នឹងលះបង់ទៅ ឯឈ្មោះប៉ុណ្ណោះនៅសល់ ដើម្បីគ្រាន់តែហៅគ្នាយ៉ាងនេះថា ពុទ្ធរក្ខិតៈ ធម្មរក្ខិតៈ ។ បទថា **មុនយោ** បានដល់ មុនីដែលជាខីណាស្រព ។ បទថា **ខេមទស្សិនោ** បានដល់ ជាអ្នកឃើញព្រះនិព្វាន ។

កាលលោកត្រូវសេចក្តីស្លាប់គ្របសង្កត់យ៉ាងនេះ ទើបព្រះមានព្រះភាគត្រាស់គាថាទី ៧ ដើម្បីសម្តែងដល់កិច្ចបដិបត្តិដែលសមគួរ ។

ក្នុងបទទាំងនោះ បទថា **បដិលីនចរស្ស** គឺរបស់ភិក្ខុដែលប្រព្រឹត្តធ្វើចិត្តពួនសម្ងំចាកអារម្មណ៍នោះៗ ។ បទថា **ភិក្ខុនោ** បានដល់ កល្យាណ-បុថុជ្ជន ឬព្រះសេក្ខៈ ។ បទថា **សាមគ្គិយមាហុ តស្ស តំ យោ អត្តានំ ភវនេ ន ទស្សយេ** សេចក្តីថា បណ្ឌិតទាំងឡាយ ពោលបុគ្គលដែលបដិបត្តិយ៉ាងនេះ មិនសម្តែងខ្លួនក្នុងភព មាននរកជាដើម ថាជាការសមគួរ អធិប្បាយថា បន្ទាប់អំពីនោះ បណ្ឌិតនោះ គប្បីផុតចាកសេចក្តីស្លាប់ ។

ឥឡូវនេះ ព្រះខីណាស្រពណា ដែលព្រះមានព្រះភាគត្រាស់យ៉ាងនេះថា អ្នកមិនបង្ហាញខ្លួនក្នុងភព ដើម្បីទ្រង់សរសើរព្រះខីណាស្រពនោះ ទើបព្រះមានព្រះភាគត្រាស់ ៣ គាថា បន្ទាប់អំពីនេះ ។

ក្នុងបទទាំងនោះ បទថា **សព្វត្ថ** គឺក្នុងអាយតនៈ ១២ ។ ក្នុងបទនេះថា **យទិទំ ទិដ្ឋំ សុតំ មុតេសុ វា** គប្បីជ្រាបការភ្ជាប់សេចក្ដីយ៉ាងនេះថា មុនី រមែងមិនជាប់ក្នុងរូបដែលបានឃើញ ក្នុងសំឡេងដែលបានឮ ឬក្នុងអារម្មណ៍ដែលបានជ្រាបយ៉ាងនេះ ។ បទថា **ធោនោ ន ហិ តេន មញ្ញតិ យទិទំ ទិដ្ឋំ សុតំ មុតេសុ វា** គប្បីជ្រាបការភ្ជាប់សេចក្ដីយ៉ាងនេះទៀតថា បុគ្គលដែលមានបញ្ញា រមែងមិនសម្គាល់ដោយរូបដែលបានឃើញ ដោយសំឡេងដែលបានឮ ឬរមែងមិនសម្គាល់ក្នុងធម្មារម្មណ៍ដែលបានជ្រាប ។ បទថា **ន ហិ សោ រជ្ជតិ នោ វិរជ្ជតិ** សេចក្ដីថា អ្នកមានបញ្ញារមែងមិនត្រេកអរ ដូចបុថុជ្ជនដែលជាបុគ្គលពាល រមែងមិនត្រេកអរ ដូចកល្យាណ-បុថុជ្ជន និងព្រះសេក្ខៈ រមែងបានឈ្មោះថា ជាអ្នកមិនត្រេកអរ មិនប្រទូស្ត ព្រោះអស់រាគៈហើយនោះឯង រមែងដល់នូវការរាប់ថា ជាអ្នកមិនជាប់ ។ បទដ៏សេស ក្នុងទីទាំងពួងជាក់ច្បាស់ហើយ ។

ក្នុងកាលចប់ទេសនា សត្វ ៨៤០០០ បានសម្រេចធម៌ហើយ ។

**អដ្ឋកថាជរាសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## តិស្សមេត្តេយ្យសូត្រទី៧

[ ១០១ ] ព្រះតិស្សមេត្តេយ្យដ៏មានអាយុ ( អារាធនាថា ) បពិត្រព្រះអង្គនិទ្ទុក្ខ សូមព្រះអង្គសម្តែងសេចក្តីចង្អៀតចង្អល់ របស់បុគ្គល អ្នកប្រកបមេថុនធម្មរឿយៗ យើងខ្ញុំបានស្តាប់ ពាក្យប្រដៅព្រះអង្គហើយ នឹងសិក្សានូវវិវេកទាំងឡាយ ។ ( ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តេយ្យ ) បុគ្គលអ្នក ប្រកបមេថុនរឿយៗ រមែងភ្លេចពាក្យប្រដៅផង ប្រតិបត្តិខុសផង ការប្រព្រឹត្តខុសនុ៎ះ ជាអំពើមិនប្រសើរចំពោះបុគ្គលនោះទេ ។ បុគ្គលណា ប្រព្រឹត្តម្នាក់ឯង គឺទ្រង់ភេទបព្វជិត ក្នុងកាល ពីមុន ( លុះខាងក្រោយ ) ត្រឡប់សេពមេថុនធម្មវិញ អ្នក ប្រាជ្ញហៅបុគ្គលនោះ ថាជាបុថុជ្ជន អ្នកថោកថយក្នុងលោក ដូចជាយានលឿនទៅ ដូច្នោះឯង ។ យស និងសេចក្តី សរសើរណា ក្នុងកាលពីមុន យស និងសេចក្តីសរសើរនោះ របស់បុគ្គលនោះ រមែងសាបសូន្យទៅ បុគ្គលឃើញការចម្រើន និងការសាបសូន្យយស សរសើរនុ៎ះហើយ គប្បីសិក្សាដើម្បី លះបង់នូវមេថុនធម្មចេញ ។ បុគ្គលនោះ ត្រូវសង្កប្បទាំង- ឡាយគ្របសង្កត់ហើយ រមែងជ្រប់នៅដូចមនុស្សកំព្រា បុគ្គល បែបនោះ ឮពាក្យជនដទៃហើយ រមែងអៀនខ្មាស ។ មួយទៀត បុគ្គលនោះ ត្រូវវាទៈអ្នកដទៃដាស់តឿនហើយ រមែងធ្វើគ្រឿង

សន្ថ្រា គឺមុសាវាទ សេចក្ដីសាំញ៉ាំជាំនោះឯង របស់បុគ្គល នោះ រមែងធ្លាក់ចុះកាន់មុសាវាទ ។ បុគ្គលដែលគេដឹងសុស-សាយថាជាបណ្ឌិត តាំងផ្ដើមការប្រព្រឹត្តម្នាក់ឯង លុះកាលខាង ក្រោយមក បែរទៅជាប្រកបក្នុងមេថុនធម្មវិញ បណ្ឌិតនោះ នឹងសៅហ្មងដូចជនពាលដែរ ។ អ្នកប្រាជ្ញ លុះជ្រាបទោសនុ៎ះ ហើយ គួរធ្វើនូវការប្រព្រឹត្តម្នាក់ឯង ឲ្យមាំក្នុងសាសនានេះ ទាំងមុនទាំងក្រោយ កុំគប្បីសេពនូវមេថុនឡើយ ។ បុគ្គល គប្បីសិក្សានូវវិវេកតែម្យ៉ាង ព្រោះវិវេកនុ៎ះ ប្រសើរផុតរបស់ ព្រះអរិយៈទាំងឡាយ ប៉ុន្តែបុគ្គលមិនគប្បីសម្គាល់ថា អាត្មា អញប្រសើរដោយវិវេកនោះទេ បុគ្គលនោះឯង ឈ្មោះថា ប្រតិស្ឋាននៅក្នុងទីជិត នៃព្រះនិព្វាន ។ ពួកសត្វជាប់នៅក្នុង កាមទាំងឡាយ តែងស្រឡាញ់អ្នកប្រាជ្ញ ដែលមានសេចក្ដី ស្ងប់ស្ងាត់ មិនអាឡោះអាល័យក្នុងកាមទាំងឡាយ ឆ្លងនូវ អន្លង់បាន ។

**តិស្សមេត្តេយ្យសូត្រទី ៧ ចប់**

# អដ្ឋកថា

## តិស្សមេត្តេយ្យសូត្រ

[ ១០១ ] *ក្នុងតិស្សមេត្តេយ្យសូត្រទី ៧ មានពាក្យផ្ដើមថា* **មេថុនមនុយុត្តស្ស** *ដូច្នេះ ។*

*សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូច្នេះ*

*បានឮថា កាលព្រះមានព្រះភាគ គង់នៅក្នុងក្រុងសាវត្ថី មានសម្លាញ់ ២ នាក់ ឈ្មោះតិស្សៈ និងមេត្តេយ្យៈ បាននាំគ្នាទៅក្រុងសាវត្ថី ។ សម្លាញ់ទាំង ២ នាក់នោះ ក្នុងវេលាល្ងាច ឃើញមហាជនមានមុខទៅកាន់វត្តជេតពន ទើបសួរថា ពួកអ្នកទៅណា កាលជនទាំងនោះប្រាប់ថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក ទ្រង់សម្ដែងធម៌ដើម្បីប្រយោជន៍ដល់ជនច្រើន ពួកយើងនឹងទៅកាន់វត្តជេតពនដើម្បីស្ដាប់ធម៌ ។ សម្លាញ់ទាំង ២ ក៏ពោលថា សូម្បីខ្ញុំទាំង ២ ក៏នឹងស្ដាប់ ក៏នាំគ្នាទៅ ។ សម្លាញ់ទាំង ២ នោះ អង្គុយស្ដាប់ធម៌របស់ព្រះមានព្រះភាគ ទ្រង់សម្ដែងធម៌ក្នុងរវាងបរិស័ទ គិតថា បើអញនៅគ្រប់គ្រងផ្ទះ មិនអាចនឹងបំពេញធម៌នេះបានដោយងាយឡើយ ។ កាលមហាជនត្រឡប់ទៅ សម្លាញ់ទាំង ២ ក៏សូមបព្វជ្ជានឹងព្រះមានព្រះភាគ ។ ព្រះមានព្រះភាគមានព្រះពុទ្ធតម្រាស់ឲ្យភិក្ខុមួយរូប បំបួសសម្លាញ់ទាំង ២ នោះ ។ ភិក្ខុនោះ កាលឲ្យសម្លាញ់ទាំង ២ បួសហើយ ក៏ឲ្យតចបញ្ចកកម្មដ្ឋាន ត្រៀមខ្លួនទៅនៅព្រៃ ។ មេត្តេយ្យភិក្ខុ ពោលនឹងតិស្សភិក្ខុថា អាវុសោ ឧបជ្ឈាយ៍នឹងទៅព្រៃ សូម្បីពួកយើងទាំង ២ ក៏ត្រូវទៅដែរ ។*

តិស្សភិក្ខុពោលថា កុំឡើយលោក ខ្ញុំត្រូវការឃើញ និងស្តាប់ធម៌របស់ព្រះមានព្រះភាគ លោកទៅតែឯងចុះ ។ មេត្តេយ្យ និងឧបជ្ឈាយ៍បំពេញសមណធម៌ក្នុងព្រៃ មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត មួយអន្លើដោយឧបជ្ឈាយ៍ដែលជាអាចារ្យ ។ បងប្រុសរបស់តិស្សភិក្ខុអនិច្ចកម្មដោយព្យាធិ តិស្សៈបានដំណឹងហើយ ក៏ទៅកាន់ផ្ទះរបស់ខ្លួន នៅឯផ្ទះនោះ ពួកញាតិក៏នាំគ្នាលួងលោមព្រះតិស្សៈឲ្យសឹក ។ ចំណែកព្រះមេត្តេយ្យ ក៏មកដល់ក្រុងសាវត្ថី មួយអន្លើដោយឧបជ្ឈាយ៍ដែលជាអាចារ្យ ។

លំដាប់នោះ ព្រះមានព្រះភាគ កាលចេញវស្សាហើយ ទ្រង់ចារិកទៅកាន់ជនបទ ។ ដល់ស្រុកនោះដោយលំដាប់ ។ គ្រានោះ មេត្តេយ្យថ្វាយបង្គំព្រះមានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គ ត្រង់ស្រុកនេះ មានសម្លាញ់ជាគ្រហស្ថរបស់ខ្ញុំព្រះអង្គម្នាក់ សូមទ្រង់បង្អង់មួយអន្ទាំស្វាសិនចុះ ហើយចូលទៅកាន់ស្រុក នាំសម្លាញ់នោះមកគាល់ព្រះមានព្រះភាគ ខ្លួនឯងឈរម្ខាង ទូលសួរបញ្ហានឹងព្រះមានព្រះភាគដោយគាថាដើម ដើម្បីជាប្រយោជន៍ដល់សម្លាញ់នោះ ។ ព្រះមានព្រះភាគ កាលទ្រង់ព្យាករបញ្ហារបស់មេត្តេយ្យភិក្ខុនោះ ទើបត្រាស់គាថាដ៏សេស ។ នេះជាការកើតឡើងនៃព្រះសូត្រ ។

ក្នុងបទទាំងនោះ បទថា **មេថុនមនុយុត្តស្ស** បានដល់ នៃបុគ្គលដែលប្រកបមេថុនធម្មជានិច្ច ។ បទថា **ឥតិ** គឺព្រះមេត្តេយ្យពោលយ៉ាងនេះ ។ បទថា **អាយស្មា** នេះ ជាពាក្យហៅដោយសេចក្តីរាប់អាន ។ បទថា **តិស្សោ**

ជាឈ្មោះរបស់ព្រះថេរៈនោះ ព្រោះព្រះថេរៈនោះមានឈ្មោះតិស្សៈ ។ បទថា **មេត្តេយ្យោ** ជាគោត្ត ។ តែព្រះថេរៈគេស្គាល់ដល់គោត្តតែម្យ៉ាង ព្រោះហេតុនោះ ក្នុងការកើតឡើងនៃរឿងនោះ ព្រះសង្គីតិកាចារ្យបានពោលថា សម្លាញ់ ២ នាក់ ឈ្មោះតិស្សៈ និងមេត្តេយ្យ ។ បទថា **វិឃាតំ** គឺការបង្អៀតបង្អល់ ។ បទថា **ព្រូហិ** គឺសូមត្រាស់ប្រាប់ ។ បទថា **មារិស** នេះ ជាពាក្យហៅដោយសេចក្តីរាប់អាន សេចក្តីថា មិនមានទុក្ខ ។ បទថា **សុត្វាន** គឺស្តាប់ពាក្យរបស់ព្រះអង្គហើយ ។ បទថា **វិវេកេ សិក្ខិស្សាមសេ** ព្រះមេត្តេយ្យទូលសូមឲ្យទ្រង់សម្តែងធម៌ ប្រារព្ធដល់សម្លាញ់ តែសម្លាញ់នោះ បានទទួលការសិក្សាល្អហើយ ។ បទថា **មុស្សតេ វាបិ សាសនំ** បានដល់ ភ្លេច គឺឃ្លាតចាកពាក្យប្រៀនប្រដៅ ២ យ៉ាង គឺបរិយត្តិ និងបដិបត្តិ ។ បទថា **វាបិ** ជាពាក្យត្រឹមតែធ្វើបទឲ្យពេញ ។ បទថា **ឯតំ តស្មឹ អនារិយំ** បានដល់ ជាវត្ថុមិនប្រសើរ គឺជាមិច្ឆាបដិបទា ក្នុងបុគ្គលនោះ ។

បទថា **ឯកោ បុព្វេ ចរិត្វាន** គឺបុគ្គលតែឯងក្នុងកាលមុន ដោយបព្វជ្ជា ឬដោយការមិនជាប់ជំពាក់ជាមួយពួកគណៈ ។ បទថា **យានំ ភន្តំវ តំ លោកេ ហីនមាហុ បុថុជ្ជនំ** សេចក្តីថា បណ្ឌិតទាំងឡាយ ពោលបុគ្គលនោះ ដែលស្ទុះទៅខុសថា ដូចយានដែលស្ទុះទៅក្បែរជ្រោះ ព្រោះស្ទុះទៅក្នុងទីមិនរាបស្មើ មានកាយទុច្ចរិតជាដើម ព្រោះទម្លាយខ្លួនក្នុងនរកជាដើម និងព្រោះធ្លាក់ទៅក្នុងជ្រោះ គឺជាតិជាដើម ដូចយាន មានយានជីរជាដើម ដែលមិនបានទូន្មាន ចូលទៅកាន់ទីដែលមិនរាបស្មើខ្វះ រមែងទម្លាយអ្នកជិះខ្វះ

ឬធ្លាក់ទៅក្នុងជ្រោះខ្លះ ដូច្នេះ ។

បទថា **យសោ កិត្តិ ច** បានដល់ លាភសក្ការៈ និងការសរសើរ ។ បទថា **បុព្វេ** គឺក្នុងកាលជាបព្វជិត ។ បទថា **ហាយតេ វាបិ តស្ស សា** បានដល់ យស និងកិត្តិគុណនៃបុគ្គលដែលស្មុះទៅខុសនោះ រមែងវិនាស ។ បទថា **ឯតម្បិ ទិស្វា** គឺឃើញសេចក្តីចម្រើននៃយស និងកិត្តិក្នុងកាលមុន និងសេចក្តីវិនាសខាងក្រោយ ។ បទថា **សិក្ខេថ មេថុនំ វិប្បហាតវេ** គឺគប្បីសិក្សាត្រៃសិក្ខា ។ ព្រោះហេតុអ្វី ព្រោះដើម្បីលះមេថុន ។ លោកអធិប្បាយថា ដើម្បីប្រយោជន៍ដល់ការលះមេថុន ពិតហើយ បុគ្គលណាលះមេថុនមិនបាន បុគ្គលនោះត្រូវសេចក្តីត្រិះរិះគ្របសង្កត់ រមែងជ្រប់នៅដូចមនុស្សកំព្រា បុគ្គលបែបនោះ ឮពាក្យជនដទៃ រមែងអៀនខ្មាស ។

ក្នុងបទទាំងនោះ បទថា **បរេសំ** គឺប្រកបហើយ ។ បទថា **បរេសំ និគ្ឃោសំ** គឺពាក្យនិន្ទារបស់ឧបជ្ឈាយ៍ជាដើម ។ បទថា **មង្កុ ហោតិ** គឺជាអ្នកអាមាស់មុខ ។

គាថាក្រៅអំពីនេះ មានពាក្យអធិប្បាយជាក់ច្បាស់ហើយ ។ ក្នុងគាថាទាំងនោះ បទថា **សត្ថានិ** បានដល់ កាយទុច្ចរិតជាដើម ។ កាយទុច្ចរិតជាដើមនោះ លោកពោលថា **សត្ថានិ** ព្រោះពុះរំលំខ្លួន និងអ្នកដទៃ ។ ម្យ៉ាងទៀត ក្នុងបុគ្គលទាំងនោះ បុគ្គលនេះត្រូវបានដាស់តឿនមកអំពីមុន ជាពិសេស គង់សាងសស្ត្រាដោយការនិយាយកុហក ដោយហេតុនោះ ទើបខ្ញុំពោលថា ជាអ្នកស្មុះទៅខុស ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគ

ត្រាស់ថា សេចក្ដីសាំញ៉ាំធំនោះឯង របស់បុគ្គលនោះ រមែងធ្លាក់ចុះកាន់មុសាវាទ ។ បទថា **មហាគេធោ** គឺចំណង់ធំ ។ បើសួរថា គឺអ្វី ឆ្លើយថា គឺង៉ាកទៅរកការពោលកុហក ។ គប្បីជ្រាបថា បុគ្គលនេះឯង ជាអ្នកមានគ្រឿងចងធំ ឈមចុះកាន់មុសាវាទ ។

បទថា **មច្ចោ បរិកិស្សតិ** គឺធ្វើនូវការសម្លាប់សត្វជាដើម សោយនូវទុក្ខ ព្រោះសម្លាប់សត្វនោះជាហេតុ និងធ្វើការស្វែងរករក្សានូវសម្បត្តិ រមែងស្រពោន ដូចបុគ្គលវង្វេង ដូច្នោះ ។ បទថា **ឯតមាទីនវំ ញត្វា មុនិ បុព្វាបរេ ឥធ** សេចក្ដីថា មុនីក្នុងសាសនានេះ ដឹងទោសខាងដើម និងខាងចុងនេះ គឺក្នុងភាពជាអ្នកស្រុះទៅខុសចាកភាពជាសមណៈ ខាងចុង បន្ទាប់អំពីខាងដើម ដូចពោលហើយ ។

តាំងអំពីពាក្យថា យស និងសេចក្ដីសរសើរនោះ របស់បុគ្គលនោះ រមែងសាបសូន្យទៅ ដូច្នេះ ។

បទថា **ឯតទរិយានមុត្តមំ** គឺវិវេកចរិយានេះ ជាកិច្ចខ្ពស់របស់ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម ព្រោះដូច្នោះ គប្បីសិក្សាវិវេកប៉ុណ្ណោះ ។ បទថា **តេន សេដ្ឋោ ន មញ្ញេថ** សេចក្ដីថា មុនីមិនគួរសម្គាល់

*ខ្ជួនថា អាត្មាអញជាបុគ្គលប្រសើរដោយវិវេកនោះ លោកអធិប្បាយថា មិនគួរពាក់ព័ន្ធនឹងវិវេកនោះ ។*

*បទថា* **វិត្តស្ស** *បានដល់ ជាអ្នកស្ងាត់ គឺវៀរចាកកាយទុច្ចរិតជាដើម ។*

*បទថា* **ឱឃតិណ្ណស្ស បិហយន្តិ កាមេសុ គធិតា បជា** *សេចក្តីថា ពួកសត្វដែលជាប់ជំពាក់ក្នុងវត្ថុកាមទាំងឡាយ រមែងសរសើរចំពោះមុនីដែលឆ្លងឱឃៈ ៤ បានហើយ ដូចម្ចាស់បំណុលសរសើរអ្នកសងបំណុល ដូច្នោះ ។ ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនាដោយកំពូលនៃធម៌ គឺអរហត្ត ។*

*កាលចប់ទេសនា តិស្សៈសម្រេចសោតាបត្តិផល ក្រោយមក បានបួស ធ្វើឲ្យជាក់ច្បាស់អរហត្ត ដូច្នេះឯង ។៚*

## អដ្ឋកថាតិស្សមេត្តេយ្យសូត្រទី ៧ ចប់

# សុត្តន្តបិដក

## បសូរសូត្រទី៨

[ ១០២ ] ពួកសមណព្រាហ្មណ៍ដទៃ ក្នុងលោកនេះ តែងពោលសរសើរថា បរិសុទ្ធ ( សំដៅទិដ្ឋិរបស់ខ្លួន ) តែមិនពោលថា បរិសុទ្ធចំពោះលទ្ធិដទៃ ( ក្រៅអំពីគ្រូរបស់ខ្លួន ) សមណព្រាហ្មណ៍ជាច្រើន អាស្រ័យនឹងលទ្ធិណា តែងសរសើរថាល្អក្នុងលទ្ធិនោះ តាំងនៅក្នុងបច្ចេកសច្ចៈ ( សេចក្តីពិតដោយឡែក ) ។ សមណព្រាហ្មណ៍ទាំងនោះ ប្រាថ្នានូវវាទៈ ចូលទៅកាន់បរិស័ទហើយ ទាំង ២ នាក់ឃើញគ្នានិងគ្នា ថាជាពាលទាំងអស់ សមណព្រាហ្មណ៍ទាំងនោះ អាស្រ័យនឹងគ្រូដទៃ ក៏ពោលជម្លោះ ប្រាថ្នានូវការសរសើរ ក៏សម្គាល់ថាយើងវាងវៃក្នុងវាទៈ ។ បុគ្គលអ្នកខ្វល់ខ្វាយក្នុងការនិយាយជជែក ប្រាថ្នានូវការសរសើរក្នុងកណ្តាលបរិស័ទ រមែងទញ់តុះ និងជាបុគ្គលអៀនខ្មាសក្នុងវាទៈ ( របស់ខ្លួន ) ដែលគេផាត់ចោល បុគ្គលស្វែងរកទោសនោះ រមែងខឹងព្រោះពាក្យនិន្ទា ។ អ្នកពិចារណានូវបញ្ហាទាំងឡាយ ពោលនូវវាទៈរបស់បុគ្គលនោះ ថាជាវាទៈថោកទាប ថាគេផាត់ចោលហើយ បុគ្គលអ្នកមានវាទៈថោកទាប តែងខ្សឹកខ្សួល សោក ថ្ងូរថាអ្នកនោះកន្លងអាត្មាអញ ( ដោយវាទៈ ) ។ វិវាទទាំងនុ៎ះកើតឡើងក្នុងពួកសមណៈ សភាពត្រេកអរ និងការអាក់អន់

ចិត្ត រមែងកើតឡើងព្រោះវាទៈទាំងនុ៎ះ អ្នកប្រាជ្ញឃើញទោសនុ៎ះហើយ គប្បីចៀសវាងនូវជម្លោះចេញ ប្រយោជន៍ដទៃអំពីការសរសើរ និងលាភមិនមានឡើយ ។ មួយទៀត បុគ្គលដែលគេសរសើរក្នុងរឿងនោះហើយ ក៏ពោលនូវវាទៈ ( របស់ខ្លួន ) ក្នុងកណ្តាលបរិស័ទ បុគ្គលនោះរីករាយផង ឡើងជោរផង ព្រោះសម្រេចប្រយោជន៍ គឺជ័យជម្នះដូចចិត្ត ។ ការឡើងជោរ ជាហេតុនៃសេចក្តីចង្អៀតចង្អល់របស់បុគ្គល បុគ្គលនុ៎ះ តែងពោលនូវមានះ និងអតិមានះ បុគ្គលឃើញទោសនេះហើយ គប្បីចៀសវាងជម្លោះ អ្នកឈ្លាសវៃទាំងឡាយ មិនពោលសរសើរថា បរិសុទ្ធដោយជម្លោះនោះឡើយ ។ ប្រៀបដូចបុគ្គលអ្នកអង់អាច ដែលស្តេចចិញ្ចឹមហើយ ដោយរាជ-រង្វាន់ កាលប្រាថ្នាគំរាមទៅរកបុគ្គលអ្នកអង់អាចតប អ្នកអង់អាចតបនោះមានក្នុងទីណា នៃអ្នកអង់អាច អ្នកចូរទៅក្នុងទីនោះចុះ កិលេសគប្បីមានដោយចម្បាំង មិនមានតាំងពីមុនមក ។ ជនទាំងឡាយដែលប្រកាន់ទិដ្ឋិ ហើយពោលជជែកផង ពោលថានេះឯងជារបស់ពិតផង អ្នកចូរជជែកនឹងជនទាំងនោះចុះ ជនអ្នកធ្វើទំនាស់ក្នុងវាទៈដែលកើតហើយ ក្នុងទីនេះមិនមានដល់អ្នកទេ ។ បុគ្គលទាំងឡាយណា ធ្វើសេនារបស់កិលេសឲ្យវិនាស មិនថ្នាំងថ្នាក់នឹងទិដ្ឋិដោយទិដ្ឋិទាំងឡាយ

ឡើយ ការប្រកាន់ទិដ្ឋិដ៏ក្រៃលែង មិនមានក្នុងបុគ្គលណា ក្នុងលោកនេះ ម្នាលបសូរៈ អ្នកគប្បីបាននូវការតបតដូចម្ដេចក្នុងបុគ្គលទាំងនោះ ។ មួយទៀត អ្នកកាលត្រិះរិះគិតនូវទិដ្ឋិទាំង-ឡាយដោយចិត្ត ហើយមកប្រណាំងប្រជែង ( នឹងព្រះសម្មា-សម្ពុទ្ធ ) ដែលមានកិលេសលាងហើយ អ្នកមិនអាចនឹងជជែកបានឡើយ ។

បសូរសូត្រទី ៨ ចប់

# អដ្ឋកថា

## បសូរសូត្រ

[ ១០២ ] ក្នុងបសូរសូត្រទី ៨ មានពាក្យផ្ដើមថា **ឥធេវ សុទ្ធិ** ដូច្នេះ

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅ

បានឮថា កាលព្រះមានព្រះភាគ គង់នៅក្នុងក្រុងសាវត្ថី បរិព្វាជកឈ្មោះបសូរៈ ជាអ្នកមានវាទៈល្បីខាងវោហារ គាត់ពោលថា ក្នុងជម្ពូទីបទាំងមូល យើងជាបុគ្គលក្រៃលែងដោយវាទៈ ព្រោះដូច្នោះ ដើមព្រីងប្រាកដដល់ជម្ពូទីប យ៉ាងណា យើងក៏ដូច្នោះ ទើបយកមែកព្រីងធ្វើជាទង់ ធ្វើឲ្យអ្នកលើកវាទៈខ្ចាចរអាពេញជម្ពូទីប មកដល់ក្រុងសាវត្ថីដោយលំដាប់ ពួក

ពំនូកខ្សាច់ត្រង់ទ្វារនគរ ដោតមែកព្រីងលើគំនរខ្សាច់នោះ ពោលថា អ្នកណាអាចលើកវាទៈជាមួយយើង បុគ្គលនោះ ចូរកាច់បំបាក់មែកព្រីងនេះ ហើយចូលទៅកាន់នគរ ។ មហាជនបានឈរចោមរោមទីនោះ ។

សម័យនោះ ព្រះសារីបុត្តធ្វើកិច្ចស្រេចហើយ ចេញអំពីក្រុងសាវត្ថី ឃើញមែកព្រីងនោះ ក៏សួរក្មេងៗ ទាំងឡាយថា នេះជាអ្វីហ្នំ ពួកក្មេងប្រាប់រឿងរ៉ាវទាំងអស់ឲ្យព្រះថេរៈជ្រាប ព្រះថេរៈពោលថា បើដូច្នោះ ចូរពួកអ្នកដកមែកឈើនោះ ហើយជាន់បំបាក់ចុះ ហើយចូរពួកអ្នកប្រាប់បុរសនោះថា បើត្រូវការលើកវាទៈ ចូរទៅកាន់វិហារ ដូច្នេះ ។ បរិព្វាជកត្រាច់បិណ្ឌបាតធ្វើភត្តកិច្ចស្រេចហើយ ក៏ដើរត្រឡប់ ឃើញមែកឈើត្រូវដក ហើយកាច់ចោល ទើបសួរថា នេះជាកម្មរបស់អ្នកណា កាលបានឮថា ព្រះសារីបុត្តជាពុទ្ធសាវកឲ្យក្មេងធ្វើ គាត់ត្រេកអរថា ថ្ងៃនេះ ពួកបណ្ឌិតនឹងបានឃើញការឈ្នះរបស់អញ និងការបរាជ័យរបស់សមណៈ ទើបចូលទៅកាន់ក្រុងសាវត្ថី ដើម្បីនាំមនុស្សមកជាសាក្សីក្នុងការល្បងបញ្ហា ទើបត្រាច់ប្រកាសតាមផ្លូវបែកជា ៤ ថា អ្នកទាំងឡាយបំណងនឹងស្តាប់ការមុតស្រួចដោយបញ្ញា ក្នុងការលើកវាទៈជាមួយអគ្គសាវករបស់ព្រះសមណគោតម ចូរនាំគ្នាមក ។ ពួកមនុស្សជាច្រើនជ្រះថ្លាខ្លះ មិនជ្រះថ្លាខ្លះក្នុងព្រះសាសនា នាំគ្នាចេញទៅ ដោយគិតថា នឹងស្តាប់ពាក្យរបស់បណ្ឌិត ។ គ្រានោះ បសូរបរិព្វាជកចោមរោមដោយមហាជន ទៅកាន់វិហារ និងគិតថា កាលព្រះសារីបុត្តពោលយ៉ាងនេះ អញនឹងពោលយ៉ាងនេះ ។ ព្រះថេរៈគិតថា សំឡេងគឹកកង

កុំបីបៀតបៀនអ្នកនៅក្នុងវិហារឡើយ ទើបឲ្យក្រាលអាសនៈ ត្រង់ខ្លោងទ្វារវត្តជេតពន ។ បរិព្វាជកចូលទៅរកព្រះថេរៈហើយ ពោលថា បព្វជិតដ៏ចម្រើន លោកឲ្យកូនក្មេងកាច់មែកព្រីងរបស់ខ្ញុំឬ ព្រះថេរៈតបថា អើ បរិព្វាជក ។ បសូរៈពោលថា ណ្ហើយចុះ លោកដ៏ចម្រើន យើងទាំង ២ នឹងផ្តើមវាទៈចុះ ព្រះថេរៈទទួលថា សាធុ ។ បសូរៈពោលថា សមណៈ ចូរសួរខ្ញុំនឹងឆ្លើយ ។

កាលនោះ ព្រះថេរៈបានពោលនឹងបរិព្វាជកថា នែបរិព្វាជក ការសួរលំបាក ឬការឆ្លើយលំបាក បរិព្វាជកឆ្លើយថា បព្វជិតដ៏ចម្រើន ការឆ្លើយលំបាកជាងការសួរ ព្រោះនរណាសួរយ៉ាងណាក៏បាន ។ ព្រះថេរៈពោលថា បរិព្វាជក អ្នកសួរចុះ ខ្ញុំនឹងឆ្លើយ ។ កាលព្រះថេរៈពោលយ៉ាងនេះហើយ បរិព្វាជកគិតថា ភិក្ខុនេះមានរូបស្អាតបាត ឲ្យក្មេងកាច់មែកឈើរបស់អញ ទើបសួរព្រះថេរៈថា អ្វីជាកាមរបស់បុរស ។ ព្រះថេរៈឆ្លើយថា ការត្រិះរិះប្រកបដោយតម្រេកជាកាមរបស់បុរស ។ បសូរបរិព្វាជកស្តាប់ដូច្នោះ មានការយល់ខុសក្នុងព្រះថេរៈ ចង់ឲ្យព្រះថេរៈចាញ់ ទើបពោលថា បព្វជិតដ៏ចម្រើន លោកមិនបានពោលដល់អារម្មណ៍ដ៏វិចិត្រថា ជាកាមរបស់បុរសទេឬ ព្រះថេរៈឆ្លើយថា ត្រូវហើយ បរិព្វាជក ខ្ញុំមិនពោលយ៉ាងនោះទេ ។ បរិព្វាជកឲ្យព្រះថេរៈទទួលអស់ ៣ ដង ហៅអ្នកកាត់បញ្ហាមកថា លោកដ៏ចម្រើនទាំងឡាយ ចូរស្តាប់ការខុសក្នុងវាទៈរបស់សមណៈចុះ ហើយពោលថា បព្វជិតដ៏ចម្រើន សព្រហ្មចារីរបស់លោកនៅក្នុងព្រៃឬ ។ ព្រះថេរៈតបថា

ត្រូវហើយបរិព្វាជក បរិព្វាជកសួរថា សព្រហ្មចារីទាំងនោះនៅក្នុងព្រៃ គន់គ្រិះរិះដល់កាមវិតក្កជាដើមឬ ព្រះថេរៈឆ្លើយថា ត្រូវហើយ បរិព្វាជក បុថុជ្ជនទាំងឡាយត្រិះរិះដល់កាមជានិច្ច ។ បរិព្វាជកសួរថា បើដូច្នោះ ភាពជាសមណៈរបស់សព្រហ្មចារីទាំងនោះនៅឯណា ជនទាំងនោះនៅជាអ្នកបរិភោគកាម គ្រប់គ្រងផ្ទះមិនមែនឬ កាលពោលយ៉ាងនេះហើយ ទើបពោលពាក្យជាប្រព័ន្ធគាថាថា

វត្ថុដែលស្អាតក្នុងលោក មិនមែនកាមរបស់លោក ហើយលោក
ពោលការត្រិះរិះប្រកបដោយរាគថាជាកាម សូម្បីភិក្ខុរបស់លោក
កាលត្រិះរិះក្នុងអកុសលវិតក្ក ក៏នឹងជាអ្នកបរិភោគកាម ។

លំដាប់នោះ ព្រះថេរៈកាលនឹងសម្តែងកំហុសក្នុងវាទៈរបស់បរិព្វាជក ទើបពោលថា នែបរិព្វាជក អ្នកមិនពោលដល់ការត្រិះរិះប្រកបដោយតម្រេកថា ជាកាមរបស់បុរស អ្នកពោលដល់អារម្មណ៍ល្អវិចិត្រថាជាកាមឬ បសូរ-បរិព្វាជកពោលថា ត្រូវហើយបព្វជិតដ៏ចម្រើន ។ លំដាប់នោះ ព្រះថេរៈឲ្យបសូរបរិព្វាជកទទួល ៣ ដង ហើយទើបហៅអ្នកសម្រេចបញ្ហាមកថា អាវុសោទាំងឡាយ ពួកអ្នក ចូរស្តាប់ការខុសក្នុងវាទៈរបស់បរិព្វាជកចុះ ហើយពោលថា នែអាវុសោបសូរៈ សាស្តារបស់អ្នកមានឬ បសូរៈឆ្លើយថា មាន បព្វជិត ព្រះសារីបុត្តសួរថា សាស្តារមែងឃើញរូបារម្មណ៍ ដែលគួរដឹងបានដោយចក្ខុ ឬថា សេពនូវសទ្ទារម្មណ៍ជាដើមឬទេ ។ បរិព្វាជកឆ្លើយថា មែន រមែងសេព ព្រះថេរៈសួរថា បើដូច្នោះ ភាពជាព្រះសាស្តារបស់

សាស្តានោះនៅឯណា សាស្តានោះ ជាអ្នកបរិភោគកាម គ្រប់គ្រងផ្ទះ មិនមែនឬ កាលព្រះថេរៈពោលយ៉ាងនេះហើយ បានពោលប្រព័ន្ធគាថាថា

ការស្អាតក្នុងលោក ជាកាមរបស់អ្នក អ្នកមិនពោលដល់ការត្រិះរិះ ប្រកបដោយតម្រេកថាជាកាម កាលឃើញរូបគួរជាទីត្រេកអរ កាលស្តាប់សំឡេងគួរជាទីត្រេកអរ កាលហិតក្លិនគួរជាទីត្រេកអរ កាលលិទ្ធភ្លក្សរសគួរជាទីត្រេកអរ កាលពាល់ត្រូវនូវផស្សៈគួរជាទីត្រេកអរ សូម្បីសាស្តារបស់អ្នកក៏គង់នៅបរិភោគកាម ។

កាលព្រះថេរៈពោលយ៉ាងនេះហើយ បរិញ្វជកទាល់ប្រាជ្ញា គិតថា បព្វជិតនេះ មានវាទៈគួររាប់អាន អញនឹងបួសក្នុងសម្នាក់បព្វជិតនេះ ហើយសិក្សាតម្រាវាចា ទើបចូលទៅកាន់ក្រុងសាវត្ថី ស្វែងរកបាត្រហើយ ចូលទៅកាន់វត្តជេតពន ឃើញលោឡុទាយីភិក្ខុក្នុងទីនោះ មានពណ៌កាយដូចមាសគួរជាទីជ្រះថ្លា ដោយហោចសូម្បីក្នុងអាការផ្លូវកាយ និងមារយាទ យល់ថា ភិក្ខុរូបនេះ គង់មានបញ្ញាច្រើន គង់ជាអ្នកជំនាញក្នុងការនិយាយ ទើបបួសក្នុងសម្នាក់របស់លោក ហើយសង្កត់សង្កិនលោកដោយវាទៈ ត្រឡប់ចូលទៅកាន់លទ្ធិនោះឯងទៀត មួយអន្លើដោយភេទ ( ភិក្ខុ ) ហើយគិតថា អញនឹងលើកវាទៈជាមួយព្រះសមណគោតមទៀត ទើបប្រកាសក្នុងក្រុងសាវត្ថីដោយន័យមុននោះឯង ចោមរោមដោយមហាជន ពោលថា អញនឹងសង្កត់សង្កិនព្រះសមណគោតមជាដើម បានទៅកាន់វត្តជេតពន ។ ទេវតា

ដែលអាស្រ័យក្នុងខ្ទោងទ្វារវត្តជេតពនគិតថា បុគ្គលនេះមិនគួរស្ងាគមន៍ ទើបបិទមាត់របស់បរិព្វាជកនោះ ។ បសូរៈចូលទៅគាល់ព្រះមានព្រះភាគ ហើយអង្គុយដូចមនុស្សគ ពួកមនុស្សគិតថា ឥឡូវនេះ បសូរៈគង់នឹងសាកសួរមើលមុខបសូរៈនោះហើយ នាំគ្នាស្រែកថា បសូរៈ សូមលោកនិយាយចុះ បសូរៈ សូមលោកនិយាយចុះ ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់ថា បសូរៈនឹងនិយាយបានដូចម្ដេច កាលទ្រង់សម្ដែងធម៌ដល់បរិស័ទដែលប្រជុំគ្នាក្នុងទីនោះ ទើបត្រាស់ព្រះសូត្រនេះ ។

ក្នុងគាថាដើមនោះ គប្បីជ្រាបសេចក្ដីសង្ខេបដូចតទៅនេះ បទថា សមណព្រាហ្មណ៍ដទៃក្នុងលោកនេះ តែងពោលសរសើរថា បរិសុទ្ធ ( សំដៅទិដ្ឋិរបស់ខ្លួន ) តែមិនពោលថា បរិសុទ្ធចំពោះលទ្ធិដទៃ ( ក្រៅអំពីគ្រូរបស់ខ្លួន ) កាលបើដូច្នេះ សមណព្រាហ្មណ៍ជាច្រើនពោលភាពល្អ ក្នុងសាស្ដាជាដើមរបស់ខ្លួន ដែលខ្លួនអាស្រ័យហើយប៉ុណ្ណោះថា នេះជាវាទៈដ៏ល្អ ប្រកាន់មាំក្នុងបច្ចេកសច្ចៈ ( ដែលខ្លួនយល់ឯង ) យ៉ាងនេះថា លោកទៀងជាដើម កាលបើប្រកាន់មាំយ៉ាងនោះ ទើបមានគាថាតមកថា **តេ វាទកាមា** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ពាលំ ទហន្តិ មិថុ អញ្ញមញ្ញំ** គឺជនទាំង ២ នោះតែងប្រកែកគ្នានិងគ្នាថា ជាបុគ្គលល្ងង់ខ្លៅ រមែងឃើញដោយភាពជាបុគ្គលល្ងង់ខ្លៅថា បុគ្គលនេះជាបុគ្គលល្ងង់ខ្លៅ បុគ្គលនេះជាបុគ្គលល្ងង់ខ្លៅ ដូច្នេះ ។ បទថា **វទន្តិ តេ អញ្ញសិតា កថោជ្ជំ** គឺសមណព្រាហ្មណ៍ទាំងនោះអាស្រ័យសាស្ដានៃគ្នានិងគ្នាជាដើម រមែងពោលនូវពាក្យឈ្មោះប្រកែក

គ្នា ។ បទថា **បសំសកាមា កុសលា វទានា** គឺប្រាថ្នាតែការសរសើរ ជាអ្នកមានសេចក្តីសម្គាល់ថា សូម្បីយើងទាំង ២ ក៏ជាអ្នកឈ្លាសក្នុងវាទៈ មានវាទៈជាបណ្ឌិត ក្នុងបុគ្គលដែលពោលជំទាស់បែបនោះ មានបុគ្គលម្នាក់ ត្រូវកំណត់ ទើបមានគាថា ( ទី ៣ ) ថា **យុត្តោ កថាយំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **យុត្តោ កថាយំ** គឺខ្វល់ខ្វាយរកនូវពាក្យ ឈ្លោះប្រកែក ។ បទថា **បសំសមិច្ឆំ វិនិឃាតិ ហោតិ** គឺប្រាថ្នាការ សរសើរដល់ខ្លួន ពោលពាក្យប្រៀបធៀបគ្នាមកអំពីមុន ដោយន័យជាដើម ថា អញនឹងសង្កត់សង្កិនបានដូចម្តេចហ្ន៎ ។ បទថា **អបាហតស្មឹ** សេចក្តីថា ព្រោះក្នុងវាទៈដែលអ្នកកាត់សម្រេចបញ្ហា មិនធ្វើឲ្យជ្រះថ្លា ដោយន័យជាដើម ថា អ្នកពោលប្រាសចាកអត្ថ អ្នកពោលប្រាសចាកព្យញ្ជនៈ ។ បទថា **និន្ទាយ សោ កុប្បតិ** គឺបុគ្គលនោះរមែងក្រោធ ព្រោះនិន្ទាដែលកើតឡើងក្នុងវាទៈ ដែលបុគ្គលអ្នកកាត់សម្រេច មិនធ្វើឲ្យជ្រះថ្លាយ៉ាងនេះ ។ បទថា **រន្ធមេសី** គឺបុគ្គលស្វែងរកទោសរបស់អ្នកដទៃ ។ មិនមែនក្រោធតែម្យ៉ាង ។ គប្បីជ្រាប គាថាតទៅផងដែរថា **យមស្ស វាទំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **បរិហីនមាហុ អបាហតំ** គឺពោលវាទៈដែល ខ្លួនមិនធ្វើឲ្យជ្រះថ្លាហើយ ដោយអត្ថ និងដោយព្យញ្ជនៈជាដើមថា ជាវាទៈ វិនាស ។ បទថា **បរិទេវតិ** គឺព្រោះវាទៈដែលមិនធ្វើឲ្យជ្រះថ្លានោះជាហេតុ បុគ្គលនោះរមែងរវើរវាយដោយពាក្យជាដើមថា អញនឹកដល់វាទៈដទៃហើយ ។ បទថា **សោចតិ** គឺរមែងសោយសោកប្រារព្ធពាក្យជាដើមថា បុគ្គលនោះឯង

ជាអ្នកឈ្នះ ។ បទថា **ឧបច្ចគា មន្តិ អនុត្ថុណាតិ** គឺបុគ្គលនោះ រមែងវើរវាយ ដោយន័យជាដើមថា មានវាទៈជាងអញហើយ ។

**សមណា** ក្នុងបទនេះថា **ឯតេ វិវាទា សមណេសុ** សំដៅដល់បរិព្វាជកក្រៅសាសនា ។ បទថា **ឯតេសុ ឧគ្ឃាតិ និគ្ឃាតិ ហោតិ** គឺកាលកើតនូវការគិតប៉ះខ្ទប់គ្នាដោយការឈ្នះ និងការចាញ់ជាដើម ក្នុងវាទៈទាំងនោះជាអ្នកប៉ះខ្ទប់គ្នា ។ បទថា **វិរមេ កថោជ្ជំ** គឺគប្បីវៀរការឈ្លោះគ្នានិងគ្នា ។ បទថា **ន ហញ្ញទត្ថត្ថិ បសំសលាភា** គឺមិនមានប្រយោជន៍ដទៃចាកការបានទទួលនូវការសរសើរក្នុងការឈ្លោះនេះ ។

គប្បីជ្រាបក្នុងគាថាទី ៦ ថា ព្រោះមិនមានប្រយោជន៍ដទៃអំពីការបានទទួលនូវការសរសើរ ដូច្នោះ បុគ្គលនោះ សូម្បីបានលាភយ៉ាងក្រៃលែងបុគ្គលដែលគេសរសើរក្នុងរឿងនោះថា បុគ្គលនេះជាមនុស្សល្អ ក៏ពោលនូវវាទៈ ( របស់ខ្លួន ) ក្នុងកណ្តាលបរិស័ទ បន្ទាប់ពីនោះ បុគ្គលនោះ ដោយប្រយោជន៍នៃការឈ្នះនោះ ទើបដល់នូវការត្រេកអរ ឬញញឹម រមែងត្រេកអរនិងលើកតម្កើងដោយមានះ ព្រោះហេតុអ្វី ព្រោះបានទទួលប្រយោជន៍អំពីជ័យជម្នះនោះ សមដូចបំណង ។ កាលលើកខ្លួនបែបនេះ ទើបមានគាថាថា **យា ឧណ្ណាតិ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **មានាតិមានំ វទតេ បនេសោ** គឺបុគ្គលនោះមិនដឹង ដល់ការលើកខ្លួននោះថា ជាបាទនៃការប៉ះខ្ទប់គ្នា ទើបពោលដល់ការប្រកាន់ខ្លួន និងការមើលងាយអ្នកដទៃរឿយៗ ទៅ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងដល់ទោសក្នុងវាទៈយ៉ាងនេះហើយឥឡូវនេះ កាលទ្រង់មិនទទួលវាទៈរបស់បសូរបរិព្វាជកនោះ ទើបត្រាស់គាថាថា **សូរោ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **រាជខាទាយ** បានដល់ រាជខាទនីយាហារ ។ លោកអធិប្បាយថា ដោយតម្លៃ គឺភត្ត ។ បទថា **អភិគជ្ជមេតិ បដិសូរមិច្ឆំ** គឺលោកសម្ដែងថា បុគ្គលនោះជាម្ចាស់ទិដ្ឋិ ប្រាថ្នានឹងជួបបុគ្គលដែលជាម្ចាស់ទិដ្ឋិ ដូចអ្នកក្លាហានប្រាថ្នាជួបបុគ្គលជាបដិបក្ខនោះ រមែងគំរាម ចូលរក ( ដាក់ ) គ្នា ដូច្នោះ ។ បទថា **យេនេវ សោ តេន បលេហិ** បានដល់ ចូរអ្នកទៅកាន់ទីដែលបុគ្គលម្ចាស់ទិដ្ឋិ ដែលជាបដិបក្ខរបស់អ្នកចុះ ។ បទថា **បុព្វេវ នត្ថិ យទិទំ យុធាយ** គឺទ្រង់សម្ដែងថា កិលេសជាត ដើម្បីការច្បាំងនេះ មិនមានក្នុងកាលមុនឡើយ កិលេសជាតនោះ តថាគតលះបង់ត្រង់មណ្ឌលពោធិព្រឹក្សនោះឯង ។ គាថាដ៏សេស មានអធិប្បាយក្លាប់គ្នាច្បាស់ហើយ ។

ក្នុងបទទាំងនោះ បទថា **វិវាទយន្តិ** គឺពោលប្រកួតប្រកាន់គ្នា ។ បទថា **បដិសេនិកត្តា** គឺអ្នកធ្វើផ្ទុយគ្នា ។ បទថា **វិសេនិកត្វា** បានដល់ កម្ចាត់

សេនា គឺកិលេសឲ្យវិនាសខ្ចាត់ទៅ ។ បទថា **ភីរុ លោកោ** គឺលោកនឹងបាន ចូលច្បាំងដោយវាទៈដូចម្ដេច ។ ព្រះមានព្រះភាគ ត្រាស់ហៅបរិព្វាជកនោះ ថា **បសូរ** ។ បទថា **យេសីធ នត្ថិ** គឺក្នុងព្រះអរហន្តដែលមិនមានការប្រកាន់ ក្នុងលោកនេះ ។ បទថា **បដិសេនិកត្តា** គឺត្រិះរិះជាដើមថា ការឈ្នះនឹងមានដល់ អាត្មាអញក្នុងទីនេះឬហ្ន៎ ។ បទថា **ធោនេន យុគំ សមាគមា** គឺកាន់យក ភាពជាគូប្រជែងជាមួយនឹងព្រះពុទ្ធ ដែលកម្ចាត់កិលេសបានហើយ ។ បទថា **ន ហិ ត្វំ សក្ខសិ សម្បយាតវេ** សេចក្ដីថា អ្នកមិនអាចកាន់យកភាពជាគូ ប្រជែងជាមួយព្រះពុទ្ធ ដែលជាអ្នកកម្ចាត់កិលេសឲ្យសម្រេចបាន សូម្បីតែ មួយបទ ឬញ៉ាំងការកាន់យកភាពជាអ្នកប្រជែងឲ្យដល់ព្រមបាន ដូចចចក ជាដើម មិនអាចប្រជែងជាមួយរាជសីហ៍បាន ដូច្នោះ ។ បទដ៏សេស ក្នុង បទទាំងពួង ប្រាកដច្បាស់ហើយ ដោយប្រការដូច្នេះ ។

**អដ្ឋកថាបសូរសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## មាគន្ទិយសូត្រទី៩

[ ១០៣ ] ( ព្រះសម្ពុទ្ធទ្រង់ត្រាស់នឹងមាគន្ទិយព្រាហ្មណ៍ថា ) អើក៏សេចក្តីប្រាថ្នាក្នុងមេថុនមិនមាន ( ដល់តថាគត ) ព្រោះឃើញនាងតណ្ហា នាងអរតី និងនាងរាគា ( ដែលជាធីតានៃមារ ) សោះទៅហើយ ធ្វើម្តេចឡើយ តថាគតនឹងមានសេចក្តីប្រាថ្នាក្នុងមេថុន ព្រោះឃើញនូវរូបរបស់ទារិកា ដែលពោរពេញដោយមូត្រ និងករីសនេះ តថាគតមិនគួរត្រូវការដើម្បីបះពាល់ នូវធីតារបស់អ្នកនោះសូម្បីតែដោយជើងឡើយ ។

( មាគន្ទិយព្រាហ្មណ៍ទូលតបថា ) បើព្រះអង្គមិនត្រូវការនារីរតន៍បែបនេះ ដែលពួកក្សត្រធំជាងនរៈច្រើនគ្នា ប្រាថ្នាទេ តើព្រះអង្គនឹងពោលនូវទិដ្ឋិផង សីលផង វត្តផង ជីវិតផង ការកើតឡើងក្នុងភព ( របស់ព្រះអង្គ ) ផង ថាដូចម្តេច ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលមាគន្ទិយៈ ) តថាគតនោះមិនប្រកាន់ថា តថាគតវិនិច្ឆ័យក្នុងធម៌ទាំងឡាយ គឺទិដ្ឋិ ៦២ ហើយ នឹងសម្តែងនូវពាក្យនេះដូច្នេះទេ ព្រោះតថាគតឃើញ ( ទោស ) ក្នុងទិដ្ឋិទាំងឡាយផង មិនប្រកាន់មាំ ( នូវទិដ្ឋិណាមួយ ) ផង ពិចារណា ( នូវសច្ចៈទាំង-ឡាយ ) ផង ក៏បានឃើញនូវសេចក្តីស្ងប់ក្នុងសន្តាន គឺព្រះ

និព្វាន ។

( មាគន្ទិយព្រាហ្មណ៍ ទូលសួរថា ) បពិត្រព្រះមុនី ទិដ្ឋិទាំងឡាយណា ដែលសត្វបានវិនិច្ឆ័យកំណត់ទុកហើយ ព្រះអង្គមិនប្រកាន់មាំនូវទិដ្ឋិទាំងនោះ សម្ដែងនូវបរមត្ថធម៌ ណា មានសេចក្ដីស្ងប់ក្នុងសន្ដានដូច្នេះ បរមត្ថធម៌នោះ តើ អ្នកប្រាជ្ញទាំងឡាយ សម្ដែងដោយប្រការដូចម្ដេច ។

( ព្រះមានព្រះភាគទ្រង់ត្រាស់តបថា ម្នាលមាគន្ទិយៈ ) អ្នកប្រាជ្ញមិនពោលថា សេចក្ដីបរិសុទ្ធព្រោះការយល់ឃើញ ព្រោះការស្ដាប់ឮ ព្រោះការដឹងច្បាស់ ព្រោះសីល និងវត្តទេ ទាំងមិនពោលថា សេចក្ដីបរិសុទ្ធព្រោះមិនមានការយល់ឃើញ ព្រោះមិនមានការស្ដាប់ឮ ព្រោះមិនមានការដឹងច្បាស់ ព្រោះ មិនមានសីល ព្រោះមិនមានវត្តទាំងនោះទេ ចំណែកបុគ្គលជា សប្បុរស តែងលះនូវធម៌មានទិដ្ឋិជាដើមនុ៎ះ ហើយមិនប្រកាន់ មិនអាស្រ័យ ( នូវធម៌ណាមួយ ) រមែងមិនប្រាថ្នាទៅកើត ក្នុងភពទៀតឡើយ ។

( មាគន្ទិយព្រាហ្មណ៍ ក្រាបទូលថា ) បើអ្នកប្រាជ្ញ មិនពោលថា សេចក្ដីបរិសុទ្ធព្រោះការយល់ឃើញ ព្រោះការ ស្ដាប់ឮ ព្រោះការដឹងច្បាស់ ព្រោះសីល និងវត្តទេ ទាំងមិន ពោលថា សេចក្ដីបរិសុទ្ធព្រោះមិនមានការយល់ឃើញ ព្រោះ

មិនមានការស្តាប់ឮ ព្រោះមិនមានការដឹងច្បាស់ ព្រោះមិនមានសីល ព្រោះមិនមានវត្តទាំងនោះទេ ខ្ញុំព្រះអង្គសម្គាល់នូវធម៌ នាំសត្វឲ្យវង្វេងក្រៃពេក មានសមណព្រាហ្មណ៍ពួកខ្លះដឹងនូវសេចក្តីបរិសុទ្ធ ព្រោះការយល់ឃើញដែរ ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលមាគន្ទិយៈ ) អ្នកអាស្រ័យនូវទិដ្ឋិ បានជាខំជជីកសួរ ( តថាគត ) អ្នកដល់នូវសេចក្តីភ័ន្តច្រឡំក្នុងទិដ្ឋិទាំងឡាយ ដែលអ្នកប្រកាន់មាំហើយ ហើយមិនបានឃើញនូវសេចក្តីសម្គាល់ សូម្បីបន្តិចបន្តួច អំពីធម្មទេសនាដែលតថាគតសម្តែងនេះឡើយ ព្រោះហេតុនោះអ្នកទើបយល់ឃើញនូវធម៌នេះថា ជាធម៌នាំសត្វឲ្យវង្វេងក្រៃពេក បុគ្គលណាសម្គាល់ខ្លួនថាជាបុគ្គលស្មើនឹងគេ ជាបុគ្គលវិសេសជាងគេ ឬជាបុគ្គលថោកទាបជាងគេ បុគ្គលនោះនឹងនិយាយទទឹងទាស់ដោយសេចក្តីសម្គាល់នោះ ( បើបុគ្គលណា ) មិនញាប់ញ័រក្នុងមានះ ៣ ទេ សេចក្តីសម្គាល់ខ្លួនថា អញជាបុគ្គលស្មើនឹងគេ អញជាបុគ្គលវិសេសជាងគេ ( ឬថា អញជាបុគ្គលថោកទាបជាងគេ ) មិនមានដល់បុគ្គលនោះឡើយ ។ បុគ្គលដែលមានបាប គឺមានះ និងទិដ្ឋិ លះបង់ហើយនោះ នឹងនិយាយថា សេចក្តីយល់នោះឯង ជាសេចក្តីយល់ត្រូវពិត ដូចម្តេចកើត ឬបុគ្គលនោះ នឹងនិយាយទទឹងទាស់ថា ( ពាក្យខ្ញុំពិត

ពាក្យអ្នកឯង ) មិនពិត ដូច្នេះ ជាមួយនឹងបុគ្គលណាបាន មួយទៀត សេចក្តីសម្គាល់ថា ស្មើ ឬមិនស្មើ មិនមានក្នុងបុគ្គលណា បុគ្គលនោះ នឹងផ្សាយវាទៈជាមួយអ្នកណាបាន ។ អ្នកប្រាជ្ញបានលះបង់ឱកៈហើយ ជាអ្នកមិនរឭកនូវអារម្មណ៍ជាគ្រឿងកំណត់ មិនធ្វើសេចក្តីស្និទ្ធស្នាល ( នឹងគ្រហស្ថ ) ក្នុងស្រុក ជាអ្នកវៀរចាកកាមទាំងឡាយ មិនធ្វើអត្តភាពឲ្យកើតតទៅទៀត អ្នកប្រាជ្ញនោះ មិនគប្បីធ្វើពាក្យពោលជំទាស់នឹងជន ( ណា ) ឡើយ ។ បុគ្គលប្រសើរ ជាអ្នកស្ងប់ស្ងាត់ចាកបាបធម៌ ( មានការយល់ខុសជាដើម ) ណា ហើយត្រាច់ទៅក្នុងលោក មិនគប្បីលើកឡើងនូវបាបធម៌ទាំងនោះមកហើយនិយាយជជែកទេ ផ្កាឈូកដុះនៅក្នុងទឹក មិនប្រឡាក់ដោយទឹកផង ដោយភក់ផង យ៉ាងណាមិញ អ្នកប្រាជ្ញជាអ្នកពោលនូវសេចក្តីស្ងប់ មានសន្តានមិនជាប់ជំពាក់ រមែងជាអ្នកមិនជក់ជាប់នៅក្នុងកាមផង ក្នុងលោកផង យ៉ាងនោះឯង ។ បុគ្គលអ្នកដល់នូវវេទ គឺមគ្គ ៤ តែងមិនប្រព្រឹត្តទៅតាមទិដ្ឋិទេ បុគ្គល

នោះមិនត្រឡប់មកកាន់មានះ ដោយការប៉ះពាល់ទេ បុគ្គលនោះមិនប្រព្រឹត្តទៅតាមអំណាចនៃតណ្ហាទិដ្ឋិនោះទេ បុគ្គលនោះមិនងាយអ្នកណាដឹកនាំដោយកម្ម ឬដោយអារម្មណ៍ដែលឮបានឡើយ បុគ្គលនោះ មិនចូលទៅនៅអាស្រ័យក្នុងនិវេសនៈគឺតណ្ហា និងទិដ្ឋិទេ ។ កិលេសគ្រឿងរួបរឹតទាំងឡាយ តែងមិនមានដល់បុគ្គលអ្នកប្រាសចាកកាមសញ្ញា ( ជាដើម ) មោហៈ ( សេចក្តីភ័ន្តច្រឡំ ) តែងមិនមានដល់បុគ្គលអ្នកផុតស្រឡះ ( ចាកកិលេសទាំងពួង ) ព្រោះវិបស្សនាបញ្ញា បុគ្គលទាំងឡាយណា ប្រកាន់មាំនូវកាមសញ្ញាជាដើមក្តី ប្រកាន់មាំនូវទិដ្ឋិក្តី បុគ្គលពួកនោះ រមែងព្យាយាមប្រព្រឹត្តនូវកាមាធិករណ៍ ឬធម្មាធិករណ៍ នូវគ្នានិងគ្នា ក្នុងលោក ។

មាគន្ទិយសូត្រទី ៩ ចប់

# អដ្ឋកថា

## មាគន្ទិយសូត្រ

[ ១០៣ ] ក្នុងមាគន្ទិយសូត្រទី ៩ មានពាក្យផ្តើមថា **ធិស្វាន តណ្ហំ** ដូច្នេះ សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្តេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅនេះ

សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងនគរសាវត្ថី ក្នុងវេលាទៀបភ្លឺ ទ្រង់ប្រមើលមើលលោកដោយទិព្វចក្ខុ ទ្រង់ឃើញឧបនិស្ស័យអរហត្តរបស់មាគន្ទិយព្រាហ្មណ៍ មួយអន្លើដោយភរិយា ដែលជាអ្នកដែនកម្មាសធម្មនិគម ដែនកុរុ ។ ក្នុងវេលានោះឯង ទ្រង់យាងដល់ទីនោះ ទ្រង់បញ្ចេញរស្មីពណ៌មាស គង់ក្នុងដងព្រៃមួយកន្លែង មិនឆ្ងាយអំពីកម្មាសធម្មនិគមនោះ ។

ខណៈនោះ មាគន្ទិយព្រាហ្មណ៍ក៏បានទៅនិគមនោះដើម្បីលុបមុខ ឃើញរស្មីពណ៌មាស គិតថា នេះជាអ្វីហ្ន៎ សម្លឹងមើលក្នុងទីផ្សេងៗ ឃើញព្រះមានព្រះភាគក៏ត្រេកអរ ។ បានឮថា ធីតារបស់ព្រាហ្មណ៍នោះ មានពណ៌សម្បុរដូចមាស បណ្តាខត្តិយកុមារជាច្រើនជាដើម នាំគ្នាសូមស្រីនោះ ក៏មិនបានព្រាហ្មណ៍បំណងថា នឹងលើកធីតាឲ្យដល់សមណៈដែលមានពណ៌ដូចមាសប៉ុណ្ណោះ ។ ព្រាហ្មណ៍ឃើញព្រះមានព្រះភាគហើយ កើតគំនិតឡើងថា សមណៈនេះ មានពណ៌សម្បុរដូចធីតារបស់អញ អញនឹងលើកធីតាឲ្យសមណៈនេះ ព្រោះដូច្នោះ កាលព្រាហ្មណ៍ឃើញក៏ត្រេកអរ ប្រញាប់ទៅកាន់ផ្ទះ ប្រាប់ព្រាហ្មណីថា នែនាង ខ្ញុំឃើញបុរសពណ៌សម្បុរដូចកូនស្រីយើងហើយ ចូរនាងប្រដាប់តាក់តែងកូនស្រីយើងចុះ យើងនឹងលើកឲ្យ

សមណៈនោះ ។ កាលព្រាហ្មណីយកទឹកក្រអូបងូតកូនស្រី ហើយតាក់តែង ដោយសំពត់ផ្កា និងគ្រឿងប្រដាប់ជាដើមនោះឯង រហូតដល់ពេលកិច្ចាចារ របស់ព្រះមានព្រះភាគ ។ លំដាប់នោះ ព្រះមានព្រះភាគយាងចូលទៅបិណ្ឌ-បាត កាន់កម្មាសធម្មនិគម ។ ព្រាហ្មណ៍ និងព្រាហ្មណីក៏នាំធីតាទៅដល់ ឱកាសដែលព្រះមានព្រះភាគគង់ ។ ក្នុងទីនោះ ព្រាហ្មណីមិនឃើញព្រះមាន ព្រះភាគ ក្រឡេកមើលឆ្វេងស្តាំ បានឃើញតែកម្រាលស្មៅ ដែលក្រាល ត្រង់ទីគង់នៅរបស់ព្រះមានព្រះភាគ ។ ដោយកម្លាំងអធិដ្ឋាននៃព្រះពុទ្ធទាំង-ឡាយ ឱកាសដែលគង់នៅ និងស្នាមព្រះបាទក៏តាំងនៅ ។ ព្រាហ្មណី ក៏ពោលនឹងព្រាហ្មណ៍ថា នែព្រាហ្មណ៍ នេះជាកម្រាលស្មៅរបស់សមណៈ នោះឬ ព្រាហ្មណ៍ឆ្លើយថា អើ នាង ។ ព្រាហ្មណីពោលថា ព្រាហ្មណ៍ បើដូច្នោះ ការមករបស់យើង មិនសម្រេចបំណងឡើយ ព្រាហ្មណ៍សួរថា នែ នាង តើព្រោះហេតុអ្វី ព្រាហ្មណីឆ្លើយថា នែព្រាហ្មណ៍ មើលចុះ កម្រាល ស្មៅរៀបរយ មិនមែនរបស់អ្នកបរិភោគកាមប្រើប្រាស់ឡើយ ។ ព្រាហ្មណ៍ ពោលថា នែនាង កាលខ្ញុំស្វែងរកវត្ថុដែលជាមង្គល នាងកុំពោលពាក្យដែល ជាអពមង្គលឡើយ ។ ព្រាហ្មណីដើរទៅខាងនោះខាងនេះ ឃើញស្នាមព្រះ បាទរបស់ព្រះមានព្រះភាគ ទើបពោលនឹងព្រាហ្មណ៍ថា នែព្រាហ្មណ៍ សូម មើលស្នាមជើងបុរសនេះ មិនមែនជាអ្នកជប់ជ្រប់ក្នុងកាមទេ ។ ព្រាហ្មណ៍សួរ ថា នាងដឹងបានដូចម្តេច កាលព្រាហ្មណីសម្តែងចំណេះដឹងរបស់ខ្លួន ទើប ពោលថា

ជាការពិត ស្នាមជើងរបស់បុគ្គលដែលប្រកបដោយរាគៈ កំពុង ត្រង់កណ្តាល ស្នាមជើងរបស់បុគ្គល ដែលប្រកបដោយ ទោសៈ ធ្ងន់ទៅខាងចុងម្រាម ស្នាមជើងរបស់បុគ្គលប្រកប ដោយមោហៈ ធ្ងន់ទៅខាងកែងជើង ជើងនេះ ជាជើងរបស់ បុគ្គលមានកិលេសដូចដំបូលបើកហើយ ។

ព្រាហ្មណ៍និងព្រាហ្មណីនោះ នៅពោលប្រកែកគ្នានៅឡើយ ខណៈនោះ ព្រះមានព្រះភាគ ទ្រង់សោយព្រះក្រយាហារស្រេចហើយ បានយាងមកកាន់ ដងព្រៃនោះ ។ ព្រាហ្មណីឃើញរូបនៃព្រះមានព្រះភាគល្អដោយព្រះលក្ខណៈ ចោមរោមដោយព្រះរស្មីមួយព្យាម ទើបពោលនឹងព្រាហ្មណ៍ថា នែព្រាហ្មណ៍ ឃើញសមណៈនោះហើយឬ ព្រាហ្មណ៍ឆ្លើយថា ឃើញហើយ ព្រាហ្មណី ពោលថា សមណៈនោះ មិនបរិភោគកាមពិត យើងមកខូចពេលវេលាហើយ អ្នកមានលក្ខណៈយ៉ាងនេះ បរិភោគកាម សេចក្តីនោះមិនមែនឋានៈឡើយ ។ កាលព្រាហ្មណ៍ និងព្រាហ្មណីសន្ទនាគ្នាយ៉ាងនេះឯង ព្រះមានព្រះភាគគង់ លើកម្រាលស្មៅ ។

លំដាប់នោះ ព្រាហ្មណ៍ដឹកដៃធីតាមកដោយដៃឆ្វេង កាន់ឃ្នោកទឹក ដោយដៃស្តាំ ចូលគាល់ព្រះមានព្រះភាគ ពោលថា បព្វជិតដ៏ចម្រើន លោក មានពណ៌សម្បុរដូចមាស ទារិកានេះក៏មានពណ៌សម្បុរដូចមាស ទើបទារិកា នេះសមគួរដល់លោក លោកដ៏ចម្រើន ខ្ញុំសូមលើកទារិកានេះឲ្យជាកិរិយា ដើម្បីមើលថែរក្សាគ្នា ហើយដើរតម្រង់ទៅរកព្រះមានព្រះភាគ បំណងនឹង

លើកធីតាឲ្យ ហើយឈរ ។ ព្រះមានព្រះភាគ ធ្វើដូចជាមិនបានសន្ទនាជាមួយនឹងព្រាហ្មណ៍ តែសន្ទនានឹងអ្នកដទៃ បានត្រាស់គាថានេះថា **ទិស្វាន តណ្ហំ** ដូច្នេះជាដើម ។

បទនេះ មានសេចក្តីដូចតទៅនេះ សូម្បីត្រឹមតែការពេញចិត្តក្នុងមេថុនក៏មិនមានដល់តថាគត ព្រោះឃើញនាងតណ្ហា នាងអរតី និងនាងរាគាដែលជាធីតាស្តេចមារ ដែលនិម្មិតរូបផ្សេងៗ គួរប្រាថ្នាក្រៃលែង នាំគ្នាមកត្រង់មណ្ឌលអជបាលនិគ្រោធ ការពេញចិត្តអ្វីនឹងមាន ព្រោះឃើញរូបដែលពេញដោយមូត្រ និងករីសរបស់ស្រីនេះ តថាគតមិនប្រាថ្នាពាល់ត្រូវសរីរៈនៃធីតារបស់អ្នក ដោយប្រការទាំងពួង សូម្បីដោយជើង កុំថាឡើយនៅរួមគ្នា ។

លំដាប់នោះ មាគន្ទិយព្រាហ្មណ៍ ដើម្បីនឹងទូលសួរថា ធម្មតាបព្វជិតលះកាមដែលជារបស់មនុស្ស ហើយបួស ដើម្បីកាមជារបស់ទិព្វ តែសមណៈនេះ មិនប្រាថ្នាកាមសូម្បីជាទិព្វ សូម្បីឥត្ថីរតនៈនេះ ក៏មិនប្រាថ្នា អ្វីហ្ន៎ជាទិដ្ឋិរបស់សមណៈនេះ ទើបពោលគាថាទី ២ ។

ក្នុងបទទាំងនោះ បទថា **ឯតាទិសំ ចេ រតនំ** សេចក្តីថា មាគន្ទិយព្រាហ្មណ៍ ពោលសំដៅដល់ស្រីកែវដែលជាទិព្វ ។ បទថា **នារឹ** សេចក្តីថា មាគន្ទិយព្រាហ្មណ៍ ពោលសំដៅដល់ធីតារបស់ខ្លួន ។ ការឃើញនោះឯង គឺទិដ្ឋិនោះឯង ឈ្មោះថា ទិដ្ឋិគតៈ ។ បទថា **សីលវតំ នុ ជីវិតំ** បានដល់ ទិដ្ឋិ សីល វត្ត និងជីវិត ។ បទថា **ភវូបបត្តិញ្ច វទេសិ កីទិសំ** គឺទ្រង់ត្រាស់ការចូលដល់ភពរបស់ទ្រង់ដូចម្តេច ។ គាថា ២ ក្រៅអំពីនេះ មានសម្ពន្ធគ្នា

ច្បាស់ហើយ ព្រោះប្រព្រឹត្តទៅ ដោយន័យក្នុងការឆ្លើយ និងការសួរ ។

ក្នុងគាថាទាំងនោះ គប្បីជ្រាបសេចក្តីសង្ខេបក្នុងគាថាដំបូងតទៅ ព្រះមានព្រះភាគត្រាស់ថា ម្នាលមាគន្ទិយៈ ការដែលតថាគតដាក់ចិត្តក្នុងធម៌ គឺទិដ្ឋិ ៦២ ហើយប្រកាន់មាំថា តថាគតពោលវត្ថុនេះថា សេចក្តីនេះប៉ុណ្ណោះពិត សេចក្តីដទៃជាមោឃ ដូច្នេះ រមែងមិនមាន រមែងមិនកើត មិនមានដល់តថាគត ។ ព្រោះហេតុអ្វី ព្រោះតថាគតឃើញទោសក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់ទិដ្ឋិណាមួយ កាលពិចារណាសច្ចៈទាំងឡាយ ក៏បានឃើញនិព្វានដែលជាការស្ងប់ខាងក្នុង ព្រោះរាគៈជាដើមខាងក្នុងស្ងប់ ។

ក្នុងគាថាទី ២ លោកពោលសេចក្តីសង្ខេបថា ទិដ្ឋិពួកណាដែលឈ្មោះថា ការដាក់ចិត្ត ព្រោះសត្វទាំងឡាយនោះដាក់ចិត្ត ហើយប្រកាន់ និងកំណត់ហើយ ដោយន័យ មានភាពដែលបច្ច័យរបស់ខ្លួនតាក់តែងហើយជាដើម ។ មាគន្ទិយព្រាហ្មណ៍ទូលថា បពិត្រព្រះមុនី ទ្រង់មិនបានកាន់យកនូវទិដ្ឋិទាំងនោះឡើយ ត្រាស់សេចក្តីណាថា ការស្ងប់ខាងក្នុង សេចក្តីនោះ អ្នកប្រាជ្ញទាំងឡាយប្រកាសដូចម្តេចហ្ន៎ សូមទ្រង់ត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គចុះ ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងដោយឧបាយដែលអ្នកប្រាជ្ញទាំងឡាយប្រកាសបទនោះ ដែលផ្ទុយគ្នាដល់មាគន្ទិយព្រាហ្មណ៍នោះ ទើបត្រាស់គាថាថា **ន ទិដ្ឋិយា** ជាដើម ។

ក្នុងគាថានោះ ព្រះមានព្រះភាគទ្រង់បដិសេធសីល និងវត្ត ក្រៅអំពីសមាបត្តិ ៨ និងញាណ ដោយបទជាដើមថា **ន ទិដ្ឋិយា** ដូច្នេះ ។ គប្បី

ប្រកប **អាហ** សព្ទ ដែលបានពោលក្នុងបទនេះថា **សុទ្ធិមាហ** ចូលជាមួយ **ន** អក្ខរៈគ្រប់បទ ហើយគប្បីជ្រាបសេចក្តីយ៉ាងនេះថា តថាគតមិនពោលការបរិសុទ្ធព្រោះទិដ្ឋិ ។ សូម្បីក្នុងបទក្រៅអំពីនេះ ក៏ដូចគ្នានឹងបទនេះ ។ ក្នុងបទទាំងនោះ បទថា **អទិដ្ឋិយាឆាហ** គប្បីជ្រាប សេចក្តីយ៉ាងនេះថា តថាគតមិនពោលសេចក្តីបរិសុទ្ធក្រៅអំពីសម្មាទិដ្ឋិ មានវត្ថុ ១០ យ៉ាងទៀត ក្រៅអំពីការមិនមានសុត្តៈ គឺវៀរចាកសុត្តៈ មានអង្គ ៩ ការមិនមានញាណ គឺវៀរកម្មស្សកតាញាណ និងសច្ចានុលោមិកញ្ញាណ វៀរចាកសីល គឺវៀរចាកការសង្រួមក្នុងបាតិមោក្ខ វៀរចាកវត្ត គឺវៀរចាកធុតង្គវត្ត ។ បទថា **នោបិ តេន** គឺតថាគតមិនពោលត្រឹមតែទិដ្ឋិជាដើមណាមួយ ក្នុងសេចក្តីបរិសុទ្ធទាំងនោះ ។ បទថា **ឯតេ ច និសជ្ជ អនុគ្គហាយ** សេចក្តីថា លះធម៌ដែលជាចំណែកខ្មៅ មានការឃើញជាដើម ដែលមានក្នុងកាលមុន ដោយការដកចោលហើយ មិនប្រកាន់មាំក្នុងធម៌ដែលជាចំណែកស មានការឃើញជាដើម ដែលមានខាងក្រោយ ដោយការដុសលាងនូវធម៌ដែលអាស្រ័យចោល ។ បទថា **សន្តោ អនិស្សាយ ភវំ ន ជប្បេ** សេចក្តីថា ឈ្មោះថា ជាបុគ្គលស្ងប់ ព្រោះស្ងប់កិលេស ដោយកិច្ចបដិបត្តិនេះ មិនអាស្រ័យធម៌ណាមួយ ក្នុងចក្ខុទ្វារជាដើម មិនគប្បីប្រាថ្នាភព ទោះភពមួយគប្បីជាអ្នកអាចដើម្បីការមិនចង់បាន ដើម្បីការមិនប្រាថ្នា អធិប្បាយថា នេះជាការស្ងប់ខាងក្នុងរបស់បុគ្គលនោះ ។

កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ មាគន្ទិយព្រាហ្មណ៍ មិន

*យល់អត្ថ ទើបពោលគាថាថា* **នោ ចេ កិរ** *ដូច្នេះជាដើម ។*

*ក្នុងគាថានោះ ការឃើញជាដើមមានន័យដូចបានពោលហើយ មាគន្ទិយ-ព្រាហ្មណ៍ពោលទាំង ២ យ៉ាង សំដៅដល់ធម៌ដែលជាចំណែកខ្មៅនោះឯង ។ លោកប្រកប* **អាហ** *សព្ទចូលជាមួយ* **នោ ចេ កិរ** *សព្ទ ជា* **នោ ចេ កិរ អាហ** *ហើយគប្បីជ្រាបសេចក្ដីយ៉ាងនេះ* **នោ ចេ កិរ ករេសិ** *( បានឮថា ) បើទ្រង់មិនត្រាស់ដូច្នេះ ។ បទថា* **មោមុហំ** *គឺក័ន្តកាំង ឬវង្វេង ។ បទថា* **បច្ចេន្តិ** *គឺដឹង ។*

*ព្រះមានព្រះភាគ កាលទ្រង់បដិសេធពាក្យសួរអាស្រ័យការឃើញនោះរបស់មាគន្ទិយព្រាហ្មណ៍ ទើបត្រាស់គាថាថា* **ទិដ្ឋិញ្ច និស្សាយ** *ដូច្នេះជាដើម ។*

*បទនោះ មានអធិប្បាយដូចតទៅនេះ ព្រះមានព្រះភាគត្រាស់ថា ម្នាលមាគន្ទិយព្រាហ្មណ៍ អ្នកអាស្រ័យការឃើញតាមរឿយៗ ដល់នូវការវង្វេងក្នុងទិដ្ឋិដែលអ្នកប្រកាន់ហើយ ហើយអ្នកក៏មិនបានឃើញសញ្ញា សូម្បីតែបន្តិចចាកការស្ងប់ខាងក្នុងដែលតថាគតពោលហើយ ឬចាកកិច្ចបដិបត្តិ ឬចាកការសម្ដែងធម៌ ដោយហេតុនោះប៉ុណ្ណោះ ទើបអ្នកឃើញធម៌នេះដោយភាពជារបស់វង្វេង ។*

*ព្រះមានព្រះភាគ កាលទ្រង់សម្ដែងការប្រកាន់លទ្ធិរបស់មាគន្ទិយ-ព្រាហ្មណ៍ ដែលវង្វេងក្នុងទិដ្ឋិ ដែលខ្លួនប្រកាន់យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងថា លទ្ធិរបស់ព្រះអង្គប្រាសចាកការវង្វេងក្នុងធម៌ទាំងនោះ និងក្នុងធម៌ដទៃ ទើបត្រាស់ថា* **សមោ វិសេសី** *ដូច្នេះជាដើម ។*

បទនោះ មានអធិប្បាយដូចតទៅនេះ បុគ្គលណារមែងសម្គាល់ដោយមានះ ៣ យ៉ាង ឬដោយទិដ្ឋិយ៉ាងនេះ បុគ្គលនោះ គប្បីវិវាទដោយមានះនោះ ដោយទិដ្ឋិនោះ ឬដោយបុគ្គលនោះ តែបុគ្គលណាមិនញាប់ញ័រក្នុង ៣ យ៉ាងនេះ ថាអញស្មើគេ វិសេសជាងគេដូច្នេះជាដើម ដូចគ្នានឹងអញ បុគ្គលនោះរមែងមិនមានវិវាទ ។ គប្បីបន្ថែមបទថា **ឆ ច ហីនោ** ចូលមក ។ សួរថា មានអ្វីទៀត ឆ្លើយថា មានគាថាថា **សច្ចន្តិ សោ** ដូច្នេះជាដើម ។

បទនោះ មានអធិប្បាយថា បុគ្គលបែបនេះជាអ្នកលះមានះ ទិដ្ឋិ បានហើយ ឈ្មោះថា ជាព្រាហ្មណ៍ ដោយន័យថា ព្រោះជាអ្នកបន្សាត់បាបបានហើយជាដើម គប្បីពោលអ្វី ពោលដើម្បីអ្វី ឬពោលដោយហេតុអ្វីថា វត្ថុនេះប៉ុណ្ណោះពិត ឬគប្បីវិវាទព្រោះមានះ ឬទិដ្ឋិណាមួយថា របស់អញពិត របស់ឯងមិនពិត ។ ម្យ៉ាងទៀត ការសម្គាល់ថា ស្មើនឹងអ្នកដទៃដោយប្រព្រឹត្តទៅថា យើងដូចគ្នានឹងគេ ឬមិនស្មើនឹងគេ ដោយប្រព្រឹត្តទៅដោយភាវៈទាំង ២ យ៉ាងនេះ រមែងមិនមានក្នុងបុគ្គលណាដែលជាខីណាស្រព ដូចអាត្មាអញ បុគ្គលនោះ គប្បីលើកវាទៈជាមួយបុគ្គលណាក្នុងការស្មើគ្នាជាដើម ។ បុគ្គលបែបនេះ មានគាថាដែលត្រូវពោលដល់ថា **ឱកំ បហាយ** ដោយចំណែកមួយមិនមែនឬ ។

ក្នុងបទទាំងនោះ បទថា **ឱកំ បហាយ** គឺលះនូវឱកាសនៃវិញ្ញាណអាស្រ័យរូប និងវត្ថុជាដើម ដោយការលះនូវតម្រេក ព្រោះការពេញចិត្តក្នុងវត្ថុនោះ ។ បទថា **អនិកេតសារី** គឺមិនរឭកដល់រូបនិមិត្តដែលជាគ្រឿង

កំណត់សម្គាល់ទាំងនោះ ដោយអំណាចតណ្ហា ។ បទថា **គាមេ អកុព្វំ មុនិ សន្ថវានិ** គឺមិនធ្វើការស្និទ្ធស្នាលជាមួយគ្រហស្ថក្នុងស្រុក ។ បទថា **កាមេហិ រិត្តោ** គឺជារបស់ទទេចាកកាមទាំងពួង ព្រោះមិនមានតម្រេក ព្រោះការពេញចិត្តក្នុងកាមទាំងឡាយ ។ បទថា **អបុរេក្ខរានោ** គឺមិនធ្វើអត្តភាពឲ្យកើតបន្តទៅទៀត ។ បទថា **កថំ ន វិគយ្ហ ជនេន កយិរា** គឺមិនគប្បីពោលជំទាស់ជាមួយជន ។ បុគ្គលបែបនោះ មានគាថាដែលគប្បីពោលដល់ថា **យេហិ វិវិត្តោ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **យេហិ** គឺចាកទិដ្ឋិជាដើម ។ បទថា **វិវិត្តោ វិចរេយ្យ** គឺជាអ្នកស្ងាត់ ហើយគប្បីត្រាច់ទៅ ។ បទថា **ន តានិ ឧគ្គយ្ហ វទេយ្យ នាគោ** គឺជាបុគ្គលប្រសើរ មិនគប្បីកាន់យកនូវទិដ្ឋិទាំងនោះ លើកឡើងពោលដោយន័យជាដើមថា ជាអ្នកមិនធ្វើបាប ។ បទថា **ឯលម្ពុជំ** លោកអធិប្បាយថា ផ្កាឈូកមានទងជាបន្លា កើតក្នុងទឹក និងភក់ ។ បទថា **យថា ជលេន បង្កេន ច នូបលិត្តំ** គឺដូចផ្កាឈូកនោះ មិនជាប់ដោយទឹក និងភក់ ។ បទថា **ឯវំ មុនិ សន្តិវាទោ អគិទ្ធោ** គឺមុនីមានពាក្យខាងក្នុងស្ងប់ មិនត្រេកអរ ព្រោះមិនមានការចង់បាន ។ បទថា **កាមេ ច លោកេ ច អនូបលិត្តោ** គឺមិនជាប់នៅក្នុងកាម ២ យ៉ាង និងក្នុងលោក មានអបាយជាដើម ដោយកាម ២ យ៉ាង ។ សួរថា មានអ្វីតទៅទៀត ឆ្លើយថា មានគាថាថា **ន វេទគូ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **ន វេទគូ ទិដ្ឋិយា** សេចក្តីថា បុគ្គលដល់នូវ

វេទ គឺមគ្គ ៤ ដូចតថាគត មិនជាអ្នកទៅដោយទិដ្ឋិ គឺមិនប្រព្រឹត្តទៅដោយទិដ្ឋិ ឬជាអ្នកមិនជឿទិដ្ឋិនោះៗ ដោយភាពជាសារៈ ។ ក្នុងបទនោះ មានវិគ្គហៈថា ឈ្មោះថា **ទិដ្ឋិយាយកោ** ព្រោះជាអ្នកទៅដោយទិដ្ឋិ ប្រើរូបវិគ្គហៈដោយតតិយាវិភត្តិ ឬព្រោះជាអ្នកទៅកាន់ទិដ្ឋិក្នុងរូបវិគ្គហៈ ដោយឆដ្ឋីវិភត្តិក្នុងអត្ថរបស់ទុតិយាវិភត្តិ ។ បទថា **ន មុតិយា សមានមេតិ** គឺបុគ្គលនោះមិនមកកាន់មានះដោយបញ្ញា មានដឹងក្នុងរូបជាដើម ។ បទថា **ន ហិ តម្មយោ សោ** គឺបុគ្គលនោះ មិនមានសភាពដូចបុគ្គលដែលសម្រេចដោយតណ្ហា និងទិដ្ឋិនោះ ។ បទថា **ន កម្មុនា នោបិ សុតេន នេយ្យោ** គឺបុគ្គលនោះដែលកម្មមានបុញ្ញាភិសង្ខារជាដើម ឬសុតៈ មានសុតៈដែលបរិសុទ្ធជាដើមនាំទៅមិនបាន ។ បទថា **អនូបនីតោ ស និវេសនេសុ** គឺបុគ្គលនោះ មិនប្រកាន់ក្នុងតណ្ហា និងទិដ្ឋិទាំងពួង ព្រោះលះការប្រកាន់ក្នុងធម៌ ២ យ៉ាងបានហើយ ។ គប្បីជ្រាបគាថាថា **សញ្ញាវិរត្តស្ស** ដូចតទៅនេះ

ក្នុងបទទាំងនោះ បទថា **សញ្ញាវិរត្តស្ស** គឺជាអ្នកលះសញ្ញា មានកាមសញ្ញាជាដើមបានហើយ ដោយភាវនា មាននេក្ខម្មសញ្ញាជាប្រធាន ។ ដោយបទនេះ លោកបំណងយកឧភតោភាគវិមុត្តបុគ្គល ឬសមថយានិកបុគ្គល ។ បទថា **បញ្ញាវិមុត្តស្ស** គឺដល់បុគ្គលរួចផុតហើយចាកកិលេសទាំងពួងដោយភាវនា ដែលមានវិបស្សនាជាប្រធាន ។ បទនេះ លោកបំណងយកសុក្ខវិបស្សកបុគ្គល ។ បទថា **សញ្ញញ្ច ទិដ្ឋិញ្ច យេ អគ្គហេសុំ តេ ឃដ្តមានា វិចរន្តិ លោកេ** សេចក្តីថា ជនពួកណាប្រកាន់សញ្ញា មានកាមសញ្ញាជាដើម

ជនទាំងនោះដោយចំពោះដែលជាគ្រហស្ថ រមែងប៉ះខ្ទប់គ្នានិងគ្នា ត្រាច់ទៅក្នុងលោក សេចក្តីថា ជនពួកណាកាន់យកសញ្ញា មានកាមសញ្ញាជាដើមដោយចំពោះ ជនទាំងនោះ ជាគ្រហស្ថទន្ទិចគ្នានិងគ្នា មានកាមជាហេតុត្រាច់ទៅ ។ ម្យ៉ាងទៀត ជនពួកណាកាន់យកទិដ្ឋិ ជនពួកនោះ ដោយចំពោះជាបព្វជិត រមែងប៉ះទន្ទិចគ្នានិងគ្នា មានធម៌ជាហេតុត្រាច់ទៅ ។ បទដ៏សេសក្នុងសូត្រនេះ បទណាមិនបានពោល បទនោះ គប្បីជ្រាបដោយទំនងដូចគ្នាតាមដែលពោលហើយនោះឯង ។

កាលចប់ទេសនា ព្រាហ្មណ៍ និងព្រាហ្មណី ចេញបួសហើយ បានសម្រេចអរហត្ត ៕

**អដ្ឋកថាមាគន្ទិយសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## បុរាភេទសូត្រទី ១០

[ ១០៤ ] ( ព្រះពុទ្ធនិម្មិត ត្រាស់សួរព្រះសម្ពុទ្ធថា ) បុគ្គលអ្នកមានទស្សនៈដូចម្តេច មានសីលដូចម្តេច ដែលព្រះអង្គត្រាស់ហៅថា អ្នកស្ងប់រម្ងាប់ បពិត្រព្រះគោតម ព្រះអង្គដែលខ្ញុំសួរហើយ សូមប្រាប់នូវឧត្តមជននោះ ។

( ព្រះមានព្រះភាគត្រាស់ថា ) មុននឹងបែកធ្លាយរាងកាយទៅ បុគ្គលណាប្រាសចាកតណ្ហា មិនអាស្រ័យនូវកាលខាងដើម និងទីបំផុត គឺកាលជាអតីត និងអនាគត ជាបុគ្គលដែលអ្នកប្រាជ្ញមិនគប្បីពោលថា ជាអ្នកត្រេកអរក្នុងបច្ចុប្បន្ន ការធ្វើនូវតណ្ហា និងទិដ្ឋិ ឲ្យជាប្រធាននៃបុគ្គលនោះ មិនមានឡើយ ។ បុគ្គលនោះឯងមិនក្រោធ មិនតក់ស្លុត មិនពោលអួត មិនរពឹសជាអ្នកពោលដោយបញ្ញា មិនរាយមាយ សង្រួមដោយវាចា ជាអ្នកប្រាជ្ញ ។ បុគ្គលមិនមានតណ្ហាក្នុងអារម្មណ៍ជាអនាគត មិនសោកស្តាយនូវអារម្មណ៍អតីត ជាអ្នកឃើញសេចក្តីស្ងប់ស្ងាត់ក្នុងផស្សៈទាំងឡាយ មិនបង្អោនចិត្តទៅក្នុងមិច្ឆាទិដ្ឋិទាំងឡាយ ជាអ្នកពួនសម្ងំ មិនបំភ័ន្តគេ មិនមានសេចក្តីប្រាថ្នាជាប្រក្រតី មិនមានសេចក្តីកំណាញ់ មិនឃ្នើសឃ្នង ជាបុគ្គលដែលគេមិនស្អប់ខ្ពើម ជាអ្នកមិនប្រកបក្នុងការញុះញង់ មិននឹកនាទៅរកវត្ថុជាទីត្រេកអរ មិនប្រកបក្នុងការមើលងាយគេ ជាអ្នកមានការឆ្ងារ

ល្អិតល្អ មានបដិភាណ មិនជឿអ្នកដទៃ មិនត្រេកអរ មិនសិក្សាព្រោះប្រាថ្នាលាភ មិនក្រេវក្រោធព្រោះមិនមានលាភ ជាអ្នកមិនទីង មិនជាប់ចិត្តក្នុងរសព្រោះតណ្ហា ជាបុគ្គលមានឧបេក្ខា មានស្មារតីសព្វពេល មិនសម្គាល់ថា ស្មើនឹងគេក្នុងលោក មិនលើកខ្លួនថាវិសេសជាងគេ មិនដាក់ខ្លួនថា ថោកទាបជាងគេ កិលេសគ្រឿងពុះពោរ មិនមានដល់បុគ្គលនោះឡើយ បុគ្គលណា មិនមាននិស្សយធម៌ គឺតណ្ហា និងទិដ្ឋិក្តី បុគ្គលណា ដឹងនូវធម៌ហើយ មិនអាស្រ័យនូវតណ្ហា និងទិដ្ឋិក្តី បុគ្គលមិនមានតណ្ហា ក្នុងសេចក្តីចម្រើន និងសេចក្តីវិនាស តថាគតហៅបុគ្គលអ្នកមិនអាឡោះអាល័យ ក្នុងកាមទាំងឡាយនោះ ថាជាអ្នកស្ងប់រម្ងាប់ កិលេសគ្រឿងចាក់ស្រេះរបស់បុគ្គលនោះមិនមាន បុគ្គលនោះ បានឆ្លងនូវតណ្ហា ដែលផ្សាយទៅហើយ ។ កូនទាំងឡាយ សត្វចិញ្ចឹមទាំងឡាយ និងស្រែចម្ការ ទីលំនៅរបស់បុគ្គលនោះមិនមានឡើយ សេចក្តីប្រកាន់ថាជារបស់ខ្លួន គឺសស្សតទិដ្ឋិក្តី សេចក្តីប្រកាន់ថាមិនមែនជារបស់ខ្លួន គឺឧច្ឆេទទិដ្ឋិក្តី មិនមានក្នុងបុគ្គលនោះទេ ។ ពួកទេវតានិងមនុស្សជាបុថុជ្ជន ឬពួកសមណព្រាហ្មណ៍ គប្បីពោលទោសចំពោះបុគ្គលនោះដោយកិលេស មានរាគៈជាដើមណា កិលេសមានរាគៈជាដើមនោះ បុគ្គលនោះ មិនធ្វើឲ្យជាប្រធានឡើយ

ព្រោះហេតុនោះ បុគ្គលមិនញាប់ញ័រ ព្រោះពាក្យពោលទាំង-ឡាយឡើយ ។ អ្នកប្រាជ្ញប្រាសចាកសេចក្តីជាប់ជំពាក់ ( ក្នុងរូបជាដើម ) មិនមានសេចក្តីកំណាញ់ មិននិយាយលើកខ្លួនក្នុងគុណដ៏ខ្ពង់ខ្ពស់ មិននិយាយប្រកបខ្លួនក្នុងគុណដ៏ស្មើៗ មិននិយាយបន្ទាបខ្លួនក្នុងគុណដ៏ថោកទាប មិនដល់នូវកប្បៈ គឺមិនមានតណ្ហា និងទិដ្ឋិ ព្រោះជាបុគ្គលមិនមានកប្បៈ ។ បុគ្គលណា មិនមានសេចក្តីប្រកាន់ថា របស់ខ្លួនក្នុងលោក បុគ្គលនោះ មិនសោកព្រោះរបស់ដែលមិនមាន មិនលុះក្នុងអគតិធម៌ទាំងឡាយ បុគ្គលនោះឯង ហៅថា អ្នកស្ងប់រម្ងាប់ ។

**បុរាភេទសូត្រទី ១០ ចប់**

# អដ្ឋកថា

## បុរាភេទសូត្រ

[ ១០៤ ] ក្នុងបុរាភេទសូត្រទី ១០ មានពាក្យផ្ដើមថា **កថំ ទស្សី** ដូច្នេះជាដើម ។

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅ

លោកពោលដល់ការកើតនៃព្រះសូត្រនេះ និងសូត្រ ៥ ទៀត គឺ កលហវិវាទសូត្រ ចូឡវិយូហសូត្រ មហាវិយូហសូត្រ តុវដកសូត្រ និងអត្តទណ្ឌសូត្រ ដូចន័យដែលពោលហើយ ក្នុងការកើតនៃសម្មាបរិព្វាជនិយ-សូត្រនោះឯង ។ តែមានការផ្សេងគ្នាដូច្នេះ ក្នុងមហាសម័យនោះ ដើម្បីទ្រង់សម្ដែងធម៌ឲ្យជាទីសប្បាយដល់ពួកទេវតាដែលជារាគចរិត ទើបទ្រង់ឲ្យពុទ្ធ-និម្មិតសួរព្រះអង្គ ហើយបានត្រាស់សម្មាបរិព្វាជនិយសូត្រ យ៉ាងណា ក្នុងមហាសម័យនោះ ក៏ដូច្នោះដូចគ្នា ព្រះមានព្រះភាគ ទ្រង់ដឹងចិត្តរបស់ពួកទេវតាដែលមានចិត្តកើតឡើងថា មុនស្លាប់ អញគួរធ្វើអ្វីហ្ន៎ កាលទ្រង់អនុគ្រោះទេវតាទាំងនោះ ទើបទ្រង់នាំពុទ្ធនិម្មិត មួយអន្លើដោយភិក្ខុជាបរិវារ ១២៥០ រូប មកតាមអាកាស ឲ្យព្រះពុទ្ធនិម្មិតនោះ សួរបញ្ហាព្រះអង្គហើយ ទើបត្រាស់សូត្រនេះ ។

គប្បីជ្រាបសេចក្ដីក្នុងពាក្យសួរនោះ ដូច្នេះថា ព្រះពុទ្ធនិម្មិតត្រាស់សួរដល់អធិប្បញ្ញា ដោយពាក្យថា បុគ្គលមានទស្សនៈដូចម្ដេច សួរដល់អធិសីល ដោយពាក្យថា បុគ្គលមានសីលដូចម្ដេច សួរដល់អធិចិត្ត ដោយពាក្យថា

បុគ្គលដូចម្តេចជាអ្នកស្ងប់ ។ បទដ៏សេស ជាក់ច្បាស់ហើយ ។

គប្បីជ្រាបក្នុងការឆ្លើយដូច្នេះថា ព្រះមានព្រះភាគ ទ្រង់មិនបានឆ្លើយអធិប្បញ្ញាជាដើមដោយត្រង់ ព្រោះការស្ងប់រម្ងាប់កិលេសឯណា ដែលត្រាស់ហៅថា អ្នកស្ងប់ កាលទ្រង់សម្តែងដល់ការស្ងប់នៃកិលេសនោះៗ ដោយអនុលោមតាមអធ្យាស្រ័យរបស់ពួកទេវតាផ្សេងៗ ទើបត្រាស់គាថាថា **វីត-តណ្ហោ** ដូច្នេះជាដើម ។

ក្នុងគាថានោះ គប្បីជ្រាបការភ្ជាប់សេចក្តីនៃគាថា ៨ តាំងអំពីដើមដោយគាថានេះថា **តំ ព្រូមិ ឧបសន្តោ** ដូច្នេះ ។ គប្បីជ្រាបការភ្ជាប់សេចក្តីនៃគាថាដទៃក្រៅអំពីនោះ ដោយបទក្រោយនៃគាថាទាំងអស់នេះថា **ស វេ សន្តោតិ វុច្ចតិ** ដូច្នេះ ។

គប្បីជ្រាបសេចក្តីដោយន័យនៃកិច្ចពណ៌នាទៅតាមលំដាប់ បទថា **វីត-តណ្ហោ បុរា ភេទា** គឺលះតណ្ហាបានមុនស្លាប់ ។ បទថា **បុព្វមន្ត-មនិស្សិតោ** សេចក្តីថា ជាបុគ្គលមិនអាស្រ័យខាងដើម ដែលផ្សេងគ្នាដោយកាល មានអតីតកាលជាដើម ។ បទថា **វេមជ្ឈេ នុបសង្ខេយ្យោ** សេចក្តីថា ដែលបុគ្គលណាម្នាក់គប្បីរាប់មិនបានថា ជាអ្នកត្រេកអរហើយ ក្នុងកាលបច្ចុប្បន្ន ។ បទថា **តស្ស នត្ថិ បុរេក្ខតំ** សេចក្តីថា ព្រះអរហន្តនោះ មិនមានការប្រាថ្នាក្នុងអនាគតកាល គឺក្នុងកាលដ៏វែងឆ្ងាយ ព្រោះមិនមានការប្រាថ្នាទាំង ២ យ៉ាង ។ គប្បីជ្រាបការប្រកបសេចក្តីក្នុងគាថានោះ យ៉ាងនេះថា **តំ ព្រូមិ ឧបសន្តោ** ដូច្នេះ ។ ក្នុងបទទាំងពួង ក៏មានន័យដូច្នេះ ។

បន្ទាប់អំពីនេះទៅ ខ្ញុំមិនសម្ដែងពាក្យប្រកបនូវសេចក្ដី និងពណ៌នាចំពោះបទដែលលំបាកប៉ុណ្ណោះ ។

បទថា **អសន្តាសី** សេចក្ដីថា មិនញាប់ញ័រ ព្រោះការមិនមានលាភនោះ ។ បទថា **អវិកត្ថី** សេចក្ដីថា មានប្រក្រតីមិនអួតដោយសីលជាដើម ។ បទថា **អកុក្កុច្ចោ** សេចក្ដីថា វៀរចាកការរពឹសដៃជាដើម ។ បទថា **មន្តាភាណី** សេចក្ដីថា ស្ងប់ហើយស្ងប់ទៀតដោយបញ្ញា ទើបបន្ទឹវាចា ។ បទថា **អនុទ្ធតោ** គឺវៀរចាកការរាយមាយ ។ បទថា **ស វេ វាចាយតោ** សេចក្ដីថា បុគ្គលនោះសង្រួមដោយវាចា ហើយពោលវាចាវៀរចាកទោស ៤ យ៉ាង ។

បទថា **និរាសត្តី** បានដល់ មិនមានតណ្ហា ។ បទថា **វិវេកទស្សី ផស្សេសុ** សេចក្ដីថា ឃើញនូវការស្ងាត់ចាកភាពជាតួខ្លួនជាដើម ក្នុងចក្ខុសម្ផស្សដែលជាបច្ចុប្បន្នជាដើម ។ បទថា **ទិដ្ឋីសុ ច ន និយ្យតិ** សេចក្ដីថា ត្រូវនាំទៅក្នុងទិដ្ឋិណាមួយ ក្នុងទិដ្ឋិ ៦២ មិនបាន ។ បទថា **បដិលីនោ** សេចក្ដីថា ប្រាសចាកកិលេសនោះៗ ព្រោះលះរាគៈជាដើមបានហើយ ។ បទថា **អកុហកោ** បានដល់ មិនបោកបញ្ឆោតដោយគ្រឿងបោកបញ្ឆោត ៣ យ៉ាង ។ បទថា **អបិហាលុ** គឺមានប្រក្រតីមិនចង់បាន ។ លោកអធិប្បាយថា វៀរចាកសេចក្ដីប្រាថ្នា និងការចង់បាន ។ បទថា **អមច្ឆរី** បានដល់ វៀរចាកសេចក្ដីកំណាញ់ ៥ យ៉ាង ។ បទថា **អប្បគព្ភោ** សេចក្ដីថា វៀរចាកភាពជាអ្នកក្ដាំក្ដងកាយជាដើម ។ បទថា **អជេគុច្ឆោ** បានដល់ មិនជាអ្នកគួរ

ខ្ពើម មិនជាអ្នកគួររង្កៀស គឺត្រេកអរពេញចិត្តដោយភាពជាបុគ្គលមានសីលបរិបូណ៌ជាដើម ។ បទថា **បេសុណេយ្យេ ច នោ យុតោ** បានដល់ មិនប្រកបក្នុងកម្ម គឺការញុះញង់ដែលគួររួបរួមចូលដោយអាការទាំងពីរ ។ បទថា **សាតិយេសុ អនស្សាវី** សេចក្តីថា វៀរចាកការសរសើរដោយការចង់បានក្នុងកាមគុណទាំងឡាយ ដែលជាវត្ថុគួរត្រេកអរ ។ បទថា **សណ្ហោ** បានដល់ ជាអ្នកប្រកបដោយកាយកម្មដែលល្អិតល្អន់ជាដើម ។ បទថា **បដិ-ភាណវា** បានដល់ ប្រកបដោយបដិភាណក្នុងការរៀន ការសាកសួរ និងការសម្រេច ។ បទថា **ន សទ្ធោ** បានដល់ មិនជឿចំពោះបុគ្គលណាម្នាក់ក្នុងធម៌ដែលខ្លួនសម្រេចហើយដោយខ្លួនឯង ។ បទថា **ន វិរជ្ជតិ** សេចក្តីថា ក្នុងបច្ចុប្បន្នមិនមានតម្រេក ព្រោះអស់រាគៈ និងព្រោះរាគៈទៅប្រាសហើយ ។ បទថា **លាភកម្យា ន សិក្ខតិ** សេចក្តីថា មិនសិក្សាព្រះសូត្រជាដើម ព្រោះប្រាថ្នាលាភឡើយ ។ បទថា **អវិរុទ្ធោ ច តណ្ហាយ រសេសុ នានុ-គិជ្ឈតិ** សេចក្តីថា មិនពិរោធ ព្រោះមិនមានការខឹងក្រោធ មិនដល់នូវការចង់បានក្នុងរសដែលជាឫសគល់នៃតណ្ហា ។ បទថា **ឧបេក្ខកោ** បានដល់ ជាអ្នកព្រងើយ គឺជាអ្នកប្រកបដោយឆឡង្គុបេក្ខា ។ បទថា **សតោ** បានដល់ ជាអ្នកប្រកបដោយសតិ មានកាយានុបស្សនាសតិប្បដ្ឋានជាដើម ។ បទថា **និស្សយតា** បានដល់ និស្ស័យ គឺតណ្ហា និងទិដ្ឋិ ។ បទថា **ញត្វា ធម្មំ** បានដល់ ដឹងធម៌ដោយអាការ មានការមិនទៀងជាដើម ។ បទថា **អនិស្សិតោ** សេចក្តីថា ជាបុគ្គលដែលតណ្ហានិស្ស័យ និងទិដ្ឋិនិស្ស័យទាំងនោះ មិន

អាស្រ័យហើយយ៉ាងនេះ ។ ដោយបទនេះ លោកសម្តែងថា មិនមានវត្ថុអាស្រ័យដទៃក្រៅអំពីធម្មញ្ញាណឡើយ ។ បទថា **ភវាយ វិភវាយ វា** បានដល់ ដើម្បីសស្សតទិដ្ឋិ ឬដើម្បីឧច្ឆេទទិដ្ឋិ ។ បទថា **តំ ព្រូមិ ឧបសន្តោ** គឺតថាគតពោលបុគ្គលបែបនោះ ដូចដែលពោលហើយ ក្នុងគាថាមួយថា ជាអ្នកស្ងប់ ។ បទថា **អតារិ សោ វិសត្តិកំ** សេចក្តីថា បុគ្គលនោះ ឆ្លងនូវមហាតណ្ហា ពោល គឺវិសត្តិកា ដោយភាវៈដែលផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗ ជាដើម ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សរសើរបុគ្គលស្ងប់នោះឯង ទើបត្រាស់ថា **ន តស្ស បុត្តា** ដូច្នេះជាដើម ។

បទថា **បុត្តា** នោះ បានដល់ បុត្រ ៤ ពួក មានបុត្រកើតអំពីខ្លួនជាដើម ។ ម្យ៉ាងទៀត ក្នុងបទនេះ គប្បីជ្រាបថា បុត្រដែលនាំមកចិញ្ចឹម លោកក៏ហៅថា បុត្រ ។ ព្រោះបុត្ររបស់ខ្លួនឯងមិនមាន ។ ម្យ៉ាងទៀត បុត្រជាដើមមិនមាន ព្រោះមិនមានបុត្រទាំងនោះ ។

បទថា **យេន នំ វជ្ជុំ បុថុជ្ជនា អថោ សមណព្រាហ្មណា** សេចក្តីថា បុថុជ្ជន ទេវតា មនុស្ស និងសមណព្រាហ្មណ៍ ខាងក្រៅអំពីនេះ គប្បីពោលនឹងបុគ្គលនោះថា បុគ្គលត្រេកអរហើយ ឬដែលប្រទូស្តហើយដោយទោសមានរាគៈជាដើមណា ។ បទថា **តំ តស្ស អបុរក្ខតំ** បានដល់ ទោស មានរាគៈជាដើមនេះ មិនមែនជាបំណងប្រាថ្នារបស់បុគ្គលដែលជាព្រះអរហន្តទេ ។ បទថា **តស្មា វាទេសុ នេជតិ** បានដល់ មិនញាប់ញ័រក្នុងពាក្យនិន្ទា ព្រោះ

ទោស មានរាគៈនោះជាហេតុ ។ បទថា **ន ឧស្សេសុ វទតេ** បានដល់ មិនពោលសរសើរក្នុងបុគ្គលដែលប្រសើរទាំងឡាយ ដោយធ្វើខ្លួនទុកខាងក្នុងហើយលើកខ្លួនថា អាត្មាអញជាបុគ្គលប្រសើរជាង ។ ក្នុង ២ បទបន្ទាប់ ក៏មានន័យដូច្នេះ ។ បទថា **កប្បំ នេតិ អកប្បិយោ** សេចក្ដីថា បុគ្គលបែបនេះ រមែងមិនមកកាន់កប្បៈ ( តណ្ហា និងទិដ្ឋិ ) ទាំង ២ យ៉ាង ព្រោះហេតុអ្វី ព្រោះជាអ្នកមិនមានកប្បៈ អធិប្បាយថា ជាអ្នកលះកប្បៈបានហើយ ។ បទថា **សកំ** បានដល់ ប្រកាន់ថា របស់អញ ។ បទថា **អសតា ច ន សោចតិ** សេចក្ដីថា មិនសោយសោក ព្រោះវត្ថុដែលមិនមានជាដើម និងព្រោះវត្ថុមិនមាន ។ បទថា **ធម្មេសុ ច ន គច្ឆតិ** សេចក្ដីថា មិនលម្អៀងក្នុងធម៌ទាំងពួង ដោយឆន្ទាគតិជាដើម ។ បទថា **ស វេ សន្តោតិ វុច្ចតិ** សេចក្ដីថា តថាគតពោលបុគ្គលឧត្ដមជាងបុគ្គលបែបនោះ ថាជាអ្នកស្ងប់ ។

ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនាដោយធម៌ជាកំពូល គឺអរហត្ត ។

កាលចប់ទេសនា ទេវតាមួយសែនកោដិបានសម្រេចអរហត្ត ។ ចំនួនបុគ្គលសម្រេចសោតាបន្នជាដើមហួសនឹងរាប់ ដោយប្រការដូច្នេះ ។

**អដ្ឋកថាបុរាភេទសូត្រទី ១០ ចប់**

# សុត្តន្តបិដក

## កលហវិវាទសូត្រទី ១១

[ ១០៥ ] ( ព្រះពុទ្ធនិម្មិតត្រាស់សួរព្រះសម្ពុទ្ធថា បពិត្រព្រះអង្គ ) ការឈ្លោះ ការទាស់ទែងគ្នា ការខ្សឹកខ្សួល ការសោកស្តាយ និងសេចក្តីកំណាញ់ ការប្រកាន់ ការមើលងាយ និងការញុះញង់កើតមកអំពីណា កិលេសធម៌ទាំងនោះបណ្តាលមកអំពីណា សូមព្រះអង្គសំដែងសេចក្តីនោះឲ្យទាន ។ ( ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ) ការឈ្លោះ ការទាស់ទែងគ្នា ការខ្សឹកខ្សួល ការសោកស្តាយ និងសេចក្តីកំណាញ់ ការប្រកាន់ ការមើលងាយ និងការញុះញង់កើតមកអំពីរបស់ជាទីស្រឡាញ់ ឯកិលេសធម៌ មានការឈ្លោះ និងការជជែកគ្នា ( ជាដើម ) ប្រកបក្នុងសេចក្តីកំណាញ់ កាលបើសេចក្តីទាស់ទែងគ្នាកើតឡើងហើយ ពាក្យញុះញង់ក៏កើតឡើងដែរ ។ ( ព្រះពុទ្ធនិម្មិតសួរថា ) សេចក្តីស្រឡាញ់ក្នុងលោក ឬលោភៈរបស់ពួកសត្វដែលត្រូវលោភៈគ្របសង្កត់ រង្គាត់ទៅក្នុងលោក កើតមកអំពីអ្វី សេចក្តីប៉ុនប៉ង និងការសម្រេច ( នៃសេចក្តីប៉ុនប៉ង ) និងធម៌ដែលមានក្នុងបរលោករបស់សត្វ កើតមកអំពីអ្វី ។ ( ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ) សេចក្តីស្រឡាញ់ក្នុងលោក ឬលោភៈរបស់ពួកសត្វ ដែលត្រូវលោភៈគ្របសង្កត់ កើតមកអំពីឆន្ទៈ សេចក្តីប៉ុនប៉ង និងការសម្រេច ( នៃសេចក្តីប៉ុនប៉ង ) និងធម៌

ដែលមានក្នុងបរលោករបស់ពួកសត្វ ក៏កើតអំពីឆន្ទៈនេះដែរ ។ ( ព្រះពុទ្ធនិម្មិតសួរថា ) ឆន្ទៈក្នុងលោក កើតមកអំពីអ្វី មួយទៀត វិនិច្ឆ័យ ( ការចូលចិត្តក្នុងតណ្ហា និងទិដ្ឋិ ) កើតមកអំពីអ្វី ការក្រេវក្រោធ ការនិយាយមោសា និងសេចក្តីសង្ស័យ ឬអកុសលធម៌ទាំងឡាយដែល ( ប្រកបដោយការក្រេវក្រោធជាដើម ) តើព្រះសមណៈសម្តែងហើយថា កើតអំពីអ្វី ។ ( ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ) អ្នកប្រាជ្ញទាំងឡាយ ក្នុងលោកបានសម្តែងហើយនូវអារម្មណ៍ណាថា ជាទីត្រេកអរ និងមិនជាទីត្រេកអរ ឆន្ទៈតែងកើតឡើង ព្រោះអាស្រ័យអារម្មណ៍នោះ សត្វក្នុងលោកឃើញសេចក្តីវិនាស និងសេចក្តីចម្រើនក្នុងរូបទាំងឡាយ ទើបធ្វើនូវវិនិច្ឆ័យ ( ក្នុងតណ្ហា និងទិដ្ឋិ ) ។ ការក្រេវក្រោធ ការពោលពាក្យមោសា សេចក្តីសង្ស័យ ធម៌ទាំង ៣ នេះឯង កាលបើអារម្មណ៍ជាទីត្រេកអរ និងមិនជាទីត្រេកអរ ទាំង ២ ប្រការនោះនៅមាន ទើបកើតមានឡើងបាន បុគ្គលអ្នកមានសេចក្តីសង្ស័យ គប្បីសិក្សាក្នុងគន្លងនៃការដឹងឯធម៌ទាំងឡាយ ព្រះសមណៈសម្តែងហើយ ព្រោះដឹង ។ ( ព្រះពុទ្ធនិម្មិតសួរថា ) អារម្មណ៍ជាទីត្រេកអរ និងមិនជាទីត្រេកអរ កើតមកអំពីអ្វី កាលបើអ្វីមិនមាន ទើបអារម្មណ៍ទាំងនុ៎ះមិនមានដែរ អត្ថ គឺសេចក្តីវិនាសនិងសេចក្តីចម្រើន

( នៃអារម្មណ៍ជាទីត្រេកអរ និងមិនជាទីត្រេកអរ ) ណា អត្ថនោះ តើកើតមកអំពីធម៌ណា សូមព្រះអង្គសម្ដែងប្រាប់ដល់ខ្ញុំឲ្យបាន ។ ( ព្រះសម្ពុទ្ធត្រាស់តបថា ) អារម្មណ៍ជាទីត្រេកអរ និងមិនជាទីត្រេកអរ កើតមកអំពីផស្សៈ កាលបើផស្សៈមិនមាន ទើបអារម្មណ៍ទាំងនុ៎ះមិនមាន អត្ថ គឺសេចក្ដីវិនាស និងសេចក្ដីចម្រើន ( នៃអារម្មណ៍ជាទីត្រេកអរ និងមិនជាទីត្រេកអរ ) ណា អត្ថនោះ កើតមកអំពីផស្សៈនេះ តថាគតសម្ដែងប្រាប់ដល់អ្នក ( ដូច្នេះ ) ។ ( ព្រះពុទ្ធនិម្មិតសួរថា ) ចុះផស្សៈក្នុងលោកកើតមកអំពីអ្វី មួយទៀត សេចក្ដីហួងហែងកើតមកអំពីអ្វី កាលបើអ្វីមិនមាន សេចក្ដីប្រកាន់ថារបស់អញៗ ទើបមិនមាន កាលបើអ្វីមិនមាន ផស្សៈទាំងឡាយទើបមិនពាល់ត្រូវ ។ ( ព្រះសម្ពុទ្ធត្រាស់តបថា ) ផស្សៈ ( កើតឡើង ) ព្រោះអាស្រ័យនាម និងរូប សេចក្ដីហួងហែងកើតមកអំពីឥច្ឆា កាលបើឥច្ឆាមិនមាន សេចក្ដីប្រកាន់ថារបស់អញៗ ក៏មិនមាន កាលបើរូបមិនមាន ផស្សៈទាំងឡាយ ក៏មិនពាល់ត្រូវ ។ ( ព្រះពុទ្ធនិម្មិតសួរថា ) កាលបុគ្គលប្រតិបត្តិដូចម្ដេច ទើបរូបវិនាសទៅ មួយទៀត រូបជាសុខ ( រូបគួរប្រាថ្នា ) និងរូបជាទុក្ខ ( រូបដែលមិនជាទីប្រាថ្នា ) វិនាសទៅវិញ ដោយប្រការដូចម្ដេច សូមព្រះអង្គសម្ដែងនូវ

រូបដែលជាសុខ និងជាទុក្ខនោះដល់ខ្ញុំ រូបដែលជាសុខ និងជាទុក្ខវិនាសទៅដោយហេតុណា ខ្ញុំដឹងនូវហេតុនោះ ខ្ញុំមានចិត្តត្រិះរិះដូច្នេះ ។ ( ព្រះសម្ពុទ្ធត្រាស់តបថា ) បុគ្គលមិនមែនជាសញ្ញាសញ្ញី បុគ្គលមិនមែនជាវិសញ្ញាសញ្ញី បុគ្គលមិនមែនជាអសញ្ញី បុគ្គលមិនមែនជាវិភូតសញ្ញី កាលបុគ្គលប្រតិបត្តិយ៉ាងនេះ រូបទើបវិនាសបាន ព្រោះធម៌ជាចំណែកនៃសេចក្តីយឺតយូរទាំងឡាយ មានសញ្ញាជាហេតុ ។ ( ព្រះពុទ្ធនិម្មិតពោលថា ) ខ្ញុំបានសួរនូវធម៌ណា ព្រះអង្គក៏បានសម្តែងធម៌នោះ ដល់ខ្ញុំរួចហើយ ខ្ញុំសូមសួរធម៌ផ្សេងទៀត សូមព្រះអង្គសម្តែងធម៌នោះដល់ខ្ញុំឲ្យទាន ( បពិត្រព្រះអង្គ ) ចុះសមណព្រាហ្មណ៍ជាបណ្ឌិតពួកខ្លះក្នុងលោកនេះ សម្តែងនូវសេចក្តីបរិសុទ្ធដ៏ប្រសើររបស់សត្វថា បំផុតត្រឹមប៉ុណ្ណេះឬ ឬក៏សម្តែងនូវសេចក្តីបរិសុទ្ធដទៃជាងអរូបសមាបត្តិនេះទៅទៀត ។ ( ព្រះសម្ពុទ្ធត្រាស់តបថា ) ពួកសមណព្រាហ្មណ៍ជាបណ្ឌិតពួកខ្លះ សម្តែងនូវអរូបសមាបត្តិទាំងឡាយនោះ ថាជាធម៌ដ៏បរិសុទ្ធប្រសើររបស់សត្វតែប៉ុណ្ណោះ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ពួកខ្លះទៀត ( ជាឧច្ឆេទវាទ ) ជាអ្នកពោលលើកខ្លួនថា ឆ្លៀវឆ្លាសក្នុងអនុបាទិសេសនិព្វាន តែងប្រកាន់ពោលនូវលទ្ធិ គឺសេចក្តីដាច់សូន្យថា ( ជាធម៌ដ៏បរិសុទ្ធប្រសើររបស់

សត្វ ) ។ ព្រះពុទ្ធជាវីមំសីបណ្ឌិត ទ្រង់ជ្រាបនូវពួកសមណ-ព្រាហ្មណ៍ទាំងនោះថា ជាអ្នកអាស្រ័យនូវសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិផង ទ្រង់ជ្រាបនូវធម៌គ្រឿងអាស្រ័យនៅ ( របស់ពួកសមណព្រាហ្មណ៍ទាំងនោះ ) ផង ជ្រាប ( នូវធម៌ទាំង-ឡាយថាជាទុក្ខ មិនទៀងជាដើម ) ហើយបានរួចស្រឡះផង ទើបមិនដល់នូវការទាស់ទែង អ្នកប្រាជ្ញតែងមិនមកដើម្បីកើតរឿយៗ ឡើយ ។

**កលហវិវាទសូត្រទី ១១ ចប់**

# អដ្ឋកថា

## កលហវិវាទសូត្រ

[ ១០៥ ] ក្នុងកលហវិវាទសូត្រទី ១១ មានពាក្យផ្ដើមថា **កុតោ បហូតា កលហា វិវាទា** ដូច្នេះ ។

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅ

ក្នុងមហាសម័យនោះឯង ព្រះមានព្រះភាគត្រាស់ព្រះសូត្រនេះ ដើម្បីទ្រង់ធ្វើធម៌ទាំងនោះឲ្យជាក់ច្បាស់ដល់ទេវតាពួកខ្លះ ដែលមានចិត្តកើតឡើងថា ធម៌ទាំងឡាយ ៨ ប្រការ មានការឈ្លោះគ្នាជាដើម កើតអំពីហេតុអ្វីហ្ន៎ ទើបឲ្យព្រះពុទ្ធនិម្មិតត្រាស់សួរព្រះអង្គដោយន័យមុននោះឯង ។

ក្នុងព្រះសូត្រនោះ គាថាទាំងអស់ មានការភ្ជាប់សេចក្ដីប្រាកដច្បាស់ហើយ ព្រោះរៀងតាមលំដាប់នៃការសួរ និងការឆ្លើយ ។ តែគប្បីជ្រាបដល់កិច្ចពណ៌នាបទដែលលំបាកនៃគាថាទាំងនោះដូច្នេះ

បទថា **កុតោ បហូតា កលហា វិវាទា** បានដល់ ធម៌ជាគ្រឿងសៅហ្មងទាំងនេះ គឺជម្លោះ និងវិវាទដែលជាខាងដើមនៃការឈ្លោះនោះកើតអំពីអ្វី ។ បទថា **បរិទេវសោកា សហមច្ឆរា ច** គឺការខ្សឹកខ្សួល សេចក្ដីសោយសោក មួយអន្លើដោយសេចក្ដីកំណាញ់ កើតអំពីអ្វី ។ បទថា **មានាតិមានា សហបេសុណា ច** គឺការប្រកាន់ខ្លួន ការមើលងាយ និងដោយពាក្យញុះញង់កើតអំពីណា ។ បទថា **តេ** បានដល់ ធម៌ គឺកិលេស ៨ យ៉ាង

ទាំងអស់នោះ ។ បទថា **តទិង្ឃ ព្រូហិ** គឺសូមព្រះអង្គទ្រង់ត្រាស់ប្រាប់អត្ថដែលខ្ញុំព្រះអង្គសួរនោះចុះ គឺខ្ញុំព្រះអង្គសូមអារាធនាទ្រង់ ។ បទថា **ឥង្ឃ** ជានិបាត សេចក្តីថា សំណូមពរ ។ បទថា **បិយប្បហូតា** គឺកើតចាកវត្ថុជាទីស្រឡាញ់ ។ អត្ថដែលត្រឹមត្រូវ ព្រះសារីបុត្តពោលក្នុងមហានិទ្ទេសហើយ ។ បទថា **មច្ឆេរយុត្តា កលហា វិវាទា** សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងថា មិនមែនវត្ថុជាទីស្រឡាញ់តែម្យ៉ាងប៉ុណ្ណោះ សូម្បីសេចក្តីកំណាញ់ក៏ជាហេតុនៃជម្លោះ និងវិវាទបាន ។ គប្បីជ្រាបថា ធម៌ទាំងនោះ ក្នុងទីនេះព្រះមានព្រះភាគត្រាស់ដោយមាតិកានៃការឈ្លោះ និងវិវាទ ។ វិវាទជាហេតុនៃពាក្យញុះញង់ ដូចសេចក្តីកំណាញ់ជាហេតុនៃការឈ្លោះ វិវាទ ដូច្នោះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **វិវាទជាតេសុ ច បេសុណានិ** ដូច្នេះ ។ បទថា **បិយា សុ លោកស្មឹ កុតោ និទានា យេ វាបិ លោភា វិចរន្តិ** សេចក្តីថា ព្រះពុទ្ធនិម្មិតទូលសួរអត្ថទាំងពីរ ដោយមួយគាថាថា ព្រះដ៏មានព្រះភាគត្រាស់ក្នុងបទនេះថា ការឈ្លោះ ការទាស់ទែងគ្នា ... កើតអំពីរបស់ជាទីស្រឡាញ់ វត្ថុដែលជាទីស្រឡាញ់ក្នុងលោកនោះមានអ្វីជាហេតុ ។ មិនមែនវត្ថុជាទីស្រឡាញ់តែម្យ៉ាង ម្យ៉ាងទៀត ជនទាំងឡាយណា មានក្សត្រជាដើម មានសេចក្តីលោភត្រាច់ទៅ គឺត្រាច់ទៅព្រោះសេចក្តីលោភជាហេតុ ព្រោះត្រូវលោភគ្របសង្កត់ សេចក្តីលោភរបស់ជនមានក្សត្រជាដើមនោះ មានអ្វីជាហេតុ ។ បទថា **អាសា ច និដ្ឋា ច** សេចក្តីថា ការសង្ឃឹម និងសេចក្តីសម្រេចនៃការសង្ឃឹមនោះ ។ បទថា **យេ**

**សម្បរាយាយ នរស្ស ហោន្តិ** *សេចក្តីថា សេចក្តីសង្ឃឹម និងសេចក្តីសម្រេចរបស់នរជនដែលមានក្នុងសម្បរាយភព លោកអធិប្បាយថា ភពជាទីទៅខាងមុខ ។ ពាក្យសួរនេះក៏ដូចគ្នា ។ បទថា* **ឆន្ទានិទានានិ** *សេចក្តីថា វត្ថុដែលជាទីស្រឡាញ់ មានការពេញចិត្តក្នុងកាមជាដើមជាហេតុ ។ បទថា* **យេ វាបិ លោភា វិចរន្តិ** *សេចក្តីថា ព្រះមានព្រះភាគទ្រង់រួបរួមរឿងទាំង ២ ទ្រង់ឆ្លើយរួមគ្នាថា ជនពួកណា មានក្សត្រជាដើម មានសេចក្តីលោភត្រាច់ទៅ សូម្បីសេចក្តីលោភរបស់ជន មានក្សត្រជាដើមនោះ ក៏មានឆន្ទៈជាហេតុ ។ បទថា* **ឥតោនិទានា** *លោកអធិប្បាយថា មានឆន្ទៈជាហេតុដូចគ្នា ។ គប្បីជ្រាបការសម្រេចនៃសព្ទក្នុងបទទាំង ២ ថា* **កុតោនិទានា** និង **ឥតោ-និទានា** *ដោយន័យដូចពោលហើយ ក្នុងសូចិលោមសូត្រនោះឯង ។ បទថា* **វិនិច្ឆយា** *បានដល់ ការវិនិច្ឆ័យ គឺការកាត់សម្រេចដោយតណ្ហា និងទិដ្ឋិ ។ បទថា* **យេ វាបិ ធម្មា សមណេន វុត្តា** *សេចក្តីថា ធម៌ដទៃឯណា ដែលសម្បយុត្តដោយសេចក្តីក្រោធជាដើម ឬធម៌ដែលជាអកុសលបែបនោះ ដែលពុទ្ធសមណៈត្រាស់ហើយ ធម៌ទាំងនោះ កើតអំពីណា ។*

*បទថា* **តម្ហបនិស្សាយ បហោតិ ឆន្ទោ** *សេចក្តីថា ការពេញចិត្តរមែងកើតព្រោះអាស្រ័យការត្រេកអរ និងការមិនត្រេកអរ ពោល គឺទីតាំង ២ យ៉ាង គឺសុខវេទនា និងទុក្ខវេទនានោះ ដោយការប្រាថ្នានៅរួមគ្នា និងការព្រាត់ប្រាសគ្នា ដោយហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ព្រះមានព្រះភាគទ្រង់ឆ្លើយបញ្ហានេះថា ឆន្ទៈក្នុងលោក កើតមកអំពីអ្វី ដូច្នេះ ។*

បទថា **រូបេសុ ទិស្វា វិភវំ ភវញ្ច** សេចក្តីថា សត្វឃើញការវិនាសទៅ និងការកើតឡើងក្នុងរូបទាំងឡាយ ។ បទថា **វិនិច្ឆយំ កុរុតេ ជន្តុ លោកេ** សេចក្តីថា សត្វក្នុងអបាយលោកជាដើមនេះ ធ្វើនូវការកាត់សម្រេចដោយតណ្ហាដើម្បីឲ្យបានភោគសម្បត្តិ និងធ្វើការកាត់សម្រេចដោយទិដ្ឋិ ដោយន័យជាដើមថា ខ្លួនរបស់អញកើតហើយ ដូច្នេះ ។ អត្ថដែលត្រឹមត្រូវ ព្រះសារីបុត្តត្ថេរពោលក្នុងមហានិទ្ទេសហើយ ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ព្រះមានព្រះភាគទ្រង់ឆ្លើយបញ្ហានេះថា មួយទៀត ការវិនិច្ឆ័យកើតមកអំពីអ្វី ដូច្នេះ ។ បទថា **ឯតេបិ ធម្មា ទ្វយមេវ សន្តេ** បានដល់ ធម៌មានសេចក្តីក្រោធទាំងនេះជាដើម រមែងកើតឡើងបាន ក្នុងកាលការត្រេកអរ និងការមិនត្រេកអរទាំងពីរនោះនៅមាននោះឯង ។ ម្យ៉ាងទៀត ព្រះសារីបុត្ត សម្តែងវិធីកើតរបស់សុខវេទនា និងទុក្ខវេទនានោះក្នុងមហានិទ្ទេសនោះហើយ ដោយហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ព្រះមានព្រះភាគត្រាស់ឆ្លើយបញ្ហាទី ៣ ហើយ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់ឧបាយដើម្បីលះសេចក្តីសង្ស័យដល់អ្នកសង្ស័យ ក្នុងកាលទ្រង់ឆ្លើយបញ្ហាទាំងនេះយ៉ាងនេះហើយ ទើបត្រាស់ថា **កថង្កថី ញាណបថាយ សិក្ខេ** ដូច្នេះ ។ លោកអធិប្បាយថា គប្បីសិក្សាសិក្ខា ៣ ដើម្បីសម្រេចញាណ គឺញាណទស្សនៈ ព្រោះហេតុអ្វី ព្រោះលោកជាសមណៈដឹងហើយ ទើបពោលធម៌ទាំងឡាយ គឺព្រះពុទ្ធសមណៈដឹងហើយ ទើបពោលធម៌ ការមិនដឹងក្នុងធម៌ទាំងឡាយ

រមែងមិនមានដល់ពុទ្ធសមណៈនោះ បុគ្គលកាលមិនដឹងធម៌ទាំងនោះ មិនគប្បីដឹង ព្រោះខ្លួនមិនមានញាណ មិនគប្បីដឹង ព្រោះទោសនៃការសម្តែង ក៏មិនមែន ព្រោះហេតុនោះ អ្នកសង្ស័យគប្បីសិក្សាដើម្បីផ្លូវនៃញាណ លោកជាសមណៈដឹងហើយ ទើបទ្រង់សម្តែងធម៌ទាំងឡាយ ។

បទថា **សាតាសាតំ** ក្នុងបទនេះថា **សាតំ អសាតញ្ច កុតោនិទានា** សេចក្តីថា ទ្រង់បំណាងយកសុខវេទនា និងទុក្ខវេទនានោះឯង ។ បទថា **ន ភវន្តិ ហោតេ** គឺធម៌ទាំងនោះ នឹងមិនមាន ។ បទថា **វិភវំ ភវញ្ចាបិ យមេតមត្ថំ ឯតំ មេ បព្រូហិ យតោនិទានំ** សេចក្តីថា សូមទ្រង់ត្រាស់ប្រាប់អត្ថ គឺទាំងការវិនាសទៅ និងទាំងការកើតឡើងនៃសេចក្តីត្រេកអរ និងការមិនត្រេកអរថា មានអ្វីជាហេតុដល់ខ្ញុំព្រះអង្គ ។ ក្នុងបទនេះ មានការផ្លាស់លិង្គ ។ បទនេះមានអធិប្បាយថា អត្ថរបស់បទថា **សាតាសាតានំ វិភវោ ភវោ ច** គប្បីជ្រាបតាមអត្ថក្នុងបទនេះថា សូមទ្រង់ត្រាស់ប្រាប់ទាំងការវិនាស និងការកើតនោះថា មានអ្វីជាហេតុ គឺការវិនាស និងការកើត ជាវិភវទិដ្ឋិ ការឃើញថា វិនាស និងភវទិដ្ឋិ ការឃើញថា កើតដែលជាទីតាំងនៃការវិនាស និងការកើតនៃការត្រេកអរ និងការមិនត្រេកអរ ។ ពិតហើយ ក្នុងចំណែកនៃការឆ្លើយបញ្ហានេះ លោកពោលក្នុងមហានិទ្ទេសថា កិរិយាឃើញថា ចម្រើនក៏មានផស្សៈជាហេតុ កិរិយាឃើញថា វិនាស ក៏មានផស្សៈជាហេតុ ។ បទថា **ផស្សនិទានំ** គឺមានផស្សៈជាហេតុ ។ បទថា **កិស្មឹ វិភូតេ ន ផុសន្តិ ផស្សា** សេចក្តីថា កាលធម៌ណាមួយកន្លងទៅហើយ ទើបផស្សៈ ៥ មាន

ចក្ខុសម្ផស្សជាដើម មិនមាន ។ បទថា **នាមញ្ច រូបញ្ច បដិច្ច** សេចក្ដីថា អាស្រ័យនាមដែលសម្បយុត្តចូលគ្នា និងអាស្រ័យវត្ថុ និងរូបដែលជាអារម្មណ៍ ។ បទថា **រូបេ វិភូតេ ន ផុសន្តិ ផស្សា** គឺកាលរូបកន្លងទៅ ផស្សៈ ៥ ក៏មិនពាល់ត្រូវ ។

បទថា **កថំសមេតស្ស** គឺកាលបុគ្គលបដិបត្តិដូចម្ដេច ។ បទថា **វិភោតិ រូបំ** គឺរូបក៏មិនមាន ឬមិនគប្បីមាន ។ បទថា **សុខំ ទុក្ខំ វា** សេចក្ដីថា ព្រះពុទ្ធនិម្មិតត្រាស់សួរដល់រូបទាំងដែលគួរប្រាប្ថា និងមិនគួរប្រាប្ថានោះឯង ។ បទថា **ន សញ្ញសញ្ញី** សេចក្ដីថា កាលបុគ្គលបដិបត្តិដូចម្ដេច ទើបរូបមិនមាន បុគ្គលនោះ ជាអ្នកមិនមានសញ្ញាដោយសញ្ញាជាប្រក្រតី ។ បទថា **ន វិសញ្ញសញ្ញី** សេចក្ដីថា មិនជាអ្នកមានសញ្ញាដោយសញ្ញាដែលខុសប្រក្រតី គឺឆ្កួត ឬចិត្តរាយមាយ ។ បទថា **នោបិ អសញ្ញី** សេចក្ដីថា មិនមែនជាអ្នកវៀរចាកសញ្ញា ជាអ្នកចូលនិរោធសមាបត្តិ ឬជាអសញ្ញីសត្វ ។ បទថា **ន វិភូតសញ្ញី** បានដល់ មិនមែនជាអ្នកឈានកន្លងសញ្ញាដោយន័យជាដើមថា ព្រោះកន្លងបង់នូវពួករូបសញ្ញា ... ដោយអាការទាំងពួង គឺមិនមែន ជាអ្នកបានអរូបជ្ឈាន ។ បទថា **ឯវំសមេតស្ស វិភោតិ រូបំ** សេចក្ដីថា បុគ្គលណា បានអរូបសមាបត្តិ កាលមិនតាំងនៅក្នុងភាពជាអ្នកមានសញ្ញា និងមិនមានសញ្ញាជាដើមនេះហើយ បដិបត្តិ ដូចលោកពោលថា កាលចិត្តតាំងមាំហើយយ៉ាងនេះ ។បេ។ បុគ្គលនោះ រមែងនាំចិត្តទៅ ដើម្បីបានអាកាសានញ្ចាយតនសមាបត្តិ ទើបរូបមិនមាន ។

បទថា **សញ្ញានិទានា ហិ បបញ្ចសង្ខា** សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងថា កាលបដិបត្តិយ៉ាងនេះហើយ ធម៌ជាចំណែកនៃការយឺតយូរ គឺតណ្ហា និងទិដ្ឋិ ដែលមានសញ្ញានោះជាហេតុ គង់លះមិនបាននោះឯង ។ បទជាច្រើនថា **ឯត្តាវតគ្គំ ។បេ។ វទន្តិ ឯកេ** សេចក្តីថា ពុទ្ធនិម្មិតត្រាស់សួរថា សមណព្រាហ្មណ៍ជាបណ្ឌិតក្នុងលោកនេះ រមែងពោលនូវការបរិសុទ្ធរបស់យក្ខថា ( សត្វ ) ជាកំពូលដោយហេតុត្រឹមប៉ុណ្ណោះឬថា រមែងពោលសេចក្តីបរិសុទ្ធដទៃ ដែលក្រៃលែងជាងអរូបសមាបត្តិនេះ ។

បទថា **ឯត្តាវតគ្គម្បិ វទន្តិ ហេកេ** សេចក្តីថា សមណព្រាហ្មណ៍ដែលមានវាទៈថាទៀងមួយពួក ប្រកាន់ខ្លួនថាជាបណ្ឌិត រមែងពោលសេចក្តីបរិសុទ្ធិថាជាកំពូល ដោយហេតុមានប្រមាណប៉ុណ្ណោះ ។ បទថា **តេសំ បុនេកេ សមយំ វទន្តិ** សេចក្តីថា សមណព្រាហ្មណ៍ជាអ្នកមានវាទៈថាដាច់សូន្យមួយពួក រមែងពោលដល់លទ្ធិថា ដាច់សូន្យរបស់សមណព្រាហ្មណ៍ទាំងនោះ ។ បទថា **អនុបាទិសេសេ កុសលាវទានា** សេចក្តីថា បុគ្គលមានវាទៈថាខ្លួន ជាអ្នកឈ្លាសក្នុងអនុបាទិសេសនិព្វាន ។ បទថា **ឯតេ ច ញត្វា ឧបនិស្សិតា** សេចក្តីថា ចំណែកលោកជាមុនី ដឹងបុគ្គលដែលជាម្ចាស់ទិដ្ឋិ

ទាំងនោះថា ជាអ្នកអាស្រ័យសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។ បទថា **ញត្វា មុនី និស្សយេ សោ វិមំសី** សេចក្ដីថា ព្រះពុទ្ធមុនីដែលជាបណ្ឌិត ពិចារណាដឹងបុគ្គលអាស្រ័យនោះឯង ។ បទថា **ញត្វា វិមុត្តោ** សេចក្ដីថា ដឹងធម៌ដោយភាពជាទុក្ខ និងមិនទៀងជាដើម រួចផុតហើយ ។ បទថា **ភវាភវាយ ន សមេតិ** សេចក្ដីថា រមែងមិនមកដើម្បីកើតរឿយៗ ។ ព្រះមានព្រះភាគទ្រង់បញ្ចប់ទេសនាដោយកំពូលធម៌ គឺអរហត្ត ។

កាលចប់ទេសនា មហាជនដូចគ្នាដែលពោលហើយក្នុងបុរាភេទសូត្រនោះឯង ត្រាស់ដឹងមគ្គផល ៗ៚

**អដ្ឋកថាកលហវិវាទសូត្រទី ១១ ចប់**

# សុត្តន្តបិដក

## ចូឡវិយូហសូត្រទី ១២

[ ១០៦ ] ( ព្រះពុទ្ធនិម្មិតត្រាស់សួរព្រះសម្ពុទ្ធថា ) សមណព្រាហ្មណ៍ទាំងឡាយ កាលជំអក់នៅក្នុងទិដ្ឋិ ( សេចក្តីយល់ឃើញ ) របស់ខ្លួនៗ រមែងប្រកាន់មាំ ប្តេជ្ញាថាខ្លួនជាអ្នកឆ្លៀវឆ្លាស ( ក្នុងទិដ្ឋិនោះ ) ហើយនិយាយផ្សេងៗ គ្នា បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះឈ្មោះថា ដឹងនូវធម៌ពិត បុគ្គលណាបដិសេធធម៌នេះ បុគ្គលនោះឈ្មោះថា មិនមានគុណបរិបូណ៌ឡើយ ។ លុះសមណព្រាហ្មណ៍ទាំងឡាយ ប្រកាន់មាំយ៉ាងនេះហើយ តែងទាស់ទែងគ្នា ទាំងពោលតិះដៀលថា បុគ្គលដទៃៗ ជាបុគ្គលពាល ជាបុគ្គលមិនឈ្លាសវៃ វាទៈរបស់សមណព្រាហ្មណ៍ទាំងឡាយនេះ បែបណា ជាវាទៈពិត ព្រោះសមព្រាហ្មណ៍ទាំងនេះ ជាអ្នកពោលលើកខ្លួនថាឆ្លៀវឆ្លាស ។ ( ព្រះសម្ពុទ្ធត្រាស់ថា ) សមណព្រាហ្មណ៍ កាលបើមិនយល់ឃើញនូវធម៌របស់ជនដទៃ ឈ្មោះថា ជាបុគ្គលពាល ជាបុគ្គលថោកទាប មានប្រាជ្ញាទន់ទាប សមណព្រាហ្មណ៍ទាំងអស់ សុទ្ធតែជាបុគ្គលពាល មានប្រាជ្ញាថោកទាប ឈ្មោះថា សមណព្រាហ្មណ៍ទាំងនេះ ជាអ្នកជំអក់នៅក្នុងទិដ្ឋិ ។ មួយទៀត បើសមណព្រាហ្មណ៍ទាំងឡាយ ជាអ្នកផូរផង់ក្នុងទិដ្ឋិរបស់ខ្លួន ជាអ្នកមានប្រាជ្ញាដ៏បរិសុទ្ធ ជាអ្នកឈ្លាសវៃ ជាអ្នកមានប្រាជ្ញា

បណ្ដាសមណព្រាហ្មណ៍ទាំងនោះ រកអ្នកណាមួយ មានប្រាជ្ញា ជោកទាបគ្មានទេ ព្រោះថា សមណព្រាហ្មណ៍ទាំងនោះ មាន ទិដ្ឋិស្មើៗ គ្នា ។ ជនទាំងឡាយ ( អ្នកធ្វើនូវជម្លោះ ) ផ្ទឹមគ្នា ជាគូៗ បានពោលសង្កត់សង្កិននូវគ្នានិងគ្នាដោយពាក្យណាថា អ្នកនេះ ជាបុគ្គលពាលដូច្នេះ តថាគតមិនបានពោលនូវពាក្យ នុ៎ះថា ជាពាក្យពិតឡើយ ព្រោះថា ជនទាំងនោះ បានធ្វើនូវ សេចក្ដីយល់ឃើញរបស់ខ្លួនៗ ថាជារបស់ពិត ព្រោះហេតុ នោះ បានជាជនទាំងនោះ ដុតកម្ដៅបុគ្គលដទៃដោយពាក្យថា បុគ្គលពាល ។ ( ព្រះពុទ្ធនិម្មិតសួរថា ) សមណព្រាហ្មណ៍ ពួកខ្លះ បានសរសើរទិដ្ឋិណាថាជារបស់ពិត ទៀងទាត់ ចំណែក សមណព្រាហ្មណ៍ពួកដទៃ តិះដៀលទិដ្ឋិនោះជារបស់ទទេ កុហក វិញ លុះសមណព្រាហ្មណ៍ទាំងនោះ ប្រកាន់ផ្សេងៗ យ៉ាង នេះហើយ ក៏ទាស់ទែងគ្នា ចុះសមណព្រាហ្មណ៍ទាំងឡាយ មិន និយាយមូលមាត់គ្នាតែបែបមួយ តើព្រោះហេតុអ្វី ។ ( ព្រះ សម្ពុទ្ធត្រាស់ថា ) ព្រោះថា បុគ្គលកាលដឹងច្បាស់ក្នុងសច្ចៈ ណា ទើបមិនទាស់ទែងគ្នា ឯសច្ចៈនោះមានតែមួយ មិនមែន មានពីរឡើយ ប៉ុន្តែជនទាំងឡាយ តែងសរសើរសច្ចៈរបស់ខ្លួន ផ្សេងៗ គ្នា ហេតុនោះបានជាពួកសមណព្រាហ្មណ៍ មិននិយាយ មូលមាត់គ្នាតែបែបមួយ ។ ( ព្រះពុទ្ធនិម្មិតសួរថា ) ព្រោះ

ហេតុអ្វីហ្ន៎ បានជាសមណព្រាហ្មណ៍ទាំងឡាយ ដែលពោល លើកខ្លួនថា ជាអ្នកឆ្លៀវឆ្លាស ជាអ្នកពោលតាមបំណងរបស់ខ្លួន តែងពោលសច្ចៈផ្សេងៗ គ្នា ចុះសមណព្រាហ្មណ៍ទាំងនោះ បានឮមកថា សច្ចៈមានច្រើនផ្សេងៗ គ្នាឬ ឬក៏សមណ-ព្រាហ្មណ៍ទាំងនោះ នឹករកដោយសេចក្តីត្រិះរិះរបស់ខ្លួនទេ ។ ( ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ) សច្ចៈទាំងឡាយច្រើនផ្សេងៗ គ្នាក្នុងលោកមិនមានទេ លើកលែងតែសេចក្តីប្រកាន់ថា ទៀងដោយសញ្ញាចេញ គឺមានតែបរមត្ថសច្ចៈមួយប៉ុណ្ណោះ មួយទៀត សមណព្រាហ្មណ៍ទាំងឡាយ កំណត់ទុកនូវសេចក្តីត្រិះរិះឲ្យប្រជុំចុះក្នុងទិដ្ឋិទាំងឡាយ ហើយនិយាយនូវហេតុមួយគូជាធម្មតា គឺសេចក្តីពិត ១ មុសា ១ ។ បុគ្គលពួកមួយអាស្រ័យនូវទិដ្ឋិធម៌ទាំងនេះ គឺអារម្មណ៍ដែលខ្លួនឃើញហើយ ឬឮហើយ ដែលខ្លួនពាល់ត្រូវហើយ ឬសីលវត្ត ជាអ្នកឃើញនូវសេចក្តីប្រកាន់ជំ គឺសន្និកាព លុះឋិតនៅក្នុងវិនិច្ឆយធម៌ គឺទិដ្ឋិ ៦២ ហើយរីករាយ ក៏ពោលតិះដៀលថា បុគ្គលដទៃជាបុគ្គលពាល មិនឆ្លៀវឆ្លាស ។ មួយទៀត បុគ្គលនោះ តែងជុតកម្ចោបុគ្គលដទៃថា ជាបុគ្គលពាលៗ ដូច្នេះ ដោយហេតុណាក៏បាន ពោលលើកខ្លួនឯងថាជាអ្នកឆ្លៀវឆ្លាស ដោយហេតុនោះ បុគ្គលនោះ ពោលលើកខ្លួនឯងថា ជាអ្នកឆ្លៀវឆ្លាសចំពោះខ្លួន

ដោយខ្លួនឯង រមែងតិះដៀលបុគ្គលដទៃ ហើយពោលប្រកាន់ទិដ្ឋិនោះ ។ បុគ្គលនោះ បរិបូណ៌ហើយដោយទិដ្ឋិ គឺការយល់ឃើញថា មានខ្លឹមសារក្រៃពេក និងដោយមានះ មានមានះដ៏បរិបូណ៌ ព្រោះព្រំសន្ធានខ្លួនដោយមានះ គឺប្រកាន់ថា ខ្លួនជាបណ្ឌិត ទិដ្ឋិនោះរបស់បុគ្គលនោះ បរិបូណ៌ហើយដោយប្រការដូច្នោះ ។ ប្រសិនបើមានបុគ្គលអ្នកថោកទាបដោយសារវាចាពាក្យតិះដៀលរបស់បុគ្គលដទៃ បុគ្គលដែលតិះដៀលគេនោះនឹងទៅជាបុគ្គលមានប្រាជ្ញាថោកទាប ស្មើនឹងបុគ្គលថោកទាបនោះ មួយទៀត បើបុគ្គលនោះជាអ្នកដល់នូវវេទ ជាអ្នកប្រាជ្ញមានប្រាជ្ញាខ្ជាប់ខ្ជួនចំពោះខ្លួនឯង ក៏រកបុគ្គលណាមួយជាមនុស្សល្ងង់ក្នុងពួកសមណៈមិនមាន ។ ពួកបុគ្គលណា សរសើរធម៌ គឺទិដ្ឋិដទៃក្រៅពីនេះ ពួកបុគ្គលនោះ ជាអ្នកមានគុណមិនបរិបូណ៌ ឈ្មោះថា ប្រទូស្តចំពោះផ្លូវដ៏បរិសុទ្ធ ពួកតិរ្ថិយតែងនិយាយតិះដៀលគ្នាដោយច្រើន យ៉ាងនេះឯង ព្រោះថា តិរ្ថិយទាំងនោះ ត្រេកអរស៊ប់ហើយដោយតម្រេកក្នុងទិដ្ឋិរបស់ខ្លួន ។ លុះពួកតិរ្ថិយ ( ត្រេកអរយ៉ាងនេះហើយ ) ទើបនាំគ្នានិយាយសរសើរសេចក្ដីបរិសុទ្ធក្នុងធម៌ ( របស់ខ្លួន ) នេះតែម្យ៉ាងមិននិយាយសរសើរសេចក្ដីបរិសុទ្ធ ក្នុងធម៌ទាំងឡាយដទៃឡើយ ពួកតិរ្ថិយតែងចូលចិត្តដោយច្រើនយ៉ាងនេះហើយ

ពោលប្រកាន់មាំក្នុងផ្លូវនៃទិដ្ឋិរបស់ខ្លួននោះ ។ មិនត្រឹមតែប៉ុណ្ណោះឡើយ ពួកតិត្ថិយទាំងនោះ សូម្បីតែមួយនាក់ កាលពោលប្រកាន់មាំក្នុងផ្លូវនៃទិដ្ឋិរបស់ខ្លួនហើយ មុខជាជុតកម្តៅបុគ្គលដទៃថាជាមនុស្សពាល ព្រោះទិដ្ឋិរបស់ខ្លួនដូច្នេះ លុះតិត្ថិយពោលនូវបុគ្គលដទៃថាជាមនុស្សពាល ថាជាអ្នកមានធម៌មិនបរិសុទ្ធហើយ គប្បីនាំមកនូវជម្លោះចំពោះខ្លួនឯង ។ តិត្ថិយនោះ តាំងនៅក្នុងវិនិច្ឆយធម៌ ( ដោយតណ្ហា និងទិដ្ឋិ ) តាំងលទ្ធិដោយខ្លួនឯងហើយ រមែងដល់នូវការទាស់ទែងគ្នា ដ៏ក្រៃលែងលើសលុបក្នុងលោក ចំណែកសត្វដែលលះបង់នូវវិនិច្ឆយធម៌ទាំងអស់ ( ដោយអរិយមគ្គ ) រមែងមិនធ្វើនូវជម្លោះក្នុងលោកឡើយ ។

ចូឡវិយូហសូត្រទី ១២ ចប់

# អដ្ឋកថា

## ចូឡវិយូហសូត្រ

[ ១០៦ ] ក្នុងចូឡវិយូហសូត្រទី ១២ មានពាក្យផ្ដើមថា **សកំ សកំ ទិដ្ឋិបរិព្វសានា** ដូច្នេះ ។

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិដូចតទៅ

ក្នុងមហាសម័យនោះឯង ព្រះមានព្រះភាគត្រាស់ព្រះសូត្រនេះ ក៏ដើម្បីប្រកាសសេចក្ដីនោះ ដល់ទេវតាពួកខ្លះ ដែលមានចិត្តកើតឡើងហើយថា បុគ្គលកាន់យកទិដ្ឋិទាំងនេះ ពោលថា អញជាបុគ្គលល្អ អះអាងក្នុងទិដ្ឋិរបស់ខ្លួនប៉ុណ្ណោះ ឬថា ទទួលយកទិដ្ឋិដទៃផងដែរ ទើបឲ្យព្ទនិម្មិតសួរទ្រង់ដោយន័យមុននោះឯង ។

ក្នុងសូត្រនោះ ២ គាថាខាងដើម ជាគាថាសួរនោះឯង ។ ក្នុងគាថាទាំងនោះ គាថាថា **សកំ សកំ ទិដ្ឋិបរិព្វសានា** បានដល់ ប្រកាន់មាំក្នុងទិដ្ឋិរៀងៗ ខ្លួន ។ បទថា **វិគ្គយ្ហ នានា កុសលា វទន្តិ** បានដល់ ប្រកាន់មាំនូវទិដ្ឋិយ៉ាងខ្លាំងក្លា ហើយប្ដេជ្ញាថា យើងជាអ្នកឈ្លាសក្នុងទិដ្ឋិនោះ និយាយច្រើន មិនពោលត្រឹមតែម្ដង ។ បទថា **យោ ឯវំ ជានាតិ ស វេទិ ធម្មំ ឥទំ បដិក្កោសមកេវលី សោ** សេចក្ដីថា បុគ្គលណាដឹងយ៉ាងនេះ សំដៅដល់ទិដ្ឋិនោះ បុគ្គលនោះ ឈ្មោះថា ជាអ្នកដឹងនូវទិដ្ឋិ បុគ្គលនោះ ឈ្មោះថា ដឹងធម៌ គឺទិដ្ឋិ ជំទាស់នូវធម៌ គឺទិដ្ឋិនេះ បណ្ឌិតពោលថា បុគ្គលនេះ ជាបុគ្គល

អាក្រក់ ។ បទថា **ពាលោ** គឺជាបុគ្គលពាល ។ បទថា **អកុសលោ** គឺ បុគ្គលមិនឈ្លាស ។

៣ គាថាទៀត ជាគាថាឆ្លើយ ។ គាថាទាំងនោះ ប្រមូលភាពដែលពោលហើយ ដោយកន្ទុះគាថាមុន ដោយកន្ទុះគាថាក្រោយ ។ ព្រះសូត្រនេះបានឈ្មោះថា ចូឡព្យូហៈ ព្រោះមានសេចក្តីតិចជាងសូត្រតទៅ ដោយការប្រមូលនោះ ។

ក្នុងបទទាំងនោះ បទថា **បរស្ស ចេ ធម្មំ** បានដល់ ការឃើញរបស់អ្នកដទៃ ។ បទថា **សព្វេវ ពាលា** អធិប្បាយថា កាលបើដូច្នេះ បុគ្គលទាំងអស់នេះ រមែងជាបុគ្គលពាល ។ ព្រោះអ្វី ព្រោះបុគ្គលទាំងនោះ ជាបុគ្គលប្រកាន់ក្នុងទិដ្ឋិ ។ បទថា **សន្ទិដ្ឋិយា ចេ បន ។បេ។ មតិមា** សេចក្តីថា បុគ្គលទាំងនោះ ជាបុគ្គលមិនផូរផង់ មិនបរិសុទ្ធ ជាអ្នកសៅហ្មង ក្នុងទិដ្ឋិរៀងៗ ខ្លួន ឈ្មោះថា ជាអ្នកមានបញ្ញាបរិសុទ្ធ ជាអ្នកឈ្លាស និងជាអ្នកមានការគិត ។ ម្យ៉ាងទៀត បាឋៈថា **សន្ទិដ្ឋិយា ចេ បន វីវទាតា** ( បើជាអ្នកផូរផង់ក្នុងការឃើញរបស់ខ្លួន ) ក៏មាន ។ អធិប្បាយថា បើបុគ្គលទាំងនោះជាបុគ្គលផូរផង់ មានបញ្ញាបរិសុទ្ធ ជាអ្នកឈ្លាស និងជាអ្នកមានការគិតក្នុងទិដ្ឋិរៀងៗ ខ្លួន ។ បទថា **ន តេសំ កោចិ** សេចក្តីថា កាលបើយ៉ាងនេះ បណ្តាម្ចាស់ទិដ្ឋិទាំងនោះ ក៏មិនមានសូម្បីតែម្នាក់ដែលមានបញ្ញាថោកថយ ។ ព្រោះអ្វី ព្រោះសមណព្រាហ្មណ៍ទាំងនោះ កាន់យកតាមទិដ្ឋិរៀងៗ ខ្លួនដូចគ្នាសមណព្រាហ្មណ៍ពួកដទៃ ដែលកាន់យកតាមទិដ្ឋិរបស់ខ្លួន ដូច្នោះ ។

គប្បីជ្រាបការភ្ជាប់សេចក្តីនៃគាថាថា **ន វាហមេតំ** ដូចតទៅ បុគ្គល ២ ពួក ពោលដល់គ្នានិងគ្នាថា ជាបុគ្គលល្ងង់ខ្លៅ ព្រោះការឃើញណា តថាគតមិនពោលការឃើញនោះថា ពិត ព្រោះអ្វី ព្រោះបុគ្គលទាំងនោះ បានធ្វើទិដ្ឋិរៀងៗ ខ្លួនថា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃជាមោឃ ដោយហេតុនោះ ទើបបុគ្គលទាំងនោះ តាំងបុគ្គលដទៃថា ជាបុគ្គលល្ងង់ខ្លៅ ។ ក្នុងបទនេះ មានឋានៈ ២ យ៉ាង គឺ **តថិយំ** និង **តថិវំ** ប្រែថា ជារបស់ពិត ។

បទថា **យមាហុ** ក្នុងគាថាជាពាក្យសួរ សេចក្តីថា សមណព្រាហ្មណ៍ពួកខ្លះ ពោលទិដ្ឋិណាថា ជាសេចក្តីពិត ។

បទថា **ឯកំ ហិ សច្ចំ** ក្នុងគាថាជាពាក្យឆ្លើយ ។ សច្ចៈមានមួយ បានដល់ គឺនិរោធ ឬមគ្គ ។ បទថា **យស្មឹ បជានោ វិវទេ បជានំ** បានដល់ដឹងច្បាស់ក្នុងសច្ចៈ នឹងត្រូវវិវាទព្រោះសច្ចៈអ្វី ។ បទថា **សយំ ថុនន្តិ** សេចក្តីថា សមណព្រាហ្មណ៍ទាំងនោះ ពោលសច្ចៈឲ្យផ្សេងគ្នាដោយខ្លួនឯង ។

បទថា **កស្មា នុ** ក្នុងគាថាជាពាក្យសួរ ប្រែថា ព្រោះហេតុអ្វីហ្ន៎ ។ បទថា **បវាទិយាសេ** គឺពោលដោយខ្លួន ។ បទថា **តេ តក្កមនុស្សរន្តិ** សេចក្តីថា សមណព្រាហ្មណ៍ទាំងនោះអនុលោមតាមការគិតរបស់ខ្លួន ។

បទថា **ន ហេវ** ជាគាថាឆ្លើយ ។ បទថា **អញ្ញត្រ សញ្ញាយ និច្ចានិ** សេចក្តីថា វៀរត្រឹមតែការកាន់យក ដោយកាន់យកត្រឹមសញ្ញាថា ទៀង ។ បទថា **តក្កញ្ច ទិដ្ឋីសុ បកប្បយិត្វា** សេចក្តីថា ត្រឹមតែឲ្យនូវការត្រិះរិះខុសរបស់ខ្លួនកើតឡើងក្នុងទិដ្ឋិទាំងឡាយ ។ ព្រោះបុគ្គលនោះ កើតវិតក្ក

ឡើងក្នុងទិដ្ឋិទាំងឡាយ ទើបកើតទិដ្ឋិ ដូច្នោះ ទើបព្រះសារីបុត្តពោលក្នុង មហានិទ្ទេសថា ញ៉ាំងទិដ្ឋិទាំងឡាយឲ្យកើត ឲ្យកើតព្រម ដូច្នេះ ។

ឥឡូវនេះ កាលសច្ចៈផ្សេងៗ មិនមាន ព្រះមានព្រះភាគដើម្បីសម្តែង ដល់កិច្ចបដិបត្តិខុសរបស់ម្ចាស់ទិដ្ឋិទាំងឡាយ ដែលនឹកគិតដោយការដៅស្មាន ទើបត្រាស់គាថាថា **ទិដ្ឋេ សុតេ** ដូច្នេះជាដើម ។

បទថា **ទិដ្ឋេ** គឺរូបដែលបានឃើញ អធិប្បាយថា សេចក្តីបរិសុទ្ធនៃរូប ដែលបានឃើញ ក្នុងសំឡេងដែលបានស្តាប់ជាដើម ក៏មានន័យដូច្នេះ ។ បទថា **ឯតេ ច និស្សាយ វិមានទស្សី** សេចក្តីថា អាស្រ័យធម៌ គឺទិដ្ឋិទាំងនេះ ឃើញនូវសភាពគួរមើលងាយ ពោល គឺសេចក្តីបរិសុទ្ធរបស់អ្នកដទៃថា មិនគួររាប់អាន ។ បទថា **វិនិច្ឆយេ ឋត្វា ។បេ។ ចាហ** សេចក្តីថា កាលឃើញសេចក្តីបរិសុទ្ធយ៉ាងនេះហើយ ក៏តាំងនៅក្នុងទិដ្ឋិនោះ ដែលខ្លួនដាក់ចិត្តនោះ កើតនូវការត្រេកអរ ពោលយ៉ាងនេះថា អ្នកដទៃ ជាបុគ្គលអាក្រក់ និងមិនឈ្លាស ។ កាលបើដូច្នេះ ទើបមានគាថាថា **យេនេវ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **សយមត្តនា** បានដល់ ខ្លួនឯងនោះឯង ។ បទថា **វិមានេតិ** បានដល់ តិះដៀល ។ បទថា **តនេវ ចាវា** សេចក្តីថា ពោលវាចាដែលជាទិដ្ឋិនោះឯង ឬក៏ពោលដល់បុគ្គលនោះ ។

គប្បីជ្រាបសេចក្តីនៃគាថា **អតិសារទិដ្ឋិយា** ជាដើម ដូចតទៅនេះ ម្ចាស់ទិដ្ឋិនោះ ពោរពេញដោយទិដ្ឋិដែលជាសារៈ ដែលមានសារៈក្រៃលែង ព្រោះក្រៃលែងដោយសារៈជាលក្ខណៈនោះ ម្យ៉ាងទៀត ពេញប្រៀបទៅដោយ

ទិដ្ឋិ និងមានះនោះ មានមានះបរិបូណ៌យ៉ាងនេះថា អញប៉ុណ្ណោះមិនខ្វះចន្លោះ អភិសេកខ្លួនឯងដោយចិត្តថា អញជាបណ្ឌិត ។ ព្រោះអ្វី ព្រោះថា បុគ្គលនោះ កាន់យកតាមទិដ្ឋិរបស់ខ្លួន ។

គប្បីជ្រាបការភ្ជាប់សេចក្ដីក្នុងគាថាថា **បរស្ស ចេ** មានដូចតទៅនេះថា មានអ្វីក្រៃលែងជាងនោះ មានដូច្នេះ បុគ្គលណាតាំងនៅក្នុងទិដ្ឋិដែលខ្លួនដាក់ចិត្តហើយត្រេកអរ ពោលថា អ្នកដទៃជាបុគ្គលពាល មិនឈ្លាស បើបុគ្គលនោះត្រូវគេពោលថា ជាបុគ្គលអាក្រក់ ដោយពាក្យសម្ដីរបស់អ្នកដទៃ ខ្លួនក៏នឹងមានបញ្ញាថោកថយទៅដែរ គឺជាអ្នកមានបញ្ញាថោកថយទៅជាមួយគេដែរ បុគ្គលនោះក៏រមែងពោលអ្នកមានបញ្ញាថោកថយថា ជាបុគ្គលល្ងង់ខ្លៅ ថោកថយ កាលបើដូច្នោះ ពាក្យរបស់បុគ្គលនោះមិនមានប្រមាណ បើបុគ្គលនោះជាអ្នកចប់នូវវេទ និងជាអ្នកប្រាជ្ញ ដោយទំនើងខ្លួនឯង កាលបើដូច្នោះ សមណៈទាំងឡាយ ក៏នឹងមិនមានអ្នកណាជាបុគ្គលល្ងង់ខ្លៅ សមណៈទាំងអស់ ក៏នឹងជាបណ្ឌិតតាមសេចក្ដីប្រាថ្នារៀងៗ ខ្លួន ។

គប្បីជ្រាបការភ្ជាប់ និងអត្ថក្នុងគាថាថា **អញ្ញំ ឥតោ** ដូចតទៅនេះ គប្បីមានបុគ្គលសួរថា កាលព្រះមានព្រះភាគត្រាស់ហើយយ៉ាងនេះថា **អថ ចេ សយំ ។បេ។ សមណេសុ អត្ថិ** សេចក្ដីថា គប្បីមានបុគ្គលខ្លះសង្ស័យថា ព្រោះហេតុអ្វី នឹងអធិប្បាយក្នុងសេចក្ដីនោះដូចតទៅ ព្រោះជនឯណា ពោលលើកតម្កើងធម៌ គឺទិដ្ឋិដទៃក្រៅអំពីនេះ ជនទាំងនោះខុស និងមិនបរិបូណ៌ មិនបរិសុទ្ធ ព្រោះតិត្ថិយទាំងឡាយពោលយ៉ាងនេះដោយច្រើន ជនឯណា

ពោលសរសើរធម៌ គឺទិដ្ឋិដទៃ អធិប្បាយថា ត្រេកអរក្រៃលែង ដោយតម្រេកក្នុងទិដ្ឋិដែលជារបស់ខ្លួន ក្រៅអំពីនេះ ជនទាំងនោះភ្លាត់ចាកផ្លូវដែលបរិសុទ្ធ និងជាអ្នកមិនបរិបូណ៌ ព្រោះហេតុនោះ ទើបលោកពោលថា ពួកតិរ្ថិយជាច្រើនពោលយ៉ាងនេះ ។ បើមានពាក្យសួរថា ព្រោះហេតុអ្វី ទើបពួកតិរ្ថិយពោលយ៉ាងនោះ ឆ្លើយថា ព្រោះថា តិរ្ថិយទាំងនោះ ត្រេកអរក្រៃលែងដោយការត្រេកអរក្នុងទិដ្ឋិរបស់ខ្លួន ។ តិរ្ថិយទាំងនោះ ត្រេកអរក្រៃលែងយ៉ាងនេះ ទើបព្រះមានព្រះភាគត្រាស់គាថាបន្តថា **ឥធេវ សុទ្ធិ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **សកាយនេ** គឺក្នុងផ្លូវរបស់ខ្លួន ។ បទថា **ធម្មំ វទានា** គឺទទួលយ៉ាងមាំទាំ ។ ម្យ៉ាងទៀត ក្នុងបណ្តាតិរ្ថិយដែលទទួលយ៉ាងមាំទាំទាំងនោះ តិរ្ថិយណាមួយទទួលយ៉ាងមាំទាំក្នុងលទ្ធិរបស់ខ្លួន គប្បីតាំងបុគ្គលដទៃណាមួយថាជាបុគ្គលល្ងង់ខ្លៅក្នុងលទ្ធិនេះ ។ តិរ្ថិយទទួលយ៉ាងមាំទាំក្នុងលទ្ធិរបស់ខ្លួនដោយសង្ខេប បានដល់ សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិដោយពិស្តារ បានដល់ នត្ថិកទិដ្ឋិ លទ្ធិថា មានបុគ្គលជាធំ ( ព្រះ ) មានអ្នកសាង ឬយល់ថា លោកទៀងជាដើម ហើយពោលថា វត្ថុនេះប៉ុណ្ណោះពិត ឃើញបុគ្គលដទៃថាជាបុគ្គលល្ងង់ខ្លៅក្នុងទិដ្ឋិនេះ ដោយធម៌តាមការឃើញរបស់តិរ្ថិយនោះ សូម្បីមនុស្សទាំងពួង ក៏ជាបណ្ឌិត និងជាអ្នកបដិបត្តិប្រពៃបានដូចគ្នា កាលបើដូច្នោះ តិរ្ថិយនោះកាលពោលអ្នកដទៃថាជាបុគ្គលល្ងង់ខ្លៅ មានធម៌មិនបរិសុទ្ធ គប្បីនាំនូវជម្លោះ និងវិវាទមកឲ្យខ្លួនតែម្យ៉ាង គឺតិរ្ថិយនោះគង់ពោលអ្នកដទៃថា បុគ្គលនេះជាបុគ្គលល្ងង់ខ្លៅ មានធម៌មិនបរិសុទ្ធ

និងនាំជម្លោះទាស់ទែងឲ្យដល់ខ្លួន ព្រោះហេតុអ្វី ព្រោះតាមការឃើញរបស់តិរ្ថិយនោះ សូម្បីជនទាំងអស់ក៏ជាបណ្ឌិត ជាអ្នកបដិបត្តិប្រពៃបានដូចគ្នា ។

កាលបើដូច្នេះ ដោយទូទៅហើយ គាថាថា **វិនិច្ឆយេ ឋត្វា ។បេ។ វិវាទមេតិ** សេចក្តីថា តិរ្ថិយនោះ តាំងនៅក្នុងទិដ្ឋិ ហើយតាក់តែងសាស្តាជាដើមឡើងដោយខ្លួនឯង ក៏ត្រូវវិវាទគ្នាក្រៃលែងឡើង ព្រោះហេតុនោះ បុគ្គលដឹងទោសក្នុងទិដ្ឋិ ដែលខ្លួនដាក់ចិត្តលះនូវការវិនិច្ឆ័យ ដោយទិដ្ឋិទាំងអស់ ដោយអរិយមគ្គ ហើយមិនធ្វើជម្លោះទាស់ទែងគ្នាក្នុងលោក ។ ព្រះមានព្រះភាគទ្រង់បញ្ចប់ទេសនាដោយធម៌ជាកំពូល គឺអរហត្ត ។

កាលចប់ទេសនា សត្វដែលបានត្រាស់ដឹង ដូចគ្នាដែលបានពោលរួចមកហើយ ក្នុងបុរាភេទសូត្រនោះឯង ។ល។

**អដ្ឋកថាចូឡវិយូហសូត្រទី ១២ ចប់**

# សុត្តន្តបិដក

## មហាវិយូហសូត្រទី ១៣

[ ១០៧ ] ( ព្រះពុទ្ធនិម្មិតសួរថា ) សមណព្រាហ្មណ៍ណាមួយត្រាំនៅក្នុងទិដ្ឋិ ( របស់ខ្លួន ) តែងជជែកគ្នាថា នេះឯងជារបស់ពិត តើពួកសមណព្រាហ្មណ៍ទាំងអស់នោះ នឹងនាំមករឿយៗ នូវពាក្យនិន្ទា ឬបាននូវពាក្យសរសើរ ព្រោះទិដ្ឋិរបស់ខ្លួននោះដែរឬ ។ ( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) ផលនៃវាទៈ គឺសេចក្ដីសរសើរនុ៎ះ មានបន្តិចបន្តួចទេ មិនគួរដើម្បីសេចក្ដីស្ងប់រម្ងាប់ ( រាគៈជាដើម ) បានឡើយ តថាគតពោលនូវផលនៃការជជែកគ្នា ព្រោះទិដ្ឋិមានពីរប្រការ គឺនិន្ទា និងសរសើរ ចំណែកជនជាបណ្ឌិតឃើញទោស ក្នុងកាជជែកគ្នានុ៎ះហើយ ឃើញច្បាស់នូវព្រះនិព្វាន ជាភូមិមិនទាស់ទែងគ្នា ថាជាទីដ៏ក្សេមក្សាន្ត ទើបមិនទាស់ទែងគ្នា ។ ទិដ្ឋិទាំងឡាយឯណាមួយ ដែលកើតច្រើន អ្នកប្រាជ្ញរមែងមិនប្រកាន់នូវទិដ្ឋិទាំងនុ៎ះ បើលោកមិនមានសេចក្ដីប្រកាន់ ( នូវទិដ្ឋិ ) មិនធ្វើសេចក្ដីស្រឡាញ់ អារម្មណ៍ដែលឃើញហើយ ឮហើយ ធ្វើម្ដេចឡើយ នឹងប្រកាន់នូវអារម្មណ៍ ដែលគួរប្រកាន់ ។ សមណព្រាហ្មណ៍ពួកមួយប្រកាន់ ពោលថា សីលជាគុណដ៏ខ្ពង់ខ្ពស់ ហើយសម្ដែងនូវសេចក្ដីបរិសុទ្ធ ដោយគុណត្រឹមតែការសង្រួម ជនទាំងឡាយនោះ សមាទាននូវវត្ត ហើយប្រកាន់មាំ ( ក្នុងវត្តដែល

ខ្លួនសមាទាននោះ ) ដោយគិតឃើញថា យើងទាំងឡាយនឹងសិក្សានូវសេចក្តីបរិសុទ្ធរបស់វត្តនោះ ក្នុងទិដ្ឋិរបស់ខ្លួននេះតែម្យ៉ាង ព្រោះជនទាំងឡាយនោះ មានភព គឺកម្មនាំចូលទៅជិតហើយ តែងពោលនូវខ្លួនថា ជាអ្នកឈ្លាស ។ បើបុគ្គលណាឃ្លាតចាកសីល និងវត្តហើយ បុគ្គលនោះ រមែងញាប់ញ័រព្រោះខុសចាកកម្ម បុគ្គលនោះឯង តែងចង់បានផង ប្រាថ្នាផងនូវសេចក្តីបរិសុទ្ធ ដូចបុគ្គល កាលព្រាត់ប្រាសចាកផ្ទះហើយ សាបសូន្យចាកពួក ។ មួយទៀត អរិយសាវក លះបង់សីលនិងវត្ត ( ដ៏បរិសុទ្ធ ) ទាំងអស់ផង កម្មមានទោសផង មិនមានទោសនុ៎ះផង ចេញហើយ មិនប្រាថ្នានូវសេចក្តីបរិសុទ្ធនិងសេចក្តីមិនបរិសុទ្ធផង ឈ្មោះថា ជាអ្នកវៀរស្រឡះ ព្រោះមិនប្រកាន់នូវទិដ្ឋិ ។ មានសមណព្រាហ្មណ៍ពួកមួយ តែងអាស្រ័យទិដ្ឋិនោះ ដែលគួរខ្ពើម មួយទៀត តែងអាស្រ័យទិដ្ឋិ ( សេចក្តីយល់ឃើញ ) ថាបរិសុទ្ធ ព្រោះឃើញបរិសុទ្ធព្រោះស្តាប់បរិសុទ្ធ ព្រោះពាល់ត្រូវ ជាឧទ្ធំសរវាទ ជាអ្នកមានតណ្ហាក្នុងភពតូច ភពធំ មិនទាន់ទៅប្រាស រមែងពោលនូវសេចក្តីបរិសុទ្ធ ។ ជប្បនៈ គឺតណ្ហាទាំងឡាយ ក៏កើតឡើងដល់បុគ្គលអ្នកប្រាថ្នា ឬសេចក្តីរន្ធត់ញាប់ញ័រ ក៏កើតឡើងក្នុងធម៌ទាំងឡាយ ដែលខ្លួនកំណត់ហើយ ការច្យុត និងការកើតឡើង

របស់បុគ្គលណា មិនមានក្នុងលោកនេះ បុគ្គលនោះ គប្បីញាប់ញ័រដោយហេតុអ្វី គប្បីប្រាថ្នាក្នុងអ្វីទៀត ។ ( ព្រះពុទ្ធនិម្មិតសួរថា ) សមណព្រាហ្មណ៍ពួកមួយ បាននិយាយធម៌ណាថា ជាធម៌ដ៏ឧត្តម សមណព្រាហ្មណ៍ពួកឯទៀត បាននិយាយធម៌នោះថា ជាធម៌ថោកទាបវិញ ចុះពាក្យរបស់សមណព្រាហ្មណ៍ទាំងពីរពួក តើពាក្យណាជាពាក្យពិតត្រង់ ព្រោះសមណព្រាហ្មណ៍ទាំងអស់នេះ តែងពោលលើកខ្លួន ថាជាអ្នកឈ្លាស ។ ( ព្រះសម្ពុទ្ធត្រាស់ថា ) សមណព្រាហ្មណ៍ពួកមួយ បានពោលធម៌របស់ខ្លួនថា ជាធម៌បរិបូណ៌ ( ល្អពេញទី ) ពោលធម៌របស់ជនដទៃ ថាជាធម៌ថោកទាប សមណព្រាហ្មណ៍ទាំងឡាយប្រកាន់យ៉ាងនេះ រមែងបង្កជម្លោះឲ្យកើតឡើង បានសរសើរទិដ្ឋិរបស់ខ្លួនៗ ថាជាធម៌ពិត ។ បើបុគ្គលនោះ នឹងទៅជាអ្នកថោកទាប ព្រោះដំនៀលរបស់បុគ្គលដទៃ មិនមានអ្នកណាមួយដែលវិសេស ក្នុងធម៌ទាំងឡាយបានទេ ព្រោះថា បុគ្គលច្រើននាក់ ជាអ្នកប្រកាន់មាំក្នុងធម៌របស់ខ្លួន តែងតិះដៀលធម៌របស់ជនដទៃ ថាជាធម៌ថោកទាប ។ ជនទាំងឡាយ តែងសរសើរនូវផ្លូវ ជាគ្រឿងប្រព្រឹត្តទៅនៃសេចក្តីប្រតិបត្តិ គឺធម៌របស់ខ្លួនយ៉ាងណា ការបូជាធម៌របស់ខ្លួន ក៏យ៉ាងនោះ ( កាលបើយ៉ាងនេះ ) ពាក្យទាំងពួង គប្បីជារបស់ពិតមែន សេចក្តីបរិសុទ្ធ

នឹងមានចំពោះខ្លួន នៃសមណព្រាហ្មណ៍ទាំងនោះពិត ។ ញាណ ដែលបុគ្គលដទៃគប្បីដឹកនាំ និងសេចក្តីប្រកាន់ ព្រោះវិនិច្ឆ័យ ក្នុងទិដ្ឋិធម៌ទាំងឡាយ មិនមានដល់ខីណាសវព្រាហ្មណ៍ ព្រោះ ហេតុនោះ ខីណាសវព្រាហ្មណ៍នោះ ទើបឆ្លងពាក្យវិវាទទាំង- ឡាយបាន ទាំងមិនយល់ឃើញធម៌ដទៃថា ប្រសើរទេ ។ សមណព្រាហ្មណ៍ពួកមួយ ពោលអាងបរិសុទ្ធដោយទិដ្ឋិថា ខ្ញុំ ដឹង ខ្ញុំឃើញរបស់នុ៎ះពិតមែន បើទុកជាមានសមណព្រាហ្មណ៍ ខ្លះ បានឃើញដោយបរចិត្តញាណជាដើម នឹងមានប្រយោជន៍អ្វី ដោយការឃើញរបស់សមណព្រាហ្មណ៍នោះ ( បានជា ) ពួក សមណព្រាហ្មណ៍ខ្លះ កន្លង ( នូវអរិយមគ្គ ) ហើយសម្តែង នូវសេចក្តីបរិសុទ្ធ ដោយឧបាយដទៃវិញ ។ នរជនកាល ឃើញ រមែងឃើញតែនាមរូប លុះឃើញហើយ រមែងដឹងនូវ នាមរូបនោះប៉ុណ្ណោះ កាលបើឃើញដោយវិបល្លាសសញ្ញា យ៉ាងនេះ ចង់ឃើញច្រើន ឬតិចក៏ដោយ អ្នកប្រាជ្ញទាំងឡាយ មិនពោលនូវសេចក្តីបរិសុទ្ធ ដោយការឃើញត្រឹមប៉ុណ្ណោះទេ ។ បុគ្គលអ្នកពោលប្រកាន់មាំ មិនងាយគេប្រដៅបានទេ បុគ្គល អ្នកធ្វើទិដ្ឋិ ដែលខ្លួនកំណត់ហើយ ឲ្យជាប្រធាន អាស្រ័យនូវ សាស្តាណា រមែងជាអ្នកពោលសរសើរថា ល្អក្នុងសាសនា នោះ បុគ្គលនោះ ជាអ្នកពោលនូវសេចក្តីបរិសុទ្ធ បានឃើញថា

ជាធម៌ពិត ក្នុងវាទៈរបស់សាសនានោះ ។ ខីណាសវព្រាហ្មណ៍ ដឹងច្បាស់ ( នូវសង្ខារធម៌ទាំងពួង ) រមែងមិនប្រកាន់នូវការកំណត់ ដោយតណ្ហា និងទិដ្ឋិ ជាអ្នកមិនប្រព្រឹត្តទៅក្នុងទិដ្ឋិ ទាំងមិនមានផៅពង្ស គឺតណ្ហា និងទិដ្ឋិ ដោយមិច្ឆាញាណទេ មួយទៀត ខីណាសវព្រាហ្មណ៍នោះ បានដឹងហើយនូវទិដ្ឋិទាំងឡាយ ដែលកើតហើយអំពីជនច្រើននាក់ ក៏ព្រងើយកន្តើយ គឺមិនប្រកាន់មាំ ដោយអំណាចតណ្ហា និងទិដ្ឋិ ចំណែកជនទាំងឡាយដទៃ រមែងប្រកាន់ស្អិត ។ អ្នកប្រាជ្ញក្នុងលោកនេះ លះបង់នូវកិលេសគ្រឿងចងក្រង កាលជនទាំងឡាយ មានការទាស់ទែងកើតហើយ លោកជាអ្នកមិនប្រព្រឹត្តជាពួក កាលជនទាំងឡាយមិនស្ងប់ លោកជាអ្នកស្ងប់ លោកជាអ្នកព្រងើយកន្តើយ មិនប្រកាន់ ចំណែកជនទាំងឡាយដទៃ រមែងប្រកាន់ស្អិត ។ ខីណាសវព្រាហ្មណ៍ លះបង់នូវអាសវៈមុន មិនធ្វើអាសវៈថ្មី ជាអ្នកមិនលុះក្នុងឆន្ទាគតិ ( ជាដើម ) ទាំងមិនចរចាតាមសេចក្តីប្រកាន់ស្អិត ខីណាសវព្រាហ្មណ៍នោះ ជាអ្នកប្រាជ្ញ រួចស្រឡះចាកទិដ្ឋិទាំងឡាយ ជាអ្នកមិនតិះដៀលខ្លួនឯង មិនជាប់នៅក្នុងលោក ។ ខីណាសវព្រាហ្មណ៍នោះ លោកជាអ្នកមិនមានមារសេនាក្នុងធម៌ទាំងពួង មិនមានមារសេនាក្នុងអារម្មណ៍ណាមួយ ដែលឃើញហើយ ឮហើយ ប៉ះពាល់ហើយ ខីណា-

សព្វព្រាហ្មណ៍នោះ ជាអ្នកប្រាជ្ញ មានភារៈដាក់ចុះហើយ រួចស្រឡះចាកកាតាទិក្កិលេស មិនមានគ្រឿងកំណត់ដោយតណ្ហា និងទិដ្ឋិ មិនត្រេកអរ មិនមានកិលេសជាតិ គ្រឿងប្រាថ្នាឡើយ ។

**មហាវិយូហសូត្រទី ១៣ ចប់**

# អដ្ឋកថា

## មហាវិយូហសូត្រ

[ ១០៧ ] ក្នុងមហាវិយូហសូត្រទី ១៣ មានពាក្យផ្ដើមថា **យេ កេចិមេ** ដូច្នេះ សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅនេះ

ក្នុងមហាសម័យនោះដូចគ្នា ព្រះមានព្រះភាគត្រាស់ព្រះសូត្រនេះ ពួកទេវតាពួកខ្លះ មានចិត្តកើតឡើងថា បុគ្គលទាំងនេះ ប្រកាន់មាំក្នុងទិដ្ឋិ រមែងបានទទួលការនិន្ទាតែម្យ៉ាងឬហ្ន៎ ឬបានទទួលការសរសើរផងដែរ អំពីសម្នាក់វិញ្ញូជនទាំងឡាយ ព្រះមានព្រះភាគ ក៏ត្រាស់ព្រះសូត្រនេះ ដើម្បីធ្វើឲ្យជាក់ច្បាស់ក្នុងរឿងនោះ ទ្រង់ឲ្យពុទ្ធនិម្មិតសួរទ្រង់ដោយន័យមុននោះឯង ។

ក្នុងបទទាំងនោះ បទថា **អន្វានយន្តិ** បានដល់ នាំមករឿយៗ គឺនាំមករឿយៗ ។ ព្រោះបុគ្គលមានវាទៈជាម្ចាស់លទ្ធិទាំងនោះ ពោលថា វត្ថុនេះប៉ុណ្ណោះពិត ជួនកាល ក៏បាននូវការសរសើរខ្លះ ផលនៃវាទៈដែលបានដល់

ការសរសើរនោះតិចតួចណាស់ មិនអាចស្ងប់រាគៈជាដើមបាន នឹងពោលថ្វី ដល់ផលនៃការនិន្ទាទី ២ ដូច្នោះ កាលព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនេះ ទើបត្រាស់គាថានេះឆ្លើយជាបឋមថា **ឧភេ វិវាទស្ស ផលានិ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឧភេ វិវាទស្ស ផលានិ** បានដល់ ការនិន្ទា និងការសរសើរ ឬបានដល់ ការឈ្នះ និងការចាញ់ជាដើម ដែលជាចំណែកពួកតែមួយជាមួយការសរសើរ និងការនិន្ទានោះ ។

បទថា **ឯតម្បិ ទិស្វា** សេចក្តីថា ឃើញនូវទោសក្នុងផលនៃវិវាទយ៉ាងនេះថា ការនិន្ទាដែលជាវត្ថុមិនគួរប្រាថ្នា ការសរសើរ មិនអាចនាំទៅកាន់ការស្ងប់ ។ បទថា **ខេមាភិបស្សំ អវិវាទភូមឹ** បានដល់ ឃើញនិព្វានដែលជាភូមិនៃការមិនទាស់ទែងថា ជាធម៌ក្សេម ។ កាលមិនវិវាទយ៉ាងនេះ គប្បីជ្រាបគាថាជាបន្តថា **យា កាចិមា** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **សម្មុតិយោ** បានដល់ ទិដ្ឋិ ។ បទថា **បុថុជ្ជា** បានដល់ កើតអំពីបុគ្គលមានកិលេសក្រាស់ ។ បទថា **សោ ឧបយំ កិមេយ្យ** សេចក្តីថា បណ្ឌិតនោះគប្បីដល់នូវធម៌ជាគ្រឿងចូលជិត ដោយអត្ថថា គប្បីចូលដល់ គឺគប្បីដល់ធម៌ណាមួយ ក្នុងរូបជាដើម ដែលគួរចូលទៅជិត ឬគប្បីចូលដល់ដោយហេតុដូចម្តេច ។ បទថា **ទិដ្ឋេ សុតេ ខន្តិមកុព្វមានោ** បានដល់ មិនធ្វើនូវការគាប់ចិត្តក្នុងសេចក្តីបរិសុទ្ធក្នុងរូប ដែលបានឃើញក្នុងសំឡេងដែលបានស្តាប់ជាដើម ។ ក្រៅអំពីនេះ គួរជ្រាបគាថាថា **សីលុត្តមា** ជាដើមដូចតទៅនេះថា

បទនោះ មានសេចក្តីដូច្នេះថា ជនពួកខ្លះមានសីលឧត្តម សម្គាល់ថា សីលប៉ុណ្ណោះជាធម៌ឧត្តម ទើបពោលថា លោកដ៏ចម្រើនទាំងឡាយ សេចក្តីបរិសុទ្ធ រមែងមានដោយត្រឹមតែការសង្រួមប៉ុណ្ណោះ ម្យ៉ាងទៀត ជនទាំងនោះសមាទានវត្ត មានហត្ថីវត្ត ( ប្រព្រឹត្តវត្តដូចសត្វដំរី ) ជាដើម តាំងមាំដោយគិតថា សេចក្តីបរិសុទ្ធរបស់សាស្តានោះ មានក្នុងទិដ្ឋិប៉ុណ្ណោះ ត្រូវនាំចូលទៅកាន់ភព លិចទៅក្នុងភព នៅតែពោលថា យើងជាអ្នកឈ្លាស ។ បណ្តាអ្នកមានសីលឧត្តមណាមួយ បដិបត្តិយ៉ាងនោះ គប្បីជ្រាបគាថាថា **សចេ ចុតោ** ដូចតទៅនេះថា

បទនោះ មានសេចក្តីដូច្នេះ បើបុគ្គលជាអ្នកឃ្លាតចាកសីល និងវត្តនោះ ដោយការកាត់សម្រេចរបស់អ្នកដទៃ ឬមិនសម្រេច បុគ្គលនោះ ញុំាងកម្មមានសីល និងវត្តជាដើម ឬកម្ម គឺបុញ្ញាភិសង្ខារឲ្យខុសហើយ ក៏ញាប់ញ័រមិនមែនញាប់ញ័រតែម្យ៉ាងទេ ដែលពិត គង់ស្រែក កន្ទក់កន្ទេញ ប្រាថ្នាសេចក្តីបរិសុទ្ធ គឺសីល និងវត្តនោះ ។ ដូចអ្វី ដូចបុគ្គល កាលព្រាត់ប្រាសចាកផ្ទះហើយសាបសូន្យចាកពួក ដូច្នោះ មានអធិប្បាយថា ដូចបុគ្គលដែលចេញចាកផ្ទះ ទៅមិនទាន់ពួក ចង់ត្រឡប់មកផ្ទះនោះ ឬចង់ទៅឲ្យទាន់ពួក ដូច្នោះ ។ កាលប្រកាន់មាំក្នុងសីល និងវត្ត ជាហេតុឲ្យញាប់ញ័រយ៉ាងនេះ ទើបមានគាថាថា អរិយសាវក លះបង់សីល និងវត្ត ( ដ៏បរិសុទ្ធ ) ទាំងអស់ផង កម្មមានទោសផង មិនមានទោសទុំះផង ចេញហើយ ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **សាវជ្ជនវជ្ជំ** បានដល់ កុសលទាំងពួង និង

លោកិយកុសល ។ បទថា **ឯតំ សុទ្ធិ អសុទ្ធិតិ អបត្ថយានោ** បានដល់ មិនប្រាថ្នាសេចក្ដីបរិសុទ្ធ មានកាមគុណ ៥ ជាដើម និងការមិនបរិសុទ្ធ មានអកុសលជាដើម ។ បទថា **វិរតោ ចរេ** បានដល់ វៀរហើយចាកសេចក្ដីបរិសុទ្ធ និងមិនបរិសុទ្ធត្រាច់ទៅ ។ បទថា **សន្តិមនុគ្គហាយ** បានដល់ មិនប្រកាន់មាំក្នុងទិដ្ឋិ ។ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងការបង្អៀតបង្អល់របស់សមណព្រាហ្មណ៍ក្នុងវាទៈថា បរិសុទ្ធដោយការសង្រួមក្នុងសីលដ៏ឧត្តមខាងក្រៅចាកសាសនានោះ និងកិច្ចបដិបត្តិរបស់ព្រះអរហន្ត ដែលលះសីលនិងវត្តយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងដល់សមណព្រាហ្មណ៍ខាងក្រៅ ដែលមានវាទៈបរិសុទ្ធដោយប្រការដទៃ ទើបត្រាស់គាថាថា **តមូបនិស្សាយ** ដូច្នេះជាដើម ។

បទនោះ មានសេចក្ដីដូចតទៅនេះ សមណព្រាហ្មណ៍ទាំងឡាយពួកដទៃអាស្រ័យការខ្ពើមបាប និងតបៈមិនពិតប្រាកដ ( អមរាតប ) ឯណាមួយក្នុងទិដ្ឋិថាបរិសុទ្ធជាដើម ឬជាបុគ្គលវេញកហួសក្នុងអកិរិយទិដ្ឋិ គង់មិនប្រាសចាកតណ្ហាក្នុងភពតូច និងភពធំ ហើយរមែងរួញរា គឺពោលដល់សេចក្ដីបរិសុទ្ធ អធិប្បាយថា កាលសមណព្រាហ្មណ៍ទាំងនោះ មិនទាន់ប្រាសចាកតណ្ហា រួញរាដល់សេចក្ដីបរិសុទ្ធ បុគ្គលណាសម្គាល់ខ្លួនថា ជាអ្នកដល់សេចក្ដីបរិសុទ្ធ ព្រោះមិនទាន់ប្រាសចាកតណ្ហា បុគ្គលនោះ នៅមានសេចក្ដីប្រាថ្នាវត្ថុនោះៗ ក្នុងភពតូច និងភពធំ គង់មានការអន្ទះអន្ទែងរឿយៗនោះឯង ។ ព្រោះតណ្ហាដែលបុគ្គលសេពជាប្រចាំហើយ ធ្វើឲ្យតណ្ហាចម្រើនច្រើនឡើង

នោះឯងនិងមិនមែនការអន្ទះអន្ទែងតែម្យ៉ាង ការញាប់ញ័រគង់មានក្នុងវត្ថុដែលខ្លួនកំណត់ទៀតផង ។ លោកអធិប្បាយថា តណ្ហា និងទិដ្ឋិ ឬការញាប់ញ័រក្នុងវត្ថុដែលខ្លួនកំណត់ រមែងមានដល់បុគ្គលនោះ ។ ព្រោះជាបុគ្គលប្រាសចាកតណ្ហាក្នុងភព និងមិនមែនភពហើយ ការចុតិ និងបដិសន្ធិតទៅ ក្នុងភពនេះ រមែងមិនមានដល់បុគ្គលណា បុគ្គលនោះ គប្បីញាប់ញ័រ ព្រោះហេតុអ្វី គប្បីអន្ទះអន្ទែងក្នុងអារម្មណ៍ណាកើត ។ នេះជាការភ្ជាប់សេចក្ដីនៃគាថានេះ ។ បទដ៏សេស មានន័យដូចពោលហើយក្នុង ( មហា ) និទ្ទេសនោះឯង ។

បទថា **យមាហុ** ជាគាថាសួរ ។

ព្រោះមិនមានវាទៈដែលពិត សូម្បីវាទៈតែមួយក្នុងសមណព្រាហ្មណ៍នេះ ដ្បិតថា សមណព្រាហ្មណ៍ទាំងនេះ ពោលត្រឹមតែទិដ្ឋិតែម្យ៉ាង ដូច្នោះឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងនូវការឃើញ ទើបត្រាស់គាថានេះថា **សកញ្ហិ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **សកំ** បានដល់ ទិដ្ឋិរបស់ខ្លួន ។ សម្រាប់បុគ្គលដែលពោលថា កាលសមណព្រាហ្មណ៍ទាំងនេះ ពោលធម៌របស់ខ្លួនថាបរិបូណ៌ ពោលធម៌របស់អ្នកដទៃថាអាក្រក់ ។ គប្បីជ្រាបគាថាថា **បរស្ស ចេ វម្ភយិតេន ហីនោ** ដូចតទៅនេះ

គាថានោះ មានសេចក្ដីដូច្នេះថា បើបុគ្គលនោះ គប្បីជាអ្នកថោកទាបព្រោះហេតុដែលអ្នកដទៃតិះដៀល បុគ្គលណាម្នាក់ ក៏មិនគប្បីជាអ្នកវិសេសគឺក្រៃលែងក្នុងធម៌ទាំងឡាយ ។ ព្រោះអ្វី ព្រោះថា បុគ្គលច្រើននាក់ ជាអ្នក

ប្រកាន់មាំក្នុងធម៌របស់ខ្លួន តែងតិះដៀលធម៌របស់ជនដទៃ ថាជាធម៌ថោកទាប គឺសមណព្រាហ្មណ៍ទាំងអស់នោះ ពោលវាទៈថាមាំទាំក្នុងធម៌របស់ខ្លួន គឺពោលយ៉ាងធ្ងន់ក្នុងធម៌របស់ខ្លួន ។ មានគាថាតទៅទៀតថា **សធម្មបូជា** ជាដើម ។

គាថានោះ មានសេចក្ដីដូច្នេះថា ពួកតិរ្ថិយទាំងនោះ សរសើរផ្លូវជាគ្រឿងយឺតយូររបស់ខ្លួន យ៉ាងណា សូម្បីការបូជាធម៌របស់ខ្លួននៃតិរ្ថិយទាំងនោះ ក៏ប្រព្រឹត្តទៅយ៉ាងនោះ ព្រោះថា ពួកតិរ្ថិយទាំងនោះ រមែងគោរពសាស្ដាជាដើមក្រៃពេក ក្នុងសេចក្ដីនោះ បើការបូជាធម៌របស់ខ្លួនគប្បីជាប្រមាណដល់ពួកតិរ្ថិយទាំងនោះ កាលបើដូច្នោះ វាទៈទាំងអស់ក៏គប្បីជារបស់ពិត ។ ព្រោះអ្វី ព្រោះថា សេចក្ដីបរិសុទ្ធនឹងមានចំពោះខ្លួននៃសមណព្រាហ្មណ៍ទាំងនោះពិត សេចក្ដីបរិសុទ្ធនោះ រមែងមិនសម្រេចក្នុងទីដទៃ ដោយបរមត្ថក៏មិនសម្រេច សេចក្ដីពិត ពាក្យនោះ ត្រឹមតែជាការកាន់យកតាមទិដ្ឋិខ្លួនប៉ុណ្ណោះ របស់បុគ្គលដែលដឹងវត្ថុ ដែលជាបច្ច័យដទៃគប្បីនាំទៅទាំងនោះ ។ តែបុគ្គលណាឃើញខុសថា ឈ្មោះថា ជាព្រាហ្មណ៍ ព្រោះបន្សាត់បាប មានគាថាសម្រាប់បុគ្គលនោះដូចតទៅនេះ **ន ព្រាហ្មណស្ស បរនេយ្យមត្ថិ** ដូច្នេះជាដើម ។

គាថានោះ មានសេចក្ដីដូច្នេះថា ញាណដែលត្រូវជឿអ្នកដទៃ រមែងមិនមានដល់ព្រាហ្មណ៍ ព្រោះឃើញប្រពៃហើយ ដោយន័យជាដើមថា សង្ខារទាំងឡាយទាំងពួងមិនទៀង ។ ការវិនិច្ឆ័យក្នុងធម៌ គឺទិដ្ឋិទាំងឡាយថា សេចក្ដីនេះប៉ុណ្ណោះពិត ដូច្នេះហើយ ប្រកាន់ទុកមិនមានដល់ព្រាហ្មណ៍ ។ ព្រោះអ្វី

ព្រោះថា ព្រាហ្មណ៍នោះ កន្លងនូវវិវាទព្រោះទិដ្ឋិចេញបាន ម្យ៉ាងទៀត ព្រាហ្មណ៍នោះ មិនឃើញធម៌ដទៃ ក្រៅអំពីសតិប្បដ្ឋានជាដើម ដោយភាពជាធម៌ប្រសើរឡើយ ។

គប្បីជ្រាបការភ្ជាប់ និងសេចក្តីនៃគាថាថា **ជានាមិ** ដូចតទៅនេះ

គប្បីជ្រាបយ៉ាងនេះមុនថា ពិតហើយ ព្រាហ្មណ៍ជាន់ខ្ពស់ រមែងមិនឃើញធម៌ដទៃ ដោយភាពជាធម៌ប្រសើរឡើយ តែពួកតិរ្ថិយដឹង ឃើញដោយបរចិត្តញ្ញាណជាដើម ទោះពោលថា ខ្ញុំដឹង ខ្ញុំឃើញ វត្ថុដែលខ្ញុំដឹងខ្ញុំឃើញនេះ យ៉ាងនោះឯង ហើយជឿសេចក្តីបរិសុទ្ធដោយទិដ្ឋិ ។ ព្រោះហេតុអ្វី ព្រោះបើតិរ្ថិយទាំងនោះណាមួយ បើបានឃើញ គឺបើបានឃើញតាមសេចក្តីពិត ដោយបរចិត្តញ្ញាណជាដើមនោះ ការឃើញនោះ នឹងមានប្រយោជន៍អ្វីដល់ខ្លួន គឺការឃើញនោះធ្វើអ្វីបាន ការកំណត់ដឹងទុក្ខសម្រេចហើយឬ ឬការលះហេតុឲ្យកើតទុក្ខណាមួយសម្រេចហើយ ព្រោះតិរ្ថិយទាំង-ឡាយនោះ ឈានកន្លងអរិយមគ្គ ដោយប្រការទាំងពួងហើយ តែងពោលសេចក្តីបរិសុទ្ធដោយធម៌ដទៃ ឬព្រះពុទ្ធជាដើម ឈានកន្លងតិរ្ថិយទាំងនោះបានហើយ រមែងពោលការបរិសុទ្ធដោយធម៌ដទៃ ។

គប្បីជ្រាបការភ្ជាប់ និងអត្ថនៃគាថាថា **បស្សំ នរោ** ដូច្នេះជាដើមដូចតទៅ នរជនណាបានឃើញដោយបរចិត្តញ្ញាណហើយ នរជននោះ កាលឃើញ រមែងឃើញនាមរូប បន្ទាប់អំពីនោះ កាលឃើញហើយ នឹងដឹងទូទៅដល់នាមរូបទាំងនោះ ដោយភាពជារបស់ទៀង ឬដោយភាពជាសុខ និងមិន

ដឹងដោយប្រការដទៃ ។ នរជននោះ កាលឃើញយ៉ាងនេះ នឹងឃើញនាមរូបច្រើន ឬតិច ដោយភាពជារបស់ទៀង និងដោយភាពជាសុខក៏ពិត តែអ្នកប្រាជ្ញទាំងឡាយ មិនពោលសេចក្តីបរិសុទ្ធដោយការឃើញបែបនោះ របស់បុគ្គលនោះឡើយ ។

គប្បីជ្រាបការភ្ជាប់ និងអត្ថនៃគាថាថា **និវិស្សវាទី** ជាដើមដូចតទៅ កាលមិនមានសេចក្តីបរិសុទ្ធ ដោយការឃើញនោះ បុគ្គលណា មានវាទៈយ៉ាងនេះថា ខ្ញុំដឹង ខ្ញុំឃើញ វត្ថុដែលខ្ញុំដឹង ខ្ញុំឃើញនោះ យ៉ាងនោះឯងអាស្រ័យការឃើញយ៉ាងនោះ ទើបជឿនូវសេចក្តីបរិសុទ្ធដោយការឃើញ ជាអ្នកមានវាទៈយ៉ាងនេះថា វត្ថុនេះប៉ុណ្ណោះពិត បុគ្គលនោះ មិនមែនទូន្មានបានងាយឡើយ ជនអ្នកធ្វើទិដ្ឋិដែលខ្លួនកំណត់ គឺតាក់តែងខាងមុខ យ៉ាងនោះបុគ្គលនោះ អាស្រ័យសាស្តាណាហើយ ក៏ជាអ្នកពោលដល់សេចក្តីល្អក្នុងសាស្តានោះ សម្គាល់ខ្លួនថា អាត្មាអញជាអ្នកពោលសេចក្តីបរិសុទ្ធ ជាអ្នកពោលសេចក្តីផូរផង់ ឬជាអ្នកឃើញការបរិសុទ្ធ ។ បទថា **តត្ថ តថទ្ទសា សោ** សេចក្តីថា បានឃើញការមិនវិបរិតក្នុងទិដ្ឋិរបស់ខ្លួននោះ អធិប្បាយថា បានឃើញការពិតនោះ ដោយប្រការដែលទិដ្ឋិនោះនៅប្រព្រឹត្តទៅ មិនប្រាថ្នានឹងឃើញដោយប្រការដទៃ ។ កាលពួកតិរ្ថិយធ្វើទិដ្ឋិដែលខ្លួនកំណត់យ៉ាងនេះខាងមុខគប្បីជ្រាបគាថាជាបន្តថា ទីណាសវព្រាហ្មណ៍ដឹងច្បាស់ ( នូវសង្ខារធម៌ទាំងពួង ) រមែងមិនប្រកាន់នូវការកំណត់ដោយតណ្ហា និងទិដ្ឋិ ។

ក្នុងបទទាំងនោះ បទថា **សង្ខាំ** បានដល់ ជ្រាប អធិប្បាយថា ដឹង ។

បទថា **ឆបិ ញាណាតន្ទុ** សេចក្ដីថា មិនធ្វើចំណងតណ្ហា និងទិដ្ឋិ ដោយសមាបត្តិញាណជាដើម ។ ក្នុងបទនោះមានវិគ្គហៈថា គ្រឿងចងដែលធ្វើដោយញាណរបស់បុគ្គលនោះមិនមាន ហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា មិនមានចំណងដោយញាណ ។ បទថា **សម្មតិយោ** បានដល់ ទិដ្ឋិដែលបុគ្គលបណ្ដុះឡើង ។ បទថា **បុថុជ្ជា** គឺមានច្រើន ។ បទថា **ឧគ្គហា-ណាន្តិមញ្ញេ** បានដល់ អ្នកដទៃរមែងប្រកាន់ អធិប្បាយថា បុគ្គលដទៃរមែងកាន់យកសម្មតិទាំងនោះ ។ មានអ្វីក្រៃលែងជាងនោះ មានគាថាថា **វិសជ្ជ គន្ថានិ** ដូច្នេះជាដើម ។

ក្នុងគាថានោះ បទថា **អនុគ្គហោ** បានដល់ វៀរចាកការប្រកាន់ ឈ្មោះថា **អនុគ្គហោ** ព្រោះមិនមានការប្រកាន់ ឬមិនប្រកាន់មាំ ។ មានអ្វីក្រៃលែងជាងនោះ មានគាថាថា **បុព្វាសវេ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **បុព្វាសវេ** បានដល់ កិលេសកើតឡើងព្រោះប្រារព្ធរូបក្នុងអតីតជាដើម ។ បទថា **នវេ** បានដល់ កិលេសកើតឡើងប្រារព្ធរូបក្នុងបច្ចុប្បន្នជាដើម ។ បទថា **ន ឆន្ទគូ** គឺមិនលម្អៀងព្រោះការពេញចិត្ត ។ បទថា **អនត្តគរហី** បានដល់ មុនីមិនតិះដៀលខ្លួនដោយការធ្វើនិងមិនធ្វើ ។ មុនីមិនតិះដៀលខ្លួនយ៉ាងនេះ មានគាថាបន្ទថា **ស សព្វធម្មេសុ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ស សព្វធម្មេសុ** បានដល់ ក្នុងធម៌ដែលមានប្រភេទយ៉ាងនេះថា ធម៌ណាមួយក្នុងធម៌ គឺទិដ្ឋិ ៦២ ។ បទថា **បណ្ណភារោ**

បានដល់ ដាក់ភារៈចុះហើយ ជាអ្នកមិនមានគ្រឿងកំណត់ ព្រោះមិនកំណត់ អធិប្បាយថា មិនធ្វើគ្រឿងកំណត់ ២ យ៉ាង ។ បទថា **ឆូបរតោ** បានដល់ មិនចូលទៅប្រឡូកប្រឡំ ដូចបុថុជ្ជន កល្យាណបុថុជ្ជន និងព្រះថេរៈ ។ បទថា **ន បត្ថិយោ** បានដល់ មិនមានតណ្ហា ។ តណ្ហាជាហេតុឲ្យសត្វប្រាថ្នា ព្រោះហេតុនោះ ទើបតណ្ហានោះ ឈ្មោះថា ជាហេតុឲ្យប្រាថ្នា ។ ឈ្មោះថា **ន បត្ថិយោ** ព្រោះតណ្ហាជាហេតុឲ្យប្រាថ្នាមិនមាន ។ បទដ៏សេស មានអធិប្បាយជាក់ច្បាស់ហើយក្នុងទីផ្សេងៗ ។ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ចប់ទេសនាដោយធម៌ដ៏កំពូល គឺអរហត្ត ដោយប្រការដូច្នេះ ។

**អដ្ឋកថាមហាវិយូហសូត្រទី ១៣ ចប់**

# សុត្តន្តបិដក

## តុវដកសូត្រទី ១៤

[ ១០៨ ] ( ព្រះពុទ្ធនិម្មិតសួរថា ) ខ្ញុំសូមសួរនូវសេចក្តីស្ងាត់ផង នូវចំណែកនៃសេចក្តីស្ងប់ផង នឹងព្រះអង្គ ជាផៅពង្សនៃព្រះអាទិត្យ អ្នកស្វែងរកគុណដ៏ធំ ចុះភិក្ខុឃើញដោយប្រការដូចម្តេច មិនប្រកាន់មាំនូវអ្វីមួយក្នុងលោក ទើបរម្ងាត់កិលេសបាន ។ ( ព្រះមានព្រះភាគទ្រង់ត្រាស់តបថា ) ភិក្ខុគប្បីបិទនូវឫស នៃបបញ្ចសង្ខារ ( ធម៌ជាគ្រឿងធ្វើសត្វឲ្យយឺតយូរ គឺតណ្ហា ទិដ្ឋិ ) ផង នូវអស្មិមានះទាំងពួងផង ដោយប្រាជ្ញា តណ្ហាទាំងឡាយណាមួយ មានខាងក្នុងសន្តានសត្វ ភិក្ខុជាអ្នកមានស្មារតីគ្រប់ពេល គប្បីសិក្សា ដើម្បីកម្ចាត់បង់តណ្ហាទាំងនោះចេញ ។ ភិក្ខុគប្បីដឹងនូវគុណធម៌ណាមួយ ជាខាងក្នុង ឬខាងក្រៅ មិនគប្បីធ្វើនូវកម្លាំង ( ការលើកតម្កើង ) ដោយគុណធម៌នោះ ព្រោះការរម្ងាត់នោះ សប្បុរសទាំងឡាយមិនបានប្រកាសឡើយ ។ ភិក្ខុមិនគប្បីសម្គាល់ថា អញជាបុគ្គលប្រសើរជាងគេ អញជាបុគ្គលថោកទាបជាងគេ ឬថាជាបុគ្គលស្មើៗ នឹងគេ ដោយសារគុណធម៌នោះឡើយ ។ ភិក្ខុប្រកបដោយគុណធម៌ មានសភាពច្រើនយ៉ាង មិនគប្បីតាំងខ្លួន តម្កើងខ្លួនទេ ។ ភិក្ខុគប្បីរម្ងាប់ ( រាគាទិក្កិលេស ) ក្នុងសន្តាន ភិក្ខុមិនគប្បីស្វែងរកសេចក្តីស្ងប់ ដោយឧបាយដទៃទេ កាល

បើលោករម្ងាប់នូវរាគាទិក្កិលេស ក្នុងសន្តានហើយ សេចក្តីយល់ឃើញថា ខ្លួន គឺសស្សតទិដ្ឋិរមែងមិនមាន សេចក្តីយល់ឃើញថា មិនមែនខ្លួន គឺឧច្ឆេទទិដ្ឋិ នឹងមានមកអំពីណា ។ រលករមែងមិនកើតឡើង ត្រង់ជម្រៅពាក់កណ្តាលសមុទ្ទ ទឹកត្រង់កណ្តាលនោះ រមែងតាំងនៅនឹង មានឧបមាយ៉ាងណាមិញ មានឧបមេយ្យដូចភិក្ខុ អ្នកតាំងនៅនឹងនួន ជាអ្នកមិនមានតណ្ហាជាគ្រឿងញាប់ញ័រដូច្នោះឯង មិនគប្បីធ្វើកិលេស ឲ្យពុះពោរក្នុងទីណាមួយ ។ ( ព្រះពុទ្ធនិម្មិតសួរថា ) ព្រះអង្គមានចក្ខុបើកហើយ បានសម្តែងធម៌ចំពោះភ្នែក គឺធម៌ដែលព្រះអង្គឃើញច្បាស់ហើយ ដោយព្រះអង្គឯង ជាធម៌កម្ចាត់នូវសេចក្តីអន្តរាយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គសម្តែងនូវបដិបទាផង នូវបាតិមោក្ខសីលផង នូវសមាធិចិត្តផង ។ ( ព្រះមានព្រះភាគត្រាស់ថា ) ភិក្ខុគប្បីជាអ្នកមិនរវើរវាយ ដោយចក្ខុទាំងឡាយផង គប្បីបិទខ្ទប់នូវត្រចៀក ក្នុងពាក្យនៃអ្នកស្រុកផង មិនគប្បីជាប់នៅក្នុងរសផង មិនគប្បីប្រកាន់នូវរបស់ណាមួយក្នុងលោកផង ។ កាលណាភិក្ខុ ត្រូវផស្សៈប៉ះពាល់ហើយ ភិក្ខុមិនគប្បីធ្វើនូវសេចក្តីខ្សឹកខ្សួលផង មិនគប្បីប្រាថ្នានូវភពណាមួយផង មិនគប្បីញាប់ញ័រ ក្នុងសត្វសាហាវដែលគួរស្ញប់ស្ញែងផង ។ មួយទៀត ភិក្ខុបើបាននូវបាយ ទឹក ខាទនីយ

ឬសំពត់ទាំងឡាយហើយ មិនគប្បីធ្វើនូវសន្និធិ ( ការសន្សំទុក ) ឡើយ កាលបើមិនបាននូវវត្ថុទាំងនោះទេ ក៏មិនគប្បីអន្ទះសា ។ ភិក្ខុគប្បីជាអ្នកអភិរម្យក្នុងឈាន គប្បីជាអ្នកមិនរពឹសជើង គប្បីវៀរចាកសេចក្តីរពឹស ( មានរពឹសដៃជាដើម ) មិនគប្បីធ្វេសប្រហែស មួយទៀត គប្បីនៅក្នុងទីអង្គុយ ទីដេក ដែលមានសំឡេងតិច ។ ភិក្ខុមានសេចក្តីព្យាយាម មិនគប្បីធ្វើការដេកលក់ឲ្យច្រើនទេ គប្បីគប់រកនូវសេចក្តីភ្ញាក់រឭក គប្បីលះបង់សេចក្តីខ្ជិលច្រអូស មាយា ល្បែងសើច ល្បែងលេងមេថុន ព្រមទាំងការស្អិតស្អាងខ្លួនចេញ ។ ភិក្ខុអ្នករាប់អានព្រះរតនត្រ័យ មិនគប្បីប្រកបអាថព្វណមន្ត ( មន្តសម្រាប់ឲ្យឧបទ្វវៈកើតឡើងក្នុងបច្ចាមិត្ត ) មន្តសម្រាប់ទាយសុបិន មន្តសម្រាប់ទាយលក្ខណៈ មន្តសម្រាប់សម្តែងឫក្សមណ្ឌល មិនគប្បីសេពគប់មន្តសម្រាប់ទាយសម្រែកសត្វផង ថ្នាំសម្រាប់ធ្វើគភ៌ឲ្យតាំងនៅផង ការរក្សារោគផង ។ ភិក្ខុមិនគប្បីញាប់ញ័រ និងពាក្យនិន្ទា បើមានគេសរសើរ ក៏មិនគប្បីឡើងជោរផង គប្បីបន្ទោបង់លោភៈ មច្ឆរិយៈ សេចក្តីក្រេវក្រោធ និងពាក្យញុះញង់ ។ ភិក្ខុមិនគប្បីតាំងនៅក្នុងការលក់ចេញទិញចូល មិនគប្បីធ្វើការពោលតិះដៀល ក្នុងទីណាមួយ មិនគប្បីជាប់ចិត្តក្នុងស្រុក មិនគប្បីចរចាទីងជន ព្រោះប្រាថ្នាលាភ ។

មួយទៀត ភិក្ខុមិនគប្បីពោលវាចាលើកខ្លួន មិនគប្បីពោលវាចាផ្ដេសផ្ដាស មិនគប្បីសិក្សានូវសេចក្ដីឃ្នើសឃ្នងកាយ វាចា ចិត្ត មិនគប្បីពោលពាក្យប្រណាំងប្រជែង ។ ភិក្ខុមិនគប្បីដឹកនាំក្នុងពាក្យមុសាវាទ មិនគប្បីធ្វើការអួតអាងទាំងដឹងខ្លួន មួយទៀត មិនគប្បីមើលងាយអ្នកដទៃ ដោយអាជីវៈ ( ការចិញ្ចឹមជីវិត ) និងបញ្ញា និងសីលវត្ត ។ ភិក្ខុកាលបើបានឮពាក្យ ( មិនជាទីគាប់ចិត្ត ) ដ៏ច្រើន របស់សមណៈទាំងឡាយ ឬរបស់បុថុជ្ជនទាំងឡាយ មិនគប្បីប្រទូស្តទៅរក មិនគប្បីពោលតប ដោយពាក្យអាក្រក់ ព្រោះថា លោកអ្នកស្ងប់រម្ងាប់ទាំងឡាយ រមែងមិនធ្វើការឈ្លោះតបតឡើយ ។ ភិក្ខុកាលបានដឹង បានពិចារណាធម៌នុ៎ះ គប្បីជាអ្នកវៀកសិក្សាសព្វកាល បើបានដឹងសេចក្ដីរម្ងត់រាគាទិក្កិលេស ថាជាសេចក្ដីស្ងប់ហើយ មិនគប្បីប្រហែសធ្វេស ក្នុងសាសនានៃព្រះគោតមឡើយ ។ ភិក្ខុនោះជាអ្នកគ្របសង្កត់រូបជាដើម ជាអ្នកដែលរូបជាដើមគ្របសង្កត់មិនបាន ជាអ្នកឃើញធម៌ចំពោះភ្នែកឯង មិនអាងគេជាដូច្នេះៗ ព្រោះហេតុនោះ ភិក្ខុគប្បីជាអ្នកមិនប្រហែស គប្បីនមស្ការសិក្សាក្នុងសាសនានៃព្រះមានព្រះភាគនោះ សព្វៗ កាល ។

**តុវដកសូត្រទី ១៤ ចប់**

# អដ្ឋកថា

## តុវដកសូត្រ

[ ១០៨ ] ក្នុងតុវដកសូត្រទី ១៤ មានពាក្យផ្ដើមថា **បុច្ឆាមិ តំ** ដូច្នេះ

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅនេះ

ក្នុងមហាសម័យដដែលនោះឯង ព្រះមានព្រះភាគត្រាស់ព្រះសូត្រនេះ ដើម្បីប្រកាសសេចក្ដីនោះដល់ទេវតាពួកខ្លះ ដែលមានចិត្តកើតឡើងថា អ្វីហ្ន៎ គឺកិច្ចបដិបត្តិដើម្បីបានសម្រេចអរហត្ត ទើបឲ្យពុទ្ធនិម្មិតត្រាស់សួរដោយន័យមុននោះឯង ។ ក្នុងគាថាដើមនោះ ព្រះពុទ្ធនិម្មិតទ្រង់ថែកពាក្យសួរ ដោយការប្រៀបធៀបជាមួយវត្ថុដែលឃើញ ក្នុងបទនេះថា **បុច្ឆាមិ** ដូច្នេះ ។ បទថា **អាទិច្ចពន្ធុំ** បានដល់ ទ្រង់ជាផៅពង្សនៃព្រះអាទិត្យ ។ បទថា **វិវេកំ សន្តិ-បទញ្ច** បានដល់ ជាអ្នកស្ងាត់ និងមានការស្ងប់ជាទីតាំង ។ បទថា **កថំ ទិស្វា** គឺឃើញដោយហេតុណា អធិប្បាយថា ជាអ្នកឃើញការប្រព្រឹត្តទៅដូចម្ដេច ។

លំដាប់នោះ ព្រោះភិក្ខុឃើញយ៉ាងណា ទើបកម្ចាត់កិលេសទាំងឡាយ ភិក្ខុឃើញហើយ គឺជាអ្នកមានទស្សនៈប្រព្រឹត្តទៅ ព្រោះឃើញយ៉ាងនោះ ទើបរលត់ ដូច្នោះ ព្រះមានព្រះភាគកាលទ្រង់ធ្វើសេចក្ដីនោះឲ្យជាក់ច្បាស់ ទើបទ្រង់ដឹកនាំទេវបរិស័ទនោះក្នុងការលះកិលេស ដោយប្រការផ្សេងៗ បានត្រាស់ ៥ គាថា មានពាក្យផ្ដើមថា **មូលំ បបញ្ចសង្ខាយ** ដូច្នេះ ។

គប្បីជ្រាបសេចក្តីសង្ខេបក្នុងគាថាដើម នៃគាថាទាំងនោះសិន ។ ធម៌ជាគ្រឿងយឺតយូរនោះឯង ឈ្មោះថា ធម៌ជាចំណែកនៃការយឺតយូរ ព្រោះរាប់ថា ជាបបញ្ចធម៌ កិលេសទាំងឡាយ មានអវិជ្ជាជាដើមដែលជាឫសគល់នៃចំណែករបស់ធម៌ជាគ្រឿងយឺតយូរ ភិក្ខុគប្បីរារាំងនូវធម៌ទាំងពួង ដែលជាឫសគល់នៃចំណែករបស់ធម៌ ជាគ្រឿងញុំាងសត្វឲ្យយឺតយូរនោះ ដែលប្រព្រឹត្តទៅថា ជាអញដោយបញ្ញា តណ្ហាណាមួយគប្បីកើតឡើងខាងក្នុង ភិក្ខុគប្បីជាអ្នកមានសតិសិក្សាសព្វកាល ដើម្បីកម្ចាត់តណ្ហាទាំងនោះ គឺគប្បីតាំងសតិសិក្សា ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងទេសនាប្រកបដោយត្រៃសិក្ខា ក្នុងគាថាទី ១ យ៉ាងនេះ ដោយធម៌ជាកំពូល គឺអរហត្តហើយ ដើម្បីសម្តែងដោយការលះមានះទៀត ទើបត្រាស់គាថាថា **យំ កិញ្ចិ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **យំ កិញ្ចិ ធម្មំ អភិជញ្ញា អជ្ឈត្តំ** សេចក្តីថា គប្បីដឹងនូវគុណរបស់ខ្លួន មានភាពជាអ្នកមានត្រកូលខ្ពស់ជាដើម ។ បទថា **អថវាបិ ពហិទ្ធា** បានដល់ គប្បីដឹងគុណរបស់អាចារ្យ និងឧបជ្ឈាយ៍ខាងក្រៅ ។ បទថា **ន តេន ថាមំ កុព្វេថ** បានដល់ មិនគប្បីធ្វើនូវការប្រកាន់ខ្លួនដោយគុណនោះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់វិធីដែលភិក្ខុនោះមិនគួរធ្វើ ទើបត្រាស់គាថាថា **សេយ្យោ ន តេន** ដូច្នេះជាដើម ។

បទនោះ មានសេចក្តីដូច្នេះថា ភិក្ខុមិនគប្បីសម្គាល់ថា អញជាបុគ្គល

ប្រសើរជាងគេ អាក្រក់ជាងគេ ឬស្មើគេ ដោយមានះនោះ សូម្បីប្រកបដោយគុណច្រើនប្រការ មានភាពជាបុគ្គលកើតក្នុងត្រកូលខ្ពស់ជាដើម ក៏មិនគប្បីកំណត់ខ្លួន តាំងនៅដោយន័យជាដើមថា អញបួសហើយចាកត្រកូលខ្ពស់ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងដោយបែបផែនឲ្យលះនូវមានះយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្ដែងឲ្យស្ងប់កិលេសទាំងពួង ទើបត្រាស់គាថាថា **អជ្ឈត្តមេវ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **អជ្ឈត្តមេវ ឧបសមេ** សេចក្ដីថា គប្បីស្ងប់កិលេសទាំងពួង មានរាគៈជាដើមក្នុងខ្លួននោះឯង ។ បទថា **ន អញ្ញតោ ភិក្ខុ សន្តិមេសេយ្យ** បានដល់ មិនគប្បីស្វែងរកនូវការស្ងប់ដោយឧបាយដទៃ ក្រៅអំពីសតិប្បដ្ឋានជាដើមឡើយ ។ បទថា **កុតោ និរត្តំ វា** សេចក្ដីថា និរត្តទិដ្ឋិ ( សេចក្ដីយល់ឃើញថា មិនមែនខ្លួន ) នឹងមានមកអំពីណា ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងថា ព្រះខីណាស្រពជាអ្នកស្ងប់ហើយខាងក្នុង ជាតាទិបុគ្គល ទើបត្រាស់គាថាថា **មជ្ឈេ យថា** ដូច្នេះជាដើម ។ គាថានោះ មានសេចក្ដីដូច្នេះថា រលករមែងមិនកើតត្រង់ទីកណ្ដាលទឹក ពោល គឺត្រង់កណ្ដាល រវាងចំណែកខាងលើ និងចំណែកខាងក្រោមនៃមហាសមុទ្រ ប្រមាណ ៤ ពាន់យោជន៍ ឬក្នុងកណ្ដាលនៃមហាសមុទ្រដែលតាំងនៅចន្លោះភ្នំ ( សត្តបរិភណ្ឌ ) សមុទ្រនោះស្ងប់ស្ងៀម មិនមានរលកយ៉ាងណា ភិក្ខុដែលមិនញាប់ញ័រ ជាព្រះខីណាស្រព តាំងមាំ មិនញាប់ញ័រក្នុងលាភជាដើម ដូច្នោះ ភិក្ខុនោះ មិនគប្បីធ្វើកិលេសជាគ្រឿងផ្សាយ

ឡើង មានរាគៈជាដើម ក្នុងអារម្មណ៍ណាមួយឡើយ ។

ឥឡូវនេះ ពុទ្ធនិម្មិតកាលអនុមោទនាព្រះធម្មទេសនា ដែលព្រះមានព្រះភាគទ្រង់សម្តែងធម៌ជាកំពូល គឺអរហត្តនេះ កាលនឹងទូលសួរដល់បដិបទាខាងដើមនៃអរហត្តនោះ ទើបត្រាស់គាថាថា **អកិត្តយិ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **អកិត្តយិ** ប្រែថា ត្រាស់ប្រាប់ ។ បទថា **វិវដចក្ខុ** បានដល់ ជាអ្នកប្រកបដោយចក្ខុ ៥ បើកហើយ គឺមិនមានអ្វីរាំង ។ បទថា **សក្ខិធម្មំ** បានដល់ ធម៌ដែលទ្រង់ដឹងដោយព្រះអង្គឯង គឺប្រចក្សដល់ព្រះអង្គ ។ បទថា **បរិស្សយវិនយំ** គឺកម្ចាត់អន្តរាយចោលទៅ ។ បទថា **បដិបទញ្ច វទេហិ** បានដល់ សូមទ្រង់ប្រាប់បដិបទាក្នុងកាលឥឡូវនេះចុះ ។ បទថា **ភទ្ទន្តេ** សេចក្តីថា ពុទ្ធនិម្មិត កាលត្រាស់ហៅព្រះមានព្រះភាគថា សូមសេចក្តីចម្រើនមានដល់ព្រះអង្គ ដូច្នេះ ម្យ៉ាងទៀត លោកអធិប្បាយថា សូមទ្រង់ប្រាប់សេចក្តីចម្រើន សេចក្តីល្អ ដែលសមគួររបស់ព្រះអង្គចុះ ។ បទថា **ចាតិមោក្ខំ អថវាបិ សមាធឹ** សេចក្តីថា ព្រះពុទ្ធនិម្មិតសួរញែកបដិបទានោះឯង ឬថា ព្រះពុទ្ធនិម្មិតទូលសួរមគ្គប្បបដិបទា ដោយបទនេះនិងទូលសួរដល់សីល និងសមាធិដោយបទដទៃ ។

ព្រះមានព្រះភាគ ព្រោះការសង្រួមឥន្ទ្រិយ ជាការរក្សាសីល ឬព្រោះទេសនាដែលទ្រង់សម្តែងទៅតាមលំដាប់នេះ ជាទីសប្បាយដល់ពួកទេវតានោះៗ ដូច្នោះ កាលទ្រង់សម្តែងបដិបទា តាំងអំពីការសង្រួមឥន្ទ្រិយ ទើបត្រាស់ផ្តើមគាថាថា **ចក្ខូហិ នេវ លោលស្ស** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ចក្ខូហិ នេវ លោលស្ស** សេចក្តីថា ភិក្ខុមិនគប្បីជាអ្នកឡេះឡោះដោយចក្ខុ ដោយគិតថា ត្រូវមើលរូបដែលមិនធ្លាប់មើលជាដើម ។ បទថា **គាមកថាយ អាវរយេ សោតំ** សេចក្តីថា គប្បីសង្រួមត្រចៀកចាកតិរច្ឆានកថា ។ បទថា **ផស្សេន** បានដល់ ផស្សៈ គឺរោគ ។ បទថា **ភវញ្ច នាភិជប្បេយ្យ** សេចក្តីថា មិនគប្បីប្រាថ្នាភព មានកាមភពជាដើម ដើម្បីបន្ទោបង់នូវផស្សៈនោះ ។ បទថា **ភេរវេសុ ច ន សម្បវេធេយ្យ** សេចក្តីថា មិនគប្បីញាប់ញ័រ ព្រោះអារម្មណ៍ដែលគួរខ្លាច មានរាជសីហ៍និងខ្លាធំជាដើម ដែលកើតអំពីផស្សៈនោះជាបច្ច័យ ឬមិនគប្បីញាប់ញ័រ ព្រោះអារម្មណ៍ក្នុងយានិន្ទ្រិយ និងមនិន្ទ្រិយដ៏សេស ឈ្មោះថា លោកពោលដល់ការសង្រួមឥន្ទ្រិយគ្រប់បរិបូណ៌ ដោយប្រការដូច្នេះ ។ម្យ៉ាងទៀត ព្រះមានព្រះភាគ កាលទ្រង់សម្តែងការសង្រួមឥន្ទ្រិយដោយបទមុនហើយ ទ្រង់សម្តែងថា ភិក្ខុអ្នកនៅក្នុងព្រៃ ឃើញ ឬស្តាប់វត្ថុដែលគួរខ្លាចហើយ មិនគប្បីញាប់ញ័រដោយបទនេះ ។

បទថា **លទ្ធា ន សន្និធឹ កយិរា** សេចក្តីថា ភិក្ខុគិតថា ការដែលបានបាយជាដើមឯណានីមួយដោយធម៌ហើយ នៅក្នុងសេនាសនៈព្រៃ ជាការបានលំបាក ដូច្នេះហើយ មិនគួរធ្វើការសន្សំ ។ បទថា **ឈាយី ន បាទលោលស្ស** សេចក្តីថា គប្បីជាអ្នកត្រេកអរក្រៃលែងក្នុងឈាន មិនគប្បីផ្តាំផ្គងជើង គឺដើរទៅកាន់ទីផ្សេងៗ ។

បទថា **វិរមេ កុក្កុច្ចា នប្បមជ្ជេយ្យ** សេចក្តីថា គប្បីបន្ទោបង់នូវ

ការផ្តាំផ្ញើ មានការផ្ញើដៃជាដើម មិនគប្បីប្រមាទក្នុងការសង្រួមនេះ ដោយមានការធ្វើសេចក្តីគោរពជាដើម ។ បទថា **តន្ទឹ មាយំ ហស្សំ ខិឌ្ឌំ** សេចក្តីថា គប្បីលះនូវការខ្ជិលច្រអូស ការបោកបញ្ឆោត ការសើចអរ ការលេង ដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងចិត្ត ។ បទថា **សវិភូសំ** បានដល់ មួយអន្លើដោយការប្រដាប់តាក់តែង ។ បទថា **អាថព្វណំ** បានដល់ ការធ្វើអថ៌ន ។ បទថា **សុបិនំ** បានដល់ វិជ្ជាទាយយល់សប្តិ ។ បទថា **លក្ខណំ** បានដល់ ការទាយលក្ខណៈ មានលក្ខណៈកែវមណីជាដើម ។ បទថា **នោ វិទហេ** បានដល់ មិនគប្បីប្រកប ។ បទថា **វិរុតញ្ច** បានដល់ ទាយសំឡេងសត្វយំមានម្រឹគជាដើម ។

បទថា **បេសុណិយំ** បានដល់ ពាក្យញុះញង់ ។ បទថា **កយវិក្កយេ** បានដល់ មិនគប្បីតាំងនៅដោយការបោកបញ្ឆោត ឬដោយឃើញដល់ចំណេញជាមួយសហធម្មិកទាំងឡាយ ៥ ពួក ។ បទថា **ឧបវាទំ ភិក្ខុ ន ករេយ្យ** សេចក្តីថា ភិក្ខុមិនទាន់កើតកិលេស ដែលធ្វើការពោលតិះដៀលឲ្យកើតឡើង មិនគួរឲ្យនូវការពោលតិះដៀលសមណព្រាហ្មណ៍ដទៃ កើតឡើងក្នុងខ្លួន ។ បទថា **គាមេ ច នាភិសជ្ជេយ្យ** សេចក្តីថា មិនគប្បីប្រឡូកប្រឡំក្នុងអ្នកស្រុក ដោយការប្រឡូកប្រឡំជាមួយគ្រហស្ថជាដើម ។ បទថា **លាភកម្យា ជនំ ន លបយេយ្យ** សេចក្តីថា មិនគប្បីចរចានឹងពួកជន ព្រោះការចង់បានលាភ ។ បទថា **បយុត្តំ** បានដល់ វាចាអាស្រ័យចីវរជាដើម ឬវាចាប្រកបដើម្បីវត្ថុនោះ ។ បទថា **មោសវជ្ជេ ន និយេថ** សេចក្តីថា ភិក្ខុមិនគប្បីប្រព្រឹត្ត

ទៅក្នុងការពោលកុហក ។ បទថា **ជីវិតេន** បានដល់ ដោយការចិញ្ចឹមជីវិត ។ ភិក្ខុត្រូវអ្នកដទៃជ្រៀតបៀត បានស្តាប់ការនិយាយច្រើនរបស់សមណៈ ឬរបស់បុថុជ្ជន គឺបានស្តាប់វាចាមិនពេញចិត្ត សូម្បីច្រើនរបស់សមណៈទាំងនោះ ឬរបស់បុថុជ្ជនដទៃ មានក្សត្រជាដើម ។ បទថា **នប្បដិវជ្ជា** បានដល់ មិនគប្បីឆ្លើយឆ្លង ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះលោកអ្នកស្ងប់រម្ងាប់ទាំងឡាយ រមែងមិនធ្វើការឈ្លោះតបតឡើយ ។ បទថា **ឯតញ្ច ធម្ម-មញ្ញាយ** សេចក្តីថា ភិក្ខុដឹងធម៌តាមដែលពោលហើយនេះទាំងអស់ ។ បទថា **វិចិនំ** បានដល់ រិះគិត ។ បទថា **សន្តីតិ និព្វុតី ញត្វា** បានដល់ ដឹងនូវការរលត់កិលេសថា ជាការស្ងប់រាគៈជាដើម ។ បើមានពាក្យសួរថា ព្រោះអ្វី ទើបមិនគួរប្រមាទ ។ ព្រោះមានគាថាថា **អភិភូ ហិ សោ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **អភិភូ** បានដល់ ជាអ្នកគ្របសង្កត់អារម្មណ៍មានរូបជាដើម ។ បទថា **អនភិភូតោ** បានដល់ ដែលអារម្មណ៍ មានរូបជាដើមគ្របសង្កត់មិនបាន ។ បទថា **សក្ខិធម្មំ អនីតិហមទស្សី** បានដល់ ជាអ្នកឃើញនូវធម៌ដែលខ្លួនឃើញឯងយ៉ាងប្រចក្សនោះឯង មិនមែនឃើញដោយការជឿថា បុគ្គលនោះពោលយ៉ាងនេះៗ ឡើយ ។ បទថា **សទា នមស្សមនុសិក្ខេ** បានដល់ គប្បីបង្អោនសិក្សានូវត្រៃសិក្ខារឿយៗ សព្វកាល ។ បទដ៏សេស ក្នុងបទទាំងពួង ជាក់ច្បាស់ហើយ ។

ម្យ៉ាងទៀត ក្នុងគាថានេះ គប្បីជ្រាបសេចក្តីសរុបដូច្នេះ លោកពោលការសង្រួមឥន្ទ្រិយដោយបទជាដើមថា ភិក្ខុជាអ្នកមិនរឡេមរឡាមដោយចក្ខុ

ទាំងឡាយ ពោលបច្ចយសន្និស្សិតសីល ដោយឃាត់នូវការសន្សំ ដោយបទជាដើមថា បើភិក្ខុបាននូវបាយទឹក ... មិនគប្បីធ្វើនូវសន្និធិឡើយ ពោលបាតិមោក្ខសំវរសីល ដោយបទថា គប្បីលះបង់ល្បែងលេង មេថុន ពាក្យមុសាវាទ និងពាក្យញុះញង់ជាដើម ពោលអាជីវបារិសុទ្ធិសីល ដោយបទជាដើមថា មិនគប្បីប្រកបអាថព្វនមន្ត មន្តសម្រាប់ទាញសុបន្តិ មន្តសម្រាប់ទាយលក្ខណៈ ត្រាស់សមាធិដោយបទនេះថា គប្បីជាអ្នកអភិរម្យក្នុងឈាន ពោលបញ្ញាដោយបទនេះថា ភិក្ខុកាលបានដឹង បានពិចារណាធម៌ទុំះ ពោលត្រៃសិក្ខាដោយសង្ខេប ដោយបទនេះថា គប្បីជាអ្នករឭកសិក្សាសព្វកាល ពោលធម៌ដែលមានឧបការៈ ការសង្គ្រោះ និងការបន្ទោបង់នៃសីល សមាធិ បញ្ញា ដោយបទជាដើមថា គប្បីនៅក្នុងទីអគ្គុយ ទីដេក ដែលមានសំឡេងតិច មិនគប្បីធ្វើការដេកលក់ឲ្យច្រើនទេ ។ ព្រះមានព្រះភាគ កាលត្រាស់បដិបទាបរិបូណ៌ដល់ពុទ្ធនិម្មិតយ៉ាងនេះហើយ ទើបទ្រង់បញ្ចប់ទេសនាដោយធម៌ជាកំពូល គឺអរហត្ត ។

កាលចប់ទេសនា មានអ្នកសម្រេចធម៌ដូចគ្នា តាមដែលពោលហើយក្នុងបុរាភេទសូត្រនោះឯង ។៚

**អដ្ឋកថាតុវដកសូត្រទី ១៤ ចប់**

# សុត្តន្តបិដក

## អត្តទណ្ឌសូត្រទី១៥

[ ១០៩ ] ( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) ភ័យកើតមកពីអាជ្ញារបស់ខ្លួន ( សេចក្តីប្រព្រឹត្តកាចអាក្រក់របស់ខ្លួន ) អ្នកទាំងឡាយ ចូរមើលជនអ្នកទាស់ទែងគ្នា តថាគត ( កាលនៅជាពោធិសត្វ ) បានតក់ស្លុតហើយយ៉ាងណា តថាគតនឹងសម្តែងនូវសេចក្តីតក់ស្លុតយ៉ាងនោះ ( ដល់អ្នកទាំងឡាយ ) ។ ភ័យមកកាន់តថាគត ព្រោះឃើញពួកសត្វកំពុងញាប់ញ័រ ( ដោយតណ្ហាជាដើម ) ដូចពួកមច្ឆជាតក្នុងទីមានទឹកតិច ព្រោះឃើញសត្វលោក បៀតបៀនគ្នានិងគ្នា ។ លោកមិនមានខ្លឹមសារដោយជុំវិញ ទិសទាំងពួងរមែងញាប់ញ័រ តថាគត កាលប្រាថ្នានូវភព ( ជាទីពឹង ) របស់ខ្លួន ក៏មិនបានឃើញភពណាមួយដែលជរាធម៌ជាដើម ជិះជាន់មិនបាន សេចក្តីមិនរីករាយ បានកើតមានដល់តថាគតហើយ ព្រោះបានឃើញសត្វទាំងឡាយត្រូវជរាធម៌ជាដើមបៀតបៀនហើយ ក្នុងកាលជាទីបំផុត តពីនោះមក តថាគតបានឃើញសរ ដែលគេឃើញបានដោយកម្រ អាស្រ័យនៅក្នុងហឫទ័យ ក្នុងសត្វទាំងឡាយនោះ ។ សត្វលោកដែលសរដោតជាប់ហើយ រមែងស្ទុះទៅកាន់ទិសផ្សេងៗ បុគ្គលជាបណ្ឌិតដកសរនោះបាន ទើបមិនស្ទុះទៅ មិនលិចចុះ ។ (អារម្មណ៍ជាទីស្រឡាញ់គឺបញ្ចកាមគុណណា មានក្នុងលោក)

ប្រជុំជនតែងសម្តែងនូវភាសិត ជាគ្រឿងសិក្សា ( មានការសិក្សាដីរជាដើម ) ដើម្បីឲ្យបានអារម្មណ៍ជាទីស្រឡាញ់នោះ បណ្ឌិតមិនគួរខ្វល់ខ្វាយក្នុងបញ្ចកាមគុណ ឬក្នុងកិច្ចសិក្សានោះឡើយ គប្បីនឿយណាយក្នុងកាមារម្មណ៍ ដោយប្រការទាំងពួង គប្បីសិក្សានូវព្រះនិព្វាន បម្រុងខ្លួន ។ បុគ្គលជាអ្នកប្រាជ្ញ គប្បីជាអ្នកមានសច្ចៈ ជាបុគ្គលមិនឃ្នើសឃ្នង មិនមានមាយា លះបង់ពាក្យញុះញង់ មិនក្រេវក្រោធ ឆ្លងឲ្យរួចនូវលោភៈដ៏លាមក និងមច្ឆរិយៈ ។ នរជន មានចិត្តឱនទៅរកព្រះនិព្វាន គប្បីគ្របសង្កត់នូវការដេកលក់ សេចក្តីខ្ជិលច្រអូស ការរួញរា មិនគប្បីដំអក់នៅ ដោយសេចក្តីប្រហែសធ្វេស មិនគប្បីតាំងខ្លួន ក្នុងមានះដ៏ក្រៃលែង ។ បុគ្គលអ្នកបង្អោនចិត្តទៅរកព្រះនិព្វាន មិនគប្បីដឹកនាំក្នុងពាក្យមុសាវាទ មិនគប្បីធ្វើសេចក្តីស្នេហាក្នុងរូប ត្រូវកំណត់ដឹងនូវមានះ ហើយគប្បីវៀរចេញចាកអំពើដ៏រួសរាន់ ។ មិនគប្បីត្រេកត្រអាលទៅរកបញ្ចក្ខន្ធ ដែលជារបស់ចាស់ គឺជាអតីត មិនគប្បីធ្វើសេចក្តីពេញចិត្ត នឹងបញ្ចក្ខន្ធដែលជារបស់ថ្មី គឺជាបច្ចុប្បន្ន មិនត្រូវសោកស្តាយនឹងបញ្ចក្ខន្ធ ដែលសាបរលាបទៅហើយ មិនត្រូវជាប់ស្អិតនៅក្នុងតណ្ហា ។ តថាគតពោលនូវសេចក្តីជាប់ចិត្ត គឺតណ្ហា ថាជាអន្លង់ធំ តថាគតពោលនូវសេចក្តីជក់ចិត្ត គឺតណ្ហា ថាជាគ្រឿងលឿនទៅនៃចិត្ត

ថាជាគ្រឿងជាប់ ញាំមនៅនៃចិត្ត ថាជាអារម្មណ៍នៃចិត្ត ថាជាគ្រឿងត្រិះរិះ ( ព្រោះ ) កាមតណ្ហាដូចជាភក់ សត្វទាំងឡាយអាចឆ្លងបានដោយលំបាក ។ អ្នកប្រាជ្ញជាព្រាហ្មណ៍ មិនគេចចេញចាកសច្ចៈ រមែងតាំងនៅលើទីទួល គឺព្រះនិព្វាន តថាគតហៅបុគ្គលនោះថា ជាអ្នកស្ងប់ ព្រោះលះអាយតនៈទាំងអស់ ។ បុគ្គលនោះ ជាអ្នកប្រាជ្ញ បុគ្គលនោះ ជាអ្នកដល់នូវវេទ ជាបុគ្គលដែលតណ្ហា និងទិដ្ឋិ មិនអាស្រ័យនៅហើយ ព្រោះឃើញសង្ខារធម៌ ( ថាជារបស់មិនទៀង ជាទុក្ខ មិនមែនខ្លួន ) បុគ្គលនោះ រមែងប្រព្រឹត្តនៅក្នុងលោកដោយប្រពៃ មិនជាប់ចិត្តនឹងបុគ្គលណាមួយឡើយ ។ បុគ្គលណាបានឆ្លងផុតនូវកាមផង នូវកិលេសគ្រឿងជាប់ ដែលឆ្លងបានដោយកម្រក្នុងលោកផង បុគ្គលនោះ ឈ្មោះថា កាត់ខ្សែតណ្ហា មិនមានចំណង រមែងមិនសោក មិនសុបសៅ ។ កិលេសជាតណ្ហាកើតឡើង ( ព្រោះប្រារព្ធ ) សង្ខារជាអតីត អ្នកចូរធ្វើកិលេសនោះឲ្យរីងស្ងួតទៅ កិលេសគ្រឿងកង្វល់ ( មានរាគៈជាដើមកើតឡើងព្រោះប្រារព្ធ ) សង្ខារដែលនឹងមានទៅខាងក្រោយ ចូរកុំមានដល់អ្នកឡើយ បើអ្នកមិនប្រកាន់ក្នុងធម៌ជាកណ្តាល ( មានរូបជាដើម ដែលជាបច្ចុប្បន្ន ) អ្នកនឹងទៅជាបុគ្គលស្ងប់ ។ បុគ្គលណា មិនមានសេចក្តីប្រកាន់ក្នុងនាម និងរូប ថាជារបស់អញសព្វគ្រប់ទេ

បុគ្គលនោះឯង រមែងមិនសោក ព្រោះនាមរូបដែលមិនមានផង មិនទ្រុឌទ្រោមទៅក្នុងលោកផង ។ កង្វល់ថា នេះរបស់អញ ទុំះ ជារបស់ជនដទៃមិនមានដល់បុគ្គលណា បុគ្គលនោះ កាលមិនបាននូវវត្ថុដែលប្រកាន់ថារបស់អញ រមែងមិនសោក ថាអញគ្មានដូច្នេះឡើយ ។ បុគ្គលដែលមិនមានឫស្យា មិនមានសេចក្តីត្រេកអរ ជាអ្នកមិនញាប់ញ័រ ជាអ្នកស្ងប់រម្ងាប់ ក្នុងអាយតនៈខាងក្នុង ខាងក្រៅទាំងអស់ តថាគតកាលបើមានបុគ្គលចូលមកសួរអានិសង្ស របស់បុគ្គលអ្នកមិនញាប់ញ័រនោះ ក៏នឹងសម្តែង ( អានិសង្សទាំង ៤ មានមិនឫស្យាជាដើមនោះ ) ។ ( បណ្តាសង្ខារទាំង ៣ មានបុញ្ញាភិសង្ខារជាដើម ) សង្ខារណាមួយ មិនមានដល់បុគ្គលអ្នកមិនញាប់ញ័រ អ្នកដឹងច្បាស់ ( នូវត្រៃលក្ខណ៍ ) បុគ្គលនោះ វៀរស្រឡះចាកសង្ខារទាំង ៣ នោះ រមែងឃើញសេចក្តីក្សេម ក្នុងទីទាំងពួង ។ អ្នកប្រាជ្ញ រមែងមិននិយាយអួតខ្លួន ( ដោយមានះថា អញជាបុគ្គលស្មើគ្នា ) ក្នុងពួកបុគ្គលស្មើគ្នា ( ថាអញជាបុគ្គលថោកទាប ) ក្នុងពួកបុគ្គលដែលថោកទាប ( ថាអញជាបុគ្គលប្រសើរ ) ក្នុងពួកបុគ្គលដែលប្រសើរ បុគ្គលនោះជាអ្នកស្ងប់ ប្រាសចាកសេចក្តីកំណាញ់ រមែងមិនប្រកាន់ មិនអន្ទះសា ។

**អត្តទណ្ឌសូត្រទី ១៥ ចប់**

# អដ្ឋកថា

## អត្តទណ្ឌសូត្រ

[ ១០៩ ] ក្នុងអត្តទណ្ឌសូត្រទី ១៥ មានពាក្យផ្ដើមថា **អត្តទណ្ឌា ភយំ ជាតំ** ដូច្នេះ

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅ ព្រះមានព្រះភាគ ទ្រង់ជ្រាបការឈ្លោះគ្នា ព្រោះរឿងទឹករបស់សក្យៈ និងកោលិយៈ ដូចបានពណ៌នាក្នុងអត្ថុប្បត្តិហេតុនៃសម្មាបរិព្វាជនិយសូត្រ ទ្រង់ព្រះតម្រិះថា ពួកព្រះញាតិទាស់ទែងគ្នាហើយចុះ តថាគតនឹងឃាត់ព្រះញាតិទាំងនោះ ដូច្នេះហើយ ទើបយាងទៅប្រថាប់ឈរត្រង់កណ្ដាល នៃពួកសេនាទាំងសងខាង ហើយទើបត្រាស់ព្រះសូត្រនេះ ។

ក្នុងសូត្រនោះ គប្បីជ្រាបសេចក្ដីក្នុងគាថាដើមដូច្នេះថា ភ័យកើតឡើងក្នុងបច្ចុប្បន្ន និងសម្បរាយភព ភ័យទាំងអស់នោះ កើតអំពីទោសរបស់ខ្លួន គឺកើតអំពីហេតុទុច្ចរិតរបស់ខ្លួន កាលបើយ៉ាងនេះ ចូរអ្នកទាំងឡាយមើលជនដែលទាស់ទែងគ្នា ចូរមើលជន មានសក្យៈជាដើមនេះឈ្លោះគ្នា ប្រទូស្តគ្នា បៀតបៀនគ្នានិងគ្នា ។

ព្រះមានព្រះភាគ កាលទ្រង់តិះដៀលជនដែលពិរោធ ឈ្លោះប្រកែកគ្នា ដែលបដិបត្តិខុសយ៉ាងនេះហើយ ដើម្បីឲ្យកើតនូវសេចក្ដីសង្វេគដល់ជនទាំងនោះ ដោយការសម្ដែងសម្មាបដិបត្តិរបស់ព្រះអង្គ ទើបត្រាស់ថា **សំវេគំ**

**កិត្តយិស្សាមិ យថា សំវិជិតំ មយា** ដូច្នេះ អធិប្បាយថា ធ្លាប់ជាព្រះពោធិសត្វមកហើយនោះឯង ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងប្រការតាមដែលទ្រង់សង្វេគមកហើយ ទើបត្រាស់ពាក្យជាដើមថា **ផន្ទមានំ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ផន្ទមានំ** បានដល់ ពួកសត្វកំពុងអន្ទះអន្ទែង ដោយតណ្ហា និងទិដ្ឋិ ។ បទថា **អប្បោទកេ** បានដល់ ក្នុងទីដែលមានទឹកតិច ។ បទថា **អញ្ញមញ្ញេហិ ព្យារុទ្ធេ ទិស្វា** សេចក្តីថា ព្រោះបានឃើញមនុស្សទាំងឡាយ ដែលខឹងក្រោធគ្នានិងគ្នា ។ បទថា **មំ ភយមាវិសិ** បានដល់ ភ័យបានចូលមកដល់តថាគតហើយ ។ បទថា **សមន្តមសារោ លោកោ** សេចក្តីថា លោកដោយជុំវិញ តាំងអំពីនរកជាដើម មិនមានខ្លឹមសារ គឺវៀរចាកខ្លឹម មាននិច្ចសារៈជាដើម ។ បទថា **ទិសា សព្វា សមេរិតា** បានដល់ ទិសទាំងពួងញាប់ញ័រហើយ ព្រោះជារបស់មិនទៀង ។ បទថា **ឥច្ឆំ ភវនមត្តនោ** បានដល់ តថាគតប្រាថ្នានូវការជ្រកកោនដល់ខ្លួន ។ បទថា **នាទ្ទសាសឹ អនោសិតំ** បានដល់ មិនបានឃើញទីណាមួយដែលទុក្ខមានជរាជាដើម មិនគ្របសង្កត់ហើយ ។ បទថា **ឱសានេត្វេវ ព្យារុទ្ធេ ទិស្វា មេ អរតី អហុ** សេចក្តីថា តថាគតមិនមានសេចក្តីត្រេកអរ ព្រោះបានឃើញសត្វទាំងឡាយដែលមានទីបំផុត ដែលដល់ទីបំផុត គឺវិនាសចាកវ័យកំលោះក្រមុំជាដើមនោះឯង មានចិត្ត ដែលជរាជាដើមរារាំង គឺបៀតបៀន ។ បទថា **អថេត្ថ សល្លំ** សេចក្តីថា តថាគតបានឃើញកិលេសដូចសរ មាន

រាគៈជាដើម ក្នុងសត្វទាំងឡាយនេះ ។ បទថា **ហទយនិស្សិតំ** បានដល់ដែលអាស្រ័យចិត្ត ។ បើមានពាក្យសួរថា កិលេសដូចសរ មានអានុភាពដូចម្តេច គប្បីជ្រាបគាថាថា **យេន សល្លេន ឱតិណ្ណោ** ដូច្នេះជាដើម ។

បទថា **ទិសា សព្វា វិធាវតិ** សេចក្តីថា សត្វរមែងស្ទុះទៅកាន់ទិសទាំងពួង គឺទិសទុច្ចរិតខ្លះ ទិសបូព៌ជាដើមខ្លះ ។ បទថា **តមេវ សល្លំ អព្វុយ្ហ ន ធាវតិ ន សីទតិ** សេចក្តីថា បណ្ឌិតដកនូវកិលេសដូចកូនសរនោះចោលបាន រមែងមិនស្ទុះទៅកាន់ទិស មិនលិចចុះក្នុងឱឃៈ ៤ ។ កាលមនុស្សទាំងឡាយត្រូវកិលេសដូចសរ មានអានុភាពច្រើនមុតយ៉ាងនេះហើយ គប្បីជ្រាបគាថាថា **តត្ថ សិក្ខានុគីយន្តិ យានិ លោកេ គធិតានិ** ដូច្នេះ ។

គាថានោះ មានសេចក្តីដូច្នេះថា កាមគុណ ៥ ណាក្នុងលោក ហៅថា **គធិតានិ** ព្រោះធ្វើវិគ្គហៈថា ជាប់ស្អិតក្នុងការបាន ឬព្រោះសេពអស់កាលយូរ ឬព្រោះទន្ទេញសិប្បៈច្រើនប្រការ មានសិប្បៈដំរីជាដើម ដែលជាគ្រឿងសម្គាល់ក្នុងកាមគុណទាំងនោះ ចូរអ្នកទាំងឡាយមើលចុះ លោកនេះ ស្រវឹងដរាបណា កុលបុត្រដែលជាបណ្ឌិតមិនគប្បីខ្វល់ខ្វាយក្នុងអារម្មណ៍ ដែលគួរត្រេកអរទាំងនោះ ឬក្នុងសិប្បៈទាំងនោះ គប្បីនឿយណាយក្នុងកាមទាំងឡាយដោយប្រការទាំងពួង ដោយការឃើញលក្ខណៈ មានលក្ខណៈមិនទៀងជាដើម ដោយពិត គប្បីសិក្សានិព្វានដើម្បីខ្លួនចុះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងនូវវត្ថុដែលគួរសិក្សា ទើបត្រាស់ពាក្យជាដើមថា **សច្ចោ សិយា** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សច្ចោ** បានដល់ គប្បីជាអ្នកប្រកបដោយវាចាសច្ច ញាណសច្ច មគ្គសច្ច ។ បទថា **រិត្តបេសុណោ** បានដល់ មានពាក្យញុះញង់លះបានហើយ ។ បទថា **វេវិច្ឆំ** បានដល់ សេចក្ដីកំណាញ់ ។ បទថា **និទ្ទំ តន្ទឹ សហេ ថីនំ** បានដល់ គប្បីគ្របសង្កត់នូវធម៌ ៣ យ៉ាង គឺការងងុយ ការច្រអូសផ្លូវកាយ ការច្រអូសផ្លូវចិត្ត ។ បទថា **និព្វាន-មនសោ** បានដល់ មានចិត្តបង្អោនទៅក្នុងនិព្វាន ។ បទថា **សាហសា** បានដល់ ចាកហេតុនៃការរួសរាន់ ដូចជាការប្រព្រឹត្តត្រេកអរជាដើមរបស់បុគ្គលអ្នកមានតម្រេក ។ បទថា **នាភិនន្ទេយ្យ** បានដល់ មិនគប្បីត្រេកអរក្នុងរូបដែលកន្លងមកហើយជាដើម ។ បទថា **នវេ** បានដល់ ក្នុងអារម្មណ៍បច្ចុប្បន្ន ។ បទថា **ហិយ្យមានេ** បានដល់ អារម្មណ៍ដែលបាត់ទៅ ។ បទថា **អាកាសំ ន សិតោ សិយា** បានដល់ មិនគប្បីជាបុគ្គលត្រូវតណ្ហាអាស្រ័យ ។ ពិតហើយ តណ្ហា លោកហៅថា អាកាស ព្រោះជាឱកាសនៃរូបជាដើម បើមានពាក្យសួរថា ព្រោះហេតុអ្វី ទើបមិនគប្បីជាអ្នកអាស្រ័យតណ្ហា ព្រោះមានគាថាបន្តថា តថាគតពោលនូវសេចក្ដីជាប់ចិត្ត គឺតណ្ហាថា ជាអន្លង់ធំ ដូច្នេះជាដើម ។

គាថានោះ មានសេចក្ដីដូច្នេះ ព្រោះតថាគតពោលតណ្ហា ដែលហៅថាអាកាសនេះថា ជាការត្រេកអរ ព្រោះជាឱកាសនៃរូបជាដើម ។ សួរថា មានអ្វីក្រៅលែងជាងនេះ ឆ្លើយថា មានដូច្នេះ គឺតថាគតហៅតណ្ហាថាជាឱឃៈ ។ ព្រោះការទម្លាយ ហៅតណ្ហាថា ជាអាជវៈ ព្រោះស្ទុះទៅរហ័ស ហៅតណ្ហាថា

ជាគ្រឿងខ្វឹប ព្រោះខ្វឹបថា នេះជារបស់អញ ហៅតណ្ហាថា ជាអារម្មណ៍ ព្រោះលែងបានដោយលំបាក ហៅតណ្ហាថា ធ្វើចិត្តឲ្យកម្រើក ព្រោះធ្វើឲ្យញាប់ញ័រ ។ ម្យ៉ាងទៀត តណ្ហានេះ ជាភក់ គឺកាម ឈ្មោះថា លំបាកដែលសត្វកន្លងទៅបាន ព្រោះជាការជាប់ជំពាក់របស់លោក និងព្រោះសត្វឈានផុតទៅបានលំបាក ។ បើមានពាក្យសួរថា កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះថា មិនគប្បីជាអ្នកអាស្រ័យតណ្ហា ( អាកាស ) ។ សួរថា អាកាសគឺអ្វី គប្បីជ្រាបសម្ពន្ធក្នុងគាថានោះថា ព្រះមានព្រះភាគត្រាស់ថា តថាគតពោលអាកាសថាជាតម្រេក ដោយពាក្យនោះ គប្បីជ្រាបការឆ្លើយ ពាក្យថា ព្រះមានព្រះភាគត្រាស់ថា តថាគតពោលអាកាសថាជាការត្រេកអរ ពោលតណ្ហាថាជាអន្លង់ធំ ពោលតណ្ហាថាជាគ្រឿងស្ទុះទៅរហ័ស ពោលតណ្ហាថាជាគ្រឿងខ្វឹប ពោលតណ្ហាថាជាអារម្មណ៍ ពោលតណ្ហាថាជាការកម្រើក ពោលតណ្ហាថាជាភក់ គឺកាមក្នុងលោក ព្រមទាំងទេវលោក ដែលសត្វឆ្លងបានដោយកម្រ ។ បុគ្គលមិនអាស្រ័យអាកាស ដែលមានពាក្យហៅដោយអមថា ការត្រេកអរជាដើមយ៉ាងនេះហើយ ទើបមានគាថាតទៅថា អ្នកប្រាជ្ញជាព្រាហ្មណ៍ មិនគេចចេញចាកសច្ចៈ ដូច្នេះ ។

គាថានោះ មានអត្ថដូច្នេះថា ព្រាហ្មណ៍មិនគេចចេញចាកសច្ចៈ ៣ ដូចពោលមកអំពីមុនហើយ ហៅឈ្មោះថា ជាមុនី ព្រោះបដិបត្តិបដិបទាដើម្បីភាពជាមុនី តាំងនៅលើគោក គឺព្រះនិព្វាន ព្រាហ្មណ៍នោះឯង លះបង់នូវអាយតនៈទាំងអស់ហើយ តថាគតពោលថាជាអ្នកស្ងប់ មានអ្វីទៀតក្រៃលែង

ជាងនោះ មានគាថាថា **សវេ វិទ្វា** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ញត្វា ធម្មំ** បានដល់ ដឹងធម៌ដែលបច្ច័យតាក់តែង ដោយន័យមានកាពជារបស់មិនទៀងជាដើម ។ បទថា **សម្មា សោ លោកេ ឥរិយានោ** សេចក្តីថា មុនីនោះជាអ្នកនៅក្នុងលោកដោយជុំវិញ ព្រោះលះនូវកិលេសដែលធ្វើឲ្យរស់នៅដោយមិនប្រពៃចេញបាន ។ កាលមិនចង់បានយ៉ាងនេះ គប្បីជ្រាបគាថាបន្តថា **យោធ កាមេ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **សង្គំ** សេចក្តីថា បុគ្គលណា ឆ្លងនូវធម៌ជាគ្រឿងជាប់ជំពាក់ ៧ យ៉ាងបាន ។ បទថា **នាជ្ឈេតិ** គឺរមែងមិនសម្លឹងព្រោះដូច្នោះ ក្នុងបណ្តាអ្នកទាំងឡាយ បុគ្គលណាប្រាថ្នាយ៉ាងនេះ តថាគតពោលដល់បុគ្គលនោះ ។ គប្បីជ្រាបគាថាបន្តថា **យំ បុព្វេ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **បុព្វេ** បានដល់ កិលេសជាត និងកម្មក្នុងអតីតប្រារព្ធសង្ខារក្នុងអតីតកើតឡើងជាធម្មតា ។ បទថា **បច្ឆា តេ មាហុ កិញ្ចនំ** សេចក្តីថា កិលេសជាតជាគ្រឿងកង្វល់ មានរាគៈជាដើម ដែលប្រារព្ធសង្ខារក្នុងអនាគតកើតជាធម្មតាកុំមានដល់អ្នក ។ បទថា **មជ្ឈេ ចេ នោ គហេស្សសិ** សេចក្តីថា បើអ្នកមិនកាន់យកធម៌មានរូបក្នុងបច្ចុប្បន្នជាដើម ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងការសម្រេចអរហត្ត ដោយបទថា **ឧបសន្តោ ចរិស្សសិ** យ៉ាងនេះហើយ ឥឡូវនេះ បានត្រាស់គាថាទាំងឡាយបន្តអំពីនេះ ដោយការសរសើរអរហត្ត ។

ក្នុងបទទាំងនោះ គប្បីជ្រាបសេចក្តីនៃគាថាថា **សព្វសោ** ជាដើមដូចតទៅ

បទថា **មមាយិតំ** បានដល់ ធ្វើនូវការប្រកាន់ថា ជារបស់អញ ឬប្រកាន់វត្ថុថា វត្ថុនេះជារបស់អញ ។ បទថា **អសតា ច ន សោចតិ** បានដល់ មិនសោយសោក ព្រោះហេតុនៃនាមរូបដែលមិនមាន ព្រោះការមិនត្រេកអរ ។ បទថា **ន ជិយ្យតិ** បានដល់ មិនដល់នូវជរា ។ តើមានអ្វីក្រៃលែងជាងនេះទៀត គឺមានគាថាថា **យស្ស នត្ថិ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **កិញ្ចនំ** បានដល់ ធម្មជាត មានរូបជាដើមណាមួយ ។ សួរថា មានអ្វីក្រៃលែងជាងនេះទៀត ឆ្លើយថា មានគាថា **អនុដ្ឋុរិ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **អនុដ្ឋុរិ** បានដល់ មិនប្រកបដោយការខ្វល់ខ្វាយ ។ អាចារ្យពួកខ្លះពោលថា **អនុទ្ធុរី** ក៏មាន ។ បទថា **សព្វធិ សមោ** បានដល់ ជាអ្នកស្មើក្នុងអារម្មណ៍គ្រប់យ៉ាង អធិប្បាយថា ជាអ្នកព្រងើយ ។ បទនេះ លោកអធិប្បាយថា បុគ្គលណាមិនសោយសោកថា របស់អញមិនមាន អញជាបុគ្គលត្រូវសួរដល់បុគ្គលនោះដែលមិនញាប់ញ័រ និងប្រាប់អានិសង្ស ៤ ក្នុងបុគ្គលនោះថា ជាអ្នកមិនខ្វល់ខ្វាយ មិនត្រេកអរ មិនញាប់ញ័រ ជាអ្នកស្មើក្នុងអារម្មណ៍ទាំងពួង ។ សួរថា មានអ្វីក្រៃលែងជាងនេះ ឆ្លើយថា មានគាថាថា **អនេជស្ស** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **និសង្ខតិ** បានដល់ សង្ខារឯណានីមួយ ក្នុងបុញ្ញាភិសង្ខារជាដើម ព្រោះសង្ខារនោះត្រូវតាក់តែង ឬរមែងតាក់តែង ដូច្នោះទើបលោកហៅថា **និសង្ខតិ**។ បទថា **វិយារម្ភា** បានដល់ ចាកអភិសង្ខារ

៣ យ៉ាង មានបុញ្ញាភិសង្ខារជាដើម ។ បទថា **ខេមំ បស្សតិ សព្វធិ** បាន ដល់ ឃើញការមិនមានភ័យ ក្នុងទីទាំងពួងនោះឯង ។ កាលបើដូច្នេះ គប្បី ជ្រាបគាថាបន្តថា **ន សមេសុ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ន វទតេ** បានដល់ មិនពោលលើកខ្លួនក្នុង បុគ្គលដែលស្មើ ដោយប្រកាន់ខ្លួនថា អញ ដូចគ្នាជាដើម សូម្បីក្នុងបុគ្គល ទាបជាង និងបុគ្គលដែលខ្ពស់ជាង ក៏ន័យនេះ ។ បទថា **នាទេតិ ន និរស្សតិ** បានដល់ មិនប្រកាន់ មិនលះនូវធម៌ណាមួយ ក្នុងបណ្តាធម៌ មានរូបជាដើម ។ បទដ៏សេស ជាក់ច្បាស់ហើយ ។ ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនា ដោយធម៌ដ៏កំពូល គឺអរហត្ត ដោយប្រការដូច្នេះ ។

កាលចប់ទេសនា សក្យកុមារ និងកោលិយកុមារ ៥០០ បានបួស ដោយឯហិភិក្ខុបព្វជ្ជា ។ ព្រះមានព្រះភាគ ទ្រង់នាំភិក្ខុទាំងនោះយាងចូលទៅ កាន់ព្រៃមហាវ័ន ។ល។

**អដ្ឋកថាអត្តទណ្ឌសូត្រទី ១៥ ចប់**

# សុត្តន្តបិដក

## សារីបុត្តសូត្រទី១៦

[ ១១០ ] ( ព្រះសារីបុត្តដ៏មានអាយុ បានពោលថា ) ព្រះមានព្រះភាគជាសាស្តាចារ្យ ព្រះអង្គចុះចាកតុសិត មកជាគណាចារ្យ ព្រះអង្គមានព្រះវាចាពីរោះយ៉ាងនេះ ខ្ញុំព្រះអង្គមិនដែលឃើញ មិនដែលឮ អំពីសម្នាក់អ្នកណាមួយ ក្នុងកាលមុនអំពីកាលដែលព្រះអង្គស្តេចចុះមកកាន់ក្រុងសង្កស្សៈសោះឡើយ ។ ព្រះសាស្តាព្រះអង្គមានចក្ខុ ( ដ៏ឧត្តម ) រមែងប្រាកដដល់មនុស្សលោកព្រមទាំងទេវលោក ព្រះអង្គជាបុគ្គលឯក បានបន្ទោបង់នូវងងឹតទាំងអស់ ហើយបានលុះធម៌ដ៏វិសេស ដែលជាទីត្រេកអរ ។ ខ្ញុំព្រះអង្គ មានសេចក្តីត្រូវការនឹងសួរប្រស្នា ដើម្បីសាវកទាំងឡាយច្រើននាក់ ទើបមកគាល់ព្រះអង្គ ជាព្រះពុទ្ធ មានសន្តានបរិសុទ្ធប្រាសចាកតណ្ហានិស្ស័យ និងទិដ្ឋិនិស្ស័យ ព្រះអង្គជាបុគ្គលមិនញាប់ញ័រ ជាបុគ្គលមិនកុហក ជាគណាចារ្យ ស្តេចមកក្នុងក្រុងសង្កស្សៈនេះ កាលបើភិក្ខុនឿម ( អំពីជាតិជាដើម ) ជាអ្នកគប់រកនូវសេនាសនៈស្ងាត់ក្តី នៅទីជិតនៃដើមឈើក្តី នៅព្រៃស្មសានក្តី ឬជាអ្នកនៅអាស្រ័យ ក្នុងល្អាងភ្នំទាំងឡាយក្តី ភិក្ខុកាលនៅក្នុងសេនាសនៈស្ងាត់ ប្រាសចាកសំឡេងគឹកកង មិនគប្បីញាប់ញ័រ ដោយហេតុគួរឲ្យភ័យណា ហេតុគួរឲ្យភ័យក្នុងសេនាសនៈថោកទាប និងឧត្តមនោះ មានប៉ុន្មាន ភិក្ខុនៅក្នុងសេនាសនៈស្ងាត់

គប្បីគ្របសង្កត់សេចក្តីអន្តរាយទាំងឡាយណា សេចក្តីអន្តរាយទាំងឡាយនោះ មានប៉ុន្មាន ដែលនឹងមានដល់ភិក្ខុ កាលទៅកាន់ទិស ដែលគេមិនធ្លាប់ទៅ គឺព្រះនិព្វាន ក្នុងលោកនេះ ។ ពាក្យពេចន៍របស់ភិក្ខុ អ្នកមានខ្លួនបញ្ជូនទៅ គឺជាអ្នកមានព្យាយាមតឹងតែង តើដូចម្តេច គោចរទាំងឡាយក្នុងលោកនេះ របស់លោកតើដូចម្តេច សីល និងវត្តទាំងឡាយរបស់លោក តើដូចម្តេច ភិក្ខុនោះគប្បីសមាទាននូវសិក្ខាដូចម្តេច ទើបជាអ្នកមានសតិ មានចិត្តមូលក្នុងអារម្មណ៍តែមួយ ជាអ្នកមានប្រាជ្ញា គប្បីបន្ទោបង់កិលេស ជាមន្ទិលរបស់ខ្លួនបាន ដូចជាងមាសដេញអាចម៍មាសឲ្យអស់ចេញបាន ។ ( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសារីបុត្ត ) ផាសុវិហារធម៌ ( គ្រឿងនៅសុខសម្រាន្ត ) ណារបស់ភិក្ខុអ្នកខ្ពើម ( អំពីជាតិជាដើម ) អ្នកប្រាថ្នានូវការត្រាស់ដឹង សេពនូវសេនាសនៈស្ងាត់ តថាគតនឹងពោលនូវផាសុ-វិហារធម៌នោះ ធម៌ដ៏សមគួរដល់អ្នកតាមដឹង ។ ភិក្ខុជាអ្នកប្រាជ្ញមានស្មារតី ប្រព្រឹត្តក្នុងគុណ មានទីបំផុតដោយជុំវិញ មិនគប្បីខ្លាចនូវភ័យទាំង ៥ យ៉ាង គឺមិនខ្លាចសត្វរបោម ១ ស្រមោច ១ ពស់តូចពស់ធំ ១ ផស្សៈនៃមនុស្សជាចោរ ១ ពួកសត្វជើងបួន ១ ភិក្ខុអ្នកប្រាជ្ញនោះ ជាអ្នកស្វះស្វែងរកកុសលធម៌ សូម្បីបានឃើញជន ដែលក្រៅអំពីសហធម្មិកៈ ឬបានឮសំឡេងដែល

ខ្លួនគួរខ្លាចដ៏ច្រើន របស់ជនទាំងនោះ ឬអន្តរាយយ៉ាងដទៃៗ គប្បីគ្របសង្កត់ មិនគប្បីតក់ស្លុត រន្ធត់ឡើយ ។ ភិក្ខុអ្នកប្រាជ្ញនោះ បើផស្សៈនៃរោគ ឬសេចក្ដីស្រេកឃ្លាន ឬក៏ត្រជាក់ និងក្ដៅពាល់ត្រូវហើយ គប្បីខំអត់សង្កត់ ភិក្ខុនោះ ដែលផស្សៈនៃរោគ និងសេចក្ដីស្រេកឃ្លាន ( ជាដើមនោះ ) ពាល់ត្រូវហើយ ( ដោយអាការផ្សេងៗ ) សូម្បីច្រើន យ៉ាងណា ក៏មិនបានធ្វើឱកាស ( ឲ្យដល់វិញ្ញាណដែលប្រកបដោយសង្ខារ គឺចិត្តដែលសម្បយុត្តដោយកុសលាកុសលចេតនា ) គប្បីធ្វើសេចក្ដីព្យាយាមប្រឹងប្រែងមុតមាំ ។ ភិក្ខុមិនគប្បីធ្វើការលួច មិនគប្បីពោលពាក្យកុហក គប្បីផ្សាយមេត្តាចិត្តចំពោះពួកសត្វ ដែលមានចិត្តតក់ស្លុត និងមានចិត្តរឹងប៉ឹង គឺពួកសត្វដែលមានចិត្តប្រកបដោយតណ្ហា និងប្រាសចាកតណ្ហាក្នុងកាលណា ភិក្ខុ បើដឹងនូវភាពនៃចិត្តកករល្អក់ក្នុងកាលនោះ គប្បីបន្ទោបង់នូវភាពនៃចិត្តកករល្អក់នោះចេញ ដោយគិតថា នុ៎ះជាពួកបក្ខនៃធម៌ខ្មៅ ។ ភិក្ខុមិនគួរលុះអំណាចនៃសេចក្ដីក្រោធ និងសេចក្ដីប្រកាន់ខ្លួនហួសហេតុ មួយទៀត គប្បីគាស់រម្លើងឫសនៃសេចក្ដីក្រោធ និងសេចក្ដីប្រកាន់ហួសហេតុទាំងនោះចេញ មួយវិញទៀត គប្បីទម្រុឌទម្រោម គ្របសង្កត់សេចក្ដីស្រឡាញ់ និងសេចក្ដីស្អប់ឲ្យជ្រះស្រឡះ ។ ភិក្ខុអ្នកមានបីតិដ៏ល្អគប្បីធ្វើប្រាជ្ញាឲ្យប្រព្រឹត្តទៅក្នុងខាងមុខហើយ គប្បីសង្កត់សង្កិន

សេចក្តីអន្តរាយនោះ គប្បីអត់សង្កត់សេចក្តីមិនត្រេកអរក្នុងសេនាសនៈស្ងាត់ គប្បីអត់សង្កត់ធម៌ជាទីតាំងនៃសេចក្តីខ្សឹកខ្សួល ៤ យ៉ាង ភិក្ខុអ្នកសិក្សាក្នុងត្រៃសិក្ខា ជាអ្នកមិនមានកន្លល់ត្រាច់ទៅ គប្បីបន្ទោបង់សេចក្តីត្រិះរិះ ៤ យ៉ាង ដែលជាទីតាំងនៃសេចក្តីខ្សឹកខ្សួល គឺត្រិះរិះថា អញនឹងបានរបស់អ្វីបរិភោគ ១ ថាអញនឹងបរិភោគក្នុងទីណា ១ ថាអញដេកជាទុក្ខក្នុងរាត្រីនេះ ១ ថាអញនឹងដេកក្នុងទីណា ( ទើបជាសុខសប្បាយ ) ១ ។ ភិក្ខុក្នុងធម្មវិន័យនេះ បានទូវបាយផង នូវសំពត់ស្លៀកដណ្តប់ផង ក្នុងកាលគួរ ភិក្ខុនោះ គប្បីដឹងប្រមាណ ( ក្នុងការទទួល ឬការប្រើប្រាស់នូវបច្ច័យ ៤ ) ដើម្បីសន្តោស ភិក្ខុនោះ គប្បីជាអ្នកគ្រប់គ្រងក្នុងបច្ច័យទាំង ៤ នោះ គប្បីជាអ្នកមានការប្រព្រឹត្តសង្រួមក្នុងស្រុកទេស សូម្បីត្រូវអ្នកណាៗ ប្រទូស្តហើយ ក៏មិនគប្បីពោលពាក្យអាក្រក់ ( ទៅរកអ្នកនោះ ) ។ ភិក្ខុគប្បីជាអ្នកមានចក្ខុដាក់ចុះ មួយទៀត មិនគប្បីជាអ្នករពឹសជើង គប្បីជាអ្នកប្រកបរឿយៗក្នុងឈាន ជាអ្នកភ្ញាក់រឭកច្រើន ជាអ្នកប្រារព្ធឧបេក្ខា ហើយមានចិត្តតម្កល់មាំ គប្បីកាត់អកុសលវិតក្ក និងធម៌ជាទីអាស្រ័យនៅនៃអកុសលវិតក្ក និងការរពឹស ( មានរពឹសដៃជាដើម ) ។ ភិក្ខុកាលគេដាស់តឿន ដោយពាក្យទាំងឡាយ គប្បីជាអ្នកមានស្មារតីទទួលត្រេកអរ គប្បីជាអ្នកទម្លាយចិត្តរឹងរូសក្នុងសព្រហ្មចារីទាំង-

ឡាយចេញ គប្បីបញ្ចេញវាចាជាកុសល មិនគប្បីបញ្ចេញវាចាហួសកំណត់ កុំគិតគូរក្នុងពាក្យគរហានិន្ទា របស់ពួកជន ។ មួយទៀត ភិក្ខុអ្នកមានស្មារតី គប្បីសិក្សាក្នុងត្រៃសិក្ខា ដើម្បីកម្ចាត់បង់ធូលីណា ធូលីនោះមាននៅក្នុងលោក ៥ យ៉ាង គឺរូបរាគៈ ១ សទ្ទរាគៈ ១ គន្ធរាគៈ ១ រសរាគៈ ១ ផស្សរាគៈ ១ ភិក្ខុនោះគប្បីអត់សង្កត់ នូវសេចក្តីត្រេកអរក្នុងរូប សំឡេង ក្លិន រស ផស្សៈទាំងនោះចេញ ។ ភិក្ខុជាអ្នកមានស្មារតី មានចិត្តផុតស្រឡះហើយដោយប្រពៃ គប្បីកម្ចាត់បង់សេចក្តីប៉ុនប៉ង ក្នុងកាមារម្មណ៍ទាំងឡាយនោះចេញ ( គ្រាសមាធិចិត្តកើតឡើងហើយ ) ភិក្ខុនោះ ( មិនបានឈប់នៅត្រឹមប៉ុណ្ណោះ ) ទំត្រិះរិះពិចារណាធម៌ ដោយត្រឹមត្រូវតាមកាលតទៅទៀត ភិក្ខុនោះ គប្បីជាអ្នកមានចិត្តជាឯកគ្គតា កម្ចាត់បង់ងងឹត គឺកិលេសចេញ ។

សារីបុត្តសូត្រទី ១៦ ចប់

អដ្ឋកវគ្គទី ៤ ចប់

## ឧទ្ទាននៃអដ្ឋកវគ្គទី ៤ នោះគឺ

និយាយអំពីកាមសូត្រ ១ គុហដ្ឋកសូត្រ ១ ទុដ្ឋដ្ឋកសូត្រ ១ សុទ្ធដ្ឋកសូត្រ ១ បរមដ្ឋកសូត្រ ១ ជរាសូត្រ ១ តិស្សមេ-តេយ្យសូត្រ ១ បសូរសូត្រ ១ មាគន្ទិយសូត្រ ១ បុរាភេទ-សូត្រ ១ កលហវិវាទសូត្រ ១ វិយូហសូត្រ ២ តុវដកសូត្រ ១ អត្តទណ្ឌសូត្រ ១ សារីបុត្តសូត្រ ១ សូត្រទាំង ១៦ នុ៎ះ មានក្នុងអដ្ឋកវគ្គទាំងអស់ ដោយប្រការដូច្នេះ ។

# អដ្ឋកថា

## សារីបុត្តសូត្រ

[ ១១០ ] ក្នុងសារីបុត្តសូត្រទី ១៦ មានពាក្យផ្ដើមថា **ន មេ ទិដ្ឋោ** ដូច្នេះ លោកពោលថា ថេរប្បញ្ហាសូត្រក៏មាន ។

សួរថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា ព្រះសូត្រនេះ មានអត្ថុប្បត្តិហេតុដូចតទៅនេះ

អត្ថុប្បត្តិហេតុនៃសូត្រនេះ ផ្ដើមតាំងអំពីសេដ្ឋីអ្នកក្រុងរាជគ្រឹះ បានពកនៃដើមចន្ទន៍ក្រហម ហើយយកពកចន្ទន៍ក្រហមធ្វើជាបាត្រ លើកឡើងព្យួរលើអាកាស ព្រះបិណ្ឌោលភារទ្វាជត្ថេរ យកបាត្រទៅដោយឫទ្ធិ ការហាមសាវក

ទាំងឡាយសម្ដែងឫទ្ធិ ព្រោះរឿងនោះ ពួកតិរ្ថិយបំណាំងនឹងធ្វើបាដិហារ្យជាមួយនឹងព្រះមានព្រះភាគ ។ ការធ្វើបាដិហារ្យ ការយាងទៅក្រុងសាវត្ថីរបស់ព្រះមានព្រះភាគ ការដើរតាមរបស់ពួកតិរ្ថិយ ការចូលគាល់ព្រះពុទ្ធរបស់ព្រះបាទបសេនទិ ក្នុងក្រុងសាវត្ថី ការកើតឡើងនៃដើមគណ្ឌម្ពព្រឹក្ស ការឃាត់បរិស័ទ ៤ សម្ដែងបាដិហារ្យដើម្បីឈ្នះតិរ្ថិយ ការធ្វើយមកប្បាដិហារ្យ ការយាងទៅតាវត្តិង្សភពរបស់ព្រះមានព្រះភាគ ក្រោយអំពីធ្វើបាដិហារ្យហើយ ការសម្ដែងធម៌អស់ ៣ ខែ ក្នុងតាវត្តិង្សនោះ និងការយាងចុះមកអំពីទេវលោកត្រង់សង្កស្សនគរ ជាមួយព្រះមហាមោគ្គល្លានត្ថេរ រឿងទាំងនេះ រួមទាំងជាតកដំបូង រហូតដល់ព្រះមានព្រះភាគបានទទួលការបូជាអំពីពួកទេវតា ក្នុងម៉ឺនចក្កវាឡ ហើយយាងចុះកាន់ត្រង់សង្កស្សនគរ ដោយជណ្ដើរកែវ ដែលជាជណ្ដើរកណ្ដាល ទ្រង់ឈរត្រង់ជើងជណ្ដើរ បានពោលហើយ ក្នុងគាថាធម្មបទ ដោយប្រការដូច្នេះ ។

អ្នកប្រាជ្ញទាំងឡាយណា ជាអ្នកខ្វល់ខ្វាយក្នុងឈាន ត្រេកអរក្នុងនេក្ខម្ម: ជាឋានស្ងប់រម្ងាប់កិលេស សូម្បីទេវតា និងមនុស្សទាំងឡាយ តែងរាប់រកចំពោះអ្នកប្រាជ្ញទាំងឡាយនោះ ដែលជាអ្នកត្រាស់ដឹងខ្លួនឯង ទាំងមានស្មារតី ដូច្នេះ ។

ព្រះសារីបុត្ត ថ្វាយបង្គំព្រះមានព្រះភាគ ដែលប្រថាប់ឈរត្រង់ជណ្ដើរបានមុនគេ បន្ទាប់មក ភិក្ខុនីឧប្បលវណ្ណា បន្តមក មហាជនដទៃៗ ។ ក្នុងទីនោះ ព្រះមានព្រះភាគទ្រង់ត្រិះរិះថា ក្នុងបរិស័ទនេះ មោគ្គល្លាន ប្រាកដជា

 ៧១០

ជាកំពូលខាងឫទ្ធិ អនុរុទ្ធជាកំពូលខាងទិព្វចក្ខុ បុណ្ណៈជាកំពូលខាងធម្មកថិក តែបរិស័ទនេះ មិនស្គាល់សារីបុត្តថា ជាកំពូលដូចម្តេចឡើយ បើដូច្នោះ តថាគតគប្បីប្រកាសសារីបុត្តដោយបញ្ញាគុណក្នុងកាលឥឡូវនេះ ។ គ្រានោះ ព្រះមានព្រះភាគក៏ត្រាស់សួរបញ្ហាជាមួយព្រះថេរៈៗ ឆ្លើយបញ្ហាបានទាំងអស់ ទាំងជាបញ្ហារបស់បុថុជ្ជន បញ្ហារបស់ព្រះសេក្ខៈ និងបញ្ហារបស់អសេក្ខៈ ។ ក្នុងកាលនោះ ទើបជនបានស្គាល់ព្រះសារីបុត្តថា ជាកំពូលខាងបញ្ញា ។ ព្រះមានព្រះភាគត្រាស់ថា សារីបុត្តមានប្រាជ្ញាតែក្នុងកាលឥឡូវនេះ ក៏មិនមែន សូម្បីក្នុងអតីតក៏ជាបុគ្គលកំពូលដោយបញ្ញា ទើបទ្រង់នាំជាតកមកត្រាស់ថា

ក្នុងអតីតកាល ឥសីច្រើនពាន់ មានមើមឈើ និងផ្លែឈើក្នុងព្រៃជាអាហារ អាស្រ័យត្រង់ជើងភ្នំ ។ អាចារ្យរបស់ឥសីទាំងនោះកើតអាពាធ ទើបត្រូវឧបដ្ឋាក ។ អន្តេវាសិកដែលជាសិស្សច្បង គិតថា អញនឹងរកភេសជ្ជៈជាទីសប្បាយ ដូច្នេះហើយ ពោលថា ពួកលោកកុំប្រមាទក្នុងការឧបដ្ឋាកអាចារ្យ ទើបចូលទៅកាន់ស្រុក ។ កាលសិស្សច្បងនៃអន្តេវាសិកនោះ មិនទាន់ត្រឡប់ អាចារ្យក៏ធ្វើមរណកាលហើយ ។ ពួកអន្តេវាសិកគិតគ្នាថា ឥឡូវនេះ អាចារ្យនឹងអនិច្ចកម្ម ។ ទើបសួរទាក់ទងដល់សមាបត្តិ អាចារ្យពោលថា **នត្ថិ កិញ្ចិ** អ្វីតិចតួចមិនមាន ដោយសំដៅដល់អាកិញ្ចញ្ញាយតនសមាបត្តិ ។ ពួកអន្តេវាសិកយល់ថា អាចារ្យមិនបានសម្រេច ។ គ្រានោះ អន្តេវាសិកច្បងនាំថ្នាំមក ឃើញអាចារ្យស្លាប់ក៏ពោលថា ពួកលោកបានសួរពាក្យណាមួយនឹងលោកអាចារ្យដែរឬ ។ អន្តេវាសិកទាំងឡាយពោលថា ពួក

ខ្ញុំបានសួរដែរ អាចារ្យពោលថា អ្វីតិចតួចមិនមាន គឺអាចារ្យមិនបានសម្រេចអ្វីឡើយ សិស្សច្បងពោលថា អាចារ្យពោលថា អ្វីតិចតួចមិនមាន លោកប្រាប់ឲ្យដឹងដល់អាកិញ្ចញ្ញាយតនៈ ចូរពួកលោកគោរពអាចារ្យ ។

ជនទាំងឡាយមកប្រជុំគ្នាហើយ សូម្បីជាងពាន់នាក់ ជនទាំងនោះឥតប្រាជ្ញា គប្បីកន្ទក់កន្ទេញអស់មួយរយឆ្នាំ បុរសណា ប្រកបដោយប្រាជ្ញា បានដឹងច្បាស់នូវអត្ថនៃភាសិត បុរសនោះ នៅតែម្នាក់ឯង ប្រសើរជាង ដូច្នេះ ។

កាលព្រះមានព្រះភាគត្រាស់ជាតកហើយ ព្រះសារីបុត្ត ដើម្បីនឹងទូលសួរដល់សេនាសនៈ និងគោចរជាទីសប្បាយ និងសីលវត្ត ដើម្បីជាប្រយោជន៍ដល់ភិក្ខុ ៥០០ ដែលជាសទ្ធិវិហារិករបស់ខ្លួន ទើបពោល ៨ គាថា ផ្ដើមនូវគាថាសរសើរនេះថា **ន មេ ទិដ្ឋោ ឥតោ បុព្វេ** ដូច្នេះជាដើម ។ ព្រះមានព្រះភាគកាលទ្រង់ឆ្លើយសេចក្ដីនោះ បានត្រាស់គាថាដ៏សេសបន្ទាប់អំពីនោះ ។

ក្នុងបទទាំងនោះ បទថា **ឥតោ បុព្វេ** បានដល់ ក្នុងកាលមុនអំពីទ្រង់ចុះត្រង់សង្កស្សនគរនេះ ។ បទថា **វគ្គុវទោ** បានដល់ មានព្រះវាចាពីរោះ ។ បទថា **តុសិតា គណិមាគតោ** សេចក្ដីថា ព្រះពុទ្ធអង្គយាងមកអំពីជាន់តុសិត ព្រោះទ្រង់ចុតិអំពីជាន់តុសិត ហើយមកបដិសន្ធិកាន់ព្រះគភ៌ព្រះមាតា ។

ដែលឈ្មោះថា **គណី** ព្រោះជាគណាចារ្យ ឬយាងមកអំពីទេវលោកគឺជាន់តុសិត ព្រោះនាំនូវការត្រេកអរ មកកាន់គណៈ ឬយាងចាកជាន់តុសិតមកកាន់គណៈរបស់ព្រះអរហន្តទាំងឡាយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ២ តទៅ បទថា **សទេវកស្ស លោកស្ស យថា ធិស្សតិ** សេចក្តីថា ប្រាកដដល់មនុស្សទាំងឡាយ ដូចប្រាកដដល់លោក ព្រមទាំងទេវលោក ឬប្រាកដដោយភាពជារបស់ពិតប្រាកដ ដោយមិនវិបរិត ។ បទថា **ចក្ខុមា** បានដល់ មានចក្ខុដ៏កំពូល ។ បទថា **ឯកោ** បានដល់ ទ្រង់ម្នាក់ឯងដោយទាក់ទងក្នុងបព្វជ្ជាជាដើម ។ បទថា **រតឹ** បានដល់ ទ្រង់ត្រេកអរក្នុងនេក្ខម្មគុណជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៣ ថា បទថា **ពហុន្នមិធ ពទ្ធានំ** សេចក្តីថា សិស្សទាំងឡាយ មានក្សត្រជាដើមជាច្រើន ដែលទាក់ទងគ្នាក្នុងទីនេះ ។ ពិតហើយ សិស្សទាំងឡាយ លោកហៅថា **ពទ្ធា** ព្រោះមានការប្រព្រឹត្តពាក់ព័ន្ធក្នុងអាចារ្យ ។ បទថា **អត្ថិ បញ្ហេន អាគមំ** សេចក្តីថា ត្រូវការដោយបញ្ហាទើបមក ឬការមករបស់បុគ្គលដែលសួរបញ្ហា ឬមានបញ្ហា ទើបមក ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៤ ថា បទថា **វិជិគុច្ឆតោ** បានដល់ ខ្ពើមរអើមដោយទុក្ខ មានជាតិជាដើម ។ បទថា **រិត្តមាសនំ** បានដល់ គ្រែនិងតាំងដ៏ស្ងាត់ ។ បទថា **បព្វតានំ គុហាសុ វា** គប្បីភ្ជាប់អត្ថជាមួយនឹងបទថា **បព្វតគុហាសុ វា រិត្តមាសនំ ភជតោ** ( សេពទីអង្គុយដ៏ស្ងាត់ត្រង់គុហានៃភ្នំទាំងឡាយ ) ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៥ ថា បទថា **ឧច្ចាវចេសុ** បានដល់ ប្រណីត និងថោកទាប ។ បទថា **សយនេសុ** បានដល់ ក្នុងសេនាសនៈ

មានវិហារជាដើម ។ បទថា **កីវន្តោ តត្ថ ភេរវា** បានដល់ ព្រោះការខ្លាច ក្នុងទីដេក ទីអង្គុយ មានប្រមាណប៉ុន្មាន ។ បាឋៈថា **កីវន្តោ** ដូច្នេះក៏មាន ។ បទនេះ មានសេចក្ដីថា ប៉ុន្មាន ។ តែបទមុខ និងបទក្រោយមិនតគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៦ ថា បទថា **កតី បរិស្សយា** បានដល់ អន្តរាយមានប្រមាណប៉ុន្មាន ។ បទថា **អមតំ ទិសំ** បានដល់ ព្រះនិព្វាន ។ ព្រោះនិព្វាននោះ ជាអមតៈ ឈ្មោះថា **ទិស** ព្រោះចង្អុលប្រាប់អត្ថ ដោយហេតុនោះ ទើបលោកពោលថា **អមតំ ទិសំ** ដូច្នេះ ។ បទថា **អភិសម្ភវេ** បានដល់ គប្បីគ្របសង្កត់ ។ បទថា **បន្តម្ហិ** បានដល់ នៅចុងក្រោយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៧ ថា បទថា **ក្យាស្ស ព្យបថយោ អស្សុ** បានដល់ ភិក្ខុនោះគប្បីមានពាក្យដូចម្ដេច ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៨ ថា បទថា **ឯកោទិ និបកោ** បានដល់ មានឯកគ្គតាចិត្តជាបណ្ឌិត ។ ព្រះមានព្រះភាគ កាលព្រះសារីបុត្តសរសើរ ៣ គាថា ហើយទូលសួរដល់សេនាសនៈ គោចរ សីល និងវត្តជាដើម ដើម្បីជាប្រយោជន៍ដល់សិស្ស ៥០០ ដោយ ៥ គាថាថា ព្រះមានព្រះភាគដើម្បីទ្រង់ប្រកាសសេចក្ដីនោះ ទើបទ្រង់ផ្ដើមឆ្លើយបញ្ហា ដោយន័យជាដើមថា **វិជិគុច្ឆមានស្ស** ដូច្នេះ ។

ក្នុងបទទាំងនោះ គប្បីជ្រាបគាថាទី ១ សិន ព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្ត បើធម៌ជាគ្រឿងនៅ និងធម៌ដែលសមគួរនេះរបស់ភិក្ខុ

ដែលខ្ទើមទុក្ខ មានជាតិជាដើម ។ បុគ្គលណានឹងត្រាស់ដឹង សេពនូវទីអង្គុយ និងទីដេកដ៏ស្ងាត់ តថាគតពោលធម៌ជាទីនៅ និងធម៌ដែលសមគួរនោះ តាមដែលដឹងដល់អ្នក ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ២ ថា បទថា **បរិយន្តចារី** បានដល់ប្រព្រឹត្តក្នុងព្រំដែន ៤ មានសីលជាដើម ។ បទថា **ឌំសាធិបាតានំ** បានដល់របោម និងមូស ព្រោះមូសទាំងឡាយឱនចុះបឺត ដូច្នោះ ទើបហៅថា **អធិបាតា** ប្រែថា ឱនបឺតឈាម ។ បទថា **មនុស្សផស្សានំ** បានដល់ ផស្សៈកើតអំពីភ័យ មានចោរភ័យជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៣ ថា សហធម្មិក ៧ ពួក ឈ្មោះថា **បរធម្មិកា** ទាំងអស់ ក៏ជាមនុស្សខាងក្រៅ ។ បទថា **កុសលានុឯសី** បានដល់ បុគ្គលស្វែងរកកុសលធម៌រឿយៗ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៤ ថា បទថា **អាតង្កផស្សេន** បានដល់ដែលផស្សៈកើតអំពីរោគ ។ បទថា **សីតំ អច្ចុណ្ហំ** បានដល់ ត្រជាក់ និងក្តៅ ។ បទថា **សោ តេហិ ផុដ្ឋោ ពហុធា** បានដល់ ជាបុគ្គលត្រូវអាការជាច្រើន មានរោគជាដើមនោះពាល់ត្រូវហើយ ។ បទថា **អនោកោ** បានដល់ មិនធ្វើឱកាសឲ្យដល់អភិសង្ខារ និងវិញ្ញាណជាដើម ។

ព្រះមានព្រះភាគ កាលទ្រង់ស្រាយបញ្ហាដែលព្រះសារីបុត្តសួរហើយ ៣ គាថា មានគាថាថា **ភិក្ខុនោ វិជិគុច្ឆតោ** យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ស្រាយបញ្ហាដែលព្រះសារីបុត្តសួរ ដោយន័យជាដើមថា **ក្យាស្ស**

**ព្យបថយោ** ទើបត្រាស់ពាក្យជាដើមថា **ថេយ្យំ ន ការេយ្យ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ផស្សេ** បានដល់ គប្បីផ្សាយទៅ ។ បទថា **យទាវិលត្តំ មនសោ វិជញ្ញា** សេចក្តីថា គប្បីបន្ទោបង់នូវការល្អក់កករនៃចិត្តដែលខ្លួនដឹងទាំងអស់នោះ ដោយគិតថា នេះជាចំណែកនៃធម៌ខ្មៅ ។ បទថា **មូលម្បិ តេសំ បលិខញ្ញ តិដ្ឋេ** បានដល់ គប្បីជីកឫសគល់ មានអវិជ្ជាជាដើមនៃសេចក្តីក្រោធ និងការមើលងាយទាំងនោះ ហើយតាំងនៅ ។ បទថា **អទ្ធា ភវន្តោ អភិសម្ភវេយ្យ** សេចក្តីថា កាលគ្របសង្កត់ ក៏គប្បីគ្របសង្កត់សេចក្តីស្រឡាញ់ ឬការមិនស្រឡាញ់ដោយពិតយ៉ាងនេះ អធិប្បាយថា មិនគប្បីព្យាយាមឲ្យធូរថយក្នុងសេចក្តីនោះ ។ បទថា **បុញ្ញំ បុរក្ខត្វា** បានដល់ ធ្វើបុណ្យទុកមុន ។ បទថា **កល្យាណបីតិ** បានដល់ ប្រកបដោយបីតិដ៏ល្អ ។ បទថា **ចតុរោ សហេថ បរិទេវធម្មេ** សេចក្តីថា គប្បីគ្របសង្កត់នូវធម៌ជាទីតាំងនៃការកន្ទក់កន្ទេញ ដូចពោលហើយក្នុងគាថាតាមលំដាប់ ។

បទថា **កឹសូ អសិស្សាមិ** បានដល់ ខ្ញុំនឹងបរិភោគអ្វី ។ បទថា **កុវំ វា អសិស្សំ** បានដល់ ខ្ញុំនឹងបរិភោគទីណា ។ បទថា **ទុក្ខំ វត សេត្ថ កុវជ្ជ សេស្សំ** បានដល់ យប់នេះ ខ្ញុំដេកជាទុក្ខពន់ពេក យប់នេះ ខ្ញុំដេកឯណា ។ បទថា **ឯតេ វិតក្កេ** បានដល់ វិតក្ក ៤ យ៉ាង គឺវិតក្កអាស្រ័យបិណ្ឌបាត ២ វិតក្កអាស្រ័យសេនាសនៈ ២ ។ បទថា **អនិកេតចារី** បានដល់ មិនមានការអាឡោះអាល័យត្រាច់ទៅ គឺមិនមានការចង់បានត្រាច់ទៅ ។

បទថា **កាលេ** អធិប្បាយថា បានបាយ គឺបិណ្ឌបាតក្នុងពេលបិណ្ឌបាត ឬបាននូវគ្រឿងស្លៀកដណ្តប់ គឺចីវរ ក្នុងចីវរកាល ដោយធម៌ដ៏ស្មើ ។ បទថា **មត្តំ សោ ជញ្ញា** សេចក្តីថា ភិក្ខុនោះ គប្បីស្គាល់ប្រមាណក្នុងការទទួល និងក្នុងការបរិភោគ ។ បទថា **ឥធ** បានដល់ ក្នុងសាសនានេះ ឬថា បទនេះ ត្រឹមតែជានិបាត ។ បទថា **តោសនត្ថំ** បានដល់ ដើម្បីការត្រេកអរ លោកអធិប្បាយថា គប្បីដឹងនូវប្រមាណក្នុងសេចក្តីត្រូវការនេះ ។ បទថា **សោ តេសុ គុត្តោ** សេចក្តីថា ភិក្ខុនោះ គ្រប់គ្រងហើយក្នុងបច្ច័យទាំងនោះ ។ បទថា **យតចារី** បានដល់ សង្រួមការនៅ សង្រួមឥរិយាបថ អធិប្បាយថា រក្សាកាយទ្វារ វចីទ្វារ និងមនោទ្វារ ។ បាឋៈថា **យថាចារី** ដូច្នេះក៏មាន ។ ឯសេចក្តីដូចគ្នាតែមួយ ។ បទថា **រុសិតោ** បានដល់ ជ្រៀតបៀត ។ អធិប្បាយថា ខឹងក្រោធ ។ បទថា **ឈានានុយុត្តោ** បានដល់ ជាអ្នកខ្វល់ខ្វាយក្នុងឈាន ដោយការធ្វើឈាន ដែលមិនទាន់កើត ឲ្យកើតឡើង និងសេពឈានដែលកើតឡើងហើយ ។ បទថា **ឧបេក្ខមារព្ភ សមាហិតត្តោ** បានដល់ ញុំាងឧបេក្ខាក្នុងចតុត្ថជ្ឈានឲ្យកើតហើយមាន ចិត្តតាំងមាំ ។ បទថា **តក្កាសយំ កុក្កុច្ចិយូបឆិន្ទេ** សេចក្តីថា គប្បីកាត់នូវវិតក្ក មានកាមវិតក្កជាដើម និងធម៌ដែលជាទីនៅនៃការត្រិះរិះ មានកាមសញ្ញាជាដើម និងការឃ្នើសឃ្នង មានឃ្នើសឃ្នងដៃជាដើម ។ បទថា **ចុទិតោ វចីភិ សតិមាភិនន្ទេ** សេចក្តីថា ភិក្ខុដែលឧបជ្ឈាយ៍ជាស់តឿនហើយដោយវាចា គប្បីជាអ្នកមានសតិត្រេកអរទទួលពាក្យជាស់តឿននោះ ។ បទថា **វាចំ បមុញ្ចេ**

**កុសលំ** បានដល់ គប្បីបន្ទឺវាចាដែលតាំងឡើងហើយដោយញាណ មិនគប្បីបន្ទឺវាចាឲ្យហួសកាលវេលា គឺមិនគប្បីបន្ទឺវាចាហួសកាលវេលា និងកន្លងសីល ។ បទថា **ជនវាទធម្មាយ** បានដល់ ក្នុងការពោលតិះដៀលជាតិអ្នកដទៃ ។ បទថា **ន ចេតយេយ្យ** បានដល់ មិនឲ្យកើតនូវចេតនា ។ បទថា **អថាបរំ** បានដល់ បន្ទាប់អំពីបច្ចុប្បន្ននេះទៅ ។ បទថា **បញ្ច រជានិ** បានដល់ ធូលី ៥ មានរូបរាគៈជាដើម ។ បទថា **យេសំ សតិមា វិនយាយ សិក្ខេ** បានដល់ គប្បីជាអ្នកមានសតិតាំងមាំ សិក្សានូវត្រៃសិក្ខាដើម្បីបង្ក្រាបនូវធូលី ។ ភិក្ខុកាលសិក្សាយ៉ាងនេះ គ្របសង្កត់នូវតម្រេកក្នុងរូប សំឡេង ក្លិន រស និងផស្សៈ មិនមែនដទៃ ។ បន្ទាប់អំពីនោះ ភិក្ខុនោះសិក្សាដើម្បីកម្ចាត់ធូលីទាំងនោះ តាមគាថាថា **ឯតេសុ ធម្មេសុ** ដូច្នេះតាមលំដាប់ ។

ក្នុងបទទាំងនោះ បទថា **ឯតេសុ** បានដល់ ក្នុងរូបជាដើម ។ បទថា **កាលេន សោ សម្មាធម្មំ បរិវីមំសមានោ** សេចក្ដីថា ភិក្ខុនោះពិចារណានូវធម៌ ដែលជាសង្ខតធម៌ទាំងអស់ ដោយន័យមានការមិនទៀងជាដើមតាមកាល ដូចលោកពោលហើយ ដោយន័យជាដើមថា កាលលើកលំដាប់ចិត្តឡើង ក៏ជាកាលនៃសមាធិ ។ បទថា **ឯកោទិភូតោ វិហនេ តមំ សោ** បាន

ដល់ ភិក្ខុនោះ មានចិត្ត មានអារម្មណ៍តែមួយ គប្បីកម្ចាត់នូវងងឹតទាំងអស់ មានមោហៈជាដើម មិនមានសង្ស័យក្នុងសេចក្តីនេះ ។ បទដ៏សេស ក្នុងបទទាំងពួង ជាក់ច្បាស់ហើយ ។ ព្រះមានព្រះភាគទ្រង់បញ្ចប់ទេសនា ដោយកំពូលនៃធម៌ គឺអរហត្ត ដោយប្រការដូច្នេះ ។

ក្នុងកាលចប់ទេសនា ភិក្ខុ ៥០០ រូប សម្រេចអរហត្តហើយ ។ ធម្មាភិសម័យមានដល់ពួកទេវតា និងមនុស្ស ៣០ កោដិ ។

**អដ្ឋកថាសារីបុត្តសូត្រទី ១៦ ចប់**

**អដ្ឋកវគ្គទី ៤ ចប់**

# សុត្តន្តបិដក

# សុត្តនិបាត បារាយនវគ្គទី៥

## វត្ថុកថា

[ ១១១ ] ( ព្រះអានន្ទដ៏មានអាយុ បានលើករឿងនេះ មកកាន់ទីប្រជុំ ក្នុងកាលធ្វើសង្គាយនាថា ព្រាហ្មណ៍ឈ្មោះពាវរី ) ជាអ្នកដល់នូវត្រើយនៃមន្ត ប្រាថ្នានូវភាពជាអ្នកមិនកង្វល់ បានចេញអំពីបុរីនៃដែនកោសល ជាបុរីដ៏សប្បាយរីករាយ ទៅកាន់ទក្ខិណាបថជនបទ ។ ពាវរីព្រាហ្មណ៍នោះ នៅអាស្រ័យទៀបច្រាំងស្ទឹងគោធាវរី ជិតដែនអស្សកៈ និងជិតដែនមុឡកៈ ចិញ្ចឹមជីវិតដោយការស្វះស្វែងរក ( សូមគេ ) ផង ដោយមើមឈើ និងផ្លែឈើផង ។ ស្រុកនោះបានរីកធំទូលាយ ព្រោះអាស្រ័យពាវរីព្រាហ្មណ៍នោះឯង ឯពាវរីព្រាហ្មណ៍នោះ បានបរិច្ចាគនូវមហាយញ្ញ ដោយសារអាករសួយរ៉ៃ ដែលកើតឡើងអំពីស្រុកនោះ លុះពាវរីព្រាហ្មណ៍ បានបូជានូវមហាយញ្ញរួចហើយ ក៏ចូលទៅកាន់អាស្រមវិញ ។ កាលពាវរីព្រាហ្មណ៍នោះ ចូលទៅកាន់អាស្រមវិញហើយ មានព្រាហ្មណ៍ដទៃទៀត មានជើងញាប់ញ័រ ស្រេកឃ្លាន មានធ្មេញពណ៌ដូចភក់ មានក្បាលប្រឡាក់ដោយធូលី ព្រាហ្មណ៍នោះ បានដើរចូលទៅរកពាវរីព្រាហ្មណ៍នោះ ហើយសូមវត្ថុ ៥០០ ។

ពាវរីព្រាហ្មណ៍បានឃើញព្រាហ្មណ៍នោះហើយ ក៏អញ្ជើញដោយអាសនៈ សាកសួរសេចក្តីសុខផង កុសលផង ហើយបានពោលពាក្យនេះថា ទេយ្យធម៌ណារបស់ខ្ញុំ ទេយ្យធម៌ទាំងអស់នោះ ខ្ញុំបានបរិច្ចាគអស់ហើយ ម្នាលព្រាហ្មណ៍ អ្នកចូរជឿខ្ញុំចុះ ខ្ញុំមិនមានវត្ថុ ៥០០ ទេ ។

( ព្រាហ្មណ៍នោះនិយាយថា ) កាលខ្ញុំសូមហើយ បើអ្នកដ៏ចម្រើនមិនឲ្យទេ ក្បាលរបស់អ្នកចូរបែក ៧ ភាគ ក្នុងថ្ងៃទី ៧ ។ ព្រាហ្មណ៍កុហកនោះបានធ្វើកលឧបាយ ហើយសម្តែងនូវហេតុដែលគួរខ្លាចដ៏ពន្លឹក ដល់ពាវរីព្រាហ្មណ៍នោះ លុះពាវរីព្រាហ្មណ៍ឮពាក្យព្រាហ្មណ៍នោះហើយ ក៏ដល់នូវសេចក្តីទុក្ខព្រួយមិនបរិភោគអាហារ ទៅជាស្គាំងស្គម ចុកណែនដោយសរ គឺសេចក្តីសោក កាលបើពាវរីព្រាហ្មណ៍មានចិត្តយ៉ាងនេះ ចិត្តក៏មិនត្រេកអរក្នុងឈាន ។ ទេវតាអ្នកប្រាថ្នាប្រយោជន៍ បានឃើញពាវរីព្រាហ្មណ៍ មានសេចក្តីតក់ស្លុត ដល់នូវសេចក្តីទុក្ខព្រួយដូច្នោះហើយ ក៏ចូលទៅរកពាវរីព្រាហ្មណ៍ និយាយដូច្នេះថា ព្រាហ្មណ៍នោះ មិនដឹងក្បាលទេ គាត់ជាអ្នកកុហក ជាអ្នកត្រូវការដោយទ្រព្យ គាត់មិនមានការដឹងនូវក្បាល និងការធ្លាក់ចុះនៃក្បាលទេ ។

( ពាវរីព្រាហ្មណ៍សួរថា ) ម្នាលអ្នកដ៏ចម្រើន ឥឡូវនេះ

អ្នកណាដឹងនូវក្បាល និងការធ្លាក់ចុះនៃក្បាល ខ្ញុំសូមសួរអ្នក ចូរអ្នកប្រាប់នូវអ្នកដែលដឹងនោះដល់ខ្ញុំចុះ ខ្ញុំនឹងចាំស្ដាប់ពាក្យរបស់អ្នកនោះ ។

( ទេវតាតបថា ) ខ្ញុំមិនដឹងនូវក្បាល និងការធ្លាក់ចុះនៃក្បាលនុ៎ះទេ ខ្ញុំមិនមានការដឹងក្នុងហេតុទាំងពីរនោះឡើយ ក្បាលក្ដី កាលធ្លាក់ចុះនៃក្បាលក្ដី មានតែព្រះជិនស្រីទេ ទើបឃើញបាន ។

( ពាវរីព្រាហ្មណ៍សួរថា ) លើមណ្ឌលប្រឹថពីនេះ តើឥឡូវនេះ មានអ្នកណាអាចដឹងនូវក្បាល និងការធ្លាក់ចុះនៃក្បាល ម្នាលទេវតា អ្នកចូរប្រាប់នូវអ្នកនោះដល់ខ្ញុំ ។

( ទេវតាប្រាប់ថា ) ព្រះលោកនាយក ព្រះអង្គជាពូជពង្សនៃព្រះបាទឱក្កាកៈ ជាសក្យបុត្រ ព្រះអង្គមានពន្លឺរស្មី ទ្រង់ចេញចាកមហាបុរី ឈ្មោះកបិលពស្តុ ( ទៅទ្រង់ព្រះផ្នួស ) ។ ម្នាលព្រាហ្មណ៍ ព្រោះព្រះលោកនាយកនោះ ព្រះអង្គត្រាស់ដឹងឯង ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង បរិបូណ៌ដោយកម្លាំងនៃអភិញ្ញាទាំងពួង មានចក្ខុក្នុងធម៌ទាំងពួង បានដល់នូវការអស់ទៅនៃកម្មទាំងអស់ មានហឫទ័យចុះស៊ប់ក្នុងធម៌ជាគ្រឿងអស់ទៅនៃឧបធិក្កិលេស ព្រះសម្ពុទ្ធមានជោគអង្គនោះ មានចក្ខុសម្ដែងធម៌ក្នុងលោក អ្នកចូរអញ្ជើញទៅសួរព្រះអង្គចុះ ព្រះអង្គ

នឹងសម្តែងហេតុនោះដល់អ្នក ។ ពាវរីព្រាហ្មណ៍គ្រាន់តែឮពាក្យថា ព្រះសម្ពុទ្ធ ក៏មានចិត្តរីករាយ មានសេចក្តីសោកស្រាលស្តើង ទាំងបាននូវបីតិដ៏ធំទូលាយ ។

លុះពាវរីព្រាហ្មណ៍នោះពេញចិត្ត មានចិត្តត្រេកអរ មានចិត្តរីករាយហើយ ក៏សួរទេវតានោះថា ព្រះលោកនាថព្រះអង្គគង់នៅក្នុងស្រុកណា និគមណា ឬជនបទណា យើងនឹងទៅថ្វាយបង្គំព្រះសម្ពុទ្ធ ឧត្តមជាងសត្វមានជើងពីរ ក្នុងទីណា ។

( ទេវតាប្រាប់ថា ) ព្រះជិនស្រី មានប្រាជ្ញាច្រើន មានប្រាជ្ញាដ៏ប្រសើរដូចផែនដី គង់នៅក្នុងកោសលមន្ទីរ ក្នុងក្រុងសាវត្ថី ព្រះមានបុណ្យនោះ ជាសក្យបុត្រ មានធុរៈដាក់ចោលអស់ហើយ មិនមានអាសវៈទេ ប្រសើរជាងនរជន ទើបដឹងនូវក្បាល និងការធ្លាក់ចុះនៃក្បាល ។ លំដាប់នោះ ពាវរីព្រាហ្មណ៍បានហៅពួកព្រាហ្មណ៍ជាសិស្ស ដែលដល់នូវត្រើយនៃមន្ត ( ចេះចប់មន្ត ) មកថា ម្នាលមាណពទាំងឡាយ អ្នករាល់គ្នាចូរមកនេះ យើងនឹងប្រាប់ ចូរអ្នកទាំងឡាយស្តាប់ពាក្យយើងចុះ ការកើតឡើង ប្រាកដរឿយៗ នៃព្រះសម្ពុទ្ធណា ដែលគេបានដោយក្រក្នុងលោក ថ្ងៃនេះ ព្រះសម្ពុទ្ធអង្គនោះ ខ្ញុំបានឮប្រាកដហើយថា ព្រះសម្ពុទ្ធកើតឡើងហើយក្នុងលោក អ្នកទាំងឡាយចូរនាំគ្នាទៅកាន់ក្រុងសាវត្ថីឲ្យឆាប់ៗ ហើយចូលទៅគាល់ព្រះអង្គ ដែល

ឧត្តមជាងសត្វមានជើងពីរ ។ ពួកព្រាហ្មណ៍ជាសិស្សសួរថា បពិត្រព្រាហ្មណ៍ ពួកយើងឃើញហើយ គប្បីស្គាល់ថា អ្នកនោះជាព្រះពុទ្ធបាន ដោយប្រការដូចម្ដេច សូមលោកប្រាប់ដល់យើងទាំងឡាយដែលជាអ្នកមិនស្គាល់ ឲ្យទាល់តែយើងទាំង-ឡាយស្គាល់ព្រះអង្គ ។ ពាវរីព្រាហ្មណ៍និយាយថា មហាបុរិស-លក្ខណៈទាំង ៣២ ប្រការ មានមកក្នុងមន្តទាំងឡាយ ដែលពួកបោរាណបានព្យាករបរិបូណ៌ហើយ ដោយលំដាប់ ។ មហាបុរិសលក្ខណៈទាំងនោះ មានក្នុងខ្លួននៃបុគ្គលណា បុគ្គលនោះមានគតិតែពីរគត់ គតិជាគម្រប់ ៣ មិនមានឡើយ គឺបើនៅគ្រប់គ្រងគេហដ្ឋាន នឹងគប្បីឈ្នះនូវផែនដីនេះ ដោយមិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រាវុធទេ គ្រាន់តែប្រៀនប្រដៅដោយធម៌ បើបុគ្គលនោះចេញចាកផ្ទះ ចូលទៅកាន់ផ្នួស រមែងជាបុគ្គលមានដំបូល គឺកិលេសបើកហើយ បានជាព្រះអរហន្ត-សម្មាសម្ពុទ្ធដ៏ប្រសើរ ។ អ្នកទាំងឡាយចូរសួរដោយចិត្តនូវជាតិផង នូវគោត្រផង នូវលក្ខណៈផង ( របស់យើង ) នូវមន្តដែលយើងបាននិយាយផង នូវពួកសិស្ស ( របស់យើង ) ដទៃទៀតផង នូវក្បាលផង នូវការធ្លាក់ចុះនៃក្បាលផង ។ បើបុគ្គលនោះប្រាកដជាព្រះពុទ្ធ អ្នកឃើញកាលទាំងពួងដោយអនាវរ-ណញ្ញាណមែន កាលបើប្រស្នាដែលអ្នកទាំងឡាយសួរហើយ

ដោយចិត្ត ព្រះអង្គនឹងដោះស្រាយដោយវាចា ។ ឯពួក ព្រាហ្មណ៍ជាសិស្សទាំងអស់ ១៦ នាក់ គឺអជិតមាណព ១ តិស្សមេត្តេយ្យ ១ បុណ្ណកៈ ១ មេត្តគូ ១ ធោតកៈ ១ ឧបសីវៈ ១ នន្ទៈ ១ ហេមកៈ ១ តោទេយ្យ និងកប្បៈ ជាពីរនាក់ ជតុកណ្ណីបណ្ឌិត ១ ភទ្រាវុធៈ ១ ឧទយៈ ១ បោសាល-ព្រាហ្មណ៍ ១ មោឃរាជមេធាវី ១ បិង្គិយមហាឥសី ១ ព្រាហ្មណ៍ទាំងអស់នេះ សុទ្ធតែជាមេគណៈផ្សេងៗ គ្នា ល្បីល្បាញពាសពេញក្នុងលោក ជាអ្នកមានឈាន ត្រេកអរក្នុងឈាន មានប្រាជ្ញាមុតមាំ បានអប់រំវាសនាទុកមកពីក្នុងជាតិមុនៗ លុះបានស្តាប់ពាក្យពាវរីព្រាហ្មណ៍ហើយ ក៏ក្រាបថ្វាយបង្គំពាវរី-ព្រាហ្មណ៍ រួចធ្វើប្រទក្សិណ ពាវរីព្រាហ្មណ៍នោះ ទាំងអស់គ្នាសុទ្ធតែទ្រទ្រង់នូវក្អួងសក់ និងស្បែកខ្លា ឈមមុខទៅទិសខាងជើង ហើយដើរចេញទៅកាន់ទីប្រតិស្ឋាន នៃក្រុងមុឡកៈ កាន់ក្រុងមាហិស្សតី ក្រុងឧជ្ជេនី ក្រុងគោនទ្ធា ក្រុងវេទិស ក្រុងវនសៈ ក្រុងកោសម្ពី ក្រុងសាកេត ក្រុងសាវត្ថីដ៏ឧត្តម ក្រុងសេតព្យៈ ក្រុងកបិលវត្ថុ ក្រុងកុសិនារា ក្រុងបាវា ក្រុងភោគៈ ក្រុងវេសាលី ក្រុងមគធៈ និងបាសាណកចេតិយ ដែលជាទីសប្បាយរីករាយចិត្ត ពួកព្រាហ្មណ៍ទាំងអស់នោះបានឡើងទៅកាន់ភ្នំ គឺចេតិយដោយប្រញាប់ប្រញាល់ ដូចបុរសស្រេកទឹក

ដើរទៅរកទឹកត្រជាក់ ឬដូចពាណិជដើរទៅរកលាភធំ ពុំនោះសោត ដូចបុរសត្រូវរដូវក្តៅគ្របសង្កត់ ដើរទៅរកម្លប់ឈើ ដោយប្រញាប់ប្រញាល់ ដូច្នោះឯង ។ គាប់ចួនសម័យនោះ ព្រះមានព្រះភាគ មានភិក្ខុសង្ឃចោមរោម កំពុងសម្តែងធម៌ដល់ភិក្ខុទាំងឡាយ ដូចជា សីហៈបន្លឺក្នុងព្រៃ ។ អជិតមាណព ( ជាសិស្សច្បង ) បានឃើញព្រះសម្ពុទ្ធ ( មានរស្មីដ៏រុងរឿង ) ដូចព្រះអាទិត្យ មានរស្មីផ្សាយចេញ ពុំនោះសោត ដូចព្រះចន្ទ្រពេញវង់រះឡើង ក្នុងថ្ងៃ ១៥ កើត ។ បន្ទាប់ពីនោះមក អជិតមាណពបានឃើញព្យញ្ជនៈដ៏បរិបូណ៌ ក្នុងសរីរៈរបស់ព្រះអង្គ ហើយឋិតនៅក្នុងទីដ៏សមគួរ មានចិត្តរីករាយ បានសួរនូវប្រស្នាទាំងឡាយក្នុងចិត្តថា សូមព្រះអង្គសម្តែងប្រាប់នូវជន្មាយុ ( របស់អាចារ្យនៃខ្ញុំ ) សូមព្រះអង្គសម្តែងប្រាប់នូវគោត្រ ព្រមទាំងលក្ខណៈ សូមព្រះអង្គសម្តែងនូវបារមី ( ការសម្រេច ) ក្នុងមន្តទាំងឡាយ ព្រាហ្មណ៍ជាអាចារ្យរបស់ខ្ញុំ ប្រៀនប្រដៅសិស្សមានប៉ុន្មាននាក់ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា អាចារ្យរបស់អ្នកនោះមានអាយុ ១២០ ឆ្នាំ ឈ្មោះពាវរី តាមគោត្រ លក្ខណៈក្នុងខ្លួនរបស់គាត់មាន ៣ ប្រការ គាត់ចេះចប់នូវត្រៃវេទ គាត់បង្រៀននូវមហាបុរិសលក្ខណៈផង នូវគម្ពីរឥតិហាសៈ ព្រមទាំងគម្ពីរនិឃណ្ឌុ និងគម្ពីរកេដុភៈផង នូវមន្ត ៥០០ ផង

ដល់នូវបារមី គឺការសម្រេចក្នុងព្រាហ្មណធម៌របស់ខ្លួន ។ អជិត-មាណពក្រាបទូលថា បពិត្រព្រះអង្គ ជាបុគ្គលឧត្តមជាងនរជន អ្នកកាត់ផ្តាច់នូវតណ្ហា សូមព្រះអង្គពិចារណានូវលក្ខណៈរបស់ពាវរីព្រាហ្មណ៍ រួបសម្តែងកុំឲ្យយើងខ្ញុំមានសេចក្តីសង្ស័យ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ពាវរីព្រាហ្មណ៍ យកអណ្តាតបាំងមុខបាន មានឧណ្ណាលោម នៅត្រង់ចន្លោះចិញ្ចើម វត្ថគុយ្ហៈ ( លិង្គ ) របស់គាត់បិទបាំងដោយស្រោម ម្នាលមាណព អ្នកចូរដឹងយ៉ាងនេះចុះ ។ មែនពិត ពួកជនទាំងអស់គ្នា មិនដែលបានឮពាក្យបុច្ឆាណាមួយ លុះឮប្រស្នាទាំងឡាយ ដែលព្រះអង្គឆ្លើយហើយ ក៏កើតសេចក្តីរីករាយ ធ្វើប្រណម្យអញ្ជលី ហើយត្រិះរិះដូច្នេះថា នរណាហ្ន៎ ទោះទេវតាក្តី ព្រហ្មក្តី ឬក៏ព្រះឥន្ទ ឈ្មោះសុជម្បតីក្តី កាលគេសួរប្រស្នាដោយចិត្តហើយ នឹងដោះស្រាយប្រស្នាដូចម្តេចបាន ។ អជិតមាណពទូលថា ពាវរីព្រាហ្មណ៍ សាកសួរនូវក្បាលផង នូវការធ្លាក់ចុះនៃក្បាលផង បពិត្រព្រះមានព្រះភាគ សូមព្រះអង្គឆ្លើយនូវប្រស្នានុ៎ះឲ្យទាន បពិត្រព្រះអង្គជាអ្នកស្វះស្វែងគុណ សូមព្រះអង្គកម្ចាត់បង់នូវសេចក្តីសង្ស័យរបស់យើងខ្ញុំទាំងឡាយ ។ ព្រះសម្ពុទ្ធត្រាស់ថា អ្នកចូរដឹងចុះថា អវិជ្ជាទុកជាក្បាល វិជ្ជាដែលប្រកបដោយសទ្ធា សតិ សមាធិ ឆន្ទៈ និងវិរិយៈទុកជាការធ្លាក់ចុះនៃក្បាល ។ លំដាប់នោះ អជិតមាណព

ខំទប់ទល់ដោយសេចក្តីត្រេកអរច្រើន ហើយយកស្បែកខ្លាពន្ធ ចៀងស្មាម្ខាង រួចក្រាបសិរ្សទៀបព្រះបាទទាំងគូ ក្រាបទូលថា បពិត្រព្រះអង្គនិទ្ទុក្ខ ព្រះអង្គមានចក្ខុ ពាវរីព្រាហ្មណ៍ដ៏ចម្រើន ព្រមទាំងពួកសិស្ស មានចិត្តរីករាយ ស្រស់ស្រាយ ថ្វាយបង្គំព្រះបាទា ( របស់ព្រះអង្គ ) ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលមាណព សូមឲ្យពាវរីព្រាហ្មណ៍ ព្រមទាំងពួកសិស្ស បានដល់នូវសេចក្តីសុខចុះ ទាំងរូបអ្នកសោត ក៏ចូរជាបុគ្គលដល់នូវសេចក្តីសុខ រស់នៅអស់កាលយូរចុះ ។ អ្នកទាំងឡាយ តថាគតបើកឱកាសឲ្យហើយ ចូរសួរនូវសេចក្តីសង្ស័យទាំងអស់ របស់ពាវរីព្រាហ្មណ៍ផង របស់អ្នកផង របស់ពួកជនទាំងអស់ផង ចូរប្រាថ្នាទុកក្នុងចិត្ត នូវហេតុណាមួយចុះ ។ លុះព្រះសម្ពុទ្ធបើកឱកាសឲ្យហើយ អជិតមាណព អង្គុយប្រណម្យអញ្ជលី សួរប្រស្នាទី ១ នឹងព្រះតថាគតក្នុងទីនោះឯង ។

វត្ថុកថា ចប់

# អដ្ឋកថា

## វត្ថុគាថានៃបាយាយនវគ្គ

[ ១១១ ] វត្ថុគាថានៃបាយាយនវគ្គទី ៥ មានពាក្យផ្ដើមថា **កោសលានំ បុរា រម្មា** ដូច្នេះ

សួរថា វត្ថុគាថានេះ មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា វត្ថុគាថានេះ មានអត្ថុប្បត្តិហេតុដូចតទៅនេះ

បានឮថា ក្នុងអតីតកាល មានជាងឈើម្នាក់ អ្នកក្រុងពារាណសី មិនមានបុគ្គលដទៃជាគម្រប់ ២ នៅក្នុងសម្នាក់អាចារ្យរបស់ខ្លួន ជាងឈើនោះ មានសិស្ស ១៦ នាក់ សិស្សនីមួយៗ មានអន្តេវាសិកម្នាក់ ១០០០ ។ អាចារ្យ និងអន្តេវាសិកទាំងនោះ បើរួមគ្នា ក៏ជា ១៦០១៧ នាក់យ៉ាងនេះ ។ ជនទាំងអស់នោះ អាស្រ័យក្រុងពារាណសីចិញ្ចឹមជីវិត បានទៅកាន់ភ្នំ យកឈើមកធ្វើប្រាសាទផ្សេងៗ ក្នុងទីនោះ លក់ដូរហើយ ចងក្បូន នាំមកពារាណសីតាមស្ទឹងគង្គា បើព្រះរាជាទ្រង់ត្រូវការ ក៏ធ្វើប្រាសាទ ១ ជាន់ ឬ ៧ ជាន់ថ្វាយ បើទ្រង់មិនត្រូវការ ក៏លក់ដូរឲ្យអ្នកដទៃ ដើម្បីចិញ្ចឹមបុត្តនិងភរិយា ។

ថ្ងៃមួយ អាចារ្យរបស់អន្តេវាសិកទាំងនោះ គិតថា យើងមិនអាចមានជីវិតបានដោយធ្វើជាជាងឈើរហូតនោះទេ ព្រោះដល់ពេលយើងចាស់ កម្មនេះនឹងធ្វើបានលំបាក ទើបហៅអន្តេវាសិកទាំងឡាយមកប្រាប់ថា នែអ្នកទាំងឡាយ ចូរពួកអ្នកទៅនាំឈើដែលមានខ្លឹមតិច មានដើមល្វាជាដើមមក ។ អន្តេវាសិកទាំងនោះទទួលពាក្យហើយ ក៏ទៅនាំមក ។ អាចារ្យនោះយកឈើ

ធ្វើជាបក្សី បំពាក់គ្រឿងយន្តខាងក្នុងបក្សីនោះ ។ បក្សីឈើហោតឡើងទៅលើអាកាស ដូចស្តេចហង្ស ត្រាច់ទៅខាងលើព្រៃ ហើយចុះនៅខាងមុខនៃអន្តេវាសិកទាំងឡាយ ។ លំដាប់នោះ អាចារ្យសួរសិស្សទាំងឡាយថា នែអ្នកទាំងឡាយ អញធ្វើពាហនៈបែបនេះបាន ក៏អាចដណ្តើមយករាជសម្បត្តិក្នុងជម្ពូទ្វីបបានទាំងអស់ សូម្បីពួកឯង ក៏ចូរធ្វើពាហនៈឈើនោះ អញនឹងដណ្តើមរាជសម្បត្តិ ដើម្បីរស់នៅ ព្រោះការចិញ្ចឹមជីវិតដោយសិប្បៈជាជាងឈើ ជាការលំបាក ។

សិស្សទាំងនោះបានធ្វើតាមនោះ ហើយប្រាប់ឲ្យអាចារ្យជ្រាប ។ គ្រានោះ អាចារ្យពោលនឹងសិស្សថា យើងគួរដណ្តើមរាជសម្បត្តិពីណាទៅមុន សិស្សប្រាប់ថា លោកអាចារ្យ ផ្តើមពីក្រុងពារាណសី ។ អាចារ្យពោលថា កុំឡើយ មិនល្អទេ ព្រោះបើពួកយើងដណ្តើមរាជសម្បត្តិក្នុងនគរពារាណសីបាន ក៏មិនផុតពីការមើលងាយថា ស្តេចជាងឈើ ឧបរាជជាងឈើ ជម្ពូទ្វីបធំទូលាយ យើងទៅទីដទៃជាមួយគ្នាចុះ ។ លំដាប់នោះ អន្តេវាសិក និងប្រពន្ធកូន នាំគ្នាឡើងពាហនៈរៀងៗ ខ្លួន រៀបចំអាវុធ មានមុខទៅកាន់ហិមវន្តប្បទេស ទៅដល់នគរមួយ ក្នុងហិមវន្តប្បទេស ទៅប្រាកដក្នុងរាជមន្ទីរនោះឯង ។ សិស្សទាំងនោះដណ្តើមរាជសម្បត្តិក្នុងនគរនោះ អភិសេកអាចារ្យក្នុងរាជសម្បត្តិ អាចារ្យនោះក៏ប្រាកដឈ្មោះថា ព្រះបាទកដ្ឋវាហនៈ ។ ក្នុងនគរនោះក៏បានឈ្មោះថា កដ្ឋវាហននគរដូចគ្នា ព្រោះព្រះបាទកដ្ឋវាហនៈដណ្តើមបាន សូម្បីរដ្ឋក៏មានឈ្មោះយ៉ាងនោះ ។ ព្រះរាជាកដ្ឋវាហនៈ បានតាំងនៅក្នុង

ធម៌ ។ម្យ៉ាងទៀត ទ្រង់តាំងព្រះឧបរាជ និងតាំងសិស្ស ១៦ នាក់ ទុកក្នុងតំណែងជាអាចារ្យ ។ ព្រះរាជាទ្រង់សង្គ្រោះសិស្សទាំងនោះ ដោយសង្គហវត្ថុ ៤ ទើបជាដែនស្កុកស្តម្ភ ជាដែនសម្បូរ មិនមានអន្តរាយ ។ អ្នកនគរ និងអ្នកជនបទ ក៏រាប់អានព្រះរាជា និងរាជការយ៉ាងក្រៃលែងថា ពួកយើងបានព្រះរាជាល្អ ខ្ញុំរាជការក៏ជាមនុស្សល្អ ។

ថ្ងៃមួយ ពួកឈ្មួញចេញពីមជ្ឈិមប្រទេស ដឹកទំនិញមកកាន់កដ្ឋវាហននគរ និងនាំគ្រឿងបណ្ណាការទៅគាល់ព្រះរាជា។ ត្រាស់សួរថា ពួកអ្នកមកអំពីណា ក៏ទូលថា បពិត្រព្រះអង្គ ទូលបង្គំមកពីក្រុងពារាណសី ។ ព្រះរាជាត្រាស់សួររឿងរ៉ាវទាំងឡាយ ក្នុងក្រុងពារាណសីនោះហើយ ត្រាស់ថា ចូរពួកអ្នកនាំមិត្តភាពរបស់យើង ទៅទូលជាមួយព្រះរាជារបស់ពួកអ្នកចុះ ឈ្មួញទាំងនោះ ទទួលព្រះរាជតម្រាស់ហើយ ។ ព្រះរាជាប្រទានស្បៀងដល់ពួកឈ្មួញទាំងនោះ លុះដល់ពេលទៅ ក៏នៅតែត្រាស់ចន្ទុលបង្ហាញដោយយកចិត្តទុកដាក់ ។ ឈ្មួញទាំងនោះត្រឡប់ទៅកាន់ក្រុងពារាណសី បានក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាប ។ ព្រះរាជាត្រាស់ថា តាំងអំពីថ្ងៃនេះជាដើមទៅ យើងមិនត្រូវទារពន្ធរបស់ឈ្មួញដែលមកអំពីដែនកដ្ឋវាហនៈ ហើយទ្រង់ឲ្យប្រកាសថា ព្រះរាជាកដ្ឋវាហនៈជាសម្លាញ់របស់យើង ព្រះរាជាទាំង ២ បានជាសម្លាញ់កំបាំងមុខដល់គ្នានិងគ្នា ។ សូម្បីព្រះរាជាកដ្ឋវាហនៈក៏ទ្រង់ប្រកាសពេញនគរថា តាំងអំពីថ្ងៃនេះទៅ មិនត្រូវយកពន្ធពីឈ្មួញដែលមកអំពីក្រុងពារាណសីឡើយ និងគួរឲ្យស្បៀងដល់ពួកគេទៀតផង ។

សម័យនោះ ព្រះបាទពារាណសីទ្រង់បញ្ជូនព្រះរាជសារដល់ព្រះបាទកដ្ឋវាហនៈថា បើមានរឿងអ្វីចម្លែក សមគួរដើម្បីឃើញ ដើម្បីស្តាប់កើតឡើងក្នុងជនបទនេះ គប្បីឲ្យខ្ញុំបានឃើញ និងបានឮផង ។ ព្រះបាទកដ្ឋវាហនៈទ្រង់បញ្ជូនព្រះរាជសារតបទៅនឹងព្រះរាជាពារាណសីដូចគ្នា ។ កាលព្រះរាជាទាំង ២ ធ្វើកតិកាយ៉ាងនេះ គ្រាមួយ ព្រះរាជាកដ្ឋវាហនៈបានសំពត់កម្ពលសាច់ម៉ដ្ឋពន់ពេក មានតម្លៃមិនអាចកាត់ថ្លៃបាន មានពណ៌ដូចអរុណោទ័យ ។ ព្រះរាជាកដ្ឋវាហនៈគ្រាន់តែទតឃើញសំពត់កម្ពលប៉ុណ្ណោះ ក៏ត្រិះរិះថា អញនឹងបញ្ជូនទៅឲ្យសម្លាញ់របស់អញ ទើបឲ្យជាងធ្វើប្រអប់ភ្លុក ៨ យកសំពត់កម្ពលដាក់ក្នុងប្រអប់ទាំងនោះ ឲ្យអ្នកជំនាញខាងល័ខ ធ្វើដុំល័ខព័ទ្ធខាងក្រៅ យកល័ខដុំ ៨ ដុំ ដាក់ក្នុងប្រអប់ យកសំពត់រុំ ប្រថាប់ត្រាហើយ ទ្រង់បញ្ជូនអមាត្យទៅ ត្រាស់ថា ចូរពួកអ្នកនាំទៅថ្វាយព្រះរាជាពារាណសី រួចទ្រង់ចារឹកអក្ខរាថា បណ្ណាការនេះ ព្រះរាជាមានពួកអមាត្យចោមរោម ក្នុងកណ្តាលព្រះនគរគប្បីបើកមើល ។ ពួកអមាត្យទៅដល់ហើយ បានថ្វាយដល់ព្រះបាទពារាណសី ព្រះបាទពារាណសីទ្រង់អានអក្ខរានោះហើយ ត្រាស់ឲ្យប្រជុំពួកអមាត្យ ហើយបើកត្រាដែលប្រថាប់លើសំពត់ចេញ បើកប្រអប់ឃើញដុំល័ខ ៨ ដុំ ទ្រង់ខ្មាសអៀនថា សម្លាញ់របស់យើង បញ្ជូនដុំល័ខមូលឲ្យយើង ដូចគ្នានឹងឲ្យកូនក្មេងលេងដុំល័ខ ទើបទ្រង់បោកដុំល័ខមួយក្នុងទីប្រថាប់គង់របស់ទ្រង់ ។ រំពេចនោះឯង ដុំល័ខក៏បែក ប្រអប់ភ្លុកក៏បែកជា ២ ទ្រង់ទតឃើញសំពត់កម្ពលនៅខាងក្នុង ទើបទ្រង់បើកប្រអប់ដទៃៗ ប្រអប់

ទាំងអស់ក៏ដូចគ្នា ។ សំពត់កម្ពលមួយផ្ទាំងៗ ប្រវែង ១៦ ហត្ថ ទទឹង ៨ ហត្ថ ។ កាលទ្រង់ញីសំពត់កម្ពលមើលលានព្រះរាជវាំង ក៏មានពន្លឺដូចព្រះអាទិត្យ ( ទើបតែរះ ) ។ មហាជនឃើញដូច្នោះ នាំគ្នាផ្ទាត់ម្រាមដៃ លើកផ្ទាំងសំពត់គ្រវី មានសេចក្តីពេញចិត្តថា ព្រះរាជាកដ្ឋវាហនៈ អទិដ្ឋសម្លាញ់របស់ព្រះរាជានៃយើង ទ្រង់បញ្ជូនបណ្ណាការបែបនេះមកថ្វាយ ការធ្វើមេត្រីបែបនេះ សមគួរហើយ ។ ព្រះរាជាត្រាស់ឲ្យហៅឈ្មួញមកវាយតម្លៃសំពត់កម្ពលមួយផ្ទាំងៗ សំពត់កម្ពលទាំងឡាយ មានតម្លៃកាត់ថ្លៃមិនបានឡើយ ។ លំដាប់នោះ ព្រះបាទពារាណសីទ្រង់ត្រិះរិះថា ការបញ្ជូនបណ្ណាការខាងក្រោយគួរបញ្ជូនរបស់ដែលមានតម្លៃក្រៃលែងជាងបណ្ណាការ ដែលបញ្ជូនមកមុន សម្លាញ់របស់អញ បញ្ជូនបណ្ណាការមានតម្លៃកាត់ថ្លៃមិនបានឲ្យអញ អញគួរបញ្ជូនអ្វីឲ្យសម្លាញ់អញហ្ន៎ ។

សម័យនោះ ព្រះមានព្រះភាគ ព្រះនាមកស្សបៈ កើតឡើងហើយក្នុងលោក គង់នៅក្នុងក្រុងពារាណសី ។ កាលនោះ ព្រះរាជាមានព្រះតម្រិះថា វត្ថុដទៃក្រៃលែងជាងរតនៈទាំង ៣ មិនមាន ណ្ហើយចុះ អញនឹងបញ្ជូនដំណឹងថា ព្រះរតនត្រ័យកើតឡើងហើយដល់សម្លាញ់របស់អញ ។ ព្រះបាទពារាណសីនោះ ទើបឲ្យគេចារឹកគាថានេះថា

ព្រះពុទ្ធកើតឡើងព្រមហើយក្នុងលោក ដើម្បីជាប្រយោជន៍ដល់សត្វទាំងពួង ព្រះធម៌កើតឡើងព្រមហើយក្នុងលោក ដើម្បីសេចក្តីសុខដល់សត្វទាំងពួង ព្រះសង្ឃកើតឡើងព្រមហើយក្នុងលោក ជាបុញ្ញក្ខេត្ត ដែលមិនមាន

ស្រែបុណ្យដទៃក្រៃលែងជាង ដូច្នេះ ៗ និងឲ្យចារឹកនូវកិច្ចបដិបត្តិរបស់ភិក្ខុមួយរូប ដរាបដល់អរហត្ត ដោយហិង្គុលក្រហម លើជំបារមាស ដាក់ក្នុងប្រអប់ដែលធ្វើដោយកែវ ៧ ប្រការ ដាក់ប្រអប់នោះ ក្នុងប្រអប់ដែលធ្វើដោយកែវមណី ដាក់ប្រអប់ដែលធ្វើដោយកែវមណី ចូលក្នុងប្រអប់កែវមរកត ដាក់ប្រអប់កែវមរកត ចូលក្នុងប្រអប់កែវទទឹម ដាក់ប្រអប់កែវទទឹមចូលក្នុងប្រអប់មាស ដាក់ប្រអប់មាសចូលក្នុងប្រអប់ប្រាក់ ដាក់ប្រអប់ប្រាក់ចូលក្នុងប្រអប់ភ្លុកដំរី ដាក់ប្រអប់ភ្លុកដំរីចូលក្នុងប្រអប់ឈើខ្លឹម ដាក់ប្រអប់ឈើខ្លឹមចូលក្នុងប្រអប់ធម្មតា រួចយកសំពត់ធម្មតារុំប្រថាប់ត្រា ទ្រង់ឲ្យប្រដាប់ដំរីដ៏ប្រសើរ មានទទង់មាស ប្រដាប់ដោយមាស បំពាក់ដោយបណ្ដាញមាស តាក់តែងបល្ល័ង្កលើដំរីនោះហើយ លើកហិបដាក់លើបល្ល័ង្ក បាំងស្វេតច្ឆត្រ បូជាដោយផ្កាកម្រង គ្រឿងក្រអូបគ្រប់ប្រភេទឲ្យអ្នកតូរ្យតន្ត្រីគ្រប់ប្រភេទច្រៀងសរសើរ ១០០ បទ ឲ្យធ្វើផ្លូវរហូតផុតរាជសីមារបស់ទ្រង់ រួចទ្រង់នាំទៅដោយព្រះអង្គឯង ៗ ហើយទ្រង់ប្រថាប់ត្រង់ផ្លូវនោះ បញ្ជូនបណ្ណាការទៅដល់ព្រះបាទបទេសរាជទាំងឡាយថា បុគ្គលធ្វើសក្ការៈយ៉ាងនេះ គួរបញ្ជូនបណ្ណាការទៅ ៗ ព្រះរាជាទាំងនោះបានស្ដាប់ដូច្នេះហើយ ទើបយាងមកទទួលទ្រង់នាំទៅរហូតដល់រាជសីមារបស់កដ្ឋវាហនរាជ ៗ សូម្បីព្រះកដ្ឋវាហនរាជបានដំណឹងហើយ ក៏យាងមកទទួល ទ្រង់បូជាយ៉ាងនោះ ទូលយាងចូលព្រះនគរ ហើយត្រាស់ឲ្យប្រជុំពួកអមាត្យ និងអ្នកនគរ ទ្រង់ដោះសំពត់ ដែលរុំចេញត្រង់លានព្រះរាជវាំង ទ្រង់បើកប្រអប់ចេញ ឃើញប្រអប់ក្នុងប្រអប់

ទើបទ្រង់បើកប្រអប់ទាំងអស់តាមលំដាប់ ទតឃើញចារឹកលើជំបារមាស ទ្រង់ពេញព្រះហឫទ័យថា សម្លាញ់របស់អញបញ្ជូនរតនបណ្ណាការដែលរកបានដោយកម្រក្រៃលែងអស់សែនកប្ប ពួកយើងបានស្តាប់សំឡេងដែលមិនធ្លាប់បានស្តាប់ថា **ពុទ្ធោ លោកេ ឧប្បន្នោ** ព្រះពុទ្ធកើតឡើងហើយក្នុងលោក ទ្រង់ត្រិះរិះថា បើដូច្នោះ អញគួរទៅគាល់ព្រះពុទ្ធ និងស្តាប់ព្រះធម៌ ដូច្នេះហើយ ត្រាស់ហៅអមាត្យទាំងឡាយមកប្រាប់ថា បានឮថា ព្រះពុទ្ធរតនៈ ព្រះធម្មរតនៈ និងព្រះសង្ឃរតនៈ កើតឡើងហើយក្នុងលោក ពួកអ្នកគិតថា គួរធ្វើអ្វី អមាត្យទាំងឡាយក្រាបទូលថា បពិត្រមហារាជ សូមទ្រង់ប្រថាប់នៅក្នុងទីនេះសិន ពួកទូលបង្គំនឹងទៅស្តាប់ដំណឹងមើល ។ លំដាប់នោះ អមាត្យ ១៦ នាក់ មួយអន្លើដោយបរិវារ ១៦០០០ ថ្វាយបង្គំព្រះរាជា ហើយក្រាបទូលថា បើព្រះពុទ្ធកើតឡើងក្នុងលោក ពួកទូលបង្គំមិនបានត្រឡប់មកវិញឡើយ បើទ្រង់មិនកើតឡើងក្នុងលោក ពួកទូលបង្គំនឹងត្រឡប់ ហើយនាំគ្នាទៅ ។ ចំណែកក្មួយរបស់ព្រះរាជាថ្វាយបង្គំព្រះរាជាក្រោយគេ ក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំក៏ទៅ ។ ព្រះរាជាត្រាស់ថា បើឯងដឹងថា ព្រះពុទ្ធកើតឡើងក្នុងទីនោះហើយ ចូរត្រឡប់មកប្រាប់យើងផង ។ ក្មួយរបស់ព្រះរាជាទទួលព្រះតម្រាស់ហើយ ទើបចេញទៅ ។ ពួកជនទាំងនោះស្នាក់ត្រឹមតែមួយរាត្រីក៏ដល់នគរពារាណសី ។ កាលពួកអមាត្យទៅមិនទាន់ដល់នោះឯង ព្រះមានព្រះភាគទ្រង់បរិនិព្វានទៅហើយ ។ ពួកជនទាំងនោះ ត្រាច់ទៅដល់វិហារ ឃើញសាវកផ្ទាល់នឹងភ្នែក ទើបសួរថា អ្នកណាជាព្រះពុទ្ធ ព្រះពុទ្ធ

នៅឯណា ។ សាវកទាំងនោះក៏ប្រាប់ដល់ជនទាំងនោះថា ព្រះពុទ្ធនិព្វាន ហើយ ។ ពួកអមាត្យទាំងនោះនាំគ្នាខ្សឹកខ្សួលថា ឱ ! ខ្ញុំមកអំពីទីឆ្ងាយ តែមិនបានសូម្បីត្រឹមតែឃើញ ទើបសួរថា បពិត្រលោកម្ចាស់ ឱវាទដែលព្រះមានព្រះភាគទ្រង់ប្រទាននៅមានដែរឬ សាវកទាំងនោះពោលថា មានឧបាសក គឺ គប្បីតាំងនៅក្នុងរតនត្រ័យ គប្បីសមាទានសីល ៥ គប្បីរក្សាឧបោសថប្រកបដោយអង្គ ៨ គប្បីឲ្យទាន គប្បីបដិបត្តិធម៌ ។ អមាត្យទាំងនោះ កាលបានស្តាប់ហើយ ក៏នាំគ្នាបួសទាំងអស់ វៀរតែអមាត្យដែលជាក្មួយព្រះរាជាប៉ុណ្ណោះ ។ អមាត្យជាក្មួយ កាន់យកបរិភោគធាតុ មានមុខទៅកាន់ដែនកដ្ឋវាហនៈ ។ ដើមពោធិព្រឹក្ស បាត្រ និងចីវរជាដើម ឈ្មោះថា បរិភោគ-ធាតុ ។ ក្មួយព្រះរាជាកាន់យកធម្មក្រករបស់ព្រះមានព្រះភាគ ហើយនាំព្រះថេរៈមួយរូប ដែលជាអ្នកទ្រទ្រង់ធម៌ និងវិន័យ ទៅកាន់នគរដោយលំដាប់ ។ ក្រាបទូលព្រះរាជាថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក ទ្រង់បរិនិព្វានហើយ ក្រាបទូលឱវាទដែលព្រះពុទ្ធប្រទានទុកឲ្យ ។ ព្រះរាជាយាងចូលទៅរកព្រះថេរៈ ស្តាប់ធម៌ហើយ ឲ្យសាងវិហារ ប្រតិស្ឋានចេតិយ ដាំដើមពោធិ៍ ទ្រង់តាំងនៅក្នុងព្រះរតនត្រ័យ និងសីល ៥ ជានិច្ច ទ្រង់រក្សាឧបោសថ ប្រកបដោយអង្គ ៨ ទ្រង់ឲ្យទាន ទ្រង់តាំងនៅដរាបដល់អស់ព្រះជន្ម ទៅកើតក្នុងកាមាវចរ-ទេវលោក ។ អមាត្យ ១៦០០០ នាក់ ក៏នាំគ្នាបួស មរណភាពទាំងនៅជាបុថុជ្ជន បានទៅកើតជាបរិវារព្រះរាជានោះឯង ។

អមាត្យទាំងនោះ នៅក្នុងទេវលោកអស់មួយពុទ្ធន្តរ កាលព្រះមានព្រះ

ភាគមិនទាន់កើតឡើង ក៏បានឃ្លាតចាកទេវលោក អាចារ្យកើតជាបុត្តបុរោហិតរបស់ព្រះជនកនៃព្រះបាទបសេនទិ មានឈ្មោះថាពាវរី ប្រកបដោយមហាបុរិសលក្ខណៈ ៣ ប្រការ ជាអ្នកដល់នូវត្រើយនៃវេទ កាលឥតអំពីបិតាទៅ បានតាំងនៅក្នុងតំណែងបុរោហិត ។ សូម្បីអមាត្យដ៏សេស ១៦០០០ នាក់ទៀត ក៏បានទៅកើតក្នុងត្រកូលព្រាហ្មណ៍ ត្រង់ក្រុងសាវត្ថីនោះឯង ។ បណ្តាអន្តេវាសិក ១៦០០០ នាក់នោះ អន្តេវាសិកដែលជាធំ ១៦ នាក់ បានរៀនសិប្បៈក្នុងសម្នាក់របស់អាចារ្យ ។ អន្តេវាសិក ១៦០០០ នាក់ក្រៅអំពីនោះ បានរៀនសិប្បៈក្នុងសម្នាក់របស់អន្តេវាសិក ១៦ នាក់នោះដូចគ្នា ព្រោះដូច្នោះ ជនទាំងនោះ ក៏មកជួបជុំគ្នាទៀត ។ ព្រះបាទមហាកោសលទ្រង់សោយទិវង្គតហើយ ទើបអភិសេកព្រះបាទបសេនទិគ្រងរាជសម្បត្តិ ។ ពាវរីព្រាហ្មណ៍ ក៏បានតាំងនៅក្នុងភាពជាបុរោហិតរបស់ព្រះរាជាបសេនទិនោះ ។ ព្រះរាជាបានព្រះរាជទានវត្ថុ ដែលព្រះជនកធ្លាប់ប្រទាន និងសម្បត្តិដទៃដល់ពាវរីបុរោហិត ។ ព្រះរាជានោះ កាលទ្រង់នៅក្មេងក៏បានរៀនសិល្បសាស្ត្រក្នុងសម្នាក់ពាវរីបុរោហិតដូចគ្នា ។ លំដាប់នោះ ពាវរីបានទូលដល់ព្រះរាជាថា បពិត្រមហារាជ ទូលបង្គំនឹងបួស ព្រះរាជាត្រាស់ថា លោកអាចារ្យ បើលោកតាំងនៅ ក៏ដូចជាបិតារបស់យើងតាំងនៅ លោកកុំបួសឡើយ ។ ពាវរីទូលថា បពិត្រមហារាជ ទូលបង្គំនឹងបួសដោយពិត ។ ព្រះរាជាមិនអាចឃាត់បាន ទើបសំណូមពរថា បើលោកបួស ចូរនៅក្នុងព្រះរាជឧទ្យាននេះចុះ យើងនឹងបានឃើញព្រឹកល្ងាច ។

អាចារ្យមួយអន្ទើដោយសិស្ស ១៦ នាក់ ជាមួយបរិវារ ១៦០០០ នាក់ បានបួសជាតាបសក្នុងព្រះរាជឧទ្យាន ។ ព្រះរាជាទ្រង់ទំនុកបម្រុងដោយបច្ច័យ ៤ យាងទៅឧបដ្ឋាកអាចារ្យនោះរាល់ល្ងាចព្រឹក ។

ថ្ងៃមួយ អន្តេវាសិកទាំងឡាយពោលនឹងអាចារ្យថា ការនៅជិតនគរមានគ្រឿងសាំញ៉ាំច្រើន យើងគួរទៅរកឱកាសដែលមិនមានមនុស្សបៀតបៀនចុះ ឈ្មោះថា ការនៅក្នុងសេនាសនៈដ៏ស្ងាត់ ជាប្រយោជន៍ដល់បព្វជិតទាំង-ឡាយ អាចារ្យទទួលថា សាធុ ទើបទូលព្រះរាជា ។ ព្រះរាជាត្រាស់ឃាត់អស់វារៈ ៣ ដង ក៏មិនអាចឃាត់បាន ទើបព្រះរាជទានកហាបណៈ ២ សែនកហាបណៈ ត្រាស់នឹងពួកអមាត្យទាំងឡាយថា ចូរពួកអ្នកសាងអាស្រមប្រគេនលោកអាចារ្យ ក្នុងទីដែលគណៈឥសីប្រាថ្នាចុះ ។ បន្ទាប់អំពីនោះអាចារ្យ មួយអន្ទើដោយជដិល ១៦០០០ ជាបរិវារ បានទទួលអនុគ្រោះអំពីពួកអមាត្យ ទើបចេញអំពីឧត្តរជនបទ មានមុខទៅកាន់ទក្ខិណាជនបទ ។ ព្រះអានន្ទកាន់យកសេចក្តីនោះ ក្នុងកាលធ្វើសង្គាយនា បានលើកនិទាននៃប៉ារាយនវគ្គឡើង ទើបពោលគាថាទាំងនេះ ។

ក្នុងបទទាំងនោះ បទថា **កោសលានំ បុរា** បានដល់ ចាកនគរកោសល អធិប្បាយថា ចាកក្រុងសាវត្ថី ។ បទថា **អាកិញ្ចញ្ញំ** បានដល់ ភាពជាអ្នកមិនមានកង្វល់ អធិប្បាយថា វិវេកដែលជាឧបករណ៍នៃការកំណត់ ។ បទថា **សោ អស្សកស្ស វិសយេ មុឡ្ហកស្ស សមាសនេ** សេចក្តីថា ព្រាហ្មណ៍នោះនៅក្នុងទីជិតព្រំដែន រវាងដែន ២ គឺដែនអស្សកៈ និងដែនមុឡ្ហកៈ

អធិប្បាយថា ត្រង់កណ្ដាលនៃដែនទាំង ២ ។ បទថា **គោធាវរី កុលេ** បាន ដល់ ឆ្នេរស្ទឹងគោធាវរី អធិប្បាយថា ស្ទឹងគោធាវរីបែកជា ២ កើតបានជា កោះត្រង់កណ្ដាល ទំហំប្រមាណ ៣ យោជន៍ លើកោះ គ្របដណ្ដប់ដោយ ព្រៃខ្វិត ក្នុងកាលមុន ប្រទេសត្រង់នោះ សរភង្គតាបសជាដើមនៅអាស្រ័យ បានឮថា អាចារ្យឃើញប្រទេសនោះហើយ ទើបប្រាប់ដល់អមាត្យទាំងឡាយ ថា ប្រទេសនេះជាលំនៅរបស់បុរាណសមណៈ ប្រទេសនេះសមគួរដល់អ្នក បួស ។ ពួកអមាត្យបានឲ្យទ្រព្យ ១ សែនដល់ព្រះបាទអស្សកៈ ១ សែន ទៀត ឲ្យដល់ព្រះបាទមុឡកៈ ដើម្បីគ្រប់គ្រងភូមិប្រទេសនោះ ។ ព្រះរាជា ទាំង ២ អង្គនោះ បានព្រះរាជទានប្រទេសនោះ និងប្រទេសដទៃប្រមាណ ២ យោជន៍ រួមទីងប្រទេសនោះជា ៥ យោជន៍ ។ បានឮថា ប្រទេសនោះ នៅ ត្រង់ចន្លោះដែនសីមារបស់ព្រះរាជាទាំងនោះ ។ ពួកអមាត្យសាងអាស្រមក្នុង ទីនោះហើយ ឲ្យនាំទ្រព្យដទៃមកអំពីក្រុងសាវត្ថី រៀបចំជាគោចរគ្រាមស្រេច ហើយ នាំគ្នាត្រឡប់ទៅ ។ បទថា **ឧញ្ឆេន ច ផលេន ច** បានដល់ ដោយ ការត្រាច់ស្វែងរកអាហារឫសឈើ ផ្លែឈើក្នុងព្រៃ ។ ព្រោះដូច្នោះ ទើប លោកពោលថា **តស្សេវ ឧបនិស្សាយ គាមោ ច វិបុលោ អហុ** ដូច្នេះ ។

ក្នុងបទទាំងនោះបទថា **តស្ស** បានដល់ ឆ្នេរស្ទឹងគោធាវរីនោះ ឬ ព្រាហ្មណ៍នោះ ។ បទថា **តស្ស** នេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃទុតិយាវិភត្តិ ។ អធិប្បាយថា អាស្រ័យឆ្នេរស្ទឹងគោធាវរី ឬព្រាហ្មណ៍នោះ ។ បទថា **តតោ ជាតេន អាយេន មហាយញ្ញមកប្បយិ** បានដល់ សួយ ១ សែន កើត

ឡើងអំពីកសិកម្មជាដើម ក្នុងស្រុកនោះ កុដុម្ពិកៈទាំងឡាយ កាន់យកសួយនោះ ទៅគាល់ព្រះបាទអស្សកៈ ទូលថា សូមទ្រង់ទទួលសួយនេះចុះ ព្រះបាទអស្សកៈត្រាស់ថា យើងមិនទទួល ចូរពួកលោកនាំទៅប្រគេនអាចារ្យចុះ សូម្បីអាចារ្យក៏មិនទទួលសួយនោះជារបស់ខ្លួន បានបូជាមហាយញ្ញ ។ អាចារ្យនោះ បានឲ្យទានរាល់ៗ ឆ្នាំ ដោយប្រការដូច្នេះ ។

គប្បីជ្រាបសេចក្តីនៃគាថាថា **មហាយញ្ញំ** ដូចតទៅនេះថា អាចារ្យនោះបូជាមហាយញ្ញ គឺទានរៀងរាល់ឆ្នាំយ៉ាងនេះ កាលបូជាមហាយញ្ញរៀងរាល់ឆ្នាំហើយ បានចេញអំពីស្រុក ត្រឡប់ចូលទៅកាន់អាស្រមវិញ លុះត្រឡប់ចូលទៅហើយ ក៏ទៅកាន់បណ្ណសាលា អង្គុយពិចារណាដល់ទានថា អញឲ្យទានដោយល្អហើយ ។ កាលពាវរីព្រាហ្មណ៍ ត្រឡប់ទៅដោយបីតិហើយ ព្រាហ្មណ៍ដទៃ ដែលត្រូវព្រាហ្មណីក្មេង ( ប្រពន្ធ ) បំណាំងទឹងធ្វើការងារមិនប្រពៃតាមធម៌ បញ្ជូនទៅថា មកព្រាហ្មណ៍ ពាវរីព្រាហ្មណ៍ លះបង់ទ្រព្យ ១ សែនរៀងរាល់ឆ្នាំ ត្រង់ច្នេរស្ទឹងគោធាវរី សូមលោកទៅសូមទ្រព្យ ៥០០ គហាបណៈ ហើយនាំទ្រព្យដែលគាត់ឲ្យហើយមក ក៏ចូលមករក ។ បទថា **ឧឃដ្ដបាទោ** សេចក្តីថា ជើងប៉ះគ្នា ដោយការឈានទៅតាមផ្លូវ ឬកែងជើងប៉ះគ្នា កជើងប៉ះគ្នា ឬក្បាលជង្គង់ប៉ះគ្នា ។ បទថា **សុខញ្ច កុសលំ បុច្ឆិ** សេចក្តីថា ពាវរីសួរដល់សុខ និងកុសលថា នៃព្រាហ្មណ៍ អ្នកសប្បាយឬអ្នកធ្វើកុសលដែរឬ ។ បទថា **អនុជានាហិ** បានដល់ សូមលោកយល់ គឺជឿខ្ញុំចុះ ។ បទថា **សត្តធា** បានដល់ ដោយបែកជា ៧ ភាគ ។ បទថា

**អភិសន្ធរិត្វា** លោកអធិប្បាយថា ព្រាហ្មណ៍កាន់យកលាមកគោ ផ្កាស្បូវក្លាំង ក្នុងព្រៃហើយ ប្រញាប់ទៅកាន់ទ្វារអាស្រមរបស់ពាវរីព្រាហ្មណ៍ យកលាមកគោជូតលើផែនដី រោយផ្កា ក្រាលស្បូវក្លាំង យកទឹកក្នុងឃ្នោកលាងជើងធ្វេង ឈាន ៧ ជំហាន អង្អែលជើងស្តាំរបស់ខ្លួន ធ្វើឧបាយបញ្ឆោតយ៉ាងនេះ ។ បទថា **ភេរវំ សោ អកិត្តយិ** សេចក្តីថា ព្រាហ្មណ៍នោះ បានពោលពាក្យដែលនាំឲ្យកើតការខ្លាច អធិប្បាយថា ព្រាហ្មណ៍នោះពោលថា កាលខ្ញុំកំពុងសូម លោកមិនឲ្យ ។ បទថា **ឧក្កិំតោ** បានដល់ ព្រាហ្មណ៍ពាវរីកើតទោមនស្ស ។ បទថា **ឧស្សុស្សតិ** បានដល់ ពាវរីព្រាហ្មណ៍សម្គាល់ថាពាក្យរបស់ព្រាហ្មណ៍នោះ ជួនកាល ជាការពិត ទើបស្ងាំងស្ងួម ។ បទថា **ទេវតា** បានដល់ ទេវតាដែលអាស្រ័យក្នុងអាស្រមនោះឯង ។ បទថា **មុទ្ធនិ មុទ្ធាធិបាតេ ច** បានដល់ ក្នុងធម៌ជាសីសៈ និងក្នុងធម៌ជាហេតុឲ្យសីសៈបែក ។ បទថា **ភោតី ចរហិ ជានាតិ** បានដល់ បើអ្នកស្គាល់ ។ បទថា **មុទ្ធាធិបាតញ្ច** បានដល់ ធម៌ជាក្បាល និងធម៌ជាហេតុឲ្យក្បាលធ្លាក់ទៅ ។ បទថា **ញាណមេត្ថ** កាត់បទជា **ញាណំ មេ ឯត្ថ** ប្រែថា ខ្ញុំមិនមានការដឹងក្នុងធម៌ទាំង ២ យ៉ាងនេះ ។

បទថា **បុរា** សេចក្តីថា កាលពាវរីព្រាហ្មណ៍នៅអាស្រ័យត្រង់ឆ្នេរស្ទឹងគោធាវរី កន្លងទៅបាន ៨ ឆ្នាំ ព្រះពុទ្ធទ្រង់កើតឡើងហើយក្នុងលោក ទ្រង់យាងចេញព្រះផ្នួសចាកក្រុងកបិលពស្តុ កាលព្រះជន្មបាន ២៩ វស្សា ។ បទថា **អបច្ចោ** បានដល់ លំដាប់វង្ស ។ បទថា **សព្វាភិញ្ញាពលប្បត្តោ**

បានដល់ ទ្រង់សម្រេចអភិញ្ញា និងទសពលញ្ញាណគ្រប់គ្រាន់ ឬទ្រង់សម្រេចអភិញ្ញាទាំងអស់ និងពលធម៌ទាំងឡាយ ។ បទថា **វិមុត្តោ** បានដល់ មានព្រះហឫទ័យបង្អោនទៅក្នុងការធ្វើអារម្មណ៍ឲ្យប្រព្រឹត្តទៅ ។ បទថា **សោកស្ស** កាត់បទជា **សោកោ អស្ស** ប្រែថា មានសេចក្តីសោកជូរស្រោល ។

បទថា **បហូតបញ្ញោ** បានដល់ មានបញ្ញាច្រើន ។ បទថា **វរភូរិមេធសោ** បានដល់ មានព្រះបញ្ញាឧត្តមបរិបូណ៌ ឬមានបញ្ញាដូចមហាព្រឹថពីក្រៃលែងក្នុងសេចក្តីពិត ។ បទថា **វិធុរោ** បានដល់ ទ្រង់មានធុរៈទៅប្រាសចាកហើយ លោកអធិប្បាយថា មិនមានការអោក់អន់ ។ បទថា **មន្តចារគេ** សេចក្តីថា ដល់នូវត្រើយនៃវេទ ។ បទថា **បស្សថា** បានដល់ ចូរអ្នកទាំងឡាយទៅគាល់ ។ បទថា **អជានតំ** បានដល់ មិនជ្រាប ។ បទថា **លក្ខណា** បានដល់ លក្ខណៈទាំងឡាយ ។ បទថា **ព្យក្ខាតា** បានដល់ ពោលហើយ អធិប្បាយថា ធ្វើឲ្យទូលាយហើយ ។ បទថា **សមត្តា** បានដល់ ចប់ហើយ អធិប្បាយថា បរិបូណ៌ហើយ ។ បទថា **ធម្មេន មនុស្សាសតិ** បានដល់ ប្រៀនប្រដៅដោយធម៌ ។ បទថា **ជាតិគោត្តញ្ច លក្ខណំ** បានដល់ ជាតិ គោត្ត និងលក្ខណៈរបស់ខ្ញុំ កើតមកយូរប៉ុនណា ។ បទថា **មន្តេ សិស្សេ** បានដល់ វេទដែលខ្ញុំប្រាប់ដល់សិស្សរបស់ខ្ញុំ ។ បទថា **មនសាយេវ បុច្ឆថ** សេចក្តីថា ចូរអ្នកទាំងឡាយសួរ ៧ បញ្ហាដោយចិត្ត ។ បទថា **តិស្សមេត្តេយ្យា** សេចក្តីថា ជាសិស្សតែម្នាក់ប៉ុណ្ណោះ ដោយប្រាប់ទាំងឈ្មោះ និងគោត្ត ។ បទថា **ឧភយោ** បានដល់ ២ នាក់ ។ បទថា **បច្ចេកគណិនោ** បានដល់ ជា

មេគណៈ ម្នាក់មួយគណៈ ។ បទថា **បុព្វវាសនវាសិតា** បានដល់ មានចិត្ត ដែលបុញ្ញវាសនា គឺគតបច្ចាគតវត្ត ដែលធ្លាប់បួសក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមកស្សបៈអប់រំហើយ ។ បទថា **បុរំ មាហិស្សតឹ** បានដល់ នគរ គឺនគរដែលឈ្មោះថាមាហិស្សតី អធិប្បាយថា ចូលទៅកាន់នគរនោះ ។ ក្នុងបទទាំងពួងក៏ន័យនេះ ។ បទថា **គោនទ្ធំ** ជាឈ្មោះនគរគោនទ្ធៈ ។ បទថា **វនសវ្ហយំ** លោកហៅថា **បវនគរ** ។ អាចារ្យពួកខ្លះពោលថា **វនសាវត្ថី** ក៏មាន ។ មានរឿងនិទានថា ជដិល ១៦ នាក់នោះ ចេញអំពីវនសាវត្ថី ដល់នគរកោសម្ពី ចេញអំពីនគរកោសម្ពី ដល់នគរសាកេតតាមលំដាប់ មានបរិស័ទប្រមាណ ៦ យោជន៍ ។

លំដាប់នោះ ព្រះមានព្រះភាគត្រិះរិះថា ពួកជដិលរបស់ពាវរីព្រាហ្មណ៍នាំមហាជនជាច្រើនមក ឥន្ទ្រិយរបស់ជដិលទាំងនោះ ក៏មិនទាន់ចាស់ក្លាផង ទឹកដីទីនោះក៏មិនជាទីសប្បាយ បាសាណកចេតិយដែនមគធៈ ជាទីសប្បាយរបស់ជដិលទាំងនោះ កាលតថាគតសម្តែងធម៌ក្នុងទីនោះ មហាជនក៏នឹងសម្រេចធម៌ ពួកជដិលចូលទៅកាន់នគរទាំងពួង ហើយនាំគ្នាមក នឹងមកព្រមដោយជនច្រើនបន្ថែមឡើងទៀត ទើបទ្រង់ចោមរោមដោយភិក្ខុសង្ឃ យាងចេញអំពីក្រុងសាវត្ថី បែរព្រះភក្ត្រទៅកាន់ក្រុងរាជគ្រឹះ ។ ពួកជដិលទាំងនោះក៏មកកាន់ក្រុងសាវត្ថី ទៅកាន់វិហារ ពិនិត្យមើលថា អ្នកណាជាព្រះពុទ្ធ ព្រះពុទ្ធនៅឯណា នាំគ្នាចូលទៅដល់ព្រះគន្ធកុដិជាទីអាស្រ័យ ឃើញស្នាមព្រះបាទរបស់ព្រះមានព្រះភាគ ក៏ដាក់ចិត្តថា ជាព្រះសព្វញ្ញុពុទ្ធពិត ព្រោះស្នាមជើង

របស់បុគ្គលដែលប្រកបដោយរាគៈ កំពុងកណ្តាល ។បេ។ ជើងបែបនេះ ជាជើងរបស់អ្នកអស់កិលេស ដូចជំបូលដែលបើកហើយ ។

ព្រះមានព្រះភាគ យាងចូលកាន់នគរ មានសេតព្យនគរ និងកបិលពស្តុជាដើមតាមលំដាប់ បន្ថែមមហាជនឡើងទៀត យាងទៅកាន់បាសាណកចេតិយ ។ ពួកជដិលក៏នាំគ្នាចេញអំពីក្រុងសាវត្ថីមួយរំពេច យ៉ាងណា ចូលទៅកាន់នគរទាំងនោះអស់ហើយ បានទៅកាន់បាសាណកចេតិយនោះដូចគ្នា ដោយហេតុនោះ ទើបលោកពោលពាក្យជាដើមថា **កោសម្ពិញ្ចាបិ សាកេតំ សាវត្ថិញ្ច បុរុត្តមំ សេតព្យំ កបិលវត្ថុំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **មាគធំ បុរំ** បានដល់ នគរមគធៈ អធិប្បាយថា នគររាជគ្រឹះ ។ បទថា **បាសាណកំ ចេតិយំ** បានដល់ បាសាណកចេតិយ កាលមុនជាទេវស្ថាន នៅខាងលើផ្ទាំងថ្មជាច្រើន ។ តែកាលព្រះមានព្រះភាគទ្រង់កើតឡើង មានវិហារកើតឡើង វិហារនោះ លោកហៅថា បាសាណកចេតិយ តាមពាក្យដើមនោះឯង ។ បទថា **តសិតោវ ឧទកំ** សេចក្តីថា ជដិលទាំងនោះ ប្រញាប់ដើរតាមព្រះមានព្រះភាគ នាំគ្នាទៅអំពីព្រឹក ចូលកាន់ផ្លូវដែលយាងទៅ ក្នុងវេលាល្ងាច និងទៅវេលាល្ងាចកាន់ផ្លូវដែលយាងទៅក្នុងវេលាព្រឹក លុះបានស្តាប់ថា ព្រះមានព្រះភាគ នៅក្នុងទីនេះ ក៏កើតបីតិបាមោជ្ជ នាំគ្នាឡើងកាន់ចេតិយនោះ ដោយហេតុនោះ ទើបលោកពោលថា **តុរិតា បព្វតមារុហុំ** ។ បទថា **ឯកមន្តំ ឋិតោ ហដ្ឋោ** សេចក្តីថា អជិតមាណពជាប្រធាននៃអន្តេវាសិក ឃើញព្រះមានព្រះភាគ

ទ្រង់គង់ត្រង់មហាមណ្ឌប ដែលសក្កទេវរាជសាងថ្វាយ នាបាសាណកចេតិយនោះ កាលព្រះមានព្រះភាគទ្រង់ធ្វើសម្មោទនីយកថា ដោយន័យជាដើមថា ម្នាលឥសីទាំងឡាយ តើអ្នកប្រព្រឹត្តទៅបានឬទេ ទើបធ្វើបដិសណ្ឋារៈដោយខ្លួនឯងថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គប្រព្រឹត្តទៅបានជាដើម មានចិត្តត្រេកអរ ឈរក្នុងចំណែកម្ខាង បានក្រាបទូលបញ្ហាដោយចិត្ត ។

ក្នុងបទទាំងនោះ បទថា **អាទិស្ស** បានដល់ ប្រារព្ធយ៉ាងនេះថា តិស្សៈ បុស្សៈ ។ បទថា **ជម្មំ** សេចក្តីថា អជិតមាណពសួរថា សូមទ្រង់ត្រាស់ប្រាប់ជាតិរបស់អាចារ្យនៃពួកខ្ញុំព្រះអង្គចុះ ។ បទថា **ធារមឹ** សេចក្តីថា ដល់នូវការសម្រេច ។ បទថា **វីសំ វស្សសតំ** បានដល់ មានអាយុ ១២០ ឆ្នាំ ។ បទថា **លក្ខណោ** បានដល់ មហាបុរិសលក្ខណៈ អធិប្បាយថា ជាអ្នកមិនខ្វះខាតក្នុងមហាបុរិសលក្ខណៈនេះ និងក្នុងគម្ពីរឥតិហាសជាដើម ដទៃចាកមហាបុរិសលក្ខណៈនេះ ។ ម្យ៉ាងទៀត គប្បីនាំបទដទៃ មកប្រកបថា ដល់នូវការសម្រេចក្នុងមន្តទាំងឡាយនោះ ។ បទថា **បញ្ចសតានិ វាចេតិ** សេចក្តីថា ពាវរីព្រាហ្មណ៍ប្រាប់មន្តដោយខ្លួនឯងដល់មាណព ៥០០ នាក់ ដែលខ្ជិលប្រអូស មានបញ្ញាថោកថយជាប្រក្រតី ។ បទថា **សធម្មេ** បានដល់ ក្នុងធម៌របស់ខ្លួន គឺក្នុងធម៌នៃព្រាហ្មណ៍របស់ខ្លួន អធិប្បាយថា ក្នុងបាវចនៈដែលបានដល់វិជ្ជា ៣ ។ បទថា **លក្ខណានំ បវិចយំ** បានដល់ សេចក្តីពិស្តារនៃលក្ខណៈទាំងឡាយ ។ អជិតមាណពទូលសួរថា លក្ខណៈ ៣ ក្នុងខ្លួនរបស់ពាវរីព្រាហ្មណ៍នោះ គឺអ្វី ។ បទថា **បុច្ឆញ្ហិ** បានដល់ អ្នកសួរ ។

បទថា **ករមេតំ បដិភាសតិ** បានដល់ អ្នកណាក៏ដោយ ក្នុងបណ្តាទេវតាជាដើម ទើបដឹងពាក្យសួរនោះ ។

ព្រាហ្មណ៍កាលបានស្តាប់ការព្យាករណ៍បញ្ហា ៥ ហើយ កាលនឹងទូលសួរបញ្ហា ២ ដ៏សេស ទើបក្រាបទូលថា **មុទ្ធំ មុទ្ធាធិបាតញ្ច** ដូច្នេះជាដើម ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ព្យាករបញ្ហាទាំងនោះ ទើបត្រាស់គាថាជាដើមថា **អវិជ្ជា មុទ្ធា** ដូច្នេះ ។

ក្នុងបទទាំងនោះ មានអធិប្បាយថា ព្រោះអវិជ្ជាជាការមិនដឹងក្នុងអរិយសច្ច ៤ ជាក្បាលនៃសង្សារវដ្ត ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **អវិជ្ជា មុទ្ធា** ដូច្នេះ ។ មួយទៀត ព្រោះអរហត្តមគ្គវិជ្ជា គឺវិជ្ជាក្នុងអរហត្តមគ្គ ប្រកបដោយសទ្ធា សតិ សមាធិ កត្តុកម្យតាឆន្ទៈ និងវិរិយៈ ដែលកើតរួមជាមួយខ្លួន ញុំាងក្បាលឲ្យធ្លាក់ទៅ ព្រោះចូលដល់ធម៌ជាសីសៈ ដោយការតាំងនៅក្នុងនាទីតែមួយជាមួយគ្នានឹងឥន្ទ្រិយទាំងឡាយ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **វិជ្ជា មុទ្ធាធិបាតនី** ដូច្នេះ ។ បទថា **តតោ វេទេន មហតា** សេចក្តីថា លំដាប់នោះ អជិតមាណពបានស្តាប់ការព្យាករណ៍បញ្ហានេះហើយ កើតមហាបីតិ មានចិត្តត្រេកអរ ដល់នូវភាពជាអ្នកមិនរួញរាផ្លូវកាយ និងចិត្ត

មានការត្រេកអរក្រៃលែង ។ អជិតមាណពក្រាបចុះហើយ ពោលគាថានេះថា **ពាវរី** ដូច្នេះជាដើម ។ លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់អនុគ្រោះពាវរីនោះ ទើបត្រាស់គាថាថា **សុខិតោ** ដូច្នេះជាដើម ។ កាលត្រាស់ហើយ ទើបទ្រង់បវារណាដោយសព្វញ្ញុបវារណាថា **ពាវរិស្ស ច** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **សព្ពេសំ** បានដល់ អន្តេវាសិក ១៦០០០ មិនមានសេសសល់ ។ បទថា **តត្ថ បុច្ឆិ តថាគតំ** សេចក្តីថា អជិតទូលសួរបញ្ហាដំបូងក្នុងបាសាណកចេតិយនោះ ក្នុងបរិស័ទនោះ ឬក្នុងទីដែលទ្រង់បវារណានោះ ។ បទដ៏សេស ក្នុងគាថាទាំងអស់ជាក់ច្បាស់ល្អហើយ ។៙

**អជ្ឈកថាវត្ថុគាថា ចប់**

# សុត្តន្តបិដក

## អជិតបញ្ហាទី១

[ ១១២ ] ( អជិតមាណពដ៏មានអាយុ ទូលសួរថា ) សត្វលោកត្រូវអ្វីបិទបាំង រមែងមិនជាក់ច្បាស់ព្រោះអ្វី ព្រះអង្គត្រាស់ថា អ្វីជាគ្រឿងប្រឡាក់ អ្វីជាភ័យធំរបស់សត្វលោកនោះ ។

( ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលអជិតៈ ) សត្វលោកត្រូវអវិជ្ជាបិទបាំង រមែងមិនជាក់ច្បាស់ព្រោះសេចក្តីកំណាញ់ និង ( សេចក្តីប្រមាទ ) តថាគតពោលថា តណ្ហាជាគ្រឿងប្រឡាក់ ទុក្ខ ជាភ័យធំរបស់សត្វលោកនោះ ។

( អជិតមាណពដ៏មានអាយុ ទូលសួរថា ) ខ្សែតណ្ហាទាំងឡាយ រមែងហូរទៅក្នុងអាយតនៈទាំងពួង អ្វីជាគ្រឿងទប់ខ្សែតណ្ហាទាំងឡាយ សូមព្រះអង្គត្រាស់ប្រាប់នូវធម៌ ជាគ្រឿងរាំងនូវខ្សែតណ្ហាទាំងឡាយ ខ្សែតណ្ហាទាំងឡាយ ត្រូវបិទដោយអ្វី ។

( ព្រះមានព្រះភាគដោះស្រាយថា ម្នាលអជិតៈ ) សតិជាគ្រឿងទប់ខ្សែតណ្ហាទាំងឡាយនោះ ដែលមាននៅក្នុងលោក តថាគតពោលថា សតិជាគ្រឿងរាំងខ្សែតណ្ហាទាំងឡាយ បុគ្គលគប្បីបិទខ្សែតណ្ហាទាំងនោះ ដោយបញ្ញា ។

( អជិតមាណពដ៏មានអាយុ ទូលសួរថា ) បពិត្រព្រះអង្គនិទ្ទុក្ខ បញ្ញាផង សតិផង នាម និងរូបផង ធម៌នុ៎ះ ដែលខ្ញុំ

ព្រះអង្គសួរហើយ សូមព្រះអង្គសម្តែង តើធម៌នុ៎ះរលត់ទៅក្នុងទីណា ។

ម្នាលអជិតៈ អ្នកបានទូលសួរនូវបញ្ហាណា ចំពោះតថាគត តថាគតនឹងសម្តែងនូវបញ្ហានោះដល់អ្នក នាម និងរូបរលត់មិនសល់ក្នុងទីណា សតិ និងបញ្ញានេះ ក៏រលត់ទៅក្នុងទីនោះ ព្រោះរលត់វិញ្ញាណ ។

ពួកអសេក្ខបុគ្គល អ្នកមានធម៌ពិចារណាហើយ និងពួកសេក្ខបុគ្គលជាច្រើនណា ក្នុងសាសនានេះ បពិត្រព្រះអង្គនិទ៌ុក្ខ ខ្ញុំព្រះអង្គសួរនូវសេចក្តីប្រព្រឹត្តទៅនៃបុគ្គលទាំងនោះ ព្រះអង្គមានបញ្ញាចាស់ក្លា សូមសម្តែងប្រាប់ដល់ខ្ញុំព្រះអង្គ ។

បុគ្គលមិនគប្បីជាប់ជំពាក់ក្នុងកាមទាំងឡាយ គប្បីជាអ្នកមានចិត្តមិនល្អក់ ជាអ្នកឈ្លាសវៃចំពោះធម៌ទាំងអស់ ជាភិក្ខុមានសតិ គប្បីវៀរស្រឡះ ( ចាកកាមទាំងឡាយ ) ។

**អជិតមាណវកបញ្ហាទី ១ ចប់**

# អដ្ឋកថា

## អជិតប្បញ្ហាទី ១

[ ១១២ ] ក្នុងបញ្ហានោះ បទថា **និវុតោ** បានដល់ បិទបាំង ។ បទថា **កិស្សាភិលេបនំ ព្រូសិ** សេចក្តីថា ព្រះអង្គត្រាស់អ្វីថាជាគ្រឿងបូកលាបនូវលោកនេះ ។ បទថា **វេវិច្ឆា បមាទា នប្បកាសតិ** បានដល់ លោកមិនជាក់ច្បាស់ ព្រោះសេចក្តីកំណាញ់ និងព្រោះសេចក្តីប្រមាទជាហេតុ ។ ពិតហើយ សេចក្តីកំណាញ់ មិនធ្វើបុគ្គលឲ្យជាក់ច្បាស់ដោយគុណ មានទានជាដើម ឯសេចក្តីប្រមាទ មិនឲ្យជាក់ច្បាស់ដោយសីលគុណជាដើម ។ បទថា **ជប្បាភិលេបនំ** សេចក្តីថា តណ្ហាជាគ្រឿងបូកលាបលោកនោះ ដូចជ័រដាក់ស្វា ជាប់នូវស្វានោះ ដូច្នោះ ។ បទថា **ទុក្ខំ** បានដល់ ទុក្ខ មានជាតិជាដើម ។ បទថា **សវន្តិ សព្វធិ សោតា** សេចក្តីថា ក្រសែ មានតណ្ហាជាដើម រមែងហូរទៅក្នុងអាយតនៈទាំងឡាយ មានរូបាយតនៈជាដើម ។ បទថា **កឹ និវារណំ** សេចក្តីថា អ្វីជាគ្រឿងរាំង អ្វីជាគ្រឿងការពារនូវក្រសែទាំងនោះ ។ បទថា **សំវរំ ព្រូហិ** សេចក្តីថា សូមព្រះអង្គទ្រង់ត្រាស់ប្រាប់គ្រឿងរាំង គឺគ្រឿងហាមក្រសែទាំងនោះ ។ ដោយបទនេះ អជិតមាណពទូលសួរដល់ការលះក្រសែដ៏សេស ។ បទថា **កេន សោតា បិធិយ្យរេ** បានដល់ ក្រសែទាំងឡាយនោះ ដែលបណ្ឌិតរមែងរាំង គឺកាត់ផ្តាច់ដោយធម៌អ្វី ។ ដោយបទនេះ អជិតមាណពទូលសួរដល់ការលះក្រសែ ដោយមិនមានសេសសល់ ។

បទថា **សតិ តេសំ និវារណំ** បានដល់ សតិដែលប្រកបដោយវិបស្សនាស្វែងរកផ្លូវនៃធម៌ ដែលជាកុសលទាំងឡាយ ជាគ្រឿងរារាំងក្រសែទាំងនោះ ។ បទថា **សោតានំ សំវរំ ព្រូមិ** អធិប្បាយថា តថាគតពោលថា សតិនោះឯងជាគ្រឿងរារាំងក្រសែទាំងឡាយ ។ បទថា **បញ្ញាយេតេ បិធិយ្យរេ** បានដល់ ក្រសែទាំងនោះ ដែលបណ្ឌិតរមែងរារាំងបានដោយមគ្គប្បញ្ញា ដែលសម្រេចដោយការចាក់ធ្លុះ ដល់ភាពជារបស់មិនទៀងជាដើម ក្នុងធម៌ទាំងឡាយ មានរូបជាដើម ដោយប្រការទាំងពួង ។

គប្បីជ្រាបសេចក្តីសង្ខេបក្នុងគាថាដែលជាពាក្យសួរថា បពិត្រព្រះអង្គនិទ្ទុក្ខ បញ្ញាផង សតិផង នាម និងរូបផង ធម៌ទាំងនុ៎ះដែលខ្ញុំព្រះអង្គសួរហើយ សូមព្រះអង្គសម្តែង តើធម៌ទាំងនុ៎ះ រលត់ទៅក្នុងទីណា យ៉ាងនេះថា បញ្ញា សតិ នាមរូបដ៏សេសឯណា ដែលព្រះអង្គត្រាស់ហើយទាំងអស់នោះ រលត់ទៅក្នុងទីណា ទ្រង់ដែលខ្ញុំព្រះអង្គទូលសួរបញ្ហា សូមត្រាស់ប្រាប់បញ្ហានោះ ដល់ខ្ញុំព្រះអង្គចុះ ។

គប្បីជ្រាបសេចក្តីក្នុងគាថាដែលឆ្លើយបញ្ហា របស់អជិតមាណពដូចតទៅនេះ ព្រោះបញ្ញា និងសតិ សង្គ្រោះរួមគ្នាដោយនាមនោះឯង ដូច្នោះទើបព្រះមានព្រះភាគមិនបានត្រាស់បញ្ញា និងសតិដោយឡែកពីគ្នា នេះជាសេចក្តីសង្ខេប ក្នុងបញ្ហានេះ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលអជិតៈ អ្នកបានសួរបញ្ហានេះថា នាម និងរូប រមែងរលត់ទៅ មិនមានសេសសល់ក្នុងទីណា តថាគតនឹងប្រាប់បញ្ហាដែលអ្នកសួរថា នាម និងរូប រមែងរលត់ទៅ

មិនមានចំណែកសេសសល់ក្នុងទីណា សតិ និងបញ្ញានេះ រមែងរលត់ទៅព្រមគ្នា មិនមុនមិនក្រោយក្នុងទីនោះ ព្រោះការរលត់នៃវិញ្ញាណនោះៗ ព្រោះការរលត់នៃវិញ្ញាណនោះឯង ទើបនាមរូបរលត់ទៅ អធិប្បាយថា ការរលត់នាម និងរូបនោះ មិនកន្លងផុតការរលត់នៃវិញ្ញាណនោះទៅបានឡើយ ។

ដោយព្រះតម្រាស់មានប្រមាណប៉ុណ្ណោះ ជាការប្រកាសដល់ទុក្ខសច្ចដោយបទនេះថា **ទុក្ខមស្ស មហាព្ភយំ** ។ ប្រកាសសមុទយសច្ចដោយបទនេះថា **យានិ សោតានិ** ។ ប្រកាសមគ្គសច្ចដោយបទនេះថា **បញ្ញាយេតេ បិធិយ្យរេ** ។ ប្រកាសនិរោធសច្ចដោយបទនេះថា **អសេសំ ឧបរុជ្ឈតិ** ។ អជិតមាណពបានស្តាប់សច្ចៈទាំង ៤ យ៉ាងនេះហើយ មិនទាន់សម្រេចអរិយ-ភូមិ កាលនឹងទូលសួរបដិបទារបស់ព្រះសេក្ខៈ និងអសេក្ខៈ ទើបទូលថា **យេ ច សង្ខាតធម្មាសេ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **សង្ខាតធម្មា** បានដល់ ធម៌ដែលពិចារណាឃើញហើយ ដោយភាពជារបស់មិនទៀងជាដើម ។ បទនេះ ជាឈ្មោះរបស់ព្រះអរហន្តទាំងឡាយ ។ បទថា **សេក្ខា** បានដល់ ព្រះអរិយបុគ្គលដ៏សេសជាអ្នកនៅសិក្សាជាដើម ។ បទថា **បុថុ** បានដល់ ជន ៧ ពួក ។ បទថា **តេសំ មេ និបកោ ឥរិយំ បុដ្ឋោ បព្រូហិ** សេចក្តីថា ទ្រង់មានបញ្ញារក្សាខ្លួន ជាបណ្ឌិត កាលខ្ញុំព្រះអង្គទូលសួរហើយ សូមទ្រង់ត្រាស់ប្រាប់បដិបទារបស់ជនទាំងនោះ ដែលជាសេក្ខៈ និងអសេក្ខៈដល់ខ្ញុំព្រះអង្គចុះ ។

ព្រោះព្រះសេក្ខៈគួរលះកិលេសទាំងអស់ តាំងអំពីកាមច្ឆន្ទនីវរណៈ

ជាដើមនោះឯង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់សម្តែងសេក្ខប្បដិបទា ដល់អជិតមាណពនោះ ដោយកន្លះគាថាថា **កាមេសុ** ដូច្នេះជាដើម ។

បទនោះ មានសេចក្តីដូចតទៅនេះថា ភិក្ខុមិនគប្បីត្រេកអរក្នុងវត្ថុកាមទាំងឡាយដោយការប្រាថ្នាកិលេស លះនូវធម៌ទាំងឡាយ ដែលធ្វើនូវការល្អក់កករដោយចិត្ត មានកាយទុច្ចរិតជាដើម គប្បីជាអ្នកមានចិត្តមិនល្អក់កករ ក៏ព្រោះព្រះអសេក្ខៈជាអ្នកឈ្លាស ព្រោះជាអ្នកពិចារណាសង្ខារទាំងពួង ដោយភាពជារបស់មិនទៀងជាដើម ជាអ្នកមានសតិ ដោយការមានសតិតាមឃើញនូវកាយជាដើមក្នុងធម៌ទាំងពួង នឹងដល់នូវភាពជាភិក្ខុ ព្រោះទម្លាយនូវសក្កាយទិដ្ឋិជាដើមបាន រមែងវៀរដោយជុំវិញគ្រប់ឥរិយាបថ ដូច្នោះ ទើបព្រះមានព្រះភាគទ្រង់សម្តែងសេក្ខប្បដិបទាដោយកន្លះគាថាថា **កុសលោ** ដូច្នេះជាដើម ។ បទដ៏សេស ក្នុងបទទាំងអស់ជាក់ច្បាស់ល្អហើយ ។ ព្រះមានព្រះភាគទ្រង់បញ្ចប់ទេសនាដោយកំពូលនៃធម៌ គឺអរហត្ត ដោយប្រការដូច្នេះ ។

កាលចប់ទេសនា អជិតមាណពបានសម្រេចអរហត្ត មួយអន្លើដោយអន្តេវាសិក ១០០០ ជនច្រើនពាន់ដទៃទៀត បាននូវធម្មចក្ខុ ។ ស្បែកខ្លាជដា និងសំពត់សម្បកឈើជាដើមរបស់អជិតៈ មួយអន្លើដោយអន្តេវាសិកក៏បាត់ទៅព្រមជាមួយការសម្រេចអរហត្ត ។ ភិក្ខុទាំងអស់ទ្រទ្រង់នូវបាត្រ និងចីវរសម្រេចដោយឫទ្ធិ មានសក់ ២ ធ្នាំងដៃ ជាឯហិភិក្ខុ អង្គុយផ្គងអញ្ជលីនមស្ការព្រះមានព្រះភាគ ដោយប្រការដូច្នេះឯង ៕ល៚

# សុត្តន្តបិដក

## តិស្សមេត្តេយ្យបញ្ហាទី២

[ ១១៣ ] ( តិស្សមេត្តេយ្យមាណព ដ៏មានអាយុទូលសួរថា ) អ្នកណា ឈ្មោះថា ជាអ្នកសន្តោសក្នុងលោកនេះ សេចក្តីញាប់ញ័ររមែងមិនមានដល់បុគ្គលណា អ្នកណាដឹងនូវចំណែកនៃខន្ធទាំងពីរ ( ខន្ធអតីត និងអនាគត ) ដោយបញ្ញាហើយ រមែងមិនជាប់នៅក្នុងខន្ធកណ្តាល ( ខន្ធបច្ចុប្បន្ន ) ព្រះអង្គត្រាស់ថា អ្នកណាជាមហាបុរស អ្នកណាធ្លងតណ្ហាជាគ្រឿងចាក់ស្រែះ ក្នុងលោកនេះបាន ។

( ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលមេត្តេយ្យ ) ភិក្ខុមានព្រហ្មចរិយៈ ( សង្រួម ) ក្នុងកាមទាំងឡាយ ប្រាសចាកសេចក្តីប្រាថ្នា មានសតិរឭកឃើញសព្វកាល ភិក្ខុជាអ្នករលត់ទុក្ខ ព្រោះពិចារណាឃើញច្បាស់ ( ឈ្មោះថា ជាអ្នកសន្តោស ) សេចក្តីញាប់ញ័រ រមែងមិនមានដល់ភិក្ខុនោះឡើយ ភិក្ខុនោះ ដឹងនូវចំណែកនៃខន្ធទាំងពីរដោយបញ្ញាហើយ រមែងមិនជាប់នៅក្នុងខន្ធកណ្តាល តថាគតពោលនូវភិក្ខុនោះថា ជាមហាបុរស ភិក្ខុនោះ ឈ្មោះថា ធ្លងនូវតណ្ហា គ្រឿងចាក់ស្រែះក្នុងលោកនេះបាន ។

**តិស្សមេត្តេយ្យមាណវកបញ្ហាទី ២ ចប់**

# អដ្ឋកថា

## តិស្សមេត្តេយ្យបញ្ហាទី ២

[ ១១៣ ] ក្នុងតិស្សមេត្តេយ្យបញ្ហាទី ២ មានពាក្យផ្ដើមថា **កោធ សន្តុសិ្សតោ** ដូច្នេះ

សួរថា តិស្សមេត្តេយ្យបញ្ហា មានអត្ថុប្បត្តិហេតុដូចម្ដេច ឆ្លើយថា តិស្សមេត្តេយ្យបញ្ហា មានអត្ថុប្បត្តិហេតុដូចតទៅ

គ្រប់សូត្រ ( ក្នុងសោឡសបញ្ហា ) មានការកើតឡើងដោយអំណាចនៃការសាកសួរទាំងអស់ ។ ព្រាហ្មណ៍ទាំងនោះ ទូលសួរសេចក្ដីសង្ស័យរៀងៗ ខ្លួន ព្រោះព្រះមានព្រះភាគទ្រង់បវារណាហើយថា ឲ្យឱកាសហើយ ពួកយើងសួរបាន ។ ព្រះមានព្រះភាគ កាលតិស្សមេត្តេយ្យមាណពទូលសួរហើយ ទើបទ្រង់ព្យាករដល់ពួកព្រាហ្មណ៍ទាំងនោះ ។ គប្បីជ្រាបថា សូត្រទាំងនេះ កើតឡើងដោយអំណាចនៃពាក្យសួរ ដោយប្រការដូច្នេះឯង ។

កាលចប់បញ្ហានៃអជិតៈហើយ មោឃរាជផ្ដើមទូលសួរបញ្ហាយ៉ាងនេះថា បុគ្គលកាលពិចារណានូវខ្លួនលោកដូចម្ដេច ទើបមច្ចុរាជមើលមិនឃើញ ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា ឥន្ទ្រិយរបស់មោឃរាជនោះ មិនទាន់ចាស់ក្លា ទើបទ្រង់ឃាត់ថា ម្នាលមោឃរាជ ចូរអ្នកឈប់សិន អ្នកដទៃចូរសួរចុះ ។ លំដាប់នោះ តិស្សមេត្តេយ្យកាលនឹងទូលសួរសេចក្ដីសង្ស័យរបស់ខ្លួន ទើបពោលគាថាថា **កោធ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **កោធ សន្តុសិ្សតោ** សេចក្ដីថា បុគ្គលណាឈ្មោះថា ជាអ្នកត្រេកអរហើយក្នុងលោកនេះ ។ បទថា **ឥញ្ជិតា** បានដល់

អន្ទះអន្ទែងដោយតណ្ហា និងទិដ្ឋិ ។ បទថា **ឧភន្តមភិញ្ញាយ** បានដល់ ដឹងនូវអន្តធម៌ទាំង ២ ។ បទថា **មជ្ឈេ ន លិម្បតិ** បានដល់ មិនជាប់ដោយបញ្ញា ។

ព្រះមានព្រះភាគ កាលទ្រង់ព្យាករបញ្ហាសេចក្ដីនោះដល់តិស្សមេត្តេយ្យ ទើបត្រាស់ ២ គាថាថា **កាមេសុ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **កាមេសុ ព្រហ្មចរិយវា** មានអធិប្បាយថា ឃើញទោសក្នុងកាមទាំងឡាយ ដែលមានកាមជាហេតុ ហើយប្រព្រឹត្តព្រហ្មចរិយៈ គឺប្រកបដោយមគ្គព្រហ្មចរិយៈ ។ ដោយព្រះតម្រាស់មានប្រមាណប៉ុណ្ណេះ ស្មើគ្នានឹងទ្រង់បានសម្ដែងដល់សេចក្ដីសន្តោស ។ ដោយបទថា **វីតតណ្ហោ** ជាដើម ទ្រង់សម្ដែងដល់ការមិនញាប់ញ័រ ។ ក្នុងបទទាំងនោះ បទថា **សង្ខាយ និព្វុតោ** បានដល់ ពិចារណាឃើញធម៌ទាំងឡាយ ដោយជារបស់មិនទៀងជាដើម ហើយរម្ងត់កិលេស ដោយការរម្ងត់រាគៈជាដើម ។ បទដ៏សេស ជាក់ច្បាស់ហើយ ព្រោះមានន័យដូចពោលហើយក្នុងទីដទៃៗ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងសូត្រនេះ ដោយធម៌ដ៏កំពូល គឺអរហត្តដូចគ្នា ។

កាលចប់ទេសនា ព្រាហ្មណ៍នេះក៏តាំងនៅក្នុងអរហត្ត មួយអន្លើដោយអន្តេវាសិក ១០០០ នាក់ អ្នកដទៃទៀតច្រើនពាន់បាននូវធម្មចក្ខុ ។ បទដ៏សេស ដូចគ្នានឹងបទមុននោះឯង ។៚

**អដ្ឋកថាតិស្សមេត្តេយ្យបញ្ហាទី ២ ចប់**

# សុត្តន្តបិដក

## បុណ្ណកប្បញ្ហាទី ៣

[ ១១៤ ] ( បុណ្ណកមាណពដ៏មានអាយុ ទូលសួរថា ) ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយបញ្ហា ទើបមកសួរព្រះអង្គ អ្នកមិនញាប់ញ័រ ទ្រង់ឃើញនូវធម៌ជាឫសគល់ ពួកមនុស្សជាច្រើនក្នុងលោកនេះ គឺឥសី ក្សត្រិយ៍ ព្រាហ្មណ៍ អាស្រ័យនូវអ្វីទើបរៀបចំនូវយញ្ញដល់ពួកទេវតា ខ្ញុំព្រះអង្គទូលសួរនូវដំណើរនោះ សូមព្រះអង្គត្រាស់ប្រាប់សេចក្ដីនោះ ដល់ខ្ញុំព្រះអង្គឲ្យទាន ។

( ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលបុណ្ណកៈ ) ពួកមនុស្សទាំងនេះ ជាច្រើនក្នុងលោកនេះ គឺឥសី ក្សត្រិយ៍ ព្រាហ្មណ៍ បានរៀបចំនូវយញ្ញដល់ពួកទេវតា ម្នាលបុណ្ណកៈ ពួកមនុស្សទាំងនេះ កាលប្រាថ្នានូវភាពនៃហេតុនេះៗ សុទ្ធតែអាស្រ័យនូវធម៌ដែលទ្រុឌទ្រោម ទើបបានរៀបចំយញ្ញ ។

( បុណ្ណមាណពដ៏មានអាយុ ទូលសួរថា ) ពួកមនុស្សចំពួកខ្លះជាច្រើន ក្នុងលោកនេះ គឺឥសី ក្សត្រិយ៍ ព្រាហ្មណ៍ បានរៀបចំនូវយញ្ញដល់ពួកទេវតា បពិត្រព្រះអង្គនិទ្ទុក្ខ ពួកមនុស្សអម្បាលនោះ បើមិនប្រមាទ ( ក្នុងគន្លងនៃយញ្ញ ) តើបានឆ្លងផុតជាតិ និងជរាដែរឬ ខ្ញុំព្រះអង្គសូមទូលសួរដំណើរនោះ សូមព្រះអង្គត្រាស់ប្រាប់សេចក្ដីនោះ ដល់

ខ្ញុំព្រះអង្គឲ្យទាន ។

( ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលបុណ្ណកៈ ) ពួកមនុស្សអម្បាលនោះ ប្រកបក្នុងការបូជា ត្រេកអរដោយអំណាចនៃភវរាគៈ ទើបប៉ុនប៉ង សរសើរ ( ជាប់ចំពាក់ ) បូជាជ្រុលជ្រប់ក្នុងកាម ព្រោះអាស្រ័យលាភ តថាគតពោលថា អ្នកបូជាយញ្ញអម្បាលនោះ មិនបានឆ្លងជាតិ និងជរាទៅបានឡើយ ។

( បុណ្ណមាណពដ៏មានអាយុ ទូលសួរថា ) បពិត្រព្រះអង្គនិទ្ទុក្ខ បើពួកអ្នកបូជាយញ្ញទាំងនោះ ឆ្លងជាតិជរាដោយយញ្ញទាំងឡាយមិនរួចទេ ដូច្នេះ តើនរណាក្នុងទេវលោក មនុស្ស-លោក ទើបឆ្លងជាតិ និងជរាទៅបាន បពិត្រព្រះមានព្រះភាគខ្ញុំព្រះអង្គទូលសួរដំណើរនោះ សូមព្រះអង្គត្រាស់សេចក្ដីនោះដល់ខ្ញុំព្រះអង្គឲ្យទាន ។

( ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលបុណ្ណកៈ ) បុគ្គលណា មិនមានកិលេសជាតគ្រឿងញាប់ញ័រ ក្នុងលោកណាមួយ ព្រោះពិចារណាឃើញនូវធម៌ដ៏ខ្ពស់ និងទាបក្នុងលោក តថាគតពោលថា បុគ្គលនោះ ជាអ្នកស្ងប់ ប្រាសចាកផ្សែង គឺទុច្ចរិត មិនមានសេចក្ដីតានតឹង មិនមានសេចក្ដីប្រាថ្នា តែងឆ្លងជាតិ និងជរាផុតបាន ។

# អដ្ឋកថា

## បុណ្ណកប្បញ្ហាទី ៣

[ ១១៤ ] ក្នុងបុណ្ណកប្បញ្ហាទី ៣ មានពាក្យផ្ដើមថា **អនេជំ** ដូច្នេះជាដើម ។ សូម្បីសូត្រនេះ ព្រះមានព្រះភាគក៏ទ្រង់ឃាត់មោឃរាជដោយន័យមុននោះឯង ។

ក្នុងបទទាំងនោះ បទថា **មូលទស្សាវី** បានដល់ ជាអ្នកឃើញឫសគល់អកុសលមូលជាដើម ។ បទថា **ឥសយោ** សេចក្ដីថា ជដិលជាឈ្មោះមួយរបស់ឥសី ។ បទថា **យញ្ញំ** បានដល់ ទេយ្យធម៌ ។ បទថា **អកប្បយឹសុ** បានដល់ ស្វែងរក ។

បទថា **អាសឹសមានា** បានដល់ ប្រាថ្នារូបជាដើម ។ បទថា **ឥត្ថត្តំ** បានដល់ ប្រាថ្នាយ៉ាងនេះ អធិប្បាយថា ប្រាថ្នានូវភាពជាមនុស្សជាដើម ។ បទថា **ជរំ សិតា** បានដល់ អាស្រ័យជរា ។ ក្នុងបទនេះ លោកពោលដល់ទុក្ខក្នុងវដ្ដៈទាំងអស់ ដោយមាតិកា គឺជរា ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគទ្រង់សម្ដែងថា សត្វទាំងឡាយអាស្រ័យទុក្ខក្នុងវដ្ដៈ កាលមិនផុតអំពីទុក្ខនោះ ទើបប្រាថ្នាយ៉ាងនេះ ។

យញ្ញនោះឯង ឈ្មោះថា **យញ្ញបថ** ក្នុងបទនេះថា **កច្ចិស្សុ តេ ភគវា យញ្ញបថេ អប្បមត្តា អតារុ ជាតិញ្ច ជរញ្ច មារិស** លោកអធិប្បាយថា សត្វទាំងនោះ ជាអ្នកមិនប្រមាទក្នុងយញ្ញ ប្រារព្ធយញ្ញចង់ផុតទុក្ខក្នុងវដ្ដៈបានខ្លះឬទេ ។

បទថា **អាសីសន្តិ** សេចក្តីថា សត្វទាំងឡាយប្រាថ្នាការបានរូបជាដើម ។ បទថា **ថោមយន្តិ** បានដល់ សរសើរយញ្ញជាដើម ដោយន័យជាដើមថា ខ្ញុំឲ្យរបស់ដែលល្អហើយ ។ បទថា **អភិជប្បន្តិ** បានដល់ រមែងបន្ទឺវាចាដើម្បីបានរូបជាដើម ។ បទថា **ជុហន្តិ** បានដល់ រមែងឲ្យ ។ បទថា **កាមាភិជប្បន្តិ បដិច្ច លាភំ** បានដល់ សត្វទាំងឡាយ រមែងខ្សឹកខ្សួលដល់កាមរឿយៗ ព្រោះអាស្រ័យការបានលាភ មានរូបជាដើម គឺរមែងពោលថា ធ្វើដូចម្តេចល្អហ្ន៎ កាមទាំងឡាយ គប្បីមានដល់អញ ។ លោកអធិប្បាយថា ធ្វើនូវតណ្ហាឲ្យចម្រើនឡើងក្នុងកាមទាំងឡាយនោះ ។ បទថា **យាជយោគា** បានដល់ បង្អោនទៅក្នុងការបូជា ។ បទថា **ភវរាគរត្តា** សេចក្តីថា សត្វទាំងឡាយ ត្រេកត្រអាលដោយរាគៈក្នុងភព ដោយការប្រាថ្នាជាដើមទាំងនេះយ៉ាងនេះ ឬត្រេកត្រអាលដោយភវរាគៈ ធ្វើនូវការប្រាថ្នាជាដើមនេះ ឈ្មោះថា មិនឆ្លងផុត គឺមិនឆ្លងផុតទុក្ខក្នុងវដ្ដៈ មានជាតិជាដើមបានទេ ។ បទថា **អថ កោ ចរហិ** សេចក្តីថា កាលបើដូច្នេះ អ្នកណាឆ្លងទៅបានក្នុងឥឡូវនេះ ។

បទថា **សង្ខាយ** បានដល់ ពិចារណាហើយដោយញាណ ។ បទថា **បរោវរានិ** អធិប្បាយថា ខ្ពស់ និងទាប មានភាពជាខ្លួនរបស់អ្នកដទៃ និង

ភាពជាខ្លួនរបស់ខ្លួនឯងជាដើម ។ បទថា **វិធូមោ** បានដល់ ប្រាសចាកផ្សែង មានកាយទុច្ចរិតជាដើម ។ បទថា **អនិឃោ** បានដល់ វៀរចាកកិលេសដែលប៉ះខ្ទប់ចិត្ត មានរាគៈជាដើម ។ បទថា **អតារិ សោ** សេចក្តីថា បុគ្គលបែបនោះ ជាអ្នកឆ្ងាយចាកកិលេស ឆ្លងជាតិ និងជរាទៅបាន ។ បទដ៏សេស ក្នុងសូត្រនេះជាក់ច្បាស់ហើយ ។ ព្រះមានព្រះភាគ ទ្រង់បញ្ចប់សូត្រនេះ ដោយកាន់យកកំពូល គឺអរហត្ត ដោយប្រការដូច្នេះ ។

កាលចប់ទេសនា បុណ្ណកព្រាហ្មណ៍ក៏បានតាំងនៅក្នុងអរហត្ត មួយអន្លើដោយអន្តេវាសិក ១០០០ ជនដទៃទៀតច្រើនពាន់បាននូវធម្មចក្ខុ ។ បទដ៏សេស មានន័យដូចបានពោលហើយនោះឯង ៕□

**អដ្ឋកថាបុណ្ណកប្បញ្ហាទី ៣ ចប់**

# សុត្តន្តបិដក

## មេត្តគូបញ្ហាទី ៨

[ ១១៥ ] ( មេត្តគូមាណពដ៏មានអាយុ ទូលសួរថា ) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់សេចក្ដីនោះ ដល់ខ្ញុំព្រះអង្គឲ្យទាន ខ្ញុំព្រះអង្គសម្គាល់ឃើញថា ព្រះអង្គជាអ្នកដល់វេទ ជាអ្នកមានខ្លួនបានអប់រំហើយ សេចក្ដីទុក្ខទាំងឡាយណាមួយ ជាច្រើនប្រការ ក្នុងលោកនេះ កើតមកអំពីអ្វី ។

( ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលមេត្តគូ ) អ្នកបានសួរអំពីដែនកើតនៃទុក្ខចំពោះតថាគត តថាគតនឹងប្រាប់ដែនកើតនៃទុក្ខនោះដល់អ្នក តាមដែលបានដឹងច្បាស់ សេចក្ដីទុក្ខទាំងឡាយណាមួយ ច្រើនប្រការ ក្នុងលោកនេះ រមែងកើតឡើងព្រោះឧបធិ បុគ្គលណាជាអ្នកល្ងង់ខ្លៅ មិនចេះដឹង តែងធ្វើឧបធិឲ្យកើតឡើង បុគ្គលនោះ រមែងបានទុក្ខរឿយៗ ព្រោះហេតុនោះ បុគ្គលកាលដឹងច្បាស់ ពិចារណាឃើញរឿយៗ នូវកំណើតជាដែនកើតនៃទុក្ខ មិនត្រូវធ្វើឧបធិឡើយ ។

ពួកខ្ញុំព្រះអង្គបានទូលសួរបទណា ព្រះអង្គក៏បានដោះស្រាយបទនោះ ពួកខ្ញុំព្រះអង្គសូមទូលសួរបទដទៃទៀត សូមព្រះអង្គសម្ដែង អ្នកប្រាជ្ញទាំងឡាយ រមែងឆ្លងផុតឱឃៈផង ជាតិ និងជរាផង សោក និងសេចក្ដីខ្សឹកខ្សួលផង ដោយហេតុ

ដូចម្តេច សូមព្រះអង្គជាព្រះមុនី ដោះស្រាយបទនោះដល់ខ្ញុំព្រះអង្គ ព្រោះថា ធម៌នុ៎ះ ព្រះអង្គជ្រាបច្បាស់ហើយ ។

( ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលមេត្តគូ ) បុគ្គលមានសតិ គួរដឹងច្បាស់នូវធម៌ណា ហើយឆ្លងតណ្ហាដែលផ្សាយទៅផ្សេងៗ ក្នុងលោកបាន តថាគតនឹងសម្តែងនូវធម៌នោះដែលតថាគតជាក់ច្បាស់ក្នុងខ្លួន ក្នុងបច្ចុប្បន្ននេះដល់អ្នក ។

បពិត្រព្រះអង្គអ្នកស្វែងរកនូវគុណដ៏ធំ បុគ្គលអ្នកមានសតិ គួរដឹងច្បាស់នូវធម៌ណា ហើយឆ្លងតណ្ហាដែលផ្សាយទៅផ្សេងៗ ក្នុងលោកបាន ខ្ញុំព្រះអង្គត្រេកអរចំពោះធម៌ដ៏ឧត្តមនោះ ។

( ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលមេត្តគូ ) អ្នកដឹងនូវហេតុណានីមួយ ក្នុងចំណែកខាងលើ ( អនាគត ) ក្នុងចំណែកខាងក្រោម ( អតីត ) ក្នុងចំណែកទទឹង ឬកណ្តាល ( បច្ចុប្បន្ន ) អ្នកចូរបន្ទោបង់សេចក្តីត្រេកអរ និងសេចក្តីប្រកាន់មាំ ក្នុងចំណែកនៃហេតុនោះចេញ ទើបវិញ្ញាណ ( របស់អ្នក ) មិនតាំងនៅក្នុងភព ភិក្ខុមានធម៌ជាគ្រឿងនៅយ៉ាងនេះ មានសតិ មិនធ្វេសប្រហែស លះបង់កិលេសដែលប្រកាន់ថាជារបស់អញ ដឹងច្បាស់ក្នុងអត្តភាពនេះហើយ ទើបលះបង់នូវទុក្ខ គឺជាតិ ជរា និងសោកខ្សឹកខ្សួលបាន ។

បពិត្រព្រះគោតម ខ្ញុំព្រះអង្គត្រេកអរនឹងព្រះវាចានោះ របស់

ព្រះអង្គ ជាអ្នកស្វែងរកនូវគុណដ៏ធំ ព្រះនិព្វាន ដែលមិនមានឧបធិ ព្រះអង្គទ្រង់សម្តែងប្រាប់ហើយ បពិត្រព្រះមានព្រះភាគ ព្រះអង្គលះទុក្ខបានដោយពិត ព្រោះធម៌នោះ ព្រះអង្គជ្រាបច្បាស់ហើយ ។ បពិត្រព្រះមុនី ព្រះអង្គប្រដៅពួកជនណាដោយមាំមួន សូម្បីពួកជនទាំងនោះ ក៏លះទុក្ខនោះបានដោយពិត បពិត្រព្រះពុទ្ធនាគ ព្រោះហេតុនោះ ខ្ញុំព្រះអង្គទើបបានមកនមស្ការចំពោះព្រះអង្គ សូម ( ព្រះមានព្រះភាគ ) ប្រដៅខ្ញុំព្រះអង្គដោយមាំមួនចុះ ។

អ្នកស្គាល់ច្បាស់នូវព្រាហ្មណ៍ណា ដល់នូវវេទ មិនមានកិលេសគ្រឿងកង្វល់ មិនជាប់ជំពាក់ក្នុងកាមភព ព្រាហ្មណ៍នោះឈ្មោះថា បានឆ្លងឱឃៈនេះដោយពិត ជនណាមិនមានសេចក្តីរឹងត្អឹង មិនមានសេចក្តីសង្ស័យ បានឆ្លងនូវត្រើយ គឺកិលេស ជននោះឈ្មោះថាជាអ្នកដឹងច្បាស់ អ្នកដល់នូវវេទ ក្នុងអត្តភាពនេះឈ្មោះថា លះធម៌ដែលជាហេតុជាប់ចំពាក់ ក្នុងភពតូចភពធំ ជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីតានតឹង មិនមានសេចក្តីប្រាថ្នា តថាគតពោលថា អ្នកនោះ បានឆ្លងផុតជាតិជរាហើយ ។

**មេត្តគូមាណវកបញ្ហាទី ៥ ចប់**

# អដ្ឋកថា

## មេត្តគូបញ្ហាទី ៤

[ ១១៥ ] ក្នុងមេត្តគូបញ្ហាទី ៤ មានពាក្យផ្ដើមថា **បុច្ឆាមិ តំ** ដូច្នេះ

ក្នុងបទទាំងនោះ បទថា **មញ្ញាមិ តំ វេទគុំ ភាវិតត្តំ** សេចក្ដីថា ខ្ញុំព្រះអង្គសម្គាល់ទ្រង់យ៉ាងនេះថា ព្រះមានព្រះភាគអង្គនេះ ក៏ជាអ្នកចប់នូវវេទ និងជាអ្នកមានខ្លួនអប់រំហើយ ដូច្នេះ ។ **អ** អក្ខរៈ ក្នុងពាក្យនេះថា **អបុច្ឆសិ** ត្រឹមតែជានិបាត គឺធ្វើបទឲ្យពេញ សេចក្ដីថា ទូលសួរហើយ ។ បទថា **តន្តេ បវក្ខាមិ យថា បជានំ** សេចក្ដីថា តថាគតប្រាប់ហេតុនោះដល់អ្នកតាមដែលដឹង ។ បទថា **ឧបធិនិទានា បភវន្តិ ទុក្ខា** សេចក្ដីថា ការផ្សេងគ្នានៃទុក្ខ មានជាតិជាដើម រមែងកើតឡើង ព្រោះឧបធិ មានតណ្ហាជាដើមហេតុ ។ កាលទុក្ខទាំងឡាយកើតឡើង ព្រោះមានឧបធិជាហេតុយ៉ាងនេះ គប្បីជ្រាបគាថាបន្ដថា **យោ វេ អវិទ្វា** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **បជានំ** បានដល់ ដឹងសង្ខារទាំងឡាយដោយភាពជារបស់មិនទៀងជាដើម ។ បទថា **ទុក្ខស្ស ជាតិប្បភវានុបស្សី** បានដល់ ពិចារណារឿយៗ ថា ឧបធិជាហេតុកើតនៃទុក្ខក្នុងវដ្ដៈ ។ បទថា **សោកបរិទ្ទវញ្ច** បានដល់ សេចក្ដីសោក និងសេចក្ដីខ្សឹកខ្សួល ។ បទថា **តថា ហិ តេ វិទិតោ ឯស ធម្មោ** សេចក្ដីថា ធម៌នេះទ្រង់ជ្រាបច្បាស់ហើយដោយកម្លាំងញាណជាដើម ដែលសត្វទាំងឡាយមិនដឹង ។

បទថា **កិត្តយិស្សាមិ តេ ធម្មំ** សេចក្ដីថា តថាគតនឹងសម្ដែងធម៌ គឺព្រះនិព្វាន និងធម៌ គឺបដិបទាឲ្យដល់ព្រះនិព្វានដល់អ្នក ។ បទថា **ទិដ្ឋេ**

**ធម្មំ** បានដល់ ក្នុងធម៌មានទុក្ខជាដើមដែលតថាគតបានឃើញហើយ ឬក្នុងអត្តភាពនេះឯង ។ បទថា **អធីតិហំ** បានដល់ ដែលខ្លួនឯងបានឃើញ ។ បទថា **យំ វិទិត្វា** សេចក្តីថា ដែលបុគ្គលពិចារណាដោយន័យជាដើមថា សង្ខារទាំងឡាយមិនទៀង ដឹងច្បាស់ហើយ ។

បទថា **តញ្ចាហំ អភិនន្ទាមិ** សេចក្តីថា ខ្ញុំព្រះអង្គត្រេកអរក្រៃលែងនូវធម៌ មានប្រការដូចទ្រង់ត្រាស់នោះ ឬពាក្យរបស់ទ្រង់ដែលចុះបញ្ចាំងដល់ធម៌ដែលទ្រង់ត្រាស់ហើយ ។ បទថា **ធម្មមុត្តមំ** បានដល់ ខ្ញុំព្រះអង្គត្រេកអរក្រៃលែង នូវធម៌ដ៏ឧត្តមរបស់ទ្រង់ ។

ក្នុងពាក្យនេះថា **ឧទ្ធំ អធោ ច តិរិយញ្ចាបិ មជ្ឈេ** សេចក្តីថា អនាគតអទ្ធា លោកពោលថា ជាចំណែកខាងលើ អតីតអទ្ធា លោកពោលថា ចំណែកខាងក្រោម បច្ចុប្បន្នអទ្ធា លោកពោលថា ជាចំណែកខាងទទឹង គឺត្រង់កណ្តាល ។ បទថា **ឯតេសុ នន្ទិញ្ច និវេសនញ្ច បនុជ្ជ វិញ្ញាណំ** សេចក្តីថា ចូរអ្នកបន្ទោបង់តណ្ហា ការប្រកាន់មាំ គឺទិដ្ឋិ និងអភិសង្ខារ-វិញ្ញាណ ក្នុងអទ្ធាជាដើមនោះចេញ កាលបន្ទោបង់ហើយ មិនគប្បីតាំងនៅក្នុងភព កាលបើដូច្នេះ ក៏មិនគប្បីតាំងនៅក្នុងភពទាំង ២ ។ គប្បីជ្រាបការភ្ជាប់សេចក្តីក្នុងការកំណត់សេចក្តីនេះនៃ **បនុជ្ជ** សព្ទថា **បនុទេហិ** ប្រែថា ចូរអ្នកបន្ទោបង់ ។ គប្បីជ្រាបការភ្ជាប់សេចក្តីនេះដូចគ្នា មិនគប្បីតាំងនៅក្នុងភព ក្នុងការកំណត់សេចក្តីនេះថា **បនុទិត្វា** ប្រែថា កាលបន្ទោបង់ហើយ លោកអធិប្បាយថា ភិក្ខុកាលបន្ទោបង់នូវការត្រេកអរក្នុងការប្រកាន់

មាំ និងវិញ្ញាណទាំងនេះហើយ មិនគប្បីតាំងនៅក្នុងភព ២ យ៉ាង ។ ភិក្ខុ កាលបន្ទោបង់យ៉ាងនេះហើយ កាលមិនតាំងនៅក្នុងភព គប្បីជ្រាបគាថាបន្ទ ថា **ឯវំវិហារី** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឥធេវ** បានដល់ ក្នុងសាសនានេះ ឬក្នុងអត្តភាព នេះ ។ បទថា **អនុបធិកំ** ក្នុងបទនេះថា **សុកិត្តិតំ គោតម អនុបធិកំ** បានដល់ និព្វាន ។ មេត្តគូមាណពសំដៅដល់ធម៌នោះ កាលនឹងទូលសួរព្រះ មានព្រះភាគ ទើបទូលថា **សុកិត្តិតំ គោតម អនុបធិកំ** ដូច្នេះ ។ មិន មែនទ្រង់លះទុក្ខបានតែម្យ៉ាងតែប៉ុណ្ណោះទេ គប្បីជ្រាបគាថាបន្ទថា **តេ ចាបិ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អដ្ឋិតំ** បានដល់ គោរព ឬអើពើ ។ បទថា **តំ តំ នមស្សាមិ** សេចក្ដីថា ព្រោះហេតុនោះ ទើបខ្ញុំព្រះអង្គសូមនមស្ការ ទ្រង់ ។ បទថា **សមេច្ច** បានដល់ ចូលទៅជិត ។ មេត្តគូមាណពកាលទូល ព្រះមានព្រះភាគ ទើបទូលថា **នាគ** ដូច្នេះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលព្រាហ្មណ៍នោះដឹងច្បាស់ហើយយ៉ាង នេះថា ព្រះមានព្រះភាគ ទ្រង់លះទុក្ខបានហើយពិតប្រាកដ ទ្រង់មិនលើក ព្រះអង្គ កាលនឹងទូន្មានព្រាហ្មណ៍នោះ ដោយលើកបុគ្គលដែលលះទុក្ខបាន ហើយ ទើបត្រាស់គាថាថា **យំ ព្រាហ្មណំ** ដូច្នេះជាដើម ។

ក្នុងគាថានោះ មានសេចក្ដីដូច្នេះថា អ្នកគប្បីដឹងបុគ្គលណាថា បុគ្គល នេះជាព្រាហ្មណ៍ ព្រោះជាអ្នកបន្សាត់បាបបានហើយ ជាអ្នកចប់នូវវេទ ព្រោះ

ជាអ្នកទៅដោយវេទទាំងឡាយ ជាអ្នកមិនមានកិលេសជាគ្រឿងកន្លង់ ព្រោះមិនមានសេចក្ដីកន្លង់ ជាអ្នកមិនជាប់ជំពាក់ក្នុងកាមភព ព្រោះមិនជាប់នៅក្នុងកាមទាំងឡាយ និងក្នុងភពទាំងឡាយ បុគ្គលនោះ ឆ្លងឱឃៈនេះ និងឆ្លងបាបបាន ពិតហើយ មិនមានចម្រូង គឺកិលេស មិនមានសេចក្ដីសង្ស័យ ។ សួរថា មានអ្វីក្រៃលែងជាងនោះ ឆ្លើយថា គប្បីជ្រាបគាថាជាបន្ទថា **វិទ្វា ច សោ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ឥធ** បានដល់ ក្នុងសាសនានេះ ឬក្នុងអត្តភាពនេះ ។ បទថា **វិសជ្ជ** បានដល់ លះហើយ ។ បទដ៏សេស ក្នុងទីទាំងពួងជាក់ច្បាស់ហើយ ។ ព្រះមានព្រះភាគ ទ្រង់សម្ដែងព្រះសូត្រនេះដោយកំពូលនៃធម៌ គឺអរហត្តដូចគ្នា កាលចប់ធម៌ទេសនា សត្វដែលសម្រេចធម៌ ដូចគ្នាតាមដែលពោលមកហើយនោះឯង ។៚

## អដ្ឋកថាមេត្តគូបញ្ហាទី ៤ ចប់

# សុត្តន្តបិដក

## ធោតកប្បញ្ហាទី ៥

[ ១១៦ ] *( ធោតកមាណពដ៏មានអាយុ ទូលសួរថា ) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គក្រាបទូលសួរព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គស្វែងរកគុណដ៏ធំ ខ្ញុំព្រះអង្គប្រាថ្នា ( ស្តាប់ ) ព្រះវាចារបស់ព្រះអង្គ បុគ្គលបានស្តាប់ព្រះពុទ្ធដីកា ជាសុរសីហនាទ របស់ព្រះអង្គហើយ នឹងសិក្សាធម៌ជាគ្រឿងរម្ងាត់កិលេសរបស់ខ្លួន ។*

*( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលធោតកៈ ) បើដូច្នោះ អ្នកចូរជាបុគ្គល មានបញ្ញាខ្ជាប់ខ្ជួន មានសតិ ធ្វើសេចក្តីព្យាយាមក្នុងសាសនានេះចុះ បុគ្គលបានស្តាប់ពាក្យ អំពីសម្នាក់នៃតថាគតនេះហើយ គប្បីសិក្សាធម៌ ជាគ្រឿងរម្ងាត់កិលេសរបស់ខ្លួន ។*

*ខ្ញុំព្រះអង្គ បានឃើញព្រះអង្គជាព្រាហ្មណ៍ ឥតមានកង្វល់ត្រាច់ទៅក្នុងទេវលោក និងមនុស្សលោក បពិត្រព្រះអង្គមានចក្ខុជុំវិញ ខ្ញុំព្រះអង្គសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គជាសក្យ-ពង្ស សូមព្រះអង្គដោះខ្ញុំព្រះអង្គ ចេញចាកសេចក្តីសង្ស័យទាំងឡាយ ។*

*ម្នាលធោតកៈ តថាគតមិនអាចដើម្បីនឹងដោះអ្នកណាមួយក្នុងលោក ដែលមានសេចក្តីសង្ស័យបានទេ ប៉ុន្តែ កាលបើអ្នក*

ដឹងធម៌ដ៏ប្រសើរយ៉ាងនេះ នឹងឆ្លងឱឃៈនេះបាន ។

បពិត្រព្រះអង្គជាព្រហ្ម សូមព្រះអង្គទ្រង់ព្រះករុណា ប្រៀនប្រដៅវិវេកធម៌ ឲ្យខ្ញុំព្រះអង្គដឹងច្បាស់ ដើម្បីខ្ញុំព្រះអង្គមិនទើសទាល់ ដូចអាកាស ជាអ្នកស្ងប់ មិនអាស្រ័យដោយកិលេសក្នុងពេលនេះ ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលធោតកៈ ) បុគ្គលមានសតិគួរដឹងច្បាស់ នូវសន្តិបទណា ហើយឆ្លងតណ្ហា ដែលផ្សាយទៅក្នុងលោកបាន តថាគតនឹងសម្តែងនូវសន្តិបទនោះ ដែលតថាគតជាក់ច្បាស់ក្នុងខ្លួន ក្នុងបច្ចុប្បន្នដល់អ្នក ។

បពិត្រព្រះអង្គ អ្នកស្វែងរកនូវគុណដ៏ធំ បុគ្គលមានសតិ គួរដឹងច្បាស់នូវសន្តិបទណា ហើយឆ្លងតណ្ហាដែលផ្សាយទៅផ្សេងៗក្នុងលោកបាន ខ្ញុំព្រះអង្គត្រេកអរ ចំពោះសន្តិបទដ៏ស្ងប់ឧត្តមនោះ ។

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលធោតកៈ ) អ្នកដឹងច្បាស់អារម្មណ៍ណានីមួយ ក្នុងចំណែកខាងលើ ( អនាគត ) ក្នុងចំណែកខាងក្រោម ( អតីត ) និងក្នុងចំណែកទទឹង ឬកណ្តាល ( បច្ចុប្បន្ន ) ដឹងច្បាស់ថា ជាអារម្មណ៍ជាប់ចំពាក់នៅក្នុងលោកយ៉ាងនេះហើយ អ្នកកុំធ្វើតណ្ហាក្នុងភពតូចភពធំទៀតឡើយ ។

# អដ្ឋកថា

## ធោតកប្បញ្ហាទី ៥

[ ១១៦ ] ក្នុងធោតកបញ្ហាទី ៥ មានពាក្យផ្តើមថា **បុច្ឆាមិ តំ** ដូច្នេះ

ក្នុងបទទាំងនោះ បទថា **វាចាភិកង្ខាមិ** កាត់បទជា **វាចំ អភិកង្ខាមិ** ប្រែថា ប្រាថ្នាយ៉ាងក្រៃលែងនូវព្រះវាចា ។ បទថា **សិក្ខេ និព្វានមត្តនោ** បានដល់ គប្បីសិក្សាអធិសីលជាដើម ដើម្បីប្រយោជន៍ដល់ការរម្ងាត់កិលេសមានរាគៈជាដើមដើម្បីខ្លួន ។ បទថា **ឥតោ** បានដល់ អំពីមាត់របស់តថាគត ។

កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ធោតកមាណព មានការត្រេកអរ សរសើរព្រះមានព្រះភាគ កាលទូលសូមឲ្យដោះសេចក្តីសង្ស័យ ទើបពោលគាថានេះថា **បស្សាមហំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **បស្សាមហំ ទេវមនុស្សលោកេ** សេចក្តីថា ខ្ញុំព្រះអង្គឃើញព្រះមានព្រះភាគជាព្រាហ្មណ៍មិនមានកង្វល់ ទ្រង់ញុំាងព្រះឥរិយាបថឲ្យប្រព្រឹត្តទៅក្នុងទេវលោក និងមនុស្សលោក ។ បទថា **តំ តំ នមស្សាមិ** បានដល់ ខ្ញុំព្រះអង្គសូមនមស្ការទ្រង់ដែលមានសភាពបែបនោះ ។ បទថា **បមុញ្ច** បានដល់ សូមទ្រង់ដោះ ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ដោះនូវសង្ស័យទាក់ទងដោយព្រះអង្គ ទើបត្រាស់គាថាថា **នាហំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **នាហំ សមិស្សាមិ** បានដល់ តថាគតនឹងមិនមកដល់ គឺមិនសិក្សា អធិប្បាយថា នឹងមិនព្យាយាម ។ បទថា **បមោ–**

**ចឆាយ** បានដល់ ដើម្បីដោះ ។ បទថា **កថំកថី** បានដល់ មានសេចក្តីសង្ស័យ ។ បទថា **តរេសិ** បានដល់ គប្បីឆ្លង ។

ព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ ធោតកមាណពត្រេកអរក្រៃលែង សរសើរព្រះមានព្រះភាគក្រៃលែង កាលទូលសូមឲ្យប្រៀនប្រដៅ ទើបពោលគាថាថា **អនុសាស ព្រហ្មេ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ព្រហ្មេ** នេះ ជាវាចាដែលប្រសើរបំផុត ។ ដោយហេតុនោះ ទើបធោតកមាណពទូលហៅព្រះមានព្រះភាគថា **អនុសាស ព្រហ្មេ** ដូច្នេះ ។ បទថា **វិវេកធម្មំ** បានដល់ ធម៌ គឺនិព្វានជាគ្រឿងស្ងាត់ចាកសង្ខារទាំងពួង ។ បទថា **អព្យាបជ្ជមានោ** បានដល់ មិនជាប់ជំពាក់ មានប្រការផ្សេងៗ ។ បទថា **ឥធេវ សន្តោ** បានដល់ នៅក្នុងទីនេះឯង ។ បទថា **អសិតោ** បានដល់ មិនអាស្រ័យ ។ ២ គាថាក្រៅអំពីនេះ មានន័យដូចពោលហើយ ក្នុងមេត្តគូសូត្រនោះឯង ។ មានការផ្សេងគ្នាតែម៉្យាង គឺក្នុងមេត្តគូសូត្រនោះ ជា **ធម្មំ** ក្នុងសូត្រនេះ ជា **សន្តិ** ។ កន្លះគាថាមុន ក្នុងគាថាទី ៣ មានន័យដូចពោលហើយ ក្នុងមេត្តគូបញ្ហានោះឯង ក្នុងចំណែកដែលខុសគ្នា គឺបទថា **សង្គោ** គឺជាឋានៈដែលជាប់ជំពាក់ អធិប្បាយថា ជាគ្រឿងជាប់ជំពាក់ ។ បទដ៏សេស ក្នុងទីទាំងពួងជាក់ច្បាស់ហើយ ។ ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនានេះ ដោយកំពូលនៃធម៌ គឺអរហត្ត ដោយប្រការដូច្នេះឯង កាលចប់ទេសនា បុគ្គលសម្រេចធម៌ ដូចគ្នាតាមដែលពោលមកហើយនោះឯង ៕

# សុត្តន្តបិដក

## ឧបសីវមាណវបុច្ឆាទី៦

[ ១១៧ ] ( ឧបសីវមាណពដ៏មានអាយុ ទូលសួរថា ) បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គម្នាក់ឯង មិនអាស្រ័យ ( ធម៌ ឬបុគ្គល ) ទើបមិនអាចឆ្លងឱឃៈដ៏ធំបាន បពិត្រព្រះអង្គមានចក្ខុជុំវិញ សូមព្រះអង្គសម្តែងនូវអារម្មណ៍ គឺនិស្ស័យដែលនាំឲ្យខ្ញុំព្រះអង្គអាស្រ័យ ហើយឆ្លងឱឃៈនេះ ។

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលឧបសីវៈ ) អ្នកចូរមានសតិសម្ផឹង អាកិញ្ចញ្ញាយតនជ្ឈាន អាស្រ័យដោយបរិកម្មថា មិនមានៗ ហើយឆ្លងឱឃៈចុះ អ្នកចូរលះកាមទាំង-ឡាយ វៀរចាកសេចក្តីសង្ស័យចេញ ចូរពិចារណាធម៌ជាទីអស់ទៅនៃតណ្ហា ទាំងយប់ ទាំងថ្ងៃចុះ ។

( ឧបសីវមាណពដ៏មានអាយុ ទូលសួរថា ) អ្នកណាប្រាសចាកតម្រេក ក្នុងកាមទាំងឡាយទាំងពួង លះបង់ឈានដទៃ អា-ស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ អ្នកនោះមិនសាបសូន្យ ឋិតនៅក្នុងអាកិញ្ចញ្ញាយតនៈនោះ បានដែរឬ ។

( ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ ) អ្នកណាប្រាសចាកតម្រេក ក្នុងកាមទាំងឡាយទាំងពួង លះឈានដទៃអាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏

ប្រសើរ បុគ្គលនោះជាអ្នកមិនសាបសូន្យ គប្បីឋិតនៅក្នុងអាកិ-ញ្ចញ្ញាយតនជ្ឈានបាន ។

បពិត្រព្រះអង្គមានចក្ខុជុំវិញ បើអ្នកនោះ ជាអ្នកមិនសាប សូន្យ គប្បីឋិតនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ អស់ប្រជុំនៃ ឆ្នាំជាច្រើន អ្នកនោះ ជាអ្នកមានចិត្តចុះស៊ប់ ត្រជាក់ក្នុង អាកិញ្ចញ្ញាយតនជ្ឈានឬ វិញ្ញាណរបស់បុគ្គលមានសភាពដូច្នោះ គប្បីឃ្លាតទៅឬ ។

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលឧបសីវៈ ) អណ្តាតភ្លើង ដែលត្រូវកម្លាំងខ្យល់បក់ រមែងរលត់ទៅ មិនដល់ នូវការរាប់ ( ថាទៅក្នុងទីណាទេ ) យ៉ាងណាមិញ មុនីរួច ស្រឡះហើយចាកនាមកាយ រមែងរលត់ទៅ មិនដល់នូវការរាប់ ( ថាទៅក្នុងទីណា ) យ៉ាងនោះដែរ ។

បុគ្គលនោះ រលត់ទៅ លែងមាន ឬថា ឥតមានមោះមៃ ដោយការតាំងនៅទៀងទាត់ សូមព្រះមុនីសម្តែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ព្រោះថា ធម៌នោះ ព្រះអង្គជ្រាបច្បាស់ហើយ ។

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលឧបសីវៈ ) បុគ្គលដែលរលត់ទៅហើយ នឹងប្រមាណពុំបានទេ ពួកជនពោល ចំពោះបុគ្គលនោះ ព្រោះកិលេសណា កិលេសនោះរបស់បុគ្គល នោះ មិនមានទេ កាលធម៌ទាំងឡាយ ដែលបុគ្គលនោះកម្ចាត់

អស់ហើយ សូម្បីគន្ធនៃពាក្យទាំងអស់ ក៏បុគ្គលនោះកម្ចាត់អស់ហើយ ។

ឧបសីវមាណវកប្បបញ្ហាទី ៦ ចប់

# អដ្ឋកថា

## ឧបសីវប្បញ្ហាទី៦

[ ១១៧ ] ក្នុងឧបសីវប្បញ្ហាទី ៦ មានពាក្យផ្តើមថា **ឯកោ អហំ** ដូច្នេះ ក្នុងបទទាំងនោះ បទថា **មហន្តមោឃំ** កាត់បទជា **មហន្តំ ឱឃំ** បានដល់ អន្លង់ទឹកធំ ។ បទថា **អនិស្សិតោ** បានដល់ មិនអាស្រ័យធម៌ ឬបុគ្គល ។ បទថា **នោ វិសហាមិ** បានដល់ ខ្ញុំព្រះអង្គមិនអាច ។ បទថា **អារម្មណំ** បានដល់ ធម៌ជាទីអាស្រ័យ ។ បទថា **យំ និស្សិតោ** បានដល់ អាស្រ័យធម៌ ឬបុគ្គល ។

ឥឡូវនេះ ព្រោះព្រាហ្មណ៍នោះបានអាកិញ្ចញ្ញាយតនៈ តែមិនដឹងធម៌ជាទីអាស្រ័យមាន ព្រោះហេតុនោះ ព្រះមានព្រះភាគកាលទ្រង់សម្តែងធម៌ជាទីអាស្រ័យ និងផ្លូវដែលជាគ្រឿងនាំចេញក្រៃលែងឡើងដល់ព្រាហ្មណ៍នោះ ទើបត្រាស់គាថាថា **អាកិញ្ចញ្ញំ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **បេក្ខមានោ** បានដល់ សម្លឹង គឺមានសតិចូលអាកិញ្ចញ្ញាយតនសមាបត្តិនោះ និងចេញចាកអាកិញ្ចញ្ញាយតនសមាបត្តិ

ហើយ ពិចារណាដោយភាពជារបស់មិនទៀងជាដើម ។ បទថា **នត្ថីតិ និស្សាយ** បានដល់ ធ្វើសមាបត្តិដែលប្រព្រឹត្តទៅហើយនោះឲ្យជាអារម្មណ៍ថា អ្វីមិនមាន ។ បទថា **តរស្សុ ឱឃំ** បានដល់ ឆ្លងឱឃៈ ៤ យ៉ាង តាមសមគួរ ដោយវិបស្សនាដែលប្រព្រឹត្តទៅហើយ តាំងអំពីនោះមក ។ បទថា **កថាហិ** បានដល់ ចាកសេចក្តីសង្ស័យ ។ បទថា **តណ្ហក្ខយំ រត្តមហាភិបស្ស** សេចក្តីថា ចូរឃើញនិព្វាន ធ្វើឲ្យជាក់ច្បាស់ទាំងយប់ និងថ្ងៃ ។ ដោយបទនេះ ព្រះមានព្រះភាគ ត្រាស់ដល់ធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នដល់ឧបសីវមាណពនោះ ។

ឥឡូវនេះ ឧបសីវមាណពកាលបានស្តាប់ថា លះកាមទាំងឡាយដូច្នេះហើយ ពិចារណាឃើញកាមដែលខ្លួនលះបានហើយ ដោយការសង្កត់សង្កិន ទើបពោលគាថាថា **សព្វេសុ** ដូច្នេះជាដើម ។

បទថា **ហិត្វា មញ្ញំ** បានដល់ លះសមាបត្តិដទៃ ៦ យ៉ាង ដែលទាបជាងអាកិញ្ចញ្ញាយតនសមាបត្តិនោះ ។ បទថា **សញ្ញាវិមោក្ខេ បរមេ** បានដល់ បង្អោនចិត្តក្នុងអាកិញ្ចញ្ញាយតនសមាបត្តិ ដែលជាសញ្ញាវិមោក្ខដ៏ឧត្តម ក្នុងបណ្តាសញ្ញាវិមោក្ខ ៧ យ៉ាង ។ បទថា **តិដ្ឋេ នុ សោ តត្ថ អនានុយាយី** សេចក្តីថា ឧបសីវមាណពទូលសួរថា បុគ្គលនោះ ជាអ្នកមិនញាប់ញ័រ តាំងនៅក្នុងអាកិញ្ចញ្ញាយតនព្រហ្មលោកមែនឬហ្ន៎ ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ប្រាប់ការតាំងនៅប្រមាណ ៦ ម៉ឺនកប្បរបស់បុគ្គលនោះ ទើបត្រាស់គាថាទី ៣ ។ ឧបសីវមាណពបានស្តាប់

ការតាំងនៅក្នុងព្រហ្មលោកនោះរបស់បុគ្គលនោះហើយ ឥឡូវនេះ កាលទូលសួរថា ជនទាំងនោះទៀងមិនដាច់សូន្យ ទើបពោលគាថាថា **តិដ្ឋេ ចេ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **បូគម្បិ វស្សានំ** បានដល់ អស់ឆ្នាំមិនមែនតិច ។ បាឋៈថា **បូគម្បិ វស្សានិ** ដូច្នេះក៏មាន ។ ក្នុងបទទាំងនោះ គប្បីធ្វើឆដ្ឋីវិភត្តិឲ្យជាបឋមាវិភត្តិ ដោយផ្លាស់វិភត្តិ ។ម្យ៉ាងទៀត បទថា **បូគំ** នេះ គួរប្រែថា ច្រើន ។ អាចារ្យពួកខ្លះពោលថា **បគានិ** ដូច្នេះក៏មាន ។ បាឋៈមុនល្អជាងបាឋៈទាំងឡាយ ។ បទថា **តត្ថេវ សោ សីតិ សិយា វិមុត្តោ** សេចក្តីថា បុគ្គលនោះដល់នូវការផុតចាកទុក្ខផ្សេងៗ ក្នុងអាកិញ្ចញ្ញាយតនៈព្រហ្មលោកនោះឯង គប្បីជាអ្នកដល់នូវភាពត្រជាក់ សម្រេចនិព្វាន ជាអ្នកទៀង តាំងនៅ ។ បទថា **ភវេថ វិញ្ញាណំ តថាវិធស្ស** បានដល់ ឧបសីវមាណពសួរដល់ការដាច់សូន្យ ដោយពាក្យថា វិញ្ញាណរបស់បុគ្គលនោះគប្បីរលត់ ព្រោះមិនប្រកាន់មាំ សួរដល់បដិសន្ធិរបស់បុគ្គលនោះ ដោយពាក្យថា វិញ្ញាណគប្បីមាន ដើម្បីកាន់យកបដិសន្ធិទៀត ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់បរិនិព្វាន ព្រោះមិនប្រកាន់មាំរបស់ព្រះអរិយសាវកដែលកើតហើយ ក្នុងអាកិញ្ចញ្ញាយតនភពនោះថា មិនចូលទៅអាស្រ័យឧច្ឆេទទិដ្ឋិ និងសស្សតទិដ្ឋិដល់ឧបសីវមាណពនោះ ទើបត្រាស់គាថាថា **អច្ចិ យថា** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **អត្ថំ បលេតិ** គឺដល់នូវការរលត់ទៅ ។ បទ

ថា **ន ឧបេតិ សង្ខំ** សេចក្តីថា ពោលមិនបានថា ទៅកាន់ទិសនោះ ។ បទថា **ឯវំ មុនី នាមកាយា វិមុត្តោ** សេចក្តីថា ព្រះសេក្ខមុនីក៏ដូច្នោះ កើតឡើងហើយ ក្នុងអាកិញ្ចញ្ញាយតនភពនោះ ផុតពីរូបកាយក្នុងកាលមុនតាមប្រក្រតីហើយ ញ៉ាំងមគ្គទី ៤ ឲ្យកើតឡើងក្នុងភពនោះ ទើបផុតហើយចាកនាមកាយទៀត ព្រោះកំណត់ដឹងនាមកាយ ជាព្រះខីណាស្រពឧភតោភាគ-វិមុត្ត រមែងចូលដល់ការរលត់ទៅ គឺបរិនិព្វានដោយអនុបាទាបរិនិព្វាន រមែងមិនចូលដល់នូវការរាប់ថា ជាក្សត្រ ឬព្រាហ្មណ៍ ។

ឥឡូវនេះ ឧបសីវមាណពបានស្តាប់ថា មុនីរមែងដល់នូវការរលត់ទៅដូច្នេះហើយ កាលមិនយល់អត្ថនៃបទនោះ ទើបពោលគាថាថា **អត្ថង្គតោ សោ** ដូច្នេះជាដើម ។

បទនោះ មានសេចក្តីដូច្នេះថា បុគ្គលនោះដល់នូវការរលត់ទៅ បុគ្គលនោះមិនមាន ឬថា បុគ្គលនោះ ជាអ្នកមិនមានអន្តរាយ ជាអ្នកមានការមិនប្រែប្រួលជាធម្មតា ដោយភាពជាអ្នកទៀង ព្រោះជាសស្សតទិដ្ឋិ បពិត្រព្រះអង្គជាមុនី សូមទ្រង់ត្រាស់ព្យាករសេចក្តីនោះ ឲ្យសម្រេចប្រយោជន៍ដល់ខ្ញុំព្រះអង្គចុះ ព្រោះអ្វី ព្រោះថា ធម៌នោះ ទ្រង់ដឹងច្បាស់ហើយពិត ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សំដែងថា ឧបសីវមាណព មិនគួរពោលយ៉ាងនោះ ទើបត្រាស់គាថាថា **អត្ថង្គតស្ស** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **អត្ថង្គតស្ស** បានដល់ ដែលបរិនិព្វាន ព្រោះមិនប្រកាន់មាំ ។ បទថា **ន បមាណមត្ថិ** បានដល់ មិនមានប្រមាណនៃរូបជាដើម ។ បទថា **យេន នំ វជ្ជុ** បានដល់ ជនទាំងឡាយគប្បីពោលបុគ្គលនោះដោយកិលេស មានរាគៈជាដើមណា ។ បទថា **សព្វេសុ ធម្មេសុ** បានដល់ ធម្មក្ខន្ធទាំងពួងជាដើម ។ បទដ៏សេសប្រាកដច្បាស់ហើយ ។ ព្រះមានព្រះភាគទ្រង់សំដែងសូត្រនេះដោយធម៌ដ៏កំពូល គឺអរហត្ត ដោយប្រការដូច្នេះ ។ កាលចប់ទេសនា បុគ្គលត្រាស់ដឹងធម៌ដូចគ្នាតាមន័យដូចពោលហើយនោះឯង ។៤៣។

## អដ្ឋកថាឧបសីវបញ្ហាទី ៦ ចប់

# សុត្តន្តបិដក

## ឆន្នប្បញ្ហាទី៧

[ ១១៨ ] ( នន្ទមាណពដ៏មានអាយុ ទូលសួរថា ) ជនទាំង-ឡាយតែងពោលថា ពួកមុនី រមែងមាននៅក្នុងលោក ដំណើរនោះ តើយ៉ាងណា ជនទាំងនោះ ហៅបុគ្គលដែលប្រកបដោយញាណថា មុនី ឬហៅបុគ្គលដែលប្រកបដោយការចិញ្ចឹមជីវិតថាជាមុនី ។

( ព្រះមានព្រះភាគដោះស្រាយថា ម្នាលនន្ទ ) ពួកជនអ្នកឈ្លាសវៃក្នុងលោកនេះ មិនហៅថា មុនី ព្រោះការឃើញ ព្រោះការស្តាប់ ព្រោះការដឹង ( ឬព្រោះសីល និងវត្ត ) តែប៉ុណ្ណោះទេ ជនទាំងឡាយណា ធ្វើខ្លួនឲ្យប្រាសចាកមារសេនា ជាអ្នកមិនតានតឹង មិនមានសេចក្តីប្រាថ្នា តថាគតហៅជនទាំងនោះថា មុនី ។

( នន្ទមាណពដ៏មានអាយុ ទូលសួរថា ) សមណព្រាហ្មណ៍ពួកខ្លះទាំងនេះ តែងពោលសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ខ្លះ ពោលសេចក្តីបរិសុទ្ធ ព្រោះសីលវត្តខ្លះ ពោលសេចក្តីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ ។ ( បពិត្រព្រះមានព្រះភាគ ) អ្នកនិទ្ទុក្ខ ពួកសមណព្រាហ្មណ៍ទាំងនោះកាលបើប្រព្រឹត្តក្នុងវត្ត ដែលឃើញថាជាគ្រឿងបរិសុទ្ធនោះ តើបានឆ្លងផុតជាតិ និងជរាបានដែរឬ បពិត្រព្រះមានព្រះភាគព្រះអង្គសូមសួរព្រះអង្គ សូមព្រះអង្គសម្តែងប្រាប់សេចក្តីនោះ

ដល់ ខ្ញុំព្រះអង្គ ។

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលនន្ទ ) សមណព្រាហ្មណ៍ទាំងឡាយពួកខ្លះទាំងនេះ ពោលថា សេចក្តីបរិសុទ្ធព្រោះអារម្មណ៍ដែលឃើញ និងអារម្មណ៍ដែលស្តាប់ខ្លះ ពោលថា សេចក្តីបរិសុទ្ធ ព្រោះសីល និងវត្តខ្លះ ពោលថា សេចក្តីបរិសុទ្ធព្រោះវិធីជាច្រើនយ៉ាងខ្លះ សមណព្រាហ្មណ៍ទាំងនោះ រមែងប្រព្រឹត្តក្នុងវត្ត ដែលឃើញថាជាគ្រឿងបរិសុទ្ធនោះ ក៏មែនពិតហើយ ប៉ុន្តែ តថាគតពោលថា សមណព្រាហ្មណ៍ទាំងនោះ មិនបានឆ្លងផុតជាតិ និងជរាបានឡើយ ។

( នន្ទមាណពដ៏មានអាយុ ទូលសួរទៀតថា ) សមណ-ព្រាហ្មណ៍ទាំងឡាយ ពួកខ្លះទាំងនេះពោលថា សេចក្តីបរិសុទ្ធព្រោះអារម្មណ៍ដែលឃើញ និងអារម្មណ៍ដែលស្តាប់ខ្លះ ពោលថា សេចក្តីបរិសុទ្ធ ព្រោះសីល និងវត្តខ្លះ ពោលថា សេចក្តីបរិសុទ្ធព្រោះវិធីជាច្រើនយ៉ាងនេះ បពិត្រព្រះអង្គជាព្រះមុនី បើព្រះអង្គត្រាស់ថា សមណព្រាហ្មណ៍ទាំងនោះ ឆ្លងឱឃៈមិនបានទេ បពិត្រព្រះអង្គនិទ្ទុក្ខ កាលបើដូច្នេះ តើនរណាក្នុងទេវលោក ឬមនុស្ស-លោក ទើបឆ្លងផុតជាតិ និងជរាទៅបាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គសម្តែងប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលនន្ទ ) តថាគត មិនបានពោលថា ពួកសមណព្រាហ្មណ៍ទាំងអស់ ត្រូវជាតិ ជរា គ្របសង្កត់ទេ តថាគតពោលថា ពួកសមណព្រាហ្មណ៍ណាក្នុង លោកនេះ លះអារម្មណ៍ដែលខ្លួនបានឃើញ បានឮ បានប៉ះពាល់ និងសីលវត្ត លះបង់វិធីជាច្រើនទាំងអស់ចេញ ឬពួកសមណ-ព្រាហ្មណ៍ណា កំណត់ដឹងនូវតណ្ហា មិនមានអាសវៈ ពួកជននោះ ឯង ឈ្មោះថា ឆ្លងផុតឱឃៈបាន ។

ខ្ញុំព្រះអង្គត្រេកអរ ចំពោះព្រះវាចាទុំ របស់ព្រះអង្គ អ្នក ស្វែងរកគុណដ៏ធំ បពិត្រព្រះគោតម ព្រះនិព្វានដែលមិនមានឧបធិ ដែលព្រះអង្គបានសម្តែងទុកល្អហើយ ព្រះអង្គពោលថា កាលពួក សមណព្រាហ្មណ៍ណា លះអារម្មណ៍ដែលខ្លួនបានឃើញ បានឮ បានប៉ះពាល់ និងសីលវត្ត លះបង់វិធីជាច្រើនយ៉ាងទាំងអស់ចេញ ឬពួកជនណា កំណត់ដឹងនូវតណ្ហា មិនមានអាសវៈ ទើបតថាគត ពោលថា ជនទាំងនោះ ឆ្លងផុតឱឃៈបាន ។

**នន្ទមាណវកបញ្ហាទី ៧ ចប់**

# អដ្ឋកថា

## ធនុប្បញ្ហាទី ៧

[ ១១៨ ] ក្នុងនទុប្បញ្ហាទី ៧ មានពាក្យផ្ដើមថា **សន្តិ លោកេ** ដូច្នេះ ក្នុងបទទាំងនោះ គប្បីជ្រាបសេចក្ដីគាថាទី ១ ដូចតទៅនេះ ជនទាំងឡាយមានក្សត្រជាដើម រមែងពោលថា មុនីមាននៅក្នុងលោក សំដៅដល់អាជីវកនិងនិគ្រន្ថជាដើម ។ បទថា **ញាណូបបន្នំ** សេចក្ដីថា ជនទាំងឡាយពោលបុគ្គលដែលប្រកបដោយញាណ ព្រោះញាណ មានសមាបត្តិញ្ញាណជាដើមកើតឡើង ឬជាអ្នកប្រកបដោយការប្រព្រឹត្តទៅ ពោល គឺការប្រព្រឹត្តទៅដែលសៅហ្មង មានប្រការផ្សេងៗ ថាជាមុនី ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់បដិសេធទាំង ២ យ៉ាងហើយទ្រង់សម្ដែងបុគ្គលជាមុនីដល់នទុមាណពនោះ ទើបត្រាស់គាថាថា **ន ទិដ្ឋិយា** ដូច្នេះជាដើម ។

ឥឡូវនេះ នទុមាណពទូលសួរថា **យេ កេចិមេ** ជាដើម ដើម្បីលះសេចក្ដីសង្ស័យនៃជនទាំងឡាយដែលពោលថា សេចក្ដីបរិសុទ្ធ រមែងមានដោយការឃើញជាដើម ។

ក្នុងបទទាំងនោះ បទថា **អនេកររូបេន** បានដល់ ដោយមង្គលភ្ញាក់ផ្អើលជាដើម ។ បទថា **តត្ថ យថា ចរន្តា** សេចក្ដីថា ដែលសក្កាយទិដ្ឋិគ្រប់គ្រង ។

គ្រានោះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងការមិនមានសេចក្ដីបរិសុទ្ធ

យ៉ាងនោះដល់នន្ទមាណព ទើបត្រាស់គាថាទី ២ ។

នន្ទមាណពបានស្ដាប់ថា សមណព្រាហ្មណ៍ទាំងនោះឆ្លងផុតជាតិ និង ជរាមិនបាន ឥឡូវនេះ បំណងនឹងជ្រាបបុគ្គលដែលឆ្លងផុតបាន ទើបទូលសួរ ថា **យេ កេចិមេ** ដូច្នេះជាដើម ។ លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ សម្ដែងដល់បុគ្គលដែលឆ្លងផុតជាតិ ជរា ដោយបំណងដល់បុគ្គលដែលឆ្លង ផុតឱឃៈ ដល់នន្ទមាណពនោះ ទើបត្រាស់គាថាទី ២ ។

ក្នុងបទទាំងនោះ បទថា **ឆិវុតា** បានដល់ ដែលជាតិ ជរា ចោមរោម ហើយ រួបរឹតហើយ ។ បទថា **យេសីធ** កាត់បទជា **យេ សុ ឥធ** ប្រែថា បុគ្គលពួកណាក្នុងលោកនេះ ។ បទថា **សុ** ក្នុងបទនេះ ត្រឹមតែជានិបាត ។ បទថា **តណ្ហំ បរិញ្ញាយ** បានដល់ កំណត់ដឹងតណ្ហាដោយបរិញ្ញា ៣ ។ បទ ដ៏សេសក្នុងបទទាំងពួងជាក់ច្បាស់ហើយ ព្រោះមានន័យដូចពោលហើយក្នុង ខាងដើមនោះឯង ។ ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនាដោយកំពូលនៃធម៌ គឺអរហត្តដូចគ្នា ដោយប្រការដូច្នេះ ។

ឯនន្ទមាណព កាលចប់ទេសនា សរសើរភាសិតរបស់ព្រះមានព្រះភាគ ថា **ឯតាភិនន្ទាមិ** ដូច្នេះជាដើម ។ ក្នុងសូត្រនេះ បុគ្គលសម្រេចធម៌ដូចគ្នា តាមដែលពោលហើយ ក្នុងសូត្រមុននោះឯង ។៚

**អដ្ឋកថានន្ទបុញ្ញាទី ៧ ចប់**

# សុត្តន្តបិដក

## ហេមកប្បញ្ហាទី៨

[ ១១៩ ] ( ហេមកមាណពដ៏មានអាយុ ទូលសួរថា ) ក្នុងកាលពីដើម មុនសាសនានៃព្រះគោតម អាចារ្យទាំងឡាយ បានពោលយ៉ាងជាក់ច្បាស់ថា ពាក្យនោះ ធ្លាប់មានមកហើយយ៉ាងនេះ ពាក្យនោះ នឹងមានតទៅ ពាក្យទាំងអស់នោះ ជាពាក្យមិនជាក់ច្បាស់ ពាក្យទាំងអស់នោះ ជាគ្រឿងចម្រើននៃសេចក្តីត្រិះរិះ ( ខ្ញុំព្រះអង្គមិនទាន់ពេញចិត្តក្នុងពាក្យនោះឡើយ ) បពិត្រព្រះអង្គជាព្រះមុនី សូមព្រះអង្គសម្តែងធម៌ សម្រាប់ដកចេញនូវតណ្ហា ដែលនាំឲ្យខ្ញុំព្រះអង្គដឹងច្បាស់ មានសតិ ឆ្លងតណ្ហាដែលផ្សាយទៅផ្សេងៗ ដល់ខ្ញុំព្រះអង្គ ។

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ) ម្នាលហេមកៈ ជនទាំងឡាយណា ដឹងច្បាស់នូវព្រះនិព្វាន ជាទីបន្ទោបង់នូវឆន្ទ-រាគ ជាគុណជាតមិនច្យុត ដែលបានឃើញ បានស្តាប់ បានប៉ះពាល់ហើយ ចំពោះរូបជាទីស្រឡាញ់ ( ដែលគេដឹងច្បាស់ហើយ ) ជាអ្នកមានសតិ រលត់កិលេស ក្នុងបច្ចុប្បន្នហើយ ជនអ្នកមានសតិស្ងប់កិលេសទាំងនោះ ឈ្មោះថា ឆ្លងតណ្ហា ដែលផ្សាយទៅផ្សេងៗ ក្នុងលោកបានហើយ ។

ហេមកមាណវកប្បញ្ហាទី ៨ ចប់

# អដ្ឋកថា

## ហេមកប្បញ្ហាទី៨

[ ១១៩ ] ក្នុងហេមកប្បញ្ហាទី ៨ មានពាក្យផ្តើមថា **យេ មេ បុព្វេ** ដូច្នេះ ក្នុងបទទាំងនោះ បទថា **យេ មេ បុព្វេ វិយាកំសុ** សេចក្តីថា អាចារ្យពួកណា មានពាវរីព្រាហ្មណ៍ជាដើម បានព្យាករលទ្ធិរបស់ខ្លួនដល់ខ្ញុំព្រះអង្គក្នុងកាលមុន ។ បទថា **ហុរំ គោតមសាសនា** គឺមុនសាសនារបស់ព្រះគោតម ។ បទថា **សព្វន្តំ តក្កវឌ្ឍនំ** សេចក្តីថា ពាក្យព្យាករទាំងអស់ជាគ្រឿងធ្វើនូវការត្រិះរិះ មានការត្រិះរិះដល់កាមជាដើមឲ្យច្រើនឡើង ។ បទថា **តណ្ហានិគ្ឃាតនំ** បានដល់ ធ្វើតណ្ហាឲ្យវិនាស ។

លំដាប់នោះ ព្រះមានព្រះភាគ កាលត្រាស់ប្រាប់ធម៌នោះដល់ហេមកមាណព ទើបត្រាស់គាថា ២ ថា **ឥធ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ឯតទញ្ញាយ យេ សតា** សេចក្តីថា ជនពួកណា ដឹងច្បាស់ដល់បទ គឺព្រះនិព្វានដែលមិនស្លាប់នោះ ដោយន័យជាដើមថា សង្ខារទាំងឡាយមិនទៀង ដឹងដោយលំដាប់ ជាអ្នកមានសតិដោយសតិក្នុងកាយានុបស្សនាជាដើម ។ បទថា **ទិដ្ឋធម្មាភិនិព្វុតា** បានដល់ ឃើញធម៌ ព្រោះដឹងច្បាស់នូវធម៌ និងរម្ងាប់កិលេស ព្រោះរម្ងាប់កិលេស មានរាគៈជាដើម ។ បទដ៏សេស ក្នុងបទទាំងពួងជាក់ច្បាស់ហើយ ។ ព្រះមានព្រះភាគទ្រង់សម្តែងសូត្រនេះ ដោយកំពូលនៃធម៌ គឺអរហត្តដូចគ្នា ។ កាលចប់ទេសនា សត្វដែលសម្រេចធម៌ដូចគ្នា តាមដែលពោលមកហើយក្នុងសូត្រមុននោះឯង ។ល។

# សុត្តន្តបិដក

## តោទេយ្យបញ្ហាទី៩

[ ១២០ ] ( តោទេយ្យមាណពដ៏មានអាយុ ទូលសួរថា ) កាមារម្មណ៍ទាំងឡាយ មិនមាននៅក្នុងបុគ្គលណា តណ្ហារបស់បុគ្គលណាមិនមាន ទាំងបុគ្គលណា ឆ្លងសេចក្តីសង្ស័យបាន វិមោក្ខធម៌ ( ការរួចផុត ) របស់បុគ្គលនោះ តើដូចម្តេច ។

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលតោទេយ្យ ) កាមារម្មណ៍ទាំងឡាយ មិនមាននៅក្នុងបុគ្គលណា តណ្ហារបស់បុគ្គលណាមិនមាន ទាំងបុគ្គលណា ឆ្លងសេចក្តីសង្ស័យបាន វិមោក្ខធម៌របស់បុគ្គលនោះ មិនមែនទៅជាយ៉ាងដទៃទេ ។

( បុគ្គលនោះ នឹងត្រូវព្យាយាម ដើម្បីធ្វើខ្លួនឲ្យរួចផុតទៅក្រៅអំពីនេះទៀតមិនមានទេ ) បុគ្គលនោះ ជាអ្នកប្រាសចាកសេចក្តីប្រាថ្នា ឬនៅប្រកបដោយសេចក្តីប្រាថ្នា ជាបុគ្គលមានប្រាជ្ញា ឬជាអ្នកគ្រាន់តែកំណត់ថាមានបញ្ញា បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គគប្បីស្គាល់បាននូវមុនី ដោយប្រការដូចម្តេច បពិត្រព្រះអង្គមានបញ្ញាចក្ខុ ឃើញធម៌ដោយជុំវិញ សូមព្រះអង្គត្រាស់ប្រាប់នូវមុនីនោះ ដល់ខ្ញុំព្រះអង្គ ។

( ព្រះអង្គទ្រង់ដោះស្រាយថា ) បុគ្គលនោះ ប្រាសចាកសេចក្តីប្រាថ្នា ទាំងជាអ្នកប្រកបដោយសេចក្តីប្រាថ្នាក៏ទេ ជាអ្នកមានបញ្ញា ទាំងជាអ្នកគ្រាន់តែកំណត់ថាមានបញ្ញាក៏ទេ ម្នាល

តោទេយ្យ អ្នកចូរដឹងបុគ្គលនោះ ថាជាមុនី ជាអ្នកមិនមាន កង្វល់ មិនជាប់នៅក្នុងកាមភព យ៉ាងនេះចុះ ។

តោទេយ្យមាណវកបញ្ហាទី ៩ ចប់

# អដ្ឋកថា

## តោទេយ្យបញ្ហាទី៨

[ ១២០ ] ក្នុងតោទេយ្យបញ្ហាទី ៩ មានពាក្យផ្ដើមថា **យស្មឹ កាមា** ដូច្នេះជាដើម ក្នុងបទទាំងនោះ បទថា **វិមោក្ខោ តស្ស កីទិសោ** សេចក្ដីថា តោទេយ្យមាណពទូលសួរថា ការផុតវិសេសដែលបុគ្គលនោះគប្បីប្រាថ្នាដូចម្ដេច ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងការមិនមាន ការរួចផុតដល់តោទេយ្យមាណពនោះ ទើបត្រាស់គាថាទី ២ ។ ក្នុងបទទាំងនោះ បទថា **វិមោក្ខោ តស្ស នាបរោ** បានដល់ កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ការផុតដទៃរបស់បុគ្គលនោះមិនមាន ការអស់តណ្ហាយ៉ាងនេះ ការផុតវិសេសយ៉ាងនេះ តោទេយ្យមាណពក៏នៅតែមិនយល់សេចក្ដីនោះបានល្អ

ទើបទូលសួរទៀតថា **និរាសសោ សោ ឧទ អាសសានោ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ឧទ បញ្ញកប្បី** សេចក្តីថា នៅកំណត់ដោយតណ្ហា និងទិដ្ឋិ ដោយញាណ មានសមាបត្តិញាណជាដើម ។

លំដាប់នោះ ព្រះមានព្រះភាគ កាលត្រាស់ប្រាប់សេចក្តីនោះ ដល់តោទេយ្យមាណព ទើបត្រាស់គាថាទី ២ ។ ក្នុងបទទាំងនោះ បទថា **កាមភវេ** បានដល់ ក្នុងកាម និងក្នុងភព ។ បទដ៏សេស ក្នុងបទទាំងពួងប្រាកដច្បាស់ហើយ ។ ព្រះមានព្រះភាគទ្រង់សម្តែងសូត្រនេះដោយកំពូលនៃធម៌ គឺអរហត្តដូចគ្នា ដោយប្រការដូច្នេះ ។ កាលចប់ទេសនា បុគ្គលដែលបានសម្រេចធម៌ដូចគ្នា ក្នុងសូត្រមុននោះឯង ។៚

**អដ្ឋកថាតោទេយ្យប្បញ្ហាទី ៩ ចប់**

# សុត្តន្តបិដក

## កប្បប្បញ្ហាទី ១០

[ ១២១ ] ( កប្បមាណពដ៏មានអាយុ ទូលសួរថា ) ពួកសត្វឋិតនៅក្នុងកណ្តាលនៃសង្សារវដ្ត ត្រូវជរា និងមច្ចុគ្របសង្កត់ ក្នុងកាលដែលឱឃៈជាភ័យធំ កើតឡើងហើយ បពិត្រព្រះអង្គនិទ៌ុក្ខ សូមព្រះអង្គត្រាស់ប្រាប់នូវទីពឹង ឲ្យទាន សេចក្តីទុក្ខក្នុងសង្សារវដ្តនេះ មិនគប្បីមានតទៅទៀត ដោយប្រការណា សូមព្រះអង្គត្រាស់ប្រាប់នូវទីពឹង ដល់ខ្ញុំព្រះអង្គ ( ដើម្បីវៀរចាកទុក្ខ ) ដោយប្រការនោះ ។

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលកប្បៈ ) ពួកសត្វឋិតនៅក្នុងកណ្តាលនៃសង្សារវដ្ត ត្រូវជរា និងមច្ចុគ្របសង្កត់ ក្នុងកាលដែលឱឃៈជាភ័យធំកើតឡើង ម្នាលកប្បៈ តថាគតនឹងសម្តែងប្រាប់ នូវទីពឹងដល់អ្នក ។ ការមិនកង្វល់ ( ដោយកិលេស ) ការមិនប្រកាន់មាំនុំះឯង ឈ្មោះថា ជាទីពឹងពំនាក់ មិនមានទីពឹងដទៃលើសជាងទេ តថាគតហៅទីពឹងនោះថា ព្រះនិព្វាន ជាទីក្ស័យនៃជរា និងមច្ចុ ។ ជនទាំងឡាយណា ដឹងច្បាស់នូវព្រះនិព្វាននោះ ជាអ្នកមានសតិ រម្ងត់ទុក្ខក្នុងបច្ចុប្បន្ននេះ ជនទាំងនោះ ជាអ្នកមិនលុះអំណាចនៃមារ ជនទាំងនោះ មិនដល់នូវភាព ជាអ្នកបម្រើនៃមារឡើយ ។

កប្បមាណវកប្បញ្ហាទី ១០ ចប់

# អដ្ឋកថា

## កប្បប្បញ្ហាទី ១០

[ ១២១ ] ក្នុងកប្បប្បញ្ហាទី ១០ មានពាក្យផ្ដើមថា **មជ្ឈេ សរស្មឹ** ដូច្នេះជាដើម ក្នុងបទទាំងនោះ បទថា **មជ្ឈេ សរស្មឹ** លោកអធិប្បាយថា ក្នុងសាគរដែលជាកណ្ដាល ព្រោះខាងដើម និងខាងចុងមិនប្រាកដ ។ បទថា **តិដ្ឋតំ** បានដល់ តាំងនៅ ។ បទថា **យថាយិទំ នាបរំ សិយា** បានដល់ ដោយប្រការដែលទុក្ខនេះមិនគប្បីមានទៀត ។

សម័យនោះ ព្រះមានព្រះភាគ កាលទ្រង់ព្យាករសេចក្ដីនោះដល់កប្ប-មាណពនោះ ទើបត្រាស់ ៣ គាថា ។

ក្នុងបទទាំងនោះ បទថា **អកិញ្ចនំ** បានដល់ ផុយគ្មានទីងគ្រឿងកង្វល់ ។ បទថា **អនាទានំ** បានដល់ ផុយគ្មានទីងការប្រកាន់មាំ លោកអធិប្បាយថា ចូលទៅស្ងប់សេចក្ដីកង្វល់ និងការប្រកាន់មាំ ។ បទថា **អនាបរំ** បានដល់ វៀរចាកទីពឹងដែលមិនជាសត្រូវដទៃទៀត លោកអធិប្បាយថា ជាទីពឹងប្រសើរបំផុត ។ បទថា **ន តេ មារស្ស បទ្ធគូ** បានដល់ ជនទាំងនោះមិនដើរទៅក្នុងផ្លូវរបស់មារ គឺមិនជាសិស្សចាំបម្រើមារ ។ បទដ៏សេស ក្នុងបទទាំងពួងជាក់ច្បាស់ហើយ ។ ព្រះមានព្រះភាគ ទ្រង់សម្ដែងសូត្រនេះដោយធម៌ជាកំពូល គឺអរហត្ត ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត កាលចប់ទេសនា បុគ្គលសម្រេចធម៌ ដូចគ្នានឹងសូត្រមុននោះឯង ។ល។

**អដ្ឋកថាកប្បប្បញ្ហាទី ១០ ចប់**

# សុត្តន្តបិដក

## ជតុកណ្ណីបញ្ហាទី ១១

[ ១២២ ] ( ជតុកណ្ណីមាណពដ៏មានអាយុ ទូលសួរថា ) បពិត្រព្រះអង្គជាវីរបុរស ខ្ញុំព្រះអង្គបានឮថា ព្រះអង្គមិនមានសេចក្តីប្រាថ្នាក្នុងកាម ធ្លងអន្លង់ គឺកិលេសបានហើយ ទើបមកដើម្បីទូលសួរព្រះអង្គ អ្នកមិនមានសេចក្តីប្រាថ្នា បពិត្រព្រះមានព្រះភាគ ព្រះអង្គមានដួងព្រះនេត្រ ឃើញនូវធម្មតាលោក ដែលកើតឡើងព្រម សូមព្រះអង្គសំដែងនូវសន្តិបទ គឺធម៌ស្ងប់ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសំដែងនូវសន្តិបទនុ៎ះ តាមសេចក្តីពិតដល់ខ្ញុំព្រះអង្គ ឲ្យទាន ។ ព្រោះថា ព្រះមានព្រះភាគ តែងប្រព្រឹត្តគ្របសង្កត់នូវកាម ( ដូចព្រះអាទិត្យមានតេជះ គឺរស្មីគ្របសង្កត់នូវប្រឹថពីមណ្ឌល ដោយតេជះ ដូច្នោះ ) បពិត្រព្រះអង្គ មានព្រះបញ្ញាធំទូលាយ ដូចផ្ទៃផែនដី សូមព្រះអង្គត្រាស់ប្រាប់នូវធម៌ ដែលខ្ញុំព្រះអង្គគួរដឹង ជាធម៌សម្រាប់លះជាតិនិងជរា ក្នុងអត្តភាពនេះ ដល់ខ្ញុំព្រះអង្គ ជាអ្នកមានបញ្ញាស្តួចស្តើង ឲ្យទាន ។

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលជតុកណ្ណិ ) អ្នកចូរកម្ចាត់បង់ នូវតម្រេកក្នុងកាមទាំងឡាយចេញ ចូរឃើញនូវនេក្ខម្មៈ ដោយសេចក្តីក្សេមក្សាន្ត កិលេសជាតគ្រឿងខ្វល់ ដែលអ្នកប្រកាន់មាំ ( ដោយតណ្ហា និងទិដ្ឋិ ) ឬដែលគួរលះបង់

កុំមានដល់អ្នកឡើយ គ្រឿងខ្វល់ណា ដែលមានហើយក្នុងកាល មុន អ្នកចូរឲ្យគ្រឿងខ្វល់នោះរីងស្ងួតចុះ គ្រឿងខ្វល់មានក្នុងខាង ក្រោយ កុំមានដល់អ្នកឡើយ បើអ្នកមិនកាន់យក នូវគ្រឿងខ្វល់ ក្នុងកណ្តាល អ្នកនឹងជាមនុស្សស្ងប់គ្រឿងខ្វល់បាន ។ ម្នាល ព្រាហ្មណ៍ បុគ្គលតែងលុះក្នុងអំណាចនៃមច្ចុ ដោយអាសវៈទាំង-ឡាយណា អាសវៈទាំងនោះ រមែងមិនមានដល់បុគ្គលដែល ប្រាសចាកតម្រេក ក្នុងនាមរូបដោយសព្វគ្រប់ ។

ជតុកណ្ណីមាណវកបញ្ហាទី ១១ ចប់

# អដ្ឋកថា

## ជតុកណ្ណីបញ្ហាទី ១១

[ ១២២ ] ក្នុងជតុកណ្ណីបញ្ហាទី ១១ មានពាក្យផ្តើមថា **សុត្វានហំ** ដូច្នេះជាដើម ក្នុងបទទាំងនោះ បទថា **សុត្វានហំ វីរំ វីរមកាមកាមី** សេចក្តីថា ខ្ញុំព្រះអង្គបានស្តាប់មកថា ព្រះពុទ្ធ ឈ្មោះថា ជាវីរៈ គឺបុគ្គលមិន គួរប្រាថ្នាកាម ព្រោះមិនប្រាថ្នាកាមទាំងឡាយ ដោយន័យជាដើមថា **ឥតិបិ សោ ភគវា** ដូច្នេះ ។ បទថា **អកាមមាគមំ** សេចក្តីថា ខ្ញុំព្រះអង្គមក ដើម្បីទូលសួរព្រះមានព្រះភាគ ដែលជាអ្នកមិនមានកាម ។ បទថា **សហាជ-នេត្ត** បានដល់ ជាអ្នកមានព្រះនេត្រ គឺសព្វញ្ញុតញ្ញាណកើតឡើងព្រមហើយ ។

បទថា **យថាតច្ឆំ** បានដល់ តាមសេចក្ដីពិត ។ បទថា **ព្រូហិ មេ** សេចក្ដីថា ជតុកណ្ណីមាណពពោលអារាធនាទៀត ។ ព្រោះថា កាលអារាធនា ទោះពោលដល់មួយពាន់ដងក៏បាន ។ រឿងអ្វីពោលត្រឹមតែ ២ ដងនោះ ។ បទថា **តេជី តេជសា** សេចក្ដីថា ព្រះមានព្រះភាគជាអ្នកមានតេជះ ទ្រង់គ្របសង្កត់ដោយតេជះ ។ បទថា **យមហំ វិជញ្ញំ ជាតិជរាយ ឥធ វិប្បហានំ** សេចក្ដីថា ខ្ញុំព្រះអង្គគប្បីដឹងធម៌ ដែលជាហេតុលះជាតិ ជរា ក្នុងទីនេះ ។

លំដាប់នោះ ព្រះមានព្រះភាគ កាលត្រាស់ប្រាប់នូវធម៌ដល់ជតុកណ្ណីមាណពនោះ ទើបត្រាស់ ៣ គាថា ។

ក្នុងបទទាំងនោះ បទថា **នេក្ខម្មំ ទដ្ឋុ ខេមតោ** បានដល់ ឃើញនិព្វាន និងកិច្ចបដិបត្តិដើម្បីដល់និព្វាន ថាជាធម៌ក្សេម ។ បទថា **ឧគ្គហិតំ** បានដល់ ប្រកាន់ដោយតណ្ហា និងទិដ្ឋិ ។ បទថា **និរត្តំ វា** បានដល់ គួរដោះចេញ លោកអធិប្បាយថា គួរលះបង់ ។ បទថា **មា តេ វិជ្ជិត្ថ** បានដល់ កុំបីមានដល់អ្នក ។ បទថា **កិញ្ចនំ** បានដល់ គ្រឿងកង្វល់ មានរាគៈជាដើម កុំបីមានដល់អ្នក ។ បទថា **បុព្វេ** បានដល់ កិលេសដែលកើតឡើង ប្រារព្ធសង្ខារក្នុងអតីត ។ បទថា **ព្រាហ្មណ** សេចក្ដីថា ព្រះមានព្រះភាគត្រាស់ហៅជតុកណ្ណីមាណព ។ បទដ៏សេស ក្នុងបទទាំងពួងជាក់ច្បាស់ហើយ ។ ព្រះដ៏មានព្រះភាគទ្រង់សម្ដែងសូត្រនេះដោយកំពូលនៃធម៌ គឺអរហត្តដូចគ្នា ដោយប្រការដូច្នេះ កាលចប់ទេសនា បុគ្គលដែលបានសម្រេចធម៌ ដូចគ្នានឹងសូត្រមុននោះឯង ។៚

# សុត្តន្តបិដក

## កប្បមាណវប្បញ្ហាទី ១២

[ ១២៣ ] ( កទ្រាវុធមាណពដ៏មានអាយុ ទូលសួរថា ) ខ្ញុំព្រះអង្គ សូមអារាធនាព្រះអង្គ អ្នកលះអាល័យ កាត់តណ្ហា មិនរំភើប ( ព្រោះលោកធម៌ ) លះសេចក្តីត្រេកអរ ឆ្លងអន្លង់ហើយ រួចផុតស្រឡះហើយ លះធម៌គ្រឿងកំណត់ ( ដោយតណ្ហា និងទិដ្ឋិ ) ព្រះអង្គមានព្រះប្រាជ្ញាញាណ បពិត្រព្រះអង្គជាវីរបុរស ពួកជនអ្នកនៅក្នុងជនបទផ្សេងៗ ចង់ស្តាប់ព្រះវាចា របស់ព្រះអង្គ បានមកព្រមគ្នាហើយ អំពីជនបទនោះៗ បើបានស្តាប់ព្រះវាចា របស់ព្រះអង្គហើយ នឹងត្រឡប់អំពីទីនេះវិញ សូមព្រះអង្គទ្រង់ដោះស្រាយបញ្ហា ដើម្បីជនទាំងអម្បាលនោះ ព្រោះធម៌នោះ ព្រះអង្គបានជ្រាបហើយ ។

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលកទ្រាវុធ ) បុគ្គលគួរកម្ចាត់បង់នូវតណ្ហា ជាគ្រឿងប្រកាន់មាំ ក្នុងចំណែកខាងលើ ក្នុងចំណែកខាងក្រោម និងក្នុងចំណែកទទឹង គឺត្រង់កណ្តាលឲ្យអស់ទៅ ព្រោះថា ជនទាំងអម្បាលនោះ ប្រកាន់មាំនូវរបស់ណាៗ ក្នុងលោក មាររមែងជាប់តាមសត្វ ដោយរបស់នោះៗ វិញដែរ ហេតុនោះ ភិក្ខុកាលដឹង ឃើញនូវពួកសត្វ អ្នកជាប់នៅក្នុងអារម្មណ៍ផ្សេងៗ ជាទីតាំងនៃមច្ចុមារនេះថា សត្វជាប់នៅព្រោះ

សេចក្តីប្រកាន់មាំដូច្នេះ គប្បីជាអ្នកមានសតិ មិនប្រកាន់មាំនូវគ្រឿងខ្វល់ ក្នុងលោកទាំងពួង ។

កប្បមាណវកបញ្ហាទី ១២ ចប់

# អដ្ឋកថា

## កប្បមាណវកបញ្ហាទី ១២

[ ១២៣ ] ក្នុងកប្បមាណវកបញ្ហាទី ១២ មានពាក្យផ្តើមថា **ឱកញ្ជហំ** ដូច្នេះ ក្នុងបទទាំងនោះ បទថា **ឱកញ្ជហំ** បានដល់ ទ្រង់លះនូវការជាប់ជំពាក់ ។ បទថា **តណ្ហច្ឆិទំ** សេចក្តីថា ទ្រង់កាត់នូវពួកតណ្ហាទាំង ៦ ។ បទថា **អនេជំ** បានដល់ មិនមានការចង់បានក្នុងលោកធម៌ទាំងឡាយ ។ បទថា **នន្ទិញ្ជហំ** សេចក្តីថា លះនូវសេចក្តីប្រាថ្នា មានរូបក្នុងអនាគតជាដើម ។ ពិតហើយក្នុងទីនេះ កប្បមាណពពោលដល់តណ្ហាតែម្យ៉ាងប៉ុណ្ណោះ ដោយប្រការផ្សេងៗ ដើម្បីសរសើរព្រះមានព្រះភាគនោះឯង ។ បទថា **កប្បជ្ជហំ** សេចក្តីថា ជាអ្នកលះកិលេសជាគ្រឿងកំណត់ ២ យ៉ាង ។ បទថា **អភិយាចេ** សេចក្តីថា ខ្ញុំព្រះអង្គទូលអារាធនាយ៉ាងក្រៃលែង ។ បទថា **សុត្វាន នាគស្ស អបនមិស្សន្តិ ឥតោ** អធិប្បាយថា បពិត្រព្រះមានព្រះភាគ ជនទាំងឡាយជាច្រើនបានស្តាប់នូវព្រះតម្រាស់របស់ទ្រង់ ដែលជាបុគ្គលប្រសើរហើយ នឹង

ចៀសចេញទៅអំពីបាសាណកចេតិយនេះ ។ បទថា **ជនបទេហិ សង្គតា** បានដល់ មកព្រមគ្នាក្នុងទីនេះ ចាកជនបទទាំងឡាយ មានជនបទឈ្មោះអង្គៈជាដើម ។ បទថា **វិយាករោហិ** សេចក្ដីថា សូមទ្រង់សម្ដែងធម៌ ។

គ្រានោះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងធម៌ ដោយអនុលោមតាមអធ្យាស្រ័យរបស់កទ្រាវុធមាណពនោះ ទើបត្រាស់ ២ គាថា ។

ក្នុងបទទាំងនោះ បទថា **អាទានតណ្ហំ** បានដល់ តណ្ហាជាគ្រឿងប្រកាន់មាំ មានការកាន់យកអារម្មណ៍ មានរូបជាដើម អធិប្បាយថា ប្រកាន់មាំដោយអំណាចតណ្ហា ។ បទថា **យំ យញ្ហិ លោកស្មឹ ឧបាទិយន្តិ** បានដល់ប្រកាន់មាំវត្ថុណាមួយ ក្នុងប្រភេទនៃធម៌ មានខន្ធជាដើមនោះ ។ បទថា **តេនេវ មារោ អន្វេតិ ជន្តុំ** សេចក្ដីថា មារ គឺខន្ធមារ ដែលមានក្នុងបដិសន្ធិ រមែងជាប់តាមសត្វនោះ ដោយអំណាចកម្មាភិសង្ខារ ដែលកើតឡើងព្រោះឧបាទានជាបច្ច័យនោះឯង ។ បទថា **តស្មា បជានំ** សេចក្ដីថា កាលដឹងទោសយ៉ាងនេះក្នុងសង្ខារ ដោយភាពជារបស់មិនទៀងជាដើម ។ បទថា **អាទានសត្តេ ឥតិ បេក្ខមានោ បជំ ឥមំ មច្ចុធេយ្យេ វិសត្តំ** សេចក្ដីថា ភិក្ខុសម្លឹងឃើញពួកសត្វដែលជាប់ហើយ ក្នុងអន្ទាក់នៃមារ ក្នុងលោកទាំង

ពួង ថាជាពួកសត្វដែលជាប់ជំពាក់ហើយ ក្នុងរូបជាដើម ដែលជាគ្រឿងប្រកាន់ ព្រោះអត្ថថា គប្បីប្រកាន់មាំ ឬសម្លឹងឃើញពួកសត្វដែលជាប់ជំពាក់ហើយ ក្នុងអន្ទាក់នៃមារថា មិនអាចនឹងសង្គ្រោះនូវការប្រកាន់មាំក្នុងបុគ្គលដែលប្រកាន់មាំ ដែលជាប់ហើយ ព្រោះការប្រកាន់មាំ និងដើម្បីឈានកន្លងចាកពួកសត្វដែលជាប់ជំពាក់ក្នុងអន្ទាក់មារនេះបាន មិនប្រកាន់មាំនូវគ្រឿងកង្វល់ក្នុងលោកទាំងពួង ។ បទដ៏សេស ក្នុងបទទាំងពួងជាក់ច្បាស់ហើយ ព្រះមានព្រះភាគ ទ្រង់សម្តែងសូត្រនេះដោយកំពូល គឺអរហត្តនោះឯង ដោយប្រការដូច្នេះ កាលចប់ទេសនា បុគ្គលសម្រេចធម៌ ដូចគ្នានឹងសូត្រមុននោះឯង ។ ៚

**អដ្ឋកថាភទ្រាវុធបញ្ហាទី ១២ ចប់**

# សុត្តន្តបិដក

## ឧទយប្បញ្ហាទី ១៣

[ ១២៤ ] ( ឧទយមាណពដ៏មានអាយុ ទូលសួរថា ) ខ្ញុំព្រះអង្គ ជាអ្នកត្រូវការដោយបញ្ហា ទើបមកគាល់ ( ដើម្បីសួរ ) ព្រះអង្គជាអ្នកបំពេញឈាន មានព្រះសន្តានប្រាសចាកធូលី គឺកិលេស មិនមានអាសវៈ បានទ្រង់ធ្វើកិច្ច ដែលគួរធ្វើស្រេចហើយ ដល់នូវត្រើយនៃធម៌ទាំងពួង សូមព្រះអង្គទ្រង់សម្តែងនូវវិមោក្ខធម៌ គឺព្រះអរហត្ត ជាគ្រឿងទម្លាយអវិជ្ជាចេញបាន ។

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលឧទយៈ ) តថាគតពោលនូវការលះ នូវកាមច្ឆន្ទៈ និងទោមនស្សទាំងពីរយ៉ាងផង ការបន្ទោបង់នូវសេចក្តីរួញរាផង ការឃាត់បង់នូវកុក្កុច្ចៈផង មានឧបេក្ខា និងសតិដ៏បរិសុទ្ធ មានសេចក្តីត្រិះរិះក្នុងធម៌ជាប្រធានថា ជាវិមោក្ខធម៌ គឺព្រះអរហត្ត ជាគ្រឿងទម្លាយនូវអវិជ្ជាចេញបាន ។

សត្វលោកមានអ្វីជាគ្រឿងចងទុក អ្វីជាគ្រឿងសញ្ចរទៅនៃសត្វលោកនោះ លោកពោលថា និព្វានៗ ដូច្នេះ តើព្រោះលះអ្វីបាន ។

សត្វលោក មានសេចក្តីត្រេកត្រអាល ជាគ្រឿងចងទុក មានសេចក្តីគិតសញ្ជឹង ជាគ្រឿងសញ្ចរទៅ នៃសត្វលោកនោះ ដែលលោកពោលថា និព្វាន ព្រោះលះតណ្ហាចេញបាន ។

កាលបុគ្គលមានសតិ ត្រាច់ទៅដូចម្តេច វិញ្ញាណទើបរលត់ យើងខ្ញុំមកគាល់ ដើម្បីនឹងទូលសួរព្រះអង្គ នឹងបានស្តាប់ព្រះវាចារបស់ព្រះអង្គ ។

កាលបុគ្គលមិនត្រេកត្រអាល ចំពោះវេទនាទាំងខាងក្នុង ទាំងខាងក្រៅ មានសតិត្រាច់ទៅយ៉ាងនេះ វិញ្ញាណទើបរលត់ទៅ ។

ឧទយមាណវកប្បញ្ហាទី ១៣ ចប់

# អដ្ឋកថា

## ឧទយប្បញ្ហាទី ១៣

[ ១២៤ ] ក្នុងឧទយប្បញ្ហាទី ១៣ មានពាក្យផ្តើមថា **ឈាយឹ** ដូច្នេះ ក្នុងបទទាំងនោះ បទថា **អញ្ញាំ វិមោក្ខំ** សេចក្តីថា ឧទយមាណពទូលសួរដល់វិមោក្ខដែលសម្រេចដោយអានុភាពនៃបញ្ញា ។

លំដាប់នោះ ព្រោះឧទយមាណពជាអ្នកបានឈានទី ៤ ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងអញ្ញាវិមោក្ខ គឺធម៌ជាគ្រឿងរួចផុត ដែលគួរដឹង ដោយប្រការផ្សេងៗ ដោយអំណាចឈាន ដែលឧទយមាណពបានហើយ ទើបត្រាស់ ២ គាថា ។

ក្នុងបទទាំងនោះ បទថា **បហានំ កាមច្ឆន្ទានំ** សេចក្តីថា តថាគត

ពោលធម៌ជាគ្រឿងលះនូវសេចក្ដីពេញចិត្តក្នុងកាមរបស់បុគ្គល ដែលញ៉ាំង បឋមជ្ឈានឲ្យកើតថា ជាអញ្ញាវិមោក្ខ ។ គប្បីប្រកបបទទាំងពួងយ៉ាងនេះ ។ បទថា **ឧបេក្ខាសតិសំសុទ្ធំ** បានដល់ បរិសុទ្ធល្អដោយឧបេក្ខា និងសតិ ក្នុងឈានទី ៤ ។ បទថា **ធម្មតក្កបុរេជវំ** សេចក្ដីថា ភិក្ខុតាំងនៅក្នុងចតុត្ថជ្ឈានវិមោក្ខនោះ ឃើញច្បាស់នូវអង្គឈានហើយ រមែងពោលដល់អរហត្តវិមោក្ខដែលខ្លួនសម្រេចហើយ ។ ពិតហើយ ការត្រិះរិះដល់ធម៌ មានសម្មាសង្កប្បដែលសម្បយុត្តដោយមគ្គជាដើមរបស់អរហត្តវិមោក្ខ ឈ្មោះថា ជាធម៌ស្ទុះទៅខាងមុខ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ធម្មតក្កបុរេជវំ** ដូច្នេះ ។ បទថា **អវិជ្ជាយ បភេទនំ** សេចក្ដីថា តថាគតពោលថា នុ៎ះឯងជាអញ្ញាវិមោក្ខសម្រាប់ទម្លាយអវិជ្ជា ដោយន័យដែលប្រៀបធៀបជាមួយហេតុ ព្រោះអាស្រ័យនិព្វាន ពោល គឺការទម្លាយអវិជ្ជាកើតឡើង ។ ឧទយមាណពបានស្ដាប់និព្វានដែលព្រះមានព្រះភាគត្រាស់ដោយព្រះតម្រាស់ ដែលជាការទម្លាយអវិជ្ជាយ៉ាងនេះហើយ កាលនឹងទូលសួរថា ដែលហៅថា និព្វាននោះ ព្រោះលះអ្វីបាន ទើបពោលគាថាថា **កឹសុ សញ្ញោជនោ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **កឹសុ សញ្ញោជនោ** សេចក្ដីថា លោកមានអ្វីប្រកប ។ បទថា **កឹសុ វិចារណោ** បានដល់ ធម្មជាតអ្វីជាគ្រឿងត្រាច់ទៅ ។ បទថា **កិស្សស្ស វិប្បហានេន** បានដល់ ព្រោះលះនូវធម៌នោះ ធម៌នោះឈ្មោះអ្វី ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ព្យាករសេចក្ដីនោះដល់ឧទយមាណពនោះ ទើបត្រាស់គាថាថា **នន្ទិសញ្ញោជនោ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **វិតក្កស្ស** បានដល់ វិតក្ក មានកាមវិតក្កជាដើម ។ ឥឡូវនេះ ឧទយមាណពកាលនឹងទូលសួរផ្លូវនៃនិព្វាននោះ ទើបពោលគាថាថា **កថំ សតស្ស** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **វិញ្ញាណំ** បានដល់ អភិសង្ខារវិញ្ញាណ ។

លំដាប់នោះ ព្រះមានព្រះភាគ កាលត្រាស់ប្រាប់ផ្លូវដល់ឧទយមាណពនោះ ទើបត្រាស់គាថាថា **អជ្ឈត្តញ្ច** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ឯវំ សតស្ស** បានដល់ មានសតិសម្បជញ្ញៈយ៉ាងនេះ ។ បទដ៏សេសក្នុងទីទាំងពួង ជាក់ច្បាស់ល្អហើយ ។

ព្រះមានព្រះភាគ ទ្រង់សម្ដែងសូត្រនេះ ដោយធម៌ដ៏កំពូល គឺអរហត្តនោះឯង ដោយប្រការដូច្នេះ កាលចប់ទេសនា បុគ្គលអ្នកសម្រេចធម៌ ដូចគ្នានឹងសូត្រមុននោះឯង ។៚

**អដ្ឋកថាឧទយប្បញ្ហាទី ១៣ ចប់**

# សុត្តន្តបិដក

## ពោសាលប្បញ្ហាទី ១៨

[ ១២៥ ] ( ពោសាលមាណពដ៏មានអាយុ ទូលសួរថា ) ខ្ញុំព្រះអង្គ ជាអ្នកត្រូវការដោយបញ្ហា ទើបមកគាល់ដើម្បីសួរ ព្រះអង្គសម្តែងព្រះប្រាជ្ញាញាណ ក្នុងកាលជាអតីត មិនញាប់ញ័រ ( ចំពោះសុខទុក្ខ ) មានសេចក្តីសង្ស័យកាត់បង់ហើយ ដល់នូវត្រើយនៃធម៌ទាំងពួង បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គសូមទូលសួរ ញាណរបស់បុគ្គល មានសេចក្តីកំណត់ កត់សម្គាល់ក្នុងរូប បានជាក់ច្បាស់ ( បានសម្រេចដល់រូបជ្ឈានហើយ ) លះបង់រូបារម្មណ៍ទាំងអស់បានហើយ ( កន្លងរូបជ្ឈានហើយ ) ឃើញទាំងខាងក្នុង ទាំងខាងក្រៅថា វត្ថុបន្តិចបន្តួចមិនមាន ( សម្រេចអរូបជ្ឈាន ដែលហៅថាអាកិញ្ចញ្ញាយតនៈ ) បុគ្គលមានសភាពដូច្នោះ តើព្រះអង្គគប្បីប្រៀនប្រដៅ ដោយប្រការដូចម្តេចទៀត ។

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលពោសាលៈ ) តថាគតជ្រាបវិញ្ញាណដ្ឋិតិ ( ភូមិជាទីតាំងនៃវិញ្ញាណ ) ទាំងអស់ ទើបជ្រាបបុគ្គលនោះ កំពុងឋិតនៅ មានចិត្តចុះស៊ប់ក្នុង ( អាកិញ្ចញ្ញាយតនៈ ) មានអាកិញ្ចញ្ញាយតនៈនោះ ប្រព្រឹត្តទៅខាងមុខ មានអាកិញ្ចញ្ញាយតនៈជាដែនកើត មានសេចក្តីត្រេកត្រអាល ជាគ្រឿងប្រកបដូច្នេះ លុះតថាគត ជ្រាបច្បាស់យ៉ាងនេះហើយ លំដាប់អំពីអាកិញ្ចញ្ញាយតនជ្ឈាននោះ ក៏រមែងពិចារណាឃើញច្បាស់ ក្នុង

សហជាតធម៌នោះ នេះឯងជាញាណដ៏ពិតប្រាកដ របស់ព្រាហ្មណ៍នោះ ជាអ្នកប្រព្រឹត្តចប់ព្រហ្មចរិយធម៌ ។

ពោសាលមាណវកបញ្ហាទី ១៤ ចប់

# អដ្ឋកថា

## ពោសាលបញ្ហាទី ១៤

[ ១២៥ ] ក្នុងពោសាលបញ្ហាទី ១៤ មានពាក្យផ្ដើមថា **យោ អតីតំ** ដូច្នេះ ក្នុងបទទាំងនោះ បទថា **យោ អតីតំ អាទិសតិ** សេចក្ដីថា ព្រះមានព្រះភាគអង្គណា ទ្រង់សម្ដែងអាងដល់អតីតជាដើមថា មួយជាតិខ្លះ របស់ព្រះអង្គ និងរបស់ពួកសត្វដទៃ ។ បទថា **វិភូតរូបសញ្ញិស្ស** បានដល់របស់បុគ្គលដែលឈានកន្លងរូបសញ្ញា ។ បទថា **សព្វកាយប្បហាយិនោ** បានដល់ លះរូបកាយបានទាំងអស់ ដោយការលះមូលម្ចាល និងដោយការសង្កត់ អធិប្បាយថា លះបដិសន្ធិក្នុងរូបភពបានហើយ ។ បទថា **នត្ថិ កិញ្ចីតិ បស្សតោ** បានដល់ ឃើញថា មិនមានអ្វី ព្រោះឃើញច្បាស់ថា វិញ្ញាណមិនមាន អធិប្បាយថា បានអាកិញ្ចញ្ញាយតនសមាបត្តិ ។ បទថា **ញាណំ សក្កានុបុច្ឆាមិ** សេចក្ដីថា ពោសាលមាណពហៅព្រះមានព្រះភាគថា **សក្យ** ។ ខ្ញុំព្រះអង្គទូលសួរដល់ញាណរបស់បុគ្គលនោះថា គួរប្រាថ្នាដូចម្ដេច ។ បទថា **កថំ នេយ្យោ** បានដល់ បុគ្គលនោះគួរទូន្មានដូចម្ដេច គួរឲ្យញាណ

កើតដល់បុគ្គលនោះក្រៃលែងឡើងបានដូចម្ដេច ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ប្រកាសញាណរបស់ព្រះអង្គ ដែលបុគ្គលណាម្នាក់កម្ចាត់មិនបាន ក្នុងបុគ្គលបែបនោះ ដើម្បីទ្រង់ព្យាករញាណនោះដល់បោសាលមាណព ទើបត្រាស់ ២ គាថាតទៅ ។

បទថា **វិញ្ញាណដ្ឋិតិយោ សព្វា អភិជានំ តថាគតោ** សេចក្ដីថា តថាគតដឹងក្រៃលែង នូវវិញ្ញាណដ្ឋិតិទាំងពួងយ៉ាងនេះ គឺវិញ្ញាណដ្ឋិតិ ៤ ដោយអំណាចអភិសង្ខារ វៀរវិញ្ញាណដ្ឋិតិ ៧ ដោយអំណាចបដិសន្ធិ ។ បទថា **តិដ្ឋន្តមេនំ ជានាតិ** បានដល់ ជ្រាបបុគ្គលនោះ ជាអ្នកតាំងនៅបានដោយកម្ម គឺអភិសង្ខារថា តទៅ សត្វនេះ នឹងមានគតិយ៉ាងនេះ ។ បទថា **វិមុត្តំ** បានដល់ ដែលបង្អោនទៅហើយក្នុងអាកិញ្ចញ្ញាយតនសមាបត្តិជាដើម ។ បទថា **តប្បរាយនំ** សេចក្ដីថា សម្រេចដោយអាកិញ្ចញ្ញាយតនសមាបត្តិនោះ ។ បទថា **អាកិញ្ចញ្ញាសម្ភវំ ញត្វា** បានដល់ ជ្រាបកម្មាភិសង្ខារ ដែលឲ្យកើតក្នុងអាកិញ្ចញ្ញាយតនភព ។ សួរថា ជ្រាបដូចម្ដេច ឆ្លើយថា ទ្រង់ជ្រាបថា នេះជាគ្រឿងចង ។ បទថា **នន្ទិសញ្ញោជនំ ឥតិ** បានដល់ ដឹងថា ការត្រេកអរដែលរាប់ថា អរូបរាគៈក្នុងភពនោះជាគ្រឿងប្រកប ។ បទថា **តតោ តត្ថ វិបស្សតិ** សេចក្ដីថា បន្ទាប់អំពីនោះ ចេញអំពីអាកិញ្ចញ្ញាយតនសមាបត្តិហើយ ឃើញច្បាស់សមាបត្តិនោះ ដោយភាពជារបស់មិនទៀងជាដើម ។ បទថា**ឯវំ ញាណំ តថំ តស្ស** បានដល់ អរហត្តញាណកើត

១- អដ្ឋកថា ខន្ធសំយុត្តថា បានដល់ រូប វេទនា សញ្ញា សង្ខារ ។

ឡើងដល់បុគ្គលនោះ ដែលឃើញច្បាស់យ៉ាងនេះ តាមលំដាប់ មិនវិបរិត ។ បទថា **វុសីមតោ** បានដល់ ប្រព្រឹត្តព្រហ្មចរិយៈចប់ហើយ ។ បទដ៏សេសក្នុងទីទាំងពួង ជាក់ច្បាស់ហើយ ។ ព្រះមានព្រះភាគទ្រង់សម្តែងព្រះសូត្រនេះ ដោយធម៌ដ៏កំពូល គឺអរហត្តនោះឯង ។ កាលចប់ទេសនា បុគ្គលដែលសម្រេចធម៌ ដូចគ្នានឹងសូត្រមុននោះឯង ៗ

**អដ្ឋកថាធោសាលបញ្ញាទី ១៤ ចប់**

# សុត្តន្តបិដក

## មោឃរាជប្បញ្ហាទី ១៥

[ ១២៦ ] ( មោឃរាជមាណពដ៏មានអាយុ ទូលសួរថា ) បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គទូលសួរ អស់វារៈ ២ ដង ហើយ ព្រះអង្គមានជួនចក្ខុ ក៏មិនទាន់បានដោះស្រាយ ដល់ខ្ញុំព្រះអង្គនៅឡើយ បពិត្រព្រះអង្គជាទេពឥសី ខ្ញុំព្រះអង្គបានឮថា បើគេទូលសួរអស់វារៈ ៣ ដង ព្រះមានព្រះភាគ គង់ដោះស្រាយ លោកនេះ លោកដទៃ ព្រហ្មលោក ព្រមទាំងទេវលោក រមែងមិនទាន់ដឹងនូវសេចក្ដីយល់ របស់ព្រះអង្គជាព្រះគោតម ដ៏ទ្រង់យសទេ ខ្ញុំព្រះអង្គ ជាអ្នកត្រូវការដោយបញ្ហា ទើបមកគាល់ ( ដើម្បីសួរ ) ព្រះអង្គជាអ្នកឃើញដ៏លើសលុបយ៉ាងនេះ បុគ្គលកាលពិចារណា នូវខន្ធលោកដូចម្ដេច មច្ចុរាជទើបមិនឃើញ ។

ម្នាលមោឃរាជ អ្នកចូរជាអ្នកមានសតិសព្វកាល ចូរពិចារណាលោក ដោយសភាពជារបស់សូន្យ បុគ្គលដកអត្តានុទិដ្ឋិ គឺសេចក្ដីឃើញថាជាខ្លួនប្រាណចេញ ទើបឆ្លងមច្ចុរាជចេញបានយ៉ាងនេះ បុគ្គលកាលពិចារណាលោកយ៉ាងនេះ មច្ចុរាជទើបមិនឃើញ ។

មោឃរាជមាណវកប្បញ្ហាទី ១៥ ចប់

# អដ្ឋកថា

## មោឃរាជប្បញ្ហាទី ១៥

[ ១២៦ ] ក្នុងមោឃរាជប្បញ្ហាទី ១៥ មានពាក្យផ្តើមថា **ទ្វាហំ សក្កំ** ដូច្នេះ ក្នុងបទទាំងនោះ បទថា **ទ្វាហំ** បានដល់ ខ្ញុំព្រះអង្គបានទូលសួរបញ្ហាអស់វារៈ ២ ដង ។ ដែលពិតនោះ មោឃរាជមាណពនោះ ធ្លាប់សួរបញ្ហានឹងព្រះមានព្រះភាគអស់វារៈ ២ ដង កាលចប់អជិតប្បញ្ហា និងតិស្សមេត្តេយ្យប្បញ្ហា ។ តែព្រះមានព្រះភាគ ទ្រង់រង់ចាំឲ្យមោឃរាជមាណពមានឥន្ទ្រិយចាស់ក្លាសិន ទើបទ្រង់មិនបានព្យាករ ។ ដោយហេតុនោះ ទើបមោឃរាជមាណពទូលថា បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គទូលសួរអស់វារៈ ២ ដងហើយ ។ បទថា **យាវតតិយញ្ច ទេវិសិ ព្យាករោតីតិ មេ សុតំ** សេចក្តីថា ខ្ញុំព្រះអង្គបានស្តាប់មកយ៉ាងនេះថា ព្រះសម្មាសម្ពុទ្ធទ្រង់ស្វែងរកគុណ ទ្រង់ចែកធម៌ ទ្រង់ជាវិសុទ្ធិទេព ត្រូវសួរបញ្ហាប្រកបដោយធម៌ហើយ ទ្រង់នឹងព្យាករក្នុងលើកទី ៣ ។ បានឮថា មោឃរាជមាណពនោះ បានស្តាប់យ៉ាងនេះ ត្រង់ឆ្នេរស្ទឹងគោធាវរីនោះឯង ដោយហេតុនោះ ទើបមោឃរាជមាណពទូលសួរថា **ព្យាករោតីតិ មេ សុតំ** ដូច្នេះ ។ បទថា **អយំ លោកោ** បានដល់ មនុស្សលោក ។ បទថា **បរោ លោកោ** បានដល់ លោកដ៏សេសវៀរមនុស្សលោកនោះ ។ បទថា **សទេវកោ** បានដល់ លោកដ៏សេសប្រកបដោយឧបបត្តិទេព និងសម្មតិទេព វៀរព្រហ្មលោក ។ បទថា **ព្រហ្មលោកោ សទេវកោ** នេះ គ្រាន់តែសម្តែងដល់ន័យជាដើមថា ក្នុងលោកព្រមទាំងទេវលោក ។ ដោយពាក្យនោះ គប្បីជ្រាបលោកដូចបានពោលហើយ

យ៉ាងនោះ ។ បទថា **ឯវំ អភិក្កន្តទស្សាវី** បានដល់ ទ្រង់មានប្រក្រតីឃើញធម៌ដ៏ស្អាត គឺធម៌ដ៏ក្រៃលែងយ៉ាងនេះ ។ មោឃរាជមាណពសម្តែងថា ទ្រង់អ្នកអាចឃើញអធ្យាស្រ័យ អធិមុត្តិ និងគតិ ដែលប្រព្រឹត្តទៅខាងមុខនៃលោកព្រមទាំងទេវលោក ។ បទថា **សុញ្ញតោ លោកំ អវេក្ខស្សុ** បានដល់ ចូរពិចារណាឃើញលោក ដោយភាពជារបស់ទទេ ដោយហេតុ ២ ប្រការ គឺ ដោយកំណត់ការមិនប្រព្រឹត្តទៅក្នុងអំណាច ១ ដោយពិចារណាឃើញរឿយៗ ថា សង្ខារជារបស់ទទេ ១ ។ បទថា **អត្តានុទិដ្ឋឹ ឩហច្ច** បានដល់ ដកនូវការឃើញថាជាតួខ្លួនជាដើម ។ បទដ៏សេស ក្នុងបទទាំងពួងជាក់ច្បាស់ហើយ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងសូត្រនេះដោយកំពូលនៃធម៌ គឺអរហត្តដូចគ្នា កាលចប់ទេសនា បុគ្គលអ្នកសម្រេចធម៌ ដូចបានពោលហើយ ក្នុងសូត្រមុននោះឯង ។៚

## អដ្ឋកថាមោឃរាជប្បញ្ហាទី ១៥ ចប់

# សុត្តន្តបិដក

## បិង្គិយបញ្ហាទី ១៦

[ ១២៧ ] ( បិង្គិយមាណពដ៏មានអាយុ ទូលសួថា ) ខ្ញុំព្រះអង្គជាមនុស្សចាស់ មិនសូវមានកម្លាំង មានពណ៌សម្បុរអាប់អន់ ភ្នែកក៏មិនសូវភ្លឺ ត្រចៀកសម្រាប់ស្តាប់ក៏មិនសូវឮ សូមកុំឲ្យខ្ញុំព្រះអង្គវង្វេងវង្វាន់វិនាសក្នុងចន្លោះ សូមព្រះអង្គត្រាស់ប្រាប់ធម៌ដែលខ្ញុំព្រះអង្គគួរដឹង ជាគ្រឿងលះជាតិ និងជរា ក្នុងអត្តភាពនេះឲ្យទាន ។

( ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលបិង្គិយៈ ) អ្នកចូរឃើញថា ជនទាំងឡាយជាអ្នកប្រមាទ រមែងលំបាកព្រោះរូបជាហេតុ រមែងឈឺចាប់ក៏ព្រោះរូបជាហេតុ ម្នាលបិង្គិយៈ ព្រោះដូច្នោះ អ្នកកុំប្រមាទ ចូរលះរូបចោលចេញ ដើម្បីមិនកើតតទៅទៀត ។

ទិសទាំងឡាយនេះ គឺទិសធំ ៤ ទិសតូច ៤ ទាំងទិសខាងលើ ១ និងទិសខាងក្រោម ១ រួមត្រូវជា ១០ ទិស វត្ថុណាមួយក្នុងលោក ដែលព្រះអង្គមិនធ្លាប់ឃើញ មិនធ្លាប់ឮ មិនធ្លាប់ប៉ះពាល់ ឬមិនធ្លាប់ជ្រាប មិនមានទេ សូមព្រះអង្គត្រាស់ប្រាប់ធម៌ដែលខ្ញុំព្រះអង្គគួរដឹងសម្រាប់លះជាតិ និងជរា ក្នុងអត្តភាពនេះ ។

( ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលបិង្គិយៈ ) កាលបើអ្នកឃើញនូវពួកមនុស្ស ដែលត្រូវតណ្ហាកំពុងគ្របសង្កត់ ជាសត្វមានសេចក្តីក្តៅក្រហាយកើតឡើងហើយ ត្រូវជរារួបរឹតហើយ ម្នាលបិង្គិយៈ ហេតុដូច្នោះ អ្នកកុំប្រមាទ ចូរលះតណ្ហាចោលចេញ ដើម្បីមិនឲ្យកើតតទៅទៀត ។

**បិង្គិយមាណវកបញ្ហាទី ១៦ ចប់**

# អដ្ឋកថា

## បិង្គិយបញ្ហាទី ១៦

[ ១២៧ ] ក្នុងបិង្គិយបញ្ហាទី ១៦ មានពាក្យផ្តើមថា **ជិណ្ណោហមស្មិ** ដូច្នេះ ក្នុងបទទាំងនោះ បទថា **ជិណ្ណោហមស្មិ អពលោ វីតវណ្ណោ** សេចក្តីថា បានឮថា ព្រាហ្មណ៍នោះត្រូវជរាគ្របសង្កត់ មានអាយុ ១២០ អំពីកំណើត មានកម្លាំងតិច គិតថា អញនឹងធ្វើបទក្នុងទីនេះ បែរជាធ្វើក្នុងទីដទៃ និងមានពណ៌សម្បុរសៅហ្មង ដោយហេតុនោះ ទើបបិង្គិយៈពោលថា **ជិណ្ណោហមស្មិ អពលោ វីតវណ្ណោ** ដូច្នេះ ។ បទថា **មាហំ នស្សំ មោមុហោ អន្តរាយ** សេចក្តីថា ខ្ញុំព្រះអង្គមិនទាន់ធ្វើឲ្យជាក់ច្បាស់នូវធម៌របស់ព្រះអង្គ នៅជាបុគ្គលមិនដឹងច្បាស់ កុំបីវិនាសក្នុងចន្លោះឡើយ ។ បទថា **ជាតិជរាយ ឥធ វិប្បហានំ** សេចក្តីថា សូមទ្រង់ប្រាប់នូវធម៌ជាគ្រឿង

លះជាតិ និងជរា គឺនិព្វានធម៌ ក្នុងបាទមូលរបស់ព្រះអង្គ ឬក្នុងបាសាណក-ចេតិយនេះ ដែលខ្ញុំព្រះអង្គគួរដឹងចុះ ។

ឥឡូវនេះ ព្រោះបិង្គិយៈពោលគាថាថា **ជិណ្ណោហមស្មិ** ព្រោះសម្លឹងក្នុងកាយ ដូច្នោះ ព្រះមានព្រះភាគដើម្បីឲ្យបិង្គិយៈនោះលះនូវការជាប់ជំពាក់ក្នុងកាយ ទើបត្រាស់ថា **ទិស្វាន រូបេសុ វិហញ្ញមានេ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **រូបេសុ** បានដល់ ព្រោះរូបជាហេតុជាបច្ច័យ ។ បទថា **វិហញ្ញមានេ** បានដល់ ក្តៅក្រហាយដោយកម្មករណៈជាដើម ។ បទថា **រុប្បន្តិ រូបេសុ** សេចក្តីថា ជនទាំងឡាយ រមែងក្តៅក្រហាយ រមែងលំបាក ដោយរោគទាំងឡាយ មានរោគភ្នែកជាដើម ព្រោះរូបជាហេតុ ។

បិង្គិយៈស្តាប់បដិបទា ដែលព្រះមានព្រះភាគត្រាស់រហូតដល់អរហត្តហើយ ក៏មិនសម្រេចធម៌វិសេស ព្រោះខ្លួនជរា និងមានកម្លាំងតិច កាលសរសើរព្រះមានព្រះភាគដោយគាថានេះ ទើបពោលថា **ទិសា ចតស្សោ** ដូច្នេះជាដើម ហើយអារាធនាសូមឲ្យព្រះមានព្រះភាគទេសនា ។ លំដាប់នោះព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងបដិបទារហូតដល់អរហត្ត ដល់បិង្គិយៈទៀត ទើបត្រាស់គាថាថា **តណ្ហាធិបន្នេ** ដូច្នេះជាដើម ។ បទដ៏សេស ក្នុង

ទីទាំងពួងជាក់ច្បាស់ល្អហើយ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងព្រះសូត្រនេះ ដោយកំពូលនៃធម៌ គឺអរហត្តដូចគ្នា ។ម្យ៉ាងទៀត កាលចប់ទេសនា បិង្គិយៈ តាំងនៅក្នុងអនាគាមិផល ។ បានឮថា បិង្គិយៈនោះគិតក្នុងចន្លោះៗ ថា ពាវរី ជាអ៊ំរបស់អញ មិនបានស្តាប់ទេសនាដ៏វិចិត្រយ៉ាងនេះ នឹងមានប្រយោជន៍អ្វី ដោយការស្តាប់របស់អញ ព្រោះការរាយមាយដោយការជាប់ជំពាក់នោះ ទើប បិង្គិយៈមិនបានសម្រេចអរហត្ត ឯជដិល ១០០០ ដែលជាអន្តេវាសិករបស់ បិង្គិយៈនោះ បានសម្រេចអរហត្ត ជនទាំងអស់ទ្រទ្រង់នូវបាត្រ និងចីវរ សម្រេចដោយឫទ្ធិ បានជាឯហិភិក្ខុ ដោយប្រការដូច្នេះ ។ល។

**អដ្ឋកថា បិង្គិយមាណវកប្បញ្ហាទី ១៦ ចប់**

# សុត្តន្តបិដក

## ចារាយនានុសន្ធិគាថា

[ ១២៨ ] កាលព្រះមានព្រះភាគ ទ្រង់គង់នៅនាបាសាណកចេតិយក្នុងដែនមគធៈ ទ្រង់បានសម្តែងសូត្រនេះ កាលពួកព្រាហ្មណ៍ ១៦ នាក់ ជាអ្នកបម្រើ ( របស់ពាវរីព្រាហ្មណ៍ ) អារាធនាហើយ ទើបព្រះអង្គទ្រង់ដោះស្រាយបញ្ហា ។ បើបុគ្គលបានដឹងនូវអត្ថ បានដឹងនូវធម៌នៃបញ្ហាមួយៗ ហើយគប្បីប្រតិបត្តិនូវធម៌ ដ៏សមគួរតាមធម៌ បុគ្គលនោះ មុខជាដល់នូវត្រើយនៃជរា និងមរណៈពុំខាន ធម៌ទាំងនេះ ជាធម៌គួរនាំសត្វទៅ ( កាន់ត្រើយ គឺព្រះនិព្វាន ) ព្រោះហេតុនោះ ពាក្យថា បារាយនៈ ( ការប្រព្រឹត្តទៅកាន់ត្រើយ ) នេះ ជាឈ្មោះនៃធម្មបរិយាយនេះឯង ។

[ ១២៩ ] ( ព្រាហ្មណមាណព ១៦ នាក់ ដែលបានក្រាបទូលសួរបញ្ហា ) នុ៎ះ គឺមាណពឈ្មោះអជិត ១ តិស្សមេត្តេយ្យ ១ បុណ្ណកៈ ១ មេត្តគូ ១ ធោតកៈ ១ ឧបសីវៈ ១ នន្ទៈ ១ ហេមកៈ ១ តោទេយ្យ ១ កប្បៈ ១ ជតុកណ្ណីមាណព ជាបណ្ឌិត ១ ភទ្រាវុធ ១ ឧទយៈ ១ ព្រាហ្មណបោសាលៈ ១ មោឃរាជជាអ្នកប្រាជ្ញ ១ បិង្គិយៈជាមហាឥសី ១ ព្រាហ្មណ៍ទាំង ១៦ នាក់នុ៎ះ បានទៅគាល់ព្រះពុទ្ធជាអ្នកស្វែងរកនូវគុណមានចរណៈ គឺធម៌ជាគ្រឿងប្រព្រឹត្តដ៏បរិបូណ៌ បានចូលទៅក្រាបទូលសួរបញ្ហាដ៏ល្អិតចំពោះព្រះពុទ្ធ ជាបុគ្គលប្រសើរ ។ ព្រះពុទ្ធជាព្រះមុនី បានដោះស្រាយនូវបញ្ហាទាំងឡាយ ដែលពួក

ព្រាហ្មណ៍ទូលសួរតាមសេចក្ដីពិត បានញ៉ាំងពួកព្រាហ្មណ៍ឲ្យត្រេកអរដោយការដោះស្រាយបញ្ហា ។ ព្រាហ្មណ៍ទាំង ១៦ នាក់នុ៎ះ កាលបើព្រះពុទ្ធជាអាទិច្ចវង្ស មានចក្ខុ គឺប្រាជ្ញាញាណ បានឲ្យត្រេកអរហើយ ក៏បានប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសម្នាក់នៃព្រះសាស្ដា មានបញ្ញាដ៏ប្រសើរ ។ ព្រះពុទ្ធវចនៈ ដែលព្រះពុទ្ធទ្រង់សម្ដែងហើយ ចំពោះបញ្ហាមួយៗ ដោយប្រការយ៉ាងណា ។ បើបុគ្គលណាប្រតិបត្តិតាមដូច្នោះ បុគ្គលនោះ គប្បីទៅអំពីទីមិនមែនជាត្រើយ កាន់ត្រើយបាន ព្រោះហេតុនោះ បុគ្គលកាលចម្រើនមគ្គដ៏ឧត្ដម គឺអដ្ឋង្គិកមគ្គ គប្បីចេញចាកទីមិនមែនត្រើយ ទៅកាន់ត្រើយ គឺព្រះនិព្វាន ។ មគ្គនោះ តែងប្រព្រឹត្តទៅ ដើម្បីទៅកាន់ត្រើយ គឺព្រះនិព្វាន ព្រោះហេតុនោះ ទើបឈ្មោះថា បារាយនៈ ដោយប្រការដូច្នេះ ។

[ ១៣០ ] ( បិង្គិយៈដ៏មានអាយុ ពោលសរសើរព្រះមានព្រះភាគក្នុងទីជិតពាវរីព្រាហ្មណ៍ដូច្នេះថា ) ខ្ញុំនឹងច្រៀងតាមបារាយនធម៌ ( ព្រះមានព្រះភាគបានឃើញយ៉ាងណា ទ្រង់សម្ដែងយ៉ាងនោះ ) ព្រះមានព្រះភាគប្រាសចាកមន្ទិល ព្រះអង្គមានប្រាជ្ញាញាណដូចជាផែនដី ព្រះអង្គមានសេចក្ដីប្រាថ្នាលះចេញហើយ មានទុក្ខរលត់ហើយ ព្រះអង្គជាបុគ្គលប្រសើរ គប្បីពោលពាក្យមុសាវាទ ដោយហេតុដូចម្ដេចកើត ។ បើដូច្នោះ

ខ្ញុំនឹងសូមសម្តែងវាចា ដែលប្រកបដោយគុណ គួរសរសើរ របស់ព្រះមានព្រះភាគ ព្រះអង្គមានមន្ទិល និងមោហៈ លះបង់ហើយ ទាំងមានះ និងមក្ខៈ ក៏ព្រះអង្គលះបង់បានដាច់ស្រឡះហើយ ។ ព្រះពុទ្ធមានចក្ខុជុំវិញ គឺសព្វញ្ញុតញ្ញាណ បន្ទោបង់នូវសេចក្តីងងឹត ដល់នូវទីបំផុតនៃលោក កន្លងផុតនូវភពទាំងពួង ព្រះអង្គមិនមានអាសវៈ លះបង់នូវទុក្ខទាំងពួង មានព្រះនាមជាសច្ចបុគ្គល ខ្ញុំក៏បានចូលទៅរកព្រះមានព្រះភាគដ៏ប្រសើរ រូបហើយ ។ បក្សីលះបង់ព្រៃតូច ( មានផ្លែឈើតិច ) មកអាស្រ័យព្រៃធំ មានផ្លែឈើច្រើនដូចម្តេចមិញ ខ្ញុំលះបង់គណាចារ្យ ដែលមានសេចក្តីឃើញតិច ( មកប្រសព្វព្រះមានព្រះភាគ ) មានព្រះប្រាជ្ញាដ៏ច្រើន ដូចហង្សហើរមកចុះក្នុងស្រះធំ ។ ពួកអាចារ្យណាមុន ( សាសនាព្រះគោតម ) អាចារ្យទាំងនោះបានព្យាករហើយ ដោយអាងគោលការណ៍ថា ដំណើរនោះតែងមានមកហើយដូច្នេះៗ នឹងមានតទៅខាងមុខដូច្នេះៗ ( នេះជាពាក្យប្រដៅក្រៅចាក ពាក្យប្រដៅព្រះគោតម ) សេចក្តីព្យាករណ៍ទាំងអស់នោះ ( មិនទាន់ប្រាកដទេ ) គ្រាន់តែពោលថាដូច្នេះៗ សេចក្តីព្យាករណ៍ទាំងអស់នោះ ជាគ្រឿងធ្វើសេចក្តីត្រិះរិះឲ្យចម្រើនឡើង ( ខ្ញុំមិនពេញចិត្តក្នុងពាក្យនោះឡើយ ) ព្រះមានព្រះភាគតែមួយព្រះអង្គប៉ុណ្ណោះ ទ្រង់បន្ទោបង់នូវងងឹត

គង់នៅជាសុខ ព្រះអង្គមានរស្មីរុងរឿង ទ្រង់ធ្វើនូវពន្លឺ ( ដល់លោក ) ។ ព្រះគោតមមានញាណដ៏ក្រាស់ដូចផែនដី ព្រះគោតម ព្រះអង្គប្រកបដោយប្រាជ្ញាក្រាស់ដូចផែនដី ទ្រង់សម្តែងធម៌ ( ជាដំណើរទៅកាន់ព្រះនិព្វាន ) ប្រកបដោយផលគួរឃើញជាក់ច្បាស់ មិនមានកំណត់កាល ជាគ្រឿងអស់តណ្ហា មិនមានឧបទ្រវៈ គឺកិលេសដល់ខ្ញុំ នឹងរកសេចក្តីឧបមាចំពោះព្រះនិព្វានក្នុងទីណាមួយ មិនបានឡើយ ។

( ពាវរីព្រាហ្មណ៍សួរបិង្គិយមាណពថា ) ម្នាលបិង្គិយៈ អ្នកដែលនៅឃ្លាតអំពីព្រះគោតម មានញាណក្រាស់ដូចផែនដី អំពីព្រះគោតម ប្រកបដោយប្រាជ្ញាក្រាស់ដូចផែនដីនោះ សូម្បីមួយរំពេចដែរឬ ព្រះគោតមដែលបានសម្តែងធម៌ ប្រកបដោយផលគួរឃើញជាក់ច្បាស់ មិនមានកំណត់កាល ជាគ្រឿងអស់ទៅនៃតណ្ហា មិនមានឧបទ្រវៈដល់អ្នក នឹងរកសេចក្តីឧបមាចំពោះព្រះនិព្វានក្នុងទីណាមួយ មិនមានមែនទេឬ ។

( បិង្គិយមាណពតបថា ) បពិត្រពាវរីព្រាហ្មណ៍ ខ្ញុំមិនដែលឃ្លាតអំពីព្រះគោតម អ្នកមានញាណក្រាស់ដូចផែនដីអំពីព្រះគោតមអ្នកប្រកបដោយប្រាជ្ញាក្រាស់ដូចផែនដីនោះ សូម្បីមួយរំពេចទេ ព្រះគោតមសម្តែងធម៌ប្រកបដោយផល គួរឃើញជាក់ច្បាស់ មិនមានកំណត់កាល ជាគ្រឿងអស់ទៅនៃតណ្ហា

មិនមានឧបទ្រវៈដល់ខ្ញុំ នឹងរកសេចក្តីឧបមាចំពោះព្រះនិព្វានក្នុងទីណាមួយ មិនមានពិតមែន ។ បពិត្រពាវរីព្រាហ្មណ៍ ខ្ញុំមិនប្រមាទទាំងយប់ទាំងថ្ងៃ ឃើញព្រះគោតមមានព្រះភាគអង្គនោះដោយចិត្ត ហាក់បីដូចជាឃើញដោយចក្ខុ ខ្ញុំនមស្ការ ( ព្រះគោតម ) នៅរហូតរាត្រី ខ្ញុំសម្គាល់ឃើញនូវការមិននៅប្រាសចាកព្រះគោតមនោះឯង ។ ធម៌ ៤ យ៉ាងនេះ គឺសទ្ធា ១ បីតិ ១ មនៈ ១ សតិ ១ ( ដែលមានក្នុងសន្តានរបស់ខ្ញុំ ) រមែងមិនប្រាសចាកសាសនានៃព្រះគោតមទេ ព្រះគោតមអ្នកមានបញ្ញាដូចផ្ទៃផែនដី ស្តេចទៅកាន់ទិសណាៗ ខ្ញុំនោះ ក៏ជាអ្នកបង្អោនចិត្តទៅហើយដោយទិសាភាគនោះៗ ឯង ។ បពិត្រពាវរីព្រាហ្មណ៍ ខ្ញុំជាបុគ្គលចាស់ មានកម្លាំងថយហើយ ហេតុនោះកាយទៅក្នុងទីនោះមិនបានទេ ខ្ញុំទៅអស់កាលជានិច្ច ដោយដំណើរ គឺសេចក្តីត្រិះរិះ ព្រោះថា ចិត្តខ្ញុំប្រកបហើយដោយការរឭកព្រះគោតមនោះ ។ ( ពាវរីព្រាហ្មណ៍តបថា ) ខ្ញុំ ( ដេកនៅ ) ក្នុងភក់ គឺកាម អន្ទះអន្ទែង ( ព្រោះតណ្ហា ) សាត់អណ្តែតទៅអំពីកោះទៅកាន់កោះ គឺចេញអំពីសម្នាក់សាស្តា ១ ទៅកាន់សម្នាក់សាស្តា ១ ខ្ញុំក៏បានជួបប្រទះនឹងព្រះសម្ពុទ្ធ ព្រះអង្គមិនមានអាសវៈ ឆ្លងផុតឱឃៈហើយ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា វក្កលិ ១ ភទ្រាវុធ ១ និងអាឡវិគោតម ១

សុទ្ធតែជាអ្នកមានសទ្ធាចុះស៊ប់ យ៉ាងណាមិញ សូមអ្នកក៏ចូរបញ្ចេញនូវសទ្ធាមកចុះ ក៏យ៉ាងនោះដែរ ម្នាលបិង្គិយៈ អ្នកនឹងដល់នូវត្រើយនៃសង្សារ ជាទីតាំងនៃមច្ចុមារ ។

( ព្រះបិង្គិយៈ ទូលសរសើរព្រះមានព្រះភាគថា ) ខ្ញុំព្រះអង្គនេះជ្រះថ្លាដោយក្រៃពេក ព្រោះបានស្តាប់ព្រះវាចានៃព្រះអង្គជាព្រះមុនី ព្រះអង្គត្រាស់ដឹងហើយដោយព្រះអង្គឯង ព្រះអង្គមានដំបូលគ្រឿងប្រក់បើកហើយ មិនមានកិលេសគ្រឿងរឹងត្អឹង ទ្រង់មានបដិភាណ ទ្រង់ជ្រាបនូវអធិទេវៈទាំងឡាយ គឺធម៌សម្រាប់ធ្វើសត្វឲ្យជាទេវតាដ៏ក្រៃលែង ទ្រង់ជ្រាបនូវធម្មជាតទាំងពួង ជាធម៌ដ៏ប្រសើរ និងថោកទាប ( ដល់ខ្លួន និងអ្នកដទៃ ) ។ ព្រះសាស្តាទ្រង់ធ្វើនូវទីបំផុតនៃបញ្ហាទាំងឡាយ ដល់ពួកជនដែលប្តេជ្ញាថា ជាអ្នកមានសេចក្តីសង្ស័យ ព្រះនិព្វានជាគុណជាតមិនកក្រើក មិនញាប់ញ័រ សេចក្តីឧបមាចំពោះព្រះនិព្វាន ក្នុងទីណាមួយមិនមានឡើយ ។ ខ្ញុំព្រះអង្គនឹងដល់ ( នូវអនុបាទិសេសនិព្វានធាតុ ) ដោយពិត សេចក្តីសង្ស័យក្នុងព្រះនិព្វាននោះ មិនមានដល់ខ្ញុំព្រះអង្គទេ សូមព្រះមានព្រះភាគចាំទុកនូវខ្ញុំព្រះអង្គថា ជាអ្នកមានចិត្តជឿស៊ប់ ( ក្នុងព្រះនិព្វាន ) ដោយប្រការដូច្នេះ ។

**បារាយនវគ្គទី ៥ ចប់**

# អដ្ឋកថា

## បារាយនានុសង្គីតិគាថា

[ ១២៨ ] បន្ទាប់អំពីនេះទៅ ព្រះសង្គីតិកាចារ្យ កាលសរសើរទេសនា ទើបពោលពាក្យជាដើមថា **ឥទមវោច ភគវា** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ឥទមវោច** សេចក្តីថា ព្រះមានព្រះភាគបាន ត្រាស់បារាយនសូត្រនេះ ។ បទថា **បរិចារកសោឡសន្នំ** សេចក្តីថា ព្រាហ្មណ៍ ១៦ នាក់ មួយអន្ទើដោយបិង្គិយៈ ជាបរិវាររបស់ពាវរីព្រាហ្មណ៍ ឬព្រាហ្មណ៍ ១៦ នាក់ ដែលជាបរិវាររបស់ព្រះមានព្រះភាគសម្មាសម្ពុទ្ធ ឈ្មោះថា **បរិចារកសោឡសន្នំ** ។ បរិវារទាំងនោះជាព្រាហ្មណ៍ទាំងអស់ ។ បណ្តាព្រាហ្មណ៍ទាំងនោះ បរិស័ទរបស់ព្រាហ្មណ៍ ១៦ នាក់ អង្គុយខាងមុខ ខាងក្រោយ ខាងឆ្វេង និងខាងស្តាំ ម្ខាង ៦ យោជន៍ បើអង្គុយជាជួរ ១២ យោជន៍ ។ បទថា **អជ្ឈិដ្ឋោ** បានដល់ ទូលអារាធនា ។ បទថា **អត្ថមញ្ញាយ** បានដល់ដឹងសេចក្តីនៃបាលី ។ បទថា **ធម្មមញ្ញាយ** បានដល់ ដឹងធម៌ក្នុង បាលី ។ ព្រះសង្គីតិកាចារ្យតាំងឈ្មោះធម្មបរិយាយនេះយ៉ាងនេះថា **បារាយន** ហើយកាលប្រកាសឈ្មោះរបស់ព្រាហ្មណ៍ទាំងនោះ បានពោលថា **អជិតោ តិស្សមេត្តេយ្យោ ។បេ។ ពុទ្ធសេដ្ឋមុបាគមុំ** ដូច្នេះជាដើម ។

[ ១២៩ ] ក្នុងបទទាំងនោះ បទថា **សម្បន្នចរណំ** សេចក្តីថា ទ្រង់ ដល់ព្រមហើយ ដោយសីលក្នុងបាតិមោក្ខជាដើម ដែលជាហេតុជិតឲ្យដល់ នូវព្រះនិព្វាន ។ បទថា **ឥសឹ** បានដល់ អ្នកស្វែងរកគុណធំ ។ ពាក្យដ៏សេស ជាក់ច្បាស់ហើយ ។ បន្ទាប់ពីនេះទៅ បទថា **ព្រហ្មចរិយមចរឹសុ** សេចក្តីថា

ព្រាហ្មណ៍ទាំងឡាយ បានប្រព្រឹត្តមគ្គព្រហ្មចរិយៈ ។ បទថា **ឆាភាយនំ** លោកអធិប្បាយថា ជាផ្លូវទៅកាន់ព្រះនិព្វាន ដែលជាគ្រើយអាយនោះ ។

[ ១៣០ ] បទថា **ឆាភាយនមនុត្តាយិស្សំ** នេះ ជាការភ្ជាប់អំពីបទថា **ឆាភាយនំ** នោះ ពិតហើយ កាលព្រះមានព្រះភាគ ទ្រង់សម្តែងបារាយន-សូត្រចប់ហើយ ជដិល ១៦០០០ បានសម្រេចអរហត្ត ទេវតា និងមនុស្ស ដ៏សេស ១៤ កោដិ បានសម្រេចធម៌ សមដូចបុរាណាចារ្យពោលថា បន្ទាប់ អំពីនោះ ព្រះពុទ្ធទ្រង់ញុំាងសត្វ ១៤ កោដិឲ្យផឹកនូវអមតធម៌ ក្នុងបារា-យនសមាគម ដែលគួរត្រេកអរ ត្រង់បាសាណកចេតិយ ។

កាលចប់ព្រះធម្មទេសនាហើយ មនុស្សទាំងឡាយដែលមកអំពីទីនោះ បានប្រាកដក្នុងគាមនិគមជាដើមរៀងៗ ខ្លួន ដោយអានុភាពរបស់ព្រះមានព្រះ ភាគនោះឯង សូម្បីព្រះមានព្រះភាគក៏យាងទៅក្រុងសាវត្ថី ចោមរោមដោយ ភិក្ខុមិនតិច មានភិក្ខុជាបរិវារ ១៦០០០ ជាដើម ។ ក្នុងទីនោះ បិង្គិយៈថ្វាយ បង្គំព្រះមានព្រះភាគទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមទៅដើម្បី ប្រាប់ពាវរីព្រាហ្មណ៍ថា ព្រះពុទ្ធទ្រង់កើតឡើងហើយ ព្រោះពាវរីព្រាហ្មណ៍ នោះនឹងទទួលស្តាប់ខ្ញុំព្រះអង្គ ដូច្នេះ ។ លំដាប់នោះ ព្រះបិង្គិយៈដែលព្រះ មានព្រះភាគទ្រង់អនុញ្ញាតហើយ ទើបទៅកាន់ឆ្នេរស្ទឹងគោធាវរីដោយឈាន បែរមុខទៅកាន់អាស្រមដោយជើង ពាវរីព្រាហ្មណ៍ឃើញបិង្គិយភិក្ខុនិមន្តទៅ ដល់ ក៏សួរថា បិង្គិយៈ ព្រះពុទ្ធទ្រង់កើតឡើងក្នុងលោកហើយឬ បិង្គិយភិក្ខុ តបថា ព្រះពុទ្ធកើតហើយ ទ្រង់ប្រថាប់គង់ក្នុងបាសាណកចេតិយ សម្តែងធម៌

ដល់ពួកអាត្មា ពួកអាត្មានឹងសម្តែងធម៌នោះដល់លោក ។ គ្រានោះ ពាវរី-ព្រាហ្មណ៍ មួយអន្ទើដោយបរិស័ទ បូជាបិង្គិយៈនោះដោយគ្រឿងសក្ការៈដ៏ច្រើន ហើយក្រាលអាសនៈឲ្យគង់ ។ ព្រះបិង្គិយៈនោះ អង្គុយលើអាសនៈនោះហើយ ពោលគាថាជាដើមថា **ចារាយនមនុគាយិស្សំ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អនុគាយិស្សំ** គឺអាត្មានឹងពោលនូវភាសិតដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ។ បទថា **យថា អទ្ទក្ខិ** អាត្មាសូមពោលតាមដែលព្រះមានព្រះភាគទ្រង់ឃើញហើយ គឺព្រះមានព្រះភាគទ្រង់ឃើញហើយ ដោយសាធារណញ្ញាណ ដែលជាការត្រាស់ដឹងក្រៃលែងតាមសេចក្តីពិត ដោយព្រះអង្គឯង ។ បទថា **និក្កាមោ** ប្រែថា មិនមានសេចក្តីប្រាថ្នា គឺលះនូវការប្រាថ្នាបានហើយ ។ បាឋៈថា **និក្ខមោ** ដូច្នេះក៏មាន ប្រែថា មានសេចក្តីព្យាយាម ឬចេញចាកធម៌ចំណែកអកុសល ។ បទថា **និព្វានោ** ទ្រង់រម្ងត់កិលេស វៀរចាកគ្រឿងរួបរឹត គឺកិលេស ឬវៀរចាកតណ្ហានោះឯង ។ បទថា **កិស្ស ហេតុ មុសា ភណេ** គប្បីត្រាស់មុសាព្រោះហេតុអ្វី ។ លោកសម្តែងថា កិលេសដែលជាហេតុឲ្យពោលមុសា ព្រះមានព្រះភាគទ្រង់លះបានហើយ ។ ព្រះបិង្គិយៈឲ្យព្រាហ្មណ៍កើតឧស្សាហ៍ក្នុងការស្តាប់ដោយបទនេះ ។ បទថា **វណ្ណុបសញ្ហិតំ** គឺវាចាដែលប្រកបដោយគុណ ។ បទថា **សច្ចវ្ហយោ** គឺមានព្រះនាមតាមសេចក្តីពិត គឺប្រកបដោយព្រះនាមថា **ពុទ្ធោ**។ បទថា **ព្រហ្មេ** ព្រះបិង្គិយៈហៅព្រាហ្មណ៍នោះ ។ បទថា **កុព្វនំ** បានដល់ ព្រៃតូច ។ បទថា **ពហុប្ផលំ កាននំ អាវសេយ្យ** មកកាន់

ព្រៃធំដែលមានផ្លែឈើច្រើន គឺមកកាន់ព្រៃធំ ដែលបរិបូណ៌ទៅដោយផ្លែឈើច្រើនប្រភេទ ។ បទថា **អប្បទស្សេ** សេចក្តីថា អាត្មាលះអាចារ្យដែលមានការឃើញតិច គឺលះគណាចារ្យ ផ្តើមអំពីពាវរីព្រាហ្មណ៍ ។ បទថា **មហោ-ទធឹ** បានដល់ អន្លង់ទឹកធំ មានអនោតត្តស្រះជាដើម ។ បទថា **យេមេ បុព្វេ** កាត់បទថា **យេ ឥមេ បុព្វេ** ។ បទថា **តមនុទាសីនោ** គឺទ្រង់បន្ទោបង់នូវងងឹតស្ងប់រម្ងាប់បាន ។ បទថា **ភូរិបញ្ញាណោ** គឺមានបញ្ញាជាគ្រឿងប្រាកដដូចទង់ ។ បទថា **ភូរិមេធសោ** គឺមានព្រះបញ្ញាទូលំទូលាយ ។ បទថា **សន្ទិដ្ឋិកមកាលិកំ** ទ្រង់សម្តែងធម៌ដែលបុគ្គលគប្បីឃើញឯង មិនប្រកបដោយកាល គឺគប្បីឃើញផលដោយខ្លួនឯង មិនគប្បីឃើញផលក្នុងកាលដែលមានចន្លោះ ។ បទថា **អនីតិកំ** មិនមានចង្រៃ គឺវៀរចាកចង្រៃ មានកិលេសជាដើម ។

សម័យនោះ ពាវរីព្រាហ្មណ៍ពោល ២ គាថានឹងបិង្គិយភិក្ខុនោះថា **កិន្នុ តម្ហា** សេចក្តីថា ហេតុអ្វីហ្ន៎ ទើបលោកប្រាសចាកព្រះសមណគោតមអង្គនោះ ដូច្នេះជាដើម ។ បន្ទាប់អំពីនោះ ព្រះបិង្គិយៈ កាលសម្តែងដល់ភាពដែលត្រូវនៅប្រាសចាកអំពីសម្នាក់របស់ព្រះមានព្រះភាគ ទើបពោលគាថាជាដើមថា **នាហំ តម្ហា** អាត្មាមិនបានទៅប្រាសចាកព្រះគោតមអង្គនោះដូច្នេះ ។ បទថា **បស្សាមិ នំ មនសា ចក្ខុនា វា** សេចក្តីថា អាត្មាឃើញព្រះគោតមនោះដោយចិត្ត ដូចឃើញដោយភ្នែក ។ បទថា **នមស្សមានោ វិវសេមិ រត្តឹ** គឺអាត្មានមស្ការអស់រាត្រី ។ បទថា **តេន តេនេវ នតោ** អាត្មា

បង្អោនទៅដោយទិសនោះៗ គឺសម្តែងថា ព្រះពុទ្ធគង់នៅដោយទិសាភាគណា សូម្បីអាត្មាក៏ទៅកាន់ទិសាភាគនោះៗ ។ បទថា **ទុព្វលថាមកស្ស** គឺមានកម្លាំងតិច ។ ម្យ៉ាងទៀត មានកម្លាំងតិច និងរោគបៀតបៀន ។ លោកអធិប្បាយថា មានកម្លាំង និងមានសេចក្តីព្យាយាមធូរថយ ។ បទថា **តេនេវ កាយោ ន បលេតិ** កាយមិនចូលទៅដោយហេតុនោះឯង គឺកាយមិនទៅព្រោះមានកម្លាំង និងសម្ទុះតិចនោះឯង ឬព្រះពុទ្ធគង់នៅក្នុងទីណា កាយមិនទៅក្នុងទីនោះ ។ បាឋៈថា **ន បរេតិ** ដូច្នេះក៏មាន ។ ឯសេចក្តីតែមួយដូចគ្នា ។ បទថា **តត្ថ** គឺក្នុងសម្នាក់របស់ព្រះពុទ្ធ ។ បទថា **សង្កប្បយន្តាយ** គឺដោយការទៅនៃការត្រិះរិះនោះ ។ បទថា **តេន យុត្តោ** សេចក្តីថា ចិត្តរបស់អាត្មាប្រកបដោយព្រះពុទ្ធនោះ លោកសម្តែងថា ព្រះពុទ្ធគង់នៅក្នុងទីណា ចិត្តប្រកបហើយ មិនប្រាសចាកការប្រកប គឺមានមុខឆ្ពោះព្រះពុទ្ធក្នុងទីនោះ ។ បទថា **បង្កេ សយានោ** អាត្មាដេកលើភក់ គឺកាមទាំងឡាយ ។ បទថា **ទីបា ទីបំ ឧបល្លវឹ** សេចក្តីថា ស្ទុះអំពីទីពឹងមួយ ទៅកាន់ទីពឹងមួយ គឺចូលទៅរកសាស្តាទាំងឡាយជាដើម ។ បទថា **អថទ្ទសាសឹ សម្ពុទ្ធំ** កាលនោះអាត្មាបានឃើញព្រះពុទ្ធ គឺអាត្មានោះបានកាន់យកការឃើញខុស ហើយត្រាច់ទៅតាមលំដាប់ កាលនោះ បានឃើញព្រះពុទ្ធក្នុងបាសាណកចេតិយ ។

កាលចប់គាថានេះ ព្រះមានព្រះភាគទ្រង់ជ្រាបការចាស់ក្លានៃឥន្ទ្រិយរបស់បិង្គិយៈ និងពាវរីព្រាហ្មណ៍ ទើបទ្រង់ឈរក្នុងក្រុងសាវត្ថីនោះឯង ផ្សាយរស្មីពណ៌មាសទៅ ។ ព្រះបិង្គិយៈអង្គុយពណ៌នានូវព្រះពុទ្ធគុណ ដល់ពាវរី-

ព្រាហ្មណ៍នោះឯង បានឃើញព្រះរស្មីហើយ គិតថា ពន្លឺអ្វីហ្ន៎ ក្រឡេកទៅឃើញព្រះមានព្រះភាគ ដូចគង់នៅខាងមុខរបស់ខ្លួន ទើបប្រាប់ពាវរីព្រាហ្មណ៍ថា ព្រះពុទ្ធទ្រង់យាងមកហើយ ។ ព្រាហ្មណ៍ក្រោកអំពីអាសនៈ ឈរផ្គងអញ្ជលី ព្រះមានព្រះភាគកាលទ្រង់ផ្សាយព្រះរស្មីហើយ ទើបទ្រង់បង្ហាញខ្លួនដល់ព្រាហ្មណ៍ ទ្រង់ដឹងធម៌ជាទីសប្បាយរបស់ជនទាំង ២ កាលនឹងត្រាស់ហៅបិង្គិយៈប៉ុណ្ណោះ ទើបត្រាស់គាថានេះថា **យថា អហុ វក្កលិ** ដូច្នេះជាដើម ។

បទនោះ មានសេចក្តីដូច្នេះថា វក្កលិភិក្ខុ កទ្រាវុធភិក្ខុនៃមាណព ១៦ និងអាឡវគោតមភិក្ខុ ជាអ្នកបង្អោនចិត្តទៅដោយសទ្ធាហើយ បានសម្រេចនូវអរហត្ត ដោយសទ្ធាគ្រប់រូប យ៉ាងណា សូម្បីអ្នកក៏ចូររក្សានូវសទ្ធានោះដូច្នេះ បន្ទាប់អំពីនោះ កាលអ្នកបង្អោនចិត្តទៅដោយសទ្ធា ប្រារព្ធវិបស្សនាដោយន័យជាដើមថា សង្ខារទាំងឡាយមិនទៀង ក៏នឹងដល់និព្វានដែលជាត្រើយនាយនៃវដ្តៈ ដែលជាអន្ទាក់នៃមច្ចុ ។ ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនាដោយធម៌ដ៏កំពូល គឺអរហត្តនោះឯង ។

កាលចប់ទេសនា ព្រះបិង្គិយៈតាំងនៅក្នុងអរហត្ត ពាវរីព្រាហ្មណ៍តាំងនៅក្នុងអនាគាមិផល ឯសិស្ស ៥០០ របស់ពាវរីព្រាហ្មណ៍ បានជាព្រះសោតាបន្ន ។

ឥឡូវនេះ បិង្គិយភិក្ខុកាលប្រកាសសេចក្តីជ្រះថ្លារបស់ខ្លួន ទើបពោលពាក្យជាដើមថា **ឯស ភិយ្យោ** ប្រែថា ខ្ញុំព្រះអង្គរមែងជ្រះថ្លាក្រៃលែង ។

ក្នុងបទទាំងនោះ បទថា **បដិភាណវា** ប្រែថា ទ្រទ្រង់នូវបដិភាណ គឺចូលបដិភាណប្បដិសម្ភិទា ។ បទថា **អធិទេវេ អភិញ្ញាយ** គឺទ្រង់ជ្រាបធម៌ជាហេតុឲ្យហៅថា **អធិទេព** ។ បទថា **បរោវរំ** គឺអាក្រក់ និងប្រណីត លោកអធិប្បាយថា ដឹងធម្មជាតទាំងពួង ដែលធ្វើភាពជាអធិទេពរបស់ខ្លួន និងរបស់អ្នកដទៃ ។ បទថា **កង្ខីនំ បដិជានតំ** គឺពួកជនដែលមានសេចក្តីសង្ស័យប្តេជ្ញាថា អាត្មាអញអស់សង្ស័យក្នុងធម៌របស់សប្បុរស ។ បទថា **អសំហីរំ** បានដល់ និព្វានដែលរាគៈជាដើមនាំទៅមិនបាន ។ បទថា **អសំកុប្បំ** គឺមិនកម្រើក ដែលមិនប្រែប្រួលជាធម្មតា ។ ព្រះបិង្គិយៈពោលដល់និព្វានដោយ ២ បទ ។ បទថា **អទ្ធា គមិស្សាមិ** គឺខ្ញុំព្រះអង្គនឹងដល់អនុ-

បាទិសេសនិព្វានធាតុនោះដោយពិតប្រាកដ ។ បទថា **ន មេត្តកង្ខា** គឺការសង្ស័យក្នុងនិព្វាននេះ មិនមានដល់ខ្ញុំព្រះអង្គ ។ បទថា **ឯវំ ធារេហិ អធិមុត្តចិត្តំ** សូមទ្រង់ចាំខ្ញុំព្រះអង្គថា ជាអ្នកមានចិត្តបង្អោនទៅហើយ គឺព្រះបិង្គិយៈដែលសទ្ធាឲ្យកើតឡើងក្នុងខ្លួន ដោយព្រះឱវាទរបស់ព្រះមានព្រះភាគថា ចូរលែងដោយសទ្ធាធុរៈនោះឯង កាលនឹងប្រកាសតាមដែលខ្លួនមានចិត្តបង្អោនទៅហើយដោយសទ្ធា ទើបទូលព្រះមានព្រះភាគថា សូមទ្រង់ចាំទុកនូវខ្ញុំព្រះអង្គថា ជាអ្នកមានចិត្តបង្អោនទៅហើយ ដោយប្រការដូច្នេះ អធិប្បាយក្នុងទីនេះ មានដូចតទៅនេះ ទ្រង់ត្រាស់នឹងខ្ញុំព្រះអង្គយ៉ាងណា សូមទ្រង់ចាំនូវខ្ញុំព្រះអង្គថា អធិមុត្តជាអ្នកបង្អោនចិត្តទៅហើយ ។៚

**បារាយនានុសន្ធិគាថា ចប់**

**បារាយនវគ្គ ចប់**

**អដ្ឋកថាខុទ្ទកនិកាយ**

**ឈ្មោះបរមត្ថជោតិកា ចប់**

# ឧទ្ទាននៃសូត្រក្នុងសុត្តនិបាត

[ ១៣១ ] ឧរគសូត្រ ១ ធនិយសូត្រ ១ ខគ្គវិសាណសូត្រ ១ កសិភារទ្វាជសូត្រ ១ ចុន្ទសូត្រ ១ បរាភវសូត្រ ១ វសលសូត្រ ១ ករណីយមេត្តសូត្រ ១ ហេមវតសូត្រ ១ អាឡវកយក្ខសូត្រ ១ វិជយសូត្រ ១ មុនិសូត្រ ជាសូត្រដ៏ប្រសើរ ១ ។

វគ្គដ៏ប្រសើរថ្លៃថ្លា តាំងនៅជាដំបូង ជាវគ្គទ្រទ្រង់នូវសូត្រ ១២ លោកចែកទុកល្អហើយ ព្រះមានព្រះភាគទ្រង់មានចក្ខុប្រាសចាកមន្ទិល ទ្រង់សម្តែងទុកហើយ យើងឮមកថា ឧរគវគ្គ ជាវគ្គដ៏ប្រសើរ ។

រតនសូត្រ ១ អាមគន្ធសូត្រ ១ ហិរិសូត្រ ១ មង្គលសូត្រ ១ សូចិលោមសូត្រ ១ កបិលសូត្រ ឬធម្មចរិយសូត្រ ១ ព្រាហ្មណធម្មិកសូត្រ ១ នាវាសូត្រ ១ កឹសីលសូត្រ ១ ឧដ្ឋានសូត្រ ១ រាហុលសូត្រ ១ វង្គីសសូត្រ ១ សម្មាបរិព្វាជនីយសូត្រ ១ ធម្មិកសូត្រដ៏ប្រសើរ ១ លោកចែកទុកល្អហើយក្នុងវគ្គនោះ បណ្ឌិតទាំងឡាយពោលនូវវគ្គនោះថា ចូឡកវគ្គដ៏ប្រសើរ ទ្រទ្រង់នូវសូត្រ ១៤ ក្នុងលើកទីពីរ ។

បព្វជ្ជាសូត្រ ១ បធានសូត្រ ១ សុភាសិតសូត្រ ១ បុរឡាស ឬសុន្ទរិកសូត្រ ១ មាឃសូត្រ ១ សភិយសូត្រ ១ កេណិយសូត្រ ឬសេលសូត្រ ១ សល្លសូត្រ ១ វាសេដ្ឋ-

សូត្រដ៏ប្រសើរ ១ កោកាលិកសូត្រ ១ នាឡកសូត្រដ៏ប្រសើរ ១ លោកចែកទុកល្អហើយ ទ្វយតានុបស្សនាសូត្រ ១ យើងឮមកថា មហាវគ្គជាវគ្គដ៏ប្រសើរ ទ្រទ្រង់នូវសូត្រ ១២ ក្នុងលើកទី ៣ ។

កាមសូត្រ ១ គុហដ្ឋកសូត្រ ១ ទុដ្ឋដ្ឋកសូត្រ ១ សុទ្ធដ្ឋកសូត្រដ៏ប្រសើរ ១ បរមដ្ឋកសូត្រ ១ ជរាសូត្រ ១ តិស្សមេត្តេយ្យសូត្រដ៏ប្រសើរ លោកចែកទុកល្អហើយ ១ បសូរសូត្រ ១ មាគន្ទិយសូត្រ ១ បុរាភេទសូត្រ ១ កលហវិវាទសូត្រ ១ វិយូហសូត្រ ២ គឺចូឡវិយូហសូត្រ និងមហាវិយូហសូត្រ តុវដ្តកសូត្រ ១ អត្តទណ្ឌសូត្រ ១ សារីបុត្តសូត្រ ១ បណ្ឌិតទាំងឡាយពោលនូវវគ្គនោះថា អដ្ឋកវគ្គជាវគ្គដ៏ប្រសើរ ទ្រទ្រង់នូវសូត្រ ១៦ ក្នុងលើកទី ៤ ។

ដូចបានឮថា ព្រះមានព្រះភាគជាបុគ្គលប្រសើរ ក្នុងគណៈ ទ្រង់គង់ក្នុងបាសាណកចេតិយដ៏ប្រសើរ ដែលបុគ្គលចាត់ចែងល្អហើយ ក្នុងប្រទេសដ៏ប្រសើរ ជាប្រទេសជាទីនៅនៃបុគ្គលអ្នកមានបុណ្យបានធ្វើហើយ ក្នុងមគធជនបទ ជារមណីយដ្ឋាន ដែលព្រាហ្មណ៍ទាំង ១៦ នាក់ ទូលសួរហើយនូវធម៌ណាទាំងពីរ ដ៏បរិបូណ៌គ្រប់គ្រាន់ក្នុងបរិស័ទ មានយោជន៍ ១២ ទ្រង់ប្រកាសប្រទាននូវធម៌តាមពាក្យបុច្ឆា គួរដល់បញ្ហាកម្ម ១៦

ព្រះជិនស្រីជាបុគ្គលប្រសើរជាងសត្វមានជើងពីរ ទ្រង់ប្រកាសនូវអត្ថបរិបូណ៌ដោយព្យញ្ជនៈ ជាទីកើតនៃសេចក្ដីក្សេមក្សាន្តដល់សត្វដទៃ ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរជាងសត្វមានជើងពីរ ទ្រង់សម្ដែងនូវសូត្រដ៏ប្រសើរ ដ៏វិចិត្រដោយធម៌ច្រើនយ៉ាង ទ្រង់សម្ដែងសូត្រដ៏ប្រសើរ ជាហេតុរួចចាកកិលេសទាំងពួង ។

ព្រះសម្មាសម្ពុទ្ធ ប្រសើរជាងសត្វមានជើងពីរ ទ្រង់សម្ដែងសូត្រដ៏ប្រសើរ ប្រកបព្រមដោយព្យញ្ជនៈ និងអត្ថ និងបទដែលគួរសម្គាល់បានដោយអក្ខរៈ ដែលចុះកាន់សេចក្ដីឧបមាជាពន្លឺដ៏ប្រសើរ គឺញាណជាគ្រឿងពិចារណានូវលោក ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរជាងសត្វមានជើងពីរ ទ្រង់សម្ដែងសូត្រដ៏ប្រសើរ មិនមានមន្ទិល ប្រាសចាកមន្ទិលដ៏ប្រសើរក្នុងមន្ទិល គឺរាគៈ មិនមានមន្ទិល ប្រាសចាកមន្ទិលដ៏ប្រសើរ ក្នុងមន្ទិល គឺទោសៈ មិនមានមន្ទិល ប្រាសចាកមន្ទិលដ៏ប្រសើរ ក្នុងមន្ទិល គឺមោហៈ ជាពន្លឺដ៏ប្រសើរ គឺញាណពិចារណានូវលោក ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលដ៏ប្រសើរជាងសត្វមានជើងពីរ ទ្រង់សម្ដែងនូវសូត្រដ៏ប្រសើរ មិនមានមន្ទិល ប្រាសចាកមន្ទិលដ៏ប្រសើរក្នុងមន្ទិល គឺកិលេស ប្រាសចាកមន្ទិលដ៏ប្រសើរក្នុង

មន្ទិល គឺទុច្ចរិត ជាពន្លឺដ៏ប្រសើរ គឺញាណជាគ្រឿងពិចារណា នូវលោក ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរជាងសត្វមានជើងពីរ ទ្រង់សម្តែងនូវកិលេសជាគ្រឿងត្រាំ គ្រឿងចង គ្រឿងប្រកប ផង នូវនីវរណៈទាំងឡាយផង នូវមន្ទិល ៣ ផង នូវសូត្រ ដ៏ប្រសើរ ជាហេតុនៃកិរិយារួចចាកកិលេសផង ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរជាងសត្វមានជើងពីរ ទ្រង់សម្តែងនូវសូត្រដ៏ប្រសើរ ជាគ្រឿងបន្ទោបង់នូវកិលេស ទាំងពួង មិនឲ្យមានមន្ទិល ប្រាសចាកកិលេសគ្រឿងត្រេកអរ មិនញាប់ញ័រ មិនសោកស្តាយ ជាធម៌ល្អិតសុខុម ដែលបុគ្គល ឃើញបានដោយកម្រក្រៃលែង ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរជាងសត្វមានជើងពីរ ទ្រង់សម្តែងនូវសូត្រដ៏ប្រសើរ ជាប្រធាននៃទីពឹង ជាទីកាត់បង់ នូវផ្លូវនៃតណ្ហា និងតម្រេក ដែលបំបាក់បង់នូវរាគៈ និងទោសៈ ឲ្យស្ងប់រម្ងាប់ និងកំណើត ទុគ្គតិ វិញ្ញាណ ៥ ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរជាងសត្វមានជើងពីរ ទ្រង់សម្តែងនូវសូត្រដ៏ប្រសើរ គ្រប់គ្រាន់ដោយអត្ថដ៏ជ្រាលជ្រៅ និងអត្ថដ៏ល្អិតដែលបុគ្គលឃើញបានដោយក្រ មានអត្ថដ៏ល្អិត ដែលបណ្ឌិតគប្បីដឹងបាន ជាពន្លឺដ៏ប្រសើរ គឺញាណជាគ្រឿង

ពិចារណានូវលោក ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរជាងសត្វមានជើងពីរ ទ្រង់សម្តែងនូវសូត្រដ៏ប្រសើរ ចែកនូវឥន្ទ្រិយ ឈាន និងវិមោក្ខ ប្រកបដោយមគ្គមានអង្គ ៨ ដ៏ប្រសើរ ជាឈានដ៏ប្រសើរ ដូចគ្រឿងប្រដាប់នៃផ្កាឈើមានពណ៌ស គឺនវង្គសត្ថុសាសនា ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរជាងសត្វមានជើងពីរ ទ្រង់សម្តែងនូវសូត្រដ៏ប្រសើរ ជាទីដល់នូវព្រះនិព្វានដ៏ក្សេម ជាសុខដ៏ត្រជាក់ស្ងប់រម្ងាប់ មានអត្ថដ៏ប្រសើរ ជាទីការពារនូវមច្ចុរាជ ជាហេតុឃើញនូវសេចក្តីស្ងប់ដ៏ប្រពៃ នៃអ្នកប្រតិបត្តិតាម ។ ល។

សុត្តនិបាត ចប់

# និគមគាថា

ដោយហេតុមានប្រមាណប៉ុណ្ណេះ ពាក្យណាដែលលោកពោលហើយថា យើងទាំងឡាយ នឹងថ្វាយបង្គំព្រះរតនត្រ័យដ៏ឧត្តមជាងបុគ្គលដែលគួរថ្វាយបង្គំទាំងឡាយ នឹងធ្វើកិច្ចពណ៌នាអត្ថនៃសុត្តនិបាត ដែលព្រះលោកនាថ-សម្មាសម្ពុទ្ធ ទ្រង់លះនូវការស្រេក គឺតណ្ហាបានហើយ ទ្រង់ស្វែងរកវិធីនាំសត្វចេញចាកលោក ត្រាស់ហើយក្នុងខុទ្ទកនិកាយ ឈ្មោះថា ខ្ញុំបានធ្វើនូវ

កិច្ចពណ៌នានៃសុត្តនិបាត ដែលមាន ៧០ សូត្រ មានឧរគសូត្រជាដើម សង្គ្រោះជា ៥ វគ្គ មានឧរគវគ្គជាដើម ក្នុងសេចក្តីនេះ ដោយហេតុនោះ ទើបលោកពោលថា កុសលណាដែលខ្ញុំធ្វើកិច្ចពណ៌នាអត្ថនៃសុត្តនិបាតនេះ ជាអ្នកប្រាថ្នាការតាំងមាំនៃព្រះសទ្ធម្ម ព្រោះអានុភាពនៃកុសលនោះ សូមជនានុជនដល់នូវសេចក្តីចម្រើនលូតលាស់ក្នុងធម៌ ដែលព្រះអរិយៈសម្តែងហើយ ដោយស្រួលរហ័សចុះ ។

គប្បីជ្រាបថា មានគាណាវារ ៨៤ គាណាវារ ដោយប្រមាណនៃបរិយត្តិ អដ្ឋកថាសុត្តនិបាត ឈ្មោះបរមត្ថជោតិកានេះ ដែលព្រះថេរៈមានឈ្មោះដែលគ្រូទាំងឡាយតាំងថា **ពុទ្ធឃោស** ដែលប្រដាប់ដោយគុណ គឺសទ្ធាពុទ្ធិ និងវិរិយៈដ៏បរិសុទ្ធក្រៃលែង ដែលប្រាកដហេតុឲ្យកើតគុណ មានសីល អាចារ ការប្រព្រឹត្តឱនលំទោន ជាអ្នកប្រកបដោយភាពឈ្លាសវៃខាងបញ្ញា អាចឈោងចុះក្នុងទិដ្ឋិទាំងឡាយក្នុងលទ្ធិរបស់ខ្លួន និងលទ្ធិអ្នកដទៃ បានជាមហាកវី ជាអ្នកមានវាទៈដ៏ប្រសើរ ពោលនូវពាក្យសមគួរ ប្រកបដោយកិច្ចពណ៌នាដ៏ពីរោះ និងវិសេស ធ្វើឲ្យកើតនូវការសម្បូរក្នុងការធ្វើ និងចូលដល់សេចក្តីសុខ ដោយការធ្វើឲ្យជាក់ច្បាស់ ព្រោះមានការដឹងណាមួយ មិនទើសទាក់ក្នុងសត្ថុសាសនៈ មួយអន្លើដោយអដ្ឋកថា ដែលមានប្រភេទជាបរិយត្តិ គឺព្រះត្រៃបិដក ជាអ្នកមានបញ្ញាទូលាយ បរិសុទ្ធ ជាគ្រឿងប្រដាប់វង្សរបស់ព្រះថេរៈ ជាអ្នកនៅក្នុងមហាវិហារ ជាប្រទីបនៃថេរវង្ស ជាអ្នកមានបញ្ញាល្អហើយ ក្នុងឧត្តរិមនុស្សធម៌ ប្រដាប់ដោយប្រភេទ មានអភិញ្ញា ៦ និង

បដិសម្ភិទាជាដើម បានរចនាហើយ ។

សូមអដ្ឋកថាខុទ្ទកនិកាយ សុត្តនិបាត ដែលសម្តែងអត្ថនៃបញ្ញាដ៏បរិសុទ្ធ ដល់កុលបុត្តទាំងឡាយ អ្នកស្វែងរកការរើខ្លួនចេញអំពីលោក ចូរតាំងនៅក្នុងលោកដរាបដល់ព្រះនាមថា **ពុទ្ធោ** របស់ព្រះលោកជេដ្ឋៈ ជាអ្នកមានចិត្តបរិសុទ្ធ ជាតាទិបុគ្គល ជាអ្នកស្វែងរកគុណធំ នៅប្រព្រឹត្តទៅក្នុងលោក ។

ដូចពោលថា សូមសត្វទាំងឡាយដែលបូជាព្រះគុណរបស់ព្រះពុទ្ធ ដូចអន្ទង់ទឹក ចូរមានសេចក្តីសុខ មានបដិភាណ មិនមានពៀរ សូមជនទាំង-ឡាយមានកាយប្រាសចាករោគ ជាអ្នកមានបញ្ញា ជាសប្បុរស តម្កល់ខ្លួនក្នុងកុសលធម៌ ដូច្នេះ ភាពដែលមានចិត្តមិននៅក្នុងអំណាច វៀរនូវសេចក្តីប្រកាន់ថាជាតួខ្លួន ព្រោះមិនមានខ្លឹមសារ ដូចដើមខ្លឹង បុគ្គលលេងកល ថ្ងៃបណ្តើរកូន ដើមចេក ដោយន័យជាដើមថា ខន្ធទាំងឡាយ ជារបស់មិនទៀងដល់នូវការកើត និងការរលត់គ្រប់ខណៈ មានធូលី គឺរាគៈជាភ័យ លះគតិដ៏ប្រសើរ មិនគួរប្រាថ្នា ចូលទៅរកគតិដ៏លាមកច្រើនយ៉ាងក្នុងលោក តែងផ្សាយទៅដោយសេចក្តីសុខ គឺភព ៣ មានកាយ វាចា ចិត្ត ទូន្មានហើយ អន្តេវាសិក សូមចូលដល់និព្វានចុះ ៕□

**អដ្ឋកថា សុត្តនិបាត ចប់**

# ក្បាលទី ៣៨

# សុត្តន្តបិដក ចាលីប្រែ -៥៤

## សន្ទឹកចង្អុលប្រាប់មាតិកា


| មាតិកា | | លេខទំព័រ |
|---|---|---|
| **ចូឡវគ្គទី ២** | | |
| ធម្មចរិយសូត្រ | ...... ...... ...... ...... | ២ |
| អដ្ឋកថា ធម្មចរិយសូត្រ | ...... ...... ...... ...... | ៤ |
| ព្រាហ្មណធម្មិកសូត្រ | ...... ...... ...... ...... | ១៨ |
| អដ្ឋកថាព្រាហ្មណធម្មិកសូត្រ | ...... ...... ...... ...... | ២៥ |
| នាវាសូត្រ | ...... ...... ...... ...... | ៥៥ |
| អដ្ឋកថានាវាសូត្រ | ...... ...... ...... ...... | ៥៦ |
| កឹសីលសូត្រ | ...... ...... ...... ...... | ៦៩ |
| អដ្ឋកថាកឹសីលសូត្រ | ...... ...... ...... ...... | ៧១ |
| ឧដ្ឋានសូត្រ | ...... ...... ...... ...... | ៨២ |
| អដ្ឋកថាឧដ្ឋានសូត្រ | ...... ...... ...... ...... | ៨៣ |
| រាហុលសូត្រ | ...... ...... ...... ...... | ៩២ |
| អដ្ឋកថារាហុលសូត្រ | ...... ...... ...... ...... | ៩៣ |
| វង្គីសសូត្រ | ...... ...... ...... ...... | ១០៥ |
| អដ្ឋកថាវង្គីសសូត្រ | ...... ...... ...... ...... | ១១០ |
| សម្មាបរិព្វាជនិយសូត្រ | ...... ...... ...... ...... | ១២៨ |
| អដ្ឋកថាសម្មាបរិព្វាជនិយសូត្រ | ...... ...... ...... ...... | ១៣២ |
| ធម្មិកសូត្រ | ...... ...... ...... ...... | ១៦០ |
| អដ្ឋកថាធម្មិកសូត្រ | ...... ...... ...... ...... | ១៦៧ |

## មហាវគ្គទី ៣

បព្វជ្ជាសូត្រ ...... ...... ...... ...... ១៨៩
អដ្ឋកថាបព្វជ្ជាសូត្រ ...... ...... ...... ...... ១៩២
បធានសូត្រ ...... ...... ...... ...... ២០២
អដ្ឋកថាបធានសូត្រ ...... ...... ...... ...... ២០៦
សុភាសិតសូត្រ ...... ...... ...... ...... ២២២
អដ្ឋកថាសុភាសិតសូត្រ ...... ...... ...... ...... ២២៤
សុន្ទរិកសូត្រ ...... ...... ...... ...... ២៣៦
អដ្ឋកថាបូរឡាសសូត្រ ...... ......... ...... ....... ២៤៥
មាឃសូត្រ ...... ...... ...... ...... ២៧០
អដ្ឋកថាមាឃសូត្រ ...... ...... ...... ...... ២៧៧
សភិយសូត្រ ...... ...... ...... ...... ២៨៨
អដ្ឋកថាសភិយសូត្រ ...... ...... ...... ...... ៣០៣
សេលសូត្រ ...... ...... ...... ...... ៣៣៦
អដ្ឋកថាសេលសូត្រ ...... ...... ...... ...... ៣៤៩
សល្លសូត្រ ...... ...... ...... ...... ៣៨៦
អដ្ឋកថាសល្លសូត្រ ...... ...... ...... ...... ៣៨៩
វាសេដ្ឋសូត្រ ...... ...... ...... ...... ៤០០
អដ្ឋកថាវាសេដ្ឋសូត្រ ...... ...... ...... ...... ៤១៣
កោកាលិកសូត្រ ...... ...... ...... ...... ៤៣៤
អដ្ឋកថាកោកាលិកសូត្រ ...... ...... ...... ...... ៤៤២
នាឡកសូត្រ ...... ...... ...... ...... ៤៦០
អដ្ឋកថានាឡកសូត្រ ...... ...... ...... ...... ៤៦៩
ទ្វយតានុបស្សនាសូត្រ ...... ...... ...... ...... ៥០៥

អដ្ឋកថាទ្វយតានុបស្សនាសូត្រ ...... ...... ...... ...... ៥២០

## អដ្ឋកវគ្គ

កាមសូត្រ ...... ...... ...... ...... ៥៣៧

អដ្ឋកថាកាមសូត្រ ...... ...... ...... ...... ៥៣៨

គុហដ្ឋកសូត្រ ...... ...... ...... ...... ៥៤៤

អដ្ឋកថាគុហដ្ឋកសូត្រ ...... ...... ...... ...... ៥៤៦

ទុដ្ឋដ្ឋកសូត្រ ...... ...... ...... ...... ៥៥៥

អដ្ឋកថាទុដ្ឋដ្ឋកសូត្រ ...... ...... ...... ...... ៥៥៧

សុទ្ធដ្ឋកសូត្រ ...... ...... ...... ...... ៥៦៧

អដ្ឋកថាសុទ្ធដ្ឋកសូត្រ ...... ...... ...... ...... ៥៦៩

បរមដ្ឋកសូត្រ ...... ...... ...... ...... ៥៧៩

អដ្ឋកថាបរមដ្ឋកសូត្រ ...... ...... ...... ...... ៥៨១

ជរាសូត្រ ...... ...... ...... ...... ៥៨៥

អដ្ឋកថាជរាសូត្រ ...... ...... ...... ...... ៥៨៧

តិស្សមេត្តេយ្យសូត្រ ...... ...... ...... ...... ៥៩៤

អដ្ឋកថាតិស្សមេត្តេយ្យសូត្រ ...... ...... ...... ...... ៥៩៦

បសូរសូត្រ ...... ...... ...... ...... ៦០២

អដ្ឋកថាបសូរសូត្រ ...... ...... ...... ...... ៦០៤

មាគន្ទិយសូត្រ ...... ...... ...... ...... ៦១៤

អដ្ឋកថាមាគន្ទិយសូត្រ ...... ...... ...... ...... ៦១៩

បុរាភេទសូត្រ ...... ...... ...... ...... ៦៣០

អដ្ឋកថាបុរាភេទសូត្រ ...... ...... ...... ...... ៦៣៣

កលហវិវាទសូត្រ ...... ...... ...... ...... ៦៣៩

អដ្ឋកថាកលហវិវាទសូត្រ ...... ...... ...... ...... ៦៤៤

ចូឡវិយូហសូត្រ ...... ...... ...... ...... ៦៥២

អដ្ឋកថាចូឡវិយូហសូត្រ ...... ...... ...... ...... ៦៥៧

មហាវិយូហសូត្រ ...... ...... ...... ...... ៦៦៤

អដ្ឋកថាមហាវិយូហសូត្រ ...... ...... ...... ...... ៦៦៩

តុវដកសូត្រ ...... ...... ...... ...... ៦៧៩

អដ្ឋកថាតុវដកសូត្រ ...... ...... ...... ...... ៦៨៣

អត្តទណ្ឌសូត្រ ...... ...... ...... ...... ៦៩១

អដ្ឋកថាអត្តទណ្ឌសូត្រ ...... ...... ...... ...... ៦៩៥

សារីបុត្តសូត្រ ...... ...... ...... ...... ៧០៣

អដ្ឋកថាសារីបុត្តសូត្រ ...... ...... ...... ...... ៧០៨


## បារាយនវគ្គ


វត្ថុកថា ...... ...... ...... ...... ៧១៩

អដ្ឋកថាវត្ថុកថា ...... ...... ...... ...... ៧២៨

អជិតប្បញ្ហាទី ១ ...... ...... ...... ...... ៧៤៧

អដ្ឋកថាអជិតប្បញ្ហាទី ១ ...... ...... ...... ...... ៧៤៩

តិស្សមេត្តេយ្យប្បញ្ហាទី ២ ...... ...... ...... ...... ៧៥៣

អដ្ឋកថាតិស្សមេត្តេយ្យប្បញ្ហាទី ២ ...... ...... ...... ...... ៧៥៤

បុណ្ណកប្បបញ្ហាទី ៣ ...... ...... ...... ...... ៧៥៦

អដ្ឋកថាបុណ្ណកប្បបញ្ហាទី ៣ ...... ...... ...... ...... ៧៥៨

មេត្តគូបញ្ហាទី ៤ ...... ...... ...... ...... ៧៦១

អដ្ឋកថាមេត្តគូបញ្ហាទី ៤ ...... ...... ...... ...... ៧៦៤

ធោតកប្បញ្ហាទី ៥ ...... ...... ...... ...... ៧៦៨

អដ្ឋកថាធោតកប្បញ្ហាទី ៥ ...... ...... ...... ...... ៧៧០

ឧបសីវប្បញ្ហាទី ៦ ...... ...... ...... ...... ៧៧២

អដ្ឋកថាឧបសីវប្បញ្ហាទី ៦ ...... ...... ...... ...... ៧៧៤
នន្ទប្បញ្ហាទី ៧ ...... ...... ...... ...... ៧៧៩
អដ្ឋកថានន្ទប្បញ្ហាទី ៧ ...... ...... ...... ...... ៧៨២
ហេមកប្បបញ្ហាទី ៨ ...... ...... ...... ...... ៧៨៤
អដ្ឋកថាហេមកប្បបញ្ហាទី ៨ ...... ...... ...... ...... ៧៨៥
តោទេយ្យប្បញ្ហាទី ៩ ...... ...... ...... ...... ៧៨៦
អដ្ឋកថាតោទេយ្យប្បញ្ហាទី ៩ ...... ...... ...... ...... ៧៨៧
កប្បប្បញ្ហាទី ១០ ...... ...... ...... ...... ៧៨៩
អដ្ឋកថាកប្បប្បញ្ហាទី ១០ ...... ...... ...... ...... ៧៩០
ជតុកណ្ណីបញ្ហាទី ១១ ...... ...... ...... ...... ៧៩១
អដ្ឋកថាជតុកណ្ណីបញ្ហាទី ១១ ...... ...... ...... ...... ៧៩២
កទ្រាវុធប្បញ្ហាទី ១២ ...... ...... ...... ...... ៧៩៤
អដ្ឋកថាកទ្រាវុធប្បញ្ហាទី ១២ ...... ...... ...... ...... ៧៩៥
ឧទយប្បញ្ហាទី ១៣ ...... ...... ...... ...... ៧៩៨
អដ្ឋកថាឧទយប្បញ្ហាទី ១៣ ...... ...... ...... ...... ៧៩៩
បោសាលប្បញ្ហាទី ១៤ ...... ...... ...... ...... ៨០២
អដ្ឋកថាបោសាលប្បញ្ហាទី ១៤ ...... ...... ...... ...... ៨០៣
មោឃរាជប្បញ្ហាទី ១៥ ...... ...... ...... ...... ៨០៦
អដ្ឋកថាមោឃរាជប្បញ្ហាទី ១៥ ...... ...... ...... ...... ៨០៧
បិង្គិយប្បញ្ហាទី ១៦ ...... ...... ...... ...... ៨០៩
អដ្ឋកថាបិង្គិយប្បញ្ហាទី ១៦ ...... ...... ...... ...... ៨១០
បារាយនានុសង្គីតិ ...... ...... ...... ...... ៨១៣
អដ្ឋកថាបារាយនានុសង្គីតិ ...... ...... ...... ...... ៨១៩